សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ


# ប្រវត្តិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា

# History of Cambodian Economic Development


សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គន្ធា



ឧបត្ថម្ភដោយ

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ប្រវត្តិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា
# History of Cambodian Economic Development

សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គន្ធា

២០២១

# រក្សាសិទ្ធ

© ឆ្នាំ២០២១

**រក្សាសិទ្ធគ្រប់យ៉ាង**

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្មឡើយ។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍(ស.គ.ន)នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

**ទំនាក់ទំនងព័ត៌មាន:**

អ្នកនិពន្ធ៖ សាស្ត្រាចារ្យរង បណ្ឌិត **ឆាយ គង្គា**

ទូរស័ព្ទ៖ (+៨៥៥) ១២ ៦៨៤ ៨២៨ / ៩៨ ៦៨៤ ៨២៨

អ៊ីមែល៖ chhaykongkea@gmail.com

© 2021 by Assoc.Prof.CHHAY Kongkea, Ph.D.All rights reserved.No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sports, Kingdom of Cambodia

Enquiries about the book:
Author: Assoc.Prof.CHHAY Kongkea, Ph.D.
Mobile phone: (+855) 12 684 828 / 98 684 828
Email: chhaykongkea@gmail.com

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា “មូលនិធិ ស.គ.ន.” និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា “RCI Fund”។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បាឋកសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ
៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្ដីថ្លែងអំណរគុណ

សៀវភៅ "**ប្រវត្តិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា**" នេះអាចប្រសូត្រចេញបានក៏ដោយសារមានការចូលរួមនិង ការផ្ដល់វិភាគទានយ៉ាងធំធេងពីបណ្ដាអ្នកវិទ្យាសាស្ត្រ និងឥស្សរជនដែលមានបទពិសោធន៍នៅក្នុងផ្នែកស្រាវជ្រាវកសិកម្មជាច្រើនរូប។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់ការពិនិត្យ ជួយកែលម្អ អក្ខរាវិរុទ្ធ ឃ្លាប្រយោគ ខ្លឹមសារ អត្ថបទ លះបង់ពេលវេលាដ៏មានតម្លៃមិនខ្លាចនឿយហត់ និងផ្ដល់ជាមតិល្អៗក្នុងការរៀបចំសៀវភៅនេះដល់៖

- ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាអង្គភាពសាមី(សាកលវិទ្យាល័យភូមិន្ទកសិកម្ម)
- ឯកឧត្ដមបណ្ឌិត **សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍
- សាស្ត្រាចារ្យរងបណ្ឌិត **ឃួន ថាវរៈ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- លោក **ឧទ សុជាតិ** នាយករងផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- គណៈកម្មការត្រួតពិនិត្យមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងគណៈកម្មការត្រួតពិនិត្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយជ្រុមជ្រែងក្នុងការស្រាវជ្រាវ
- គណៈកម្មការត្រួតពិនិត្យ៖ លោកបណ្ឌិត សឹន សុទ្ធ លោកបណ្ឌិត ម៉ក់ ពុទ្ធី លោកបណ្ឌិត ឆាំង ហ៊ុយ លោកបណ្ឌិត ហែម ឡាច លោកបណ្ឌិត វង្ស ឌីណា លោក អេង លេង លោកស្រី ហ៊ូ ផល្លា លោកស្រី ឆាយ ស្រីល័ក្ខ និងលោកស្រី ឆាយ ស្រីមុំ
- អ្នកផ្ដល់យោបល់នានា ក៏ដូចជាអ្នកផ្ដល់ជាឯកសារយោងទាំងភាសាជាតិ និងភាសាបរទេសនានា
- ភរិយា និងកូនស្រីទាំងពីរជាទីស្រឡាញ់របស់ខ្ញុំ ព្រមទាំងមិត្តភក្តិដែលបានជួយជ្រោមជ្រែងទាំងអស់

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់៖

- Prof.Dr.Joon-Keun Park, Professor Emeritus, Department of Agricultural Economics, Graduate School, Chonnam National University (CNU), Gwangju City, South Korea.
- លោកស្រី យ៉ែម ម៉ុយហ៊ុង

- កញ្ញា គង្គា សុជាតា និស្សិតឆ្នាំទី៤ ផ្នែកឱសថការីឧត្តម សាលាអន្តរជាតិ មហាវិទ្យាល័យឱសថការី នៃសាកលវិទ្យាល័យជិនណាន សាធារណរដ្ឋប្រជាមានិតចិន (International School, College of Pharmacy, Jinan University, China)។
- កញ្ញា គង្គា សិរីល័ក្ខ សិស្សថ្នាក់ទី៩ នៃសាលារៀនប៊ែលធីអន្តរជាតិ សាខាទី៩ នៃព្រះរាជាណាចក្រកម្ពុជា។

ដែលបានជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ និងឃ្លាប្រយោគ ការវាយអត្ថបទ ការរចនារូបភាព ដ្យាក្រាម និងក្រាភិចមួយចំនួនតាមកម្មវិធីកុំព្យូទ័រសម្រាប់ជាឧទាហរណ៍នៅក្នុងការគណនា និងការវិភាគទិន្នន័យនានានៅក្នុងវិធីសាស្ត្ររៀបចំតាមកម្មវិធីកុំព្យូទ័រនានាដូចជា៖ SPSS, SAS, MiniTab, GAME, ...។ល។

# អារម្ភកថា

បច្ចុប្បន្ននេះមុខវិជ្ជាការ ប្រវត្តិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (History of Cambodian Economic Development) គឺការអត្ថាធិប្បាយពីដំណើរការវិវត្តនៃបរិបទសេដ្ឋកិច្ចកម្ពុជាពីសម័យមួយទៅសម័យមួយទៀតបានក្លាយជាកញ្ចក់ឆ្លុះបញ្ចាំងពីទស្សនាទានដ៏ស៊ីជម្រៅនៃប្រវត្តិសាស្ត្រនៃការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជាតិកម្ពុជា។

សៀវភៅនេះបង្ហាញពីភោគផលនៃការអភិវឌ្ឍន៍លើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យសេវាកម្ម និងវិស័យរដ្ឋាភិបាល ព្រមទាំងបង្ហាញពីផលទុនជាតិ កម្លាំងពលកម្មជាតិ អតិផរណានិងឧបករណ៍នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចកម្ពុជា និងចរាចរនៃការនាំចេញ និងនាំចូលទំនិញ និងសេវារបស់ប្រទេសកម្ពុជាផងដែរ។

ម្យ៉ាងទៀតសព្វថ្ងៃនេះ បរិមាណបញ្ញវន្ត គឺកាន់តែកើនឡើងច្រើន បើប្រៀបធៀបទៅនឹងប៉ុន្មានឆ្នាំកន្លងមក ក៏ប៉ុន្តែយើងពុំសូវឃើញមានសៀវភៅសិក្សា សៀវភៅបច្ចេកទេស និងឯកសារស្រាវជ្រាវពីសកម្មភាពសេដ្ឋកិច្ចផ្សេងៗឯទៀតជាភាសារខ្មែរឱ្យច្រើនសំបូរនៅឡើយទេ។

ខ្ញុំជឿជាក់ថា អ្នកខ្លះមានចិត្តចង់សសេរដែរ តែកង្វះខាតជីវភាពរស់នៅ និងថវិកា អ្នកចេះដឹង និងបញ្ញវន្តជាច្រើនជាប់រវល់មមាញឹកធ្វើការឱ្យអង្គការឯកជន ក្រុមហ៊ុនអាជីវកម្មនានា អង្គការមនុស្សធម៌ ដើម្បីអ្វី គឺ ដើម្បីរកប្រាក់មកចិញ្ចឹមគ្រួសាររបស់គេ គេពុំបានយកចិត្តទុកដាក់ក្នុងការចងក្រងជាសៀវភៅ ឯកសារបច្ចេកទេស សម្រាប់ទុកឱ្យក្មេងជំនាន់ក្រោយនៅឡើយ។ បញ្ហាមួយទៀតអ្នកដែលទើបនឹង បញ្ចប់ថ្នាក់ឧត្តម (បរិញ្ញាប័ត្រ) ភាគច្រើន មានបទពិសោធន៍ផ្នែកបច្ចេកទេស និងចំណេះដឹង ផ្នែកភាសាបរទេស ពុំទាន់បានជ្រៅជ្រះនៅឡើយ ដែលជាបញ្ហារមួយពិបាកដល់ការស្រាវជ្រាវរកឯកសារបច្ចេកទេស។

ដើម្បីចូលរួមចំណែកក្នុងការឆ្លើយតបទៅនឹងសំណូមពររបស់មិត្តអ្នកអាននានា ជាពិសេសអ្នកដែលមានចំណង់ចំណូលចិត្តទៅលើកិច្ចការស្រាវជ្រាវអំពីវិស័យសេដ្ឋកិច្ចនោះ ខ្ញុំសង្ឃឹមថា ព័ត៌មាន និងការណែនាំដែលមាននៅក្នុងសៀវភៅនេះ អាចជាជំនួយដល់អ្នកដែលមានចំណង់ចំណូលចិត្តស្វែងយល់ពីសេដ្ឋកិច្ចវិទ្យា អ្នកស្រាវជ្រាវ និស្សិត ហើយជាពិសេសជាងនេះទៅទៀត គឺអ្នកដែលមានគំនិតចង់វិភាគពីគម្រោងអាជីវកម្មមុននឹងគេចាប់ផ្ដើមប្រកបមុខរបរធ្វើអាជីវកម្មផ្ទាល់ខ្លួនជាអាជីពនៅពេលដ៏ខ្លីខាងមុខ ទុកជាមាគ៌ាបង្ហាញផ្លូវនៃការគិតជាមុន និងទុកជាឯកសារផងដែរ។

អ្វីដែលសព្វថ្ងៃនេះមាន វានឹងអាចប្រែប្រួលនៅថ្ងៃស្អែក ស្នាដៃនេះជាជំហានដំបូងរបស់ខ្ញុំ ជាពន្លឺនាំមុខមួយដើម្បីត្រួសត្រាយផ្លូវនៃផ្នែកឯកសារទាក់ទងនឹងជំនាញសេដ្ឋកិច្ច ធុរកិច្ចកសិកម្ម សំដៅដោះស្រាយនូវបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាដែលកំពុងជួបប្រទះ ទោះបីជាពុំបានទាំងស្រុងក៏ដោយ។

ខ្ញុំបាទនឹងរង់ចាំទទួលនូវការរិះគន់កែលម្អក្នុងន័យស្ថាបនា និងការអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យឯកសារនេះកាន់តែមានភាពសុក្រិតថែមទៀត។ ខ្ញុំបាទសូមអភ័យទោសដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បញ្ញវន្ត និស្សិត អ្នកស្រាវជ្រាវ និងប្រជាជនទាំងអស់ ព្រមទាំងមិត្តអ្នកអានទាំងអស់ផងដែរ ប្រសិនបើមានការខុសឆ្គងដោយអចេតនាក្នុងការប្រើឃ្លាប្រយោគ ឬកំហុសអក្ខរាវិរុទ្ធ ដែលកើតមាននៅក្នុងសៀវភៅនេះ។

ជាអវសានសេចក្តី ខ្ញុំបាទសូមជូនពរ ដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង អ្នកស្រាវជ្រាវ បញ្ញវន្ត និស្សិត និងមិត្តអ្នកអានទាំងអស់សូមជួបតែនឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ព្រមទាំងមានសុភមង្គលល្អប្រពៃទាំងក្នុងជីវិតផ្ទាល់ខ្លួន និងក្នុងជីវិតក្រុមគ្រួសារ ថែមទាំងមានសំណាងល្អ និងទទួលបាននូវសេចក្តីចម្រុងចម្រើនគ្រប់ពេលវេលាជានិច្ច។

ថ្ងៃច័ន្ទ ៩រោច ខែទុយសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១

**អ្នកនិពន្ធ**

**សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គង្គា**

Assoc.Prof.CHHAY Kongkea, Ph.D.

# អំពីអ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ សាស្ត្រាចារ្យរង បណ្ឌិត **ឆាយ គង្គា**
(Assoc.Prof.CHHAY Kongkea, Ph.D.)

**អាសយដ្ឋាន** ៖ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

**ស្ថាប័នការងារ** ៖ មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ឯកទេស ឬមុខជំនាញ** ៖ បណ្ឌិតផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចកសិកម្ម

**ប្រវត្តិការសិក្សា៖**

- 2003-2006 Ph.D.Degree in Economics, Major in Agricultural Economics
  Chonnam National University, Gwangju City, South Korea.
- 2001–2003 Master's Degree in Economics, Major in Agricultural Economics
  Chonnam National University, Gwangju City, South Korea.
- 1993-1998 Bachelor's Degree in Economics, Major in Enterprise Management
  Faculty of Law and Economics, Phnom Penh, Cambodia
  [Present: Royal university of Law and Economics (RULE)]
- 1993-1996 Diplôme de Baccalauréat en sciences économiques, Faculté de droit et des sciences économiques, Royaume du Cambodge.
- 1990-1992 Diplima Up-Grading of Psychogical Pedagogy, Major in Mathematics,
  Battambang Psychogical Pedagogy School, Battamabng Province.
- 1992-1993 Certificate of Preparatory Class, Institute of Economic Sciences (Present: National University of Management), Cambodia.
- 1990-1992 Diplima of Sinor Hight School, Battambang Secondary School, Battambang Province, Kingdom of Cambodia.

**បទពិសោធន៍ការងារ៖**

- 2007 - បច្ចុប្បន្ន៖ព្រឹទ្ធបុរសរង (Vice Dean) មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ព្រះរាជាណាចក្រកម្ពុជា
- 2012 - បច្ចុប្បន្ន៖សាស្ត្រាចារ្យរង (Associate Professor) តាមអនុក្រឹត្យលេខ ៥៤៤

អនក្រ.តក ស្តីពីការតែងតាំងឋានៈជាសាស្ត្រាចារ្យរងជូនមន្ត្រីរាជការ និងគ្រូបង្រៀនថ្នាក់ឧត្តម ក្នុងវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ2012

- 1990 - 1992៖ជាប្រធានគណនេយ្យ នៃការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រុមហ៊ុនដានីម៉ិច រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- 1998 - បច្ចុប្បន្ន៖គ្រូបង្រៀនតាមសាកលវិទ្យាល័យនានា៖ NUM, BBU, NIB, HRU, UME, ...

# មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

**ទំព័រ**

សេចក្តីថ្លែងអំណរគុណ ........ i
អារម្ភកថា ........ iii
មាតិកា ........ vii

## មេរៀនទី ១
## ប្រវត្តិនៃសេដ្ឋកិច្ចកម្ពុជា និងទីតាំងភូមិសាស្ត្រកម្ពុជា

១.១.ផ្តើមសេចក្តី ........ ១
១.២.ក្របខ័ណ្ឌប្រវត្តិសាស្ត្រ ........ ២
១.២.១. ស្ថានភាពសេដ្ឋកិច្ចសម័យហ្វូណាន និងចេនឡា ........ ៥
១.២.២. ទស្សនៈទាន នៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអង្គរ ........ ១០
១.២.៣.ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអាណានិគមបារាំង ........ ១៤
១.២.៤.ទស្សនៈទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសម័យសង្គមរាស្ត្រនិយម ........ ១៦
១.២.៥.ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យសាធារណៈរដ្ឋខ្មែរ ........ ១៨
១.២.៦.ស្ថានភាពវិស័យសេដ្ឋកិច្ចសម័យកម្ពុជាប្រជាធិបតេយ្យ ........ ១៨
១.៣.ក្របខ័ណ្ឌនយោបាយ ........ ២១
១.៤.ក្របខ័ណ្ឌភូមិសាស្ត្រ ........ ២២
១.៤.១.សណ្ឋានដី ........ ២២
១.៤.២.អាកាសធាតុ ........ ២៤
១.៤.៣.ជលសាស្ត្រ និងទឹកជំនន់ ........ ២៥
១.៤.៤.ប្រភពធនធានរ៉ែ ........ ២៧
១.៥.ក្របខ័ណ្ឌប្រជាសាស្ត្រ ........ ២៨
១.៥.១.ទិដ្ឋភាពប្រជាសាស្ត្រទូទៅ ........ ២៨
១.៥.២.ការបែងចែកប្រជាជនតាមភូមិសាស្ត្រ ........ ៣២
១.៥.៣.ប្រជាជនសកម្ម ........ ៣៤
១.៦.ក្របខ័ណ្ឌ សង្គមកិច្ច និងវប្បធម៌ ........ ៣៧
១.៦.១.អត្ថិភាពនៃជនជាតិភាគតិច ........ ៣៨
១.៦.២.សារៈសំខាន់នៃព្រះពុទ្ធសាសនា ........ ៤០
១.៦.៣.កម្រិតការចេះដឹង ........ ៤៣

១.៧.ដើម្បីឱ្យមានការអភិវឌ្ឍដោយរីករាយ ............ ៤៣
១.៧.១.ស្ថាបត្យកម្ម និងការប្រព្រឹត្តិទៅនៃប្រពៃណី ............ ៤៤
១.៧.២.គោលការណ៍ទូទៅនៃការអភិវឌ្ឍ ............ ៤៥
១.៧.៣.ប្រតិទិនអនុវត្តន៍ ............ ៤៦
១.៨.យោបល់រួមស្តីពីប្រវត្តិសេដ្ឋកិច្ច ឆ្នាំ ១៩៧៩-១៩៩១ ............ ៤៦
១.៨.១.ការស្តាបនាឡើងវិញ ៖ ១៩៧៩-១៩៨១ ............ ៤៧
១.៨.២.១៩៨១-១៩៨២: ការរៀបចំឱ្យមានរបៀបនិង ការចាប់ផ្តើមបទពិសោធសង្គមនិយម ............ ៤៧
១.៨.៣.សង្គមនិយម និងការលំបាក៖ ១៩៨៣-១៩៨៦ ............ ៤៨
១.៨.៤.និន្នាការនៃការធ្វើឱ្យងើបឡើងវិញនៃសង្គមនិយមនិងជោគជ័យនៃផ្នែកឯកជន៖ ១៩៨៧-១៩៩០ ............ ៤៩
១.៨.៥.ការបញ្ចប់នៃសេដ្ឋកិច្ចចាស់ ៖ ឆ្នាំ ១៩៩១ ............ ៥១

**មេរៀនទី ២**

**លក្ខណៈផ្សេងៗនៃផលទុនជាតិ**

២.១.រចនាសម្ព័ន្ធនៃផលទុនជាតិ ............ ៥២
២.២.កំណើននៃផលទុនជាតិ ............ ៥៥
២.៣.បញ្ហាកំណើននៅកម្ពុជា ............ ៥៧
២.៤.ការកាត់បន្ថយនៃកំណើនផលិតផលក្នុងស្រុកសរុប ............ ៦៣
២.៤.១.វិភាគសេដ្ឋកិច្ចផលទុនដុលជាតិម្នាក់ៗ ............ ៦៣
២.៤.២.ខ្លឹមសារម៉ាក្រូសេដ្ឋកិច្ច ............ ៦៣
២.៤.៣.រចនាសម្ព័ន្ធថាមពលនៃផលទុនដល់ជាតិ ............ ៦៤
២.៤.៤.ការវិភាគវិស័យនានានៃផលទុនដល់ជាតិ ............ ៦៥

**មេរៀនទី ៣**

**កសិកម្ម**

៣.១.កត្តានានានៃផលិតកម្មកសិកម្ម និងរចនាសម្ព័ន្ធដីធ្លីកសិកម្ម ............ ៧២
៣.២.ផលិតផលនៃផ្នែកកសិកម្ម ............ ៧៥
៣.២.១.ស្រូវ ............ ៧៩
៣.២.២.ពោត ............ ១០៨
៣.២.៣.ដំឡូងមី ............ ១៣៣

៣.២.៤.កៅស៊ូ ........................................................................................ ១៦២
៣.៣.ការធ្វើពាណិជ្ជកម្ម ផលិតកម្ម កសិកម្ម ........................................................ ១៦៣
៣.៣.១.សៀគ្វីប្រពៃណី ............................................................................ ១៦៣
៣.៤.និន្នាការកែលម្អសៀគ្វី ....................................................................... ១៦៤

## មេរៀនទី ៤
## វិស័យឧស្សាហកម្ម និងសេវាកម្មនៅកម្ពុជា

៤.១.វិស័យឧស្សាហកម្ម ........................................................................... ១៦៦
៤.១.១.ឧស្សាហូបនីយកម្មនៅកម្ពុជា ........................................................... ១៦៦
៤.២.រចនាសម្ព័ន្ធឧស្សាហកម្ម....................................................................... ១៦៩
៤.៣ ឧស្សាហកម្មនានា ................................................................................ ១៧០
៤.៤.រចនាសម្ព័ន្ធអាជីវកម្មកសិកម្ម និងការដឹកជញ្ជូន ................................... ១៧៣
៤.៤.១.លក្ខខ័ណ្ឌនានានៃអាជីវកម្មរបស់សហគ្រាស ......................................... ១៧៣
៤.៤.២.រចនាសម្ព័ន្ធ និងការដឹកជញ្ជូន .......................................................... ១៧៤
៤.៥.សេវាកម្មផ្សេងៗទៀត........................................................................... ១៧៥

## មេរៀនទី ៥
## ការប្រើប្រាស់ផលទុនជាតិ

៥.១.ការបែងចែកនូវផលទុនជាតិ ................................................................ ១៧៧
៥.២.ការប្រើប្រាស់នៃគេហជន....................................................................... ១៨០
៥.៣.ការប្រើប្រាស់នៃវិនិយោគឯកជន ............................................................ ១៨២
៥.៤.ចំណាយរដ្ឋាភិបាល ............................................................................. ១៨៣
៥.៥.ការបង្កើតទុន ..................................................................................... ១៨៣
៥.៦.លំនឹងនៃជញ្ជីងពាណិជ្ជកម្ម ................................................................... ១៨៦

## មេរៀនទី ៦
## ពាណិជ្ជកម្មក្រៅប្រទេស

៦.១.ប្រវត្តិនៃពាណិជ្ជកម្មក្រៅប្រទេស .......................................................... ១៨៨
៦.១.១ ស្ថាប័ននានាៈ សូណិចស៊ីម.................................................................. ១៨៩
៦.២.ប្រវត្តិ និងទ្រឹស្តីតុល្យភាពជញ្ជីងទូទាត់ពាណិជ្ជកម្ម.......................................... ១៩០
៦.២.១.រហូតមកដល់ឆ្នាំ ១៩៦៣ ..................................................................... ១៩០

៦.២.២.ចាប់ពីឆ្នាំ ១៩៦៣ ............................................................................. ១៩៣
៦.៣.ការតម្រង់ទិសនានា៖ កិច្ចព្រមព្រៀងពាណិជ្ជកម្ម ............................................. ១៩៤
៦.៣.១.ការនាំចូល........................................................................................ ១៩៧
៦.៣.២.សារៈសំខាន់នៃការនាំចូល ................................................................. ១៩៧
៦.៤.ការនាំចេញ ............................................................................................ ១៩៩
៦.៤.១.ការនាំចេញអង្ករ ............................................................................... ១៩៩
៦.៤.២.ការនាំចេញកៅស៊ូ ............................................................................. ២០១
៦.៤.៣.ការនាំចេញផ្សេងៗទៀត.................................................................... ២០៤
៦.៥.រចនាសម្ព័ន្ធនៃការនាំចេញ និងការវិវដ្តរបស់ខ្លួន.............................................. ២០៥
៦.៥.១.ផលិតផលនាំចេញ ........................................................................... ២០៥
៦.៥.២.អតិថិជនរបស់កម្ពុជា ......................................................................... ២០៦
៦.៦.រចនាសម្ព័ន្ធនៃផលិតផល .......................................................................... ២០៧
៦.៧.រចនាសម្ព័ន្ធតាមប្រទេស ........................................................................... ២០៧
៦.៨.ជញ្ជីងទូទាត់ ............................................................................................ ២០៨
៦.៨.១.ជញ្ជីងពាណិជ្ជកម្ម ............................................................................ ២១០
៦.៨.២.ប៉ុស្តិ៍នៃជញ្ជីងទូទាត់ដទៃទៀត ............................................................. ២១១
៦.៨.៣.ប្រតិបត្តិការទុន មិនអាចកែលម្អឱ្យភាពបានទេ........................................ ២១២

## មេរៀនទី ៧
## នយោបាយសេដ្ឋកិច្ច

៧.១.ផែនការរូបនីយកម្ម............................................................................... ២១៤
៧.២.ការរៀបចំផែនការ .................................................................................. ២១៤
៧.៣.ខ្លឹមសារផែនការ .................................................................................... ២១៦
៧.៣.១.ផែនការពីរឆ្នាំទីមួយ .......................................................................... ២១៦
៧.៣.២.ផែនការប្រាំឆ្នាំទី១ ........................................................................... ២១៧
៧.៣.៣.ផែនការប្រាំឆ្នាំលើកទីពីរ..................................................................... ២១៨
៧.៤.ការអនុវត្តនៃផែនការ............................................................................... ២២០
៧.៥..យន្តការសេដ្ឋកិច្ច ................................................................................... ២២១
៧.៥.១.ការប្រព្រឹត្តិទៅ ធម្មតា នៃប្រព័ន្ធ .......................................................... ២២២
៧.៥.២.កត្តាមិនធម្មតានៃការបែងចែកទាំងស្រពិចស្រពិល ................................... ២២៤
៧.៥.៣.ការបង្រួបបង្រួមគ្នាបានដោយឥទ្ធិពលពីខាងក្រៅ..................................... ២២៥

៧.៦.ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា ..................................................... ២២៧
៧.៧.គោលនយោបាយសេដ្ឋកិច្ច ..................................................... ២២៨
៧.៧.១.គោលនយោបាយទី១: គ្រប់គ្រងសេដ្ឋកិច្ច និង អភិវឌ្ឍវិស័យហិរញ្ញវត្ថុ ..... ២២៨
៧.៧.២.គោលនយោបាយទី២: គ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ និង ទ្រព្យសម្បត្តិរដ្ឋ ២៣១

## មេរៀនទី ៨
## ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារសង្គម

៨.១.ហេដ្ឋារចនាសម្ព័ន ..................................................... ២៣៩
៨.២.សិក្សាធិការ ..................................................... ២៤០
៨.៣.វិស័យសុខាភិបាល ..................................................... ២៤១
៨.៤.វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ..................................................... ២៤៣
៨.៤.១.សកម្មភាពលើផលិតកម្ម ..................................................... ២៤៣
៨.៤.២.សកម្មភាពនៃកំណាបសារណៈក្នុងវិស័យឧស្សាហកម្មនិង ពាណិជ្ជកម្ម..... ២៤៧

## មេរៀនទី ៩
## ប្រព័ន្ធសារពើពន្ធកម្ពុជា

៩.១.ចំណូល-ចំណាយថវិកាជាតិ ..................................................... ២៥២
៩.១.១.ការចំណាយតាមហិរញ្ញវត្ថុ ..................................................... ២៥២
៩.១.២.ចំណូលតាមពន្ធដារ ..................................................... ២៥៤
៩.១.៣ ចំណូលនិងចំណាយថវិកា: ២០០៩-២០១៣ ..................................................... ២៥៥
៩.២.កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ..................................................... ២៥៧
៩.២.១.ការប្រឈមមុខនៃ PMFRP ..................................................... ២៥៨
៩.៣.គោលនយោបាយសារពើពន្ធ ..................................................... ២៥៩
៩.៤.ប្រភេទពន្ធអាករនានា ..................................................... ២៥៩
៩.៥.លំនឹងនៃហិរញ្ញវត្ថុសាធារណៈ ..................................................... ២៦៤

## មេរៀនទី ១០
## ប្រព័ន្ធហិរញ្ញវត្ថុ និង រូបិយវត្ថុនៅកម្ពុជា

១០.១.សេចក្តីផ្តើម ..................................................... ២៦៧
១០.២.ប្រព័ន្ធធនាគារកម្ពុជា ..................................................... ២៦៩
១០.២.១.ធនាគារជាតិនៃកម្ពុជា (B.N.C) ..................................................... ២៧០

១០.២.២.ធនាគារពាណិជ្ជកម្ម.......................................................................២៧៤
១០.២.៣.បេឡាសោធនវត្តន៍ស៊ីវិល នៃកម្ពុជា (C.P.C.E)៖ ............................២៧៤
១០.២.៤ បេឡាសម្ភារៈ(C.N.E.)៖ ...............................................................២៧៤
១០.២.៥.មន្ទីររាជសហករណ៍ (OROC.)៖ ......................................................២៧៥
១០.៣.តួនាទីធនាគារនៃប្រទេសកម្ពុជា .........................................................២៧៥
១០.៤.នយោបាយរូបិយវត្ថុកម្ពុជា ...................................................................២៧៦
១០.៤.១.ស្តេរកម្មប្រាក់រៀល.............................................................................២៧៧
១០.៤.២.ការផ្តល់ហិរញ្ញវត្ថុដល់ពាណិជ្ជកម្ម .....................................................២៧៩
១០.៤.៣.រុញផលិតកម្ម ..................................................................................២៨០
១០.៥.យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ .............................................២៨២
១០.៥.១.ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០.........................២៨៣
១០.៥.២.ផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥.......................... ២៨៥
១០.៥.៣.គោលនយោបាយទី១: គ្រប់គ្រងសេដ្ឋកិច្ច និង អភិវឌ្ឍវិស័យហិរញ្ញវត្ថុ... ២៨៦
១០.៥.៤.គោលនយោបាយទី២: គ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ និង ទ្រព្យសម្បត្តិរដ្ឋ២៨៨
១០.៦.និន្នាការនៃការប្តូរប្រាក់ និងគោលនយោបាយអត្រាប្តូរប្រាក់ ............................ ២៩៥
១០.៦.១ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លាអាមេរិក.................... ២៩៥
១០.៦.២ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗមួយចំនួន....... ២៩៦
១០.៧.ហិរញ្ញវត្ថុសាធារណៈ.............................................................................២៩៧
១០.៧.១.ទិដ្ឋភាពរូបិយប័ណ្ណ.............................................................................២៩៧
១០.៧.២.ទិដ្ឋភាពតថភាព ................................................................................ ២៩៨
១០.៨.ចំណូល ចំណាយសាធារណៈ .................................................................... ៣០០
១០.៨.១.តួនាទី និង បេសកកម្មចម្បងៗ សម្រាប់ឆ្នាំ(២០១៧-២០១៩)........... ៣០១
១០.៨.២.ការគ្រប់គ្រងចំណូលចំណាយសាធារណៈ ....................................... ៣០៦

**មេរៀនទី ១១**

**សេដ្ឋកិច្ចទីផ្សារសេរីនៅកម្ពុជា**

១១.១.សេដ្ឋកិច្ចទីផ្សារសេរី និង កំណើនសេដ្ឋកិច្ចកម្ពុជា ........................................... ៣១១
១១.២.សេដ្ឋកិច្ចឧស្សាហកម្មក្នុងស្រុក និង សេដ្ឋកិច្ចក្នុងតំបន់.....................................៣១២
១១.៣.ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានៅក្នុងអាស៊ាន ....................................................៣១៣

**មេរៀនទី ១២**

## កំណើនសេដ្ឋកិច្ចនៅកម្ពុជា

១២.១.ប្រភពនៃកំណើនសេដ្ឋកិច្ចកម្ពុជា ........ ៣១៥
១២.២.បញ្ហានៃកំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ........ ៣១៦
១២.៣.ការកាត់បន្ថយនៃបញ្ហារបស់កំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ........ ៣១៧
១២.៤.តុល្យការ និង ទស្សនៈវិស័យ ........ ៣១៨
១២.៤.១.តុល្យការសង្គម ការផ្ដើមពីគ្នា ........ ៣១៨
១២.៤.២.ការវិភាគនយោបាយ ........ ៣២០
១២.៥.អនាគតនយោបាយ ........ ៣២១
១២.៦.សក្ដានុពលសេដ្ឋកិច្ច ........ ៣២១

## មេរៀនទី ១៣
## ជំនួយអន្តរជាតិនៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា

១៣.១.ធម្មជាតិនៃជំនួយ ........ ៣២៥
១៣.១.១.ប្រភពជំនួយផ្សេងៗ ........ ៣២៥
១៣.១.២.រូបភាពនានានៃជំនួយ ........ ៣២៨
១៣.២.តួនាទីនៃជំនួយ ........ ៣២៩
១៣.២.១.ផលប៉ះពាល់ផ្ទាល់នៃជំនួយ ........ ៣២៩
១៣.២.២.ផលប៉ះពាល់មិនផ្ទាល់នៃជំនួយ ........ ៣៣០
១៣.៣.ទំនាក់ទំនងទ្វេភាគី ........ ៣៣១
១៣.៤.ទំនាក់ទំនងពហុភាគី ........ ៣៣៣
១៣.៤.១.ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ........ ៣៣៣
១៣.៤.២ ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី........ ៣៣៣
១៣.៥.ទំនាក់ទំនងជាមួយអាស៊ាន ........ ៣៣៤
១៣.៥.១.សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ........ ៣៣៤
១៣.៥.២ សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន + ៣ ........ ៣៣៥
១៣.៦.ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្ដាលអាស៊ីអាគ្នេយ៍ (ស៊ាសិន SEACEN) ........ ៣៣៥

## មេរៀនទី ១៤
## តុល្យការសេដ្ឋកិច្ច (១៩៥០~១៩៧០)

១៤.១.តុល្យការសង្គមវប្បធម៌ ........ ៣៣៧
១៤.១.១.ការប៉ះទង្គិចសេដ្ឋកិច្ច ........ ៣៣៨

១៤.១.២.ភាពអន្តរាយនៃបរិស្ថាន ........................................................................ ៣៣៩
១៤.១.៣.ប៉ះទង្គិចខាងប្រជាសាស្ត្រ ........................................................................ ៣៤០
១៤.២.តុល្យការបរិមាណ ........................................................................ ៣៤០
១៤.៣.ការរុករកការផ្លាស់ប្តូរ ........................................................................ ៣៥៨
១៤.៣.១.ការវិភាគបរិមាណនៃការផ្លាសប្តូរក្រៅប្រទេស ........................................................................ ៣៥៨
១៤.៣.២.ការវិភាគគុណភាព និង ផ្នែកនានា ........................................................................ ៣៦០
១៤.៣.៣.ការវិភាគពិស្តារ ........................................................................ ៣៦៣
១៤.៤.ការកែប្រែមុខងារ ........................................................................ ៣៦៥
១៤.៤.១.ការប្តូរសមភាគី ........................................................................ ៣៦៥
១៤.៤.២.ការប្តូរភ្នាក់ងារ ........................................................................ ៣៦៦
១៤.៤.៣.តុល្យការះ តើការសន្និដ្ឋានបែបណា ដែលអាចផ្តល់ឱ្យឃើញ នូវផលទុនដុលទុនដុលក្នុងប្រទេសរបស់កម្ពុជាបាន ? ........................................................................ ៣៦៨
**បណ្ណាល័យសាស្ត្រ** ( Bibliography )

# មេរៀនទី ១
# ប្រវត្តិនៃសេដ្ឋកិច្ចកម្ពុជា និងទីតាំងភូមិសាស្ត្រកម្ពុជា

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ក្របខណ្ឌប្រវត្តិសាស្ត្រ
- ក្របខណ្ឌនយោបាយ
- ក្របខណ្ឌភូមិសាស្ត្រ
- ក្របខណ្ឌប្រជាសាស្ត្រ
- ក្របខណ្ឌសង្គមកិច្ច និងវប្បធម៌

## ១.១.ផ្ដើមសេចក្ដី

សេដ្ឋកិច្ចកម្ពុជា ជាសេដ្ឋកិច្ចដែលស្គាល់មិនច្បាស់ ជាសេដ្ឋកិច្ចដែលត្រូវបានគេធ្វើការសិក្សាតិចតួច។ ជាយូរមកហើយ គេមិនទាន់ឃើញមានសំណុំឯកសារនិយាយអំពីប្រធានបទនេះទេ ហើយក៏មិនទាន់មានការវិភាគលម្អិតច្បាស់លាស់ពីតំបន់ និងផ្នែកនានានៃសេដ្ឋកិច្ចកម្ពុជាឡើយ។ ប្រភពស្ថិតិដែលមិនអាចខ្វះបាន ជាប្រភពនៃលទ្ធភាពដល់ការសិក្សា ក៏មិនទាន់មានគ្រប់គ្រាន់ទាំងគុណភាព និងបរិមាណ។

ទោះបីជាខ្វះខាត គេក៏ប្រមូលបាននូវឯកសារអង្កេតនានា ស្ដីអំពីសេដ្ឋកិច្ចកម្ពុជា។ គណនេយ្យសេដ្ឋ-កិច្ច និងលទ្ធភាពនៃការធ្វើជំរឿនប្រជាជន នាឆ្នាំ ១៩៦២ ហើយត្រូវបានបោះពុម្ពផ្សាយ នាឆ្នាំ ១៩៦៦ បានផ្ដល់ជាឯកសារសម្បូរណ៍បែបដល់ពុទ្ធិនៃរចនាសម្ព័ន្ធ និងយន្តការនៃសេដ្ឋកិច្ចរបស់ប្រទេស។ សៀវភៅដែលបានបោះពុម្ពផ្សាយមានឈ្មោះថា " ទីពិសោធន៍នៃវិបត្តិមួយ និងតុល្យការសេដ្ឋកិច្ច " របស់លោក Jacque Népotá និងលោក Marie-Sybille de Vience នឹងបំពេញបន្ថែមនូវសភាពការណ៍សេដ្ឋកិច្ច ក្នុងទសវត្ស ឆ្នាំ ១៩៧០ ១៩៨០ និងដើមទសវត្ស ឆ្នាំ ១៩៩០។ ពេលវេលាបង្កលទ្ធភាពដល់ការសាកល្បងប្រមូលផ្ដុំព័ត៌មាន យកមកធ្វើជាអត្ថាធិប្បាយនូវសំណុំមេរៀន សេដ្ឋកិច្ចកម្ពុជា បានជាស្នាមនិមិត្តរូបមួយ។

កម្ពុជាមិនមែនជា "ប្រទេសមួយតូច" នោះទេ បើប្រៀបធៀបជាមួយប្រទេសដែលមានប្រជាជនតិច ឬជាមួយប្រទេសកម្ពុជា ជាប្រទេសមួយនៃភូមិភាគអាស៊ីអាគ្នេយ៍ ស្ថិតនៅចន្លោះរវាងកម្រិតទី ១០ ដល់ទី ១៥ អង្សារ នៃខ្សែរយៈទទឹងភាគខាងជើង មានព្រំប្រទល់ខាងកើតជាមួយប្រទេសវៀតណាម ភាគខាងជើងជាមួយប្រទេសឡាវ ភាគខាងជើង និងខាងលិចជាមួយប្រទេសថៃ និងភាគនិរតីជាប់នឹងឈូងសមុទ្រថៃ។

ប្រទេសដែលមិនលាតសន្ធឹងធំទូលាយជាងកម្ពុជានោះ។ នៅឆ្នាំ១៩៦៧ប្រជាជនកម្ពុជាមានចំនួន៦លាននាក់។ ហើយនៅឆ្នាំ ១៩៩៣ចំនួនប្រជាជននេះបានកើនឡើងដល់ជាង៩លាននាក់ក្រោយពីឆ្លងកាត់នូវសង្គ្រាមហែកហួរជាងពីរទសវត្ស។

ផ្ទៃដីកម្ពុជាមានទំហំ ១៨១,០៣៥ គម² ប្រហែលស្មើនឹង ១/៣ នៃផ្ទៃដីប្រទេសបារាំង។

## ១.២.ក្របខ័ណ្ឌប្រវត្តិសាស្ត្រ

កម្ពុជាជាអ្នកបន្តកេរមរតកសង្គមប្រវត្តិសាស្ត្រដ៏យូរលង់នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍៖ សម័យអាណាចក្រភ្នំសម័យហ្វូណនដែលបានទទួលឥទ្ធិពលវប្បធម៌ និងពាណិជ្ជកម្មមកពីប្រទេសឥណ្ឌាគឺបានបន្សល់ទុកដល់ពេលបច្ចុប្បន្ន នៅតំបន់រាចចា "ហាទៀង-អតីតឈ្មោះក្រមួនស" ដែលជាកំពង់ផែនៃជ្រោយកូសាំងស៊ីន សព្វថ្ងៃស្ថិតនៅជាប់នឹងព្រំដែនកម្ពុជា នៃខេត្តកំពត។

អតីតអាណាចក្រដែនសមុទ្រ មានប្រភពដើមជាជនជាតិខ្មែរ ដែលជាអ្នកធ្វើឱ្យមានអរិយធម៌ដល់ភូមិភាគ មាត់សមុទ្រនៃឥណ្ឌូចិន មានរយៈពេលពីសតវត្សទី ១ ដល់ សតវត្សទី ៦ ក្រោយគ.ស.។ ប្រជាជនទាំងនោះធ្លាប់បានអភិវឌ្ឍន៍វិស័យកសិកម្មនៅតំបន់ដីសណ្តរ ដែលជាតំបន់មានប្រព័ន្ធធារាសាស្ត្រធម្មជាតិ ទទួលទឹកពីជំនន់ទន្លេមេគង្គ។

ចូលមកដល់សតវត្សទី ៧ អាណាចក្រនេះបានត្រូវគ្រប់គ្រងដោយក្រុមមនុស្សមកពីផ្ទៃក្នុងនៃជ្រោយឧបទ្វីប គឺជាពួកខ្មែរនៃអាណាចក្រចេនឡា "ភាគខាងត្បូងឡាវសព្វថ្ងៃ" ។ ពួកនោះមានប្រភេទនៃការចាត់ចែងខាងរដ្ឋាភិបាលដ៏ខ្លាំងមួយ ហើយបានរៀបចំក្របខ័ណ្ឌឋានានុក្រម នយោបាយ ប្រពៃណី គោរពបូជាតាមបែបហិណ្ឌូ ដែលទាញយកមកពីប្រភពប្រព័ន្ធធារាសាស្ត្រកសិកម្ម និងការរៀបចំនគរោបនីយកម្មទឹកដី។ គំរូនៃសម័យអង្គរ ដែលមានប្រព័ន្ធធារាសាស្ត្រ កសាងឡើងនៅរវាងសតវត្សទី ៩ ដល់ សតវត្សទី ១៤ ជារោងចក្រ ផលិតស្រូវដែលអាចប្រមូលផលច្រើនដងក្នុងមួយឆ្នាំ ហើយមហាអំណាចនេះ ក៏មានសក្តានុពលភាពយោធាមួយ ដែលជាមូលដ្ឋានកំណត់នៃឡូហ្សិក នៃការផ្លាស់ប្តូរពាណិជ្ជកម្ម។ ព្រះរាជាណាចក្រខ្មែរ គឺជារដ្ឋដ៏ធំមួយនៅរវាងសតវត្សទី ១០ និងទី ១៤ ។

ព្រះរាជាណាចក្រនោះ បានជួបប្រទះនឹងឧបសគ្គ ចាប់តាំងពីសតវត្សទី ១៣ មក នូវការបាត់លំនឹងពីរបែបដោយសារ៖

ក.ការផ្តាច់ពីប្រភពដើមរបស់វប្បធម៌ឥណ្ឌា ដោយសារការវាតទីរបស់ពួកមុយស៊ីនម៉ង់នៅប្រទេសឥណ្ឌា ជាការផ្តាច់ចេញតាមរយៈការឆ្លងកាត់ពីសាសនាព្រហ្មញ្ញ មកកាន់ព្រះពុទ្ធសាសនា ថេរវាទ និងពីការផ្លាស់ប្តូរនៃការប្រើប្រាស់អក្សរ ពីសំស្រ្កឹត មក ភាសាបាលី ។ល។

ខ.ការគាបសង្កត់ ពី "ពួកចោរព្រៃ" គឺពួកសៀម។ ការប្រយុទ្ធគ្នានៅសមរភូមិអង្គរ បានបង្កនូវវិនាស កម្ម ដល់ប្រព័ន្ធធារាសាស្ត្រយ៉ាងធ្ងន់ធ្ងរ។

សរុបមកអ្វីទាំងអស់បាននាំទៅដល់ជាបឋមនូវការផ្លាស់ប្តូរនូវមនោគមវិជ្ជានៃរាជវង្សជានិមិត្តរូប មានជំនឿរឿងព្រះបាទត្រសក់ផ្អែម បន្ទាប់មកមានការផ្លាស់ប្តូរទីតាំងមូលដ្ឋាននយោបាយ និងកសិកម្ម នៃព្រះរាជាណាចក្រ មកកាន់ដីសណ្តរនៃទន្លេមេគង្គ នៅជ្រុងម្ខាង ជិតអតីតអាណាចក្រហ្វូណន នាសតវត្សទី ១៤ ។នៅជំណាក់កាលនោះ ប្រពណី នយោបាយ និងវប្បធម៌ខ្មែរ បានស្ថិតនៅចន្លោះរវាងមួយផ្នែកប្រពណី ប្រវត្តិសាស្ត្ររបស់ខ្លួន និងឡូហ្សិកនៃ

សង្គមកសិកម្មសម័យអង្គរ ហើយមួយផ្នែកទៀត មកជាការចាំបាច់ជានា ដែលត្រូវចងភ្ជាប់ជាមួយអតីតប្រពៃណីពាណិជ្ជកម្មផ្លាស់ប្តូរ ជាមួយបរទេសនៃសម័យហ្វូណន។ ជាកស្តុតាងនៃទំនាស់ទាំងនោះ គឺការលេចឡើងនៅការចាយប្រាក់នាសតវត្សទី ១៦ និងបង្កហេតុនៃឧបករណ៍សេដ្ឋកិច្ច ដ៏រស់ រវើកនេះ នៅតែស្ថិតនៅឯកកោ ពីទម្លាប់ខ្មែរបុរាណ ស្របទៅនឹងរូបភាព ដុយអាលីស ដែលការអភិវឌ្ឍទាំងផ្នែក បុរាណ និងសម័យ។តាំងយូរយារណាស់មកហើយ លុយរៀលខ្មែរបានខ្ចីឈ្មោះលុយបរទេសមកសម្របតាម គឺសម្របតាមលុយរៀល ពួកអេស្ប៉ាញ លដែលជិះសំពៅមកធ្វើជំនួញនៅកម្ពុជា ហើយក៏ជាការលើកទឹកចិត្តដែរដល់អ្នកសេដ្ឋកិច្ចសម័យសតវត្ស ទី ១៦ ដែលយកប្រាក់មកប្រើប្រាស់ចាយវាយក្នុងផ្នែកសេដ្ឋកិច្ច ធ្វើឱ្យប្រជាជននៃសង្គមស្ថិតនៅក្នុងស្ថានភាពជាប់ទាក់ទងតិច ឬច្រើនជាមួយពួកបរទេស ដូចជា ចិន ម៉ាឡេ ជប៉ុន ពៃក្ស ហូឡង់ ព័រទុយហ្គេ និងបរទេសដទៃទៀត។

កម្ពុជាស្ថិតក្នុងទំនាស់បែបនេះ ដែលនាំទៅដល់ការឱ្យនិយមន័យ តុល្យការនឹងនមួយ ដែលពួកឈ្លានពានដូចជា ពួកវៀតណាម និងពួកថៃ មិនព្រមបញ្ឈប់នូវការឈ្លានពាននេះ តាំងពីសតវត្សទី ១៧ តាម រយៈការកេងប្រវញ្ច័យកទឹកដីខ្មែរ មិនឈប់ឈរ។

នៅក្នុងរយៈពេលពាក់កណ្តាលដើមសតវត្សទី ១៩ ពេលដែលកម្ពុជាបានធ្លាក់ចូលទៅក្នុងជង្គាប់ប្រទេសនេះ បានត្រូវសង្គ្រោះដោយព្រះរាជវង្សពីរព្រះអង្គ គឺព្រះបាទសម្តេចព្រះអង្គច័ន្ទ " ១៨០៦-១៨៣៤ " និងព្រះបាទអង្គឌួង "១៨៤៥-១៨៦០" ដែលព្រះអង្គទាំងពីរ បានទទួលការជោគជ័យក្នុងការទាក់ទាញការយកចិត្តទុកដាក់របស់ពួកលោកខាងលិចដែលជាអ្នកគាំពារបរទេស ក្នុងសង្គ្រាមតាមតំបន់នានារបស់ពួកគេ។ ព្រះរាជបុត្រព្រះអង្គឌួង គឺព្រះបាទសម្តេចព្រះនរោត្តម "១៨៦០-១៩០៤" បានទទួលផ្លែផ្កាពីការបើកចំហ ហើយកិច្ចព្រមព្រៀងនៃអាណាចក្រ ណាប៉ូឡេអុងទី ៣ និងព្រះរាជាណាចក្រសៀម ដែលបានចុះហត្ថលេខានៅបាងកក ទើបសង្គ្រោះបាននូវប្រពៃណីរាជានិយមខ្មែរ។ប៉ុន្តែក្រោយមកបន្តិចនៃព្រឹត្តិការណ៍សាធារណរដ្ឋបារាំង "ចុងឆ្នាំ១៨៧០" អាណានិគមរាជានិយមនេះ បានក្លាយជាឯកតោភាគី ទៅជាអាណានិគម "សាធារណរដ្ឋ" យោធា ហើយសាធារណរដ្ឋនោះ ក៏ធ្វើឱ្យមានជំនឿលើរបៀបរបបការិយាល័យនិយម នៅក្នុងផ្ទៃនៃសេដ្ឋកិច្ចកម្ពុជា " ទិដ្ឋភាពនៃរឿងរ៉ាវ គឺកម្មវត្ថុនៃការងារសព្វថ្ងៃ " ដែលប្រព្រឹត្តទៅនៅក្នុងស្ថានភាពដែលចេះតែកើតឡើងនៃជំងឺ និងភាពល្ងង់ខ្លៅដល់តថភាពក្នុងស្រុក។ វិធានការណ៍ដោះស្រាយរបស់រដ្ឋអំណាចអាណានិគមមួយចំនួនបានដាក់ឲ្យអនុវត្តន៍ គឺការរៀបចំផ្នែកសុរិយោដីការធ្វើជំរឿនប្រភពធនធានទាំងឡាយ។ល។ ការរៀបចំរដ្ឋបាលតាមរូបភាពលោកខាងលិច ការរៀបចំសេដ្ឋកិច្ចកម្ពុជា ដែលហួសពីការជឿទៅទៀតនោះ គឺការប្រើអំណាចបញ្ចូលសេដ្ឋកិច្ចនេះទៅក្នុងសហព័ន្ធឥណ្ឌូចិនហើយកាន់តែធ្វើឱ្យមានការជាប់ទាក់ទងគ្នាកាន់តែខ្លាំងឡើងៗជាប្រព័ន្ធសេដ្ឋកិច្ច ដែលជាស្នូលសកម្មភាពប្រព្រឹត្តទៅដោយប្រព័ន្ធនៃជនជាតិចិន។

ប្រវត្តិសេដ្ឋកិច្ចក្នុងរយៈកាលនៃសម័យអាណានិគមបារាំង នៅមានអ្វីៗត្រូវធ្វើច្រើនទៀត។ ចំណុចខ្វះខាតទាំងនោះត្រូវបំពេញបន្ថែម ព្រោះថាមានភាពងាយស្រួលច្រើនដែរ ព្រោះ

ប្រភពស្ថិតិនានាដូចមានច្រើនសម្បូរ ហើយហោចណាស់ គឺការងារពាណិជ្ជកម្មក្រៅប្រទេស និងហិរញ្ញវត្ថុសាធារណៈ "ពន្ធអាករ" ។ គឺនៅចំណុចនៃអានុភាពការនាំចេញ និងពន្ធអាករនោះហើយ ដែលជាផលប្រយោជន៍នៃវិស័យរដ្ឋបាលអាណានិគម បានត្រូវយកចិត្តទុកដាក់ ហើយការនាំទៅដល់ការសិក្សាផងដែរ នូវផ្នែកផលិតកម្ម រចនាសម្ព័ន្ធ ឬវិស័យប្រជាសាស្ត្រកម្ពុជា។ មុននេះ សេដ្ឋកិច្ចកម្ពុជា ជាសេដ្ឋកិច្ចអាណានិគម។ ដូចអត្ថបទមួយបានវាយតម្លៃយ៉ាងត្រឹមត្រូវ ដែលបានបោះពុម្ពផ្សាយដោយអគ្គទេសាភិបាលជាន់ខ្ពស់បារាំងនៅកម្ពុជា នាឆ្នាំ ១៩៥២ ថា៖ "តួនាទីសេដ្ឋកិច្ចកម្ពុជា គឺគ្រាន់តែសម្រាប់ការផ្គត់ផ្គង់មួយផ្នែកនៃទីផ្សារសៃហ្គន-ចូលុង ហើយទីពីរ គឺបម្រើឥណ្ឌូចិនទាំងមូលនូវផលិតកម្ម ព្រមទាំងវត្ថុធាតុដើមសម្រាប់នាំចេញ ឬក៏ជាផលិតផលចុងក្រោយ ដែលនាំចូលមកវិញ ឬជាទំនិញពាក់កណ្តាលសម្រេច"។ ដូច្នេះហើយ បានជា គ្មានវត្ថុអ្វីមួយដែលបានត្រូវកសាងឡើងទេសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា រួមទាំងអ្វីដែលសម្រាប់គាំទ្រដល់ឧស្សាហកម្ម ដែលមានរូបភាពជាសិប្បកម្មដែលមានអតីតភាពរួចហើយ ឬក៏ត្រូវកើតឡើង ដោយខ្លួនឯងនៅកម្ពុជា។

ការប្រព្រឹត្តទៅនៃប្រទេសបារាំង គឺមានភាពអវិជ្ជមានលើវិស័យសេដ្ឋកិច្ច។ ប៉ុន្តែអាណានិគមបានបំពាក់ឱ្យកម្ពុជានូវរោងចក្រ រចនាសម្ព័ន្ធផ្លូវគោក ផ្លូវដែក ការរៀបចំក្រុង ។ល។ បានសមស្រប និងមានការរៀបចំ ពង្រីកនូវក្រុមហ៊ុនចំការកៅស៊ូធំៗទៀតផង។ អាជ្ញាធរអាណានិគម ដឹកនាំដោយមនោគមវិជ្ជាដាច់ខាតសេរីនិយម មិនមានការដាក់ឱ្យអនុវត្តន៍នូវនយោបាយសេដ្ឋកិច្ចទេ ហើយបានទុកឱ្យទីផ្សារជាអ្នកធ្វើច្បាប់តែម្តង។

គេអាចនិយាយបានទៀតថា កម្ពុជា គឺជាប្រទេសដែលបារាំង "មិនយកចិត្តទុកដាក់" ដោយទុកឱ្យ កម្ពុជា ជាផលប្រយោជន៍នៃទឹកដីឥណ្ឌូចិនដទៃទៀត។ លោក ត្រាវែល បានសម្តែងនូវការតវ៉ាមួយ ដោយលោកសរសើរថា "កម្ពុជា មិនទាន់រក្សាបាននូវព្រះអាទិត្យនៃអាណានិគម និងពួកបារាំងនៅឡើយ នូវតួនាទីដែលបារាំងត្រូវផ្តល់នូវការលើកទឹកចិត្ត "..." ដែលថាធ្វើឱ្យប្រទេសនេះមានការអភិវឌ្ឍ ព្រោះជាប្រទេសសម្បូរទ្រព្យធនបំផុត ដោយគ្មានសង្ស័យនៅឥណ្ឌូចិន។ សូមជានាថា គ្មានអ្វីដែលខ្វះខាតទៀតទេនៅលើទឹកដីខ្មែរ ដែលល្បីល្បាញយូរមកហើយ ដើម្បីបញ្ឈប់នូវការចាត់ទុកទឹកដីនេះថាគ្រាន់តែជាខ្លាក់ដាក់ផេះបារី ចុងបូព៌ាបារាំងរបស់យើង" ។

លក្ខណៈសំខាន់នៃការវិវឌ្ឍនេះ គឺការកើនឡើងយ៉ាងនឹងន និងខ្លាំងក្លានៃផ្ទៃដីដាំដុះស្រូវជាសំខាន់ ដែលសម្របសម្រួលដល់ការចិញ្ចឹមប្រជាជន ដែលមានកំណើតឡើង ទោះបីទិន្នផលនៅនឹងថ្កល់ក៏ដោយ។ ប៉ុន្តែការធ្វើវិភាគដ៏ហ្មត់ចត់នៃសេដ្ឋកិច្ចកម្ពុជា ចាប់តាំងពីដើមសតវត្សបានបង្ហាញថានៅលើផ្នែករីកចម្រើននានានៃផលិតកម្ម កសិកម្ម ជាពិសេសស្រូវនោះមានលេចឡើង និងមានការអភិវឌ្ឍដំណាំម្រេច ផ្ទៃ ផលិតផលសូត្រ ឬកប្បាសដែរ។ នៅឆ្នាំ ១៩០០ មានរោងចក្រសំឡីកប្បាស ដែលផលិតបាន ៧,០០០ តោនក្នុងមួយឆ្នាំ ហើយនៅឆ្នាំ ១៩២២ ក្រុមហ៊ុនបារាំងដ៏ធំមួយបានធ្វើអាជីវកម្មដាំដុះមនរាប់ពាន់ហិចតា។ សហគ្រាសទាំងនោះ ក៏បាត់រូបតំណាក់កាលបន្ទាប់មក គឺជាពេលវេលាដែលគេបានស្គាល់កម្ពុជាបង្គួរដែរ គឺនៅក្នុងរយៈ

ពេលជិតកន្លះសតវត្សនៃអាណានិគមពីរជាន់ " បារាំង និងចិន " ។ សង្គ្រាមលោកលើកទី ២ បានបើកផ្លូវឱ្យកម្ពុជា ទៅរកឯករាជ្យ។ សេដ្ឋកិច្ចកម្ពុជាបានត្រូវរើបម្រះផ្តាច់ចេញពីក្របខ័ណ្ឌនៃវិធានការនានា នៅឥណ្ឌូចិន និងពីក្របខ័ណ្ឌសេដ្ឋកិច្ចនៃប្រព័ន្ធរបស់ចិន។

តើសម្តេចព្រះនរោត្តមសីហនុបានធ្វើអ្វីខ្លះ សម្រាប់ "ព្រះរាជបូជនីយកិច្ច" ដើម្បីឯករាជ្យដែលទទួលបាននៅឆ្នាំ ១៩៥៣ ដោយគ្មានការបង្ហូរឈាម?

ដើម្បីសិក្សាតំណាក់កាលនៃប្រវត្តិសាស្រសេដ្ឋកិច្ចកម្ពុជានេះ ហើយនិងបណ្តាឆ្នាំនៃរដ្ឋប្រហារប្រឆាំងសម្តេច ដែលទម្លាប់ប្រទេសទៅក្នុងភ្លើងសង្គ្រាម ព្រមទាំងនិយាយផងដែរនូវក្នុងដំណាក់កាលនៃការស្តារជាបន្ត បន្ទាប់រហូតមកដល់ការឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារនាដើមសតវត្សឆ្នាំ ១៩៩០ យើងត្រូវធ្វើកាជ្រើសរើស ដើម្បី ចាប់ផ្តើមសិក្សានូវទិដ្ឋភាព នយោបាយ វប្បធម៌ ជនជាតិ សាសនា ចាប់ពីឆ្នាំ ១៩៥០ មក ។

## ១.២.១. ស្ថានភាពសេដ្ឋកិច្ចសម័យហ្វូណន និងចេនឡា

### ក.ការស្វែងយល់អំពីឫសគល់សេដ្ឋកិច្ចមុនសម័យហ្វូណន

បើយើងងាកមើល អំពីបុរប្រវត្តិសាស្រ្តខ្មែរអោយបានឆ្ងាយបន្តិច ពេលគឺក្នុងសម័យកាលមុនគ.ស (មុនពេលកកើតរដ្ឋ ហ្វូណន) និងតាមរយៈលទ្ធផលកំណាយបុរាណវត្ថុនៅស្ថានីយ៍ ស្រាវជ្រាវ (ស្ថានីយ៍សំរោង សែន រន្លង់ផ្តៅ និងម្លូព្រៃ) គឺបានរកឃើញនូវវត្ថុតាងជាច្រើន ខ្លះជារបស់របរប្រើប្រាស់ធ្វើពីដែក ស្ពាន់ លង្ហិន ខ្លះទៀតធ្វើអំពីដីឥដ្ឋ ឬដុត ខ្លះទៀត ធ្វើពីឆ្អឹងសត្វ និងខ្លះទៀត ធ្វើពីថ្មរំលីង)។

ចំពោះប្រដាប់ប្រដាប្រើប្រាស់ធ្វើអំពីថ្មរំលីង គេឃើញមាន ផ្លែ ពូថៅគ្រប់យ៉ាង ពន្លាកញញួរ អន្លងដ៏សម្បកឈើ កាំបិត ថ្មសំលៀង អង្រែ ពុម្ពចាក់ករ ត្រល់ ខ្នោសកោសស្បែក កងដៃកងជើង អង្កា និងគ្រឿងអលង្ការផ្សេងៗទៀត។ រីឯប្រដាប់ប្រដាធ្វើអំពីឆ្អឹងសត្វ គេ ឃើញមានផ្លែព្រួញ ផ្លែសន្ទូច ម្ជុលដេរ កាំបិត កណ្តៀវ និងធ្វើគ្រឿងអលង្ការ ដែលមានខ្លះទៀតធ្វើអំពីសម្បកខ្យងដែរ។ ដោយឡែក ប្រដាប់ប្រដាធ្វើអំពីដីឥដ្ឋរួមមាន បំណែកឆ្នាំង ក្រឡ ចានគ្រប់ប្រភេទ គ្រឿងអលង្ការប្រកបដោយក្បូរក្បាច់រចនាល្អបវរ ក្នុងកម្រិតសិល្បៈទឹកដៃ យ៉ាងស្ទាត់ជំនាញទៀតផង។ វត្ថុប្រើប្រាស់ដែលធ្វើអំពីលោហៈធាតុវិញ គេឃើញមានផ្លែព្រួញ ផ្លែដឹង កណ្តៀវ ពន្លាក ជាដើម ដែលធ្វើឡើង ពីលោហៈធាតុដែក និងស្ពាន់។ ក្រៅពីបានរុករកឃើញនូវសំណល់ បុរាណវត្ថុទាំងអស់នេះ គេក៏បានប្រទះឃើញទៀតនូវ ឆ្អឹងសត្វត្រកួត ឆ្អឹងអណ្តើកកន្ធាយ ត្រី ជ្រូក គោ ឆ្កែ មាន់ និងឆ្អឹងសត្វចតុបាទផ្សេងៗ ជាច្រើនទៀត ។

សរុបសេចក្តីមក បើយើងពិនិត្យពិចារណាទៅលើកាកសំណល់ កំណាយបុរាណវត្ថុតាងទាំងអស់ ដែលពួកកុលសម្ព័ន្ធខ្មែរដើម បានផលិត និងបានប្រើប្រាស់នោះ យើងអាចធ្វើសេចក្តីសំយោគបានដូចខាងក្រោមនេះ៖

- ខ្មែរយើងនៅយុគថ្មរំលីង និងយុគលោហៈ មានការរីកលូតលាស់ខាងវិស័យសិប្បកម្មយ៉ាងទូលំទូលាយប្រកបដោយទេពកោសល្យ ច្នៃប្រឌិតខ្ពស់រួចស្រេចទៅហើយ។

- ចំពោះ វត្ថុតាងសម្រាប់ចាក់ពុម្ពផ្អែកល្មៅ អង្រែ (សម្រាប់បុកស្រូវ) ផ្លែសន្ទូច និងឆ្អឹងសត្វស្រុកគ្រប់ប្រភេទ បង្ហាញថា ខ្មែរយើងចេះធ្វើរបរកសិកម្មដាំដុះ ការចិញ្ចឹមសត្វ និងនេសាទ ដែលជាវិស័យសេដ្ឋ កិច្ចកសិកម្មដ៏សំខាន់បំផុត ក្នុងការផ្គត់ផ្គង់ស្បៀងអាហារ។
- រីឯ វត្ថុប្រើប្រាស់ដែលផលិតពីវត្ថុធាតុផ្សេងៗ ដូចជា ផ្លែព្រួញ កណ្តៀវ ផ្លែដឹង ពន្លាក បានស្តែងឡើងអោយឃើញនូវពន្លកនៃការចាប់ ផ្តើមក្នុងវិស័យឧស្សាហកម្មស្លលោហៈ។

លើសពីនេះទៀតបើយើងវិភាគទៅតាមគោលការណ៍និយមន័យ សេដ្ឋកិច្ច យើងឃើញថា ជីវភាពរស់នៅ និងទម្រង់ផលិតកម្មរបស់ខ្មែរ នាជំនាន់បុរេប្រវត្តិ ព្រមទាំងទំនាក់ទំនងដោះដូរ ក្នុងសង្គមកុលសម្ព័ន្ធ យើងអាចសន្និដ្ឋានបានថា នៅសម័យកាលនោះ គឺបានកើតមានឡើងនូវទម្រង់បឋម នៃសកម្មភាពសេដ្ឋកិច្ច សង្គម រួចស្រេចទៅហើយ។

## ខ.សេដ្ឋកិច្ចកម្ពុជាសម័យហ្វូណន

សេដ្ឋកិច្ចប្រទេសកម្ពុជាក្នុងសម័យហ្វូណន បានបន្តដំណើររបស់ខ្លួន តភ្ជាប់ពីជំនាន់បុរេប្រវត្តិសាស្ត្រ ដែលជាមូលដ្ឋានគ្រឹះនៃវិស័យសេដ្ឋកិច្ចដំបូងបង្អស់ ក្នុងនោះមានវិស័យកសិកម្ម សិប្បកម្ម និងសេវាកម្ម ដែលបានបន្តនិរន្តរភាព ចូលមកដល់សម័យកាលក្រោយៗទៀត។ ផ្អែកតាមឯកសារមួយចំនួន បានបង្ហាញអំពីការរីកលូតលាស់ គួរអោយកត់សម្គាល់ លើវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់ខ្មែរយើង ក្នុងសម័យហ្វូណន ដែលបានធ្វើអោយរដ្ឋនេះ ក្លាយទៅជាអាណាចក្រនគរភ្នំ ដែលជាមហាអំណាចមួយមានអនុភាពនយោបាយ កិត្យានុភាពល្បីល្បាញ និងឥទ្ធិពលយោធាដ៏ខ្លាំងក្លា គ្របដណ្តប់លើជ្រោយនៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។

- វិស័យកសិកម្ម

នៅសម័យហ្វូណន វិស័យកសិកម្មមានការរីកចម្រើនយ៉ាងខ្លាំងក្លា នេះបើតាមការបញ្ជាក់ពីឯកសារមួយចំនួន ព្រោះវិស័យនេះ បានផ្គត់ផ្គង់សេចក្តីត្រូវការស្បៀងអាហារសម្រាប់ប្រជាជនក្នុងស្រុក ហើយព្រមទាំងបាន បម្រើអោយការនាំចេញទៀតផង ជាពិសេសផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ គ្រឿងទេស និងសត្វព្រៃ។ភាពជោគជ័យលើវិស័យកសិកម្មនេះ បណ្តាលមកពីព្រះរាជានូវគ្រប់រជ្ជកាលនៃអាណាចក្រហ្វូណនបានយកចិត្តទុកដាក់ខ្ពស់លើការរៀបចំនយោបាយអភិវឌ្ឍន៍ សេដ្ឋកិច្ច កសិកម្មបានត្រឹមត្រូវជាពិសេសបានរៀបចំនយោបាយធារាសាស្ត្រ ពោលគឺការកសាងនូវទំនប់ទឹក ប្រឡាយជីកស្រះទឹក អាងស្តុកទឹកដើម្បីផ្គត់ផ្គង់ធនធានទឹកបម្រើអោយវិស័យកសិកម្មអោយបានគ្រប់គ្រាន់ និងគ្រប់រដូវកាល។

ចំពោះវិស័យសិប្បកម្ម នាសម័យហ្វូណន ក៏មានសន្ទុះលឿន លឿនខ្លាំងក្លាណាស់ដែរ។ ខ្មែរយើងជំនាន់នោះ ចេះធ្វើកិច្ចការជាច្រើន ដែលទាក់ទងនឹងវិស័យសិប្បកម្ម។ សិប្បករហ្វូណនអាចផលិតនូវផលិតផលប្រើប្រាស់ជាច្រើនប្រភេទដូចជា ចេះត្បាញរវៃអំបោះសូត្រ ត្បាញក្រណាត់ ចេះស្លរកែវយ៉ាងស្ទាត់ជំនាញ ឆ្លាក់គ្រឿងអលង្ការ ធ្វើពី លោហៈមានតម្លៃ ក្នុងនោះមានការធ្វើចិញ្ចៀន កងដៃ កងជើង ខ្សែដៃ ខ្សែកាន់ កងកាន់ អង្កាំ មានចានប្រាក់ ចានមាស ថាសប្រកបដោយ សិល្បៈក្បូរក្បាច់រចនាចម្លាក់ក្នុងទេពកោសល្យទឹកដៃដ៏ល្អ ប៉ិនប្រសព្វ ខ្ពស់ណា

ស់។ វត្ថុសិប្បកម្មរបស់សិប្បករខ្មែរសម័យហ្វូណន បាននាំ ចេញទៅបង្គួតនៅតាមទីផ្សារក្រៅប្រទេស នៃភូមិភាគអាស៊ីខាងត្បូង ជាពិសេស នាំចេញទៅប្រទេសចិន។ ក្រៅពីនេះទៀត គេឃើញមាន សិប្បកម្មធ្វើទូក សំពៅធំៗឆ្លងកាត់សមុទ្រ ធ្វើរទេះធ្វើគ្រឿងក្រអូប និងចេះសូនរូប និងធ្វើចម្លាក់ទេវរូបពីលោហៈធាតុសំរិត ពីថ្ម និងពីឈើ។

- វិស័យពាណិជ្ជកម្ម

គួរបញ្ជាក់ថា ព្រះរាជាណាចក្រហ្វូណន ជារដ្ឋមួយដែលមានសកម្មភាពពាណិជ្ជកម្មយ៉ាងខ្លាំងក្លា។ នៅសម័យនោះ ដោយសារតែការរៀបចំស្រុកទេសបានត្រឹមត្រូវ ធ្វើអោយវិស័យពាណិជ្ជកម្មជួញដូរទូទៅ ហាក់មានដំណើរការទៅមុខជាលំដាប់។ ម្យ៉ាងទៀត យើងមានកំពង់ផែអន្តរជាតិអូរកែវ ដែលបានបំពេញតួនាទីរបស់ខ្លួនប្រកបដោយភាពទាក់ទាញ ហេតុដូចនេះហើយទើបកំពង់ផែអន្តរជាតិមួយនេះ បានក្លាយទៅជាទីគាប់ចិត្ត និងទី ជំនួបប្រសព្វពាណិជ្ជកម្មអន្តរជាតិយ៉ាងសំខាន់ ពាណិជ្ជកម្មក្នុងស្រុក និងឈ្មួញបរទេស (ចម្រុះជាតិសាសន៍ យ៉ាងច្រើនកុះករ។ សកម្មភាពពាណិជ្ជកម្មទាំងអស់នេះ បញ្ជាក់អំពីការរីកលូតលាស់ផ្នែកផលិតកម្មក្នុងស្រុកសម្រាប់ការនាំចេញ និងបង្ហាញអំពីតម្រូវការប្រើប្រាស់របស់ប្រជាជនម្ចាស់ស្រុកចំពោះការនាំចូល ហើយក៏ឆ្លុះបញ្ចាំងអំពីការរីកលូតលាស់នូវ ទម្រង់មីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច ក្នុងបរិបថបើកចំហរទៀតផង។

- វិស័យគមនាគមន៍

យើងដឹងហើយថា វិស័យគមនាគមន៍ គឺជាវិស័យគន្លឹះ ព្រោះជាមធ្យោបាយសម្រាប់សម្របសម្រួលដល់ការដឹកជញ្ជូនផលិតផលទៅ កាន់ទីផ្សារគោលដៅ និងការធ្វើដំណើររបស់ប្រជាជនទៅគ្រប់ទិសទីទាំងអស់ ហើយការរីកលូតលាស់វិស័យពាណិជ្ជកម្ម ក៏ដូចជាវិស័យសេដ្ឋកិច្ច និងសង្គមផ្សេងៗទៀតទៅបានអាស្រ័យដោយមានការទ្រ ទ្រង់សម្របសម្រួលពីវិស័យគមនាគមន៍ដឹកជញ្ជូននេះឯង។

នៅសម័យអាណាចក្រហ្វូណន វិស័យគមនាគមន៍មិនទាន់មាន ការរីកចម្រើនខ្លាំងក្លាទេ ហើយប្រជាជនខ្មែរនិយមធ្វើដំណើរ និងដឹក ជញ្ជូនផលិតផលតាមផ្លូវគោក និងផ្លូវទឹក។ ហេតុដូចនេះហើយ ដើម្បីងាយស្រួលក្នុងការដឹកជញ្ជូនទំនិញទៅកាន់កំពង់ផែសមុទ្រ ឬដឹកជញ្ជូនទំនិញដែលនាំចូលពីក្រៅប្រទេសមកកាន់រាជធានី និងទីប្រជុំជន គេបានអោយប្រជារាស្ត្រ ជីកព្រែកខ្វាត់ខ្វែងប្រទាក់គ្នា តភ្ជាប់រហូតដល់កំពង់ផែសមុទ្រអន្តរជាតិអូរកែវ។

- វិស័យសំណង់

សំណងរាជធានី វ្យាធបុរៈ (បច្ចុប្បន្ននៅអង្គរបុរី ខេត្តតាកែវ) ក៏ ដូចជាសំណង់ ទីក្រុងដ៏ទៃទៀត ក្នុងព្រះរាជាណាចក្រហ្វូណនដែរ បានរៀបចំឡើងដោយមានកំពែងយ៉ាងរឹងមាំសម្រាប់ការពារខ្លួន និងមានជីក គួរទឹកព័ទ្ធជុំវិញ ព្រមទាំងមានចិញ្ចឹមសត្វក្រពើក្នុងនោះផង។ សំណង់ស្ថាបត្យកម្មនៃព្រះបរមរាជវាំងទាំងអស់ បានស្ថាបនាឡើង អំពីឈើដែល មានធ្វើជាប្រាសាទ ឬធ្វើជាដំណាក់ជាច្រើនជាន់។

នៅសម័យអាណាចក្រហ្វូណន គេឃើញមានផងដែរនូវសំណង់ បណ្ណាល័យជាតិធំៗ ដែលសម្បូរទៅដោយសៀវភៅ មានក្បួនតម្រាសាស្រ្តាគម្ពីរ និងកម្រងឯកសារសព្វបែបយ៉ាង តម្កល់ទុកនៅទីនោះ។ទាំងនេះបង្ហាញថាអ្នកគ្រប់គ្រងរបស់ខ្មែរយើងនៅសម័យនោះ បានយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំសិក្សាធិការ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ។

នៅក្រៅក្រុង ប្រជារាស្រ្តខ្មែរតែងតែប្រមូលផ្តុំគ្នារស់នៅ ដោយបង្កើតជាភូមិ ស្រុក ទីប្រជុំជនធំៗ ដែលមានផ្ទះពី ៥០ ទៅ ៦០ខ្នង និងមានជីកស្រះទឹកសម្រាប់ការប្រើប្រាស់រួមគ្នា។ សំណង់លំនៅដ្ឋានរបស់ពួកគេសង់ឡើងអំពីឈើ សង់លើជន្ទល់ខ្ពស់ពីដី និងមានប្រកស្លឹកចាក។

- វិស័យហិរញ្ញវត្ថុ

យោងតាមឯកសារប្រវត្តិរូបិយវត្ថុខ្មែរ បានបញ្ជាក់ថា រូបិយវត្ថុរបស់ខ្មែរយើងក្នុងសម័យកាលនោះមាន ៣ប្រភេទ ដែលបានបោះពុម្ពប្រើប្រាស់ក្នុងសតវត្សទី២ រហូតដល់ សតវត្សទី៦ រូបិយវត្ថុ ក្នុងសម័យកាលហ្វូណន។ តាមរយៈស្ថានីយ៍កំណាយបុរាណវត្ថុនៅឯ អង្គរបុរី ខេត្តតាកែវ និងនៅស្ថានីយ៍ អូរកែវ (ខេត្តក្រមួនសរ ទឹកដីកម្ពុជាក្រោម) គឺបានរកឃើញនូវវត្ថុតាងនៃរូបិយវត្ថុខ្មែរទាំងអស់នេះ។ រូបិយវត្ថុទាំង ៣ប្រភេទនោះ មានរូបិយវត្ថុ ខ្យងស័ង្ខ រូបិយវត្ថុ ព្រះអាទិត្យ និង រូបិយវត្ថុ រូបពស់ ដែលមានទំហំ វិជ្ជមាត្រ និងទម្ងន់ខុសៗគ្នា។ គេអាចប្រើប្រាស់រូបិយវត្ថុទាំងមូលតែម្តង ឬអាចយកទៅពុះជៀកជាជម្រៀកៗ សម្រាប់ការចរាចរលើទីផ្សារ ស្របទៅតាមតម្រូវការប្រើប្រាស់ និងសមាមាត្រនឹងតម្លៃទំនិញ ដែលត្រូវដោះដូរគ្នា។[24]

ក្រៅពីនេះ តាមរយៈឯកសារផ្សេងទៀត បានអះអាងថា នៅសម័យនោះ ក៏មានការប្រើប្រាស់នូវរូបិយប័ណ្ណបរទេសជាច្រើនប្រភេទជាពិសេស នៅតំបន់កំពង់ផែអន្តរជាតិអូរកែវ ដែលជាទីក្រុងបុរាណនៅ ជាប់មាត់សមុទ្រ ដែលរូបិយប័ណ្ណបរទេសទាំងនោះមានរូបិយប័ណ្ណ រ៉ូម៉ាំង ឥណ្ឌា និងចិន(អាយុកាលនៃរូបិយប័ណ្ណបរទេសទាំងនោះ ស្ថិតក្នុង គ.សទី១ មកម្ល៉េះ)។ ចំពោះកិច្ចការពន្ធដារវិញ ប្រជាជនហ្វូណនបានបង់ពន្ធជូនរាជការ ជារូបិយវត្ថុ ជាមាស ប្រាក់ ត្បូងមានតម្លៃ គុជ គ្រឿង ក្រអូប និងផ្សេងៗទៀត។

សរុបមក ពត៌មានជាមូលដ្ឋាន និងភស្តុតាងទាំងអស់នេះ អាចអោយយើងសន្និដ្ឋានបានថា នៅសម័យហ្វូណនមានការរីកលូតលាស់ ខាងវិស័យហិរញ្ញវត្ថុសាធារណៈមួយកម្រិតរួចទៅហើយ ព្រោះមានស្ថាប័នរដ្ឋដែលទទួលខុសត្រូវលើកិច្ចការទាំងអស់នេះ ពោលគឺមានប្រព័ន្ធធនាគារ ដែលជាស្ថាប័នគ្រប់គ្រងកិច្ចការនយោបាយរូបិយវត្ថុជាតិ និងមានបេឡាជាតិជាឃ្លាំងប្រាក់ (ឃ្លាំងព្រះរាជទ្រព្យ) ដែលមានតួនាទីក្នុងការរក្សាការពារ និងចាត់ចែងចំណូលចំណាយរដ្ឋ។

### គ.សេដ្ឋកិច្ចកម្ពុជាសម័យចេនឡា

- វិស័យកសិកម្ម

នៅសម័យចេនឡា ពុំបានរកឃើញឯកសារណាមួយដែលបាន បញ្ជាក់ច្បាស់លាស់ អំពីការរីកលូតលាស់នៃវិស័យកសិកម្មនោះឡើយ ប៉ុន្តែអ្វីដែលយើងអាចកំណត់បាននោះ យើងឃើញថា មានការទាក់ទង នឹងការបង្កើតទីក្រុង ឦសានបុរៈ (នៅក្បែរស្ទឹងសែន) និងការឡើងគ្រងរាជ្យសម្បត្តិរបស់ព្រះអង្គម្ចាស់បុស្សរៈ នៅឯសម្ភុបុរៈ ដោយតាំងអំណាច ជាអាណាចក្រចេនឡាទឹកលិច (រដ្ឋចេនឡាទឹកលិច) ដែលបច្ចុប្បន្នស្ថិតនៅស្រុកសម្បូរ ខាងលើក្រុងក្រចេះ។

ហេតុការណ៍ខាងលើនេះ តិចឬច្រើនមានការទាក់ទងទៅនឹងការ សិក្សាច្បាស់លាស់អំពីនយោបាយទឹក ព្រោះស្ទឹងសែន អាចបង្ហូរចូលក្នុងស្រះ ឬប្រឡាយព័ទ្ធជុំវិញទីក្រុង ឬក្នុងអាងស្តុកទឹកឯទៀតៗ ដែលធ្វើអោយមានទឹកគ្រប់គ្រាន់បម្រើអោយវិស័យកសិកម្មដាំដុះ។ ចំពោះការកំណត់យកទីក្រុងសម្ភុបុរៈ សម្រាប់ជារាជធានីនៃរដ្ឋចេនឡាទឹកលិច ប្រហែលជានៅតំបន់នោះជាតំបន់មានបឹង ទន្លេលាតសន្ធឹងលើអាងទន្លេ មេគង្គ ពីល្បាក់ខោន រហូតមកដល់សមុទ្រ។ ដោយឡែកនៅរាជធានី វ្យាធបុរៈវិញ ដំណើរការវិស័យកសិកម្ម បានបន្តសកម្មភាពដូចធម្មតាប្រកបដោយភាពជោគជ័យ តាំងពីសម័យអាណាចក្រហ្វូណនមកម្ល៉េះ។ ដូច្នេះបើពិនិត្យលើហេតុផលជាមូលដ្ឋានខាងលើនេះ យើងអាចសន្និដ្ឋានថា វិស័យកសិកម្មនៅសម័យចេនឡា មានការរីកលូតលាស់ជាប្រក្រតី។

- វិស័យសិប្បកម្ម

វិស័យសិប្បកម្មបានរស់រានជាមួយនឹងជីវភាពរស់នៅរបស់ខ្មែរយើងតាំងពីសម័យយូរលង់ណាស់មកហើយ ហេតុនេះយើងមិនមានមន្ទិលណាមួយអំពីការលូតលាស់របស់វិស័យនេះទេ។

យោងតាមឯកសារខ្លះក៏បានបញ្ជាក់បន្ថែមអំពីស្ថានភាពរបស់វិស័យសិប្បកម្មនេះដែរពោលគឺ នៅសម័យចេនឡា សិប្បកម្មផលិតកម្មពីវត្ថុធាតុដើមនានា ត្រូវបានសិប្បករខ្មែរចេនឡាបន្តកិច្ចការរបស់ខ្លួនជាធម្មតា។ ក្នុងនោះយើងឃើញមាន របស់របរដែលធ្វើអំពីវត្ថុធាតុដើមដីមានដូចជា ភាជន៍ ចាន ឆ្នាំង ក្អម កោដ្ឋ (ធ្វើពីដីដុត) ឥដ្ឋ ផលិតបាយអរ (ដែលផ្សំពីកំបោរលាយជាមួយស្ករ សម្រាប់សំណង់ផ្ទះ និងប្រាសាទ) និងរបស់របរប្រើប្រាស់ផ្សេងៗទៀត។ ម្យ៉ាងទៀត ដូចគ្នាដែរនឹងសម័យ ហ្វូណន ប្រជារាស្ត្រចេនឡា គឺជាជាងទងប្រកបដោយទេពកោសល្យ ស្ទាត់ជំនាញ ក្នុងការធ្វើគ្រឿងអលង្ការពីលោហៈធាតុផ្សេងៗ ដូចជា ការ ធ្វើចិញ្ចៀនក្រយ៉ា កងដៃ ក្រវិលមាស ក្រវិលប្រាក់ ពីស្ពាន់ និងសំណ និងចេះស្លៀកែវធ្វើជាកងដៃ ធ្វើអង្កាំពាក់នៅកដៃ និងក ដែលជាគ្រឿង លម្អ។

ក្រៅពីនេះសិប្បកម្មតម្បាញសូត្រ ក្រណាត់សំពត់ ការសូនរូប សិប្បកម្មចម្លាក់ពីលោហៈពីថ្ម និងឈើ ចេះធ្វើទូកធ្វើរទេះ និងធ្វើ សំពៅតូច ធំ បម្រើអោយវិស័យពាណិជ្ជកម្ម និងចម្បាំងទៀតផង។

- វិស័យគមនាគមន៍

ដូចដែលយើងបានដឹងរួចមកហើយថា វិស័យគមនាគមន៍ គឺជាវិស័យមួយដ៏សំខាន់ក្នុងការធ្វើទំនាក់ទំនង សម្របសម្រួលគ្រប់ចលនា សង្គម សេដ្ឋកិច្ច និងនយោបាយ។ មានឯកសារ

ខ្លះ ក៏បានលើកឡើង អំពីស្ថានភាពនេះដែរក្នុងសម័យចេនឡា ដោយគ្រាន់តែបានបញ្ជាក់ថា វិស័យគមនាគមន៍ក្នុងសម័យកាលនោះ មាន២ប្រភេទ គឺ គមនាគមន៍ ផ្លូវគោក និងផ្លូវទឹក ហើយប្រជាជនបានប្រើប្រាស់សត្វដំរី គោ សេះ និងប្រើស្នែងរទេះ សម្រាប់ធ្វើជាមធ្យោបាយដឹកជញ្ជូនផ្លូវគោក និងប្រើប្រាស់ ទូក សំពៅ សម្រាប់ធ្វើគមនាគមន៍តាមផ្លូវទឹក និងមានកំពង់ផែ ជាចំណត និងជាទីប្រសព្វសំខាន់ៗ។

- វិស័យហិរញ្ញវត្ថុ

នៅសម័យចេនឡា គេបានរកឃើញរូបិយប័ណ្ណបរទេសជាច្រើន ដែលមានប្រភពមកពីបណ្ដាទ្វីបផ្សេងៗគ្នា ដូចជា រូបិយប័ណ្ណឥណ្ឌា រូម៉ាំង ក្រិច និងចិន ដែលធ្លាប់បានចូលមកធ្វើទំនាក់ទំនងពាណិជ្ជកម្ម នៅកំពង់ផែអន្តរជាតិអូរកែវ ឬមានទំនាក់ទំនងនយោបាយការទូត នៅអង្គបុរី នៅ សុផានបុរី នៅ កញ្ចនៈបុរី (ប្រទេសថៃបច្ចុប្បន្ន)។

ម៉្យាងទៀត រាជរដ្ឋាភិបាលនាសម័យអាណាចក្រចេនឡា ដែលមានប្រពៃណីគ្រប់គ្រងប្រទេសតាមលទ្ធិរាជាធិបតេយ្យឥណ្ឌា ក៏បានបន្តរៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈដូចសម័យហ្វូណននោះដែរ។ តាមឯកសារខ្លះ លើកឡើងថា ប្រភពចំណូលរបស់រដ្ឋបានមកពីការបង់ពន្ធរបស់ប្រជារាស្ត្រ ប្រាក់កាក់ ជាមាស ជារបស់របរមានតម្លៃ និងជាគ្រឿងក្រអូប ដែលអាចលក់ប្ដូរយកសាច់ប្រាក់ ឬទុកសម្រាប់ការប្រើប្រាស់របស់រដ្ឋ។

## ១.២.២. ទស្សនៈទាន នៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអង្គរ

យើងពិនិត្យឃើញថា ព្រះរាជារបស់ខ្មែរយើងបានជ្រើសរើស យកទីតាំងភូមិសាស្ត្រតំបន់អង្គរ ដើម្បីតាំងរាជធានី មិនមែនប្រព្រឹត្តទៅ ដោយចៃដន្យនោះទេ ពីព្រោះថា តំបន់នេះស្ថិតនៅចំកណ្ដាលនៃព្រះរាជាណាចក្រ។ ម្យ៉ាងទៀត តំបន់នេះ ជាទីប្រជុំជននៃផ្លូវជំនួញ ទាំងផ្លូវ គោក និងផ្លូវទឹក ហើយសម្បូរទៅដោយធនធានធម្មជាតិគ្រប់បែបយ៉ាង ដូចជា មច្ឆាជាតិ (នៅតំបន់បឹងទន្លេសាប) ម្រឹគីម្រឹគា និងនៅក្នុងព្រៃ មាន ប្រភេទឈើល្អៗ។ ក្រៅពីនោះ តំបន់នេះមានថ្មភក់សម្រាប់ជាវត្ថុធាតុដើម ក្នុងការសង់ប្រាសាទនៅលើភ្នំគូលែន។ល។ ឯវាលទំនាបជុំវិញតំបន់នោះសុទ្ធសឹងជាវាលទំនាបដែលពោរពេញទៅដោយជីជាតិ សម្រាប់ប្រកបរបរដំណាំកសិកម្មសព្វសារពើ។[35]

ស្ថានភាពភូមិសាស្ត្រដ៏ប្រពៃនេះ រួមផ្សំជាមួយនឹងបច្ចេកទេសផលិតកម្មដ៏ចំណាន និងធនធានមនុស្សដែលឧស្សាហ៍ព្យាយាម ចេះ តស៊ូស្វិតស្វាញក្នុងការងារ បានធ្វើអោយវិស័យកសិកម្មខ្មែរនៅសម័យ កាលនោះមានការរីកចម្រើនជាអតិបរមា។

ម្យ៉ាងទៀត នៅប្រទេសកម្ពុជាយើងនាសម័យកាលនោះ ការអភិវឌ្ឍសេដ្ឋកិច្ច ពឹងផ្អែកលើវិស័យកសិកម្ម ហើយវិស័យកសិកម្មតែង តែពឹងផ្អែកទៅលើមេឃ ឬប្រវាស់នឹងមេឃ។ បើខ្យល់រដូវមានការប្រែប្រួល ភ្លៀងធ្លាក់ច្រើនខែ ធ្វើអោយវិស័យកសិកម្មអាចទទួលរងគ្រោះខូចខាតដោយសារតែទឹកជំនន់។ ម្យ៉ាងទៀត មានឆ្នាំខ្លះភ្លៀងធ្លាក់តិចពេក ធ្វើអោយដំណាំស្រូវផ្ដល់ផលមិនគ្រប់គ្រាន់ សម្រាប់បំពេញសេចក្ដីត្រូវ ការក្នុងស្រុក។ ដូច្នេះហើយ ទើបនៅសម័យអង្គរ

គាំទ្រដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ (ស.គ.ន) នៃក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាមានបំណង ចង់គ្រប់គ្រងទៅលើការប្រែប្រួលវិស័យជលសាស្ត្រ ដែលតែងតែមាន ភាពមិនទៀងទាត់ តាមរយៈការស្ថាបនានៅជុំវិញរាជធានីអង្គរ នូវបឹងធំៗដែលហៅថា បារាយណ៍ សម្រាប់សន្សំទឹកភ្លៀងនូវរដូវវស្សា គួបផ្សំជាមួយ ទឹកស្ទឹងសៀមរាប ដែលហូរចុះពីលើភ្នំគូលែន។ លុះផុតរដូវវស្សា គេអាចចែកចាយទឹកបារាយណ៍ទាំងនោះ តាមប្រឡាយនានាបង្ហូរចូលទៅក្នុងស្រែ។ តាមរយៈមធ្យោបាយនេះ នាំអោយគេអាចធ្វើស្រែបានពីរដង បន្តបន្ទាប់គ្នា ហើយនៅរដូវប្រាំង គេអាចធ្វើដំណាំស្រូវម្តងទៀតនៅបាតបារាយណ៍ដែលទីនោះមានដីល្បាប់ដ៏មានជីជាតិ ហើយនឹងមានសភាពសើមស្រាប់។

ការស្ថាបនាបារាយណ៍ជំនាន់នោះគឺជាសមិទ្ធិមួយធំសម្បើមណាស់។ បើយើងគ្រាន់តែលើកយកបារាយណ៍បីសំខាន់ៗមកពិភាក្សា យើងឃើញថា គួរឲ្យស្ងើចសរសើរពន់ពេកណាស់ ដូចជាបារាយណ៍ លលៃ មានបណ្តោយប្រវែង ៣ គ.ម និងទទឹង ០,៨ គ.ម អាចផ្ទុកទឹក បានរហូតដល់ ៦.០០០.០០០ ម៣ រីឯបារាយណ៍ខាងកើត មានបណ្តោយ ប្រវែង ៧ គ.ម និងទទឹងប្រវែង ១,៨ គ.ម អាចផ្ទុកទឹកបានប្រមាណជាង ៣០.០០០.០០០ម៣ ចំណែកឯបារាយណ៍ខាងលិចមានបណ្តោយប្រវែង ៨គ.ម និងទទឹងមានប្រវែង ២,២ គ.ម អាចផ្ទុកទឹកមិនតិចជាង ៤០.០០០.០០០ម៣ នេះយើងមិនទាន់រាប់បណ្តាញជលគតិជាច្រើនទៀត ដែលគេស្ថាបនារបៀបគ្នានេះ នៅតាមបណ្តាខេត្តទាំងឡាយទៀតផង។

ហេតុដូចនេះហើយ ទើបលោក B.Groslier បានពោលថា នៅសម័យនោះ ធនធានទឹកនៅតំបន់អង្គរមិនជាខ្វះទេ តែចំណោទបញ្ហា ស្ថិតនៅត្រង់ថា តើធ្វើយ៉ាងណាដើម្បីចែកចាយទឹកអោយបានទៅដល់ គ្រប់ទីកន្លែង។ លោកបានបន្ថែមទៀតថា ដោយខ្មែរមានដូនតាជាអ្នកជំនាញខាងនយោបាយទឹក គេក៏បានបន្តនយោបាយទឹកនេះតទៅទៀត ដោយបានបោះជំហានយ៉ាងវែងក្នុងវិស័យនេះ បានសេចក្តីថា គេបានផ្លាស់ប្តូរបច្ចេកទេសបញ្ចេញទឹកពីស្រែ ទៅជាការបញ្ចូលទឹកទៅក្នុងស្រែវិញ។ ឯនយោបាយសន្សំទឹក ដើម្បីបង្ហូរទៅក្នុងស្រែនៅពេលដែលគេត្រូវការ ត្រូវបានរៀបចំយ៉ាងម៉ត់ចត់ តាំងពីសម័យកាល ព្រះបាទឥន្ទ្រវរ្ម័នទី១ ដោយព្រះអង្គបានយកព្រះទ័យទុកដាក់នឹងវិស័យកសិកម្ម ដែលជាធម្មតាពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង និងខ្យល់រដូវ។ ការកើនឡើងនូវចំនួនប្រជាពលរដ្ឋ តម្រូវអោយគេធ្វើការប្រឹងប្រែងបង្កើនផលិត ផលកសិកម្មបន្ថែមទៀត យ៉ាងណាមិញ ព្រះបាទឥន្ទ្រវរ្ម័នទី១ បានរៀបចំនយោបាយទឹក តាមរបៀបដែលប្រទេសចេនឡា ធ្លាប់មានរួចមកហើយ ពោលគឺ ទប់ទឹកបង្ខាំងទុកនៅក្នុងទំនប់ធំៗ រួចដឹកប្រឡាយបង្ហូរ ទឹកនោះ បញ្ចូលទៅក្នុងស្រែផង ហើយបញ្ចូលទៅក្នុងស្រះធំៗ និងប្រឡាយផ្សេងៗទៀតនៅក្នុងទីក្រុងផង ក្នុងទិសដៅ ទុកប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

នយោបាយទឹករបៀបនេះ ត្រូវបានព្រះរាជានៅជំនាន់ក្រោយៗ ជាពិសេស នៅសម័យអង្គរតែម្តង ដែលគេបានអនុវត្តជាបន្តទៀតយ៉ាង ម៉ត់ហ្មត់ជាហេតុនាំអោយកើតមានភាពសម្បូរសប្បាយដល់ប្រទេស ជាតិអស់រយៈកាលជាច្រើនសតវត្ស។ យើងគួរធ្វើការសិក្សាអំពីនយោបាយទឹក និងការរីកចម្រើននៃសេដ្ឋកិច្ចខ្មែរនៅសម័យអង្គរអោយបាន ពិស្តារបន្ថែមទៀត

ព្រោះវាជាមូលដ្ឋានមួយដ៏សម្ខាន់ ដែលញ៉ាំងអោយ អរិយធម៌ខ្មែរជំនាន់នោះមានការរីកលូតលាស់រុងរឿងដល់កំពូល។

ក្រៅពីនេះទៀត មានអ្នកប្រាជ្ញជាច្រើនបានធ្វើការត្រិះរិះពិចារ អោយណាអំពីឥទ្ធិពលនៃមជ្ឈដ្ឋានរូបវន្តទៅលើកំណើននៃអរិយធម៌ខ្មែរ ដូចជាលោក P.Gourou បានសរសេរថា កត្តាភូមិសាស្ត្រ និងនយោបាយទឹក ប្រាកដជាមានសារៈសំខាន់ណាស់ក្នុងការញ៉ាំងអោយអរិយធម៌នៃប្រទេសមួយ មានការរីកចម្រើនរុងរឿង ក៏ប៉ុន្តែជួនកាលគេអាចជួបប្រទះនូវបញ្ហាចំឡែកមួយទៅវិញ ពេលគឺដោយសារតែស្ថានភាពទឹកដីអំណោយផល អាចធ្វើអោយមនុស្សទៅវាខ្ជិលច្រអូសមិនចេះប្រឹងប្រែង ប្រយុទ្ធជាមួយនឹងធម្មជាតិ ព្រោះគេអាចរស់នៅបានស្រួលដោយមិនចាំ បាច់វល់ខ្វាយខ្វល់ច្រើននោះឡើយ។ ហេតុនេះតើមានអ្វីទៀតជាគ្រឿងផ្សំដែលជំរុញអោយគេ ធ្វើដំណើរឆ្ពោះទៅរកវឌ្ឍនភាព។ ត្រង់ចំណុចនេះយើងមានការពិភាក្សាថា តើត្រូវការកត្តាផ្សេងៗអ្វីទៀត ដែលជាមូលដ្ឋានទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច នាយុគសម័យអង្គរ។

ក្នុងចំណុចនេះ ប្រសិនបើយើងលើកយកកត្តាមរត៌កវប្បធម៌ពីអតីតកាលមកពិចារណាពេលគឺ កត្តាមរត៌កជាទេពកោល្យ និងសមិទ្ធិ ផល ដែលខ្មែរក្នុងយុគសម័យមុនៗបានបន្សល់ទុក នោះយើងអាចយល់ បានបន្ថែមទៀតអំពីមូលហេតុនៃការរីកចម្រើនរបស់អរិយធម៌អង្គរ។ ខាងក្រោមនេះ គឺជាមរត៌កវប្បធម៌ ក្នុងសម័យហ្វូណន និងចេនឡា។

- កត្តាមនុស្ស និងមរត៌កពីអតីតកាលជុំវិញវិស័យសេដ្ឋកិច្ច

គេដឹងថាខ្មែរនៅសម័យអង្គរជាជនជាតិឧស្សាហ៍ ហើយបំណងធំបំផុតគឺការធ្វើអោយរីកចម្រើនលូតលាស់លើគ្រប់វិស័យ និងភាពសម្បូរសប្បាយរុងរឿងរបស់ប្រទេសជាតិ។ ជាភស្តុតាងនៃវត្ថុបំណងនេះ ព្រះរាជានៅសម័យអង្គរ បានបញ្ជាអោយវិចិត្រករអង្គរឆ្លាក់ក្បាច់ រឿងកូរសមុទ្រទឹកដោះនៅលើប្រាសាទជាច្រើន និងនៅគ្រប់ច្រកទ្វារ ចូលនៃបូរីអង្គរធំជាដើម ព្រោះទឹកអម្រឹតដែលហូរចេញពីការកូរសមុទ្រ ទឹកដោះនេះ គឺជានិមិត្តរូបនៃថាមពលខាងការងារ និងការប្រណាំង ប្រជែងបង្កើតផលិតផលយ៉ាងជាក់ច្បាស់។ ម្យ៉ាងទៀតការសិក្សាតាម ផ្លូវចិត្តវិទ្យា អំពីសិល្បៈខ្មែរបុរាណ បានផ្តល់ព័ត៌មានជាច្រើនទៀត ស្តីពីការតស៊ូ ចិត្តអំណត់ និងសេចក្តីប្រាថ្នាយ៉ាងមុតមាំរបស់ខ្មែរជំនាន់នោះ ចំពោះអ្វីដែលខ្លួនចាត់ថា ល្អប្រសើរ។

ប៉ុន្តែបើយើងពិនិត្យឲ្យបានជិតដល់ យើងឃើញថាការប៉ងប្រាថ្នា អោយមានការរីកលូតលាស់នេះ មានតាំងពីសម័យមុនៗមកម៉្លេះ ពេលគឺ តាំងពីសម័យហ្វូណន និងសម័យចេនឡា។ ប្រវត្តិវិទូជាច្រើនយល់ថា ពេលដែលខ្មែរមកតាំងរាជធានីនៅអង្គរ ខ្មែរមានអរិយធម៌ខ្ពង់ខ្ពស់ មួយរួចទៅហើយ ជាងនេះទៀតអរិយធម៌នេះគ្រាន់តែធ្វើអោយលូត លាស់ថែមទៀត នៅសម័យអង្គរតែប៉ុណ្ណោះ។ យើងនឹងធ្វើការបង្ហាញនូវលក្ខណៈសម្បត្តិទាំងឡាយដែលជាមរត៌កពីអតីតកាលដោយត្រួសៗ ដូចតទៅ ៖

- នៅសម័យហ្វូណន អ្នកស្រុកចេះប្រកបការងារជំនាញ ៖
    - ពូកែរកស៊ីលក់ដូរ ជាពិសេស ធ្វើជំនួញតាមផ្លូវសមុទ្រ

- ជាសិប្បករយ៉ាងចំណាន ចេះឆ្លាក់ឈើ ត្បាញសូត្រ និង ផលិតប្រដាប់ប្រដាផ្សេងៗយ៉ាងស្ទាត់ជំនាញ
- ជាជាងចម្លាក់ និងជាងសំណង់រាជវាំង ប្រាសាទ
- ជាអ្នកជំនាញខាងនយោបាយទឹកផ្នែកជីសណ្តូរ

• នៅសម័យចេនឡា ខ្មែរមានជីវភាពរស់នៅផ្សេងពីមុនបន្តិចហើយខ្មែជំនាន់នោះ ៖
- ជាសិប្បករយ៉ាងស្ទាត់ជំនាញ។
- ជាជាងសំណង់យ៉ាងប៉ិនប្រសព្វបង្គួរទៅហើយ
- ជាអ្នកបន្តវេននយោបាយទឹកពីសម័យហ្វូណន ប៉ុន្តែតាមបែបទំនើបថ្មីមួយពោលគឺគេលើកទំនប់ យាំងទឹកទុកប្រើប្រាស់នៅរដូវរាំងស្ងួត
- ជាអ្នកជំនាញខាងចម្បាំង និងពង្រីកទឹកដី។

ដូច្នេះមរត៌កវប្បធម៌ ដែលខ្មែរហ្វូណន និងចេនឡាបានបន្សល់ ទុកអោយខ្មែរសម័យអង្គរគឺមានតម្លៃពន់ពេកណាស់ នេះពុំទាន់និយាយ ពីមរត៌ក ជាប្រពៃណីផ្នែកវប្បធម៌ទេ។ ទេពកោសល្យរបស់មនុស្សខ្មែរ បានធ្វើអោយអ្វីៗដែលមានកាលពីមុនមក អោយកាន់តែរីកលូតលាស់ និងកាន់តែប្រសើរឡើងជាលំដាប់ ដែលនៅក្នុងលោកយើងនេះសឹងរក អរិយធម៌ណា មកប្រៀបផ្ទឹមអោយស្មើពុំបានឡើយ។

➢ **សេចក្តីសន្និដ្ឋាន**

សរុបមក ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នាយុគសម័យអង្គរ មានខ្លឹមសារដូចខាងក្រោមនេះ ៖

• ព្រះរាជា បានកំណត់យកទីតាំងភូមិសាស្ត្រតំបន់អង្គរ មកតាំង ជារាជធានី ក៏ព្រោះតែតំបន់នេះ មានជ័យភូមិល្អ ម្យ៉ាងទៀតគឺជាតំបន់ ដែលសម្បូរទៅដោយសម្បត្តិធនធានធម្មជាតិគ្រប់ប្រភេទ ដែលជួយទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
• ការបន្តការអភិវឌ្ឍនយោបាយធារាសាស្ត្រ គឺជាមធ្យោបាយមួយ ដ៏សំខាន់បំផុត ក្នុងការអភិវឌ្ឍ
វិស័យសេដ្ឋកិច្ចកសិកម្មផលិតកម្ម។
• ការប្រើប្រាស់ទេពកោសល្យ ដែលជាកេរ្តិ៍មរតក៌វប្បធម៌របស់ប្រជារាស្ត្រខ្មែរដែលមានស្រាប់តាំងពីសម័យកាលមុនៗ បានជួយធ្វើអោយវិស័យសេដ្ឋកិច្ចផលិតកម្មគ្រប់ប្រភេទបន្តការរីកលូតលាស់ទៅ មុខឥតឈប់ឈរ។
• ការប្រកាន់យករបបរាជានិយមបែបលទ្ធិទេវរាជ និង សាសនា ដែលធ្វើអោយប្រជារាស្ត្រមានការជឿជាក់ និងគោរពប្រតិបត្តិតាមបញ្ជា របស់ព្រះមហាក្សត្រ (ជាអាទិទេព) ចូលរួមក្នុងកិច្ចការសាធារណៈ និង កិច្ចការ អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

សរុបសេចក្តីមក ដោយមានការគ្រប់គ្រងគោលនយោបាយ សេដ្ឋកិច្ចបានត្រឹមត្រូវ តាមរយៈការសំយោគបញ្ចូលគ្នានូវទីតាំងភូមិសាស្ត្រដែលមានលក្ខណៈអំណោយផល មានសម្បត្តិធម្មជាតិគ្រប់គ្រាន់ មានគោលនយោបាយធារាសាស្ត្រល្អ មានមរត៌ក និងទេពកោសល្យដ៏ ល្អប្រពៃ

រួមផ្សំជាមួយនឹងការប្រកាន់យកលទ្ធិទេវរាជដ៏មានប្រសិទ្ធិភាព (សម្រាប់យុគសម័យកាលនោះ) ដែលទាំងអស់នេះ គឺជាគោលគំនិត និងជាមូលដ្ឋានគ្រឹះនៃទស្សនៈអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ព្រមទាំងអរិយធម៌អង្គរយ៉ាងពិតប្រាកដ។

## ១.២.៣.ទស្សនៈខាងនៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអាណានិគមបារាំង

ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រដ្ឋការបារាំងមានគោលបំណងបង្កើតសិទ្ធិឯកជនលើដីធ្លី ស្រែចំការតាមបែបមូលធននិយម។ ស្របតាមកិច្ចព្រមព្រៀងចុះថ្ងៃទី ១៧ មិថុនា ១៨៨៤ និង ស្របទៅតាមក្រមមួយចំនួនរបស់ព្រះមហាក្សត្រនរោត្តម និងសារាចរនានារបស់ទេសាភិបាល ជាន់ខ្ពស់រដ្ឋការអាណានិគមបារាំងបានអនុវត្តច្បាប់នៃការផ្តល់កម្មសិទ្ធឯកជនលើដីធ្លី។ នៅក្នុង កិច្ចព្រមព្រៀងខាងលើនេះបានចែងថា "ចាប់ពីពេលនេះតទៅ ដីទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ដែលពីមុនជាកម្មសិទ្ធិផ្ទាល់របស់រាជបល្ល័ង្ក ឈប់ទៅជាដីដែលគេមិនអាចទិញបាន ទៀតឡើយ"។ នៅក្នុងរាជក្រឹត្យព្រះបាទនរោត្តម ចុះថ្ងៃ ទី ១១ កក្កដា ១៨៩៧ មានសេចក្តីបញ្ជាក់ថា "រាជរដ្ឋាភិបាលរក្សាទុកនូវសិទ្ធិក្នុងការបែងចែកដីទំនេរទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា ហើយម្ចាស់កម្មសិទ្ធិដីសម្បទាន អាចប្រើប្រាស់ពេញច្បាប់របស់ខ្លួន ក្នុងការរក្សាកម្មសិទ្ធិឯកជនចំពោះវើទិញ ឬក៏ផ្តល់ជាសម្បទាន" មាត្រា ១២។ នៅក្នុងសារាចរចុះថ្ងៃទី ២៩ ធ្នូ ១៨៩៧ ស្ថានភាពច្បាប់បានត្រូវ កំណត់ច្បាស់លាស់ដោយមានសេចក្តីបញ្ជាក់ថា "រាជរដ្ឋាភិបាលរក្សា នូវសិទ្ធិរបស់ខ្លួនក្នុងការលក់ ឬបែងចែកដីទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធ្វើអោយដីទាំងនោះ ទៅជាកម្មសិទ្ធិឯកជនរបស់ម្ចាស់ដី ធានារ៉ាប់រងដល់ស្ថេរភាពនៃកម្មសិទ្ធិលើដីទាំងនោះ ហើយព្រមទាំងបង្កបង្កើតល័ក្ខខ័ណ្ឌដ៏ប្រសើរក្នុងការប្រើប្រាស់ដីអោយ មានទំហំច្រើនជាអតិបរមា ក្នុងការធ្វើដំណាំស្រូវ ដែលអាចបង្កើត ទ្រព្យសម្បត្តិរបស់ម្ចាស់ដីព្រោះថា នៅក្នុងប្រទេសកម្ពុជាមានសល់ដី ទំនេរ និងមិនទាន់ត្រសត្រាយមានទំហំធំផង" ។

ដើម្បីដំណើរការឡើងនូវក្រឹត្យច្បាប់ខាងលើអោយមានប្រសិទ្ធ ភាពនៅថ្ងៃទី២៥ មេសា ១៩០២ មានការចុះផ្សាយរាជក្រឹត្យរបស់ព្រះមហាក្សត្រនរោត្តម ដែលនៅក្នុងនោះមានសេចក្តីបង្គាប់ដល់ភូមិទាំង អស់អោយចុះបញ្ជីដីធ្លី និងម្ចាស់ដីត្រូវបញ្ជាក់អំពីទំហំដីច្បាស់លាស់។

និន្នាការបែបនេះ ទាក់ទងនឹងការបង្កើតក្រសួងសុរិយោដី ការរៀបចំគម្រោងកសិដ្ឋានតាមបែបអឺរ៉ុប និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចក្នុងការផ្តល់ដីសម្បទាន ដល់ក្រុមហ៊ុនទាំងឡាយដោយរដ្ឋការអាណានិគមបារាំង។

ពួកអាណានិគមបារាំង បានខិតខំបង្កើតក្រសួងសុរិយោដីនៅក្នុងប្រទេស ដើម្បីដំណើរការចុះបញ្ជីដីធ្លី។ ការចុះបញ្ជីដោយក្រសួង សុរិយោដី បានប្រព្រឹត្តទៅនៅឆ្នាំ ១៩០៦ ម្តង ឆ្នាំ ១៩១៨ ម្តង និង នៅ សម័យឆ្នាំ ១៩៣០-១៩៤៥ ម្តងទៀត។ បើនិយាយអោយខ្លីទៅ ការចុះបញ្ជីដីធ្លីបានប្រព្រឹត្តទៅនៅក្នុងសម័យកាលនៃរបបអាណានិគមនិយមទាំងមូល។ ម្ចាស់ដីដែលអាចក្លាយទៅជា

អ្នកមានកម្មសិទ្ធិដីធ្លី លុះត្រាតែដីរបស់ខ្លួន ត្រូវបានចុះបញ្ជីត្រឹមត្រូវដោយក្រសួងសុរិយោដីដោយមានលិខិតបញ្ជាក់ថា មានការបង់ពន្ធ និងចុះបញ្ជីត្រឹមត្រូវ ។

ដោយយោងតាមច្បាប់ស្តីពីការកាន់កាប់ដីធ្លីដែលបានអនុម័តរួចមក រដ្ឋការអាណានិគមបានបែងចែកដីឡូត៍ធំៗ ដល់ពលរដ្ឋបារាំងជាពិសេសដល់ក្រុមហ៊ុនផ្តាច់មុខសម្រាប់ការដាំដំណាំកសិកម្មស្រូវ ពោត កាហ្វេ ម្រេច កៅស៊ូ និងសម្រាប់ការចិញ្ចឹមសត្វ។ ដីឡូត៍ធំៗ ជាច្រើនបានត្រូវបែងចែកដល់បណ្តាមន្ត្រីខ្មែរដែលបានធ្វើការសហការ យ៉ាងសកម្មជាមួយរដ្ឋបាលអាណានិគមបារាំង។

តាំងដើមដំបូងមកម្ល៉េះ បន្ទាប់ពីការតែងតាំងរបបអាណាព្យាបាលបារាំងនៅកម្ពុជា ទេសាភិបាលជាន់ខ្ពស់ មានសិទ្ធិបែងចែកដីធ្លី ជាលក្ខណៈសម្បទានដោយឥតគិតថ្លៃ ហើយដោយមានទំហំរហូតដល់ ១.០០០ ហិកតា។ លុះនៅឆ្នាំ ១៩២៨ ទំហំដីសម្បទាន ដែលរដ្ឋការអាណាព្យាបាលបានបែងចែកអោយ បានត្រឹមតែកម្រិតប្រមាណជា ៣០០ ហិកតា វិញប៉ុណ្ណោះ។ នៅឆ្នាំ ១៩៣១ ការផ្តល់ដីសម្បទានត្រូវបានផ្លាស់ប្តូរទៅតាមលក្ខណៈរូបភាពលក់ដេញថ្លៃ ហើយដែលមានការអនុញ្ញាតអោយចូលរួមដេញថ្លៃ មិនមែនសម្រាប់តែពលរដ្ឋបារាំងនោះទេ ប៉ុន្តែពួកអភិជន ឬនាហ្មឺនខ្មែរក៏អាចចូលរួមផងដែរ។ តាមទិន្នន័យនាឆ្នាំ ១៩៣០ ទំហំដីសម្បទានដែលបែងចែកដោយរដ្ឋការអាណាព្យាបាលបារាំង មានចំនួនពី ១៩០.០០០ ដល់ ២០០.០០០ ហិកតា។ ក្នុងនោះពលរដ្ឋបារាំង បានទទួលដីសម្បទានដែលមានទំហំទៅដល់ ៧០% រីឯដីសម្បទានដែលនៅសល់ត្រូវបានបែងចែកជាពិសេសដល់អភិជនខ្មែរទាំងឡាយ។

គួរបញ្ជាក់ថា កសិករជាង ៨០% ដែលជាអ្នកស្រែចំការ ក៏បានក្លាយជាម្ចាស់កម្មសិទ្ធិឯកជនលើដីធ្លីរបស់ខ្លួន។ កាលនោះនៅប្រទេស កម្ពុជា នៅមានដីទំនេរច្រើន ហើយការត្រួតត្រាលើដីទាំងនោះ មិនចាំ បាច់ទាមទារអោយមានការចំណាយប្រាក់ច្រើនទេ។ ដីស្រែទាំងឡាយប្រកបដោយដីជាតិហើយជាមធ្យមកសិករម្នាក់ៗ មានកម្មសិទ្ធិមិន លើសពី ៥ហិកតា។ ក្នុងបណ្តាកសិករទាំងនោះ មានកសិករចំនួនពី ១,២ ទៅ ២% ប៉ុណ្ណោះដែលមានដីស្រែចំការលើសពី១០ហិកតា។

ក្រៅពីគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចខាងលើនេះ រដ្ឋការអាណាព្យាបាលបារាំងបានបង្កើតវិធីសាស្ត្រទាញយកផលប្រយោជន៍ ផ្សេងទៀត តាមរយៈការបង្កើតរបាំងពន្ធអាករគ្រប់ប្រភេទ តាំងពីការ យកពន្ធលើមនុស្ស លើការចិញ្ចឹមសត្វ និងលើផលដំណាំកសិកម្ម រហូត ដល់ពន្ធនាំចេញ-នាំចូល ដែលតម្លៃអត្រាពន្ធទាំងនោះមានការប្រែប្រួលគ្រប់ពេលវេលា ដោយធ្វើយ៉ាងណា បម្រើផលប្រយោជន៍ដល់សេដ្ឋកិច្ច របស់ប្រទេសបារាំង។ ជាងនេះទៀត ប្រទេសកម្ពុជានៅក្នុងសម័យកាលនោះ ក៏បានក្លាយទៅជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម សម្រាប់បម្រើអោយឧស្សាហកម្មបារាំង ហើយក្លាយជាអ្នកទទួលទិញនូវទំនិញ ផលិតសម្រេចពីប្រទេសបារាំងមកវិញ។

សរុបសេចក្តីមក ទស្សនៈទានសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា នាសម័យអាណានិគម គឺទាក់ទងនឹងនយោបាយបែងចែកដីសម្បទាន ដើម្បីក្លាយទៅជាកម្មសិទ្ធិឯកជន ក្នុងទិសដៅអភិវឌ្ឍន៍ វិស័យកសិកម្ម និងឈានទៅរកការអភិវឌ្ឍឧស្សាហកម្មធុនស្រាល។ ក្នុងលក្ខ

ណៈនេះ រដ្ឋមានតួនាទីជាអ្នកបែងចែកដ៏ស្របច្បាប់ និងទទួលបានមកវិញនូវប្រាក់ចំណូលតាមរូបភាពបង់ពន្ធលើដីធ្លី និងលើផលដំណាំ ក៏ដូចជាលើប្រាក់ចំណេញ។ ទន្ទឹមនឹងនោះដែរ អាណាព្យាបាលបារាំង បានបង្កើតគោលនយោបាយពន្ធអាករ ដែលកេងប្រវ័ញ្ចលើប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់ ហើយធ្វើអោយសេដ្ឋកិច្ចខ្មែរទាំងមូល បានស្ថិត នៅក្នុងសភាពក្រីក្រដដែល។ រីឯការវិនិយោគសាធារណៈ និងការបែងចែកមកវិញនូវចំណូលពន្ធអាករ មិនបានផ្តល់នូវភាពយុត្តិធម៌ និងការរីកចម្រើនដល់សេដ្ឋកិច្ចជាតិ និងសង្គមខ្មែរ នាសម័យកាលនោះឡើយ។

## ១.២.៤.ទស្សនៈទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសម័យសង្គមរាស្ត្រនិយម

ចាប់តាំងពីយុគសម័យដើមមកម្ល៉េះ ប្រទេសខ្មែរយើងជាប្រទេស ដែលប្រកបរបរកសិកម្មជាធំ ហើយផលិតផលដែលផលិតចេញពីដី គឺមានអានុភាពខ្លាំងក្លាណាស់ចំពោះសេដ្ឋកិច្ចជាតិ។ ដូចជានៅក្រោមរបប អាណាព្យាបាលបារាំងប្រទេសខ្មែរបានយកវិស័យកសិកម្មធ្វើជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច។ រីឯ វិស័យអាជីវកម្មផ្សេងៗទៀត គឺមានតិចតួច ស្តួចស្តើងណាស់ ដូចដែលយើបានសិក្សារួចមកហើយ ពោលគឺមានតែរបរសិប្បកម្មបន្តិចបន្តួច និងកម្មន្តសាលតូចតាចប៉ុណ្ណោះ ហើយវិស័យទាំងនោះស្ថិតនៅក្នុងកណ្តាប់ដៃជនបរទេស។ ដោយសារតែកង្វះខាតផ្នែកឧស្សាហកម្មនេះហើយ ទើបធ្វើអោយវិស័យបច្ចេកទេស និងបច្ចេកវិទ្យានៅសម័យកាលនោះ ពុំមានការជឿនលឿន។ នៅខណៈពេលនោះ ប្រទេសយើងបានធ្វើការនាំចេញទៅក្រៅប្រទេសនូវភោគផលធម្មជាតិ ហើយនាំចូលមកវិញនូវផលិតផលឧស្សាហកម្ម សម្រាប់យកមកប្រើ ប្រាស់ក្នុងស្រុក។

ក្រោយពីបានទទួលឯករាជ្យមក រាជរដ្ឋាភិបាលខ្មែរបានជម្រុញអោយវិស័យសេដ្ឋកិច្ចគ្រប់ផ្នែកមានសន្ទុះកើន ឡើង ហើយរដ្ឋាភិបាល ក៏បានធ្វើការគ្រប់គ្រង និងកាន់កាប់យកផ្នែកសំខាន់ៗខ្លះ ដែលជាអាយុជីវិតនៃសេដ្ឋកិច្ចជាតិ។

ចំពោះគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជានាសម័យកាលនោះ រាជរដ្ឋាភិបាល បានកំណត់គោលដៅ ៣យ៉ាង គឺ

- កសាងសេដ្ឋកិច្ចថ្មី តាមរយៈការធ្វើជាតូបនីយកម្ម ផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងស្ថាប័នហិរញ្ញវត្ថុ ដោយប្រើប្រាស់ជំនួយបរទេស។
- ជ្រៀតចូលជាសមាជិកភាពនៃស្ថាប័នធនាគារពិភពលោក ដូច ជា ADB, IMS និង IBRD។
- បង្កើតច្បាប់វិនិយោគអោយមានការទាក់ទាញ ដើម្បីអូសទាញទុនវិនិយោគពីបរទេស និង

  វិនិយោគក្នុងស្រុកតាមរយៈការធ្វើឯកជនភាវូបនីយកម្ម វិស័យពាណិជ្ជកម្ម ធនាគារ និង ឧស្សាហកម្ម ។

ទាក់ទងទៅនឹងទស្សនៈទាននៃការអភិវឌ្ឍវិស័យកសិកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើគោលនយោបាយពង្រីកដីស្រែចំការថ្មី ការជ្រើសរើសពូជស្រូវ និងពូជដំណាំ ការប្រើ

ប្រាស់ដីធម្មជាតិគួបផ្សំនឹងជីគីមី ការអភិវឌ្ឍនយោបាយទឹក និងការផ្តល់ឥណទានយ៉ាងច្រើនក្នុងវិស័យកសិកម្ម។

បើយើងពិនិត្យមើលអោយបានពិស្តារ ទៅលើកម្មវិធីលម្អិតនៃការអភិវឌ្ឍវិស័យកសិកម្ម យើងឃើញថា រាជរដ្ឋាភិបាលសម័យនោះបានបែងចែកថវិការដ្ឋប្រមាណ ២៥% សម្រាប់ការវិនិយោគលើវិស័យកសិកម្ម (ជាលក្ខណៈឥណទាន និងមិនមែនឥណទាន) ជាពិសេសទៅលើដំណាំសំខាន់ៗជាមូលដ្ឋាន ដូចជា ដំណាំស្រូវ កៅស៊ូ ពោត កប្បាស ត្នោត តែ និងកាហ្វេ ព្រមទាំងបានវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ សម្រួលដល់ការធ្វើកសិកម្មច្រើនរដូវកាល។

ក្រៅពីនេះ រដ្ឋាភិបាលបានជម្រុញអោយកសិករខ្មែរចេះប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ចេះធ្វើទំនើបកម្មកសិកម្ម ដោយប្រើប្រាស់ត្រាក់ទ័រ និងបរិក្ខារកសិកម្មផ្សេងៗទៀត និងលើកលែងពន្ធនាំចូលលើ សម្ភារៈកសិកម្មទាំងនោះ។ សំខាន់ជាងនេះទៀត នៅក្នុងគោលនយោបាយអភិវឌ្ឍន៍កសិកម្មយើងពិនិត្យឃើញថា រដ្ឋាភិបាលបានផ្តល់ដី កសិកម្ម និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាកសិករ បានបង្កើតស្ថានីយ៍ ស្រាវជ្រាវកសិកម្ម និងជ្រើសរើសភូមិកសិកម្មគម្រូ ពិសេសទៀត រដ្ឋបានធ្វើការកំណត់តម្លៃផលិតផលកសិកម្ម ដើម្បីអោយកសិករអាចជ្រួតជ្រាបជាមុនអំពីតម្លៃទីផ្សារងាយស្រួលក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងផែនការផលិតកម្មរបស់ខ្លួន។

ចំពោះទស្សនៈទាននៃការអភិវឌ្ឍ វិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលបានជម្រុញការសាងសង់នូវរោងចក្រជាច្រើនដូចជា រោងចក្រ តម្លើង គ្រឿងយន្ត រោងចក្រចម្រាញ់ប្រេងកាត រោងចក្រស្រាបៀររោងចក្រវាយនភ័ណ្ឌ រោងចក្រស៊ីម៉ង់ត៍ រោងចក្រក្រដាស រោងចក្រផលិតកែវ រោងចក្រផលិតកង់រថយន្ត រោងចក្រផលិតឱសថ រោងចក្របាវ ក្រចៅ រោងចក្រត្រីខកំប៉ុង រោងចក្រក្តារបន្ទះ និងផ្សេងៗទៀតនៅទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។

ផ្សេងពីនេះទៀត ទាក់ទងទៅនឹងវិស័យសេវាកម្ម យើងឃើញថា រាជរដ្ឋាភិបាលបានពង្រីកហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការសាងសង់កំពង់ផែសំខាន់ៗ ដើម្បីធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ជាមួយបណ្តាប្រទេសជាច្រើននៅលើពិភពលោក។ គួបញ្ជាក់ថា ការធ្វើពាណិជ្ជកម្មក្រៅប្រទេស គឺបានស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការរបស់រដ្ឋក្នុងភាគហ៊ុន ៦០% ជាដើមទុនរបស់រដ្ឋ និង ៤០ ជាដើមទុនរបស់ឯកជន។ ម្យ៉ាងទៀតរដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ច ពាណិជ្ជកម្ម ដោយបានបង្កើតក្រុមហ៊ុននាំចេញ-នាំចូលរបស់ជាតិ ក្នុងគោលបំណងគ្រប់គ្រងចរាចរលំហូរទំនិញចេញពីក្នុងស្រុក និងលំហូរចូលពីបរទេស ក្នុងទិសដៅធានាបាននូវតុល្យភាពជញ្ជីងពាណិជ្ជកម្ម និងទទួលបាននូវអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនេះដែរ រដ្ឋបានបង្កើតក្រុមហ៊ុនជាតិ ចែកចាយទំនិញក្នុងស្រុក ដើម្បីកាត់បន្ថយនូវគម្លាតនិងអន្តរការីសេដ្ឋកិច្ច (ឈ្មួញកណ្តាល) ពោលគឺធ្វើយ៉ាងណាអោយអ្នកផ្គត់ផ្គង់ទំនិញ និងអ្នកប្រើប្រាស់បានខិតជិតគ្នា។

ដោយឡែកចំពោះវិស័យសិក្សាធិការជាតិ និងសុខាភិបាលសាធារណៈវិញ ដែលជាវិស័យគន្លឹះនាសម័យកាលនោះ រាជរដ្ឋាភិបាលបានធ្វើការជម្រុញយ៉ាងខ្លាំងក្លា ដោយពង្រីកការប

ណ្តុះបណ្តាលធន ជានមនុស្សលើគ្រប់កម្រិតសិក្សា និងគ្រប់ជំនាញ ព្រមទាំងធ្វើការពង្រីកវិស័សុខាភិបាល និងវប្បធម៌ជាតិ ដែលនៅសម័យអាណានិគមពុំត្រូវបានយកចិត្តទុកដាក់។

### ១.២.៥.ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យសាធារណៈរដ្ឋខ្មែរ

ផ្ទុយពីសម័យសង្គមរាស្ត្រនិយម យុទ្ធសាស្ត្រសំខាន់ៗ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នាសម័យសាធារណៈរដ្ឋខ្មែរ គឺជាការទទួលយកនូវប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចជាតិ តាមរូបភាព សេដ្ឋកិច្ចទីផ្សារសេរី។ នៅសម័យនោះ ប្រព័ន្ធសេដ្ឋកិច្ចជាតិទាំងមូលត្រូវបានរៀបចំឡើង ដោយថតចម្លងនូវក្បួនខ្នាត នៃការធ្វើសេដ្ឋកិច្ចទីផ្សារសេរីរបស់សហរដ្ឋអាមេរិក យកមកអនុវត្តផ្ទាល់នៅក្នុងប្រទេសកម្ពុជា ដោយដំណើរការសេដ្ឋកិច្ចជាតិទាំងមូល ពឹងផ្អែកទាំងស្រុងលើវិស័យឯកជន ហើយរដ្ឋដើរតួជាអ្នកសម្របសម្រួល និងធ្វើនិយ័តកម្មក្នុងយន្តការសេដ្ឋកិច្ច ។ ជាលទ្ធផល មូលដ្ឋានសេដ្ឋកិច្ចសំខាន់ៗ ត្រូវបានផ្ទេរទៅអោយ ផ្នែកឯកជនជាអ្នកគ្រប់គ្រង ជាពិសេសវិស័យពាណិជ្ជកម្ម ដែលជាវិស័យគន្លឹះនាសម័យនោះ។

### ១.២.៦.ស្ថានភាពវិស័យសេដ្ឋកិច្ចសម័យកម្ពុជាប្រជាធិបតេយ្យ

#### ក.វិស័យកសិកម្ម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានឈរលើទស្សនៈវិស័យថា មានស្រូវគឺមានអ្វីៗទាំងអស់។ ដូច្នេះ ក្នុងរបប ប៉ុល ពត ពួកគេបានបង្ខំប្រជាជនអោយទៅរស់នៅតាមទីជនបទ ហើយបង្ខំអោយធ្វើស្រែចំការយ៉ាងធ្ងន់ធ្ងរ។កសិករទាំងអស់ បានធ្វើការងារជាសមូហភាព ដោយបង្ខំដូចសត្វធាតុ ។

នៅសម័យកម្ពុជាប្រជាធិបតេយ្យ ប្រជាពលរដ្ឋស្ទើរតែ ១០០% ត្រូវបានពួកអង្គការបង្ខំអោយធ្វើការងាររួមគ្នា ប្រកបរបរកសិកម្មយ៉ាងធ្ងន់ធ្ងរជាទីបំផុត ទាំងយប់ទាំងថ្ងៃមិនថាឈឺឬជានោះទេ ពោលគឺ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្មែរក្រហម គឺការពង្រឹងវិស័យកសិកម្មសម្រាប់ការផ្គត់ផ្គង់វិស័យសេដ្ឋកិច្ចទាំងមូល។[161] ដោយពឹងផ្អែកលើវិស័យកសិកម្មនេះ ប្រទេសកម្ពុជាបានត្រូវធ្វើសមូហភាវូបនីយកម្ម និង ជាតូបនីយកម្ម លើគ្រប់វិស័យនៃខឿនសេដ្ឋកិច្ចជាតិទាំងមូល។ ជាមួយនេះផងដែរ ពួកថ្នាក់ដឹកនាំរបស់អង្គការ បានបង្កើតនយោបាយ ខ្លួនទីពឹងខ្លួន ដោយរដ្ឋាភិបាលគ្រប់គ្រងលើកម្លាំងពលកម្មទាំងអស់ អោយដាំដំណាំស្រូវ និងធ្វើការងារជីកប្រឡាយ លើកទំនប់ទឹកជីកស្រះ និងបំពេញការងារយ៉ាងធ្ងន់ធ្ងរផ្សេងៗទៀត ព្រោះពួកគេបានមើល ឃើញពីបទពិសោធន៍នៃភាពរីកចម្រើនដ៏ខ្លាំងក្លានៅសម័យអង្គរ ដោយសារតែប្រព័ន្ធធារាសាស្ត្រនេះ។

ប៉ុន្តែទោះបីជាតែប្រទេសកម្ពុជានាសម័កាលនោះ បានទទួលយកឯកទេសកម្មខាងការផលិតស្រូវក៏ដោយ ក៏ប៉ុន្តែប្រជាជនខ្មែរពុំមានអាហារបរិភោគគ្រប់គ្រាន់នោះទេ ពីព្រោះផលិតផលអស់ទាំងនោះ ត្រូវផ្តល់ ជាជំនួយអោយទៅប្រទេសចិន។[162] ជាទូទៅក្នុងមួយថ្ងៃៗ ប្រជាជនខ្មែរសម័យនោះ គេអោយហូបតែបបររាវ ២ពេល ប៉ុណ្ណោះក្នុងមួយថ្ងៃ។

ក្នុងការប្រកបរបរកសិកម្ម ប្រជាជនខ្មែរត្រូវបានរៀបចំជាសហករណ៍ សម្រាប់បង្កបង្កើនផល ដោយមានការរៀបចំជាក្រុមសាមគ្គីតូចៗ នៅតាមបណ្តាភូមិនិមួយៗនៃទីជនបទ ស្រែចំការ ដែលភាគច្រើនជ្រើសរើស យកកម្លាំងយុវជន (កងចល័ត) ធ្វើជាកម្លាំងស្នូល ដើម្បីអនុវត្តអោយបានតាមផែនការបង្កបង្កើនផលទាំងយប់ទាំងថ្ងៃ (ក្រោមពាក្យស្លោកថា ផលិតស្រូវគឺ ៣ តោន/ហិកតា)។[163] ប្រព័ន្ធធារាសាស្ត្រ បានបន្សល់ទុក រហូតដល់បច្ចុប្បន្ននេះ។ ចំណែកឯធនធានធម្មជាតិ ក្នុងសម័យនោះ ត្រូវបានប្រើប្រាស់អស់លទ្ធភាព ហើយសូម្បីតែកំប្លោកក៏ត្រូវអូសយក មកកាប់ចិញ្ច្រាំធ្វើជាជីសម្រាប់ដាក់ស្រែអស់ដែរ។

ក្រៅពីដំណាំស្រូវ ការដាំបន្លែ ផ្លែឈើ ថ្នាំជក់ ចិញ្ចឹមសត្វ និងនេសាទវិញ បក្សកុម្មុយនីស្តបានអោយប្រជាពលរដ្ឋ ដែលមានវ័យចាប់ពីអាយុ ៥០ឆ្នាំ ឡើងទៅ និងអ្នកទោសកម្រិតស្រាល ទទួលយកភារកិច្ចទាំងនោះ។ ផ្ទៃដីបង្កបង្កើនផលអាចមានដល់ទៅ ២.៤ លាន ហិកតា រួមទាំងដីទំនាបខ្ពង់រាបដីល្បាប់ដីមានជីជាតិ និងដីហិលមួយចំនួនទៀត។ ប៉ុន្តែការអនុវត្តកន្លងមក កម្ពុជាប្រជាធិបតេយ្យ ធ្វើបានតែ ៥៨% នៃផ្ទៃដីដាំដុះតែប៉ុណ្ណោះ។ ដូច្នេះហើយ អ្នកសេដ្ឋកិច្ចសម័យនោះ បានបង្កើតផែនការសម្រាប់ពង្រីកផ្ទៃដីដាំដុះ និងផែនការពង្រីកការដាំ ដុះស្រូវរយៈពេល៤ឆ្នាំ។ ចំពោះទិន្នផលស្រូវល្អបំផុតនៅសម័យនោះ អាចទទួលបានប្រហែលជា ២ តោន ទៅ ២,៣តោនប៉ុណ្ណោះក្នុងមួយហិកតា។

ប៉ុន្តែអ្វីដែលគួរអោយកត់សម្គាល់នោះ ប្រជាជនខ្មែរក្នុងរបប ប៉ុល ពត គឺរកតែបបររាវហូបក៏មិនបានឆ្អែតផង។ តាមឯកសារខ្លះបង្ហាញថា នៅឆ្នាំ ១៩៧៧ ភូមិភាគពាយ័ព្យអាចប្រមូលផលស្រូវបានប្រហែលតែ ពី ៧០០.០០០ ទៅ ៩០០.០០០ តោន ប៉ុណ្ណោះ ប៉ុន្តែជាលទ្ធផលក្នុងឆ្នាំ ១៩៧៨ ភូមិភាគនេះ គឺបានខ្វះស្រូវពី ៧០០.០០០ ទៅ ៨០០.០០០តោន ដែលនាំអោយកើតមានគ្រោះទុរ្ភិក្ស ព្រោះស្រូវទាំងនោះ ត្រូវបានមជ្ឈិមបក្សនាំចេញទៅបរទេស។ បើយោងតាមឯកសារបក្ស នៅឆ្នាំ១៩៧៧ គឺបានដាក់បទបញ្ជាអោយភូមិភាគ នេះត្រូវតែផលិតស្រូវអោយបាន ១.៦២០.០០០ តោន ដែលមួយភាគធំ សម្រាប់ធ្វើការនាំចេញទៅលក់នៅបរទេស។

ដោយឡែកនៅឆ្នាំ ១៩៧៦ ស្រូវភាគច្រើនគឺមជ្ឈិមបក្សបាន ទទួលពីភូមិភាគបូព៌ាទៅវិញ ប៉ុន្តែ លុះដល់ឆ្នាំ ១៩៧៧-១៩៧៨ មជ្ឈមបក្សលែងទទួលបានស្រូវពីភូមិភាគនេះហើយ ព្រោះការដឹកនាំក្នុងតំបន់នេះ បានយកចិត្តទុកដាក់លើកម្រិតជីវភាពប្រជាជនប្រសើរជាងតំបន់ដ៏ទៃទៀតក្នុងប្រទេសខ្មែរ ដែលជាមូលហេតុនៃការចាប់ផ្តើងឡើងនូវទំនាស់ផ្ទៃកនយោបាយ និងការស្លាប់របស់លោក សោ ភឹម។

## ខ.វិស័យឧស្សាហកម្ម និងសិប្បកម្ម

ក្នុងរបបដិវត្តន៍កុំម្មុយនីស្តកម្ពុជា បានផ្លាស់ប្តូរទីតាំងរោងចក្រពីទីក្រុង ទៅជនបទវិញ។ ពួកអង្គការបានកែច្នៃម៉ាស៊ីនយានយន្តមួយចំនួន តាមរយៈការស្លម៉ាស៊ីនទាំងនោះ រួចចាក់ជាផ្ទាំង ជាស ខ្វះ

ជាដើម។ ចំពោះផលិតកម្មឧស្សាហកម្ម ដែលប្រទេសកម្ពុជាធ្លាប់មានពីមុនមកដូចជា រោងចក្រសហគ្រាស មធ្យោបាយដឹកជញ្ជូន និងផ្លូវគមនាគមន៍ ត្រូវបានកំទេចចោលទាំងស្រុង។ ចំពោះវិស័យសិប្បកម្ម គឺពុំមានអ្វីជាដុំកំភួននោះទេ ព្រោះប្រជាពលរដ្ឋគ្មានពេលសម្រាប់ចាក់ជាម្ចូកស្លឹកត្នោត និងស្មូនផ្ទាំងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនទេ (ព្រោះជាកម្មសិទ្ធិរួម ប្រជាជនមានកម្មសិទ្ធិតែស្លាបព្រាមួយ និងកំប៉ុងទឹកដោះគោមួយប៉ុណ្ណោះ សម្រាប់ដាក់ទឹកបរិភោគ)។ ហើយអ្វីដែលពួកអង្គការបង្ខំ អោយធ្វើនៅតាមភូមិនិមួយៗនោះគឺធ្វើ បង្គី ចប និង កណ្ដៀវច្រូតស្រូវ ដែលជាឧបករណ៍ផលិតកម្មកសិកម្មសំខាន់បំផុតក្នុងសម័យ ប៉ុល ពត។

### គ.វិស័យសេវាកម្ម

### គ.១.វិស័យពាណិជ្ជកម្ម

វិស័ពាណិជ្ជកម្ម ត្រូវបានបំបាត់ចោលទាំងស្រុង ព្រោះជាសេដ្ឋ កិច្ចក្នុងទ្រង់ទ្រាយ និងទម្រង់អន់ថយ ជាសេដ្ឋកិច្ចបែបសម័យបុរេប្រវត្តិ ព្រោះគេបានបំបាត់ក្រដាសប្រាក់ ទីផ្សារ និងទំនាក់ទំនងដោះដូរ។

ប៉ុន្តែដោយសារតែភាពអត់ឃ្លានរបស់ប្រជាពលរដ្ឋបានបង្ខំ អោយមានការដោះដូរស្រូវអង្ករដោយលួចលាក់ជាមួយរបស់របរដែល ពួកប្រជាជនមូលដ្ឋានចាស់(ជាម្ចាស់ស្រុកមុនរបបខ្មែរក្រហម)មានតម្រូវការដូចជា នាឡិការ ឬគ្រឿងអលង្កាផ្សេងៗពីព្រោះសម័យនោះគឺគ្មានការចរាចរដារូបិយវត្ថុ នោះទេ។

ចំពោះពាណិជ្ជកម្មក្រៅប្រទេសត្រូវបានផ្អាក ប៉ុន្តែបានដំណើរការឡើងវិញ នៅចុងឆ្នាំ ១៩៧៦ និងដើមឆ្នាំ ១៩៧៧ ជាមួយប្រទេសចិន ដែលជាដៃគូរពាណិជ្ជកម្មដ៏សំខាន់។ បើតាមផែនការរបស់ ពួកខ្មែរក្រហម គឺនៅឆ្នាំ ១៩៧៨ គេមានគម្រោងនាំស្រូវអង្ករចេញ ចំនួន ១.៦២៩.០០០ តោន ។ នៅក្នុងផែនការ៤ឆ្នាំរបស់ ប៉ុល ពត គេមានគម្រោងនាំចេញអង្ករ អោយបានជិត ៤ដង ដោយសង្ឃឹមថា ទទួលបានរូបិយប័ណ្ណប្រមាណ ១.៣ ពាន់លានដុល្លា។ [171]

ប៉ុន្តែត្បិតតែយើងឃើញមាន ការដោះដូររវាងកម្ពុជា និងចិន លើផលិតផលស្រូវ និងសព្វាវុធ ប៉ុន្តែមិនមែនជាពាណិជ្ជកម្មនោះទេ គឺជាជំនួយទៅវិញទៅមក។ ចំពោះទំហំពាណិជ្ជកម្មមានក្នុងតម្លៃត្រឹមតែ ៣ ឬ ៤លាន ដុល្លារប៉ុណ្ណោះ។ ក្រោយមកក៏បានទំនាក់ទំនងជាមួយប្រទេស បារាំង អង់គ្លេស និងសហរដ្ឋអាមេរិក ដោយឆ្លងកាត់តាមហុងកុង។

### គ.២.វិស័យគមនាគមន៍

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានផ្លូវដែក ផ្លូវទឹក និងផ្លូវថ្នល់។ ហើយនៅលើដី គឺមានរទេះគោ និងនៅលើទឹកមានទូក។ ដោយសារតែគោលនយោបាយនាំប្រជាជនឆ្ពោះទៅរកម្ហូបអាហារ (ព្រោះពិបាកដឹក ស្បៀងអាហារយកទៅផ្គត់ផ្គង់ដល់ប្រជាជននៅទីក្រុង) ដូច្នេះ រថភ្លើង និងរថយន្ត ត្រូវបានផ្អាកការប្រើប្រាស់ ហើយគេប្រើប្រាស់រទេះគោ ទូក និងថ្មើរជើងជំនួសវិញ។

### គ.៣.វិស័យហិរញ្ញវត្ថុ

ក្រោយពីបានវាយរំលំរដ្ឋាភិបាល លន់ នល់ មកពួកខ្មែរក្រហម បានឡើងកាន់អំណាច ហើយធ្វើការបិទមិនអោយមានការចាយលុយ និងមិនអោយមានការដោះដូរទៀតទេ។ ប៉ុន្តែ បក្សកុំមុយនីស្តកម្ពុជា សម័យនោះ គេបានបោះពុម្ពក្រដាសប្រាក់ដែរ។ ហើយរូបិយវត្ថុទាំងនេះ បានបោះពុម្ពនៅក្នុងឆ្នាំ ១៩៧៥ និងគ្រប់គ្រងដោយធនាគារកម្ពុជា។ ការបោះពុម្ពសាច់ប្រាក់នេះ មានគោលបំណង៣យ៉ាងគឺៈ

- ជានិមិត្តរូបដើម្បីបំភ័នភ្នែកសកលលោក
- សម្រាប់ទូទាត់ពាណិជ្ជកម្មជាមួយបរទេស (ចិនជាដើម)
- ទុកបើកប្រាក់បៀវត្សដល់កម្មាភិបាលរបស់ពួកគេ។

ប៉ុន្តែយើងពិនិត្យឃើញថា ជាក់ស្តែង រូបិយវត្ថុទាំងអស់នោះ ពេញមួយសម័យកាលនៃរបប ប៉ុល ពត ពុំបានចរាចរនោះឡើយ។

## ១.៣.ក្របខ័ណ្ឌនយោបាយ

កម្ពុជាប្រការជាគោលការណ៍លន់ណុលរបបរាជាធិបតេយ្យអាស្រ័យសភា ហើយនៅពេលខ្លះព្រះរាជបល្ល័ង្កត្រូវបានទុកនៅទំនេរ។ នៅទសវត្សឆ្នាំ ១៩៥០-១៩៦០ មានគណបក្សដែលប្រមូលផ្តុំជាសង្គមរាស្ត្រនិយម ដែលជំនួសនូវគណបក្សនយោបាយចាស់នានា ចាប់តាំងពីឆ្នាំ ១៩៥៥ មក ។ សម្តេចព្រះនរោត្តមសីហនុ បានដាក់រាជ្យនៅឆ្នាំ ១៩៥៥ ដើម្បីព្រះអង្គបានខិតទៅជិតជនរួមជាតិ ហើយមានក្តីរីករាយក្នុងនាមជាព្រះប្រមុខរដ្ឋ។ នៅតំណាក់កាលចាប់ផ្តើមនាឆ្នាំ ១៩៥៥ ហើយជានិច្ចកាល គេតែងតែហៅថាយុគសម័យសង្គម គឺនៅលើផ្នែកនយោបាយ មានស្ថេរភាព ដ៏ធំមួយដែលផ្ទុយស្រឡះទាំងស្រុង ពីការប្រឆាំងគ្នា និងការខ្វះរបៀបរៀបរយ នៃតំណាក់កាលមុននេះ។តំណាងរាស្ត្របានជាប់ឆ្នោតក្នុងលក្ខណៈប្រជាធិបតេយ្យមួយ អនុម័តច្បាប់ ជាពិសេសអនុម័តច្បាប់ហិរញ្ញវត្ថុ។ ការអនុវត្តជាក់ស្តែងពេលនោះ ជីវភាពនយោបាយកម្ពុជា គឺព្រះបាទសម្តេចព្រះនរោត្តមសីហនុ ជា សសរទ្រូងនៃនយោបាយប្រទេស។ ព្រះប្រមុខរដ្ឋបានជួយប្រជាជនខ្មែរ ដែលព្រះអង្គបានជំរុញការអភិវឌ្ឍវិស័យអប់រំ សិក្សាតាមរយៈព្រះមេត្តាធម៌ ដែលធ្វើឱ្យព្រះអង្គមានប្រជាប្រិយនៅក្នុងចិត្តប្រជាជនព្រះអង្គ។

ព្រះរាជបំណង គឺសង្គ្រោះ និងចិញ្ចឹមប្រទេសព្រះអង្គ។ គោលការណ៍ទាំងនោះ ជាទិសដៅនយោបាយ និងជាពិសេស នយោបាយក្រៅប្រទេសរបស់ព្រះអង្គ។ ក្នុងពេលនោះ កម្ពុជារក្សាបាននូវឯករាជ្យរបស់ខ្លួន។ កម្ពុជា ជានិច្ចកាលបដិសេធរាល់ការភ្ជាប់ខ្លួនទៅនឹងប្លុកនានា ហើយកម្ពុជាពេលនោះ ក៏បានក្លាយជាដើកឯកដែលគេយកចិត្តទុកដាក់ស្តាប់នៅក្នុងចលនាអព្យាក្រិត្យ។ ប៉ុន្តែផ្ទុយស្រឡះ កម្ពុជាមិនមែនជាប្រទេសបិទទ្វារនោះទេ កម្ពុជាតែងទទួលនូវរាល់ជំនួយ ដែលជួយការពារបូរណភាពទឹកដីខ្លួន ពីឧបាយកលនៃប្រទេសជិតខាង និងទទួលជំនួយ ក្នុងការកសាងសេដ្ឋកិច្ច។ ដូច្នេះហើយ បានជាកម្ពុជាបានទទួលជំនួយពីប្រទេស ចិន សហរដ្ឋអាមេរិក បារាំង សហភាពសូវៀត។ នាឆ្នាំ ១៩៦៣ នៅពេលដែលកម្ពុជាបានធ្វើកា

សន្និដ្ឋានថា ជំនួយសហរដ្ឋ មិនមានសារៈសំខាន់ទៀតទេនោះ ប្រទេសនេះបានបដិសេធ លែងទទួលយកជំនួយនោះ។ ទំនាក់ទំនងខ្មែរ-អាមេរិក បន្ទាប់មកមានភាពតឹងតែង រហូតដល់ការផ្តាច់ចំណងការទូត កើតឡើងនៅឆ្នាំ ១៩៦៥ ។ លើកលែងតែសហរដ្ឋអាមេរិក វៀតណាម និងថៃ កម្ពុជានៅតែរក្សាទំនាក់ទំនងល្អ ជាមួយគ្រប់ប្រទេសទាំងអស់ លើពិភពលោក ពិសេសជាមួយបារាំង សូវៀត ចិន ។នៅកម្ពុជា មានពួកមូលធនឯកជន ពួកចងការប្រាក់ ពួកពាណិជ្ជករ ពួកមេសហគ្រាស ដែលសុទ្ធតែបានបំពេញតួនាទីនៃការប្រព្រឹត្តទៅនៃវិស័យសេដ្ឋកិច្ច។ ប៉ុន្តែនៅក្នុងប្រទេសមួយដែលឧស្សាហកម្មកំពុងតែមានពន្លក ហើយតួនាទីរបស់ម្ចាស់ដីមានការធ្វេសប្រហែស ហើយនៅទីនោះ កសិករជាង ៨០% ជាម្ចាស់កម្មសិទ្ធិដីធ្លី ធ្វើការដាំដុះ ផលិតកសិផល បែរជាមិនយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាថែមទៀត ដល់សារៈសំខាន់ផ្នែកនយោបាយ និងសេដ្ឋកិច្ចរបស់ក្រុមទាំងនោះ។

បញ្ហាចោទឡើងដូចដែលនិស្សិតម្នាក់បានដាក់ឈ្មោះថា"មូលធនរដ្ឋ"នៅទីនេះក្នុងសម័យនោះមានសារៈសំខាន់ណាស់។មូលធនរដ្ឋនេគឺគ្មានអ្នកណាជាងពួកមន្ត្រីឬមន្ត្រីថ្នាក់មួយនោះនិងពួកអ្នកគ្រប់គ្រងសហគ្រាសមធ្យោបាយដ៏ល្អបំផុត ដែលបង្កើននូវទ្រព្យធន ឬលើសពីនេះទៀត គឺការរកចំណូលក្នុងកម្រិតខ្ពស់។ នៅកម្ពុជា ក៏ដូចនៅក្នុងបទេសនានាដែរជាប្រពៃណីគឺមានអំណាចមានទ្រព្យសម្បត្តិហើយមិនមែនមានទ្រព្យធនដែលដណ្តើមអំណាចបាននោះទេ។

## ១.៤.ក្របខ័ណ្ឌភូមិសាស្ត្រ

ការកត់សម្គាល់នូវភូមិសាស្ត្រ រូបនិយម នឹងបំពេញបន្ថែមខ្លឹមសារនៃសេចក្តីផ្តើម នៃសេដ្ឋកិច្ចកម្ពុជា។ អ្វីដែលតម្រូវចាំបាច់ឱ្យបំពេញបន្ថែមនោះ គឺនៅប្រទេសមិនសូវមានភាពរីកចម្រើនជាងនៅប្រទេស ដែលលូតលាស់ឧស្សាហកម្ម ស្ថានភាពភូមិសាស្ត្រ ទឹកដី អាកាសធាតុ និងធនធានធម្មជាតិ ផ្តល់និយមន័យបានត្រឹមត្រូវ ទូលាយក្នុងវិធានការសេដ្ឋកិច្ច។

### ១.៤.១.សណ្ឋានដី

កម្ពុជា ជាប្រទេសវាលរាប ឬខ្ពង់រាប ជាទូទៅមានកំពស់ដីរាប ហើយស្ថានភាពទឹកដីគ្មានឧបសគ្គដល់គមនាគមន៍ឡើយ។ មណ្ឌលកណ្តាលរបស់ប្រទេស មានវាលរាបដែលត្រូវទឹកលិចយ៉ាងធំ ហើយនៅតាមបរិវេណព្រំដែន មានជួរភ្នំ តែមិនសូវខ្ពស់។

អ្នកភូមិសាស្ត្រ បានបែងចែកតំបន់ធម្មជាតិធំៗជាប្រាំ៖ ជួរភ្នំក្រវាញ ភូមិភាគដីទួល វាលទំនាបកណ្តាល តំបន់ខ្ពស់នៅភាគខាងជើង និងខ្ពង់រាបនៅតាមបរិវេណព្រំដែន។

ជួរភ្នំក្រវាញ ឬភ្នំដំរី លាតសន្ធឹងនៅនិរតីនៃប្រទេស ស្របនឹងសមុទ្រពីប៉ៃលិន មក កំពត។ កំពូលភ្នំខ្លះ កំពស់លើសពី ១,០០០ ម ហើយកន្លែងដែលខ្ពស់ជាងគេឡើងដល់ ១,៨១៣ ម នៅភ្នំឱរាល់។

តំបន់ទួល ស្ថិតនៅពទ្ធ័ជុំវិញជួរភ្នំធំរី ជាចំណុចភ្ជាប់រវាងភ្នំ និងវាលរាប។ ភូមិភាគនេះមានកំពស់ជាមធ្យម ៣០០ ម គឺជាជួរភ្នំទាបៗ កន្លែងស្ថិតនៅឯកកោ អាចមានកំពស់ដល់ ៨០០ ម ។

វាលទំនាបកណ្តាល ជាតំបន់មួយដែលសម្បូរដោយដីល្បាប់ មានទទឹងប្រហែល ១១០ គ.ម.និងមានបណ្តោយ ៥០០ គ.ម.ដែលលាតសន្ធឹងពីព្រំដែនថៃ រហូតដល់ភាគខាងត្បូងវៀតណាម នៅជុំវិញបឹងទន្លេសាប និងជុំវិញទន្លេធំ ឬទន្លេមេគង្គផ្នែកខាងក្រោម។

គេកត់សម្គាល់ថា វាលទំនាបកណ្តាលនេះ មិនមែនជាវាលទំនាបមេគង្គទេ លើកលែងតែខាងក្រោមនៃទន្លេនេះ។ គឺនៅវាលរាប និងវាលទំនាបកណ្តាលនេះហើយ ដែលមានការប្រមូលផ្តុំប្រជាជនដ៏ច្រើនកុះករ ហើយជា តំបន់សកម្មភាពសេដ្ឋកិច្ចរបស់ប្រទេស។ វាលទំនាបនេះ បានត្រូវបែងចែកជាបីតំបន់។ ទីមួយ ជាតំបន់ស្រទាប់ដីល្បាប់ មានទទឹងរាប់ពាន់ម៉ែត្រគ្រប់ដណ្តប់តាមច្រាំងទន្លេ នៅតាមកោះ តំបន់នេះមានដីដែលមានជីជាតិណាស់។ តំបន់ទីពីរជាកន្លែងមានទឹកលិច និងវាលភក់ កន្លែងខ្លះមានបឹងត្រពាំង ជាប់នឹងតំបន់ទីមួយ។ តំបន់ទីបីជាដីវាលរាប មានស្រែ លាតសន្ធឹងឆ្ងាយពីតំបន់ទឹកលិច នៅលើផ្ទៃដីដទៃទៀតនៃទំនាបកណ្តាល។

តំបន់ខ្ពស់ ជាតំបន់ខ្ពង់រាប ឡើងចំណោទថ្មមៗ ពីភូមិភាគវាលរាបកណ្តាល ឆ្ពោះទៅព្រំដែនខាងជើង និងទិសខាងលិច។ ភូមិភាគនោះ គ្របដណ្តប់ដោយព្រៃល្បោះ ហើយកកើតឡើងដោយដីល្បាប់ចាស់។ កន្លែងខ្លះមាន ថ្ម គ្រួស ស្ថិតនៅផ្នែកខាងកើត ដូចជានៅខេត្តកំពង់ចាម។ គេជួបនឹងថ្មបាសាល់ ដែលមានសមាសភាពគ្រប់ដណ្តប់ នៅផ្ទៃដីខាងលើដោយដីក្រហមៈ តំបន់ទាំងនោះ សុទ្ធសឹងតែគ្រប់ដណ្តប់ទាំងស្រុង ដោយដំណាំកៅស៊ូ។

នៅតាមខ្ពង់រាបនៃបរិវេណតាមព្រំដែន គឺជាភ្នំ តភ្ជាប់ពីប្រទេសថៃ និងវៀតណាម។ នៅភាគពាយ័ព្យ ជួរភ្នំដងរែក កំណត់បញ្ជាក់ព្រំដែនជាមួយប្រទេសថៃ។ នៅឥសាន្ត កន្ទបជាភ្នំនៃភាគកណ្តាលវៀតណាម ដែល បន្តលូតចូលមកក្នុងខេត្តរតនគីរី ហើយខ្ពង់រាបដាក់ឡាក់របស់វៀតណាម ក៏បន្តជាប់នឹងខ្ពង់រាបឆ្លូងលើ នៃខេត្ត មណ្ឌលគីរី។ ខ្ពង់រាបទាំងនោះ ក៏សុទ្ធតែគ្រប់ដណ្តប់ដោយឡែកៗ ដោយសមាសភាពបាសាល់ នៃដីក្រហម គេឃើញមានដំណាំកៅស៊ូនៅទីនោះដែរ។

លោក Delvert បានឱ្យនិយមន័យ និងបានសិក្សានូវ " កម្ពុជា ដ៏មានប្រយោជន៍ " ហើយបានបញ្ជាក់ច្បាស់លាស់ជាងនេះទៅទៀតគឺ " កម្ពុជាដែលមានមនុស្សរស់នៅច្រើន " នោះគឺតំបន់វាលរាបកណ្តាល និងតំបន់ ដែលសម្បូរទៅដោយដីជាតិបាសាល់ នៅភូមិភាគខាងកើតនៃតំបន់ខ្ពង់រាប។ កម្ពុជាផ្នែកនេះ មានផ្ទៃដីប្រហែល ៥ លានហិចតា ជិតស្មើនឹង ១,៣ នៃផ្ទៃដីកម្ពុជាទាំងមូល។

ប្រភេទដីកម្ពុជា បើប្រៀបធៀបជាទូទៅ មិនសូវល្អសម្រាប់កសិកម្មនោះទេ។ដីបាសាល់ ឬហៅថាដីជី មានសមាសភាពបាសាល់ ដូចជា ដីក្រហម ដីប្រផេះ ដីខ្មៅ គឺជាប្រភេទដីមានជីជាតិល្អ ដោយឡែក។ នៅមានប្រភេទដីល្បាយគ្រួស ស្រួយហើយធូន់ ដែលជាប្រភេទដីស្អិត

ពិបាកភ្ជួររាស់ ដាំដុះ ហើយដីក្រហមទៀតសោតក៏មិនសូវល្អដល់ការដាំដុះស្រូវដែរ។ ដីមាត់ច្រាំងទន្លេ ដីភូមិ ដីចំការដំណាំមាត់ទន្លេ ទទួលល្បាប់ គឺជាប្រភេទដីល្អ។ ប្រភេទដីល្បាប់លាយគ្រួស ដែលនៅភាគខ្លះនៃខេត្តបាត់ដំបង ក៏មានជីជាតិដែរ។ ផ្ទៃដីសរុប ដែលជាប្រភេទដីល្អបានត្រូវប៉ាន់ស្មានប្រហែល ១ លានហិចតា គឺស្មើនឹង ១,៥ នៃផ្ទៃដីវាលរាបកណ្តាល និងផ្ទៃដីខ្ពង់រាបដែលបានដាំដុះ។

ជាសំខាន់ ដីនានានៅតាមវាលទំនាបប្រទេសកម្ពុជា ខ្សោះគ្មានជីជាតិ៖ ដីខ្សាច់ គ្រួស ឬដីឥដ្ឋ ហើយ នៅ រដូវប្រាំង រឹងដូចឥដ្ឋ។ ដីទាំងនោះជាដីសម្រាប់ដាំឈើ ល្អជាងដាំស្រូវ។

ក្រៅពីទិដ្ឋភាពដី ឬប្រភេទដី ធាតុអាកាសក៏មានសារៈសំខាន់ ដល់កសិកម្ម និងសេដ្ឋកិច្ចកម្ពុជាដែរ។

## ១.៤.២.អាកាសធាតុ

ប្រទេសនេះ មានរបបអាកាសធាតុខ្យល់មូសុង នៃតំបន់ប្រទេសក្តៅនៅទ្វីបអាស៊ី។ កម្រិតកម្តៅ មិនផ្លាស់ប្តូរច្រើនទេនៅក្នុងរយៈពេលមួយឆ្នាំៗ លើកលែងតែនៅតំបន់ភ្នំ។ ជាមធ្យម កម្តៅប្រចាំឆ្នាំក្នុងតំបន់វាលរាប គឺខ្ពស់ជាង ២៧ អង្សាសេ ។ នៅខែមីនា មេសា កម្តៅឡើងខ្ពស់ នៅខែវិច្ឆិកា ធ្នូ ជាតុអាកាសមិនសូវក្តៅទេ ហើយចន្លោះនៃការផ្លាស់ប្តូរកម្តៅមានកម្រិតតែ ៤ អង្សាសេ ប៉ុណ្ណោះ។

ខ្យល់រដូវ ជាអ្នកបញ្ចប់នូវរបបទឹកភ្លៀង ហើយជាការចាប់ផ្តើមនូវរដូវថ្មី។ ពីខែវិច្ឆិកា ដល់ខែមេសា ខ្យល់បក់មកពីទិសឥសាន្ត៖ គឺជាខ្យល់រដូវត្រជាក់ ហើយធ្វើឱ្យត្រជាក់តែមិននាំភ្លៀងមកទេ។ រដូវនេះជារដូវក្តៅ ។ តាមលោក Delvert ខ្យល់រដូវត្រជាក់បក់មកពីខែវិច្ឆិកា ដល់ មករា ហើយការពិតរដូវក្តៅនេះចែកជារដូវតូចពីរទៀត គឺ៖ រដូវរំហើយពីខែវិច្ឆិកា ដល់ មករា ធ្វើឱ្យមនុស្សពេញចិត្ត ហើយធ្វើឱ្យស្រូវធាប់ទុំ និងរដូវក្តៅពីខែមករា ដល់ មេសា ធ្វើឱ្យមនុស្សលំបាកនឿយហត់ ហើយធ្វើឱ្យដំណាំក្រៀមក្រោះ។ពីខែឧសភា ដល់ កញ្ញា ខ្យល់បក់ពីទិសនិរតី ក្តៅ ហើយសើម៖ ជាខ្យល់រដូវផ្ការីក និងជារដូវភ្លៀង។

អាកាសធាតុនៅកម្ពុជា សម្រួលដោយពិតប្រាកដដល់ការរីកលូតលាស់នៃធម្មជាតិ។ ក៏ប៉ុន្តែ ក៏មិនអាចចាត់ទុកទាំងអស់ថាសុទ្ធតែមានភាពប្រសើរដល់កសិកម្មដែរ។ជាពិសេសសម្រាប់បង្កើនរដូវដាំដុះដំណាំស្រូវ។

បរិមាណទឹកភ្លៀងដែលបានធ្លាក់ចុះមកកាន់តំបន់វាលរាបកណ្តាលមានកម្រិតទាបបង្គួរ៖ ពី ១,២០០ ដល់ ១,៦០០ មម នៅតាមស្ថានីយ៍ទឹកភ្លៀងនានា " ចំណែកឯនៅ សៃហួន និងបាងកក មានកំពស់ ២,០០០ មម "។ មានតែតំបន់ភ្នំ និងតំបន់គ្មានជីជាតិនៃជួរភ្នំក្រវាញ តំបន់ទួលនៅភាគខាងជើង ដែលទទួលបានការស្រោចស្រពបរិបូរណ៍។ ភូមិភាគវាលរាប ដូចគេបានបញ្ជាក់ថា គឺជា " ម្លប់នៃទឹកភ្លៀង " ។

បរិមាណទឹកភ្លៀងខ្វះខាតហើយថែមទាំងធ្លាក់មិនទៀតទាត់ហើយមិនស្មើតាមពេលវេលាទៀតផង។ រដូវប្រាំងមានរយៈពេលវែង ហើយមានភាពតឹងតែងណាស់៖ ពីថ្ងៃទី ១ ធ្នូ

ដល់ថ្ងៃទី ១ ឧសភា ភ្លៀងធ្លាក់តែ ២០០ មម ប៉ុណ្ណោះ។ វាលេចចេញនូវលទ្ធផល លើកលែងតែករណីខ្លះនៃភាពមិនទៀងទាត់របស់ទឹកភ្លៀង ពីខែធ្នូ ដល់ មេសា ការដាំដុះមិនសូវមានលទ្ធភាពទេ។

បន្ថែមពីលើបញ្ហានានា ការធ្លាក់ទឹកភ្លៀងទីមួយ នាខែឧសភា មិថុនា ក៏មិនជាក់លាក់ថែមទៀត ដល់ការភ្ជួររាស់ និងការសាបព្រោះស្រូវ ហេតុនេះគេត្រូវរង់ចាំទឹកភ្លៀងថែមទៀត។

នៅខែកក្កដា និងសីហា ក្នុងពេលដែលស្រូវត្រូវការទឹក ដើម្បីដុះលូតលាស់ ប្រទេសកម្ពុជាត្រូវជួបប្រទះ គ្រោះរាំងស្ងួត ឬទឹកជំនន់លិចលង់ " សីហា ១៩៩១ ដល់ សីហា ១៩៩៤ " ដោយសារបរិស្ថានប្រែប្រួល ព្រោះ តំបន់ភ្នំបាត់បង់ព្រៃឈើ។ នោះជារដូវរាំងស្ងួតតូចមួយ ដូចនេះគេអាចនិយាយបានថាជា " ភាពពិការដ៏សំខាន់មួយ" នៃការដាំដុះស្រូវនៅកម្ពុជា។

គ្មានអ្វីដែលគួរឱ្យសង្ស័យថាគ្មានសារៈសំខាន់នោះឡើយ នៅពេលដែលយើងបញ្ជាក់ពីចំណុចជាយថាហេតុនានា។ បើសិនជាអាកាសធាតុនៅតំបន់ក្ដៅធ្វើឱ្យមានភាពងាយស្រួលក្នុងដំណោះស្រាយបញ្ហានានា ដូចគ្រឿងដុត សម្លៀកបំពាក់ និងជម្រក នោះវាមានការកែប្រែសមាមាត្រជាមួយប្រទេសជាតុអាកាសត្រជាក់នូវរចនាសម្ព័ន្ធនៃតម្រូវការ និងសេចក្ដីផ្គត់ផ្គង់ចុងក្រោយ ហើយផលិតផលវានឹងលើកទឹកចិត្តដល់មនុស្ស និងសេដ្ឋកិច្ចជាតិ ជាឈ្នាន់ដែលមានស្ថេរភាពនៅទីនោះ។ អាថ៌កំបាំងធម្មជាតិ មិនមែនគ្មានសារៈសំខាន់ក្នុងសេដ្ឋកិច្ចជាតិនោះទេ អាកាសធាតុនៅកម្ពុជាធ្វើឱ្យមានពលកម្មនិងការខិតខំដ៏លំបាកខ្លាំងណាស់។

ប្រភពជលសាស្ត្រ អាចកែលម្អដោយឡែក ដល់ការខ្វះខាតនៃអាកាសធាតុ។

## ១.៤.៣.ជលសាស្ត្រ និងទឹកជំនន់

សារៈសំខាន់នៃទន្លេ បឹង ស្ទឹង និងចរិតរបស់វា បានត្រូវចាត់ទុកថាមានប្រយោជន៍ ដល់សេដ្ឋកិច្ច កម្ពុជា។ គម្រោងនានាក្នុងនោះមានគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម របស់គណៈកម្មាធិការទន្លេមេគង្គ បានចាត់ចែងជុំវិញបញ្ហាធ្វើឱ្យ មានតម្លៃឡើងដល់ទន្លេមេគង្គ។

ចន្ទ្រទឹកកម្ពុជាមានច្រើន ហើយមានប្រយោជន៍ដែលអាចចែកចេញជា បីអាងសំខាន់ៗ៖

**១.អាងឈូងសមុទ្រថៃ** មិនតំណាងឱ្យផលប្រយោជន៍ទេ បើពិនិត្យលើចំណុចសេដ្ឋកិច្ចជាការប្រមូលផ្ដុំនូវជំរាលទឹកធ្លាក់ ដែលមានកំណើតនៅក្នុងជួរភ្នំក្រវាញ ហើយធ្លាក់ទៅក្នុងឈូងសមុទ្រថៃ។ ប៉ុន្តែវាអាចផ្ដល់ជាថាមពលវារីអគ្គិសនី ដូចជាទំនប់ភ្នំកំចាយនៅខេត្តកំពត ដែលបានរៀបចំកសាងម្ដងរួចមកហើយ នៅចុងទសវត្ស ឆ្នាំ ១៩៦០ ។

**២.អាងទន្លេមេគង្គ ឬទន្លេធំ** គឺមានសារៈសំខាន់ណាស់ ។ ទន្លេមេគង្គប្រវែង " ៤,២០០ គ.ម." ស្រោច ស្រពកម្ពុជា ចម្ងាយ ៥០០ គ.ម.ដែលគេហៅថា ទន្លេធំ ។ គេអាចបែងចែកទន្លេជាពីរផ្នែក៖

**២.១.**ទន្លេមេគង្គលើ គិតចាប់ពីក្រចេះ ឡើងតាមចន្ទទន្លេមេគង្គ ដែលនាវាមិនអាចបើកបរបានមានដុះថ្ម ពេញផ្ទៃទន្លេ ដែលអាចសង់ទំនប់វារីអគ្គិសនី មានការចាប់ផ្ដើមសិក្សា តាំងពីដើមឆ្នាំ ១៩៦០ មក" នៅ សម្បូរ និងស្ទឹងត្រែង " ។

**២.២.**ទន្លេមេគង្គក្រោម ចាប់ពីក្រចេះ នាវាអាចបើកបរ រហូតដល់សមុទ្រ។ នៅភ្នំពេញ ទន្លេមេគង្គបានទទួលដៃទន្លេឈ្មោះ ទន្លេសាប ហើយក៏មានការបែកចេញជាដៃមួយទៀតឈ្មោះថា ទន្លេបាសាក់ ដែលគេហៅទន្លេទាំងនេះថា ទន្លេចតុមុខ ។ ទីនេះមានដីសណ្តរទន្លេមេគង្គ ដែលមានដៃច្រើន កើតជា កោះ និងជាដីខ្សាច់ស ហើយចេះតែបន្តរហូត ដល់ប្រទេសវៀតណាម។

**៣.អាងទន្លេសាប** មានប្រភពដើមតាមទិសកំណត់ ដែលជាទន្លេសាបមានបឹងធំ ឬជាបឹងបន្តបន្ទាប់ រាងដូចវីយូឡុង។ ដៃទន្លេសាប គឺមានស្ទឹងភ្ជាប់ជាច្រើន។

ប្រព័ន្ធជលសាស្ត្រកម្ពុជាសម្បូរបែប ហើយបង្កើតបានជាប្រយោជន៍ល្អដល់ប្រទេស៖ ការនេសាទ ការដឹកជញ្ជូន ការបញ្ចូលទឹកចូលស្រែ និងថាមពលវារីអគ្គិសនី មានភាពងាយស្រួលណាស់។

ប៉ុន្តែ គឺចរិតនៃរបបទឹក គឺទឹកជំនន់ប្រចាំឆ្នាំទេ ដែលផ្តល់មុខមាត់ទៅផ្នែកជលសាស្ត្រកម្ពុជា ហើយបញ្ជាក់នូវសារៈប្រយោជន៍ នៃសេដ្ឋកិច្ច។

ជាអនុភាព ជារៀងរាល់ឆ្នាំ ទន្លេនានានៅកម្ពុជា ពិសេសទន្លេមេគង្គមានទឹកជំនន់។ មេគង្គដែលរីងស្ងួតនៅខែមីនា និងមេសា បានចាប់ផ្តើមឡើងទឹកចាប់ពីខែឧសភា។ នៅខែមិថុនា មានការកើតឡើងនៅចតុមុខ នូវបាតុភូតដ៏ល្បី គួរឱ្យឆ្ងល់ និងមានសារៈសំខាន់៖ ទឹកជំនន់ឡើងមួយផ្នែកនៃទន្លេមេគង្គ ហូរចូលធម្មតាតាមចរន្តមេគង្គ និងទន្លេបាសាក់ តែមួយផ្នែកទៀតបានរុញច្រានទឹកទន្លេសាប បំបែរចរន្តក្នុងរយៈពេល ៤ខែ ធ្វើឱ្យអាងទឹក ទន្លេសាប ក្លាយជាផ្នែកទទួលទឹកពីទន្លេមេគង្គ។ ពេលនោះជំនន់ទន្លេមេគង្គចេះតែមានបន្ត។ ទឹកមានកម្រិតខ្ពស់ខ្លាំងនៅខែកញ្ញានិងតុលា។ ទឹកស្រកចាប់ផ្តើមយ៉ាងលឿនហើយទៀងទាត់ជាងទឹកជំនន់។

ទោះបីទន្លេនៅកម្ពុជាទទួលបានទឹកជំនន់ ជាសារៈសំខាន់ក៏ដោយ ដោយឡែក ទឹកទន្លេមេគង្គហូរជាធម្មតាតាមចន្លោះច្រាំងទាំងពីរ ដែលនៅទំនាបក្រោយច្រាំងទាំងពីរនោះ មានវាលទំនាប ហើយកន្លែងខ្លះជាបឹង ហើយនៅឆ្ងាយពីបឹងនោះទៅ គឺជាតំបន់ស្រែ។ បឹង ត្រពាំងទាំងនោះតភ្ជាប់ទៅកាន់ទន្លេ កាត់តាមទួលមាត់ច្រាំងដោយសារព្រែក ជួនកាលជាព្រែកធម្មតា ជួនកាលជាព្រែកជីក ជាទូទៅព្រែកទាំងនោះ មានសភាពជ្រៅ។

នៅពេលទឹកទន្លេឡើងហូរចូលតាមព្រែកទៅបំពេញបឹង ត្រពាំង និងដីស្រែទៅតំបន់វាលរាប បាតុភូតទាំងនោះ កើតឡើងដោយសារភ្លៀងដែលធ្លាក់ ដែលបង្កឱ្យមានទឹកជំនន់។

ផ្ទៃដីត្រូវទឹកជំនន់ជារៀងរាល់ឆ្នាំពីខែសីហា ដល់ តុលា ហើយទឹកមានសភាពទូលាយណាស់។ ទឹកលិចជាមធ្យមប្រហែល ២ លានហិចតា ត្រូវនឹង ១,៣ នៃផ្ទៃដីវាលរាបកណ្តាល។ បឹងទន្លេសាបពេលនោះ ក្លាយទៅជាសមុទ្រជ្រៅកណ្តាលប្រទេស ហើយអាចឱ្យនាវាចរាចរបាន។ ចាប់ពីខែតុលា ទឹកស្រកនាំឱ្យមានការកើនឡើង នូវភាពក្តៅស្ងួតនៅតំបន់ទឹកលិចទាំងនោះ។

តើអនុភាពសេដ្ឋកិច្ចនៃទឹកជំនន់មានអ្វីខ្លះ?

ទឹកជំនន់ កំណត់នូវដំណាំ។ បើសិនជាជម្រៅទឹកកើនឡើងខ្ពស់ជាង ១០ ម គេមិនអាចដាំដុះស្រូវធម្មតា ដែលហៅថាស្រូវវស្សា ឬស្រូវស្លងបានទេ តែគេអាចដាំស្រូវឡើងទឹក ដែលមានដើមលូតលាស់ រហូតដល់ ៣ ម ទៅ ៤ ម បាន នៅក្នុងករណីដែលទឹកឡើងមិនសូវលឿនហើយគេដាំស្រូវប្រាំងនៅពេលដែលទឹកស្រក នៅរវាងខែវិច្ឆិកា និងឧសភា។បើសិនជាជម្រៅទឹកទាបជាង ១ ម ការដាំដុះស្រូវធម្មតាមានលទ្ធភាពល្អ។

ទឹកជំនន់កែប្រែគុណភាពដី។ ជាអនុភាពទឹកទន្លេមេគង្គដែលជន់លិចវាលទំនាប បាននាំដីល្បាប់មកចាក់បំពេញ បង្គរ ហើយកែប្រែដីនោះ ទៅជាដីមានជីជាតិល្អ។ សកម្មភាពដែលធ្វើឱ្យដីមានជីជាតិនេះ កើតមានជាទូទៅ នៅតាមដីប្រហែលជា ២ គម ពីច្រាំងទន្លេ គឺស្ថិតនៅតាមច្រាំង និងដីដុះបន្ទាប់ពីច្រាំងទន្លេនោះ ជាដីមានជីជាតិបំផុតរបស់ប្រទេស។

ជំនន់ នាំឱ្យមានផលនេសាទល្អ។ តាមរយៈព្រែក ត្រីហែលចូលទៅកាន់តំបន់ទឹកលិចដែលនៅទីនោះ លក្ខខ័ណ្ឌនៃការពងកូនប្រព្រឹត្តទៅបានសមស្រប។ នៅពេលទឹកស្រក គេអាចចាប់ត្រីបានយ៉ាងងាយស្រួល។ ការនេសាទត្រីទឹកសាប ប្រព្រឹត្តទៅនៅក្នុងលក្ខខ័ណ្ឌល្អណាស់នៅកម្ពុជា។តទៅទៀត មេរៀនក៏ចាំបាច់ត្រូវរំលឹកថែមទៀត អំពីប្រភពធនធានរ៉ែនៅកម្ពុជា។

### ១.៤.៤.ប្រភពធនធានរ៉ែ

រហូតមកដល់បច្ចុប្បន្នការស្រាវជ្រាវតាមបែបបទរុករកប្រភពធនធានរ៉ែក្នុងដីនៃកម្ពុជា មិនទាន់បញ្ចប់ នៅឡើយទេ។ ពេលខ្លះគេអាចរក្សាបាននូវការភ្ញាក់ផ្អើលជាច្រើនដែរ។ អត្ថិភាពនៃប្រភពធនធាន ប្រេងកាត និងឧស្ម័នធម្មជាតិត្រូវបានគេសន្មត់ថាមានច្រើន។ ពួកក្រុមហ៊ុនពហុជាតិ សង្ឃឹមថាអាចនឹងជីកយកប្រេងកាត និងឧស្ម័នធម្មជាតិ នៅក្នុងខ្ពង់រាបសមុទ្រកម្ពុជា។

ត្បូងមានតម្លៃ បានត្រូវជីកនៅតំបន់ប៉ៃលិន និងបរកែវ ជាផលិតផលថ្មមានតម្លៃ ដែលសព្វថ្ងៃមានតួនាទីសេដ្ឋកិច្ច ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម បានត្រូវធ្វើអាជីវកម្ម ដោយអាណាធិបតេយ្យ ដោយក្រុមហ៊ុនក្នុងកម្រិត ៥០ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗ។

កម្ពុជា មានភ្នំដែកនៅខេត្តកំពង់ធំ ដែលមានបរិមាណវត្ថុធាតុដើមប្រមាណ ៥ លានតោន។ ប្រភពធនធាននេះពិបាកក្នុងការចូលទៅធ្វើអាជីវកម្មណាស់ ដោយសារខ្វះរបនាសម្ព័ន្ធ និងសន្តិសុខ។

កម្ពុជា ក៏មានរ៉ែផូស្វាត នៅតំបន់ទូកមាស ខេត្តកំពត និងនៅខេត្តបាត់ដំបង " សព្វថ្ងៃបន្ទាយមានជ័យ " ដែលមានភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម។

ការធ្វើសារពើភ័ណ្ឌនៃប្រភពធនធាននានានៅកម្ពុជា អនុញ្ញាតឱ្យគេគូសវាសបាននូវតារាង សេដ្ឋកិច្ច កម្ពុជា។ នៅក្នុងប្រទេសមិនសូវរីកចម្រើនដូចកម្ពុជា ក្រោយសង្គ្រាមរយៈពេលពីរទសវត្ស សេដ្ឋកិច្ចមិនស្ថិតនៅ ឆ្ងាយពីភូមិសាស្ត្រ របស់ខ្លួនទេ។

## ១.៥.ក្រុមខ័ណ្ឌប្រជាសាស្ត្រ

ក្នុងប្រទេសមួយចំនួន មនុស្សប្រុស អាយុ គុណសម្បត្តិ ការបែងចែកតាមតំបន់រស់នៅ មុខរបរ និងកំណើតរបស់គេសុទ្ធតែជាកត្តានៃតួលេខ ដែលជះឥទ្ធិពលទៅលើជីវភាព និងការវិវដ្ត សេដ្ឋកិច្ចរបស់ប្រទេស។ ដោយសារសារៈសំខាន់នោះហើយ ដែលធ្វើឱ្យយើងចាប់ផ្ដើមសិក្សាអំពី ប្រជាពស្ត្រនៅកម្ពុជា។

ដើម្បីធ្វើកាសិក្សា គេត្រូវមានប្រភពបីសំខាន់ៗ៖ ការសន្និដ្ឋាន ការអង្កេតពីអ្នកដំណើរ លទ្ធផលអង្កេតជាផ្នែកៗ។ តែគេក៏ត្រូវយកចិត្តទុកដាក់ផងដែរ ដល់ការប្រើប្រាស់នូវប្រភព ស្រាវជ្រាវទាំងនោះ ដោយប្រុងប្រយ័ត្ន។

**ទីមួយ** គឺការធ្វើជំរឿន ជាគោលការណ៍លម្អិតស៊ីជម្រៅកាលពីឆ្នាំ ១៩២១ ដោយសេវាកម្មរបស់ពួក អាណានិគមដោយមិនត្រឹមត្រូវចំពោះចំនួនមនុស្សទេ តែបានផ្ដល់នូវការបែងចែក ប្រជាជនតាមភូមិសាស្ត្រ រចនាសម្ព័ន្ធ តាមអាយុ និងជនជាតិភាគតិចរបស់ជាតិ។

**ទីពីរ** គឺការធ្វើអង្កេត។ មានការធ្វើអង្កេតពីរ ប្រព្រឹត្តទៅនៅឆ្នាំ ១៩៥៨ និង១៩៥៩ នៅក្នុងភូមិ ចំនួន ៣៥,០០០ ដោយមានការជ្រើសរើសតាមបែបវិទ្យាសាស្ត្រ។ ការអង្កេតទាំងនោះ នាំមកនូវភាពច្បាស់លាស់សំខាន់ៗ ស្ដីពីប្រជាជនសកម្ម និងចលនារបស់ប្រជាជន។

**ទីបី** គឺជំរឿនជាលម្អិត ប្រព្រឹត្តទៅនៅកាលពីឆ្នាំ ១៩៦២ ហើយនៅក្នុងពេលនោះ មានសំនួរធំៗមួយចំនួនបានចោទឡើង ស្ដីពី អាយុ ស្ថានភាពលុយកាក់ និងវិជ្ជាជីវៈ កម្រិតចេះដឹង។ល។ លទ្ធផលនៃការជំរឿននោះ បានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៦៦ បាននូវព័ត៌មានជាច្រើន ស្ដីអំពីប្រជាជននៅកម្ពុជា។

ការសាកល្បងបង្ហាញអំពីប្រជាជននេះ ត្រូវឆ្លើយនឹងសំនួរបួន គឺ៖

- ប្រជាជននេះ មានចំនួនប៉ុន្មាន? មានបញ្ហាចោទឡើងច្រើន ពីការវិវដ្ត នៃប្រជាជនខ្មែរ មុនសង្គ្រាម និងក្រោយសង្គ្រាម។
- តើប្រជាជននោះរស់នៅកន្លែងណា?តើយើងបានដឹងអ្វីខ្លះអំពីការបែងចែកប្រជាជនតាមភូមិសាស្ត្រ?
- តើប្រជាជននោះធ្វើអ្វីខ្លះ? គឺការនាំទៅដល់ការចោទសំនួរ ស្ដីអំពីប្រជាជនសកម្មរបស់ប្រទេស។
- តើពួកគេជានរណា? និយាយពីទិដ្ឋភាពផ្សេងៗនៃផ្នែកសង្គម វប្បធម៌ នៃប្រជាជន។

### ១.៥.១.ទិដ្ឋភាពប្រជាសាស្ត្រទូទៅ

ដោយសារជំរឿននាឆ្នាំ១៩៦២ គេប្រមូលបានតួលេខជាបរិមាណសឹងតែច្បាស់លាស់ស្ដីអំពីប្រជាជន កម្ពុជា ។ ស្ថិតិ " អ៊ុនតាក់ " សម័យកាលមុនថ្ងៃបោះឆ្នោតទូទៅនាខែឧសភា ១៩៩៣ ក៏បានបញ្ជាក់កាន់តែច្បាស់ ថែមទៀតនូវការវិវដ្តប្រជាសាស្ត្រកម្ពុជា ឆ្លងកាត់វិនាសកម្ម

ជាងពីរទសវត្ស។ ការសិក្សាប្រព្រឹត្តទៅជាបន្តបន្ទាប់ នៅផ្នែកផ្សេងៗទៀត ដែលឱ្យនិយមន័យ ដល់ចលនារបស់ប្រជាជន ហើយចុងបញ្ចប់ការវិវដ្តជាបរិមាណទូទៅ នៃប្រជាជនកម្ពុជា។

### ក.រចនាសម្ព័ន្ធ អាយុ និងភេទ

ស្ថានភាពនៃប្រជាជនកម្ពុជា ជាបឋមគេឱ្យនិយមន័យតាមអាយុ និងតាមភេទ។ ស្ថានភាពនោះអាច គូសវាស់តាមពីរ៉ាមីតអាយុ។ ក្នុងសំណុំពីរ៉ាមីតយោង អាយុស៊ីមេទ្រីគ្នាហើយស្របទៅតាមភេទ។ សមាសភាព នោះមានភាពធម្មតា ហើយឆ្លុះបញ្ចាំងនូវចលនាធម្មជាតិរបស់ប្រជាជននោះ។ ព្រឹត្តិការណ៍សង្គ្រាម ទុរភិក្ស ដែល ធ្វើឱ្យរំជួយសមាសភាពនោះ និងចលនាអន្តោប្រវេសន៍អន្តរជាតិ និងរួមចំណែកធ្វើឱ្យមានការប្រែប្រួលយ៉ាង សំខាន់ដល់រូបភាពនៃពីរ៉ាមីត។

ក្នុងការលម្អិតពីរ៉ាមីត បង្ហាញពីភាពមិនទៀងទាត់នៃតួលេខនៃជំរឿន ដែលបញ្ចេញឱ្យឃើញថា ប្រជាជនមានអាយុពី ៤ ទៅ ៩ ឆ្នាំ មានចំនួនច្រើនជាងប្រជាជនមានអាយុ ០ ឆ្នាំ ដល់ ៤ ឆ្នាំ។ ការខូចខាតចន្លោះនេះ ពន្យល់ដោយឡែកបាន ដោយការប្រព្រឹត្តទៅនៃអ្នកអង្កេតនានាដែលបានរៀបចំ បែងចែកកុមារ អាយុលើសពី ៤ ឆ្នាំ និងតិចជាង ៩ ឆ្នាំ ដាក់ចូលទៅក្នុងក្រុមអាយុ ៥-៩ ឆ្នាំ ពីព្រោះថាកុមារជាច្រើនមានអាយុក្រោម ១ ឆ្នាំ មិនទាន់បានចុះនៅក្នុងបញ្ជីនៅឡើយ។ ជាប្រពៃណីនៅកម្ពុជា ការរាប់អាយុគិតត្រឹមតែពីក្បាលឆ្នាំ ទោះបីទារក ទើបនឹងកើតបានជាង ១ ឆ្នាំ កន្លះ ក៏រាប់ជា ២ឆ្នាំ ទៅហើយ។ការខ្វះចន្លោះផ្សេងទៀត គឺភាពខុសគ្នារវាងប្រជាជន អាយុពី ១០ ទៅ ១៥ ឆ្នាំ និងភាពខុសសគ្នារវាង អាយុពី ១៥ ទៅ ២០ ឆ្នាំ។ មានកុមារអាយុលើសពី ១៥ ឆ្នាំ បែរជាប្រកាសថាអាយុតិចជាង ១៥ ឆ្នាំ ដោយខ្លាច គ្មានសិទ្ធិចូលរៀន។ រចនាសម្ព័ន្ធតាមអាយុ ត្រូវបានសរុបលើតារាងបញ្ជាក់ដូចតទៅ៖

**តារាង១.១ រចនាសម្ព័ន្ធតាមអាយុ នៃយុវជនរបស់កម្ពុជា**

| អាយុ | ប្រជាជន (%) |
|---|---|
| ០ - ១៩ | ៥៣ |
| ២០ - ៥៩ | ៤២ |
| ៦០ - | ៥ |

តួលេខទាំងនេះ បង្ហាញពីលក្ខណៈសំខាន់នៃរចនាសម្ព័ន្ធតាមអាយុនៃយុវជនរបស់កម្ពុជា។

### ខ.អត្រាកត់សម្គាល់

ដោយសារតែភាពមិនច្បាស់លាស់ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន បញ្ជីជាតិកំណើត និងបញ្ជីមរណៈភាពនៅកម្ពុជា ហើយមិនអាចយកជាមូលដ្ឋានគិតគូរ ដល់អត្រាដែលបានបញ្ជាក់ពីចលនារបស់ប្រជាជន គេយកជាការបានតែចំពោះលទ្ធផលនានានៃការអង្កេត ដែលប្រព្រឹត្តទៅនៅឆ្នាំ ១៩៥៨ ១៩៥៩ ១៩៦២ និងមុនខែឧសភា ១៩៩៣ របស់អ៊ុនតាក់។

### ខ.១ កំណើត

អត្រាកំណើតរស់ នាឆ្នាំ ១៩៥៨-១៩៥៩ ផ្តល់តួលេខ ៤២% ហើយតាមជំរឿនឆ្នាំ ១៩៦២ ដែលខិតខំរកកំណើតក្នុងរយៈពេលមួយឆ្នាំ ផ្តល់តួលេខ ៤០% ។ អត្រាទាំងនេះ សុទ្ធតែខ្ពស់ បើប្រៀបធៀបទៅនឹងអត្រាកំណត់សម្គាល់នៅប្រទេសអឺរ៉ុប តែជាអត្រាទាប បើគេមើលធៀបនឹងតួលេខនៅឯ ទ្វីបអាហ្វ្រិក និងអាមេរិក ព្រមទាំងតួលេខប្រទេសនៅអាស៊ីអាគ្នេយ៍។ អត្រា ៤០‰ ទៅ ៤២‰ នោះ គឺជាអត្រាកំណើតនៅកម្ពុជាពិតឬទេ? ដូចគេបានដឹងហើយថាអត្រាកំណើតបានផ្តល់ឲ្យនូវបាតុភូតជាគំនិតប្រហាក់ប្រហែលប៉ុណ្ណោះប្រជាជនទាំងអស់ រួមមានមនុស្សជាច្រើន ទាំងកុមារ ទាំងចាស់ទុំ ហើយស្ថិតនៅក្នុងស្ថានភាពខុសៗគ្នា។

ការប្រើប្រាស់ " អត្រាកំណើតពិសេស " ដែលហៅថា អត្រាកំណើត អាចឱ្យយើងដឹងបង្ហួរពីបាតុភូតនោះ។ នៅលើមូលដ្ឋាននៃជំរឿនឆ្នាំ ១៩៦២ អត្រាកំណើតទូទៅ គឺ ១៧៥% ដែលនេះ គឺជាអត្រាទាប ចំពោះ ប្រទេសក្តៅ។ នៅអាហ្វ្រិក អាមេរិកឡាទីន អត្រាកំណើតមានចំនួន ២៥០% ។

អត្រាកំណើតទូទៅ គឺជាចំនួនកុមារកើតមករស់ ក្នុងរយៈពេលមួយឆ្នាំ ចែកនឹងចំនួនប្រជាជនភេទស្ត្រី ដែលមានអាយុពរពោះបាន គឺស្ត្រីមានអាយុចន្លោះ ១៥ ទៅ ៤៩ ឆ្នាំ។

បាតុភូតទាំងនោះ អាចពន្យល់បាន ដោយសារការខ្វះខាតនៃការចុះបញ្ជីកំណើត។ ក្នុងករណីនេះអត្រាដែលបានគិតគូរ ពិតជាមានកម្រិតទាបជាងអត្រាពិត។ មានបញ្ហាពីរត្រូវយកមកគិត គឺការពន្លូតកូន និងការធ្វើមិនឱ្យមានកូន តែមិនសូវកើតមានបែបនេះទេនៅកម្ពុជា ជាពិសេសនៅទីក្រុង។ មានបាតុភូតបញ្ជាក់ថា ៨៣% នៃស្ត្រីដែលមានអាយុពី ១៥ ទៅ ២០ឆ្នាំ និង៣២% នៃស្ត្រីដែលមានអាយុពី ២០ ទៅ ២៥ មិនទាន់រៀបការ។ ស្ត្រីមេម៉ាយក៏ច្រើនដោយសារសង្គ្រាម។ ក្រោយឆ្នាំ ១៩៧៩ ស្រីមានចំនួន ៦០% នៅក្នុងសង្គម ក្នុងនោះស្ត្រីមេម៉ាយមានកម្រិតខ្ពស់។ កំណើតខុសច្បាប់មានចំនួនតិចតួចទេនៅកម្ពុជា។

ការពន្យល់នូវបាតុភូតនានា មិនទាន់គ្រប់គ្រាន់នៅឡើយ ចំពោះកម្រិតទាបនៃអត្រាកំណើតដែលបានចុះក្នុងបញ្ជី ហើយអ្នកជំនាញការបានណែនាំឱ្យកែតម្រូវនូវអត្រាកំណើតទាបបែបនេះ។ ការអនុវត្តនូវអត្រាតាមអាយុនៃប្រជាជនកំណើតជាស្ត្រីភេទនាឆ្នាំ ១៩៦២ ដោយមានការបែងចែកតាមក្រុមអាយុ បានត្រូវទទួលស្គាល់ថាការសន្និដ្ឋានកំណើតនាឆ្នាំ ១៩៦២ មានការកែតម្រូវតួលេខពី ៤២% ដល់ ៤៤.៥% ។

តួលេខនោះ នៅមិនឆ្ងាយពីការពិតទេ។ យើងសន្មត់នូវអត្រាកំណើតនៅកម្ពុជានាឆ្នាំ ១៩៦២ ថាមាន តួលេខ ៤៤% ហើយអត្រាកំណើតក្រោយសង្គ្រាម ដែលធ្វើជំរឿនដោយអ៊ុនតាក់ គឺ ២.៨% នាឆ្នាំ ១៩៩៣ ។

កំណើតតាមអាយុនៃប្រជាជនជាស្ត្រីភេទនាឆ្នាំ ១៩៦២ ដោយមានការបែងចែកតាមក្រុមអាយុ បានត្រូវទទួលស្គាល់ថាការសន្និដ្ឋានកំណើតនាឆ្នាំ ១៩៦២ មានការកែតម្រូវតួលេខពី ៤២% ដល់ ៤៤.៥% ។

តួលេខនោះ នៅមិនឆ្ងាយពីការពិតទេ។ យើងសន្មត់នូវអត្រាកំណើតនៅកម្ពុជានាឆ្នាំ ១៩៦២ ថាមាន តួលេខ ៤៤%ហើយអត្រាកំណើតក្រោយសង្គ្រាម ដែលធ្វើជំរឿនដោយអ៊ុនតាក់ គឺ ២.៨% នាឆ្នាំ ១៩៩៣ ។

អត្រាស្លាប់តាមអាយុ និងភេទ មានភាពមិនច្បាស់លាស់ជាងអត្រាស្លាប់ទូទៅ។ មរណៈភាពរបស់កុមារមានចំនួន ១២៧‰ ជាអត្រាខ្ពស់ហួសហេតុ។ ស្ត្រីភេទនៅជនបទមានមរណៈភាពក្នុងអត្រាខ្ពស់នៅពេលឆ្លងទន្លេ។

### ខ.២ កំណើនធម្មជាតិ

បើអត្រាកំណើននាឆ្នាំ ១៩៦០ មានចំនួន ៤៤‰ ហើយអត្រាមរណៈភាពមាន ១៨% គឺអត្រាកំណើន ប្រជាជនពេលនោះមានចំនួន ២៦‰ ។ អត្រានេះ ប្រហាក់ប្រហែលនឹងការសន្និដ្ឋានរបស់អ៊ុនតាក់នាឆ្នាំ ១៩៩៣ មុនពេលបោះឆ្នោតទូទៅ គឺ ២៨‰ ។

ការយល់ដឹងគ្រប់គ្រាន់នៃអត្រាទាំងបីខាងលើ នាំឱ្យយើងពិចារណាលើការវិវឌ្ឍនៃប្រជាជនកម្ពុជាបាន កាន់តែច្បាស់លាស់។

## គ.ការវិវឌ្ឍបរិមាណ

ប្រជាជនកម្ពុជាក្នុងសម័យរុងរឿង ពិសេសសម័យអង្គរ ក៏គ្មានចំនួនប្រជាជនពិតប្រាកដដែរ។ គេគ្រាន់តែដឹងថាពេលនោះប្រទេសមានប្រជាជនច្រើន ឬមានចំនួនច្រើនជាងពេលបច្ចុប្បន្ន។ នៅមុនឆ្នាំ ១២០០ តួលេខមានចំនួន ១០,០០០,០០០ នាក់ វាដូចជាច្រើនណាស់សម្រាប់ពេលនោះ បើសិនយើងគិតទៅដល់ផ្ទៃដីនៃព្រះរាជាណាចក្រ ដែលធំជាងសព្វថ្ងៃប្រហែល ៥-៦ ដង។ ពិតណាស់ហើយ នៅក្នុងរយៈពេលចំនួនរាប់សតវត្ស នៃសង្គ្រាមស៊ីវិល និងសង្គ្រាមជាមួយបរទេស ពិសេសជាមួយពួកសៀម ដែលតែងតែជម្លៀសប្រជាជន ពីខេត្តដែលគេដណ្តើមបានទៅខេត្តផ្សេងៗទៀត ពេលខ្លះប្រជារាស្ត្រទាំងនោះត្រូវគេសម្លាប់រង្គាលទៀតផងនោះ គេឃើញចំនួនប្រជាជនកម្ពុជា ពិតជាថយចុះយ៉ាងពិតប្រាកដ។

ការសន្និដ្ឋានដំបូងៗ ពីបញ្ហាប្រជាជន បានប្រព្រឹត្តទៅចាប់ពីវត្តមានដំបូងរបស់បារាំង។ ប្រទេសកម្ពុជា បើនិយាយចំពោះទឹកដីសព្វថ្ងៃ មានប្រជាជនចំនួន ១,០០០,០០០ នាក់។ លោក Aymonnier ជាមនុស្សតែមួយ ដែលបានសន្និដ្ឋាននៅក្នុងសៀវភៅកំណត់ហេតុរបស់លោកថា នៅឆ្នាំ ១៩០០ កម្ពុជាមានប្រជាជន ចំនួនប្រមាណ ២,៣០០,០០០ នាក់ ក្នុងនោះខ្មែរមាន ១,២០០,០០០ នាក់ ជាង ៨០០,០០០ នាក់ទៀត ជាខ្មែរដែលត្រូវគេកាត់ខេត្តភាគខាងលិច និងខាងកើតពីកម្ពុជា ឱ្យទៅវៀតណាម និងជនអន្តោប្រវេសន៍ជាង ៣០០,០០០ នាក់។

ចេញពីតួលេខ ចំនួនប្រជាជននៅឆ្នាំ ១៩៦២ ដែលជាតួលេខមានការធានាច្បាស់លាស់ គឺគេគិតទាំងជន អន្តោប្រវេសន៍ផងដែរ។ តួលេខនោះមានចំនួនខ្ពស់ជាង។ ការជំរឿននាឆ្នាំ ១៩២១ មានចំណុចខ្វះខាតចំនួន ប្រជាជនដល់ទៅ ២០០,០០០ នាក់ ស្មើនឹង ៧%។ ចំនួន

នេះមិនច្រើនហួសពេកទេ ព្រោះការធ្វើជំរឿនរបស់ ពួកអាណានិគម មានគោលដៅផ្នែកពន្ធអាករ។

អត្រាកំណើនប្រជាជននាឆ្នាំ ១៩៦២ កំណត់ថាមាន ២៦‰ ។ ដូច្នេះប្រជាជនកម្ពុជាមានចំនួន ៨ លាននាក់ គិតដល់ឆ្នាំ ១៩៧៥។ បើអត្រាកំណើននេះថយចុះខ្លាំង " អនុភាពនៃរចនាសម្ព័ន្ធ " បញ្ជាក់ថាប្រជាជនមិនកើនឡើងរហ័សទេ។ ជំនាន់អ្នកដែលមានអាយុ ០ ទៅ ១៤ ឆ្នាំ គឺជាអ្នកទើបនឹងកើតថ្មីនោះ គឺកុមារមានចំនួនច្រើន។ នៅក្នុងរចនាសម្ព័ន្ធសព្វថ្ងៃ " សក្តានុពលកំណើន " មានសភាពខ្ពស់។

## ១.៥.២.ការបែងចែកប្រជាជនតាមភូមិសាស្ត្រ

តួលេខនៃចំនួនប្រជាជនមធ្យមក្នុង ១ គ.ម.$^{២}$ នៅក្នុងកម្ពុជា គឺ ៣៤ នាក់ វាមានកម្រិតទាប តែជាការភាន់ច្រឡំមួយ។ តាមពិតប្រជាជនកម្ពុជា មានការបែងចែកកន្លែងរស់នៅមិនស្មើគ្នាទេ។ ប្រទេសនេះផ្តល់នូវទិដ្ឋភាពមានលក្ខណៈ ជាប្រទេសដែលតំបន់ខ្លះមិនសូវមានប្រជាជននៅទេ និងភូមិភាគផ្សេងទៀតសម្បូរប្រជាជនកុះករ។ ចំណុចទីមួយ និយាយដល់សារៈសំខាន់នៃការរៀបចំបែងចែកប្រជាជន និងទីពីរ និយាយសារៈសំខាន់នៃបាតុភូតនៃការរៀបចំទីក្រុង។

### ក.ភាពអន់ថយ និងប្រជាជនកុះករនៃកម្ពុជា

ខុសពីប្រទេសនានានៅអាស៊ី ដូចជា វៀតណាម ឬចិន ដែលបញ្ហាប្រជាជនច្រើនកុះករជាមូលដ្ឋាននៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រទេសកម្ពុជា មិនមែនជាប្រទេសដែលមានប្រជាជនរស់នៅច្រើនកុះករនោះទេ ហើយ នោះជាកត្តាសំខាន់មួយ។ ប្រជាជននេះនៅមិនទាន់ចែកការរស់នៅតែប៉ុណ្ណោះ។ ប្រជាជននេះមានបញ្ហាត្រង់ថា កន្លែងខ្លះមានមនុស្សរស់នៅតិច កន្លែងខ្លះទៀតមានមនុស្សរស់នៅច្រើនហួសពេក។

២/៣ នៃប្រទេសស្ថិតនៅក្នុងភាពទទេ។ ភូមិភាគឥសាន្ត ភាគខាងជើង និងនិរតី នៃប្រទេសមានចំនួន ប្រជាជនទាបជាង ៥ នាក់ក្នុង ១ គ.ម.$^{២}$ ជា " កម្ពុជាដែលគ្មានមនុស្សរស់នៅ " ។

ប៉ុន្តែនៅភូមិភាគនៃ " កម្ពុជាមនុស្សកុះករ " ក៏មានរបាយប្រជាជនមិនស្មើគ្នាដែរ។ នៅតំបន់វាលរាប និងខ្ពង់រាបបាសាល់ មានមនុស្សរស់នៅ ១០០ នាក់ ក្នុង ១ គ.ម.$^{២}$ តែឃុំជាច្រើនមានមនុស្សរស់នៅតិចជាង ៥០ នាក់ ក្នុង ១ គ.ម.$^{២}$ ហើយឃុំផ្សេងទៀត មានមនុស្សដល់ ២០០ នាក់ ក្នុង ១ គ.ម.$^{២}$។ ការបែងចែកតំបន់រស់នៅគឺយោងទៅតាមលក្ខណៈភូមិសាស្ត្រជាកំណត់ ។

គេបែងចែកតំបន់ប្រជាជនជាច្រើនតំបន់៖

- តំបន់មានប្រជាជនច្រើនកុះករនៅតាមមាត់ទន្លេមេគង្គ បាសាក់ ទន្លេសាប ដែលមានប្រជាជន ពី ២០០ ដល់ ៦០០ នាក់ ក្នុង ១ គ.ម.$^{២}$ ។
- តំបន់មានមនុស្សរស់នៅច្រើន គឺអ្នករស់នៅជុំវិញបឹងទន្លេសាប និង

តំបន់ខាងកើតទន្លេមេគង្គដែលមានប្រជាជនរស់នៅតិច ។

ភូមិសាស្ត្រ ពន្យល់មិនច្បាស់លាស់ពីការបែងចែកការរស់នៅរបស់ប្រជាជនទេ។ តំបន់ដែលមានមនុស្សរស់នៅកុះករ មិនមែនជាកន្លែងដែលមានដី និងអាកាសធាតុល្អនោះទេ។ ដីខ្សាច់គ្មានជីជាតិ និងមានអាកាសធាតុស្ងួតនៃស្រុកជាច្រើននៅខេត្តតាកែវ កណ្តាល កំពង់ស្ពឺ មានមនុស្សរស់នៅលើសពី ១០០ នាក់ ឬ២០០ នាក់ ក្នុង ១ គ.ម.២ ក្នុងពេលដែលគេឃើញមានមនុស្សតិចជាង ១០០ នាក់ ក្នុង ១ គ.ម.២ រស់នៅតំបន់ដីសម្បូរជីជាតិ នៃខេត្តបាត់ដំបង។ប្រវត្តិសាស្ត្រទេ ដែលទទួលខុសត្រូវចំពោះបញ្ហានេះ។ ប្រជាជនបានកើនចំនួននៅតំបន់ដែលមានការកាប់គាស់ដីដែលមិនទាន់ដាំដុះនៅជិតៗបំផុត។ជាអ្វីដែលលោកM.Delvert ឱ្យឈ្មោះថា " ការទន្ទ្រានយកដី កម្ពុជានៅនឹងកន្លែង " ។

ជាលទ្ធផល នៅតំបន់ខ្លះៗ គឺតំបន់ដែលមានប្រជាជនរស់នៅដើមសម័យអាណានិគម ហើយមិនមែនជាតំបន់សម្បូរបែបរបស់ប្រទេសទេ តែមានមនុស្សច្រើនកុះករ។ នេះជាករណីដែលស្ថិតនៅភូមិភាគខាងត្បូងក្រុងភ្នំពេញ។ មនុស្សរស់នៅច្រើនកុះករមានលេចឡើងនូវការបែងចែកដីជាផ្នែកតូចៗ ហើយមានការធ្វើអាជីវកម្ម តូចៗ ។ ពេលខ្លះមានសកម្មភាពការងារបន្ថែម ដូចជា ឡើងត្នោត និងសិប្បកម្មជនបទ ដូចជា ត្បាញសូត្រ ជាង ដែក ជាងឈើ ដែលមានផលិតភាពការងារទាប ដែលនាំឱ្យមានបាតុភាពរត់ចោលជនបទ។

នៅកម្ពុជាមិនសូវមានអន្តោប្រវេសន៍ក្នុងស្រុកទេលើកលែងតែក្នុងសម័យសង្គ្រាមឆ្នាំ ១៩៧០-១៩៧៥ និង១៩៧៥-១៩៧៩។ ការរត់ចោលភូមិស្រុកចូលទីក្រុង និងការកែនដោយអាវុធចេញពីក្រុងទៅជនបទ ដោយ សារបញ្ហានយោបាយ សេដ្ឋកិច្ច គឺជាវិនាសកម្ម និងសោកនាដកម្មនៅកម្ពុជា។ បន្ទាប់មកមានការរត់ចូលទីក្រុង ដើម្បីរកការងារធ្វើ ដែលដើម្បីដោះស្រាយអ្វីទាំងនេះ រដ្ឋត្រូវមានវិធានការបង្កើនពលកម្ម អភិវឌ្ឍន៍ជនបទ ជៀស វាងបាតុភូតខាងលើ។

### ខ.ប្រជាជនទីក្រុង និងប្រជាជនជនបទ

គេធ្វើការកត់ចំណាំច្រើនបែប ស្តីពីការបែងចែករវាងប្រជាជនទីក្រុង និងប្រជាជនជនបទ។

ក.បាតុភូតពីរនៃការរៀបចំទីក្រុង គឺទើបនឹងកើតមាន ហើយមានការអភិវឌ្ឍខ្លះៗនៅកម្ពុជា។ ការរៀបចំទីក្រុងនានានៅឆ្នាំ ១៩៦០ បានធ្វើឱ្យ "តំបន់ជនបទ" ដាច់ខុសពី "តំបន់ទីក្រុង" ។ ក្រុងថ្មីៗបានកើតឡើងដូចជា ទីក្រុងភ្នំពេញ បូកគោ កែប គីរីរម្យ និងក្រុងនៃទីរួមខេត្តទាំងអស់។ ក្នុងឆ្នាំ ១៩៦២ ប្រជាជនក្រុងមានចំនួន ៦០០,០០០ នាក់ ស្មើនឹង ១០% នៃប្រជាជនសរុប។ នៅឆ្នាំ ១៩៧១ ប្រជាជនទីក្រុងមានតែ ១៣០,០០០ នាក់ទេ លើសពី ៥% នៃប្រជាជនទូទៅបន្តិច។ វាកើតមានបាតុភាពធ្វើអន្តោប្រវេសន៍ពីជនបទ មកទីក្រុង នៅក្រោយ សង្គ្រាមលោក ក៏ដូចនៅឆ្នាំ ១៩៨០ និង១៩៩០ ដែរ។ ការចាកចោលជនបទនេះ មាននិន្នាការឆាប់បន្ទាន់ ។ នៅ ឆ្នាំ ១៩៦៧ ប្រជាជនទីក្រុងមានចំនួន ៧០០,០០០ នាក់ ស្មើ ១២% នៃប្រជាជនសរុប។ ក្រោយសង្គ្រាម តាម ស្ថិតិអ៊ុនតាក់នាឆ្នាំ ១៩៩៣ ប្រជាជនក្រុងភ្នំពេញមានចំនួន

កើនឡើងដល់ ១ លាននាក់ ដោយមិនទាន់រាប់បញ្ចូលប្រជាជនដែលចេញ និងចូលក្រុងប្រចាំថ្ងៃនៅឡើយ។ ប្រជាជនទីក្រុងទាំងនេះមានប្រភពដើមនៅជនបទ។ សង្គ្រាមរវាងពួកបារាំង និងវៀតមិញ ពីឆ្នាំ ១៩៤៨ ដល់ ១៩៥៤ បានធ្វើឱ្យប្រជាជនជនបទប្រមូលផ្តុំ រស់នៅតាមផ្លូវជាតិ ហើយពេលសង្គ្រាមចប់គេមិនវិលទៅភូមិដ្ឋានវិញទេ គឺវិលមករកទីក្រុងដូចជា ក្រោយថ្ងៃ ៧ មករា ១៩៧៩ ដែរ។ កម្លាំងចលនាសំខាន់ ដែលធ្វើឱ្យមានអន្តោប្រវេសន៍ពីជនបទ មកកាន់ទីក្រុង គឺចលនាសេដ្ឋកិច្ចៈ កសិករក្រីក្រ រកប្រភពបន្ថែមសម្រាប់ចិញ្ចឹមគ្រួសារ ហើយអ្នកខ្វះការងារធ្វើនៅជនបទ ស្វែងរកការងារនៅទីក្រុង។

បញ្ហាសំខាន់មួយទៀត គឺអនក្ខរកម្ម ដែលនៅឆ្នាំ ១៩៦២ នៅក្នុងក្រុងមានអ្នកមិនចេះអក្សរ ៣២% និងជនបទមាន ៦១% ។

**ខ.**ការកើនឡើងនៃប្រជាជនសរុប ប្រព្រឹត្តទៅទន្ទឹមគ្នានឹងការកើនឡើងនៃប្រជាជនជនបទ។ ផ្ទុយគ្នា ស្រឡះពីអ្វីដែលកើតមាននៅអឺរ៉ុប និងជប៉ុន ការកើនឡើងនៃប្រជាជនមិនត្រូវបានស្រូបយកដោយទីក្រុងទេ។ រវាងឆ្នាំ ១៩២១ និង១៩៦៦ ប្រជាជនកម្ពុជាបានកើនឡើងដល់ ៣,១៤០,០០០ នាក់ ហើយនៅទីក្រុងកើនឡើង ដល់ ៦០០,០០០ នាក់ ។ ផលិតភាពកសិកម្មត្រូវតែកើនឡើងតាមចំនួននៃមនុស្ស និងតាមរយៈផ្ទៃដីដាំដុះ បើគេ ចង់ឱ្យចំណូលផលបរេពិតនៃកសិករបានកើនឡើង។ប្រជាជនកម្ពុជា មាននៅជនបទជិត ៩០% ។ ការសិក្សាពីប្រជាជនសកម្ម អាចឱ្យយើងរកលក្ខណៈពិសេសសេដ្ឋកិច្ចកម្ពុជាពិសេសផ្នែកពលកម្មសម្រាប់ចលនារៀបចំទីក្រុងដែលបានចាប់ផ្តើមរួចមកហើ-យ។

## ១.៥.៣.ប្រជាជនសកម្ម

ការសិក្សាប្រជាជនកម្ពុជា ត្រូវសិក្សាក្នុងនាមប្រជាជននោះធ្វើពលកម្ម។ នេះជាការគិតគូរបញ្ហាប្រជាសាស្ត្រនៅក្រោមមុំនៃសេដ្ឋកិច្ច។ ជាមតិមួយ ធ្វើយ៉ាងណាប្រមូលផ្តុំឱ្យបាននូវតួលេខមុនឆ្នាំ ១៩៥៨ ស្តីពីប្រជាជនសកម្ម និងតួលេខនៅឆ្នាំ ១៩៩៣ ក្រោយសង្គ្រាមជាងពីរទសវត្ស។ ប្រជាជនសកម្មនេះឯង ដែលតំណាងឱ្យថាមពលពិសេសក្នុងផ្នែកសេដ្ឋកិច្ច។

### ក.សារៈសំខាន់នៃប្រជាជនសកម្ម

ប្រជាជនសកម្ម បានត្រូវគេឱ្យនិយមន័យថា ជាកន្សោមមនុស្សដែលធ្វើពលកម្មទទួលបាននូវកម្រៃ។ ព្រះសង្ឃ លោកអាចារ្យនៃសាសនាទាំងអស់ រួមទាំងអ្នកស្វែងរកការងារធ្វើ និងអ្នកមានជំងឺបណ្តោះអាសន្ន ក៏សុទ្ធតែជាប្រជាជនសកម្មក្នុងសេដ្ឋកិច្ចដែរ។ តែប្រជាជនដ៏ទៃទៀតបានត្រូវចាត់ទុកថា ប្រជាជនអសកម្ម។

**ក.**នៅឆ្នាំ ១៩៦២ ប្រជាជនសកម្មនៅកម្ពុជាមានចំនួន ២,៥០០,០០០ នាក់ ប្រហែល ៤៤% នៃប្រជាជនសរុប។ តួលេខនេះ ប្រហាក់ប្រហែលនឹងប្រជាជនដែលមានអាយុ ១៥ ដល់ ៦០ ឆ្នាំ ដែលមាន ២,៨០០,០០នាក់ស្មើនឹង៥១%នៃប្រជាជនសរុប។រចនាសម្ព័ន្ធអាចផ្តល់នូវ

ភាពទន់ខ្សោយនៃប្រជាជនសកម្ម ធៀបនឹង ប្រជាជនសរុប។ កំណើនអត្រាកម្រិតខ្ពស់នៅកម្ពុជា បញ្ជាក់ពីជន " អសកម្ម " មានច្រើនជាង " ជនសកម្ម " ។

ការថយចុះនៃមរណៈភាព នឹងបង្កើនទម្ងន់ដល់មនុស្ស ដែលភាគច្រើនគ្មានសកម្មភាពពលកម្ម ហើយការសិក្សារបស់យុវជន និស្សិត ពន្យឺតពេលនៃការចូលខ្លួនរបស់ពួកគេទៅក្នុងទីផ្សារពលកម្ម។ នេះជាបញ្ហាសំខាន់ ដែលផលិតភាពការងាររបស់មនុស្សម្នាក់ៗ កើនឡើងយឺតជាងផលិតផលតាមពលកម្មនីមួយៗ នោះគឺផលិតភាពការងារ។ មួយផ្នែកនៃការរីកចម្រើនសេដ្ឋកិច្ច នឹងត្រូវបាន " ស៊ី " តាមរយៈការថយចុះនៃអត្រាសកម្មភាព។

បើគិតដល់មនុស្សដែលមានអាយុ ១៥ ដល់ ៦០ ឆ្នាំដែលគ្មាន " សកម្មភាព " គឺមាន ៥០០,០០០ នាក់ ដែលរស់នៅតែក្នុងផ្ទះ។ គេបានកត់សម្គាល់ទៀតថាមនុស្សអាយុក្រោម ១៥ ឆ្នាំ និងលើលពី ៦០ ឆ្នាំ ក៏មានច្រើន ណាស់ដែរ។ មិនបាច់សង្ស័យឡើយផលិតភាពការងារ គឺមិនខ្ពស់នោះទេ។

**ខ.**ការវិភាគយ៉ាងល្អិតល្អន់ នៃអត្រាសកម្មភាពផ្សេងៗ ដែលអាចឱ្យយើងគិតគូរបាន នាំទៅរកការកត់ ចំណាំ ដូចតទៅះ

ជាធម្មជាតិ ប្រជាជនសកម្មភេទប្រុស មានសារៈសំខាន់ជាងប្រជាជនសកម្មភេទស្ត្រី។

ប៉ុន្តែការពិតនៃតួលេខនៃភេទស្ត្រី " សកម្ម " គឺមានអត្រាសកម្មភាពខ្ពស់គួរឱ្យកត់សម្គាល់ គឺ ៣៧% នៃ ប្រជាជន។ នៅក្នុងវិស័យកសិកម្ម ស្ត្រីដើរតួនាទីពលកម្មដូចបុរស។ នៅក្នុងវិស័យផ្សេងទៀត គឺមានភាពខុស គ្នា។ អត្រាសកម្មភាពនៃប្រជាជនសកម្មភេទស្ត្រី នៅក្នុងវិស័យមិនមែនកសិកម្ម ឬនៅទីក្រុងមានចំនួនទាប។ ស្ត្រីភេទនៅកម្ពុជាធ្វើការតិចតួចណាស់ បើគេមានប្ដីជាអ្នកក្រុង។ ប៉ុន្តែនៅជនបទស្ត្រីក៏រកស៊ីមុខរបរផ្សេងៗដែរ បើសិនប្ដីគេជាកសិករ។

ជាគោលការណ៍ ក្នុងមតិបែបនេះ ទើបអត្រាសកម្មភាពមានកម្រិតខ្ពស់ជាង នៅក្នុងប្រជាជនកសិករ ជាងប្រជាជនមិនមែនកសិករ ឬនៅជនបទច្រើនជាងនៅទីក្រុង។ នៅកម្ពុជាប្រជាជនសកម្មផ្នែកបុរស ក៏កត់សម្គាល់ឃើញមាន " សកម្មភាព " ខ្លាំងនៅមជ្ឈដ្ឋានជនបទ ក្នុងវិស័យកសិកម្ម ជាងមជ្ឈដ្ឋានទីក្រុង ឬមិនមែនកសិកម្ម។ តាមការប្រែប្រួលនៃរចនាសម្ព័ន្ធអាយុ និងយោលទៅតាមមជ្ឈដ្ឋាននានា មានស្ថានភាពផ្ទុយទៅវិញ ដែលនាំឱ្យមានអត្រាសកម្មភាពមិនសូវខ្ពស់នៅជនបទ ជាងនៅទីក្រុង។ យើងត្រូវមើលឱ្យឃើញនូវអានុភាពនៃភាពគ្មានការងារធ្វើនៅទីក្រុង ឬការខ្វះពលកម្មនៅជនបទ។ នៅទីក្រុងការរកពលកម្មមកធ្វើមិនសូវលំបាកទេតែនៅតំបន់ជនបទបែរជាមានការលំបាកក្នុងការរកការងារធ្វើ ដោយសារកសិកម្មរណបទៅនឹងរដូវកាលឯនៅទីក្រុងមានឧស្សាហកម្មដែលទើបនឹងចេញពន្លកថ្មី និងមានសេវាកម្មផ្សេងៗច្រើនជាងនៅជនបទ។

នៅកម្ពុជាមានភាពអត់ការងារធ្វើនៅគ្រប់ផ្នែកហើយផលិតភាពការងារនៅខ្សោយណាស់។តែក្នុងវិស័យ កសិកម្ម ជាឧទាហរណ៍ ការកាប់គាស់ដីស្រែ ចំការថ្មី ការដោះមីនចេញពីដីស្រែ ការអភិវឌ្ឍដំណាំស្រូវ ជា រៀងរាល់ឆ្នាំ ជានាបាននូវពលកម្មដល់កសិករ ដើម្បីពង្រីកផលិតភាពការងារឱ្យកើនឡើង តាមរយៈធ្វើកសិកម្ម ដើម្បីបម្រើពាណិជ្ជកម្ម។

### ខ.ការបែងចែកប្រជាជនសកម្ម

នៅមុនឆ្នាំ ១៩៧០ ក៏ដូចនៅក្រោយឆ្នាំ១៩៩០ប្រជាជនសកម្មនៅកម្ពុជាគិតតាមផ្នែកទាំងបីនៃវិស័យសេដ្ឋកិច្ចមិនមានអ្វីប្រែប្រួលទេ៖

- ផ្នែកទីមួយ ........................................៨១ %
- ផ្នែកទីពីរ........................................៤ %
- ផ្នែកទីបី........................................១៥ %

ផ្នែកពលកម្មក្នុងកសិកម្ម មានកម្រិតខ្ពស់ជាងគេ។ នៅក្នុងប្រទេស " ឱនាភិវឌ្ឍន៍ " ចំនួន ១៥ បានបែងចែកពលកម្ម តាមផ្នែកសេដ្ឋកិច្ចដូចតទៅ៖

- ផ្នែកទីមួយ ........................................៥២%
- ផ្នែកទីពីរ........................................១៨%
- ផ្នែកទីបី........................................២៦%

ដូចនេះយើងឃើញថាភាគច្រើននៃពលករកម្ពុជាប្ញជាកម្លាំងកាយ ដើម្បីវិស័យកសិកម្ម រុក្ខកម្ម នេសាទ ប្រមាញ់។ ការអង្កេតឆ្នាំ ១៩៥៨ អាចបញ្ជាក់រូបភាពនៃសកម្មភាពនានា តាមរយៈការបែងចែកភាគរយនៃពលករ សរុបនៃវិស័យកសិកម្ម៖

- អ្នកដាំដុះស្រូវ...............................៨១%
- កសិករផ្សេងទៀត ...............................១៦%
- អ្នកនេសាទ...............................៣%

តួលេខនេះ បញ្ជាក់ពីសារៈសំខាន់នៃដំណាំស្រូវ។ កសិករជាង ៨០% តំណាងឱ្យ ៦៥% នៃប្រជាជនសកម្មសរុបនៅឆ្នាំ ១៩៦២ មានចំនួន ១,៧០០,០០០ នាក់ ដែលធ្វើពលកម្មស្រូវ។

ប្រៀបធៀបពលកម្មនៅក្នុងឧស្សាហកម្មក៏បានលេចចេញនូវរូបភាពមិនទាន់រីកចម្រើនដែរ។ នៅឆ្នាំ១៩៦២តាមជំរឿនមួយគេរាប់ឃើញពលករក្នុងវិស័យកម្មន្តសាលមានចំនួនតិចជាង ៧០,០០០ នាក់តែប៉ុណ្ណោះ និងមានចំនួនជាង ២០,០០០ នាក់ នៅក្នុងវិស័យសំណង់ និងសាធារណៈការ ហើយមានពលករប្រហែលរាប់ពាន់នាក់ ក្នុងវិស័យជីករ៉ែ ផលិតផលអគ្គិសនី ទឹក និងឧស្ម័ន។ សរុបមក មានចំនួនតិចជាង ១០០,០០០ នាក់ទេ។

ការសន្និដ្ឋាននានានៃក្រសួងការងារនាឆ្នាំ ១៩៦២ បានបញ្ជាក់តួលេខខុសគ្នាបន្តិចបន្តួច ស្តីពីការចែក ពលកម្មក្នុងវិស័យឧស្សាហកម្ម ដែលមានតួលេខចំនួន ១១០,០០០ នាក់ រាប់ទាំងកម្មករផ្នែកសំណង់ដែលមាន ចំនួន ១៣,០០០ នាក់ និងផ្នែកថាមពលដែលគេចាត់ចូលក្នុង " វិស័យទី៣ " ។

ប្រជាជនសកម្មធ្វើការនៅក្នុងផ្នែកទីពីរ ទោះបីជាមានការរីកចម្រើន ក៏នៅតែមានសភាពខ្សោយនៅ ឡើយ។ នៅពេលនោះ មានមិនលើសពី ៤% នៃប្រជាជនសកម្មសរុបនោះទេ។

ផ្នែកនៃវិស័យទីបី មានសារៈសំខាន់ទីបី ព្រោះមានចំនួនតិចជាង ៤០០,០០០ នាក់ ធ្វើការនៅក្នុងផ្នែក នេះ។ ជំរឿនឆ្នាំ ១៩៦២ បានផ្តល់តួលេខចំនួន ៣៩៧,០០០ នាក់ ក្នុងនោះមាន ៣៧,០០០ នាក់ ស្ថិតនៅក្នុង " សកម្មភាព " ពិបាកដាក់ឈ្មោះឱ្យ។

- ដឹកជញ្ជូន និងគមនាគមន៍................................១%
- ពាណិជ្ជកម្ម និងធនាគារ................................៦%
- សេវាកម្មផ្សេងទៀត................................៧%

តាមការសិក្សារបស់លោក M.KUZ NETS ថា តួលេខមធ្យមនៃប្រទេស "ឱនាភិវឌ្ឍន៍" ចំនួន ១៥ មានតារាងបង្ហាញថា៖ ៣%, ៧%, ១២%។ ដូចនេះប្រទេសកម្ពុជានៅមានចំណុច "ឱនាភិវឌ្ឍន៍" នៃ "សេវាកម្ម" និងការងារដឹកជញ្ជូន ដែលមិនបានស្តារឡើងវិញទាំងស្រុង ពីការបំផ្លាញនៃសង្គ្រាម។

នៅឆ្នាំ ១៩៦៧ ក្រសួងការងារ បានផ្តល់តួលេខថា ប្រជាជនសកម្មនៅក្នុងវិស័យសេវាកម្ម មានចំនួន ៣៨០,០០០ នាក់៖

- សំណង់ ថាមពល ................................១៣.១០០ នាក់
- ពាណិជ្ជកម្ម................................៩១.០០០ នាក់
- ដឹកជញ្ជូន................................៤៨.៧០០ នាក់
- ផ្នែកសាធារណៈការ ................................៩៣.៨០០ នាក់
- ផ្នែកសាសនា ................................៦៤.៥០០ នាក់
- សេវាកម្ម សហគ្រាស................................១.៣០០ នាក់
- សេវាកម្ម លំហែកាយ................................៣.៤០០ នាក់
- សេវាកម្ម បុគ្គលិក................................៦០.០០០ នាក់

ការសិក្សាពីប្រជាជនសកម្ម បញ្ជាក់ពីគំនូសជាមូលដ្ឋាននៃសេដ្ឋកិច្ចកម្ពុជា។ វានៅសល់តែការបញ្ជាក់ថា ប្រជាជនសកម្មនោះ គេផលិត និងប្រើប្រាស់អ្វីខ្លះនៅកម្ពុជា។

## ១.៦.ក្របខ័ណ្ឌ សង្គមកិច្ច និងវប្បធម៌

លក្ខណៈសង្គមវប្បធម៌ មានសារៈសំខាន់ជាបន្ថែម ដើម្បីស្វែងយល់ពីសេដ្ឋកិច្ចនៅកម្ពុជា និងជាពិសេសសំខាន់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ ឧបសគ្គនៃការលូតលាស់សេដ្ឋកិច្ច គឺស្ថិតនៅក្នុងគំនិតរបស់សង្គម ដែលពាក់ព័ន្ធ ទៅនឹងបញ្ហាកត្តាសង្គមទាំងឡាយ និងពីចិត្តសាស្ត្រសង្គមនោះ ដែលមានតថភាពរបស់ខ្លួននៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ការសិក្សាវិទ្យាសាស្ត្រនានា មានចំណុចខ្វះខាតស្ទើរតែទាំងស្រុង នៅលើបញ្ហាការធ្វើអត្ថាធិប្បាយពី ចិត្តសាស្ត្រសង្គម ដែលរួមចំណែកដល់ការរីកលូតលាស់នៃវិស័យសេដ្ឋកិច្ច។

ក្រោយរំលឹកត្រង់ចំណុចជនជាតិខ្មែរ យើងដឹងថា ជនជាតិនេះជាជនជាតិដើមនៅជ្រោយឥណ្ឌូចិន មិនខុសអ្វីពីជនជាតិឥណ្ឌូនេស៊ី ម៉ាឡេ ដែលមានសម្បុរស្រដៀងគ្នា ហើយបានបង្កើតជាកូនកាត់ ជាតំណរជាមួយពួកឥណ្ឌា ពួកព័រទុយហ្គេ ពួកអេស្ប៉ាញ ឡាវ ថៃ វៀតណាម បារាំង និងចិន។ យើងកត់សម្គាល់បញ្ហាបីចំណុច ដែលមានផលលំបាកយ៉ាងធ្ងន់ធ្ងរទៅលើវិស័យសេដ្ឋកិច្ចៈ អត្ថិភាពនៅកម្ពុជានៃសារៈសំខាន់ នៃចិត្តសាស្ត្រជនជាតិភាគតិច នៃព្រះពុទ្ធសាសនា ដែលជាសាសនារបស់ប្រជាជនភាគច្រើន និងនៃកម្រិតចេះដឹងទាបរបស់ ប្រជាជន។

## ១.៦.១.អត្ថិភាពនៃជនជាតិភាគតិច

អត្ថិភាពនៃសារៈសំខាន់របស់ជនជាតិភាគតិច វប្បធម៌ និងសាសនាទាំងឡាយជាលក្ខណៈមួយពិសេសរបស់ប្រទេសកម្ពុជា។

ជនជាតិពីរ ដែលតាមផ្លូវច្បាប់ត្រូវបានគេបែងចែកដោយឡែក គឺៈ ជនជាតិចិន និងវៀតណាម ដែលត្រូវគេចាត់ទុកជាជនបរទេស។ ជនជាតិទាំងពីរនេះ មានចំណុចខុសគ្នា។ សហគមជនជាតិចិនភាគច្រើនបានចូលរស់នៅលាយឡំសាច់ឈាម បង្កាត់ពូជជាមួយខ្មែរ។ ឯពួកជនជាតិវៀតណាម មិនអាចបញ្ចូលគ្នាបានទេ។

**ក.ជនជាតិវៀតណាមៈ** នៅឆ្នាំ ១៩៦៧ មានជនជាតិវៀតណាមប្រហែល ២៥០,០០០ នាក់ ស្មើនឹង ៤% នៃប្រជាជនសរុប។ កាលនោះ ពួកវៀតណាមមានច្រើននៅភ្នំពេញ ពិសេសនៅតាមក្រុងនានា នៅតាមព្រំដែន កម្ពុជា-វៀតណាម លើដងទន្លេ ពិសេសក្នុងតំបន់បឹងទន្លេសាប។

ជនជាតិវៀតណាមមានសារៈសំខាន់ខាងសេដ្ឋកិច្ចលើវិស័យបីសំខាន់ គឺសិប្បកម្មសំណង់និងនេសាទ។ ក្នុងសម័យអាណានិគម ជនជាតិវៀតណាម បានបម្រើការមួយចំនួនក្នុងវិស័យរដ្ឋបាលនិងសេវាកម្មនានា ប៉ុន្តែរដ្ឋធម្មនុញ្ញនៃអតីតព្រះរាជាណាចក្រកម្ពុជា បានហាមជនបរទេសចូលបម្រើក្នុងវិជ្ជាជីវៈផ្សេងៗ។

១/៤ នៃជនជាតិវៀតណាម កាន់សាសនាកាតូលិក។ ក្នុងកំណត់ហេតុរបស់លោក M.Delvert បាន និយាយថា ជនជាតិវៀតណាមជាជនជាតិមួយ ដែលមានគ្រោះអាសន្នខាងផ្នែកនយោបាយ ហើយមិនមែនជាទី ពេញចិត្តនៃប្រជាជនក្នុងស្រុកទេ។

នៅក្នុងរដ្ឋប្រហារឆ្នាំ ១៩៧០ ជនជាតិវៀតណាមនៅកម្ពុជា បានត្រូវកាប់សម្លាប់ និងដេញចេញអស់ពី កម្ពុជាដោយពួកខ្មែរក្រហម។ ពេលដែលពួកខ្មែរក្រហមដួលរលំពីអំណាច ពួកជនជាតិនេះបានវិលត្រឡប់មកវិញក្នុងចំនួនមិនទាន់ពិតប្រាកដ។ បើតាមការប្រកាសរបស់ក្រសួងមហាផ្ទៃ សព្វថ្ងៃចំនួនជនជាតិវៀតណាម មានជិតស្មើនឹងកាលឆ្នាំ ១៩៦៧ ។

**ខ.ជនជាតិចិនៈ** ជនជាតិចិននៅកម្ពុជា ពិបាកឱ្យនិយមន័យណាស់។ គេអាចប្រើនូវលក្ខណៈ ៤ យ៉ាង សម្រាប់សម្គាល់ៈ

- លក្ខណៈជនជាតិ ជាជនជាតិចិន គឺជាអ្នកដែលមានឈាមជ័រជាជនជាតិចិន

- លក្ខណៈផ្លូវច្បាប់ ជាជនជាតិចិនដែលកាន់លិខិតឆ្លងដែនចិន
- លក្ខណៈភាសាជាចិន ជាជនជាតិចិនដែលនិយាយភាសាចិននៅផ្ទះ
- លក្ខណៈវប្បធម៌ ជាអ្នកដែលដឹងខ្លួនថាជាចិន

លក្ខណៈទីមួយមិនអាចយកជាការបាន ព្រោះចិនជាច្រើនបានបញ្ចូលសាច់ឈាមជាមួយខ្មែរ តាម រយៈអាពាហ៍ពិពាហ៍។ ជនអន្តោប្រវេសន៍ចិនមានយូរលង់ណាស់មកហើយ តាំងពីសម័យអង្គរនៃសតវត្សទី ១៣។ នៅឆ្នាំ ១៨៥០ ដល់ ១៩៥០ អន្តោប្រវេសន៍នៃចិន បានត្រូវកាត់បន្ថយ ដោយបារាំង លើកលែងតែនៅ តុងកឹង និងអានណាម ដោយឡែកនៅកម្ពុជាគ្មានការអនុញ្ញាតនូវអន្តោប្រវេសន៍ចិនឡើយ។

ការធ្វើអន្តោប្រវេសន៍នេះ គឺជាការធ្វើអន្តោប្រវេសន៍មនុស្សប្រុស។ បុរសទាំងនោះ បានរៀបការជាមួយ ស្ត្រីខ្មែរ ហើយបានបង្កើតកូនចៅកាត់ខ្មែរចិន ពួកកូនកាត់ខ្មែរចិននេះ រស់នៅតាមក្រុងនានា និងនៅតាមមាត់ទន្លេ នានា។ នៅក្រុងភ្នំពេញ ជនជាតិចិន ឬជនជាតិកាត់ខ្មែរចិន មានប្រមូលផ្តុំសឹងតែពេញភ្នំពេញ។ ហើយជនជាតិ ទាំងនេះក៏មានការរៀនសូត្រខ្ពស់នៅតាមអនុវិទ្យាល័យ និងមហាវិទ្យាល័យ។ បច្ចុប្បន្នជនជាតិខ្មែរ ក៏បានរត់ចូលទីក្រុងយ៉ាងច្រើនណាស់ដែរ ហើយបានធ្វើឱ្យសមាមាត្រនេះមានការប្រែប្រួល។

ភាពរារែកនៃការបញ្ជាក់តួលេខពិត នៃជនជាតិចិន គឺមកតែពីបញ្ហាកូនកាត់នេះឯងពោល គឺពិបាកក្នុងការកំណត់សញ្ជាតិ។ នៅមានកូនកាត់ខ្មែរចិន ដែលកំណត់យកសញ្ជាតិចិន តែភាគច្រើនបានកំណត់យកសញ្ជាតិខ្មែរ។ បើគេយកសញ្ជាតិជាខ្មែរ នោះគេនឹងទទួលបាននូវសិទ្ធិខាងសេដ្ឋកិច្ចដ៏មានសារៈសំខាន់។

លក្ខណៈខាងភាសា មានការលំបាកក្នុងការកំណត់ថាជាខ្មែរ ឬចិនណាស់។ នៅហ្វីលីពីន តាមជំរឿនមួយបានបញ្ជាក់ថា អ្នកដែលចាត់ទុកថាជាចិន ច្រើនជាងអ្នកដែលចេះនិយាយភាសាចិនទៅទៀត។ រឿងនេះក៏កើតមាន នៅឥណ្ឌូនេស៊ី និងម៉ាឡេស៊ីដែរ។ ករណីបែបនេះ ក៏កើតមាននៅកម្ពុជាដែរ។

ភាសានិងរបៀបរស់នៅជាចិន។ចំណុចសំខាន់លក្ខណៈសំខាន់ដែលបានបញ្ជាក់ថាជាចិនគឺជាផ្នែកវប្បធម៌។ អ្នកដែលជាចិន គឺអ្នកដែលគោរពប្រពៃណី ជំនឿ សាសនា ទំនៀមទម្លាប់និយាយមួយ គឺនៅត្រង់វិធីនៃការធ្វើពិធីបុណ្យសព បើសពត្រូវបានគេកប់ នោះជាជនជាតិចិន។ បើសពត្រូវគេដុតបូជាវិញ នោះគេជាជនជាតិខ្មែរ។

នៅឆ្នាំ ១៩៦៦ ជនជាតិចិនត្រូវបានគេសន្និដ្ឋានថាមានចំនួន ៣៨០,០០០ នាក់ ស្មើនឹង ៥% នៃប្រជាជនកម្ពុជា។ ចិនជាឈ្មួញ ពួកគេកាន់កាប់ពាណិជ្ជកម្មសឹងតែ ១០០% នៅកម្ពុជា ពិសេសពាណិជ្ជកម្មស្រូវ អង្ករ និងកសិផល។ នៅតាមភូមិនីមួយៗមានយ៉ាងតិចចិនមួយគ្រួសារដែរ ដែលជាអ្នកលក់ទំនិញ ឱ្យខ្ចីបុល និងទិញ កសិផលពីកសិករខ្មែរ។ ចិនក៏ជាសិប្បករ ជាសហគ្រិន ជាកម្មករ។ មានចិនដែលជាកសិករមកពីកោះហាយណាំ ជាអ្នកដាំម្រេចនៅកំពត។ ពីមុនក៏ដូចសព្វថ្ងៃសហគមចិននៅរក្សាបានសិទ្ធិបង្កើតសហគម ដែលមានការចាត់ ចែងជា

សាលារៀន មានវត្តអារាម កាសែត និងការភ្ជាប់ទំនាក់ទំនងជាមួយប្រទេសដើម និងសមាគមចិន នៅប្រទេសនានានៅអាស៊ីអាគ្នេយ៍។

ចិន និងវៀតណាម បង្កើតបានជាក្រុមសហគមន៍ ដែលមិនអាចបញ្ចូលបាននូវតួនាទីផ្លូវច្បាប់ និងសកម្មភាព សេដ្ឋកិច្ច មិនដូចសភាពការណ៍ពួកផ្ទីស នៅអឺរ៉ុប ដូចពីមុននោះទេ។

**គ.ជនជាតិចាម និងម៉ាឡេ៖** ជាក្រុមជនជាតិសំខាន់ទីបី។ លើផ្លូវច្បាប់ ជនជាតិទាំងនេះត្រូវបានបញ្ចូលជាជនជាតិភាគតិចដើមនៅកម្ពុជា។ ពួកគេមានសិទ្ធិដូចជនកម្ពុជាដែរ។ ប្រភពដើមនៃជនជាតិនេះ គឺជាជនជាតិភាគតិច ដែលមានវប្បធម៌ និងសាសនា។ ពួកចាម និងម៉ាឡេ ទទួលអនុភាព ម៉ុលស្លុយម៉ង ហើយគេតែងហៅថា ខ្មែរអ៊ីស្លាម។

នៅឆ្នាំ ១៩៦៧ មានជនជាតិចាមចំនួនប្រហែល ១៥០,០០០នាក់ នៅកម្ពុជា។ ពួកចាមទាំងនេះ មកពីមាត់សមុទ្រ ក្រោយពេលដែលអាណាចក្រចំប៉ា បានត្រូវបំផ្លាញដោយពួកវៀតណាម " ដាណាង-ញ៉ាចាង " ។ ពួកម៉ាឡេ មកពីស៊ូម៉ាត្រា កោះជ្វា និងជ្រោយម៉ាឡេស៊ី។ ពួកចាម និងជ្វា បានរស់នៅលាយឡំគ្នា។ ប៉ុន្តែប្រពៃណី ភាសា និងពិសេសសាសនា ដែលពួកគេគោរពបូជាហើយបានរក្សាប្រកាន់យកខុសពីជនជាតិកម្ពុជា។ ពួកខ្មែរអ៊ីស្លាម រស់នៅតាមខេត្តកំពត កំពង់ចាម តាមដងទន្លេមេគង្គ និងទន្លេសាប។

នៅក្នុងសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ពួកខ្មែរអ៊ីស្លាម ក៏ដូចពួកជនជាតិភាគតិចឯទៀតដែរ មានតួនាទីយ៉ាងសំខាន់ ។ ពួកគេជាអ្នកនេសាទ ជាអ្នកដឹកជញ្ជូន ជាឈ្មួញ អ្នកកាប់ឈើ និងជាឈ្មួញពាហនៈ។ សាសនារបស់ពួកគេ មិនហាមឃាត់ការសម្លាប់សត្វទេ។ ពួកខ្មែរអ៊ីស្លាម ជាក្រុមមានសារៈសំខាន់ ដែលបានត្រូវបញ្ចូលតាមផ្លូវច្បាប់ គ្រាន់តែមានការបែងចែកខាងសង្គមតែប៉ុណ្ណោះ។

**ឃ.ជនជាតិភាគតិចដទៃទៀត៖** ក្រុមជនជាតិភាគតិចដទៃទៀត ក៏ត្រូវបានបញ្ចូលគ្នាដូចករណី ជនជាតិឡាវ នៅខេត្តស្ទឹងត្រែង ពួកភូមា ឥណ្ឌា ឬពួកប៉ាគីស្ថាន រួមជាមួយពួកជនជាតិដើមដែលគេហៅថា ខ្មែរលើ រស់នៅតំបន់ព្រៃភ្នំ តាមបរិវេណព្រំដែនកម្ពុជា។ ពួកជនជាតិទាំងនោះ ទទួលបានការទទួលស្គាល់ខាងផ្លូវច្បាប់ ថាជាជនមានសញ្ជាតិកម្ពុជា។ ពួកខ្មែរលើ មានចំនួនប្រហែល ៥០,០០០ នាក់ ធ្វើកាដាំដុះដំណាំ ចំការដុតព្រៃពនេចរ និងបន្ថែមដោយការប្រមាញ់ និងនេសាទ ការបេះផលព្រៃឈើ និងសិប្បកម្ម។ សារៈសំខាន់ផ្នែកសេដ្ឋកិច្ច នៃពួកជនជាតិភាគតិចទាំងនោះ ដូចជាមិនសូវមានទំហំធំទេ។

## ១.៦.២.សារៈសំខាន់នៃព្រះពុទ្ធសាសនា

គេបានដឹងថា ចាប់ពីដើមសម័យទីមួយនៃ គ.ស.ភូមិភាគឥណ្ឌូចិន បានទទួលឥទ្ធិពលនៃចរន្តអរិយធម៌អាស៊ីធំពីរះអរិយធម៌ឥណ្ឌានិងអរិយធម៌ចិន។ នៅកម្ពុជាអរិយធម៌ឥណ្ឌានេះ បានរក្សានូវលំនឹងយ៉ាងនឹង។ ការចាត់ចែងនយោបាយ " ព្រះរាជាណាចក្រកម្ពុជាប្រមូលផ្តុំ " វប្បធម៌ " សំស្ក្រឹត " សិល្បៈ ច្បាប់ វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងពិសេសសាសនាឥណ្ឌា បានត្រូវអនុម័តយកមកអនុវត្តតាម។ ចាប់ពីសតវត្សទី ១៣ មក ឥទ្ធិពលឥណ្ឌា ចេះតែពង្រីកឡើង។

វប្បធម៌ឥណ្ឌា បានចាក់ឫសយ៉ាងជ្រៅរឹងមាំនៅកម្ពុជា ភូមា ថៃ។ លោក M.COEDES បានធ្វើនៅក្នុងជ្រោយឥណ្ឌូចិនដែលទទួលឥទ្ធិពលឥណ្ឌា ជាមួយជនជាតិឥណ្ឌាម្នាក់ ហើយបានធ្វើការអង្កេតប្រតិកម្មនានា ដើម្បីសន្និដ្ឋានថា ដល់ចំណុចណាទៅ ដែលបរិយាកាសសង្គមវប្បធម៌ កើតមានឡើងពីឥទ្ធិពលឥណ្ឌា នៅក្នុងប្រទេសនោះ រាប់ទាំងចរិតខាងក្រៅ រហូតដល់របៀបគោរពសំពះគ្នា ការលើកដៃសំពះប្រណម នៅលើក្បាល លើទ្រូង រហូតដល់សីលធម៌រស់នៅប្រចាំថ្ងៃ។

កេរដំណែលឥណ្ឌាដែលមានសារៈសំខាន់នោះ គឺព្រះពុទ្ធសាសនាហើយប្រជាជនខ្មែរសឹងតែទាំង ស្រុងសុទ្ធតែកាន់ព្រះពុទ្ធសាសនា។រាជរដ្ឋធម្មនុញ្ញក៏បានបញ្ជាក់ថា" ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ " ។

យើងបានដឹងថាព្រះពុទ្ធសាសនាមានដើមកំណើតពីឥណ្ឌា ហើយរីកចម្រើនរាលដាលនៅទូទាំងអាស៊ី។ ប៉ុន្តែព្រះពុទ្ធសាសនា មិនដូចសាសនា កាតូលិក ឬអ៊ីស្លាម នោះទេ។ ព្រះពុទ្ធសាសនា ជាទស្សនៈវិជ្ជាជាចរន្តនៃទ្រឹស្តី គំនិត ដូចជាទស្សនៈវិជ្ជារបស់ ប្លាតុងជាដើម។ ព្រះពុទ្ធសាសនា មានតថភាព ឃើញទំនាស់នៅក្នុងសង្គម។

គេអាចបំភ្លឺបាន អំពីបញ្ហា ដោយបែងចែកឱ្យបានច្បាស់លាស់រវាង " សាវ័គ្គរបស់ព្រះពុទ្ធ-ព្រះសង្ឃ "និង" ពុទ្ធសាសនិកជន " ។

**ក.សាវ័គ្គរបស់ព្រះពុទ្ធ៖** នៅកម្ពុជា គេគោរពបូជាតាមបែបព្រះពុទ្ធសាសនា " យានតូច " ហៅថា " ហីនយាន " ដែលកើតជាបន្តនៅស្រីលង្ការ ភូមា ឡាវ និងថៃ។ វាជាយានដែលនៅជិតប្រភពនៃព្រះពុទ្ធសាសនា។

ទោះបីមានលក្ខណៈជាបុគ្គលនិយម នៃទស្សនៈវិជ្ជារបស់ព្រះសមណគោត្តម សាវ័គ្គព្រះអង្គ បានប្រមូលផ្តុំនៅក្នុងវត្ត។ សាវ័គ្គ ក្លាយជាព្រះសង្ឃ ដែលមានការចាត់ចែងតាមឋានានុក្រម។ ព្រះសង្ឃមិនដូចសង្ឃកាតូលិកទេ ព្រះសង្ឃ មិនមែនជាអ្នកកណ្តាល ចម្លងបុណ្យបាបរវាងមនុស្ស និងអាទិទេពនោះទេ។ ទោសៈ មោហៈ លោភៈ ជាហិង្សាដែលព្រះពុទ្ធហាម ព្រះអង្គបង្គាប់ឱ្យយើងខិតខំជួយអ្នកក្រីក្រ សមាធិធ្វើបុណ្យសន្សំកុសល ប្រព្រឹត្តដោយគ្មានហិង្សា។ ព្រះសង្ឃអាចសឹកបាន តាមបំណងប្រាថ្នា។ តាមប្រពៃណី បុរសខ្មែរត្រូវទៅបួសពីរ ឬបីខែ ឬយ៉ាងតិចមួយដងក្នុងមួយជីវិត។ តែសព្វថ្ងៃ ប្រពៃណីនេះបានថយចុះហើយ។ លោក Matini បានបញ្ជាក់ថា " ព្រះសង្ឃនៃព្រះពុទ្ធសាសនានៅកម្ពុជាមានវិន័យចាត់តាំង ដែលបែងចែកជាពីរផ្នែក៖ មហានិកាយ និងធម្មយុត្តិកនិកាយ។ ឋានានុក្រមនៃព្រះសង្ឃ បានត្រូវអនុម័តដោយព្រះរាជាជាអ្នកការពារសាសនាហើយមានលក្ខណៈប្រហែលនឹងរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជាមានអំណាច និងមានស្ថេរភាព។ ឋានានុក្រមនៃព្រះពុទ្ធសាសនាបានរួមចំណែកវិភាគទានដ៏មានឥទ្ធិពលនៅក្នុងផ្នែកសីលធម៌ និងនយោបាយ ដែលព្រះសង្ឃមាន នៅក្នុងប្រជាជនកម្ពុជា " ។

**ខ.ប្រជាជន៖** អ្នកដែលជាពុទ្ធសាសនិកជន រួមមានអាចារ្យ និងពុទ្ធសាសនិកជនទាំងអស់ ដែលខិតខំ គោរពបូជា ទៅតាមធម៌របស់ព្រះពុទ្ធ។ ក្នុងការគោរពបូជានៃប្រជាជននេះរួមមាន ការសន្តោសប្រណី ការគោរព ព្រះពុទ្ធរូប និងមានព្រហ្មញ្ញសាសនាលាយឡំផង ដូចជាការ

សែនព្រេនជាដើម ។ល។ ដែលគ្មាននៅក្នុងទស្សនៈវិជ្ជារបស់ព្រះពុទ្ធ ។ អ្នកស្រី Lacouture បាននិយាយថា៖ វត្តមានរបស់ព្រះសង្ឃនៅក្នុងពិធីមួយនោះ ជាអ្នកនាំមកនូវសុភមង្គល។

ជាក់ស្តែងប្រជាជនកម្ពុជា ជា " អ្នកកាន់ព្រះពុទ្ធសាសនា ឬពុទ្ធសាសនិក " តាមសីលធម៌របស់ខ្លួន។ ការគោរពជីវិត មិនហ៊ានកាប់សម្លាប់សត្វ ចង់បានកិត្តិយស ស្មោះត្រង់ជិតស្និទ្ធ ការបដិសេធមិនឱ្យសេពសុរា គ្រឿងញៀន ការគោរពស្រ្តីភេទ គឺត្រូវបានអប់រំ និងមានវិធានការអនុវត្ត។ នៅមានការលំបាកក្នុងការសន្និដ្ឋានដល់ឥទ្ធិពលផ្នែកសេដ្ឋកិច្ច ចំពោះជំនឿ និងការអនុវត្តបែបនេះ។

– គេតែងនិយាយថាព្រះពុទ្ធសាសនាក្នុងនាមនៃការងារទេសនាគឺធ្វើឱ្យធុញទ្រាន់ចំពោះខ្លួនឯងនិងពិភពលោកបន្ថយនូវការប្រើប្រាស់ និងការផ្តួចផ្តើម រហូតដល់ក្លាយជាឧបសគ្គនៃការអភិវឌ្ឍសេដ្ឋកិច្ច។ និក្ខេបទនេះមានការលំបាកក្នុងការគាំទ្រ។ ឧទាហរណ៍នៅប្រទេសជប៉ុនការរីកចម្រើនសេដ្ឋកិច្ច គឺមានការរួមវិភាគ ទានរបស់ព្រះពុទ្ធសាសនា។ ចំណុចទីមួយ ព្រះពុទ្ធសាសនា ជាសីលធម៌របស់ប្រជាជន។ ក្នុងនាមនៃទ្រឹស្តី របស់ព្រះពុទ្ធសាសនា មានសារៈសំខាន់ខាងសេដ្ឋកិច្ច។

– អ្នកខ្លះថា វត្តមានទម្ងន់ដល់សេដ្ឋកិច្ចនៃប្រទេស យោងទៅតាមនិក្ខេបទរបស់ពួក **Radicale** ។ គេថាចំណូលសកម្មមួយចំណែករបស់ប្រជាជន បានបូជាចំពោះព្រះពុទ្ធសាសនា។ ចំនួនព្រះសង្ឃ ក៏មានច្រើនណាស់ដែរ បើពិនិត្យលើប្រជាជនសកម្មជាព្រះសង្ឃ គឺមានចំនួន ៦០,០០០ អង្គ គឺស្មើនឹង ៥% នៃប្រជាជនសកម្មបុរស។ ប៉ុន្តែព្រះសង្ឃ ពិសេសចៅអធិការនៃវត្តនីមួយៗ នៅក្នុងភូមិសុទ្ធតែជាអ្នកផ្តួចផ្តើមគំនិត។ លោក M.Delvert និយាយដល់ការចំណាយក្នុងពិធីបុណ្យ និងការសាងសង់អាគារសាសនានានា គឺជាការចំណាយថវិកាដ៏ធ្ងន់ធ្ងររបស់ប្រជាជនកម្ពុជាគ្រប់រូប។

ការអង្កេតមួយទៀតថាក្រៅពីផ្តល់នូវសេចក្តីត្រូវការផ្នែកនយោបាយ ឬសាសនាដល់ប្រជាជនការចំណាយរបស់ប្រជាជន ដើម្បីសាសនាក៏មិនបានបញ្ចូលទៅក្នុងគណនេយ្យជាតិទៀតផង។ ប៉ុន្តែគេភ្លេចថា ជាយូរមកហើយ វត្តអារាម ព្រះសង្ឃ ជាជម្រកនៃវប្បធម៌ខ្មែរ ជាកន្លែងដែលរក្សាអក្សរសាស្រ្តខ្មែរ។ ព្រះសង្ឃ ជាគ្រូ បង្រៀន។ យុវជនខ្មែរត្រូវឆ្លងកាត់វត្តអារាមច្រើនឆ្នាំ រៀនសរសេរ រៀនអាន។ ដូចនេះហើយ បានជាគេតែង និយាយថា អ្នកបានបួសគឺជាអ្នកចេះដឹង ហើយអត្រាអនក្ខរកម្មផ្នែកបុរសនៅកម្ពុជា មានទាបណាស់។ ការរីក ចម្រើនលើវិស័យអប់រំសាធារណៈ បានបន្ថយតួនាទីរបស់វត្តអារាមលើវិស័យអប់រំ តែក៏នៅមានការអប់រំផ្នែកសាសនា ផងដែរ។

សរុបមក សារៈសំខាន់នៃព្រះពុទ្ធសាសនាក្នុងផ្នែកសេដ្ឋកិច្ច គឺមិនមែនជាឧបសគ្គ ឬជាហ្រាំងទប់ពន្យឺតនោះទេ។

### ១.៦.៣.កម្រិតការចេះដឹង

ពួកអាណានិគម បានរៀបចំរចនាសម្ព័ន្ធយ៉ាងសំខាន់ តែចំពោះវិស័យអប់រំនៅកម្ពុជា ពួកគេមិនយកចិត្តទុកដាក់សោះ។ វិស័យអប់រំ មានការកែប្រែឃើតបំផុត ព្រោះការបណ្តោះបណ្តាល ត្រូវចំណាយពេលយូរណាស់។ ទោះបីជាមានការខិតខំ ដ៏ខ្លាំងក្លារបស់រាជរដ្ឋាភិបាលក៏ដោយ ក្រោយសម័យឯករាជ្យ ប្រជាជនកម្ពុជានៅតែជួបបាតុភាពនៃអនក្ខរកម្ម ដែលនាំឱ្យមានផលវិបាកធ្ងន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

នៅឆ្នាំ ១៩៦២ សិស្ស ៨៥,០០០ នាក់ ស្មើនឹង ២% នៃប្រជាជនអាយុជាង ១០ ឆ្នាំ បានប្រឡងជាប់ បញ្ចប់បឋមសិក្សា។ សិស្សបានបញ្ចប់មធ្យមសិក្សាមានចំនួន ១២,០០០ នាក់ គឺនៅតិចនៅឡើយ។ តួលេខទាំង នេះ មានចំនួនតិច ប្រៀបធៀបនឹងប្រជាជនសរុប។ការអប់រំប្រព្រឹត្តទៅជាភាសាបារាំង ការអប់រំនោះ វាស្របនឹងការអប់រំពួកអភិជនបារាំង តែមិនសមស្របនឹងសេចក្តីត្រូវការរបស់កម្ពុជាឡើយ។ ការសម្របភាសាបរទេស " បារាំង " អាចត្រូវបានពន្យល់បានថាសិស្សចាប់យកបានតែផ្នែកខ្លះនៃមេរៀនតែប៉ុណ្ណោះ។ ប៉ុន្តែឥទ្ធិពលប្រពៃណីពួកអភិជនទាំងនោះ សារៈសំខាន់ របស់វា គឺជាមេសូត្រ ជាជាងការពិចារណា ហើយយកសញ្ញាបត្រ ជាជាងការចេះដឹង។

នៅពេលបច្ចុប្បន្ន កម្រិតអប់រំសិក្សានៅតែខ្វះខាតទាំងបរិមាណ និងគុណភាព។ នៅកម្ពុជា មានការខ្វះខាតនូវក្របខ័ណ្ឌដែលត្រូវបណ្តុះបណ្តាលទាំងផ្នែកបច្ចេកទេស ទាំងមន្ត្រីរដ្ឋបាល ទាំងផ្នែកដំណាំដាំដុះ គណនេយ្យ វិស្វករ អ្នកសេដ្ឋកិច្ច និងទាំង " សហគ្រិន " ដែលមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

អ្នកដឹកនាំកម្ពុជាដឹងពីបញ្ហា ហើយក៏បានខិតខំព្យាបាលជំងឺនេះ។ នៅកម្ពុជា មានតែយុវជនពាក់កណ្តាលបញ្ញាវន្ត ការិយាល័យនិយម តែបញ្ហាពលកម្មថ្មីស្របតាមតិចណូឡូស៊ី សម្រាប់បម្រើវិស័យឧស្សាហកម្ម សេវាកម្ម មានមិនគ្រប់គ្រាន់។ នោះជាសភាពការណ៍ ដែលចេញមកពីការសម្របសម្រួលប្រព័ន្ធអប់រំជាតិ មិនស្របនឹងសេចក្តីត្រូវការរបស់បរទេស។

## ១.៧.ដើម្បីឱ្យមានការអភិវឌ្ឍដោយរីករាយ

យើងសន្និដ្ឋានថា " ការផ្ទុះឡើង " នៃសេដ្ឋកិច្ច និងផែនការសន្តិភាព មិនអាចដោះស្រាយបញ្ហាដល់ស៊ីជម្រៅទេ ព្រោះខ្មែរក្រហមមិនព្រមចូលមកបោះឆ្នោត។ សង្គ្រាមស៊ីវិល មានសភាពតិចតួច ហើយចេះតែរសាបរលាបទៅម្តងបន្តិចៗ ដូចសភាពការថៃ និងម៉ាឡេស៊ី ...។ល។

ឡូស៊ីកនយោបាយ បង្កមាគ៌ា និងលទ្ធភាពដល់កិច្ចកសាងឡើងវិញនៅថាមពលសង្គមសេដ្ឋកិច្ចនោះគឺបរិយាកាសរីករាយ បង្កើតតម្លៃវប្បធម៌ខ្មែរសម្រាប់ទំនើបភាវូបនីយកម្ម ភាពចាំបាច់នៃវប្បធម៌សំខាន់ណាស់ក្នុងការប្រមូលផ្តុំជំនឿលើការកសាងប្រទេស ។

## ១.៧.១.ស្ថាបត្យកម្ម និងការប្រព្រឹត្តិទៅនៃប្រពៃណី

លើចំណុចវប្បធម៌កម្ពុជាដំណើរការតាមខ្សែរយៈពីរ៖

១- ខ្សែរយៈបន្ទាត់ផ្ដេក គឺជាការប្រមូលផ្ដុំក្រុមអង្គជាតុសង្គម ថ្នាក់បឋម " ក្រោម " យោងតាមនិយមន័យនៃមូលដ្ឋានទឹកដី គ្រួសារ កេរ្តិ៍ដំណែល ដែលកំពុងមានទំនាក់ទំនងនៅក្រៅប្រទេស ហើយប្រជែងគ្នា។

២- ខ្សែរយៈចោតដែលអ្នកនយោបាយទូទៅ ជាទីទុកចិត្តពីក្រុមសង្គមថ្នាក់ក្រោមទាំងឡាយ ហើយជា អ្នកបញ្ជាឱ្យមានសន្តិភាព នៅជុំវិញអំណាច និងព្រះរាជវង្ស។

គឺការទាក់ទងគ្នារវាងខ្សែរយៈទាំងពីរនោះ ហើយដែលបែបបទសង្គម ការឯកភាពនៅជុំវិញព្រះរាជ បល័ង្កធ្វើឱ្យមានជំនឿរវាងក្រុមថ្នាក់ក្រោមនានា ដែលផ្ដុំជាអង្គសង្គម កម្ពុជាទាំងមូល។

ការដាក់ឱ្យមានរបៀបរបបនេះកំពុងតែប្រព្រឹត្តទៅតាមបែបបទពីរយ៉ាង៖ បែបបទប្រពៃណី និងកាលអាកាស និងពិភពទំនើប ដែលត្រូវទទួលយកក្នុងអនាគត។

### ក.ការប្រព្រឹត្តទៅនៃប្រពៃណីបន្ទាន់

ការបំពេញបន្ថែមនៃក្រុមសង្គមនានា ប្រព្រឹត្តទៅជានិមិត្តរូប

- តាមតថភាពលើមូលដ្ឋាននៃពីរ៉ាមីតសង្គម ជុំវិញវត្តអារាម ព្រះពុទ្ធសាសនា ព្រោះនៅទីនោះកូនប្រុសខ្មែរ សឹងគ្រប់គ្រួសារតែងទៅបួសសងគុណមាតាបិតា រៀនសូត្រមុន និងវិលទៅរៀបការនៅក្នុងភូមិ ជាមូលដ្ឋាននៃម្ចាស់ទឹកដី។

- នៅលើកំពូលភ្នំពីរ៉ាមីតសង្គម ជុំវិញព្រះរាជវាំង នៃព្រះមហាក្សត្រ ឬគ្មានព្រះអង្គម្ចាស់មានការចង សម្ព័ន្ធជាមួយប្រជារាស្ត្រ ដែលជាម្ចាស់ទឹកដី។

ការបំពេញបន្ថែម ប្រព្រឹត្តទៅជាផ្នែករដ្ឋបាលមានបីថ្នាក់។

១- ចេញពីកំពូលសង្គម ព្រះរាជវាំង មានទ្បូស៊ីកនៃវិមជ្ឈការនយោបា ។ ព្រះមហាក្សត្រទ្រង់ចាត់ ព្រះរាជប្រតិភូ ឱ្យកាន់អំណាចតាមឋានានុក្រមយោងទៅតាមនិមិត្តរូបអង្គភាពទាំងប្រាំ៖ ព្រះរាជបុត្រច្បងសោយរាជជាអ្នកគ្រប់គ្រងទិសទាំងបួន។ ព្រះរាជបុត្រពៅគ្រប់គ្រងរដ្ឋបាលជាចៅហ្វាយខេត្ត ចាំប្រតិភូ កាន់អំណាចជា ស្ដេចក្រាញ់ ហើយបានប្រគល់អំណាចជាបន្តទៀតទៅអភិជនក្នុងកម្រិត ថ្នាក់ក្រោមបន្តបន្ទាប់។

២- នៅតាមភូមិ ឃុំស្រុកនានា មានក្រុមសាមគីក្នុងចំណោមអ្នកភូមិ ជួយគ្នាទៅវិញទៅមក។ ភូមិទាំងឡាយរួមគ្នាជា នយោបាយ-សាសនា មិនមែនជារដ្ឋបាល តែដោយវត្តអារាមជាផ្ទះរួម ហើយទទួលស្គាល់គ្នានោះ ជាអំណាចសីលធម៌ កុងសង់សុល ជុំវិញព្រះចៅអធិការ។ វត្តអារាមសហការគ្នានៅ ជុំវិញការបួសព្រះសង្ឃ បំពេញការសិក្សាអក្សរសាស្ត្រធម៌ ដើម្បីបង្កើតជាអង្គសង្គមយ៉ាងទូលាយឡើយ។

៣- អភិក្រមខាងលើ ប្រព្រឹត្តតាមបេសកកម្មនៃមន្ត្រីជាន់ខ្ពស់ ពីរាជធានីចូលទៅថ្វាយបង្គំគាល់ ព្រះចៅអធិការ ជាតំណាងព្រះមហាក្សត្រនៅក្នុងវត្តអារាម។ បេសកកម្មទាំងនេះ

បម្រើការដោះស្រាយផ្នែកយុទ្ធធម៌ប្រមូលព័ន្ធ ដែលមានទំពការពារធ្វើតាមច្បាប់រដ្ឋបាល។ បញ្ហាផ្សេងៗ និងសកម្មភាពនានា បានត្រូវដោះស្រាយដោយអំណាចស្រុក ឃុំ ដោយគ្មានអន្តរាគមន៍ពីពួកអភិជនឡើយ ។

### ខ.ការប្រព្រឹត្តនៅ "ពិភពទំនើប"

តាមរយៈការគ្រប់គ្រងសហគមន៍ប្រមូលផ្តុំ ជុំវិញវត្តអារាមរដ្ឋបាលខេត្ត ស្រុក ឃុំ ភូមិគ្រប់គ្រងរាល់កិច្ចការរដ្ឋសំដៅបង្កើតជំនឿ និងសកម្មភាពបំពេញការងារតាមផ្នែកស្របច្បាប់ទទួលបន្ទុក ពាំនាំបែបបទទំនើបចូល ដល់ផ្នត់គំនិតជនកម្ពុជាគ្រប់រូប នៅជនបទ ជៀសវាងនៅការគៀបសង្កត់ ហឹង្សា និងការគេងប្រវ័ញ្ច ធ្វើឱ្យជនបទចេះតែក្រទៅៗ បែរមុខទៅរកអ្វីដែលរីកចម្រើន ដូចប្រទេសជិតខាងយើង។

## ១.៧.២.គោលការណ៍ទូទៅនៃការអភិវឌ្ឍ

ដើម្បីឱ្យសង្គមប្រព្រឹត្តទៅល្អ និងបញ្ចូលកិច្ចអភិក្រមទំនើបភាវូបនីយកម្ម គឺគ្មានការជ្រើសរើសណាជាជាងដាក់ឱ្យដំណើរការ " ស្ថាប័ន " នៅវប្បធម៌ខ្មែរផ្ទាល់ ប្រពៃណី ព្រះរាជបល្ល័ង្គ និងសហគមន៍ប្រះពុទ្ធសាសនាវត្តអារាម។ វប្បធម៌ខ្មែរនោះហើយ ដែលបង្រួបបង្រួមខ្មែរជៀសវាងបានអភិក្រមនៃភាពបាក់បែកជាភាគីនានា ដែលជានាឱ្យមានការអភិឌ្ឍតាមរយៈអ្នកកណ្តាល។

### ក.និមិត្តរូបនៃព្រះមហាក្សត្រ

ព្រះមហាក្រត្រជាស៊ីម៉ង់ត៍ និងជានិមិត្តរូបនៃសាមគីភាព ក្នុងការប្រយុទ្ធ ធ្វើជាវាសាស្រ្តភូមិគំរូ តំបន់អភិវឌ្ឍន៍ ដែលប្រមូលផ្តុំភូមិនៅជិតៗគ្នា ពង្រឹងជាក្បាលម៉ាស៊ីទំនើបកម្ម ដែលជាឡស៊ីកនៃការគ្រប់គ្រងកាល អាកាស។ អភិបាលក្រុងនានា មានមុខនាទីរៀបចំប្រទេស រួមមានទីប្រជុំជនស្រុក ឃុំ ដែលជាអ្នកចម្លងរវាង ពិភពទីក្រុង និងជនបទឱ្យទំនើបដូចគ្នា កុំឱ្យអ្នជនបទចាត់ទុកថាខ្លួនក្រគេបោះបង់ចោល។ មុខនាទីព្រះមហាក្សត្រ គឺជានិមិត្តរូបនៃការពង្រីក សេដ្ឋកិច្ចសង្គម ជាកំពូលអ្នកដឹកនាំសេដ្ឋកិច្ចអភិវឌ្ឍន៍។

### ខ.ក្របខ័ណ្ឌនៃការប្រព្រឹត្តទៅរបស់វត្តអារាម ព្រះពុទ្ធសាសនា

ឆ្នាំ ១៩៧០ មានវត្តចំនួន ៣៣០០ គឺប្រមូលផ្តុំប្រជារាស្រ្ត ពី ២៥០០ នាក់ទៅ ៣៥០០ នាក់ក្នុងវត្តនីមួយៗជាឧបាសក ឧបាសិកា ផ្សារភ្ជាប់បុណ្យកុសល និងអង្គធាតុអភិវឌ្ឍន៍ជនបទ។ ពិធីបុណ្យនានាប្រមូលបច្ច័យ បម្រើពុទ្ធចក្រផង អាណាចក្រផង គឺសង្ឃព្រះវិហារកុដិផងនិងសាលារៀន ផ្លូវថ្នល់ ស្ពាន គិលានដ្ឋានជាដើម គឺធ្វើទំនើបកម្ម។ ព្រះចៅអធិការ ជាប្រធានគណៈកម្មការសាងសង់ទំនប់ប្រឡាយ ស្ថានីយ៍បូមទឹក កេះឥណទាន អភិវឌ្ឍន៍ទីជនបទ ស្ថានីយ៍ភ្ជាប់ទូរស័ព្ទ។ល។ ទាំងអស់ស្ថិតនៅក្នុងការត្រួតពិនិត្យរួមនៃព្រះសង្ឃបុរាណ និងមនុស្សមានឥទ្ធិពលទំនើប ជាអ្នកដឹកនាំបែបសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនៃបែបបទសង្គម នៃការងាររដ្ឋបាល។

បើក្របខ័ណ្ឌមួយមិនទាន់មានទីតាំងមិនច្បាស់លាស់ នៅពេលណាដែលការចាត់ចែងកាលអាកាស នៅមិនទាន់មាននិមិត្តរូបនោះ ឡូស៊ីកនៃការអភិវឌ្ឍជនបទ នៅមិនទាន់ដំណើរការល្អទេ បើខ្មែរទាំងមិនទាន់មានជំនឿ ធ្វើសកម្មភាពឱ្យរីកចម្រើន។

### ១.៧.៣.ប្រតិទិនអនុវត្តន៍

ប្រតិបត្តិការ បីបែប អាចសម្រេចបាននៅទំនើបភាវូបនីយកម្ម។

១.ការកសាងឡើងវិញនៅនយោបាយ និងក្របខ័ណ្ឌអ្នកគ្រប់គ្រងការងារទំនើបកម្ម គឺការអភិវឌ្ឍ រួមមានការអភិវឌ្ឍជនបទ និងការវិនិយោគបរទេស តាមស្បៀម៉ាសេដ្ឋកិច្ច នៃកាលអាកាស ភូមិសាស្ត្រ ជាសក្ការៈនៃនិមិត្តរូបព្រះមហាក្សត្រ។ ឆ្លៀតពេលរៀបចំនីតិជាតិ សម្បទាទីក្រុង ត្រូវបង្កពលកម្មដល់កសិករដែលចាកចេញពីជនបទ នៅតាមខេត្តនានា ។ ត្រូវបញ្ឈប់នូវការប្រើប្រាស់ខ្ជះខ្ជាយ ដែលនាំឱ្យកើតអំពើពុករលួយ។

ទីតាំងក្រុងភ្នំពេញចាស់ បានរក្សាទុកដូចដើម ត្រូវពង្រីកទីក្រុង មធ្យម ឬទៅក្រុងរណប ធ្វើឱ្យមានទីតាំងឧស្សាហកម្ម នៅឆ្ងាយពីទីក្រុង។

២.កសាងឡើងវិញនៅអង្គភាពជាមូលដ្ឋានសង្គម ដោយពង្រីកបណ្តាលជនបទ នូវរដ្ឋបាលវិមជ្ឈការដែលមានសមត្ថភាព ទំនាក់ទំនងល្អជាមួយព្រះចៅអធិការ សម្រួលរាល់កិច្ចការសង្គមកិច្ច។

ប្រើប្រាស់ក្របខ័ណ្ឌនេះ ជាមណ្ឌលប្រមូលផ្តុំចលនា ឱ្យប្រជារាស្ត្រទទួលបន្ទុកការងារទ្រទ្រង់គ្រួសារក្រីក្រឱ្យមានដីធ្វើស្រែចំការ ជួយចាស់ជរា ក្មេងកំព្រា និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល សាលារៀន ទំនើបកម្ម កសិកម្ម ប្រព័ន្ធឥណទានជនបទ ទឹក ភ្លើង ផ្លូវ ស្ពាន ...។

៣.ការវិនិយោគពង្រីកឧស្សាហកម្ម និងផ្ទៃដីដាំដុះធំៗ និងសម្ភារសង្គម និងពង្រីកកាលអាកាស សង្គមដោយពង្រីកប្រព័ន្ធកណ្តាល ការកសាងសង្គមឡើងវិញ ការកសាងរដ្ឋ និងមេដឹកនាំ។ មធ្យោបាយមួយនៃការកសាង មេដឹកនាំគ្រប់ជាន់ថ្នាក់ នោះជាភារកិច្ចរបស់សាលាភូមិន្ទរដ្ឋបាល ដែលត្រូវបណ្តុះបណ្តាលទាំងផ្នែកនយោបាយ សង្គមរដ្ឋបាល រួមមានមន្ត្រីជាន់ខ្ពស់ដែលដឹកនាំថ្នាក់ក្រសួង ខេត្ត និងស្រុក។ ទន្ទឹមនោះ នូវមូល- ដ្ឋានសង្គមថ្នាក់ក្រោម រៀបចំប្រពៃណី ដែលវត្តអារាមមានសាលារៀន ធ្វើឱ្យពិភពជនបទ រត់បត់តាមវប្បធម៌ខ្មែរ និងប្រមូលផ្តុំបណ្តុះថ្នាក់ក្រសួង ខេត្ត ស្រុកនានា ឱ្យខិតទៅជិតរាស្ត្រ ស្គាល់បញ្ហារបស់រាស្ត្រ ដោះស្រាយបញ្ហា បាន។ នៅថ្នាក់កណ្តាលរៀបចំប្រព័ន្ធសិក្សាធិការទំនើប ដែលមានការជ្រើសរើសរកអ្នកដែលពូកែ ដោយធ្វើការ បណ្តុះបណ្តាល ឱ្យធ្វើការអនុវត្ត ច្រើនជាងទ្រឹស្តី សម្របតាមសេចក្តីត្រូវការរបស់ប្រទេស។

## ១.៨.យោបល់រួមស្តីពីប្រវត្តិសេដ្ឋកិច្ច ឆ្នាំ ១៩៧៩-១៩៩១

ពេលធ្វើការវិភាគពីសភាពការណ៍សេដ្ឋកិច្ច និងលទ្ធផលទាំងឡាយ យើងអាចបញ្ជាក់បានពីប្រវត្តិសេដ្ឋកិច្ចរវាងឆ្នាំ ១៩៧៩-១៩៩១

ចលនានៃសេដ្ឋកិច្ចនេះអាចចែកជាដំណាក់កាលយោលតាមទិសដៅកំណត់នៃគោលការណ៍ដឹកនាំ។

## ១.៨.១.ការស្ដារឡើងវិញ ៖ ១៩៧៩-១៩៨១

**ក.១៩៧៩-១៩៨០ ៖** ការស្រូបយកផលប៉ះពាល់របស់ខ្មែរក្រហម

១- ឆ្នាំ ១៩៧៩ ជាឆ្នាំនៃការចាប់ផ្ដើមសូន្យ នៃសេដ្ឋកិច្ចកម្ពុជាដោយមានឧស្សាហកម្មមួយគ្មានការចាត់ចែងពីពាណិជ្ជកម្មមួយដែលគ្មានសកម្មភាពទាំងស្រុង និងផលិតកម្មកសិកម្មគិតជាភាគរយតិចតួចពីឆ្នាំ១៩៧៩ ។ ផលិតកម្មស្រូវ ០.៥៦០ លានតោនគឺ១៥% នៃឆ្នាំមុន សង្គ្រាម គឺមនុស្សម្នាក់ៗមានអង្ករជាអាហាតិចជាង ១០០ គីឡូក្រាម ស្មើនឹង ១/៤ នៃតម្រូវការស្បៀងចិញ្ចឹមប្រជាជនកម្ពុជា ចំណែកការនេសាទ ក៏ថយចុះក្នុងសមាមាត្រដូចគ្នាដែរ ។ នៅពេលនោះកម្ពុជារស់បានដោយសប្បុរសធម៌ និងសាមគីភាពអន្តរជាតិ ។

២-សេដ្ឋកិច្ចបានវិលទៅកត់ត្រាបានក្នុងស្ថិតិនៃឆ្នាំ ១៩៨០ ផលិតកម្មស្រូវ លោតផ្លោះដល់ ១/៧ លានតោន ប៉ុន្តែអនុភាពស្បៀងនៅខ្វះប្រហែល ១/៤ ទៀត។ បរិមាណត្រូវការខាងផ្នែកសាច់ក៏កាន់តែច្រើនតែសត្វពាហនៈពេលនោះមានតែ ១លានក្បាល ឯត្រីសាច់ផ្ដល់បានតែ ៨ គ.ក្រ.ក្នុងមនុស្សម្នាក់ ក្នុងមួយឆ្នាំ ដែលមុនសង្គ្រាមម្នាក់ប្រើសាចដល់ទៅជិត ៤០ គីឡូក្រាម។ គេក៏គិតផងដែរនៅតួលេខនៃស្ថិតិទាក់ទងផលិតកម្ម ឧស្សាហកម្ម ២៥.៧ លាន U.S.D.។ ពាណិជ្ជកម្មចាប់ផ្ដើម ឯឧបករណ៍ផ្លាសប្ដូររូបិយវត្ថុបានកើនឡើង គឺលុយរៀលថ្មី ។

## ១.៨.២.១៩៨១-១៩៨២: ការរៀបចំឱ្យមានរបៀបនិង ការចាប់ផ្ដើមបទពិសោធសង្គមនិយម

**ក-ក្នុងឆ្នាំ ១៩៨១**

មិនត្រឹមតែក្បាលម៉ាស៊ីនសេដ្ឋកិច្ចទេ ដែលបានត្រូវដាក់ឱ្យដំណើរការ ។ ក្នុងស្ថានភាពស្មុគស្មាញគេក៏ពិនិត្យឃើញនៅកំណើនប្រជាប្រចាំ នៃទិន្នន័យផលិតកម្មប្រពៃណី ដែលបានបន្តជាយុទ្ធសាស្ត្រនៃកំណើននៅសតវត្សក្រោយមកទៀត ប៉ុន្តែភាគច្រើននៃតួលេខសេដ្ឋកិច្ចទំនើបហាក់ជាមានជីវិត ទោះបីតួលេខស្ថិតិនោះនៅពេលខ្លះឆ្ងាយពីការពិតក៏ដោយ ។

ក្នុងចំណមការបញ្ជាក់នៅផលិតផលប្រពៃណីគេរក្សាបាននៅឧទាហរណ៍ដូចតទៅ ៖

- ក្នុងទស្សនៈវិស័យយូរអង្វែង ស្រូវនឹងផ្ដល់ពី ២៤០ គ.ក្រ.ក្នុងមនុស្សម្នាក់ៗនៅដើមឆ្នាំ ១៩៨០ ទៅ ២៧០ គ.ក្រ.នៅឆ្នាំ១៩៩០ ។
- ការនេសាទ និងការចិញ្ចឹមសត្វ ។

ក្នុងចំណោមតួលេខផលិតកម្មទំនើប គេឃើញដូចតទៅ ៖

- ជាការបញ្ជាក់នៅរយៈពេលខ្លី ផលិតផល ជ័រកៅស៊ូឆ្លងពី ១.៣-៤ ពាន់តោននៅចុងដំណាក់កាលនោះក៏ដូចផលិតផលបន្លែរវាង ឆ្នាំ ១៩៨០ ទៅ ១៩៨១ ឡើងទៅដល់ ១៩០ ពាន់តោន ។

- ការសន្និដ្ឋានបានស្តែងចេញជាសុទិដ្ឋិនិយម ក្នុងផលិតកម្ម ឧស្សាហកម្មគឺ ១៧.៨ លានដុល្លារ អាមេរិក ហើយអ្វីដែលមានការពិតច្រើននោះ គឺមានតម្លៃជុំវិញ ១១ លានដុល្លារ អាមេរិកជាតួលេខផលសរុបមធ្យម នៃសហគ្រាសមធ្យម និង តូចដែលមានពលករ ពី ១៥នាក់ ឡើងទៅដល់ឆ្នាំ ១៩៩០ ។

- ចំពោះបញ្ហាពាណិជ្ជកម្ម ក៏មានអត្ថាធិប្បាយប្រហែលគ្នាដែរ តួលេខនៃស្ថិតិគួរលើកទឹកចិត្ត គឺ ៣៥ លានដុល្លារអាមេរិក ឬការប្រុងប្រយ័ត្នចំពើតួលេខនេះ អាចថាតួលេខនេះចែកនឹង២ គឺ ១៧លានដុល្លារអាមេរិក។

**ខ-នៅក្នុងឆ្នាំ ១៩៨២**

វិស័យឧស្សាហកម្ម ឈរនូវលើផលិតកម្ម ដែលមានតម្លស ១៣.២លានដុល្លារអាមេរិក រួមទាំងជំនួយអន្តរជាតិ និងពាណិជ្ជកម្មក្នុងប្រទេសផង ។

សភាពការបែបនេះលេចឡើមានក្តីសង្ឃឹម និងមានផាសុខភាព ទោះបីមានថាមពល និងការអភិវឌ្ឍផ្នែកឯកជន តែរដ្ឋបាលបានទទួលស្គាល់ នូវការពិតពាណិជ្ជកម្មរីកចម្រើន និង ផលិតកម្ម ឧស្សាហកម្ម ដែលជាមូលដ្ឋានចង់ឆ្លងកាត់ទៅរកស៊ីបែបសេដ្ឋកិច្ចសង្គមនិយម។

## ១.៨.៣.សង្គមនិយម និងការលំបាកៈ ១៩៨៣-១៩៨៦

**ក.១៩៨៣-១៩៨៣៖ ការទទួលជោគជ័យមួយ នៃសេដ្ឋកិច្ចសង្គមនិយម**

ក្នុងរយៈពេលពីរគេអាចជឿថា បទពិសោធសេដ្ឋកិច្ចសង្គមនិយម អាចទទួលបានជោគជ័យព្រោះ៖

១.ភាគច្រើននៃការបញ្ជាក់ នៃតួលេខមានកំណើនពេញ៖

- កៅស៊ូមានផលិតភាពឡើងវិញ មានចំនួន ០.៦ តោនក្នុងមួយហិចតា

- ពាណិជ្ជកម្មឆ្លង ពី ២១.២ លានដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៣ ដល់ ៣០.៤ លាន ទៅ ឆ្នាំ ១៩៨៤ ជាកំណើនបន្ទាន់ពាណិជ្ជកម្ម ក្រៅប្រទេសសរុបដែលកើនទ្វេក្នុងរយៈ ៣ឆ្នាំ ឆ្លងពី ២៩.៧ លានដុល្លារអាមេរិក នៅ ឆ្នាំ១៩៨២ ដល់ ៣៥ លាន នៅឆ្នាំ ១៩៨៣ និងដល់ ៥៩ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៤ ។

២.តួលេខ គណនេយ្យ មានស្ថេរភាព និងមានការកែលម្អ៖

- លុយរៀលមានភាពរឹងមាំហើយអត្រារបស់ខ្លួនជាផ្លូវការគឺ ៤-៧ រៀល/ដុល្លារអាមេរិក

- អត្រាគម្រប់នៃការផ្លាស់ប្តូរទំនិញ បានកែលម្អយឺតៗ ក្រោយពេលរណបទៅនិងក្រៅប្រទេសប៉ុន្មានឆ្នាំមុន ។ អត្រានោះកើនពី ៧.៨% ឆ្នាំ ១៩៨២ ទៅ ១២.៣ នៅឆ្នាំ១៩៨២ បន្ទប់មកដល់ ១៣.៧% នៅឆ្នាំ ១៩៨៤ ដោយសារមានកំណើននៃការនាំចេញ ដែលឆ្លងពី៤.៣ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៣ ដោយសារកំណើនមានទិន្នផលនៃពលករ ហើយបន្ទាប់មក មានការធ្លាក់ចុះនៃតម្លៃផលិតកម្មមកដល់ ១២.២ លានដុល្លារអាមេរិក។

**ខ.១៩៨៥-១៩៨៦: ការលំបាកលើគ្រប់វិស័យ**

ចំណាក់កាលថ្មីនៃសង្គមនិយម កាមការលំបានដោយសារមានការបញ្ជាក់តួលេខសេដ្ឋ

កិច្ចតួទៅជាផ្លូវថយចុះជាសក្ដីកម្ម គឺជាភាពអន្តរាយជាបន្តបន្ទាប់ នៃម៉ាស៊ីនសេដ្ឋកិច្ចផ្លូវការៈ

- ក្នុងវិស័យឧស្សាហកម្មការចាប់ផ្ដើមពីឆ្នាំ ១៩៨៤ ដល់មានផលិតកម្ម ១២.២លានដុល្លារអាមេរិក រឹងមាំមារយៈពេលយូរទោះបីជាភាពច្បាស់លាស់នៃមីក្រូសេដ្ឋកិច្ចនៃការស្តារឡើងវិញ ដែលនៅឆ្នាំ ១៩៨៥ ផលិត កម្មឡើងដល់តម្លៃ ១២.៨ លានដុល្លារអាមេរិក ដល់ ១៣.១ លានដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៦ ។

ការជំរុញខ្លាំងខ្លានាំឱ្យការធ្លាក់ចុះនៃផលិតភាពការងារ ។

- ស្ថានភាពវិស័យកសិកម្មនៅទីក្រុង៖ ស្រូវមានផលិតផលត្រឹម ១.៨ លានតោនតែដោយសារកំណើនប្រជាជនរហ័សពេកដោយឱ្យមានឧនភាពស្បៀង ។

ការធ្លាក់ចុះនៃនយោបាយសេដ្ឋកិច្ចសង្គមនិយម គឺមានអត្ថន័យត្រង់ការបញ្ឈប់ការផលិតនៃសហគ្រាសទីពីរ របស់រដ្ឋដែលទទួលការវិនិច្ឆ័យថា រកស៊ីមិនសូវចំណេញ ។

វិធានការរបស់រដ្ឋបានត្រឹមតែធ្វើឱ្យផ្នែកឯកជនឈានចូលធ្វើសកម្មភាពសេដ្ឋកិច្ច ជំនួយជាបន្តបន្ទាប់នៅសេដ្ឋកិច្ចសមូហភាពដែយមានការអភិវឌ្ឍខ្លួនឯតែម្តង ៖

- ដោយសារហេតុផលឧស្សាហកម្ម ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ជាឯកជនឬនៅក្នុងស្រុក មានកំណើនរហូតក្នុងពេលពីឆ្នាំនោះហើយមានល្បឿនលើសសាធារណៈឆ្ងាយណាស់ សគ្រាសរដ្ឋមានចំនួន ៨៧% នៃផលិតកម្ម ឧស្សាហកម្មនៅឆ្នាំ១៩៨៤ នៅសល់តែជាង ៥៣% ទេនៅឆ្នាំ ១៩៨៦ ។ សហគ្រាសឯកជនតូចៗ មានកំណើន ៥ដង ក្នុងរយៈប៉ុន្មានខែសោះ ។

- សភាពការកាន់តែច្បាស់ទៅទៀតចំពោះពាណិជ្ជកម្មឯកជនដែលមានកំណើន លើសពាណិជ្ជកម្មរដ្ឋដែលពេលមុននោះរដ្ឋមានចំនួនជាង ៤៦% នៃពាណិជ្ជកម្ម ឆ្នាំ ១៩៨៥ និងចុះដល់ ៣៩% នៅ ឆ្នាំ ១៩៨៦ ។

ពាណិជ្ជកម្មគិតជាតម្លៃ គឺចុះ ១/៣ គឺពី ៥៩ ដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៤ មកត្រឹម ៤១ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៥ ហើយបន្ទាប់មក នៅទ្រឹងត្រឹម ៤៦.៨ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៦ និង ២៨.៨លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៧ ។

### ១.៨.៤.និន្នាការនៃការធ្វើឱ្យងើបឡើងវិញនៃសង្គមនិយមនិងជោគជ័យនៃផ្នែកឯកជន៖ ១៩៨៧-១៩៩០

#### ក.១៩៨៧-១៩៨៨

គាត់ខិតខំធ្វើឱ្យងើបឡើងវិញ នៅចំពោះមុននៃការបាត់បង់បន្តិចម្តងៗ នៃអំណាចសេដ្ឋកិច្ចក៏មានបំណងធ្វើសកម្មភាពជាថ្មី ជួយដល់វិស័យសេដ្ឋកិច្ចមួយចំនួន នឹងដឹកនាំនយោបាយឯកជនភាវូបនីយកម្មផង ១០% នៃរោងចក្ររដ្ឋលក់ឱ្យឯកជន ។ វិធានការនោះគ្រាន់តែជាការបញ្ចូលខ្យល់ អុកស៊ីហ្សែន ជួយអ្នកជំងឺធ្ងន់ធ្ងរប៉ុណ្ណោះ ។

ដោយយល់ឃើញថាភាគចំណែក នៃសេដ្ឋកិច្ចហាក់ដូចជាថយចុះផលិតផលឧស្សាហកម្មត្រួតពិនិត្យដោយក្រសួង កើនពី ១៣.១ លានដុល្លារ អាមេរិកនៅឆ្នាំ ១៩៨៦ ដល់ ១៦ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៧ និង ១៨.៥ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៨ ហើយផ

លិតភាពឧស្សាហកម្ម តាមពលកម្មកើនក្នុងពេលមួយ ពី១,២៣ លានដុល្លារ នៅ ឆ្នាំ១៩៨៧ ដល់ ១,៤៣ លានដុល្លារ ១៩៨៨ ។

គេត្រូវមើលឱ្យឃើញនូវការរីចម្រើនផលិតកម្មបារី ក្នុងរយៈពេលពីឆ្នាំចំនួនប្រាក់នៃតម្លៃលក់បារីកើនលើសតម្លៃឧស្សាហកម្មសរុប។ ប៉ុន្តែដើម្បីប្រយុទ្ធមុខនឹងសភាពការចំណាយសង្គ្រាមរដ្ឋបានបូជាព្រៃឈើដើម្បីទប់ទល់ និងភាពខ្វះខាតនៃជញ្ជីងពាណិជ្ជកម្ម ជំនួសឱ្យការនាំជ័រកៅស៊ូចេញ ដែលកម្រិតកើនឡើងដល់កម្ពស់ទៅហើយ ហើយថយចុះក្រោយ ១៩៨៧ ។ ការខិតខំរបស់រដ្ឋ គឺបានរួមចំណែកដោយផ្នែកឯកជនដែលបានពន្លកឡើងទៅតាមរបៀបរបបសង្គម ចាប់ពីផ្នែកកសិកម្ម ដែលកំពុងរៀបចំជាកម្មសិទ្ធឯកជនឡើងវិញ។ គេពិនិត្យឃើញ៖

- ការកើនឡើងវិញនៅផលិតភាពផ្នែកនេសាទ ពីឆ្នាំ ១៩៨៧ ដែលផលិតផលមានការលោតផ្លោះពី ៦៩.១ ពាន់តោន នៅឆ្នាំ ១៩៨៦ កើនដល់ ៨២.១ ពានតោន នៅឆ្នាំ ១៩៨៧ ដែលការហូបចុករបស់ប្រជាជនកើនពី ៩.២ ដល់ ១០.៦ គ.ក្រ.ក្នុងមនុស្សម្នាក់ៗក្នុង១ឆ្នាំ ។

- ការស្តារឡើងវិញមួយនៃជីវភាពកសិកម្ម ដែលមានផ្ទៃដាំដុះជាស្រូវ ពីឆ្នាំ ១៩៨ កើនឡើងហើយ ផលិតផលបន្លែកើនទ្វេ ពីឆ្នាំ ១៩៨៧ ១៦៦.១ ពាន់តោន នៅឆ្នាំ ១៩៨៨ មានចំនួន ២៦៦.៥ ពាន់តោន ។

គួររំលឹកផងដែរ នៅវិស័យឧស្សាហកម្ម ដែលកំណើនផ្នែកឯកជនកើនស្មើផ្នែកឧស្សាហកម្មរដ្ឋ។ ចំពោះពាណិជ្ជកម្មរដ្ឋត្រួតត្រាផ្នែកនោះនៅឆ្នាំ ១៩៨៨ មានតែ ១/៤ ប៉ុណ្ណោះ ។

### ខ.១៩៨៩-១៩៩០៖ ផ្លូវអនុគ្រោះដល់សេដ្ឋកិច្ចសង្គមនិយម

ការខិតខំលើកកម្ពស់ឡើងវិញ នៃសេដ្ឋកិច្ច គឺដូចភ្លើងចម្បើង

- ផលិតផលលើឧស្សាហកម្មក្រោមការគ្រប់គ្រងរបស់ក្រសួងដួលរលំធ្លង ១៨.៥ លានដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៨ មកត្រឹម ១៣.៦ លាន នៅឆ្នាំ ១៩៩០ ដែលអត្រាផលិតភាពនៃពលករធ្លាក់ចុះដល់ ៩៧០ ដុល្លារ នៅឆ្នាំ ១៩៩០ ។ ផលិតផលផ្នែកឧស្សាហកម្មនេះកំពុងមានការប្រែប្រួលប្រែផលអំណោយ នៅក្នុងផ្នែកឯកជន នៅឆ្នាំ១៩៨៩ ដែលនៅឆ្នាំ ១៩៩០ មាននៅសល់តែ ៣០% ប៉ុណ្ណោះ ។

- ជាទូទៅតួលេខរដ្ឋ មានភាពមិនច្បាស់លាស់ល្អទេតែតថភាពសេដ្ឋកិច្ច ដែលឃើញមានពិត គឺការចិញ្ចឹមសត្វ គឺមានចំនួន ០.៤៣ ក្បាល ក្នុងមនុស្សម្នាក់ចាប់ពី ឆ្នាំ ១៩៨៩ មក ។ នៅខាងក្រោយផ្ទាំងស្បៃផ្សេងនៃស្ថិតិផ្លូវការ មានការកើនឡើននៅតថភាពនៃសេដ្ឋកិច្ចនោះ គឺផ្នែកឯកជន៖

- ផលិតកម្មឯជននៃសកម្មភាពឧស្សាហកម្ម កើនឡើង ពី ១៦.៦ លានដុល្លារអាមេរិក នៅ ឆ្នាំ១៩៨៨ ដល់ ១៩ លាន នៅឆ្នាំ ១៩៨៩ បន្ទាប់មកកើនដល់ ៣២.២ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៩០ ។

- ចំណែកផ្នែកពាណិជ្ជកម្មឯកជនគឺមាន ៩០% នៃការផ្លាស់ប្តូរ

### ១.៨.៥.ការបញ្ចប់នៃសេដ្ឋកិច្ចចាស់ ៖ ឆ្នាំ ១៩៩១

ឆ្នាំ ១៩៩១ ជាឆ្នាំនៃជោគជ័យ របស់ពួកឯកជនក្លាយជាក្បាលម៉ាស៊ីន សេដ្ឋកិច្ចកម្ពុជាដើរតាមវិធាន ផ្ទាល់នៃការអភិវឌ្ឍនៃការនាំចូលឯកជនកើនឡើង ៣ដង នៃការនាំចេញ។

ឧស្សាហកម្មគ្រប់គ្រងដោយរដ្ឋ គឺមានការស្តារ និងការលោតផ្លោះ ពី ១៣.៦ លានដុល្លារអាមេរិក នៅឆ្នាំ១៩៩១ គឺស្មើនឹង ១៣% ដែលមានតម្លៃសំខាន់ៗ នៃរដ្ឋករ និងបារី ដែលត្រួតពិនិត្យមើលផ្នែកឯកជន គឺកើនដល់ ១៣៨ លានដុល្លារអាមេរិកនៅឆ្នាំ ឆ្នាំ១៩៩១ ។ ការបោះបង់ចោលផ្នែករដ្ឋ បានប្រព្រឹត្តទៅតាមប្រតិបត្តិការ នៃចលនាពីរៈ

១.ទីមួយ ការបើកឱ្យទុនបរទេសចូលក្នុងចំណោមគម្រោង ៣០០ មានគម្រោង ៥៥ ដែលបានអនុម័តពីឆ្នាំ ១៩៨៩ ហើយក្រុមហ៊ុនចម្រុះ ជាង ៥០ បានដំណើរការរួចហើយ នៅពាក់កណ្តាលឆ្នាំ១៩៩២ ប៉ុន្តែគេឃើញថាមានតែចំនួន ២០ សហគ្រាសថ្មីទេ ដែលរៀបចំរចនាសម្ព័ន្ធឧស្សាហកម្មថ្មី។ ក្រុមហ៊ុនចម្រុះមានទាក់ទង ផ្នែកសក្តានុពលដែលមានទិន្នផលខ្ពស់ពិសេសសេវាកម្ម ពួកថៃមាន ៥៦ គម្រោង កសិឧស្សាហកម្មរោងចក្របារី ក្រចៅ រោងចក្រកៅស៊ូ ស្ករ ក្រដាស់ ...ក្នុងនោះមានការស្តាររោងចក្រស៊ីម៉ង់ ចក្រីទីង ដោយចិនប្រជាមានិត សង់នៅឆ្នាំ ១៩៦០ ដោយជំនួយចិនបម្រើ ៨០% នៃតម្រូវការ គម្រោងមានលក្ខណៈនយោបាយកំពុងចរចារ ។

២.ដោយឡែកការរំសាយជាតូបនីយកម្ម ពីខែ វិច្ឆិកា ១៩៩១ សហគ្រាសជាកម្មសិទ្ធសម្ងហភាព មានភាពងាយស្រួលដែលកាន់កាប់ដោយ កិរិយាធិបតេយ្យ ។ នៅខែ មិថុនា ឆ្នាំ ១៩៩២ រោងចក្រ ៤៩ ក្នុងចំណោម ៥៣ នៃក្រសួងឧស្សាហកម្ម បានប្រគល់ពួកវិនិយោគបរទេស ក្នុងរោងចក្រ ១០ បានត្រូវលក់ ៣១ រោងចក្រ ៨ ទៀត បញ្ចូលជាក្រុមហ៊ុនចម្រុះ ។ រោងចក្រនៃក្រុងភ្នំពេញ បានប្រគល់ឱ្យឯកជន ហើយខេត្តនានាក៏មានចលនាដូចគ្នាដែរ ។

ចុងឆ្នាំ ១៩៩២ ផលិតផលឧស្សាហម្មសរុប លើកឡើងតែថាមពល និងសេវាកម្មសឹងតែទាំងអស់បានត្រូវផ្នែកឯកជនរ៉ាប់រង។ សរុបមកគេបានចូលទៅក្នុង ពិភពសេដ្ឋកិច្ចមួយទៀត។ រដ្ឋនៅសល់តែសមត្ថកិច្ចនយោបាយប៉ុណ្ណោះ។ នរណាជាអ្នកគ្រប់គ្រងសេដ្ឋកិច្ច? ហើយគ្រប់គ្រងដោយរបៀបណា។

# មេរៀនទី ២
# លក្ខណៈផ្សេងៗនៃផលទុនជាតិ

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ការកាត់បន្ថយនៃកំណើនផលិតផលក្នុងស្រុកសរុប
- លក្ខណៈផ្សេងៗនៃផលិតផលក្នុងស្រុកសរុប
- ប្រភពនៃកំណើនផលិតផលក្នុងស្រុកសរុប
- បញ្ហានៃកំណើនផលិតផលក្នុងស្រុកសរុប

យើងចាប់យកទិដ្ឋភាពទូទៅនៃផលទុនជាតិមកពិនិត្យនូវរចនាសម្ព័ន្ធ គឺបំណែកដែលបានផលិតតាមផ្នែកសកម្មនីមួយៗ ហើយមួយផ្នែកទៀតសិក្សាពីសាខាសេដ្ឋកិច្ចដែលជាប់ទាក់ទងគ្នាពីមួយទៅមួយ។ បន្ទាប់មកយើងសិក្សាពីកំណើននៃផលិតផល គឺកំណើនសេដ្ឋកិច្ចកម្ពុជា។

## ២.១.រចនាសម្ព័ន្ធនៃផលទុនជាតិ

ក.ការសិក្សាពីប្រជាជនសកម្មបានធ្វើឱ្យលេចចេញលក្ខណៈកសិកម្មនៃសេដ្ឋកិច្ចកម្ពុជា។ លក្ខណៈទាំងនោះ មិនសូវលេចចេញច្បាស់លាស់ពេកទេ នៅពេលដែលគេវិភាគរចនាសម្ព័ន្ធផលិតកម្ម លើភាគរយនៃផលិតផលដុលរបស់ជាតិ។

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ផ្នែកទីមួយ | ៤៩ | ៤៨ | ៤៨ |
| ផ្នែកទីពីរ | ១៩ | ២០ | ២០ |
| ផ្នែកទីបី | ៣២ | ៣២ | ៣២ |

សារៈសំខាន់នៃផ្នែកសេវាកម្ម មានកាន់តែធំឡើង។ ភាគចំណែកនៃផ្នែកសេវាកម្មក្នុងផលទុនដុល របស់ជាតិ កាន់តែមានសារៈសំខាន់ខ្លាំងឡើងទៀត ប្រៀបនឹងប្រទេសឱនាភិវឌ្ឍន៍។

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ផ្នែកទីមួយ | ៤២ | ៤២ | ៤២ |
| ផ្នែកទីពីរ | ១៧ | ១៨ | ១៧ |
| ផ្នែកទីបី | ៤១ | ៤០ | ៤១ |

ការសិក្សារបស់លោក N.KOTNETS ពីក្រុមប្រទេសឱនាភិវឌ្ឍន៍ចំនួន ៣០ ឃើញថាតួលខមធ្យម មានដូចតទៅ គិតជាផលទុនសរុបះ

| | |
|---|---|
| ផ្នែកទីមួយ | ៤៦ |
| ផ្នែកទីពីរ | ១៨ |
| ផ្នែកទីបី | ៣២ |

សារៈសំខាន់នៃផ្នែកទាំងបីក្នុងផលទុនជាតិ គឺគួរឱ្យកត់សម្គាល់ នៃភាគចំណែករបស់ផ្នែកសេវាកម្មនេះនៅក្នុងប្រជាជនសកម្មដែលមានតែ ១៥% ប៉ុណ្ណោះ។ ការប្រៀបធៀបនេះបញ្ជាក់ថាការបែងចែកផលទុនមិន ស្មើភាពគ្នាទេ។

នៅក្នុងវិស័យរដ្ឋបាល គឺមានតែប្រាក់បៀវត្សរបស់មន្ត្រីទេ ដែលបានកត់ចូលក្នុងគណនេយ្យជាតិ តែការគិតគូរបញ្ចូលនូវសេវាកម្មរបស់រដ្ឋបាល មិនទាន់បានគិតគូរដល់នៅឡើយទេ។

ខ.ការប្រុងប្រយ័ត្ន ក៏ត្រូវគិតគូរថែមទៀត នូវការបកស្រាយតួលេខនៃតារាងផ្លាស់ប្តូរវាងសេដ្ឋកិច្ច ដែលបានរៀបចំនៅឆ្នាំ ១៩៦២ និង១៩៦៣ ។ មិនមែនជាតម្លៃបន្ថែមនោះទេ តែជាផលិតផលនៃសាខានេះ ឬសារៈប្រយោជន៍នៃការប្រើប្រាស់នូវផលិតផលនៃផ្នែកសេដ្ឋកិច្ចនោះ។ យើងសួរថា តើផលិតផលនៃផ្នែកនោះ មកពីការនាំចូល ឬជាផលិតផលក្នុងស្រុក។ តើជាផលិតផលនាំចេញ ឬសម្រាប់ប្រើប្រាស់ចុងក្រោយ តើជាការផ្គុំទុន ឬសម្រាប់ផ្តល់ដល់សាខាសេដ្ឋកិច្ចដទៃទៀត? ក្នុងការបញ្ជាក់ពីទំនាក់ទំនងរវាងសាខា និងសាខានេះហើយ ដែលធ្វើឱ្យយើងសិក្សាស៊ីជម្រៅអំពីសេដ្ឋកិច្ចនៃកម្ពុជា។

គេកត់សម្គាល់ថា ភាគចំណែកនៃការនាំចូលក្នុង " ផលិតផលសរុប " នៃសាខានីមួយៗប្លែកៗគ្នាះ

| | |
|---|---|
| ផលិតផលបន្លែ និងសាច់សត្វ | ១.៦ |
| ផលិតផលស្បៀង | ១៥ |
| ថាមពល | ២៥ |
| វត្ថុធាតុដើម, ពាក់កណ្តាលសម្រេច | ២៧ |
| ផលិតផលឧស្សាហកម្ម និងអគ្គិសនី | ៦៦ |
| វាយនភ័ណ្ឌ និងស្បែក | ៧៦ |
| ផលិតផលឧស្សាហកម្មផ្សេងៗ | ៤៧ |
| សំណង់, ការងារសាធារណៈ | ០ |
| សេវាកម្មនានា | ៣ |

តួលេខបង្ហាញទាំងឡាយក៏មានសារៈសំខាន់ពីការនាំចេញ និងការងារផ្សេងៗទៀត ។ ផលិតផលផ្នែក ថាមពល បានត្រូវយកទៅប្រើប្រាស់ចុងបញ្ចប់តែម្តងសម្រាប់សហគ្រាស

គ្រួសារ និងរដ្ឋបាលអស់ចំនួន ៦០%។ ៤០% ដែលនៅសល់ត្រូវបានយកទៅប្រើសម្រាប់ភ្នាក់ងារកណ្ដាលនៃសាខាដទៃទៀត ដូចជា៖

| | |
|---|---|
| សេវាកម្ម | ៨.៩ |
| សំណង់ និងសាធារណៈការ | ៦.៤ |
| វត្ថុធាតុដើម, ពាក់កណ្ដាលសម្រេច | ៥.៥ |
| ពាណិជ្ជកម្ម | ៥.៥ |
| ថាមពល | ៥.៤ |
| ផលិតផលស្បៀង | ៤.0 |

គេអាចដឹងបាននូវ " អតិបិជន "សំខាន់ៗនៃផ្នែកនីមួយៗនៅលើតារាងខាងលើដែលជារចនាសម្ព័ន្ធបច្ចេកទេសនៃផលិតកម្មនៅកម្ពុជាយើង អាចឱ្យយើងដឹងពីអានុភាពដែលជាភាពចាំបាច់នៃសាខានីមួយៗ ដើម្បីបង្កើតនូវនោះ។

ដើម្បីផលិតបាន ១០០ រៀល " រៀលឆ្នាំ ១៩៦០"នៃផលិតផលឧស្សាហកម្មផ្នែកយន្តកម្ម និងអគ្គិសនី គេត្រូវចំណាយ៖

២៤ រៀល សម្រាប់ " ផលិតផលយន្តកម្ម និងអគ្គិសនីឧស្សាហកម្ម "

១៩ រៀល សម្រាប់ " ផលិតផលផ្នែកឧស្សាហកម្មផ្សេងៗទៀត "

0៨ រៀល សម្រាប់ " ផលិតផលបន្លែ និងសាច់សត្វ "

0៦ រៀល សម្រាប់ " វត្ថុធាតុដើម និងពាក់កណ្ដាលសម្រេច "

0៣ រៀល សម្រាប់ " ថាមពល "

ដើម្បីផលិតបានតម្លៃ ១០០ រៀល នូវផលិតផល " ឧស្សាហកម្ម យន្តសាស្ត្រ និងអគ្គិសនី " កម្ពុជាត្រូវ នាំចូល និងចំណាយ ២៧ រៀល លើទំនិញនាំចូល។ " ខ្លឹមសារនៃការនាំចូល " មានតម្លៃទាបជាងសាខាដទៃទៀត៖

| | |
|---|---|
| វាយនភ័ណ្ឌ និងស្បែក | .២១ |
| សំណង់ និងសាធារណៈការ | ១៨ |
| ផលិតផលឧស្សាហកម្មផ្សេងៗ | ១០ |
| ថាមពល | ៩ |
| វត្ថុធាតុដើម, ពាក់កណ្ដាលសម្រេច | ៨ |

គេអាចទាញចេញនូវតារាងផ្លាស់ប្ដូរ រវាងសាខានានា នូវព័ត៌មាន ស្ដីពីរចនាសម្ព័ន្ធផលិតផលក្នុងស្រុក។

## ២.២.កំណើននៃផលទុនជាតិ

ការវិវដ្តពីឆ្នាំ ១៩៥២ មានកត្តាល្អ គឺ ថ្លៃនឹងនរ មានផលិតផលក្នុងប្រទេស និងតម្លៃបន្ថែមតាមផ្នែកនីមួយៗ។ ទាំងអស់នេះជាកតិកាសម្រាប់គណនា សន្និដ្ឋានតម្លៃបន្ថែមតាមផ្នែកសេដ្ឋកិច្ចនីមួយៗ ជាមូលដ្ឋាន និងមានការប្រុងប្រយ័ត្នចំពោះការបកស្រាយពីអត្រាកំណើន។

ដោយឡែក ការគណនាពីអត្រាកំណើនក្នុងរយៈពេលមួយ ប៉ុន្តែអត្រានោះ ចំណុះទៅនឹងពេលវេលា ដែលបានកំណត់មួយ។ កំណត់កាលនោះ អាចចាប់ផ្តើមពីឆ្នាំ " អាក្រក់ " ហើយបញ្ចប់នៅឆ្នាំ " ល្អ " ដែលមានអត្រាកំណើនខ្ពស់ ហើយត្រូវបញ្ចប់បន្តទៀតនៅក្នុងឆ្នាំ " អាក្រក់ " ដែលនឹងលេចចេញនូវអត្រាកំណើនខ្សោយ។

យើងអាចធ្វើការបញ្ជាក់នូវមតិចំនួនបី នៃអត្រាកំណើនៈ

**ក.មតិទីមួយ** សេដ្ឋកិច្ចកម្ពុជា មានការលូតលាស់ គឺពីឆ្នាំ ១៩៥២ ដល់ ១៩៦៣ ។ នៅឆ្នាំ ១៩៦៣ ជាឆ្នាំ" ល្អ " ហើយអត្រាកំណើន " លើសពីការសន្និដ្ឋាន " នៃកំណើន។ប៉ុន្តែនៅឆ្នាំ ១៩៦៣ ជាឆ្នាំនៃការផ្លាស់ប្តូរ នយោបាយ សេដ្ឋកិច្ច បើពិនិត្យលើចំណុចសេដ្ឋកិច្ច។ ១៩៦៣ ជាឆ្នាំនៃដំណាក់ការចុងបញ្ចប់ ដែលត្រូវបែងចែកដំណាក់កាល។ អត្រានានា មានដូចតទៅៈ

| | ១៩៥២-១៩៦៣ |
|---|---|
| ផ្នែកទីមួយ | ៣.២ |
| ផ្នែកទីពីរ | ៨.២ |
| ផ្នែកទីបី មិនរាប់ផ្នែករដ្ឋបាលទេ | ៦.៧ |
| ផលទុនដុលជាតិ | ៥.១ |
| ផ្នែកទីបី " សេវាកម្ម " រាប់ចូលនូវរដ្ឋបាល | ៨.៧ |
| ផលទុនដុលជាតិ | ៥.៩ |

យើងដឹងហើយថា អត្រាកំណើនប្រជាជនប្រចាំឆ្នាំនៃតំណាក់កាលនោះ គឺ ២.៦% ។ ដើម្បីបាននូវអត្រាកំណើនប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗ ក្នុងស្ថានភាពផ្លាស់ប្តូរខ្លះៗ គេបន្ថែមនូវអត្រាកំណើនប្រជាជន ទើបគេឃើញនូវកំណើនអត្រាសេដ្ឋកិច្ច។

សេដ្ឋកិច្ចកម្ពុជានាពេលនោះ បានកើនឡើងតាមអត្រាកំណើនប្រចាំជាមធ្យមលើសពី ៥% ក្នុងមួយឆ្នាំនោះគេនឹងរកបានផលទុននៃមនុស្សម្នាក់ៗ កើនឡើងជាមធ្យម ២.៥% ក្នុងមួយឆ្នាំ។ អត្រានេះ មានភាពគ្រប់គ្រាន់ពេញចិត្ត។ ជាអត្រាដែលគេបានឃើញនៅក្នុងប្រទេសអឺរ៉ុបខាងលិច។ ប៉ុន្តែជាអត្រាខ្ពស់ជាងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

**ខ.មតិទីពីរ** អាចទាញចេញពីការពិនិត្យ នូវអត្រានៃកំណើន ដែលជាភាគចំណែកនៃផ្នែកនីមួយៗរបស់សេដ្ឋកិច្ចកម្ពុជា រួមវិភាគទានដល់កំណើនផលទុនជាតិសរុប។ អត្រាទាំងនោះមិនស្មើគ្នាទេ។

ផ្នែកឧស្សាហកម្ម ជាផ្នែកដែលមានអត្រាខ្ពស់ជាងគេ ស្មើនឹងអត្រាមធ្យម ៨% ក្នុងមួយឆ្នាំ។ ការរីកចម្រើនរហ័សនេះ ដោយសារចំណុចចេញដំណើរមានលក្ខខ័ណ្ឌនៃការអភិវឌ្ឍ។

ទោះបីយ៉ាងណា អត្រាកំណើនវិស័យឧស្សាហកម្ម មិនមែនជាអត្រាកំណើននៃផលទុនជាតិដែរ។

ការរីកចម្រើនផ្នែកវិស័យកសិកម្ម មានប្រហែល ៣.៥% ក្នុងមួយឆ្នាំនេះ ជាការជ្រើសរើសឆ្នាំ " ល្អ " គឺ ឆ្នាំ ១៩៦៣ ជាឆ្នាំបញ្ចប់។ ផលិតផលកសិកម្មរបស់មនុស្សម្នាក់ៗ បានកើនឡើងប្រហែល ១% ប៉ុណ្ណោះ ជាមធ្យមក្នុង ១ ឆ្នាំ។ គ្មានអ្វីគួរឱ្យព្រួយបារម្ភនោះទេ ព្រោះប្រជាជនកម្ពុជាអាចហូបអាហារតាមឃ្លាន ព្រោះនេះជាការរីកចម្រើនមួយជំហ៊ានហើយ។ ប៉ុន្តែអត្រាកំណើនទាបផ្នែកកសិកម្មបែបនេះ បើមិនខំទៀតទេ នោះអាចជាឧបសគ្គនៃការអភិវឌ្ឍសេដ្ឋកិច្ចទៅវិញ។ ការអភិវឌ្ឍសេដ្ឋកិច្ចត្រូវការចំណែកវិស័យឧស្សាហកម្ម និងសេវាកម្មខ្លាំងក្លា តែភាគចំណែកនៃវិស័យកសិកម្ម ត្រូវថយចុះក្នុងផលទុនជាតិសរុប។ រឿងនេះមានន័យថា អត្រាកំណើនវិស័យឧស្សាហកម្ម និងសេវាកម្ម ត្រូវខ្ពស់ជាងវិស័យកសិកម្ម។ ប៉ុន្តែដំបូងត្រូវធ្វើឱ្យអត្រាកំណើនវិស័យកសិកម្មកើនខ្ពស់សិន ទើបវិស័យទាំងពីរកើនខ្ពស់ដែរ។ នៅក្នុងរយៈពេលខ្លី ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវមានអត្រាកំណើនមិនមែនកសិកម្មកើនឡើងលើសពី ២ ដង នៃវិស័យកសិកម្មទេ។ ការកំណត់នូវអត្រាខ្ពស់បំផុតនេះ ធ្វើឱ្យមាន លទ្ធភាពនៃការរីកចម្រើនទូទៅ។ ជាអានុភាព វិស័យកសិកម្មត្រូវផ្តល់ជាបរិមាណផលនៃកំណើន ទាំងចំណូល រូបិយវត្ថុ ទាំងអំណាចទំនិញ និងការសន្សំដែលជាមូលដ្ឋានចាំបាច់នៃការរីកចម្រើនដល់វិស័យឧស្សាហកម្ម និងសេវាកម្ម។

ការរីកចម្រើននៃវិស័យសេវាកម្ម បានកើនរហ័ស នៅក្នុងដំណាក់កាលនោះ បើគេរាប់បញ្ចូលទាំងសេវាកម្ម រដ្ឋបាលផង។ អត្រាកំណើនប្រចាំឆ្នាំមាន ៨% ចន្លោះឆ្នាំ ១៩៥២-១៩៦៣ ប៉ុន្តែនៅដំណាក់កាលចុងក្រោយពីឆ្នាំ ១៩៥៩ ដល់ ១៩៦៣ អត្រាកំណើនមានតែ ៥% ប៉ុណ្ណោះ។ នេះហើយជាការលំបាកក្នុងការបកស្រាយនូវ សារៈសំខាន់នៃការរីកចម្រើននៃវិស័យសេវាកម្ម។

**គ.មតិទីបី** គឺពិនិត្យលើសង្វាក់នៃកំណើន ដែលមានការយឺតចុះមកវិញនៅប៉ុន្មានឆ្នាំចុងក្រោយ។ នៅឆ្នាំ ១៩៦៤ ផលទុនរបស់ជាតិបានកើនឡើងតែ ១.៩% ទេ ប្រៀបនឹងឆ្នាំ ១៩៦៣ ។ ហើយសន្ទស្សន៍បានបង្ហាញពីអត្រាកំណើនចុះយឺតៗជាបន្តបន្ទាប់នៅឆ្នាំ ១៩៦៥, ១៩៦៦, ១៩៦៧ ។ ផលិតផលស្រូវបានថយចុះជាបន្តបន្ទាប់បានធ្វើឱ្យសកម្មភាពឧស្សាហកម្មដែលជាប់ទាក់ទងនឹងស្រូវ " ម៉ាស៊ីនកិនស្រូវ ការដឹកជញ្ជូន ជួញដូរផលិតផល អាល់កុល ។ល។ " ក៏ថយចុះដែរ។ តួលេខនៃវិស័យដទៃទៀត ក៏បង្ហាញថា ផ្នែកឧស្សាហកម្មអគ្គិសនី សំណង់ វាយនភ័ណ្ឌ យន្តសាស្ត្រ ។ល។ ក៏មាននិន្នាការថយចុះដូចគ្នាដែរ។ នេះគឺជាហ្វ្រាំងនៃកំណើនមួយនៃផលទុនជាតិ ដែលបានកើតមានឡើងនៅកម្ពុជា មុននឹងចូលនៅក្នុងភ្លក់ភ្លើងសង្គ្រាមជាង ២ ទសវត្សហើយតំណាក់កាលស្តារនាពេលបច្ចុប្បន្ន ធ្វើឱ្យផលិតផលផ្គត់ផ្គង់បម្រើមិនទាន់សេចក្តីត្រូវការ។

## ២.៣.បញ្ហាកំណើននៅកម្ពុជា

តម្រូវការស្រូវសរុបនាពេលអនាគតសម្រាប់ការប្រើប្រាស់អាហារដោយផ្ទាល់ ត្រូវបានព្យាករណ៍តាម ៤វិធីសាស្ត្រ។ ទីមួយការប្រើប្រាស់ស្រូវក្នុងមនុស្សម្នាក់ៗត្រូវបានគេប៉ាន់ស្មានដោយផ្អែកលើនិន្នា ការពីអតីតកាលក្នុងឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩។ បន្ទាប់មកតម្រូវការស្រូវសរុបសម្រាប់ការប្រើប្រាស់អាហារដោយផ្ទាល់ត្រូវបានព្យាករណ៍ ដោយគុណបរិមាណនេះនឹងចំនួនប្រជាជននាពេលអនាគត។ សមីការសម្រាប់ការប្រើប្រាស់របស់មនុស្សម្នាក់ៗ ត្រូវបានគេព្យាករណ៍ដោយគុណនឹងការប្រើប្រាស់ដែលបានបង្អាក់ដល់មនុស្សម្នាក់ ដោយអត្រាកំណើនជាមធ្យមក្នុងរយៈពេល ៥ឆ្នាំកន្លងមក ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩។ បន្ទាប់មកចំនួនប្រជាជនត្រូវបានគេព្យាករណ៍ដោយផ្អែកលើអត្រាកើនឡើងជាមធ្យមក្នុងរយៈពេល ២៦ឆ្នាំកន្លងមក។ លទ្ធផលនេះនឹងត្រូវបានគេហៅថាការព្យាករណ៍ទី១ ដែលត្រូវបានបង្ហាញដូចខាងក្រោម៖

**តារាងទី២.១ ការព្យាករណ៍ពីចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា (ការព្យាករណ៍ទី១)**

| ឆ្នាំ | ចំនួនប្រជាជន (មនុស្ស) |
|---|---|
| ២០២០ | ១៦,៧៩៩,៧៨៦ |
| ២០២១ | ១៧,១១៨,៩៨២ |
| ២០២២ | ១៧,៤៤៤,២៤៣ |
| ២០២៣ | ១៧,៧៧៥,៦៨៤ |
| ២០២៤ | ១៨,១១៣,៤២២ |
| ២០២៥ | ១៨,៤៥៧,៥៧៧ |
| ២០២៦ | ១៨,៨០៨,២៧០ |
| ២០២៧ | ១៩,១៦៥,៦២៨ |
| ២០២៨ | ១៩,៥២៩,៧៧៥ |
| ២០២៩ | ១៩,៩០០,៨៤០ |
| ២០៣០ | ២០,២៧៨,៩៥៦ |

យោងតាមតារាងទី (ការព្យាករណ៍ទី១) តម្រូវការស្រូវសរុបនឹងកើនឡើងពី ១,៨៧០,៦០៦ តោនក្នុងឆ្នាំ២០២០ ដល់ ២,០២១,៥៦២តោន ក្នុងឆ្នាំ២០៣០ កើនឡើង ៨.០៧%។ ទន្ទឹមនឹងនេះការប្រើប្រាស់ស្រូវសម្រាប់មនុស្សម្នាក់ៗនឹងថយចុះពី ១១០.១២ គីឡូក្រាម/ឆ្នាំ មក ៩៩.៦៩គីឡូក្រាម/ឆ្នាំ ហើយប្រជាជននឹងកើនឡើងពី ១៦,៧៩៩,៧៨៦នាក់ ដល់ ២០,២៧៨,៩៥៦នាក់។ ជាការពិតយោងតាមការព្យាករណ៍ទី១ ឃើញថាអតិរេកផលស្រូវនឹងកើនឡើងពី ៦,៤៧៣,៣០២តោនក្នុងឆ្នាំ២០២០ ដល់ ១៤,៦៧២,២៣៥តោន ក្នុងឆ្នាំ ២០៣០។ ដូច្នេះបរិមាណទាំងនេះអាចត្រូវបាននាំចេញទៅបរទេស ឬប្រើប្រាស់ក្នុងការកែច្នៃដូច

ជា គុយទាវ នំបញ្ចុក នំប៉័ង នំខេក ម៉ៀវមី ទឹកខ្មេះ ស្រាបៀរ អាកុល ចំណីសត្វ និងផលិតផលចម្រុះផ្សេងទៀត។

វិធីមួយទៀតនៃការធ្វើការប៉ាន់ស្មាននាពេលអនាគតត្រូវបានសាកល្បងធ្វើតាមវិធីសាស្ត្ររបស់លោក Hayami ១៩៨៦។ យោងតាមវិធីសាស្ត្រព្យាករណ៍របស់លោក Hayami តម្រូវការស្រូវសរុបរបស់កម្ពុជាអាចត្រូវបានបង្ហាញដូចខាងក្រោម៖

តម្រូវការស្រូវសរុប = ចំនួនប្រជាជន x តម្រូវការស្រូវក្នុងមនុស្សម្នាក់

ឬ $Q = N(\frac{Q}{N}) = N \times q$ (១)

ដែល $Q$ ៖ តម្រូវការស្រូវសរុប

$N$ ៖ ចំនួនប្រជាជន

$q$ ៖ តម្រូវការស្រូវក្នុងមនុស្សម្នាក់

ពីសមីការ (១) ទៅជាសមីការទី (២) ទម្រង់លោការីត

$\ln Q = \ln N + \ln(\frac{Q}{N}) = \ln N + \ln q$ (២)

ពីសមីការ (២) ទៅជាសមីការទី (៣) ទម្រង់ឌីផេរ៉ង់ស្យែល

$\frac{dQ}{q} = \frac{dN}{N} + \frac{dq}{q}$ (៣)

ដែល $dQ = Q_1 - Q_0$

$dQ$ ៖ អត្រាកំណើននៃតម្រូវការស្រូវសរុប

$Q_1$ ៖ តម្រូវការស្រូវសរុបនៅឆ្នាំបច្ចុប្បន្ន

$Q_0$ ៖ តម្រូវការស្រូវសរុបនៅឆ្នាំមុន

ឥឡូវនេះបន្ទាប់ពីធ្វើការជំនួស យើងបាន៖

$\frac{dQ}{Q} = \frac{Q_1 - Q_0}{Q_0}$

ដែល $\frac{dQ}{Q}$ ៖អត្រាផ្លាស់ប្តូរតម្រូវការស្រូវ

ដូច្នេះ $Q_1 = N_1 \cdot q_1 = N_0(1+\frac{dN}{N}) \cdot q_0(1+\frac{dq_0}{q_0})$

$Q_1 = N_0 \cdot q_0 \cdot [1+\frac{dq_0}{q_0} + n + n \cdot \frac{dq_0}{q_0}]$ (៤)

$= N_0 \cdot \frac{Q_0}{N_0} \cdot [1+\frac{dq_0}{q_0} + n + n \cdot \frac{dq_0}{q_0}]$

$= Q_0 \cdot [1+\frac{dq_0}{q_0} + n + n \cdot \frac{dq_0}{q_0}]$

នាំឱ្យ $\frac{Q_1}{Q_0} = 1 + \frac{dq_0}{q_0} + n + n \cdot \frac{dq_0}{q_0}$

ដែល $n=\frac{dN}{N}$ ៖អត្រាកំណើនប្រជាជន

បន្ទាប់មក $\frac{dQ}{Q}=\frac{Q_1-Q_0}{Q_0}$

$$\frac{dQ}{Q}=\frac{dq_0}{q_0}+n+n\cdot\frac{dq_0}{q_0} \quad (៥)$$

$$\frac{dQ}{Q}=n+(n+1)\cdot\frac{dq_0}{q_0}$$

អត្រាកំណើនប្រជាជនជាមធ្យម ១.៤៤៦% ដែលបានដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ធនាគារពិភពលោក (World Bank) ។ ដូច្នេះរូបមន្តដើម្បីគណនាចំនួនប្រជាជននាពេលអនាគតអាចត្រូវបានបង្ហាញដូចខាងក្រោម៖

$$N_1=N_0\times(១+\frac{dN}{N})$$

ដែល $N_1$៖ ចំនួនប្រជាជននៅឆ្នាំបច្ចុប្បន្ន

$N_0$ ៖ ចំនួនប្រជាជននៅឆ្នាំមុន

$n=\frac{dN}{N}$ ៖ អត្រាកំណើនប្រជាជន

ហើយបន្ទាប់មកតម្រូវការស្រូវមានអត្រាកំណើនជាមធ្យមក្នុងរយៈពេល ៥ឆ្នាំកន្លងមក ពីឆ្នាំ២០១៥ដល់ ឆ្នាំ២០១៩ គឺ $\frac{dq_0}{q_0}=-0.០១១$ ។

ដូច្នេះរូបមន្តដើម្បីគណនាតម្រូវការស្រូវសរុបនាពេលអនាគតត្រូវបានបង្ហាញដូចខាងក្រោម៖

$$Q_1=Q_0\cdot[១+\frac{dq_0}{q_0}+n+n\cdot\frac{dq_0}{q_0}]$$

ដែល $Q_1$៖ តម្រូវការស្រូវសរុបនៅឆ្នាំបច្ចុប្បន្ន

$Q_0$ ៖ តម្រូវការស្រូវសរុបនៅឆ្នាំមុន

$\frac{dq_0}{q_0}$ ៖ អត្រាផ្លាស់ប្តូរតម្រូវការស្រូវក្នុងមនុស្សម្នាក់ៗ

$n=\frac{dN}{N}$ ៖ អត្រាកំណើនប្រជាជនជាមធ្យម

ដើម្បីគណនាការប៉ាន់ស្មានស្រូវសរុបតាមរយៈរូបមន្តខាងលើ ហើយលទ្ធផលទាំងនេះត្រូវបានសង្ខេបនៅក្នុងតារាងទី៤.១១ ដែលហៅថាការព្យាករណ៍ទី២ នៃការព្យាករណ៍ពីតម្រូវការស្រូវ។

**តារាងទី២.២ ការព្យាករណ៍ពីតម្រូវការចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា (ការព្យាករណ៍ទី ២)**

| ឆ្នាំ | ចំនួនប្រជាជន (មនុស្ស) |
|---|---|
| ២០២០ | ១៦,៧២៤,៩៣៧ |
| ២០២១ | ១៦,៩៦៦,៧៨០ |
| ២០២២ | ១៧,២១២,១២០ |
| ២០២៣ | ១៧,៤៦១,០០៧ |
| ២០២៤ | ១៧,៧១៣,៤៩៣ |
| ២០២៥ | ១៧,៩៦៩,៦៣០ |
| ២០២៦ | ១៨,២២៩,៤៧១ |
| ២០២៧ | ១៨,៤៩៣,០៦៩ |
| ២០២៨ | ១៨,៧៦០,៤៧៩ |
| ២០២៩ | ១៩,០៣១,៧៥៥ |
| ២០៣០ | ១៩,៣០៦,៩៥៥ |

**សម្គាល់៖**១/

$$Population_t = Population_{t-1}(១ + \frac{dN}{N}) = Population_{t-1} \times (១ + ០.០១៤៤៦)$$

២/ ការប្រើប្រាស់ស្រូវប្រចាំឆ្នាំក្នុងមនុស្សម្នាក់ = តម្រូវការស្រូវសរុប ÷ ចំនួនប្រជាជន

៣/ ការប៉ាន់ស្មានការប្រើប្រាស់ស្រូវសរុប៖ $Q_1 = Q_0 \cdot (១ + \frac{dq_0}{q_0} + n + n \cdot \frac{dq_0}{q_0})$

៤/ $\frac{dq}{q} = -០.០១១$ និង $n = \frac{dN}{N} = ០.០១៤៤៦$

យោងតាមការព្យាករណ៍ទី២ តម្រូវការស្រូវសរុបនឹងកើនឡើងពី ១,៨៦២,២៧២តោន ក្នុងឆ្នាំ ២០២០ ដល់ ១,៩២៤,៦៦៥តោន ក្នុងឆ្នាំ២០៣០ ពោលគឺកើនឡើងប្រមាណ ៣.៣៥%។ ក្នុងពេលដំណាលគ្នាចំនួនប្រជាជននឹងកើនឡើងពី ១៦,៧២៤,៩៣៧នាក់ ដល់ ១៩,៣០៦,៩៥៥នាក់ និងការប្រើប្រាស់ស្រូវសម្រាប់មនុស្សម្នាក់នឹងថយចុះពី ១១១.៣៥ គីឡូក្រាម/ឆ្នាំ មក ៩៩.៦៩គីឡូក្រាម/ឆ្នាំ។ ចំពោះតម្រូវការស្រូវសរុបដែលបានគ្រោងទុកដោយការព្យាករណ៍ទី២ ឃើញថាអតិរេកផលស្រូវនឹងកើនឡើងពី ៦,៤៨១,៦៣៦តោន ក្នុងឆ្នាំ ២០២០ ដល់ ១៤,៧៦៩,១៣២តោន ក្នុងឆ្នាំ២០៣០ កើនឡើង ១២៧.៨៦%។

ម៉្យាងវិញទៀតយោងតាមរបាយការណ៍របស់ ទីស្ដីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួនប្រជាជនជាមធ្យមត្រូវបានគេព្យាករណ៍ថានឹងកើនឡើង ១.៤% ក្នុងមួយឆ្នាំ។

ដូច្នេះការព្យាករណ៍ ពីតម្រូវការស្រូវសរុបនឹងខុសគ្នាបន្តិចបន្តួចពីការព្យាករណ៍ទី១ និងការព្យាករណ៍ទី២ ហើយលទ្ធផលផ្អែកលើការព្យាករណ៍ទី៣ ត្រូវបានរៀបចំក្នុងតារាងទី៤.១២។

**តារាងទី២.៣ ការព្យាករណ៍ពីចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា (ការព្យាករណ៍ទី៣)**

| ឆ្នាំ | ចំនួនប្រជាជន (មនុស្ស) |
|---|---|
| ២០២០ | ១៦,៧១៧,៣៥៤ |
| ២០២១ | ១៦,៩៥១,៣៩៧ |
| ២០២២ | ១៧,១៨៨,៧១៦ |
| ២០២៣ | ១៧,៤២៩,៣៥៨ |
| ២០២៤ | ១៧,៦៧៣,៣៦៩ |
| ២០២៥ | ១៧,៩២០,៧៩៦ |
| ២០២៦ | ១៨,១៧១,៦៨៧ |
| ២០២៧ | ១៨,៤២៦,០៩១ |
| ២០២៨ | ១៨,៦៨៤,០៥៦ |
| ២០២៩ | ១៨,៩៤៥,៦៣៣ |
| ២០៣០ | ១៩,២១០,៨៧២ |

**សម្គាល់៖**១/ $Population_t = Population_{t-1}(១+\frac{dN}{N}) = Population_{t-1}\times(១+0.0១៤)$

២/ ការប្រើប្រាស់ស្រូវប្រចាំឆ្នាំក្នុងមនុស្សម្នាក់ = តម្រូវការស្រូវសរុប ÷ ចំនួនប្រជាជន

៣/ ការប៉ាន់ស្មានការប្រើប្រាស់ស្រូវសរុប៖ $Q_1 = Q_0 \cdot (1+\frac{dq_0}{q_0}+n+n\cdot\frac{dq_0}{q_0})$

៤/ $\frac{dq}{q} = -0.0១១$ និង $n = \frac{dN}{N} = 0.0១៤$

យោងតាមការព្យាករណ៍ទី៣ តម្រូវការស្រូវសរុបនឹងកើនឡើងពី ១,៨៦១,៤២៨តោន ក្នុងឆ្នាំ ២០២០ ដល់១,៩១៥,០៨៧តោន ក្នុងឆ្នាំ២០៣០ កើនឡើង ២.៨៨%ប៉ុណ្ណោះ។ នៅក្នុងការព្យាករណ៍ទី៣ ប្រជាជននឹងកើនឡើង ១៤.៩១% ពី ១៦,៧១៧,៣៥៤នាក់ ដល់ ១៩,២១០,៨៧២នាក់ និងការប្រើប្រាស់ស្រូវសម្រាប់មនុស្សម្នាក់នឹងថយចុះ ១០.៤៧% ពី ១១១.៣៥គីឡូក្រាម/ឆ្នាំមក ៩៩.៦៩ គីឡូក្រាម/ឆ្នាំ។ ដូច្នោះហើយផ្អែកលើការព្យាករណ៍ទី៣ នេះ ឃើញថាអតិរេកផលស្រូវនឹងកើនឡើង ១២៧,៩៨% ពី ៦,៤៨២,៤៨០តោន ក្នុងឆ្នាំ ២០២០ ដល់ ១៤,៧៧៨,៧១០តោន ក្នុងឆ្នាំ ២០៣០។ នេះបង្ហាញថាអត្រាកំណើនប្រជាជនមានសារៈសំខាន់ណាស់នៅក្នុងឧស្សាហកម្មស្រូវអង្ករកម្ពុជា។

ជាចុងក្រោយយោងតាមសៀវភៅ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ចំនួនប្រជាជនជាមធ្យមត្រូវបានគេព្យាករណ៍ថានឹងកើនឡើង ១.២% ក្នុងមួយឆ្នាំ។ ផ្អែកលើចំនួននេះការព្យាករណ៍ពីតម្រូវការស្រូវសរុបត្រូវបានបង្ហាញនៅក្នុងតារាងទី ដែលហៅថាការព្យាករណ៍ទី៤ នៃការព្យាករណ៍ពីតម្រូវការស្រូវ។

**តារាងទី២.៤.ការព្យាករណ៍អំពីចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា (ការព្យាករណ៍ទី៤)**

| ឆ្នាំ | ចំនួនប្រជាជន (មនុស្ស) |
|---|---|
| ២០២០ | ១៦,៦៨៤,៣៨១ |
| ២០២១ | ១៦,៨៨៤,៥៩៣ |
| ២០២២ | ១៧,០៨៧,២០៨ |
| ២០២៣ | ១៧,២៩២,២៥៥ |
| ២០២៤ | ១៧,៤៩៩,៧៦២ |
| ២០២៥ | ១៧,៧០៩,៧៥៩ |
| ២០២៦ | ១៧,៩២២,២៧៦ |
| ២០២៧ | ១៨,១៣៧,៣៤៣ |
| ២០២៨ | ១៨,៣៥៤,៩៩១ |
| ២០២៩ | ១៨,៥៧៥,២៥១ |
| ២០៣០ | ១៨,៧៩៨,១៥៤ |

**សម្គាល់៖** ១/ $Population_t = Population_{t-1}(១+\frac{dN}{N}) = Population_{t-1}\times(១+0.0១២)$

២/ ការប្រើប្រាស់ស្រូវប្រចាំឆ្នាំក្នុងមនុស្សម្នាក់ = តម្រូវការស្រូវសរុប ÷ ចំនួនប្រជាជន

៣/ ការប៉ាន់ស្មានការប្រើប្រាស់ស្រូវសរុប៖ $Q_1 = Q_0\cdot(1+\frac{dq_0}{q_0}+n+n\cdot\frac{dq_0}{q_0})$

៤/ $\frac{dq}{q} = -0.0១១$ និង $n = \frac{dN}{N} = 0.0១២$

យោងតាមការព្យាករណ៍ទី៤ តម្រូវការស្រូវសរុបនឹងមានការផ្លាស់ប្តូរពី ១,៨៥៧,៧៥៦ តោនក្នុងឆ្នាំ ២០២០ ដល់ ១,៨៧៣,៩៤៤ តោន ក្នុងឆ្នាំ២០៣០ កើនឡើង ០.៨៧% ប៉ុណ្ណោះ។ នៅក្នុងរយៈពេលនេះចំនួនប្រជាជននឹងកើនឡើង ១២,៦៧% ពី ១៦,៦៨៤,៣៨១នាក់ ដល់ ១៨,៧៩៨,១៥៤ នាក់ និងការប្រើប្រាស់ស្រូវសម្រាប់មនុស្សម្នាក់នឹងថយចុះ ១០.៤៧% ពី ១១១.៣៥គីឡូក្រាម/ឆ្នាំ មក ៩៩.៦៩គីឡូក្រាម/ឆ្នាំ។ ជាលទ្ធផលឃើញថាអតិរេកផលស្រូវនឹងកើនឡើង ១២៨.៤៨% ពី ៦,៤៨៦,១៥២ តោន ក្នុងឆ្នាំ២០២០ ដល់ ១៤,៨១៩,៨៥៣តោន ក្នុង

ឆ្នាំ២០៣០។ លទ្ធផលទាំងអស់នៃការព្យាករណ៍ទាំងបួនត្រូវបានពន្យល់ប្រៀបធៀបក្នុងរូបភាពទី ៤.១៤។

## ២.៤.ការកាត់បន្ថយនៃកំណើនផលិតផលក្នុងស្រុកសរុប

### ២.៤.១.វិភាគសេដ្ឋកិច្ចផលទុនដុលជាតិម្នាក់ៗ

ក្នុងការផ្តុំគ្នានូវការវាយតម្លៃមុននេះ នៃផលទុនដុលជាតិ ជាមួយការសន្និដ្ឋានរបស់ប្រជាជនកម្ពុជាមាននិន្នាការវិវឌ្ឍន៍ ជាផលទុនដុលជាតិនៃមនុស្សម្នាក់ៗ ត្រូវគុណនឹង បីដងក្នុងរយៈពេល ម្ភៃឆ្នាំ គឺឆ្លងពីតិចជាង ៦០ ដុល្លារអាមេរិក នៅឆ្នាំ ១៩៥០ ដល់ ១៧០ ដុល្លារ នៅឆ្នាំ ១៩៧០ " គឺជាកម្រិតជីវភាពមធ្យម សរុបចិត្តប្រហែលនិងផល ទុនជាតិម្នាក់ៗ របស់ប្រទេសថៃក្នុងរយៈពេលដូចគ្នា" ឆ្លងកាត់ ៨៥ ដុល្លារក្នុងឆ្នាំ ១៩៥៥ មកដល់ ១១០ ដុល្លារនៅក្នុងឆ្នាំ ១៩៦០ និង ១៣០ ដុល្លារនៅក្នុងឆ្នាំ ១៩៦៥ ។

តាមរយៈការការធ្វើមេគុណនៃអត្រាកំណើន ជាយន្តការនៃតួលេខខាងលើ ប្រជាជនកម្ពុជាម្នាក់ទទួលបានផលទុនយ៉ាងតិចក៏ ៥០០ ដុល្លារ នៅក្នុង ឆ្នាំ ១៩៩០ ។ តាមហេតុការណ៍ បើចាប់យកសម្មតិកម្មថា នៅក្នុងឆ្នាំ ១៩៩០ ផលទុនដល់របស់ជាតិ កើនឡើងដោយ ៧ពាន់ដុល្លារ "១៩៩៥ នៅត្រឹម នៅត្រឹម ២,២០០ លានដុល្លារ" ដែលកំណើនប្រជាជនកើនដល់ ១២ លាននាក់ បើសន្តិភាពរក្សាបានរហូតនោះ ប្រជាជនអាចទទួលបានផលទុនជាតិជិត ៦០០ ដុល្លារ ម្នាក់ៗ ។ នៅក្នុងឆ្នាំ ២០០០ ផលទុនដុលជាតិម្នាក់ៗ កើនដល់ប្រហែល ១០០០ ដុល្លារ ។

### ២.៤.២.ខ្លឹមសារម៉ាក្រូសេដ្ឋកិច្ច

សភាពការណ៍បែបនេះនៃប្រទេសកម្ពុជា នាឆ្នាំ១៩៧០ ព្រមទាំងគម្រោងវិវត្តនៅក្នុងឆ្នាំ ១៩៩០ គឺជាភាពធម្មតាសម្រាប់ប្រទេសមានបរិមាណប្រជាជន និង សភាពការណ៍សេដ្ឋកិច្ចបែបនេះ ។ នៅក្នុងឆ្នាំ ១៩៧០ សភាពការណ៍សេដ្ឋកិច្ចកម្ពុជា ប្រហែលនិងសភាពការណ៍សេរីលង្កា ដែលស្ថិតនៅក្នុងតំបន់មូសុង ហើយក៏ស្ថិតក្នុងស្ថានភាពប្រហែលគ្នា និងប្រទេសកំពុងអភិវឌ្ឍន៍នានា ។ ព្រោះការគ្រប់គ្រងសេដ្ឋកិច្ចកន្លងមក មិនដែលជួបនឹងសេដ្ឋកិច្ចនៅឡើយ ។ ប៉ុន្តែនៅឆ្នាំ ១៩៩០ ការប៉ាន់ស្មានស្ថានការណ៍ សេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន ព្រោះភាគនៅប្រទេសនៅតំបន់នេះបានស្គាល់នូវការអភិវឌ្ឍប្រភេទ "នាគ" រួមមានទាំង ថៃឡង់ ដែលជាប្រទេសជិតខាង មានវប្បធម៌ដ៏ដូចគ្នាបេះបិទ ហើយដែលមានផលទុនដល់ជាតិ ក្នុងម្នាក់ នាឆ្នាំ ១៩៧០ ដូចកម្ពុជាដែរនៅឆ្នាំ ១៩៩០ ផលទុនដល់ជាតិអ្នកកើនឡើងដល់ ១,៤០០ ដុល្លារ គឺកើនទ្វេ ឬ បីដង នៃសម្មតិកម្ម ដែលបានបង្ហាញនៅខាងលើ សម្រាប់កម្ពុជា នាឆ្នាំ ១៩៩០។

## ២.៤.៣.រចនាសម្ព័ន្ធថាមពលនៃផលទុនដល់ជាតិ

សម្រាប់ការពិនិត្យមើល នូវបន្ទាត់ធំៗនៃការសរុបភាពមធ្យមនៃសមាសភាព ផលទុនដូចជាតិ ការសន្និដ្ឋាននៃចំណុចធំៗខាងលើ យោលតាមលក្ខណៈនៃគណនេយ្យជាតិ បានផ្តល់នូវការវិវដ្តដូចតទៅ៖

ពាក់កណ្តាលនៃផលទុនដូចជាតិកើនឡើងដល់ផ្នែកកសិកម្ម មួយភាគបួននៃផលទុនដុលផ្នែកសេវាកម្ម និង មួយភាគបី ទៀតចំណូលផលទុនជាតិផ្នែកឧស្សាហកម្ម និង រដ្ឋបាល ។

ប៉ុន្តែបែងចែកជា ទំហំមិនស្មេរទេ នៅក្នុងទសវត្សរ៍ទាំងពីរគន្លង ។ ការបែងចែកវិវដ្តន៍តាមឡូស៊ិកនៃនិន្នាការចន្លោះឆ្នាំ ១៩៥០ និង ១៩៧០

- ផ្នែកកសិកម្មនៅឆ្នាំ ១៩៥០ មានផលទុន ៥៣ដល់ឆ្នាំ ១៩៧០ % មានតែ ១/៣ ទេគឺ "៣៦,៧"%
- ផ្នែកសេវាកម្ម ស្ថិតនៅនឹងថ្កល់ ឆ្លងពី ២៦ %នៃផលទុនដុលជាតិនាឆ្នាំ ១៩៥០ មក ២៧,៥៣% នៅឆ្នាំ ១៩៧០
- ផ្ទុយទៅវិញ ផ្នែកឧស្សាហកម្ម មានកំណើនគួរឱ្យកត់សម្គាល់ គឺកើនទ្វេនៃភាគចំណែកក្នុងផលទុនជាតិពី ១១ទៅ ១៩ %,៩ ។%

ភាគចំណែករបស់រដ្ឋបាលកើនជាសមាមាត្រ ប្រហែលជាពាក់កណ្តាល ឆ្លងទី ១០% ទៅ ១៥,៦% ។

គេធ្វើគណនានៃតួលេខសម្រាប់ឆ្នាំ ១៩៩០ អាចបង្ហាញឱ្យយើងឃើញ នូវថាមពល៖

- ផ្នែកកសិកម្ម បង្កើតបានតិចជាង ១/៤ នៃផលទុនដុល។
- ផ្នែកឧស្សាហកម្ម" រាប់បញ្ចូលទាំងរដ្ឋបាល" បង្កើតបាន ពាក់កណ្តាលនៃផលទុនជាតិដុលជាតិ។
- ក្នុងពេលនោះដែរ ផ្នែកសេវាកម្ម ស្ថិតនៅនិង និងគួរឱ្យកត់សម្គាល់គឺ ១/៤ នៃផលទុនដុលជាតិ។

សក្តានុពលនៃមូលដ្ឋានសេដ្ឋកិច្ច មានភាពរអិល ពីផ្នែកកសិកម្ម ទៅផ្នែកឧស្សាហកម្ម ដោយរាប់ទាំងភាគចំណែកនៃរដ្ឋបាល ក្នុងនោះមួយភាគនៃសេដ្ឋកិច្ចមានការគ្រប់គ្រងដោយក្រុមហ៊ុនជាតិ។

ឡូស៊ីកនៃកំណើនសេដ្ឋកិច្ច ធ្វើឱ្យប្រទេសឆ្លងកាត់ពីស្ថានភាពនៃ ឱនាភិវឌ្ឍន៍ តាមរយៈភាពសម្បូរជាច់ខាតនៃផ្នែកកសិកម្មឆ្ពោះទៅរកលំនឹងមួយភាគបួននៃផ្នែកសេដ្ឋកិច្ចថាមពលនៃកំណើនមាននិន្នាការប្រព្រឹត្តទៅដោយសារការអភិវឌ្ឍនៃផ្នែកឧស្សាហកម្មទាំងអស់ ក្រោមទ្រង់នៃរដ្ឋដែលគេឃើញច្បាស់រួមទាំងភាគចំណែក នៃរដ្ឋបាលនាឆ្នាំ ១៩៩០ គឺ ២០% ។

### ២.៤.៤.ការវិភាគវិស័យនានានៃផលទុនដល់ជាតិ

យោងតាមប្រវត្តិនានាមាន ការលំបាកលើកនូវសំណួមពរ នៃប្រវត្តិពិស្តារ នៃការបង្វិលតួលេខ ទៅតាមផ្នែកផល្លិតកម្មនៃផលទុនជាតិដុលគេអាចគិតទៅដល់ឆ្នាំ ១៩៦២ ជាឆ្នាំដែលគេទទួលស្គាល់ឃើញថៃមមានរូបភាពមធ្យមនៃផលិតកម្មព្រោះ ៖

- ទីមួយ វាស្ថិតនៅក្នុងដំណាក់កាលដើមនៃពាក់កណ្ដាលសម័យទីពីរ ដែលត្រូវសិក្សាហើយបានផ្ដល់នូវរូបភាពជាសក្ខានុពល ចុងក្រោយនៃសេដ្ឋកិច្ច។
- ទីពីរ ព្រោះពេលនោះ ក៏បានផ្ដល់ផលដែរ នូវរូបភាពច្បាស់លាស់ប្រហាក់ប្រហែលឆ្នាំ ១៩៧០ ទោះបីជាផលិតផលកសិកម្ម ធ្លាក់ក្នុងស្ថានភាពអាក្រក់យ៉ាងណាក៏ដោយ ដើម្បីជៀសនូវការវាយតម្លៃខ្ពស់ពេក និងបំប៉ោងតួលេខ ប៉ុន្តែផ្នែកកសិកម្មបាន ចាប់ផ្ដើមមានកំណើនហើយ។

ក្នុងរូបមន្តមធ្យមនៃគោលដៅនាឆ្នាំ ១៩៦០ ៖

**១.ផ្នែកកសិកម្ម ដែលមានចំនួនផលិតផល ពាក់កណ្ដាលផលទុនដុលរបស់ជាតិ អាចចែកចេញជាសំណុំពីរមិនស្មើគ្នា៖**

- កសិកម្ម ”ក្នុងនាមនៃផលិតផលស្បៀង និងដំណាំគ្រួសារដូចជាថ្នាំជក់កប្បាសក្រចៅម្រេចផ្លែឈើ“បន្លែ” ល ។ មានចំនួន ៣/៤ នៃផ្នែកកសិកម្ម គឺ ស្មើនឹង ១/៣ នៃផលទុនដល់ជាតិ។
- ១/៤ នៃផ្នែកទីមួយ គឺ ១០នៃផលទុនដល់ជាតិគឺកើនឡើងដោយ % ពាក់កណ្ដាល ពីផលិតផលសត្វ“ប្រពៃណីចិញ្ចឹមនិងនេសាទ” ហើយពាក់កណ្ដាលទៀត ដោយសារផលិតផល “ឧស្សាហកម្ម” ”កៅស៊ូ និងឈើ”។
-

**២.ផ្នែកដែលមានស្ថេរភាពជាងគេ ដែលមានចំនួន ១/៤ នៃផលទុនដល់ជាតិគឺ**

- ពាណិជ្ជកម្មមាន១/៥នៃផលទុនដុលរបស់ជាតិធនាគារទទួលបានផលទុន “ចំណូល” ផ្នែកសេវាទៅដល់ ៣/៤ នៃផ្នែកនេះ។
-

**៣.ផ្នែកឧស្សាហកម្ម៖** ដែលគេឃើញមានការបើកទូលាយ ផ្ដល់នូវការរីកចម្រើន ១២ ផ្នែកនៃវិស័យឧស្សាហកម្មតូចនិងមធ្យមដែលរួមវិភាគទាននៃផ្នែកនីមួយៗតិចជាង ២% នៃការផលទុនដុលជាតិហើយជារៀងរាល់ឆ្នាំមានការកសាងរោងចក្រថ្មីៗទៀត ។ ក្នុងរូបភាព image នៃផលទុនដល់ជាតិចំនួនសហគ្រាសបានកើនឡើងប្រាំដងចេញពីចំនួន ២៦៨ នាឆ្នាំ ១៩៦៤ ទៅដល់ ៣,៥០០ សហគ្រាសនាឆ្នាំ ១៩៧០។

សហគ្រាសចំនួន ១៨ ដែលមានសារៈសំខាន់ទីមួយ ៣/៤ ជាសហគ្រាសរដ្ឋហើយសហគ្រាសនានាទៀត រដ្ឋចំណុះឯកជន ស៊ីម៉ង់ត៍ចក្រីទីងរោងចក្រ វាយនភណ្ឌកំពង់ចាម និងបាត់

ដំបង រោងចក្រកង់រថយន្តតាខ្មៅ រោងចក្រក្រដាសឆ្លូញ រោងចក្រផូស្វាត ទូកមាស រោងចក្រកែវ វត្តស្ទឹងមានជ័យរោងចក្រចម្រាញ់ប្រេងកាតក្រុងព្រះសីហនុរោងចក្រក្តារបន្ទះ ជីឥដ្ឋ។ល។

**៤.ភាគចំណែករដ្ឋបាលៈ** គេមិនស្គាល់នៅសមាមាត្រហ្នឹងសមាសភាពនៅឡើយ។

**សេចក្តីបញ្ជាក់ជាបឋមផ្សេងៗទៀត**

នៅភាគទីពីរនេះ យើងបង្ហាញពីអង្គធាតុមានលក្ខណៈច្បាស់លាស់នៃ ផលទុនដុលជាតិ ពីផ្នែកមួយទៅផ្នែកមួយទៀតជាតិពីផ្នែកមួយទៅផ្នែកមួយទៀត។

**ក.ផ្នែកទីមួយៈកសិកម្ម**

**ដំណាំស្រូវៈ**

នៅឆ្នាំ ១៩៦២ នៅក្នុងផ្នែកទី មួយ សកម្មភាពមួយត្រូវបែងចែកទៅតាមទម្ងន់សេដ្ឋកិច្ចរបស់ខ្លួនលើកលែងតែដំណាំស្រូវដំណាំស្រូវ ។ តែមួយមានចំនួនជាង ១/៣ នៃផ្នែកកសិកម្ម ហើយផ្តល់ចិត្ត ១៥% នៃផលគុណដល់ជាតិ គឺលើសជាងភាគចំណែកទាំងស្រុងនៃផ្នែករដ្ឋបាល ហើយតិចជាងភាគចំណែកនៃផលទុនដុលជាតិនៃផ្នែកឧស្សាហកម្ម។ ដំណាំស្រូវគឺផ្នែកដ៏ធំនៃផលិតផលជាតិដុល។

ផ្នែកនេះមានការកត់សម្គាល់ដោយមានកំណើតបួនដងដែលយើងបង្ហាញពីអាណត្តិនិន្នាការ។

១.ផលិតផលស្រូវកើនឡើងទ្វេដងពី ពី ១,៥ លានតោននៅឆ្នាំ ១៩៥០ មកជិត ៣ លានតោននាឆ្នាំ ១៩៧០ ។

២.កំណើននៃផល្លិតកម្មនេះបកស្រាយបាននូវកំណើនកម្រិតជីវភាពនៃអ្នកផលិតស្រូវបន្ទាប់មកពីគុណភាពអង្ករដែលចិញ្ចឹមមនុស្សម្នាក់បាន ៣៥០ គីឡូក្រាមនៅក្នុងមួយឆ្នាំនៅឆ្នាំ ១៩៥០ ឡើងលើស ៤០០ គីឡូក្រាមនៅឆ្នាំ ១៩៧០។

៣.គេចងចាំបានថាកំណើតមិនដាច់ខាតនៃទិន្នផលមានតែមាន ០,៩៥ តោនក្នុងមួយហិចតានៅឆ្នាំ ១៩៥០ ដល់ ១,១ តោនមួយហិកតានាឆ្នាំ ១៩៧០ តែប៉ុណ្ណោះតែប៉ុណ្ណោះ។

៤.តម្លៃនៃផលិតផលស្រូវកើនបីដងកែវពីអថេរប្រចាំឆ្នាំនៃថ្លៃផលិតផលដែលមានតម្លៃ ៥០ លានដុល្លារអាមេរិកនៅឆ្នាំ ១៩៥០ កើនដល់ ១៥៤ ដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ ១៩៧០។

កំណើនថ្លៃអង្ករច្បាស់លាស់ត្រង់ភាគចំណែករបស់អង្ករ ក្នុងផលទុនដុលជាតិបានថយចុះពាក់កណ្តាល។ផលិតផលអង្ករមានចំនួន២០% នៃផលទុនដុលជាតិនៅឆ្នាំ ១៩៥០ ហើយមានចំនួនតែ ១០% ប៉ុណ្ណោះនៅក្នុងឆ្នាំ ១៩៧០។ នេះហើយជាការប្រែប្រួលនៃមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាដែលនៅជំនាន់អនានិគមអង្ករមានចំនួន ១/៤ នៃទ្រព្យធនហើយនៅក្នុងឆ្នាំ ១៩៧០ អង្ករមានតំណាងជាទ្រព្យសម្បត្តិតែ ១០% ប៉ុណ្ណោះ ។

គេទទួលស្គាល់នូវជោគជ័យក្នុងវិស័យអភិវឌ្ឍន៍នៃសម័យសង្គមរាស្ត្រនិយមក្នុងភាពឱ្យស្រឡះនៃការជ្រើសរើសបែបបទរបស់ខ្មែរក្រហមដែលសង្កត់លើតែផ្នែកចែកស្រូវអង្ករតែមួយមុខប៉ុណ្ណោះ។

**ដំណាំកៅស៊ូ៖**

កសិផលទីពីរ ផ្តល់នូវរូបភាពនៃការវិភាគដោយសារសំខាន់មិនដាច់ខាតនៃប្រភពធនធាននេះដែលមានភាគចំណែកក្នុងការនាំចេញដំណាំកៅស៊ូដែលនៅក្នុងឆ្នាំ ១៩៦២ មាន ៣% នៃផលទុនដុលជាតិដំណាំ។ កៅស៊ូមានកំណើនច្បាស់លាស់នៃផលកម្ម ៖

- ដំណាំកើនបីដង ពី ១៦ ពាន់តោននាឆ្នាំ ១៩៥០ ដល់ ៥០ ពាន់តោននាឆ្នាំ ១៩៧០
- ការវិវត្តនៃផលិតផលនៃមនុស្សម្នាក់ៗកើនខ្ពស់មានកំណើនទ្វេដងពី ៣,៥ គីឡូក្រាមក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំនាឆ្នាំ ១៩៧០ ដល់ជាង ៧ គីឡូក្រាមក្នុងឆ្នាំ ១៩៧០។

គួរកត់សម្គាល់បានថា ភាគចំណែកនៃ នៃដំណាំកៅស៊ូក្នុងផលទុនដុលជាតិកម្ពុជាមានការវិវដ្តច្បាស់លាស់ហើយបន្ទាប់មកមានការថយចុះចលនានេះប្រព្រឹត្តទៅពីដំណាក់កាល

១.ដើមនៅឆ្នាំ ១៩៥០ ដល់ដើមនៅឆ្នាំ ១៩៦០ ភាគចំណែកនៃដើមដំណាំកៅស៊ូក្នុងផលទុនជាតិហាក់ដូចជាដើរទន្ទឹមជាមួយកំណើននៃផលិតកម្មព្រោះផលិតផលនេះវាចុះឡើងជុំវិញ ៣០% នៃផលទុនដុលជាតិ ។

២.ចាប់ពីដើមដល់បណ្តាចុងឆ្នាំ ១៩៦០ ពេលនោះផលិតផលជាគុណភាពនិងជាតម្លៃកៅស៊ូកើនឡើងមិនឈប់ឈរភាគចំណែកក្នុងផលទុនជាតិចុះមកវិញតិចជាង ២% ជាភស្តុតាងនៃកម្រិត របស់ផលិតផលកៅស៊ូនៃការបែងចែកតាមវិស័យ និងធ្វើឱ្យប្រទេសសម្បូរឡើងក្នុងវិស័យកសិកម្មទោះបីគុណភាពផលិតផលបាត់បង់នូវសារសំខាន់ខ្លះក៏ដោយ

**កសិផលដទៃទៀត៖**

ផលិតផលកសិកម្មដទៃទៀតជាសំណុំដែលមានបរិមាណកើនឡើង នៃវិស័យនេះព្រោះសរុបផលទុនជាតិនៃកសិកម្មគឺ ១៥% ច្រើនជាងផលិតផលស្រូវ ។ ប៉ុន្តែដំណាំទាំងនោះមានជាង ដប់ ប្រភេទដំណាំឧស្សាហកម្មហូបផ្លែផលិតផលកាហ្វេតែ ។ល។ មានកម្រិត ១% នៃផលទុនដុលជាតិក្នុងប្រទេសដំណាំនីមួយៗ ។

ដំណាំទាំងនោះសរុបមកជាដំណាំយុទ្ធសាស្ត្រ ហើយដំណាំខ្លះទៀតក៏មានប្រយោជន៍បក្សប្រយោជន៍ជាយុទ្ធវិធីហើយពេលខ្លះធ្វើឱ្យស្មុគស្មាញដល់ការតាមដានការវិវដ្ត ព្រោះជាផលិតផលប្រណិតដូចជាខ្លឹមចាន់ក្រវាញមានការរកស៊ីចំណេញលូតលាស់នាំចេញ ដែលទាក់ទងនឹងតម្លៃទីផ្សារពិភពលោក cours modiaux ដែលការនាំចេញគ្មានទុកស្នាមនៃការកត់បញ្ជីគណនេយ្យឡើយ។

**សមាសភាពបីផ្សេងទៀតនៃផ្នែកកសិកម្មនេសាទការចិញ្ចឹមសត្វនិងរុក្ខា ការវិភាគ សរុប ៖**

ក្រៅអំពីភាពមិនច្បាស់លាស់និងអថេរនៃប្រភពពីមួយឆ្នាំ ទៅមួយឆ្នាំសមាសភាពផ្សេងទៀតនៃវិស័យកសិកម្មដូចជានេសាទការចិញ្ចឹមសត្វ និងរុក្ខាហាក់ដូចជាការគិតជាភាគរយគឺមានស្ថេរភាពក្នុងរយៈពេលមួយក៏ដូចជាសារៈសំខាន់នៃតម្លៃផងដែរ។

ផលិតផលទាំង ៣ មុខនេះក្នុងអាណត្តិនៃនិន្នាការ

- ក្នុងឆ្នាំ ១៩៩៦០ មាន ៨.៥% នៃផលទុនជាតិ
- ឆ្នាំ ១៩៧០ មាន ១០.៥% នៃផលទុនជាតិ

នៅក្នុងផ្នែកនីមួយៗនេះលំនឹងសេដ្ឋកិច្ចឃើញ តែដំណាំស្បៀងទេដែលរកឃើញឡើងវិញនូវការខិតខំខ្លាំងក្លា។

### ខ.ការវិភាគតាមប៉ុស្តិ៍៖

គណនាឡើងវិញមួយនៃផលិតផលសត្វពាហនៈតាមមនុស្សម្នាក់ៗឱ្យកំណត់នៃតម្លៃប្រៀបធៀប៖

- ចំពោះត្រីជាតួលេខដូចជាមានស្ថេរភាពក្នុងរយៈពេលវែង គឺមនុស្សម្នាក់ប្រើប្រាស់ត្រីក្នុងមួយឆ្នាំមួយឆ្នាំរវាងពី ២៥ ដល់ ៣០ គីឡូក្រាមគីឡូក្រាម។
- ចំពោះសត្វពាហនៈក្របីគោរួមមាន គឺមានកំណើនជាប្រចាំ គឺកើតទ្វេដងក្នុងរយៈពេល ២០ ឆ្នាំ គឺពីឆ្នាំ ១៩៥០ មនុស្សម្នាក់ម្នាក់មាន ០,២ ក្បាលឡើងដោយ ០,៤ ក្បាលម្នាក់ម្នាក់នៅក្នុងឆ្នាំ ១៩៧០។ រឿងនេះបកស្រាយ ការសម្បូរឡើងនៃសត្វពាហនៈ នៅជនបទជាការកែលម្អជីវភាពការងារដោយសារសត្វទាំងនោះជាកម្លាំងអូសទាញនិងផ្តល់ជាអាហារផងដែរ។

ការប្រើប្រាស់ព្រៃឈើមានចំណូលប្រហែលការប្រើប្រាស់ព្រៃឈើមានចំណូលប្រហែល ៣៥០.០០០ម$^{២}$ នៅឆ្នាំ ១៩៦០ និងជារៀងរាល់ឆ្នាំក៏ត្រូវការចំនួនដូចខាងលើដែរដែល ១/៣ សម្រាប់នាំចេញ។

### គ.ផ្នែកទីពីរ៖រដ្ឋបាល និង សេវាកម្ម

ចំពោះផ្នែកផលិតកម្មពីរទៀត មានការវិភាគតាមផ្នែកតូចៗ ដូចតទៅ៖

#### ១.ផ្នែកឧស្សាហកម្ម

ផ្នែកឧស្សាហកម្ម បានកើនទ្វេ ក្នុងប៉ុន្មានឆ្នាំ ដោយសាររោងចក្របានសង់ឡើង ពីមួយឆ្នាំទៅមួយឆ្នាំ តាមចង្វាក់ឧស្សាហូបនីយកម្ម នៃកម្ពុជា ព្រោះវិស័យនេះ ចេញដំណើរ ពីផលិតកម្មសូន្យ មកដល់ផលិតកម្ម ដែលពេញទៅដោយកំណើន តាមរយៈការសង់រោងចក្រថ្មីៗ ។

យើងដឹងហើយថា សម័យសង្គមនយោបាយ ឧស្សាហកម្ម គឺការទទួលជំនយបរទេស កសាងរោងចក្រដែលធ្វើឱ្យកម្ពុជា មានសេចក្តីត្រូវការប្រចាំថ្ងៃ គួរជាទីពេញចិត្ត ។

#### ២.ផ្នែករដ្ឋបាល

ដំណើរវដ្តបាល គឺបញ្ជាក់នូវឡូស៊ីក ក្នុងប្រព័ន្ធសេកិច្ចដែលនៅឆ្នាំ ១៩៦៣ បានធ្វើជាតូបនីយកម្ម ផ្នែកសេដ្ឋកិច្ច ដូចជាធនាគារ និង ពាណិជ្ជកម្មក្រៅប្រទេស ។

**៣.ផ្នែកសេវាកម្ម**

ផ្នែកសេវាកម្ម ស្ថិតនៅនឹងនគួរឱ្យកត់សម្គាល់ ដោយសារការជ្រើសរើស ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ។ បរិមាណទំនិញចម្លងការពាណិជ្ជកម្ម ប្រព្រឹត្តទៅនៅក្នុងផ្ទៃនៃប្រទេស កើនឡើងក្នុងសង្វាក់មួយស្របទៅនឹង ផលទុនដុលជាតិ ។

ចំពោះការហូរ ( Flux ) ផ្សេងៗទៀត ដូចជា ពាណិជ្ជកម្មក្រៅប្រទេស មានរូបភាពប្លែកៗ ដែលត្រូវវិភាគ ព្រោះជាសមាសភាពយុទ្ធសាស្ត្រ ដែលនាំឱ្យមានការវិវដ្តន៍ដល់សំណុំ នៃសេដ្ឋកិច្ច ។

**៤.ពាណិជ្ជកម្មក្រៅប្រទេស**

ការសន្និដ្ឋានរួម នៃការនាំចូល នាំចេញ ពីឆ្នាំ ១៩៥៩ ដល់ ១៩៧០ ឱ្យដឹងថា៖

១.ឆ្នាំចុងក្រោយនោះមិនអាចយកជាការបាននោះទេ ដោយហេតុថាជាឆ្នាំនៃការចាប់ផ្តើមសង្គ្រាមដែលរារាំង ដល់ចលនាពាណិជ្ជកម្ម ។

២.តួលេខពីឆ្នាំ១៩៦៧ ដល់ ១៩៦៩ ផ្លាស់ប្តូរពីប្រភពមួយទៅប្រភពមួយផ្សេងទៀត។ គេអាចសន្និដ្ឋានបានឡើងវិញ អត្រាប្តូរប្រាក់មួយដុល្លារ ស្មើរ ៣៥ រៀល ។

៣.បើតួលេខបង្ហាញនូវការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំគេអាចគិតតួលេខឡើងវិញពីឆ្នាំ ១៩៥៧ ដល់ ១៩៦៩ ។

ការវិភាគសរុប៖

ការបង្ហិតជិតគ្នា ក្នុងនាមនៃនិន្នាការ អាចបញ្ជាក់លើសសម្មតិកម្ម ការកសាងឡើងតាមការកម្រិតរីកចម្រើនរបស់ប៉ូលត្បូង " កំពុងអភិវឌ្ឍន៍"។ សង្ខេបយោបល់ គឺដូចតទៅ៖

១.មានកំណើនមួយដាច់ខាត៖ ការពិនិត្យលើនិន្នាការបានឱ្យដឹងថា ពាណិជ្ជកម្មក្រៅប្រទេស បានកើនឡើងជិតបីដង ក្នុងរយៈពេល ២០ ឆ្នាំ កើនពី ៨០ លានដុល្លារ នៅឆ្នាំ ១៩៥០ ដល់ជិត ២២០ លានដុល្លារ នៅឆ្នាំ ១៩៧០ ។

២.មានការថយចុះមិនដាច់ខាតមួយ៖ សមាមាត្រ រវាងបរិមាណ នៃពាណិជ្ជកម្មក្រៅប្រទេស និង ផលទុនដុលជាតិ៖ នៅឆ្នាំ ១៩៥០ ពាណិជ្ជកម្មក្រៅប្រទេសមាន ២៧% នៃ P.N.B គឺប្រហែល ១/៤ ។ នៅឆ្នាំ ១៩៧០ មានចំនួនតែ ១៨% នៃផលទុនដុលជាតិ គឺ ស្មើនឹង ២២០ លានដុល្លារ P.N.B.។ កម្ពុជា ទទួលបានផលសំខាន់ល្មម ពីការផ្លាស់ប្តូរជាមួយបរទេស ។

៣.និន្នាការមួយ ផ្ទុយពីសមាមាត្រ នៃការនាំចូល ពីការនាំចេញ៖ បើកម្រិតនៃការនាំចូលកើនជាងតម្លៃនៃការនាំចេញ "ពេលខ្លះកើនដល់ ១០០% ដូចឆ្នាំ ១៩៦២ ដែលនៅឆ្នាំនោះ ការនាំចេញឡើងដល់ ៤៩.៥ លានដុល្លារ ហើយការនាំចូលដល់ ១០២ លានដុល្លារ" នៅក្នុងរយៈពេលនោះការនាំចូលនៅតែរក្សានិន្នាការ រវាង ២០ និង ៣០ លានដុល្លារ លើសការនាំចេញ ។

ទំនើបភាវូបនីយកម្មនៃកម្ពុជាក្នុងវិស័យសង្គម គឺបានប្រត្តិបត្តិការជាបុព្វសិទ្ធិដោយបង្កើនឧស្សាហូបនីយកម្មបម្រើទីផ្សារក្នុងប្រទេសផង និងបម្រើកំណើនផលិតកម្មកសិកម្មឧស្សាហកម្មសម្រាប់ទីផ្សារក្រៅប្រទេសផងនោះជារូបភាពនៃការអភិវឌ្ឍមួយប្រមូលផ្តុំខុសប្លែកពីប្រទេសភូមា ដែលវាមិនសូវបានទទួលជោគជ័យលើផ្នែកសេដ្ឋកិច្ច។ ឡូស៊ីកនៃការអភិវឌ្ឍនៅកម្ពុជា គឺជាការរំដោះខ្លួនចេញពីភាពរណេបនៃពិភពខាងក្រៅ ។

រូបភាពមធ្យមនៃការនាំចេញ នៅពាក់កណ្តាលតំណាក់កាលសិក្សានៅជុំវិញឆ្នាំ ១៩៦០ គឺដូចតទៅ៖

- ៧០% នៃការនាំចេញ គឺជានាដោយផលិតផលអង្ករ និង កៅស៊ូ
- ២៧% គឺជាអង្គធាតុ នៃផលិតផល ចំនួន ១០ ប្រភេទដែលមានការឆ្លៀតយកចំនេញខ្ពស់ប៉ុន្តែជាស្ថិតិមិនអាចដឹងប្រាកដបាន ។

បើស្រូវ និង កៅស៊ូ មានសារៈសំខាន់ដល់កម្រិតខ្ពស់ នៅឆ្នាំ ១៩៦១ ការនាំចេញ កសិផលទាំងពីរប្រភេទវិវឌ្ឍន៍ជាប្រព័ន្ធផ្ទុយគ្នា ៖

– ដល់ឆ្នាំ ១៩៥០ សភាពការណ៍ផ្ទុយមកវិញ ព្រោះកៅស៊ូបាននាំចេញតែជាង២០% ។

– នៅបណ្តាឆ្នាំ ១៩៥០ កៅស៊ូ ៥០% បាននាំចេញ គឺស្មើនឹងទ្វេដងនៃតម្លៃនាំអង្ករចេញ ២៥%

– ពោត ដែលការនាំចេញថយចុះឃើតៗ តែនៅតែមាននាំចេញជាប្រចាំពី ១៥% ទៅ ១០%

– កសិផលផ្សេងៗទៀត ដែលភាគចំណែកកើន ១/៤ គឺជា ១៥% ទៅជិត ២០% ។

នៅក្នុងថាមពលនេះ គេយល់ថា ពួកខ្មែរក្រហមជឿដល់អនាគតកម្ពុជា លើវិស័យស្រូវអង្ករ ។ ការនាំស្រូវចេញ ឃើញមានតម្លៃស្ថេរភាព ។

រូបភាពមធ្យមនៃការនាំចូល នៅចុងឆ្នាំ ១៩៦០ បង្ហាញថា មានភាពខុសគ្នាពីការនាំចូលគ្មានវិស័យណាមួយ គ្របដណ្តប់លើគេនោះទេ ។ ផ្នែកជាង ១៥ សរុបមកបាននាំចូល ៨៤% នៃការនាំចូល៖

១.ផលិតផលពីរប្រភេទ ឈរនៅជួរទីមួយ ដែលមានផ្នែកនីមួយៗ ជាមធ្យម គឺ ១៣% ទៅ ១០% នៃការនាំចូល៖ ១ ផលិតផលគីមី ១៥.៣% និង ២ ម៉ាស៊ីនឧស្សាហកម្ម ១១.៤%។

២.ផលិតផលបីប្រភេទ ឈរនៅជួរទីពីរ ផ្នែកនីមួយៗជាមធ្យម ៨% នៃការនាំចូលៈ ៣ ផលិតផលប្រេងកាត "៨.៣% " ៤ វាយនភ័ណ្ឌ "៨%" និង ៥ រថយន្ត ម៉ូតូ និង គ្រឿងបន្លាស់ "៧.៧% ។

៣.ផលិតផលបួនប្រភេទឈរនៅជួរទីមួយ នៃភាគនាំចូលគឺ ៥% ក្នុងផលិតផលនីមួយៗ ៦ សម្ភារអគ្គិសនី ៧ ផលិតផលស្បៀង ៨ ដែក និង ដែកថែប ៩ វត្ថុលោហៈធាតុ ។

៤.ផលិតផលបួនឈរនៅជួរទីបួនមាន ២.៥% ជាមធ្យម គឺ ១០ សម្ភារផ្លូវដែក ១១ ផលិតផលឱសថ ១២ ស៊ីម៉ង់ និង ១៣ សម្ភារកសិកម្ម។

៥.ផលិតផលនាំចូលផ្សេងៗទៀត ១៦% មានប្រភេទនីមួយៗ តិចជាង ១% ដូចជា លោហៈធាតុមិនមែនជាដែក និង ក្រដាស គេមិនអាចដឹងបានពិតឡើយ ។

គេអាចកត់ត្រាបាននូវការវិវដ្តនៃការនាំចូលតាមមធ្យោបាយមិនផ្ទាល់ តាមតួលេខពីឆ្នាំ ១៩៥៧ដល់ ១៩៦៨។ គេអាចប្រមូលផ្តុំការនាំចូលជាប៉ុស្តិ៍ធំៗចំនួន៧សម្រាប់ពិនិត្យនូវស្ថេរការនាំចូលតាមរយៈគណនេ-យ្យជាតិ។

យើងបង្ហាញនូវនិន្នាការពីរ៖

- នៅឆ្នាំ ១៩៥០៖ ជាង ៧% នៃការនាំចូល មានការបង្កើនឡើង នូវប៉ុស្តិ៍បីសំខាន់ នៃផលិតផលថយចុះ៖ ផលិតផលស្បៀង ហើយនិង ក្រណាត់ ។ មួយភាគបួនធំនៅសល់ប្រមូលផ្តុំ ផាល់ការនាំចូលផ្សេងៗទៀត ក្នុងនោះរាប់ទាំងលោហៈធាតុ ។ នោះជាសេដ្ឋកិច្ច ឱនាភិវឌ្ឍន៍ដែលជាអាទិភាព នៅមានការនាំចូលៀផលិតផលស្បៀង និង វាយណភណ្ឌ ហើយសកម្មភាពសំខាន់នៃកម្ពុជា គឺកសិកម្ម និង សិប្បកម្មជនបទជាស្នាដៃស្ត្រីនោះគឺ តំបាញ ។
- នៅឆ្នាំ ១៩៧០ សភាពការណ៍ផ្ទុយស្រឡះ ២/៣នៃការនាំចូល គឺប៉ុស្តិ៍ពីរ "លោហៈធាតុ " ៤០% ដែលជាជំពូករួមមានផលិតផល ដូចជា ម៉ាស៊ីនឧស្សាហកម្ម សម្ភារអគ្គីសនី សម្ភារផ្លូវដែក ។ល។ នោះជាធន្ទៈនៃការបំពាក់សម្ភារ។ ចំពោះផ្នែកផ្សេងៗ"២០%"ជាផលិតផលមូលដ្ឋាន ផលិតផលគីមីឱសថ ។ល។ ដែលនៅឆ្នាំ ១៩៥០ គ្មានការនាំចូលទេ។ ១/៣នៅសល់ ប្រមូលផ្តុំលើការនាំចូល នូវផលិតផលរ៉ែដែលមាននិន្នាការរីកខ្លាំងឡើង ។

ផ្នែកនាំចូលឆ្នាំ ១៩៥០ ជាស្បៀង និងវាយនភណ្ឌបានថយចុះ ៣/៤ នៃតម្លៃដាច់ខាត ហើយផលិត ផល " ប្រណិត" ដូចរថយន្ត មិនកើនភាគរយទេ ។ ចលានាពាណិជ្ជកម្មនៅក្រៅប្រទេស បញ្ជាក់តាមការសិក្សា ទាញចេញពីស្ថិតិផលិតកម្ម៖ រវាង ១៩៥០ និង ១៩៧០ កម្ពុជាបានចេះឆ្លងកាត់ស្ថានភាពសង្គម កសិកម្ម ទៅកាន់សង្គម កំពុងអភិវឌ្ឍន៍ ឧស្សាហកម្ម ហើយការចំណាយជាអាទិភាព គឺហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ នៃកំណើនឧស្សាហកម្ម ជាមូលដ្ឋាន ។

# មេរៀនទី ៣
# កសិកម្ម

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ការចូលរួមនៃកម្មវិធីកសិកម្មក្នុងការអភិវឌ្ឍន៍ឿនសេដ្ឋកិច្ចជាតិ
- កត្តាសំខាន់ៗនៃផលិតកម្មកសិកម្ម និងរចនាសម្ព័ន្ធកសិកម្ម
- ផលិតផលនៃវិស័យកសិកម្ម
- ការធ្វើពាណិជ្ជកម្មកសិកម្ម
- បរិបទនៃលំហូប្រពៃណី
- និន្នាការកែលម្អសៀគ្វី

នៅក្នុងវិស័យកសិកម្ម មានប្រជាជនសកម្ម ធ្វើការងារចំនួន ៨០% ហើយរួមវិភាគទានដល់ផលទុនជាតិចំនួនជាង ៤០% ។ យើងនឹងសិក្សាជាបន្តបន្ទាប់នូវកត្តាផលិតកម្មកសិកម្មធម្មជាតិ នៃផលិតកម្មនេះ ហើយនៅចុងបញ្ចប់សិក្សាពីបញ្ហាពាណិជ្ជកម្ម វិស័យកសិកម្ម។

## ៣.១.កត្តានានានៃផលិតកម្មកសិកម្ម និងរចនាសម្ព័ន្ធដីធ្លីកសិកម្ម

ក្រៅពីពលកម្ម ដីដាំដុះ គឺជាកត្តាសំខាន់នៃផលិតលកម្មកសិកម្ម។ លក្ខណៈគួរឱ្យកត់សម្គាល់នៅទីនេះ គឺគ្មានបញ្ហាដីធ្លីជាប្រចាំនៅកម្ពុជាទេ។

**ក.**ដីដាំដុះមិនខ្វះទេ ហើយផ្ទៃដីនេះចេះតែកើនជាប្រចាំ។ ការកើនឡើងនៃផ្ទៃដីដាំដុះនេះ មិនស្មើគ្នាទេ យោងទៅតាមប្រភេទដំណាំ។ ផ្ទៃដីដាំដុះកៅស៊ូកើនឡើងជាប្រចាំ តែឆ្លងកាត់សង្គ្រាម ២ ទសវត្ស ផ្ទៃដីអាជីវកម្ម កៅស៊ូថយចុះ មិនទាន់បានស្តារឱ្យបានស្មើមុនសម័យសង្គ្រាមនៅឡើយ។ ផ្ទៃដីដាំកៅស៊ូស្មើនឹង ២% នៃផ្ទៃដីដាំ កៅស៊ូនៅទូទាំងប្រទេស។ ផ្ទៃដីដាំដុះសម្រាប់ដំណាំផ្សេងៗទៀតក្រៅពីស្រូវ មានការផ្លាស់ប្តូរខ្លាំងក្លាណាស់ ដូចជា ពោត កប្បាស សណ្តែកដី ម្រេច។ ឧទាហរណ៍ គួរឱ្យចាប់អារម្មណ៍ គឺ ដីដាំពោតៈ ចន្លោះឆ្នាំ ១៩៤០-១៩៤១ ផ្ទៃដី ដាំពោតមានចំនួនលើសពី ២៥០,០០០ ហិចតា ចន្លោះ ១៩៤៥-១៩៤៦ មាន ១,០០០ ហិចតាហើយសព្វថ្ងៃមានតែ ១៥០,០០០ ហិចតាប៉ុណ្ណោះ។ គឺមានតែផ្ទៃដីដាំស្រូវទេ ដែលមានចំនួនពី ៧០% ទៅ៩០% នៃផ្ទៃដីដាំដុះសរុប។ ផ្ទៃដីដាំស្រូវនេះទៀតក៏រេណបតាមឆ្នាំមួយទៅមួយដែរ ឆ្នាំខ្លះភ្លៀងធ្លាក់ល្អ ឆ្នាំខ្លះទឹកជំនន់។ និន្នាការទឹកភ្លៀង មិនសូវច្បាស់លាស់។ ចន្លោះរវាងឆ្នាំ ១៩៤០-១៩៦០អត្រាកំណើនប្រជាជនកើនឡើងប្រហែល ២៣ ហើយ ផ្ទៃដីដាំដុះស្រូវក៏កើនឡើងក្នុងសង្វាក់ប្រហែល ២% ក្នុងមួយឆ្នាំដែរ។ ផ្ទៃដីដាំដុះក្នុងមនុស្សម្នាក់ មិនថយចុះទេ តែកើនឡើងបន្តិចៗដែរ។

**ខ.ភាពយឺត Elasticité៖** នៃការផ្តល់ដីជាំជុះនេះ ហើយដែលគ្មានការចោទឡើងនូវបញ្ហាដីធ្លីជាំជុះ ប្រចាំនៅកម្ពុជា។

**ទីមួយ** ភាគច្រើននៃកសិករកម្ពុជា គឺជាម្ចាស់កម្មសិទ្ធិដីធ្លី។ នៅកម្ពុជា មិនសូវមានពលករស៊ីឈ្នួលទេ ក្នុងវិស័យកសិកម្ម មានតែកម្មករចំការកៅស៊ូតែប៉ុណ្ណោះ។

តួលេខកម្មករកសិកម្មគ្មានចំនួនច្បាស់លាស់ទេ។ ប៉ុន្តែគេដឹងថានៅឆ្នាំ ១៩៦២ នាតំបន់ជនបទ មានកម្មករប្រភេទនេះ ចំនួន ១៥០,០០០ នាក់ ស្មើ ៧% នៃប្រជាជនសកម្មនៅតាមតំបន់នានាទាំងនោះ។ ហើយបើគេដកចេញនូវមន្ត្រីនានា ព្រះសង្ឃ និងកម្មករមិនមែនកសិកម្មនោះគេសន្និដ្ឋានថា កម្មករកសិកម្មមានចំនួនតិចជាង ១០០,០០០ នាក់ គឺស្មើនឹង ៥% នៃប្រជាជនសកម្មជាកសិករទូទៅនៅសម័យនោះ។ នៅរដូវជាំជុះ ច្រូតកាត់ មានការអំពាវនាវ កម្មករបណ្តោះអាសន្នតាមរដូវ មកជួយធ្វើការងារ គឺជាកម្មករស៊ីឈ្នួលប្រចាំថ្ងៃ។

កសិករជាម្ចាស់កម្មសិទ្ធិរួមមាន ៨០០,០០០ គ្រួសារ នាឆ្នាំ ១៩៦២ ដែលបែងចែកភាគរយ៖

ម្ចាស់កម្មសិទ្ធិ..............................................៨៤
កសិដ្ឋាន និងម្ចាស់បំណុល..............................................៦
ម្ចាស់កសិដ្ឋានបុលបណ្តាក់..............................................៧
អ្នកមិនមែនឯកទេសខាងកសិកម្ម..............................................៣

ការបុលបណ្តាក់ពាក់កណ្តាល គឺបានត្រូវម្ចាស់កម្មសិទ្ធិដីធ្លីផ្តល់ពូជឱ្យ។ អត្រាបែងចែកមានផលប្រយោជន៍ដ៏ខ្លាំងដល់ម្ចាស់ដី ជាការអនុវត្តនៅក្នុងប្រទេសឱនាភិវឌ្ឍន៍។ ការជួលដីយោងទៅតាមដីល្អថ្លៃជាង ដីមធ្យម។ ជួនកាលថ្លៃឈ្នួលគិតជាស្រូវ។ ដោយសារការផ្តល់ដីសម្បូរ អត្រាថ្លៃឈ្នួលដីមិនខ្ពស់ទេ។ ការខ្ចីបុលយកឈ្នួលដី ប្រព្រឹត្តទៅជាបណ្តោះអាសន្ន ដោយកសិករជាម្ចាស់ដី ដែលចង់ពង្រីកផ្ទៃដីអាជីវកម្ម ។

**ទីពីរ** ការបែងចែកកម្មសិទ្ធិដីធ្លី គឺមិនខុសគ្នាពេកទេ។ លោក M.Delvert ពិនិត្យឃើញសំណូមពរ

តួលេខនាឆ្នាំ ១៩៥៦ ជាភាគរយដូចតទៅ៖

កម្មសិទ្ធិ តិចជាង ១ ហ.ត..............................................៥៥
កម្មសិទ្ធិ ពី ១ ទៅ ២ ហ.ត..............................................២៥
ពី ២ ទៅ ៥ ហ.ត..............................................១២
ពី ៥ ទៅ ១០ ហ.ត..............................................៧
ពី ១០ ទៅ ២០ ហ.ត..............................................១
លើសពី ២០ ហ.ត..............................................០.២

តួលេខនេះ មិនសូវច្បាស់លាស់ទេ តែបានបញ្ជាក់ថា កម្មសិទ្ធិដីធ្លីធំៗមានតិចតួចទេនៅកម្ពុជា។ ទាំងព្រះរាជា ទាំងព្រះរាជវង្ស ទាំងវត្តអារាម ទាំងពួកពាណិជ្ជករ អ្នកមាន ទាំងមន្ត្រី

ជាន់ខ្ពស់ មានដីនៅទីនេះ ឬទីនោះ មិនលើសពី ២០ ហិចតា ដែលមិនមានតួនាទីសំខាន់ក្នុងវិស័យកសិកម្មឡើយ។ ក្រុមហ៊ុនធំៗដែលដាំកៅស៊ូ ៥,០០០ ហិចតា ក្នុងក្រុមហ៊ុននីមួយៗ ទៅលើដីក្រហម មិនមែនជាម្ចាស់កម្មសិទ្ធិដីនោះទេ គេគ្រាន់តែជួលដីជាសម្បទាន តាមគោលការណ៍ច្បាប់រដ្ឋតែប៉ុណ្ណោះ តាមប្រពៃណីនៅកម្ពុជា ពួកអ្នកមានមិនមែនជាម្ចាស់ដី ម្ចាស់ឧស្សាហកម្មទេ តែជាពួកពាណិជ្ជករ ឬ មន្ត្រីនានា។ នោះហើយជាស្នាមសង្គមសេដ្ឋកិច្ចកម្ពុជា។

ទោះបីផ្ទៃដីត្រូវបានបែងចែកឡើងវិញឱ្យកសិករ ក្រោយពីធ្វើសមូហកម្មជាសហករណ៍សមូហភាព អស់រយៈពេលជាង បីឆ្នាំ ក៏សមាសភាពនៃកម្មសិទ្ធិដីដាំដុះ មិនមានការប្រែប្រួលច្រើនទេ។ រាជរដ្ឋាភិបាល អនុញ្ញាតឱ្យមានការសម្បទានដី សម្រាប់អាជីវកម្មដំណាំផ្សេងៗរយៈពេល ៦០ ឆ្នាំ ។

កម្មសិទ្ធិធំៗ ក៏គ្មានសារៈសំខាន់អ្វីដែរ នៅទូទាំងប្រទេស ដែលនៅមានខ្លះៗ នៅខេត្តបាត់ដំបង និងស្វាយរៀង។ កម្មសិទ្ធិដីធំៗទាំងនោះ មាននិន្នាការលិចបាត់ទៅវិញ។ ប៉ុន្តែបាតុភាពមួយបានកើតឡើង គឺពួក ពាណិជ្ជករ និងមន្ត្រីនានាបានទិញដីយកមកជួល។ នៅឆ្នាំ ១៩៦២ គ្រួសារចំនួន ៣០,០០០ ដែលមិនមែនជាកសិករ ជាម្ចាស់ កម្មសិទ្ធិដីទាំងនោះ។

ដូចនេះឃើញថា កម្ពុជាជាប្រទេស ដែលមានកម្មសិទ្ធិដីធ្លីតូចៗ។

**គ**.លទ្ធផលដែលមានការខិតខំធ្វើអាជីវកម្ម កសិកម្ម ភាគច្រើននៅកម្ពុជាគឺកម្មសិទ្ធតូចៗ និងមធ្យម។

ការបែងចែកអាជីវកម្មធ្វើឡើងដោយឯកជនខាងកសិកម្មដែលអាចគិតជាភាគរយនៅឆ្នាំ ១៩៦២ ដូចតទៅះ

| ចំនួនអាជីវកម្ម | ផ្ទៃដីធ្វើអាជីវកម្ម |
|---|---|
| តិចជាង ១ ហ.ត | .៣១៥ |
| ១ ទៅ ២ ហ.ត | ២២១០ |
| ២ ទៅ ៥ ហ.ត | ៣៣៣៨ |
| ៥ ទៅ ១០ ហ.ត | ១០២៥ |
| ១០ ទៅ ២០ ហ.ត | ៣.៤១៦ |
| លើសពី ២០ ហ.ត | ០.៦៦ |

ផ្ទៃដីដាំដុះ ជាមធ្យមដាំស្រូវ ម្នាក់មានដីមធ្យម ១.៣ ហ.ត.។ ផ្ទៃដីនេះ គឺច្រើនណាស់។ នៅប្រទេសអាស៊ី លើកលែងតែភូមា និងថៃ គ្រួសារកសិករ មានដីដាំស្រូវក្នុងមួយគ្រួសារពី ០.២ ហ.ត.ទៅ ២ ហ.ត.ហើយអ្នកដែលមានដីធ្វើអាជីវកម្មខ្ពស់បំផុត គឺពី ០.៤ ដល់ ០.៦ ។

**ឃ**.សារៈសំខាន់នៃកត្តាផលិតកម្មផ្សេងៗទៀត មិនសូវមានអានុភាពពេកទេ។ កសិករធ្វើការងារជាមួយ ដើមទុនតិច គោ ១ នឹម ឬក្របី នង្គ័ល រនាស់ កណ្ដៀវ និងរទេះ តែខ្វះឧបករណ៍

ទាំងនេះមិនបានឡើយ។ ការធ្វើ អន្តរតូបនីយកម្មគ្រាន់តែជាការចាប់ផ្តើម៖ នាឆ្នាំ ១៩៦៣ មានត្រាក់ទ័រចំនួន ៦០០ គ្រឿង ក្នុងនោះ ៤០០ គ្រឿង នៅក្នុងខេត្តបាត់ដំបង ។

ការប្រើប្រាស់ជីគីមី ក៏ចាប់ផ្តើមនៅក្នុងមជ្ឈដ្ឋានកសិករដែរ" គិតជាតោន "

១៩៦១........................................៩៥០
១៩៦២........................................១,៤០០
១៩៦៣........................................៦,៦០០
១៩៦៤........................................៨,៥០០
១៩៦៥........................................៤,៦០០
១៩៦៦........................................១១,៧០០
១៩៦៧........................................១៣,៣០០

ក្រោយឆ្នាំ ១៩៨០ ដើមឆ្នាំ ១៩៩០ ការអនុញ្ញាតឱ្យឯកជននាំចូលជីគីមី កើនឡើងរាប់ម៉ឺនតោន ក្នុងមួយឆ្នាំ។ តាមតួលេខខាងលើ គឺការប្រើប្រាស់ជី ៥ គ.ក្រ.ក្នុង ១ ហ.ត.ប្រៀបធៀបប្រទេសជប៉ុន ៨០០ គ.ក្រ.តៃវ៉ាន់ ២០០ គ.ក្រ.ឬស្រីលង្កា ៥០ គ.ក្រ.។ ប៉ុន្តែតួលេខនេះ ឈរនៅខាងមុខប្រទេសភូមាដែរ។

## ៣.២.ផលិតផលនៃផ្នែកកសិកម្ម

យើងពិនិត្យមើលផ្នែករចនាសម្ព័ន្ធនៃផលិតផលកសិកម្មដោយវិភាគលើផលិតកម្មផ្សេងៗនិងការវិវដ្ត របស់ដំណាំទាំងនេះ។

សម្រាប់ឆ្នាំ ១៩៦២ និង១៩៦៣ មានការផ្តល់នូវតម្លៃបន្ថែម តាមរយៈការបង្វិលនៃចម្លងការច្រើនមានដូចជា៖

**តារាង៣.១ ការផ្តល់នូវតម្លៃបន្ថែម តាមរយៈការបង្វិលនៃចម្លងការសម្រាប់ឆ្នាំ ១៩៦២ និង ១៩៦៣**

| | ១៩៦២ | ១៩៦៣ | ១៩៩៦៤ |
|---|---|---|---|
| ស្រូវ | ៣៤ | ៤១ | ៣៥ |
| ដំណាំឱ្យផ្លែ | ១១ | ១២ | ៩.៥ |
| ដំណាំបន្លែ | ៩ | ៨ | ១០ |
| ការចិញ្ចឹមសត្វ | ៧ | ៦ | ១៣ |
| កៅស៊ូ | ៧ | ៧ | ៦ |
| នេសាទ | ៧ | ៧ | ៦ |
| ព្រៃឈើ | ៤ | ៤ | ៨ |
| ពោតក្រហម | ២ | ២ | ៣ |
| ស្ករត្នោត | ២ | ៣ | ១.៥ |

| | | | |
|---|---|---|---|
| ដំណាំផ្សេងៗ | ១៥ | ១១ | ៧ |

រចនាសម្ព័ន្ធនេះ មិនត្រូវកែប្រែច្រើនទេ ក្នុងដំណាក់ការក្រោយសង្គ្រាម។ គួរកំណត់សម្គាល់ថាស្រូវមិន មែនដំណាំតែមួយគត់នៅកម្ពុជានោះទេ។ ផលិតផលកៅស៊ូ ជាចំណែកធំមួយទៀតនៃវិស័យកសិកម្មប្រទេស ដែលមានចំនួន ជាង ៦០,០០០ ហ.ត.ស្មើនឹង ២% នៃផ្ទៃដីដាំកៅស៊ូបានតែប៉ុណ្ណោះ។ គេក៏ឃើញមានដំណាំឱ្យ ផ្លែ ដំណាំបន្លែ ជាច្រើនទៀត។

ក.ស្រូវជាដំណាំសំខាន់នៃកម្ពុជា ព្រោះផលិតផលនេះ បានរួមវិភាគទាន ដល់ទៅ ១/៣ នៃផលិតកម្មហើយជាមូលដ្ឋាននៃស្បៀងអាហារ និងជាទំនិញនាំចេញទីមួយរបស់ប្រទេស ព្រោះយើងដឹងហើយថា ៦៤% នៃ ប្រជាជនសកម្មកម្ពុជា គឺជាកសិករដែលដាំដុះស្រូវលើផ្ទៃដី ពី ៧០% ទៅ ៩០%។ ផ្ទៃដីដាំស្រូវ ពលករសកម្ម ចូលរួមដាំដុះ និងផលិតកម្ម មានដូតទៅះ

– ផលិតផលសរុបកើនជានិច្ចក្នុងសង្វាក់ ស្មើនឹងកំណើនប្រជាជន។ សង្វាក់នេះមាននិន្នាការថយចុះនៅចុងឆ្នាំក្រោយមក ពិសេសក្នុងសម័យសង្គ្រាម។ ក្រោយសង្គ្រាមដោយសារមីនច្រើនពេក ផ្ទៃដីនៅមិនទាន់ស្តារដូចមុនសង្គ្រាមនៅឡើយ។ ប្រជាជនមានស្រូវហូបគ្រប់គ្រាន់ ហើយមានកសិផលនាំចេញទៀតផង។

– ផលិតផលក៏ដូចផ្ទៃដាំដុះមានការផ្លាស់ប្តូរជារៀងរាល់ឆ្នាំដោយសាររបបទឹកភ្លៀងមិនទៀងទាត់។ ដូចនេះ សេដ្ឋកិច្ចកសិកម្មនៅតំបន់ក្តៅ ក៏ដូចកម្ពុជាដែរ មានភាពផ្សងព្រេងច្រើន។

– ផលិតភាពនៃពលករម្នាក់ៗ បានកើនឡើងជានិច្ចសឹងខ្លាំងក្លាតាំងពីដើមសតវត្សមក ។ ទំហំនៃចលនាពលកម្មបានបញ្ជាក់នៃតថភាពនៃបាតុភូតនោះ។ ការថយចុះនៃភាពអត់ការងារធ្វើ ក្នុងផ្នែកកសិកម្មដែល ពីមុននេះមានច្រើនបំផុត។ ការកើនឡើងនៃពលកម្មសង្គមកើនឡើងដោយអនុភាពនៃការពង្រីកផ្ទៃដីដាំដុះថ្មី ដោយមនុស្សម្នាក់ៗ ដែលកើនឡើងពី ០.៥ ហ.ត.ក្នុង ១ នាក់ ឡើងដល់ ១.៣ ហ.ត.នាពេលសព្វថ្ងៃ។

– ទិន្នផលស្រូវ មិនទាន់បានកើននៅឡើយទេ តាំងពីសតវត្សទី ២០ មក ។ ទិន្នផលស្រូវនៅកម្ពុជា ស្ថិតក្នុងចំណោមប្រទេសដែលទាបបំផុតនៅក្នុងលោក។ ក្រៅពីកូនភូមិសាស្ត្រ កម្ពុជានៅមានភាពទន់ខ្សោយខាងវិធានការផ្សេងៗ ។ ការពង្រីកផ្ទៃដីដាំដុះច្រើន ក៏ជាដើមហេតុនៃទិន្នផលទាបនេះដែរ។ ដីដែលត្រូវសត្រាយថ្មី ភាគច្រើនជាដីខ្វះជីជាតិ។ ប៉ុន្តែកម្ពុជា អាចធ្វើប្រពលវប្បកម្មស្រូវបាន។ គំរូជាច្រើនមានការណែនាំ ឧបត្ថម្ភដោយសេវាកម្ម រដ្ឋាភិបាល កសិករខ្លះអាចបង្កើនទិន្នផលស្រូវដល់ពី ៣ ទៅ ៤ តោន ក្នុងមួយហិចតា។ ការធ្វើប្រពលវប្បកម្មនេះ ជាចំណុចសំខាន់នៃសេដ្ឋកិច្ចកសិកម្មកម្ពុជា។

– តាមរយៈអ្នកបច្ចេកទេសកម្ពុជាឱ្យដឹងថា ការធ្វើប្រពលវប្បកម្មស្រូវ គឺតាមរយៈបំប៉នដីស្រែដោយជី ធម្មជាតិ ការរៀបចំភ្លឺទប់ទឹក ការប្រើជីគីមី ការជ្រើសរើសពូជថ្មី ទិន្នផលខ្ពស់ ការអនុម័តយកបច្ចេសទេសដាំដុះ និងតាមរយៈនយោបាយធារាសាស្ត្រ ដែលផ្តល់ដល់ការធ្វើប្រព័ន្ធធារាសាស្ត្រតូចៗ ។

ផលស្រូវពាក់កណ្តាល ទុកសម្រាប់ប្រើប្រាស់ក្នុងស្រុក។ តួលេខនាឆ្នាំ ១៩៥៩ ដល់ ១៩៦៤ បានបញ្ជាក់ពីការប្រមូលផលស្រូវប្រើប្រាស់ដូចតទៅ៖

| | |
|---|---|
| ប្រើប្រាស់ក្នុងប្រទេស | ៥០ |
| នាំចេញ | ២៣ |
| ពូជ | ៧ |
| ធ្វើពាណិជ្ជកម្ម | ៥ |
| ផ្គត់ផ្គង់ដល់ឈ្មួញកណ្តាល | ៥ |
| បាត់បង់ និងដាក់ជង្រុក | ១០ |

ផលិតផលស្រូវ ថយចុះក្នុងប៉ុន្មានឆ្នាំចុងក្រោយមុនសង្គ្រាម ១៩៦៥-១៩៦៦-១៩៦៧ គឺមានបរិមាណទាបជាងឆ្នាំ ១៩៦៣-១៩៦៤ ។ លក្ខខ័ណ្ឌអាកាសធាតុ ជាកត្តាកំណត់នៃការថយចុះនេះ។ ការធ្វើពាណិជ្ជកម្ម ស្រូវនៃការប្រមូលផលឆ្នាំ ១៩៦៤-១៩៦៥ មិនបានល្អទេ។ ថ្លៃស្រូវធ្លាក់ចុះពី ២,២៨០ រៀល ក្នុងមួយតោន នាឆ្នាំ ១៩៦៣ ទៅ ១,៨៧០ រៀល នាឆ្នាំ ១៩៦៤។ កសិករដែលបាត់ក្តីសង្ឃឹមពីការលក់ផលស្រូវ បានបន្ថយការខិតខំ។

**ខ.**ដំណាំឱ្យផ្លែ ក៏បានឱ្យតម្លៃបន្ថែមច្រើនដែរ ។ តម្លៃបន្ថែមនោះ ស្មើនឹង ៣.៥ នៃតម្លៃបន្ថែមរបស់ដំណាំស្រូវ។ តែផលិតផល មិនបានបញ្ជាក់តួលេខច្បាស់លាស់ ។

ផលិតផលផ្លែឈើ មានភាគរយ ដូចខាងក្រោម នាឆ្នាំ ១៩៦២-១៩៦៣

| | |
|---|---|
| ពពួកក្រូច | ៤០ |
| ចេក | ៣០ |
| សាច់ដូង | ១០ |
| ដទៃទៀត | ២០ |

ដំណាំផ្លែឈើខ្វះបច្ចេកទេស មានទិន្នផលមធ្យមទាប។ ដំណាំនេះ ដាំយកផ្លែហូបក្នុងស្រុក ៩០% ។ នៅខេត្តបាត់ដំបង កំពង់ចាម ។ ផ្លែក្រូចពោធិ៍សាត់ បានត្រូវនាំចេញ និងជាវត្ថុធាតុដើមទឹកក្រូច។

ដំណាំបន្លែសណ្តែកខៀវ ប៉េងប៉ោះ ត្រសក់ សាលាដ ឪឡឹក មាននៅគ្រប់កន្លែងពិសេសតាមមាត់ទន្លេ មេគង្គ ដែលដីនេះក៏ត្រូវដាំដុះផងដែរ នូវដំណាំឧស្សាហកម្មដូចជា ពោតក្រហម ថ្នាំជក់ មន កប្បាស ជាដើម។ កាដាំដំណាំចំការ មានភាពជាប្រពលវប្បកម្ម ជាងការដាំដុះស្រូវ។ តែទិន្នផលនៅទាប គឺបាន ១០ តោនក្នុងមួយ ហិចតានូវបន្លែ។ លើកលែងតែសណ្តែកខៀវ សណ្តែកសៀង ដែលធ្វើពាណិជ្ជកម្មបានសម្រាប់នាំចេញ។ បន្លែគ្រប់ គ្រាន់សម្រាប់ប្រើប្រាស់ក្នុងប្រទេស។ ចង់នាំចេញបាន លុះណាតែបន្ថយថ្លៃដើម តាមរយៈការអនុវត្តបច្ចេកទេសដាំដុះ ចាត់តាំងពាណិជ្ជកម្មបន្លែ ដោយបង្កើតរោងចក្រកែច្នៃ។

**គ**.ការចិញ្ចឹមសត្វ គឺ ជាផលិតកម្មកសិកម្មសំខាន់មួយដែរនៅកម្ពុជា។ ការកើនឡើងនៃចំនួនសត្វពាហនៈ ត្រូវរាប់បញ្ចូលទៅជាផលិតកម្មសំខាន់ និងរួមវិភាគទានដល់តម្លៃបន្ថែមដូចជា ការផ្គត់ផ្គង់ឱ្យដល់ឈ្មួញកណ្តាលសម្រាប់យកសត្វទៅកន្លែងសត្តឃាតដែរ។

រវាងឆ្នាំ ១៩៥៥-១៩៥៧ និង១៩៦៣-១៩៦៥ ចំនួនជ្រូកកើនឡើងទ្វេ។ ចំនួនគោ និងក្របី កើនឡើង ពី ៦០% - ៨០% ក្នុងរវាងឆ្នាំខាងលើ។ ទោះបីត្រូវបំផ្លាញដោយសង្គ្រាមក្រោយឆ្នាំ ១៩៧៥-១៩៧៩ ចំនួនសត្វ ពាហនៈនេះ បានកើនឡើងវិញក្នុងអត្រាមួយខ្ពស់។

ក្នុងតម្លៃបន្ថែម គឺផលិតកម្ម " ជ្រូក " ដែលមានសារៈសំខាន់។ តាមតួលេខឆ្នាំ ១៩៦២ ជ្រូកមានប្រហែល ៤០០,០០០ ក្បាល ត្រូវបានផ្គត់ផ្គង់ជាអាហារប្រចាំឆ្នាំនៅកម្ពុជា ហើយជាង ១០០,០០០ ក្បាលសម្រាប់នាំចេញ។ ចំពោះគោ និងក្របី តួលេខដែលផ្តល់ជាសេចក្តីត្រូវការមានចំនួនពី ៥០,០០០ និង២០,០០០ ក្បាល ប្រចាំឆ្នាំ។ ប្រជាជនខ្មែរ ហូបសាច់ និងត្រីជាអាហារ។

ប៉ុន្តែការចិញ្ចឹមសត្វ ឬការចិញ្ចឹមគោ ក្របីមានផលប្រយោជន៍ជាមធ្យោបាយអូសទាញ និងដឹកជញ្ជូន៖

– សត្វ គោ ក្របី នៅកម្ពុជា ផ្តល់ជាពលកម្ម ភ្ជួររាស់ ដឹកជញ្ជូន។ ប៉ុន្តែការប្រើប្រាស់គោនៅ កម្ពុជាមានចំណុចខ្វះខាតត្រង់ថា ប្រើតែគោឈ្មោល ហើយមួយឆ្នាំប្រើតែ ៦០ ថ្ងៃ។ ការពង្រីកសត្វហ្វូង សម្រាប់នាំចេញ ឬយកទឹកដោះ មិនទាន់មានការអភិវឌ្ឍនៅឡើយ។

– សត្វពាហនៈផ្តល់អាចម៍ជាជី ហើយផ្ទៃដីស្រែចំការរាប់លានហិចតាត្រូវការជីបែបនេះ។

– មេគោគួរតែផ្តល់ទឹកដោះ ប៉ុន្តែនៅកម្ពុជា គ្មានករណីបែបនេះទេ ដោយសារការខ្វះលទ្ធភាព នៃបច្ចេកទេស។

ការអភិវឌ្ឍដំណាំស្រូវនៅកម្ពុជា ត្រូវឆ្លងកាត់ការចិញ្ចឹមសត្វ ព្រោះចំការស្រែ ចិញ្ចឹមសត្វពាហនៈទាំង នោះ តាមរយៈចំបើង ហើយផ្ទុយមកវិញ សត្វទាំងនោះ ចិញ្ចឹមស្រែចំការវិញដោយផ្តល់អាចម៍ជាជីស្រស់។

**ឃ**.ការនេសាទ មានភាពជាគ្រួសារ និងសិប្បកម្ម ប៉ុន្តែត្រីជាអាហារមូលដ្ឋានប្រចាំថ្ងៃ បែបជាមច្ឆាស្រស់ ងៀត ប្រឡាក់ ឆ្អើរ ឬជាប្រហុក ផ្អក ឬជាទឹកត្រី។ ការនេសាទប្រព្រឹត្តទៅ នៅទឹកសាប និងសមុទ្រ។ផលិតផលទឹកសាប មានបរិមាណថយចុះ និងបាត់ពូជត្រីជាច្រើន ក្នុងរយៈពេលជាង ៤០ ឆ្នាំកន្លងមក។ ការសិក្សាបញ្ជាក់ថា តួលេខ ១០០,០០០ តោន ត្រីស្រស់ក្នុងមួយឆ្នាំ។រហូតមកដល់សព្វថ្ងៃនេះ ការនេសាទទឹកប្រៃ នៅមិនទាន់អភិវឌ្ឍន៍នៅឡើយ ហើយការបែងចែកការងារនៅមិនទាន់ច្បាស់លាស់។ ការនេសាទទឹកប្រៃធ្វើសម្រាប់ការនាំចេញ ព្រោះប្រជាជននៅមាត់សមុទ្រ មានចំនួនតិចណាស់។ ប្រៀបធៀបមុនសម័យសង្គ្រាមលោក ផលត្រីសមុទ្រក៏ថយចុះដែរ ហើយទីផ្សារខាងក្រៅ ដូចជាមិនទាន់ផ្សារភ្ជាប់នឹងផលិតផលសោះ។ ផលិតផលសរុបមានចំនួន ៤០០,០០០ តោនក្នុងមួយឆ្នាំ។

មួយភាគនៃត្រីទាំងនោះ គឺសម្រាប់នាំចេញ។ ដោយខ្វះវត្ថុធាតុដើម រោងចក្រសម្រាប់កែច្នៃត្រីសមុទ្រ មាន ដំណើរការរអាក់រអួល។ ការនាំចេញភាគច្រើន ធ្វើដោយលួចលាក់។ ការប្រើប្រាស់ក្នុងស្រុក ក៏មានសារៈសំខាន់ណាស់ដែរ។

ធនធាននេសាទ ជាប្រភពធនធានប្រពៃ ដែលផ្តល់អាហារមានជាតិប្រូតេអ៊ីន ដល់ប្រជាជនកម្ពុជា ប៉ុន្តែការធ្វើអាជីវកម្មមិនទាន់មានទិន្នផលខ្ពស់ ហើយមិនរក្សាបាននូវបរិយាកាសជុំវិញ ព្រោះមានការរំលោភច្បាប់នេសាទ ។

**ង.**កៅស៊ូមានឈ្មោះល្បី ជាដំណាំចំការធំៗ ដែលបានបញ្ចូលមកកម្ពុជាដោយក្រុមហ៊ុនអឺរ៉ុបចំនួន ៦ ចាប់ពីឆ្នាំ១៩២០មកនៅលើដីមានដីជាតិ-ដីក្រហមដែលធានាបាននូវផលិតផលនេះ។ ចាប់ពីឆ្នាំ១៩៥៧រដ្ឋាភិ-បាលបានលើកទឹកចិត្តការអភិវឌ្ឍដំណាំកៅស៊ូ ជាលក្ខណៈគ្រួសារ ហើយបង្កើតជាក្រុមហ៊ុនរដ្ឋនៅឡាបានសៀក ខេត្តរតនគិរី។

ក្នុងវិស័យនេះ មានការកត់ចំណាំពីរ ដែលពិនិត្យឃើញ៖ ដំណាំកៅស៊ូ ជាដំណាំនាំចេញ។ ជ័រកៅស៊ូ មិនត្រូវបាននាំចេញទៅទេ គឺត្រូវបានធ្វើការកែច្នៃជាបឋមសិន រោងចក្រនានានៅតាមក្រុមហ៊ុនបានកែច្នៃជាកៅស៊ូក្រែប។ ក្រៅពីនេះរោងចក្រ និងសិប្បកម្ម កម្មន្តសាល កែច្នៃកង់ឡាន កង់ម៉ូតូ កង់ បានត្រូវបង្កើតឡើង ដោយប្រើប្រាស់មួយភាគតូច នៃបរិមាណផលិតផលពាក់កណ្តាលសម្រេច។

## ៣.២.១.ស្រូវ

### ក.ស្ថានភាពផលិតកម្មដំណាំស្រូវនៅកម្ពុជា

ស្ថិតិរបស់រាជរដ្ឋាភិបាលបានបង្ហាញឱ្យឃើញថានៅក្នុងប្រទេសកម្ពុជា ដំណាំស្រូវ និងផលិតកម្មចិញ្ចឹមសត្វមានការកើនឡើងគួឱ្យកត់សម្គាល់នាពេលទសវត្សរ៍កន្លងមកនេះ ក៏ប៉ុន្តែផលិតកម្មដំណាំស្បៀង និងដំណាំជាបែបឧស្សាហកម្មដទៃ គឺមិនដើរទៅមុខ។ ចាប់តាំងពីឆ្នាំ ១៩៩០-១៩៩១ មកដល់ឆ្នាំ២០០០-២០០១ ផលិតកម្មដំណាំស្រូវបានកើនឡើងពី ២.៥ ដល់ ៤ លានតោន គឺមានកំណើនប្រហែលជាង ៦០ភាគរយ។ ផលិតកម្មស្រូវបានកើនពីតម្រូវការក្នុងស្រុក ដែលជាកត្តាធ្វើឱ្យប្រទេសកម្ពុជាមានផលស្រូវលើសពីឆ្នាំកន្លងៗមកនេះ ប៉ុន្តែផលិតកម្មលើសនេះនៅតែមានភាពមិនស្មើគ្នា។ តំបន់ជាច្រើននៅក្នុងប្រទេសកម្ពុជានៅបន្តជួបប្រទះនឹងកង្វះខាតស្រូវ ដោយមានកត្តាលំបាកដូចជា កត្តារូបសាស្ត្រដែលមានផលប៉ះពាល់ទៅលើតំបន់ផលិតកម្ម (ឧទាហរណ៍ គុណភាពទឹកដី) ហេដ្ឋារចនាសម្ព័ន្ធនៅខ្សោយ ព្រមទាំងនៅខ្សោយក្នុងផ្នែកលំហូពាណិជ្ជកម្ម និងពត៌មានទីផ្សារ។

ស្រូវបានកើនឡើងគួឱ្យកត់សម្គាល់នៅក្នុងទសវត្សរ៍កន្លងមកនេះ យោងតាមស្ថិតិក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្ហាញឱ្យដឹងថា កំណើននៃផលិកម្មដំណាំស្រូវបានកើនឡើងស្ទើរតែទាំងអស់កើនមានឡើងក្នុងអំឡុងរយៈពេលពីខុសគ្នា នៅក្នុងរយៈពេលចាប់ពីឆ្នាំ ១៩៩៤-១៩៩៥ ដល់ ១៩៩៥-១៩៩៦ ដែលមានកំណើនច្រើនជាងគេ ១.២លានតោន និងរ

យៈពេលចាប់ពីរឆ្នាំចាប់ពីឆ្នាំ ១៩៩៨-១៩៩៩ ដល់ ១៩៩៩-២០០ អំឡុងពេលនេះផលិតកម្មស្រូវមានកំណើនដល់ ០.៥ លានតោន។ កំណើនផលិតកម្មយ៉ាងគំហុកបានឆ្លុះបញ្ចាំងពីកំណើនទិន្នផល និងផ្ទៃដីប្រមូលផលមានការកើនឡើង។

ការបង្កើតទិន្នផលជាយន្តកម្មសំខាន់នៃផលិតកម្មដំណាំស្រូវនាទសវត្សរ៍កន្លងមកនេះ មិនមានជាការពង្រីកផ្ទៃដីដាំដុះឡើយ។ ទិន្នផលស្រូវជាមធ្យមមានការកើនឡើងពី ១.៣៥តោន ក្នុងមួយហិចតា ដល់ ២.១២តោនក្នុងមួយហិចតា ក្នុងអំឡុងឆ្នាំ១៩៩០-១៩៩១ ដល់ ២០០០-២០០១ គឺកំណើននេះជិតដល់ ៦០ភាគរយ ។ ថ្វីបើអំឡុងពេលនេះផ្ទៃដីដំណាំស្រូវមានការកើនឡើងពី ១.៨៩លានហិចតា រហូតដល់ ២.៣២លានហិចតា ប៉ុន្តែផ្ទៃដីប្រមូលផលជាក់ស្តែងមិនមានការកើនឡើងឡើ-យ។ នៅក្នុងរយៈពេលបីឆ្នាំបន្តបន្ទាប់គ្នាកន្លងមក (១៩៩៨-១៩៩៩ ដល់ ២០០០-២០០១) មានផ្ទៃដីតែ ១.៩៧ លានហិចតា ដែលបានធ្វើការប្រមូលផលជាមធ្យមបើធៀបទៅនឹង ១.៨៦លានហិចតា ក្នុងឆ្នាំ១៩៩០-១៩៩១។ ដោយសារតែផលិតកម្មពឹងផ្អែកទៅលើផ្ទៃដីប្រមូលផល ដែលអាចឡើងចុះរៀងរាល់ឆ្នាំដោយ (សារអាកាសធាតុ ការខូច ដោទឹកជំនន់ និងភាពរាំងស្ងួត) ដូចនេះផលិតផលក្នុងមួយហិចតា គឺជាកត្តាដែលប្រសើរ ដែលតំណាងឱ្យសន្ទស្សន៍រយៈពេលវែងនៃការវិវដ្តរបស់កំណើនផលិកម្មដំណាំស្រូវ ។

ទោះបីជានៅប្រទេសកម្ពុជាយើងមានភាពមិនប្រក្រតីបាតុភូតធម្មជាតិ ឬស្ថានភាពផលិតកម្មកសិកម្មជារួម ក៏មានកម្រិតល្អនៅទូទាំងប្រទេសនាឆ្នាំ២០០៩ ។ យើងបានដាំដុះស្រូវវស្សាលើផ្ទៃដី សរុបជាង ២.៣៣ លានហិចតា ដែលមានទិន្នផលជាមធ្យមចំនួន ២.៦២ តោន/ហិចតា ដោយទទួលបរិមាណផលសរុបប្រមាណជាង ៦០០លានហិចតា និងស្រូវប្រាំងឆ្នាំ ២០០៩ - ២០១០ លើផ្ទៃដីជាង ០.៣៨លានហិចតា ដែលមានទិន្នផលជាមធ្យម ៤.១២តោន/ហិចតា ដោយទទួលបានបរិមាណផលសរុបជាង ១.៥៨លានតោន។ សរុបមកទាំងរដូវប្រាំង និងរដូវវស្សា យើងអនុវត្តន៍បានលើផ្ទៃដីសរុបជាង ២.៧១លានហិចតា ដោយទទួលបរិមាណផលសរុបប្រមាណជា ៧.៥៨លានតោនស្រូវ និងទិន្នផលមធ្យមប្រចាំឆ្នាំ ២.៨៣តោន/ហិចតា ។ ដូច្នេះតុល្យភាពស្បៀង យើងនៅសល់ ជាង ២.២៤លានតោនអង្ករ គិតជាស្រូវជាង ៣.៥០លានតោន លើសឆ្នាំមុនជាង ០.៣៣លានតោនស្រូវ និងខ្ពស់ជាងមធ្យមភាគ ១០ឆ្នាំកន្លងមកជាង ១.២០លានតោនអង្ករ នេះជាជោគជ័យមួយដ៏ធំធេងណាស់។

### ក.១ ផ្ទៃដីដាំដុះស្រូវប្រាំង និងស្រូវវស្សា

ផ្ទៃដីដាំដុះស្រូវប្រាំង នាពេលបច្ចុប្បន្ននេះមានច្រើនរាប់ពាន់ហិចតាដែលកើនឡើង ៤១ភាគរយ បើធៀបនឹងឆ្នាំ១៩៦៧ មាន ១៦៤,០០០ហិចតា ដែលក្រោយសង្គ្រាមការផលិតស្រូវប្រាំងស្មើសូន្យ ហើយនៅឆ្នាំ១៩៨៣ ផលិតកម្មស្រូវប្រាំងបានកើនឡើង ១ភាគរយប៉ុណ្ណោះ។ នៅឆ្នាំ ១៩៩២ ដល់ ១៩៩៣ ផ្ទៃដីដាំដុះស្រូវប្រាំងមាន ៧.៨ភាគរយ នៃផ្ទៃដីដាំដុះសរុប ១,៨៤៤,០០០ ហិចតា ។ ហើយនៅឆ្នាំ១៩៩៦ ដល់ ១៩៩៧ ផ្ទៃដីស្រូវប្រាំងមាន ១០.៤ភាគរយ នៃផ្ទៃដីសរុប ២,០៩០,០០០ហិចតា ។ នៅឆ្នាំ១៩៩៧ មាន ១១.៩៨ភាគរយ នៃផ្ទៃដីសរុប

២,០៧៦,០១១ហិចតា ។ នៅឆ្នាំ១៩៩៨ ដល់ ១៩៩៩ មាន ១៣.៦៦ភាគរយ នៃផ្ទៃដីសរុប ២,១០៤,០១៣ ហិចតា ធៀបនឹងឆ្នាំ១៩៩៧ មានថយចុះ ១.០១ភាគរយ។ នៅឆ្នាំ២០០០ ដល់ ឆ្នាំ២០០១ មាន ១១.២១ភាគរយ នៃផ្ទៃដីសរុបមាន ២,៣១៨,៤៩៥ហិចតា ។

នៅឆ្នាំ២០០០ ដល់ឆ្នាំ២០០៣ មាន ១៣.៦៦ភាគរយ នៃផ្ទៃដីសរុប ២,១៣៧,១២៥ ហិចតា បើប្រៀបធៀបទៅនឹងឆ្នាំ១៩៩៧ មានកើនឡើង ១.៦៨ភាគរយ ។

### ក.២ តំបន់ដាំដុះស្រូវប្រាំង

កាលពី ៣០ឆ្នាំកន្លងទៅស្រូវប្រាំងត្រូវធ្វើការដាំដុះនៅតាមតំបន់ផ្សេងៗ ដែលក្នុងនោះមានតំបន់ ៤ សំខាន់គឺ

- តំបន់ទី១ គឺស្ថិតនៅតាមតំបន់ទំនាបនៅតាមទន្លេធំ នៅក្នុងខេត្តក្រចេះហូតដល់ភ្នំពេញ តំបន់ស្ថិតតាមទន្លេតូចគឺតំបន់នៅតាមទន្លេសាបហូតដល់ខេត្តកំពង់ឆ្នាំង ហើយតំបន់នេះគេចាត់ទុកជា (Northern meso Potamia) គឺស្ថិតនៅតាមទន្លេមេគង្គ។
- តំបន់ទី២ គឺជាតំបន់ទំនាបស្ថិតនៅទិសនិរតីនៃខេត្តព្រៃវែង ហើយទំនាបទាំងអស់នោះមានរហូតទៅភាគខាងតាកែវ ដែលតំបន់នៅទទួលបានទឹកជំនន់ពីទន្លេបាសាក់ ។
- តំបន់ទី៣ គឺតំបន់ទំនាបស្ថិតនៅខេត្តសៀមរាប ។

ក្រៅពីតំបន់ទាំងបីខាងលើនេះ ផលិតកម្មដំណាំស្រូវប្រាំងត្រូវបានធ្វើការដាំដុះបាននៅគ្រប់ទីកន្លែង (បន្ទាប់ស្រូវវស្សា) ឱ្យតែមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពពេញមួយខួបផលិតកម្ម គឺស្រោចស្រពទាំងស្រុង

រួមសេចក្តីមក ផលិតកម្មស្រូវប្រាំងត្រូវបានធ្វើការដាំដុះនៅតំបន់ បី គឺ

- តំបន់ដាំដុះដោយស្រោចស្រពម្តងម្កាល ឬមិនដែលស្រោចស្រពដែលស្ថិតនៅជិត បឹង ទន្លេ ព្រែក និងវាលទំនាបធម្មជាតិ ។
- តំបន់ដាំដុះដោយស្រោចស្រពម្តងម្កាល ដែលដាំដុះក្នុងតំបន់ទឹកជម្រៅគ្មានការដាំដុះពីមុន ។
- តំបន់ដាំដុះដោយស្រោចស្រពទាំងស្រុង បន្ទាប់ពីស្រូវវស្សា ។

នៅប្រទេសកម្ពុជា ខេត្តដែលមានផ្ទៃដីដាំដុះស្រូវប្រាំងច្រើនជាងគេ មានខេត្តតាកែវ កណ្តាល កំពង់ចាម សៀមរាប និងកំពង់ធំ ។

### ក.៣ រដូវកាលដាំដុះស្រូវប្រាំង

នៅប្រទេសកម្ពុជាយើង គេដាំដុះស្រូវប្រាំងប្រដេញទឹកជាបណ្តើរៗ ទន្ទឹមការស្រកទៅវិញនៃទឹក ទន្លេមេគង្គ។ រដូវសម្រកចាប់ពីខែធ្នូ ទៅនឹងរដូវក្តៅបានចូលមកដល់តាំងពីខែមុនមកម្លេះ រួមមកដល់ខែមីនា។ នៅក្នុងរយៈពេលនេះវាមានការអនុគ្រោះច្រើន (មានពន្លឺថ្ងៃល្អ ដី

ល្បាប់ដែលទឹកជំនន់នាំមកដីដែលមានជីជាតិ) ដែលបង្កលក្ខណៈងាយស្រួលដល់ដាំដុះ និងការលូតលាស់របស់ស្រូវ ។

- ប្រភេទទី១ គឺដាំដុះក្រោយប្រមូលផលស្រូវវស្សាមានរដូវដាំដុះ ពីរគឺ (ស្រូវធ្ងន់រដូវប្រាំង គឺចាប់ពីខែតុលា ដល់ ខែមីនា និងស្រូវស្រាលរដូវប្រាំង គឺចាប់បីខែធ្នូ ដល់ខែមករា) ។
- ប្រភេទទី២ គឺស្រូវពង្រោះស្រោចស្រពដែលស្ថិតនៅជុំវិញបឹង ទន្លេ និងកន្លែងស្តុកទឹក។ ស្រូវប្រភេទនេះចាប់ផ្តើមសាបយ៉ាងឆាប់ហើយនៅចុងខែតុលា ហើយយ៉ាងយូរនៅខែកុម្ភៈ ។

## ខ.កត្តាផលិតកម្ម

កត្តាផលិតកម្ម គឺជាធនធានទាំងឡាយណាដែលគេត្រូវការចាំបាច់ ដើម្បីតម្រូវការផលិតនូវផលិត ផលសម្រេច រួមមានកត្តាដីធ្លី កត្តាទុនផលិតកម្ម កត្តាកម្លាំងពលកម្ម កត្តាបច្ចេកទេស និងកត្តាទីផ្សារ កសិផល។ ដើម្បីឱ្យបរិមាណស្រូវកើនឡើងវាអាស្រ័យទៅលើកត្តាផលិត កម្មខាងលើ ហើយបរិមាណផលិតផលកើនឡើងជាលំដាប់ ក៏អាស្រ័យទៅលើប្រសិទ្ធភាពសេដ្ឋកិច្ចនៃកត្តាផលិតកម្មខាងលើផងដែរ។

### ខ.១ កត្តាដីធ្លី

ដីធ្លី គឺជាធនធានដែលបានសង្គមរៀបចំ និងប្រើប្រាស់ក្នុងគោលបំណងដ៏ពិសិដ្ឋ និងសម្បូរបែប របស់ខ្លួន ។

#### *a.*ដីធ្លីក្នុងវិស័យកសិកម្ម

ដីធ្លី គឺជាមជ្ឈដ្ឋានមានជីវិតដែលមិនអាចខ្វះបានសម្រាប់ដំណាំរុក្ខជាតិគ្រប់ប្រភេទក្នុងកសិកម្ម ដីធ្លីមានតួនាទីជាកម្មវត្ថុពលកម្មផង ជាមធ្យោបាយពលកម្មផង។ ដីធ្លីបានដើរតួនាទីជាប្រភពអាហារ ផលិតកម្មឈើ ដីវាលស្មៅ និងដីព្រៃ។ ដីធ្លីជាបង្អែក និងជាមធ្យោបាយសម្រាប់រុក្ខជាតិ និងដំណាំគ្រប់ប្រភេទក្រេបយកជីជាតិចិញ្ចឹមខ្លួន និងរីកលូតលាស់ មិនតែប៉ុណ្ណោះដីធ្លីជាមធ្យោបាយផលិតកម្មដែលមិនអាចជំនួសបានខុសប្លែកពីវិស័យផលិតកម្មផ្សេងៗក្នុងសង្គម គ្រប់មធ្យោបាយផលិតកម្មដែលកំពុងដំណើរការផលិត គេអាចជំនួយដោយមធ្យោបាយផលិតកម្មថ្មីៗ ក្នុងករណីមធ្យោបាយផលិតកម្មទាំងនោះទទួលនូវរងការសឹករិចរឹល ឬខូចខាត។ តែក្នុងកសិកម្មគ្មានមធ្យោបាយផលិតកម្មណាយកមកជំនួស ដីធ្លីដែលសឹករិចរឹលបានឬខូចគុណភាពបានឡើយ។ ដោយហេតុនេះហើយគុណភាពដីធ្លី (កម្រិតជីជាតិ) ត្រូវបានយកចិត្តទុកដាក់ជាន់ខ្ពស់ បើយើងប្រើប្រាស់ដោយសមហេតុផលពោល គឺការប្រើប្រាស់ដីធ្លីត្រឹម ត្រូវទៅតាមបទដ្ឋាន នោះកម្រិតជីជាតិរបស់ដីបែរជាកើនឡើងឥតលំដាប់។ គុណភាពដីធ្លីនេះជះឥទ្ធិពលទាំងស្រុងទៅលើទិន្នផលដំណាំ និងទិន្នផលកសិកម្ម ដូច្នេះការថែរក្សាលើកកម្ពស់គុណភាពដីធ្លីជាភារកិច្ច សំខាន់ និងចាំបាច់បំផុតរបស់អ្នកបច្ចេកទេសកសិកម្ម។

*b.*ផ្ទៃទឹក

ផ្ទៃទឹក គឺគ្រប់ដណ្តប់ប្រភេទដែលបានប្រើប្រាស់សម្រាប់ផលិតកម្មកសិកម្មដូចជាសម្រាប់ចិញ្ចឹម ត្រី ឬឃ្លាំងត្រី ដាំចក ដាំបន្លែ កំប្លោក ដែលបានបម្រើដល់តម្រូវការរបស់មនុស្សដើម្បីយកធ្វើចំណីសត្វ។ ផ្ទៃទឹកដែលបានរក្សាទឹកទុក ជាពាសាស្ត្រ និងជាមធ្យោបាយគមនាគមន៍សំខាន់ គឺមិនបានរាប់បញ្ចូល ឬចាត់ទុកថាជាផ្ទៃដីកសិកម្មឡើយ ។

## ខ.២ កត្តាកម្លាំងពលកម្មក្នុងវិស័យកសិកម្ម

កម្លាំងពលកម្ម គឺជាកត្តាផលិតកម្មដ៏សំខាន់មួយក្នុងចំណោមកត្តាផលិតកម្មទាំងឡាយដោយ សារតែម៉ាស៊ីន និងកម្លាំងពលកម្មក្នុងដំណើរការផលិតកម្មកសិកម្មមិនអាចជំនួសគ្នាបានទាំងស្រុងនោះ ទេ ។

ប្រភពកម្លាំងពលកម្មកសិកម្ម ជាពលកម្មដ៏សំខាន់របស់សង្គម គឺជាកម្លាំងពលកម្មទាំងមូលក្នុងវិស័យ កសិកម្ម ពោលគឺ បរិមាណ និងគុណភាព ។

*a.*ផ្នែកបរិមាណ

- ប្រុសៈ ចាប់ពីអាយុ ១៦ឆ្នាំ ដល់ ៦០ឆ្នាំ ។
- ស្រីៈ ចាប់ពីអាយុ ១៥ឆ្នាំ ដល់ ៥៥ឆ្នាំ ។

ប៉ុន្តែគេអាចរាប់បញ្ចូលក្មេងអាយុទាបជាង ១៦ឆ្នាំ ៣នាក់ ស្មើនឹងកម្លាំងពលកម្មពេញលេញ ១នាក់ និងចាប់ពីអាយុ ៦០ឆ្នាំឡើង ២នាក់ ស្មើនឹងកម្លាំងពលកម្មពេញលេញ ១នាក់ ។

*b.*ផ្នែកគុណភាព

ផ្នែកគុណភាពជាសមត្ថភាពបំពេញការងារប្រកបដោយផ្លែផ្កាក្នុងការងារ មានសុចន្ទៈបំពេញកិច្ច ការចប់ចុងចប់ដើម អ្នកធ្វើពលកម្មពេញលេញ។ ដូចនេះកម្លាំងពលកម្មក្នុងកសិកម្មត្រូវបានគេចាត់ថ្នាក់ ដូចខាងក្រោមៈ

### ក្រាភិច៣.១ ចំណាត់ថ្នាក់ពលកម្មកសិកម្ម




## ខ.៣ កត្តាទុនផលិតកម្ម

ទុនជាកត្តាចាំបាច់នៃផលិតកម្ម វាជាទ្រព្យទាំងឡាយណាដែលយកទៅប្រើប្រាស់ក្នុងផលិតកម្ម គេចាត់ទុកថាវាជាទុនផលិតកម្ម។ ទុនផលិតកម្មកសិកម្មកើតចេញពីប្រភពមួយចំនួនដូចជា ការសន្សំ ការខ្ចីបុលកេរ្តិ៍មរតក អំណោយ ការរៀបអាពាហ៍ពិពាហ៍។ ជាទូទៅគេចែកទុនផលិតកម្មជាពីរប្រភេទ គឺអចលនទុន (សត្វ ដើមឈើ កសិដ្ឋាន អាគារ។ល។) និងចលនទុន (គ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វល្អិត។ល។) ។

## ខ.៤ កត្តាបច្ចេកទេស

គ្រួសារកសិករនៅតាមជនបទក្នុងប្រទេសកម្ពុជាមានប្រហែល ១.៥លានគ្រួសារ ត្រូវជា ៨៥ភាគរយ នៃប្រជាជនទាំងអស់។ ៨២ភាគរយ នៃកម្លាំងពលកម្មនៅទីជនបទទាក់ទងនឹងវិស័យកសិកម្មព្រៃឈើ និងនេសាទផង ហើយការងារសំខាន់ៗគឺ ការផលិតស្រូវ។ ការដាំដុះស្រូវត្រូវបានប្រជាជននៅកម្ពុជាដែលរស់នៅតាមទីជនបទច្រើនជាង ៨០ភាគរយ នៃប្រជាពលរដ្ឋសរុបដែលជ្រើសរើសជាមុខរបរប្រចាំជីវិតមុនគេ ថែមទាំងជាប្រភពរូបិយប័ណ្ណសំខាន់របស់សេដ្ឋកិច្ចជាតិតាមរយៈការនាំផលិតផលកសិកម្មចេញទៅលក់នៅបរទេស។ ផ្ទៃដីដាំដុះស្រូវនៅប្រទេសកម្ពុជាបានកើនឡើងយ៉ាងខ្លាំង គឺប្រហែល ១.៩ ទៅ ២.៣លានហិចតា ក្នុងរយៈពេល ៦ឆ្នាំកន្លងមកនេះ ដែលក្នុងនោះដីទំនាបអាស្រ័យលើរបបទឹកភ្លៀងប្រហែល ៨៨ភាគរយ។ បើតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថាទិន្នផលស្រូវជាមធ្យមដែលបានកើនឡើងពី ១.២ ទៅ ១.៩ តោន/ហិចតា។

*a*.**ការជ្រើសរើសប្រភេទពូជ**

ពូជ គឺជាកត្តាមួយកំណត់អាយុកាល និងទិន្នផលរបស់ដំណាំ។ ប្រភេទពូជនីមួយៗវាមានតម្រូវការបរិស្ថានផ្សេងគ្នា។ ដើម្បីទទួលបានទិន្នផលខ្ពស់មុន និងធ្វើការដាំដុះត្រូវជ្រើសរើសពូជឱ្យបានត្រឹមត្រូវ គឺពូជដែលមានតម្រូវការបរិស្ថានសមស្របទៅនឹងមជ្ឈដ្ឋានដាំដុះ។

តាមការពិសោធន៍របស់លោក លឹម វិជ្ជដា ដែលបានសិក្សាស៊ីជម្រៅអំពីការប្រែប្រួលទិន្នផលអាស្រ័យទៅលើពូជ (ស្រូវស្រាល) ក្នុងគោលបំណងកំណត់រកពូជដែលផ្តត់ផ្គង់ទិន្នផលខ្ពស់ជាងគេដើម្បីយកទៅផ្សព្វផ្សាយជូនកសិករឱ្យបានដឹងថា ក្នុងចំណោមពូជស្រូវស្រាលទាំង ១០ ពូជដែលដាំដុះក្នុងលក្ខខណ្ឌដូចគ្នា គឺមានពូជ ៥ ដែលផ្តល់ទិន្នផលខ្ពស់ជាងគេគឺះ

- ពូជលេខ ១ គឺ ពូជ Cuulong មានទិន្នផលខ្ពស់ជាងគេ គឺ ៦.៧៦ តោន ក្នុងមួយហិចតា
- ពូជលេខ ២ គឺ ពូជ IR ៥០៣៥៣ ១៦-១-២១២ ផ្តល់ទិន្នផល ៦.៧ តោន ក្នុងមួយហិចតា
- ពូជលេខ ៣ គឺ ពូជ IR ១៣៤២៩ ១៥០-៣-២ ផ្តល់ទិន្នផល ៦.៦៧ តោន ក្នុងមួយហិចតា
- ពូជលេខ ៤ គឺ ពូជ IR ៦៦ ផ្តល់ទិន្នផល ៥.៣៥ តោន ក្នុងមួយហិចតា
- ពូជលេខ ៥ គឺ ពូជ IR ៧២ ផ្តល់ទិន្នផល ៥.៣៣ តោន ក្នុងមួយហិចតា

តាមរយៈរបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំរបស់អង្គរ ឆ្នាំ១៩៩៦ បានឱ្យដឹងថា ទិន្នផលស្រូវប្រែប្រួលទៅតាមពូជផ្សេងៗគ្នាគេបានធ្វើពិសោធន៍ទៅលើស្រែ ក្នុងខេត្តតាកែវដែលធ្លាប់មានសត្វកណ្តុលបំផ្លាញ់ និងជួបគ្រោះរាំងស្ងួតគេបានប្រើពូជ Kru ជាគំរូដែលទទួលបានផល ៤ តោនក្នុងមួយហិចតា។ ក្នុងចំណោមពូជដែលទទួលធ្វើការពិសោធន៍ ពូជ BR ១៧០៤-៦-៣-៣៤ ទទួលបានទិន្នផលទាបជាងគេ គឺ ៣.៥តោនក្នុងមួយហិចតា ហើយពូជដែលបានធ្វើទទួលបានទិន្នផលខ្ពស់ជាងគេ គឺ ពូជ IR ៥៦៤៥០-២៨-២-២ ដែលបានផ្តល់ទិន្នផលជាមធ្យម ៤.៣ តោនក្នុងមួយហិចតា ។

*b*.**ការភ្ជួររាស់ដី**

ការភ្ជួររាស់ដីរបស់កសិករធ្វើឡើងពីរដងក្នុងមួយរដូវ គឺលើកទី១ ធ្វើការភ្ជួរប្រែដីនៅរដូវធ្លាក់ភ្លៀងដើមដៃ និងលើកទី២ មុនពេលស្ទូង។ ការរៀបចំលើកទី១ ប្រព្រឹតទៅនៅចុងខែមេសា ឬដើមខែឧសភា និងលើកទី២ ភ្ជួរនៅខែកក្កដាដល់ខែកញ្ញាដែលនៅពេលនោះសំណាបមានអាយុល្មម។ កសិករខ្លះចូលចិត្តរាស់មុនពេលស្ទូងបន្ទាប់ពីភ្ជួរលើកទី១ ប៉ុន្តែកសិករខ្លះទៀតមិនចូលចិត្តការភ្ជួររបៀបនេះទេ ព្រោះពួកគេយល់ថាការភ្ជួររាស់ដីលើកទី២ ធ្វើឱ្យដីរឹងពិបាកស្ទូង។ កសិករខ្លះទៀតយល់ថាការរាស់នេះអាចជួយកាត់បន្ថយស្មៅចង្រៃបានមួយចំនួន។

*c*.**ការប្រើប្រាស់ទឹក**

ទឹកជាកត្តាមួយសំខាន់ណាស់នៅក្នុងផលិតកម្មស្រូវ។ ទឹកមានឥទ្ធិពលទៅលើលក្ខណៈរូបនៃដើមស្រូវ។ ជាតុចិញ្ចឹមរបស់ដី និងការអនុវត្តការងារស្រែចម្ការរបស់កសិករ ការផ្គត់ផ្គង់បានល្អ

និងគ្រប់គ្រាន់នៅក្នុងដំណាក់កាលលូតលាស់ធ្វើឱ្យដំណាំស្រូវទទួលបានទិន្នផលខ្ពស់ ហើយទឹកមានតួនាទីដូចជា៖

- ជួយចូលរួមចំណែកក្នុងការរំលាយសារធាតុខនិចដែលមាននៅក្នុងដី
- បង្កភាពងាយស្រួលដល់ឬស ក្នុងការស្រូបយកជីជាតិ
- ចូលរួមបង្កើតឧស្ម័នអ៊ីដ្រោត តាមរយៈរស្មីសំយោគ

ការខ្វះខាតទឹកជាឧបសគ្គដំបូងដល់ការទទួលទិន្នផលខ្ពស់ តែបើទឹកច្រើនពេកគឺជាបញ្ហាមួយដែរ ដោយធ្វើឱ្យស្រូវលួយ បង្កភាពងាយស្រួលដល់ការកកើតជំងឺ។ល។

កាលណាការគ្រប់គ្រងទឹកបានល្អសម្រាប់ដំណាំស្រូវក្នុងមួយផលិតកម្ម គឺទទួលបានទិន្នផលពី ៣០ ទៅ ៥០ភាគរយ ច្រើនជាងស្រូវមានទឹកតែមិនគ្រប់គ្រាន់។

ការបង្កើតផលស្រូវនៅរដូវប្រាំង គឺមានលក្ខណៈងាយស្រួលជាងការបង្កើតផលស្រូវនៅរដូវវស្សា ពីព្រោះនៅរដូវប្រាំងកសិករអាចគ្រប់គ្រងទឹកបានល្អ (ដោយប្រភពទឹកនិងមធ្យោបាយស្រោចស្រព) ប៉ុន្តែក៏ត្រូវចំណាយច្រើនដែរ គ្រាន់តែការចំណាយទៅលើការបូមទឹក លើផ្ទៃដីមួយហិចតាក្នុងមួយផលិតកម្មអស់ ១៨.៤៥ភាគរយ នៃចំណាយសរុប (ស្រោចស្រពដោយអណ្តូង)។

ការបញ្ចូលទឹកធ្វើឱ្យស្រូវល្អមានទិន្នផលខ្ពស់ និងមិនទាន់មានស្មៅចង្រៃ ប៉ុន្តែពុំទាន់មានបច្ចេក- ទេសណាមួយអាចកំណត់ការបញ្ចេញបញ្ចូលទឹកឱ្យបានច្បាស់លាស់ទេ កសិករបញ្ចូលទឹកស្រែអាស្រ័យ ដោយឃើញ ទឹកស្ងួតដីស្រែ ឬអាស្រ័យដោយមានថវិកាទិញប្រេង ឬជួលម៉ាស៊ីនបូមទឹកតែប៉ុណ្ណោះ។ ការបញ្ចូលទឹកជាមធ្យមរបស់កសិករពី ៥ ទៅ ១០ថ្ងៃម្តង ហើយក្នុងមួយរដូវអាចបញ្ចូលទឹកពី ៥ ទៅ ៦ ដង។

### *ឋ*.ការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិត

កសិករប្រើប្រាស់ជីទៅតាមលទ្ធភាពដែលពួកគាត់មាន ជាទូទៅគាត់បានប្រើប្រាស់ជីខ្មៅ (១៦-២០-០០) ចំនួន ១បាវក្នុងមួយហិចតា និងជីស (អ៊ុយរ៉េ) ចំនួន ២បាវក្នុងមួយហិចតា។ លើសពីនេះកសិករបានប្រើជីអ៊ុយរ៉េជាជីបំប៉ន គឺបាចនៅពេលស្រូវបែកគុម្ពម្តង និងលើកទីពីរនៅពេលស្រូវម៉ូរដើម។ លើសពីនេះកសិករបានប្រើប្រាស់ជីសរីរាង្គមួយចំនួនផងដែលសម្រាប់ថ្នាលសំណាប។ កសិករមួយចំនួនបានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតក្នុងការកម្ចាត់ជំងឺ ដើម្បីឱ្យដំណាំស្រូវរបស់គាត់ជៀសផុតពីកត្តាចង្រៃផ្សេងៗ។ តែទោះបីជាយ៉ាងណាក៏ដោយកសិករទាំងនោះនៅតែជួបប្រទះជាមួយ និងបញ្ហាស្រឹងស្រូវនៅក្នុងដំណាក់កាលដាក់ទឹកដដែល។

### *ឌ*.ការច្រូតកាត់

មុនពេលដែលកសិករធ្វើការច្រូតកាត់ ពួកគាត់បានបង្ហាក់ទឹកទុកក្នុងស្រែសិន ហើយធ្វើការច្រូតកាត់តែដើមស្រូវប្រវែងប្រហែល ៥០ ទៅ ៦០ស.ម ពីដីដោយបន្សល់ទុកគល់ជញ្ជ្រាំងនៅជាប់នឹងដីខ្លះដែរ។ លើកលែងតែស្រូវស្រាលការច្រូតកាត់ប្រព្រឹត្តិទៅក្នុងរដូវរាំងស្ងួត ហើយត្រជាក់ពីខែធ្នូដល់ខែមករា។ ចំពោះការចំណាយកម្លាំងវិញប្រហែល ១០ថ្ងៃក្នុងមួយហិចតា គេត្រូវច្រូតជាក្រុមៗជាមួយអ្នកជិតខាងដូចជាការស្ទួងនោះដែរ។ ក្រោយពីច្រូតកាត់ហើយ គេយកវាទៅ

សម្ដិលហាលដើមស្រូវនៅក្រោមពន្លឺថ្ងៃលើភ្លឺ ស្រែរបស់ពួកគេដើម្បីឱ្យដើមស្រូវស្ងួតសិន ទើបគេធ្វើការចងវាជាកណ្ដាប់តូចៗ។

### គ.ការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករនៅកម្ពុជា

យោងទៅតាមសក្ដានុពល សម្រាប់បង្កើតផលិតផលស្រូវក្នុងព្រះរាជាណាចក្រកម្ពុជា និងតម្រូវការអង្ករក្នុងពិភពលោកដែលនឹងកើនដល់ ៤៩៦លានតោនក្នុងឆ្នាំ២០២០ និង ៥៥៣ លានតោនក្នុងឆ្នាំ២០៣៥ គឺស្មើនឹង ១៣% និង ២៦% ច្រើនជាងឆ្នាំ២០១០ ដែលមានតែ ៤៣៩លានតោននោះ និងជាពិសេសដើម្បីប្រែក្លាយអង្ករឱ្យក្លាយទៅជា **មាស ស** ពិតប្រាកដរបស់ប្រទេសកម្ពុជា កាលពីថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១០ កន្លងទៅនេះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានប្រកាសដាក់ឱ្យអនុវត្តន៍នៅឯកសារគោលនយោបាយស្ដីពីការជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករ។ ឯកសារគោលនយោបាយនេះ បានដាក់ចុះនូវវិធានការគោលនយោបាយជាច្រើន សំដៅសម្រេចឱ្យបាននូវការនាំចេញអង្ករទៅក្រៅប្រទេសឱ្យបាន ១ លានតោន នៅឆ្នាំ២០១៥ ។ ទន្ទឹមនឹងនេះដែរ រដ្ឋាភិបាលក៏បានតម្រូវឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្សព្វផ្សាយជូនកសិករប្រើប្រាស់ឱ្យបានទូលំទូលាយ បូករួមទាំងបច្ចេកទេសបង្កើនផលិតផលឱ្យបានច្រើនថែមទៀតផង។

### ឃ.បញ្ហាប្រឈមចំពោះផលិតកម្មស្រូវ

#### ឃ.១ របាយទឹកភ្លៀង ទឹកជំនន់ និងភាពរាំងស្ងួត

ការដាំដុះដំណាំស្រូវនៅកម្ពុជា ច្រើនស្ថិតនៅក្នុងតំបន់ ដែលទទួលបានរបបទឹកភ្លៀងចន្លោះពី ១,២៥០ ទៅ ១,៧៥០ម.ម។ របបទឹកភ្លៀងបែបនេះមានលក្ខណៈសមស្របឱ្យដំណាំស្រូវទទួលនូវភោគផលល្អប្រសិនបើមានរបបទឹកភ្លៀងទៀងទាត់។ ផ្ទុយទៅវិញភាពមិនប្រក្រតីនៃរបបទឹកភ្លៀង បណ្ដោយឱ្យទិន្នផលស្រូវត្រូវធ្លាក់ចុះនឹងភាពមិនអំណោយផលដល់ប្រព័ន្ធកសិកម្មផ្សេងៗទៀត។ ភ្លៀងចាប់ផ្ដើមធ្លាក់មានការពន្យាពេល ហើយតែងតែកើតមានដំណាក់កាលរាំងស្ងួត (កូនរដូវប្រាំង) រយៈពេលពី ៣សប្ដាហ៍ ឬច្រើនជាងនេះនៅចុងខែកក្កដា រហូតដល់ខែសីហា។ ជួនកាលភ្លៀងធ្លាក់ជោគជាំពេកនៅលើដីដាំទឹក ក៏អាចបណ្ដាលឱ្យមានការខូតខាតដល់ផលដំណាំដទៃទៀត ដែលគេនិយមដាំនៅដើមរដូវវស្សាមុនដំណាំស្រូវ។

ភាពខ្សត់ទឹកភ្លៀងនៅចុងរដូវបានកាត់បន្ថយនូវសក្ដានុពលនៃការដាំដុះ ដំណាំបន្ទាប់បន្សំដទៃទៀតក្រោយដំណាំស្រូវ ដោយសារដំណាំទាំងនោះមានប្រព័ន្ធឫសរាក់រួមផ្សំជាមួយនឹងដីមានសមត្ថភាពចាប់យកទឹកមានកំណត់ផងនោះ បានធ្វើឱ្យដីប្រែក្លាយជាមានសភាពស្ងួតយ៉ាងឆាប់រហ័យ។ យ៉ាងណាមិញភាពមិនទៀងទាត់នៃរបាយទឹកភ្លៀងចុងនៃដើមរដូវវស្សា បានជំរុញឱ្យប្រជាកសិករធ្វើពិពិធកម្មពូជស្រូវដែលមានអាយុកាលខុសៗគ្នាជាហេតុធ្វើឱ្យការទទួលទិន្នផលមិនបានសមស្រប។

ការខ្វះខាត់ប្រព័ន្ធស្រោចស្រព គឺជាបញ្ហាលំបាកជាទូទៅមួយក្នុងការបង្កើតផលិតកម្មនៅប្រទេសកម្ពុជា។ ទឹកភ្លៀងមិនទៀងទាត់នៅក្នុងរដូវវស្សា និងមានការខ្វះខាត់នៅក្នុងរដូវប្រាំង បានបង្កើតនូវតម្រូវការយ៉ាងខ្លាំងក្នុងការពង្រីកការស្រោចស្រពព្រមទាំងកែលម្អការគ្រប់គ្រងទឹក។

### ឃ.២ កត្តាដែលធ្វើឱ្យដីធ្លីកសិកម្មខូចខាត

កសិកម្មវាបង្ករឱ្យបរិស្ថានខូចខាតដីធ្លីកើតចេញជាកត្តាពីរសំខាន់ៗគឺ កត្តាមនុស្ស និងកត្តាធម្មជាតិ។ ជាទូទៅគេចាត់ទុកដីធ្លីខូចខាតនៅពេលវាអស់គុណភាព និងទទួលការសឹករិចរឹល។ ចំពោះការដាំដំណាំនេះមានន័យថា វាធ្វើឱ្យទិន្នផលដំណាំថយចុះជាងមុន រីឯការចិញ្ចឹមសត្វ គឺសមត្ថភាពទ្រទង់សត្វបានតិចជាងមួយឯកត្តាផ្ទៃដី។ បញ្ហាចម្បងចំពោះដីធ្លីមាននៅពេសពេញពិភពលោក គឺសំណឹកដី ការបាត់បង់សារជាតុដី សារជាតុចិញ្ចឹម សំណល់ថ្មបាយក្រៀម និងកង្វក់ដីដោយសារមានវត្តមានអំបិល ទឹក និងសារជាតុគីមីជាច្រើន ។

### ឃ.៣ កត្តាដែលធ្វើឱ្យផលិតភាពដីធ្លីប្រែប្រួល

ផលិតកម្មដីធ្លីប្រែប្រួលតាមរយៈឥទ្ធិពលជាច្រើនដូចជា រដូវកាល ពេលវេលា ទំហំកសិដ្ឋាន អាកាសធាតុ កម្រិតជីជាតិ ពូជសត្វ ដំណាំ ដង់ស៊ីតេដំណាំ ប្រព័ន្ធប្រពលវប្បកម្ម និងគ្រប់គ្រងលើការអនុវត្តបច្ចេកទេស ដូចជា កសិករត្រូវយកចិត្តទុកដាក់ឱ្យច្រើនលើការថែរទាំគុណភាពដីជ្រើសរើសពូជយកមកប្រើប្រាស់ និងជំនាញទាំងឡាយដែលអាចជួយការប្រើប្រាស់ដីធ្លីមាននិរន្តភាព។

### ឃ.៤ កត្តាសត្វចង្រៃ និងជំងឺ

បច្ចុប្បន្នសត្វល្អិត និងជំងឺជាកត្តាចង្រៃដែលអាចធ្វើឱ្យទិន្នផលស្រូវថយចុះ។ សត្វល្អិតចង្រៃដែលបំផ្លាញដំណាំកសិកម្មរួមមាន ដង្កូវស៊ីរូងដើម មមាចត្នោត មមាចខៀវ ទ្រីប កណ្តូបដង្កូវមូលស្លឹក ច្រឹង ដង្កូវស៊ីស្លឹក និងដង្កូវហ្វូង។ ទិន្នផលស្រូវក៏អាចត្រូវបានបំផ្លាញដោយក្លាមតាមរយៈការកាត់សំណាប សត្វស្លាបស៊ីពូជ ឬស៊ីគ្រាប់ស្រូវពេលទុំ សត្វកណ្តុរបំផ្លាញនៅគ្រប់វគ្គលូតលាស់របស់ដំណាំ។ ស្មៅចង្រៃអាចបង្កជាបញ្ហាដល់ការដាំដុះស្រូវប្រាំង ប៉ុន្តែមិនសូវបង្ករនៅរដូវវស្សាទេប្រសិនបើទឹកនៅក្នុងស្រែគេរក្សាទុកឱ្យមាន ។

### ង.ស្ថានភាពបច្ចុប្បន្ននៃផលិតផលស្រូវរបស់ប្រទេសកម្ពុជា

ផលិតផលស្រូវសរុបរបស់ប្រទេសកម្ពុជាបានកើនឡើងពី ២,៣៨៣,៤០០តោនក្នុងឆ្នាំ ១៩៩៣ ដល់ ១២,៥៥៦,២២៩តោន គិតត្រឹមឆ្នាំ២០១៩ ។ ការកើនឡើងនេះ គឺដោយសារតែការនាំចេញមានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីឆ្លើយតបទៅនឹងទីផ្សារពិភពលោកដែលកំពុងមានការរីកចម្រើន។ ផលិតផលស្រូវរបស់កម្ពុជាក៏បានកើនឡើងយ៉ាងខ្លាំងផងដែរ ដូចជានៅតំបន់ជាច្រើននៅទូទាំងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសហរដ្ឋ

អាមេរិកដែលបង្ហាញថាផលិតផលស្រូវរបស់អាស៊ាន និងសហរដ្ឋអាមេរិកអាចនឹងកើនឡើងយ៉ាងឆាប់រហ័ស ក្នុងករណីដែលការផ្គត់ផ្គង់អង្ករពិភពលោកមានការធ្លាក់ចុះ និងអាចធ្វើឱ្យតម្លៃថ្លៃមានការកើនឡើងខ្ពស់។ នៅរដូវវស្សាផលិតផលស្រូវបានកើនឡើងពី ២,០០៨,៤០០តោន ក្នុងឆ្នាំ១៩៩៣ ដល់ ៩,៥២០,៣០០តោន ក្នុងឆ្នាំ២០១៩ ដែលទិន្នផលស្រូវរដូវវស្សាបានកើនឡើងពី ១.២០ តោន/ហិចតា ក្នុងឆ្នាំ១៩៩៣ ដល់ ៣.៤៤ តោន/ហិចតា ក្នុងឆ្នាំ២០១៩ ហើយក្នុងអំឡុងពេលដូចគ្នានេះដែរ ផ្ទៃដីប្រមូលផលស្រូវរដូវវស្សាបានកើនឡើងពី ១,៦៧៣,៦០០ហិចតា ដល់ ២,៧៦៨,៩២០ហិចតា។ នៅរដូវប្រាំងផលិតផលស្រូវបានកើនឡើងពី ៣៧៥,០០០តោន ក្នុងឆ្នាំ១៩៩៣ ដល់ ៣,០៣៥,៩០០តោន ក្នុងឆ្នាំ២០១៩។ ក្នុងរយៈពេលដូចគ្នានេះដែរទិន្នផលស្រូវរដូវប្រាំងបានកើនឡើងពី ២.៥០តោន/ហិចតា ដល់ ៤.៩៥តោន/ហិចតា និងផ្ទៃដីប្រមូលផលស្រូវក្នុងរដូវប្រាំងបានកើនឡើងពី ១៥០,០០០ហិចតា ដល់ ៦១៣,២០០ហិចតា។ ទាំងនេះត្រូវបានសង្ខេបនៅក្នុងតារាងទី៤.២ ។

យោងតាមការប៉ាន់ប្រមាណមួយដែលមានផ្ទៃដីជាង ៣លានហិចតាក្នុងឆ្នាំ២០០០ សមស្របសម្រាប់ផលិតស្រូវដោយពិចារណាលើប្រព័ន្ធជារាសាស្ត្រ និងឧបសគ្គវិលជុំនៅប្រទេសកម្ពុជា។

ដូចករណីដំណាំផ្សេងៗទៀត ដែលមានការរំពឹងទុកសុទ្ធសឹងតែដើរតួយ៉ាងសំខាន់សម្រាប់កសិករក្នុងការសម្រេចចិត្តលើផ្ទៃដីដែលបានប្រមូលផល ដែលត្រូវបានរងផលប៉ះពាល់នៅពេលដែលដីមិនសូវមានជីវជាតិ ត្រូវធ្វើការកែសម្រួល និងផ្លាស់ប្តូរដំណាំទៅតាមស្ថានភាពដី។ ចាប់តាំងពីការកែទម្រង់ឆ្នាំ១៩៨៩ ផលិតផលស្រូវនៅកម្ពុជាត្រូវបានអនុវត្តនៅក្នុងការផ្លាស់ប្តូរសេដ្ឋកិច្ចទីផ្សារ។ យោងតាមស្ថិតិ កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៩៩៣-២០១៩ ផលិតផលស្រូវបានកើនឡើងយ៉ាងឆាប់រហ័សពីមួយឆ្នាំទៅមួយឆ្នាំនៅកម្ពុជា ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៤.៤ ដើម្បីប្រាកដថាវិស័យកសិកម្ម គឺជាវិស័យដ៏ធំបំផុតនៃសេដ្ឋកិច្ចកម្ពុជាដែលស្មើនឹង ៤៥~៥០% នៃផលិតផលក្នុងស្រុកសរុប (GDP) ដែលក្នុងនោះស្រូវ គឺជាវិស័យធំបំផុតតែមួយដែលបានរួមចំណែកជាមធ្យម ១៧% នៃផលិតផលក្នុងស្រុកសរុប។ វិស័យផលិតផលបានរួមចំណែក ១៥~២០% និងផ្នែកសេវាកម្ម ៣៣~៣៦% នៃផលិតផលក្នុងស្រុកសរុបតាមលក្ខខណ្ឌជាក់ស្តែង (ធនាគារពិភពលោក ១៩៩៥)។ ផលិតផលស្រូវបានតំណាងឱ្យអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍ពាណិជ្ជកម្មអន្តរជាតិ។ យុទ្ធសាស្ត្រនៃឧស្សាហកម្មស្រូវត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងជំរុញកំណើនសេដ្ឋកិច្ចបង្កើនប្រាក់ចំណូលនៅតាមជនបទ (ប្រជាជន) និងអភិវឌ្ឍន៍ឧស្សាហកម្មនាំចេញកសិកម្ម។

# តារាងទី៣.២ ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ទិន្នផលមធ្យម និងផលិតផលស្រូវ

| ១/ | សរុប | | | | រដូវវស្សា ២/ | | | | រដូវប្រាំង ២/ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ន្ទផល មធ្យម ៣/ (ត/ហ.ត) | លិតផល (000ត) | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ន្ទផល មធ្យម ៣/ (ត/ហ.ត) | លិតផល (000ត) | ដីដាំដុះ (000ហ.ត) | ដី ប្រមូល ផល (000ហ.ត) | ន្ទផល មធ្យម ៣/ (ត/ហ.ត) | លិតផល (000ត) |
| ៩៩៣ | ,៨៥៦.៦ | ,៨២៣.៦ | .៣១ | ,៣៨៣.៤ | ,៧០១.៦ | ,៦៧៣.៦ | .២០ | ,00៨.៤ | ៥៥.0 | ៥0.0 | .៥0 | ៧៥.0 |
| ៩៩៤ | ,៩២៤.0 | ,៤៩៤.៦ | .៤៩ | ,២២៣.៥ | ,៧៥៣.៩ | ,៣២៩.៦ | .៣0 | ,៧២៨.៥ | ៧0.១ | ៦៥.0 | .00 | ៩៥.0 |
| ៩៩៥ | ,0៨៦.0 | ,៩២៤.0 | .៧៩ | ,៤៤៧.៨ | ,៨៧0.0 | ,៧0៩.0 | .៦៤ | ,៨0២.៨ | ១៦.0 | ១៥.0 | .00 | ៤៥.0 |
| ៩៩៦ | ,១៧0.៩ | ,៨៧៩.0 | .៨៤ | ,៤៥៨.0 | ,៩៣៦.៩ | ,៦៤៩.0 | .៦៧ | ,៧៥៩.0 | ៣៤.0 | ៣0.0 | .0៤ | ៩៩.0 |
| ៩៩៧ | ,0៧៦.0 | ,៩២៨.៧ | .៧៧ | ,៤១៤.៩ | ,៨២៧.៣ | ,៦៨៤.៩ | .៥៩ | ,៦៧២.៦ | ៤៨.៧ | ៤៣.៨ | .0៤ | ៤២.៣ |
| ៩៩៨ | ,១0៤.0 | ,៩៦២.៦ | .៧៩ | ,៥0៩.៩ | ,៨៧៣.១ | ,៧៤៥.៤ | .៦៥ | ,៨៧៣.៩ | ៣0.៩ | ១៧.២ | .៩៣ | ៣៦.0 |
| ៩៩៩ | ,១៥៧.៦ | ,0៧៩.៥ | .៩៤ | ,0២៩.៦ | ,៩១៥.៦ | ,៨៤៦.៥ | .៨0 | ,៣២១.៦ | ៤២.0 | ៣៣.0 | .0៤ | 0៨.0 |
| 000 | ,១៥៧.៥ | ,0៧៩.៤ | .៩៤ | ,0៤0.៩ | ,៩១៥.៥ | ,៨៤៦.៤ | .៨១ | ,៣៣២.៩ | ៤២.0 | ៣៣.0 | .0៤ | 0៨.0 |
| 00១ | ,២៤១.១ | ,៩0៣.៣ | .១៥ | ,0៩៩.១ | ,៩៧៤.១ | ,៦៤៨.0 | .៩៩ | ,២៧៦.0 | ៦៧.0 | ៥៥.៣ | .២២ | ២៣.១ |
| 00២ | ,0១៣.១ | ,៩៩៤.៧ | .៩២ | ,៨២៣.0 | ,៨២១.១ | ,៧0៩.៧ | .៧១ | ,៩១៦.0 | ៩២.0 | ៨៥.0 | .១៨ | 0៧.0 |
| 00៣ | ,៣១៤.២ | ,២៤២.0 | .១0 | ,៧១0.៩ | ,0៣0.៧ | ,៩៦៧.0 | .៩៥ | ,៨៣៧.៩ | ៨៣.៥ | ៧៥.0 | .១៧ | ៧៣.0 |
| 00៤ | ,៣៤៦.៩ | ,១0៨.៨ | .៩៨ | ,១៧0.៣ | ,0៤៨.៤ | ,៨១៥.៦ | .៧៣ | ,១៣២.៦ | ៩៨.៥ | ៩៣.២ | .៥៤ | ,0៣៧.៧ |
| 00៥ | ,៤៣៨.0 | ,៤១៤.៥ | .៤៨ | ,៩៨៦.២ | ,១១៦.១ | ,0៩៣.៦ | .២៦ | ,៧៣៤.៣ | ២១.៩ | ២0.៩ | .៩0 | ,២៥១.៩ |
| 00៦ | ,៥៤១.៤ | ,៥១៧.១ | .៤៩ | ,២៦៤.0 | ,២១២.0 | ,១៨៨.៧ | .២៧ | ,៩៧៣.៧ | ២៩.៤ | ២៨.៤ | .៩៣ | ,២៩0.៣ |
| 00៧ | ,៥៨៥.៩ | ,៥៦៧.0 | .៦២ | ,៧២៧.១ | ,២៤១.១ | ,២២២.៦ | .៤១ | ,៣៦៣.៧ | ៤៤.៨ | ៤៤.៤ | .៩៦ | ,៣៦៣.៤ |
| 00៨ | ,៦១៥.៧ | ,៦១៣.៣ | .៧៥ | ,១៧៥.៤ | ,២៥៥.១ | ,២៥២.៧ | .៥៤ | ,៧២២.១ | ៦0.៦ | ៦0.៦ | .0៣ | ,៤៥៣.៣ |
| 00៩ | ,៧១៩.១ | ,៦៧៤.៧ | .៨៤ | ,៥៨៥.៩ | ,៣៣៤.២ | ,២៩0.៦ | .៦២ | ,00១.៤ | ៨៤.៩ | ៨៤.១ | .១៣ | ,៥៨៤.៥ |
| 0១0 | ,៧៩៥.៩ | ,៧៧៧.៣ | .៩៧ | ,២៤៩.៤ | ,៣៩១.0 | ,៣៧២.៥ | .៧៦ | ,៥៤៨.៧ | 0៤.៩ | 0៤.៨ | .២0 | ,៧00.៧ |
| 0១១ | ,៩៦៨.៦ | ,៧៦៦.៦ | .១៧ | ,៧៧៩.៣ | ,៤៩៦.៦ | ,២៩៤.៨ | .៩២ | ,៧00.៤ | ៧២.0 | ៧១.៨ | .៤១ | ,0៧៨.៩ |
| 0១២ | ,00៧.៥ | ,៩៨0.៣ | .១២ | ,២៩0.៨ | ,៥១២.0 | ,៤៨៤.៨ | .៨៧ | ,១៣៦.0 | ៩៥.៥ | ៩៥.៥ | .៣៥ | ,១៥៤.៨ |
| 0១៣ | ,0៥២.៤ | ,៩៦៨.៩ | .១៦ | ,៣៨៩.៧ | ,៥៦៧.៧ | ,៤៨៥.៥ | .៩៣ | ,២៧១.0 | ៨៤.៧ | ៨៣.៤ | .៣៨ | ,១១៨.៧ |
| 0១៤ | ,0៥៥.៥ | ,0២៨.៨ | .0៨ | ,៣២៤.៤ | ,៥៦៤.៦ | ,៥៣៧.៩ | .៨១ | ,១៤៣.៥ | ៩0.៩ | ៩0.៩ | .៤៤ | ,១៨0.៩ |
| 0១៥ | ,0៥១.៤ | ,0១៥.៥ | .១0 | ,៣៣៥.២ | ,៥៦១.៩ | ,៥២៦.១ | .៨៤ | ,១៧0.៦ | ៨៩.៥ | ៨៩.៤ | .៤២ | ,១៦៤.៦ |
| 0១៦ | ,១៣១.៥ | ,១0២.៥ | .២៤ | 0,0៥២.៨ | ,៦១១.៨ | ,៥៨៤.៧ | .៩៨ | ,៦៩៧.១ | ១៩.៧ | ១៧.៨ | .៥៥ | ,៣៥៥.៦ |
| 0១៧ | ,២១៤.៤ | ,១៩២.៥ | .៣៩ | 0,៨២៥.៨ | ,៦៦២.៦ | ,៦៤៤.៧ | .១២ | ,២៦២.៣ | ៥១.៨ | ៤៧.៨ | .៦៨ | ,៩៦៣.៥ |
| 0១៨ | ,៣00.៣ | ,២៨៥.៧ | .៥៥ | ១,៦៥៨.៨ | ,៧១៤.៤ | ,៧0៦.១ | .២៨ | ,៨៦៩.0 | ៨៥.៩ | ៧៩.៦ | .៨១ | ,៧៨៩.៧ |
| 0១៩ | ,៣៨៩.៣ | ,៣៨២.១ | .៧១ | ២,៥៥៦.២ | ,៧៦៧.២ | ,៧៦៨.៩ | .៤៤ | ,៥២0.៣ | ២២.១ | ១៣.២ | .៩៥ | ,0៣៥.៩ |

**សម្គាល់៖**១/ ឆ្នាំដំណាំ - ខែកុម្ភៈ ដល់ ខែមីនា

២/ រដូវវស្សា - ឧសភា ដល់ ខែមករា

រដូវប្រាំង - ខែកុម្ភៈ ដល់ ខែមេសា

៣/ ទិន្នផលមធ្យម = ផលិតផល / ផ្ទៃដីប្រមូលផល

**ប្រភព៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ***ព្រឹត្តិប័ត្រស្ថិតិកសិកម្មកម្ពុជាប្រចាំឆ្នាំ ២០២០***

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ***សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៧***

ផ្ទៃដីដាំដុះស្រូវសរុបរបស់ប្រទេសកម្ពុជាបានកើនឡើងពី ១,៨៥៦,៦០០ហិចតា ក្នុងឆ្នាំ ១៩៩៣ ដល់ ៣,៣៨៩,៣០០ហិចតា ក្នុងឆ្នាំ២០១៩។ ការកើនឡើងនេះដោយសារតែការកើនឡើងនៃការនាំចេញក្នុងអំឡុងទសវត្សឆ្នាំ១៩៩៣ ដើម្បីឆ្លើយតបទៅនឹងទីផ្សារពិភពលោកដែលកំពុងមានការកើនឡើង។ វាមានន័យថាការបង្កើនបរិមាណស្រូវរបស់កម្ពុជាអាចនឹងកើនឡើងយ៉ាងឆាប់រហ័សក្នុងករណី ដែលការផ្គត់ផ្គង់អង្ករបស់អាស៊ានធ្លាក់ចុះ ធ្វើឱ្យតម្លៃនាំចេញនឹងមានការកើនឡើង។ យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរបស់កម្ពុជានៅឆ្នាំ២០០១។ ទិន្នផលស្រូវជាមធ្យមបានកើនពី ១.៣១តោន/ហិចតា ដល់ ១.៨៤ តោន/ហិចតា ក្នុងឆ្នាំ១៩៩៣ និងពី ៣.១០តោន/ហិចតា ដល់ ៣.៧១តោន/ហិចតាក្នុងឆ្នាំ ២០១៤។ ម្យ៉ាងវិញទៀតផ្ទៃដីប្រមូលផលស្រូវសរុបរបស់ប្រទេសកម្ពុជាបានកើនឡើងពី ១,៨២៣,៦០០ហិចតា ដល់ ៣,៣៨២, ១០០ហិចតា។

ក្រាភិចទី៣.២.ផលិតផលស្រូវសរុបនៅរដូវវស្សា និងរដូវប្រាំងពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩




## ច.តម្លៃផលិតផលស្រូវនៅកម្ពុជា

បន្ទាប់ពីការកែទម្រង់ឆ្នាំ១៩៨៩ ទាំងចំណូល និងថ្លៃដើមនៃផលិតផលស្រូវត្រូវបានសង្ខេបនៅតារាងទី៤.២ ចន្លោះពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩ ប្រាក់ចំណូលសរុបរបស់កសិករបានកើនឡើងពី ៥០០ដុល្លារ/ហិចតា ដល់ ១,៣៧០ដុល្លារ/ហិចតា ចំណែកឯនៅក្នុងរយៈពេលដូចគ្នានេះដែរ តម្លៃផលិត ផលស្រូវបានកើនឡើងពី ២៥០ដុល្លារ ទៅ ៤៩៨ដុល្លារ។ ការគ្រប់គ្រងថ្លៃដើមបានកើនឡើងពី ១៣០ ដុល្លារ ដល់ ៤៤៦ដុល្លារ ផងដែរ។ ក្នុងចំណោមរបស់ផ្សេងទៀតថ្លៃដើមសម្រាប់កម្លាំងពលកម្ម កសិកម្មជីគីមី និងថ្នាំសម្លាប់សត្វល្អិតបានហក់ឡើងយ៉ាងខ្លាំងចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩ ដូចដែលបានបង្ហាញក្នុងរូបភាពទី៤.៥ មានការកំណត់ជាក់លាក់ក្នុងការកាត់បន្ថយថ្លៃដើមផលិតផលដោយគ្រាន់តែជំនួសគ្រឿងម៉ាស៊ីនសម្រាប់កម្លាំងពលកម្មក្នុងផលិតស្រូវប៉ុណ្ណោះ។

ថ្លៃដើមទាំងជីជ្លី និងដើមទុនមានចំនួន៨% ជាមធ្យមនៃថ្លៃដើមផលិតផលសរុប ប៉ុន្តែវាក៏បានកើនឡើងជាលំដាប់ៗផងដែរ។ គិតត្រឹមឆ្នាំ២០១៩ ការចំណាយលើជីជ្លីមានចំនួន ៤០ ដុល្លារ/ហិចតា កម្លាំងពលកម្ម ៥០ដុល្លារ/ហិចតា និងគ្រឿងម៉ាស៊ីន ២០ដុល្លារ/ហិចតា។ ទន្ទឹមនឹងនោះតម្លៃស្រូវជាមធ្យមសម្រាប់កសិករវិញបានកើនឡើងពី ៨១០រៀល/គីឡូក្រាម ក្នុងឆ្នាំ ១៩៩៣ ដល់ ១,៧៤៥រៀល/គីឡូក្រាមក្នុងឆ្នាំ ២០១៩។

ម្យ៉ាងទៀតចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩ ថ្លៃដើមផលិតផលផ្ទាល់ពី ៣,២៤% ទៅ ៧% នៃថ្លៃដើមផលិតផលសរុប ហើយថ្លៃដើមដែលកសិករបានចំណាយត្រូវបានគិតគូយ៉ាងខ្លាំង។ កសិករជាធម្មតាត្រូវចំណាយថ្លៃដើមប្រតិបត្តិការនៃគម្រោងប្រព័ន្ធធារាសាស្ត្រ ថ្លៃដើម និងដើមទុនសម្រាប់ ការ វិនិយោគ។ ថ្លៃដើមផលិតស្រូវសម្រាប់ប្រជាកសិករកម្ពុជា គឺសំខាន់បំផុត

នៅគ្រប់តំបន់ទាំងអស់ក្នុងការវាយតម្លៃពីភាពប្រកួតប្រជែងរបស់ទីផ្សារអន្តរជាតិ ដោយសារអង្ករនាំចេញមួយចំនួនផលិតនៅតាមខេត្តជុំវិញបឹងទន្លេសាប។ ប្រាក់ចំណូលនៃការផលិតផលស្រូវក្នុងមួយហិចតានៅប្រទេសកម្ពុជាមានចាប់ពី ៣៧០ដុល្លារ ដល់ ៩២៤ដុល្លារ ជាមធ្យមក្នុងអំឡុងឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩ ប្រាក់ចំណូលសុទ្ធក្នុងមួយហិចតាបានកើនឡើងពី ២៥០ ដុល្លារ ក្នុងឆ្នាំ១៩៩៣ ដល់ ៨៧៧ដុល្លារ ក្នុងឆ្នាំ២០១៩ (របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០២០) ជិត ០៤ដង ។

### តារាងទី៣.៣ ប្រាក់ចំណូលដុល ផលិតផលថ្លៃដើម ការគ្រប់គ្រងថ្លៃដើម ប្រាក់ចំណូល និង ចំណេញ

(ឯកតា៖ ដុល្លារ/ហិចតា)

| ឆ្នាំ | ប្រាក់ចំណូលដុល (A) | ថ្លៃដើមផលិតផល[១] (B) | ការគ្រប់គ្រងថ្លៃដើម[២] (C) | ប្រាក់ចំណូល (A-C) | ប្រាក់ចំណេញ (A-B) |
|---|---|---|---|---|---|
| ១៩៩៣ | ៥០០ | ២៥០ | ១៣០ | ៣៧០ | ២៥០ |
| ១៩៩៤ | ៦០០ | ២៦៨ | ១៤៦ | ៤៥៤ | ៣៣២ |
| ១៩៩៥ | ៦២០ | ២៧៤ | ១៥០ | ៤៧០ | ៣៤៦ |
| ១៩៩៦ | ៦៣៥ | ២៨០ | ១៦០ | ៤៧៥ | ៣៥៥ |
| ១៩៩៧ | ៦៧៥ | ២៨៨ | ១៨០ | ៤៩៥ | ៣៨៧ |
| ១៩៩៨ | ៧០០ | ២៩៥ | ១៩៨ | ៥០២ | ៤០៥ |
| ១៩៩៩ | ៨០០ | ៣០០ | ២០០ | ៦០០ | ៥០០ |
| ២០០០ | ៩៩០ | ៣២០ | ២៤០ | ៧៥០ | ៦៧០ |
| ២០០១ | ១,០១០ | ៣២៧ | ២៤៨ | ៧៦២ | ៦៨២ |
| ២០០២ | ១,០៣០ | ៣៣៥ | ២៥៦ | ៧៧៤ | ៦៩៥ |
| ២០០៣ | ១,០៥១ | ៣៤៣ | ២៦៥ | ៧៨៦ | ៧០៨ |
| ២០០៤ | ១,០៦០ | ៣៥០ | ២៧៣ | ៧៨៧ | ៧១០ |
| ២០០៥ | ១,០៨១ | ៣៥៩ | ២៨៣ | ៧៩៩ | ៧២៣ |
| ២០០៦ | ១,១០០ | ៣៦៧ | ២៩២ | ៨០៨ | ៧៣៣ |
| ២០០៧ | ១,០៧៤ | ៣៧៥ | ៣០២ | ៧៧២ | ៦៩៩ |
| ២០០៨ | ១,១២០ | ៣៨៤ | ៣១២ | ៨០៨ | ៧៣៦ |
| ២០០៩ | ១,១៤២ | ៣៩៣ | ៣២២ | ៨២០ | ៧៥០ |
| ២០១០ | ១,១៦៥ | ៤០២ | ៣៣៣ | ៨៣៣ | ៧៦៤ |
| ២០១១ | ១,១៨៩ | ៤១១ | ៣៤៤ | ៨៤៥ | ៧៧៨ |
| ២០១២ | ១,២១២ | ៤២០ | ៣៥៥ | ៨៥៧ | ៧៩២ |
| ២០១៣ | ១,២៣៧ | ៤៣០ | ៣៦៧ | ៨៧០ | ៨០៧ |
| ២០១៤ | ១,២៤០ | ៤៤០ | ៣៧៩ | ៨៦១ | ៨០០ |
| ២០១៥ | ១,២៦៥ | ៤៥០ | ៣៩២ | ៨៧៣ | ៨១៥ |
| ២០១៦ | ១,២៩០ | ៤៦០ | ៤០៥ | ៨៨៦ | ៨៣០ |
| ២០១៧ | ១,៣១៥ | ៤៧១ | ៤១៨ | ៨៩៧ | ៨៤៤ |
| ២០១៨ | ១,៣៤៣ | ៤៨២ | ៤៣២ | ៩១១ | ៨៦១ |
| ២០១៩ | ១,៣៧០ | ៤៩៣ | ៤៤៦ | ៩២៤ | ៨៧៧ |

**សម្គាល់៖**១) ការគ្រប់គ្រងថ្លៃដើម + ថ្លៃដើមកម្លាំងពលកម្ម + ថ្លៃដើមសេវាកម្មជីជ្លី + ថ្លៃដើមសេវាកម្ម

២) ថ្លៃដើមធាតុចូល + ថ្លៃដើមកម្លាំងពលកម្មបុគ្គលិក + ថ្លៃដើមលើកាដួលកម្លាំងពលកម្មសត្វ

**ប្រភព៖** - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០១៩*

- ទីស្តីការគណៈរដ្ឋមន្ត្រី *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០០២*
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ ២០២០*
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៧*
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *របាយការណ៍របស់ប្រទេសកម្ពុជាការស្ទង់មតិសេដ្ឋកិច្ចសង្គមឆ្នាំ២០១៧*

## ក្រាភិច៣.២.ប្រាក់ចំណូលដុល ផលិតផលថ្លៃដើម ការគ្រប់គ្រងថ្លៃដើម ប្រាក់ចំណូល និង ចំណេញ




### ឆ.ចរាចរអង្ករនៅលើទីផ្សារ

ផលិតផលអង្កររបស់កម្ពុជាបានកើនឡើងពី ២,៣៨៣,៤០០តោនក្នុងឆ្នាំ១៩៩៣ ដល់ ១២,៥៥៦,២២៩ តោនក្នុងឆ្នាំ២០១៩។ ជាមួយនឹងអត្រាកិនជាមធ្យម ៦២% ការផ្គត់ផ្គង់អង្ករបានកើនឡើងពី ១,២២៦,៤៩៧.៦៤ តោន ដល់ ៦,៤៦១,៤៣៥.៦២តោន ក្នុងរយៈពេលដូចគ្នា ដូចដែលបានសង្ខេបនៅតារាងទី៤.៤ ក្នុងពេលតែមួយ ចរាចរអង្ករបានកើនឡើងពី ១,៥០៨,៤១០តោន ដល់ ១,៨៥៦,១៤៤.៧១តោន។ ដូច្នេះទាំងតម្រូវការ និងការផ្គត់ផ្គង់អង្ករមានការកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (រូបភាពទី៤.៦)។

នៅពេលសេដ្ឋកិច្ចរីកចម្រើន ការប្រើប្រាស់អង្ករប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់បានថយចុះពី ១៥១.៣ គីឡូក្រាមក្នុងឆ្នាំ១៩៩៣ ដល់ ១១២.៦គីឡូក្រាមក្នុងឆ្នាំ២០១៩ ដូចដែលបានបង្ហាញក្នុងតារាងទី៤.៤។ ក្នុងពេលដំណាលគ្នាប្រាក់ចំណូលក្នុងមួយឆ្នាំៗ នៅក្នុងប្រទេសកម្ពុជាបានកើនឡើងពី ៧១០ដុល្លារ ក្នុងឆ្នាំ១៩៩៣ ដល់ ៤,៣២០ដុល្លារ ក្នុងឆ្នាំ២០១៩ ។

ការប្រើប្រាស់អង្ករសម្រាប់មនុស្សម្នាក់ បានចាប់ផ្ដើមថយចុះយ៉ាងលឿនចាប់តាំងពីឆ្នាំ ១៩៩៥មកដោយសារតែចំណូលរបស់មនុស្សម្នាក់កំពុងកើនឡើងជាលំដាប់ (រូបភាពទី៤.៧)។ ដោយសារតែអតិផរណានៃផលិតកម្មស្រូវនៅកម្ពុជាដូចដែលបានសង្ខេបនៅតារាងទី៤.៥ រាជរ

ដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យប្រសើរឡើងនូវវិស័យនាំចេញអង្ករ និងទីផ្សារអង្ករដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មអង្ករបន្ថែមទៀត។ ដូចដឹងហើយថាសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើវិស័យកសិកម្មប្រហែល ៥០%នៃផលិតផលក្នុងស្រុកសរុប (GDP) ដែលក្នុងនោះអង្ករ គឺជាវិស័យធំបំផុតតែមួយដែលរួមចំណែកជាមធ្យម ១៧% នៃផលិតផលក្នុងស្រុកសរុប។ ដូច្នេះឧស្សាហកម្មស្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិកម្ពុជាផងដែរ។ លើសពីនេះទៅទៀតប្រជាជនកម្ពុជាប្រមាណ ៨៥% រស់នៅតាមតំបន់ជនបទ ប្រកបមុខរបរកសិកម្មនៅតែជាឧស្សាហកម្មដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា។

ចាប់ពីឆ្នាំ១៩៨០ ដល់ដើមទសវត្សឆ្នាំ១៩៩០ អង្ករត្រូវបានគេចាត់ទុកថាល្អទៅលើផ្នែកនយោ- បាយហើយឧស្សាហកម្មស្រូវអង្ករត្រូវបានអន្តរាគមន៍យ៉ាងខ្លាំងដោយខេត្តក្នុងតំបន់។ យន្តការទីផ្សារត្រូវបានបង្ក្រាបហើយប្រព័ន្ធទីផ្សារស្រូវត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹង។ ផលិតកម្មអង្ករត្រូវបានអនុវត្តដោយរដ្ឋាភិបាលក្នុងទម្រង់ជាបីជម្រើស។

ជម្រើសទីមួយកសិកម្មនីមួយៗ ឬក្រុមផលិតអង្ករត្រូវតែផ្គត់ផ្គង់បរិមាណស្រូវឱ្យបានជាក់លាក់ទៅរដ្ឋាភិបាល។

ជម្រើសទីពីរ កម្រៃសេវាសាធារណៈត្រូវបានប្រមូលជាថ្នូរនឹងប្រព័ន្ធធារាសាស្ត្រ ការរៀបចំដី គ្រាប់ពូជ ជី ឬឈ្មួញទំនិញសម្រាប់ផលិត។ល។

ជម្រើសទីបី កសិករអាចលក់ស្រូវទៅឱ្យរដ្ឋដោយផ្អែកលើតម្លៃកិច្ចសន្យាដែលទាបជាងតម្លៃទីផ្សារ។ ដូច្នេះមានតែស្រូវប្រមាណ ២ ទៅ ៣% ប៉ុណ្ណោះនៃស្រូវសរុបដែលត្រូវបានជួញដូរនៅលើទីផ្សារសេរី។ ជាការពិតណាស់មុនឆ្នាំ១៩៨៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលបន្ទុកក្នុងការចែកចាយស្រូវ ឬអង្ករទាំងអស់នៅទូទាំងប្រទេស។ នៅថ្នាក់ភូមិកសិកម្មទទួលខុសត្រូវក្នុងការចែកចាយស្បៀងអាហារដល់សមាជិកនិងសម្រាប់ផលិតកម្មស្រូវអង្ករក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបំពេញកាតព្វកិច្ចចំពោះរដ្ឋាភិបាល។

គោលនយោបាយកំណែទម្រង់ដែលបានផ្តួចផ្តើមឡើងក្នុងឆ្នាំ១៩៨៩ បានធ្វើសេរីភាវូបនីយកម្មទីផ្សារអង្ករក្នុងស្រុក។ ឈ្មួញកណ្តាល និងឈ្មួញមួយចំនួនតូចបានចូលទីផ្សារស្រូវអង្ករដើម្បីប្រកួតប្រជែងជាមួយប្រព័ន្ធទីផ្សាររបស់រដ្ឋ។ ក្រុមហ៊ុនស្បៀងអាហារសាធារណៈដែលពីមុនជាអ្នកចែកចាយ ផ្តាច់មុខនូវការចែកចាយអង្ករលក់រាយឥឡូវនេះផ្តោតលើការកែច្នៃអង្ករ និងអនុវត្តការធ្វើពាណិជ្ជកម្ម និងនាំចេញអង្ករតាមតំបន់។ ឥឡូវនេះពួកគេពឹងផ្អែកជាចម្បងលើពាណិជ្ជករឯកជនសម្រាប់ជានាការផ្គត់ផ្គង់ស្រូវ។ ទីផ្សារលក់ដុំត្រូវបានបង្កើតឡើងនៅចំណុចផ្គត់ផ្គង់ជាច្រើនដូចជា ខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។

# តារាងទី៣.៥.ការផ្គត់ផ្គង់ និងតម្រូវការអង្ករទៅលើអន្តរជាតិ

| ឆ្នាំ | ផលិតផលស្រូវសរុប (តោន) | ការកាត់បន្ថយ ១៧%* (តោន) | អង្ករផុលសម្រាប់ប្រើប្រាស់ (តោន) | ចំនួនប្រជាជន (មនុស្ស) | អង្ករសរុប (អត្រារោងម៉ាស៊ីន62%) (តោន) (A) | ការប្រើប្រាស់អង្ករសរុប(តោន) (B) | ការប្រើប្រាស់អង្ករ (គីឡូក្រាម/ម្នាក់) | ភាពគ្រប់គ្រាន់នៃអង្ករ (A/B) (%) |
|---|---|---|---|---|---|---|---|---|
| ១៩៩៣ | ២,៣៨៣,៤០០ | ៤០៥,១៧៨.០០ | ១,៩៧៨,២២២.០០ | ៩,៩៧០,៧៣៣ | ១,២២៦,៤៩៧.៦៤ | ១,៥០៨,៤១០.០០ | ១៥១.៣ | ៨១ |
| ១៩៩៤ | ២,២២៣,៥០០ | ៣៧៧,៩៩៥.០០ | ១,៨៤៥,៥០៥.០០ | ១០,៣១៧,៨៩៩ | ១,១៤៤,២១៣.១០ | ១,៥៤៨,០២៣.០០ | ១៥០.០ | ៧៤ |
| ១៩៩៥ | ៣,៤៤៧,៨០០ | ៥៨៦,១២៦.០០ | ២,៨៦១,៦៧៤.០០ | ១០,៦៥៦,១៣៨ | ១,៧៧៤,២៣៧.៨៨ | ១,៧០១,០០០.០០ | ១៥៩.៦ | ១០៤ |
| ១៩៩៦ | ៣,៤៥៨,០០០ | ៥៨៧,៨៦០.០០ | ២,៨៧០,១៤០.០០ | ១០,៩៨២,៩១៧ | ១,៧៧៩,៤៨៦.៨០ | ១,៦៩៩,១៦០.០០ | ១៥៤.៧ | ១០៥ |
| ១៩៩៧ | ៣,៤១៤,៩០០ | ៥៨០,៥៣៣.០០ | ២,៨៣៤,៣៦៧.០០ | ១១,២៩៨,៦០០ | ១,៧៥៧,៣០៧.៥៤ | ១,៧០២,០៣៨.៤៣ | ១៥០.៦ | ១០៣ |
| ១៩៩៨ | ៣,៥០៩,៩០០ | ៥៩៦,៦៨៣.០០ | ២,៩១៣,២១៧.០០ | ១១,៦០០,៥០៨ | ១,៨០៦,១៩៤.៥៤ | ១,៨០៣,០១០.១៩ | ១៥៥.៤ | ១០០ |
| ១៩៩៩ | ៤,០២៩,៦០០ | ៦៨៥,០៣២.០០ | ៣,៣៤៤,៥៦៨.០០ | ១១,៨៨៦,៤៥៨ | ២,០៧៣,៦៣២.១៦ | ១,៨៤៤,២៣៧.២២ | ១៥៥.២ | ១១២ |
| ២០០០ | ៤,០៤០,៩០០ | ៦៨៦,៩៥៣.០០ | ៣,៣៥៣,៩៤៧.០០ | ១២,១៥៥,២៣៩ | ២,០៧៩,៤៤៧.១៤ | ១,៨៧៥,៨៤៦.២៥ | ១៥៤.៣ | ១១១ |
| ២០០១ | ៤,០៩៩,១០០ | ៦៩៦,៨៤៧.០០ | ៣,៤០២,២៥៣.០០ | ១២,៤០៥,៤០៨ | ២,១០៩,៣៩៦.៨៦ | ១,៧៥១,៦៤៣.៦១ | ១៤១.២ | ១២០ |
| ២០០២ | ៣,៨២៣,០០០ | ៦៤៩,៩១០.០០ | ៣,១៧៣,០៩០.០០ | ១២,៦៣៧,៧២៧ | ១,៩៦៧,៣១៥.៨០ | ១,៧៥៩,៤២៤.៣៥ | ១៣៩.២ | ១១២ |
| ២០០៣ | ៤,៧១០,៩០០ | ៨០០,៨៥៣.០០ | ៣,៩១០,០៤៧.០០ | ១២,៨៥៦,១៦៣ | ២,៤២៤,២២៩.១៤ | ១,៧៦៤,៧៦៥.៥០ | ១៣៧.៣ | ១៣៧ |
| ២០០៤ | ៤,១៧០,៣០០ | ៧០៨,៩៥១.០០ | ៣,៤៦១,៣៤៩.០០ | ១៣,០៦៦,៤៦៩ | ២,១៤៦,០៣៦.៣៨ | ១,៧៦៨,៥៤៦.៥៨ | ១៣៥.៤ | ១២១ |
| ២០០៥ | ៥,៩៨៦,២០០ | ១,០១៧,៦៥៤.០០ | ៤,៩៦៨,៥៤៦.០០ | ១៣,២៧៣,៣៥៤ | ៣,០៨០,៤៩៨.៥២ | ១,៧៧១,៣២៩.០៩ | ១៣៣.៥ | ១៧៤ |
| ២០០៦ | ៦,២៦៤,០០០ | ១,០៦៤,៨៨០.០០ | ៥,១៩៩,១២០.០០ | ១៣,៤៧៧,៧០៩ | ៣,២២៣,៤៥៤.៤០ | ១,៧៧៣,៣៩៦.៩៥ | ១៣១.៦ | ១៨២ |
| ២០០៧ | ៦,៧២៧,១០០ | ១,១៤៣,៦០៧.០០ | ៥,៥៨៣,៤៩៣.០០ | ១៣,៦៧៩,៩៦២ | ៣,៤៦១,៧៦៥.៦៦ | ១,៧៧៤,៨៣៨.២៧ | ១២៩.៧ | ១៩៥ |
| ២០០៨ | ៧,១៧៥,៤០០ | ១,២១៩,៨១៨.០០ | ៥,៩៥៥,៥៨២.០០ | ១៣,៨៨៣,៨៣៤ | ៣,៦៩២,៤៦០.៨៤ | ១,៧៧៦,១៥៨.៨៨ | ១២៧.៩ | ២០៨ |
| ២០០៩ | ៧,៥៨៥,៩០០ | ១,២៨៩,៦០៣.០០ | ៦,២៩៦,២៩៧.០០ | ១៤,០៩៣,៦០៤ | ៣,៩០៣,៧០៤.១៤ | ១,៧៧៧,៦២៦.២៧ | ១២៦.១ | ២២០ |
| ២០១០ | ៨,២៤៩,៤០០ | ១,៤០២,៣៩៨.០០ | ៦,៨៤៧,០០២.០០ | ១៤,៣១២,២១២ | ៤,២៤៥,១៤១.២៤ | ១,៧៨០,០០៩.៨១ | ១២៤.៤ | ២៣៨ |
| ២០១១ | ៨,៧៧៩,៣០០ | ១,៤៩២,៤៨១.០០ | ៧,២៨៦,៨១៩.០០ | ១៤,៥៤១,៤២៣ | ៤,៥១៧,៨២៧.៧៨ | ១,៧៨៨,៦២៣.០៩ | ១២៣.០ | ២៥៣ |
| ២០១២ | ៩,២៩០,៨០០ | ១,៥៧៩,៤៣៦.០០ | ៧,៧១១,៣៦៤.០០ | ១៤,៧៨០,៤៥៤ | ៤,៧៨១,០៤៥.៦៨ | ១,៧៩៨,០២៦.១០ | ១២១.៦ | ២៦៦ |
| ២០១៣ | ៩,៣៨៩,៧០០ | ១,៥៩៦,២៤៩.០០ | ៧,៧៩៣,៤៥១.០០ | ១៥,០២៦,៣៣២ | ៤,៨៣១,៩៣៩.៦២ | ១,៨០៧,៨២៩.៥៨ | ១២០.៣ | ២៦៧ |
| ២០១៤ | ៩,៣២៤,៤០០ | ១,៥៨៥,១៤៨.០០ | ៧,៧៣៩,២៥២.០០ | ១៥,២៧៤,៥០៣ | ៤,៧៩៨,៣៣៦.២៤ | ១,៨១៧,៤៧២.៦៧ | ១១៩.០ | ២៦៤ |
| ២០១៥ | ៩,៣៣៥,២០០ | ១,៥៨៦,៩៨៤.០០ | ៧,៧៤៨,២១៦.០០ | ១៥,៥២១,៤៣៦ | ៤,៨០៣,៨៩៣.៩២ | ១,៨២៦,៥៣៩.១៧ | ១១៧.៧ | ២៦៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២០១៦ | ១០,០៥២,៧៦៣ | ១,៧០៨,៩៦៩.៧៣ | ៨,៣៤៣,៧៩៣.៣៨ | ១៥,៧៦៦,២៩២ | ៥,១៧៣,១៥១.៩០ | ១,៨៣៤,៩៤៤.៥៧ | ១១៦.៤ | ២៨២ |
| ២០១៧ | ១០,៨២៥,៨៤៨ | ១,៨៤០,៣៩៤.១៤ | ៨,៩៨៥,៤៥៣.៧៤ | ១៦,០០៩,៤០៩ | ៥,៥៧០,៩៨១.៣២ | ១,៨៤២,៧៤៣.៨៧ | ១១៥.១ | ៣០២ |
| ២០១៨ | ១១,៦៥៨,៧៨១ | ១,៩៨១,៩៩២.៧៩ | ៩,៦៧៦,៧៨៨.៣២ | ១៦,២៤៩,៧៩២ | ៥,៩៩៩,៦០៨.៧៦ | ១,៨៤៩,៨៣៨.៣៣ | ១១៣.៨ | ៣២៤ |
| ២០១៩ | ១២,៥៥៦,២២៩ | ២,១៣៤,៥៥៨.៩៩ | ១០,៤២១,៦៧០.៣៦ | ១៦,៤៨៦,៥៤២ | ៦,៤៦១,៤៣៥.៦២ | ១,៨៥៦,១៤៤.៧១ | ១១២.៦ | ៣៤៨ |

**សម្គាល់៖** កត់សម្គាល់លើការកាត់បន្ថយ ១៧%សម្រាប់ការបម្រុងទុកគ្រាប់ពូជ និងការបាត់បង់ការប្រមូលផលក្រោយ។

**ប្រភព៖** - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៧*

## ក្រាភិចទី៣.៤ ការផ្គត់ផ្គង់ និងតម្រូវការអង្ករសរុប ចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩




ទាំងតម្លៃទីផ្សារក្នុងស្រុក និងនាំចេញសម្រាប់អង្ករត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ថ្ងៃនៅទីផ្សារអង្ករលក់ដុំចាប់តាំងពីឆ្នាំ១៩៩៥។ បន្ទាប់ពីការនាំចូលអង្ករពីអង្គការជំនួយ អង្ករអន្តរជាតិជាច្រើនទសវត្សរ៍ចុងក្រោយប្រទេសកម្ពុជាមានការផ្គត់ផ្គង់លើសយ៉ាងហោចណាស់ជាង ៧៣,២៥២តោន គិតត្រឹមឆ្នាំ១៩៩៥។ ឆ្នាំ១៩៩៥ ដល់ ឆ្នាំ២០១៩ ផលិតផលស្រូវបានកើនឡើង ៥.៣% ហើយការនាំចេញអង្ករបានកើនឡើង ១០%ក្នុងមួយឆ្នាំ។ ពាណិជ្ជកម្មអង្ករពិភពលោកបានកើនឡើងពី ១០ ទៅ ១២លានតោន នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៨០ ដល់ជាង

២០លានតោន នៅឆ្នាំ១៩៩៥ ដែលផ្តល់នូវច្រកចេញសម្រាប់ការកើនឡើងការនាំចេញអង្ករមួយចំនួនពីប្រទេសកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៥ គុណភាពនៃការនាំចេញដែលបានជំរុញឱ្យមានរោងម៉ាស៊ីនកិនស្រូវមានការកើនឡើងទាំងការវិនិយោគឯកជន និងរដ្ឋនៅក្នុងប្រទេសកម្ពុជា។ បច្ចេកវិទ្យាបានកែច្នៃមកពីបណ្តាប្រទេសអាស៊ាន ជប៉ុន បារាំង និងអូស្ត្រាលីត្រូវបានណែនាំ។ បច្ចុប្បន្នវិស័យរោងម៉ាស៊ីនកិនស្រូវនៅប្រទេសកម្ពុជារួមមានរោងម៉ាស៊ីនធុនតូចចំនួនជាង ១,៨០០កន្លែង ដែលត្រូវបានប្រើប្រាស់នៅតាមភូមិទាំងអស់ដើម្បីបម្រើទីផ្សារក្នុងស្រុកម៉ាស៊ីនកិនស្រូវធុនមធ្យមចំនួន ៣,៧៧៥ ដែលមានសមត្ថភាពជាមធ្យមជាង ២តោនក្នុងមួយម៉ោង បំពាក់ដោយឧបករណ៍កំណត់ និងរំលីងគ្រាប់ឱ្យបានស្អាត និង ១,០០០ រោងម៉ាស៊ីនធំ ដែលមានសមត្ថភាពផលិតលើសពី ៤តោនក្នុងមួយម៉ោង។

តំបន់កណ្តាលនៃប្រទេសកម្ពុជា និងតំបន់ផ្សេងទៀតគឺជាតំបន់ដែលមានស្រូវលើសតម្រូវការ។ តិចជាងមួយភាគបីនៃអង្ករកម្ពុជាត្រូវបានផ្គត់ផ្គង់នៅខាងក្រៅតំបន់ជុំវិញបឹងទន្លេសាប។ ការចូលរួមរបស់ភ្នាក់ងារទីផ្សារឯកជននៅក្នុងតំបន់ទាំងពីរនេះភាគច្រើនគឺទីផ្សារក្នុងស្រុក។ ភ្នាក់ងារផ្គត់ផ្គង់ឯកជនប្រហែល ៨០% នៃតម្រូវការក្នុងស្រុកដែលគ្រប់គ្រងបរិមាណតិចតួចពី ៣ ទៅ ៥លានតោន ក្នុងមួយឆ្នាំ។ រោងម៉ាស៊ីនកិនស្រូវប្រហែល ១,៥០០កន្លែង បម្រើដល់ទីផ្សារខេត្តបាត់ដំបង។ ប្រហែល ៣៦% នៃតម្រូវការអង្ករសរុប គឺមកពីអតិថិជននៅតំបន់កណ្តាល ២៦% នៅតំបន់ខ្ពង់រាប ៣៤% នៅខេត្តខាងលិច និង ៤% នៅទីផ្សារព្រំដែនខ្មែរ។ បណ្តាលទីផ្សារផ្សេងៗគ្នាកាន់តែទូលំទូលាយត្រូវបានប្រើប្រាស់នៅក្នុងតំបន់ទន្លេមេគង្គ និងតំបន់កណ្តាល ដូចជាកសិករ អ្នកប្រើប្រាស់ អ្នកកិនស្រូវ អ្នកបរិភោគ បុគ្គលិកក្រុមហ៊ុន ក្រុមហ៊ុនឯកជន អ្នកជំនួញឯកជន កសិករ ពាណិជ្ជករឯកជន លក់រាយ អតិថិជន។

ខណៈពេលដែលទីផ្សារក្នុងស្រុកត្រូវបានធ្វើសេរីភាវូបនីយកម្ម ភាគច្រើននៃវិស័យនាំចូល និងនាំចេញនៅតែត្រូវបានធ្វើអាជីវកម្មផ្តាច់មុខដោយរដ្ឋនៅទសវត្សឆ្នាំ១៩៨០។ ក្រុមហ៊ុនវិស័យឯកជនមួយចំនួនត្រូវបានអនុញ្ញាតឱ្យនាំចេញអង្ករក្នុងឆ្នាំ១៩៩៥ ជាលើកដំបូង ប៉ុន្តែមានតែការបែងចែក និងកូតាផ្ទាល់ពីរដ្ឋាភិបាលខេត្តប៉ុណ្ណោះ។ ដំណើរការធ្វើសេរីភាវូបនីយកម្មនៅពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ សហគ្រាសដែលគ្រប់គ្រងដោយរដ្ឋាភិបាលត្រូវបានផ្តល់ការអនុញ្ញាតឱ្យនាំចេញអង្ករភាគច្រើន។ ពួកគេខ្លះមិនមានបទពិសោធន៍ក្នុងការទាក់ទងជាមួយអ្នកទិញ អន្តរជាតិ និងស្វែងរកប្រភពនៃការផ្គត់ផ្គង់ក្នុងស្រុក។ ការរៀបចំនេះបាននាំឱ្យមានហានិភ័យខ្ពស់ក្នុងការប្រព្រឹត្តិកិច្ចសន្យា ដូច្នេះវាជួយធ្វើឱ្យតម្លៃអង្ករនាំចេញរបស់កម្ពុជាធ្លាក់ចុះទាប បើប្រៀបធៀបនឹងអង្ករមានគុណភាពប្រហាក់ប្រហែលពីប្រទេសថៃ និងវៀតណាម។ នៅចុងឆ្នាំ១៩៩៥ រដ្ឋាភិបាលបានសម្រេចកំណត់ចំនួនអង្គភាពនាំចេញអង្ករបន្ថែមទៀត ដោយផ្តល់អាជ្ញាប័ណ្ណនាំចេញទៅកាន់តែក្រុមហ៊ុនធំៗចំនួន ៥ប៉ុណ្ណោះ។

នាយករដ្ឋមន្ត្រីជាធម្មតាអនុម័តគោលដៅនាំអង្ករចេញជារៀងរាល់ឆ្នាំ ដោយផ្អែកលើអនុសាសន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម។ ក្រសួងកសិកម្ម

វុក្ខាប្រមាញ់ និងនេសាទទទួលខុសត្រូវក្នុងការថែរក្សាការផ្គត់ផ្គង់ស្បៀងអាហាររបស់ប្រទេស និងសម្រាប់ការណែនាំពីទីកន្លែង និងពេលវេលាដែលត្រូវនាំចេញ។

ក្រសួងពាណិជ្ជកម្មត្រួតពិនិត្យរាល់សកម្មភាពនាំចូល នាំចេញ និងកំណត់តម្លៃនាំចេញអង្ករអប្បបរមាដែលត្រូវបានកែសម្រួលដោយផ្អែកលើការប្រែប្រួលតម្លៃពិភពលោក។ កូតានាំចេញដែលមានចំនួន ៧០ភាគរយ នៃគោលដៅនាំចេញត្រូវបានចែកចាយទៅឱ្យក្រុមហ៊ុននាំចេញដែលមានអាជ្ញាប័ណ្ណនៅដើមឆ្នាំនីមួយៗ។

**តារាងទី៣.៦ ការប្រើប្រាស់អង្ករក្នុងមនុស្សម្នាក់ តម្លៃអង្ករសម្រាប់អ្នកប្រើប្រាស់ តម្លៃពោតសម្រាប់អ្នកប្រើប្រាស់ និងប្រាក់ចំណូលប្រចាំឆ្នាំក្នុងមនុស្សម្នាក់ ចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ ២០១៩**

| ឆ្នាំ | ការប្រើប្រាស់អង្ករក្នុងមនុស្សម្នាក់ (គីឡូក្រាម/ម្នាក់) | តម្លៃអង្ករសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | តម្លៃពោតសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | ប្រាក់ចំណូលប្រចាំឆ្នាំក្នុងមនុស្សម្នាក់ (ដុល្លារ) |
|---|---|---|---|---|
| ១៩៩៣ | ១៥១.៣ | ៨១០ | ៩៣០ | ៧១០ |
| ១៩៩៤ | ១៥០.០ | ៨២០ | ៥៧៥ | ៧៤២ |
| ១៩៩៥ | ១៥៩.៦ | ៨៤០ | ៤៩៥ | ៧៨០ |
| ១៩៩៦ | ១៥៤.៧ | ៨៥០ | ៦៦០ | ៨១០ |
| ១៩៩៧ | ១៥០.៦ | ៨៧០ | ៥៦០ | ៨៤០ |
| ១៩៩៨ | ១៥៥.៤ | ៩០០ | ៦២០ | ៨៦០ |
| ១៩៩៩ | ១៥៥.២ | ៩៦០ | ៧៩៥ | ៩៥០ |
| ២០០០ | ១៥៤.៣ | ១,០០០ | ៦២៥ | ១,០៤០ |
| ២០០១ | ១៤១.២ | ១,០៣០ | ៥១៥ | ១,១២០ |
| ២០០២ | ១៣៩.២ | ១,០៦១ | ៥៣០ | ១,១៨០ |
| ២០០៣ | ១៣៧.៣ | ១,០៩៣ | ៥៤៦ | ១,២៩០ |
| ២០០៤ | ១៣៥.៤ | ១,១២៦ | ៥៦៣ | ១,៤៤០ |
| ២០០៥ | ១៣៣.៥ | ១,២១៤ | ៦០៧ | ១,៦៤០ |
| ២០០៦ | ១៣១.៦ | ១,១២១ | ៥៦១ | ១,៨៥០ |
| ២០០៧ | ១២៩.៧ | ១,៤៥១ | ៧២៦ | ២,០៨០ |
| ២០០៨ | ១២៧.៩ | ១,១២៣ | ៥៦២ | ២,២២០ |
| ២០០៩ | ១២៦.១ | ៩០៧ | ៤៥៤ | ២,២០០ |
| ២០១០ | ១២៤.៤ | ១,០០៨ | ៥០៤ | ២,៣២០ |
| ២០១១ | ១២៣.០ | ១,០២៧ | ៥១៤ | ២,៤៩០ |
| ២០១២ | ១២១.៦ | ១,០៤៧ | ៥២៣ | ២,៧២០ |
| ២០១៣ | ១២០.៣ | ១,០៦៧ | ៥៣៣ | ២,៩២០ |
| ២០១៤ | ១១៩.០ | ១,៧១៨ | ៨៥៩ | ៣,០២០ |
| ២០១៥ | ១១៧.៧ | ១,៤៨៨ | ៦៧២ | ៣,១៨០ |
| ២០១៦ | ១១៦.៤ | ១,៥២៩ | ៦២៣ | ៣,៤៥០ |
| ២០១៧ | ១១៥.១ | ១,៥៩៥ | ៦១១ | ៣,៦៨០ |
| ២០១៨ | ១១៣.៨ | ១,៦៥៩ | ៦៦៧ | ៣,៩៧០ |
| ២០១៩ | ១១២.៦ | ១,៧៤៥ | ៦៨៤ | ៤,៣២០ |

**ប្រភព៖** - ធនាគារអភិវឌ្ឍន៍អាស៊ី *របាយការណ៍ប្រចាំឆ្នាំ២០០០*

- ទីស្តីការគណៈរដ្ឋមន្ត្រី *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០០២*

- នាយកដ្ឋានផែនការស្ថិតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ *ព្រឹត្តិប័ត្រកសិកម្មស្តង់ដារប្រទេសកម្ពុជាឆ្នាំ ២០០១*
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ ២០២០*
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *របាយការណ៍របស់ប្រទេសកម្ពុជា ការស្ទង់មតិសេដ្ឋកិច្ចសង្គមឆ្នាំ២០១៧*
- ធនាគារពិភពលោក *របាយការណ៍ប្រចាំឆ្នាំ២០២០*

នៅសល់ ៣០% ត្រូវបានបម្រុងទុកសម្រាប់ការចែកចាយនៅពេលក្រោយ ដោយផ្អែកលើការវាយតម្លៃអំពីកង្វះខាតដែលអាចកើតមាននៅក្នុងការផ្គត់ផ្គង់ក្នុងស្រុក។ ក្រុមហ៊ុននានាបង់ពន្ធនាំចេញចាប់ពី ១ ទៅ ៤% នៃតម្លៃសរុប អាស្រ័យលើតម្លៃផលិតផល ២% ក្នុងករណីស្រូវបូកនឹងការចូលរួមវិភាគទានថវិកាជាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០២០)។ល។ គោលដៅនាំចេញអង្ករសម្រាប់ឆ្នាំ២០១៩ គឺប្រហែល ៤,៦០៥,២៩១តោន (ក្រសួងពាណិជ្ជកម្មកម្ពុជា ខែធ្នូ ឆ្នាំ ២០២០ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួង។

**ក្រាភិចទី៣.៥ ការប្រើប្រាស់អង្ករក្នុងមនុស្សម្នាក់ក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ ២០១៩**



ទីផ្សារអង្ករ គឺជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា ទោះបីការសិក្សាយ៉ាងទូលំទូលាយអំពីប្រព័ន្ធទីផ្សារអង្ករកំពុងខ្វះខាត ហើយបរិមាណពាណិជ្ជកម្មភាគច្រើនមិនត្រូវបានកំណត់ទេ។ អង្ករត្រូវបាននាំចេញទៅប្រទេសវៀតណាម និងថៃ ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០។ វាក៏មានពាណិជ្ជកម្មអង្ករក្នុងស្រុក ដើម្បីបំពេញតាមតម្រូវការនៅក្នុងទីក្រុង ទីប្រជុំជន និងតំបន់ជនបទដែលមានឱនភាពស្រូវ។ អង្ករត្រូវបានលក់ជាសាច់ប្រាក់ ហើយត្រូវបានគេដូរជាទំនិញផ្លាស់ប្ដូរទំនិញ និងសេវាកម្មជាច្រើននៅក្នុងទីផ្សារក្រៅប្រទេស។ ផលិតកម្មគ្រាប់ធញ្ញជាតិដែលមានរយៈពេលខ្លី គឺមានដំណាំផ្សេងៗទៀត ដែលមានន័យថាស្រូវប្រហែលជាមានឥទ្ធិពលសេដ្ឋកិច្ចធំបំផុតទៅលើសកម្មភាពឧស្សាហកម្ម និងសេវាកម្មដែលទាក់ទងនឹងកសិកម្ម។ សកម្មភាពទាំងនេះរួមមានការកែច្នៃកសិផល ការរៀបចំដី ការប្រមូលផល ដឹកជញ្ជូន លក់ដុំ និងលក់រាយកសិកម្ម។ល។

ទីផ្សារអង្ករនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ដោយកម្រិតនៃការបែងចែក និងភាពគ្មានប្រសិទ្ធភាព។ មូលហេតុនៃការបែងចែករួមមានហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងទំនាក់ទំនងមិនល្អដែលជាកន្លែងកំណត់ការធ្វើចលនទំនិញ និងព័ត៌មាន។ ប្រការនេះផ្ដល់នូវការកើនឡើងនូវភាពខ្វះចន្លោះរវាងការផ្គត់ផ្គង់ និងតម្រូវការស្រូវនៅទូទាំងប្រទេស និងតាមពេលវេលា ការទម្លាក់ទ្រង់ទ្រាយតម្លៃធ្ងន់បញ្ចាំងពីភាពមិនល្អឥតខ្ចោះទាំងនេះ។ ឧទាហរណ៍នៅខែកញ្ញាឆ្នាំ១៩៩៤ គេបានរកឃើញថាអង្ករត្រូវបានលក់នៅខេត្តតាកែវក្នុងតម្លៃ ១៦០ដុល្លារ/តោន ដែលទាបជាងតម្លៃនៅភ្នំពេញក្នុងតម្លៃ ២១០ដុល្លារ/តោន ទោះបី ជាពួកគេនៅឆ្ងាយពី ៩០គីឡូម៉ែត្រ ក៏ដោយ ជាការផ្លាស់ប្ដូរតិចតួចនៃតម្លៃលើសនៃការចំណាយលើការដឹកជញ្ជូន។ ការបែងចែកនេះក៏មានន័យថាការវិលត្រឡប់មករកកសិករវិញ គឺមានកម្រិតទាប ជាញឹកញាប់ដោយមានចំណែកប្រាក់ចំណេញភាគច្រើនដែលទទួលបានពីឈ្មួញអ្នកលក់ដុំ និងអ្នកលក់រាយ។

ទីផ្សារអង្ករជាធម្មតាទាក់ទងនឹងអង្ករកែច្នៃ ឬកិនជំនួសឱ្យអង្ករសម្រាប់ម្នាក់ៗ។ អង្ករត្រូវបានកែច្នៃជាផលិតផលចំនួន៤ គឺ អង្កាម កន្ទក់ អង្ករគ្រាប់ស្រូវ និងអង្ករសម្រូប។ ការផ្គត់ផ្គង់អង្ករម្នាក់ៗនៅក្នុងឆ្នាំណាមួយមានផលិតផលកសិផលក្នុងឆ្នាំបច្ចុប្បន្ន និងស្តុកទុកពីឆ្នាំមុន។ ការផ្គត់ផ្គង់អង្ករម្នាក់ៗបន្ទាប់ពីបានកំណត់ការស្តុកទំនិញ និងកសិផលសម្រាប់ឆ្នាំក្រោយ។ ការផ្គត់ផ្គង់អង្ករម្នាក់ៗនេះត្រូវបានកែច្នៃ ដើម្បីផលិតអង្ករ និងផលិតផលផ្សេងៗ ដូចជាអង្ករ និងកន្ទក់។

ការផ្គត់ផ្គង់អង្ករសរុបស្មើនឹងផលិតផលអង្ករបូកនឹងស្តុកនិងការនាំចូលអង្ករសុទ្ធ។ ក្នុងចំណោមការផ្គត់ផ្គង់អង្ករសរុបនេះ អ្នកផ្គត់ផ្គង់ចុងក្រោយនានាបានអនុវត្តន៍តាម។ ផលិតផលទាំងនេះ គឺជាការប្រើប្រាស់ចំណីអាហារក្នុងស្រុកដោយផ្ទាល់ ដំណើរការផលិតស្រាបៀរ ការនាំចេញ ស្តុកអង្ករ និងសំណល់ដែលត្រូវបានពន្យល់យ៉ាងច្បាស់នៅគំនូសបំព្រួញទី៤.១។

## ក្រាភិចទី៣.៦ ប្រព័ន្ធទីផ្សារស្រូវនៅកម្ពុជា




**ប្រភព៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ***របាយការណ៍ទីផ្សារកសិកម្មនៅកម្ពុជាឆ្នាំ ២០០១*** ទំព័រទី៥០

កសិករអាចជ្រើសរើសវិធីសាស្ត្រកំណត់តម្លៃល្អបំផុតសម្រាប់ខ្លួនគេក្នុងចំណោមជំហ៊ានផ្សេងៗគ្នា ដូចជាការធ្វើអាងស្តុកទឹកសម្រាប់សហប្រតិបត្តិការ ការដេញថ្លៃ ការធ្វើកិច្ចសន្យាដោយផ្ទាល់ ការការពារហានិភ័យជាដើម។ ប្រហែល ៨០% នៃផលិតផលស្រូវនៅកម្ពុជាត្រូវបានដាក់លក់តាមរយៈឈ្មួញទីផ្សារស្រូវដែលត្រូវបានដាក់បញ្ចូលបញ្ឈរក្នុងករណីភាគច្រើន។ ពួកគេនឹងរួមបញ្ចូលទាំងសកម្មភាពទីផ្សារ ពីការផ្តល់ស្រូវពូជ ម៉ាស៊ីន ជី និងឥណទានផ្សេងដល់ផលិតផលស្រូវ ដើម្បីសម្ងួតការស្តុកទុក និងការដឹកជញ្ជូនសម្រាប់ការចែកចាយទីផ្សារចុងក្រោយ ហើយអ្នកផលិតស្រូវត្រូវបានអនុញ្ញាតឱ្យចូលរួមចំណែកប្រាក់ចំណេញ ដែលទទួលបានត្រូវបានអ្នកផលិត។ ទីផ្សារស្រូវនៅកម្ពុជាមានបីប្រភេទ គឺឯកជន រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។

ទីផ្សារទាំងនេះត្រូវបានចុះកិច្ចសន្យាជាលក្ខណៈប្រភេទស្រូវ និងចំនួនហិចតាដែលត្រូវដាំ ហើយស្រូវត្រូវបានបញ្ចូលមុន ឬក្រោយពេលកិន ដោយប្រើកម្រិតដូចជាថ្នាក់គុណភាព។ល។ ប្រភេទស្រូវអាចត្រូវបានសម្គាល់ដោយកិច្ចសន្យាឯកជនរវាងអ្នកផលិត និងរោងម៉ាស៊ីន។ ហើយកម្មសិទ្ធិត្រូវបានផ្ទេរដោយផ្ទាល់បន្ទាប់ពីការប្រមូលផល។ ជាទូទៅការប្រើប្រាស់កិច្ចសន្យាទីផ្សារ និងផលិតផលរបស់កសិករ គឺមានសារៈសំខាន់ណាស់ហើយជាផ្នែកមួយនៃការរីកលូតលាស់នៃកសិកម្មរបស់ប្រទេសកម្ពុជា។

វាត្រូវបានគេប៉ាន់ប្រមាណថាប្រហែល ២៥% នៃទីផ្សារស្រូវត្រូវបានធ្វើតាមរបៀប។ ជាពិសេសខេត្តបាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ សៀមរាប កំពង់ធំ កំពង់ឆ្នាំង កណ្តាល តាកែវ ព្រៃវែង និងកំពង់ចាម អ្នកផលិតពេញចិត្តនឹងវិធីសាស្ត្រនេះ។ មួយវិញទៀតអ្នកផលិតអង្ករអាចធ្វើកិច្ចសន្យាជាមួយសាជីវកម្មឥណទាន ទំនិញដែលធានាបាននូវអង្ករដោយផ្តល់ ប្រាក់កម្ចីមិនសងដល់អ្នកដាំដុះស្រូវ។

ឧស្សាហកម្មកិនស្រូវនៅកម្ពុជា មានរោងម៉ាស៊ីនកិនស្រូវជាច្រើននៅទូទាំងប្រទេស។ ក្នុងអំឡុងឆ្នាំ១៩៨០ ដល់ ឆ្នាំ១៩៩០ មានរោងម៉ាស៊ីនសកម្មចំនួន ១,០០០ ទៅ ៣,០០០ នៅក្នុងផលិតផលស្រូវខេត្តធំៗ ចំនួន ១០។ ទោះយ៉ាងណានៅឆ្នាំ២០០០ ចំនួនរោងម៉ាស៊ីនកិនស្រូវសកម្មសរុបមានចំនួន ៦,៥៧៥ នៅក្នុងខេត្តចំនួន ២៤ នៃប្រទេសកម្ពុជា។ ជាធម្មតាពួកគេធ្វើសកម្មភាពទីផ្សារផ្សេងៗគ្នារួមមានការទិញស្តុកអង្ករ ការកែច្នៃក្នុងស្រុក និងការវេចខ្ចប់ដើម្បីចែកចាយអង្ករទៅទីផ្សារចុងក្រោយ។

វិស័យរោងម៉ាស៊ីនកិនស្រូវ គឺជាឧទាហរណ៍មួយទៀតនៃឧស្សាហកម្មចម្រុះ និងការផ្តោតអារម្មណ៍ខ្ពស់នៅក្នុងប្រទេសកម្ពុជាសម្រាប់ក្រុមហ៊ុនតូចដែលគ្រប់គ្រងបរិមាណអង្ករច្រើន។

ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិសាលភាពនៃទីផ្សារជោគជ័យ។ ឥណទានធនាគារផ្លូវការមិនអាចប្រើបានសម្រាប់អ្នកផលិតខ្នាតតូច និងកម្មករ កសិពាណិជ្ជកម្ម ដែលជាឆ្អឹងខ្នងនៃឧស្សាហកម្មនេះទេ។ លទ្ធភាពទទួលបានឥណទាននៅក្នុងទីផ្សារស្រូវត្រូវបានត្រួតត្រាដោយអ្នកខ្ចីប្រាក់ក្រៅផ្លូវការ ដែលជាទូទៅគិតអត្រាប្រាក់កម្ចីជាសាច់ប្រាក់ពី ២០% ទៅ ៣០% ក្នុងមួយខែ និងការប្រាក់ ១០០% ចំពោះប្រាក់កម្ចីស្រូវក្នុងរយៈពេល ០៦ខែ។

តាមរយៈការកែសម្រួលយន្តការនៃសេដ្ឋកិច្ចទីផ្សារសេរី ទីផ្សារអង្ករបានផ្ទេរទៅវិស័យឯកជន។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាមិនបានធ្វើអន្តរាគមន៍គ្រប់គ្រងទីផ្សារស្រូវក្នុងស្រុកទេ។ ក្នុងស្ថានភាពនេះកសិករខ្មែរ អ្នកអន្តរការី ឧស្សាហកម្មកិនស្រូវ អ្នកលក់ដុំ អ្នកលក់រាយ បានបង្កើតទីផ្សារដែលមាន បណ្តាញក្នុងស្រុកជាច្រើន។ ដូចនៅក្នុងរូបភាពទី៩ ភ្នាក់ងារទាំងអស់រួមទាំងកសិករបានធ្វើជំនួញដើម្បីប្រើប្រាស់ធនធានទាំងអស់។ សញ្ញាព្រួញតំណាងឱ្យការលក់ស្រូវដោយផ្ទាល់ពីកសិករទៅឧស្សាហកម្មកិនស្រូវ និងការទិញអង្កររបស់អ្នកលក់រាយដោយផ្ទាល់ទិញពីឧស្សាហកម្មរោងម៉ាស៊ីន ហើយព្រួញតំណាងឱ្យការលក់អង្ករ។ នៅក្នុងបរិបទទីផ្សារបណ្តាញចែកចាយ គឺជាបណ្តាក្រុមហ៊ុន ឬបុគ្គលដែលជួយសម្រួលដល់ចលនផលិតផលស្រូវពីអ្នកផលិតអង្ករ រហូតដល់អ្នកប្រើប្រាស់ចុងក្រោយ។

ក្នុងករណីជាច្រើនបណ្តាញទាំងនេះរួមមានបណ្តាញដែលបានរៀបចំឡើងរបស់កសិករ អ្នកលក់ដុំ និងអ្នកលក់រាយ ដែលបង្កើតទំនាក់ទំនង និងធ្វើការជាមួយគ្នាដើម្បីធ្វើឱ្យផលិតផលស្រូវមានភាពងាយស្រួលសម្រាប់អ្នកទិញដែលចង់បាន បណ្តាញចែកចាយមានរាង និងទំហំខុសៗគ្នា។

ឧទាហរណ៍នៅពេលអ្នកទិញស្រូវនៅកសិដ្ឋានដែលពួកគេត្រូវបានដាំដុះនោះ គឺជាទីផ្សារផ្ទាល់។ ក្រុមហ៊ុនដែលលក់អង្ករដោយខ្លួនឯងតាមរយៈកាតាឡុក ឬហាងលក់នៅតាមរោងចក្រប្រើបណ្តាញផ្ទាល់។ ប៉ុន្តែបណ្តាញជាញឹកញាប់ គឺដោយប្រយោល ពីព្រោះពួកគេរួមបញ្ចូលអ្នកសម្របសម្រួលឆានែលមួយ ឬច្រើនក្រុមហ៊ុន ឬបុគ្គលដូចជាអ្នកលក់ដុំ ភ្នាក់ងារឈ្មួញកណ្តាល និងអ្នកលក់រាយ ដែលតាមរបៀបណាមួយជួយផ្លាស់ប្តូរផលិតផលស្រូវទៅអ្នកប្រើប្រាស់ ឬអ្នកប្រើប្រាស់អាជីវកម្ម។ ឧទាហរណ៍ឧស្សាហកម្មកិនស្រូវ អាចជ្រើសរើសលក់អង្ករទៅឱ្យអ្នកលក់ដុំដែលនឹងលក់ករណីអង្ករទៅឱ្យផ្សារទំនើប និងភោជនីយដ្ឋានដែលជាលទ្ធផលលក់ទៅឱ្យអតិថិជន។ ទោះយ៉ាងណាបណ្តាញចែកចាយស្រូវអនុវត្តន៍មុខងារខុសគ្នាមួយចំនួន ដែលធ្វើឱ្យលំហូរផលិត ផលស្រូវពីអ្នកផលិតអង្ករទៅដល់អ្នកប្រើប្រាស់ចុងក្រោយ។ មុខងារទាំងនេះត្រូវតែត្រូវបានគ្រប់គ្រងដោយនរណាម្នាក់ជាអ្នកផលិត អន្តរការី ឆានែល ឬ សូម្បីតែអតិថិជន។

ដើម្បីឱ្យប្រាកដការលក់អង្ករទៅឱ្យឧស្សាហកម្មកិនស្រូវក្នុងស្រុក និងអន្តរការីលក់ដុំអង្ករ។ ឧស្សាហកម្មកិនស្រូវធ្វើអាជីវកម្មជាមួយក្រុមហ៊ុនផលិតផ្សេងៗគ្នា និងអតិថិជនផ្សេងៗគ្នាជាច្រើន។ ដោយសារតែពួកគេមិនមែនជាម្ចាស់ ឬគ្រប់គ្រងដោយក្រុមហ៊ុនផលិតណាមួយ ពួកគេធ្វើឱ្យរោងចក្រស្រូវជាច្រើនអាចបម្រើអតិថិជននៅទូទាំងពិភពលោកខណៈពេលដែលរក្សាតម្លៃទាប។ ទោះយ៉ាងណាអន្តរការី អ្នកលក់ដុំអង្ករ គឺជាភ្នាក់ងារដែលគ្រប់គ្រងលំហូរផលិតផលស្រូវពីប្រជាកសិករដល់ឧស្សាហកម្មកិនស្រូវក្នុងស្រុក និងអ្នកលក់ដុំអង្ករបរទេស។ ជាការពិតឧស្សាហកម្មកិនស្រូវក្នុងស្រុក គឺជាភ្នាក់ងារដែលគ្រប់គ្រងលំហូរស្រូវទៅកាន់អ្នកលក់រាយក្នុងស្រុក ដើម្បីចែកចាយអង្ករទៅអ្នកប្រើប្រាស់ចុងក្រោយ។ ជាការពិតនៅក្នុងផលិតផលក្នុងតំបន់អ្នកលក់រាយអង្ករបាន ផ្តល់ពូជស្រូវល្អៗ និងអង្ករសម្រាប់កសិករ។ ម្យ៉ាងវិញទៀតនៅក្នុងការប្រើប្រាស់ក្នុងតំបន់អ្នកលក់ដុំ ជាអ្នកអន្តរការីឯករាជ្យដែលទិញអង្ករពីឧស្សាហកម្មកិនស្រូវ និងលក់ទៅឱ្យអ្នក

លក់រាយ អ្នកលក់ និងអតិថិជនអាជីវកម្ម ពីជំនួញផ្សេងៗទៀត។ ហើយបន្ទាប់មកអ្នកលក់រាយអង្គរជួយសម្រួលដល់លំហូរនៃអង្ករពីអ្នកលក់អង្ករទៅអ្នកប្រើចុងក្រោយ។

## ក្រាភិចទី៣.៧ បណ្តាញនៃការចែកចាយស្រូវនៅកម្ពុជា




**ប្រភព៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម ***ការកែលម្អប្រព័ន្ធទីផ្សារ និងការត្រួតពិនិត្យគុណភាពស្រូវក្រោយប្រមូលផលនៅកម្ពុជា*** របាយការណ៍ចុងក្រោយរបស់ JICA ខែកញ្ញា ឆ្នាំ២០០១ ទំព័រទី ៣៩ ។

### ៣.២.២.ពោត

#### ក.ស្ថានភាពបច្ចុប្បន្ននៃការផ្គត់ផ្គង់ និងតម្រូវការពោតរបស់ប្រទេសកម្ពុជា

ផលិតផលពោត សរុបរបស់ប្រទេសកម្ពុជាបានកើនឡើងពី២៣៣.៧០០តោនក្នុងឆ្នាំ ១៩៩៣ ដល់ ១,៣២៨,៧០០តោន គិតត្រឹមឆ្នាំ២០១៩ ។ ការកើនឡើងនេះ គឺដោយសារតែការនាំចេញមានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីឆ្លើយតបទៅនឹងទីផ្សារពិភពលោក ដែលកំពុងមានការរីកចម្រើន។ ផលិតផលពោតរបស់កម្ពុជាក៏បានកើនឡើងយ៉ាងខ្លាំងផងដែរ ដូចជានៅតំបន់ជាច្រើននៅទូទាំងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសហរដ្ឋអាមេរិកដែលបង្ហាញថាផលិតផលពោតរបស់អាស៊ាន និងសហរដ្ឋអាមេរិកអាចនឹងកើនឡើងយ៉ាងឆាប់រហ័ស ក្នុងករណីដែលការផ្គត់ផ្គង់ពោតពិភពលោកមានការធ្លាក់ចុះ និងអាចធ្វើឱ្យតម្លៃថ្លៃមានការកើនឡើងខ្ពស់។ នៅរដូវវស្សាផលិតផលពោតបានកើនឡើងពី ២៣៣.៧០០ តោន ក្នុងឆ្នាំ១៩៩៣ ដល់ ១,៣២៨.៧០០តោន ក្នុងឆ្នាំ២០១៩ ដែលទិន្នផលពោតរដូវវស្សាបានកើនឡើងពី ១.២០ តោន/ហិកតា ក្នុងឆ្នាំ១៩៩៣ ដល់ ៣.៤៤ តោន/ហិកតា ក្នុងឆ្នាំ ២០១៩ ហើយក្នុងអំឡុងពេលដូចគ្នានេះដែរ ផ្ទៃដីប្រមូលផលពោតរដូវវស្សាបានកើនឡើងពី ២៨០.៤៤០ហិកតា ដល់ ៤,៥៧០.៧៣០ហិកតា។ នៅរដូវប្រាំងផលិតផលពោតបានកើនឡើងពី ១៦៥,៣០០តោន ក្នុងឆ្នាំ១៩៩៣ ដល់ ៤,៣៨២,៧០០តោន ក្នុងឆ្នាំ ២០១៩។ ក្នុងរយៈពេលដូចគ្នានេះដែរទិន្នផលពោតរដូវប្រាំងបានកើនឡើងពី ២.៥០តោន/ហិចតា ដល់ ៤.៩៥តោន/ហិចតា និងផ្ទៃដីប្រមូលផលពោតក្នុងរដូវប្រាំងទទួលបានកើនឡើងពី ៦៨,១០០ហិកតា ដល់ ៩៩,៥០០ហិកតា។ ទាំងនេះត្រូវបានសង្ខេបនៅក្នុងតារាងទី ៤.២។

យោងតាមការប៉ាន់ប្រមាណមួយដែលមានផ្ទៃដីជាង៧៩.៣០ហិកតា ក្នុងឆ្នាំ២០០០ សមស្របសម្រាប់ផលិតពោតដោយពិចារណាលើប្រព័ន្ធជារាសាស្ត្រ និងឧបសគ្គរិលជុំនៅប្រទេសកម្ពុជា (សុន្ទរ-កថារបស់ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០១)។

ដូចករណីដំណាំផ្សេងៗទៀត ដែលមានការរំពឹងទុកសុទ្ធសឹងតែដើរតួយ៉ាងសំខាន់សម្រាប់កសិករក្នុងការសម្រេចចិត្តលើផ្ទៃដីដែលបានប្រមូលផល ដែលត្រូវបានរងផលប៉ះពាល់នៅពេលដែលដីមិនសូវមានជីវជាតិ ត្រូវធ្វើការកែសម្រួល និងផ្លាស់ប្តូរដំណាំទៅតាមស្ថានភាពដី។ ចាប់តាំងពីការកែទម្រង់ឆ្នាំ១៩៨៩ ផលិតផលពោតនៅកម្ពុជាត្រូវបានអនុវត្តនៅក្នុងការផ្លាស់ប្តូរសេដ្ឋកិច្ចទីផ្សារ។ យោងតាមស្ថិតិ កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១៩៩៣-២០១៩ ផលិតផលពោតបានកើនឡើងយ៉ាងឆាប់រហ័ស ពីមួយឆ្នាំទៅមួយឆ្នាំនៅកម្ពុជា ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៤.៤ ដើម្បីប្រាកដថាវិស័យកសិកម្ម គឺជាវិស័យដ៏ធំបំផុតនៃសេដ្ឋកិច្ចកម្ពុជាដែលស្មើនឹង ៤៥-៥០% នៃផលិតផលក្នុងស្រុកសរុប (GDP) ដែលក្នុងនោះពោត គឺជាវិស័យធំបំផុតតែមួយដែលបានរួមចំណែកជាមធ្យម ១៧% នៃផលិតផលក្នុងស្រុកសរុប។ វិស័យផលិតផលបានរួមចំណែក ១៥-២០% និងផ្នែកសេវាកម្ម ៣៣-៣៦% នៃផលិតផលក្នុងស្រុកសរុបតាមលក្ខខណ្ឌជាក់ស្តែង (ធនាគារពិភពលោក

១៩៩៥)។ ផលិតផលពោត បានតំណាងឱ្យអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍ពាណិជ្ជ-កម្មអន្តរជាតិ។ យុទ្ធសាស្ត្រនៃឧស្សាហកម្មពោតត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងបានជំរុញកំណើនសេដ្ឋកិច្ចបង្កើនប្រាក់ចំណូលនៅតាមជនបទ (ប្រជាជន) និងអភិវឌ្ឍន៍ឧស្សាហកម្មនាំចេញកសិកម្ម (អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ ១៩៩៤)។

## តារាងទី ៣.៨ ៖ ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ទិន្នផលមធ្យម និងផលិតផលពោត

| ១/ | សរុប | | | | រដូវវស្សា ២/ | | | | រដូវប្រាំង ២/ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ន្ទផលមធ្យម ៣/ (ត/ហ.ត) | លិតផល (000ត) | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ន្ទផលមធ្យម ៣/ (ត/ហ.ត) | លិតផល (000ត) | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ន្ទផលមធ្យម ៣/ (ត/ហ.ត) | លិតផល (000ត) |
| ៩៩៣ | ៨.១០ | ៦.១០ | .៩៧១ | ៣៣.៧០ | ៨.១០ | ៦.១០ | .២ | ៨០.៤៤ | ៨.១០ | ៦.១០ | .៥ | ៦៥.៣ |
| ៩៩៤ | ៧.២០ | ២.៣០ | .៩២៧ | ៣៥.៨០ | ៧.២០ | ២.៣០ | .៣ | ០៦.៥៤ | ៧.២០ | ២.៣០ | .០ | ៨៦.៩ |
| ៩៩៥ | ១.២០ | ៩.១០ | .៩៧១ | ៤៣.៣០ | ១.២០ | ៩.១០ | .៦៤ | ៩៩.០១ | ១.២០ | ៩.១០ | .០ | ០៧.៣ |
| ៩៩៦ | ៩.៥០ | ២.៣០ | .០៤ | ១៥.២០ | ៩.៥០ | ២.៣០ | .៦៧ | ២៦.៣៨ | ៩.៥០ | ២.៣០ | .០៤ | ១៩.៨ |
| ៩៩៧ | ៧.១០ | ២.៩០ | .៩៤៦ | ១៦.៣០ | ៧.១០ | ២.៩០ | .៥៩ | ០២.៩២ | ៧.១០ | ២.៩០ | .០៤ | ២១.៦ |
| ៩៩៨ | ៥.២៥ | ២.១០ | .៩៥៨ | ១២.៦០ | ៥.២៥ | ២.១០ | .៦៥ | ១៥.៧៩ | ៥.២៥ | ២.១០ | .៩៣ | ១១.៣ |
| ៩៩៩ | ១.១៥ | ៩.២០ | .៩៧៦ | ២៥.៧០ | ១.១៥ | ៩.២០ | .៨ | ៨៦.២៦ | ១.១៥ | ៩.២០ | .០៤ | ៤០.៨ |
| ០០០ | ៩.៣០ | ៨.៣០ | .៩៨៧ | ០៤.២០ | ៩.៣០ | ៨.៣០ | .៨១ | ៥០.៦០ | ៩.៣០ | ៨.៣០ | .០៤ | ៣៨.០ |
| ០០១ | ៥.៧០ | ២.១០ | .៩៥៨ | ២៥.៣០ | ៥.៧០ | ២.១០ | .៩៩ | ៤៧.៣៥ | ៥.៧០ | ២.១០ | .២២ | ៦៤.៤ |
| ០០២ | ៧.៦០ | ៣.៥០ | .៨៥៦ | ៥២.២០ | ៧.៦០ | ៣.៥០ | .៧១ | ០២.២៦ | ៧.៦០ | ៣.៥០ | .១៨ | ៦៥.៥ |
| ០០៣ | ៨.១០ | ៥.៧០ | .៨៧៤ | ៧២.១០ | ៨.១០ | ៥.៧០ | .៩៥ | ២៥.៦០ | ៨.១០ | ៥.៧០ | .១៧ | ៧១.៧ |
| ០០៤ | ០២.៥០ | ០២.២០ | .៩៩៧ | ១២.២០ | ០២.៥០ | ០២.២០ | .៧៣ | ១៣.១១ | ០២.៥០ | ០២.២០ | .៥៤ | ៦១.៨ |
| ០០៥ | ៣២.២០ | ៤២.១០ | .០៧៥ | ២៥.៣០ | ៣២.២០ | ៤២.១០ | .២៦ | ៦១.១៨ | ៣២.២០ | ៤២.១០ | .៩ | ៥៤.២ |
| ០០៦ | ៤៣.១៥ | ៤៥.៩០ | .០១៩ | ១២.៣០ | ៤៣.១៥ | ៤៥.៩០ | .២៧ | ,១៦២.៩២ | ៤៣.១៥ | ៤៥.៩០ | .៩៣ | ៧៣.៤ |
| ០០៧ | ៥៦.២០ | ៥៣.២០ | .៩៨១ | ១២.៥០ | ៥៦.២០ | ៥៣.២០ | .៤១ | ,២៣៥.១៣ | ៥៦.២០ | ៥៣.២០ | .៩៦ | ០៦.៧ |
| ០០៨ | ៦៣.១០ | ៦៣.៣០ | .០០១ | ១១.៩០ | ៦៣.១០ | ៦៣.៣០ | .៥៤ | ,៥៥៤.២៣ | ៦៣.១០ | ៦៣.៣០ | .០៣ | ៥៨.១ |
| ០០៩ | ២១.៣០ | ១៣.០០ | .៩៦២ | ២៤.០០ | ២១.៣០ | ១៣.០០ | .៦២ | ,៤២០.៨៨ | ២១.៣០ | ១៣.០០ | .១៣ | ៧៩.៧ |
| ០១០ | ១២.៦០ | ៨៩.៥០ | .៦០៦ | ៧៣.៣០ | ១២.៦០ | ៨៩.៥០ | .៧៦ | ,១៣៤.៣១ | ១២.៦០ | ៨៩.៥០ | .២ | ៩៥.៩ |
| ០១១ | ៤៨.៤០ | ៥៩.៨០ | .០៧៧ | ៦៨.៤០០ | ៤៨.៤០ | ៥៩.៨០ | .៩២ | ,៩៥១.៧៣ | ៤៨.៤០ | ៥៩.៨០ | .៤១ | ០៤.៧ |
| ០១២ | ៧៥.៥០ | ១៥.៤០ | .២២៧ | ០៦.៨០ | ៧៥.៥០ | ១៥.៤០ | .៨៧ | ,៣១៥.៥២ | ៧៥.៥០ | ១៥.៤០ | .៣៥ | ៣៧. |
| ០១៣ | ០១.៨០ | ១៧.២០ | .០៧៦ | ៤៨.៤០ | ០១.៨០ | ១៧.២០ | .៩៣ | ,៤៨៥.៨១ | ០១.៨០ | ១៧.២០ | .៣៨ | ៥១.៣ |
| ០១៤ | ១៦.៨០ | ១៥.៣០ | .៤១២ | ៧៥.២០ | ១៦.៨០ | ១៥.៣០ | .៨១ | ,៧៤០.៣១ | ១៦.៨០ | ១៥.៣០ | .៤៤ | ២៨៧.៩ |
| ០១៥ | ៧.៥០ | ៤៦.៦០ | .២៤៧ | ៨២.២០ | ៧.៥០ | ៤៦.៦០ | .៨៤ | ,៧៨៩.៤៥ | ៧.៥០ | ៤៦.៦០ | .៤២ | ៤១៦. |

| ១/ | សរុប | | | | រដូវវស្សា ២/ | | | | រដូវប្រាំង ២/ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ទិន្នផលមធ្យម ៣/ (ត/ហ.ត) | ផលិតផល (000ត) | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ទិន្នផលមធ្យម ៣/ (ត/ហ.ត) | ផលិតផល (000ត) | ដីដាំដុះ (000ហ.ត) | ដីប្រមូលផល (000ហ.ត) | ទិន្នផលមធ្យម ៣/ (ត/ហ.ត) | ផលិតផល (000ត) |
| ០១៦ | ៨.៣០ | ៥០.១០ | .៦១៣ | ៩៥.៧០ | ៨.៣០ | ៥០.១០ | .៩៨ | ,៩៦៧.១៩ | ៨.៣០ | ៥០.១០ | .៥៥ | ៩៥៨. |
| ០១៧ | ៥.២០ | ៧៥.១០ | .៩២៤ | ,១០៥.៦០ | ៥.២០ | ៧៥.១០ | .១២ | ,៤៤៩.៤៧ | ៥.២០ | ៧៥.១០ | .៦៨ | ១៥៩.៥ |
| ០១៨ | ៧.៩០ | ១០.២០ | .១១៧ | ,២៧៥.២០ | ៧.៩០ | ១០.២០ | .២៨ | ,១៨២.៦៦ | ៧.៩០ | ១០.២០ | .៨១ | ៤១៦.១ |
| ០១៩ | ៩.៥០ | ៨៥.៤០ | .៨៩៨ | ,៣២៨.៧០ | ៩.៥០ | ៨៥.៤០ | .៤៤ | ,៥៧០.៧៣ | ៩.៥០ | ៨៥.៤០ | .៩៥ | ៣៨២.៧ |

**សម្គាល់៖**១/ ឆ្នាំដំណាំ - ខែកុម្ភៈ ដល់ ខែមីនា

២/ រដូវវស្សា - ឧសភា ដល់ ខែមករា

រដូវប្រាំង - ខែកុម្ភៈ ដល់ ខែមេសា

៣/ ទិន្នផលមធ្យម = ផលិតផល / ផ្ទៃដីប្រមូលផល

**ប្រភព៖**- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ *ព្រឹត្តិប័ត្រស្ថិតិកសិកម្មកម្ពុជាប្រចាំឆ្នាំ ២០២០*

- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧*

ផ្ទៃដីដាំដុះពោតសរុបរបស់ប្រទេសកម្ពុជាបានកើនឡើងពី ៦៨.១០០ហិកតាក្នុងឆ្នាំ ១៩៩៣ដល់ ៩៩.៥០០ ក្នុងឆ្នាំ២០១៩។ ការកើនឡើងនេះដោយសារតែការកើនឡើងនៃការនាំចេញក្នុងអំឡុងទសវត្សឆ្នាំ១៩៩៣ ដើម្បីឆ្លើយតបទៅនឹងទីផ្សារពិភពលោកដែលកំពុងមានការកើនឡើង។ វាមានន័យថាការបង្កើនបរិមាណពោតរបស់កម្ពុជាអាចនឹងកើនឡើងយ៉ាងឆាប់រហ័សក្នុងករណី ដែលការផ្គត់ផ្គង់អង្ករបស់អាស៊ានធ្លាក់ចុះ ធ្វើឱ្យតម្លៃនាំចេញនឹងមានការកើនឡើង។

**ក្រាភិចទី ៣.៨ ៖ ផលិតផលស្រូវសរុបនៅរដូវវស្សា និងរដូវប្រាំងពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩**




## ខ.តម្លៃផលិតផលស្រូវនៅកម្ពុជា

ក្នុងចំណោមរបស់ផ្សេងទៀតថ្លៃដើមសម្រាប់កម្លាំងពលកម្ម កសិកម្មជីគីមី និងថ្នាំសម្លាប់សត្វល្អិតបានហក់ឡើងយ៉ាងខ្លាំងចាប់ពីឆ្នាំ១៩៩៣ដល់ឆ្នាំ២០១៩ដូចដែលបានបង្ហាញក្នុងរូបភាពទី ៤.៥ មានការកំណត់ជាក់លាក់ ក្នុងការកាត់បន្ថយថ្លៃដើមផលិតផល ដោយគ្រាន់តែជំនួសគ្រឿងម៉ាស៊ីនសម្រាប់កម្លាំងពលកម្មក្នុងផលិតពោតប៉ុណ្ណោះ។

ថ្លៃដើមទាំងជីជ្លី និងដើមទុនមានចំនួន៨% ជាមធ្យមនៃថ្លៃដើមផលិតផលសរុប ប៉ុន្តែវាក៏បានកើនឡើងជាលំដាប់ៗផងដែរ។ គិតត្រឹមឆ្នាំ២០១៩ ការចំណាយលើជីជ្លីមានចំនួន ៤០ ដុល្លារ/ហិកតា កម្លាំងពលកម្ម ៥០ដុល្លារ/ហិកតា និងគ្រឿងម៉ាស៊ីន ២០ដុល្លារ/ហិចតា (របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៩)។ ទន្ទឹមនឹងនោះតម្លៃពោតជាមធ្យមសម្រាប់កសិករវិញបានកើនឡើងពី ២០០រៀល/គីឡូក្រាមក្នុងឆ្នាំ១៩៩៣ ដល់ ៦៥០រៀល/គីឡូក្រាមក្នុងឆ្នាំ ២០១៩ (របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០២០)។

ម្យ៉ាងទៀតចាប់ពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩ ថ្លៃដើមផលិតផលផ្លាស់ពី ៣,២៤% ទៅ ៧% នៃថ្លៃដើមផលិតផលសរុប ហើយថ្លៃដើមដែលកសិករបានចំណាយត្រូវបានគិតគូយ៉ាងខ្លាំង។ កសិករជាធម្មតាត្រូវចំណាយថ្លៃដើមប្រតិបត្តិការនៃគម្រោងប្រព័ន្ធធារាសាស្ត្រ ថ្លៃដើម និងដើមទុនសម្រាប់ការ វិនិយោគ។ ថ្លៃដើមផលិតពោតសម្រាប់ប្រជាកសិករកម្ពុជា គឺសំខាន់បំផុតនៅគ្រប់តំបន់ទាំងអស់ក្នុងការវាយតម្លៃពីភាពប្រកួតប្រជែងរបស់ទីផ្សារអន្តរជាតិ ដោយសារពោតនាំចេញមួយចំនួនផលិតនៅតាមខេត្តជុំវិញបឹងទន្លេសាប។ ប្រាក់ចំណូលនៃការផលិតផលពោតក្នុងមួយហិចតានៅប្រទេសកម្ពុជាមានចាប់ពី ៣៧០ដុល្លារ ដល់ ៩២៤ដុល្លារ ជាមធ្យមក្នុងអំឡុងឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩ ប្រាក់ចំណូលសុទ្ធក្នុងមួយហិចតាបានកើនឡើងពី

២៥០ដុល្លារ ក្នុងឆ្នាំ១៩៩៣ ដល់ ៨៧៧ដុល្លារ ក្នុងឆ្នាំ២០១៩(របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០២០) ជិត៤ដង ។

## តារាងទី ៣.៩ ៖ ប្រាក់ចំណូលដុល ផលិតផលថ្លៃដើម ការគ្រប់គ្រងថ្លៃដើម ប្រាក់ចំណូល និង ចំណេញ

(ឯកតា៖ ដុល្លារ/ហិកតា)

| ឆ្នាំ | ប្រាក់ចំណូលដុល | ថ្លៃដើមផលិតផល (១) | ការគ្រប់គ្រងថ្លៃដើម (២) | ប្រាក់ចំណូល | ប្រាក់ចំណេញ |
|---|---|---|---|---|---|
| | (A) | (B) | (C) | (A - C) | (A - B) |
| ១៩៩៣ | ៣៧០ | ១៧០ | ២០០ | ១៧០ | ២០០ |
| ១៩៩៤ | ៣៨៥ | ១៧៥ | ២១០ | ១៧៥ | ២១០ |
| ១៩៩៥ | ៣៨០ | ១៧០ | ២១០ | ១៧០ | ២១០ |
| ១៩៩៦ | ៤២០ | ១៩០ | ២៣០ | ១៩០ | ២៣០ |
| ១៩៩៧ | ៤០៥ | ១៧០ | ២៣៥ | ១៧០ | ២៣៥ |
| ១៩៩៨ | ៤០០ | ១៨០ | ២២០ | ១៨០ | ២២០ |
| ១៩៩៩ | ៤៣០ | ២០០ | ២៣០ | ២០០ | ២៣០ |
| ២០០០ | ៤១០ | ១៩០ | ២២០ | ១៩០ | ២២០ |
| ២០០១ | ៤២០ | ១៩៥ | ២២៥ | ១៩៥ | ២២៥ |
| ២០០២ | ៤៣៥ | ២០០ | ២៣៥ | ២០០ | ២៣៥ |
| ២០០៣ | ៤៥៥ | ២០៥ | ២៥០ | ២០៥ | ២៥០ |
| ២០០៤ | ៤៧០ | ២០០ | ២៧០ | ២០០ | ២៧០ |
| ២០០៥ | ៤៧០ | ២១០ | ២៦០ | ២១០ | ២៦០ |
| ២០០៦ | ៤៩៥ | ២១៥ | ២៨០ | ២១៥ | ២៨០ |
| ២០០៧ | ៥២០ | ២២០ | ៣០០ | ២២០ | ៣០០ |
| ២០០៨ | ៥០៥ | ២០០ | ៣០៥ | ២០០ | ៣០៥ |
| ២០០៩ | ៥៤០ | ២៣០ | ៣១០ | ២៣០ | ៣១០ |
| ២០១០ | ៥៦០ | ២៤០ | ៣២០ | ២៤០ | ៣២០ |
| ២០១១ | ៥៣០ | ២៣០ | ៣០០ | ២៣០ | ៣០០ |
| ២០១២ | ៥៩០ | ២៥០ | ៣៤០ | ២៥០ | ៣៤០ |
| ២០១៣ | ៦២០ | ២៧០ | ៣៥០ | ២៧០ | ៣៥០ |
| ២០១៤ | ៦៦០ | ២៩០ | ៣៧០ | ២៩០ | ៣៧០ |
| ២០១៥ | ៦៩០ | ២៩០ | ៤០០ | ២៩០ | ៤០០ |
| ២០១៦ | ៧២០ | ៣១០ | ៤១០ | ៣១០ | ៤១០ |
| ២០១៧ | ៧៥០ | ៣៣០ | ៤២០ | ៣៣០ | ៤២០ |
| ២០១៨ | ៨៨០ | ៣៨០ | ៥០០ | ៣៨០ | ៥០០ |
| ២០១៩ | ១០៣០ | ៣៨០ | ៦៥០ | ៣៨០ | ៦៥០ |

**សម្គាល់៖**១) ការគ្រប់គ្រងថ្លៃដើម + ថ្លៃដើមកម្លាំងពលកម្ម + ថ្លៃដើមសេវាកម្មជីជ្លី + ថ្លៃដើមសេវាកម្ម

២) ថ្លៃដើមធាតុចូល + ថ្លៃដើមកម្លាំងពលកម្មបុគ្គលិក + ថ្លៃដើមលើកាជួលកម្លាំងពលកម្មសត្វ

**ប្រភព៖** - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០១៩*

- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៧*

**ក្រាភិចទី ៣.៩ ៖ ប្រាក់ចំណូលដុល ផលិតផលថ្លៃដើម ការគ្រប់គ្រងថ្លៃដើម ប្រាក់ចំណូល និងចំណេញ**




### គ.ចរាចរពោតនៅលើទីផ្សារ

ផលិតផលពោតរបស់កម្ពុជាបានកើនឡើងចាប់ពី ៣៨៣,៤០០តោនក្នុងឆ្នាំ១៩៩៣ ដល់២,០៥៦,២២៩ តោនក្នុងឆ្នាំ២០១៩។ ជាមួយនឹងអត្រាកិនជាមធ្យម៦២% ការផ្គត់ផ្គង់ពោតបានកើនឡើងពី ៩៧៨,២២២.០០ តោន ដល់ ៥,៤២១,៦៧០.៣៦តោន ក្នុងរយៈពេលដូចគ្នា ដូចដែលបានសង្ខេបនៅតារាងទី៤.៤ក្នុងពេលតែមួយចរាចរពោតបានកើនឡើងពី ៣៨៣,៤០០តោនដល់ ២,០៥៦,២២៩តោន។ ដូច្នេះទាំងតម្រូវការ និងការផ្គត់ផ្គង់ពោតមានការកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ (រូបភាពទី៤.៦)។

នៅពេលសេដ្ឋកិច្ចរីកចម្រើន ការប្រើប្រាស់ពោតប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់បានថយចុះចាប់ពី ៥១.៣ គីឡូក្រាមក្នុងឆ្នាំ១៩៩៣ ដល់ ១២.៦គីឡូក្រាមក្នុងឆ្នាំ២០១៩ ដូចដែលបានបង្ហាញក្នុងតារាងទី ៤.៤។

ការប្រើប្រាស់ពោតសម្រាប់មនុស្សម្នាក់ បានចាប់ផ្ដើមថយចុះយ៉ាងលឿនចាប់តាំងពីឆ្នាំ ១៩៩៥មកដោយសារតែចំណូលរបស់មនុស្សម្នាក់កំពុងកើនឡើងជាលំដាប់ (រូបភាពទី៤.៧)។ ដោយសារតែអតិផរណានៃផលិតកម្មពោតនៅកម្ពុជាដូច ដែលបានសង្ខេបនៅតារាងទី៤.៥ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យប្រសើរឡើង នូវវិស័យនាំចេញពោត និងទីផ្សារពោតដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មពោតបន្ថែមទៀត។ ដូចដឹងហើយថាសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើវិស័យកសិកម្មប្រហែល ៥០%នៃផលិតផលក្នុងស្រុកសរុប (GDP) ដែលក្នុងនោះពោត គឺជាវិស័យធំបំផុតតែមួយដែលរួមចំណែកជាមធ្យម ១៧% នៃផលិតផលក្នុងស្រុកសរុប។ ដូច្នេះឧស្សាហកម្មស្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិកម្ពុជាផងដែរ។ លើសពីនេះទៅទៀតប្រជាជនកម្ពុជាប្រមាណ ៨៥% រស់នៅតាមតំបន់ជនបទ ប្រកបមុខរបរកសិកម្មនៅតែជាឧស្សាហកម្មដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា។

ចាប់ពីឆ្នាំ១៩៨០ ដល់ដើមទសវត្សឆ្នាំ១៩៩០ ពោតត្រូវបានគេចាត់ទុកថាល្អទៅលើផ្នែកនយោបាយហើយឧស្សាហកម្មពោតត្រូវបានអន្តរាគមន៍យ៉ាងខ្លាំងដោយខេត្តក្នុងតំបន់។ យន្តការទីផ្សារត្រូវបានបង្ក្រាបហើយប្រព័ន្ធទីផ្សារពោតត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹង។ ផលិតកម្មពោតត្រូវបានអនុវត្តដោយរដ្ឋាភិបាលក្នុងទម្រង់ជាបីជម្រើស។

ជម្រើសទីមួយកសិកម្មនីមួយៗ ឬក្រុមផលិតពោតត្រូវតែផ្គត់ផ្គង់បរិមាណពោត ឱ្យបានជាក់លាក់ទៅរដ្ឋាភិបាល។

ជម្រើសទីពីរ កម្រៃសេវាសាធារណៈត្រូវបានប្រមូលជាថ្នូរនឹងប្រព័ន្ធធារាសាស្ត្រ ការរៀបចំដី គ្រាប់ពូជ ជី ឬឈ្នួញទំនិញសម្រាប់ផលិត។ល។

ជម្រើសទីបី កសិករអាចលក់ពោតទៅឱ្យរដ្ឋដោយផ្អែកលើតម្លៃកិច្ចសន្យា ដែលទាបជាងតម្លៃ

ទីផ្សារ។ ដូច្នេះមានតែពោតប្រមាណ ២ ទៅ ៣% ប៉ុណ្ណោះនៃពោតសរុបដែលត្រូវបានជួញដូរនៅលើ

ទីផ្សារសេរី។ ជាការពិតណាស់មុនឆ្នាំ១៩៨៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលបន្ទុកក្នុងការចែកចាយពោតទាំងអស់នៅទូទាំងប្រទេស។ នៅថ្នាក់ភូមិកសិកម្មទទួលខុសត្រូវក្នុងការចែកចាយស្បៀងអាហារដល់សមាជិក និងសម្រាប់ផលិតកម្មពោត ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដើម្បីបំពេញកាតព្វកិច្ចចំពោះរដ្ឋាភិបាល។

គោលនយោបាយកំណែទម្រង់ ដែលបានផ្ដួចផ្ដើមឡើងក្នុងឆ្នាំ១៩៨៩ បានធ្វើសេរីភាវូបនីយកម្មទីផ្សារពោតក្នុងស្រុក។ ឈ្មួញកណ្ដាល និងឈ្មួញមួយចំនួនតូចបានចូលទីផ្សារពោតដើម្បីប្រកួតប្រជែងជាមួយប្រព័ន្ធទីផ្សាររបស់រដ្ឋ។ ក្រុមហ៊ុនស្បៀងអាហារសាធារណៈដែលពីមុនជាអ្នកចែកចាយ ផ្ដាច់មុខនូវការចែកចាយពោតលក់រាយឥឡូវនេះផ្ដោតលើការកែច្នៃជាម្សៅចំណីសត្វ និងអនុវត្តការធ្វើពាណិជ្ជកម្ម និងនាំចេញពោតតាមតំបន់។ ឥឡូវនេះពួកគេពឹងផ្អែកជាចម្បងលើពាណិជ្ជករឯកជនសម្រាប់ជានាគារផ្គត់ផ្គង់ពោត។ ទីផ្សារលក់ដុំត្រូវបានបង្កើត

ឡើងនៅចំណុចផ្គត់ផ្គង់ជាច្រើន ដូចជា ខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ចាម កំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។

## តារាងទី ៣.១០ ៖ ការផ្គត់ផ្គង់ និងតម្រូវការពោតទៅលើទីផ្សារអន្តរជាតិ

| ឆ្នាំ | ផលិតផលពោតសរុប (តោន) | ការកាត់បន្ថយ ១៧%*(តោន) | ពោតដុលសម្រាប់ប្រើប្រាស់ (តោន) | ចំនួនប្រជាជន (មនុស្ស) | ពោតសរុប (អត្រារោងម៉ាស៊ីន62%) (តោន) (A) | ការប្រើប្រាស់ពោតសរុប(តោន) (B) | ការប្រើប្រាស់ពោត (គីឡូក្រាម/ម្នាក់) | ភាពគ្រប់គ្រាន់នៃពោត(A/B) (%) |
|---|---|---|---|---|---|---|---|---|
| ១៩៩៣ | ៣៨៣,៤០០ | ៤០៥,១៧៨.០០ | ៩៧៨,២២២.០០ | ៩,៩៧០,៧៣៣ | ២២៦,៤៩៧.៦៤ | ៥០៨,៤១០.០០ | ៥១.៣០ | ០.៤៤៦ |
| ១៩៩៤ | ២២៣,៥០០ | ៣៧៧,៩៩៥.០០ | ៨៤៥,៥០៥.០០ | ១០,៣១៧,៨៩៩ | ១៤៤,២១៣.១០ | ៥៤៨,០២៣.០០ | ៥០.០០ | ០.២៦៣ |
| ១៩៩៥ | ៤៤៧,៨០០ | ៥៨៦,១២៦.០០ | ៨៦១,៦៧៤.០០ | ១០,៦៥៦,១៣៨ | ៧៧៤,២៣៧.៨៨ | ៧០១,០០០.០០ | ៥៩.៦០ | ១.១០៤ |
| ១៩៩៦ | ៤៥៨,០០០ | ៥៨៧,៨៦០.០០ | ៨៧០,១៤០.០០ | ១០,៩៨២,៩១៧ | ៧៧៩,៤៨៦.៨០ | ៦៩៩,១៦០.០០ | ៥៤.៧០ | ១.១១៥ |
| ១៩៩៧ | ៤១៤,៩០០ | ៥៨០,៥៣៣.០០ | ៨៣៤,៣៦៧.០០ | ១១,២៩៨,៦០០ | ៧៥៧,៣០៧.៥៤ | ៧០២,០៣៨.៤៣ | ៥០.៦០ | ១.០៧៩ |
| ១៩៩៨ | ៥០៩,៩០០ | ៥៩៦,៦៨៣.០០ | ៩១៣,២១៧.០០ | ១១,៦០០,៥០៨ | ៨០៦,១៩៤.៥៤ | ៨០៣,០១០.១៩ | ៥៥.៤០ | ១.០០៤ |
| ១៩៩៩ | ៦២៩,៦០០ | ៦៨៥,០៣២.០០ | ១,៣៤៤,៥៦៨.០០ | ១១,៨៨៦,៤៥៨ | ៩៧៣,៦៣២.១៦ | ៨៤៤,២៣៧.២២ | ៥៥.២០ | ១.១៥៣ |
| ២០០០ | ៦៤០,៩០០ | ៦៨៦,៩៥៣.០០ | ១,៣៥៣,៩៤៧.០០ | ១២,១៥៥,២៣៩ | ៩៧៩,៤៤៧.១៤ | ៨៧៥,៨៤៦.២៥ | ៥៤.៣០ | ១.១១៨ |
| ២០០១ | ៦៩៩,១០០ | ៦៩៦,៨៤៧.០០ | ១,៤០២,២៥៣.០០ | ១២,៤០៥,៤០៨ | ៩៨០,៣៩៦.៨៦ | ៧៥១,៦៤៣.៦១ | ៤១.២០ | ១.៣០៤ |
| ២០០២ | ៨២៣,០០០ | ៦៤៩,៩១០.០០ | ១,១៧៣,០៩០.០០ | ១២,៦៣៧,៧២៧ | ៩៦៧,៣១៥.៨០ | ៧៥៩,៤២៤.៣៥ | ៣៩.២០ | ១.២៧៤ |
| ២០០៣ | ៨១០,៩០០ | ៨០០,៨៥៣.០០ | ១,៩១០,០៤៧.០០ | ១២,៨៥៦,១៦៣ | ៩៨៤,២២៩.១៤ | ៧៦៤,៧៦៥.៥០ | ៣៧.៣០ | ១.២៨៧ |
| ២០០៤ | ៧៧០,៣០០ | ៧០៨,៩៥១.០០ | ១,៤៦១,៣៤៩.០០ | ១៣,០៦៦,៤៦៩ | ១,១៤៦,០៣៦.៣៨ | ៧៦៨,៥៤៦.៥៨ | ៣៥.៤០ | ១.៤៩១ |
| ២០០៥ | ៩៨៦,២០០ | ១,០១៧,៦៥៤.០០ | ១,៩៦៨,៥៤៦.០០ | ១៣,២៧៣,៣៥៤ | ១,០៨០,៤៩៨.៥២ | ៧៧១,៣២៩.០៩ | ៣៣.៥០ | ១.៤០១ |
| ២០០៦ | ៩៦៤,០០០ | ១,០៦៤,៨៨០.០០ | ២,១៩៩,១២០.០០ | ១៣,៤៧៧,៧០៩ | ១,២២៣,៤៥៤.៤០ | ៧៧៣,៣៩៦.៩៥ | ៣១.៦០ | ១.៥៨២ |
| ២០០៧ | ៩២៧,១០០ | ១,១៤៣,៦០៧.០០ | ២,៥៨៣,៤៩៣.០០ | ១៣,៦៧៩,៩៦២ | ១,៤៦១,៧៦៥.៦៦ | ៧៧៤,៨៣៨.២៧ | ២៩.៧០ | ១.៨៨៧ |
| ២០០៨ | ៩៨៥,៤០០ | ១,២១៩,៨១៨.០០ | ២,៩៥៥,៥៨២.០០ | ១៣,៨៨៣,៨៣៤ | ១,៦៩២,៤៦០.៨៤ | ៧៧៦,១៥៨.៨៨ | ២៧.៩០ | ២.១៨១ |
| ២០០៩ | ១,០៨៥,៩០០ | ១,២៨៩,៦០៣.០០ | ២,២៩៦,២៩៧.០០ | ១៤,០៩៣,៦០៤ | ១,៩០៣,៧០៤.១៤ | ៧៧៧,៦២៦.២៧ | ២៦.១០ | ២.៤៤៨ |
| ២០១០ | ១,១៤៩,៤០០ | ១,៤០២,៣៩៨.០០ | ២,៨៤៧,០០២.០០ | ១៤,៣១២,២១២ | ២,២៤៥,១៤១.២៤ | ៧៨០,០០៩.៨១ | ២៤.៤០ | ២.៨៧៨ |
| ២០១១ | ១,៣៧៩,៣០០ | ១,៤៩២,៤៨១.០០ | ៣,២៨៦,៨១៩.០០ | ១៤,៥៤១,៤២៣ | ២,៥១៧,៨២៧.៧៨ | ៧៨៨,៦២៣.០៩ | ២៣.០០ | ៣.១៩៣ |
| ២០១២ | ១,២៩០,៨០០ | ១,៥៧៩,៤៣៦.០០ | ៣,៧១១,៣៦៤.០០ | ១៤,៧៨០,៤៥៤ | ២,៧៨១,០៤៥.៦៨ | ៧៩៨,០២៦.១០ | ២១.៦០ | ៣.៤៨៥ |
| ២០១៣ | ១,៣៨៩,៧០០ | ១,៥៩៦,២៤៩.០០ | ៣,៧៩៣,៤៥១.០០ | ១៥,០២៦,៣៣២ | ២,៨៣១,៩៣៩.៦២ | ៨០៧,៨២៩.៥៨ | ២០.៣០ | ៣.៥០៦ |
| ២០១៤ | ១,៣២៤,៤០០ | ១,៥៨៥,១៤៨.០០ | ៣,៧៣៩,២៥២.០០ | ១៥,២៧៤,៥០៣ | ២,៧៩៨,៣៣៦.២៤ | ៨១៧,៤៧២.៦៧ | ១៩.០០ | ៣.៤២៣ |
| ២០១៥ | ១,៣៣៥,២០០ | ១,៥៨៦,៩៨៤.០០ | ៣,៧៤៨,២១៦.០០ | ១៥,៥២១,៤៣៦ | ២,៨០៣,៨៩៣.៩២ | ៨២៦,៥៣៩.១៧ | ១៧.៧០ | ៣.៣៩២ |
| ២០១៦ | ១,៥៥២,៧៦៣ | ១,៧០៨,៩៦៩.៧៣ | ៣,៣៤៣,៧៩៣.៣៨ | ១៥,៧៦៦,២៩២ | ៣,១៧៣,១៥១.៩០ | ៨៣៤,៩៤៤.៥៧ | ១៦.៤០ | ៣.៨០០ |
| ២០១៧ | ១,៨២៥,៨៤៨ | ១,៨៤០,៣៩៤.១៤ | ៣,៩៨៥,៤៥៣.៧៤ | ១៦,០០៩,៤០៩ | ៣,៥៧០,៩៨១.៣២ | ៨៤២,៧៤៣.៨៧ | ១៥.១០ | ៤.២៣៧ |
| ២០១៨ | ១,៩៥៨,៧៨១ | ១,៩៨១,៩៩២.៧៩ | ៤,៦៧៦,៧៨៨.៣២ | ១៦,២៤៩,៧៩២ | ៣,៩៩៩,៦០៨.៧៦ | ៨៤៩,៨៣៨.៣៣ | ១៣.៨០ | ៤.៧០៦ |
| ២០១៩ | ២,០៥៦,២២៩ | ២,១៣៤,៥៥៨.៩៩ | ៥,៤២១,៦៧០.៣៦ | ១៦,៤៨៦,៥៤២ | ៤,២០១,៤៣៥.៦២ | ៨៥៦,១៤៤.៧១ | ១២.៦០ | ៤.៩០៧ |

**សម្គាល់៖**កត់សម្គាល់លើការកាត់បន្ថយ ១៧% សម្រាប់ការបម្រុងទុកគ្រាប់ពូជ និងការបាត់បង់ការប្រមូលផលក្រោយ។

**ប្រភព៖-** ទីស្តីការគណៈរដ្ឋមន្ត្រី ***របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០០២***

- នាយកដ្ឋានផែនការស្ថិតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ***ព្រឹត្តិប័ត្រកសិកម្មស្តង់ដារប្រទេសកម្ពុជាឆ្នាំ២០០២***
- អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ ***របាយការណ៍កសិកម្មកម្ពុជា ឆ្នាំ២០០១***
- ក្រសួងពាណិជ្ជកម្ម ***របាយការណ៍កសិកម្មកម្ពុជាប្រចាំឆ្នាំ២០០១***
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ***សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៧***
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ***របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០២០***

**ក្រាភិចទី ៣.១១ ៖ ការផ្គត់ផ្គង់ និងតម្រូវការពោតសរុបចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៩**




ទាំងតម្លៃទីផ្សារក្នុងស្រុក និងនាំចេញសម្រាប់ពោតត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ថ្ងៃនៅទីផ្សារពោតលក់ដុំចាប់តាំងពីឆ្នាំ១៩៩៥។ តំបន់កណ្តាលនៃប្រទេសកម្ពុជា និងតំបន់ផ្សេងទៀត គឺជាតំបន់ដែលមានពោតលើសតម្រូវ ការ។ តិចជាងមួយភាគបីនៃពោតកម្ពុជាត្រូវបានផ្គត់ផ្គង់នៅខាងក្រៅតំបន់ជុំវិញបឹងទន្លេសាប។ ការចូលរួមរបស់ភ្នាក់ងារទីផ្សារឯកជននៅក្នុងតំបន់ទាំងពីរនេះភាគច្រើន គឺទីផ្សារក្នុងស្រុក។ បណ្តាលទីផ្សារផ្សេងៗគ្នាកាន់តែទូលំទូលាយត្រូវបានប្រើប្រាស់នៅក្នុងតំបន់ទន្លេមេគង្គ និងតំបន់កណ្តាលដូចជាកសិករ អ្នកប្រើប្រាស់ អ្នកកិនពោត អ្នកបរិភោគ បុគ្គលិកក្រុមហ៊ុន ក្រុមហ៊ុនឯកជន អ្នកជំនួញឯកជន កសិករពាណិជ្ជករឯកជន លក់រាយ អតិថិជន។

ខណៈពេលដែលទីផ្សារក្នុងស្រុកត្រូវបានធ្វើសេរីភាវូបនីយកម្ម ភាគច្រើននៃវិស័យនាំចូល និងនាំចេញនៅតែត្រូវបានធ្វើអាជីវកម្មផ្តាច់មុខ ដោយរដ្ឋនៅទសវត្សឆ្នាំ១៩៨០។ ក្រុមហ៊ុន

វិស័យឯកជនមួយចំនួនត្រូវបានអនុញ្ញាតឱ្យនាំចេញពោតក្នុងឆ្នាំ១៩៩៥ ជាលើកដំបូង ប៉ុន្តែមានតែការបែងចែក និងកូតាផ្ទាល់ពីរដ្ឋាភិបាលខេត្តប៉ុណ្ណោះ។ ដំណើរការធ្វើសេរីភាវូបនីយកម្មនៅក្នុងពាក់កណ្តាលទស-វត្សឆ្នាំ១៩៩០ សហគ្រាសដែលគ្រប់គ្រងដោយរដ្ឋាភិបាល ត្រូវបានផ្តល់ការអនុញ្ញាតឱ្យមានការនាំចេញពោតភាគច្រើន។ ពួកគេខ្លះមិនមានបទពិសោធន៍ក្នុងការទាក់ទងជាមួយអ្នកទិញ អន្តរជាតិ និងស្វែងរកប្រភពនៃការផ្គត់ផ្គង់ក្នុងស្រុក។ ការរៀបចំនេះបាននាំឱ្យមានហានិភ័យខ្ពស់ក្នុងការប្រព្រឹត្តិកិច្ច-សន្យា ដូច្នេះវាជួយធ្វើឱ្យតម្លៃពោតនាំចេញរបស់កម្ពុជាធ្លាក់ចុះទាប បើប្រៀបធៀបនឹងពោតមានគុណភាពប្រហាក់ប្រហែលពីប្រទេសថៃ និងវៀតណាម។ នៅចុងឆ្នាំ១៩៩៥ រដ្ឋាភិបាលបានសម្រេចកំណត់ចំនួនអង្គភាពនាំចេញពោតបន្ថែមទៀត ដោយផ្តល់អាជ្ញាប័ណ្ណនាំចេញទៅកាន់តែក្រុមហ៊ុនធំៗចំនួន ៥ប៉ុណ្ណោះ (សហគ្រាសគ្រប់គ្រងដោយរដ្ឋាភិបាល)។

នៅប៉ុន្មានឆ្នាំថ្មីៗនេះ តម្លៃ និងតម្រូវការនាំចេញពោត បានប្រឈមនឹងការធ្លាក់ចុះ។ តម្លៃនៅឆ្នាំ២០១៤ គឺ ៤០ភាគរយ ទាបជាងតម្លៃកាលពីឆ្នាំ២០១៣។ ខេត្តបាត់ដំបង នាំមុខគេលើផលិតកម្មពោតនៅប្រទេសកម្ពុជា ជាមួយនឹងផ្ទៃដីដាំដុះប្រមាណជាជាង ២៧,០០០ ហិកតា។ ជាមួយមធ្យមកសិករផលិតពោតបាន ៤តោន ក្នុងដីមួយហិកតា។ កង្វះខាតសម្ភារៈបរិក្ខាររក្សាទុកគ្រាប់ពូជគឺជាបញ្ហាប្រឈមសំខាន់មួយ។

ក្រសួងពាណិជ្ជកម្មត្រួតពិនិត្យរាល់សកម្មភាពនាំចូល នាំចេញ និងកំណត់តម្លៃនាំចេញពោតអប្បបរមាដែលត្រូវបានកែសម្រួល ដោយផ្អែកលើការប្រែប្រួលតម្លៃពិភពលោក។ កូតានាំចេញដែលមានចំនួន ៧០ភាគរយ នៃគោលដៅនាំចេញត្រូវបានចែកចាយទៅឱ្យក្រុមហ៊ុននាំចេញដែលមានអាជ្ញាប័ណ្ណនៅដើមឆ្នាំនីមួយៗ។

**តារាងទី ៣.១១ ៖ ការប្រើប្រាស់ពោតក្នុងមនុស្សម្នាក់ តម្លៃពោតសម្រាប់អ្នកប្រើប្រាស់ តម្លៃស្រូវសម្រាប់អ្នកប្រើប្រាស់ និងប្រាក់ចំណូលប្រចាំឆ្នាំក្នុងមនុស្សម្នាក់ ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ ២០១៩**

| ឆ្នាំ | ការប្រើប្រាស់ពោតក្នុងមនុស្សម្នាក់ (គីឡូក្រាម/ម្នាក់) | តម្លៃពោតសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | តម្លៃស្រូវសម្រាប់អ្នកប្រើប្រាស់ (រៀល/គីឡូក្រាម) | ប្រាក់ចំណូលប្រចាំឆ្នាំក្នុងមនុស្សម្នាក់ (ដុល្លារ) |
|---|---|---|---|---|
| ១៩៩៣ | ៥១.៣ | ២០០ | ៨១០ | ៧១០ |
| ១៩៩៤ | ៥០.០ | ២១០ | ៨២០ | ៧៤២ |
| ១៩៩៥ | ៥៩.៦ | ២១០ | ៨៤០ | ៧៨០ |
| ១៩៩៦ | ៥៤.៧ | ២៣០ | ៨៥០ | ៨១០ |
| ១៩៩៧ | ៥០.៦ | ២៣៥ | ៨៧០ | ៨៤០ |
| ១៩៩៨ | ៥៥.៤ | ២២០ | ៩០០ | ៨៦០ |
| ១៩៩៩ | ៥៥.២ | ២៣០ | ៩៦០ | ៩៥០ |
| ២០០០ | ៥៤.៣ | ២២០ | ១,០០០ | ១,០៥០ |
| ២០០១ | ៤១.២ | ២២៥ | ១,០៣០ | ១,១២០ |
| ២០០២ | ៣៩.២ | ២៣៥ | ១,០៦១ | ១,១៨០ |
| ២០០៣ | ៣៧.៣ | ២៥០ | ១,០៩៣ | ១,២៩០ |
| ២០០៤ | ៣៥.៤ | ២៧០ | ១,១២៦ | ១,៤៤០ |
| ២០០៥ | ៣៣.៥ | ២៦០ | ១,២១៤ | ១,៦៤០ |
| ២០០៦ | ៣១.៦ | ២៨០ | ១,១២១ | ១,៨៥០ |
| ២០០៧ | ២៩.៧ | ៣០០ | ១,៤៥១ | ២,០៨០ |
| ២០០៨ | ២៧.៩ | ៣០៥ | ១,១២៣ | ២,២២០ |
| ២០០៩ | ២៦.១ | ៣១០ | ៩០៧ | ២,២០០ |
| ២០១០ | ២៤.៤ | ៣២០ | ១,០០៨ | ២,៣២០ |
| ២០១១ | ២៣.០ | ៣០០ | ១,០២៧ | ២,៤៩០ |
| ២០១២ | ២១.៦ | ៣៤០ | ១,០៤៧ | ២,៧២០ |
| ២០១៣ | ២០.៣ | ៣៥០ | ១,០៦៧ | ២,៩២០ |
| ២០១៤ | ១៩.០ | ៣៧០ | ១,៧១៨ | ៣,០២០ |
| ២០១៥ | ១៧.៧ | ៤០០ | ១,៤៨៨ | ៣,១៨០ |
| ២០១៦ | ១៦.៤ | ៤១០ | ១,៥២៩ | ៣,៤៥០ |
| ២០១៧ | ១៥.១ | ៤២០ | ១,៥៩៥ | ៣,៦៨០ |
| ២០១៨ | ១៣.៨ | ៥០០ | ១,៦៥៩ | ៣,៩៧០ |
| ២០១៩ | ១២.៦ | ៦៥០ | ១,៧៤៥ | ៤,៣២០ |

**ប្រភព៖** - ធនាគារអភិវឌ្ឍន៍អាស៊ី *របាយការណ៍ប្រចាំឆ្នាំ២០០០*

- ទីស្តីការគណៈរដ្ឋមន្ត្រី *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០០២*
- នាយកដ្ឋានផែនការស្ថិតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ *ព្រឹត្តិប័ត្រកសិកម្មស្តង់ដារប្រទេសកម្ពុជាឆ្នាំ២០០១*
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *របាយការណ៍កសិកម្មប្រទេសកម្ពុជាឆ្នាំ២០២០*
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *របាយការណ៍របស់ប្រទេសកម្ពុជាការស្ទង់មតិសេដ្ឋកិច្ចសង្គមឆ្នាំ២០១៧*

- ធនាគារពិភពលោក *របាយការណ៍ប្រចាំឆ្នាំ២០២០*

**ក្រាភិចទី ៣.១១ ៖ ការប្រើប្រាស់ពោតក្នុងមនុស្សម្នាក់ក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៩**




ទីផ្សារពោត គឺជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា ទោះបីការសិក្សាយ៉ាងទូលំទូលាយអំពីប្រព័ន្ធទីផ្សារពោតកំពុងខ្វះខាត ហើយចំពោះបរិមាណពាណិជ្ជកម្មភាគច្រើនមិនត្រូវបានកំណត់បរិមាណពោតដែលសល់ពីការនាំចេញយ៉ាងច្រើនសន្ធឹកសន្ធាប់ បានដឹកចូលទៅកាន់រោងចក្រកែច្នៃចំណីសត្វក្នុងស្រុក ស្របតាមគោលនយោបាយរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការកែច្នៃផលិតផលកសិកម្ម និងបង្កើនការចិញ្ចឹមសត្វក្នុងស្រុក រួមទាំងការអនុវត្តគោលនយោបាយរបស់កម្ពុជាក្នុងការដំឡើងពន្ធនាំចូលពោតពីខាងក្រៅមកកែច្នៃនៅកម្ពុជាផងដែរ។

ទីផ្សារពោតនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ដោយកម្រិតនៃការបែងចែក និងភាពគ្មានប្រសិទ្ធភាព។ មូលហេតុនៃការបែងចែករួមមានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងទំនាក់ទំនងមិនល្អ ដែលជាកន្លែងកំណត់ការធ្វើចលនទំនិញ និងព័ត៌មាន។ ប្រការនេះផ្តល់នូវការកើនឡើងនូវភាពខ្វះចន្លោះរវាងការផ្គត់ផ្គង់ និងតម្រូវការពោតនៅទូទាំងប្រទេស និងតាមពេលវេលា ការទម្លាក់ទ្រង់ទ្រាយតម្លៃធ្លុះបញ្ចាំងពីភាពមិនល្អឥតខ្ចោះទាំងនេះ។ ការបែងចែកនេះក៏មានន័យថាការវិលត្រឡប់មករកកសិករវិញ គឺមានកម្រិតទាប ជាញឹកញាប់ដោយមានចំណែកប្រាក់ចំណេញភាគច្រើនដែលទទួលបានពីឈ្មួញអ្នកលក់ដុំ និងអ្នកលក់រាយ។

ការផ្គត់ផ្គង់ពោតសរុបស្មើនឹងផលិតផលពោតបូកនឹងស្តុក និងការនាំចូលពោតសុទ្ធ។ នៅក្នុងចំណោមការផ្គត់ផ្គង់ពោតសរុបនេះ អ្នកផ្គត់ផ្គង់ចុងក្រោយនានាបានអនុវត្តន៍តាម។ ផលិតផលទាំងនេះ គឺជាការប្រើប្រាស់ចំណីអាហារក្នុងស្រុកដោយផ្ទាល់ ដំណើរការផលិតម្សៅ

ពោត ការនាំចេញ ស្តុកអង្ករ និងសំណល់ដែលត្រូវបានពន្យល់យ៉ាងច្បាស់នៅគំនូសបំព្រួញទី ៤.១។

**ក្រាភិច ៣.១២ ៖ ប្រព័ន្ធទីផ្សារពោតនៅកម្ពុជា**




**ប្រភព៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ *របាយការណ៍ទីផ្សារកសិកម្មនៅកម្ពុជាឆ្នាំ ២០០១*

កសិករអាចជ្រើសរើសវិធីសាស្ត្រកំណត់តម្លៃល្អបំផុតសម្រាប់ខ្លួនគេក្នុងចំណោមជំហ៊ានផ្សេងៗគ្នា ដូចជាការធ្វើអាងស្តុកទឹកសម្រាប់សហប្រតិបត្តិការ ការដេញថ្លៃ ការធ្វើកិច្ចសន្យាដោយផ្ទាល់ ការការពារហានិភ័យជាដើម។ ប្រហែល ៨០% នៃផលិតផលពោតនៅកម្ពុជាត្រូវបានដាក់លក់តាមរយៈ ឈ្មួញទីផ្សារពោត ដែលត្រូវបានដាក់បញ្ចូលបញ្ឈរក្នុងករណីភាគច្រើន។

ពួកគេនឹងរួមបញ្ចូលទាំងសកម្មភាពទីផ្សារ ពីការផ្តល់ពោតពូជ ម៉ាស៊ីន ជី និងឥណទានផ្សេង ដល់ផលិតផលពោត ដើម្បីសម្ងួតការស្តុកទុក និងការដឹកជញ្ជូនសម្រាប់ការចែកចាយទីផ្សារចុងក្រោយ ហើយអ្នកផលិតពោតត្រូវបានអនុញ្ញាតឱ្យចូលរួមចំណែកប្រាក់ចំណេញ ដែលទទួលបានត្រូវបានអ្នកផលិត។ ទីផ្សារពោតនៅកម្ពុជាមានបីប្រភេទ គឺឯកជន រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។ ទីផ្សារទាំងនេះត្រូវបានចុះកិច្ចសន្យាជាលក្ខណៈប្រភេទពោត និងចំនួនហិចតាដែលត្រូវដាំ ហើយពោតត្រូវបានបញ្ចូលមុន ឬក្រោយពេលកិន ដោយប្រើកម្រិតដូចជាថ្នាក់គុណភាព។ល។ ប្រភេទពោតអាចត្រូវបានសម្គាល់ដោយកិច្ចសន្យាឯកជនរវាងអ្នកផលិត ហើយកម្មសិទ្ធិត្រូវបានផ្ទេរដោយផ្ទាល់បន្ទាប់ពីការប្រមូលផល។ ជាទូទៅការប្រើប្រាស់កិច្ចសន្យាទីផ្សារ និងផលិតផលរបស់កសិករ គឺមានសារៈសំខាន់ណាស់ហើយជាផ្នែកមួយនៃការរីកលូតលាស់នៃកសិកម្មរបស់ប្រទេសកម្ពុជា។ តាមរយៈការកែសម្រួលយន្តការ នៃសេដ្ឋកិច្ចទីផ្សារសេរី ទីផ្សារពោតបានផ្ទេរទៅវិស័យឯកជន។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាមិនបានធ្វើអន្តរាគមន៍គ្រប់គ្រង

ទីផ្សារពោតក្នុងស្រុកទេ។ ក្នុងស្ថានភាពនេះកសិករខ្មែរ អ្នកអន្តរការី ឧស្សាហកម្មកិនពោត អ្នកលក់ដុំ អ្នកលក់រាយ បានបង្កើតទីផ្សារដែលមានបណ្តាញក្នុងស្រុកជាច្រើន។ ដូចនៅក្នុងរូបភាពទី ៤.២ ភ្នាក់ងារទាំងអស់រួមទាំងកសិករបានធ្វើជំនួញ ដើម្បីប្រើប្រាស់ធនធានទាំងអស់។ សញ្ញាព្រួញតំណាងឱ្យការលក់ពោតដោយផ្ទាល់ពីកសិករទៅឧស្សាហកម្មកិនពោត និងការទិញពោតរបស់អ្នកលក់រាយដោយផ្ទាល់ទិញពីឧស្សាហកម្មរោងម៉ាស៊ីន ហើយព្រួញតំណាងឱ្យការលក់ពោត។ នៅក្នុងបរិបទទីផ្សារបណ្តាញចែកចាយ គឺជាបណ្តាក្រុមហ៊ុន ឬបុគ្គលដែលជួយសម្រួលដល់ចលនផលិតផលពោតពីអ្នកផលិតពោតរហូតដល់អ្នកប្រើប្រាស់ចុងក្រោយ។

វាត្រូវបានគេប៉ាន់ប្រមាណថាប្រហែល២៥% នៃទីផ្សារពោតត្រូវបានធ្វើតាមរបៀបនេះ។ ជាពិសេសខេត្តបាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ សៀមរាប កំពង់ធំ កំពង់ឆ្នាំង កណ្តាល តាកែវ ព្រៃវែង និងកំពង់ចាម អ្នកផលិតពេញចិត្តនឹងវិធីសាស្ត្រនេះ។ មួយវិញទៀតអ្នកផលិតពោតអាចធ្វើកិច្ចសន្យាជាមួយសាជីវកម្មឥណទាន ទំនិញដែលធានាបាននូវពោតដោយផ្តល់ប្រាក់កម្ចីមិនសងដល់អ្នកដាំដុះពោត។

ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិសាលភាពនៃទីផ្សារជោគជ័យ។ ឥណទានធនាគារផ្លូវការមិនអាចប្រើបានសម្រាប់អ្នកផលិតខ្នាតតូច និងកម្មករ កសិពាណិជ្ជកម្ម ដែលជាឆ្អឹងខ្នងនៃឧស្សាហកម្មនេះទេ។ លទ្ធភាពទទួលបានឥណទាននៅក្នុងទីផ្សារពោត ត្រូវបានត្រួតត្រាដោយអ្នកខ្ចីប្រាក់ក្រៅផ្លូវការ ដែលជាទូទៅគិតអត្រាប្រាក់កម្ចីជាសាច់ប្រាក់ពី ២០% ទៅ ៣០% ក្នុងមួយខែ និងការប្រាក់ ១០០% ចំពោះប្រាក់កម្ចីពោតក្នុងរយៈពេល ០៦ ខែ ។ ដើម្បីឱ្យប្រាកដការលក់ពោតទៅឱ្យឧស្សាហកម្មកែច្នៃពោតក្នុងស្រុកក និងអន្តរការីលក់ដុំពោត។ ឧស្សាហកម្មកិនពោតធ្វើអាជីវកម្មជាមួយក្រុមហ៊ុនផលិតផ្សេងៗគ្នា និងអតិថិជនផ្សេងៗគ្នាជាច្រើនដោយសារតែពួកគេមិនមែនជាម្ចាស់ ឬគ្រប់គ្រងដោយក្រុមហ៊ុនផលិតណាមួយពួកគេធ្វើឱ្យរោងចក្រពោតជាច្រើនអាចបម្រើអតិថិជននៅទូទាំងពិភពលោកខណៈពេលដែលរក្សាតម្លៃទាប។

ទោះយ៉ាងណាអន្តរការី អ្នកលក់ដុំពោត គឺជាភ្នាក់ងារដែលគ្រប់គ្រងលំហូរផលិតផលពោតពីប្រជាកសិករដល់ឧស្សាហកម្មកិនពោតក្នុងស្រុក និងអ្នកលក់ដុំពោតបរទេស។ ជាការពិតឧស្សាហកម្មកិនពោតក្នុងស្រុក គឺជាភ្នាក់ងារដែលគ្រប់គ្រងលំហូរពោតទៅកាន់អ្នកលក់រាយក្នុងស្រុក ដើម្បីចែកចាយពោតទៅអ្នកប្រើប្រាស់ចុងក្រោយ។ ជាការពិតនៅក្នុងផលិតផលក្នុងតំបន់អ្នកលក់រាយពោតបាន ផ្តល់ពូជពោតល្អៗ និងពោតសម្រាប់កសិករ។ ម៉្យាងវិញទៀតនៅក្នុងការប្រើប្រាស់ក្នុងតំបន់អ្នកលក់ដុំ ជាអ្នកអន្តរការីឯករាជ្យដែលទិញពោតពីឧស្សាហកម្មកិនពោត និងលក់ទៅឱ្យអ្នកលក់រាយ អ្នកលក់ និងអតិថិជនអាជីវកម្ម ពីជំនួញផ្សេងៗទៀត។ ហើយបន្ទាប់មកអ្នកលក់រាយពោតជួយសម្រួលដល់លំហូរនៃអង្គរពីអ្នកលក់ពោតទៅអ្នកប្រើចុងក្រោយ។

**ក្រាភិចទី ៣.១៣ ៖ បណ្តាញនៃការចែកចាយពោតនៅកម្ពុជា**




**ប្រភព៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម ***ការកែលម្អប្រព័ន្ធទីផ្សារ និងការត្រួតពិនិត្យគុណភាពស្រូវក្រោយប្រមូលផលនៅកម្ពុជា*** របាយការណ៍ចុងក្រោយរបស់ JICA ខែកញ្ញា ឆ្នាំ២០០១ ទំព័រទី ៣៩ ។

## ឃ.យុទ្ធសាស្ត្រកែលម្អផលិតកម្មពោតនៅកម្ពុជា

### ឃ.១.យុទ្ធសាស្ត្រជំរុញការនាំចេញ

ផ្អែកលើការវិភាគពេលកន្លងមក ពោតនៅប្រទេសកម្ពុជាមានការលើសពីតម្រូវការខ្ពស់នៅពេលអនាគត។ ដូច្នេះការលើកកម្ពស់ការនាំចេញគួរតែត្រូវបានរៀបចំឡើង ដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីប្រកួតប្រជែងជាមួយបណ្តាប្រទេសនាំពោតចេញដទៃទៀត កម្ពុជាត្រូវកែលម្អពាណិជ្ជកម្មអន្តរជាតិ ដោយអនុលោមតាមស្តង់ដារទីផ្សារពិភពលោក។ ក្រៅពីនេះដើម្បីរក្សាការប្រកួតប្រជែងក្នុងទីផ្សារពោត ប្រទេសកម្ពុជាត្រូវរក្សាថ្លៃដើមផលិតកម្មឱ្យទាបបំផុត និងបរិមាណពោតឱ្យបានល្អតាមដែលអាចធ្វើទៅបាន ហើយយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្សេងទៀត គួរតែត្រូវបានសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតកម្មពោតដែលនឹងត្រូវពន្យល់បន្ថែមនៅខាងក្រោម។

### ឃ.២.ការកែលម្អសមត្ថភាពប្រកួតប្រជែង

ការកើនឡើងនូវកង្វះខាត និងតម្លៃឡើងខ្ពស់នៃធាតុផ្សំផលិតផលពោតដូចជា ជី និងថ្នាំសម្លាប់សត្វល្អិតអាចបណ្តាលឱ្យមានការថយចុះគួរឱ្យកត់សម្គាល់ នៅក្នុងផ្ទៃដីដាំដុះពោត។ មានប្រជាកសិករ ដែលបានបង្ហាញការត្រៀមខ្លួនវិលត្រឡប់មករកពោតតាមបែបប្រពៃណីវិញ ប្រសិនបើការចំណាយខ្ពស់គួរតែធ្វើឱ្យការបណ្តាក់ទុនជាមួយពោតផ្តល់ទិន្នផលមិនអាចទទួលបានផលចំណេញ។ដូច្នេះដើម្បីថែរក្សាការដាំដុះ ដែលមានស្រាប់នាពេលបច្ចុប្បន្ននឹងទាមទារឱ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំង។ យុទ្ធសាស្ត្រក្នុងការជំរុញផលិតកម្មពោត ដើម្បីលើកកម្ពស់ការប្រកួតប្រជែងផលិតកម្មពោតនៅកម្ពុជាគួរតែផ្តោតលើៈ

- គោលបំណងទី១ៈ ការរឹបអូសយកដីបង្កបង្កើនផលថ្មីសម្រាប់កសិកម្ម ដែលពឹងផ្អែកខ្លាំង ជាពិសេសការសាងសង់ឧបករណ៍ និងការត្រួតពិនិត្យទឹក។
- គោលបំណងទី២ៈ ការកែលម្អទិន្នផលគ្រាប់ធញ្ញជាតិ ដែលមានស្រាប់ក្នុងមួយឯកតា ពោលគឺ ពង្រីកអតិបរិមាការប្រើប្រាស់ដីដាំដុះបច្ចុប្បន្ន។
- ខណៈពេលដែលគោលបំណងទី១ ខាងលើត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង នោះគោលបំណងទី២ ហាក់ដូចជាអាចធ្វើទៅបាននៅពេលអនាគត។
- ការកែលម្អទិន្នផលគ្រាប់ធញ្ញជាតិ នៃផ្ទៃដីដាំដុះដែលមានស្រាប់ នឹងត្រូវការទាំងផែនការយុទ្ធសាស្ត្ររយៈពេលវែង និងផែនការយុទ្ធសាស្ត្ររយៈពេលខ្លី។ យុទ្ធសាស្ត្រទាំងពីរនេះត្រូវចាត់ទុកជាការបំពេញបន្ថែមមួយទៅយុទ្ធសាស្ត្រមួយទៀត។ ផ្នែកនេះភាគច្រើនបានមកពីផែនការអភិវឌ្ឍន៍ដែលបានស្នើដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ឃ.៣.យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលខ្លី

#### a ការមិនពង្រីកផ្ទៃដីដែលមានទិន្នផលខ្ពស់

វាអាចប្រាកដបានថាការកែលម្អទិន្នផលគ្រាប់ធញ្ញជាតិ អាចទទួលបានដោយគ្មានការប៉ះពាល់ដល់បរិស្ថានសង្គម បរិយាកាស ប្រសិនបើឧបសគ្គខាងក្រោមអាចយកមកកំណត់បាន៖

- កម្រិតអប់រំរបស់កសិករលើបច្ចេកវិទ្យាដំណាំទំនើប គួរតែត្រូវបានកែលម្អតាមមធ្យោបាយទាំងអស់នៅក្នុងយុទ្ធសាស្ត្របច្ចេកវិទ្យា។ គ្រាន់តែផ្តល់ឱ្យកសិករនូវគ្រាប់ពូជថ្មី និងទឹកស្រោចស្រពគឺដូចជាផ្តល់ឱ្យគាត់នូវក្រណាត់មួយដុំដោយប្រើកន្សែងខ្លះ និងម្ជុលដោយមិនបង្ហាញគាត់អំពីរបៀបដេរសំលៀកបំពាក់ទំនើប។ ការអប់រំរបស់កសិករ ត្រូវតែផ្តល់ការយកចិត្តទុកដាក់ខ្ពស់ហើយគួរតែយកចិត្តទុកដាក់លើសកម្មភាពអភិវឌ្ឍន៍ដទៃទៀត។
- ការផ្សព្វផ្សាយផ្នែកកសិកម្មត្រូវតែដើរតួនាទីកាន់តែធំ ព្រោះវាអាចទៅដល់កសិករគ្រប់រូបឱ្យបានយល់ដឹងអំពីវិធីសាស្ត្រផ្នែកកសិកម្ម។
- យុទ្ធសាស្ត្រការពារដំណាំចម្រុះគួរតែត្រូវបានដាក់ឱ្យដំណើរការភ្លាមៗ។ គ្រាប់ពូជថ្មីៗនិងពោតទិន្នផលខ្ពស់ដែលធន់នឹងជំងឺ គួរតែត្រូវបានចែកចាយយ៉ាងទូលំទូលាយ ដល់កសិករឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ វិធានការណ៍បង្ការនៅក្នុងការត្រួតពិនិត្យសត្វល្អិតត្រូវតែលើកទឹកចិត្តឱ្យរក្សាទុកថ្នាំសម្លាប់សត្វល្អិតដ៏មានតម្លៃបន្ថែមទៀត។
- កិច្ចខិតខំប្រឹងប្រែងការគ្រប់គ្រងអេកូឡូស៊ីនេះ ចំពោះកសិករនឹងមានប្រសិទ្ធភាពបំផុត និងមានតម្លៃថ្លៃបំផុតក្នុងការបង្កើនផលិតកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅតាមជនបទ សេវាវេជ្ជសាស្ត្រ សេវាផ្គត់ផ្គង់ទឹក និងប្រព័ន្ធលូជាដើម។
- ឥណទានកសិកម្ម គួរតែត្រូវបានផ្តល់ជូនដល់កសិករកាន់តែច្រើន។ ភាពងាយស្រួលនៃឥណទានត្រូវមានដល់កសិករតូចៗជាច្រើន តាមដែលអាចធ្វើទៅបាន ដើម្បីសម្រេចបាននូវទំហំសេដ្ឋកិច្ចតាមរយៈការបន្ធូរបន្ថយដែនកំណត់លើកសិដ្ឋាន និងផ្តល់ឥណទានរយៈពេលវែង និងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍។ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារកសិករ និងធនាគារជនបទគួរចែករំលែកបន្ទុកដែលកើតចេញពីការពង្រីកកសិដ្ឋាន តាមរយៈការចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្ម និងគោលនយោបាយ តម្លៃគួរតែត្រូវបានរក្សាឱ្យមានភាពទាក់ទាញតាមដែលអាចធ្វើទៅបាន។

#### b ការពង្រីកផ្ទៃដីដែលផ្តល់ទិន្នផលខ្ពស់

ចំពោះករណីនេះជំហានទាំងអស់ ដែលបានពិពណ៌នាខាងលើចាំបាច់ត្រូវអនុវត្តន៍។ បន្ថែមលើនេះប្រព័ន្ធធារាសាស្ត្រខ្នាតតូចគួរតែត្រូវបានបង្កើតឡើងនៅក្នុងតំបន់ដែលនៅជិតប្រភពទឹក នៅក្នុងផ្ទៃដីកសិកម្ម ដីទំនាប តំបន់ខ្ពង់រាប និងតំបន់ដាំដុះពោតទ្វេរដង ដើម្បីអនុញ្ញាតឱ្យមានការដាំដុះទ្វេដងជាមួយស្រូវដែលផ្តល់ទិន្នផលខ្ពស់។ យុទ្ធសាស្ត្រនេះត្រូវបានសម្រេចដោយរាជរដ្ឋាភិបាលកម្ពុជា។ សូមបញ្ជាក់ជាថ្មីម្តងទៀតថា នៅពេលដែលចំនួននៃគ្រោង

ផែនការទាំងនេះមានការកើនឡើង ប្រព័ន្ធត្រួតពិនិត្យត្រូវតែធ្វើការវាយតម្លៃគុណប្រយោជន៍ប្រៀបធៀបទៅនឹងផលប៉ះពាល់សក្តានុពល ដែលបានធ្វើចំពោះតំបន់ដែលរងផលប៉ះពាល់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអត្រាលទ្ធភាពគ្រប់គ្រាន់ក្នុងការផលិតផលកសិកម្មសំខាន់ៗ សម្រាប់សន្តិសុខស្បៀងអាហារ។

### ឃ.៤.យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង

យុទ្ធសាស្ត្ររយៈពេលវែង នៃការបង្កើនផលិតផលពោតត្រូវបានគេរំពឹងថានឹងមានយុទ្ធសាស្ត្រស្រាវជ្រាវពោតដែលមានមូលដ្ឋានគ្រឹះរហ័ស បន្សាំ និងយន្តការបន្តិចម្តងៗនៃប្រតិបត្តិការកសិកម្មរួមទាំងការកែច្នៃក្រោយប្រមូលផល។

#### *a.*ពន្លឿនយុទ្ធសាស្ត្រស្រាវជ្រាវពោត

យុទ្ធសាស្ត្រស្រាវជ្រាវពោត នៅក្នុងបរិស្ថានតំណពូជក្នុងតំបន់ដីសណ្តត្រូវតែមានគោលបំណងដើម្បីបង្កើនទិន្នផលគ្រាប់ធញ្ញជាតិក្នុងលក្ខខណ្ឌដី និងទឹកផ្សេងៗគ្នា។ គាំទ្រក្នុងការបង្រួបបង្រួមក្នុងគោលបំណងដោះស្រាយនូវទិដ្ឋភាពដូចខាងក្រោមនេះ៖

**ការស្រាវជ្រាវបន្សាំ**

- ការវាយតម្លៃអំពីបណ្តាញពូជពោតដែលផ្តល់ទិន្នផលខ្ពស់ពីបណ្តាប្រទេសដទៃទៀត ក្រោមលក្ខខណ្ឌធម្មតាក្នុងស្រុកជាមួយនឹងការប្រើប្រាស់ជីល្មម និងដោយមិនប្រើថ្នាំសម្លាប់សត្វ ល្អិត។ ការវាយតម្លៃនេះត្រូវតែអនុវត្តន៍ក្រោមការគ្រប់គ្រងទៅលើទឹកភ្លៀង និងស្ថានភាពទឹកផងដែរ។ ការជ្រើសរើសយ៉ាងហោចណាស់គួរមានលក្ខណៈដូចខាងក្រោម៖
    - ភាពធន់ចំពោះស្ថានភាពទឹកមិនគ្រប់គ្រាន់
    - ភាពធន់នឹងសត្វល្អិតចង្រៃ
    - ភាពធន់នឹងជំងឺចង្រៃ
    - ការប្រើប្រាស់ចំពោះកម្រិតជី N-P ទាប និង
    - សមត្ថភាពទិន្នផលខ្ពស់
- ការវាយតម្លៃថ្នាំសម្លាប់សត្វល្អិតដែលបានប្រើប្រាស់ និងការអនុវត្តលើពោត។
- ការវាយតម្លៃថ្នាំបាញ់ស្មៅដែលបានជោគជ័យសម្រាប់ដំណាំពោត។

**មូលដ្ឋាននៃការស្រាវជ្រាវ**

- សិក្សាអំពីលក្ខណៈរូបវិទ្យានិងគីមីនៃប្រភេទដីផ្សេងៗគ្នានៅតំបន់ដីសណ្ត ដើម្បីដោះស្រាយឱ្យដីមានជីវជាតិក្នុងការប្រើប្រាស់ សមត្ថភាពសក្តានុពលឱ្យបានល្អបំផុតសម្រាប់ផលិតកម្មពោតក្រោមរបបទឹកផ្សេងៗ។

- ការវាយតម្លៃស្ថានភាពដីនីមួយៗនៅតាមបណ្តាខេត្ត ដីសណ្តដើម្បីផ្តល់ជាអនុសាសន៍ត្រឹម
  ត្រូវបន្ថែមទៀតដល់ប្រជាកសិករក្នុងមូលដ្ឋាន។
- ការបង្កាត់ពូជឱ្យបានទិន្នផលខ្ពស់ និងដីដែលមានជាតិអាស៊ីត ខណៈពេលដែលឧបករណ៍ត្រួតពិនិត្យទឹកនៅតែមិនមាន។
- ការបង្កាត់ពូជពោតនៅពេលគ្រោះរាំងស្ងួត ទិន្នផលពោតខ្ពស់ដែលត្រូវដាំ ដោយមិនមានប្រព័ន្ធធារាសាស្ត្រនៅក្នុងតំបន់ ពោតអណ្តែតទឹកអប្បបរមាបន្ទាប់ពីបានប្រមូលផលរួច។
- សិក្សាអំពីបរិស្ថានវិទ្យាពោត សក្តានុពលប្រជាជន និងបង្កើតបណ្តាញព្យាករណ៍សត្វល្អិតចង្រៃដែលមានប្រសិទ្ធភាពនៅទូទាំងតំបន់ដីសណ្ត។

### ៦.យន្តការផលិតកម្មពោត

ប្រតិបត្តិការធ្វើកសិកម្មតាមមេកានិចពីការស្ទូងរហូតដល់ការប្រមូលផល សម្ងួត គួរតែត្រូវបានលើកទឹកចិត្ត។ ការយកចិត្តទុកដាក់បន្ថែមទៀតចំពោះឧបករណ៍រៀបចំដី ដើម្បីធានាឱ្យមានការភ្ជួររាស់ដីកាន់តែប្រសើរ។ ការអនុវត្តការងារនីមួយៗ ដីគួរតែត្រូវបានរៀបចំយ៉ាងហ្មត់ចត់ និងធ្វើការរៀបចំឡើងវិញប្រសិនបើចាំបាច់ដើម្បីឱ្យសមស្របទៅនឹងស្ថានភាពដី ជាទូទៅនៅក្នុងតំបន់ដីសណ្ត តំបន់ទំនាប និងតំបន់ខ្ពង់រាប។

ប្រព័ន្ធបញ្ចូលគ្នានៃការសម្ងួតពោត ការស្តុកទុកពោត គួរតែត្រូវបានជំរឿងដើម្បីសន្សំសំចៃការខាតបង់ដែលអាចទទួលយកបាន ដោយការខូចពោត។ វិធីល្អបំផុតដើម្បីទទួលបានបរិមាណច្រើន និងស្រូវល្អប្រសើរដល់អតិថិជន គឺការសម្ងួតពោតឱ្យបានល្អដើម្បីការពារកុំឱ្យខូច ប្រសិនបើពោតមិនល្អនោះនឹងត្រូវបដិសេធចោលក្នុងការទិញ។

ម៉្យាងវិញទៀតរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តន៍កញ្ចប់គោលនយោបាយ រៀបចំរចនាសម្ព័ន្ធជនបទនៅតាមជនបទរយៈពេលមធ្យម និងយូរអង្វែងជាច្រើន ដើម្បីដោះស្រាយបញ្ហាកសិកម្មដែលបានកើតឡើងក្នុងអំឡុងពេលប្រកួតប្រជែងតាមរយៈការធ្វើទំនើបកម្ម និងមេកានិចត្រូវបានអនុវត្តន៍ចាប់តាំងពីឆ្នាំ១៩៩២ មក។ ផែនការនេះសង្កត់ធ្ងន់ទៅលើការធ្វើឱ្យប្រសើរឡើងនូវជនបទ សហគមន៍ ការអភិវឌ្ឍកសិកម្មដែលផ្តោតលើទីផ្សារ និងការធ្វើពិពិធកម្មដំណាំដើម្បីកាត់បន្ថយហានិភ័យ។

### ឃ.៥.ការលើកកម្ពស់ការកែច្នៃពោត

អតិផរណាពោតអាចត្រូវបាននាំចេញទៅបរទេសប្រសិនបើពាណិជ្ជកម្មល្អ។ ទោះយ៉ាងណាក៏ដោយប្រសិនបើការលក់មិនអាចស្វែងរកនៅទីផ្សារពោតអន្តរជាតិ ពោតគួរតែត្រូវបានប្រើប្រាស់ក្នុងការកែច្នៃក្នុងស្រុក។ ផលិតផលពោតកែច្នៃអាចពង្រីកការប្រើប្រាស់ក្នុងស្រុក ក៏ដូចជាតម្រូវការនាំចេញពោតទៅបរទេស តាមវិធីណាក៏ដោយវាអាចធ្វើឱ្យផលិតកម្មពោតនៅកម្ពុជា

មានភាពប្រសើរឡើង។ ដូច្នេះយុទ្ធសាស្ត្រផ្សព្វ ផ្សាយនៃការកែច្នៃពោត គឺមានសារៈសំខាន់ណាស់។ ផលិតផលពោតក្នុងស្រុកមួយចំនួន អាចត្រូវបានកែច្នៃដើម្បីធ្វើជាផលិតផលមុខទំនិញដូចជា ម្សៅ ចំណីសត្វ និងផលិតផលចម្រុះផ្សេងទៀត។

**ង ស្ថានភាពផលិតកម្មពោត**

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគជារួមទៅលើអនុវិស័យកសិកម្មដំណាំពោត ដែលឆ្លុះបញ្ចាំងដោយកំណើននៃការនាំចេញពោត បានបង្ហាញថាស្ថានភាពនៃវិស័យកសិកម្មកម្ពុជាបច្ចុប្បន្នកំពុងតែមានការកើនឡើង និងការនាំចេញកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ស្ថិតនៅក្នុងសាកលភាវូប-នីយកម្មសតវត្សទី២១ កម្ពុជាត្រូវតែបង្កើននូវផលិតភាពកសិកម្មរបស់ខ្លួន ក្នុងការប្រកួតប្រជែងជាមួយនឹងផលិតផលកសិកម្មរបស់ប្រទេសផ្សេងទៀត ដើម្បីចាប់យកចំណែកទីផ្សារពិភពលោកជាអតិបរមា។

ផ្ទៃដីប្រមូលផលពោតបានកើនឡើងពី ៦៨,១០០ហិកតា ក្នុងឆ្នាំ១៩៩៣ ដល់ ៩៩,៥០០ហិកតា ក្នុងឆ្នាំ២០១៩។ ទន្ទឹមនឹងនេះដែលទិន្នផលពោតជាមធ្យមបានកើនឡើងពី ១.៣១តោន/

ហិកតា ក្នុងឆ្នាំ១៩៩៣ ដល់ ៣.៧១តោន/ហិកតា ក្នុងឆ្នាំ២០១៩។ ប្រសិនបើផលិតកម្មពោតក្នុងស្រុកនៅតែបន្តកើនឡើងក្នុងអត្រាបច្ចុប្បន្ន នោះប្រទេសកម្ពុជាអាចប្រឈមនឹងបញ្ហាកើនឡើង ពីអតិរេកផលពោតហើយត្រូវនាំពោតចេញទៅបរទេសបន្ថែមទៀតឬប្រើប្រាស់ពោតក្នុងការកែច្នៃជាផលិតផល។យោងតាមលទ្ធផលនៃការសិក្សានេះ ភាពយឺតនៃផលិតកម្មពោតគឺទាក់ទងនឹងតម្លៃពោត ដោយមិនមានគុណភាពក្នុងរយៈពេលខ្លីទេ ប៉ុន្តែវានឹងក្លាយទៅជាភាពយឺតក្នុងរយៈពេលវែង។ ភាពរឹងមាំនៃតម្រូវការពោតទាក់ទងនឹងតម្លៃ គឺមានន័យថាពោតបានក្លាយជាភាពចាំបាច់ នៅក្នុងប្រទេសកម្ពុជា។ ដូច្នេះនៅពេលចំណូលរបស់អ្នកប្រើប្រាស់កើនឡើង ការប្រើប្រាស់ពោតរបស់មនុស្សម្នាក់នឹងថយចុះបន្តិចម្តងៗនាពេលអនាគត។

យោងតាមលទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញឱ្យឃើញថា ផលិតផលពោតកម្ពុជាបានកើនឡើងចាប់ពី ៣៨៣,៤០០តោន ក្នុងឆ្នាំ១៩៩៣ ដល់២,០៥៦,២២៩ តោនក្នុងឆ្នាំ២០១៩។ ជាមួយនឹងអត្រាកិនជាមធ្យម ៦២% ការផ្គត់ផ្គង់ពោតបានកើនឡើងពី ៩៧៨,២២២.០០ តោន ដល់ ៥,៤២១,៦៧០.៣៦តោន ក្នុងរយៈពេលដូចគ្នា។ ក្នុងពេលតែមួយការចរាចរពោតបានកើនឡើងពី ៣៨៣,៤០០តោន ដល់ ២,០៥៦,២២៩តោន។ ដូច្នេះទាំងតម្រូវការ និងការផ្គត់ផ្គង់ពោតគឺមានការកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅពេលសេដ្ឋកិច្ចរីកចម្រើន ការប្រើប្រាស់ពោតប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់បានថយចុះចាប់ពី ៥១.៣ គីឡូក្រាមក្នុងឆ្នាំ១៩៩៣ ដល់ ១២.៦គីឡូក្រាមក្នុងឆ្នាំ២០១៩។

យោងតាមតម្រូវការ និងការផ្គត់ផ្គង់គិតត្រឹមឆ្នាំ២០៣០ ពោតប្រទេសកម្ពុជាអាចនឹងផលិតបាននូវការផ្គត់ផ្គង់ពោតត្រូវបានធ្វើឡើងសម្រាប់ឆ្នាំ២០២០ ដល់ឆ្នាំ២០៣០ អថេរដែលបានកំណត់ទុកជាមុនត្រូវបានគេសន្មតថាធ្វើតាមនិន្នាការអតីតកាលរបស់ពោតនាពេលអនាគត ហើយលទ្ធផលនៃការព្យាករណ៍ត្រូវបានធ្វើឡើង ដែលការផ្គត់ផ្គង់ពោតសរុបក្នុងឆ្នាំ២០៣០។

ដូច្នេះត្រឹមឆ្នាំ២០៣០ គេរំពឹងថាកម្ពុជាអាចមានលទ្ធភាពផ្គត់ផ្គង់ពោតបានយ៉ាងហោចណាស់ ១៤.៨១ លានតោន ហើយអតិរេកផលពោតនេះត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងប៉ុន្មានឆ្នាំខាងមុខទៀតដល់ឆ្នាំ២០៣០។ ផលដែលប៉ះពាល់ពោតមានសារៈសំខាន់ណាស់នៅក្នុងនោះទោះបីមិនមានការកាត់បន្ថយថ្លៃដើមផលិតកម្មយ៉ាងច្រើនក៏ដោយ ក៏បរិមាណពោតលើសនៅតែអាចបន្តកើនឡើង ដែលនឹងនាំឱ្យមានការនាំចេញពោតដែលលើសទាំងនេះទៅបរទេស ឬធ្វើឱ្យមានការកែច្នៃពោតក្នុងស្រុកសម្រាប់ផលិតផលដូចជា ម្សៅ ចំណីសត្វ និងផលិតផលចម្រុះផ្សេងទៀត។

ផ្អែកលើការវិភាគផលិតកម្មពោតនៅកម្ពុជា ឃើញថាពោតមានការលើសពីតម្រូវការខ្ពស់នៅពេលអនាគត។ ដូច្នេះការលើកកម្ពស់ការនាំចេញគួរតែត្រូវបានរៀបចំឡើងដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីប្រកួតប្រជែងជាមួយបណ្តាប្រទេសនាំពោតចេញដទៃទៀត។ កម្ពុជាត្រូវកែលម្អពាណិជ្ជកម្មអន្តរជាតិ ដោយអនុលោមតាមស្តង់ដារទីផ្សារពិភពលោក។ ក្រៅពីនេះដើម្បីរក្សាការប្រកួតប្រជែងក្នុងទីផ្សារពោតប្រទេសកម្ពុជាត្រូវរក្សាថ្លៃដើមផលិតកម្មឱ្យទាបបំផុត និងបរិមាណពោតឱ្យបានល្អតាមដែលអាចធ្វើទៅបាន ហើយត្រូវយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលខ្លី និងរយៈពេលវែង។ ផ្តល់ការគាំទ្រលើការបំពេញខ្សែច្រវាក់តម្លៃផលិតកម្ម ធ្វើយ៉ាងនេះដើម្បីបង្កើនតម្លៃបន្ថែមដល់កសិផល ពង្រីក និងពង្រឹងការកែច្នៃ វេចខ្ចប់ ឃ្លាំងស្តុក ឡសម្ងួត។ល។ ជាងនេះផ្អែកដឹកជញ្ជូនប្រកបដោយជំនាញ បច្ចេកទេស និងការធានាដល់គុណភាព សុវត្ថិភាពទាំងអនាម័យ និងភូតគាមអនាម័យ ដើម្បីជាការបន្ថយការនាំចេញវត្ថុធាតុដើម។ ការលើកកម្ពស់ការកែច្នៃពោតដើម្បីធ្វើជាផលិតផលមុខទំនិញដូចជា ម្សៅ ចំណីសត្វ និងផលិតផលចម្រុះផ្សេងទៀត។

ម្យ៉ាងវិញទៀតដើម្បីរួមចំណែកបំពេញនូវការផ្គត់ផ្គង់ពោតសម្រាប់ប្រើប្រាស់ទាំងក្នុង និងក្រៅស្រុក ការស្វែងរកទីផ្សារលក់ផលិតផលពោត និងការរៀបចំយុទ្ធសាស្ត្រជំរុញវិស័យពោតនៅកម្ពុជាចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៩ នេះ ការសិក្សាស្រាវជ្រាវនៃគោលបំណរបស់ប្រធានបទខាងលើ ក៏ស្របនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលផងដែរ គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ឱ្យមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពបង្កើនប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាតាមអភិក្រម និងវិសាលភាពថ្មី ដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបវិបុលកម្ម។ ពោល គឺពឹងផ្អែកជាសំខាន់លើធនធានដែលមានស្រាប់ (ធនធានដី និងធនធានធម្មជាតិផ្សេងៗទៀត) ឈានទៅរកដំណាក់កាលថ្មី ដែលផ្តោតលើប្រពលវប្បកម្ម ពោល គឺពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី កសិកម្មវៃឆ្លាត ការស្រាវជ្រាវ និងការអភិវឌ្ឍយរូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងទីផ្សាររួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

## ច.ការបង្កើនផលិតភាពកសិកម្ម

### ច.១.ប្រជាកសិករ

កសិករគប្បីចូលរួមរាល់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសកសិកម្មផ្សេងៗ ព្រមទាំងកែលម្អរចនាសម្ព័ន្ធចំការពោតរបស់ខ្លួនឱ្យមានសភាពល្អប្រសើរ ដើម្បីរក្សាទឹកក្នុងចំការពោតបានរយៈពេលយូរ។

ពង្រីកបន្ថែមនូវផ្ទៃដីដាំដំណាំពោតឱ្យកាន់តែធំជាងមុន ព្រមទាំងធ្វើការកែច្នៃពោតទៅជាម្សៅពោតក្នុងករណី ដែលតម្លៃទីផ្សារពោតមានកម្រិតទាបនោះ។

ជំរុញការប្រើប្រាស់ដី ឱ្យកាន់តែមានប្រសិទ្ធភាព ដោយចៀសវាងការទុកផ្ទៃដីចោលឱ្យនៅទំនេរ តាមរយៈអ្នកមានដីកសិកម្មច្រើន និងគប្បីជួល ឬលក់មួយចំណែកទៅឱ្យកសិករដើម្បីបង្កបង្កើនទិន្នផលថែមទៀត។

### ច.២ សហគមន៍កសិករ

ជំរុញឱ្យក្រុមកសិករ កសាងឃ្លាំងស្តុកផលិតផលកសិកម្មរួមគ្នាសម្រាប់រក្សាទុក នៅពេលដែលកសិផលដោរជន់លើទីផ្សារ ក្នុងគោលបំណងទប់ស្កាត់ការធ្លាក់ចុះ នៃតម្លៃកសិផល និងលើកទឹកចិត្តឱ្យកសិករ ក្នុងសហគមន៍ដាំដំណាំពោតខុសប្រភេទគ្នា ដើម្បីបញ្ចៀសការធ្លាក់ចុះនៃតម្លៃពេលប្រមូលផល។

លើកទឹកចិត្តឱ្យសហគមន៍កសិករ ត្រូវគប្បីសហការណ៍ជាមួយនឹងបណ្តាសហគមន៍កសិករផ្សេងទៀត ដើម្បីចែករំលែកពីបទពិសោធន៍កសិកម្ម បច្ចេកទេស និងព័ត៌មានទីផ្សារផ្សេងៗទៀត។

### ច.៣.ស្ថាប័នពាក់ព័ន្ធ

ជំរុញដល់ការធ្វើទំនើបកម្មកសិកម្ម តាមរយៈការអភិវឌ្ឍជារបៀបកសិដ្ឋានគំរូ ឱ្យបានច្រើននៅទូទាំងប្រទេសក្នុងការផលិតនូវផលិតផលកសិកម្មសុវត្ថិភាព ទាំងដំណាំពោត សារប្បកម្ម និងដំណាំឧស្សាហកម្ម ដោយប្រើប្រាស់បច្ចេកទេសការអនុវត្តកសិកម្មឱ្យបានល្អ។

ស្ថាប័ន និងមន្ទីរកសិកម្មខេត្ត គួរជានាព័ត៌មានទីផ្សារពោតនៅពេលជិតប្រមូលផលជូនដល់កសិករដើម្បីរក្សាលំនឹងថ្លៃផលិតផលឱ្យមានស្ថេរភាព

ធនាគារអភិវឌ្ឍន៍ជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន គប្បីបន្ថយអត្រាការប្រាក់ឱ្យទាបដើម្បីផ្តល់ឥណទានឱ្យកសិករក្នុងការពង្រីកផលិតកម្មកសិកម្ម។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា គួរតែអភិវឌ្ឍន៍ និងគាំទ្រការងារស្រាវជ្រាវស្តីពីគ្រាប់ពូជដែលមានផលិតភាព គុណភាព ធន់នឹងអាកាសធាតុ រួចផ្សព្វផ្សាយទៅឱ្យកសិករប្រើប្រាស់បន្ថែមទៀតដើម្បីបង្កើនទិន្នផលកសិកម្ម ក៏ដូចជាបង្កើនប្រាក់ចំណូល។

## ច.៤.រាជរដ្ឋាភិបាល

- លើកទឹកចិត្តឱ្យកសិករប្រើប្រាស់បន្ថែមនូវគ្រឿងយន្តកសិកម្មតាមរយៈការកាត់បន្ថយ ឬមិន យកពន្ធលើគ្រឿងយន្តទាំងនោះ ដើម្បីឱ្យពួកគាត់អាចមានលទ្ធភាពទិញ មកប្រើប្រាស់ក្នុងដំណើរការកសិកម្ម។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ពន្ធត្រូវបង្កើនការយកចិត្តទុកដាក់ឱ្យកាន់តែប្រសើរដើម្បីជំរុញឱ្យបាននូវទីផ្សារ និងតម្លៃស្រូវដែលអាចទទួលយកបានចំពោះផលិតផលស្រូវដែលកសិករប្រមូលបាន ព្រមទាំងការពង្រីកទីផ្សារសម្រាប់នាំចេញពោត។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំរុញឱ្យការបណ្តុះបណ្តាលមន្ត្រីកសិកម្មនៅតាមមូលដ្ឋានឱ្យមានជំនាញកាន់តែច្បាស់ក្នុងការពង្រឹងសមត្ថភាព និងចែកចាយទៅកាន់សហ-គមន៍ប្រជាកសិករឱ្យបានទូលំទូលាយ និងបង្កើតបរិយាកាសកសិ-ពាណិជ្ជកម្ម តាមរយៈកសិកម្មតាមកិច្ចសន្យាដោយតម្លាភាពរវាងអ្នកផលិត និងអ្នកប្រមូលទិញ។

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវមានការអនុវត្តផែនការយុទ្ធសាស្ត្រក្នុងវិស័យកសិកម្មដោយត្រូវតែខិតខំយកចិត្តទុកធ្វើយ៉ាងណាអនុវត្តឱ្យបានសកម្ម និងខ្លាំងក្លាដូចបានដាក់ចេញ និងឱ្យបានលទ្ធផលល្អប្រសើរ។

- បន្តការងារស្តារ និងកសាងបន្ថែមប្រព័ន្ធធារាសាស្ត្រដូចជា ប្រឡាយទឹកតូច-ធំ ទំនប់ទឹក សំណង់ស្នាក់ទឹកផ្សេងៗ ដែលមានគុណភាពខ្ពស់ ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ ដើម្បីឱ្យកសិករអាចធ្វើស្រែ និងចំការបានពី ២ ទៅ ៣ដងក្នុងមួយឆ្នាំ។

- រាជរដ្ឋាភិបាល តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងក្រសួងដែលពាក់ព័ន្ធគួរជំរុញ និងបង្កើនកិច្ចសហការណ៍គ្នា ដើម្បីស្វែងរកទីផ្សារកសិកម្មបន្ថែមទៀត (ទាំងក្នុង និងក្រៅស្រុក)។

- រាជរដ្ឋាភិបាលគួរតែមានផែនការឧបត្ថម្ភធនដល់កសិករពេលជួបប្រទះបញ្ហាទីផ្សារ ក៏ដូចជាការផ្តល់នូវសម្ភារៈ ឧបករណ៍ និងធនធានផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកសិកម្មគ្រួសារ។

- រដ្ឋាភិបាលគួរលើកទឹកចិត្តដល់កសិករតាមរយៈការបង្កើតរោងចក្រ ឬសហគ្រាស ដើម្បីប្រមូលទិញ កសិផលដំណាំពោតជាវត្ថុធាតុដើមក្នុងស្រុក (ដោយកាត់បន្ថយពន្ធ ឬមិនយកពន្ធសម្រាប់ម្ចាស់សហគ្រាស)។

## ៣.២.៣.ដំឡូងមី

### ក.ស្ថានភាពផលិតកម្មដំឡូងមីនៅកម្ពុជា

នៅប្រទេសកម្ពុជា ដំណាំដំឡូងមីគឺជាដំណាំមានសារសំខាន់ទី៣ បន្ទាប់ពីដំណាំស្រូវ និងពោត។ ដំណាំដំឡូងមីត្រូវបានដាំដុះនៅកម្ពុជានៅក្នុងសតវត្សទី១៩ ដែលជាទូទៅប្រជាកសិករនិយមដាំដើម្បីយកមើម ពីព្រោះដំណាំប្រភេទនេះ ងាយស្រួលដាំ និងមានភាពធន់ទ្រាំទៅនឹងភាពរាំងស្ងួត ។

នៅប្រទេសកម្ពុជា មុនសម័យសង្គ្រាមឆ្នាំ ១៩៧០ មានដាំដំឡូងមីបន្តិចបន្តួច។ ឆ្នាំ ១៩៩៦ មានខេត្តចំនួន ៨ បានដាំដុះ (កណ្ដាល កំពត កំពង់ចាម បាត់ដំបង ព្រៃវែង កំពង់ធំ មណ្ឌលគីរី និងសៀមរាប) លើផ្ទៃដី ២,១០០ហិតា និងទទួលបានបរិមាណផល ២៣ តោនក្នុងមួយហិតា។ ក្នុងឆ្នាំ ១៩៨០ ដល់ ១៩៨១ ទិន្នផលទទួលបាន ៨ តោន។ ចាប់ពីឆ្នាំ ១៩៩២ ដល់ ១៩៩៣ ទទួលបានទិន្នផល ៩ តោន។ ក្នុងឆ្នាំ២០១២ ដំណាំដំឡូងមី មានផ្ទៃដីចំនួន ៣៦១,៨៥៤ ហិតា ទិន្នផលជាមធ្យម ២២តោនក្នុងមួយហិតា។នាពេលបច្ចុប្បន្នវាបានផ្លាស់ប្ដូរពីដំណាំសម្រាប់អាហារទៅជាដំណាំឧស្សាហកម្មដូចជា យកម្សៅ អេតាណុល និង ចំណីសត្វ។ ដំណាំដំឡូងមីត្រូវបានដាំគ្រប់ផ្នែកទាំងអស់នៃប្រទេសកម្ពុជា ជាពិសេសក្នុងខេត្ត កំពង់ចាម បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ និងក្រចេះជាដើម។

### ក.១ ផ្ទៃដីដាំដុះដំឡូងមី

នៅក្នុងឆ្នាំ២០០២ ការផលិតមើមដំឡូងមីនៅលើពិភពលោកមានចំនួនប្រមាណ១៨៤ លានតោនហើយការផលិតបានកើនដល់២២៦ លានតោននៅឆ្នាំ២០០៩។ នៅក្នុងឆ្នាំ២០០២ ដដែល នៅក្នុងទ្វីបអាស៊ីផលិតបានចំនួន៥៥.៥ លានតោន និងនៅក្នុងទ្វីបអាមេរិចឡាទីនផលិតបានចំនួន៣៣.២ លានតោន។ ឯនៅប្រទេសកម្ពុជា មុនសម័យសង្គ្រាមឆ្នាំ ១៩៧០ មានដាំដំឡូងមីបន្តិចបន្តួច។ឆ្នាំ ១៩៩៦ មានខេត្តចំនួន ៨ បានដាំដុះ (កណ្ដាល កំពត កំពង់ចាម បាត់ដំបង ព្រៃវែង កំពង់ធំ មណ្ឌលគីរី និងសៀមរាប) លើផ្ទៃដី ២,១០០ហិតា និងទទួលបានបរិមាណផល ២៣តោនក្នុងមួយហិតា។ ក្នុងឆ្នាំ ១៩៨០ ដល់ ១៩៨១ ទិន្នផលទទួលបាន ៨ តោន។ ចាប់ពីឆ្នាំ ១៩៩២ ដល់ ១៩៩៣ ទទួលបានទិន្នផល ៩ តោន។ ក្នុងឆ្នាំ២០១២ ដំណាំដំឡូងមី មានផ្ទៃដីចំនួន ៣៦១,៨៥៤ ហិតា ទិន្នផលជាមធ្យម ២២តោនក្នុងមួយហិតា។

### ខ.កត្តាផលិតកម្ម

កត្តាផលិតកម្ម គឺជាធនធានទាំងឡាយណាដែលគេត្រូវការចាំបាច់ ដើម្បីតម្រូវការផលិតនូវផលិតផលសម្រេច រួមមានកត្តាដីធ្លី កត្តាទុនផលិតកម្ម កត្តាកម្លាំងពលកម្ម កត្តាបច្ចេកទេស និងកត្តាទីផ្សារកសិផល។ ដើម្បីឱ្យបរិមាណដំឡូងមីកើនឡើងវាអាស្រ័យទៅលើកត្តាផលិតកម្មខាងលើ ហើយបរិមាណផលិតផលកើនឡើងជាលំដាប់ ក៏អាស្រ័យទៅលើប្រសិទ្ធិភាពសេដ្ឋកិច្ចនៃកត្តាផលិតកម្មខាងលើផងដែរ ។

### ខ.១.កត្តាទុនផលិតកម្ម

ទុនជាកត្តាចាំបាច់នៃផលិតកម្ម វាជាទ្រព្យទាំងឡាយណាដែលយកទៅប្រើប្រាស់ក្នុងផលិតកម្ម គេចាត់ទុកថាវាជាទុនផលិតកម្ម។ ទុនផលិតកម្មកសិកម្មកើតចេញពីប្រភពមួយចំនួនដូចជា ការសន្សំ ការខ្ចីបុលកេរ្តិ៍មរតក អំណោយ ការរៀបអាពាហ៍ពិពាហ៍។ ជាទូទៅគេចែកទុនផលិតកម្មជាពីរប្រភេទ គឺអចលនទុន (សត្វ ដើមឈើ កសិដ្ឋាន អាគា...) និងចលនទុន (គ្រាប់ពូជ ដី ថ្នាំសម្លាប់សត្វល្អិត...) ។

### ខ.២ កត្តាបច្ចេកទេសនៃការដាំដុះដំណាំដំឡូងមី

*a.*ការរៀបចំដី

អ្នកត្រូវកាប់ឬភ្ជួរដីអោយបានជំរៅប្រហែលពី ២០-៣០ស.ម ភ្ជួរឲ្យបានពីរទៅបីដងដើម្បីឲ្យដីផុសល្អ បន្ទាប់មកអ្នកត្រូវរើសយកស្មៅចេញអោយបានស្អាត អ្នកត្រូវហាលដី អោយបានស្ងួតល្អ។ ប្រភេទដីដែលសមស្រប សម្រាប់ការដុះលូតលាស់របស់ដំណាំដំឡូងមី គឺជាប្រភេទដីមានជីជាតិល្អ មិនដាំទឹក និងមានដង្ហើមខ្យល់ចេញចូលល្អ មិនមានសារជាតុពុលនៅក្នុងដី ជាប្រភេទល្បាប់ខ្សាច់។ ដោយសារដំណាំដំឡូងមី ជាប្រភេទដំណាំមិនត្រូវការសំណើមខ្ពស់ ដូច្នេះ ការដាំដុះទាមទារនូវការរៀបដី ឲ្យមានប្រព័ន្ធបញ្ចេញបញ្ចូលទឹក និងមានជម្រៅដីជាមធ្យមពី ៥០ ស.ម ទៅ១ម៉ែត្រ ។

*b.*ការជ្រើសរើសពូជ

- អ្នកត្រូវរើសយកដើមដំឡូងណា ដែលធំមានលក្ខណៈដុះលូតលាស់ល្អ និងមានអាយុ កាលយ៉ាងតិចមួយឆ្នាំ ។
- អ្នកត្រូវកាត់ជាកង់ៗ ប្រវែងពី ២០ស.ម (២តឹក) ។
- ដើមដែលមិនខ្ចីពេកធាប់ស្ងួតទឹក ទុកមិនយូនៅរដូវប្រាំងព្រោះវាងាយនឹងទទួលការបំផ្លាញពីជម្ងឺ។នៅពេលយកដាំត្រូវពិនិត្យមើលជ័ររបស់វាបើវាចេញមកយឺតមិនត្រូវយកមដាំទេ ។
- កុំប្រើដើមណាដែលស្គមព្រោះមានសារជាតុចិញ្ចឹមនិងសំណើមតិច ពន្លកដុះខ្សោយ និង អាចបង្កើតឫសបានតិចតួច គួរប្រើដើមណាដែលធំក្រាស់ល្អ។ ទំហំដែលល្អប្រសើរនោះគឺកាំ១សង់ទីម៉ែត្រ
- ចំនួនផ្នែកវាអាស្រ័យទៅតាមប្រភេទពូជ ប្រវែងកង់ពី២០ទៅ២៥សង់ទីម៉ែត្រដែលមានភ្នែកពី ៥ទៅ៧ភ្នែក ។
- កំណាត់កង់ខ្លីពេក ឬក៏ចំនួនភ្នែកតិច(១ទៅ៣ភ្នែក)ធាប់ស្ងួតជាតិទឹក និងងាយ ទទួលរង

### ខ.៣.ការប្រើប្រាស់ទឹក

ដំឡូងមីដុះល្អលូតលាស់ល្អបំផុត នៅក្នុងកម្រិតទឹកភ្លៀងប្រចាំឆ្នាំពី ៥០០ ម.ម - ៥០០០ ម.ម។ ទឹកភ្លៀងកម្រិតនេះ អាចឲ្យដំណាំដំឡូងមីបន្តការដុះលូតលាស់ពេញមួយរដូវប្រាំងបានទៀត ដែលដំណាំខ្លះមិនមានភាពធន់ទ្រាំបែបនេះបាន។

ដំណាំដំឡូងមីមិនមែនជាប្រភេទដំណាំដែលត្រូវការសំណើមខ្ពស់ ឬជាំទឹកឡើយ។ នៅពេលមានសំណើមខ្ពស់ ឬជាំទឹក ធ្វើឲ្យការដុះលូតលូតលាស់ចុះខ្សោយ ដូចជា ដើមតូច ទាប ស្លឹកមានពណ៌លឿង និងជ្រុះស្លឹកជាបន្តបន្ទាប់ ពិសេសក្នុងអំឡុងពេលប្រមូលផល ធ្វើឲ្យមើមរលួយជាមូលហេតុធ្វើ ឲ្យទិន្នផលចុះទាប។

សីតុណ្ហភាពសមស្របសម្រាប់ការដុះលូតលាស់ដំណាំដំឡូងមីគឺ ចន្លោះពី ២៥-២៩ អង្សាសេ។ ក៏ប៉ុន្តែដំណាំដំឡូងមីអាច ធន់ទ្រាំនឹងសីតុណ្ហភាពចន្លោះពី ១៦-៣៨ អង្សាសេ ។ កាលណា សីតុណ្ហភាព ទាបជាង១៦ អង្សាសេ ការដុះលូតលាស់របស់ដំឡូង ដែលដាំដោយកំណាត់ដើមត្រូវបានពន្យាពេលការពង្រីកមើម ការដុះលូតលាស់ស្លឹក និងថតចុះបរិមាណមើម។

### ខ.៤.ការប្រើប្រាស់ជីថែទាំ និងថ្នាំសម្លាប់សត្វល្អិត

ប្រភេទជីដែលអ្នកត្រូវប្រើនោះ គឺ ជីប្រភេទ ៨-១៦-១៩ ដាក់ក្នុងចំនួនពី៦០-១០០ គីឡូក្រាមក្នុងផ្ទៃដី ១៦០០ សង់ទីម៉ែត្រការ៉េ។ លើកទី១នៅពេលដែលដំឡូងមានអាយុបានមួយខែបន្ទាប់ពីដាំ។ដាក់លើកទីពីរនៅពេល ដំឡូងមីមានអាយុបីខែក្រោយពីដាំហើយត្រូវដាក់អោយបានឆ្ងាយពីគល់ដំឡូងបន្តិចគឺប្រហែលពី ២៥-៣០សមហើយលុបដី។ក្រោយពីដាំដំឡូងពី ៥-៧ ថ្ងៃ ត្រូវពិនិត្យមើលការដុះពន្លករបស់ដំឡូង អ្នកត្រូវដាំជួសឡើងវិញ ជាបន្ទាន់ចំពោះកន្លែងណាដែលមិនដុះ។បន្ទាប់ពីដំឡូអមានអាយុ ៣០ ថ្ងៃ ត្រូវជ្រួយដី បោចស្មៅអោយបានស្អាតល្អ ដើម្បីឲ្យដីផុសត្រសុសល្អ។ លើសពីនេះ មានវត្តមានសត្វល្អិតចង្រៃជាច្រើនប្រភេទ ដែលតែងធ្វើការបំផ្លាញផលដំណាំរបស់ប្រជាកសិករជារៀងរាល់ឆ្នាំ។ ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយនេះ ប្រជាកសិករតែងប្រើប្រាស់គ្រប់វិធានការ ដើម្បីការពារផលដំណាំរបស់ខ្លួន ក្នុងនោះវិធានការក្សេត្រសាស្ត្រជាជម្រើសទី១ របស់ពួកគាត់ព្រោះជាវិធានការដែលមិនមានការចំណាយច្រើន។ វិធានការទី២គឺជាវិធានការគីមី ដែលវិធានការនេះ គឺជាវិធានការចុងក្រោយ នៅពេលដែលវិធានការក្សេត្រសាស្ត្រ មិនទទួលបានជោគជ័យរាល់ការប្រើប្រាស់វិធានគីមី ត្រូវតែមានការពិចារណាឲ្យបានល្អិតល្អន់មុនពេលសម្រេចថាត្រូវប្រើប្រាស់ថ្នាំគីមី ពិសេសត្រូវមានការប្រឹក្សាជាមួយអ្នកជំនាញកសិកម្ម។

### ខ.៥.ការប្រមូលផល

- ដំឡូងមីអាចផលបានពេញ ១ ឆ្នាំ
- ការប្រមូលផលដំឡូងមីអាយុតិចជាងនេះធ្វើឲ្យទិន្នផលធ្លាក់ចុះ

- ❖ ចំពោះការដាំជាលក្ខណៈគ្រួសារ ការប្រមូលផលអាចធ្វើទៅតាមតម្រូវការជាក់ស្តែង
- ❖ គួរប្រមូលផលនៅរដូវប្រាំង ព្រោះដំឡូងមានកម្រិតជាតិម្សៅល្អ មានតម្លៃខ្ពស់ និងមានតម្រូវការច្រើននៅលើទីផ្សារ
- ❖ ការប្រមូលផលនៅរដូវវស្សាដំឡូងមានកម្រិតជាតិម្សៅតិច មានតម្លៃថោក មានតម្រូវការទីផ្សារទាប ពិបាកសម្ងួត
- ❖ ដំឡូងអាយុចាប់ពី៨ ទៅ ១៤ ខែ អាចធ្វើការប្រមូលផលបាន
- ❖ ជាការប្រសើរគួរប្រមូលផលពេលដែលដំឡូងមានអាយុ ១២ខែ
- ❖ ការពន្យាពេលធ្វើការប្រមូលផលអាចធ្វើឲ្យកម្រិតជាតិម្សៅរបស់មើមមានការថយចុះ និងកើនឡើងសសៃ រឹងដូចឈើ។

ការប្រមូលផលដំឡូងអាចធ្វើទៅបានក៏អាស្រ័យទៅតាមពេលវេលានៃ ការដាំដុះ ប្រភេទពូជ កត្តាអាកាសធាតុ ដីពិសេសតម្រូវការទីផ្សារ។

ដំណាំដំឡូងឈើពូជស្រាល អាចប្រមូលផលបានក្នុងរយៈពេលពី៥-៦ខែក្រោយពេលដាំ។ លក្ខណៈសម្គាល់ គឺស្លឹកវាឡើងពណ៌លឿង ហើយចាប់ផ្តើមជ្រុះស្លឹកនៅគល់ ដេញឡើងទៅលើ។ មុនគាស់មើមត្រូវកាប់ដើមចេញសិន ដោយទុកប្រហែល ៣០-៤០ ស.ម ពីដី។

ចំពោះដំឡូងមីពូជធ្ងន់ អាចប្រមូលផលបានក្នុងរយៈពេល ១ឆ្នាំ ឬលើសពី ១ឆ្នាំ។ ការប្រមូលផលអាចប្រែប្រួល ទៅតាមប្រភេទពូជ និងសេចក្តីត្រូវការរបស់អ្នកដាំ។

- ➢ កំណត់សម្គាល់៖

ការប្រមូលផលសម្រាប់បំរើការហូបចុក អាចធ្វើទៅបានចាប់តាំងពីមើមដំឡូងនៅខ្ចីរហូតដល់ចាស់។ ប៉ុន្តែសម្រាប់ បម្រើនៅក្នុងរោងចក្រឧស្សាហកម្មវិញ ត្រូវទុកមើមឲ្យចាស់គ្រប់អាយុពេញលេញទើបប្រមូលផល ដើម្បីបង្កើនជាតិម្សៅបានច្រើន។

- ➢ ការទុកដាក់មើមដំឡូង៖

មើមដំឡូងឈើ ជាទូទៅគឺមិនអាចធានាទុកបានយូរពេកទេ ពីព្រោះវាងាយរលួយខូចណាស់ការដែលឆាប់រលួយបែបនេះគឺបណ្តាលមកពីមេរោគ និងជំងឺផ្សេងៗ ។ គេអាចជៀសវាងចំពោះការដែលបណ្តោយឲ្យរលួយនេះ បានដោយយើងត្រូវរក្សាមើមដំឡូងនោះ ដោយកប់មើមដំឡូងទៅក្នុងដី ឬខ្សាច់ ឬក៏អាចដាក់ក្នុងបាវ ឬក្រដាស់សើម។

គេអាចរក្សាទុកមើមដំឡូងក្នុងរយៈពេលយូរបាន ដោយទុកវានៅក្នុងទូ ឬបន្ទប់ត្រជាក់ដែលមានសីតុណ្ហភាពត្រឹម ២៥អង្សាសេ។

វិធីទុកដាក់ម្យ៉ាងទៀត គឺគេចិតមើមដំឡូងនៅស្តើងៗ ហាលថ្ងៃឲ្យស្ងួតរហូតដល់សំណើមក្នុងមើមដំឡូងនោះនៅត្រឹម ១០-១២ភាគរយប៉ុណ្ណោះ។ គេអាចបន្ថយនៅការរលួយមើមបានមួយកម្រិតតាមរយៈការកប់ដើមចោលមុនប្រមូលផលប្រមាណពី ៧-១១ ថ្ងៃ។ ការទុកដាក់ដោយខ្ចប់ក្រដាស់

សើម គឺអាចបន្ថយភាពល្វេយបានមួយកម្រិត បើក្នុងករណីដែលគេត្រូវនាំចេញមើមស្រស់ទៅលក់នៅកន្លែងឆ្ងាយ ឬ បរទេស គេត្រូវតែប្រមូលផលនៅពេលដែលដំឡូងមានអាយុមិនលើសពី ១០ ខែ បន្ទាប់ពីដាំ។

- ➢ ឧបករណ៍សម្រាប់ធ្វើការប្រមូលផល
  - ចប (ចប់ជីក ចបកាប់)
  - កាំបិត
  - កណ្ដៀវ
  - គ្រឿងចក្រសម្រាបការដាំលក្ខណៈឧស្សាហកម្ម
- ➢ គុណប្រយោជន៍មើមដំឡូងមីផ្នែកអាហារូបត្ថម្ភ

មើមដំឡូងសម្បូរទៅដោយជាតិម្សៅ ដែលអាចឲ្យអ្នកបរិភោគទទួលបាននូវរបបអាហារទ្រ

ទ្រង់រាង្គកាយពិសេសសម្រាប់ដល់កុមារ មិនតែប៉ុណ្ណោះមើមដំឡូងមីគេអាចយកវាទៅធ្វើចំណីសត្វ ហើយម្សៅដំឡូងគេអាចយកទៅធ្វើជានំប៉័ងជំនួសស្រូវសាឡីបាន ជាវត្ថុធាតុដើមសម្រាប់រោងចក្រក្នុងផលិតជាក្រដាស់ ជាពិសេសអាចកែច្នៃធ្វើជាគ្រាប់សាគូ និងមុខរណាសម្រាប់ធ្វើជាបង្អែមយ៉ាងឆ្ងាញ់ពិសារ។

## គ.ទីផ្សារកសិផល

ទីផ្សារកសិផលគឺជាទីផ្សារមួយដែលមានអត្រាដែលអ្នកប្រើប្រាស់ចង់ទិញផលិតផល។ ទ្រឹស្ដីសេដ្ឋកិច្ចតំរូវការនោះមានកត្តាពីរយ៉ាង៖រសជាតិ និងសមត្ថភាពក្នុងការទិញ ។ រសជាតិដែលជាការចង់បានទំនិញ កំណត់ពីឆន្ទៈក្នុងការទិញទំនិញក្នុងតម្លៃជាក់លាក់។ សមត្ថភាពក្នុងការទិញមានន័យថាដើម្បីទិញទំនិញក្នុងតម្លៃជាក់លាក់ បុគ្គលត្រូវតែមានទ្រព្យសម្បត្តិ ឬប្រាក់ចំណូលគ្រប់គ្រាន់។

## ឃ បញ្ហាប្រឈមចំពោះផលិតកម្មដំឡូងមី

### ឃ.១.របាយទឹកភ្លៀង និងជំនន់ និងភាពរាំងស្ងួត

ការដាំដុះដំណាំដំឡូងមីនៅកម្ពុជា ច្រើនស្ថិតនៅក្នុងតំបន់ ដែលទទួលបានរបបទឹកភ្លៀងចន្លោះពី ១២៥០ ទៅ ១៧៥០ ម.ម។ របបទឹកភ្លៀងបែបនេះមានលក្ខណៈសមស្របឱ្យដំណាំដំឡូងមីទទួលនូវភោគផលល្អប្រសិនបើមានរបបទឹកភ្លៀងទៀងទាត់។ ផ្ទុយទៅវិញភាពមិនប្រក្រតីនៃរបបទឹកភ្លៀង បណ្ដាយឱ្យទិន្នផលដំណាំដំឡូអមីត្រូវធ្លាក់ចុះនឹងភាពមិនអំណោយផលដល់ប្រព័ន្ធកសិកម្មផ្សេងៗទៀត។ ភ្លៀងចាប់ផ្ដើមធ្លាក់មានការពន្យាពេល ហើយតែងតែកើតមានដំណាក់កាលរាំងស្ងួត (កួនរដូវប្រាំង) រយៈពេលពី ៣ សប្ដាហ៍ ឬច្រើនជាងនេះនៅចុងខែ កក្កដា រហូតដល់ខែសីហា។ ជួនកាលភ្លៀងធ្លាក់ជោគជាំពេកនៅលើដីជាំទឹក ក៏អាចបណ្ដាលឱ្យមានការខូតខាតដល់ផលដំណាំដទៃទៀត ដែលគេនិយមដំឡូងមី។

### ឃ.២.កត្តាដែលធ្វើឲ្យខូតខាត

កសិកម្មវាបង្កឱ្យបរិស្ថានខូចខាតដីធ្លីកើតចេញជាកត្តាពីរសំខាន់ៗគឺ កត្តាមនុស្ស និងកត្តាធម្មជាតិ។ ជាទូទៅគេចាត់ទុកដីធ្លីខូចខាតនៅពេលវាអស់គុណភាព និងទទួលការសឹករិចរឹល។ ចំពោះការដាំដំណាំនេះមានន័យថា វាធ្វើឱ្យទិន្នផលដំណាំថយចុះជាងមុន រីឯកាចិញ្ចឹមសត្វ គឺសម្មតភាពទ្រទង់សត្វបានតិចជាងមួយឯកត្តាផ្ទៃដី។ បញ្ហាចម្បងចំពោះដីធ្លីមាននៅពេសពេញពិភពលោក គឺសំណឹកដី ការបាត់បង់សារធាតុដី សារធាតុចិញ្ចឹម សំណល់ថ្នាំបាយក្រៀម និងកង្វក់ដីដោយសារមានវត្ថុមានអំបិល ទឹក និងសារធាតុគីមីជាច្រើន ។

### ឃ.៣ កត្តាដែលធ្វើឲ្យផលិតភាពដីប្រែប្រួល

ផលិតកម្មដីធ្លីប្រែប្រួលតាមរយៈឥទ្ធិពលជាច្រើនដូចជា រដូវកាល ពេលវេលា ទំហំកសិដ្ឋាន អាកាសធាតុ កម្រិតជីជាតិ ពូជសត្វ ដំណាំ ដង់ស៊ីតេដំណាំ ប្រព័ន្ធប្រពលវប្បកម្ម និងគ្រប់គ្រងលើការអនុវត្តបច្ចេកទេស។ ដូចជា កសិករត្រូវយកចិត្តទុកដាក់ឱ្យច្រើនលើការថែរទាំគុណភាពដី ជ្រើសរើសពូជយកមកប្រើប្រាស់ និងជំនាញទាំងឡាយដែលអាចជួយការប្រើប្រាស់ដីធ្លីមាននិរន្តរភាព។

### ឃ.៤.កត្តាសត្វចង្រៃ និងជំងឺ

បច្ចុប្បន្នសត្វល្អិត និងជំងឺជាកត្តាចង្រៃដែលអាចធ្វើឱ្យទិន្នផលដំណាំដំឡូងមីថយចុះ។ សត្វល្អិតចង្រៃដែលបំផ្លាញដំណាំកសិកម្មរួមមាន ដង្កូវស៊ីរូងដើម មមាចត្នោត មមាចខៀវ ទ្រីបកណ្តូប ដង្កូវមូលស្លឹក ច្រឹង ដង្កូវស៊ីស្លឹក និងដង្កូវហ្វូង។ ទិន្នផលដំឡូងមីក៏អាចត្រូវបានបំផ្លាញដោយក្តាមតាមរយៈការកាតសំណាប សត្វល្អិតស៊ីពូជ ឬស៊ីដើម។

## ង.ស្ថានភាពទូទៅរបស់កសិករដំឡូងមី

### ង.១.ស្ថានភាពបច្ចុបន្បន្ននិងបញ្ហាប្រឈម

ការដំណាំដំឡូងមីនៅកម្ពុជា ច្រើនស្ថិតនៅក្នុងតំបន់ ដែលទទួលបានរបបទឹកភ្លៀងចន្លោះពី ១២៥០ ទៅ ១៧៥០ ម.ម។ របបទឹកភ្លៀងបែបនេះមានលក្ខណៈសមស្របឱ្យដំណាំដំឡូងមីទទួលនូវភោគផលល្អប្រសិនបើមានរបបទឹកភ្លៀងទៀងទាត់។ប៉ុន្តែស្ថានភាពបច្ចុបន្បន្នកសិកម្មវាបង្កឱ្យបរិស្ថានខូចខាតដីធ្លីកើតចេញជាកត្តាពីរសំខាន់ៗគឺ កត្តាមនុស្ស និងកត្តាធម្មជាតិ។ ហើយជាទូទៅគេចាត់ទុកបញ្ហាប្រឈមនៅពេលដីធ្លីខូចខាតនៅពេលវាអស់គុណភាព និងទទួលការសឹករិចរឹល។

### ង.២.ស្ថានភាពសេដ្ឋកិច្ច

ក្នុងចំណោមឃុំស្ដៅនៅក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបងមានប្រជាពលរដ្ឋ ៨ ភូមិជាអ្នកប្រកបរបរកសិកម្មជាចម្បង និងប្រកបរបរបន្ទាប់បន្សំផ្សេងៗទៀត សម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ ដូចជា ចិញ្ចឹមសត្វ នេសាទ លក់ដូរ ដាំបន្លែបង្ការ ធ្វើការរោងចក្រ។ល។ ស្ថានភាពនៃលក្ខណៈភូមិសាស្ត្រជាក់ស្តែងរបស់ឃុំ គឺជាតំបន់ខ្ពង់រាប ដែលមានផ្ទៃដីប្រកបដោយជីវជាតិ សម្រាប់ផលិតកម្មកសិកម្មព្រមទាំងមាន បឹងបួរ ព្រៃក ប្រឡាយ ផ្តល់លទ្ធផលសម្រាប់ប្រជាកសិករយើងបង្កបង្កើនផល ដាំដុះ ដំណាំគ្រប់ប្រភេទ ទៅតាមរដូវការជាក់ស្តែង។

### ង.៣ ស្ថានភាពសង្គមកិច្ច

ឃុំស្ដៅនៅក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបងមានសាលារៀនថ្នាក់មត្តេយ្យរហូតដល់អនុវិទ្យាល័យ ក្នុងនោះមានសាលាមត្តេយ្យសហគម មត្តេយ្យរដ្ឋបឋមសិក្សា និងសាលាអនុវិទ្យាល័យ។ ចំពោះឃុំនេះមានមណ្ឌលសុខភាព មានបុគ្គលិកប្រចាំការសម្រាប់បម្រើសេវាព្យាបាលជំងឺរបស់ប្រជាពលរដ្ឋត្រូវឃុំសហការជាមួយមន្ទីរពេទ្យបង្អែកស្រុកដែលមានបុគ្គលិកសុខាភិបាល មានជំនាញសម្រាប់ប្រចាំការបម្រើសេវាសុខភាព ជូនប្រជាជនពិសេស ស្ត្រីនិងកុមារ ដែលជាជនងាយរងគ្រោះ។

### ង.៤.ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ឃុំជារដ្ឋបាលថ្នាក់ក្រោមជាតិមួយដែលចាត់តាំងមានរចនាសម្ព័ន្ធ ដឹកនាំត្រឹមត្រូវ ដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ នៅក្នុងរដ្ឋបាលឃុំមានក្រុមប្រឹក្សាឃុំ និងស្មៀនឃុំ ម្នាក់ ជួយលើការងាររដ្ឋបាលទូទៅក្នុងឃុំ និងមានជំនួយការឃុំចំនួនក្នុងការបំពេញមុខងារ និងតួនាទីរបស់ខ្លួនឱ្យ បានប្រសើរ ស្របតាមច្បាប់គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាការងារចាំបាច់ដែលអាជ្ញាធរភូមិ ឃុំ ត្រូវអនុវត្តន៍ឱ្យខានតែបាន នៅថ្នាក់ឃុំមានគណៈបញ្ជាការឯកភាពរដ្ឋបាលឃុំ ដែលមានសភាពឃុំ ភូមិ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ យើងបានចុះផ្សព្វផ្សាយ និងធ្វើវេទិកាសាធារណៈនៅតាមភូមិបានទៀងទាត់ ដើម្បីផ្សព្វផ្សាយពីច្បាប់នានាជូនប្រជាពលរដ្ឋឱ្យមានការយល់ដឹង និងអនុវត្តន៍។

## ក្រាភិច៣.១៣.ផែនទី ទីតាំង ឃុំស្ដៅ ស្រុករតនៈមណ្ឌលខេត្តបាត់ដំបង



**ក្រាហ្វិកទី៣.១៤ : ភេទប្រជាកសិករដាំដំឡូងមី**




ប្រភព : វិភាគទិន្នន័យបឋម

កសិករដែលត្រូវបានសម្ភាសន៍ មានចំនួន ២០ គ្រួសារ ក្នុងនោះមានកសិករជាស្ត្រីចំនួន ៤០% និងបុរស ៦០% ដែលដាំដំណាំដំឡូងមីនៅក្នុងភូមិដូនមាយ ឃុំស្ដីស្រុករតនមណ្ឌល ខេត្តបាត់ដំបង។

**ក្រាហ្វិកទី៣.១៥ : អាយុរបស់កសិករ**




ប្រភព : វិភាគទិន្នន័យបឋម

កសិករមានអាយុជាមធ្យម ៤២.៧ ឆ្នាំ ដែលក្នុងនោះអាយុទាបបំផុត ៣០ឆ្នាំ និងច្រើនបំផុត ៥៦ ឆ្នាំ។ ពួកគាត់មានកម្រិតជីភាពមធ្យម និងភាគច្រើនមានសមាជិកគ្រួសារចំនួន ៦ នាក់។

## ច.ស្ថានភាពផលិតកម្មដំឡូងមី

### ច.១.ការរៀបចំដី

ក្រាហ្វិកទី៣.១៦ : ពេលវេលាដែលកសិករចាប់ផ្តើមដាំដំឡូងមី




ប្រភព : វិភាគទិន្នន័យបឋម

ដំណាំដំឡូងមីត្រូវបានដាំក្នុងខែមីនាចំនួន ២០% ខែមេសាចំនួន៤០% និង៤០%ទៀតអាស្រ័យនឹងការធ្លាក់ភ្លៀង។ ប្រជាកសិករមួយចំនួនធ្វើការភ្ជួរដីចំនួនពីរលើកមុននឹងដាំ ដោយលើកទីមួយ គឺ ភ្ជួរដីហាលរយៈពេល ១៥ ថ្ងៃ ឬ រងចាំដល់មានភ្លៀងធ្លាក់ ទើបធ្វើការភ្ជួរជាលើកទីពីរម្តងទៀត។ កសិករខ្លះទៀតភ្ជួរដីចំនួនបីលើក គឺ លើកទីមួយភ្ជួរដោយត្រាក់ទ័រធំផាលបី ហើយលើកទីពីរ និងទីបីភ្ជួរដោយគោយន្តកន្ត្រៃ។ នៅពេលភ្ជួរលើកចុងក្រោយបង្អស់រួច កសិករដែលបានភ្ជួរដីតែពីរលើកធ្វើការផ្ទុំរពង រីឯកសិករដែលបានភ្ជួរបីលើកហើយនោះមិនផ្ទុំរពងទេ ពួកគាត់រៀបចងខ្សែធ្វើជាបន្ទាត់តំរងជួរសម្រាប់ដោតពូជដំឡូងមីតែម្តង។ កសិករផ្ទុំរពង ឬ ទុកចន្លោះពីជួរនីមួយៗនៃដើមដំឡូងមីពី១ម៉ែត្រ ទៅ ១,៥ម៉ែត្រ និងរក្សាគំលាតរវាងដើមនីមួយៗពី៦ដេស៊ីម៉ែត្រ ទៅ ៧ដេស៊ីម៉ែត្រ។

### ច.២ បច្ចេកទេសដាំ

ពូជដែលប្រជាកសិករយកមកដាំមានប្រភពពីប្រទេសថៃ ដែលត្រូវបានគេស្គាល់ថាពូជយ៉ងប៉ែន ពូជជាងក្រហម និងពូជជាងស។ ពូជទាំងបីនេះមានលក្ខណៈខុសគ្នាត្រង់ពណ៌នៅ

លើជាងស្លឹង ដោយយ៉ងប៉ែនមានពណ៌ក្រហមក្រមៅ ពូជជាងក្រហមមានជាងស្លឹកពណ៌ក្រហមពងផ្កាឈូក និងពូជជាងសមានជាងស្លឹកពណ៌ស។ ពូជយ៉ងប៉ែន និងជាងក្រហមផ្តល់មើម ដែលមានគុណភាពដូចគ្នា គឺ ១គីឡូក្រាមមើមស្រស់ អាចសម្ងួតបានមើមស្ងួត ០,៦គីឡូក្រាម។ រីឯពូជជាងសវិញ មើមស្រស់១

គីឡូក្រាម អាចសម្ងួតបានមើមស្ងួត០,៥គីឡូក្រាម ដូចនេះកសិករលក់មើមដំឡូងមីពូជជាងសតែមើមស្រស់ប៉ុណ្ណោះ។ ចំពោះវិធីសាស្ត្រដាំដុះប្រភេទដំឡូងមីទាំងបីប្រភេទនេះគឺមានលក្ខណៈដូចគ្នា។

**ក្រាហ្វិកទី៣.១៧ : ជម្រៅដីដែលដោតដើមដំឡូងមី**




ប្រភព : វិភាគទិន្នន័យបឋម

កសិករ៧០% ប្រើប្រាស់ពូជដែលខ្លួនមានស្រាប់ និង៣០%ទៀតទិញពូជពីអ្នកដាំដំឡូងមីដូចគ្នានៅក្នុងភូមិ។ ពួកគាត់កាត់ដើមដំឡូងមីជាពូជឲ្យស្មើ និងដោតដើមទាំងនោះតាមទិសឈរ ព្រោះការកាត់ដើមដំឡូងមីបញ្ចិត និងដោតដើមជាពូជតាមទិសដេក ឬ ទ្រេតធ្វើឲ្យដើមដំឡូងមីបាត់បង់ជាតិជ័រមួយចំហៀង ដូចនេះមើមដុះចេញពីដើមតែមួយចំហៀងប៉ុណ្ណោះ។ មុងនឹងយកពូជនោះទៅដោតដាំ ពួកគាតយកកំណាត់ដើមទាំងនោះទៅត្រាំទឹកធម្មតា ឬ ទឹកអរម៉ូនជាមុនសិន ព្រោះការធ្វើបែបនេះ ធ្វើឲ្យដើមដំឡូងមីរបស់ពួកគាត់ធន់នឹងភាពរាំងស្ងួត ហើយវាអាចប្រឆាំងនឹងការឆ្លងជំងឺ និងការកើតឡើងនៃសត្វចៃលើដើមដំឡូងមីបានមួយកម្រិត។ ការត្រាំទឹកធម្មតា ឬ ទឹកអរម៉ូននេះប្រើរយៈពេលពី៥ ទៅ ១០ នាទី ហើយកសិករអាចលាយជាមួយថ្នាំសំលាប់សត្វល្អិត។ ទឹកអរម៉ូនធ្វើឲ្យដើម និងមើមលូតលាស់បានលឿន ហើយធននឹងជំងឺផ្សេងៗ។

កសិករដាំដំឡូងមីដោយដោតដើមក្នុងដីជម្រៅខុសៗគ្នា ភាគច្រើន ៧សង់ទីម៉ែត្រ និងជាមធ្យម ៧.៦ សង់ទីម៉ែត្រ។ ភាពខុសប្លែកគ្នានៃជម្រៅដីនេះ អាស្រ័យលើភាពធូរបស់ដី

ព្រោះការដោតដើមដំឡូងមីទៅក្នុងដីរាក់ពេកអាចធ្វើឲ្យដើមរបស់វាដួល និងទទួលបានមើមតិច ដោយសារផ្នែកដែលប៉ះនឹងដីមានតិច និងមានមើមដុះចេញតែមួយជួរប៉ុណ្ណោះ។ រីឯការដោតដើមដំឡូងមីជ្រៅពេលវិញ ធ្វើឲ្យមើមតូចមិនសូវទទួលបានទិន្នផលខ្ពស់ទេ។

**តារាងទី៣.១២ : ជម្រៅដីដែលកសិករដោតដើមដំឡូងមី**

| ជម្រៅដី (សង់ទីម៉ែត្រ) | ចំនួនកសិករ | ភាគរយ | ជម្រៅដីជាមធ្យម (សង់ទីម៉ែត្រ) | គំលាតស្តង់ដារជម្រៅដី (សង់ទីម៉ែត្រ) |
|---|---|---|---|---|
| ៦,០ | ៣ | ១៥% | ៧.៦ | ១.៤ |
| ៦,៥ | ១ | ៥% | | |
| ៧,០ | ៨ | ៤០% | | |
| ៨,០ | ៤ | ២០% | | |
| ១០ | ៤ | ២០% | | |
| សរុប | ២០ | ១០០% | | |

ប្រភព : វិភាគទិន្នន័យបឋម

### ច.៣.ការថែទាំ

ក្នុងកំឡុងពេលលូតលាស់របស់ដើមដំឡូងមី ការថែទាំសំខាន់បំផុតនៅក្នុងតំបន់ស្រាវជ្រាវនេះ គឺ ការកំចាត់ស្មៅ ដែលត្រូវធ្វើឡើងចំនួនពីរ ឬ បីលើក គឺអាស្រ័យទៅនឹងពេលវេលា ដែលកសិករមាន និងការលូតលាស់រវាងស្មៅ និងដើមដំឡូងមី។ ការកំចាត់ស្មៅលើកទីមួយតែងធ្វើឡើងនៅពេលដើមដំឡូងមីមានអាយុ ១៥ ថ្ងៃ និងលើកទីពីរ នៅពេលវាមានអាយុ២ខែ។ ក្រោយពីការកំចាត់ស្មៅលើកទីពីរហើយ ដើមដំឡូងមីមានកំពស់ខ្ពស់ល្មមអាចទប់ទល់នឹងស្មៅបានដោយខ្លួនឯង លើកលែងនៅតំបន់ជាប់នឹងជើងភ្នំ ដែលត្រូវធ្វើការកំចាត់ស្មៅជាលើកទីបីម្តងទៀត ព្រោះដីមានជីជាតិធ្វើឲ្យស្មៅដុះលឿន អាចប៉ះពាល់ដល់ការលូតលាស់របស់ដំឡូងមីបាន។ ការកំចាត់ស្មៅនេះធ្វើឡើងដើម្បីឲ្យដើមដំឡូងមីលូតលាស់ល្អ មានមើមធំ និងធ្ងន់ ហើយវាជួយកាត់បន្ថយប្រភេទសត្វកកេរមួយចំនួនដូចជាកណ្តុរជាដើម ព្រោះនៅពេលមានស្មៅក្រាស់ពពួកសត្វកណ្តុរទាំងនោះនឹងមកធ្វើសំបុក និងកាយដីដែលអាចនាំឲ្យខូចខាតដល់ដើម និងមើមរបស់ដំឡូងមី។

**ក្រាហ្វិកទី៣.១៨ : វិធីសាស្ត្រកំចាត់ស្មៅរបស់កសិករ**




ប្រភព : វិភាគទិន្នន័យបឋម

ក្នុងការកំចាត់ស្មៅ កសិករទាំងអស់សុទ្ធតែប្រើប្រាស់ថ្នាំកិនត្រាសម្រាប់កំចាត់ស្មៅ ដែលដុះក្រាស់ៗ និងប្រើប្រាស់កំលាំងពលកម្មមនុស្សដើម្បីដកស្មៅនៅកន្លែងដែលមានស្មៅដុះស្តើងបន្ថែម។ ក្នុងនោះ ការដកស្មៅដោយដៃមាន ៧៥% និងការប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅជំនួសកំលាំងពលកម្មមនុស្សមាន ២៥%។ ដើម្បីដកស្មៅក្នុងទំហំដីមួយហិចតាក្នុងមួយថ្ងៃឲ្យបានរួចរាល់ តម្រូវការកំលាំងពលកម្មរបស់មនុស្សជាមធ្យមប្រមាណ ២០ នាក់។ ប៉ុន្តែទោះជាការដកស្មៅត្រូវបានធ្វើឡើងយ៉ាងល្អយ៉ាងណាក៏ដោយ កសិករនៅតែប្រើប្រាស់ថ្នាំកិនត្រាបាញ់បន្ថែមទៀត ដើម្បីកាត់បន្ថយការដុះឡើងវិញនៃស្មៅទាំងនោះ។

ក្រៅពីការកំចាត់ស្មៅ កសិករមួយចំនួនបានប្រើប្រាស់ជីអ៊ុយរេដើម្បីពន្លឿនការលូតលាស់របស់ដើម និងមើមរបស់ដំឡូងមី។

### ក្រាហ្វិកទី៣.១៩ : បម្រើបម្រាស់ជី




ប្រភព : វិភាគទិន្នន័យបឋម

មានកសិករតែ ៣០% ប៉ុណ្ណោះដែលប្រើប្រាស់ជីគីមីសម្រាប់បង្កើនទិន្នផល ព្រោះដីនៅក្នុងតំបន់នេះមានជីជាតិគ្រប់គ្រាន់អាចឲ្យកសិករទទួលបានទិន្នផលខ្ពស់ ទោះបីជាមិនប្រើប្រាស់ជីក៏ដោយ។ ក្នុងការប្រើប្រាស់ជី កសិករយកជីអ៊ុយរេ ទៅលាយជាមួយនឹងថ្នាំកំចាត់ស្មៅ រួចបាញ់ជី និងថ្នាំកំចាត់ស្មៅក្នុងពេលជាមួយគ្នា។ ពួកគាត់ប្រើប្រាស់ជីអ៊ុយរេ ប្រមាណ១០គីឡូក្រាមក្នុងមួយហិចតា រួមនឹងថ្នាំកំចាត់ស្មៅ ២ ធុង ដែល១ធុងមានចំនុះ ១០ លីត្រ។

### ច.៤.ការប្រមូលផល

ក្រាហ្វិកទី៣.២០ : រដូវកាលប្រមូលផល




ប្រភព : វិភាគទិន្នន័យបឋម

កសិករអាចប្រមូលផលពីដំណាំដំឡូងមីបាន នៅពេលដែលវាអាយុពី ៨ ទៅ ១១ ខែ។ តាមការស្រាវជ្រាវនៅក្នុងតំបន់សិក្សា ៧៥% ការប្រមូលផលធ្វើឡើងនៅក្នុងខែកុម្ភៈ និង២៥% ផ្សេងទៀតធ្វើឡើងនៅក្នុងខែមករា។

### ច.៥ កត្តារាំង

ទោះបីជាភូមិដូនមាយមានសណ្ឋានដីជាតំបន់ភ្នំ ដែលអំណោយផលដល់កសិកម្មដំឡូងមីនេះដ៏ដោយ ប៉ុន្តែនៅតែមានឧបសគ្គរាំងខ្លះ ដែលអាចប៉ះពាល់ដល់ទិន្នផលដែរ ដែលក្នុងនោះកត្តារាំងដែលសំខាន់ៗមានចំនួនបី គឺ បញ្ហាស្មៅ កង្វះខាតប្រព័ន្ធធារាស្ត្រ និងអស្ថេរភាពថ្លៃនៃមើមដំឡូងមីនៅលើទីផ្សារ។ លើសពីនេះទៀត ភូមិដូនមាយកំពុងមានខ្វះខាតកំលាំងពលកម្ម ដោយសារយុវជនមួយចំនួនបានធ្វើចំណាកស្រុកទៅប្រទេសថៃ បញ្ហាប្រភពដើមទុនសម្រាប់ទ្រទ្រង់លើចំណាយប្រតិបត្តិការ និងឡើងថ្លៃនៃសម្ភារ ជី និងថ្នាំកំចាត់ស្មៅលើទីផ្សារ។

ក្រាហ្វិកទី៣.២១ : ប្រភពទុនទ្រទ្រង់ចំណាយប្រតិបត្តិការ




ប្រភព : វិភាគទិន្នន័យបឋម

កសិករ ៣៥% មានកង្វះខាតដើមទុនសម្រាប់ប្រើប្រាស់ជាទុនបង្វិល ហើយធ្វើការខ្ចីនូវឥណទានពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ ដែលមានការប្រាក់ជាមធ្យម ១.៥០% ក្នុងមួយខែ។

ក្រៅពីកត្តារាំងខាងលើ កសិករធ្លាប់បានជួបប្រទះនូបញ្ហាមួយចំនួនទៀតដូចជា ជំងឺស្លឹកលឿង និងចៃលើដើមដំឡូងមី។ ក្នុងករណីនេះកសិករប្រើប្រាស់ថ្នាំកំចាត់សត្វល្អិត និងដកដើមដែលមានជំងឺស្លឹកលឿងទាំងនោះចេញ ដើម្បីកុំឲ្យឆ្លងដល់ដើមដទៃទៀត។ ប៉ុន្តែបញ្ហានេះកំនឹងកើតមានឡើងណាស់ ព្រោះកសិករប្រើប្រាស់វិធីត្រាំពូជក្នុងទឹក ឬ ទឹកអរម៉ូនលាយនឹងថ្នាំកំចាត់សត្វល្អិតមុនពេលដាំ បានធ្វើឲ្យដើមរបស់វាធន់នឹងជំងឺ ដែលនាំឲ្យជំងឺស្លឹកលឿងមិនអាចរាតត្បាតឆ្លងពីដើមមួយ ទៅដើមមួយបាន ហើយបញ្ហាសត្វកកេរ និងសត្វល្អក៏មិនសូវកើតឡើងដែរ។

កត្តាជាកង្វល់ធំបំផុតរបស់កសិករនោះគឺ ការធ្លាក់ចុះនៃតម្លៃមើមដំឡូងមីនៅលើទីផ្សារ ដែលអាចប៉ះពាល់ដល់កម្រិតប្រាក់ចំណូលរបស់ពួកគាត់។ តម្លៃមើមដំឡូងស្រស់អាចនឹងធ្លាក់ចុះក្រោម ១០០ រៀលក្នុងមួយគីឡូក្រាមនៅក្នុងរដូវកំពុងប្រមូលផល ហើយតម្លៃនៅលើទីផ្សារអាចនឹងកើនឡើងវិញដល់ ៤០០ ទៅ ៤៥០ រៀល ក្នុងមួយគីឡូក្រាមក្នុងរយៈពេលប្រមាណបីខែបន្ទាប់។ យ៉ាងណាមិញកសិករតែងតែលក់មើមដំឡូងភ្លាមៗនៅរដូវប្រមូលផលខែមករា និងកុម្ភៈ ព្រោះពួកគាត់ត្រូវសាច់ប្រាក់ដើម្បីសងប្រាក់កម្ចី ទិញសម្ភារៈប្រើប្រាស់ និងមិនចង់ទទួលហានិភ័យនៃការសម្ងួតមើមដំឡូងមី។

## ធ ប្រសិទ្ធភាពសេដ្ឋកិច្ចកសិកម្មដំឡូងមី

### ធ.១.ការចំណាយលើផលិតកម្មកសិកម្មដំឡូងមី

ការវិភាគចំណាយផលិតកម្មដំឡូងមីក្នុងតំបន់សិក្សាត្រូវបានបែងចែកជាពីរក្រុមគឺ កសិករដែលលក់មើមដំឡូងមីស្រស់ និងស្ងួត។ ចំណាយចាប់ពីការជួលដីប្រើប្រាស់ រហូតដល់ការកាប់ដើមប្រើមូលផលគឺដូចគ្នា តែកសិករលក់មើមដំឡូងស្ងួតត្រូវចំណាយបន្ថែមលើការការសម្ងួតមើមបន្ថែមទៀត។ ការចំណាយផលិតកម្មរបស់កសិករដំឡូងមីដែលលក់មើមស្រស់ជាមធ្យម គឺ ៤.៣០៤.២៣៩ រៀលក្នុងមួយហិចតា។ រីឯការចំណាយផលិតកម្មរបស់កសិករដំឡូងមី ដែលលក់មើមស្ងួតវិញ គឺ ៧.៥៩៨,៦៣២។

**តារាងទី៣.១៣ : សង្ខេបចំណាយមធ្យមរបស់លើផលិតកម្មដំឡូងមីលក់មើមស្រស់**

| ល.រ | ប្រភេទនៃការចំណាយ | ចំណាយ /ផលិតកម្ម (៛) មធ្យម | គំលាតស្តង់ដារនៃចំណាយផលិតកម្ម (៛) |
|---|---|---|---|
| ១ | ថ្លៃជួលដីប្រើប្រាស់ | ៧៥០.០០០ | ១១០.០២៤ |
| ២ | ការរៀបចំដី និងភ្ជួរ | ៧៦០.០០០ | ៩៤.០៣២ |
| ៣ | ពូជសម្រាប់ដាំដុះ | ៨៣៧.៥០០ | ១២៥.៥២៥ |
| ៤ | បម្រើបម្រាស់ដី | ២៧,១៦៥ | ៤២.៥៩៧ |
| ៥ | ថ្នាំកំចាត់ស្មៅ | ៣១២.៨០០ | ៦៣.៩៤២ |
| ៦ | សេវាកំចាត់ស្មៅ | ៧៩៤.០០០ | ១៦៦.៥៨៨ |
| ៧ | កាប់ដើមពេលប្រមូលផល | ១៦៤.៥០០ | ៥៧.៤០០ |
| ៨ | ការប្រាក់កម្ចី | ៦៥៦.២៧៤ | ៩១.១៧៧ |
| ចំណាយផលិតកម្មសរុប | | ៤.៣០៤.២៣៩ | ៥០៦.៥៣៩ |

ប្រភព : វិភាគទិន្នន័យបឋម

**តារាងទី៣.១៤ : សង្ខេបចំណាយមធ្យមរបស់លើផលិតកម្មដំឡូងមីលក់មើមស្រស់**

| ល.រ | ប្រភេទនៃការចំណាយ | ចំណាយ /ផលិតកម្ម (៛)(មធ្យម) | គំលាតស្តង់ដារនៃចំណាយផលិតកម្ម (៛) |
|---|---|---|---|
| ១ | ថ្លៃជួលដីប្រើប្រាស់ | ៧៥០.០០០ | ១១០.០២៤ |
| ២ | ការរៀបចំដី និងភ្ជួរ | ៧៦០.០០០ | ៩៤.០៣២ |
| ៣ | ពូជសម្រាប់ដាំដុះ | ៨៣៧.៥០០ | ១២៥.៥២៥ |
| ៤ | បម្រើបម្រាស់ដី | ២៧,១៦៥ | ៤២.៥៩៧ |
| ៥ | ថ្នាំកំចាត់ស្មៅ | ៣១២.៨០០ | ៦៣.៩៤២ |
| ៦ | សេវាកំចាត់ស្មៅ | ៧៩៤.០០០ | ១៦៦.៥៨៨ |
| ៧ | កាប់ដើមពេលប្រមូលផល | ១៦៤.៥០០ | ៥៧.៤០០ |
| ៨ | ប្រមូលមើម | ១.២១០.០០០ | ៦២.៤៥០ |
| ៩ | ជញ្ជាំមើម | ១.២១០.០០០ | ៦២.៤៥០ |
| ១០ | សម្ងួតមើម | ៨០៦.៦៦៧ | ៤១.៦៣៣ |
| ១១ | ដឹកជញ្ជូន | ៧២៦.០០០ | ៣៧.៤៧០ |
| ១២ | ការប្រាក់កម្ចី | ១.៣៦៧.៧៥០ | ១០.៦២២ |
| ចំណាយផលិតកម្មសរុប | | ៨.៩៦៦.៣៨៦ | ៥៩.០១៣ |

ប្រភព : វិភាគទិន្នន័យបឋម

តារាងទី ៤.១: បង្ហាញពី GDPជាមធ្យម នៅក្នុងស្រុកសម្រាប់មនុស្សម្នាក់ពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ២០១៩

ការបង្ហាញផលិតផលក្នុងស្រុកសរុប ចាប់ពីឆ្នាំ ១៩៩៣ គឺ ១០.១៤ ពាន់លានរៀលហើយមានការកើនឡើង ១០៦.៧៨ ពាន់លានរៀលនៅក្នុងឆ្នាំ ២០១៩ ។ ចំណែកឯ ផលិតផលក្នុស្រុកសរុប គឺ ២.៧៣ លានដុល្លាអាមេរិកនៅឆ្នាំ ១៩៩៣ នឹងកើន ឡើងដល់ ២៦ .២៥លានដុល្លារអាមេរិកនៅក្នុងឆ្នាំ ២០១៩ ហើយ ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ គឺ ២៣៧ ដុល្លារអាមេរិក នៅឆ្នាំ ១៩៩៣ នឹង១.៦៣ ដុល្លារអាមេរិក នៅឆ្នាំ ២០១៩ ចំណែក ចំណាយក្នុងគ្រួសារទទួលបាន ៨១.៩ នៅឆ្នាំ ១៩៩៣នឹងកើនឡើងដល់ ៩៨.៨១ នៅឆ្នាំ ២០១៩, ចំណាយក្នុងមនុស្សម្នាក់HFCE នៅឆ្នាំ ១៩៩៣ គឺ ៨៣៨ ពាន់លានរៀល នឹង ឆ្នាំ២០១៩ គឺ ១៣.៥ ពាន់លានរៀលរីឯ ចំណាយក្នុងមនុស្សម្នាក់ នៅឆ្នាំ ១៩៩៣ គឺ ៣២.៧០ ពាន់លានរៀល/ខែ នឹងកើនឡើងដល់ ពាន់លានរៀល/ខែនៅឆ្នាំ២០១៩ ។

| ឆ្នាំ | ផលិតផលក្នុងស្រុកសរុបគិតជាពាន់លានរៀល | ផលិតផលក្នុងស្រុកសរុបគិតជាលានដុល្លារអាមេរិក | ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់គិតជាដុល្លារអាមេរិក | ចំណាយក្នុងគ្រួសារ | ចំណាយក្នុងមនុស្សម្នាក់(ពាន់លានរៀល) | ចំណាយក្នុងមនុស្សម្នាក់(ពាន់លានរៀល) |
|---|---|---|---|---|---|---|
| ១៩៩៣ | ១០.១៤ | ២.៧៣ | ២៣៧.០០ | ៩.៨១ | ៨៣៨.០០ | ៧០.៣២ |
| ១៩៩៤ | ១០.៤៦ | ២.៨១ | ២៤០.០០ | ១០.០៣ | ៨៥០.០០ | ៧១.១៦ |
| ១៩៩៥ | ១០.៧៧ | ២.៨៨ | ២៤៤.០០ | ១០.២៤ | ៨៦១.០០ | ៧២ |
| ១៩៩៦ | ១១.០៩ | ២.៩៦ | ២៤៨.០០ | ១០.៤៦ | ៨៧២.០០ | ៧២.៨៤ |
| ១៩៩៧ | ១១.៤១ | ៣.០៣ | ២៥១.០០ | ១០.៦៧ | ៨៨៣.០០ | ៧៣.៦៨ |
| ១៩៩៨ | ១១.៧២ | ៣.១១ | ២៥៥.០០ | ១០.៨៩ | ៨៩៤.០០ | ៧៤.៥២ |
| ១៩៩៩ | ១៣.៣៨ | ៣.៥១ | ២៨៦.០០ | ១១.៧៣ | ៩៥៥.០០ | ៧៩.៦២ |
| ២០០០ | ១៤.០៨ | ៣.៦៥ | ២៩៥.០០ | ១២.២១ | ៩៨៦.០០ | ៨២.១៦ |
| ២០០១ | ១៥.៦៣ | ៣.៩៨ | ៣១៩.០០ | ១២.៩៥ | ១.០៤ | ៨៦.៣៩ |
| ២០០២ | ១៦.៧៨ | ៤.២៨ | ៣៤០.០០ | ១៣.៧២ | ១.០៩ | ៩០.៧១ |
| ២០០៣ | ១៨.៥៤ | ៤.៦៦ | ៣៦៧.០០ | ១៥.០៦ | ១.១៩ | ៩៨.៧៥ |
| ២០០៤ | ២១.៤៤ | ៥.៣៤ | ៤១៧.០០ | ១៧.៧៥ | ១.៣៩ | ១១៥.៤២ |
| ២០០៥ | ២៥.៧៥ | ៦.២៩ | ៤៨៧.០០ | ២១.១០ | ១.៦៣ | ១៣៦.០៣ |
| ២០០៦ | ២៩.៨៥ | ៧.២៨ | ៥៥៨.០០ | ២៣.៥០ | ១.៨០ | ១៥០.១៨ |
| ២០០៧ | ៣៥.០៤ | ៨.៦៣ | ៦៥៦.០០ | ២៦.៦៣ | ២.០៣ | ១៦៨.៧១ |
| ២០០៨ | ៤១.៩៧ | ១០.៣៤ | ៧៦០.០០ | ៣២.៥១ | ២.៣៩ | ១៩៩.១៩ |
| ២០០៩ | ៤៣.០៦ | ១០.៤០ | ៧៥៣.០០ | ៣១.៨៧ | ២.៣១ | ១៩២.៣២ |
| ២០១០ | ៤៧.០៥ | ១១.៦៣ | ៨៣០.០០ | ៣៧.២៦ | ២.៦៦ | ២២១.៤០ |
| ២០១១ | ៥២.០៧ | ១២.៩៧ | ៩១១.០០ | ៤២.០៥ | ២.៩៦ | ២៤៦.៣០ |
| ២០១២ | ៥៦.៦៨ | ១៤.០៥ | ៩៧៣.០០ | ៤៥.៨២ | ៣.១៧ | ២៦៤.២០ |
| ២០១៣ | ៦១.៣៣ | ១៥.២៣ | ១.០៤ | ៤៩.៩៣ | ៣.៤២ | ២៨៤.៦៣ |
| ២០១៤ | ៦៧.៤៤ | ១៦.៧៣ | ១.១៣ | ៥៤.៤០ | ៣.៦៨ | ៣០៦.៤១ |
| ២០១៥ | ៧៣.៤២ | ១៨.២៤ | ១.២២ | ៥៩.២៨ | ៣.៩៦ | ៣២៩.៨៧ |
| ២០១៦ | ៨១.២៤ | ២០.១៦ | ១.៣៣ | ៦៤.៦០ | ៤.២៦ | ៣៥៥.១៣ |
| ២០១៧ | ៨៩.៧៥ | ២២.១៩ | ១.៤៣ | ៧០.៣៩ | ៤.៥៣ | ៣៧៧.៧៩ |
| ២០១៨ | ៩៨.២៧ | ២៤.២២ | ១.៥៣ | ៧៦.១៨ | ៤.៨៣ | ៤០០.៤៥ |
| ២០១៩ | ១០៦.៧៨ | ២៦.២៥ | ១.៦៣ | ៨១.៩៨ | ៥.១៣ | ៤២៣.១១ |
| TOTAL | ៤៧៣.៤៦ | ៩.៩១ | ៣៤៩.៤៩ | ៣១.៩៦ | ២៦៦.៣៩ | ១៨៦.៧៩ |

**តារាងទី ៣.១៥ : បង្ហាញពី GDP នឹងតម្លៃមធ្យម តម្លៃអប្បបរមា នឹងតម្លៃអតិបរមា**

តារាងទី៣.១៦ ខាងក្រោមបង្ហាញពី ផលិតផលក្នុងស្រុកសរុប ដែលមានតម្លៃមធ្យមគឺ ៤៦.៤៧៣ ពាន់លានរៀល ហើយ តម្លៃអប្ប បរមាគឺ ១៤.១០ ពាន់លានរៀល នឹង តម្លៃអតិបរមា គឺ ១១៧២០ ពាន់

លានរៀល ចំណែកឯ ផលិតផលក្នុងស្រុកសរុប បង្ហាញពីតម្លៃ មធ្យមគឺ ៩១.៩លានដុល្លារអាមេរិក តម្លៃអប្បបរមា គឺ៧៣.២លានដុល្លារអាមេរិកនឹងតម្លៃអតិបរមា គឺ២៥.២៦លានដុល្លារអាមេរិក រីឯ ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ ដុល្លារអាមេរិកបានបង្ហាញតម្លៃមធ្យម គឺ៤៩.៣៤៩ដុល្លារអាមេរិក ហើយតម្លៃអប្បបរមា គឺ ០៤.១ដុល្លារអាមេរិកនឹង តម្លៃអតិបរមា ៩៧៣ ដុល្លារអាមេរិកក្នុងកម្រិត ចំនួន ២៧ ។

ម្យ៉ាងវិញទៀត នៅក្នុងចំណុច ចំណាយក្នុងគ្រួសារបានបង្ហាញពីតម្លៃមធ្យម ៩៦.១៣ ហើយតម្លៃអប្ប បរមា ៨១.៩ នឹង តម្លៃអតិបរមា គឺ ៩៨.៨១ ហើយត្រង់ចំណុច ចំណាយក្នុងមនុស្សម្នាក់ តម្លៃមធ្យមគឺ ៣៩.២៦៦ ពាន់លានរៀល តម្លៃអប្បបរមា ០៤.១ ពាន់លានរៀល នឹងតម្លៃអតិបរមា ៩៨៦ ពាន់លានរៀល ចំណែកឯ ចំណាយក្នុងមនុស្សម្នាក់ មានតម្លៃមធ្យមគឺ ៧៩.១៨៦ ពាន់លានរៀល ហើយតម្លៃអប្បបរមា ៣២.៧០ ពាន់លានរៀល នឹងតម្លៃអតិបរមាគឺ ១១.៤២៣ ពាន់លានរៀល ក្នុងកម្រិត ចំនួន ២៧ ដូចៗគ្នា ។

**តារាង៣.១៦ផលិតផលក្នុងស្រុកសរុប**

| ពណ៌នា | តម្លៃមធ្យម | តម្លៃអប្បបរមា | តម្លៃអតិបរមា | ចំនួន |
|---|---|---|---|---|
| ផលិតផលក្នុងស្រុកសរុបគិតជាពាន់លានរៀល | ៤៧៣.៤៦ | ១០.១៤ | ១១៧២០.០០ | ២៧ |
| ផលិតផលក្នុងស្រុកសរុបគិតជាលានដុល្លារអាមេរិក | ៩.៩១ | ២.៧៣ | ២៦.២៥ | ២៧ |
| ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់គិតជាដុល្លារអាមេរិក | ៣៤៩.៤៩ | ១.០៤ | ៩៧៣.០០ | ២៧ |
| ចំណាយក្នុងគ្រួសារ(HFCE) | ៣១.៩៦ | ៩.៨១ | ៨១.៩៨ | ២៧ |
| ចំណាយក្នុងមនុស្សម្នាក់HFCE ពាន់លានរៀល | ២៦៦.៣៩ | ១.០៤ | ៩៨៦.០០ | ២៧ |
| ចំណាយក្នុងមនុស្សម្នាក់HFCE ពាន់លានរៀល | ១៨៦.៧៩ | ៧០.៣២ | ៤២៣.១១ | ២៧ |
| សរុប | ២១៩.៦៧ | ១.០០ | ១១៧២០.០០ | |

ប្រភព៖ វិភាគទិន្នន័យបឋម

### ឆ.២ ចំណូលពីផលិតកម្មដំឡូងមី

កសិករនៅភូមិដូនមាយមានផ្ទៃដីដាំដំឡូងមីជាមធ្យម ២,៦១ ហិចតាក្នុងមួយគ្រួសារ។ កសិករអាចផលិតបានមើមដំឡូងមីស្រស់បានទិន្នផលនៅចន្លោះពី ៣០ តោន ទៅ ៤២ តោន ដោយគិតជាមធ្យមស្មើនឹង៣៦,៥៨តោនក្នុងមួយហិចតា។ មើដំឡូងមីស្រស់នៅលើទីផ្សារមានតម្លៃ ១២០ រៀ ទៅ ២០០ រៀលក្នុងមួយគីឡូក្រាម និងមើមស្ងួតមានតម្លៃពី៤០០រៀល ទៅ ៨០០រៀលក្នុងមួយគីឡូក្រាម។

**ក្រាហ្វិកទី៣.២២ : ទិន្នផលដំណាំដំឡូងមីក្នុងមួយហិចតា**




ចំណូលពីការប្រមូលផលមានការប្រែប្រួល អាស្រ័យលើវិធីសាស្ត្រនៃការលក់មើមដំឡូងមីរបស់កសិករតែមួយគត់ ព្រោះកសិករមិនប្រើប្រាស់ស្លឹក និងដើមដំឡូងមីដែលខ្លួនមានសម្រាប់រកចំណូលបន្ថែមទេ ព្រោះទីផ្សារតំបន់សិក្សាពុំមានតម្រូវការ។ កសិករ ៨៥% លក់មើមដំឡូងស្រស់ក្នុងតម្លៃជាមធ្យម ១៧៥ រៀល ក្នុងមួយគីឡូក្រាម និងកសិករ ១៥% ផ្សេងទៀតលក់មើមដំឡូងមីស្ងួតក្នុងតម្លៃជាមធ្យម ៦៥០ រៀលក្នុងមួយគីឡូក្រាម។ មើមដំឡូងមីស្រស់១គីឡូក្រាមអាចសម្ងួតបានមើមដំឡូងមីស្ងួតបានជាមធ្យម ០,៦គីឡូក្រាម។ ដូចនេះ កសិករលក់មើមដំឡូងមីស្រស់ទទួលបានប្រាក់ចំណូលជាមធ្យម ៦.៤០០.៦២៥ រៀល ក្នុងមួយហិចតា និងកសិករលក់មើមដំឡូងស្ងួតទទួលបានចំណូលជាមធ្យម ១៤.២៦៤.២៥០ រៀលក្នុងមួយហិចតា។

### ក្រាហ្វិកទី៣.២៣.: ការលក់មើមដំឡូងមីរបស់កសិករ




ប្រភព : ទិន្នន័យវិភាគ

**តារាងទី ៣.១៧: បង្ហាញពីតម្លៃមធ្យម អប្បបរមា នឹងអតិបរមា នៃការប្រមូលផលពីឆ្នាំ១៩៩៣ ដល់ ឆ្នាំ២០១៩**

តាមតារាងទី ៤.១ បង្ហាញពី ផ្ទៃដីប្រមូលផល ដែលមាន ២ផ្នែក ដែលមាន ប្រមូលផលរដូវវស្សា នឹង ប្រមូលផលរដូវប្រាំង ។

សរុបមក យើងឃើញថា ផ្ទៃដីប្រមូលជាមធ្យម ៦៨,១៨៩ហើយ តម្លៃអប្បបរមា ២១,៨ ហិកតា នឹងតម្លៃអតិបរមាន សរុប ៨៣,៦១៨ ហិកតា ។ម្យ៉ាងវិញទៀត ទិន្នផលសរុប គិតជាតម្លៃមធ្យម ៩៩,១៣ តោន/ហិកតា ហើយ តម្លៃអប្បបរមា ២០,៥ តោន/ហិកតា នឹងតម្លៃអតិបរមា ៩០,២៥ តោន/ហិកតា

| ពណ៌នា | តម្លៃមធ្យម | តម្លៃអប្បបរមា | តម្លៃអតិបរមា |
|---|---|---|---|
| ប្រមូលផលរដូវវស្សា | ១៨០.៦៤ | ១២.៦៥ | ៦៨០.៤៨ |
| ប្រមូលផលរដូវប្រាំង | ១៩.៩៦ | ៨.៤៩ | ៥៦.៥៣ |
| ផ្ទៃដីប្រមូលផលសរុប (ហិកតា) | ១៨៩.៦៨ | ៨.២១ | ៦១៨.៨៣ |
| ទិន្នផលរដូវវស្សា | ១៦.៨៤ | ៥.៨០ | ២៦.២០ |
| ទិន្នផលរដូវប្រាំង | ១៤.៤២ | ៥.៦០ | ៣១.១០ |
| ទិន្នផលសរុប (តោន / ហិកតា) | ១៣.៩៩ | ៥.២០ | ២៥.៩០ |
| សរុប | ៧២.៥៩ | ៥ | ៦៨១ |

ប្រភព៖ ទិន្នវិភាគ Secondary Data

## តារាងទី៣.១៨ : បង្ហាញពីផ្ទៃដីប្រមូលផលមធ្យម នឹង ទិន្នផលនៃដំណាំដំឡូងមីមធ្យមពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ២០១៩

នៅក្នុងតារាងទី ៤.២ បានបង្ហាញអំពីផ្ទៃដីប្រមូលផលដែលកើនឡើងពី ៩.៨០ ហិកតា ក្នុងឆ្នាំ ១៩៩៣ ទៅ ៨៣.៦១៨ ហិកតា នៅក្នុងឆ្នាំ ២០១៩ ចំណែកឯ ទិន្នផលសរុបនៃការប្រមូលផល ក្នុងរដូវប្រាំង នឹងរដូវវស្សា កើនឡើងពី ២០.៥ តោន/ហិកតា ក្នុងឆ្នាំ ១៩៩៣ទៅ ៣០.២៣ តោន/ហិកតា នៅក្នុងឆ្នាំ ២០១៩ ។

| ឆ្នាំ | ប្រមូលផលរដូវវស្សា | ប្រមូលផលរដូវប្រាំង | ផ្ទៃដីប្រមូលផលសរុប (ហិកតា) | ទិន្នផលរដូវវស្សា | ទិន្នផលរដូវប្រាំង | ទិន្នផលសរុប (តោន / ហិកតា) |
|---|---|---|---|---|---|---|
| ១៩៩៣ | ១២.៦៥ | ៨.៤៩ | ៩.៨០ | ៥.៨០ | ៥.៦០ | ៥.២០ |
| ១៩៩៤ | ១៣.៦៥ | ៨.៧៩ | ១០.០០ | ៦.៧០ | ៦.១០ | ៦.៥០ |
| ១៩៩៥ | ១៣.៦៥ | ៩.០៨ | ១២.៤១ | ៧.៦០ | ៦.៧០ | ៦.៦០ |
| ១៩៩៦ | ១៣.៦៥ | ៩.៣៨ | ១៣.០០ | ៨.៥០ | ៧.២០ | ៥.៤០ |
| ១៩៩៧ | ១៣.៦៥ | ៩.៦៧ | ១០.០៦ | ៩.៥០ | ៧.៨០ | ៧.៧០ |
| ១៩៩៨ | ១៣.៦៥ | ៩.៩៦ | ៨.២១ | ១០.៤០ | ៨.៣០ | ៨.១០ |
| ១៩៩៩ | ១៣.៦៥ | ១០.២៦ | ១៤.០០ | ១១.៣០ | ៨.៩០ | ១៦.៣០ |
| ២០០០ | ១៣.៧០ | ១០.៥៥ | ១៥.៣៨ | ១២.២០ | ៩.៤០ | ៩.៦០ |
| ២០០១ | ១៣.៧០ | ១០.៨៥ | ១៣.៥៩ | ១៣.១០ | ១០.០០ | ១០.៥០ |
| ២០០២ | ១៣.៧០ | ១១.១៤ | ១៩.៥៦ | ១៤.០០ | ១០.៥០ | ៦.២០ |
| ២០០៣ | ១៣.៧០ | ១១.៤៣ | ២៥.៥៤ | ១៤.៩០ | ១១.១០ | ៧.០០ |
| ២០០៤ | ១៣.៧០ | ១១.៧៣ | ៣១.៥១ | ១៥.៨០ | ១១.៦០ | ៧.៨០ |
| ២០០៥ | ១៣.៧០ | ១២.០២ | ៣៧.៤៨ | ១៦.៧០ | ១២.២០ | ៨.៥០ |
| ២០០៦ | ១៣.៧០ | ១២.៣២ | ៤៣.៤៦ | ១៧.៦០ | ១២.៧០ | ៩.៣០ |
| ២០០៧ | ១៣.៧០ | ១២.៦១ | ៤៩.៤៣ | ១៨.៦០ | ១៣.៣០ | ១០.០០ |
| ២០០៨ | ១៣.៧០ | ១២.៩០ | ៥៥.៤០ | ១៩.៥០ | ១៣.៨០ | ១០.៨០ |
| ២០០៩ | ១៣.៧០ | ១៣.២០ | ៦១.៣៧ | ២០.៤០ | ១៤.៤០ | ១១.៥០ |
| ២០១០ | ១៨៤.៩៣ | ១៧.៥៧ | ២០២.៤៩ | ២១.៥០ | ១៥.៣០ | ២១.០០ |
| ២០១១ | ៣៤៤.០១ | ២៥.៥០ | ៣៦៩.៥២ | ២១.០០ | ៣១.១០ | ២១.៧០ |
| ២០១២ | ៣០៨.៦៩ | ២៩.១១ | ៣៣៧.៨០ | ២១.៩០ | ២៨.៩០ | ២២.៥០ |
| ២០១៣ | ៣៥១.៦៨ | ២៥.៥៦ | ៣៧៧.២៤ | ២១.៧០ | ១១.៨០ | ២១.០០ |
| ២០១៤ | ៤៧៣.៧៧ | ៤១.៥២ | ៥១៥.២៩ | ២៣.៥០ | ១៩.៨០ | ២៣.២០ |
| ២០១៥ | ៥១២.៥៧ | ៣៣.៨៣ | ៥៤៦.៤១ | ២៤.៤០ | ២៣.៧០ | ២៤.៣០ |
| ២០១៦ | ៥៥៤.៥៥ | ៣៤.១៣ | ៥៩២.៣៨ | ២៥.៣០ | ២៤.៣០ | ២៥.១០ |
| ២០១៧ | ៥៩៦.៥៣ | ៣៤.៤២ | ៥៩៨.៣៥ | ២៦.២០ | ២៤.៨០ | ២៥.៩០ |
| ២០១៨ | ៦៣៨.៥១ | ៥៦.២៤ | ៦១២.៨៦ | ២២.៨០ | ១៩.៨០ | ២២.៦០ |
| ២០១៩ | ៦៨០.៤៨ | ៥៦.៥៣ | ៦១៨.៨៣ | ២៣.៧០ | ២០.៣០ | ២៣.៣០ |
| TOTAL | ១៨០.៦៤ | ១៩.៩៦ | ១៨៩.៦៨ | ១៦.៨៤ | ១៤.៤២ | ១៣.៩៩ |

## តារាងទី៣.១៩៖ ភាគរយនៃផ្ទៃដីប្រមូលផលជំឡូងមីក្នុងរដូវវស្សាគិតជាហិកតា

ប្រមូលផលរដូវវស្សា

មធ្យម = ១៨០.៦៤ គម្លាតគំរូ = ២៤១.៣៩

| ប្រមូលផលរដូវវស្សា | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង១២៤ | ១៧ | ៦៣.០០% |
| ពី ១២៤ ទៅ ២៣៥ | ១ | ៣.៧០% |
| ពី ២៣៥ ទៅ ៣៤៧ | ២ | ៧.៤០% |
| ពី ៣៤៧ ទៅ ៤៥៨ | ១ | ៣.៧០% |
| ពី ៤៥៨ ទៅ ៥៦៩ | ៣ | ១១.១០% |
| ពី ៥៦៩ប ទៅ ៦៨១ | ២ | ៧.៤០% |
| ច្រើនជាង៦៨១ | ១ | ៣.៧០% |
| សរុប | ២៧ | ១០០% |




ក្រាភិច៣.២៥ផ្ទៃដីប្រមូលផលជំឡូងមីដែលបានគិតជាភាគរយនៅក្នុងរដូវវស្សា

យោងតាមរូបភាពទី៣.២៥៖បង្ហាញឲ្យឃើញអំពីផ្ទៃដីប្រមូលផលជំឡូងមីដែលបានគិតជាភាគរយ នៅក្នុងរដូវវស្សា។ ក្នុងការវិភាគទិន្នន័យខាងលើនេះ គឺតម្លៃគិតជាមធ្យមចំនួន ១៨០.៦៤ ហិកតា និងកម្រិតលំអៀត Std deviation ចំនួន ២៤១.៣៩ ដែលត្រូវបានយកមកធ្វើការប្រៀបធៀប។

### តារាងទី៣.២០៖ ភាគរយនៃផ្ទៃដីប្រមូលផលជំឡូងមីក្នុងរដូវប្រាំងគិតជាហិកតា

ប្រមូលផលរដូវប្រាំង

មធ្យម = ១៩.៩៦ គម្លាតគំរូ = ១៤.៣០

| ប្រមូលផលរដូវប្រាំង | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង១៦.៥០ | ១៧ | ៦៣.០០% |
| ពី ១៦.៥០ ទៅ ២៤.៥១ | ១ | ៣.៧០% |
| ពី ២៤.៥១ ទៅ ៣២.៥១ | ៣ | ១១.១០% |
| ពី ៣២.៥១ ទៅ ៤០.៥២ | ៣ | ១១.១០% |
| ពី ៤០.៥២ ទៅ ៤៣.៥៣ | ១ | ៣.៧០% |
| ពី ៤៨.៥៣ ទៅ ៥៦.៥៣ | ១ | ៣.៧០% |
| ច្រើនជាង ៥៦.៥៣ | ១ | ៣.៧០% |
| សរុប | ២៧ | ១០០% |




**ក្រាភិច ៣.២៦ផ្ទៃដីប្រមូលផលជំឡូងមីដែលបានគិតជាភាគរយ នៅក្នុងរដូវប្រាំង**

យោងតាមរូបភាពទី២៖ បង្ហាញឲ្យឃើញអំពី ផ្ទៃដីប្រមូលផលជំឡូងមីដែលបានគិតជាភាគរយ នៅក្នុងរដូវប្រាំង។ ក្នុងការវិភាគទិន្នន័យខាងលើនេះ គឺតម្លៃគិតជាមធ្យមចំនួន ១៩.៩៦ ហិកតា និងកម្រិតលំអៀត Std deviationចំនួន ១៤.៣០ ដែលត្រូវបានយកមកធ្វើការប្រៀបធៀប។

**តារាងទី៣.២១៖ ភាគរយនៃផ្ទៃដីប្រមូលផលដំឡូងមីសរុបទាំងពីររដូវគិតជាហិកតា**

ផ្ទៃដីប្រមូលផលសរុប (ហិកតា)

មធ្យម = ១៨៩.៦៨ គម្លាតគំរូ = ២៣៣.៥៣

| ផ្ទៃដីប្រមូលផលសរុប (ហិកតា) | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង១១០ | ១៧ | ៦៣.០០% |
| ពី ១១០ ទៅ ២១២ | ១ | ៣.៧០% |
| ពី ២១២ ទៅ ៣១៤ | ០ | ០.០០% |
| ពី ៣១៤ ទៅ ៤១៥ | ៣ | ១១.១០% |
| ពី ៤១៥ ទៅ ៥១៧ | ១ | ៣.៧០% |
| ពី ៥១៧ ទៅ ៦១៩ | ៤ | ១៤.៨០% |
| ច្រើនជាង ៦១៩ | ១ | ៣.៧០% |
| សរុប | ២៧ | ១០០% |




**ក្រាភិច៣.២៧ផ្ទៃដីប្រមូលផលដំឡូងមីដែលបានគិតជាភាគរយ នៅសរុបទាំងអស់ ទាំងរដូវប្រាំង និងរដូវវស្សា**

យោងតាមរូបភាពទី៣៖ បង្ហាញឲ្យឃើញអំពី ផ្ទៃដីប្រមូលផលដំឡូងមីដែលបានគិតជាភាគរយ នៅសរុបទាំងអស់ ទាំងរដូវប្រាំង និងរដូវវស្សា។ ក្នុងការវិភាគទិន្នន័យខាងលើនេះ គឺតម្លៃគិតជាមធ្យមចំនួន ១៨៩.៦៨ ហិកតា និងកម្រិតលំអៀត Std deviationចំនួន ២៣៣.៥៣ ដែលត្រូវបានយកមកធ្វើការប្រៀបធៀប។

## តារាងទី៣.២២៖ ភាគរយនៃទិន្នផលដំឡូងមីក្នុងរដូវវស្សាគិតជាតោក្នុងមួយហិកតា

ទិន្នផលរដូវវស្សា

មធ្យម = ១៦.៨៤ គម្លាតគំរូ = ៦.២៣

| ទិន្នផលរដូវវស្សា | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង៩.២០ | ៤ | ១៤.៨០% |
| ពី ៩.២០ ទៅ ១២.៦០ | ៤ | ១៤.៨០% |
| ពី ១២.៦០ ទៅ ១៦.០០ | ៤ | ១៤.៨០% |
| ពី ១៦.០០ ទៅ ១៩.៤០ | ៣ | ១១.១០% |
| ពី ១៩.៤០ ទៅ ២២.៨០ | ៦ | ២២.២០% |
| ពី ២២.៨០ ទៅ ២៦.២០ | ៥ | ១៨.៥០% |
| ច្រើនជាង ២៦.២០ | ១ | ៣.៧០% |
| សរុប | ២៧ | ១០០% |




**ក្រាភិច៣.២៨ទិន្នផលដំឡូងមីដែលបានគិតជាភាគរយ នៅក្នុងរដូវវស្សា**

យោងតាមរូបភាពទី៤៖ បង្ហាញឲ្យឃើញអំពីទិន្នផលដំឡូងមីដែលបានគិតជាភាគរយ នៅក្នុងរដូវវស្សា។ ក្នុងការវិភាគទិន្នន័យខាងលើនេះ គឺតម្លៃគិតជាមធ្យមចំនួន ១៦.៨៤ត/ហ.ត និងកម្រិតលំអៀត Std deviationចំនួន ៦.២៣ ដែលត្រូវបានយកមកធ្វើការប្រៀបធៀប។

**ក្រាភិចទី៣.២៣៖ ភាគរយនៃទិន្នផលជំឡូងមីក្នុងរដូវប្រាំងគិតជាតោក្នុងមួយហិកតា**

ទិន្នផលរដូវប្រាំង

មធ្យម = ១៤.៤២ គម្លាតគំរូ = ៧.១៨

| ទិន្នផលរដូវប្រាំង | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង១០ | ៨ | ២៩.៦០% |
| ពី ១០ ទៅ ១៤ | ៩ | ៣៣.៣០% |
| ពី ១៤ ទៅ ១៨ | ២ | ៧.៤០% |
| ពី ១៨ ទៅ ២៣ | ៣ | ១១.១០% |
| ពី ២៣ ទៅ ២៧ | ៣ | ១១.១០% |
| ពី ២៧ ទៅ ៣១ | ១ | ៣.៧០% |
| ច្រើនជាង ៣១ | ១ | ៣.៧០% |
| សរុប | ២៧ | ១០០% |




**ក្រាភិច៣.២៩ទិន្នផលជំឡូងមីដែលបានគិតជាភាគរយ នៅក្នុងរដូវប្រាំង**

យោងតាមរូបភាពទី៥៖ បង្ហាញឲ្យឃើញអំពី ទិន្នផលជំឡូងមីដែលបានគិតជាភាគរយ នៅក្នុងរដូវប្រាំង។ ក្នុងការវិភាគទិន្នន័យខាងលើនេះ គឺតម្លៃគិតជាមធ្យមចំនួន ១៤.៤២ត/ហ.ត និងកម្រិតលំអៀត Std deviationចំនួន ៧.១៨ ដែលត្រូវបានយកមកធ្វើការប្រៀបធៀប។

**តារាងទី៣.២៤៖ ភាគរយនៃទិន្នផលជំឡូងមីសរុបទាំងពីររដូវ( គិតជាតោក្នុងមួយហិកតា)**

ទិន្នផលសរុប (តោន / ហិកតា

មធ្យម = ១៣.៩៩ គម្លាតគំរូ = ៧.៤៧

| ទិន្នផលសរុប (តោន / ហិកតា | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង៩ | ១០ | ៣៧.00% |
| ពី ៩ ទៅ ១២ | ៦ | ២២.២0% |
| ពី ១២ ទៅ ១៦ | 0 | 0.00% |
| ពី ១៦ ទៅ ១៩ | ១ | ៣.៧0% |
| ពី ១៩ ទៅ ២៣ | ៣ | ១១.១0% |
| ពី ២៣ ទៅ ២៦ | ៦ | ២២.២0% |
| ច្រើនជាង២៦ | ១ | ៣.៧0% |
| សរុប | ២៧ | ១00% |

ប្រភព៖ ទិន្នវិភាគ Secondary Data




**ក្រាភិច៣.៣០ទិន្នផលជំឡូងមីដែលបានគិតជាភាគរយសរុបទាំងពីររដូវ)រដូវប្រាំង និងរដូវវស្សា**

យោងតាមរូបភាពទី៦៖ បង្ហាញឲ្យឃើញអំពី ទិន្នផលជំឡូងមីដែលបានគិតជាភាគរយសរុបទាំងពីររដូវ)រដូវប្រាំង និងរដូវវស្សា(។ ក្នុងការវិភាគទិន្នន័យខាងលើនេះ គឺតម្លៃគិតជាមធ្យមចំនួន ១៣.៩៩ត/ហ.ត និងកម្រិតលំអៀត Std deviationចំនួន ៧.៤៧ ដែលត្រូវបានយកមកធ្វើការប្រៀបធៀប។

### ៣.២.៤.កៅស៊ូ

អនុវិស័យកសិកម្មទីពីររបស់ប្រទេសកម្ពុជាគឺដំណាំកៅស៊ូ។ ប្រទេសកម្ពុជាមានលក្ខខណ្ឌអំណោយផលសម្រាប់ដំណាំកៅស៊ូ។ ដូចច្នេះហើយបានជាចាប់តាំងពីទស្សវត្សន៍ទី៥០ និង៦០ ផ្ទៃដីដំណាំកៅស៊ូត្រូវបានពង្រីកជាបន្តបន្ទាប់ ហើយរហូតដល់ឆ្នាំ ១៩៧០ បានឈានដល់៧០.០០០ហិកតា ក្នុងនោះ៤៧.៥០០ហិកតា ជាផ្ទៃដីប្រមូលផល និងបរិមាណផលិតកៅស៊ូក្រែបមានចំនួន ៥០.០០០តោនក្នុងមួយឆ្នាំ។ ចំពោះចម្ការកៅស៊ូជាលក្ខណៈគ្រួសារនៅឆ្នាំ១៩៦៨ មាន១៣.០០០ហិកតា។ នៅសម័យកាលនោះ ផ្ទៃដីដាំកៅស៊ូរបស់ប្រទេសកម្ពុជា ស្មើនឹង ២.៣% នៃដីកសិកម្មសរុប និងមានតម្លៃ ៧.៦% នៃតម្លៃផលិតផលកសិកម្មសរុប និងជាផលិតផលដ៏សំខាន់សម្រាប់ការនាំចេញ។ ដំណាំកៅស៊ូប្រហែល៩២% ត្រូវបានដាំដុះនៅក្នុងចម្ការធំៗនៃខេត្តកំពង់ចាម និងខេត្តក្រចេះ។ តាមការវាយតម្លៃនៅខេត្តរតនគិរី គឺមានផ្ទៃដីប្រមាណ ១៥០.០០០ហិកតា ដែលមានលក្ខណៈអំណោយផលសម្រាប់ដំណាំកៅស៊ូ ប៉ុន្តែនៅទីនោះ គឺមានបញ្ហាស្មុគស្មាញជាច្រើន សម្រាប់ការអភិវឌ្ឍដំណាំកសិឧស្សាហកម្មបែបនេះ ពេលគឺទាក់ទងនឹងកង្វះកម្លាំងពលកម្ម (ព្រោះដង់ស៊ីតេប្រជាជនទាប) បញ្ហាជំងឺគ្រុនចាញ់និងការចំណាយខ្ពស់លើមធ្យោបាយដឹកជញ្ជូន ប៉ុន្តែបញ្ហាទាំងនេះអាចដោះស្រាយបានប្រសិនបើមានការគ្រប់គ្រងប្រកបដោយសមត្ថភាព។

ផលិតផលផលិតកម្មកៅស៊ូនៅប្រទេសកម្ពុជា ជាទូទៅដើម្បីបម្រើឲ្យទិសដៅសម្រាប់ការនាំចេញដែលនៅសម័យកាលនោះ ការនាំចេញជ័រកៅស៊ូទទួលបានចំណាត់ថ្នាក់លេខមួយ ក្នុងចំណោមការនាំចេញសរុប។ ដើម្បីកាត់បន្ថយការចំណាយលើការដឹកជញ្ជូនទឹកជ័រកៅស៊ូ រដ្ឋាភិបាលបានសាងសង់រោងចក្រកែច្នៃទឹកជ័រនៅក្បែរមូលដ្ឋានចម្ការកៅស៊ូធំៗតែម្តង។

ចំពោះសេចក្តីត្រូវការ សម្រាប់ផលិតកម្មក្នុងស្រុក យើងឃើញថាប្រហែលមួយជិត ១.១%ទៅ៣%នៃជ័រកៅស៊ូ ត្រូវបានផ្គត់ផ្គង់ឲ្យសហគ្រាសក្នុងស្រុកសម្រាប់ជាវត្ថុធាតុដើម។ រោងចក្រផលិតកង់រថយន្តនៅតាខ្មៅក្នុងមួយឆ្នាំៗ ផលិតសម្បកកង់រថយន្តបាន២០.០០០គ្រាប់ ផលិតផលិតសម្បកទោចក្រយានយន្ត បាន១២.០០០គ្រាប់ សម្បកទោចក្រយានបាន ២០០.០០០គ្រាប់ ផលិតទុយោជ័របាន៤០.០០០ម៉ែត្រ ផលិតស្បែកជើងផ្ទាត់ និងផលិតរបស់របរប្រើប្រាស់ផ្សេងៗទៀត។ ដោយឡែក ចំពោះដើមកៅស៊ូវិញ គឺជាមុខទំនិញនាំចេញដ៏សំខាន់មួយទៀត ដើមកៅស៊ូគេអាចប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតគ្រឿងសង្ហារឹមយ៉ាងប្រណីតសម្រាប់ការនាំចេញប្តូរយករូបិយប័ណ្ណផងដែរ។

នៅខែមិថុនា ឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានចាប់ផ្តើមដំបូងគេលើកិច្ចស្តារឡើងវិញ នៅចម្ការកៅស៊ូដែលធ្លាប់មានពីសម័យមុនៗមក។ នៅឆ្នាំដំបូងនេះរដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនចម្ការកៅស៊ូរបស់រដ្ឋចំនួន៣កន្លែង ពោលគឺក្រុមហ៊ុន៧មករានៅមូលដ្ឋានជប់ ក្រុមហ៊ុនមិត្តភាពនិងសាមគ្គីនៅមេមត់។ ក្រុមហ៊ុនទាំងនេះទាំង៣នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានចម្ការកៅស៊ូនៃក្រសួងកសិកម្ម។ ចំពោះរោងចក្រផលិតកៅស៊ូក្រែបនៅប្រទេសកម្ពុជា ពីមុនមកធ្លាប់ដំណើរការបានចំនួន៧រោងចក្រ ក៏ប៉ុន្តែក្រោយឆ្នាំ១៩៨០ អាចធ្វើដំណើរការបានតែ២

រោងចក្រប៉ុណ្ណោះគឺរោងចក្រចម្ការជប់ និងឫស្សីកែវ។ ដើម្បីស្ដាបនាហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និងសង្គម នៅតំបន់ចម្ការកៅស៊ូឡើងវិញ រដ្ឋាភិបាលសម័យនេះបានខិតខំពុះពារគ្រប់ឧបសគ្គ បង្កើតឲ្យមានប្រក្រតីភាពក្នុងវិស័យដ៏សំខាន់នេះពោលគឺបានសាងសង់លំនៅឋានមន្ទីរពេទ្យ សាលារៀន និងក្លឹបហាត់ប្រាណ សម្រាប់បុគ្គលិកកម្មករនិងមន្ត្រីរាជការនៅមានការផ្គត់ផ្គង់ជីវភាពជាដើម។ រដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍដំណាំកៅស៊ូដែលក្លាយជាមុខព្រួញសេដ្ឋកិច្ចដែលមានអាទិភាពមួយក្នុងចំណោមមុខព្រួញសេដ្ឋកិច្ចផ្សេងៗទៀតនៃកម្មវិធីកសិកម្មរបស់រដ្ឋ ហើយក្នុងជំហានដំបូង គឺសង្កត់ធ្ងន់លើការព្យាបាលដើមកៅស៊ូដែលមានជំងឺ។

ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៩ ផ្ទៃដីដំណាំកៅស៊ូបានស្ដារឡើងវិញរហូតដល់ ៤២.៨០០ ហិកតា។ កំណើននៃការដាំដុះកើនដល់៣.១៣% នៅឆ្នាំចុងក្រោយ។ បុគ្គលិកកម្មករចម្ការកៅស៊ូសរុបមានចំនួន២៦.២២០នាក់ រីឯការផលិតកៅស៊ូក្រែបវិញឈានដល់៣០.០០០ តោននៅក្នុងឆ្នាំ១៩៨៨ ក្នុងនោះ៣០.០០០តោន សម្រាប់ការនាំចេញ។ រហូតដល់ឆ្នាំ១៩៩០ រោងចក្រស្លកៅស៊ូក្រែបមានចំនួន៤ដែលអាចដំណើរការបាន ក្នុងនោះមានរោងចក្រចម្ការកៅស៊ូជប់ (មានដប់ពីរខ្សែផលិតកម្ម) រោងចក្រចម្ការកៅស៊ូមេមត់ (មានប្រាំមួយខ្សែផលិតកម្ម) រោងចក្រចម្ការកៅស៊ូបឹងកេត និងឫស្សីកែវ

## ៣.៣.ការធ្វើពាណិជ្ជកម្ម ផលិតកម្ម កសិកម្ម

ពិនិត្យលើរចនាសម្ព័ន្ធបែងចែកដីធ្លី ផលិតកម្មកសិកម្មនៅកម្ពុជា មិនសូវមានការកេងប្រវ័ញ្ចនោះ យើងឃើញលើចំណុចពាណិជ្ជកម្មកសិផល ដំណាក់កាលនៃការទិញថោក លក់ថ្លៃ ។

### ៣.៣.១.សៀគ្វីប្រពៃណី

លោក M.Delvert បានពណ៌នាថា៖ ចិនដែលមានហាងលក់ដូរក្នុងភូមិនីមួយៗបំពេញបាននៅតួនាទីពីរ៖ ផ្ដល់ដល់កសិករនូវការទិញ។ ពួកនេះប្រមូលទិញកសិផលនាំចេញ។ នៅក្នុងហាងនោះមានទំនិញគ្រប់ប្រភេទ ដែលកសិករត្រូវការចាប់ពីគ្រឿងទេស រហូតដល់ ស្ករ ទឹកដោះគោ ខោអាវ ម៉ុងភួយ។ល។ ទំនិញទាំងនោះ ចិនបានឱ្យកសិករមុនពេលប្រមូលផល។ កសិករត្រូវការលុយ ទំនិញដែលចិនផ្ដល់ឱ្យហើយ ត្រូវសងមកវិញនៅពេលប្រមូលផលជា ពោត ស្រូវ ថ្នាំជក់។ល។ ពួកចិនតាមភូមិនេះ តែងទទួលប្រាក់ពីពួកឈ្មួញធំៗ ពីទីក្រុង ដែលមានក្រុមហ៊ុននាំចេញ នាំចូល ដែលភាគច្រើនជាកូនកាត់ចិន។

ផ្ទុយទៅវិញតាមរយៈសៀគ្វីនេះសម្រាប់ការនាំចេញកសិករត្រូវសងជាស្រូវ កប្បាស សណ្ដែក ឬ ផលិតផល ដែលបេះពីព្រៃ ដូចជា ក្រវាញ ដង្ហោ ឬស្មែង ភ្លុក ពីការប្រមាញ់មកឱ្យចិន។ ពួកអ្នកប្រមូលកសិផលទាំងនោះ ធ្វើការច្រកកសិកផលក្នុងបាវ ដឹកតាមរថយន្ត ទុកថ្ងៃ។ សព្វថ្ងៃ ដោយសារម៉ាស៊ីនកិនស្រូវមានកើនឡើងច្រើន ការប្រមូលទាំងនោះធ្វើឡើងដោយម្ចាស់

ម៉ាស៊ីនកែច្នៃធំៗ។ ពួកពាណិជ្ជករទាំងនោះ ខ្ចីលុយពីធនា គារយក លុយទៅឱ្យពួកឈ្មួញកណ្តាលជាអ្នកប្រមូលទិញ។ សៀគ្វីពាណិជ្ជកម្មបែបនេះប្រព្រឹត្តទៅជាធម្មតា។

ទោះបីកសិករមិនបានខ្ចីប្រាក់ពីឈ្មួញតាមភូមិក៏ដោយ ក៏ពេលខ្លះបានបង្ខំចិត្ត លក់ក្នុងតម្លៃថោក ព្រោះគេខ្វះជង្រុក ឃ្លាំងស្តុក។ គេលក់ពេលប្រមូលផល ដែលពេលនោះតម្លៃកសិផលទាបណាស់។ នៅទីផ្សារអន្តរជាតិមានការផ្គត់ផ្គង់ខ្ពស់។ កសិករខ្វះមធ្យោបាយដឹកជញ្ជូនត្រូវលក់នៅក្នុងចំការស្រែ។

គេឱ្យខ្ចីបណ្តាក់មុនដល់កសិករ ក្នុងអត្រាការប្រាក់ខ្ពស់ ១០% ក្នុងមួយខែ។ ក្នុងពេលដែលកសិករត្រូវការសម្ភារបម្រើផលិតកម្ម ឬបុណ្យទាន ពួកចិននៅតាមភូមិធ្វើកាឱ្យខ្ចីមុន។ កសិករទាំងនោះ គ្មានការបែងចែករវាងឥណទានប្រើប្រាស់ និងឥណទានសម្រាប់ផលិតកម្មទេ។ ហេតុដូចនេះហើយ បានជាមានការកេងប្រវ័ញ្ចខ្ពស់លើកសិករ ។

ប៉ុន្តែប្រព័ន្ធកសិកម្មនេះ មានប្រសិទ្ធិភាពណាស់។ គឺការរកស៊ីបែបនេះ បានរួមចំណែកដល់ការនាំចេញកសិផលកម្ពុជា។ ចេញពីប្រព័ន្ធនេះ បានធានាដល់ការផ្គត់ផ្គង់នូវកសិផលតម្រូវការជាតិ និងអន្តរជាតិ។ នៅជង្រុកម្ខាងពួកឈ្មួញក៏បានលើកទឹកចិត្តកសិករឱ្យខំផលិតទោះបីជាមានការទិញថោក លក់ថ្លៃកប់ក្តោងក៏ដោយ។

## ៣.៤.និន្នាការកែលម្អសៀគ្វី

ដោយគិតទៅដល់កតិកាសង្គមជាងផលប្រយោជន៍សេដ្ឋកិច្ច នៃប្រព័ន្ធចាស់នោះរដ្ឋអំណាចសាធារណៈបានខិតខំកែលម្អសៀគ្វីពាណិជ្ជកម្ម ពិសេសការប្រមូលផលស្រូវ ឬក៏ការប្រមូលផលស្រូវ និងកសិផលមួយភាគសម្រាប់នាំចេញ។

ជាបឋម គឺការធ្វើជាតូបនីយកម្មធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដែលសម្រេចឡើងនាខែវិច្ឆិកា ១៩៦៣ មុនពេលធ្វើពាណិជ្ជកម្មនៃការប្រមូលផលឆ្នាំ ១៩៦៤ ដែលមានគោលដៅបញ្ចប់នូវឯកជន មកនៅក្រោមដៃរបស់រដ្ឋអំណាចសាធារណៈ ដែលលោក M.Delvert និយាយពីតួនាទីរបស់សូណិចស៊ីម ក្នុងការនាំស្រូវចេញរបស់កម្ពុជា។

ស្រូវមួយភាគបានត្រូវសូណិចស៊ីម ទិញពីឈ្មួញឯកជន ប៉ុន្តែគេបានទិញពីអង្គការសាធារណៈបីផ្សេងទៀតដែលបានប្រកួតជាមួយឈ្មួញឯកជន គឺ សូរាប៉ា អូរ៉ុក និងសាត្រា។

សូរាប៉ា " ក្រុមហ៊ុនប្រមូលស្រូវ " ជាសាខារបស់សូណិចស៊ីម ដែលទទួលបន្ទុកប្រមូលស្រូវ។ អូរ៉ុក ជា ការិយាល័យនៃរាជសហករណ៍ ត្រួតពិនិត្យការប្រព្រឹត្តទៅនៃសហករណ៍ ដែលខិតខំលក់ដូរផលិតផលរបស់សមាជិកខ្លួន។ សាត្រា ជាសាខារបស់ អូរ៉ុក ជាសេវាប្រមូលទិញ និងកែច្នៃ និងរៀបចំលក្ខខ័ណ្ឌកសិផល ដែលប្រមូលផលពីកសិករដែលមិនទាន់ក្លាយជាសមាជិកសហករណ៍។

អង្គការសាធារណៈទាំងនេះ មានភាពទន់ខ្សោយអស់រយៈពេលជាយូរ ។ ប៉ុន្តែ អូរ៉ុក កាន់តែមានតួនាទី សំខាន់ខ្លាំងឡើង។ នៅឆ្នាំ ១៩៦៧ ការធ្វើពាណិជ្ជកម្ម អូរ៉ុក បានប្រមូលស្រូវក្នុងបរិមាណពាក់កណ្តាល ផ្តល់ដល់ សូណិចស៊ីម សម្រាប់នាំចេញ។

ពាណិជ្ជកម្មឯកជន មិនមានការលុបបំបាត់ចោលទេ ប៉ុន្តែការផ្តាច់មុខប្រមូលផលពីមុនបានថយចុះ។

# មេរៀនទី ៤
# វិស័យឧស្សាហកម្ម និងសេវាកម្មនៅកម្ពុជា

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- វិស័យឧស្សាហកម្ម
- រចនាសម្ព័ន្ធឧស្សាហកម្ម
- ឧស្សាហកម្មនានា
- រចនាសម្ព័ន្ធអាជីវកម្មកសិកម្ម និងការដឹកជញ្ជូន
- សេវាកម្មកសិកម្ម

វិស័យឧស្សាហកម្ម និងសេវាកម្ម មានប្រជាជនសកម្មចំនួន ១៩% ហើយបង្កើតបានផលទុនជាតិសរុបចំនួន ៥៨%។នេះជាសារៈសំខាន់នៃការរីកចម្រើនរបស់ឧស្សាហកម្មដែលភ្ជាប់ការនិយាយពីរចនាសម្ព័ន្ធនានា និងវិស័យដឹកជញ្ជូន និងសេវាកម្មផ្សេងៗ។

## ៤.១.វិស័យឧស្សាហកម្ម

កម្ពុជា គ្មានប្រពៃណីឧស្សាហកម្មទេ។ ចំណែកសិប្បកម្មទៀតសោធ តាំងពីដើមមក មិនទាន់មានភាពរីកចម្រើនទេ។ ពួកអាណានិគម មិនបានបានរៀបចំធ្វើឧស្សាហូបនីយកម្ម លើប្រទេសដែលគេបានចាត់ទុកថា គ្រាន់តែជាអ្នកផ្គត់ផ្គង់នូវកសិផល ក៏ដូចជាអ្នកប្រើប្រាស់ទំនិញចុងក្រោយ។ ឧស្សាហកម្មសូត្រ កប្បាស បានរលាយទៅវិញក្នុងសម័យអាណានិគម។

ហេតុនេះហើយ ឧស្សាហកម្មមុននេះ គឺគ្មានអត្ថិភាពទេ រហូតមកដល់មុនពេលឯករាជ្យនាឆ្នាំ ១៩៥៣។ នាឆ្នាំ ១៩៤២ ក្រៅពីរោងចក្រកែច្នៃជ័រកៅស៊ូ មានតែរោងចក្រសុរាគារកម្ពុជាប៉ុណ្ណោះ ដែលជាឧស្សហកម្ម។ សហគ្រាសកើតថ្មីៗ ដូចជាស្លប្រេង ម៉ាស៊ីនកិនស្រូវ ផលិតស្បៀង ឥដ្ឋ តម្បាញ សុទ្ធតែជារោងជាងលក្ខណៈគ្រួសារ និងសិប្បកម្ម ។ ចំនួននិយោជិកឧស្សាហកម្មពេលនោះមានតិចជាង ១,០០០ នាក់។

ចាប់ពីពេលឯករាជ្យ កម្ពុជាបានចូលក្នុងមាគ៌ាឧស្សាហូបនីយកម្មដោយខ្វះស្ថិតិពិត។

### ៤.១.១.ឧស្សាហូបនីយកម្មនៅកម្ពុជា

ដើម្បីវិភាគបានល្អនូវការរីកចម្រើនដ៏ខ្លាំងក្លា ដែលសម្រេចឡើងក្នុងវិស័យឧស្សាហកម្ម គេត្រូវយកទ្រឹស្តីមកបែងចែក រវាងការកើនឡើងនៃទុនឧស្សាហកម្ម គឺការវិវដ្តនៃការវិនិយោគ និងការកើនឡើងជាបន្តបន្ទាប់ នូវផលិតកម្មឧស្សាហកម្ម។

អ្វីដែលបញ្ជាក់លក្ខណៈនៃផ្នែកឧស្សាហកម្ម ហើយនិងភាពខុសគ្នានៃផ្នែកកសិកម្ម ហើយជាបឋមពីផ្នែកសេវាកម្ម គឺនៅត្រង់មានការកើនឡើងនៃផលិតកម្ម " Du flux " មិនអាច

មានលទ្ធភាពបាន បើគ្មានការកើនឡើងនៃទុន " Du stock " ។ អត្ថន័យមួយទៀតទុនជាកត្តាសំខាន់នៃផលិតកម្មឧស្សាហកម្ម។ បើការវិវឌ្ឍនៃកត្តា និងផលិតកម្មនៅមានចំណងរវាងគ្នានោះ គេមិនអាចបែងចែកបានទេ។ ដូចនេះហើយបានជាយើងត្រូវសិក្សា ដាច់ដោយឡែក។ យើងអាចសិក្សា និងវិភាគបានពីទំនាក់ទំនងដែលចងភ្ជាប់រវាងគ្នា និងការវិវឌ្ឍរបស់វា មេគុណនៃទុន និងផលិតភាព ជាឧបករណ៍ដែលត្រូវលត់ជុំនៅក្នុងការវិភាគនេះ។

ប៉ុន្តែ តាមការអនុវត្តវាមានគ្មានលទ្ធភាព ដើម្បីប្រមូលផ្ដុំរាល់អត្ថន័យនៃការវិវឌ្ឍទុនឧស្សាហកម្មនៅ កម្ពុជា។ តួលេខជាច្រើន ដែលទុកស្មាមការវិវឌ្ឍនៃចំនួនសហគ្រាសឧស្សាហកម្ម ផ្ដល់នូវគំនិតនៃការរីកចម្រើន ដែលសម្រេចបាន។ គេត្រូវការនូវតួលេខនៃវិស័យនោះ ហើយពិសេសចំណុចខុសៗគ្នា។ តួលេខដែលរាយការណ៍ពីការវិនិយោគទុនឧស្សាហកម្ម គ្មានលក្ខណៈគ្រប់គ្រាន់សោះ។

មានស្នាមនៃការវិវឌ្ឍនៃថ្លៃនឹងនរនៃតម្លៃបន្ថែម ដែលទុកជាឯកសារ ដោយវិស័យឧស្សាហកម្ម និងគោលការណ៍សមាសភាព បានត្រូវគណនាក្នុងរយៈពេលឆ្នាំ ១៩៥២-១៩៦៤ ហើយបង្ហាញនូវការជានាច្រើន។ គឺឯកសារនោះហើយ ដែលយើងអាចបែងចែកបាន រវាងទុនវិនិយោគ ឬទុនឧស្សាហកម្ម និងផលិតកម្មឧស្សាហកម្ម។

ការរួមវិភាគទានតម្លៃបន្ថែមនៃផ្នែកឧស្សាហកម្មបានកើនទ្វេ ក្នុងរយៈពេលនោះ ដែលគេអាចសន្មត់នូវការកើនឡើងនៃអត្រាប្រចាំឆ្នាំមធ្យមលើសពី ៨% ។

អត្រាកំណើនមានភាគខុសគ្នាពីសាខាមួយទៅមួយ។ អត្រាមានកម្រិតខ្ពស់ ចំពោះឧស្សាហកម្មដែលគ្មានអត្ថិភាពនាពេលមុននេះ៖ អុកស៊ីហ្សែន អាសេទីឡែន ក្រដាស ក្តារបន្ទះ ។ អត្រាកើនឡើងដល់ ១៣% ចន្លោះឆ្នាំ ១៩៥២-១៩៦៣ នៃវិស័យសំណង់ និងសាធារណៈ និងសម្ភារៈសំណង់ ទន្ទឹមនោះឧស្សាហកម្មបម្រើសំណង់ ក៏កើនឡើងដែរ។ ផ្នែកផលិតបារី និងឈើគូស កើនឡើងដល់ ៨% ។ ផ្នែកជួសជុលគ្រឿងយន្ត អគ្គិសនី ទឹក ភេសជ្ជៈ និងឧស្សាហកម្មផ្សេងទៀតមានអត្រាកំណើន ៨% ដែរ។

ផ្ទុយទៅវិញ មានការរីកចម្រើនយឺត តែ ២% ក្នុងផ្នែកឧស្សាហកម្មស្បៀង និងឧបករណ៍សម្ភា-រៈកសិកម្ម។ ចាប់ពីឆ្នាំ ១៩៦៣ ការរីកចម្រើនឧស្សាហកម្មនៅកម្ពុជា ហាក់ដូចជាជួបឧបសគ្គមួយចំនួន។ ឆ្នាំ ១៩៦៤ ជាឆ្នាំចុងក្រោយ ដែលគេមានតួលេខជារួមមានការកត់សម្គាល់នូវភាពថយចុះនៃសកម្មភាពសំណង់ និងការងារ សាធារណៈ។ តួលេខនៃឆ្នាំបន្តបន្ទាប់ មិនអាចនិយាយថាផ្នែកទី ២ នេះ បន្តអត្រាកំណើនខ្ពស់ទេ។ វាលេចឡើងនូវទុទិដ្ឋិនិយម។ ការប្រើប្រាស់អគ្គិសនី ដែលជាមូលដ្ឋានសំខាន់នៃប្រទេសរីកចម្រើន បែរជានៅនឹងថ្កល់។ ផ្នែកសំណង់ដែលជាដើមហេតុនៃឥទ្ធិពលលើវិស័យដទៃ ហាក់ដូចជាមិនអាចងើបឡើងឱ្យស្មើមុនឆ្នាំ ១៩៦៣ បានឡើយ។ តួលេខនៃផលរបរនៃសាខាជាច្រើនរបស់ឧស្សាហកម្មដូចជា ស្បៀង តំបាញ រោងពុម្ព ក្រដាស យន្តសាស្ត្រ បានថយចុះនៅឆ្នាំ ១៩៦៦ ប្រៀបឆ្នាំ ១៩៦៥ ដែលមុននេះគឺឆ្នាំ ១៩៦៤ មានភាពរីកចម្រើន សន្ទស្សន៍ទាំងនេះ ត្រូវបានបកស្រាយដោយប្រុងប្រយ័ត្ន ដែលជាចំណុចកត់សម្គាល់នូវការទ្រើង និងថយចុះនៅឆ្នាំ ១៩៦៣ មក។

គេក៏ត្រូវគូសបញ្ជាក់ផងដែរ អំពីតួនាទីនៃអំណាចសាធារណៈ ក្នុងអភិក្រមនៃឧស្សាហូបនីយកម្ម។ រដ្ឋមិនឈរនៅតែឯងទេក្នុងការធ្វើអន្តរាគមន៍ ដោយបង្កនូវលក្ខខ័ណ្ឌនៃការអភិវឌ្ឍនៃការផ្តួចផ្តើមផ្នែកឯកជន។ បើខ្វះជំនឿក្នុងប្រសិទ្ធភាពនៃការផ្តួចផ្តើម រដ្ឋចាំបាច់ចូលរួមដោយផ្ទាល់។

រដ្ឋបានកសាងរោងចក្រ ពេលបញ្ចូលទុកជាមួយឯកជនក្នុងសហគ្រាសនានា ដែលហៅថា សេដ្ឋកិច្ចចម្រុះពេលខ្លះទទួលជំនួយពីបរទេសជាអំណោយ ឬខ្ចីបុល។ ដូចនេះហើយបានជាមានការរីកចម្រើន ផ្នែកឧស្សាហកម្ម នៃវិស័យសាធារណៈ ដូចជារដ្ឋាករទឹក រោងចក្រក្រដាសវាយនភ័ណ្ឌបីកន្លែង សុរាគារ រោងចក្រកង់រថយន្ត រោង ចក្រធ្វេចកប្បាស រោងចក្រស្ករ ក្តារបន្ទះឥដ្ឋ បាវក្រចៅ អារឈើ ទឹកក្រូច កែវ ។ល។ និងពាក់កណ្តាល សាធារណៈ ដូចវិស័យ អគ្គិសនីបារី ឈើគូស ផលិតជីផូស្វាត។ ប៉ុន្តែ សារៈសំខាន់នៃផ្នែកសាធារណៈនេះត្រូវផ្តល់គុណភាពជាជាងមានតែបរិមាណ។

ប៉ុន្តែរហូតដល់ពេលបច្ចុប្បន្នការរីកចម្រើនផ្នែកឧស្សាហកម្ម គឺកើនឡើងដោយវិស័យទុនឯកជន ដែលបានវិនិយោគនៅកម្ពុជា ក៏មានវណ្ណៈសហគ្រិនដែរ។ នៅកម្ពុជា មនុស្សចេះធ្វើផលរបរដ៏មានថាមពល ចេះសន្សំ ចេះធ្វើការ ដើម្បីប្រាក់ចំណេញ ឬជាពពួកមនុស្សមានសមត្ថភាពបង្កើត និងដឹកនាំសហគ្រាស គឺពួកខ្មែរកូនកាត់ចិន។ ទីនេះ ពាណិជ្ជកម្ម អូសទាញសកម្មភាពអាជីវកម្មជាងឧស្សាហកម្ម។ ពួកគេក្លាយពីពាណិជ្ជករ ទៅជាឧស្សាហករ។

ឧស្សាហូបនីយកម្មនៅកម្ពុជា បានប្រព្រឹត្តទៅពុំសូវមានរបៀបរបបបន្តិច។ តួនាទីរបស់សហគ្រាសឯកជនបានបង្ហាញពីបាតុភាពអាណាធិបតេយ្យ៖ ពួកមូលធនរកប្រាក់ចំណូល គ្មានការដឹកនាំដោយផែនការរួមទេ។ ឃើញអ្វីចំណេញ នាំគ្នាបោះទុនចូលទីនោះភ្លាម។ ការមិនបានសិក្សាស្រាវជ្រាវផ្នែកសេដ្ឋកិច្ចនៃតថភាព និងលទ្ធភាព ធ្វើឱ្យប្រតិបត្តិការមិនបានក្នុងតម្លៃមួយខ្ពស់ ហើយនាំកើតជាឧបសគ្គក្នុងទិសដៅអភិវឌ្ឍន៍ឧស្សាហកម្ម នៃពុទ្ធិមួយសមស្រប។

តាមធម្មជាតិនៃកម្ពុជា ផែនការមួយដែលមានទិសដៅល្អត្រឹមត្រូវ លុះត្រាតែគិតគូរដល់លក្ខខ័ណ្ឌធម្មជាតិគិតដល់អាកាសធាតុ ធនធានក្នុងដី ថាមពល រ៉ែ ធនធានមនុស្ស ដែលមានវត្ថុធាតុដើមបម្រើ ឧស្សាហកម្ម ក្នុងតម្លៃមួយទាប ទើបប្រកួតប្រជែងបាន។ កសិផលនាំចេញ លើកលែងតែកៅស៊ូត្រូវកែច្នៃជាទំនិញ ទើបនាំចេញមានតម្លៃ។ ត្រូវដាំកប្បាស អំពៅ សម្រាប់ជាវត្ថុធាតុដើមនៃរោងចក្រកែច្នៃ។ ការជ្រើសរើសបែបនោះ គឺជាបញ្ហាលំបាក។

នៅប៉ុន្មានឆ្នាំក្រោយនេះ មានសេចក្តីសម្រេចចិត្តវិនិយោគច្រើនណាស់ដែរ ទាំងផ្នែករដ្ឋនិងសហគ្រិន ឯកជន ដោយមិនបានគិតគូរដល់ទីផ្សារលក់ដូរ ការផ្គត់ផ្គង់ និងទីផ្សារទីតាំងទៀតផង។ នេះហើយបានជាមានការអភិវឌ្ឍឧស្សាហកម្មដ៏លឿនបំផុតនៅកម្ពុជា ដោយគ្មានចោទឡើងនូវបញ្ហាទេនោះ។ ជាបឋម គេត្រូវសិក្សាពី រចនាសម្ព័ន្ធឧស្សាហកម្មនេះសិន។

## ៤.២.រចនាសម្ព័ន្ធឧស្សាហកម្ម

រចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាមិនត្រូវបានស្គាល់ច្បាស់លាស់នៅឡើយទេ។ គេមិនទាន់មានព័ត៌មាន ច្បាស់លាស់ពីសមត្ថភាពផលិតកម្មនៅឡើយ។ តាមរយៈគណនេយ្យសេដ្ឋកិច្ចដែលជាវិធានការស្ថិតិពន្ធដារនោះ ធ្វើឱ្យគេឃើញពីទំហំនៃការបែងចែករចនាសម្ព័ន្ធឧស្សាហកម្មតាមទំហំ តាមខេត្ត និងតាមផ្នែក។

– ការបែងចែកតាមទំហំសហគ្រាសឧស្សាហកម្មដែលថាមានទំហំធំតាមរយៈតួលេខពន្ធអាករលើប្រាក់ចំណេញឧស្សាហកម្ម គឺការបង់ពន្ធលើសពី ១,៥០០ រៀល ។ មានតែសហគ្រាស ១០% ទេ ដែលមានផលទុនលើសពី ១០០,០០០ រៀល ។ ៩០% នៃសហគ្រាសឯទៀតមានលក្ខណៈជាសិប្បកម្ម។ ការស្រាវជ្រាវឯកសារឆ្នាំ ១៩៦៥ នៅភ្នំពេញ អនុញ្ញាតឱ្យបែងចែកតួលេខនៃផលរបរ ជាលានរៀលដូចតទៅ៖

| | |
|---|---|
| តិចជាង | ៣៩ សហគ្រាស |
| ០.១ ទៅ ០.៥ | ៥៩ សហគ្រាស |
| ០.៥ ទៅ ១.០ | ៣៥ សហគ្រាស |
| ១.០ ទៅ ៥.០ | ២៦ សហគ្រាស |
| ៥.០ ទៅ ២៥.០ | ១៣ សហគ្រាស |
| លើសពី ២៥.០ | ៧ សហគ្រាស |

សហគ្រាសជាង ៥០ នៅរាជធានីភ្នំពេញ មានលក្ខណៈជាសហគ្រាសឧស្សាហកម្ម។ ក្រុមនោះមានផលរបរលក់លើសពី ១ លានរៀល ។ ប៉ុន្តែសហគ្រាសទាំងនោះ មិនស្ថិតនៅភ្នំពេញទេ។

ការបែងចែកតាមភូមិសាស្ត្រ៖ គឺនៅភ្នំពេញ និងខេត្តកណ្តាលដែលមានសហគ្រាសជាច្រើន។ប៉ុន្តែសហគ្រាសទាំងនោះមានចំនួនតែ ៤០% នៃសហគ្រាសរបស់ប្រទេស។ ក្រុងព្រះសីហនុ កំពង់ចាម កំពង់ធំ ព្រៃវែង និងបាត់ដំបង ក៏ជាមជ្ឈមណ្ឌលឧស្សាហកម្មដែរ។

បើគិតដល់សារៈសំខាន់នៃសហគ្រាស មានការផ្លាស់ប្តូរតារាងដ៏សំខាន់។ គេឃើញថាភ្នំពេញជាមជ្ឈមណ្ឌលឧស្សាហកម្មរបស់ប្រទេសព្រោះ ៧៥% នៃផលរបរដែលបានប្រកាសពីសហគ្រាសនៅកម្ពុជា បានសម្រេចឡើងដោយសហគ្រាសនៅភ្នំពេញ។ ពិនិត្យលើសារៈសំខាន់នេះ ខេត្តបាត់ដំបង ឈរនៅជួរទី ២ ជាមជ្ឈមណ្ឌលឧស្សាហកម្ម ទាំងចំនួនសហគ្រាស ដែលមានលក្ខណៈជាឧស្សាហកម្ម " មានផលទុនដែលត្រូវបង់ពន្ធលើសពី ១០០,០០០ រៀល " ជាផលរបរ។

សង្ខេបមក មានសហគ្រាសជាច្រើន នៅលើទឹកដីកម្ពុជា តែសហគ្រាសធំៗ គឺនៅភ្នំពេញ និងបន្ទាប់មកនៅខេត្តបាត់ដំបង។

– ការបែងចែករវាងផ្នែកឯកជន និងសាធារណៈនៃសហគ្រាស និងសកម្មភាពនានានៃឧស្សាហកម្ម ក៏ជាលក្ខណៈនៃរចនាសម្ព័ន្ធសំខាន់ណាស់ដែរ។ គណនេយ្យសេដ្ឋកិច្ចនៅ

ឆ្នាំ ១៩៦៤ ផ្តល់តួលេខជាភាគរយ៖

សហគ្រាសក្រុមហ៊ុនឯកជន សហគ្រាសសាធារណៈ សាធារណៈនិងចម្រុះឯកជនបុគ្គល

តម្លៃបន្ថែម...............២.២.....................៣២.៨ ៦៥.០ = ១,០០០

ការបែងចែកបៀវត្ស........៥.១....................៥៣.១ ៤១.៨ = ១០០

ពន្ធ និងតាក់ដែលបានបង់........២.៨............៨២.២ ១៥.០ = ១០០

ផលទុនថេរ........................០.៥................១៥.១ ៨៤.៤ = ១០០

នៅឆ្នាំ ១៩៦៤ សារៈសំខាន់ នៃផ្នែកសាធារណៈបានចុះខ្សោយទាំងការរួមវិភាគទានដល់ផលទុនជាតិ ទាំងការរួមចំណែកដល់កេសររបស់រដ្ឋ។ ចាប់ពីពេលនោះមក រោចក្រថ្មីៗទៀតក៏ត្រូវបានបង្កើតឡើង សារៈសំខាន់នៃផ្នែកសេដ្ឋកិច្ច មានការថយចុះនៅកម្ពុជា ក៏មានឧស្សាហកម្មដែលមានប្រភេទទុនឯកជន ផ្ទុយពីមតិដែលបានឃោសនាផ្សព្វផ្សាយថា មានតែការពង្រឹកផ្នែករដ្ឋនោះ។

## ៤.៣ ឧស្សាហកម្មនានា

ពិនិត្យតាមសារៈសំខាន់ ឧស្សាហកម្មប្រទេស គិតជាភាគរយនៃតម្លៃបន្ថែម ប្រៀបនឹងផ្នែកទី ៤ នៃវិស័យសេដ្ឋកិច្ចនាឆ្នាំ ១៩៦២ និង ១៩៦៣ ។

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| សំណង់ និងសាធារណៈការ | ៣៤ | ៣៤ | ២៩ |
| ឧស្សាហកម្មស្បៀង | ១៨ | ១៨ | ២៩ |
| ថាមពល និងទឹក | ១៧ | ១៦ | ៨ |
| បារី | ១០ | ១១ | ១៣ |
| ជួសជុលគ្រឿងយន្ត | ៦ | ៥ | ៦ |
| សម្ភារសំណង់ | ៥ | ៥ | ៤ |
| សម្ភារៈ និងឧបករណ៍នៃសាទ | ៥ | ៤ | ៤ |
| រោងចក្រអារឈើ | ២ | ២ | ១ |
| ឧស្សាហកម្មផ្សេងៗ | ៣ | ៥ | ៧ |

ការចាត់ថ្នាក់បែបនេះ មានការកែប្រែច្រើនណាស់ក្នុងរយៈពេល ១៥ ឆ្នាំ ព្រោះសាខានានា នៃផ្នែកឧស្សាហកម្ម បានស្គាល់នូវអត្រាកំណើនខុសៗគ្នា។ ដោយឡែក វាទាមទារនូវការកែប្រែយ៉ាងឆាប់រហ័សនាឆ្នាំ បន្តទៀត ដោយហេតុនៃការកសាងរោងចក្រថ្មីៗថែមទៀត។

**១.ឧស្សាហកម្មសំណង់ និងសាធារណៈការ** ជាឧស្សាហកម្មទីមួយនៃប្រទេស។ កាលពីឆ្នាំ ១៩៥២ ផ្នែកនេះឈរនៅជួរទី ៤ ប៉ុន្តែអត្រាកំណើនរហ័សពេក ធ្វើឱ្យគេឈរនៅជួរទី ១ វិ

ញ។ នៅឆ្នាំ ១៩៦៤ ការរីកចម្រើន នៃវិស័យនេះ បែរជាទ្រឹង ហើយថយចុះ គួរឱ្យកត់សម្គាល់។ នៅឆ្នាំក្រោយៗមក វិស័យនេះថយចុះខ្លាំង រហូតដល់ក្នុងសង្គ្រាម។ នៅពេលបើកចំហសេដ្ឋកិច្ចទីផ្សារនាឆ្នាំ ១៩៩០ វិស័យនេះមានអត្រាខ្ពស់ឡើងវិញ។

សាខានេះ ដោយសារធម្មជាតិ គឺជាការ " បង្កើនទុន " គឺមានន័យថា ផលិតកម្មរបស់វារួមវិភាគទានដល់ការវិនិយោគ។ ពួកអតិថិជននៃសាខានេះត្រូវបានគេបែងចែក ជាភាគរយ នៃផលិតផលសរុបដូចតទៅះ

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| គេហដ្ឋាន | ៥២ | ៤៥ | ៤៥ |
| សហគ្រាស | ៧ | ១២ | ៦ |
| រដ្ឋបាល | ៤១ | ៤៣ | ៤៩ |

ដើម្បីផលិត ១០០ រៀល នៃអាគារសំណង់ និងការងារសាធារណៈ គេត្រូវចំណាយនៅឆ្នាំ ១៩៦៣

| | |
|---|---|
| ៤ រៀល | សម្រាប់ថាមពល |
| ៤២ រៀល | សម្រាប់វត្ថុធាតុដើម និងពាក់កណ្តាលសម្រេច |
| ៨ រៀល | សម្រាប់ផលិតផលនៃឧស្សាហកម្មយន្តសាស្ត្រ |
| ៨ រៀល | សម្រាប់ផលិតផលឧស្សាហកម្មផ្សេងៗ |

ផ្នែកសំណង់ មានសកម្មភាពសំខាន់ណាស់ នៅលើសាខានៃវត្ថុធាតុដើម និងពាក់កណ្តាលសម្រេច ដូចជា ស៊ីម៉ង់ ដែក បេតុង ឥដ្ឋ ។ល។ ហើយបង្កើតបាននូវទីផ្សារ ៤០% ។ សំណង់មានតួនាទីជា " ក្បាលម៉ាស៊ីន " នៃសេដ្ឋកិច្ចកម្ពុជា ។ ដូចនេះ បានជាសុភាសិតមួយថា " បើសំណង់ដើរ អ្វីៗក៏ដើរដែរ " ។ ឧស្សាហកម្មសំណង់ និងសាធារណៈ មានសារៈសំខាន់ផ្នែកឯកជន ពេលខ្លះមានសហគ្រាសសំណង់រដ្ឋដែរ។

**២.ឧស្សាហកម្មស្បៀង** ស្ថិតក្នុងសេដ្ឋកិច្ចកសិកម្ម។ នៅចន្លោះឆ្នាំ ១៩៥២-១៩៦២ អត្រាកំណើន តិចជាង ២% ក្នុងមួយឆ្នាំ ប្រហែលអត្រាកំណើនផ្នែកកសិកម្មដែរ ដូចនេះមានន័យថា កសិផល បានត្រូវនាំចេញ ត្រង់តែម្តង មិនសូវបានកែច្នៃមុនការនាំចេញទេ។ ឧស្សាហកម្មស្បៀងសម្រាប់ភ្ជាប់អ្វី ដែលដុះនៅចំការស្រែ និងគុ ហូបបាយ ប៉ុណ្ណោះ។

ឧស្សាហកម្មស្បៀងនៅកម្ពុជា គឺគិតជាភាគរយ នៃតម្លៃបន្ថែមះ

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ស្រូវ ឬអង្ករ | ៤៤ | ៥៤ | ៥៧ |
| អាល់កុល | ២២ | ១៧ | ១៣ |
| សាច់ជ្រូក | ១០ | ៧ | ៤ |
| ទឹកកក | ៣ | ៥ | ៦ |
| ភេសជ្ជៈ | ៣ | ៥ | ៦ |

| | | | |
|---|---|---|---|
| សាច់គោ | ២ | ២ | ២ |
| ផ្សេងៗ | ១៦ | ១៥ | ១៨ |

នៅក្បែរម៉ាស៊ីនកិនស្រូវ សត្តឃាត ចម្រាញ់ប្រេង ឡដុតនំប៉័ង គេឃើញមានសហគ្រាស ទំនើប សុរាគារកម្ពុជា បេសេអ៊ី បៀរអង្គរ កូកា ប៉េបស៊ី ជាដើម។ល។

**៣.សាខា " ថាមពល និងទឹក "** ឈរនៅជួរបន្ទាប់ពីឧស្សាហកម្មស្បៀង។ ផ្នែកនោះ មានការលំបាកក្នុងការដាក់ឈ្មោះថា ឧស្សាហកម្ម លើចំណុចនៃការប្រើអុសដុតជាថាមពល បញ្ហាទឹក ដោះស្រាយបាននៅតាមទីក្រុង ឯជនបទប្រើទឹកអណ្តូង ទន្លេ មិនទាន់សម្បូរម៉ាស៊ីនបូមទឹក និងច្រោះទឹកស្អាត។ ១/៣ នៃថាមពលអគ្គិសនីប្រើដោយម៉ាស៊ីនភ្លើងតូចៗ។

ក្នុងសាខានេះ មានសហគ្រាសពីរធំៗ គឺ ក្រុមហ៊ុនអគ្គិសនីកម្ពុជា និងរដ្ឋាករទឹក គឺ សុទ្ធតែជា សហគ្រាសរដ្ឋ។

**៤.ឧស្សាហកម្មថ្នាំជក់** មានសារៈសំខាន់ ព្រោះការផលិតបារី រួមវិភាគទានបានដល់ទៅ ១០% នៃតម្លៃបន្ថែមក្នុងផ្នែកឧស្សាហកម្ម។ កម្មន្តសាលថ្នាំជក់ចំនួនបីកន្លែង ផលិតបារីចេញពីវត្ថុធាតុដើមថ្នាំជក់ក្នុងស្រុក ជា ក្រុមហ៊ុនចម្រុះ។ សព្វថ្ងៃ ក្រុមហ៊ុនឯកជន បានជួលកម្មន្តសាលនោះ ដោយចុះកិច្ចសន្យាអាជីវកម្ម តាមរយៈការដាក់ខ្សែផលិតកម្មថ្មី។

**៥.វិស័យឧស្សាហកម្មផ្សេងៗទៀត** ជារបស់រដ្ឋ ដែលបានធ្វើអន្តរាគមន៍យ៉ាងសកម្ម ក្នុងការបង្កើនល្បឿនអភិវឌ្ឍន៍ឧស្សាហកម្ម។ សាខាសំខាន់ៗ មានដូចតទៅៈ

– ការជួសជុលរថយន្ត និងយន្តសាស្ត្រ ដែលជានាប់រងដោយរោងជាងតូចៗ។ គេរាប់ឃើញ នៅក្នុងឆ្នាំ ១៩៦១ មានរោងជាង ២០០ កន្លែង ប្រើពលកម្មជា ៨០០ នាក់។

– សម្ភារសំណង់ មានភាពរុងរឿងស្របពេលនឹងឧស្សាហកម្មសំណង់ៈ ឥដ្ឋ ក្បឿង ខ្សាច់ គ្រួស ការ៉ូ ក្តារបន្ទះ ថ្នាំពណ៌ និងចាប់ពីឆ្នាំ ១៩៦៤ ស៊ីម៉ង់ដែលផលិតដោយរោងចក្ររដ្ឋនៅចក្រីទីង ដែលមកដល់ឆ្នាំ ១៩៦៦ ការផ្គត់ផ្គង់សឹងតែពាក់កណ្តាលបរិមាណស៊ី ជាតម្រូវការក្នុងប្រទេស។ រោងចក្រអារឈើ ធ្វើឱ្យរស់ឡើងវិញនូវសហគ្រាសតូចៗ។

– សម្ភារ និងឧបករណ៍កសិកម្មៈ ជាសិប្បកម្មបោះរទេះ ជួសជុលនង្គ័ល កណ្តៀរ ចប នោស់។ល។ មានសារៈសំខាន់ដល់ប្រទេសកសិកម្ម។ រោងចក្រដំឡើងត្រាក់ទ័រ កសាងនៅឆ្នាំ ១៩៦៤ នៅក្រុង ព្រះសីហនុ រហូតដល់ឆ្នាំ ១៩៦៧ ទើបដំណើរការផលិតកម្ម។

– រោងចក្រតម្បាញ ភាគច្រើននៅតែជាសិប្បកម្ម ប៉ុន្តែសហគ្រាសរដ្ឋ ផ្ដេច និងតំបាញកប្បាស នៅ កំពង់ចាម ចាប់ផ្តើមផលិតនៅឆ្នាំ ១៩៦០។ រោងចក្រទី ២ របស់រដ្ឋនៅបាត់ដំបង បើកទ្វារតាំងពីឆ្នាំ ១៩៦៦ ដែរ។

– ឧស្សាហកម្មកៅស៊ូៈ កែច្នៃជ័រ នាំចេញដោយក្រុមហ៊ុនចំការកៅស៊ូខ្លួនឯងតែម្តង មានលក្ខណៈជា ឧស្សាហកម្ម។ ក្រៅពីផលិតជ័រក្រែបរោងចក្រមួយចំនួនផលិតកង់រថយន្ត " ៩៦៦ " " រដ្ឋ " ផលិតស្បែកជើង ទុយោ។

– ឧស្សាហកម្មក្រដាស ជារោងចក្ររដ្ឋ **SONAPAP** នៅឆ្លូង ចាប់ដំណើរការពីឆ្នាំ

១៩៦២។ នៅមាន រោងចក្រជាច្រើន ដែលផលិតក្រដាសពីម្សៅក្រដាស។

– អុកស៊ីសែន អាសេទីឡែន និងឧស្ម័នកាបូនិច ជាក្រុមហ៊ុនចម្រុះ។

– រោងចក្រផលិតសាប៊ូ ពីពិសោធន៍ផលិតឱសថ ដែកគោល និងផលិតវត្ថុពីប្លាស្ទិច។

ទិដ្ឋភាពខាងលើ បង្ហាញពីការរីកចម្រើនឧស្សាហូបនីយកម្មនៅកម្ពុជា។ ប៉ុន្តែក៏បានបង្ហាញ ចំណុចខ្វះខាតដែរ ពិសេសឧស្សាហកម្មគីមី ដែលមិនទាន់មានសោះនៅកម្ពុជា។ ការខ្វះរោងចក្រស្លដែក មិនគួរឱ្យភ្ញាក់ផ្អើលទេ ចំពោះប្រទេសកម្ពុជា។ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មប្រពលវប្បកម្ម “ labo-intensive” និងការសន្សំទុនមានតិចតួចណាស់។

## ៤.៤.រចនាសម្ព័ន្ធអាជីវកម្មកសិកម្ម និងការដឹកជញ្ជូន

### ៤.៤.១.លក្ខខ័ណ្ឌនានានៃអាជីវកម្មរបស់សហគ្រាស

ឧស្សាហកម្មនៅកម្ពុជា មិនទាន់មានការលើកទឹកចិត្តនៅឡើយ អំពីការធានាពីវត្ថុធាតុដើម។ ក្រៅពីនោះកត្តាផ្សេងទៀតសម្រាប់អាជីវកម្មរបស់សហគ្រាស មានភាពងាយស្រួល។

ពលកម្មសម្បូរ មានគុណភាព។ កម្រិតបៀវត្សនៅទាប ដែលមិនល្អត្រង់ចំណុចសង្គម ប៉ុន្តែជាចំណុចល្អចំពោះការអភិវឌ្ឍសេដ្ឋកិច្ច។

ថាមពលមុនឆ្នាំ ១៩៧០ មិនខ្វះទេ។ បច្ចុប្បន្នខ្វះខ្លាំងណាស់ ពិសេសថាមពលអគ្គិសនីគឺបញ្ហាប្រកតពផង និងថ្លៃផង។ នៅគ្រប់សហគ្រាស និងគេហជន “ ménage ” ការប្រើម៉ាស៊ីនភ្លើងដោយខ្លួនផ្ទាល់ជាការចាំបាច់ បំផុត។ ក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្តល់បានតែ ២០% នៃថាមពល ជាប្រើប្រាស់របស់ឧស្សាហកម្មនៅភ្នំពេញ។ ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី គ្មានជាប្រចាំទេ។ ទំនប់គិរីរម្យដែលផ្តល់ថាមពល កាលពីឆ្នាំ១៩៦៨ ត្រូវខូចដោយសារសង្គ្រាម។ ទំនប់អគ្គិសនីព្រែកត្នោត និងកំចាយត្រូវបោះបង់ចោលគម្រោងសាងសង់ពាក់កណ្តាលការ ដោយ សារសង្គ្រាម។

ផ្នែកពន្ធអាករមានភាពស្មុគស្មាញ តែពន្ធធូជាងបើប្រៀបនឹងប្រទេសអន់ថយដូចគ្នា។ ពន្ធលើប្រាក់ចំណេញប៉ះពាល់ដល់ក្រុមហ៊ុន ២៥% ។ ពន្ធលើផលរបរ លើការលក់ដូរទំនិញលើកទីមួយ ៥% ។

វាមានការលំបាក ក្នុងការខ្ចីទុនរយៈពេលវែង ដើម្បីវិនិយោគ “ អវត្តមានទីផ្សារហិរញ្ញវត្ថុធនាគារឱ្យខ្ចីរយៈពេលយូរ ” ។ ការខ្ចីប្រាក់រកស៊ីពាណិជ្ជកម្មរយៈពេលខ្លី និងមធ្យមក៏លំបាកដែរ។ អត្រាការប្រាក់មិនច្បាស់ លាស់ ប៉ុន្តែមិនខ្ពស់ទេ។

កម្ពុជានាទសវត្ស ១៩៦០ អនុវត្តន៍យោបាយការពារទំនិញ ដែលធ្វើឱ្យផលិតផលក្នុងស្រុក ប្រជែងបាននឹងទំនិញនាំចូល ធ្វើឱ្យឧស្សាហកម្មក្នុងស្រុករីកចម្រើន។ បច្ចុប្បន្នមិនទាន់មាននយោបាយនេះនៅឡើយទេ។

ទាំងសហគ្រាសឯកជន និងរដ្ឋ ជាទូទៅតែងជួបឧបសគ្គ ព្រោះការសិក្សាស៊ីជម្រៅតាំងពីការដាក់ទីតាំង និងការសិក្សាពីផលចំណេញដែលធ្វើឱ្យមានការជ្រើសរើសខុសក្នុងការវិនិយោ

គ។ ដើម្បីប្រើប្រាស់ទុន ដែលជាប្រភព ធនធានលំបាកក្នុងការរកបាននោះ គេត្រូវសិក្សាស៊ីជម្រៅ ក្នុងការប្រើប្រាស់ទុនឱ្យមានប្រសិទ្ធភាព។

### ៤.៤.២.រចនាសម្ព័ន្ធ និងការដឹកជញ្ជូន

ស្តីអំពីការដឹកជញ្ជូនគេត្រូវចែកឱ្យបានដាច់ពីគ្នា រវាងតម្លៃបន្ថែមនៃស្តុកជាទុន ដែលបម្រើឱ្យមានផលប្រយោជន៍។ ក្នុងទស្សនៈវិស័យថាមពល ន័យនៃពាក្យថា ទុន មានសារៈសំខាន់ជាងពាក្យថា Flux។ តម្លៃបន្ថែម ក្នុងផ្នែកដឹកជញ្ជូន កើតឡើងយឺតជាងផ្នែកឧស្សាហកម្ម។ ការត្បាញក្រណាត់មួយម៉ែត្រ កម្មករត្បាញក្នុងរយៈពេលខ្លី។ ឯការដឹកជញ្ជូន ត្រូវរង់ចាំដល់ដំណាក់ការពេលវែង ទើបតម្លៃបន្ថែមបំពេញបាន។

**ក.**កម្ពុជាមានរចនាសម្ព័ន្ធដឹកជញ្ជូនល្អ។ ជាធម្មតា កម្ពុជាមានទន្លេ ស្ទឹង បឹង។ មេគង្គអាចទទួលនាវា សមុទ្របាន ទន្លេសាបក៏អាចឱ្យនាវាទៅមកបាននៅរដូវវស្សា។ ពិសេសទិដ្ឋភាពកម្ពុជា មានភាពងាយស្រួលដល់ការកសាងផ្លូវថ្នល់ និងផ្លូវដែក។

ផ្លូវថ្នល់ មានសារៈសំខាន់ជាងផ្លូវដែក។ ពួកអាណានិគម បានកសាងផ្លូវនោះយ៉ាងមានប្រសិទ្ធភាព ទុកឱ្យរដ្ឋាភិបាលកម្ពុជាបន្តប្រើប្រាស់។ ផ្លូវគោកប្រវែង ២,០០០ គ.ម.ចាក់ជ័រកៅស៊ូ។ ក្រុមហ៊ុនរថយន្តដឹកជញ្ជូនមានសារៈសំខាន់ណាស់។

ផ្លូវដែក កសាងពីឆ្នាំ ១៩៣០ ដល់ ១៩៣២ ពីភ្នំពេញ ទៅព្រំដែនថៃ ប្រវែង ៣៨២ គ.ម.។ ការភ្ជាប់ផ្លូវដែក រវាងភ្នំពេញ និងតំបន់កសិកម្មដ៏សំខាន់នៃខេត្តបាត់ដំបង មានសារៈសំខាន់ណាស់។ ផ្លូវដែក ១ ខ្សែទៀត ចាប់ដំណើរការនៅឆ្នាំ ១៩៦១ ពីភ្នំពេញ ទៅក្រុងព្រះសីហនុ ប្រវែង ២៧០ គ.ម.។ ការកសាងផ្លូវនេះ ឈរលើមូលដ្ឋាននៃសុធន្ទៈ និងការឱ្យខ្ចីពីប្រទេសបារាំង។

រចនាសម្ព័ន្ធកំពង់ផែ និងព្រលានយន្តហោះ ក៏មានការរីកចម្រើនក្នុងរយៈពេល ១០ ឆ្នាំនៃទសវត្ស ១៩៦០ ដែរ។

ព្រលានយន្តហោះពោធិ៍ចិនតុង ជាជំនួយបារាំង មានផ្លូវហោះហើរ ៣,២០០ ម.។ នៅសៀមរាប ក៏មានព្រលានយន្តហោះអន្តរជាតិ។ តាមខេត្តនានា មានព្រលានយន្តហោះតូចៗអាចឱ្យយន្តហោះធុនស្រាលចុះចតបាន។

កំពង់ផែសមុទ្រក្រុងព្រះសីហនុ អាចទទួលនាវាសមុទ្រធំៗបាន។ កំពង់ផែភ្នំពេញមានការលំបាក ដោយសារទឹករាក់នៅរដូវក្តៅ។

វិស័យទូរគមនាគមន៍ ក៏មានការរីកចម្រើនដែរ។ បុស្តិ៍ទូរស័ព្ទកើនចំនួនរហូតដល់ទៅ ៥,០០០ គ្រឿង នាឆ្នាំ ១៩៦៧ ។ សព្វថ្ងៃ វិស័យនេះមានតិចណូឡូស៊ីថ្មី ដែលភ្ជាប់ដោយកាណាល់ផ្កាយរណប ទៅពាសពេញពិភពលោក។

**ខ.**រចនាសម្ព័ន្ធនេះ" ផលិតនូវផលប្រយោជន៍ " ៖ តម្លៃបន្ថែមនៃផ្នែកដឹកជញ្ជូន រួមចំណែកជាង ២% ដល់ផលទុនជាតិ។ ការវិវដ្តថ្មី គឺការដឹកជញ្ជូន ផ្លូវអាកាស ផ្លូវដែក និងផ្លូវសមុទ្រ។

## ៤.៥.សេវាកម្មផ្សេងៗទៀត

សេវាកម្មផ្សេងៗរួមមានការសិក្សាស្រាវជ្រាវសណ្ឋាគារភោជនីយដ្ឋាន រោងភាពយន្ត សិក្សាធិការ ការជួសជុលអាគារសេវាកម្មមេធាវីនិងពាណិជ្ជកម្មធនាគារនិងរដ្ឋបាលមានតម្រូវការជាចាំបាច់នូវទុនជារូបិយ។

**ក.**ប្រជាជនសកម្មចំនួន ១៣% បម្រើក្នុងវិស័យ ″ សេវាកម្ម ″ ហើយរួមវិភាគទានប្រហែល ៤០% នៃផលទុនជាតិ។

**ខ.**ផ្នែករដ្ឋបាលមានតែខ្មែរទេដែលជាអ្នកធ្វើកាងារនេះ។ ពួកចិន និងកូនកាត់ចិនគ្រប់គ្រងពាណិជ្ជកម្ម។

**គ.**រដ្ឋជាអ្នកសកម្មក្នុងកិច្ចការរដ្ឋបាល ហើយរួមចំណែក ៣៥% នៃតម្លៃបន្ថែមដោយសេវាកម្មផ្សេងៗ គឺស្មើនឹង ១៣% នៃផលទុនដុល។ រដ្ឋអន្តរាគមន៍លើវិស័យបីៈ

- ឧស្សាហកម្មគ្មានផ្សែង ″ សណ្ឋាគារ **Sokha** ″
- ធនាគារ និងធានារ៉ាប់រង ឱ្យបានធ្វើជាតូបនីយកម្ម នាឆ្នាំ ១៩៦៣
- ពាណិជ្ជកម្មក្រៅប្រទេសៈ បង្កើតឡើងនៅឆ្នាំ ១៩៦៣ ក្រុមហ៊ុនសេដ្ឋកិច្ចចម្រុះក្លាយជាក្រុមហ៊ុនរដ្ឋ។ ក្រុមហ៊ុននាំចេញ-ចូល **SONEXIM SONAPRIM OROC,Magain d'Etat** ធ្វើពាណិជ្ជកម្មធំៗ ការលក់រាយស្ថិតនៅលើឯកជន។សកម្មភាពរដ្ឋ លើសេវាកម្មស្ថិតក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ចទូទៅ។

# មេរៀនទី ៥
# ការប្រើប្រាស់ផលទុនជាតិ

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពី៖

- លំនឹងជញ្ជីងតុល្យភាពពាណិជ្ជកម្ម
- ការបែងចែកផលទុនជាតិ
- ការប្រើប្រាស់នៃគេហជន(គ្រួសារ)
- ការប្រើប្រាស់នៃវិនិយោគឯកជន
- ចំណាយរដ្ឋាភិបាល
- ការបង្កើតផលទុន

នៅក្នុងជំពូកមុនៗ យើងពិនិត្យមើលសកម្មភាពសេដ្ឋកិច្ចកម្ពុជា ក្រោមមុំផលិតកម្ម។ ការពិនិត្យបែបនេះជាអានុភាពមូលដ្ឋាន ហើយមានសារៈសំខាន់ខ្លាំង នៅត្រង់ការចង់ដឹងថាទ្រព្យធន និងសេវាកម្មអ្វីខ្លះ ដែលបង្កើតឡើងនៅក្នុងប្រទេស។ ការពិនិត្យទាំងនោះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ហើយគេត្រូវបន្ថែមនូវអ្វីដែលជាគណនេយ្យជាតិ បានហៅការពិនិត្យផ្សេងៗទៀតនៅជ្រុងនៃផលទុនចំណូល និងការចំណាយ។ ទន្ទឹមនឹងមានសកម្មភាពផលិតកម្ម ត្រូវមានសកម្មភាពបែងចែកនូវចំណូលផលទុន បើនិយាយមួយបែបទៀត គឺផលទុនដុលបានត្រូវបែងចែកតាមរបៀបណា? ចំណូលផលទុនដែលប្រមូលជាសមិទ្ធិផលត្រូវយកទៅចំណាយ ឬសន្សំ ដែលមានសារៈសំខាន់ត្រូវបញ្ជាក់ឱ្យច្បាស់។ ដូចនេះគណនេយ្យជាតិ ជាឧបករណ៍ដែលអនុញ្ញាតឱ្យបញ្ជាក់ច្បាស់ជាការចាំបាច់។

តើផលទុនជាតិ ត្រូវបានយកទៅបម្រើអ្វីខ្លះ? តើទ្រព្យធន និងសេវាកម្មអ្វីខ្លះ កើតមាននៅកម្ពុជា? ការ ត្រួតពិនិត្យ ដែលគេហៅថា ″ ការចំណាយរបស់ជាតិ ″ អាចឆ្លើយបាននូវសំនួរទាំងនេះ។ រចនាសម្ព័ន្ធនៃការចំណាយរបស់ជាតិ មានដូចតទៅនាឆ្នាំ ១៩៦២-១៩៦៣ និង ១៩៦៤ គិតជាភាគរយ៖

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| - ការប្រើប្រាស់របស់គេហជន | ៧០ | ៦៦ | .៦៤ |
| ការចំណាយរបស់រដ្ឋបាល | ២០ | ២១ | ៧១ |
| វិនិយោគនានា | ១៨ | ១៨ | ១៦ |
| - ការនាំចេញមិនសូវសំខាន់ | ៨ | ៤ | ១ |

តួលេខមានការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ដែលគួរឱ្យកត់សម្គាល់ គឺពាណិជ្ជកម្មក្រៅប្រទេស។ ប៉ុន្តែ សារៈសំខាន់បន្ទាប់បន្សំនៃការចំណាយទូទៅរបស់រដ្ឋបាល ការប្រើប្រាស់របស់គេហជន និងការបង្កើតទុន គឺមាន ចំនួនច្រើនភាគរយ។

## ៥.១.ការបែងចែកនូវផលទុនជាតិ

ផលទុនជាតិមិនប្លែកពីផលទុនដុលនោះទេ។ អ្វីដែលជាការចំណេញរបស់ភ្នាក់ងារសេដ្ឋកិច្ចរបស់ កម្ពុជា គឺអ្វីដែលពួកគេបានផលិត។ វានៅសល់ការចង់ដឹងថា តើផលិតផលដុលនោះត្រូវបានបែងចែក ″ ផលចំណេញ ″ តាមរបៀបណា? បញ្ហានេះអាចត្រូវបានសិក្សាបាន ជាបីផ្នែក៖

**ក.ជាបឋម** គេត្រូវសិក្សាតាមការបែងចែកទុនជាផ្នែក ដោយគិតទៅដល់ការរួមចំណែកនៃផ្នែកនីមួយៗនៃប្រជាជនសកម្មនៅក្នុងផ្នែកនោះ។ គេចង់ឃើញថា តើតម្លៃបន្ថែមជាមធ្យមនៃមនុស្សសកម្មមានការប្រែប្រួលបែបណាពីផ្នែកមួយទៅផ្នែកមួយទៀត គិតជាប្រាក់រៀល សម្រាប់ឆ្នាំ ១៩៦២៖

| | |
|---|---|
| ផ្នែកទីមួយ | ៧,៦៧០ |
| ផ្នែកទីពីរ | ៤១,៦០០ |
| ផ្នែកទីបី | ២៤,១០០ |
| កម្ពុជា | ៩,០៣០ |

ការគណនានេះ គឺជំពេងណាស់ ហើយតួលេខនេះត្រូវតែបកស្រាយដោយប្រុងប្រយ័ត្ន។ តម្លៃបន្ថែមនៃ ផ្នែកទីមួយ ចំណុះទៅនឹងតម្លៃនៃស្វ័យប្រើប្រាស់។ ចំពោះផ្នែកទីបី គឺជាកតិកាដែលអនុម័តបន្ថែមនូវការរួមវិភាគ ទាននៃផ្នែកនីមួយៗទៅនឹងចំណូលពន្ធដារ។ ភាពខុសគ្នានីមួយៗ គឺខ្លាំងក្លាណាស់។ ផលទុនមធ្យមនៃកសិករដែលរកបាន គឺ ៩ ដង តិចជាងពលករធ្វើការនៅក្នុងផ្នែកឧស្សាហកម្ម ហើយតិចជាង ៥ ដង ជាងពលករ ឬ និយោជិកនៅក្នុងផ្នែកសេវាកម្ម។ កសិករផលិតស្រូវម្នាក់រួមវិភាគទាន តែ ២,១០០ រៀលទេ ចំពោះផលទុនដុលជាតិក្នុងនាមជាកសិករ។ ប៉ុន្តែគេឃើញថា ការបានចូលរួមក្នុងសកម្មភាពពលកម្មផ្សេងៗទៀត ក្នុងផ្នែកសិប្បកម្ម ហើយ ចំណូលផលទុនរបស់គេមានកម្រិតខ្ពស់ជាងពីសកម្មភាពជាស្នូលរបស់ពួកគេ។ ដោយតួលេខនាឆ្នាំ ១៩៦២ ជាឆ្នាំអាក្រក់សម្រាប់ដំណាំស្រូវ។ ចំណែកនៅឆ្នាំ ១៩៦៣ និង ១៩៦៤ ជាឆ្នាំដែលផលិតផលស្រូវមានតម្លៃជាច់ខាតខ្ពស់ជាង។

តួលេខទាំងនេះ ជាតួលេខដុល ដែលមិនទាន់គិតដល់ទុនរំលោះ។ រឿងនេះមានសារៈសំខាន់នៅក្នុងផ្នែកកសិកម្ម និងឧស្សាហកម្ម។ ការយកចិត្តទុកដាក់ដល់ផ្នែកទាំងពីរនោះ ធ្វើឱ្យមានការថយចុះនូវផលទុនរបស់មនុស្សសកម្ម ពិសេសនៅក្នុងផ្នែកឧស្សាហកម្ម។ ផលិតភាព

ខុសគ្នារវាងផ្នែកទី ១ និងទី ២ បានបន្ថយ តែរវាងផ្នែកទី ១ និងទី ៣ ផលិតភាពកាន់តែកើនឡើង។

នៅគ្រប់ប្រទេសទាំងអស់ក្នុងសកលលោក ផលទុនរបស់កសិករ មានចំនួនទាបជាងផលទុនមធ្យម ព្រោះថាការរីកចម្រើនសេដ្ឋកិច្ច គឺជាការផ្លាស់ប្តូរ ពីសកម្មភាពកសិកម្ម ឆ្ពោះទៅកាន់សកម្មភាពសេវាកម្ម និងជាពិសេសឆ្ពោះទៅផ្នែកឧស្សាហកម្ម។ ប៉ុន្តែបាតុភាពគួរឱ្យកត់សម្គាល់នៅក្នុងប្រទេសកម្ពុជាងជាងនៅឯនាយសមុទ្រ។

| | កម្ពុជា | ប្រទេសក្រ | ប្រទេសក្រខ្លាំង |
|---|---|---|---|
| - ផ្នែកកសិកម្ម | ០.៥២ | ០.៨៤ | ០.៦៩ |
| - ផ្នែកឧស្សាហកម្ម | ៤.៦០ | ១.០៨ | ១.០៦ |
| - ផ្នែកសេវាកម្ម | ២.៧០ | ១.៥២ | ១.៣២ |
| - ប្រទេស | ១.០០ | ១.០០ | ១.០០ |

ផលិតភាពមិនដាច់ខាតរបស់ពលកម្មនៅកម្ពុជាមានភាពខ្សោយ ផ្នែកកសិកម្ម តែខ្លាំងនៅក្នុងផ្នែកមិនមែនកសិកម្ម។

**ខ.**ការបែងចែកផលទុនតាមមុខនាទី កាន់តែមានសារៈសំខាន់ តាមមធ្យោបាយផលិតកម្មនីមួយៗ ដូចជា ពលកម្មទុន គឺមានទាក់ទងនឹងការផ្តល់រង្វាន់ជាប្រាក់បៀវត្ស និងផលប្រយោជន៍ផ្សេងៗទៀត។ ក្រៅអំពីការទូរទាត់របស់កសិករ ទៅឱ្យគេហជនប្រមូលផ្តុំ សឹងតែទាំងអស់នៃផលទុនរបស់គេហជន ការទូរទាត់នោះ គឺជាបៀវត្ស ជាផលទុនចំណូល ជាកម្មសិទ្ធិ និងសហគ្រាស ″ ភាគរយសរុបនៃចំណូលផលទុនរបស់គេហជន ″ ។

| | |
|---|---|
| បៀវត្ស | ២៦ |
| ចំណូលទុននៃកម្មសិទ្ធិ និងសហគ្រាស | ៧២ |

តួលេខដូចគ្នាដដែល មាននៅឆ្នាំ ១៩៦២ ១៩៦៣ និង ១៩៦៤ ។ តួលេខនេះប្រហាក់ប្រហែលនឹងប្រាក់បៀវត្សនៃប្រជាជនសកម្ម៖ ១០.៧% នៅឆ្នាំ ១៩៦២។ ចំណូលមធ្យមនៃអ្នកបម្រើម្នាក់ទទួលបានបីដង ខ្ពស់ជាង ចំណូលរបស់អ្នកដែលមិនបានធ្វើការយកប្រាក់បៀវត្សគឺ ១៨,៩០០រៀល ទល់នឹង៦,២០០រៀល។ ប៉ុន្តែគម្លាតនៃចំណូល មានសារៈសំខាន់ណាស់។ ចំណូលផលទុននេះ ជាចំណូលផលទុនដុលពួកអ្នកមិនបានបម្រើយកបៀវត្សត្រូវដកចេញនូវទុនរំលោះនៃសម្ភារ និងឧបករណ៍មួយភាគនៃប្រាក់ចំណូល ៦,២០០ រៀល ត្រូវផាត់ទៅលើការប្រាក់ដើមទុនរកស៊ីថែមទៀត ហើយគណនាសព្វគ្រប់ទៅអ្នកមិនបម្រើយកបៀវត្ស ទទួលបានប្រាក់ចំណូលផលទុនតែ ៥,០០០ រៀលប៉ុណ្ណោះ។ អ្នកមិនបម្រើយកប្រាក់ខែ

គឺជាកសិករសុទ្ធសាធ។ នៅប្រទេសក្រីក្រ អ្នកបម្រើយកប្រាក់ សុទ្ធតែមានបុព្វសិទ្ធិបង្គួរដែរ។ ដូចនេះគេយល់ច្បាស់ណាស់ថា យុវជនចង់បានសញ្ញាបត្រ ដើម្បីឱ្យគេរកបាន ពលកម្មដែលមានបៀវត្ស ។

ចំណូលផលទុនសុទ្ធនៃពួកមូលធន ទាំងការប្រាក់ ទាំងទ្រព្យធនដើម គឺជាផ្នែកមួយមានសារៈសំខាន់ដែរ គឺស្មើនឹង ១,៥ % នៃចំណូលទុនសរុបរបស់គេហជន។ ហើយគណនេយ្យជាតិ មិនបានគិតគូរដល់ការប្រាក់បន្ថែមផង។ ការប្រាក់បុលបណ្តាក់ ចងការ ឈ្នួលដី មិនត្រូវបានរាប់បញ្ចូល ក្នុងគណនេយ្យសេដ្ឋកិច្ចនៅឡើយនោះទេ។ ដូចនេះ ចំណូលពួកមូលធនមានចំនួនច្រើនជាងនេះ តែតួលេខមិនទាន់គិតដល់។

**គ.**ការបែងចែកផលទុនតាមបុគ្គល នៅមិនទាន់ដឹងច្បាស់ទេនៅកម្ពុជា។ មិនទាន់មានការអង្កេត ស្តីពី ប្រធានបទ និងស្ថិតិពន្ធអាករ លើបញ្ហានេះនៅឡើយ។ ប៉ុន្តែការពិតការបែងចែងតាមបុគ្គលនេះ មានវិសាលភាពខ្លាំងណាស់។ និយោជិក ដែលបម្រើនៅផ្នែកមិនមែនកសិកម្មមានចំនួន ២០% នៃប្រជាជនសកម្ម ទាញយក ៦០% នៃចំណូលផលទុនជាតិ។ ប៉ុន្តែនៅក្នុងផ្ទៃក្នុងនៃផ្នែកទាំងពីរ គឺឧស្សាហកម្ម និងសេវាកម្ម ចំណូលនេះ កាន់តែមានភាពខុសគ្នាឆ្ងាយទៅទៀត រវាងថៅកែ និងកូនឈ្នួល និងរវាងម្ចាស់សហគ្រាស និងនិយោជិក រវាងមន្ត្រីជាន់ខ្ពស់ និងមន្ត្រីតូចៗ។ គេដឹងថា មានបុគ្គល ១២៥,០០០ នាក់ ជាអ្នកមានបំផុត គឺស្មើនឹង ៥% នៃប្រជាជនសកម្ម បានទទួលផលទុនចំណូលដល់ ៣០% ។ តួលេខនេះជាធម្មតាទេ នៅក្នុងប្រទេសក្រីក្រ។ ពួកគេទាំងនេះជាតំណាងអត្ថន័យសំខាន់របស់សង្គម។ ប៉ុន្តែគេក៏ផ្តល់នូវផលវិបាកជាច្រើនដល់សេដ្ឋកិច្ចដែរ៖ ពួកអ្នកមាន ជាអ្នកសន្សំទ្រព្យធន ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

គេអាចចោទសួរចំណូលផលទុនមធ្យមរបស់មនុស្សម្នាក់ៗ ប៉ុន្តែគេត្រូវឆ្លើយដោយប្រុងប្រយ័ត្នបំផុត។បើយើងឱ្យតម្លៃទុនរំលោះដល់ ៥% នៃផលទុនរបស់ជាតិ គេធ្វើគណនាជាចំណូលផលទុនមធ្យមនៃមនុស្សម្នាក់ ស្មើនឹង ៣,៣០០ រៀល នាឆ្នាំ ១៩៦២ ហើយ ៣,៦០០ រៀល នាឆ្នាំ ១៩៦៣ ឬ ៣,៨០០ រៀល នាឆ្នាំ ១៩៦៤ ។ ប៉ុន្តែដោយសារភាពជាសារវន្តនៃតួលេខ ប្រមូលផ្តុំនូវព័ត៌មានច្រើនពេក រឿងនេះមិនជាចំណុចសំខាន់ប៉ុន្មានទេ។ ពេលខ្លះគេបដិសេធ មិនព្រមគិតលុយជាដុល្លារ ដើម្បីប្រៀបធៀបជាមួយអន្តរជាតិ។ ភាពខុសគ្នានៃរចនាសម្ពន្ធ័ថ្លៃនេះ មិនគិតជាលក្ខណៈអនាធិបតេយ្យនៃអត្រាប្តូរប្រាក់ផងនោះ ធ្វើឱ្យលំហាត់បែបនេះគ្មានន័យទាំងស្រុង។

## ៥.២.ការប្រើប្រាស់នៃគេហជន

គេត្រូវបញ្ចូលការប្រើប្រាស់របស់គេហជននៅក្នុងចំណាយទាំងអស់របស់គេហជនជាភាគរយសរុបនៃផលទុនចំណូលរបស់គេហជនៈ

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ការប្រើប្រាស់ | ៨៣ | ៧៨ | ៧៦ |
| ពន្ធផ្ទាល់ | ៤ | ៤ | ៤ |
| សន្សំ | ១១ | ១៥ | ១៧ |
| ផ្សេងៗ | ២ | ៣ | ៣ |

ការប្រើប្រាស់ គឺជាទ្រព្យធនដែលចំណាយជាធម្មតារបស់គេហជន។ រចនាសម្ព័ន្ធនៃការប្រើប្រាស់ ដោយការខ្វះខាតនៃការសង្កេតលើថវិកានៃគេហជន មិនបានដឹងតួលេខពិតប្រាកដទេ។ ប្រធានបទនេះ មានបញ្ជាក់តាមការសន្និដ្ឋានរបស់គណនេយ្យជាតិដោយឡែក និងតាមរយៈការអង្កេតមួយ ស្តីអំពីថវិការបស់គេហ ជននៅភ្នំពេញ ដែលបានធ្វើឡើងនៅឆ្នាំ ១៩៦២ ជាតួលេខមួយទៀត។

**ក**.នៅឆ្នាំ ១៩៦៣ គេបានប្រមូលផ្តុំរាល់តួលេខ ស្តីអំពីការប្រើប្រាស់សរុបនៃគេហជនដោយបែងចែកដាច់ពីគ្នា រវាងផលិតផលនាំចូល និងក្នុងស្រុក ។ នៅពេលដែលតួលេខបានត្រូវរៀបចំក្នុងបណ្តាឆ្នាំច្បាស់លាស់ការប្រៀបធៀបតួលេខរវាងឆ្នាំទៅនោះ អាចឱ្យមានការសិក្សាពីការវិវដ្តនៃរចនាសម្ព័ន្ធការប្រើប្រាស់។ នាពេលសព្វថ្ងៃ គេអាចបញ្ជាក់បានត្រឹម រចនាសម្ព័ន្ធគិតជាភាគរយសរុបនៃការចំណាយសម្រាប់ការប្រើប្រាស់។

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ស្បៀងអាហារ | ៧១.៥ | ៧១ | ៧៣ |
| លំនៅដ្ឋាន | ៩ | ៨ | ៩ |
| សម្លៀកបំពាក់ | ៧.៥ | ១០ | ៧ |
| ការដឹកជញ្ជូន | ៥ | ៤ | ៥ |
| លម្ហែ វប្បធម៌ អនាម័យ | ៧ | ៧ | ៧ |

ការចំណាយទៅលើអង្ករ ឈរនៅលើជួរទី ១ នៃការចំណាយរបស់ជនកម្ពុជា ព្រោះការចំណាយនេះបង្ហាញជិត ១/៤ នៃចំណាយទាំងអស់ ។ បន្ទាប់មក គឺការចំណាយទិញផ្លែឈើបន្លែ " ប្រហែលជាង ១៥% " ហើយការចំណាយសម្រាប់ សាច់ទា មាន់ និងត្រី " ប្រហែល ១២% " ។

បរិមាណការប្រើប្រាស់ផលិតផលស្បៀងតាមមនុស្សម្នាក់ៗ មានស្ថេរភាព " ជា គ.ក្រ. និងតាមឆ្នាំ " ៖

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| អង្ករ | ១៤៧ | ១៥៣ | ១៤៦ |
| បន្លែ | ៥៩ | ៦០ | ៦៥ |
| ផ្លែឈើ | ៤០ | ៤១ | ៤៣ |
| ត្រី | ២៧ | ២១ | ២២ |
| សាច់ | ៧ | ៥ | ៨ |

តាមតួលេខខាងលើនៅកម្ពុជា គ្មានអ្នកខ្វះស្បៀង ឬខ្វះចំណីបំប៉នទេ។ អ្នកទេសចរបានបញ្ជាក់ នៅក្នុងពេលទស្សនៈកិច្ចនៅកម្ពុជាថា មនុស្សមានមុខស្រស់ និងមានសាច់ឈាមល្អ មិនដូចនៅប្រទេសអាស៊ីខ្លះ ដែលនៅបង្ហាញពីភាពទុរភិក្សនោះទេ។

**ខ**.ការធ្វើអង្កេត ស្ដីពីការប្រើប្រាស់នៃគេហជននៅភ្នំពេញ បានបញ្ជាក់ឱ្យយើងដឹងតែពីចរិតនៃគេហជនមួយចំនួននៅប្រហែល ៦% ប៉ុណ្ណោះ ។ គេហជនមួយភាគនៅភ្នំពេញ មានចំណូលខ្ពស់ ព្រោះពួកគេធ្វើការនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម។ ១/៣ នៃការចំណាយប្រើប្រាស់របស់ព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តទៅនៅភ្នំពេញ ។ ពិតហើយការអង្កេតធ្វើឡើងនាឆ្នាំ ១៩៦២ គិតតែទៅលើចរិតនៃអ្នកស៊ីប្រាក់ខែធ្វើពល-កម្ម ដោយហត្ថកម្ម មិនបាននិយាយដល់ជនបរទេស ដល់នយោជិក មន្ត្រីជាន់ខ្ពស់ និងអ្នកមានចំណូលទុនខ្ពស់នៅឡើយ។

លទ្ធផលនៃការអង្កេត ប្រមូលផ្ដុំលើចំណុចពីរនៃគណនេយ្យសេដ្ឋកិច្ច គិតជាភាគរយៈ

| | |
|---|---|
| ស្បៀងអាហារ | ៦៧ |
| ក្នុងនោះថ្នាំជក់ ម្លូស្លា ស្រា | ៤ |
| ជម្រក និងការជួសជុល ថែទាំ | ១១ |
| សម្លៀកបំពាក់ | ៥ |
| ផ្សេងៗ | ១៧ |

គេកំណត់សម្គាល់ថារចនាសម្ព័ន្ធនៃការប្រើប្រាស់ប្រហាក់ប្រហែលគ្នានៅក្នុងផ្នែកទីបីនៃសង្គមវិជ្ជាជីវៈដែលបានបែងចែកដោយការអង្កេត" បៀវត្ស " ដោយហត្ថកម្ម ប្រើខួរក្បាល និងពលករផលិតយកផលផ្ទាល់។ការអង្កេតពិនិត្យលើភាពខុសគ្នាក្នុងរចនាសម្ព័ន្ធចំណូលផលទុនដែលធ្វើឱ្យកម្មករ និយោជិក ដែលមានចំណូលទាប ប្រើប្រាស់ស្បៀងតិច។ គេប្រមូលផ្ដុំជាក្រុមនូវគេហជន ទៅតាមកម្រិតប្រើប្រាស់។ គេអាចបែងចែកការប្រើប្រាស់របស់គេហជន ដែលចំណាយតិចជាង ២០០ រៀល តាមអង្គភាពនៃការប្រើប្រាស់ និងខែ ពីការចំណាយរបស់

គេហជន ដែលចំណាយពី ២០០ ទៅ ៤០០ រៀល ក្នុងអង្គភាពនៃការប្រើប្រាស់ និងតាមខែនីមួយៗ។ល។ គេអាចទាញចេញពីការសន្និដ្ឋាននេះនូវភាពយឺត ″ Elasticité ″ ធៀបនឹងចំណូលផលទុន ″ revenue ″ ធៀបនឹងចំណាយសរុបនៃតម្រូវការនៃទំនិញប្រើប្រាស់ផ្សេងៗ៖

| | |
|---|---|
| ចំណាយស្បៀងអាហារ | ០.៧១ |
| អង្ករ | ០.៣៤ |
| ត្រី | ០.៤២ |
| សាច់ | ០.៨២ |
| ចំណាយមិនមែនស្បៀង | ១.៤៩ |
| សម្លៀកបំពាក់ | ១.៥៤ |

តួលេខទាំងនេះ ផ្តល់សម្រាប់ទំនិញនីមួយៗ នូវគំនិតនៃកំណើននូវការប្រើប្រាស់ ដែលនាំឱ្យមានការកើនឡើងនូវចំណូលផលទុន ឬឱ្យកើនឡើងនូវការចំណាយសរុប។ បើការចំណាយសរុបកើន ១០% ការចំណាយលើសម្លៀកបំពាក់កើន ១៥% ។ តួលេខទាំងនេះអនុញ្ញាតឱ្យតែទុកជាមុននូវខ្សែបន្ទាត់នយោបាយ សម្រាប់ការវិវដ្តនៃរចនាសម្ព័ន្ធនៃការប្រើប្រាស់។

តួលេខអង្កេតទាំងនោះ មិនគ្រប់គ្រាន់ទេ តែធ្វើឱ្យគេដឹងពីការប្រើប្រាស់នៃគេហជន។ ការសិក្សាពីការ បង្កើតទុន គឺជារឿងមួយទៀតនៃការបង្កើតគុណភាព សម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។

## ៩.៣.ការប្រើប្រាស់នៃវិនិយោគឯកជន

គឺជាការប្រើប្រាស់ផលិតផលមួយផ្នែកដោយក្រុមហ៊ុនឯកជនសម្រាប់ផលិតផលិតផលនាពេលអនាគតត្រូវបានគេអោយឈ្មោះថាការវិនិយោគ។ ការចំណាយទៅលើការវិនិយោគអាចបង្ហាញរូបភាពជាផ្នែកមួយនៃGNPប្រើប្រាស់ដើម្បីបង្កើនភាគហ៊ុនជាតិ។ ដែកថែបហើយនិងឥដ្ឋប្រើសម្រាប់សាងសង់រោងចក្រ គឺជាផ្នែកមួយនៃការចំណាយទៅលើការវិនិយោគរួមផងដែលនូវសេវាកម្មដែលផ្តល់ដោយអ្នកបច្ចេកទេសដែលជួយបង្កើតជំនួញផ្នែកកុំព្យូទ័រ។ សហគ្រាសទិញសន្និធិក៏រាប់ផងដែរ ក្នុងការចំណាយទៅលើការវិនិយោគ ពីព្រោះសន្និយោងបន្តគឺជារបៀបមួយដែលសហគ្រាសផលិតនាពេលបច្ចុប្បន្នទៅប្រើប្រាស់នាពេលអនាគត។ ការវិនិយោគគឺមានបំរែបំរួលច្រើនជាងការប្រើប្រាស់ នៅសហរដ្ឋអាមេរិចចំនួនសន្និធិសរុបមានការប្រែប្រួលចន្លោះពី១២ទៅ១៩ភាគរយនៃGNPនៅក្នុងឆ្នាំថ្មីៗនេះ។ យើងជាញឹកញាប់ប្រើប្រាស់ពាក្យការវិនិយោគតែសម្រាប់ពិពណ៌នាការទិញហ៊ុន,ប័ណ្ណបំណុលនិងអចលនទ្រព្យ អ្នកគួរប្រយ័ត្នច្រឡំជាមួយនិងនិយមន័យសេដ្ឋកិច្ចនៃការវិនិយោគជាសមាសភាគនៃGNP នៅពេលអ្នកទិញភាគហ៊ុនរបស់ក្រុមហ៊ុន Microsoft មិនមែនជាការទិញទំនិញរឺសេវាកម្មនោះការទិញរបស់អ្នកមិនបង្ហាញក្នុងGNPនោះទេ។

## ៥.៤.ចំណាយរដ្ឋាភិបាល

ទំនិញហើយនិងសេវាកម្មផ្សេងៗដែលបានទិញដោយសហព័ន្ធ,រដ្ឋ,រឺតំបនគឺជាចំណាយរបស់រដ្ឋាភិបាលនៅក្នុងគណនេយ្យចំណូលជាតិ។ រួមបញ្ចូលទាំងការចំណាយរបស់រដ្ឋាភិបាលទៅលើសហព័ន្ធកងទ័ព ការចំណាយទៅលើការស្រាវជ្រាវជំងឺមហារីក ហើយនិងមូលនិធិរបស់រដ្ឋាភិបាលចំណាយលើការជួសជុលផ្លូវហើយនិងការអប់រំ។ រដ្ឋាភិបាលបានផ្ទេរការចំណាយដូចជាសន្តិសុខសង្គមហើយនិងថវិការខ្លះៗសម្រាប់អ្នកអត់ការងារធ្វើហើយមិនទាមទាអោយអ្នកដែលទទួលផ្តល់ទំនិញរឺសេវាកម្មត្រលប់មកវិញទេ។ ដូចនេះការផ្ទេរការចំណាយមិនរួមបញ្ចូលការចំណាយរបស់រដ្ឋាភិបាលទេ។

## ៥.៥.ការបង្កើតទុន

ការបង្កើតទុន គឺជាវិនិយោគដែលជាការចាំបាច់ សម្រាប់ការអភិវឌ្ឍប្រទេសមួយ។ ក្នុងរយៈពេលរីកចម្រើនល្អអស់ ១៥ ឆ្នាំ ពីឆ្នាំ ១៩៤៥ ដល់ ១៩៦០ អ្នកសេដ្ឋកិច្ចបានបង្កើននូវរូបភាពសំខាន់ៗ ជាមូលដ្ឋានតែមួយនៃការអភិវឌ្ឍហើយគំរូនៃអត្រាកំណើនពីការចាប់ផ្តើមនៃអត្រាវិនិយោគដែលមិនអាចខ្វះបាន។ នៅក្នុងអភិក្រមនៃការអភិវឌ្ឍតួនាទីនៃការរីកចម្រើនបច្ចេកទេសអត្តចរិតរបស់មនុស្ស គឺមិនសូវសំខាន់ដល់តួនាទីនៃកត្តាទុនឡើយ។ ហើយកំណើនមិនអាចកើតមានបាន ដោយខ្វះលទ្ធភាពនៃការវិនិយោគទេ ។

វាមានការខ្វះព័ត៌មានច្រើន ស្តីអំពីការវិវឌ្ឍនៃការវិនិយោគទុនមុនឆ្នាំ ១៩៦២ ការវិនិយោគផ្នែកឯកជន ទើបបានដឹងច្បាស់ តាមរយៈមធ្យោបាយនៃការសន្និដ្ឋាន ដោយគ្មានមូលដ្ឋានហើយការវិនិយោគសាធារណៈទៀតសោធ នៅមានការលំបាកក្នុងការបញ្ជាក់ឱ្យច្បាស់លាស់។ ការបែងចែក រវាងថវិកាផែនការ ដែលសម្រាប់ទូទាត់ចំណាយវិនិយោគ និងថវិកាជាតិ សម្រាប់ធានាដល់ការចំណាយនៃការប្រព្រឹត្តទៅរបស់រដ្ឋបាលដោយឡែកទៀត គឺ មិនបានត្រូវគោរពច្បាស់លាស់ទេះ តាមអង្គហេតុនានា ឥណទាន ទិញសម្ភារនៃផែនការ បានយកទៅបម្រើ ដោះស្រាយការចំណាយនៃការប្រព្រឹត្តទៅនៃផ្នែកសេវានានា។ ទន្ទឹមនោះ ប្រតិបត្តិការនៃការវិនិយោគត្រូវបានធានាដោយថវិកាជាតិ។ គេរង់ចាំនូវការរៀបចំគណនេយ្យជាតិ ដើម្បីឱ្យមានតួលេខប្រើប្រាស់បាន ក្នុងការបង្កើតទុននៅកម្ពុជា។

យើងពិនិត្យជាបន្តបន្ទាប់ នូវបញ្ហាដែលជាប់ទាក់ទងនឹងកម្រិតទុន រចនាសម្ព័ន្ធហិរញ្ញវត្ថុនិងទិន្នផលនៃការវិនិយោគ។

**ក.**ស្តីអំពីកម្រិតទុនវិនិយោគនៅកម្ពុជា គេមានតួលេខពីរ។ សមាមាត្រនៃការបង្កើតទុនដើមដុល ទៅនឹងផលទុនដុលរបស់ជាតិនៅឆ្នាំ ១៩៦២ ក៏ដូចនៅឆ្នាំ ១៩៦៣ ប្រហែល ១៧% ។ ការកើនឡើងនូវស្តុក គឺជារូបភាពមួយនៃការវិនិយោគនៅសម័យនោះ តំណាងឱ្យ ១% នៃផលទុនជាតិដុល។ នៅឆ្នាំ ១៩៦៤ តួលេខវិនិយោគ ទាបជាងភាគរយខាងលើ។

តួលេខនេះខ្ពស់ ប៉ុន្តែទាបជាងការកត់សម្គាល់ទូទៅនៅក្នុងប្រទេសលូតលាស់ គឺប្រហាក់ប្រហែលអត្រាវិនិយោគនៅប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិច ប៉ុន្តែវាខ្ពស់ជាងអត្រានៃប្រទេសអន់ថយ។ ប្រទេសកម្ពុជាមានការវិនិយោគច្រើន។ នេះគឺជាការធានាដល់ការអភិវឌ្ឍ។

**ខ.**វាត្រូវតែមាននូវការផ្តល់ការវិនិច្ឆ័យខុសៗគ្នា តាមរយៈការវិភាគរចនាសម្ព័ន្ធ នៃវិនិយោគ ដែលមាន សារៈសំខាន់លើកម្រិតចំនួនទុន។ តារាងខាងក្រោមផ្តល់ភាគរយនៃវិនិយោគ៖

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| - សំណង់ | ៤៨ | ៥១ | ៤៨ |
| សាធារណៈការ | ១៧ | ២១ | ១៥ |
| ម៉ាស៊ីន និងឧបករណ៍ | ២៥ | ២១ | ១៨ |
| ស្តុក | ១០ | ៧ | ១៨ |
| - សិក្សា និងស្រាវជ្រាវ | - | - | ១ |

ភាគចំណែកនៃការវិនិយោគផ្ទាល់ ផ្នែកផលិតកម្មលេចចេញក្នុងស្ថានភាពខ្សោយ។ ការវិនិយោគនៃ សហគ្រាសសាធារណៈ និងឯកជន ដែលត្រូវរាប់ទាំងការទិញម៉ាស៊ីន និងឧបករណ៍របស់រដ្ឋបាល មានប្រហែល ១/៤ នៃការវិនិយោគទាំងអស់។ ការវិនិយោគបែបនេះ គឺការបង្កើតនូវប៉ុស្តិ៍ការងារ ការបង្កើតពលកម្ម ទន្ទឹមនឹង ការកើនឡើងនៃការដែលធ្វើឱ្យមានការអភិវឌ្ឍប្រទេស។

ការវិនិយោគផ្នែករដ្ឋបាល រួមមានរចនាសម្ព័ន្ធសិក្សាធិការ។ល។ រួមវិភាគទានដល់ការអភិវឌ្ឍប្រទេស ប៉ុន្តែការរួមចំណែកមិនផ្ទាល់៖ គ្រាន់តែបង្កើតលក្ខខ័ណ្ឌនានាដល់ការអភិវឌ្ឍ។ យើងគ្រាន់តែចង់ដឹងថា ការវិនិយោគលើសំណង់អាគារ ការងារសាធារណៈនៃរដ្ឋបាល ប្រៀបនឹងការចំណាយនៃការវិនិយោគទាំងអស់នៅ កម្ពុជាមានកម្រិតខ្ពស់ឬទេ។

បញ្ហាស្រួលដោះស្រាយទេ ស្តីអំពីការវិនិយោគក្រោមរូបភាពលំនៅដ្ឋាន។ ការរីកចម្រើននៃទីក្រុងនៅ កម្ពុជា ធ្វើឱ្យមានសេចក្តីត្រូវការ ការសាងសង់ក្នុងតម្លៃខ្ពស់។ លំនៅដ្ឋានដែលមាន ១/៣ នៃការវិនិយោគសរុប ស្រូបយកប្រភពទុនដ៏កម្រនេះច្រើនណាស់ ដោយគ្មានរួមចំណែកដល់ការបង្កើតសមត្ថភាពផលិតកម្មប្រទេស ឡើយ។

នៅកម្ពុជា ពុំមានយន្តការសន្សំទុនពីកសិករឡើយ។ ប្រតិបត្តិការសន្សំ និងចំណាយប្រព្រឹត្តទៅនៅក្នុង ផ្នែកក្នុងនៃហោបៅផ្ទាល់របស់កសិករ គឺស្ថិតនៅក្នុងស្ថានភាពនៃស្វ័យហិរញ្ញវត្ថុ។ ប៉ុន្តែនៅផ្នែកឧស្សាហកម្ម និងសេវាកម្ម ពិសេសគេហជននៅទីក្រុង បេះសន្សំប្រាក់ដោយផ្ញើនៅធនាគារ ហើយការសន្សំនេះមិនបានផ្គត់ផ្គង់ទៅ រកការវិនិយោគផ្នែកផលិតកម្មទេ គឺដូចការចាក់ទឹកនៅកណ្តាលវាលខ្សាច់។ អវត្តមាននៃស្ថាប័នសន្សំប្រាក់របស់ កសិករ ធ្វើឱ្យគេរក ″ ច្រក ″ ចេញមិនរួច ពីរង្វង់កម្ម ″ Cercle Vicieux ″ ដោយមិនអាចសន្សំទុនវិនិយោគមធ្យម ឬធំនៃវិស័យកសិកម្មបាន។ នៅកម្ពុជាចាំបាច់មានលទ្ធភាពនៃការផ្ញើប្រាក់ដែលមានភាពធម្មតា និងធានាប្រាកដនិយម ដែលមានផលប្រយោជន៍ដល់ប្រទេស។

ផ្នែករដ្ឋបាលនានា លេចឡើងមានសារៈសំខាន់ណាស់នៃការ ˝ វិនិយោគ ˝ របស់ប្រទេសព្រោះផ្នែកនេះ ប្រព្រឹត្តទៅ និងផ្តល់ជាហិរញ្ញវត្ថុជាង ១/៣ នៃការវិនិយោគទាំងឡាយ។ មួយភាគចំណែកនៃការវិនិយោគនេះបានផ្តល់ជាហិរញ្ញវត្ថុដោយ ˝ ការសន្សំប្រាក់ ˝ របស់ផ្នែករដ្ឋបាល គឺផលលើសនៃចំណូល ˝ recette ˝ លើការចំណាយទូទៅ។ នៅសល់ប៉ុន្មាន បានត្រូវផ្តល់ហិរញ្ញវត្ថុដោយបំណុល។ ការបង្ហាញកម្មវត្ថុបែបនោះ នាំទៅដល់ការភាន់ ច្រលំ ក្នុងវិធានការដែលនៅក្នុងចំណូលរដ្ឋបាល រួមមានជំនួយបរទេសផងដែរ ដែលបម្រើឱ្យការវិនិយោគ ដូចនេះពាក្យថាការសន្សំរបស់រដ្ឋបាល បាត់បង់នូវអត្ថន័យរបស់ខ្លួន។ ការខិតខំរបស់ផ្នែករដ្ឋបាលនៅទីនេះ គឺនាំតាមរយៈខ្ចីបុល តាមរយៈជំនួយបរទេស និងសន្សំក្នុងប្រទេស ដើម្បីបម្រើការវិនិយោគ...។

ការសន្សំរបស់សហគ្រាស ដែលភាគច្រើន គឺជាការសន្សំ ˵ រយៈពេលខ្លី ˵ គឺចាំបាច់សម្រាប់ការអភិវឌ្ឍ ប្រទេស។ សហគ្រាសបុគ្គល ˵ entreprises individuelle ˵ គឺសន្សំបានច្រើនណាស់។ ការសន្សំក្នុងសហគ្រាស បុគ្គលបានល្អបែបនេះ គ្មានអ្វីភ្ញាក់ផ្អើលទេ ព្រោះនៅកម្ពុជាមានតែសហគ្រាសកសិកម្ម សហគ្រាសឧស្សាហកម្ម សេវាកម្មតូចៗជាមូលដ្ឋាន។ ការវិនិយោគនានា ដែលគេបានឃើញ គឺផ្តល់ហិរញ្ញវត្ថុផ្ទាល់ពីការសន្សំរបស់គេហជន ជាម្ចាស់កម្មសិទ្ធិនៃសហគ្រាសទាំងនោះ។

សហគ្រាសក្រុមហ៊ុនធំៗ ឯកជន និងចម្រុះ ធ្វើវិនិយោគច្រើនជាងសហគ្រាសបុគ្គល។ ការវិនិយោគនៃ សហគ្រាសធំៗទាំងនោះ ផ្តល់ហិរញ្ញវត្ថុ ដោយការសន្សំរបស់ក្រុមហ៊ុនទាំងឡាយ ដែលក្រោយពីទទួលបានលទ្ធផលនៃការធ្វើអាជីវកម្មហើយបានបញ្ចូលការបង់ពន្ធ និងសងការប្រាក់រួចសន្សំសម្រាប់ធ្វើស្វ័យហិរញ្ញវត្ថុ។

ស្ថានភាពនៃសហគ្រាសសាធារណៈ ហាក់ដូចជាមិនសូវជាទីពេញចិត្តសោះ។ ប្រាក់ចំណេញនៃសហគ្រាសទាំងនោះមានភាពខ្សោយ ហើយទទួលការជួយឧបត្ថម្ភពីរដ្ឋ ក៏មិនអាចធ្វើប្រតិបត្តិការវិនិយោគ ដោយគ្មានការខ្ចីបុលនោះឡើយ។ សហគ្រាសសឹងតែទាំងអស់ មានការខ្ចីបុលតិចតួច ហើយដើមហេតុនៃការខ្វះសៀគ្វី គឺហិរញ្ញវត្ថុ។

ស្នាមគួរឱ្យកត់សម្គាល់ នៃការផ្តល់ហិរញ្ញវត្ថុសម្រាប់ការវិនិយោគ សហគ្រាសផ្សេងៗទៀត គឺការអវត្តមានទាំងស្រុងនៃការវិនិយោគបរទេស។ ការវិនិយោគរបស់ក្រុមហ៊ុនឯកជន និងចម្រុះ ជាវិធានការនៃវិនិ-យោគបរទេស ព្រោះក្រុមហ៊ុនឯកជន ពិសេសក្រុមហ៊ុនចំការកៅស៊ូ ជាក្រុមហ៊ុនបរទេសដែលធ្វើការវិនិយោគ។ ប៉ុន្តែនោះជាការវិនិយោគឡើងវិញនៃប្រាក់ចំណេញនៅនឹងកន្លែង។ ក្នុងទសវត្សឆ្នាំ ១៩៥០-១៩៦០ សឹងតែគ្មានការវិនិយោគ បរទេសច្រើនទេនៅកម្ពុជា។ ប៉ុន្តែផ្នែកសហគ្រាសសាធារណៈបានទទួលទុនពីសាធារណៈបរទេស។

ការសង្ខេបដោយមានការកត់ចំណាំនូវចំណុចមួយចំនួន ស្តីអំពីការផ្តល់ហិរញ្ញវត្ថុវិនិយោគនៅកម្ពុជា គឺភាគចំណែកតិចតួចនៃសហគ្រាស តួនាទីសំខាន់នៃស្វ័យហិរញ្ញវត្ថុ ហើយនិងអវត្តមាននៃយន្តការហិរញ្ញកិច្ច ដែលជួយដល់ការសន្សំឯកជនយ៉ាងសំខាន់ ឱ្យគេចូលរួមក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ការវិនិយោគ។

គ.គេអាចសួរអំពីទិន្នផលនៃការវិនិយោគនានា។ បើគេគិតទៅដល់កម្រិតនៃការបង្កើតទុន " ដុល " ជា មធ្យមនៅឆ្នាំ ១៩៦២ និង ១៩៦៣ ប្រហែល ៤,៣០០ លានរៀល នៃការកើនឡើងនូវផលទុនទទួលបាន ជា មធ្យមក្នុងរយៈពេល ២ ឆ្នាំ ប្រហែល ១,៥០០ រៀល គេអាចឱ្យនិយមន័យនៃអត្រាកំណើនទុនដល់ទៅ ២.៨% ។

របនាសម្ព័ន្ធវិនិយោគគឺមានកម្រិតខ្ពស់នៃប្រតិបត្តិការសំណង់ដែលទិន្នផលទទួលបាននៅឆ្នាំ ១៩៦២ និង១៩៦៣លេចឡើងខ្ពស់។ការខិតខំវិនិយោគសម្រេចឡើងដោយកសិករក្រោមរូបភាពនៃការបង្កើនដីដាំដុះឬបង្កើតនូវសហគ្រាសបុគ្គលតូចៗបានបង្កើននូវសកម្មភាពផលិតកម្មថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៍ធំៗដល់ប្រទេស។

ការធ្វើគណនាបន្ថែមនៃការវិនិយោគរបស់គេហជន ជាថាមពល និងប្រសិទ្ធភាពនៃការរីកចម្រើនសេដ្ឋកិច្ចមិនទាន់ប្រមូលផ្តុំបាននៅឡើយ ។

កំណត់សម្គាល់នានា ស្តីពីការបែងចែក និងការប្រើប្រាស់ផលទុនរបស់ជាតិ បំពេញបន្ថែមនូវសកម្ម ភាពសេដ្ឋកិច្ចកម្ពុជា។ យើងពិនិត្យសកម្មភាពនៃប្រតិបត្តិការពាណិជ្ជកម្ម ដោយធ្វើការវិភាគថែមទៀត នូវពាណិជ្ជកម្មក្នុង និងក្រៅប្រទេស។

## ៥.៦.លំនឹងនៃជញ្ជីងពាណិជ្ជកម្ម

ប៉ុន្តែដែលរកបានផលលើសនៃជញ្ជីង គឺជំនួយបរទេស។ ពីឆ្នាំ ១៩៥៦ ដល់ ១៩៦៤ កម្រិតនៃប្រាក់ជំនួយ មិនតិចជាង ២០ លានដុល្លារទេ។ នៅឆ្នាំ ១៩៥៧ ជំនួយឡើងដល់ ៥៦ លានដុល្លារ។ ប្រសិទ្ធភាពនៃជំនួយនោះ គឺ ពិតជាវាស់វែងមិនសូវល្អ ដោយតួលេខនានាទេ។ គឺជំនួយបរទេសនោះហើយ ដែលជួយដល់កម្ពុជា ជំនះបាននូវរាល់ក្តីលំបាកទាំងឡាយនៃតំណាក់កាលនោះ នូវរាល់ការដោះស្រាយជញ្ជីងពាណិជ្ជកម្ម និង ជញ្ជីងទូទាត់ដទៃទៀត ដែលតែងតែជួបឱនភាព។

គឺរូបិយប័ណ្ណសន្សំ ដែលបំពេញឱ្យការខាតផ្នែកពាណិជ្ជកម្មក្រៅប្រទេស និងការទូទាត់ផ្សេងៗទៀត ធ្វើឱ្យកម្ពុជា បម្រុងទុកបាននូវមាស និងរូបិយប័ណ្ណយ៉ាងសំខាន់។ ជានិយមន័យជញ្ជីងទូទាត់មានលំនឹង។ លំនឹងនៃការនាំចូល និងការនាំចេញនៃរូបិយប័ណ្ណ ហើយធានាបាននូវចលនាមាស និងរូបិយវត្ថុ និងម្ចាស់ឥណទាននៅបរទេស ។ រវាងឆ្នាំ ១៩៥៦-១៩៦៤ កម្ពុជាមិនជំពាក់បំណុលក្រៅប្រទេសទេ ធ្វើឱ្យកម្ពុជាមានស្តុកមាស និង រូបិយប័ណ្ណដ៏ច្រើនទៀតផង។ ពីពេលនោះមក ការបន្ថយជំនួយបរទេស "ការទាត់ចោលនូវជំនួយអាមេរិក" ហើយនិងការកើតមាននូវឱនភាពនៃជញ្ជីងពាណិជ្ជកម្ម និងជញ្ជីងទូទាត់ផ្សេងៗទៀត នាំឱ្យមានទម្ងន់ទៅលើការផ្ទេរមាស រូបិយប័ណ្ណបម្រុង ហើយក្រោយមកមានជាប់បំណុលបរទេសទៀត។

ការផ្លាស់ប្តូរពាណិជ្ជកម្ម ជាមួយបារាំង នឹងមានលំនឹង ហើយពេលខ្លះមានចំណេញលើស។ ជាមួយប្រទេសដទៃទៀត ជញ្ជីងពាណិជ្ជកម្មកម្ពុជា មានឱនភាពដោយសារការផ្ទេរប្រាក់ចំណេញ ផ្ទេរប្រាក់បៀវត្សរ៍ និង ការធ្វើដំណើរទៅបរទេស។ ជំនួយបារាំងជួយបំពេញដល់ឱ

នភាពនោះ ព្រោះចលនានៃទ្រព្យសម្បត្តិកម្ពុជានៅប្រទេសបារាំង មានកម្រិតដូចឆ្នាំមុនៗ ហើយកើនឡើងទៀតផង។

សរុបមក នៅតំណាក់កាលនោះ ជញ្ជីងទូទាត់កម្ពុជា មានលំនឹងដោយគ្មានការលំបាក។ ការទាត់ចោល ជំនួយអាមេរិចមានមិនតិចទេ។ បញ្ហានេះបានដោះស្រាយបាន តាមរយៈជញ្ជីងពាណិជ្ជកម្ម និងជំនួយបរទេស ព្រមទាំងរកឥណទានអន្តរជាតិនាឆ្នាំ ១៩៦៥ ។ កម្ពុជានៅមាសនិងរូបិយប័ណ្ណក្នុងការដោះស្រាយជាមួយជើងទូទាត់។

# មេរៀនទី ៦
# ពាណិជ្ជកម្មក្រៅប្រទេស

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ជញ្ជីងទូទាត់ពាណិជ្ជកម្ម
- ប្រវត្តិនៃពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា
- ប្រវត្តិ និងទ្រឹស្តីតុល្យភាពជញ្ជីងទូទាត់ពាណិជ្ជកម្ម
- ការនាំចេញ
- ការនាំចូល
- របនាសម្ព័ន្ធនៃផលិផល
- របនាសម្ព័ន្ធនាំចេញ នាំចូលនៅកម្ពុជា

កម្ពុជាមិនរស់ និងមិនដែលរស់នៅក្នុងស្ថានភាពនៃសេដ្ឋកិច្ចបិទជិតនោះទេ គឺដូច ប្រទេសក្រីក្រដទៃទៀតដែរ កម្ពុជានាំចូលផលិតផលឧស្សាហកម្មសម្រេចដែលគេត្រូវការ ហើយ ផ្ទុយទៅវិញបាននាំចេញមួយភាគនៃស្បៀងកសិផលដែលផលិតបាន។ ក្នុងសម័យអាណានិគម គឺទិដ្ឋភាពនៃជីវភាពសេដ្ឋកិច្ចបែបនេះ ដែលពួកគេរក្សាទុកជាសំខាន់របស់ពួកអ្នករដ្ឋបាល និង ពួកសេដ្ឋកិច្ចជំនាន់នោះ។ ប្រទេសកម្ពុជា បានត្រូវចាត់ទុកថា ជាប្រទេសផ្គត់ផ្គង់ វត្ថុធាតុដើម ដល់ពួកប្រទេសធ្វើអាណានិគម និងប្រទេសដែលហៅថា "sous-metropole" គឺ វៀតណាម។ តាំងពីបានឯករាជ្យ ការខិតខំបានបង្កើនឡើង ដើម្បីប្រែក្លាយសភាពការណ៍នោះៈ ការបញ្ចូលគ្នា នូវសេរីភាវូបនីយកម្ម និងអន្តរាគមន៍ដោះស្រាយរបស់រដ្ឋ ធ្វើឱ្យមានលទ្ធភាពដែលជំនួសបាន និងត្រួតពិនិត្យនូវពាណិជ្ជកម្មក្រៅប្រទេស។ កម្ពុជាបានសាកល្បងបំបែកចេញពីគ្នា នូវសមាស ភាពនៃការនាំចូល និងការនាំចេញរបស់ខ្លួន។ មានអ្នកផ្គត់ផ្គង់ថ្មីៗ និងអតិថិជនថ្មីៗទៀត បាន ត្រូវរាប់បញ្ចូលជាផ្លូវការមុនចូលទៅពិនិត្យលទ្ធផលនៃនយោបាយថ្មីនៃពាណិជ្ជកម្មក្រៅប្រទេស យើងសិក្សាឱ្យបានពិស្តារដែរនូវការនាំចូល និងការនាំចេញ ដោយពិនិត្យមើលវិធាននានា នៃ ពាណិជ្ជកម្មក្រៅប្រទេស។ នៅចុងបញ្ចប់នៃភាគទីបី យើងពិនិត្យមើលជញ្ជីងទូទាត់។

## ៦.១.ប្រវត្តិនៃពាណិជ្ជកម្មក្រៅប្រទេស

ការសិក្សាអំពីបទបញ្ជា " réglementation " នៃពាណិជ្ជកម្មក្រៅប្រទេស ជាការចាំបាច់ ដាច់ខាតនៃបញ្ហាលើបញ្ហានានា។ លក្ខខ័ណ្ឌនៃការប្តូរប្រាក់ ដែលជាពិសេស បានធ្វើឱ្យតម្លៃនៃតួ លេខ នៃជញ្ជីងទូទាត់ដែលបានផ្សព្វផ្សាយ មិនបញ្ជាក់ពីតម្លៃពិតនៃការនាំចូល និងការនាំចេញ នៃចលនាទុន។

នាឆ្នាំ ១៩៥០-១៩៦០ ពាណិជ្ជកម្មក្រៅប្រទេសមិនមែន " សេរី " ទេ នៅកម្ពុជា គឺជា វិស័យមួយនៃការអន្តរាគមន៍របស់រដ្ឋអំណាចសាធារណៈយ៉ាងសកម្ម។យើងសិក្សាពីរូបភាព នៃនយោបាយពាណិជ្ជកម្មក្រៅប្រទេសដែលវិភាគជាបន្តបន្ទាប់នូវស្ថាប័ននានាការត្រួតពិនិត្យនិងការតម្រង់ទិសដែលរដ្ឋាភិបាលបានធ្វើ។

### ៦.១.១ ស្ថាប័ននានាៈ សូណិចស៊ីម

ខែ វិច្ឆិកា ១៩៦៣ ជាសម័យនៃការចាត់ចែង នូវពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា។ គឺជាការចាប់ផ្តើមនៃជាតូបនីយកម្មពាណិជ្ជកម្មក្រៅប្រទេស ឬហៅថា ភាពផ្តាច់មុខនៃប្រតិបត្តិការនាំចូល-នាំចេញ របស់ក្រុមហ៊ុន សេដ្ឋកិច្ចចម្រុះ ដែលមានឈ្មោះថាក្រុមហ៊ុនជាតិនាំចេញ-នាំចូល " SONEEXIM " ។

មុននេះមានក្រុមហ៊ុនធំៗ របស់ពួកអឺរ៉ុបនិងសហគ្រាសតូចៗ របស់ពួកចិនបានទទួលខុសត្រូវលើប្រតិបត្តិការការនាំចូល-នាំចេញ។ ដោយសារភាពងាយស្រួលដែលធ្វើឱ្យកាន់តែស្មុគស្មាញដោយបទបញ្ញាផ្សេងៗបង្កើតបាននូវកំហុសឆ្គងនៃការរកស៊ីបង្វិលបន្លំធ្វើឱ្យសកម្មភាពទាំងនោះរកចំណេញបានកាន់តែច្រើន។

ការបង្កើតសូណិចស៊ីម មិនបានបំបាត់ទាំងស្រុង នូវពួកអ្នកឯកទេសខាងនាំចេញ-នាំចូលនោះទេ។ និយាយពីការនាំចេញ សូណិចស៊ីម មិនទាន់មានបុគ្គលិកដែលមានគុណភាពបង្គួរ និងមានបទពិសោធន៍គ្រប់គ្រាន់សម្រាប់ស្រាវជ្រាវទីផ្សារល្អនៅឡើយ។ អ្នកនាំចេញមួយចំនួន នៅមានមុខនាទីធ្វើការនាំចេញ តាមរយៈអ្នកលក់ជាខ្មែរ អ្នកទិញជាបរទេស ពិសេសក្រុមហ៊ុនបរទេសនានា មិនមានទីស្នាក់ការនៅក្រុងភ្នំពេញនៅឡើយ ហើយធ្វើការចរចា រកស៊ីសម្រាប់ផលប្រយោជន៍ពួកគេ។សូណិចស៊ីម ខិតខំបើកទីស្នាក់ការនៅ ប៉ារីស និងសិង្ហបូរី។

សូណិចស៊ីម មិនអាចបំបាត់ទាំងស្រុងបាននូវឈ្មួញកណ្តាលក្នុងវិស័យនាំចូលនៅឡើយ។ ចំពោះផលិតផល ជាទំនិញមួយចំនួន មានតែពួកពាណិជ្ជករទេ ដែលធ្វើការបញ្ជាទិញតាមរយៈសូណិចស៊ីម។ ប៉ុន្តែជាគោលការណ៍ គឺ សូណិចស៊ីម ជាអ្នកនាំចូលផ្លូវការ ហើយជាឧបករណ៍ទទួលបន្ទុកធ្វើប្រតិបត្តិការគយ និងទូទាត់តាមផ្លូវច្បាប់។

ការបែងចែកទំនិញនាំចូល បានត្រូវជានាមួយភាគ ដោយពាណិជ្ជករឯកជន ប្រមូលផ្តុំជាសមាគមវិជ្ជាជីវៈ មួយភាគទៀតដោយរដ្ឋ។ អង្គការទាំងនោះ ត្រូវបានបង្កើតឡើងដោយរដ្ឋ ក្នុងគោលដៅនោះ ដូចជា " O.R.O.C " អូរ៉ុក ទទួលផលិតផលបម្រើកសិករ ហើយលក់ទំនិញទាំងនោះ តាមរយៈសហករណ៍រដ្ឋភណ្ឌាគារ " magasin d'Etat " បម្រើវិស័យស្បៀង សម្រាប់ផលិតផលស្បៀងអាហារនាំចូល ហើយមានតួនាទីជាឈ្មួញលក់រាយ ព្រោះរដ្ឋភណ្ឌាគារមានចំណុចលក់នានានៅភ្នំពេញ ក្រុមហ៊ុនជាតិនៃផលិតផលនាំចូល សូណាព្រីម" SONAPRIM " ជាអង្គការបានត្រូវបង្កើតឡើង ដើរតួជាឈ្មួញលក់ទំនិញនាំចូល ហើយសាកល្បងលក់រាយដោយបើកនូវអាគារលក់ដូរ។ គោលដៅរបស់ សូណាព្រីម គឺជាអ្នកលក់រាយនូវទំនិញនាំចូលដូចរដ្ឋភណ្ឌាគារ និងអូរ៉ុកដែរ។ នៅឆ្នាំ ១៩៦៦ សូណិចស៊ីម មានការកែប្រែពីរសំខាន់។

មុនដំបូង សូណិចស៊ីម ជាក្រុមហ៊ុនសេដ្ឋកិច្ចចម្រុះ បានក្លាយទៅជាក្រុមហ៊ុនរដ្ឋ តាមរយៈការកែប្រែនូវ លក្ខន្តិកៈផ្លូវច្បាប់។ វាមិនធម្មតាទេ មុននេះមានការអនុញ្ញាតឱ្យមូលធនឯកជនអាចរកចំណេញដោយបុព្វសិទ្ធិ តាមរយៈសូណិចស៊ីម ក្នុងផលប្រយោជន៍ប្រទេស ដូចជា ការផ្តាច់មុខផ្នែកពាណិជ្ជកម្មក្រៅប្រទេស ហើយធ្វើការ នាំចូលដោយរួចពន្ធ។ ហេតុដូចនេះហើយបានជា សូណិចស៊ីម ដែលគ្រប់គ្រងដោយមូលធនឯកជនបានត្រូវភ្ជាប់ជារបស់រដ្ឋវិញ នាឆ្នាំ ១៩៦៦ ដែលមានភាគហ៊ុនដល់ទៅ ៤០% ។

ដោយឡែក សូណិចស៊ីម ស្តីអំពីការនាំចូល មាននិន្នាការជាទូទៅ គឺការធ្វើការវេញថ្លៃ។ សូណិចស៊ីម បានបញ្ជាក់ជាមុននូវអ្វីដែល ត្រូវនាំចូលឱ្យបានច្បាស់លាស់ ហើយអ្នកលក់ទាំងឡាយត្រូវបញ្ជាក់ពីការផ្គត់ផ្គង់ ឱ្យបានពិតប្រាកដដែរ។

ស្ថាប័នពីរ មានតួនាទីសំខាន់ ក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេស គឺៈ ទីចាត់ការពាណិជ្ជកម្មក្រៅប្រទេស " D.C.E " – Direction du Commerce Exterieur និង " O.N.C " – Office National des Changes គឺជាមន្ទីរជាតិប្តូរប្រាក់។

ទីចាត់ការពាណិជ្ជកម្មក្រៅប្រទេស ជានាយកដ្ឋាននៃក្រសួងពាណិជ្ជកម្ម ជាគោលការណ៍ទទួលបន្ទុក នយោបាយពាណិជ្ជកម្មក្រៅប្រទេស រៀបចំគម្រោងផែនការនាំចូល នាំចេញ គ្រប់គ្រងរូបិយវត្ថុ ចេញអាជ្ញាប័ណ្ណ បែងចែក និងត្រួតពិនិត្យថ្លៃផលិតផលនាំចូល ធ្វើការចរចាចុះកិច្ចព្រមព្រៀងពាណិជ្ជកម្ម។ល។

សូណិចស៊ីម ស្ថិតនៅក្នុងអាណត្តិរបស់ក្រសួងពាណិជ្ជកម្ម ហើយក្រុមហ៊ុនរដ្ឋនេះរៀបចំពីមួយឆមាសទៅមួយឆមាសនូវការបែងចែកតំបន់ និងផលិតផល និងរូបិយប័ណ្ណសម្រាប់នាំចូល។ តួនាទីរបស់សូណិចស៊ីម មានសារៈសំខាន់ណាស់។

មន្ទីរជាតិប្តូរប្រាក់ កើតពីធនាគារជាតិនៃកម្ពុជា ទទួលបន្ទុកអនុវត្តបទបញ្ជានៃការប្តូរប្រាក់ ដែលជា មធ្យោបាយសំខាន់ សម្រាប់ត្រួតពិនិត្យពាណិជ្ជកម្មក្រៅប្រទេស។

## ៦.២.ប្រវត្តិ និងទ្រឹស្តីតុល្យភាពជញ្ជីងទូទាត់ពាណិជ្ជកម្ម

ទំនិញ និងទុន មិនត្រូវបានចរាចរដោយសេរី ឆ្លងកាត់ព្រំដែនកម្ពុជាទេ។ អត្ថបទមួយចេញផ្សាយនាឆ្នាំ ១៩៥៥ ជាគោលការណ៍បានហាមការនាំចូល និងនាំចេញទំនិញ និងទុនដោយគ្មានការអនុញ្ញាតជាមុន។ ជា អង្គហេតុគោលការណ៍ត្រួតពិនិត្យ គឺជាច្បាប់នៃការប្តូរប្រាក់។ ប៉ុន្តែការបដិរូបនាឆ្នាំ ១៩៦៣ មានការបញ្ចូលនូវការកែប្រែជាច្រើនចំណុច។

### ៦.២.១.រហូតមកដល់ឆ្នាំ ១៩៦៣

សម្រាប់ការនាំចេញ " ការអនុញ្ញាតជាមុន " មានភាពងាយស្រួលក្នុងការយល់ព្រម ជាអាជ្ញាប័ណ្ណនាំចេញ ដោយទីចាត់ការពាណិជ្ជកម្មក្រៅប្រទេសសម្រាប់ទំនិញ។ ពេលនោះ ដូចជាគ្មានច្បាប់គយនៅឡើយទេ សម្រាប់ការនាំទំនិញចេញ។ ចំណុចសំខាន់នៅទីនោះ គឺការនាំចូល

មកវិញនូវរូបិយប័ណ្ណ។ បទបញ្ញាទាំងឡាយបានបញ្ជាក់ថា រូបិយប័ណ្ណចំណេញពីការនាំចេញនូវផលិតផលកម្ពុជា ត្រូវប្តូរតាមអត្រាផ្លូវការនៅមន្ទីរជាតិប្តូរប្រាក់។

ប៉ុន្តែបទបញ្ញានេះ ចាប់ពីឆ្នាំ ១៩៦៣ ប្រព័ន្ធនោះត្រូវកែប្រែស៊ីជម្រៅ មានករណីលើកលែងពីរ៖ ភាគរយ មួយចំនួននៃកម្រិតប្រាក់ចុះបញ្ជីការលក់ ត្រូវផ្ទេរទៅគណនេយ្យ " Exporation-Frais accessories " ដែលគេហៅថាគណនេយ្យ E.F.A.C.ហើយទុកសម្រាប់តែការនាំចេញ ហើយអាចលក់រូបិយប័ណ្ណនោះ នៅទីផ្សារស្រេបណាមួយ ដោយឡែកទៀត ដើម្បីជៀសវាងកំហុស គណៈកម្មាការ Cotation មួយ កំណត់ថ្លៃមួយសម្រាប់ រាល់ផលិតផលនាំចេញថ្លៃនេះជាថ្លៃទាប ហើយការលក់អាចមានថ្លៃខ្ពស់ជាង ក្នុងករណីនេះអ្នកនាំចេញអាចផ្ទេរ ចូលទៅគណនេយ្យ E.F.A.C.៧៥% នៃភាពខុសគ្នាផ្សេងៗរវាងថ្លៃលក់ និងថ្លៃ Cotation ហើយនៅសល់ ប៉ុន្មាន គិតទៅតាមថ្លៃកំណត់នៃមន្ទីរជាតិប្តូរប្រាក់។ " រូបិយប័ណ្ណ E.F.A.C." ដែលចំណេញបានពីការលក់នៅ ទីផ្សារស្រេប មិនខុសច្បាប់ ទល់នឹងលុយរៀល អត្រាប្តូរប្រាក់នៃរូបិយប័ណ្ណមានការផ្លាស់ប្តូរទៅតាមពេលវេលា។ តាមការគណនាពេលនោះ អត្រាមធ្យម គឺអត្រា ៨២ រៀល/ដុល្លារអាមេរិក។

ឧទាហរណ៍បំភ្លឺ៖ អ្នកនាំចេញកម្ពុជាម្នាក់ លក់អង្ករតាមការកំណត់របស់គណៈកម្មាការ Cotation សន្និដ្ឋានជាមួយ Cargaison នៅក្នុងពេលកំណត់ប្រគល់ទទួលថ្លៃ ១០០ ដុល្លារអាមេរិក គឺស្មើនឹងអត្រាផ្លូវការ ៣,៥០០ រៀល ។ អ្នកនាំចេញរបស់យើង ត្រូវលក់ទំនិញថ្លៃ ១១០ ដុល្លារ ។ តើត្រូវបើកប្រាក់ដូចម្តេច?

គាត់ត្រូវបើកលុយថ្លៃ cession ចំនួន ៨៧ ដុល្លារ " ១០០-១៣=៨៧ " នៅមន្ទីរជាតិប្តូរប្រាក់ គឺមានន័យថា ៣,០៤៥ រៀល " ៨៧ ៣៥ = ៣,០៤៥ " បន្ថែមនឹងប្រាក់ ២.៥ ដុល្លារ " ២៥% នៃ ១១០-១០០=២,៥ " ស្មើ ៨៧.២ រៀល " ២,៤ ៣៥ = ៨៧.២ " ។ គាត់ត្រូវផ្ទេរចូលគណនេយ្យរបស់ខ្លួន នៅដោយឡែក ១៣ ដុល្លារ និងមួយចំណែកទៀត ៧.៥ ដុល្លារ " ៧៥% នៃ ១១០-១០០=៧.៥ " ស្មើ ២០.៥ ដុល្លារ ដែលមានតម្លៃ ១,៦៨១ រៀល " ២០.៥ ៨២= ១,៦៨១ " ។ ការនាំអង្ករចេញដែលចុះបញ្ជីស្ថិតិគយ ថ្លៃ ៣,៥០០រៀល គឺធ្វើឱ្យមានសមាមាត្រ ៤,៨១៣.២ រៀល។ សរុបតួលេខមកយើងឃើញ " តម្លៃពិត " នៃការនាំចេញ។

តថភាពកាន់តែមានភាពស្មុគស្មាញជាង ចំពោះផលិតផលមួយចំនួន និងទីផ្សារមួយចំនួន ដូចជា បាងកក ហុងកុង សិង្ហបូរី ផលិតផលនាំចេញ មិនអាចបង្ខំឱ្យកាត់តាមការកំណត់របស់មន្ទីរជាតិប្តូរប្រាក់ទេ ប៉ុន្តែគឺការប្រើប្រាស់លុយនោះ សម្រាប់បម្រើឱ្យប្រទេសកម្ពុជា។ នោះគឺការនាំចេញទំនិញអ្វីពីកម្ពុជា ត្រូវភ្ជាប់ការនាំចូលទំនិញអ្វីពីកម្ពុជា ត្រូវភ្ជាប់ការនាំចូលនូវទំនិញផ្សេងទៀតមកកម្ពុជា។ បែបបទនេះ គេហៅថា " échange compensé " ប្តូរដោយបន្ថែមឱ្យគ្នាទៅវិញទៅមក ដោយឱ្យអ្នកនាំចេញនូវផលិតផលមួយចំនួនលក់នៅលើទីផ្សារមួយ ហើយទទួលយករូបិយប័ណ្ណដោយសេរី ដែលខ្លួនចំណេញ។ ក្នុងករណីនេះ ក៏ដូចករណីមុនដែរ គឺតួលេខគយ មិនផ្តល់ការប្តូរនូវរូបភាពដែលខុសនោះទេ។

ការនាំចូល ក៏មានការត្រួតពិនិត្យដ៏ច្រើន និងយ៉ាងតឹងតែងបំផុតដែរ។ នោះគឺតួនាទីរបស់អ្នកធនាគារិក។ គេអាចបែងចែករវាងរបបពីរ យោលទៅតាមការនាំចូលនានា ដែលបានទូទាត់ជារូបិយប័ណ្ណ ទិញមកពីមន្ទីរជាតិប្តូរប្រាក់ ក្នុងអត្រាផ្លូវការ ឬមិនមែន។

ក្នុងករណីទី ១ អាជ្ញាប័ណ្ណនាំចូលត្រូវតែមានជាចាំបាច់។ អាជ្ញាប័ណ្ណនោះ ប្រគល់ឱ្យក្រោយពេលដែល គណៈកម្មការ បែងចែករូបិយប័ណ្ណដែលទទួលបាន រូបិយប័ណ្ណដែលមានការប្រើប្រាស់អំណាចត្រួតពិនិត្យ។ ក្នុង ករណីទី ២ អាជ្ញាប័ណ្ណគ្មានភាពចាំបាច់ទេ ប៉ុន្តែការនាំចូលត្រូវរកឱ្យបាននូវរូបិយប័ណ្ណទីផ្សារស្របគ្នា៖ ទីផ្សារនោះមានភាពស្របច្បាប់ ដែលផ្គត់ផ្គង់ដោយការលក់ "រូបិយប័ណ្ណ E.F.A.C." ហើយនិងរូបិយប័ណ្ណបានមកពីការនាំចេញ តាមរូបភាពផ្លាស់ប្តូរទំនិញ ទៅវិញទៅមក។ ទីផ្សារស្របក៏នៅបានផ្គត់ផ្គង់ដោយខុសច្បាប់ តាមរយៈការរកស៊ីដោយឈ្មួញកណ្តាល នៅលើទីផ្សារងងឹត ឬការរកស៊ីដំឡើងថ្លៃ ឬតាមរូបភាពនៃការនាំចូលដោយ "មិនប្រើរូបិយប័ណ្ណ" ដែលអនុញ្ញាតឱ្យប្រើរូបិយប័ណ្ណស្របរកបាន ដូចជាគោលការណ៍នាំចូល "រូបិយប័ណ្ណ" ដែលក្រុមហ៊ុនធំៗ បរទេសនានាផ្តល់ឱ្យដោយឥតគិតថ្លៃ នូវឧបករណ៍ផ្សាយពាណិជ្ជកម្មទៅឱ្យភ្នាក់ងាររបស់គេនៅកម្ពុជា។ប៉ុន្តែសារៈសំខាន់នៃការនាំចូល"គ្មានរូបិយប័ណ្ណ" បង្ហាញអំពីការនាំចូល"គ្មានរូបិយប័ណ្ណស្របច្បាប់"។ ទំនិញនាំចូលតាមគំរូនានាយោលទៅតាមបទបញ្ជាដែលមានមិនច្បាស់លាស់។ និយាយរួម គឺជារូបភាពនាំចូល ដែលអាចនាំចូលបាន។ ទ្រព្យធនចាំបាច់ គឺបានមកដោយកិច្ចព្រមព្រៀង របស់គណៈកម្មការបែងចែករូបិយប័ណ្ណ ហើយជាការនាំចូល ដោយរូបិយប័ណ្ណទិញតាមអត្រាផ្លូវការ " ៣៥ រៀលក្នុងមួយដុល្លារអាមេរិក " ទ្រព្យធនផ្សេងទៀត ជាគោលការណ៍ គឺ " ឧបករណ៍សម្ភារៈ និងផលិតផលប្រើប្រាស់ចាំបាច់ " គឺជាទំនិញប្រណីត ពាក់ កណ្តាលប្រណីត ដែលប៉ះពាល់ដល់បញ្ជីពិសេស ហើយអាចនាំចូលបានតែតាមរយៈ " រូបិយប័ណ្ណ E.F.A.C." ទិញក្នុងអត្រាស្រប គឺ ៨២ រៀល/ដុល្លារអាមេរិក ទំនិញផ្សេងទៀតមិនអាចនាំចូលមកកម្ពុជាបានទេ តែពេលខ្លះបានក្នុងនាមនៃការនាំចូលគ្មានរូបិយប័ណ្ណ ហើយទូទាត់ជាមួយរូបិយប័ណ្ណទិញនៅទីផ្សារងងឹត ដែលអត្រាប្តូរ ប្រាក់ស្មើនឹងអត្រាស្របដោយសារការមិនជ្រាបចូលគ្នារវាងទីផ្សារងងឹត និងទីផ្សារស្រប។ នៅចំណុចទាំងនោះ តើមានស្ថិតិប៉ុន្មានរបស់គយ ដែលបានចុះបញ្ជីការនាំចូលមានតម្លៃជារៀល គណនាតាមអត្រាផ្លូវការខុសពីតថភាព។

ការត្រួតពិនិត្យផ្ទាល់ និងតាមរយៈធនាគារិកត្រូវបានបន្ថែមដោយបណ្តាញពន្ធនៃការនាំចូល។ ច្បាប់ពន្ធគយដែលបន្ថែមទៅលើអត្រាផ្លាស់ប្តូរ យោងទៅតាមផលិតផល គឺជាពន្ធដ៏មានសារៈសំខាន់នៃផលិតផល ដូចជា ប្រេងឥន្ទនៈ ស្រាបៀរ ថ្នាំជក់ ។ល។

ប្រព័ន្ធប្តូរប្រាក់ដែលបង្កើតឡើងបានជាឧបករណ៍សំខាន់ៗនៃការត្រួតពិនិត្យពាណិជ្ជកម្មក្រៅប្រទេស ប្រហាក់ ប្រហែលនឹងប្រព័ន្ធនៃអត្រាប្តូរប្រាក់ មានរូបភាពស្មុគស្មាញ និងច្រើនបែបយ៉ាង។ សរុបឱ្យខ្លីមានអត្រាប្តូរប្រាក់ ៣ ប្រភេទ។ ទី ១ គឺអត្រាផ្លូវការសម្រាប់ផ្ទេរទុន និងការនាំចូលតាមអាជ្ញាប័ណ្ណស្មើ ៣៥រៀល/ដុល្លារអាមេរិក។ បន្ទាប់មកមានអត្រាមធ្យមសម្រាប់ការនាំចេញដែលខ្ពស់ជាងអត្រាផ្លូវការ ដោយសារមាន " ប្រាក់លើកទឹកចិត្តរបស់ E.F.A.C." គឺជាលទ្ធ

ផលនៃការលក់ក្នុងអត្រាស្រប នូវរូបិយប័ណ្ណមួយភាគដែលទទួលបានពីការនាំចេញ គឺអត្រា ៤៣.៧ រៀល/ ដុល្លារអាមេរិក។ ទី ៣ ជាអត្រាដែលសម្រេចបានពីការប្តូរទំនិញ និងទំនិញ និង ពិសេសពីការនាំចូល តាមរូបិយប័ណ្ណនៃ E.F.A.C.គឺជាអត្រាស្របប្រហែល ៨២ រៀល/ដុល្លារអាមេរិក។

ប៉ុន្តែសភាពការណ៍មានភាពស្មុគស្មាញ ដោយសារជំហររបស់ធនាគារិកដែលមិនមែនស្ថិតក្នុងសភាពធម្មតា ហើយប្រហែលជាមានតែមួយនៅក្នុងលោកនេះ។

នៅពេលដែលរដ្ឋាភិបាលលោក M.Faure ជាមួយ M.Gaillard នៃក្រសួងហិរញ្ញវត្ថុ បានសម្រេចចិត្ត កាលពីខែធ្នូ ១៩៥២ បញ្ចុះតម្លៃប្រាក់ហ្វ្រង់បារាំង ប្រៀបនឹងដុល្លារអាមេរិក នឹងជាមួយមាសកម្ពុជា បដិសេធមិន កែប្រែមានជាផលវិបាកដល់អត្រាប្តូរប្រាក់រៀល ធៀបនឹងលុយហ្វ្រង់ ឬដុល្លារអាមេរិក។ ការបញ្ចុះតម្លៃលុយហ្វ្រង់លើកទី ២ ប្រៀបនឹងដុល្លារអាមេរិក ក្នុងខែធ្នូ ១៩៥៨ ដោយរដ្ឋាភិបាល លោកឧត្តមសេនីយ De Gaulle មានលោក M.Pinary ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ មិនបាននាំប្រទេសកម្ពុជាឱ្យកែប្រែអត្រាទាំងបីនៃការប្តូរប្រាក់ឡើយ។ លទ្ធផលទាំងនេះមានឈ្មោះថា ការប្រៀបនៃការប្តូរប្រាក់ ដែលបញ្ជាក់តាមហេតុនៅលើទីផ្សារប្តូរប្រាក់នៅភ្នំពេញ ១ ដុល្លារថ្លៃ ៣៥ រៀល និង ១ហ្វ្រង់ ថ្លៃ ១០ រៀល ហើយនៅលើទីផ្សារនានាការប្តូរប្រាក់ គឺ ១ ដុល្លារ ស្មើនឹង ៥ ហ្វ្រង់។

ការប្រៀបធៀបការប្តូរប្រាក់ ជាគោលការណ៍មានអានុភាព ចំពោះការប្រកាន់ជំហរប្រឆាំងនឹងការនាំចូលមកពីប្រទេសបារាំង តែក៏មានការលើកទឹកចិត្តវិញដែរ ដល់ការនាំចេញឆ្ពោះទៅបារាំង។ ការបញ្ចុះតម្លៃប្រាក់ហ្វ្រង់ សម្រេចឡើងដោយគ្មានការសួរមតិយោបល់ពីរដ្ឋាភិបាលកម្ពុជាទេ ធ្វើឱ្យប៉ះពាល់ផលប្រយោជន៍កម្ពុជា ក្នុងវិធានការមួយ ដែលជាទ្រព្យធនរបស់ខ្មែរនៅស្រុកបារាំងបានថយតម្លៃ ប្រៀបនឹងដុល្លារអាមេរិក។ កម្ពុជាត្រូវរក្សាការប្រៀបធៀបនៃការប្តូរប្រាក់នេះ ដើម្បីចរចាជាមួយភាគីបារាំងឱ្យជួយបំពេញបន្ថែមឱ្យវិញ។

ការប្រៀបធៀបការប្តូរប្រាក់នេះ ជាអង្គធាតុសំខាន់សម្រាប់ត្រួតពិនិត្យ និងគាបសង្កត់ដែលដាក់ទម្ងន់ទៅលើពាណិជ្ជកម្មក្រៅប្រទេស។

### ៦.២.២.ចាប់ពីឆ្នាំ ១៩៦៣

ម៉ាស៊ីនបទបញ្ញាដែលគេទើបនឹងសិក្សា បានត្រូវកែប្រែលើពីរចំណុចចាប់ពីខែវិច្ឆិកា ១៩៦៣ មក ដោយមានការបង្កើតនូវក្រុមហ៊ុន សូណិចស៊ីម។

ទីមួយ គឺការត្រួតពិនិត្យរបស់រដ្ឋអំណាចសាធារណៈ ទៅលើពាណិជ្ជកម្មក្រៅប្រទេស ធ្វើឡើងតាមរយៈមធ្យោបាយ អាជ្ញាប័ណ្ណការប្តូរបាក់ពន្ធអាករ ដែលចេះតែពង្រឹងឡើង ព្រោះអង្គការសាធារណៈបានត្រូវយល់ព្រមឱ្យរៀបចំធ្វើការផ្តាច់មុខពាណិជ្ជកម្មក្រៅប្រទេស។ រដ្ឋមានមធ្យោបាយថែមទៀត ចូលផ្ទាល់ជាងផ្នែកដទៃ ដើម្បីធ្វើការត្រួតពិនិត្យកាន់តែតឹងតែងលើការនាំចូល និងការនាំចេញ។

ទីពីរ បែបបទគណនេយ្យ E.F.A.C.បានត្រូវលុបចោល។ ប៉ុន្តែបង្កើនអត្រាប្តូរប្រាក់ថែមទៀត គ្របដណ្តប់តាមបែបបទនេះ គឺគ្មានការបន្ធូរបន្ថយអ្វីទេ។ នោះគឺការរក្សានូវមធ្យោបាយនៃប្រព័ន្ធប្រកតែមួយ។ ការនាំចូល គឺតាមតែរយៈ សូណិចស៊ីម តែមួយដែលមានការបង់ពន្ធតាក់ហើយការនាំចេញក៏ត្រូវមានជំនួយបន្ថែម។ ប្រកតែមួយជាអវិជ្ជមាន គឺការនាំចូល សូណិចស៊ីម រកចំណេញ ដែលបំពេញការខាតបង់ទៅលើការនាំចេញ។ ទំនិញមួយឡូត៍ដែល សូណិចស៊ីម ទូទាត់ ៤,០០០ រៀល ទៅឈ្មួញកណ្តាលកម្ពុជា សូណិចស៊ីម លក់ ១០០ ដុល្លារ អាមេរិកនៅលើទីផ្សារបរទេស គេទទួលបាន ៣,៥០០រៀល " ៣៥x១០០=៣,៥០០ " បូកនិងផលិតផល Peréquation negative ប្រហែល ៥០០ រៀល ។ អត្រា Peréquation positive និង negative ប្តូរតាមផលិតផល និងប្រទេស ដែលឱ្យនិយមន័យដល់ប្រព័ន្ធអត្រាប្តូរប្រាក់ច្រើនបែបច្រើនយ៉ាង និងស្មុគស្មាញ។ គេកត់សម្គាល់ថា ប្រតិបត្តិការទាំងឡាយនៃការបំពេញបន្ថែមប្រព្រឹត្តទៅក្នុងផ្ទៃក្នុង នៅក្រុមហ៊ុនសូណិចស៊ីម "អត្រា Peréquation ជាគោលការណ៍ មិនបានផ្សព្វផ្សាយជាសាធារណៈទេ ហើយក៏ជាប្រធានបទនៃការកែប្រែ" ហើយនឹងផ្លូវការណ៍កម្ពុជាមានអត្រាប្តូរប្រាក់តែមួយ ចំពោះរាល់រូបិយប័ណ្ណ។

ដោយឡែក បែបបទនៃការផ្លាស់ប្តូរទំនិញបន្ថែមឱ្យគ្នាទៅវិញទៅមក ដែលបានលុបចោលក្នុងពេលបង្កើត សូណិចស៊ីម បានត្រូវបង្កើតឡើងវិញនាឆ្នាំ ១៩៦៧។ ថ្លៃកសិផលបន្ទាប់បន្សំខ្លះ ដែលសូណិចស៊ីមបញ្ជាទិញពីឈ្មួញក្នុងស្រុក មិនត្រូវបានឈ្មួញទាំងនោះប្រមូលផ្តល់ឱ្យសូណិចស៊ីមទេ នៅពេលដែលគេសន្និដ្ឋានថាថ្លៃទាបពេក។ ជួនកាលឈ្មួញប្រមូលនាំចេញតាមរយៈការរត់ពន្ធ ដូចនេះការចំណេញ គឺបានទៅឈ្មួញ មិនមែនបានទៅកសិករទេ។

បច្ចុប្បន្នមានរូបភាពនាំចេញ ៣ ប្រភេទ។ ការនាំចេញធ្វើឡើង តាមអត្រាប្តូរប្រាក់ផ្លូវការក្នុងករណីកៅស៊ូ ការចំណេញពី Peréquation អវិជ្ជមាន ដូចជាពោត ឬការដាក់នៅក្រោមរបបនៃការផ្លាស់ប្តូរទំនិញ ទៅវិញទៅមកដូចករណី សណ្តែកដី ជាដើម។

បទបញ្ជាទាំងនោះ មានភាពស្មុគស្មាញជាការតម្រង់ទិសនៃពាណិជ្ជកម្មក្រៅប្រទេស ដែលបានត្រូវបំពេញបន្ថែមដោយឧបករណ៍សកម្មភាពផ្សេងៗទៀត ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការទូទាត់។

## ៦.៣.ការតម្រង់ទិសនានា៖ កិច្ចព្រមព្រៀងពាណិជ្ជកម្ម

ក្នុងសម័យអាណានិគមសារៈសំខាន់នៃពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាប្រព្រឹត្តទៅជាមួយបារាំងឬរៀតណាម។ការគិតគូរទីមួយរបស់រាជរដ្ឋាភិបាលកម្ពុជាឯករាជ្យគឺស្វែងរកអ្នកផ្គត់ផ្គង់ថ្មីនិងអតិថិជនថ្មីៗទៀត។

ការត្រួតពិនិត្យរបស់ស្ថាប័ននានា អាចបម្រើនូវនយោបាយនោះ ដែលជំហរនៃការប្តូរប្រាក់បានដើរតួនាទីសំខាន់៖ ការប្រៀបការប្តូរប្រាក់ បានធ្វើឱ្យឈ្មួញកម្ពុជាទិញទំនិញ ក្រៅពីប្រទេសបារាំងនូវផលិតផលដែលគេត្រូវការ។ ប៉ុន្តែការត្រួតពិនិត្យ គិតតែទៅលើផលិតផលជាង

ប្រទេស។ ពេលខ្លះ កម្ពុជាអាចសម្របសម្រួលពាណិជ្ជកម្មជាមួយប្រទេសមួយចំនួន ហើយក៏បន្ថយការរកស៊ីលក់ដូរ ជាមួយប្រទេសផ្សេងទៀតដែរ។

កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងទូទាត់ គឺជាឧបករណ៍តម្រង់ទិសដ៏មានឥទ្ធិពល។ កិច្ចព្រមព្រៀងបានចុះហត្ថលេខា ជាមួយប្រទេសមិនមែនសង្គមនិយម។ ប៉ុន្តែភាគច្រើនកម្ពុជាចុះកិច្ចព្រមព្រៀងជាមួយអតីតប្រទេសសង្គមនិយម ដូចជាជាមួយចិនប្រជាមានិតនាឆ្នាំ ១៩៥៦ ឆេក្ក ១៩៥៦ សូវៀត ១៩៥៧ ប៉ូឡូញ ១៩៥៧វៀតណាមខាងជើង ១៩៥៨ យូហ្គូស្លាវី ១៩៥៩ ប៊ុលហ្គារី ១៩៦១ កូរ៉េខាងជើង១៩៦៣ និងហុងគ្រី ១៩៦៦។

អត្ថបទកិច្ចព្រមព្រៀងមានតម្លៃក្នុងរយៈពេលមួយឆ្នាំក៏ប៉ុន្តែការរំលឹកបន្តកិច្ចព្រមព្រៀងគ្រាន់តែធ្វើការប្តូរលិខិតតូចមួយតែប៉ុណ្ណោះ។ កិច្ចព្រមព្រៀងពាណិជ្ជកម្ម មានជាការសម្តែងនូវឆន្ទៈរួមនៃភាគីទាំងពីរ ដើម្បីបង្កើននូវការផ្លាស់ប្តូរទំនិញ។ កិច្ចព្រមព្រៀងមិនបានចងភ្ជាប់អ្នកណាម្នាក់ទេហើយគេទុកដូចជាលិខិតមរណៈ។ ពិតហើយភាគីទាំងពីរចូលរួមដោយយល់ព្រមទៅវិញទៅមក ដោយអនុញ្ញាតឱ្យអនុម័តនូវការអនុញ្ញាត ដល់ការនាំ ចេញហើយនិងការរៀបចំបញ្ជីទំនិញ ដែលអាចប្តូរគ្នាបានតាមរយៈការសិក្សាទីផ្សារ។ ការបញ្ជាក់នូវគោលការណ៍ និងបែបបទទូទៅ ក៏មានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មដែរ។កិច្ចព្រមព្រៀង ក៏និយាយដល់ស្ថេរភាពនៃការផ្លាស់ប្តូរ។ កម្រិតទំនិញនាំចេញទៅប្រទេសណាមួយ ត្រូវស្មើនឹងកម្រិតទំនិញនិងតម្លៃនៃទំនិញនាំចូលពីប្រទេសនោះដែរ។ បញ្ជីទូទាត់មិនអាចលើសពីគោលការណ៍កំណត់ដែលបានកំណត់របស់ភាគីឡើយ។

កិច្ចព្រមព្រៀងទូទាត់គឺចេញមកពីអត្ថបទនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម។ ភាគីនីមួយៗដែលបានចុះកុងត្រាត្រូវបើកគណនេយ្យនៅធនាគារកណ្តាលនៃប្រទេសរបស់ខ្លួនក្នុងនាមនៃភាគីមួយទៀ-ត។ គណនេយ្យនេះនៅផ្នែក Debit ក្នុងរាល់ការនាំចេញ ហើយនៅផ្នែកឥណទាន Credit នៅរាល់ការនាំចូល។ នៅពេលSolde នៃគណនេយ្យ débiteur អ្នកជំពាក់ទៅនៅផ្នែកសកម្ម Actif នៃតុល្យការ bilan នៃធនាគារជាតិនៃកម្ពុជាB.N.C មានន័យថាប្រទេសនោះបាននាំចូលពីកម្ពុជាហើយគេថាអ្នកជំពាក់ Débiteur កម្ពុជា។ គណនេយ្យ គឺរក្សាទុកនៅក្នុងគណនេយ្យប្រាក់ជាលីវស្ទែលីង ដុល្លារអាមេរិក។ Solde អាចដោះស្រាយនៅក្នុងគណនេយ្យប្រាក់ monnaie de compte គឺជារូបិយប័ណ្ណ។

ដូចគេបានឃើញ ក្នុងការសិក្សាការនាំចូល និងនាំចេញកម្ពុជា នូវកិច្ចព្រមព្រៀងនានាដ៏មានអានុភាពល្អ។ កិច្ចព្រមព្រៀង បានអនុញ្ញាតឱ្យកម្ពុជាបង្កើននូវការផ្លាស់ប្តូរ ជាមួយប្រទេសហត្ថលេខី គឺជាប្រទេសសង្គមនិយម ហើយបានធ្វើឱ្យពាណិជ្ជកម្មក្រៅប្រទេសមានមែកជាងរីកដុះដាលឡើង។ លទ្ធផលទាំងនោះ គឺបានមកដោយសារការចុះហត្ថលេខានៃឯកសារទាំងនោះ។

ប៉ុន្តែនៅជ្រុងម្ខាងទៀត បែបបទនេះមិនផ្តល់នូវការពេញចិត្តទាំងស្រុងនោះទេ។ បែបបទនោះនាំឱ្យមាន អានុភាពខូចប្រយោជន៍ ពីការចុះហត្ថលេខាទ្វេរភាគី ស្តីអំពីពាណិជ្ជកម្មក្រៅប្រទេស។

អ្វីដែលកម្ពុជាទិញពីប្រទេសឆេកូស្លូវ៉ាគី នៅមានកម្រិត ដោយកម្ពុជាបំពេញមិនបាននូវកម្រិតកំណត់ដែលកម្ពុជាត្រូវលក់ទៅឱ្យប្រទេសឆេកូស្លូវ៉ាគីវិញ។ បើកម្ពុជាមិនអាចធ្វើតុល្យការបាននូវការផ្លាស់ប្តូរទំនិញ ជា មួយឆេកូស្លូវ៉ាគីបាន កម្ពុជាត្រូវតែទិញទំនិញលើសពីប្រទេសនេះ។ ជាមួយប្រទេសប៉ូឡូញ ក៏ដូចនោះដែរ។

ដោយឡែក ប្រព័ន្ធកិច្ចព្រមព្រៀងទូទាត់សំខាន់ដល់កម្ពុជា មិនអាចមានលទ្ធភាពទិញ ឬលក់ក្នុងតម្លៃ មួយល្អទេ។ ផលិតផលមួយចំនួនលក់មកឱ្យកម្ពុជា ពេលខ្លះតម្លៃ "ពិត" លើទីផ្សារពិភពលោក ធ្វើឱ្យប្រទេស អ្នកលក់បានចំណេញពីផលិតផលប្រទេសកម្ពុជា។ គេអាចរាប់ករណីប្រទេសដែលបានយកអង្ករខ្មែរ ទៅលក់បន្ត ទៀតទល់នឹងរូបិយប័ណ្ណខ្លាំង ដូចជានៅក្រុងដាកា ឬហុងកុង រំខានដល់ការលក់អង្ករពីកម្ពុជាខ្លួនឯង នៅលើទីផ្សារនោះ។ នៅជ្រុងមួយទៀតប្រព័ន្ធនោះអនុញ្ញាតឱ្យភាគីជំពាក់ débitriceជាទូទៅនៅកម្ពុជាទទួលបានដោយស្វ័យប្រវត្តិពីភាគីមួយទៀត នូវឥណទាន Credit មិនគិតការប្រាក់។

បើគេចង់វាស់វែង នូវសារៈសំខាន់នៃពាណិជ្ជកម្មក្រៅប្រទេស ក្នុងសេដ្ឋកិច្ចផ្ទៃក្នុង គឺជាការសន្និដ្ឋាន នូវអ្វីដែលចំណេញពីការនាំចេញ ហើយនិងអ្នកដែលជាថ្លៃដើមនៃការនាំចូល ឧទាហរណ៍ ប្រៀបធៀបតួលេខដែលមិនដាច់ខាត ទៅនឹងសកម្មភាពជាតិនោះ គេត្រូវបន្ថែមតួលេខរបស់ផ្នែកគយ ឬតួលេខនៃជញ្ជីងទូទាត់ នូវចំនួនទឹកប្រាក់ ដែលជាវង្វាន់នៃ E.F.A.C.និង Peréquation ។ ភាពខុសគ្នារវាង តួលេខដែលបានកែតម្រូវ និងតួលេខ "ដុល" អាចឡើងដល់ ៣០% ។

សមាមាត្រនៃផលបូកការនាំចូល និងនាំចេញ ទៅនឹងផលទុនជាតិដុល គឺប្រហែល ៣០% ។ ការកើន ឡើងនៃពាណិជ្ជកម្មក្រៅប្រទេស នៅក្នុងសេដ្ឋកិច្ចកម្ពុជាមានតិចតួចទេ។ នៅឆ្នាំ ១៩៦៤ គេបានចុះបញ្ជី មានការថយចុះនៃភាគចំណែករបស់ពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា នៅក្នុងសេដ្ឋកិច្ចកម្ពុជា។

តួលេខខាងលើ បញ្ជាក់ថាពាណិជ្ជកម្មក្រៅប្រទេស មានសារៈសំខាន់ចំពោះសេដ្ឋកិច្ចកម្ពុជា តែមិនត្រូវឱ្យពាណិជ្ជកម្មនេះ មានភាពរណបទាំងស្រុងទៅបរទេស។

នៅក្នុងស្ថិតិរបស់មន្ទីរប្តូរប្រាក់ ឬនៅគយរដ្ឋាករ គណនេយ្យចុះជារៀល បើផលិតផលមួយ នាំចូលទិញថ្លៃ ១០០ ដុល្លារអាមេរិក គឺ គេចុះក្នុងស្ថិតិ ៣,៥០០ រៀល លក់ដូចជាការទូទាត់ ជារូបិយប័ណ្ណ E.F.A.C.ឬPeréquation នៃផលិតផល គឺចុងក្រោយទូទាត់ ៨,០០០ រៀល នៃអ្នកនាំចូលនីមួយៗ។ គណនេយ្យនោះ គឺចុះ បញ្ជីជា "រៀលរូបិយប័ណ្ណ" ។ លុយ "រៀល" រូបិយប័ណ្ណ ឱ្យយើងដឹងស្រួលជាងលុយរៀល ដែលបានផ្ទេរ ឬទទួលបាននៅប្រតិបត្តិការទីមួយ ក្នុងការផ្លាស់ប្តូរទំនិញជាអន្តរជាតិ លើសារៈសំខាន់នៃការនាំចូលនាំចេញ ប្រភព និងការប្រើប្រាស់នៃរូបិយប័ណ្ណ ដូចជាបែបបទពេលខ្លះមានឱនភាពទើបឡើងដែលត្រូវបំពេញ។ វាមានភាពស្របច្បាប់ ហើយក៏មានការលើកទឹកចិត្តដែរ ចំពោះប្រទេសមួយដែលប្រើប្រាស់អត្រាប្តូរប្រាក់ផ្សេងៗគ្នា យោងទៅតាមផលិតផលដែលបានរៀបចំនូវជញ្ជីងទូទាត់ជារូបិយប័ណ្ណបរទេសខ្លាំង ឬអាចដូរបាន ដូចជា ដុល្លារអាមេរិកជាដើម។ ប្រាក់ ៣,៥០០រៀល ស្មើនឹងការនាំលុយ

ចូល ៣៥០ ហ្វ្រង់ ស្មើនឹង ១០០ ដុល្លារអាមេរិក។ ហើយមានការលំបាកក្នុងការបញ្ចូល ១០០ ដុល្លារអាមេរិក ទៅនឹង ៣៥០ហ្វ្រង់ ព្រោះនៅលើទីផ្សារពិភពលោក ១០០ ដុល្លារអាមេរិក ស្មើនឹង ៥០០ហ្វ្រង់។ ដើម្បីរៀបចំតួលេខតំណាងការនាំចេញ នាំចូល ឬរៀបចំតួលេខនៃជញ្ជីងទូទាត់ គេត្រូវបែងចែកឱ្យដាច់ពីគ្នា នូវតួលេខទាក់ទងទៅនឹងប្រតិបត្តិការនានាជាមួយប្រទេសនៃតំបន់លុយហ្វ្រង់ ដោយគិតជាលុយ ហ្វ្រង់ ព្រោះគេនឹងផ្ទេរលុយ គិតតាមដុល្លារអាមេរិក គឺអត្រា ៥ហ្វ្រង់ / ដុល្លារអាមេរិក ហើយគេបន្ថែមទៅតួលេខ ដែលជាប់ទាក់ទងនឹងប្រតិបត្តិការនានា គិតជាលុយដុល្លារអាមេរិក។

គឺលទ្ធផលនៃការគណនាទាំងនោះ ដែលសម្រាប់បម្រើជាមូលដ្ឋាននៃការវិភាគជាបរិមាណនៃពាណិជ្ជកម្មក្រៅប្រទេស។ មូលដ្ឋាននោះ លេចឡើងជាភាពប្រេះស្រួយ បើគេប្រៀបនឹងតួលេខផ្តល់ឱ្យដោយមន្ទីរជាតិប្តូរប្រាក់ និងសេវាកម្មគយរដ្ឋាករ។ តួលេខនោះ ខុសគ្នាឆ្ងាយណាស់។ ទីមួយ ការហូរចូល និងការហូរចេញនៃទំនិញ ទីពីរ ការចុះបញ្ជីនៃបទបញ្ញា Réglements នាំចូល និងនាំចេញ។ ការកត់សម្គាល់នេះ មិនគ្រប់គ្រាន់ក្នុងការពន្យល់ នូវសារៈសំខាន់នៃភាពខុសគ្នារវាងផ្នែកទាំងពីរនោះទេ។ គេហាក់ដូចជាឃើញថា តួលេខគយរដ្ឋាករ មិនសូវល្អ ខាងគុណភាព ដូចតួលេខនៃមន្ទីរជាតិប្តូរប្រាក់ទេ។ ចំណេះដឹងពីពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា ត្រូវគិតដល់ប្រធានបទផ្សេងៗទៀត ដូចជាការវិភាគលើការនាំចូល និងការនាំចេញ ហើយនិងជញ្ជីងទូទាត់។

## ៦.៣.ការនាំចូល

ការសិក្សា ស្តីអំពីបទបញ្ញាពាណិជ្ជកម្មក្រៅប្រទេស បានបង្ហាញនូវភាពចាំបាច់ ក្នុងការកែតួលេ វិស័យ សេដ្ឋកិច្ច។ ភាពមិនទាន់ត្រឹមត្រូវនេះ មកពីការនាំចូលទំនិញច្រើនប្រភេទ ដែលធ្វើឱ្យលំបាកដល់ការវិភាគ នូវបរិមាណផលិតផលនោះ។ ដោយឡែកភាពខុសគ្នា រវាងប្រភពស្ថិតិមានសារៈសំខាន់ណាស់។ ដូចនេះ ការប្រមូលគំនិតពិត និងត្រឹមត្រូវនៃរចនាសម្ព័ន្ធនាំចូលរបស់ប្រទេសតាមផលិតផលនីមួយៗ ក៏លំបាក។

### ៦.៣.១.សារៈសំខាន់នៃការនាំចូល

ការនាំចូលផ្អែកទៅតាមឆ្នាំនីមួយៗ មានចំនួនពី ១% ទៅ ២១% នៃផលទុនដុលរបស់ជាតិ ដោយមាន និន្នាការកើនឡើងពិតប្រាកដ។ ប៉ុន្តែតួលេខនោះពិបាកយកជាការពិតបានណាស់ ចំពោះសារៈសំខាន់នៃការនាំចូល។ គេកត់សម្គាល់ថា ផលិតផលនៃវិស័យសេវាកម្ម ដូចជាពាណិជ្ជកម្ម សេវាផ្សេងៗ មន្ត្រី ។ល។ មិនអាចនាំចូលបានទេ។ ប៉ុន្តែ សមាមាត្រនៃការនាំចូលប្រៀបនឹងផលិតផលកសិកម្ម និងឧស្សាហកម្មកម្ពុជា មានលើសពីតួលេខបញ្ជាក់ទៅទៀត។

តារាងផ្លាស់ប្តូរទំនិញឧស្សាហកម្ម បានបង្ហាញថា ភាគចំណែកនៃការនាំចូលប្រៀបនឹងផលិតផលសរុបនាឆ្នាំ ១៩៦២ គឺលើសពី ២៥% នៅក្នុងសាខាសេដ្ឋកិច្ចប្រាំ៖ ថាមពល ២៥% វត្ថុធាតុដើម និងពាក់កណ្តាលសម្រេច ២៧% ផលិតផលឧស្សាហកម្មផ្សេងៗ ៤៧%

ផលិតផលឧស្សាហកម្មយន្តសាស្ត្រ និងអគ្គិ-សនី ៦៦% វាយនភ័ណ្ឌ និងស្បែក ៧៦%។ មានតែផ្នែកមួយទេ ដែលភាគចំណែកនាំចូលគ្មានសារៈសំខាន់នោះ គឺផលិតផលបន្លែ និងសាច់ សត្វ ១.៦% និងផលិតផលស្បៀង ១៥% សំណង់ និងសាធារណៈការ និងសេវានានា គឺជាសាខាដែលការនាំចូល មិនសូវមានសារៈសំខាន់។ ផលិតផលក្នុងស្រុក ស្មើនឹងផលិតផលសរុប ដកនឹងការនាំចូល មិនបញ្ចូលទៅក្នុងការនាំចូលទេ។ ប៉ុន្តែឧស្សាហកម្មក្នុងស្រុកក៏ប្រើប្រាស់ផលិតផលនាំចូលដែរ។ ការគណនាពីខ្លឹមសារនៃការនាំចូល នៃសាខានីមួយៗ អាចបញ្ជាក់សារៈសំខាន់នៃផលិតផលនាំចូល។ តួនាទីនៃ ការនាំចូលនៅក្នុងផលិតផលក្នុងស្រុក មិនមែនគ្មានសារៈសំខាន់នោះទេ ព្រោះខ្លឹមសារនៃការនាំចូល គឺ ២៧% សម្រាប់ឧស្សាហកម្មយន្តសាស្ត្រ និងអគ្គិសនី ២១% សម្រាប់វាយនភ័ណ្ឌ និងស្បែក និង១៨% សម្រាប់សំណង់ និងសាធារណៈការ។

គ្រឿងបន្លាស់នាំចូល និងថ្លៃបង្ករ ត្រូវរាប់បញ្ចូលជាការប្រើប្រាស់កណ្តាលនៃរោងចក្រ ហើយមិនបន្ថែម ទម្ងន់ដល់ខ្លឹមសារនៃការនាំចូល នៃផលិតកម្មរបស់រោងចក្រនោះទេ អាចក្នុងពេលនោះធ្វើឱ្យខូចរោងចក្រទាំងស្រុង។

នៅកម្ពុជា ការនាំចូល ឬភាគខ្លះនៃការនាំចូល មិនត្រឹមតែមានសារៈសំខាន់នោះទេ តែជានិច្ចកាល ជាការចាំបាច់ទៀតផង។ ចំពោះកម្ពុជា គឺការគិតទៅដល់ទំហំរបស់ប្រទេស ដែលត្រូវការនាំចូលនូវឧស្សាហកម្មនៃការផលិតសម្ភារ និងការដំឡើងទិញសម្ភារទាំងនោះ ដូចជាម៉ាស៊ីន ដែលជាមូលដ្ឋាននៃការអភិវឌ្ឍ។

ជាបន្តបន្ទាប់ ការនាំចូលកាន់តែមានសារៈសំខាន់សម្រាប់ប្រទេសនេះ ដែលឈានទៅធ្វើឧស្សាហូបនីយកម្ម។ ឧស្សាហូបនីយកម្ម ប្រព្រឹត្តទៅក្នុងសង្វាក់មួយលឿន នាំឱ្យទិញម៉ាស៊ីនថ្មីជារៀងរាល់ឆ្នាំ។ រូបិយប័ណ្ណដែលសន្សំបានពីការផលិតរបស់ម៉ាស៊ីននាំចូលពីឆ្នាំមុនៗ ត្រូវយកទៅចំណាយលើការនាំចូលនូវម៉ាស៊ីនថ្មីៗទំនើបជាងទៀត។ "ខ្លឹមសារ" នៃការនាំចូលវិស័យឧស្សាហកម្ម មានកម្រិតខ្ពស់ជាងវិស័យកសិកម្ម។ នៅពេលដែលវិស័យឧស្សាហកម្មរីកចម្រើន ការនាំចូលត្រូវថយមកជាមធ្យមទៅវិញដែលជំនួសដោយការប្រើប្រាស់ផលិត ផលក្នុងស្រុក។ ដូចនេះ គេឈានទៅបន្ថយបាននូវការនាំចូលនូវទំនិញប្រើប្រាស់ចុងក្រោយ មកជាការនាំចូលនូវការចាំបាច់នូវការប្រើប្រាស់ ទំនិញពាក់កណ្តាលសម្រេច។

ប្រទេសមួយចំនួន ដូចជា ឥណ្ឌា មានលក្ខណៈធំធេងគ្រប់គ្រាន់ ដើម្បីបង្កើតនូវឧស្សាហកម្មផលិតទិញសម្ភារៈ បានផ្តល់នូវបទពិសោធន៍នៃយន្តការទាំងនោះ ដែលបានធ្វើឧស្សាហូបនីយកម្ម ប្រទេសយ៉ាងរហ័សក្នុងតម្លៃដើមដ៏ខ្ពស់ ក្នុងការចំណាយរូបិយប័ណ្ណ ហើយក៏តែងជួបផងដែរនូវឧបសគ្គធំៗ។ ដូចនេះគេត្រូវពិនិត្យជាមុនសម្រាប់ការនាំចូលរបស់កម្ពុជា ដែលមានតួនាទីសំខាន់បំផុតនោះ។

សារៈសំខាន់នៃពន្ធអាករលើពាណិជ្ជកម្មក្រៅប្រទេស ក៏ត្រូវតែសិក្សាថែមទៀតដែរ។ ពន្ធលើការនាំចូល យោងទៅតាមឆ្នាំនីមួយៗ គឺពី ៣៧% ទៅ ៤៧% នៃចំណូលជាតិ។

## ៦.៤.ការនាំចេញ

សិក្សាការនាំចេញ មានភាពងាយស្រួលជាងការសិក្សាការនាំចូល។ ភាពខុសគ្នា រវាងជញ្ជីងទូទាត់ និងឯកសាររបស់គយ និងរដ្ឋាករ មិនខុសធ្ងន់ធ្ងរពេកទេពីការនាំចូល។ ដោយគេមានឯកសារឯកជន ដែលចុះបញ្ជីពីចលនានៃបរិមាណ ផលិតផល និងតាមប្រទេស ។

### ៦.៤.១.ការនាំចេញអង្ករ

អង្ករ គឺជាទំនិញនាំចេញសំខាន់ទាំងតម្លៃទាំងបរិមាណដែលត្រូវសិក្សាដោយឡែក។ ស្រូវដែលប្រមូលផលដោយកសិករហើយសម្រាប់បម្រើជាពាណិជ្ជកម្មបានត្រូវទិញ និងប្រមូលដោយពួកឈ្មួញម្ចាស់ម៉ាស៊ីនកិនស្រូវ។ ចលនាសហករណ៍ មាននិន្នាការបែបនេះដែរ។ មុនឆ្នាំ ១៩៦៣ មុនត្រូវនាំចេញ គឺត្រូវឆ្លងកាត់ក្រុមហ៊ុនធំៗ ដែលបម្រើឱ្យទីផ្សារក្នុងស្រុកមួយចំណែកផង។ ចាប់ពីឆ្នាំ១៩៦៣ពួកក្រុមហ៊ុនឯកជន និងម្ចាស់ម៉ាស៊ីនកិនស្រូវ លក់អង្ករឱ្យ សូណិចស៊ីម ជាអ្នកណាំចេញតែមួយគត់ ។ អង្គការចាត់តាំងមួយនោះ ដំបូងជាឯកជនក្រោយមកជាសេដ្ឋកិច្ចចម្រុះ សហករណ៍តាមដានផលិតផលនាំចេញ C.O.S.U.R ធ្វើ អន្តរាគមន៍ ស្របការងារនេះដើម្បីតាមដានកិនស្រូវ ការវេចខ្ចប់ និងការបញ្ជូនអង្ករ ហើយធានារ៉ាប់រងនូវសុវត្ថិភាពនៃបរិមាណអង្ករ។ ការតាមដានបច្ចេកទេសនេះ គឺធ្វើឱ្យអតិថិជនបរទេសជឿលើផលិតផលកម្ពុជា។

អ្វីដែលម៉ាស៊ីនកិនស្រូវផលិតនោះ គឺមិនមែនតែអង្ករនោះទេ តែមានលាយដោយអង្ករនិងចុងអង្ករ និងកន្ទក់។ សូណិចស៊ីម នាំចេញទាំងអង្ករ ទាំងចុងអង្ករ និងកន្ទក់ ពាក្យថានាំអង្ករក្នុងនោះ គឺមានតម្លៃខុសៗគ្នានៅត្រង់មានលាយទៅដោយចុងអង្ករជា % ។

ការថយចុះនៃការប្រមូលផល និងផលិតកម្ម មិនប៉ះពាល់ដល់ការប្រើប្រាស់ ដែលកើនឡើងជាប្រចាំ ជា មួយកំណើនប្រជាជនរបស់ប្រទេសទេ ។ ការប្រមូលផលអាក្រក់បំផុត នៅឆ្នាំ ១៩៦២ នាំឱ្យមានការបន្ថយនូវការប្រើប្រាស់ពី ៥% ទៅ ១០% ។ ការប្រមូលផលនាឆ្នាំ ១៩៦២ នាំទៅដល់ការលំរលាយនៃការនាំចេញ ដែលត្រូវបាត់បង់ទៅដល់ទៅ ៥០% ។ បាតុភូតបែបនេះ មិនមែនគ្មានលេចចេញនូវផលប៉ះពាល់នោះទេ ការថយចំណូលជារូបិយប័ណ្ណបោទជាបញ្ហាដល់ថិការជាតិ។

គេអាចបញ្ជាក់នូវគំនិតមួយ ដោយនិយាយថា ការនាំអង្ករចេញមិនសូវមានភាពអេឡាស្ទិកទេ ប្រៀបទៅនឹងថ្លៃអង្ករអន្តរជាតិ ។ បាតុភូតនេះ រណបតែនឹងការប្រមូលផលស្រូវតែប៉ុណ្ណោះ។

ការសិក្សាការនាំអង្ករចេញទៅកាន់ប្រទេសនីមួយៗ នាំទៅដល់ការកត់ចំណាំដូចតទៅៈ

ជាបឋម ទីផ្សារមានការផ្លាស់ប្តូរខ្លាំងណាស់ ហើយការទិញរបស់អតិថិជន មិនផ្តល់នូវការតាមមកទិញនោះទេ។ ឧទាហរណ៍ ប្រទេសមួយបានទិញអង្ករចំនួន ៣០,០០០ តោន នៅឆ្នាំណាមួយ មិនទិញបន្តទៀតទេនៅឆ្នាំបន្ទាប់។

កម្ពុជាមានអតិថិជនពី ៣ ទៅ ៤ ប្រទេសសំខាន់ៗ។ ប្រទេសបារាំង និងសហគមន៍តំបន់លុយហ្វ្រង់ ដែលជាប្រទេស់នៅឆ្ងាយ តែជានាដល់ការទិញអង្ករពីកម្ពុជា។ គេដឹងថា សេណេហ្គល់ ជាអតិថិជនសំខាន់របស់កម្ពុជាបន្ទាប់មកគឺ ហុងកុង និងសិង្ហបុរី ជាអតិថិជនដ៏ល្អដែលបានទិញអង្ករគ្រប់ប្រភេទពីកម្ពុជា។ អង្ករដែលផ្ទេរនៅកំពង់ផែទាំងពីរនេះ មិនមែនសុទ្ធតែយកទៅប្រើប្រាស់នៅទីនោះទាំងអស់ទេ មួយចំនួនត្រូវនាំចេញបន្តប្រទេសដទៃទៀត។ ជប៉ុនជាអ្នកទិញអង្ករកម្ពុជា ជាប្រចាំតែត្រូវការតែបន្តិចបន្តួច។ការកើនឡើងនៃបរិមាណអង្ករនាំចេញចាប់ពីឆ្នាំ ១៩៦៣ មិនមែនជាសេចក្តីត្រូវការរបស់អតិថិជនប្រពៃណីនោះទេ តែដោយសារការបើកទីផ្សារថ្មីៗ។ អតិថិជនថ្មី គឺប្រទេសសង្គមនិយម និងប្រទេសអាស៊ី ដូចជា ឥណ្ឌា ហ្វីលីពីន ចិន និងវៀតណាមខាងជើង។

ទីផ្សារកន្ទាក់ និងចុងអង្ករ គឺជាទីផ្សារដោយឡែក បានកើនឡើងដល់ ៤០,០០០ តោន ពីដំណាក់កាលដំបូង រហូតដល់ ៧០,០០០ តោន នៅចុងដំណាក់កាល។ សឹង្ហបុរី ទិញ ៣/៤ នៃចុងកន្ទក់ និងចុងអង្ករ ហើយនៅសល់ប៉ុន្មានទីផ្សារ ហុងកុង ស្រូបយកទាំងអស់។

ជាទូទៅ អង្ករកម្ពុជាមានគុណភាពល្អ ដោយសារការត្រួតពិនិត្យជាប្រចាំរបស់ C.O.S.U.R ជាផលិតផល ដែលគេត្រូវការ ហើយកម្ពុជាមិនមានការលំបាកនឹងរកច្រកទីផ្សារបន្ថែមទៀតទេនៅឆ្នាំថ្មីនោះ។ ចំពោះអនាគត មានការលើកទឹកចិត្តខ្លាំងណាស់ ដល់ការនាំចេញឱ្យកើនឡើងថែមទៀត នូវផលលើសរបស់កម្ពុជា។ ការនាំចូលអង្ករ ពីប្រទេសកំពុងអភិវឌ្ឍន៍ជូនទៅកាន់ប្រទេលូតលាស់ នឹងថយចុះ ដោយជប៉ុនមានច្បាប់ហាមឃាត់។ ប៉ុន្តែសភាពការណ៍ស្បៀងនៅប្រទេស ឥណ្ឌា និងចិន ត្រូវការនូវការនាំចេញអង្ករជាចាំបាច់។ សំណួរនៅត្រង់ថា តើតម្រូវការសក្តានុពល នឹងកាន់តែត្រូវការពិតប្រាកដ គឺថាប្រទេសទាំងនោះ មានរូបិយប័ណ្ណសម្រាប់ទិញអង្ករជាសេចក្តីត្រូវការរបស់ពួកគេឬ? បញ្ហាមានភាពស្មុគស្មាញបន្តិចត្រង់ថាការប្រមូលផលស្រូវល្អ គឺប្រព្រឹត្តទៅនៅទូទាំងអាស៊ីអាគ្នេយ៍ ហើយនៅពេលដែលកម្ពុជាមានអង្ករច្រើនសម្រាប់លក់ ប្រទេសជិតខាងមិនសូវចង់ទិញ។ កម្ពុជាត្រូវឆ្លៀតឱកាស ក្នុងពេលដែលប្រទេសភូមា និងវៀតណាម ពេលនោះមានការថយចុះ ឬបាត់បង់នូវផលស្រូវលើស សម្រាប់នាំចេញ។

គុណភាពអង្ករកម្ពុជាដ៏ល្អ រក្សាបាននូវតួនាទីលើទីផ្សារមូលធននិយម។ នយោបាយពាណិជ្ជកម្ម ឆ្ពោះទៅកាន់ប្រទេសសង្គមនិយម ពេលនោះបានធ្វើឱ្យក្លាយជាអតិថនជននៃអង្ករកម្ពុជា។បើការនាំចេញអង្ករកម្ពុជា មិនចោទលើបញ្ហាបរិមាណ និងគុណភាពនោះ ត្រូវគិតដល់បញ្ហាថ្លៃ។

ថ្លៃអង្ករពិភពលោក គិតជាលុយរៀលតាមអត្រាផ្លូវការមានកម្រិតទាបណាស់ប្រៀបនឹងថ្លៃស្រូវក្នុង ស្រុក។ ដោយផលិតភាពនៃការងារដាំដុះស្រូវកម្ពុជាខ្សោយ និងគិតដល់អត្រាប្តូរប្រាក់នោះ ថ្លៃដើមផលិតកម្ម ស្រូវខ្ពស់ណាស់។ ការនាំអង្ករចេញបានដោយសារតែថ្លៃផ្គត់ផ្គង់បន្ថែមពីរដ្ឋ។ ថ្លៃបន្ថែមនោះ ជារង្វាន់ដល់E.F.A.C ហើយក្រោយឆ្នាំ ១៩៦៣ ដោយមានការនាំចេញតាមច្រកតែមួយរបស់ សូណិចស៊ីម ចំនួនប្រាក់បន្ថែមលើថ្លៃអង្ករ សម្រាប់នាំចេញពីឆ្នាំ

១៩៦២ ដល់ ១៩៦៦ មានចំនួនប្រហែល ៥០លានរៀល ពាក់កណ្តាលនៃ រង្វាន់សរុបផ្តល់ឱ្យអ្នកនាំចេញ ។ ប៉ុន្តែនៅឆ្នាំ ១៩៦៧ ការឡើងថ្លៃអង្ករពិភពលោក ការនាំចេញត្រូវប្តូរតាមអត្រាផ្លូវការ ដោយគ្មានជំនួយបន្ថែមទេ ។ ប៉ុន្តែនៅពេលណាដែលប្រទេសនៅអាស៊ីអាគ្នេយ៍ ប្រមូលផលស្រូវបានល្អដូចគ្នា នោះថ្លៃស្រូវថយចុះ។

សភាពការណ៍បែបនេះ ធ្វើឱ្យមានការលំបាកដល់ការទស្សន៍ទាយ អំពីការនាំចេញអង្កររបស់កម្ពុជា។ ទីផ្សារមានមិនខ្វះទេ តែបើអង្ករឡើងថ្លៃដូចឆ្នាំ ១៩៦៥ និង ១៩៦៦ ជាបន្តបន្ទាប់នោះ លទ្ធភាពនាំអង្ករចេញមាន ភាពល្អណាស់ ជាសំណាងធំណាស់ នៃពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា។ វានៅតែត្រូវការចាប់យកឱកាសនៃសំណាងនោះឱ្យបាន គឺការផលិតឱ្យមានផលលើសសម្រាប់នាំចេញ គឺបង្កើនផលិតកម្មឱ្យលើសពីការប្រើ ប្រាស់។ នោះហើយជាបញ្ហាមួយធំនៃនយោបាយកសិកម្ម ហើយក៏មិនមែនជានយោបាយពាណិជ្ជកម្មក្រៅប្រទេសដែរ តែជាបញ្ហាក្នុងផលប្រយោជន៍ ពាណិជ្ជកម្មក្រៅប្រទេស ដែលត្រូវទទួលបាននូវបុព្វសិទ្ធិដ៏ធំមួយ។

## ៦.៤.២.ការនាំចេញកៅស៊ូ

កៅស៊ូ ជាប្រភពរូបិយប័ណ្ណទីពីរនៃកម្ពុជា។ នៅឆ្នាំ ១៩៥៩ ១៩៦០ ១៩៦២ និង ១៩៦៧ ការនាំចេញ កៅស៊ូ បានកើនច្រើនជាងការនាំអង្ករចេញ គិតជាតម្លៃ ដោយមិនគិតអំពីបរិមាណជាទំងន់នៃចំនួនតោន ព្រោះថ្លៃ កៅស៊ូក្នុងមួយតោន ខ្ពស់ជាងអង្ករឆ្ងាយណាស់។

ក.ថ្លៃកៅស៊ូ រណបទៅនឹងគុណភាព ឬក៏យោលទៅលើរូបភាពរបស់ផលិតផលកៅស៊ូសម្រាប់នាំចេញ ដែលមានរូបភាពបី៖

– ជាកៅស៊ូផ្អើរ ដែលបានត្រូវកែច្នៃ មានគុណភាពល្អ សម្រាប់ប្រើប្រាស់ជាវត្ថុធាតុដើមផលិតកង់រថយន្ត
– ជាជ័រទាំង មិនទាន់បង្កក
– ជាជ័រក្រែប ដែលមានគុណភាពដែរ

ថ្លៃនៃប្រភេទជ័រកៅស៊ូទាំងនោះ មានការឡើងចុះជាធម្មជា។ តែជាទូទៅ ជ័រទឹកជារូបភាពមានតម្លៃ។ ជ័រក្រែប ក៏មានតម្លៃលើទីផ្សារបង្គួរដែរ។

ការនាំចេញកៅស៊ូ បានកើនឡើងជានិច្ច ហើយមានការគាំទ្រថ្លៃ ក្នុងសង្វាក់ប្រចាំឆ្នាំប្រហែល ៥% រហូតដល់ខែ មករា ១៩៦៦ ។ នៅឆ្នាំ ១៩៦៧ ការថយចុះនៃថ្លៃកៅស៊ូ ធ្វើឱ្យមានការបន្ថយនូវបរិមាណកៅស៊ូនាំចេញ។

សមាសភាពនៃការនាំចេញ មានការកែប្រែ ដោយសារការនាំចេញទឹកជ័រ កាន់តែច្រើនឡើង ២៥% នៃផលិតផលនាំចេញសរុប នាបណ្តាឆ្នាំខាងលើ ហើយកើនដល់ ៣៥% នៅចុងបញ្ចប់នៃដំណាក់កាលនោះ។ចំណែកឯការនាំចេញជ័រសន្លឹកផ្អើរបានថយចុះ ៥០% ។ បច្ចុប្បន្នការនាំចេញជ័រកែបបានត្រូវរក្សាបានក្នុងកម្រិតនឹងនរ។

ហួតដល់ឆ្នាំ ១៩៦៣ ការលក់កៅស៊ូ គឺក្នុងស្ថានភាពសេរី ហើយស្ថិតនៅក្រោមការគ្រប់គ្រងនៃក្រុមហ៊ុនអឺរ៉ុបធំៗដែលមានឯកទេសផ្នែកនេះ។ ការនាំចេញក៏នៅបានរក្សាទុក ជារូបិយប័ណ្ណចំណេញជួលទៅក្នុងមន្ទីរជាតិប្តូរប្រាក់ លើកលែងតែប្រាក់ដែលសម្រាប់ជាការលើកទឹកចិត្តទៅក្រុម E.F.A.C ដែលកម្រិតទឹកប្រាក់មានចំនួន ១០% នៃការលក់ទំនិញទៅលើតំបន់លុយហ្វ្រង់ និង ១៣% សម្រាប់ការលក់ដទៃទៀត ដែលគេអាចដកហូតប្រើប្រាស់ដោយសេរី។

ចាប់ពីឆ្នាំ ១៩៦៣ មក ការនាំចេញកៅស៊ូបានត្រូវត្រួតពិនិត្យដោយ សូណិចស៊ីម ដែលតែងតែធ្វើការណែនាំ ពីរដងក្នុងមួយសប្តាហ៍ នូវការលក់ដេញថ្លៃ ។ អ្នកលក់ប្រកាសការលក់តាមរយៈការអញ្ជើញឱ្យដេញថ្លៃ ដោយបញ្ជាក់ពីគុណភាព និងបរិមាណកៅស៊ូត្រូវលក់។ ក្រោយការដេញថ្លៃបរិមាណកៅស៊ូទាំងនោះ ត្រូវប្រគល់ទៅឱ្យអ្នកដែលដេញថ្លៃបាន។ អ្នកទិញភាគច្រើន ជាក្រុមហ៊ុនដែលមានការិយាល័យនៅទីនោះ និងសាខានៃក្រុមហ៊ុនអន្តរជាតិ ដូចជា Alcan ។ ថ្លៃផ្គត់ផ្គង់របស់អ្នកទិញ គឺជាប់ទាក់ទងនឹងថ្ងៃដែលអនុវត្តន៍នៅសិង្ហបុរី។ ការនាំចេញប្រព្រឹត្តទៅតាមអត្រាផ្លូវការនៃការប្តូរប្រាក់។

កៅស៊ូកម្ពុជា បានត្រូវនាំចេញក្នុងទសវត្សឆ្នាំ ៦០ ទៅកាន់តំបន់លុយហ្វ្រង់ ពិសេសទៅកាន់ប្រទេស បារាំង។ មួយចំនួននៃបរិមាណកៅស៊ូទាំងនោះ បានត្រូវនាំចេញបន្តទៅទៀត។

**ខ.**ភាពស្របច្បាប់នេះ នាំឱ្យមានផលប្រយោជន៍ ដល់ការបែងចែកទៅតាមភូមិសាស្ត្រនៃការនាំចេញ កៅស៊ូ។ ការនាំចេញ ដោយបែងចែកតាមភូមិសាស្ត្រ គឺយោលទៅតាមតម្លៃ និងបរិមាណ ។ ការនាំចេញទៅកាន់ តំបន់លុយហ្វ្រង់ គឺជាកៅស៊ូមានគុណភាព ហើយមានតម្លៃខ្ពស់។ ចំពោះជ័របង្កក គឺមានតែពាក់កណ្តាល ទេ ដែល បញ្ជូនទៅកាន់តំបន់លុយហ្វ្រង់ ហើយជ័រក្រែបមួយភាគតូចក៏នាំចេញ ទៅកាន់តំបន់នោះដែរ។

ពិនិត្យទៅលើ " ការប្រៀបធៀបនៃការប្តូរប្រាក់ " តើអ្នកទិញកៅស៊ូខ្មែរ ជាប្រទេសណាខ្លះ?

សហរដ្ឋអាមេរិក នៅដំណាក់កាលដំបូង គឺជាអតិថិជនទីមួយ។ សហរដ្ឋបានទិញកៅស៊ូពីកម្ពុជា នាឆ្នាំ ១៩៥៨ មានចំនួនប្រាក់ដល់ទៅ ១៣ លាន ដុល្លារអាមេរិក ហើយនៅឆ្នាំបន្ទាប់មក ការនាំចូលទៅអាមេរិក មានការថយចុះ គឺ មិនលើសពី ១ លាន ដុល្លាអ៊ុយអេស។

ប្រទេសបារាំង ជាអតិថិជនដ៏ល្អ ឆ្នាំ ១៩៦០ ព្រោះបានស្រូបយក ១/៤ នៃបរិមាណកៅស៊ូនាំចេញ។

អ្នកទិញកៅស៊ូដទៃទៀត គឺសុទ្ធតែជាប្រទេសអឺរ៉ុបខាងលិច ដែលសរុបមកចិញ លើសប្រទេសបារាំងបន្តិចបន្តួច។ ប្រទេសទាំងនោះ គឺ អង់គ្លេសបានទិញជាង ៦ លានដុល្លារអាមេរិក នាឆ្នាំ ១៩៦១ និង ១៩៦២ ។ ប្រទេសអាល្លឺម៉ង់ អ៊ីតាលី អេស្ប៉ាញ និងហូឡង់ ក៏បានបញ្ជាទិញច្រើនណាស់ដែរ។

ប្រទេសទាំងបី និងក្រុមប្រទេសទាំងនោះ ជាទីផ្សារកៅស៊ូសំខាន់របស់កម្ពុជា។ ប្រទេសសង្គមនិយមអឺរ៉ុប បានជូនមកវិញក្នុងបរិមាណតិច ហើយសរុបអ្នកទិញអឺរ៉ុបខាងកើតទិញមិន

លើសពី ១ លានដុល្លារអាមេរិកទេ។ ប្រទេសសឹង្ហបុរី បានបង្កើនបរិមាណនៃការទិញកៅស៊ូពីកម្ពុជានៅពេលចុងក្រោយនោះ។ កៅស៊ូកម្ពុជានាំចេញទៅ សឹង្ហបុរី បានត្រូវនាំចេញបន្តទៅទៀត។ នៅឆ្នាំ ១៩៦៦ ប្រទេសជប៉ុន បានលេចចេញឡើងជាប្រទេសសំខាន់ ដោយបានទិញជាង ២ លានដុល្លារអាមេរិកនូវកៅស៊ូពីកម្ពុជា។

**គ.**តើអនាគតនៃការនាំចេញកៅស៊ូកម្ពុជាទៅជាយ៉ាងណា? ជាទូទៅ តាមការសិក្សាដែលសរសេរដោយ អង្គការហ្វាវ F.A.O ថា កៅស៊ូធម្មជាតិនឹងជួបប្រទះនូវការប្រកួតប្រជែងយ៉ាងខ្លាំងក្លាពីកៅស៊ូសំយោគ។ ការប្រកួតប្រជែងកើតឡើងទៅលើបរិមាណត្រូវលក់ និងពិសេសថ្លៃ។

ភាគចំណែកនៃកៅស៊ូធម្មជាតិ ក្នុងចំនួនសរុបនៃកៅស៊ូប្រើប្រាស់ ចេះតែថយបរិមាណទៅ ហើយនឹងបន្ថយចំនួនថែមទៀត។ ប៉ុន្តែការថយនូវបរិមាណប្រើប្រាស់មិនដាច់ខាតនេះ ដើរទន្ទឹមនឹងការកើនឡើងយ៉ាងដាច់ខាត ជាប្រចាំនៃគុណភាពរបស់កៅស៊ូធម្មជាតិ ដែលកៅស៊ូសំយោគមិនអាចប្រៀបបាន។ ហើយអ្នកឯកទេសគិតថា នៅក្នុងអាណត្តិណាមួយ បរិមាណនៃការនាំចេញកៅស៊ូធម្មជាតិ ពិភពលោក នឹងបន្តកើនឡើងក្នុងសង្វាក់បង្គួរដែរ។ នៅទសវត្ស ឆ្នាំ ១៩៩០ នេះ សេចក្តីត្រូវការកៅស៊ូធម្មជាតិមាននិន្នាការ កើនឡើងមែន ព្រោះតែគុណភាពកៅស៊ូ សំយោគ មិនអាចប្រៀបបាន។

ថ្លៃកៅស៊ូក៏ជាកត្តាកំណត់មួយទៀត ព្រោះនៅពេលដែលថ្លៃកៅស៊ូសំយោគ ថោកជាងកៅស៊ូធម្មជាតិ នោះនអតិថិជននឹងបង្ខំចិត្ត បោះបង់ចោលកៅស៊ូធម្មជាតិ។ ដូចនេះ អ្នកលក់កៅស៊ូធម្មជាតិ ក៏បង្ខំចិត្តលក់ក្នុងតម្លៃថោកជាង។ ថ្លៃកៅស៊ូធម្មជាតិ ត្រូវស្ថិតនៅក្រោមបង្គាប់នៃថ្លៃកៅស៊ូសំយោគ។ ដោយយោលទៅលើថ្លៃប្រកួតប្រជែងក្នុងជួរនៃកៅស៊ូសំយោគ ថ្លៃកៅស៊ូសំយោគរេបទៅតាមថ្លៃដើមនៃការផលិតកៅស៊ូសំយោគ។ ក្នុងបច្ចេកទេសកៅស៊ូសំយោគត្រូវការនូវការកែលម្អបច្ចេកទេសផលិតភាពការងារ និងការចាត់ចែងដោយបន្ថយនូវថ្លៃដើមផលិតកម្មដែលនាំទៅដល់ការបន្ថយថ្លៃលក់បាន។ចរន្តនេះបានបន្តថយចុះពីឆ្នាំ១៩៥៩មក ហើយថ្លៃកៅស៊ូមានការថយចុះជាបន្តបន្ទាប់ដែរ។ ផលិតករកៅស៊ូធម្មជាតិ ដើម្បីរស់បាន ក៏ត្រូវបន្ថយនូវថ្លៃដើមផលិតកម្មផងដែរ។ ដីក្រហមមានជីជាតិនៃកម្ពុជា និងគុណភាពនៃការចាត់ចែងការងាររបស់ក្រុមហ៊ុន ធានាបាននូវទិន្នផល ក្នុងមួយហិចតាយ៉ាងខ្ពស់ហើយកើនឡើងជាប្រចាំ។ ទិន្នផលក្នុងមនុស្សម្នាក់ គឺផលិតភាពការងារទ្រើង ហើយពលកម្មក៏ជាសមាសភាពសំខាន់នៃថ្លៃដើមដែរ។

ទស្សនៈវិស័យនៃការនាំចេញកៅស៊ូនៅកម្ពុជានាពេលនោះ មិនទាន់ភ្លឺច្បាស់សម្រាប់សេដ្ឋកិច្ចកម្ពុជានៅឡើយ។ ទោះបីជា បច្ចេកទេសមានការឈានទៅមុខលើអ្នកប្រកួតប្រជែងឥណ្ឌូនេស៊ី ម៉ាឡេ ស្រីលង្កា ហើយនិងការថយចុងនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនចម្ការកៅស៊ូ បរិមាណជ័រនាំចេញចេះតែកើនឡើងជានិច្ច។ ប៉ុន្តែថ្លៃលក់ក៏ថយចុះជាប្រចាំដែរ។ ចលនាផ្ទុយរវាងបរិមាណជ័រ និងថ្លៃជ័របាន ត្រូវកត់សម្គាល់ឃើញនាឆ្នាំចុងក្រោយ ទេ។ ចំណូលបានមកពីការនាំចេញកៅស៊ូ ដូចជាស្ថិតនៅក្នុងកម្រិត ២០ លានដុល្លារអាមេរិក។ ដោយឡែក ចំនួនទឹក

ប្រាក់ខាងលើ គឺខ្ពស់ណាស់ ប៉ុន្តែចំនួនជាចំណូលផលទុនជាប្រចាំ។ ចំណូលកៅស៊ូ មិនអាចទប់ទល់បាននឹងសេចក្តីត្រូវការរូបិយប័ណ្ណ ដែលចេតែកើនឡើងរបស់កម្ពុជាឡើយ។

### ៦.៤.៣.ការនាំចេញផ្សេងៗទៀត

កម្ពុជានាំចេញនូវ អង្ករ និងកៅស៊ូ។ ក្រៅពីនោះ ក៏នៅមានការនាំចេញកសិផលផ្សេងៗទៀត។

**ក.**ការនាំចេញមាននិន្នាការថយចុះ គិតជាតម្លៃដាច់ខាត។ ចំណូលពីការនាំចេញនៅនឹងត្រឹមប្រហែល ១៥ លានដុល្លារអាមេរិក % នៃការនាំចេញសរុបបានថយចុះប្រហែល ២៥% ដើមតំណាក់កាល ហើយសព្វថ្ងៃមានអត្រា ១៥% ។

**ខ.**ការនាំចេញពោតក្រហម មានទីតាំងពិសេសគួរជាទីលើកទឹកចិត្ត។ កម្រិតនៃការនាំចេញពោតក្រហម មានការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ ហើយក៏មិនមានលេចឡើងនូវការកើនឡើង ឬថយចុះទេ។ ប៉ុន្តែ ការនាំពោតក្រហមចេញ ដូចជានៅនឹងថ្កល់។

អតិថិជនពោតកម្ពុជា គឺសុទ្ធតែប្រទេសអាស៊ី។ ជប៉ុន សឹង្ហបុរី ហុងកុង ជាអតិថិជនដ៏ល្អ។ ប្រទេសចិន និងវៀតណាមខាងជើង ពេលនោះក៏បានទិញក្នុងបរិមាណសំខាន់ណាស់ដែរ។

**គ.**ភាពនិងកើតឡើង លើការនាំចេញនូវកសិផល បី ប្រភេទ គឺ ម្រេច គរ និងផលិតផលព្រៃឈើ ដែល ជាកសិផលសំខាន់បន្ទាប់ពីពោត។ ថ្ងៃជាកត្តាកំណត់ ដែលមិនលើកទឹកចិត្តឱ្យពង្រីកផលិតកម្មសោះ។

**ឃ.**ផលិតផល បី មុខទៀត គឺ ផលនេសាទ សត្វពាហនៈរស់ និងសណ្តែកស្ងួត។ ការនាំចេញទំនិញ បី ប្រភេទនេះ មាននិន្នាការថយចុះដែរ។ ការនាំចេញសត្វពាហនៈ និងផលព្រៃឈើ ដោយរត់ពន្ធប្រព្រឹត្តទៅដោយគ្មានសង្ស័យឡើយ។ តួលេខ មិនបានចូលក្នុងបញ្ជីផ្លូវការច្រើនទេ។

មុននឹងស្វែងរកនូវការបញ្ចប់មតិ លើបញ្ហានាំចេញ គួរតែសួរដល់ការវិវដ្តនៃអាណត្តិនៃការផ្លាស់ប្តូរ ទំនិញនៅកម្ពុជា។ យើងត្រូវរៀបចំវិស័យថ្ងៃឱ្យច្បាស់លាស់។ តើការវិវដ្តនៃថ្លៃផលិតផលនាំចូល ប្រៀបនឹងថ្លៃផលិតផលនាំចេញខុសគ្នាយ៉ាងណា។

មានគណនាជាច្រើនបានធ្វើឡើងសម្រាប់វាយតម្លៃដល់ការវិវដ្តនៃអាណត្តិការផ្លាស់ប្តូរ។ ពីឆ្នាំ ១៩៥៧ ពាក្យថា term d'echange ឬអាណត្តិការផ្លាស់ប្តូរនេះ មិនសូវបានគិតគូរដល់ទេនៅក្នុងប្រទេសក្រីក្រ។ ប៉ុន្តែគេដឹងថាសភាពការណ៍ ជាបយ៉ាប់យ៉ឺនដែរ បើប្រៀបនឹងឆ្នាំ ១៩៥៥ និង ១៩៥៦ ។

ប៉ុន្តែត្រូវបកស្រាយតួលេខទាំងនោះ ដោយប្រុងប្រយ័ត្ន ព្រោះនជាតួលេខរៀបចំឡើងតាមស្ថិតិគួរឱ្យ សង្ស័យ។ ពាក្យថាថ្លៃផលិតផលនាំចូល និងថ្លៃផលិតផលនាំចេញ មិនសូវគ្រប់គ្រាន់ទេ។ គុណភាពនៃផលិត ផលមានការផ្លាស់ប្តូរ ដែលមិនសូវត្រូវការយកចិត្តទុកដាក់ពីការគណនាះ អ្វីដែលគេដឹងបាននោះ គឺថ្ងៃវិវដ្តន៍នៃទម្ងន់ ទំនិញជាតោន នៃផលិតផលគីមីជាដើម ដែលបាននាំចូល។

ការឡើងថ្លៃលក់អង្ករ គឺដើម្បីបំពេញឱ្យការថយចុះនៃថ្លៃលក់កៅស៊ូ។ ពាក្យថា អាណត្តិនៃការផ្លាស់ប្តូរ ពិតជាបានកត់សម្គាល់តាំងពីឆ្នាំ ១៩៦៣ ម្ល៉េះ ។ ដោយសារសេចក្តីត្រូវការរូបិយប័ណ្ណរបស់ប្រទេស ដែលចេះតែកើនឡើង ចម្លើយតែមួយ ដើម្បីបំពេញសេចក្តីត្រូវការនោះ គឺត្រូវបង្កើនការនាំចេញស្រូវ និងកសិផលផ្សេងទៀត។ ផលិតផលស្រូវ ត្រូវតែផលិតឱ្យកើនខ្ពស់ជាងការប្រើប្រាស់ក្នុងស្រុក គឺជាការប្រមូលផលស្រូវ ត្រូវកើនឡើងក្នុង អត្រា ៣% ក្នុងមួយឆ្នាំៗ ដើម្បីឱ្យមានផលស្រូវលើសសម្រាប់នាំចេញ។ សភាពការណ៍ទីផ្សារអង្ករ ក្នុងពិភពលោក អាចធានាបាននូវការបញ្ចេញផលលើសទាំងនោះឱ្យបានច្រើន ដើម្បីលើកទឹកចិត្ត ឱ្យកសិករបង្កើនផលិតកម្ម។

ការនាំអង្ករចេញតែមួយមុខ ជាគ្រោះថ្នាក់បំផុត ព្រោះផលិតផលនេះរណបសឹងតែទាំងស្រុងទៅនឹង អាកាសធាតុ។ គេត្រូវលើកទឹកចិត្តឱ្យមានការនាំចេញកសិផលផ្សេងៗទៀត ដូចជាពោតក្រហម ម្រេច លើ គរ ត្រី និងសត្វពាហនៈជាដើម។

## ៦.៥.រចនាសម្ព័ន្ធនៃការនាំចេញ និងការទិញដូររបស់ខ្លួន

រចនាសម្ព័ន្ធនៃការនាំចេញ ត្រូវតែពិនិត្យតាមផលិតផល និងប្រទេស ។

### ៦.៥.១.ផលិតផលនាំចេញ

អង្ករ កៅស៊ូ និងពោតក្រហម ជាផលិតផលនាំចេញយ៉ាងសំខាន់របស់កម្ពុជា។ ទីតាំងនៃផលិតផលនីមួយៗ នៃផលិតផលក្នុងការនៃចេញសរុប ផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ។ ពីឆ្នាំ ១៩៥៧ ដល់ ១៩៦៦ មធ្យមភាគរយនៃផលិតផលមានដូចតទៅ៖

| | |
|---|---|
| អង្ករ | ៤១ |
| កៅស៊ូ | ៣៣ |
| ពោត | ៩ |
| ផលិតផលផ្សេងៗ | ១៧ |
| សរុប | ១០០ |

រចនាសម្ព័ន្ធនៃការនាំចេញតាផលិតផល មានការប្រែប្រួលក្នុងរយៈពេល ១០ ឆ្នាំនោះគឺមានការកើនឡើងនៃការនាំចេញ ជាងការនាំចេញអង្ករ។

ការផ្លាស់ប្តូរគ្រឡាប់ចាក់ នៃរចនាសម្ព័ន្ធនាំចេញបានកើនឡើងដល់ ៥០% នៃផលិតផលនាំចេញសរុប។ ចំណែកផលិតផលកៅស៊ូ ពោត និងផលិតផលដទៃទៀតបានថយចុះ។ ការនាំចេញរបស់កម្ពុជាប្រមូលផ្តុំជា ២ផ្នែក ផលិតកម្ម។ អង្ករ និងកៅស៊ូជារៀងរាល់ឆ្នាំមានចំនួនពី ៧០%ទៅ៨០% នៃការនាំចេញ។សភាពការណ៍នៃការនាំចេញកសិផលតែមួយ ឬពីរមុខមិនគ្រប់គ្រាន់ទេ ព្រោះវាជាក់គំរាមកំហែងដល់ជញ្ជីងទូទាត់កម្ពុជា។ បើសិនផលស្រូវមិនបានល្អនៅឆ្នាំខ្លះ ដូចឆ្នាំ ១៩៦២ នោះ ការនាំចេញអង្ករជាផលលើស ក៏ដូចជាការធ្លាក់ចុះនៃផលិតផលកៅស៊ូបានធ្វើឱ្យចំណូលជារូបិយប័ណ្ណត្រូវគំរាមកំហែងរលត់រលាយ។

## ៦.៥.២.អតិថិជនរបស់កម្ពុជា

រចនាសម្ព័ន្ធ នៃការនាំចេញរបស់កម្ពុជា ចាត់ថ្នាក់តាមតំបន់ភូមិសាស្ត្រមានភាពសមស្របជាង ព្រោះគ្មានប្រទេស ឬក្រុមប្រទេសណាដែលដើរតួសំខាន់ជាងគេទេ ដូចជាលេខខាងក្រោមបញ្ជាក់នូវមានមធ្យមភាគរយសម្រាប់ឆ្នាំ ១៩៤៧ ដល់ ១៩៦៤ ៖

| | |
|---|---|
| ប្រទេសអាស៊ី | ៣៣ |
| ប្រទេសនៃតំបន់ហ្វ្រង់ | ២៦ |
| ប្រទេសដទៃ | ៤១ |
| សរុប | ១០០ |

ប្រទេសអាស៊ី ស្រូបយកប្រហែល ១% នៃការនាំចេញរបស់កម្ពុជា។ ក្នុងចំណោមប្រទេសទាំងនោះ គឺសិង្ហបុរី និង ហុងកុង។ ទំនាក់ទំនងពាណិជ្ជកម្ម និងធនាគារដែលចងភ្ជាប់ជនជាតិចិននៅកម្ពុជា ជាមួយទីក្រុងចិនទាំងពីរនេះ គឺមិនប្លែកអ្វីឡើយ។ បន្ទាប់មក គឺប្រទេសចិន និងជប៉ុន ។ ការនាំចេញរបស់កម្ពុជាទៅកាន់ប្រទេសអាស៊ីសំខាន់នេះ កាន់តែសកម្មឡើងនៅចុងទសវត្សទី ៦០ ។ ប្រទេសកំពុងលូតលាស់ ដូចកម្ពុជា ត្រូវធ្វើពាណិជ្ជកម្ម ជាមួយប្រទេសឧស្សាហកម្ម ដូច ហុងកុង និងជប៉ុន ។

ប្រទេសបារាំង និងប្រទេសតំបន់ហ្វ្រង់ ដូច សេណេហ្គាល់ ជាអ្នកទិញអង្ករសំខាន់កម្ពុជា បានទិញតែ ១/៤ នៃការនាំចេញរបស់កម្ពុជា ។ ដោយសារចំណងជិតស្និទ្ធ រវាងកម្ពុជា និងបារាំង ពិសេសអត្រាប្តូរប្រាក់ បានលើកទឹកចិត្ត ដល់ការនាំចេញកម្ពុជាឆ្ពោះទៅកាន់ប្រទេសបារាំង និងតំបន់ហ្វ្រង់ ។

ក្នុងរយៈឆ្នាំ១៩៥៧-៦៥ ភាគចំណែកនៃក្រុមប្រទេសនីមួយៗទាំងពីរក្រុមនេះ ប្រទេសអាស៊ី និងតំបន់ហ្វ្រង់ ហាក់ដូចជាប្រឹងបន្តិច ព្រោះកម្ពុជាក៏បាននាំចេញទៅប្រទេសដទៃដែរដែលអាចមានបីប្រទេស៖ សហរដ្ឋ និងកាណាដា ប្រទេសសង្គមនិយមអឺរ៉ុប និងប្រទេសអឺរ៉ុបឯទៀត ។

និន្នាការទីមួយ គឺមានការថយចុះនៃសារៈសំខាន់របស់សហរដ្ឋ។ រហូតដល់ឆ្នាំ ១៩៥៩ សហរដ្ឋជាអតិថិជនទី ១ របស់កម្ពុជា ដែលស្រូបយក ៣០% នៃការនាំចេញកម្ពុជា ហើយក្រោយមកបានទិញផលិតផលកម្ពុជាតែ ៥% ។

តួនាទីនេះបានត្រូវជំនួយដោយប្រទេសសង្គមនិយម ដែលបានទិញផលិតផលកម្ពុជាចេះតែកើនឡើង និងជាប្រចាំ ។ មុនឆ្នាំ ១៩៦០ ប្រទេសទាំងនោះគ្មានទិញអ្វីសោះពីកម្ពុជា ក្រោយមកបានបង្កើតការនាំចេញពីកម្ពុជាពី ១០% ទៅ ២០% នៃការនាំចេញកម្ពុជា ។ នេះជាលទ្ធផលនៃឆន្ទៈបំបែកច្រកទីផ្សាររបស់អាជ្ញាធរកម្ពុជាដោយធ្វើការចរចាជាមួយប្រទេសទាំងនោះនូវកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការទូទាត់។

## ៦.៦.រចនាសម្ព័ន្ធនៃផលិតផល

ក្រោយពីពិនិត្យលើប្រទេសមួយចំនួន ដែលបាននាំទំនិញជូនកម្ពុជា យើងត្រូវប្រមូលព័ត៌មាន ពីប្រភព ឯកសារគយ និងរដ្ឋាករ ដែលមិនសូវមានចំនួនគ្រប់គ្រាន់។ ប្រភពឯកសារគយ មិនអាចឱ្យធ្វើការបែងចែកតាម ផលិតផលបានច្បាស់លាស់ទេ។ ការបែងចែករវាងការនាំចូលពីបារាំង និងពីប្រទេសដទៃក៏មានមិនច្បាស់លាស់ ដែរ លើបញ្ហាអត្រាប្តូរប្រាក់។ គេអាចរកឃើញសន្ទុទស្សន៍ជា "រៀល-រូបិយប័ណ្ណ" នូវការនាំចូលពីបារាំង។

រចនាសម្ព័ន្ធ នៃការនាំចូលតាមក្រុមផលិតផល ក្នុងរយៈពេលឆ្នាំ ១៩៥៧-១៩៦៦ អាចសង្ខេបក្នុងតួលេខ ជាមធ្យមភាគរយសរុបនៃការនាំចូល៖

| | |
|---|---|
| លោហៈធាតុ | ២៨ |
| វាយនភ័ណ្ឌ | ១៥ |
| ផលិតផលស្បៀង | ១១ |
| រថយន្ត និងម៉ូតូ កង់ | ៨ |
| ផលិតផល រ៉ែ | ៣, |
| ផ្សេងៗ | ២៧ |

រចនាសម្ព័ន្ធនេះ មានស្ថេរភាពក្នុងដំណាក់កាលឆ្នាំនោះ។ ប្រេងឥន្ធនៈ រថយន្ត ស៊ីម៉ង់ មានស្ថេរភាព។ ដែក ដែកថែប សំណង់ ម៉ាស៊ីន អគ្គិសនី សម្ភារដឹកជញ្ជូន មានការកើនឡើងជាងផលិតផលស្បៀង។លក្ខណៈទីមួយ គឺកម្ពុជានាំចូលទំនិញប្រើប្រាស់។ ទំនិញសម្ភារមានចំនួន ១/៣ នៃទំនិញនាំចូល។ លក្ខណៈទីពីរ គឺរចនាសម្ព័ន្ធមានការកែប្រែ រហូតដល់ការកើនឡើងនៃសម្ភារៈ។ ការនាំចូលសម្ភារកើនឡើងនៅឆ្នាំ ១៩៥៧ ចំនួន ២២% ដល់ឆ្នាំ ១៩៦៦ ឡើងដល់ ៣៨%។

## ៦.៧.រចនាសម្ព័ន្ធតាមប្រទេស

ជញ្ជីងទូទាត់ ព្រមទាំងបញ្ជីពន្ធគយ បានប្រមូលផ្តុំជាក្រុមនៃប្រទេសដើម ដោយបែងចែកជាក្រុមប្រទេសផ្សេងៗគ្នា៖ តំបន់ដុល្លារ តំបន់ស្ទែរលីញ តំបន់អឺរ៉ុប តំបន់កិច្ចព្រមព្រៀងទូទាត់ និងតំបន់ផ្សេងៗទៀត។ ការបែងចែកនេះ មិនគ្រប់គ្រាន់ទេ។ គេអាចប្រមូលផ្តុំបាន នូវតំបន់ស្ទែរលីញ រួមមាន ហុងកុង និងអង់គ្លេស ដែលស្ថិតនៅក្នុងការបែងចែកជាតំបន់ភូមិសាស្ត្រទៅវិញ។

ការនាំចូលជាភាគរយសរុបមធ្យម តាមភូមិសាស្ត្រ៖

| | |
|---|---|
| អាស៊ី, | ៣៥ |
| អឺរ៉ុប, | ៤៣ |
| ក្នុងនោះប្រទេសមូលធន, | ១៧ |
| បារាំង, | ១៩ |

| | |
|---|---|
| ប្រទេសសង្គមនិយម, | ៧ |
| សហរដ្ឋអាមេរិច និងកាណាដា, | ២០ |

ការនាំចូលពីអាហ្វ្រិក និងអាមេរិកឡាទីន មិនសូវមានសកម្មភាពទេ។

នាទសវត្សឆ្នាំ ១៩៦០ គឺអឺរ៉ុប ជាអ្នកផ្គត់ផ្គង់ដល់កម្ពុជា ជាមធ្យម ៤៣% នៃការនាំចូលរបស់កម្ពុជា ចេញមកពីប្រទេសអឺរ៉ុប។ ការនាំចូលសំខាន់ពីប្រទេសបារាំង ចន្លោះឆ្នាំ ១៩៥៧-៦៥ បារាំងផ្គត់ផ្គង់ ១/៤ នៃការនាំចូលរបស់កម្ពុជា។ ប្រទេសមូលធនអឺរ៉ុប មានការនាំចូលតិចជាងបារាំង នោះជាការនាំចូលពី អង់គ្លេស និង អាឡឺម៉ង់។

ភាគចំណែកនៃប្រទេសសង្គមនិយមអឺរ៉ុប ឆេកូស្លូវ៉ាគី សូវៀត ប៉ូឡូញ ប៊ុលហ្គារី ជាមធ្យមនាំចូលកម្ពុជា មិនលើសពី ៧% ទេ។ ចាប់ពីឆ្នាំ ១៩៦០ មក ក្រោយពីការចុះកិច្ចសន្យាពាណិជ្ជកម្មមក សកម្មភាពនាំចូលមក កម្ពុជាពីប្រទេសទាំងនោះបានកើនឡើង។ សរុបមក គឺស្មើនឹង ១០% នៃការនាំចូលសរុបមកកម្ពុជា។

សហរដ្ឋអាមេរិក និងកាណាដា ក៏ជាប្រទេសផ្គត់ផ្គង់សំខាន់ដល់កម្ពុជាដែរ។ សម្ភារផ្គត់ផ្គង់ ជាអំណោយរបស់សហរដ្ឋអាមេរិកដល់កម្ពុជា បានត្រូវធ្វើបញ្ចីក្នុងគណនេយ្យ "នាំចូល" នៃជញ្ជីងទូទាត់ ជាឧទាហរណ៍ នៅឆ្នាំ ១៩៥៩ ៣៩% នៃការនាំចូលកម្ពុជា សម្រេចឡើងដោយជំនួយសហរដ្ឋអាមេរិក។ យោងទៅតាមគម្រោងបន្តជំនួយ របស់សហរដ្ឋអាមេរិក យោងទៅតាមជញ្ជីងទូទាត់ នាឆ្នាំ ១៩៦៤ ជាឧទាហរណ៍ គឺមានចំនួន ២៦ លានដុល្លារអាមេរិក។ ប៉ុន្តែតួលេខពន្ធគយមានចំនួនទាបជាង។

ប្រទេសផ្គត់ផ្គង់ដល់កម្ពុជានៅអាស៊ី គឺ ជប៉ុន ហុងកុង ប្រទេសចិន សិង្ហបូរី ។ ឥណ្ឌា និងវៀតណាម ឈរ នៅជួរទីពីរ។ សរុបមក ប្រទេសទាំងនោះបានរួមវិភាគទានជាមធ្យម ៣៥% នៃការនាំចូលរបស់កម្ពុជា។

## ៦.៧.ជញ្ជីងទូទាត់

នៅឆ្នាំ២០១០ ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាមានស្ថានភាពល្អប្រសើរឡើងវិញ។

សមតុល្យគណនីបង្វែរផ្លូវការ និងគណនីហិរញ្ញវត្ថុមានអតិរេក១.៤៣៤.៣លានដុល្លាអាមេរិក ខណៈដែល សមតុល្យគណនីវរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) មានឱនភាព១.២៣៧.៩ លានដុល្លាអាមេរិក។ ជាលទ្ធផលសមតុល្យរួម មានអតិរេកចំនួន១៤៣.២លានដុល្លាអាមេរិកបន្ទាប់ពីមានឱនភាពចំនួន៤.៧លានដុល្លាអាមេរិក នៅឆ្នាំ២០០៩។ ក្នុងឆ្នាំ ២០១០នេះផលធៀបនៃសមតុល្យរួមនិងផលិតផលក្នុងស្រុកសរុបមានកម្រិត១.៣% ។ ៣.១ គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ)។

សមតុល្យគណនីចរន្តមានឱនភាពប្រមាណ១.២៣៧,៩លានដុល្លាអាមេរិកបានកើនឡើង ៣៥ លានដុល្លាអាមេរិក (២,៩%)ធៀបនឹងឆ្នាំ២០០៩ ។ ឱនភាពគណនីចរន្ត(មិនរាប់

បញ្ចូលបង្វែរផ្លូវការ)មានចំណែកប្រមាណ ១១,២% នៃ ផលិតផលក្នុងស្រុកសរុប។ ការកើនឡើងឱនភាពគណនីទំនិញប្រមាណ ៣,៩% និង ឱនភាពគណនីប្រាក់ចំណូលសុទ្ធ ប្រមាណ ២,៨%ជាមូលហេតុចម្បងដែលបណ្តាលឱ្យមានការកើនឡើងឱនភាពគណនីចរន្ត។ ឱនភាពគណនីចរន្តនេះត្រូវ បានផាត់ទាត់ដោយកំណើនអតិរេកនៃគណនីបង្វែរឯកជនសុទ្ធ៥% និងគណនីសេវាសុទ្ធ ៤,៤ % ។




ក្រាភិច៦.១.ជញ្ជីងពាណិជ្ជកម្ម១៩៩៨-២០១០

ក្នុងឆ្នាំ២០១០នេះដោយសារវិបត្តិសេដ្ឋកិច្ចសាកលបានធូរស្រាលបន្តិចនាំឱ្យ មានសញ្ញាវិជ្ជមានចំពោះតម្រូវការ នៅក្រៅប្រទេស។ ស្ថានភាននេះ បានផ្តល់លទ្ធភាពដល់ប្រទេសកម្ពុជាក្នុងការនាំចេញផលិតផលក្នុងស្រុកប្រមាណ ៤.៣៦៣,៤ លានដុល្លាអាមេរិកកើនឡើង ៤៨៤ លានដុល្លាអាមេរិក (១២,៥%)ធៀបនឹងឆ្នាំ២០០៩ ។ ការនាំចេញ សម្លៀកបំពាក់ និង វាយនភ័ណ្ឌ បានកើនឡើងចាប់ពីត្រីមាសទី១រហូតដល់ដំណាច់ឆ្នាំ២០១០ បន្ទាប់មកតម្រូវការប្រើ-ប្រាស់នៅក្រៅប្រទេសបានរួមតូចកាលពីឆ្នាំ២០០៩។ ក្នុងអំឡុងឆ្នាំ២០១០នេះការនាំចេញសម្លៀកបំពាក់ និង វាយនភ័ណ្ឌ មានចំនួនប្រមាណ ២.៨៩៨,៣ លានដុល្លាអាមេរិក បានកើនឡើង ៣៨៣,៥ លានដុល្លាអាមេរិក (១៥,២%) បន្ទាប់ពីបាន ធ្លាក់ចុះ១៦%នៅឆ្នាំ២០០៩។ ស្របពេលនេះដែរ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតកើនឡើង ៧,៤%។ ការកើនឡើងថ្លៃនៃផលិតផលស្រូវត្រីនិងកៅស៊ូ បានរួមចំណែកក្នុងការកើនឡើងតម្លៃការនាំចេញផលិតផលក្នុងស្រុកនេះ។

ក្នុងឆ្នាំ២០១០ការនាំចេញទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកមានតម្លៃប្រមាណ ៦.១០៩,៥ លានដុល្លាអាមេរិក (៩,៨%) ធៀបនឹងឆ្នាំ២០០៩ ។ ការកើនឡើងនៃការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ១៤,៧% និងការនាំចូលសម្ភារៈសាង

សង់២,៣% ជាសាមាសជាតុសំខាន់នាំឱ្យមានកំណើននៃការនាចូលទំនិញសម្រាប់ ប្រើប្រាស់ក្នុងស្រុកនេះ។

ក្នុងអំឡុងពេលដូចគ្នានេះអតិរេកនៃគណនីសេវាសុទ្ធបានកើនឡើងពី ៦០៦,៤ លានដុល្លាអាមេរិក នៅឆ្នាំ២០០៩ ដល់ ៦៣៣លានដុល្លាអាមេរិក ។ ការកើនឡើងអតិរេកនេះដោយសារប្រាក់ចំណូលពីផ្នែកសេវាបានកើនឡើង ២៧,៧ លានដុល្លាអាមេរិក (១,៧%) ខណៈដែលចំណាយទូទាត់សេវាទៅឱ្យអនិវាសជន បានកើនឡើង ១,១ លានដុល្លាអាមេរិក (០,១%) ។ ចំណូលពីសេវាទេសចរណ៍មានចំនួនប្រមាណ ១.២៤៩, ៨ លានដុល្លាអាមេរិក បានកើនឡើង ៥៥ ធៀបនឹង ឆ្នាំកន្លងទៅ ។ ចំនួនភ្ញៀវទេសចរបរទេសដែលបានចូលមកទស្សនាប្រទេសកម្ពុជាត្រូវបាន)៉ាន់ស្មានមានចំនួន ២,៤លាន នាក់កើនឡើងប្រមាណ១០% ទោះបីកំណើនសេដ្ឋកិច្ចពិភពលោករងសម្ពាធពីវិបត្តិសាកលនៅឆ្នាំ២០០៩ និង ដំណើរងើបឡើងសន្សឹមៗនៅឆ្នាំ២០១០នេះក៏ដោយ។ តាមរយៈការវាយតម្លៃថ្មីៗ បានបង្ហាញថា ប្រទេសជាច្រើននៅទ្វីបអាស៊ី មិនទទួលរងផលវិបាកធ្ងន់ធ្ងរពីវិបត្តិសាកលទេដែលនាំឱ្យអ្នកទេសចរនៅតំបន់អាស៊ីដែលបានចូលរួមប្រទេសកម្ពុជានៅតែបន្តកើនឡើងក្នុងនោះភ្ញៀវវៀតណាមមានសាមាត្រខ្ពស់ជាងគេ (១៣,៥%) បន្ទាប់គឺកូរ៉េ (១២,១%) និងជប៉ុន (៧,៧ %) ។ ក្នុងអំឡុងពេលនេះដែរគណនីប្រាក់ចំណូលសុទ្ធមានឱនភាពប្រមាណ៤៨១,២ លានដុល្លាអាមេរិក បានកើនឡើង ១៣លានដុល្លាអាមេរិក(២,៨%)ធៀបនឹងឆ្នាំ២០០៩។ការកើនឡើងការផ្ទេរប្រាក់ចំណូលពីការវិនិយោគនៅកម្ពុជា បាន កើនឡើង៣%បណ្តាលឱ្យមានកំណើនឱនភាពប្រាក់ចំណូលសុទ្ធនេះ។ គណនីបង្វែរឯកជនសុទ្ធមាន អតិរេកប្រមាណ ៣០៧,៨លានដុល្លាអាមេរិក បានកើនឡើង(៥%)។ ការកើនឡើងនេះដោយសារកំណើនប្រាក់បង្វែររបស់ជនជាតិកម្ពុជា ធ្វើការងារនៅក្រៅប្រទេស។

ជញ្ជីងទូទាត់ ជាគណនេយ្យ ដែលបញ្ជាក់ពីសំណុំប្រតិបត្តិការប្រព្រឹត្តទៅ រវាងប្រទេសមួយ ជាមួយពិភពលោក។ ចំពោះប្រតិបត្តិការនាំចេញ នាំចូល ជាអង្គធាតុដែលហៅថាជញ្ជីងពាណិជ្ជកម្ម បន្ថែមនូវប្រតិបត្តិការផ្ទេរ ឬប្រតិបត្តិការទុន។ នៅចុងបញ្ចប់គណនេយ្យ មានតុល្យការដោយការបន្ថែម ឬបន្ថយទ្រព្យធនជាមាស រូបិយប័ណ្ណជាអំណោយ ឬជាបំណុល។ ត្រូវពិនិត្យនូវចំណុចនីមួយៗ នៃចំណុចទាំងបីនេះ។

## ៦.៧.១.ជញ្ជីងពាណិជ្ជកម្ម

**ក.**អ្វីដែលបញ្ជាក់លក្ខណៈជញ្ជីងពាណិជ្ជកម្មកម្ពុជានេះ គឺអ្វីដែលកើតឡើងជានិច្ចកាលនូវឱនភាព ដែល មានការលំបាក ក្នុងការបញ្ជាក់ឱ្យបានត្រឹមត្រូវ ចេញពីប្រភពពីរដែលមិនស៊ីចង្វាក់គ្នា៖ ស្ថិតិគយរដ្ឋាករ និង ស្ថិតិមន្ទីរជាតិប្តូរប្រាក់។ ប៉ុន្តែ គេអាចនិយាយថា ឱនភាពជាទូទៅសំខាន់ណាស់ ព្រោះឱនភាពតាមឆ្នាំនីមួយៗ តំណាងពី ២០% ទៅ ៦០% នៃការនាំចេញ។ ឆ្នាំ ១៩៦៥ ជាឆ្នាំលើកលែង៖ យោលទៅតាមតួលេខរបស់មន្ទីរជាតិប្តូរប្រាក់ វាជាលក្ខណៈនៃឱនភាពល្អមួយ យោលទៅតាមតួលេខគយ និងរដ្ឋាករ។

ខ.សារៈសំខាន់ នៅត្រង់ការពិនិត្យការវិវដ្តនៃជញ្ជីងពាណិជ្ជកម្មតាមក្រុមប្រទេស។ ជាទូទៅគេកត់ សម្គាល់ឃើញថា ការផ្លាស់ប្តូរទំនិញរបស់កម្ពុជា គឺមានឱនភាពជាមួយគ្រប់តំបន់នៃក្រុមប្រទេស។

ភាពខុសគ្នា រវាងជញ្ជីងជាមួយបារាំង នៃជញ្ជីងជាមួយប្រទេសដទៃ "ជញ្ជីងពាណិជ្ជកម្ម" គឺមានទំហំធំ។ នៅឆ្នាំ ១៩៦២ កម្ពុជានាំចេញលើសជាងការនាំចូលពីតំបន់ហ្វ្រង់ ធ្វើឱ្យជញ្ជីងពាណិជ្ជកម្មចំណេញបាន ១៣ លានដុល្លារ excédent ។ តាមទិដ្ឋភាពនៃការប្តូរប្រាក់នាឆ្នាំ ១៩៥៨-១៩៥៩ វាមានការលើកទឹកចិត្តឱ្យមានការនាំចេញជាងការនាំចូល។ មុននេះមួយឆ្នាំនៅពេលមិនទាន់មាន disparite de changes ការនាំចេញរបស់ កម្ពុជាទៅបារាំង តែងតែមានឱនភាព។

គឺការធ្វើពាណិជ្ជកម្មជាមួយនឹងតំបន់ភូមិសាស្ត្រ ដែលឱនភាពនៃការប្តូរពាណិជ្ជកម្មមានទំហំធំ។ ឱន ភាពជាមួយចំនួនតំបន់ផ្សេងៗ មានភាពខុសៗគ្នា ពីមួយឆ្នាំទៅមួយឆ្នាំ។ ឱនភាពជាមួយអាស៊ីនាឆ្នាំ ១៩៦៣ ឡើងដល់ ១៩ លានដុល្លារ ដែលទុកឱ្យឆ្នាំ ១៩៦៤ មានការចំណេញ excedent ដល់ ៦ លានដុល្លារ ហើយឱន ភាពជាមួយ អាមេរិកដល់ទៅ ២០ លានដុល្លារ នាឆ្នាំ ១៩៦២ បានត្រូវលុបចោល នាឆ្នាំ ១៩៦៣ ហើយឱនភាពបានកើនឡើង ដល់ជាង ២៤ លាន នៅឆ្នាំ ១៩៦៥ ។

ឱនភាពដ៏ធំ គឺមានចំពោះសហរដ្ឋអាមេរិក និងប្រទេសអាស៊ី។ ចំពោះ អាមេរិក ឱនភាពគឺអនុវត្តន៍ទៅលើសារៈសំខាន់នៃជំនួយសហរដ្ឋ ដែលត្រូវចុះបញ្ជីគណនេយ្យជាការនាំចូល ហើយក្នុងពេលជាមួយគ្នានោះ ការនាំចេញកៅស៊ូទៅកាន់សហរដ្ឋ មានការថយចុះដែរ ដោយបញ្ហាសេដ្ឋកិច្ចជាងបញ្ហានយោបាយ ហើយនៅពេលចុងក្រោយនាឆ្នាំ ១៩៦៥ ឱនភាពចំពោះសហរដ្ឋ កើនឡើងដល់កម្រិតខ្ពស់។

ឱនភាពនៃប្រទេសអាស៊ី មានសារៈសំខាន់ដែរ។ កម្ពុជានាំចូលយ៉ាងច្រើន នូវផលិតផលឧស្សាហកម្ម ពីជប៉ុន ហុងកុង ចិន និង ឥណ្ឌា ហើយប្រទេសទាំងនោះមិនសូវទិញកៅស៊ូពីកម្ពុជាទេ។ ការនាំចូលពីប្រទេសអាស៊ីទាំងនោះ កាន់តែមានបរិមាណច្រើនថែមទៀត។ ក្រោយមកជប៉ុន និងសឹង្ហបុរី បានក្លាយជាអ្នកទិញកៅស៊ូកម្ពុជា ហើយការនាំចេញអង្ករទៅឥណ្ឌា ហ្វីលីពីន ហុងកុង ជប៉ុន បានកើនឡើងទៀត។ ហេតុដូចនេះហើយ បានជានៅឆ្នាំ ១៩៦៤-១៩៦៥ ឱនភាពជាប្រពៃណីពីមុនបានក្លាយទៅជាចំណេញ ដែលលើសពី ១៣ លានដុល្លារ នៅឆ្នាំ ១៩៦៥ ។

## ៦.៧.២.ប៉ុស្តិ៍នៃជញ្ជីងទូទាត់ដទៃទៀត

បើពិនិត្យប៉ុស្តិ៍នៃជញ្ជាំងដទៃ គឺការទូទាត់ធម្មតានិងប្រតិបត្តិការទុនដោយឡែកនោះគេឃើញនូវភាពទន់ខ្សោយដ៏ធំមិនដាច់ខាត នៃជុំទំងន់ជញ្ជីងពាណិជ្ជកម្ម។

**ក.**ការទូទាត់ធម្មតា ដែលមានសារៈសំខាន់នោះ គឺចំណូល និងចំណាយរបស់រដ្ឋាភិបាលនៅបរទេស ការផ្ទេរបៀវត្សរ៍ ការផ្ទេរ dividence និងការប្រាក់ការចំណាយលើការដឹកជញ្ជូននិងការចំណាយទេសចរណ៍។

ចំណូល និងចំណាយរដ្ឋាភិបាលនៅបរទេស មានតុល្យភាពបង្គួរ ដោយសារបេសសកម្មការទូតកម្ពុជា នៅបរទេស មានតម្លៃប្រហែលនឹងរូបិយប័ណ្ណកម្ពុជា នៅបរទេសថ្លៃស្មើនឹងការចំណាយរូបិយប័ណ្ណនៃបេសសកម្មការទូតបរទេសនៅកម្ពុជាដែរ។

ការផ្ទេរបៀវត្សរ៍ពីបរទេស ពិសេសពីបារាំង ប្រព្រឹត្តទៅធម្មតា និងប្រហែល ២ លានដុល្លារអាមេរិក ក្នុង មួយឆ្នាំ។ ការផ្ទេរពីកម្ពុជា នូវបៀវត្សរ៍ទៅបរទេស មិនប្រព្រឹត្តទៅច្រើននេះកម្ពុជា មិនបានធ្វើនិវត្តន៍លុយដែល ចំណេញពីបរទេសទេ។

ការផ្ទេរការប្រាក់នឹង dividence របស់កម្ពុជាទៅបរទេស និងការផ្ទេរពីបរទេសមកកម្ពុជាវិញ ក៏មាន សារៈសំខាន់ដែរ។

ផលទុន ជាមូលធនផ្ទេរប្រចាំឆ្នាំ នៅក្រៅកម្ពុជា ជាមធ្យមគឺ ៤ លានដុល្លារ។ នោះជាប្រាក់ចំណេញនៃ ក្រុមហ៊ុនបារាំង ពិសេស ការផ្ទេរប្រាក់ចំណេញរបស់ក្រុមហ៊ុនចម្ការកៅស៊ូទៅកាន់ប្រទេសបារាំង។ ផ្ទុយមកវិញ ការផ្ទេរលុយពីបារាំងមកកម្ពុជា មានចំនួនតិចជាង ៣ លានដុល្លារ។ នោះជាការប្រាក់ និង dividences នៃ ធនាគារជាតិកម្ពុជានៅបរទេស ជាប្រាក់ចំណេញពីចលនៈវត្ថុ។ គេហជនកម្ពុជា មានថ្លៃចលនៈវត្ថុជាច្រើនដែល មិនផ្ទេរមកកម្ពុជាឡើយ។

ក្នុងនាមនៃការដឹកជញ្ជូន គ្រឿងបន្លាស់ និងការធានារ៉ាប់រង កម្ពុជាមានការខាតបង់ប្រាក់ប្រចាំឆ្នាំដល់ ទៅជាង ២ លានដុល្លារ។ នោះជាការដឹកជញ្ជូនតាមអាកាស ដែលពេលនោះក្រុមហ៊ុនអាកាសចរបារាំង ទាញយក ពាក់កណ្តាលនៃចំនួនប្រាក់នោះ។

សារៈសំខាន់នៃវិស័យទេសចរណ៍ គឺទទួលបានលើសពីការកំណត់ទៅទៀត។ចំណូលរូបិយប័ណ្ណទេសចរណ៍បានតិចជាង ១ លានដុល្លារ។ ប៉ុន្តែជញ្ជីងនេះ បានទទួលទម្ងន់ប្រឆាំងមកវិញ ពីការចេញដំណើររបស់ទេសចរណ៍កម្ពុជានៅបរទេស មានការចំណាយប្រហែល ឬលើសចំនួនប្រាក់ចំណូលទៅវិញ។ គឺនៅឆ្នាំ ១៩៦៥ ទេ ដែលគេសង្កេតឃើញនូវការបញ្ឈប់ការចេញដំណើរនៃទេសចរណ៍។ ឥទ្ធិពលអាក្រក់ នៃវិស័យទេសចរណ៍ លើជញ្ជីងទូទាត់ មិនសូវមានសារៈសំខាន់ទេ។

រាល់គ្រប់ប្រតិបត្តិការ ជញ្ជីងទូទាត់បានធ្វើបញ្ជីការ ដោយមានឱនភាពជាប្រចាំ ប្រហែល ៥ លានដុល្លារ។

### ៦.៧.៣.ប្រតិបត្តិការទុន មិនអាចកែលម្អឱ្យភាពបានទេ

Solde មិនកើនលើសច្រើនពី ១ លានដុល្លារទេ។ មិនសូវមាននូវការវិនិយោគ និងការដកវិនិយោគ បរទេសពីកម្ពុជាទេ។ ចលនាទុនឆ្ពោះទៅ ស្វីស បារាំង "មានសន្តិសុខល្អ" ទៅហុងកុង និងសឹង្ហបុរី ការប្រាក់ខ្ពស់ ឬទៅប្រទេសចិន "ធ្វើឱ្យគ្រួសារចិននៅទីនោះ" មិនបានប្រព្រឹត្ត

ទៅតាមផ្លូវច្បាប់ទេ ហើយមិនបានចុះបញ្ជីជញ្ជីង ទូទាត់ដែរ។ ការហូរចេញនូវទុននេះ មិនសូវសំខាន់ប៉ុន្មានទេ។

កម្ពុជា មិនដែលរៀបចំបែបបទខ្ចីបុលពីបរទេសក្នុងដំណាក់កាលនោះ លើកលែងតែករណីមួយ ដែល ប្រទេសឆេកូស្លូវ៉ាគី និងយ៉ូហ្គូស្លាវី បានយល់ព្រមឱ្យខ្ចីទុនលក់រោងចក្រ និងម៉ាស៊ីនវារីអគ្គិសនី និងប្រាក់ឱ្យខ្ចីពី បារាំង និងអាល្លឺម៉ង់ ដោយឡែកទៀតគឺ ជញ្ជីងពាណិជ្ជកម្ម នាឆ្នាំ ១៩៦៥ ដែលមានប្រតិបត្តិការប្រាក់លើសចំនួន ១៣ លានដុល្លារ។

ឱនភាពនៃជញ្ជីងពាណិជ្ជកម្ម មិនអាចកែលម្អ និងបន្ថយបានដោយសារប្រតិបត្តិការទុន និងការទូទាត់ផ្សេងៗបានទេ។ ត្រូវមើលឃើញថា តើឱនភាពបានត្រូវបំពេញដោយវិធីណា។

# មេរៀនទី ៧
# នយោបាយសេដ្ឋកិច្ច

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- សេដ្ឋកិច្ចអភិវឌ្ឍន៍នៅកម្ពុជា
- ផែនការូបនីយកម្ម
- ការអនុវត្តន៍ផែនការ
- គោលនយោបាយសេដ្ឋកិច្ច
- ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅកម្ពុជា
- គម្រូនៃនយោបាយសេដ្ឋកិច្ច

## ៧.១.ផែនការូបនីយកម្ម

ផែនការូបនីយកម្ម ជាគោលការណ៍ណែនាំនៃនយោបាយសេដ្ឋកិច្ច។ លោក M.GOURDON បាន សរសេរថាៈ " រវាងផែនការូបនីយកម្មតាមគំរូសូវៀត និងសេដ្ឋកិច្ចសេរីនិយម ប្រហាក់ប្រហែលនឹងផែនការ សេដ្ឋកិច្ចហ្វីលីពីន និងកម្ពុជា ជ្រើសរើសកណ្តាលតាមគំរូវេណ្ណា ជាផែនការូបនីយកម្មទន់ភ្លន់ " ។

រូបភាពផែនការូបនីយកម្មវត្ថុធំធេងណាស់ តែមធ្យោបាយដើម្បីសម្រេចផែនការនោះនៅមិនទាន់ច្បាស់លាស់។គោលដៅ គឺមិនត្រឹមតែលើកកម្ពស់ជីវភាពប្រជារាស្ត្រនោះទេ តែចង់ធ្វើសង្គមឱ្យមាន " យុត្តិធម៌ " ឡើង។ ដើម្បីសម្រេចបានផែនការទន់ភ្លន់ត្រូវយកចិត្តទុកដាក់ដល់ការប្រកួតប្រជែងដោយសេរីរបស់អ្នកវិនិយោគនានានិងសហគ្រិនឯកជនរួមទាំងអ្នកចូលភាគហ៊ុននិងការចូលរួមប្រយោលរបស់អំណាចសាធារណៈ។ ផែនការជា គោលការណ៍នៃគម្រោងវិនិយោគសាធារណៈ និងក្របខ័ណ្ឌសម្រាប់នយោបាយសេដ្ឋកិច្ច។

ផែនការពីរ បានកើតឡើងនៅកម្ពុជាជាបន្តបន្ទាប់ៈ

- ផែនការពីរឆ្នាំទីមួយ " វិច្ឆិកា ១៩៥៦-មិថុនា ១៩៥៨ "
- ផែនការប្រាំឆ្នាំទីមួយ " មករា ១៩៦០- ធ្នូ ១៩៦៤ "

ផែនការទាំងនោះ ជាព្រលឹងនៃជីវភាព ឬជានយោបាយសេដ្ឋកិច្ចកម្ពុជា។

## ៧.២.ការរៀបចំផែនការ

ផែនការពីរឆ្នាំ លើកទីមួយ ត្រូវបានរៀបជាបន្ទាន់ បន្ទាប់ពីទទួលបានឯករាជ្យ មិនមែនជាផែនការជាក់ ស្តែងនៃការប្រព្រឹត្តទៅនោះទេ ព្រោះដោយខ្វះស្ថិតិ ខ្វះអ្នកមានគុណសម្បត្តិសម្រាប់ធ្វើផែនការ ខ្វះសច្ចៈភាពនៃ ប្រភពហិរញ្ញវត្ថុ ដែលភាគច្រើនជាជំនួយបរទេស។ ផែនការនោះ គឺជាកន្សោមនៃគម្រោងការ។ គម្រោងនានា ជា គោលការណ៍រៀបចំរឿង និងដំណើរការ

ទាក់ទងនឹងលក្ខណៈសេដ្ឋកិច្ចមួយមានសារៈសំខាន់ លើចំណុចបែបបទបន្ទុក និងផលិតផលនានា ដែលជាលទ្ធផលប្រចាំនៃការដាក់ឱ្យអនុវត្តន៍គម្រោង ក្លាយជាមានស្ថេរភាព។ ការ វិនិយោគមួយចំនួនជាអនុភាព ដូចជា ការចំណាយលើការសាងសង់សម្ភារសង្គម ដូចជា សាលារៀន មន្ទីរពេទ្យ ឬ ការលើករចនាសម្ព័ន្ធផ្លូវ ស្ពាន កំពង់ផែ។ល។ បង្កើតបានជាបន្ទុកប្រចាំឆ្នាំថ្មី១ទៀត ការវិនិយោគលើផលិតកម្ម ផ្ទុយមកវិញ គឺបង្កើតបាននូវចំណូល។ ភាគរយនៃបន្ទុកនានា និងផលិតផលធៀបនឹងកម្រិតទុនវិនិយោគ បានត្រូវស្គាល់ច្បាស់ និងបានត្រូវសន្និដ្ឋានត្រឹមត្រូវ។ មានលទ្ធភាពក្នុងការបញ្ជាក់បាននូវការបែងចែកគម្រោងនានា ដែលធានាបាននូវលំនឹងនៃបន្ទុក និងគម្រោង។ បច្ចេកទេសរៀបចំគម្រោងផែនការប្រចាំឆ្នាំលើកទី ១ មានការអំពាវនាវច្រើនទៅលើ coefficient ក្លាសស៊ីនៃទុន។ គេគណនាជាបឋមនូវគោលដៅដែលត្រូវទៅដល់នាចុងបញ្ចប់នៃការកំណត់៖ ផលទុនដែលនឹងអាចឱ្យមានការកើនឡើង នូវផលិតផលរបស់មនុស្សម្នាក់ៗ ចំនួន ៣% ក្នុង១ឆ្នាំ ។ ផលដករវាងផលទុនដុលនៅក្នុងតំណាក់កាលនិងផលទុនដុលនាដើមតំណាក់កាលបញ្ជាក់អំពីកំណើនផលិតផលដែលសម្រេចជាសម្មិទ្ធិផលបាន ក្នុងរយៈពេលនៃដំណើរការផែនការ។ ការអនុវត្តនូវ coefficient ទុនផ្តល់ឱ្យនូវចំនួនប្រាក់ដែលចាំបាច់វិនិយោគដើម្បីឱ្យបង្កើតបាននូវផលិតកម្មនោះ។ ការរៀបចំបែងចែកនូវចំនួនសរុបនៃវិនិយោគនានា ដែលបានគណនារួចមកហើយ រវាងសាខា និងគម្រោងនានា ក៏ដូចជាការចែករវាងផ្នែកឯកជន និងផ្នែកសាធារណៈ បានប្រព្រឹត្តទៅ យោងទៅតាមលក្ខខ័ណមិនច្បាស់លាស់ តែហាក់ដូចជាបានប្រើប្រាស់នូវ coefficient នៃទុនតាមសាខានានា។

បច្ចេកទេសប្រើប្រាស់សម្រាប់តាក់តែងនូវផែនការប្រាំឆ្នាំទីពីរដែលគ្របដណ្តប់រវាងឆ្នាំ ១៩៦៨-១៩៧២ គឺដូចគ្នាទៅនឹងផែនការទីមួយ។ ក្រុមប្រឹក្សាជាន់ខ្ពស់ផែនការ ធ្វើការជ្រើសរើសនូវអត្រាកំណើននោះ។ ការបែងចែកការវិនិយោគតាមផ្នែក និងតាមភ្នាក់ងារសេដ្ឋកិច្ច គឺទៅតាមការសន្និដ្ឋាន ឈរលើមូលដ្ឋាននៃការបែងចែកតាមកំណត់សម្គាល់នាឆ្នាំកន្លងមក ហើយកែតម្រូវក្នុងន័យដែលគិតថាសមរម្យ។ បច្ចេកទេសចុងក្រោយនេះមាន ការប្រុងប្រយត្ន័ ហើយទំនើបជាងមុន ក៏នៅបានប្រើផងដែរ ដល់គម្រោងនានាស្តីអំពីពាណិជ្ជកម្មក្រៅប្រទេស និងហិរញ្ញវត្ថុសម្រាប់វិនិយោគ។

ក្រុមប្រឹក្សាជាន់ខ្ពស់ផែនការ ធ្វើការកោះប្រជុំ ក្រោមអធិបតីភាពនៃនាយករដ្ឋមន្ត្រី តំណាងសភាជាតិ រដ្ឋមន្ត្រីសំខាន់ៗ ចូលរួមអនុវត្តន៍កម្មវិធីខាងសម្ភារ ទេសាភិបាលធនាគារជាតិនៃកម្ពុជា នាយករដ្ឋមន្ទីរជាតិប្តូរ ប្រាក់ ប្រធានសភាពាណិជ្ជកម្ម បានត្រូវបង្កើតនៅតាំងពីមុនពេលចាប់ផ្តើមធ្វើផែនការពីរឆ្នាំម្ល៉េះ។

តួនាទីរបស់ក្រុមប្រឹក្សានេះ មាននាទីធំ តែដោយខ្វះចំណេះ បច្ចេកទេសនៃសមាជិកក្នុងការរៀបរៀង ផែនការ សមាជិកនោះចូលរួមមានចំនួនតិច។ តំណាងខាងផ្នែកឯកជន គ្មានវត្តមានទេ។ ឯកសារបង្កើតផែនការ រៀបចំដោយមន្ត្រី ឬអ្នកឯកទេសមួយចំនួនដែលគ្មានអំណាចធ្វើកាសម្រេចចិត្ត។ ហេតុដូចនេះហើយ ឯកសារនោះ មិនសូវបានយកទៅអនុវត្តន៍ច្រើន

ទេ។ មុនសិក្សាបញ្ហាសម្រេចជាសម្មិទ្ធិផលនៃផែនការ ត្រូវនិយាយពីខ្លឹមសាររបស់ផែនការនោះសិន។

## ៧.៣.ខ្លឹមសារផែនការ

ផែនការដែលបញ្ជាក់ជាលាយលក្ខអក្សរ គឺជាតំណាងនៃឆន្ទៈ ក្នុងការអភិវឌ្ឍរបស់រដ្ឋាភិបាលកម្ពុជា ហើយ ខ្លឹមសារនៃផែនការនោះ បញ្ជាក់ពីការជ្រើសរើស និងស្នូលនៃនយោបាយសេដ្ឋកិច្ច។

### ៧.៣.១.ផែនការពីរឆ្នាំទីមួយ

ផែនការឆ្នាំទីមួយមានលក្ខណៈបីយ៉ាង៖

**ទីមួយ** ការវិនិយោគរបស់ផ្នែកឯកជន មិនបានចុះបញ្ជីនៃផែនការនោះទេ ដោយខ្វះព័ត៌មាន ។ ផែនការជា ឯកសារចំណាយសាធារណៈ ជាប្រភេទថវិកាពីរឆ្នាំ។

**ទីពីរ** មានការយកចិត្តទុកដាក់ដល់ហេដ្ឋារចនាសម្ពន្ធ័ និងផលិតកម្ម។ គិតជាភាគរយ គឺ៖

| | |
|---|---|
| ហេដ្ឋារចនាសម្ពន្ធ័ | ៣៨ |
| ផលិតកម្ម | ៣៨ |
| សម្ភារសង្គម | ១៩ |
| ទូទៅ | ១៥ |

ផ្នែកហេដ្ឋារចនាសម្ពន្ធ័មានចែងជា ៧ ជំពូក " កសាងរោងចក្រអគ្គិសនី ប្រពន្ធ័ទឹក ផ្លូវនិងស្ពាន ផ្លូវដែក ផ្លូវទឹក បញ្ជូនសារ ផ្នែកអាកាសចរ " ដែលមានការត្រៀមលក្ខណៈជាការងារធំៗ។ ផ្នែកខាងសម្ភារសង្គម មានការបែងចែកស្មើគ្នា រវាងអប់រំសិក្សា សុខាភិបាល និងនគរូបនីយកម្ម។ ការវិភាគវិនិយោគ ត្រៀមនូវប្រភេទផលិតកម្មឃើញថាផ្នែកកសិកម្មមានភាពពិស្តារ ត្រូវចំណាយវិនិយោគច្រើនជាងគេ " la part du lion ″ ហើយ លេចឡើងនូវសារៈសំខាន់ជាងគេ។

**ទីបី** ចំពោះការផ្គត់ផ្គង់ជាហិរញ្ញវត្ថុនោះ បានគិតទៅដល់ជំនួយក្រៅប្រទេស ដូចតារាងខាងក្រោម៖

| | |
|---|---|
| ជំនួយអាមេរិច | ៥៧ |
| ជំនួយចិន | ២៣ |
| ជំនួយបារាំង | ១៧ |
| ថវិកាខ្មែរ | ២ |
| ផ្សេងៗ | ១ |

### ៧.៣.២.ផែនការប្រាំឆ្នាំទី១

ផែនការប្រាំឆ្នាំ បានជានាបង្កើននូវផលទុនដុលរបស់ជាតិ ក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ ៣% ក៏បានត្រៀមបរិមាណទុនវិនិយោគជាច្រើន។ ការវិនិយោគ ត្រូវបានបែងចែកដូចតទៅ គិតជាភាគរយៈ

| | |
|---|---|
| វិនិយោគឯកជន | ៣៣ |
| វិនិយោគសាធារណៈ | ៦៧ |

ចំពោះផ្នែកឯកជនអ្នកធ្វើផែនការបានត្រៀមការសន្និដ្ឋាន ដោយដកយកតួលេខដែលមានពីឆ្នាំចាស់។ ផែនការនោះ មិនទាមទាររកនូវការប្រើឥទ្ធិពលទៅលើអត្តចរិត នៃសហគ្រាសឯកជននោះទេហើយក៏មិនបានត្រៀមនូវឧបករណ៍ណាមួយផ្ទាល់ សម្រាប់ជានានូវការសម្រេចជាសមិទ្ធិផលនៃការសន្និដ្ឋានទេ។ ឯកសារត្រៀមលក្ខណៈផែនការ ដោយរៀបចំបែងចែកផ្នែកវិនិយោគឯកជន តាមផ្នែកៗ ប៉ុន្តែកម្រិតទុនសរុប នៃការវិនិយោគ ឯកជន ដែលបានត្រៀមហើយនោះ គឺបានបន្ថយជាច្រើនទុកឱ្យការវិនិយោគសាធារណៈទៅវិញ។ ការបង្វិល បែបនេះ គឺការបូជាសម្រាប់ការវិនិយោគតែខាងផ្នែកសាធារណៈ។

តួលេខនេះជាការបង្វិលទុនពីផ្នែកវិនិយោគឯកជនមកផ្នែកសាធារណៈ "គិតជាភាគរយនៃការវិនិយោគសរុប" ៖

| | |
|---|---|
| ផលិតកម្ម | ៤០ |
| ហេដ្ឋារចនាសម្ព័ន្ធ | ២៨ |
| សម្ភារសង្គម | ២៤.៥ |
| សម្ភាររដ្ឋបាល | ៧.៥ |

ជាគោលការណ៍ គឺសង្កត់ធ្ងន់លើការអភិវឌ្ឍផលិតកម្ម។ គេត្រៀមអភិវឌ្ឍន៍ និងពង្រីកនូវដំណាំចម្ការ ធំៗ ក្នុងបំណងបន្ថយ ឬបំបាត់ការនាំចូលសំខាន់ៗ ដូចជា កប្បាស បារៃក្រហៅ ស្ករស កាហ្វេ ប្រេងឆា ។ល។ ហើយបង្កើនទំហំនៃការនាំចេញនូវកសិផល។ ប្រព័ន្ធធារាសាស្ត្រតូចៗ បានរៀបចំកសាងឡើង ដើម្បីពង្រីកផ្ទៃដីដាំដុះ។ ការខិតខំមួយខាងវិស័យឧស្សាហកម្មដូចជាចង់កសាងឡស្លដែក ការវិនិយោគលើរ៉ែ និងឧស្សាហកម្ម និងទីចាត់ការនៃសហគ្រាសរដ្ឋ បានរួមគ្នាធ្វើការចំណាយដល់ទៅ ៣០% បម្រើផលិតកម្ម។ ការវិនិយោគមួយទៀត ដែលបម្រើមិនផ្ទាល់ដល់ផលិតកម្ម រួមមានការបម្រើសេវាសុខភាពពលរដ្ឋ ដូចជាចំណាយសាងសង់វិទ្យាស្ថានប៉ាស្ទ័រ ប្រព័ន្ធ ទឹក ទេសចរណ៍ សាលាកសិកម្ម ។ល។ហេដ្ឋារចនាសម្ព័ន្ធ គាំទ្រចាំបាច់ដល់ការពង្រីកផលិតកម្ម និងពាណិជ្ជកម្ម ក៏ទាមទារនូវការចំណាយសំខាន់ ដែលបានត្រៀមក្នុងផែនការដែរ។ លើវិស័យសង្គម ការខិតខំតម្រង់ទិស បំពេញដល់ការពង្រឹង ដែលចេញជាលទ្ធផល ភ្លឺច្បាស់រួចមកហើយនៃវិស័យអប់រំជាតិ ហើយខិតខំបំពេញតម្រូវការអនាម័យ និងសង្គមថ្នាក់ស្រុក និងឃុំ។ ការចំណាយលើសម្ភាររដ្ឋបាល គឺបម្រើសេវាមិនមែនផលិតកម្ម តែមានលក្ខណៈនយោបាយ និង រដ្ឋបាលទូទៅ។

ស្ដីអំពីហិរញ្ញវត្ថុ គេបានត្រៀមឱ្យមានការរួមវិភាគទានរបស់បរទេស ដែលមានការថយចុះ " គិតជាភាគរយ ប្រៀបនឹងផែនការ ២ ឆ្នាំ " នូវភាគរយវិនិយោគសាធារណៈ

| | |
|---|---|
| ថវិកា ខ្មែរ, | ៦៩ |
| ជំនួយ បរទេស, | ៣១ |

ឯកសារៀបចំបាននិយាយ និងធ្វើអត្ថាធិប្បាយ អំពីការខិតខំខាងពន្ធអាករ ដែលបានចូលរួមដើម្បីជាតិ ដែលអាចសម្រេចបាន។ គេបានគិតថា បញ្ហាហិរញ្ញវត្ថុនៃផែនការ គឺបានដោះស្រាយ។ ការបង្វិលការចំណាយតាមមុខងារ គឺធ្វើទៅបាន។ គេអាចមើលឃើញនូវការវិនិយោគដែលបានត្រៀមរួមហើយ នៅក្រោមមុំនៃផ្នែក គឺគិតជាភាគរយៈ

| | |
|---|---|
| សំណង់ | ៦៣ |
| សម្ភារ | ២២ |
| បុគ្គលិក | ១៣ |
| ផ្សេងៗ | ២ |

ការចំណាយតែមួយ ដែលជាក្បាលម៉ាស៊ីនសេដ្ឋកិច្ច គឺការបង្កើនផលិតកម្មរយៈពេលខ្លីនោះគឺការទិញ សម្ភារ។ ក្នុងចំនួនភាគរយនៃការវិនិយោគនោះ ២០% សម្រាប់ពង្រីកនូវហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារសង្គម។ ឯការវិនិយោគខាងសម្ភារផលិតកម្ម មានចំនួនតែ ៨% នៃការវិនិយោគសាធារណៈសរុប។ ប៉ុន្តែការពិត ការវិនិយោគផ្ទាល់ដល់ផលិតកម្ម គឺមានកំណើនខ្ពស់នៅក្នុងផ្នែកឯកជន ដែលមានចំនួន ១/៣ នៃការវិនិយោគទាំង អស់។ រចនាសម្ព័ន្ធវិនិយោគបែបនេះ ដែលចង់បង្កើនផលិតកម្មនៃផលទុនកំណត់ មិនអាចអនុវត្តន៍បានឡើយ។មធ្យោបាយមិនសមស្របនឹងគោលដៅ។ ផែនការប្រាំឆ្នាំទីមួយ បង្ហាញនូវការខុសឆ្គងខ្លះៗក្នុងផ្នែកបច្ចេកទេស។

## ៧.៣.៣.ផែនការប្រាំឆ្នាំលើកទីពីរ

ផែនការប្រាំឆ្នាំលើកទីពីរ "តាមការបកស្រាយនៃការសិក្សាខែកញ្ញា ១៩៦៧ " ជាអត្ថបទមានតថភាព ជាងផែនការប្រាំឆ្នាំលើកទីមួយ។ គេឃើញជាបឋមថា អ្នកតាក់តែងផែនការបានគូសវាសនូវ "ស្បេម៉ាសេដ្ឋកិច្ច "ដែលជាគម្រោងវិនិយោគ រៀបចំឡើងឈរលើមូលដ្ឋាននៃអត្រាកំណើន ៥% និង coefficient marginal នៃទុន ៣.៦ ។ ការបង្វិលទុនវិនិយោគទៅតាមផ្នែកគឺបានកំណត់ដូចតទៅ ″ គិតជាភាគរយសរុប" ៖

| | |
|---|---|
| អាគារ | ៣៧ |
| ការងារសាធារណៈ | ១៨ |
| សម្ភារ និងឧបករណ៍ | ៣៥ |
| អថេរ នៃស្តុក | ១០ |

ដើម្បីបានតួលេខនេះ គេកាត់បន្ថយនូវភាគចំណែកនៃអគារ និងការងារសាធារណៈ ដែលមានក្នុងបញ្ជីកន្លងមក ឱ្យទៅភាគចំណែកនៃសម្ភារ និងឧបករណ៍។

ហិរញ្ញវត្ថុបម្រើការវិនិយោគ ក៏នៅបានកំណត់។ សម្រាប់ឆ្នាំ ១៩៧២ ជាឆ្នាំចុងក្រោយនៃផែនការ គេនឹងបាន "ភាគរយសរុប" ៖

| | |
|---|---|
| **រដ្ឋបាល** | ៣៨ |
| ក្នុងនោះ: | |
| - ការរួមវិភាគទានថវិកា | ៣ |
| - ការរួមវិភាគទានដោយធន្ទ: | ២៩ |
| **ជំនួយបរទេស** | ៦ |
| **សហគ្រាស** | ៤៦ |
| ក្នុងនោះ: | |
| - សហគ្រាសរដ្ឋ | ៧ |
| - ក្រុមហ៊ុនចម្រុះនៃឯកជន | ១៤ |
| - សហគ្រាសបុគ្គលិក | ២៥ |
| គេហជន | ១៥ |
| វិជ្ជាស្ថានហិរញ្ញវត្ថុនានា | ១ |

ការបង្វិលតាមផ្នែកលើកជាសំណុំពរ គឺគិតជាភាគរយដូចតទៅ៖

| | |
|---|---|
| ផលិតកម្ម | ៦៥ |
| ហេដ្ឋារចនាសម្ព័ន្ធ | ២០ |
| សម្ភារសង្គម | ១០ |
| សម្ភាររដ្ឋបាល | ៥ |

ការខិតខំ គឺបម្រើផលិតកម្ម ហើយនៅក្នុងក្របខ័ណ្ឌនៃការខិតខំនោះ ភាគចំណែកមានស្មើគ្នា រវាងកសិកម្ម និងឧស្សាហកម្ម។ ផ្នែកនីមួយៗត្រូវស្រូបយក ១/៤ នៃការវិនិយោគសរុប។

ភាគរយបានបែងចែកទៅនឹងការវិនិយោគសរុបមិនធូន់តែទៅលើការវិនិយោគសាធារណៈទេ។ ចំណុចនេះហើយដែលជាការតក់សម្គាល់ រវាងផែនការនេះទៅនឹងផែនការមុនៗ។ តួលេខនេះ មិនអាចប្រៀបជាមួយការបង្វិល តាមផ្នែកដែលបានកំណត់ក្នុងផែនការនានាទេ។ ការបង្វិលទុនវិនិយោគ គឺជាមធ្យោបាយកែរម្រូវតែ ប៉ុណ្ណោះ។ ដូចនេះហើយ បានជាតួលេខខ្លះមិនស្របនឹង "ស្បេម៉ាសេដ្ឋកិច្ច" ទេ។ ការបង្វិលតាមផ្នែក ធ្វើឱ្យគេមិនឃើញលេចឡើង នូវការវិនិយោគលើផ្នែកអាគារ សម្រេចឡើងដោយគេហជន។

អនុវត្តន៍បានល្អ ឬមិនល្អ ផែនការគឺជាឯកសារដែលត្រូវប្រឈមមុខនឹងសមិទ្ធិផលដែលសម្រេចបាន។ ដូចនេះ យើងពិនិត្យមើលលើបញ្ហាអនុវត្តន៍ផែនការវិញ ដែលអាចរក្សាបាន នូវការប្រុងប្រយ័ត្នរបស់យើង។

## ៧.៤.ការអនុវត្តនៃផែនការ

ផែនការល្អយ៉ាងណាក៏ដោយ នៅលើពិភពលោកនេះ បើមិនដាក់ឱ្យអនុវត្តន៍ទេ គឺគ្មានផលប្រយោជន៍ឡើយ។ សំណួរចោទថា តើផែនការដែលបង្កើតបាននូវកម្ពុជាបានត្រូវយកទៅប្រតិបត្តិការយ៉ាងណា ឬអាចនិយាយអំពីតួនាទីនៃផែនការនៅប្រទេសខ្មែរ។

ជាតថភាពសេដ្ឋកិច្ចកម្ពុជាមានការអភិវឌ្ឍឯករាជ្យពីផែនការទាំងឡាយ។ នៅកម្ពុជាផែនការមិនដើរតួជាមូលដ្ឋាន ដូចប្រទេសកុម្មុយនីស្តទេ។ យើងក៏ឃើញផងដែរនូវឥទ្ធិពលនៃផែនការ លើសេចក្តីសម្រេចចិត្ត នៃអ្នកវិនិយោគ ហើយអំណាចសាធារណៈគឺនូវកម្ពុជាមិនសូវមានសារៈសំខាន់ជាងប្រទេសបារាំងទេ។ យើងនឹងឃើញថាភស្តុតាងនៃព្រឹត្តិកាណ៍ដែលថាថវិកាប្រចាំឆ្នាំ គឺបានរៀបចំឡើងដោយមិនយោងទៅរកផែនការហើយជាការខ្វះចន្លោះមួយ ដែលគ្មានរបាយការណ៍ពីកិច្ចប្រតិបត្តិការនៃផែនការ។ ក្រសួងផែនការ តាមរយៈទីចាត់ការផែនការ គឺជាអ្នកទទួលបន្ទុករៀបចំផែនការ និងតាមដានការអនុវត្តផែនការ។

ចំណែកផ្នែកឯកជន ផែនការមិនមានឥទ្ធិពលបន្តិចណាទេ។ ព្រោះផែនការមិនបានគិតដល់ផ្នែកឯកជននោះទេ។ ប៉ុន្តែដោយហេតុថា ផ្នែកឯកជនមានសារៈសំខាន់ជាផ្នែកផលិតកម្មនៅកម្ពុជា គឺគ្មានការណែនាំពីនយោបាយសេដ្ឋកិច្ចឡើយ។ វាមានតែវិធានការណ៍រូបិយវត្ថុ ពន្ធអាករ និងបទបញ្ញាខ្លះៗទេ ដែលរដ្ឋយកចិត្តទុកដាក់។ វិធានការនយោបាយសេដ្ឋកិច្ច មិនបាននិយាយនៅក្នុងផែនការទេ។ នោះហើយជាចំណុចខ្វះខាតមួយទៀតនៃផែនការ ដែលពន្យល់បានពីការខ្វះប្រសិទ្ធភាព។

ផែនការមិនអាចគោរពទៅតាមរចនាសម្ព័ន្ធវិនិយោគសាធារណៈ ដែលបានធ្វើសេចក្តីព្រាងឡើយ។ ការបែងចែកការចំណាយ គឺចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធ ជាងទៅលើការចំណាយសម្រាប់ផលិតកម្ម។ ចំណុចទាំងពីរនេះ ត្រូវចំណាយវិនិយោគស្មើគ្នា តែការពិតផ្នែកហេដ្ឋារចនាសម្ព័ន្ធចំណាយកើនលើស ៤ដងនៃផ្នែកចំណាយវិនិយោគផលិតកម្ម។

វាមានការលំបាក ក្នុងការឆ្លើយចំពោះផែនការប្រាំឆ្នាំលើកទីមួយ ព្រោះខ្វះរបាយការណ៍ស្តីពីការអនុវត្តផ្លូវការ។ របាយការណ៍បែបនេះ ពិបាករៀបចំណាស់ដោយសារជាគោលការណ៍នៅពេលចាប់ផ្តើមផែនការប្រាំឆ្នាំទី១ គឺបានសម្រេចឱ្យក្រសួងផែនការជាអ្នកគ្រប់គ្រង នូវការរួមវិភាគទានផ្នែកហិរញ្ញវត្ថុ នៃការវិនិយោគសារធារណៈទោះបីការរួមវិភាគទាននោះ មកពីប្រភពថវិការ ឬបរទេសក៏ដោយ។ តែការអនុវត្តឃើញថា ឥណទាន សម្ភារ ដែលមានសារៈសំខាន់ឃើញចុះបញ្ជីនៅក្នុងថវិលាជាតិ ហើយជំនួយបរទេសជាច្រើន ដូចជាការខ្ចីបុល មិនបានបញ្ចូលទៅក្នុងក្រសួងផែនការទេ ហើយការរួមចំណែករបស់ប្រជារាស្ត្រ តាមពលកម្មសុធន្ទៈ ដែលជាការប្រព្រឹត្តទៅបាន ត្រូវទូទាត់លើឥណទានសម្ភារ ជាពិសេសចាប់ពីការអនុវត្តផែនការមកម្លេះ។

យើងឃើញថាបរិមាណសរុបនៃការវិនិយោគសាធារណៈ មានកម្រិតទាបជាង ៣៥% នៃការត្រៀមទុក។ រចនាសម្ព័ន្ធវិនិយោគ សម្រេចបានប្រហាក់ប្រហែលនឹងរចនាសម្ព័ន្ធដែលបានត្រៀមទុក ហើយគំនូរមានការបាត់លំនឹងចំពោះផ្នែកសម្ភារសង្គម ដែលទទួលការវិនិយោគនៃផលិតកម្ម។ កិច្ចប្រតិបត្តិការក្រៅផែនការ លេចឡើងនៅឆ្នាំទី២ នៃផែនការដែលចាប់ពីឆ្នាំ ១៩៦២ ពាក់កណ្តាលនៃការវិនិយោគសាធារៈបានត្រូវចំណាយ ហើយភាគចំណែកនៃការចំណាយនេះ កើនឡើងទៀតនៅឆ្នាំ ១៩៦៣ និង ១៩៦៤ ដូចជាពហុកីឡាដ្ឋានជាតិអូឡាំពិក ផ្លូវដែកភ្នំពេញ-ក្រុងព្រះសីហនុ ទំនប់វារីអគ្គិសនី។ល។ មួយភាគនៃគម្រោងផែនការក៏បានបោះបង់ចោលដែរ។

ចំពោះអំណាចសាធារណៈ ផែនការមិនមែនជាច្បាប់នៃសកម្មភាពសេដ្ឋកិច្ចទេ។ និយាយរួមសេដ្ឋកិច្ចកម្ពុជាពេលនោះ មិនមានសេដ្ឋកិច្ចផែនការទេ។ ភស្តុតាង គឺនៅឆ្នាំ ១៩៦៥-១៩៦៦ និង ១៩៦៧ គ្មានផែនការណាដែលមានអតិភាពទេ។

គេអាចគិតថា ដោយខ្វះស្ថិតិ ខ្វះបុគ្គលិក ដោយមិនទាន់និយាយដល់ចំណុចខ្វះខាតទ្រឹស្តីសេដ្ឋកិច្ចផងនោះធ្វើឱ្យការបែងចែកផែនការឱ្យ "ល្អ" ខ្វះលទ្ធភាព។ វាមានភាពល្អដែរ ដែលថាផែនការគឺជាត្រីវិស័យចង្អុលទិស។ ហើយការអនុវត្តផែនការ ក៏មិនមែនជាឧបសគ្គដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាដែរ។ គោលដៅជាមូលដ្ឋាននៃផែនការប្រាំឆ្នាំលើកទីមួយ ដែនកំណត់បង្កើនទុនម្នាក់ៗ ៣% ឆ្នាំ គឺដូចជាបានដល់គោលដៅ។

ផែនការរដ្ឋនេះក៏កំណត់ផងដែលថានៅនយោបាយសេដ្ឋកិច្ចដល់ពួកវិនិយោគឯកជនធ្វើឱ្យគេយល់ពីអាជ្ញាធរសាធារណៈដែលអាចចូលរួមជាមួយភ្នាក់ងាររដ្ឋ។ នោះគឺជាមធ្យោបាយឈានដល់គោលដៅ។ ការរៀបចំផែនការហើយនិងការទទួលយកផែនការដោយភ្នាក់ងារសេដ្ឋកិច្ច គឺជាសន្លឹកបៀសេដ្ឋកិច្ចជាកត្តាអភិ-វឌ្ឍ។

ការរៀបចំផែនការក៏ត្រូវគិតទីមួយដល់សារៈសំខាន់នៃផ្នែកឯកជន ព្រោះជាផ្នែកផលិតកម្មដ៏ធំហើយធ្វើនិយមន័យនៃនយោបាយឱ្យផ្នែកនេះធ្វើតាម។ មួយទៀត គឺការបញ្ចូលនូវការត្រៀមផលិតកម្ម និងការវិនិយោគដោយមានការគិតគូរដល់ការត្រៀមហិរញ្ញវត្ថុ ដែលថាគ្មានហិរញ្ញវត្ថុផែនការគឺគ្មានន័យ។ មួយទៀតគឺគោលដៅត្រូវកំណត់មធ្យោបាយដែលអាចសម្រេចបានកំណត់បាន។ ចំពោះការអនុវត្តផែនការទាមទានូវអង្គការ ដែលមានអំណាចគ្រប់គ្រាន់ ធ្វើសេចក្តីសម្រេចចិត្តជាសមិទ្ធិផលគោលដៅបាន។ តួនាទីផែនការពីរឆ្នាំ និងប្រាំឆ្នាំ ពីឆ្នាំ ១៩៥៥ ដល់ ១៩៦៧ មានជាបន្ទាប់បន្សំ។ រដ្ឋាភិបាលបន្តបន្ទាប់បានខិតខំខ្លាំង ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ពង្រីកសម្ភារសង្គម និងលើកទឹកចិត្ត និងតម្រង់ទិសដល់កំណើនផលិតកម្ម។

## ៧.៥..យន្តការសេដ្ឋកិច្ច

ក្នុងស្ថានភាពប្រទេសកំពុងមានសង្គ្រាមផង សន្តិភាពការគ្រប់គ្រងសេដ្ឋកិច្ច ទាមទានូវសមត្ថភាពមួយដែលការគៀបសង្កត់កើតមានពីភ្នាក់ងារសេដ្ឋកិច្ចឯកជននិងការបែងចែកអំណាចជាមួយកម្លាំងនយោបាយផ្សេងៗ ផងធ្វើឱ្យគេសន្និដ្ឋាន បាននូវការបាត់បង់នៅការត្រួត

ពិនិត្យ នៃភាគខ្លះនៃសេដ្ឋកិច្ច ដែលជាលទ្ធផល នៃការបាត់លំនឹងមួយ។ ដើម្បីយល់ពីប្រវត្តិនៃយន្តការសេដ្ឋកិច្ចកម្ពុជា គឺត្រូវស្គាល់ពី ឡូស៊ីក នៃជញ្ជីងនយោបាយ រវាងរដ្ឋ និងពួកតស៊ូដទៃទៀត ។

ក្នុងការវិភាគនយោបាយ គេស្ថិតនៅក្រៅពីតថភាពនៃសេដ្ឋកិច្ច ។ តើសេដ្ឋកិច្ចកម្ពុជានៅពេលនោះ ប្រព្រឹត្តទៅបែបណា? ភ្ជាប់គ្នាតាមរបៀបណា? មានលក្ខណៈឯករាជ ឬភ្ជាប់ទៅជាមួយនឹងសភាពការណ៍នយោបាយ ?

ដើម្បីឆ្លើយតបយើងពិនិត្យនូវដំណើរការបីយ៉ាង ៖

១.យើងពីនិត្យលើស្ថានភាពសរុបទូទៅនៃសេដ្ឋកិច្ចដែលយើងមើលឃើញជាផ្លូវការ និងមិនផ្លូវការចាប់ពីពេលនោះ មានការបែងចែកភ្នាក់ងារនយោបាយ ដែលបម្រើឱ្យអង្គភាពប្រតិបត្តិការនយោបាយសេដ្ឋកិច្ច ។

២.ការផ្តល់អត្ថន័យបែបនេះអាចកត់សម្គាល់បាននៅគំរូបត់បែននៃផ្នែកនានា ។

៣.អាចឱ្យយើងវិភាគបាននៅដំណាក់កាលទីបីនៅថាមពលសរុបនៃប្រព័ន្ធ ។

### ៧.៥.១.ការប្រព្រឹត្តិទៅ ធម្មតា នៃប្រព័ន្ធ

#### ក.ការពិនិត្យដោយសុទិដ្ឋិនិយមនៃនយោបាយ ៖ ការបែងចែកជា៤ចំណែក

គេចាប់ផ្តើមយកចិត្តទុកដាក់ថានៅក្រោមការប្រជែងគ្នានៃអាណត្តិនយោបាយ អាចបញ្ជាក់នៅស្ថានភាពនយោបាយប្លែកៗ ។ គ្រប់តែភាគីទំនាស់សុទ្ធតែមានចំណុចដូចគ្នាខាងផ្នែកសេដ្ឋកិច្ចរួមនយោបាយ ។ ភាគីនីមួយៗ ពេលនោះមានភាគចំណែកទឹកដីអាកាសសង្គម និងប្រភពរៀងខ្លួន ៖

- **ភាគីគណបក្សប្រជាជន ៖** មានប្រការគ្រប់គ្រងរដ្ឋបាល ទឹកដីនិងរាជធានី ។ រដ្ឋាភិបាលភ្នំពេញទទួលបន្ទុកគ្រប់គ្រងទឹក ៤/៥ នៃប្រជាជន មានប្រភពទុនចំនួលគយ រដ្ឋករ ជាង ២០ លានដុល្លារអាមេរិក ថវិការដ្ឋមួយផ្នែកនៃរដ្ឋកម្ពុជា នឹងតម្លៃនៃផលិតកម្មសហគ្រាសរដ្ឋ និងជំនួយសហភាពសូវៀត សរុបមានប្រភពប្រហែល ២០០ លានដុល្លារអាមេរិក ។

- **ភាគីហ៊្វុនស៊ីនប៉ិច** ៖ បន្តរកប្រពៃណីព្រះរាជាណាចក្រប៉ុន្តែខ្វះផ្នែកកស្តុភា លើទឹកដីផ្ទាល់រក្សាបាននូវទម្ងន់និមិត្តរូប ដែលគាំទ្រពីប្រភពប្រពៃណីហើយជាបណ្តោះអាសន្នមានមូលដ្ឋាន រឹងមាំនៅភ្នំពេញ។ ភាគីនេះក៏ទទួលបានចំណូលផលទុនពីសេដ្ឋកិច្ចក្រៅផ្លូវការតាមរយៈការលក់របស់ជំនួយ អន្តរជាតិ អហរដ្ឋអាមេរិក និង ថៃ និងមានផលទុនសកម្មផ្ញើរទៅបរទេសសរុបប្រហែល ១០០-១៥០ លានដុល្លារអាមេរិក ។

- **ភាគីរណសិរ្សរំដោះជាតិប្រជាបលរដ្ឋខ្មែរ៖** គ្មានមូលដ្ឋាននៅកម្ពុជាទេ តាំងពីការធ្លាក់ចុះនៃសាធារណៈ ប៉ុន្តែគាំទ្រដោយមេដឹកនាំចាស់ៗ និង ខ្មែរនៅបរទេស ។ ភាគីនេះក៏បានទទួលមួយភាគនៃសេដ្ឋកិច្ចក្រៅប្រទេសមានចំនួនប្រហែល ២០ លានដុល្លារអាមេរិក ។

- **ភាគីខ្មែរក្រហម** ៖ គាំទ្រដោយសារខ្លួនមានមូលដ្ឋាននៅជាប់ព្រំដែនថៃ។ ប្រភពចំណូលគឺ ត្បូង រ៉ែ ប៉ៃលិន ជាង ១០០ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗ មួយចំណែកទៀតបាន

មកពីការកាប់ឈើ លក់ក្រៅផ្លូវការបាន ១៨ លានដុល្លារអាមេរិក និងជំនួយពីប្រទេសចិនប្រជាមានិតសរុបទាំងអស់គឺរវាង ៣០០-៥០០ លានដុល្លារអាមេរិក ក្នុងនោះមានមាសរាប់សិបតោន នៅប្រទេសដែលជាប្រាក់ចំណូល ។

ក្នុងនៃការបែងចែកនេះ គឺមានភាពស្វយ័ត និងសេដ្ឋកិច្ច នៅក្នុងឡូស៊ីក ដែលធ្លាប់បានបែងចែកនៅភាគខាងត្បូង និងខាងជើងវៀតណាម។ លើកលែងតំបន់ខ្មែរក្រហមចេញនៅពេលដែលអភិក្រម នៃសន្តិភាពប្រព្រឹត្តទៅស្រមច្បាប់ ប្រទេសកម្ពុជា និងវិលត្រឡប់ទៅជាសុំណុំមួយទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ចប្រាក់រៀលចរាចរណ៍នៅគ្រប់ទីកន្លែងនៃទឹកដី រួមទាំងតំបន់ខ្មែរក្រហមកាន់កាប់បណ្តោះអាសន្នផងនាពេលសព្វថ្ងៃ ។

## ខ.អតិថិជនកណ្តាលជួយស្តារទំនាក់ទំនង

ការបែងចែកជាសហគមន៍សេដ្ឋកិច្ចមុននេះ ដោយភាគីផ្សេងៗ បានប្រែប្រួលមកជាការប្រជែងខាងសេដ្ឋកិច្ចរួមគ្នា តាមរយៈការប្រឈមមុខខ្លះៗនៃការប្រយុទ្ធខាងយោធា ។

ពាក្យថា ភាគី នយោបាយជាគំរូរបស់លោកខាងលិច តែជាពាក្យធម្មតានៃតថភាពក្នុងស្រុក ។ ភាគីទាំងនោះមិនមានឥទ្ធិពលជាក្លង់នយោបាយចាត់តាំងជាងគណបក្សនយោបាយនោះទេ ។ ប៉ុន្តែទាំងអ្នកទំនាក់ទំនងរបស់មនុស្សនានា ផ្សារភ្ជាប់ឡើងវិញតាមរយៈសមាជិកគ្រួសារ តាមតំបន់ តាមសាសនា តាមការអប់រំ តាមផលប្រយោជន៍សេដ្ឋកិច្ច រំលាយនៅគំនុំ ។ល។ ទំនាក់ទំនងឡើងវិញនេះជា សាមគីជាប់ទាក់ទងនិងមុខងារពីរៈ

១- ចងភ្ជាប់និងសម្ព័ន្ធភាពនិងគ្នានៅតួឯកនយោបាយ ប្រធានភាគីខ្មែរបានចងមិត្តគ្នានិង បង្គោលបង្អែកសេដ្ឋកិច្ច គឺថៅកែរកស៊ីជាជនជាតិចិន បានចូលរួមបង្រួមបង្រួមប្រធាននៃភាគីខ្មែរនានា ។

២- ការបម្រើជាស្ពានចម្លងរវាងមេប្លង់សំខាន់ៗ ។ សាមគីធម៌ទាំងនោះជានាដល់ការធ្វើជាស្ពានចម្លង រវាងផលប្រយោជន៍នៃនយោបាយ និងសេដ្ឋកិច្ចដែលនាំទៅដល់ការបង្រួបបង្រួមគ្នា ។ សាមគីភាពបានប្រែក្លាយការប្រជែងគ្នាទៅជាការបង្រួបបង្រួម អតិថិជនដែលក្លាយទៅជាយន្តការនៃការផ្លាសប្តូរ ជាសម្ព័ន្ធផលប្រយោជន៍ជាទ្រព្យសម្បត្តិទាមរយៈអំណោយជង្វាយ ។ល។

ទំនាក់ទំនងបែបនេះ បានចំណេញដល់ចំណុលផលទុន និងសន្តិសុខនៃការអនុវត្តនយោបាយបង្រួបបង្រួមទាំងរដ្ឋបាល ទឹកដីតែមួយបញ្ចូលគ្នាបាន ទាំងសេដ្ឋកិច្ច ទាំងហិរញ្ញវត្ថុ។ គេអាចនិយាយបានថា ចាប់ផ្តើមពីភាគីនយោបាយ ក្លាយជា ក្រុមហ៊ុនពាណិជ្ជកម្ម រួមគ្នាដែលលោកឧត្តមសេនីយ៍ ថៃ ឆាវ៉ាលីត បានជួយក្នុងចំណែកទាំងនោះ ។

## គ.ប្រព័ន្ធចិនជាជំហរទំនាក់ទំនង់បន្ថែម និង បង្រួបបង្រួម

ការបញ្ជាក់ទៅលើការវាភាគនានា ឃើញថាយន្តការក្នុស្រុក និង ទំនាក់ទំនងក្លង់ ព្រមទាំងគោលការណ៍ស្ពានចម្លងគ្នាទៅវិញទៅមកប៉ុន្តែ ក៏មិនមែនការប្រព្រឹត្តរួមគ្នា ឬ ស្វយ័តសេដ្ឋ

កិច្ចនោះទេ ។ ទោះបីជាការបត់បែន រវាងការគ្រប់គ្រងនយោបាយ និង ការគ្រប់គ្រងសេដ្ឋកិច្ចបានកសាងឡើងវិញ ដោយសានៃមធ្យមបាយនសអតិថិជន ។ ប្រព័ន្ធនេះនៅតែជាផ្នែកៗដាច់ពីគ្នាដដែល ...។ ដើម្បីឈានទៅដល់ដំណាក់កាលគឺធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមួយប្រព្រឹត្តទៅបានប្រព័ន្ធនេះទាមទានូវអត្តភាពកម្រិតទំនាក់ទំនងបន្ថែម ជាមួយនោះគឺអត្តភាពនៃប្រព័ន្ធសង្គមប្រព័ន្ធសេដ្ឋកិច្ចឯកភាពមួយ ។ នូវក្នុងស្ថានភាពនោះ គេតែងជួបប្រទះនៅក្នុងសង្គម នេះនូវសុំណុំបេះដូងក្តួងនានា នូវសមាសភាពដែលមានភាពទន់ភ្លន់ បង្កើតជាប្រព័ន្ធរួមគ្នា ក្នុងផលប្រយោជន៍នៃផ្នែកសេដ្ឋកិច្ច ។

សមាសភាពនោះមាននូវក្នុងកម្ពុជា ហើយពួកនោះគឺពួកចិន និងចិនកាត់ខ្មែរ គឺមិនត្រឹមតែអាចបង្កើតស្រទបសង្គមបន្ត និងស្វយ័តបាននោះទេ សារព័ត៌មាន សាលារៀន សមាគមន៍ប៉ុន្តែនៅគ្រប់កាលៈទេសៈពួកគេមានវត្តមាននៅគ្រប់ការជួបប្រសព្វនៃផលប្រយោជន៍ប្រព័ន្ធសេដ្ឋកិច្ចដែលពួកគេជានាដល់ចារចរណ៍ ផលិតផល និង ជំនោចលនាទំនិញត្រួតពិនិត្យការប្រមូលផលកសិផលឥណទាន និង ពិសេសពាណិជ្ជកម្ម ។ បន្ថែមពីលើនោះការផ្សារភ្ជាប់ពួកកូនកាត់ ខ្មែរ-ចិន ដែលគេបានចាក់ឫសជ្រៅ នៅក្នុងសង្គមខ្មែរតែម្តង ។ ទន្ទឹមនោះប្រព័ន្ធបម្រើបានជាអ្នកកណ្តាលដល់ភាគីនានា តាមរយៈអន្តរាគមន៍លើចម្លងការទាំងអស់ និង ផ្តល់ជំនឿនៃ ការផ្គត់ផ្គង់ខាងហិរញ្ញវត្ថុ និងជានាបានដល់ការភ្ជាប់គ្នាជាមួយពិភពខាងក្រៅ ។ អ្នកនយោបាយណាក៏តែងតែមានជំការពីពួកចិន ឬចិនកាត់ខ្មែរដែរ ។

នៅឆ្នាំ ១៩៩២ ជាឆ្នាំច្របូកច្របល់មួយ ដែលការប្រគួកគ្នាផ្នែកពាណិជ្ជកម្ម បើអាជ្ញាធរគេយ និងរដ្ឋករ មានការលំបាក ធ្វើឱ្យការបិនប្រសប់ខាងបច្ចេកទេសនាំចេញនាំចូល មានភាពក្រៅច្បាប់ ។ ពួករកស៊ីនាំចេញចេញចូលមានការការពាពិសេសនៅក្រៅការប្រឈរមុខនយោបាយ ។ ក្រោយមកប្រព័ន្ធនេះបានទៅវិលរក សកត្តានុពលឯកភាពវិញ ខាងសេដ្ឋកិច្ចដែលនាំទៅដល់ ការស្តារឡើងវិញ នៃមរណៈភាពទំនាក់ទំនងនយោបាយសង្គម និង ទំនិញ ។ ត្រលក្បាកម៉ាស៊ីននៃសង្គ្រាម បានឆ្លើយតបតាមរយៈក្បាលម៉ាស៊ីសេដ្ឋកិច្ចឯកភាពខាងសន្តិភាព ។

ការបំពេញបន្ថែមតាមរយៈវិស័យសេដ្ឋកិច្ច និង នយោបាយព្រោមទាំងការឯកភាពខាងសេដ្ឋកិច្ច បានរៀបចំឡើងតាមប្រព័ន្ធចិន និង ថៅចិន ។

## ៧.៥.២.កត្តាមិនធម្មតានៃការបែងចែកនាំងស្រពិចស្រពិល

ការវិភាគនយោបាយជាភាគី ពីមុនការបោះឆ្នោតសាកល ២៣ ឧសភា ១៩៩៣ នៅតែមិនច្បាស់នៅ អ្វីៗទាក់ទងនិងអតិថិជនស្របច្បាប់ មានផលប្រយោជន៍នោះ ជាចំនោផលគមនិត ។ ទំនាក់ទំនងមិនបរិសុទ្ធនៅក្នុងក្រុងភាគីនីមួយៗមានភាពទំនាស់ ។ ព្រឹត្តិការណ៍ចុងក្រោយនានា បានធ្វើឱ្យមានការប៉ះទង្គិចផ្នែកសង្គមនោះជាឡូស៊ីកប្រចាំថ្ងៃនៃជីវភាព ដែលផ្តល់ជាថ្មីនៅក្នុងកិច្ចអភិក្រម ដែលតែងតែមានការបែងចែកភាគីនានា តាមកម្រិតនៃចលនាសង្គមទាំងមូល ។ ឆ្លើយតបនិងភាពប្រះឆា ដួលរលំតែងតែកើតមាននូវពន្លកដោយឯកឯង នូវដឹកនាំ

កើតឡើងពីមូលដ្ឋាននៃព្រឹត្តិការណ៍ ដែលមានតែមាត់នៃវប្បធម៌ ដែលស្របច្បាប់ហើយជាភាពស្របច្បាប់របស់ បុគ្គល ។

**ក.ភាគីនិយមគ្រួសារ**

ពាក្យខាងដើមថាអតិថិជនមានន័យថា ជាប្រព័ន្ធដែលត្រូវផ្តល់និយមន័យជាថ្មីជាអចិន្ត្រៃយ៍ និងត្រូវបញ្ជាក់នៅសាមគីភាពឡើងតាមរយៈការលេងល្បែងពហុបៀរ ត្រូវបង្កើតសម្ព័ន្ធ និងកិច្ចការងារ។

ចំណុចគោលសង្គម គឺស្ថិតនៅលើចំណងវប្បធម៌ នៃបែបបទសង្គមនយោបាយ ដែលរឹតភ្ជាប់សមាជិកគ្រួសារ ដើម្បីរស់ក្នុងសាមគីធម៌ជុំវិញមេដឹកនាំហើយតាមរយៈសមាជិកគ្រួសារនីមួយៗ មានការភ្ជាប់និងអតិថិជនជាយុទ្ធសាស្ត្រគឺការចងភ្ជាប់គ្រួសារកូនកាត់ខ្មែរចិន ជាស្នាមវប្បធម៌នៃឡូស៊ីកនៃរចនាសម្ព័ន្ធដែលមានប្រសិទ្ធភាព។

**ខ.នៅខាងក្រោមមុខការសេដ្ឋកិច្ចរួមគ្នានៅមានឡូស៊ីកនៃការបង្រួបបង្រួមពីក្នុងចិន**

ក្នុងចិនជាកត្តារបៀបរបប ជានាបានជាប្រព័ន្ធខ្សែរសង្វាក់ទំនាក់ទំនងតាមលក្ខខ័ណ្ឌនានា ។

- ជាដំបូងតាមរយៈសមាគមន៍ជាច្រើនឡើងប្រព័ន្ធនេះ មានការបែកបាក់គ្នាយោងទៅតាម ភាសា ភូមិគោក កំណើតដើម សាសនា ពិសេសគ្រួសារ ។ បន្ទាប់មកពួកគេរៀបចំរចនាសម្ព័ន្ធស្របគ្នា ដោយបម្រើមុខងារ ជុំវិញគីខ្មែរនីមួយៗ ឱ្យទទួលបានជោគជ័យលើផ្នែកនយោបាយ ។

ដោយឡែកឡូស៊ីកសេដ្ឋកិច្ចនៃពួកចិនជាយុទ្ធសាស្ត្រ មានទាក់ទងនិងការរកចំណេញឆក់ឪកាសរយៈពេលខ្លីធ្វើដូចជាពង្រីកថាមពលជាសេដ្ឋកិច្ចដល់សង្គម ដែលស្វាកមន៍ខ្លួនឈរលើមូលដ្ឋានសាមគីភាព មិនអាចធ្វើបាននៅក្នុងប្រទេសមួយពួកគេងាកទៅប្រទេសជិកខាងមួយទៀត ។

សង្គមយោងតាមគំនិតបែបនេះគេរៀបចំការគ្រប់គ្រងស្រពិចស្រពិល ប្រព្រឹត្តទៅជារបៀបប្រអប់ខ្មៅ ។ ការរៀបចំបែបនេះ នៃប្រព័ន្ធចិនអាចធ្វើឱ្យលេចឡើងនៃការប្រព្រឹត្តទៅនៃសេដ្ឋកិច្ចកម្ពុជាតែឯកឯង តាមរយៈភ្ជាប់ជាសមួយភាគីខ្មែរនានា ដែលប្រសិទ្ធភាពសេដ្ឋកិច្ចបែបនោះមានសកត្តានុពលរឹងមាំ ។

## ៧.៥.៣.ការបង្រួបបង្រួមគ្នាបានដោយឥទ្ធិពលពីខាងក្រៅ

**ក.ការសាកល្បងបង្រួបបង្រួមដោយប្រទេសជិតខាង**

ដោយមានការប្រជែងគ្នាជាអចិន្ត្រៃយ៍ ភាគីនយោបាយនានា តែងតែស្វែងរកការគាំទ្រពីខាងក្រៅដើម្បីសម្រួលហើយជាពិសេស ពីប្រទេសជិតខាង គឺ វៀតណាមនិងថៃ ព្រោះសង្គ្រាមស៊ីវិលស្ថិតនៅមាត់ទ្វាររបស់គេធ្វើឱ្យគេធ្វើអន្តរាគមន៍ទាំងបង្ខំចិត្ត ។

សម្មតិកម្មប្រចាំថ្ងៃពីរ ដែលភាគីខ្មែរតែងតែពឹងពាក់ ៖

- ជាក់ជំហរភ្ជាប់ជាមួយវៀតណាមនោះជាឡូស៊ីកគំរូចិន នោះជាសភាពការរបស់កម្ពុជាក្នុងប្រវត្តិឆ្នាំ ១៨៣០-១៨៤០ ហើយស្ថិតនៅក្នុងជំហរសេដ្ឋកិច្ច ដូចគ្នានៅក្នុងពេលដែលបារាំងត្រួតត្រា នៅអតិតឥណ្ឌូចិន ។

- ជាប្រទេសរណបពួកសៀម ក្នុងឡូស៊ីកនៃឥណ្ឌា ដូចស្ថានភាពកម្ពុជា មុនវត្តមានពួកបារាំង ។

ប្រតិបត្តិការបែបនេះ បានប្រព្រឹត្តទៅក្នុងសង្គ្រាមពីទស្សវត្សរកន្លង ហើយពួកពាណិជ្ជកម្មធំៗ តែងបានត្រូវជ្រើសរើស ផ្តល់អាទិភាពជាភាគីខាងក្រៅ ឱ្យដើរតួសេដ្ឋកិច្ច ដើម្បីជានាការរស់រាន់របស់បុគ្គល ។

## ខ.ប្រព័ន្ធចិននៅក្រៅប្រទេសលេងល្បែងពហុបៀរ

ការពន្យល់នៅត្រង់ការវិភាគដល់ជោគជ័យផ្នែកសេដ្ឋកិច្ចរបស់ថៃ។ ជាតថភាពគេត្រូវគិតគូរដល់ប្រព័ន្ធពួកកូនកាត់ ចិន-ថៃ ដែលបង្កើតបានជរង្វង់នៃសេចក្តីសម្រេចចិត្តសេដ្ឋកិច្ច តាមរយៈប្រព័ន្ធចិននៅបរទេស។ ឧទាហរណ៍បានបញ្ជាក់នៅ ព្រឹត្តិការណ៍ថាជាភាគីហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្នុងចំណោទប្រព័ន្ធសេដ្ឋកិច្ចដែលបានបែងចែកផលប្រយោជន៍ចិន ដែលសម្រាប់ពួកខ្មែរទាំងឡាយ មានតំណាងនៅក្នុងសហរដ្ឋជិកខាងទាំងនោះជារង្វង់អំណាចសេដ្ឋកិច្ចពីរ ។ នៅក្នុងកម្រិតនេះ ភាគីនានាសុទ្ធតែមានយុទ្ធវិធី រយៈពេលខ្លីនៃការរកស៊ីរហ័ស យកចំណេញ ។

តាមរយៈគ្រួសារភាគីនយោបាយនានាតែងភ្ជាប់ប្រព័ន្ធកម្ពុជា ទៅនិងភាគីអន្តរជាតិ នៅពួកចិននៅនាយសមុទ្រ លោកណោប៉ូត បានបញ្ជាក់ថា មានចិន នៅហុងកុង ម៉ាកៅ តៃវ៉ាន់ សិង្ហបូរី និង ប្រព័ន្ធចិនក្រៅប្រទេសអាស៊ាននានា បង្កើតបានជាសាមគីភាពតាំពីយូមកហើយ ។

ទន្ទឹមនិងកិច្ចប្រតិបត្តិការនាំចេញនាំចូលផ្លូវការក៏នៅបានប្រើប្រាស់កម្ពុជា ជាផ្លាក់បង្វិលសម្រាប់ការជួញមាស រូបិយប័ណ្ណ បង្កើតទុនអចលនវត្ថុ រួចលក់បង្វិលទុនចំណេញចេញក្រៅទៅប្រទេសដើមវិញ ។

- កំពង់ផែ សាយហ្គន កាន់កាប់ដោយពួកចិននិងវៀតណាម ក្លាយជាចំណុចចេញដំណើរនៃប្រតិបត្តិការក្រៅ គយ រដ្ឋករជាមួយហុងកុង និង ហ្គងដុង ។

- ការប្តូរគ្នារវាងថៃនិងប្រទេសចិន តាមរយៈកម្ពុជានិងឡាវ ក៏ដូចជារវាង ថៃ និងវៀតណាម ...។

- កម្ពុជាបានក្លាយជាចំណុចបុព្វសុទ្ធិខាងជំនួញមាស នាំចូលពីសិង្ហបូរី ហើយនាំចេញទៅក្រៅបន្ត ។

ពេលខ្លះតាមរយៈផលប្រយោជន៍ភូមិសាស្ត្រ ពួកចិននៅឯនាយសមុទ្រ បានរួមចំណែកជាអតិថិជន ហិរញ្ញវត្ថុ ឬ ពាណិជ្ជកម្ម ធ្វើឱ្យមានការបង្រួបបង្រួមភាគីខ្មែរក្នុងប្រទេសឡើងវិញ ។

### គ.ការបង្កើតជាសមសមភាពតែមួយ

ពេលខ្លះឯកភាពកម្ពុជាមិនអាចប្រព្រឹត្តទៅបានតាមរយៈរង្វង់ទំនាក់ទំនងក្រៅប្រទេស ទាល់តែមានការសម្របសម្រួលពីភាគីទីបីទៀត ឈរលើឡូស៊ីកថ្មីទៀត ជាឡូស៊ីកនយោបាយ ដែលបានដើរតួនាទីអស់រយៈពេលមួយសតវត្សកន្លងមក តាមរយៈសកត្តានុពលអាណានិគមន៍ចាស់ គឺបារាំង ។

ប្រទេសចិននិងជប៉ុន បានយល់ព្រមផងដែរ ឱ្យមានការប្រព្រឹត្តទៅនៃសេដ្ឋកិច្ចកម្ពុជា ។ ប្រទេសចិនមានរូបមន្តលំនឹង និង ការផ្លាស់ប្តូរកម្លាំង តាមរយៈជញ្ជីងទំងន់ ពីភាគីមួយទៅភាគីមួយ ជៀសវាងការប្រឈមដាក់គ្នាដោយសារសមត្ថភាពនៃប្រព័ន្ធ ចិននៅនាយសមុទ្រ ដោយពង្រីកភាគីសេដ្ឋកិច្ច ។ ចិនបានអនុគ្រោះដល់ការពង្រីកផ្នែកសង្គមសេដ្ឋកិច្ចកម្ពុជា ឱ្យប្រព្រឹត្តទៅដោយឯកឯង ។

ចំណែកប្រទេសជប៉ុនវិញ មានតួនាទីផ្ទុយទៅវិញ គឺផបចំទស្សនៈវិស័យថាមពលអភិវឌ្ឍន៍ ក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា ដើម្បីជួយបំបាត់ការហាមឃាត់នានាពីបរទេសដល់កម្ពុជាពីឆ្នាំ ១៩៨០ ។ ជប៉ុន ជាអ្នកជួយ កម្ពុជាទីមួយ ក្នុងកម្មវិធីជំនួយពហុភាគី ជំរុញឱ្យកម្ពុជាបានសន្តិភាពធាប់ ដោយផ្តល់ហិរញ្ញវត្ថុដ៏ច្រើនៗ ដល់កម្ពុជាបញ្ឈប់ការប្រឈមមុខដាក់គ្នាពីភាគីខ្មែរទាំងអស់ ។ យុទ្ធសាស្ត្រនៃការផ្គត់ផ្គង់របស់ជប៉ុនគឺឆ្លងតាមអង្គការអន្តរជាតិផង និង ជាលើកដំបូងដែលជប៉ុន បញ្ជូនកងទាហាន ជាង របស់ខ្លួនមកជួយកម្ពុជា តាមរយៈការផ្តល់នៅហិរញ្ញវត្ថុ និង តិចណូ-ឡូស៊ី ។

## ៧.៦.ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា

ប្រទេសកម្ពុជាបានឈានចូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលឈរទៅលើការកំណត់តាមរយៈទីផ្សារសេរីក្នុងកំឡុង ពេលពាក់កណ្តាលនៃការធ្វើ globalization របស់សេដ្ឋកិច្ចពិភពលោក។ ប្រទេសកម្ពុជាក៏បានធ្វើសេរីកម្មទៅលើ ពាណិជ្ជកម្មអន្តរជាតិក៏ដូចជាការធ្វើវិនិយោគបរទេសក្នុងឆ្នាំ1993និង1994 ។ ទោះបីជាការចូលជាសមាជិកអាស៊ានត្រូវ បានផ្អាកមួយរយៈពេលក្នុងឆ្នាំ 1997 ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែព្យាយាមដើម្បីចូលរួមជាសមាជិកអាស៊ានពេញសិទ្ធក្នុងឆ្នាំ999 ។

ទោះបីជាការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចក្នុងតំបន់ នឹងនាំមកនូវឱកាសក្នុងការអភិវឌ្ឍប្រទេសកម្ពុជាក្នុងពេល អនាគតក៏ដោយ ប្រទេសកម្ពុជាក៏មានការប្រឈមមុខមួយចំនួនដែរចំពោះ អ្នកបង្កើត និង គ្រប់គ្រងគោលនយោបាយ សេដ្ឋកិច្ច ពីព្រោះប្រទេសកម្ពុជាទាមទារអោយមានការពង្រឹងសមត្ថភាព និង បទពិសោធន៍មួយចំនួយធំ ក្នុងការគ្រប់គ្រង សមាហរន្តកម្មសេដ្ឋកិច្ច ទីផ្សារនេះ ។

ការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចក្នុងតំបន់ និង ពិភពលោកមានលក្ខណៈនឹងប្រយោជន៍ដូចខាងក្រោម :

1- ការកាត់បន្ថយ របាំង ឬឧបសគ្គក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ

2- ការបង្កើនតួនាទី របស់ច្បាប់បញ្ញត្ត ឬវិន័យក្នុងតំបន់ និង អន្តរជាតិដូចជា ASEAN និង WTO ជាដើម

3- ការធ្វើ globalization ក្នុងការបង្កើនផលិតផល ដែលមានឥទ្ធិពលទៅលើប្រសិទ្ធភាពនៃការធ្វើពាណិជ្ជកម្ម និង វិនិយោគ ។

គោលបំណងមួយរបស់ប្រទេសកម្ពុជាក្នុងការធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួននៅក្នុងអាស៊ានគឺដើម្បីបង្កើននូវ ឱកាសការងារថ្មី ដែលជាយាន្តក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទន្ទឹមនឹងនេះដើម្បីធានាថាការធ្វើសមាហរន្តកម្មសេដ្ឋកិច្ច កងអាស៊ាននេះនាំអោយមានភាពជោគជ័យដែលនាំមអោយមានកំណើនសេដ្ឋកិច្ចជាតិនោះ ប្រទេសកម្ពុជាគរផ្តោតការ យកចិត្តទុកដាក់ទៅលើ :

- ការពង្រឹងស្ថេរភាពនយោបាយក្នុងប្រទេស
- ការពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច
- ការពង្រឹងរចនាសម្ព័ន្ធច្បាប់ ឬបញ្ញ័តិដើម្បីអោយមានតំលាភាព ក្នុងការធ្វើជំនួញឬពាណិជ្ជកម្មផ្សេ-ងៗ

យុទ្ធសាស្ត្រដើម្បីទទួលបានសមិទ្ធិផលខ្ពស់ពីការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចក្នុងអាស៊ានគឺ :

1- ការអភិវឌ្ឍ និរន្តភាពនៃវិស័យកសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ
2- ការអភិវឌ្ឍវិស័យឧស្សាហកម្ម និង សេវកម្ម ព្រមទាំង
3- ការបង្កើនអោយមានភាពស្មើគ្នាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ជាប្រទេសកម្ពុជាបានចូលជាសមាជិកពេញសិទ្ធរបស់អាស៊ានហើយថែមទាំងបានទទួលផលប្រយោជន៍យ៉ាងច្រើនក្នុងការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចនេះក៏ដោយ ក៏ប្រទេសកម្ពុជាមានបញ្ហា សេដ្ឋកិច្ចឧស្សាហកម្ម ដូចខាងក្រោម :

1- ការអភិវឌ្ឍ ឧស្សាហកម្មដែលទាក់ទិន្នទៅនឹងផលិតកសិកម្ម
2- - កង្វះខាតនូវកម្មករជំនាញ
3- ការត្រូវការជំនួយទៅលើសហគ្រាសធុនមធ្យម និង តូច (SMEs)
4- ការគ្រប់គ្រងលើបញ្ហាបរិស្ថានដែលត្រូវបំពល់ដោយកាកសំណល់ឧស្សាហកម្ម

## ៧.៧.គោលនយោបាយសេដ្ឋកិច្ច

### ៧.៧.១.គោលនយោបាយទី១: គ្រប់គ្រងសេដ្ឋកិច្ច និង អភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ការអនុវត្តចំណាយថវិកាសម្រាប់គោលបំណងគោលនយោបាយទី១មានចំនួន ៣,៧៥៨.៥លាន រៀលស្មើនឹង ១០១% នៃឥណទានក្នុងច្បាប់ នៅក្នុងនោះកម្មវិធីទី១មានចំនួនរហូតដល់ទៅ ២,០១៦.១ លានរៀលស្មើនឹង ១៧១.៨% នៃឥណទានក្នុងច្បាប់ និង កម្មវិធីទី២មានចំនួន ១,៧៤២.៨ លាន រៀល ស្មើ នឹង ៦៨.៤% នៃឥណទានក្នុងច្បាប់។ វឌ្ឍន

ភាពសមិទ្ធកម្ម នៃគោលបំណងគោលនយោបាយទី១ ស ម្រេ ច បាន ៨៥% ក្នុងនោះកម្មវិធីទី១ សម្រេចបាន ៩០% កម្មវិធីទី២សម្រេចបាន ៨០%។

ការអនុវត្តចំណាយលម្អិត និង ការវឌ្ឍនភាពសមិទ្ធកម្មតាមកម្មវិធីទាំង២ នៃគោលបំណងគោល នយោបាយទី១ មានដូចតទៅ៖

### ក.កម្មវិធីទី១៖ ការគ្រប់គ្រងសេដ្ឋកិច្ច

កម្មវិធីទី១ មានតែអនុកម្មវិធីទី១.១ ចំនួន០១ប៉ុណ្ណោះ ដែលការអនុវត្តចំណាយមានចំនួន ២,០១៦.១លានរៀល ស្មើនឹង ១៧១,៨% នៃឥណទានក្នុងផែនការច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី១ សម្រេច បាន ៩០%។

**អនុកម្មវិធីទី១.១ (អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សាធារណៈ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩០% នៃគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួម មាន៖

- របាយការណ៍ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សារពើពន្ធហិរញ្ញវត្ថុ និង របាយការណ៍សិក្សាតាមវិស័យ ត្រូវបានរៀបចំសម្រាប់វិស័យចំនួន០៤ គឺអប់រំ សុខាភិបាល កសិកម្ម និង ការអភិវឌ្ឍជំនាញ
- របាយការណ៍វាយតម្លៃសារពើពន្ធពាក់កណ្តាលឆ្នាំត្រូវបានរៀបចំ
- របាយការណ៍ចុងក្រោយស្តីពីអនុលោមភាពពន្ធគយនៅកម្ពុជា ត្រូវបានរៀបចំ
- ស្តង់ដារស្ថិតិ TOFE&GFS និង ឯកសារណែនាំស្តីពីការអនុវត្តស្តង់ដារស្ថិតិត្រូវបានគិតគូរ និង រៀប ចំបង្កើនគុណភាព ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវិភាគនានា
- ទិន្នន័យស្ថិតិត្រូវបានចងក្រង រក្សាទុកក្នុងឃ្លាំងផ្ទុកទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF-Database) រួមមាន ១១ផ្នែក និង ៦០សូចនាករ
- របាយការណ៍ស្តីពីការអនុវត្តកម្មវិធីកាត់បន្ថយ និង លុបពន្ធនាំចូលរបស់កម្ពុជាលើ(HS2012) និង របាយការណ៍ ស្តីពីបញ្ជីវិធានដោយឡែកសម្រាប់ផលិតផលលើ(HS2012) និង របាយការណ៍នានា ស្តី ពីការអនុវត្តគម្រោងសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយនឹងលទ្ធផលនៃការស្រាវជ្រាវ និង ការវិភាគការអនុវត្តកាតព្វកិច្ចក្រោមតំបន់ពាណិជ្ជកម្មសេរី និង សហប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានរៀបចំ។

### ខ.កម្មវិធីទី២៖ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

កម្មវិធីទី២ មានអនុកម្មវិធីចំនួន ០៣ ក្នុងនោះការអនុវត្តចំណាយក្នុងអនុកម្មវិធីទី២.១ មាន ចំនួ ន ៩៩៥.៧លានរៀល ស្មើនឹង ៨១.៥% នៃឥណទានក្នុងច្បាប់ អនុកម្មវិធីទី២.២ អនុ

វត្តបាន ៤១០.៧ លានរៀលស្មើនឹង ៨៩.៦% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធី២.៣ អនុវត្តបាន ៣៣៦.៤លានរៀល ស្មើ នឹង ៣៨.៨% នៃឥណទានក្នុងច្បាប់ ។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី២ សម្រេចបាន ៨០%។

ការសម្រេចបានតាមគោលដៅសូចនាករសមិទ្ធកម្មដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី២.១ (អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩០% នៃ គោលដៅសូចនាករដែលបានកំណត់។ ដែលក្នុងនោះ សមិទ្ធកម្មគន្លឹះដែលសម្រេចបានក្នុងឆ្នាំ ២០១៥ រួមមា ន ៖

- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត(ច្បាប់ អនុក្រិត្យនិងប្រកាស)ពាក់ព័ន្ធនឹងវិស័យមូលបត្ររដ្ឋ ការគ្រប់គ្រងរមណីយដ្ឋានសមាហរណ៍ និង ពាណិជ្ជកម្មល្បែង ការផ្តល់អាជ្ញាប័ណ្ណកាស៊ីណូ ការ គ្រប់គ្រង អាជីវកម្មអភិវឌ្ឍន៍លំនៅដ្ឋាន និង ការគ្រប់គ្រងអាជីវកម្មបញ្ចាំ និងប្រាតិភោគ ដោយអនុប្ប ទាន ត្រូវបានរៀបចំដោយមួយចំនួនកំពុងស្ថិតក្នុងដំណាក់កាលពិភាក្សាក្នុងក្រុមប្រឹក្សានីតិកម្មនិង មួយ ចំនួន ទៀត ស្ថិត ក្នុងកិច្ចពិភាក្សាអន្តរក្រសួង ស្ថាប័ន។

- ការតាមដានត្រួតពិនិត្យស្ថានភាពអាជីវកម្មរបស់គ្រឹះស្ថានជានាវ៉ាប់រងដល់ទីកន្លែងត្រូវបានអនុវត្ត

**អនុកម្មវិធីទី២.១ (អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៧០% នៃគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- សេចក្តីព្រាងច្បាប់ស្តីពីគណនេយ្យ និង សវនកម្ម ត្រូវបានរៀបចំទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រី និង កំពុងស្នើសុំការអនុម័តយល់ព្រមពីរដ្ឋសភា
- បទបញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យ និង សវនកម្ម ត្រូវបានផ្សព្វផ្សាយតាមរយៈសិក្ខាសាលាចំនួន លើកនៅតាមរាជធានី ខេត្ត ។
- សមត្ថភាពមន្ត្រីលើស្តង់ដារគណនេយ្យ ត្រូវបានពង្រឹង និង បង្កើនតាមរយៈការបញ្ជូនចូលរួម សិក្ខាសាលានានា។

**អនុកម្មវិធីទី២ (គណៈកម្មការមូលបត្រកម្ពុជា)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីសម្រេចបានសមិទ្ធកម្មកម្មជារួមប្រមាណ៧ ០% នៃគោលដៅសូចនករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- ក្របខ័ណ្ឌគតិយុត្តមួយចំនួនសម្រាប់ការគ្រប់គ្រងទីផ្សារមូលប័ត្រ យន្តការ និង ការត្រួតពិនិត្យ អន្តរការីមូលបត្រ ការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និង ការបោះផ្សាយលក់មូលបត្រត្រូវបានរៀបចំ រួចរាល់ក្នុងនោះរួមមានប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ និង ការគ្រប់គ្រងអាជីវកម្មឧបកណ៍និស្សន្ទ ប្រកាសស្តី ពី ការបោះផ្សាយលក់មូលប័ត្រកម្មសិទ្ធិសាធារណៈ សម្រាប់សហគ្រាសធុនតូច និងមធ្យម និង ប្រកាស ស្តីពីការស៊ើបអង្កេតក្នុងវិស័យមូលបត្រត្រូវបានរៀបចំ
- ការបណ្តុះបណ្តាល និង ការផ្សព្វផ្សាយលើវិស័យមូលបត្រ ត្រូវបានរៀបចំតាមរយៈសិក្ខាសាលា សា ធារណៈសិក្ខាសាលានៅតាមសកលវិទ្យាល័យ និង នៅតាមបណ្តាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
- ការស្រាវជ្រាវ និង ស៊ើបអង្កេតបទល្មើស ក្នុងវិស័យមូលបត្រត្រូវបានអនុវត្តពេញមួយឆ្នាំ ។

## ៧.៧.២.គោលនយោបាយទី២: គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ទ្រព្យសម្បត្តិរដ្ឋ

ការអនុវត្តចំណាយថវិកាសម្រាប់គោលបំណងគោលនយោបាយទី២មានចំនួន ៣៩៥,២២៤.៤ លានរៀល ស្មើនឹង៩៦.៦% នៃឥណទានក្នុងច្បាប់ ក្នុងនោះចំណាយក្នុងកម្មវិធីទី៣អនុវត្តបាន ចំនួន ២៣ ៥,៤៧៤.១លានរៀល ស្មើនឹង៩៩.៥% នៃឥណទានក្នុងច្បាប់ ចំណាយក្នុងកម្មវិធីទី៤អនុវត្តបាន ៧,១១ ២.៨លានរៀលស្មើនឹង៨៧.២% នៃឥណទានក្នុងច្បាប់ និង ចំណាយក្នុងកម្មវិធីទី៥សម្រេចបាន ១៥២, ៦៣៧.៥លាន រៀល ស្មើនឹង៩៣% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃគោលបំណងគោលនយោបាយទី២សម្រេចបាន ៨៨% ក្នុងនោះកម្មវិធីទី២សម្រេចបាន ៨០% កម្មវិធីទី៣ សម្រេចបាន ៨៩% កម្មវិធីទី៤ សម្រេចបាន៩៤% និង កម្មវិធីទី៥សម្រេចបាន៨៣% ។

ការអនុវត្តការចំណាយលម្អិត និង វឌ្ឍនភាពសមិទ្ធកម្មតាមកម្មវិធីទាំង៣ នៃគោលបំណងគោល នយោបាយទី២ មានដូចតទៅៈ

### ក.កម្មវិធីទី៣ ការកៀរគរចំណូលថវិកាជាតិ និង ការគ្រប់គ្រងទ្រព្យសម្បត្តិ រដ្ឋ

កម្មវិធីទី៣ រួមមានអនុកម្មវិធីចំនួន ០៣ អនុវត្តចំណាយបាន ២៣៥,៤៧៤.១លានរៀល ស្មើនឹង ៩៩.៥% នៃឥណទានក្នុងច្បាប់ ដោយក្នុងនោះការអនុវត្តចំណាយក្នុងអនុកម្មវិធីទី៣.១ មានចំនួន ២១៣,៧៩១.៥លានរៀល ស្មើនឹង ១០២.៥% នៃឥណទានក្នុងច្បាប់ អនុកម្មវិធីទី៣.២ អនុវត្តចំណាយ បាន ៥,៩៤៧.៣ លានរៀល ស្មើនឹង ៧៦.៩% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធីទី៣.៣ អនុវត្តចំណាយបាន ៥,៩៤៧.៣លានរៀល ស្មើនឹង ៧៩.២% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី៣ សម្រេចបាន ៨៩%។

ការសម្រេចបានតាមគោលដៅសូចនាករសមិទ្ធកម្ម បានកំណត់ក្នុងផែនការសកម្មភាពប្រចាំ ឆ្នាំ ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី៣.១ (អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩២% នៃ គោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះដែលសម្រេចបានរួមមាន៖

- យន្តការនិង វិធានការនៃការគ្រប់គ្រងប្រព័ន្ធហានិភ័យគយ ការពង្រឹងប្រសិទ្ធភាពការងារបង្ការ និង បង្ក្រាបអំពើរត់គេចពន្ធត្រូវបានគិតគូររៀបចំ
- ការវាយតម្លៃអនុលោមភាពតាមគោលការណ៍របស់ WTO លើតម្លៃគិតពន្ធគយ ការវាយតម្លៃការ អនុវត្តតម្លៃចម្លងលើទំនិញនាំចូល ក្រោមរបបអនុគ្រោះពន្ធ និង ការវាយតម្លៃប៉ះពាល់ផលិតកម្មក្នុងស្រុកជំនួសការនាំចូលត្រូវរៀបចំ
- ប្រសិទ្ធភាពនៃយន្តការភាពជាដៃគូរគយ ផ្នែកឯកជន ត្រូវបានពង្រឹង
- ប្រព័ន្ធម៉ាស៊ីនគូជា និង ម៉ាស៊ីនស្កែន ត្រូវបានពង្រីកការគ្របដណ្តប់ដល់ ៥៧ ការិយាល័យបំពេញបែបបទគយ
- លើកកម្ពស់និង អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈសិក្ខាសាលាវគ្គជំនាញ និង ទស្សនកិច្ចសិក្សា
- អនុវត្តប្រកបដោយអប្បមានខ្ពស់នូវគោលនយោបាយអន្តរាគមន៍សេដ្ឋកិច្ច របស់រាជរដ្ឋាភិបាល

**អនុកម្មវិធីទី ៣.២ (អគ្គនាយកដ្ឋានពន្ធដារ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះសម្រេចបានសមិទ្ធកម្មជារួមប្រមាណ៨៣% នៃគោលដៅសូចនករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះដែលសម្រេចបាន រួមមាន៖

- សមត្ថភាពមន្ត្រី និង ស្ថាប័ន ត្រូវបានពង្រឹងតាមរយៈ វគ្គបណ្តុះបណ្តាលមន្ត្រីលើជំនាញពន្ធដារ ទាំងក្នុង និង ក្រៅប្រទេស
- បណ្តាញបច្ចេកវិទ្យាព័ត៌មាន ត្រូវបានតភ្ជាប់ទៅគ្រប់សាខាពន្ធដារខេត្ត ខណ្ឌ ទូទាំងប្រទេស
- សហគ្រាសចំនួន៣,៥៥១(ផែនការកំណត់២,៥៩០)ត្រូវបានចុះបញ្ជីតាមរបបស្វ័យប្រកាស
- ប្រសិទ្ធភាពនៃការផ្តល់សេវា និង ការយល់ដឹងពីការបង់ពន្ធ ត្រូវបានបង្កើនតាមរយៈការផ្តល់សេវា ពិសេស និង ការផ្សព្វផ្សាយដល់សាធារណជន ព្រមទាំងធ្វើសាមញ្ញកម្មនីតិវិធីតាមរយៈការបង្កើតសេវា កម្ម Online ក្នុងការចុះបញ្ជីពន្ធដារ ការប្រកាសពន្ធប្រចាំខែ និង ប្រចាំឆ្នាំ និង ការបង់ពន្ធតាមធនាគារពាណិជ្ជ

- សវនកម្មចំនួន២,២២២សហគ្រាស ត្រូវបានអនុវត្តដោយនាយកដ្ឋាន ថ្នាក់កណ្តាល និង ៤៥០សហគ្រាស ត្រូវបានអនុវត្តដោយសាខាពន្ធដាខេត្ត-ខណ្ឌ
- យន្តការក្នុងការគ្រប់គ្រងមន្ត្រីពន្ធដារ និង ការផ្តល់សេវាដល់អ្នកជាប់ពន្ធ នៅតាមសាខាពន្ធដារខេត្ត- ខណ្ឌ ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យដំណើរការម៉ាស៊ីន ស្កេនម្រាមដៃ ការដាក់ឱ្យអនុវត្តក្រមសីលធម៌ មន្ត្រីពន្ធដារ និង ការរៀបចំរចនាសម្ព័ន្ធថ្មីនៃអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ។

**អនុកម្មវិធីទី៣.៣ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិ និង ចំណូលមិនមែនសារពើពន្ធ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩ ១ % នៃ គោលដៅសូចនករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះ ដែលសម្រេចបានរួមមាន៖

- ការកៀងគរចំណូលមិនមែនសារពើពន្ធ និង ចំណូលពីទ្រព្យសម្បត្តរដ្ឋ ដោយក្រសួង ស្ថាប័នត្រូវ បាន ពង្រឹងដោយចំណូលមិនមែនសារពើពន្ធ សម្រេចបាន ៩៨.៤% និង ចំណូលពីទ្រព្យសម្បត្តិរដ្ឋ សម្រេ ច បាន ៧៨.២៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៥
- ប្រកាសរួមនានា សម្រាប់ការផ្តល់សេវាសាធារណៈ និង ការផ្តល់រង្វាន់លើកទឹកចិត្តជាមួយក្រសួង ស្ថាប័នត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត
- ព្រះរាជក្រឹត្យស្តីពី វិសោធនកម្មលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល អនុក្រឹត្យគំរូស្តីពីការបង្កើតគ្រឹះស្ថាន សាធារណៈរដ្ឋបាល និង លិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀតត្រូវបានរៀបចំ និង ប្រកាសដាក់អោយអនុវត្ត និង កំពុងបន្តរៀបចំ អនុក្រឹត្យស្តីពីថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។
- គម្រោងវិនិយោគសាធារណៈរបស់រដ្ឋ និង សម្បទានដទៃទៀត ត្រូវបានសិក្សាវាយតម្លៃព្រមទាំង ចាត់វិធានការណ៍ដើម្បីទាមទារបំណុល និង កៀងគរចំណូលភាគលាភ។

**ខ.កម្មវិធីទី៤៖ បង្កើនប្រសិទ្ធភាពនិង ស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងចំសាធារណៈ**

កម្មវិធីទី៤ រួមមានអនុកម្មវិធីចំនួន៤ អនុវត្តចំណាយបាន៧,១១២.៨លានរៀល ស្មើនឹង ៨៧.២ % ធៀបនឹងឥណទានក្នុងច្បាប់ ក្នុងនោះអនុវត្តចំណាយក្នុងអនុកម្មវិធីទី៤.១ មានចំនួន ១,៤៦៩.២ លាន រៀល ស្មើនឹង ៥៧% នៃឥណទានក្នុងច្បាប់ អនុវត្តកម្មវិធីទី៤.២ អនុវត្តចំណាយបាន ៨៥៤.១ លានរៀល ស្មើនឹង ៦៨.៦% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធីទី ៤.៤ អនុវត្តចំណាយបាន ៤,១១៦.៨ លានរៀល ស្មើនឹង១១៥.៨% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី៤ សម្រេចបាន ៩៤%។

វឌ្ឍនភាពនៃការអនុវត្ត ផែនការសកម្មភាព ប្រចាំឆ្នាំ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី៤.១ (អគ្គនាយកដ្ឋានថវិកា**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩៨% នៃ គោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- សារាចរទាំង៣( សារាចរណែនាំស្តីពីការអនុត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ និង សារាចរណែនាំស្តីពីការរៀបចំនូវសេចក្តី ព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០១៦) ត្រូវបានរៀបចំនិង ផ្សព្វផ្សាយ អនុវត្តដោយអនុលោមទៅតាមប្រតិទិននៃដំណើរការរៀបចំថវិកា ប្រចាំឆ្នាំ
- ការធានាចំណាយត្រូវបានអនុវត្តតាមគោលការណ៍ ១៤៥% នៃតម្លៃទំនិញ និង សេវា
- ការត្រួតពិនិត្យការអនុវត្តថវិកា ត្រូវបានអនុវត្តដោយអនុលោម តាមសារាចរបិទបញ្ជីឆ្នាំ២០១៥
- គម្រោងវិនិយោគចំនួន១៧ ត្រូវបានដាក់ដេញថ្លៃតាមនីតិវិធីជាធរមាន។

**អនុកម្មវិធីទី ៤.២ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាព ក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្ម ៩០%នៃគោលដៅ សូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះដែលសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- គោលការណ៍ និង វិធានក្នុងការអនុវត្តថវិការ និង ការផ្តល់សេវាដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ បានរៀបចំនិង ដាក់ឱ្យអនុវត្ត រួមមានសារាចរស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សារាចររៀបចំផែនការយុទ្ធសាស្ត្រ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសារាចរ ស្តីអំពីនីតិវិធីបច្ចេកទេសនៃការរៀបចំថវិកាប្រចាំឆ្នាំ ២០១៦ សារាចរបិទបញ្ជី និង រៀបចំរបាយការណ៍សម្រេចទូទាត់ ថវិកា ប្រចាំ ឆ្នាំ ២០១៥ ប្រកាសស្តីពីវិធាន និង នីតិវិធីអនុវត្តបេសកកម្មរដ្ឋបាលថ្នាក់ក្រោមជាតិប្រកាសអន្តរក្រសួងស្តីពីការប្រើប្រាស់កញ្ចប់សេវាអនាម័យ បរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹងរាវ តាមទីប្រជុំជននៅរដ្ឋបាលថ្នាក់ក្រោម ជាតិ និង ប្រកាសស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃ មាតិកាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- ការចុះតាមតានការអនុវត្តថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត។

**អនុកម្មវិធីទី ៤.៣ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាព នៃអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៨៩% នៃគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះ សម្រេចបានក្នុងឆ្នាំ២០១៥ រួម មាន៖

- វិធាន និង គោលការណ៍ណែនាំ ក្នុងការរៀបចំផែនការលទ្ធកម្ម ការអនុវត្តកិច្ចលទ្ធកម្ម និង ការដោះស្រាយវិវាទពាក់ព័ន្ធកិច្ចលទ្ធកម្ម ត្រូវបានរៀបចំនិង ផ្សព្វផ្សាយការណែនាំអនុវត្តជូនក្រសួងស្ថាប័ន ជាពិសេសក្រសួងស្ថាប័នអនុវត្តថវិកាកម្មវិធី
- ការអនុម័តផែនការលទ្ធកម្ម ផែនការលទ្ធកម្មកែតម្រូវ និង ការអនុវត្តកិច្ចលទ្ធកម្មលើសិទ្ធិត្រូវបាន ផ្តល់ជូនក្រសួង ស្ថាប័ន
- របាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មរបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំបូកសរុប ។

**អនុកម្មវិធីទី ៤.៤ (អគ្គនាយកដ្ឋានរតនាគារជាតិ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះសម្រេចបានសមិទ្ធកម្មជារួមប្រមាណ៩៨% នៃ គោលដៅសូចនករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះដែលសម្រេចបានក្នុងឆ្នាំ២០១៥ រួម មាន៖

- ប្រតិបត្តិការចំណូលចំណាយ ត្រូវបានអនុវត្តតាមរយៈប្រព័ន្ធធនាគារ
- ការគ្រប់គ្រងសាច់ប្រាក់មានប្រសិទ្ធិភាពដោយសម្រេចបានអតិរេកសាច់ប្រាក់ ១,៨៣៨,៩៩០ លានរៀល
- កិច្ចបញ្ជីការគណនេយ្យមានភាពត្រឹមត្រូវ និង ស្របតាមស្តង់ដាអន្តរជាតិ ព្រមទាំងការរៀបចំនូវ របាយការណ៍ហិរញ្ញវត្ថុបានទាន់ពេលវេលា
- វិស័យព័ត៌មានវិទ្យានៅអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានពង្រឹងហើយប្រព័ន្ធគ្រប់គ្រងឯកសា រ e-doc ត្រូវបានដាក់អោយដំណើរការនៅថ្នាក់កណ្តាល
- អគ្គនាយកដ្ឋានរតនាគារជាតិ និង រតនាគាររាជធានី-ខេត្ត បានអនុវត្តនូវភារកិច្ចក្នុងនាមជា គណនេយ្យករសាធារណៈ ប្រកបដោយភាពត្រឹមត្រូវ និង ទាន់ពេល ។

### គ.កម្មវិធីទី៥៖ ការផ្តល់សេវាគាំទ្រទូទៅ និង គណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីទី៥ រួមមានអនុកម្មវិធីចំនួន០៥ អនុវត្តចំណាយបាន ១៥២,៦៣៧.៥ លានរៀល ស្មើនឹង ៩៣% នៃឥណទានថវិកាក្នុងច្បាប់ ដោយក្នុងនោះការអនុវត្តចំណាយក្នុងអនុកម្មវិធីទី៥.១ មានចំនួន ១,០៨៨.៥លានរៀល ស្មើនឹង៦៧.១% នៃឥណទានមានក្នុងច្បាប់ អនុកម្មវិធីទី៥.២ អនុវត្តចំណាយ បាន ១៣២,៦៣៤.៩លានរៀល ស្មើនឹង៩៥.៦% នៃឥណទានក្នុងច្បាប់ ដោយក្នុងនោះអនុកម្មវិធីទី៥.៣ អនុវត្ត ចំណាយបាន ១៩,០៨៣.៩លានរៀល ស្មើនឹង ៩៥.៦% នៃឥណទានក្នុងច្បាប់ អនុកម្មវិធីទី៥.៤ អនុវត្តចំណាយ បាន ៦៤៦.១លានរៀល ស្មើនឹង១១៧.១% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធីទី៥.៥ អនុវត្តចំណាយបាន ២៧២.៥ លានរៀល ស្មើនឹង៨៥,៨% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាព សមិទ្ធកម្មនៃកម្មវិធីទី៥ សម្រេចបាន ៨៣%។ ចំណាយលម្អិតនៅក្នុងអនុកម្មវិធីនីមួយៗ នៃកម្មវិធីទី៥ សម្រេចបាន ៨៣% ។

ចំណាយលម្អិតក្នុងអនុកម្មវិធីនីមួយៗ និង ការសម្រេចបានតាមគោលដៅសូចនាករ សមិទ្ធកម្ម ដែលបានកំណត់ក្នុងផែនការ សកម្មភាពប្រចាំឆ្នាំ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី៥.១ (អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៧៦% ធៀបនឹងគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះដែលសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- កិច្ចដំណើរការនៃការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានធានាប្រកបដោយនិរន្តរភាព និង ប្រសិទ្ធភាព ទន្ទឹមនឹងការត្រួតពិនិត្យកែលម្អនិង ដាក់ឱ្យអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង
- វឌ្ឍនភាពប្រចាំឆ្នាំ២០១៤ និង ប្រចាំត្រីមាសនៃឆ្នាំ២០១៥ ត្រូវបានត្រួតពិនិត្យវាយតម្លៃប្រកប ដោយសុក្រឹតភាព និង រាយការណ៍ជូនគណៈកម្មការការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផែនការសកម្មភាពរួមដំណាក់កាលទី៣(CAP3) និង ផែនការសកម្មភាព ការកែទម្រង់នៃក្រសួងស្ថាប័ន(MAP3) និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(GDAP3) ត្រូវបានរៀបចំរួចរាល់ និ ង ត្រៀមប្រកាសដាក់ឱ្យអនុវត្តនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៦
- របាយការណ៍វាយតម្លៃអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឆ្នាំ ២០១៥ (PEFA Report) ត្រូវបានរៀបចំរួចរាល់។
- សារាចរស្តីពីយន្តការដោះស្រាយកិច្ចប្រឈម និង សារាចរស្តីពីវិធាន និង នីតិវិធីនៃការរៀបចំការ អនុវត្តការត្រួតពិនិត្យតាមដាន និង វាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត ។
- សមត្ថភាពមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន**គ.ហ.ស**ត្រូវបានពង្រឹងតាមរយៈវគ្គបណ្តុះបណ្តាលក្នុង និង ក្រៅប្រទេស។

**អនុកម្មវិធីទី ៥.២ (អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៨៥% នៃ គោលដៅសូចនករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ ២០១៥ រួមមាន៖

- វិធាន និង គោលការណ៍ណែនាំផ្ទៃក្នុងក្រសួងសម្រាប់ការអនុវត្តថវិកាកម្មវិធី និង សេចក្តីព្រាង វិធាន និង គោលការណ៍សម្រាប់ដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ត្រូវបានរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ(២០១៦-២០១៨) និង កញ្ចប់ថវិកាឆ្នាំ២០១៦ របស់ក្រសួងត្រូវបានសម្របសម្រួលរៀបចំបូកសរុប និង ចងក្រងជាសៀវភៅ

- របាយការណ៍វឌ្ឍនភាពរបស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស៩ខែ និង ឆ្នាំ ត្រូវបានបូកសរុបជូន គណៈរដ្ឋមន្ត្រី

- កិច្ចស្រាវជ្រាវដើម្បីអភិវឌ្ឍផលិតភាព កម្លាំងពលកម្ម និង ភាពប្រកួតប្រជែង ត្រូវបានអនុវត្ត និង បានប្រមូលជាតុចូល ដើម្បីរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រសំខាន់ៗរបស់ជាតិ

- បញ្ហាប្រឈមនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវបានសម្របសម្រួលដោះស្រាយ

- កិច្ចការសម្រប និង ការគាំទ្រទូទៅ បានសម្រេចលទ្ធផលដូចតទៅ ៖

- សេវារដ្ឋបាល និង ហិរញ្ញវត្ថុ សម្រាប់ថ្នាក់ដឹកនាំក្រសួង អង្គភាពថវិកា ត្រូវបានអនុវត្តប្រកប ដោយប្រសិទ្ធភាព

- សេវាបុគ្គលិក រួមមាន ការកសាងផែនការបណ្តុះបណ្តាល, ការគ្រប់គ្រងបុគ្គលិក ការផ្តល់ការលើក ទឹកចិត្ត និង ការរៀបចំបៀវត្សមន្ត្រីរាជការ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព

- សេវានីតិកម្មរួមមាន ការផ្តល់មិតប្រឹក្សាច្បាប់ លើការរៀបចំបទដ្ឋានគតិយុត្តរបស់អង្គភាពក្រោម ឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រៀបចំប្រមូលចងក្រង កម្រងសម្រង់បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុសាធារណៈ វិស័យទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង វិស័យគយ

- សេវាបច្ចេកវិទ្យាពត៌មាន ត្រូវបានអនុវត្តប្រកបដោយរលូន

- សេវាបណ្តុះបណ្តាល ត្រូវបានអនុវត្តនិង បានឆ្លើយតបទៅតាមតម្រូវការជាក់ស្តែង ពិសេសការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអនុវត្តថវិការកម្មវិធី។

**អនុកម្មវិធីទី ៥.៣៖ ផ្តល់សេវាគាំទ្រទូទៅ ថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាព និង ស័ក្តសិទ្ធភាព (មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី -ខេត្ត)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩២% នៃគោលដៅសូចនាករដែលបានកំណត់ក្នុងនោះគ្រប់ចង្កោមសកម្មភាពទាំង ២៤ នៅមិនទាន់អា ចសម្រេច បានតាមគោលដៅពេញលេញ នូវសូចនករគន្លឹះប្រចាំឆ្នាំ៖ ជានាប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព នៃការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅរាជធានី ខេត្ត ។

**អនុកម្មវិធីទី ៥.៤ (អគ្គាធិការដ្ឋាន)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ៖ សម្រេចបានសមិទ្ធកម្មប្រមាណ ៧៥% នៃ គោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ ២០១៥ រួមមាន៖

- ការចាត់វិធានការណ៍លម្អដល់ ក្រសួង ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ លើនីតិវិធីនៃការគ្រប់ គ្រងចំណូលចំណាយថវិការដ្ឋ ត្រូវបានអនុវត្តចំនួន២៣ករណី

- ការដោះស្រាយបណ្ដឹងតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំត្រូវបានអនុវត្ត ចំនួន២ក្រសួង និង ១ មន្ទីរក្នុងទិសដៅពង្រឹងគណនេយ្យភាព ប្រសិទ្ធភាពក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ
- ការចុះបញ្ជីធ្វើអធិការកិច្ចនៅតាមក្រសួង ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបាន អនុវត្តសម្រេច បានមួយផ្នែកធំធៀបនឹងផែនការសកម្មភាព ។

**អនុកម្មវិធីទី ៥.៥ អគ្គនាយដ្ឋានសវនកម្មផ្ទៃក្នុង)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាព ក្នុងអនុកម្មវិធីនេះសម្រេចបានសមិទ្ធកម្មជារួម ប្រមាណ ៨ ៦% ធៀបនឹងគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះ ដែលសម្រេចបានក្នុងឆ្នាំ ២០១៥ រួមមាន៖

- ការធ្វើសវនកម្ម នៅអង្គភាពថ្នាក់មូលដ្ឋានចំនួន៦៦ និង នៅអគ្គនាយកដ្ឋាន ចំនួន៥ អនុវត្តពាក្យ បណ្ដឹងចំនួន៥ ចុះតាមតានការអនុវត្តអនុសាសន៍សវនកម្មនៅអង្គភាព ថ្នាក់មូលដ្ឋានចំនួន២៩ និង ក្រុម ការងារថ្នាក់ជាតិចុះខេត្តកោះកុងចំនួន៣លើក ។

# មេរៀនទី ៨
# ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារសង្គម

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- វិស័យផ្សេងៗ
- ហេដ្ឋារចនាសម្ព័ន្ធ
- សិក្សាធិការ
- វិស័យសុខាភិបាល
- វិស័យអភិវឌ្ឍន៍ជនបទ
- វិស័យទេសចរណ៍
- វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច

ការវិភាគពីកិច្ចប្រតិបត្តិការផែនការបានឱ្យឃើញនូវកិច្ចប្រឹងប្រែងនៃអាជ្ញាធរសាធារណៈ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារសង្គម។ ការវិនិយោគដែលត្រៀមសម្រាប់ផ្នែកនេះមានការចំណាយលើសខ្លាំងបើគិតជាភាគរយ និងទំហំការងារ។ រាជរដ្ឋាភិបាលសម័យសង្គមនិយម មានមោទនៈនូវសមិទ្ធិផលនោះ ជាពិសេសស្នាដៃបំពេញបានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ សិក្សាធិការ និងសុខាភិបាលសាធារណៈ។

## ៨.១.ហេដ្ឋារចនាសម្ព័ន

ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធមានតួលេខ ៦២% និង ២៦% នៃការវិនិយោគសាធារណៈ ក្នុងដំណាក់កាលនៃកិច្ចប្រតិបត្តិការនៃផែនការលើកដំបូងពីរ។ ទោះបីទុនបម្រុងតិចជាងតួលេខ ក៏នៅបានបកស្រាយពីការខិតខំនៃវិស័យនេះ។ តួលេខនៃគណនេយ្យជាតិនាឆ្នាំ ១៩៦២ និង១៩៦៣ ការចំណាយលើ "សាធារណៈការ" មាន ៤៦% និង ៥៤% នៃវិនិយោគរដ្ឋបាលនាឆ្នាំទាំងពីរ។ ការប្រឹងប្រែងនោះគឺមានចំណុចដូចតទៅៈ

- បណ្តាញផ្លូវបន្សល់ទុកពួកអាណានិគម ក៏មានសារៈសំខាន់ដែលត្រូវបានពង្រឹងជួសជុលពង្រី-ក។ ប្រតិបត្តិការគួរឱ្យតក់សម្គាល់គឺកសាងផ្លូវភ្ជាប់ភ្នំពេញទៅក្រុងព្រះសីហនុ"ជំនួយសហរដ្ឋអាមេរិក"។ ថាបនភ័ណ្ឌ **ouvrage** សិល្បៈជាច្រើនក៏បានសាងសង់។ ស្ពានជ្រោយចង្វារភ្ជាប់លើទន្លេសាប "១៩៦៤" និងស្ពានទន្លេបាសាក់ភាគខាងត្បូងរាជធានី "ចប់នៅឆ្នាំ ១៩៦៦" គឺជាសមិទ្ធិផលគួរឱ្យតក់សម្គាល់។
- ការកសាងផែក្រុងព្រះសីហនុ "ជំនួយបារាំង" នៅក្នុងតំបន់ដែលគ្មានមនុស្សនៅទាំងស្រុង នាឆ្នាំ ១៩៥៥ បានធ្វើប្រតិបត្តិការដ៏ធំធេង។ ការងារទីមួយគឺកសាងផែលយ "៣០០ ម." ជាបេតុងចូលទៅក្នុងសមុទ្រ ដែលបន្ថែមសមត្ថភាពផែបានសម្រេចនៅឆ្នាំ ១៩៦៦ ។

- សំណង់ផ្លូវដែកភ្ជាប់ភ្នំពេញ-ក្រុងព្រះសីហនុ “២៧០ គ.ម.” បានសម្រេចចិត្តនាឆ្នាំ ១៩៦០។ នៅឆ្នាំ ១៩៦៧ ផ្លូវជាង ១០០ គ.ម.បានធ្វើអាជីវកម្មពីភ្នំពេញ ទៅតាកែវ។ គម្រោងនេះមានការវិនិ យោគដល់ទៅ ១,៧៥០លានរៀល “រាប់បញ្ចូលទាំងសម្ភារផ្លូវដែក បម្រើជាសម្ភារអាជីវកម្ម” គឺបានមកពីការខ្ចីបុលពីប្រទេសបារាំង និងអាឡឺម៉ង់។ ពលកម្មមួយផ្នែកផ្តល់ក្នុងក្របខ័ណ្ឌ “ការងារហត្ថកម្មសុធន្ទៈ” ។

- ហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ក៏គ្មានការធ្វេសប្រហែសដែរ ព្រោះភ្នំពេញមានព្រលានយន្តហោះអន្តរជាតិ ហើយព្រលានយន្តហោះសៀមរាបក៏ទទួលបានយន្តហោះធន់ធ្ងន់ ហើយព្រលានយន្តហោះតូចៗ ក៏បានកសាងឡើង ពិសេសនៅតំបន់ព្រំដែនប្រទេស។

- នគរូបនីយកម្ម និងលំនៅស្ថានក៏ជាកម្មវត្ថុដោយឡែកដែរ។ ការដ្ឋានធំៗជាទំនប់ទឹកជុំវិញភ្នំពេញ មាត់ទន្លេ ប្រព័ន្ធចែកចាយទឹកស្អាតកសាងផ្លូវក្នុងក្រុង។ល។ ធ្វើឱ្យភ្នំពេញមានសោភ័ណ និងស្អាត នៅអាស៊ីអាគ្នេយ៍ធ្វើឱ្យទីក្រុងអាចអូសទាញប្រជាជនឱ្យកើនឡើង។ សមិទ្ធិផលពហុកីឡាដ្ឋានក្នុងនោះស្ថាតមាន ១០០,០០០កៅអី ។

- សំណង់ទំនប់វារីអគ្គិសនីបានរៀបចំកសាង។ កន្លែងជាច្រើន បានត្រូវកត់សម្គាល់ និងសិក្សា៖ គិរីរម្យ បាណន់ ព្រែកត្នោត កំចាយ សំបូរ ទន្លេសាប។ ការងារបានចាប់ផ្តើមនៅគិរីរម្យ និងកំចាយ។ គិរីរម្យបានចប់សព្វគ្រប់ ប៉ុន្តែសង្គ្រាមបានបញ្ឈប់ការដ្ឋានកំចាយ។

ការវិនិយោគដ៏ច្រើន អាចពន្យល់បានកំណើនយ៉ាងរហ័សនៃផ្នែក “សំណង់ និងសាធារណៈការ” ដែលរួមចំណែកដល់ប្រទេស ឱ្យមានហេដ្ឋារចនាសម្ព័ន្ធដ៏ល្អមួយ ដែលជាសមិទ្ធិផលនៃទសវត្សចុងក្រោយនេះ។ ប៉ុន្តែសកម្មភាពរបស់អំណាចសារធារណៈ ក្នុងវិស័យអប់រំក៏មានសារៈសំខាន់ខ្លាំងដែរ។

## ៨.២.សិក្សាធិការ

ពួករដ្ឋបាលអាណានិគម បានកសាងហេដ្ឋារចនាសម្ព័ន្ធជាច្រើន តែវិស័យសិក្សាធិការគេមិនយកចិត្តទុកដាក់សោះ។ ឧត្តមសិក្សា និងមធ្យមសិក្សា ស៊ឹងតែគ្មានសោះនៅសម័យអាណានិគម។ សារៈសំខាន់នៃបឋមសិក្សាគឺនៅក្នុងវត្ត "សាលាវត្ត"។ ប្រៀបនឹងប្រទេសនៅឥណ្ឌូចិន ប្រទេសកម្ពុជាត្រូវបានពួកអាណានិគម បំភ្លេចចោលលើវិស័យសិក្សាធិការ។ ហេតុដូចនេះហើយ រាជរដ្ឋាភិបាលបានខិតខំខ្លាំងក្លាណាស់ក្រោយទទួលបានឯករាជ្យ។

ការកសាងសំណង់ សាលារៀន សាកលវិទ្យាល័យ និងការបណ្តុះបណ្តាល ការប្រើប្រាស់សាស្ត្រាចារ្យ កើនឡើងយ៉ាងខ្លាំង។ ការកើនឡើងនូវចំនួនអាគារ និងចំនួនសិស្សដ៏ច្រើនៗ។

នៅបឋសិក្សា សាលារៀនជិត ២,០០០ បានត្រូវកសាងហើយ ចំនួននេះកើនទ្វេក្នុងរយៈពេលចន្លោះឆ្នាំ ១៩៥៥-១៩៦៥។

ប៉ុន្តែនៅកម្រិតមធ្យមសិក្សា គឺការរីកចម្រើនអស្ចារ្យ ព្រោះអាគារសាធារណៈ និងឯកជនដែលមានចំនួនក្រោម ១០ នៅឆ្នាំ ១៩៥៥ កើនឡើងដល់ ២០០ ហើយសិស្សមានចំនួនតែ

៥,០០០ នាក់ នៅឆ្នាំ ១៩៥៥ កើនឡើងដល់ ១០០,០០០នាក់ នៅឆ្នាំ ១៩៦៥។ សិក្សាធិការឯកជនជាភាសាចិន បារាំង វៀតណាម មានចំនួន១/៤ នៃសាលាសរុប។

សិក្សាបច្ចេកទេសមិនសូវរីកចម្រើនហើសទេ គឺមានសិស្សតែ ៤ ទៅ ៥ពាន់អ្នកតែប៉ុណ្ណោះ។សិក្សាធិការដែលហៅថាឧត្តមសិក្សា នៅក្នុងករណីខ្លះជាទីសិក្សាអប់រំបច្ចេកទេស ហើយចាប់ពីឆ្នាំ ១៩៦៤មក សាលាជាតិពាណិជ្ជកម្ម សាលាភូមិន្ទកសិកម្ម សាលាភូមិន្ទវិចិត្រសិល្បៈ ក្លាយទៅជាមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ។

ឧត្តមសិក្សាក៏ត្រូវបានសាង។ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សកលវិទ្យាល័យភូមិន្ទភ្នំពេញ រួមមានមហាវិទ្យាល័យច្បាប់សេដ្ឋកិច្ច វេជ្ជសាស្ត្រ ឱសថសាស្ត្រ និងសាកលវិទ្យាល័យបច្ចេកទេស រួមមានវិទ្យាស្ថាន ខ្មែរ-សូវៀត បណ្តុះបណ្តាលវិស្វករ។

ទោះបីមានជំនួយដ៏ធំធេង ក្នុងវិស័យសិក្សាធិការ និងសម្ភារពីបារាំង-សូវៀត ក៏កម្រិតចំណេះដឹងនៅមិនទាន់បានខ្ពស់ទេនៅកម្ពុជា។ អនក្ខរកម្មនេះមានច្រើន រហូតដល់ឆ្នាំ ១៩៦២ អត្រាអក្ខជននៅបឋមសិក្សាមានចំនួន ៥០% ប៉ុណ្ណោះ ពីពេលនេះមកកម្រិតកាន់តែកើនឡើង។ នៅមធ្យមសិក្សាលទ្ធផលជាបរិមាណល្អប្រសើរ តែការតម្រង់ទិសគុណភាពនៅខ្វះខាតច្រើន។ នៅឧត្តមសិក្សា សាស្ត្រចារ្យ ទាំងនិស្សិតគ្មានពេលគ្រប់គ្រាន់ធ្វើការស្រាវជ្រាវ និងសិក្សាទេ។

ការងារហ្វឹកហ្វឺនធនធានមនុស្ស នៅមានទំងន់ខ្លាំងច្រើនសម្រាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ។ ការតម្រង់ទិសអប់រំ ត្រូវពិនិត្រជាថ្មីត្រូវបម្រើសេចក្តីត្រូវការរបស់កម្ពុជាខាងអភិវឌ្ឍន៍សេដ្ឋកិច្ច។ កម្មវិធី និងរបៀបបង្រៀនត្រូវឃ្លាតឆ្ងាយពីគំរូបារាំង ដែលអប់រំកូនអភិជនការិយាធិបតេយ្យ គឺត្រូវតម្រង់មនុស្សឱ្យចេះធ្វើ ពលកម្ម ផលិតកម្ម តិចណូឡូស៊ីទំនើប ទើបឆ្លើយតបបាននឹងការវិនិយោគថ្មីៗ របស់ពួកវិនិយោគបរទេស។

ប្រទេសកម្ពុជា ស្ថិតនៅជាប្រទេសកសិកម្មយូរអង្វែង សាលាត្រូវហ្វឹកហ្វឺនមនុស្សដើម្បីកសិកម្ម ធ្វើជាកសិករទំនើប គឺមិនត្រូវបម្រើតែវណ្ណៈដូចលោក M.Dumont និយាយថានៅ Afrique គឺអប់រំសិក្សាសម្រាប់ចូលទៅធ្វើការនៅក្នុងដំណែងមន្ត្រីសាធារណៈនោះទេ។

ការតម្រង់ទិសអប់រំស្ថិតនៅលើចិត្តបំណងរបស់សិស្ស ដូចប្រទេសបារាំងនោះដូចនោះ គ្មានការបែងចែកវិជ្ជាជីវៈត្រឹមត្រូវទេមិនអាចបម្រើតាមតម្រូវការសេដ្ឋកិច្ចទេ។ ឧទាហរណ៍មាននិស្សិតជាច្រើននៅមហាវិទ្យាល័យអក្សរសាស្ត្រជាងនៅសាកលវិទ្យាល័យបច្ចេកទេស ដែលប្រទេសកម្ពុជាត្រូវការវិស្វករជាងអ្នកវិទ្យាសាស្ត្រ។ទន្ទឹមនឹងការអប់រំក្នុងវិស័យសិក្សាធិការ វិស័យសុខាភិបាលសាធារណៈ ជាវិស័យមួយសំខាន់ទៀតដែលអំណាចសាធារណៈបានខិតខំខ្លាំងក្លាដែរ។

## ៨.៣.វិស័យសុខាភិបាល

សកម្មភាពនៃអំណាចសាធារៈក្នុងវិស័យសុខាភិបាលសាធារៈមានសារៈសំខាន់លើពីរចំណុច។ ទីមួយ គឺការកសាងអាគារពេទ្យ ដែលមានសកម្មភាពខ្លាំងដូចមានតួលេខខាងក្រោម៖

| | ១៩៥៥ | ១៩៦៣ | ១៩៦៦ |
|---|---|---|---|
| មន្ទីពេទ្យ និងមណ្ឌលសុខាភិបាល | ១៥ | ៣៣ | ៤៣ |
| ឱសថាល័យ និងគិលានដ្ឋាន | ១០៣ | ៣២៥ | ៤០៨ |
| ប៉ុស្តិ៍សម្រាលកូនជនបទ | ៦០ | ៤១០ | ៦៤៤ |

ទីពីរ គឺការបណ្តុះបណ្តាលបុគ្គលិកពេទ្យ និងឱសថការី នៅក្នុងមហាវិទ្យាល័យវេជ្ជសាស្ត្រដែលបាន កសាងឡើងនៅឆ្នាំ ១៩៥៧ ទាំងនៅមហាវិទ្យាល័យឱសថសាស្ត្រ ដែលកសាងឡើងនៅឆ្នាំ ១៩៦១ និងនៅសាលាភូមិន្ទគិលានុបដ្ឋាក និងឆ្មបរដ្ឋ។ លទ្ធផលសកម្មភាពនោះមានដូចតទៅះ

| | ១៩៥៥ | ១៩៦៣ | ១៩៦៦ |
|---|---|---|---|
| គ្រូពេទ្យ | ៧៧ | ២១៩ | ៣៣៣ |
| ឱសថការី | ៤ ៦ | ៤៣ | |
| ទន្តពេទ្យ៣ | ៦ | ៤ | ៣ |
| គិលានុបដ្ឋាក និងយិកា | ៦៣០១ | ៥៥៤២ | ២១៤ |
| ឆ្មបរដ្ឋ | ៥២ | ១៦២ | ២២៤ |
| ឆ្មបជនបទ | ៧៣ | ៤៣៨ | ៦៤៤ |
| ភ្នាក់ងារសុខាភិបាល | ០១ | ១០ | ៣៧៧ |

តួនាទីឆ្មបជនបទ និងភ្នាក់ងារសុខាភិបាលមានការលើកទឹកចិត្តដោយឡែក។ ភ្នាក់ងារទាំងនេះមានថង់ឱសថ និងទោចក្រយាន ១គ្រឿង មានតួនាទីថែទាំស្ត្រីមានផ្ទៃពោះ ហើយជាអ្នកបង្កើតកូន និងថែរក្សាព្យាបាលជំងឺស្ត្រីភេទ។

អត្ថិភាពនៃឆ្មបជនបទ ជាកត្តាសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងការស្លាប់នាពេលឆ្លងទន្លេ និងមរណភាពនៃកុមារភាព ដែលមុននោះមានមរណភាព មានកម្រិតខ្ពស់នៅកម្ពុជា។ ភ្នាក់ងារសុខាភិបាលហ្វឹកហ្វឺននៅសាលាភូមិន្ទគិលានុបដ្ឋាកមានតួនាទីការពារជំងឺកុំឱ្យរាតត្បាត និងចម្លងដូចជា គ្រុនចាញ់ អ៊ុតស្វាយ របេង។

ការខិតខំនេះ បានប្រយុទ្ធប្រឆាំងនឹងជំងឺ និងមរណភាព ដែលធ្វើឱ្យមានការថយចុះ ខែអត្រាមរណះ ដល់ ១៨% " សម្រាប់ប្រជាជន ដែលមានអាហារហូបគ្រប់គ្រាន់ ។នៅមានការងារច្រើនទៀត ដែលត្រូវធ្វើ។

កាតព្វកិច្ច ដែលអំណាចសាធារណៈ បានខិតខំក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ សិក្សាអប់រំ សុខាភិបាល សាធារណៈ មានច្រើនណាស់។ ប៉ុន្តែការខិតខំខាងផលិតកម្ម ឬផលទុនជាតិ គឺជា

ការទទួលលទ្ធផលនៅពេលយូរ អង្វែង ។ កសាងផ្លូវ ហ្វឹកហ្វឺនមនុស្ស ឬ ព្យាបាលគេឱ្យជា ជាការងារអនាគត ។ អ្នកសេដ្ឋកិច្ចសន្និដ្ឋានថាវិស័យអប់រំ រីកចម្រើន ជាកត្តាកំណើនសេដ្ឋកិច្ច។ ការធ្វើឱ្យរីកចម្រើននូវ " ស្តុកទុនមនុស្ស " គឺជាការបង្កើននូវស្តុកប្រភពធនធានរូបនិយម ។

## ៨.៤.វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច

### ៨.៤.១.សកម្មភាពលើផលិតកម្ម

ការកើនឡើង និងការចែកជាផ្នែកនៃផលិតកម្មក្នុងរយៈពេលខ្លី ជាគោលដៅ នៃអំណាចសាធារណៈ។ រដ្ឋាភិបាល មិនដែលបង្កើតនូវលក្ខខ័ណ្ឌសម្រួលដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ផ្នែកឯកជន តាមរយៈនយោបាយ សេដ្ឋកិច្ចទេ។ ប៉ុន្តែរដ្ឋាភិបាលធ្វើសកម្មភាពប្រយោលដោយបង្កើតអង្គការ ឬសហគ្រាសនានា ដើម្បីបង្កើតនូវបទបញ្ញា បង្កើតនូវការត្រួតពិនិត្យ។ល។ សម្រាប់ធ្វើសកម្មភាពដោយផ្ទាល់ និងឆាប់រហ័សបំផុត លើផ្នែកផលិតកម្ម និងលើជីវភាព សេដ្ឋកិច្ចប្រទេស។ ដូចគេបានឃើញនៅក្នុងការងារពាណិជ្ជកម្មក្រៅប្រទេស យើងត្រូវមើលទៅវិស័យដទៃទៀត នូវបែបបទ និង ទំហំសកម្មភាពផ្ទាល់របស់អំណាចសាធារណៈ មានការប្រែប្រួលទៅតាមវិស័យ ហើយមានភាពល្អប្រសើរ នៅក្នុងវិស័យកសិកម្ម ហើយកាន់តែឃើញច្បាស់ថែមទៀត នៅផ្នែកឧស្សាហកម្ម និង សេវាកម្ម។

#### ក.សកម្មភាពកំណាបសារណៈនៅក្នុងវិស័យកសិកម្ម

នៅក្នុងវិស័យកសិកម្ម ដែលមានពលករជាង ៨០% នៃប្រជាជនសកម្ម ។ អំណាចសាធារណៈ បានខិតខំបង្កើនផលិតកម្ម និងបំបែកសាខាផលិតកម្មនោះទៀតផង។

សកម្មភាព មានរូបភាពបី ៖ រូបភាពប្រពៃណី រូបភាពផ្ទាល់ និង រូបភាពសហករណ៍ ។

#### ក.១ រូបភាពប្រពៃណី

ជាបឋម សេវាកម្ម នៃក្រសួងកសិកម្ម មានភាពសកម្មក្នុងវិស័យជាច្រើនគេអាចរាប់បានជាសំខាន់គឺ ៖

- ការសិក្សា និងស្រាវជ្រាវសមិទ្ធិផលសម្រេចបាន នៅផ្នែកនេះ គឺការធ្វើរូបថតបាន នូវទឹកដីកម្ពុជា ដែល អនុញ្ញាតឱ្យបង្កើតបាកនូវសារពើភ័ណនៃប្រភពធនធានព្រៃឈើ សេវាកម្មរុក្ខា ដែលបានរៀបចំឡើងវិញនៅឆ្នាំ ១៩៦៣ ហើយនិងវិជ្ជាស្ថានស្រាវជ្រាវ និងសិក្សាព្រៃឈើក៏បានត្រូវបង្កើតឡើងដែរ ការសិក្សាស្រាវជ្រាវអំពី ស្រូវ ជី ពូជ សត្វពាហនៈ និង តែ ក៏ត្រូវបានរៀបចំជាសហគ្រាស។

- ការប្រយុទ្ធទល់នឹងគ្រោះអាសន្ននៃជំងឺសត្វ " ប៉េស្ត សត្វពាហនៈ " និង ជំងឺរុក្ខជាតិ "កប្បាស " គឺត្រូវ បានណែនាំ ហើយទទួលបានលទ្ធលល្អលើវិស័យការពារជំងឺសត្វ។

- នយោបាយទឹករបស់ព្រះប្រមុខរដ្ឋ បានត្រូវក្រសួងកសិកម្មលើកទឹកចិត្ត និងដឹកនាំជីកព្រែក ប្រឡាយ ស្រោចស្រពលើកទំនប់ការពារទឹកជំនន់ ហើយពិសេសបង្កើតផ្ទៃប្រព័ន្ធ និងអាងផ្ទុកទឹកបញ្ចូលស្រែ។
- បង្កើនការហ្វឹកហ្វឺក ដើម្បីឆ្លើយតបទៅនឹងរបៀបដាំដុះ "ចម្ការគំរូ" បានបើកចំហឱ្យអនុវត្តន៍ការដាក់ជី ការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ ដល់កសិករឱ្យគេចេះប្រើប្រាស់ ។
- បង្កើតមជ្ឈមណ្ឌលទំនើបកម្មជនបទ ជាតំបន់គំរូ មានពីរកន្លែង ជាសេវាកម្មរបស់ក្រសួងកសិកម្ម និង អូរ៉ុក ដែលចូលកាន់កាប់ការងារផ្ទាល់នៅក្នុងដៃ ដែលមានប្រតិបត្តិការចាត់ចែងការងារ នៅក្នុងយុទ្ធនាការដាំដុះ តាមបច្ចេកទេសគំរូ។

### ក.២.រូបភាពផ្ទាល់

អំពើប្រព្រឹត្ត អំណាចសាធារណៈ ក្នុងវិស័យកសិកម្ម គឺមិនសុទ្ធតែធ្វើតាមផ្លូវប្រពៃណីងទេ គឺតាមរយៈ ការបង្កើតចម្ការរដ្ឋល់តែម្តងផងដែរ ។ ចម្ការកៅស៊ូរដ្ឋ បានត្រូវបង្កើតឡើងតាមរយៈជំនួយបច្ចេកទេស នៃក្រុមហ៊ុនចម្ការកៅស៊ូងកងកម្មួយ ក្រុមហ៊ុនកម្ពុជា ។ ចម្ការតែ ក៏បានបង្កើតឡើងដែរ គឺដាំបានជាង ៣០ ហិចតា នៅតំបន់កម្ពស់មធ្យម មណ្ឌលគិរី បូកគោ គិរីរម្យ ។ គម្រោងមួយទៀត ស្តីអំពីផលិតកម្ម ទឹកដោះគោឆៅ ដែលជាការ សិក្សារបស់ក្រុមហ៊ុនរដ្ឋមួយ ។

### ក.៣.រូបភាពសហករណ៍

ចុងក្រោយបំផុត រដ្ឋធ្វើអន្តរាគមន៍ក្នុងការរៀបចំ និងបង្កលក្ខណៈអភិវឌ្ឍន៍ចលនាសហករណ៍មួយ។ មន្ទីររាជសហករណ៍ Office Royal de Cooperative "O.R.O.C." បានបង្កើតនៅឆ្នាំ ១៩៥៦ បន្ទាប់ពីការបង្កើត នូវមន្ទីរឥណទានប្រជាជន។ នៅក្នុងអណត្តិ នៃលក្ខន្តិកៈបេសកកម្ម នៃអូរ៉ុក គឺត្រូវបង្កើតនិងចាត់ចែងសហករណ៍ ក្នុងគ្រប់វិស័យកសិកម្ម និង សេដ្ឋកិច្ចនៃព្រះរាជាណាចក្រ ស្តីអំពីឥណទាន ផលិតកម្ម និងការប្រើប្រាស់ គ្រប់គ្រង និងណែនាំសកម្មភាពសហករណ៍ដែលត្រូវរៀបចំសាខាផ្គត់ផ្គង់សម្ភារ ហិរញ្ញវត្ថុ ឱ្យដំណើរការប្រព្រឹត្តទៅ និងធ្វើប្រតិបត្តិការ ទិញ លក់ នាំចេញ នាំចូលក្នុងផលប្រយោជន៍សាខាសហករណ៍ ។

### ១.រចនាសម្ព័ន្ធ នៃចលនាសហករណ៍

ចាប់ពីឆ្នាំ ១៩៥៦ សហករណ៍ បឋម បានបង្កើតនៅកម្ពុជា តាមការផ្តួចផ្តើមរបស់អូរ៉ុក ដែលមានការ បង្កើតនូវសាខាខាខារបស់ខ្លួន។ សហករណ៍ប្រមូលផ្តុំឈរលើមូលដ្ឋានសុធន្ទៈ នៃអាជីវកម្មកសិកម្មតូចៗ។ ចំនួនសហករណ៍តូចៗនោះ មាឌមិនលើសពី ៣០០ ទេ ពីឆ្នាំ ១៩៥៨ មក ។ នៅពេលខ្លះចំនួនសហករណ៍ទៅទ្រឹង ហើយថយចំនួនទៀតផង ហើយចាប់ពីឆ្នាំ១៩៦៤ មានកើតចំនួនយ៉ាងរហ័សឡើងវិញ។

ការចាប់ផ្តើមដំបូង សហករណ៍ជាសហករណ៍ឧបភោគបរិភោគ តែចាប់ពី ឆ្នាំ១៩៦១ មកសហករណ៍ ទាំងនោះ បានក្លាយជាសហករណ៍មានមុខងារច្រើនប្រភេទ។ គេរាប់ឃើញមានសហករណ៍ពហុមុខងារនេះចំនួន ៥,៦១៣ ឆ្នាំ ១៩៦៦ ដែលមានសមាជិកចំនួនជាង

២០០,០០០ នាក់ ព្រមទាំងសហករណ៍ឧបភោគបរិភោគជា ៤០ និង សហករណ៍លិតកម្មឯកទេសជាង ១៥ ។

បន្ថែមលើសហករណ៍ "បឋម គេឃើញសហករណ៍ខេត្តចំនួន ១៨ ទៀត គឺខេត្តមួយមានសហករណ៍មួយ ។ សហករណ៍ទាំងនោះ មានសមាជិកលើសពី ១០០,០០០ នាក់ នោះសុទ្ធតែជាសហករណ៍ឥណទាន។

ក្រៅពីនោះ អ្ញ៉ុក បង្កើត និង គ្រប់គ្រងនូវសហគ្រាសមានលក្ខណៈជាឧស្សាហកម្ម និងពាណិជ្ជកម្ម ដូចជា សហគ្រាសកសិកម្ម យន្តកម្ម នៅបាត់ដំបង សំរាប់ផលិតកម្មស្រូវ និងចិញ្ចឹមសត្វ សេវាកម្មផ្គត់ផ្គង់ និង បែងចែក "S.A.D.I" តែ ផ្តាច់មុខ និង ការបែងចែកជីនាំចូល និង ផលិតផលប្រណិត សេវាកម្មប្រមូលទិញ ដឹកជញ្ជូន និង កែច្នៃតាមលក្ខណៈ ដែលទិញស្រូវកែច្នៃ ស្រូវ ជាអង្ករលក់ឱ្យសូណិចស៊ីម " S.A.T.R.A.R " សេវាកម្មប្រមូលទិញ កែច្នៃជាអង្ករដើម្បីលក់ឱ្យ សូណិចស៊ីម : សេវាទិញ កែច្នៃ និង ចរាចរត្រីសមុទ្រ " S.A.T.E.P " រោងចក្រត្បាញ កប្បាស " U.S.E.C.O.T " និង សេវាកម្មស្រាវជ្រាវ និង ជំនួយដល់ទំនើបកម្មជនបទ "S.R.A.P.M.O.R" ។

## ខ.សកម្មភាព នៃចលនាសហករណ៍

មិនមែនជារឿងងាយស្រួល ក្នុងការវាយតម្លៃ នូវគោលដៅសកម្មភាពនៃចលនាសហករណ៍នោះទេ ទោះ បីជាចលនា នៃសកម្មភាពនោះ មានការអភិវឌ្ឍន៍រហ័ស នៅក្នុងឆ្នាំចុងក្រោយនោះក៏ដោយ ។

ការតម្រង់ទិស ជាទូទៅ នៃសកម្មភាពរបស់អ្នក ហាក់ដូចជាមានការបញ្ជា ដោយការយកចិត្តទុកដាក់ ផ្នែកសង្គម ៖ រំដោះកសិករ ពីការគ្រប់គ្រងរបស់ពួកឈ្មួញ។ ដូចអ្នកឯកទេសបរទេសម្នាក់បានសរសេរថាអ្ញ៉ុកមានគោលដៅសំខាន់ គឺបង្កើននូវផលទុនរបស់ផលិតករ តាមរយៈការបន្ថយនូវឈ្មួញកណ្តាលនានា ដែលកាត់យក ផលចុងផលិតកម្ម ដោយបង្កើននូវផលិតភាពការងារ ។

សកម្មភាពនេះ បានជួបឧបសគ្គធំៗជាច្រើន ។ មួយចំណែកពួកពាណិជ្ជករ ដែលជាអ្នកប្រមូលទិញការ ប្រមូលផលផង ជាអ្នកលក់ទំនិញឧស្សាហផលផង និង ជាអ្នកមេបំណុលបណ្តាក់ចងការផង " មានមធ្យោបាយ ឧប់ទល់ យ៉ាងមានប្រសិទ្ធិភាព ។ ពួកគេមានលទ្ធភាពផ្តល់ឱ្យដល់ប្រជារាស្ត្រនៅជនបទ នូវអ្វីៗ ដែលកសិករត្រូវ ការ ក្នុងពេលដែលគេចង់បានបន្ទាន់ ដោយគ្មានបែបបទអ្វីទាំងអស់ គ្រាន់តែចុះកិច្ចសន្យា ហើយក្នុងថ្លៃខ្ពស់ ។ មួយ ចំណែកទៀត ទំហំនៃជោគជ័យរបស់ អ្ញ៉ុក និង ការអភិវឌ្ឍយ៉ាងរហ័ស នៃការទទួលខុសត្រូវ ធ្វើឱ្យការត្រួត ពិនិត្យនិងការអភិរក្សនូវសហករណ៍នានា និងសហគ្រាសគ្រប់គ្រងដោយ អ្ញ៉ុក បានតែលំបាកឡើងៗ ។ ហេតុ ដូច្នោះហើយ បានជាមុខងារផ្សេងៗ នៃចលនាសហករណ៍ មិនអាចបំពេញបានដោយប្រសិទ្ធិភាពឡើយ ។ គេអាច បែងចែកនូវមុខងារនោះ ដល់ទៅបួនយ៉ាង ។

ជាបឋមអូរ៉ុក ដើរតួនាទីចំពោះសមាជិកសហករណ៍ និងសហករណ៍នូវការផ្តល់ជំនួយខាងបច្ចេកទេស។ ភ្ជាក់ងាររាប់រយនាក់ ខិតខំជួយពត៌មាន ឃោសនា បណ្តុះបណ្តាល កសិករជាសមាជិកសហករណ៍ ។

ទីពីរ ស្ថាប័នសហករណ៍បម្រើ ជាអ្នកផ្សាភ្ជាប់ជាឈ្មួញកណ្តាល ដើម្បីលក់ឱ្យកសិករនូវឧស្សាហផល ទំនិញ ប្រើប្រាស់ ឧបភោគបរិភោគ ៖ ទឹកដោះគោ សាប៊ូ ក្រណាត់ ។ល។ និងទំនិញបម្រើការផលិត ៖ ជីគីមី បារ ស៊ីម៉ង់ ដែកសំណង់ ។ល ។ ក្នុងការប្រែក្លាយជាសហករណ៍មានមុខងារច្រើនបែប សហករណ៍ឧបភោគបរិភោគ ក៏មិនភ្លេច មុខងារទីមួយដែរ ៖ គឺបើហាងធំៗដែលនៅទីនោះ សមាជិកអាចទិញក្នុងតម្លៃសមស្រប នូវអ្វីដែលគេត្រូវការ ។អូរ៉ុក អន្តរាគមន៍ដូចពួកឈ្មួញធំៗ ដោយប្រមូលទិញនូវផលិតផលឱ្យ សូណិចស៊ីម ហើយលក់ នូវអ្វីៗ ទៅ សហករណ៍បឋម ហើយក៏នៅបានប្រគល់ផ្ទាល់ ដល់អ្នកទិញដែលមិនមែនជាសមាជិកសហករណ៍នូវទំនិញដែលបាន ដាក់លក់នៅតាមហាង ឬ អាគារប្រជាជននានា ។ តួលេខនៃផលរបរនៃការលក់ ហាក់ដូចជាទ្រឹង នៅជុំវិញ ១០០ លានរៀល គឺជាចំណែក ប្រាក់តិចតួចណាស់ ប្រៀបនឹងការទិញសរុបរបស់កសិករ ។ តម្លៃសរុប ៖ មិនទាន់បាន បញ្ជាក់ច្បាស់នៅឡើយ តែ មានចំនួនមិនតិចជាង ៥,០០០ លានរៀលឡើយ ។

ទីបី អូរ៉ុក អន្តរាគមន៍ក្នុងការធ្វើពាណិជ្ជកម្មកសិផល ដែលប្រមូលបានដោយ សាត្រា ។ សហករណ៍បឋម ដែលក្នុងចំណែកដ៏ធំរបស់ខ្លួន មានមធ្យោបាយស្តុក អាចប្រមូលទិញកសិផលទាន់ពេល ប្រមូលផលនិង ជានាបាន ដល់ការលក់ តួលេខនៃផលរបរសហករណ៍ទាំងនោះ បានកើនឡើងរហ័ស ដល់ជាង ២០០ លានរៀលនៅឆ្នាំ១៩៦៥ នៅឆ្នាំ ១៩៦៦ តួលេខនោះ ចុះមកវិញខ្លះ ហើយនៅឆ្នាំ ១៩៦៧ មានការលោតផ្លោះឡើងវិញគួរឱ្យកត់សម្គាល់ ។ បរិមាណកសិផលដែលទិញបានកម្រិតណា បានត្រូវលក់ទៅវិញ ក្នុងកម្រិតដែលបានទិញពីកសិករដែរ ព្រោះគេឥតបាន សន្សំសំចៃទុកទេ ។ ភាគចំណែក នៃការប្រមូលផល ដើម្បីធ្វើពាណិជ្ជកម្ម ដោយសហករណ៍ លេចឡើងនៅចុង បញ្ចប់ ដូចជាខ្សោយទៅឡើយ តែក៏កើនឡើងរហ័សណាស់ដែរ ។

នៅចុងបញ្ចប់អូរ៉ុកធ្វើការងារក្នុងផ្នែកឥណទានហើយនោះជាមុខងាររបស់គេដែលមានសារៈសំខាន់ ។ ក្រៅពីការឱ្យខ្ចី ពិសេស " ទៅដល់សហគ្រាសរបស់អូរ៉ុក ជាឧទាហរណ៍ " ការខ្ចីបុលយល់ព្រមពីមន្ទីរ អូរ៉ុក មានពីរ ប្រភេទ ។ ចំណែកទីមួយ មន្ទីរអូរ៉ុក ឱ្យខ្ចីទៅសហករណ៍ខេត្តដែលសុទ្ធតែជាសហករណ៍ឥណទាន ហើយសហករណ៍ ក៏បានផ្តល់ការខ្ចីទៅឱ្យសមាជិកខ្លួនជាបន្តទៀត ។ ដោយឡែក មន្ទីរអូរ៉ុកឱ្យខ្ចីដល់សហករណ៍ដែលមានមុខងារ ច្រើនប្រភេទ ដែលឱ្យខ្ចីបន្តទៀតដល់សមាជិកខ្លួន ។ ការប្រើប្រាស់តួនាទីជាធនាគារ " បច្ចេកទេសនឹងស្មុគស្មាញ"។ ប្រព្រឹត្តទៅដោយមានបញ្ហាជាច្រើនអំពីការបែងចែកឥណទាន និង ការទារប្រាក់មកវិញ ។

## ៨.៤.២.សកម្មភាពនៃអំណាចសាធារណៈក្នុងវិស័យឧស្សាហកម្មនិង ពាណិជ្ជកម្ម

### ក.សកម្មភាពឆ្ពោះទៅរកផ្នែកឯកជន

គេជាកឃើញនៅក្នុងផ្នែកឯកជន មានសារៈសំខាន់ខ្លាំងជាងផ្នែកសាធារណៈ ទាំងបៀវត្សរ៍ដែលបានបែងចែកក៏ដូចជាតម្លៃបន្ថែមដែលបានរួមវិភាគទានដល់ចំណូលថវិកា ហើយក៏ជាទឡ្ហីកម្ម ដែលបានបញ្ជាក់នៅក្នុង ទសវត្សកន្លង នូវថាមពលគួរឱ្យកត់សម្គាល់ ។ ជារួម កម្ពុជាមិនខ្វះពួកសហគ្រិនទេ ហើយពួកគេះ មានសញ្ជាតិជា ចិន ជាវៀតណាម និង ជាខ្មែរ ។ ពួកសហគ្រិនទាំងនេះជាពាណិជ្ជករ ។ ប៉ុន្តែពួកគេមិនសុទ្ធតែចេញមកពីពាណិជ្ជករ នោះទេ ហើយក្នុង ចំណោមពួកគេបានបង្កើតនូវរោងជាង ឬ ក៏រោងចក្រតូចៗ មានលក្ខណៈជាឧស្សាហកម្ម ។

ប៉ុន្តែ នយោបាយរដ្ឋាភិបាលកម្ពុជាពេលនោះ ចំពោះពួកគេដូចជាមិនសូវច្បាស់លាស់ពាក្យដែលត្រូវដាក់ ឱ្យចំនយោបាយនោះ គឺការអនុគ្រោះ ការពិត ផ្នែកឯកជន ស្ថិតនៅក្នុងភាពអនុគ្រោះ តែមិនត្រូវបានលើកទឹក ចិត្តពិតប្រាកដទាំងស្រុងទេ ។

ពិតហើយ សហគ្រាសឯកជនមួយចំនួនបានទទួលការខ្ចីទុនពី Caisse Nationale d' Equipment ព្រម ទាំងការយកពន្ធ និង ច្បាប់គយ ។ ពិតហើយ អំណាចសាធារណៈ បានខិតខំផ្តល់ការធានាទល់និងជាតូបនីយកម្ម ដោយឱ្យនិយម័យឧស្សាហកម្ម ដែលនៅក្នុងផ្នែកសាធារណៈ ឧស្សាហកម្មអាវុធ ថាមពល ទឹក សំណង់ ទិព្វ សម្ភារធុនធ្ងន់ សម្រាប់សំណង់ " និង ផ្នែកឯកជន " ទំនិញប្រើប្រាស់សម្ភារធុនស្រាល សម្រាប់សំណង់ " ។ ប៉ុន្តែ ការផ្តល់និយមន័យនេះមិនគ្រប់គ្រាន់ ហើយក៏មិនច្បាស់លាស់ដែរ ។ ការរាយបញ្ជីឈ្មោះក៏មានការលើកលែង ដែល ធ្វើឱ្យខ្វះសេចក្តីទុកចិត្តរបស់អ្នកវិនិយោគ ។ មួយចំណែកទៀត រដ្ឋកាន់នៅក្នុងដៃនូវពាណិជ្ជកម្មក្រៅប្រទេស ចាប់តាំងពីការធ្វើជាតូបនីយកម្មមក ។ ពួកឧស្សាហករសក្តានុពល ដែលចំណុះទៅលើការនាំចូល ជានិច្ចកាល មានការ សង្ស័យ ។ ពួកសង្ស័យក្នុងការ បដិសេធមិននាំចូលផ្លូវវត្ថុជាតុដើម ឬ គ្រឿងបន្លាស់ ដែលធ្វើឱ្យម៉ាស៊ីន រោងចក្រ របស់គេ មិនដំណើរការងាយស្រួល ។

ជាព្រឹត្តការណ៍ នោះជាកិច្ចការនៃបរិយាកាសចិត្តសាស្ត្រក្នុងវិស័យនេះ ។ ហើយការយោគយល់ដែលកើត មានហាក់ដូចជាសមស្រប ចំពោះសហគ្រាសឯកជន ហើយជំនឿនោះមានការថយចុះ នៅឆ្នាំបន្តបន្ទាប់មក ។ ពាក្យថា "ចំណេញ " ដូចជាមិនសូវយកចិត្តទុកដាក់ទេ ហើយក៏មិនបានគិតគូរផងដែរ ។ ទោះបីជាយ៉ាងណា ពួកសហគ្រិនសង្ស័យថា ជាតូបនីយកម្មនោះជាខណ្ឌកម្មនៃលទ្ធផលរបស់ពួកគេ ។ បរិយាកាសមិនទុកចិត្តនោះរហើយ ដែលពន្យល់បាននូវភាពយឺតយ៉ាវនៃការវិនិយោគ ផ្នែកឯកជំងឺ ក្នុងបណ្តាឆ្នាំចុងក្រោយ ។

គេកត់សម្គាល់ថា ការវិនិយោគឯកជនបរទេសក៏មានមតិដូចនោះដែរក៏មិនគិតពីការវិនិយោគ នៅកម្ពុជា ទេ លើកលែងតែការវិយោគ ដែលអនុវត្តដោយពួកម្ចាស់ចម្ការកៅស៊ូដែលជំហរនយោបាយ បានត្រូវចាត់ទុកជា ពិសេស ។ ពួកមូលធនបរទេស មិនបានឃើញបរិយាកាស នៃជំនឿ ដែលគេសង្ឃឹមទុកជាកត្តាចាំបាច់ ដើម្បី សម្រេច ចិត្តវិនិយោគនៅកម្ពុជាឡើយ ។

ជាអត្ថន័យស៊ីជម្រៅបើសិនពួកមូលធនឯកជន គ្មានជំនឿលើរដ្ឋអំណាចសាធារណៈទេនោះ គឺមានន័យថា អំណាចនោះ គ្នាជឿលើពួកមូលធនឯកជនដូច្នោះដែរ ។ រាជរដ្ឋាភិបាលកម្ពុជាពេលនោះ គិតហើយនិយាយថា គេមិនបានគិតដល់យន្តការមូលធននិយម ដើម្បីជំរុញនូវការអភិវឌ្ឍដោយរីករាយរបស់ប្រទេសឡើយ ។ នោះជា ទស្សនៈការពារនិយមទេ បំណង គឺឱ្យតួនាទីសាធារណៈមានសារៈសំខាន់ជាង។ អ្វីដែលអំណាចសាធារណៈ បានគិតនៅកម្ពុជា គឺបញ្ជាក់នូវសកម្មភាពរបស់ខ្លួន ឆ្ពោះទៅផ្នែកឯកជននោះហើយ ។

### ខ.សកម្មភាពឆ្ពោះទៅផ្នែកសាធារណៈ

ផ្នែកសាធារណៈ និង ពាក់កណ្តាលសាធារណៈ បានទទួលរ៉ាប់រងពីអំណាចសាធារណៈ បានចូលរ៉ាប់រងពី អំណាចសាធារណៈ និង សារៈសំខាន់របស់ផ្នែកនោះ បានកើតឡើងក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ។ ផ្នែក សាធារណៈ ជាកត្រូវរៀបចំឡើង ហើយមានការអភិវឌ្ឍតាមរូបភាពជាច្រើន ។ គេអាចរាប់បានដូចតទៅៈ

- ការប្រមូលទិញទាំងអស់ ឬ ភាគខ្លះនៃភាគហ៊ុនសហគ្រាស ដែលមានស្រាប់ដូចការទិញយក សហគ្រាសសុរាតារខ្មែរ "S.ED." អគ្គិសនីកម្ពុជា និង កម្មន្តផលិតបារីនៅកម្ពុជា "M.A.C," ។
- អំណោយបរទេស ពិសេសពីប្រទេសចិន : សហគ្រាស ៥ បានត្រូវបង្កើតឡើង ក្រុមហ៊ុនជាតិ ក្រដាស "SONA PAP" ក្រុមហ៊ុនជាតិក្តារបន្ទះ ក្រុមហ៊ុនជាតិស៊ីម៉ង់ ក្រុមហ៊ុនវាយណភ័ណ្ឌ រោងចក្រកែវ នៅស្ទឹងមានជ័យ ជិតភ្នំពេញ ។
- ការខ្ចីបុលបរទេស ពីប្រទេស ឆេកូស្លូវ៉ាគី និង គ្រឿងបន្លាស់ ពីបារាំង។ បានលក់ឥណទានរយៈពេលវែង គឺរោងចក្រស្ករកំពង់ត្រាំរោងចក្រតម្លើងត្រាក់ទ័រ រោងចក្រផលិតកង់រថយន្ត។ បារាំងផ្តល់ហិរញ្ញវត្ថុ ដូចគ្នាដល់រោងចក្រត្បាញកប្បាស រោងចក្រចម្រាញ់ប្រេងកាត ផ្លូវរថភ្លើង ភ្នំពេញ-ក្រុងព្រះសីហនុ ។
- ការកសាងនូវសហគ្រាសថ្មីៗដូចជាការវិនិយោគផ្ទាល់ដូចជារោងចក្របាវក្រចៅបាត់ដំបង"aok jute" ឬ រដ្ឋសណ្ឋាគារនៅភ្នំពេញ ឬ ជាទូទៅការចូលហ៊ុនជាមួយទុនឯកជន ក្នុងក្របខ័ណ្ឌ នៃក្រុមហ៊ុន សេដ្ឋកិច្ចចម្រុះ ដូចជាករណីអាកាសចរកម្ពុជា " មានការចូលភាគហ៊ុមពីអាកាសចរ បារាំង +សព្វថ្ងៃ R A C / ក្រុមហ៊ុនឧទ្ធម្ភាចក្រម៉ាឡេស៊ី " ក្រុមហ៊ុនខ្មែរ អុកស៊ីហ្សែន អាសេឌីឡែន "SOKOA" ដែលមានចូលរួមពី L' Air Liguide
- ក្រុមហ៊ុនខ្មែរ ម៉ូតែល សណ្ឋាគារ "deo ause Royaler" Solar " ក្រុមហ៊ុនសញ្ញាតារ

សៀមរាប កសាងសណ្ឋាគារនៅតាកែវ ក្រុងព្រះសីហនុ ពោធិចិនតុង " រោងចក្រជីហ្វូស្វាត "SOK PHOS" រោងចក្រ បាវក្រចៅ និង រោងចក្រស្រាបៀអង្គរ នៅក្រុងព្រះសីហនុ ។

គេអាចនិយាយបានថា អំណាចសាធារណៈ បានបូជានូវការខិតខំយ៉ាងធំធេង ក្នុងវិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម ដើម្បីជំនួយពួកមូលធននិយម ដែលត្រូវបានវិនិច្ឆ័យថាមានគ្រោះអាសន្ន ការខិតខំនោះ បានទទួលនូវជោគជ័យក្នុងទិសដៅនោះដែលនាំទៅដល់ការបង្កើតឡើងនូវវិស័យសាធារណៈដ៏មានសារៈសំខាន់។

វិស័យនេះ ក៏មិនមែនគ្មានការចោទឡើងនូវបញ្ហាជាច្រើននោះដែរ ។ បញ្ហាធំ គឺលិទ្ធផលនៃសហគ្រាសទាំងនោះ ដែលបង្កើតឡើងដោយរដ្ឋ ។ គេហាក់ដូចជាខ្វះនូវការសង្កេតលើប្រធានបទនេះ ព្រោះសហគ្រាសមួយចំនួន មិនអាចរៀបចំបញ្ជីគណនេយ្យធម្មតារបស់ខ្លួនបាន ។ ប៉ុន្តែក៏នៅមានសហគ្រាសរកស៊ី បានចំណេញខ្លាំងដែរ ដូចជា: SOKHA, MIAC, EDC រដ្ឋសណ្ឋាគារ SOVATEX ។ ល ។ ក្រុមហ៊ុនដែល មានឱន ភាពថវិកា គឺ SONA និង SONA PAP ។ល ។ ហើយក៏មានសហគ្រាសរកស៊ីអាជីវកម្មផ្ដាច់មុខ ហើយចំណូលក៏ត្រូវបានបង់ជូនរដ្ឋ ដូចករណី S.N.A S.A.D.និង រោងចក្រស៊ីម៉ង់ ជាដើម ។

ការលំបាកជាច្រើនដែលសហគ្រាសសាធារណៈ កើតឡើងដោយមូលហេតុពីរ ដែលភ្ជាប់និងការដាក់ទីតាំង ដោយចៃដន្យ និង ការគ្រប់គ្រងមិនជិតដល់ ។

ការកសាងរោងចក្រមួយ គឺមិនសូវបានគិតដល់ការសិក្សាសេដ្ឋកិច្ចជាមុខ ដោយមិនគិតដល់ផងដែរ អំពី ផលប្រយោជន៍ "Utilite" នៃតម្រូវការ "demande" នៃផលិតផលការគិតដល់ទំហំនៃរោងចក្រសេចក្ដីត្រូវ ការ នូវរូបិយប័ណ្ណ ។ល ។ ឧទាហរណ៍ គឺរោងចក្រតម្លើងត្រាក់ទ័រកសិកម្ម ពេលតម្លើងរោងចក្ររួចហើយយល់ថា កម្ពុជាមានស្រែដែលមានស្ថានភាពតូចៗ ដែលមិនត្រូវការត្រាក់ទ័រធំៗ ហើយត្រាក់ទ័រដែលតម្លើងនៅទីនោះថ្លៃជាងត្រាក់ទ័រ ដែលមានផ្លាក " marque " ដូចគ្នានាំចូលទៅទៀត ។ រោងចក្រក្ដារបន្ទះសង់ឡើងមិនអាច បញ្ចេញទាន់ពេលបាន ហើយថ្លៃដើមកាន់តែឡើងធ្ងន់ធ្ងរ ។ រោងចក្រ កង់រថយន្ត ក៏សាងឡើង ដោយមិនបានសិក្សា ស៊ីជម្រៅពីតម្រូវការ " demande " កង់រថយន្តនៅកម្ពុជា វាហាក់ដូចជាបំពេញបានតែឱកាសនិយម នៃការបោះទីតាំងរោងចក្រចម្រាញ់ស្ករស ដែលកែច្នៃស្ករត្នោត ៩៦% ដែលអាចប្រើប្រាស់បាននូវស្ករសក្នុងកម្រិត៩៨% ក៏បានដែរ ។ សរុបមក គឺការជ្រើសរើស ការវិនិយោគ ដែលជាបញ្ហាធំ ចំណេញខាត មានភាពស្មុគស្មាញ លើបញ្ហាទ្រឹស្ដី នៃការអភិវឌ្ឍ ដែលនៅកម្ពុជា ការប្រព្រឹត្តទៅបែបនេះ មិនបាវិទ្យាសាស្ត្រនៅឡើយ ។ ការជ្រើសរើសបើមិនត្រូវ ទៅដល់នូវការលំបាក ក្នុងការគ្រប់គ្រងសហគ្រាស នោះឯង ។

ការគ្រប់គ្រងនូវសហគ្រាសខ្លះៗនៃសាធារណៈ ឬ ពាក់កណ្ដាលសាធារណៈ ពេលខ្លះ គឺទុកបណ្ដោយតាម យថាផល ។ ការខ្វះនូវបញ្ជីគណនេយ្យ រាំងស្ទះដល់ការបញ្ជាក់នូវកំហុសឆ្គងនៃការគ្រប់គ្រង ដែលបញ្ជាក់ថា ជា ការគ្រប់គ្រងដ៏អាក្រក់ ។ ការអវត្តមាន នៃគណនេយ្យ វិភាគថ្លៃដើមលើបញ្ហានេះ ក៏ត្រូវបានកត់សម្គាល់ឡើងដែរ ។ មន្ត្រីនិយម ដែលខ្វះការចេះដឹងខាងច្បាប់ សេដ្ឋកិច្ច ជាអធិភាពនៃការគ្រប់គ្រងសហគ្រាស ឧទាហរណ៍ ដូចជា ការបើកការិយាល័យប្រមូលទិញកប្បាស នៃរោងចក្រតម្បាញដែលកម្រិតម៉ោងពេលធ្វើការ បង្ខំឱ្យកសិករលក់កប្បាស ទៅឱ្យឈ្មួញក្នុងថ្ងៃទាបជាង ជាជាងរង់ចាំយូរថ្ងៃ ។

ចុងបញ្ចប់ ការសង្ស័យខាងទិន្នផល គឺគេមិនយកចិត្តទុកដាក់ដែរ ។ ពេលខ្លះគេបំប៉ោងបញ្ជីឈ្មោះ កម្មករ ដើម្បីលួចបើកបៀវត្សរ៍បន្ថែម ។ ជាលទ្ធផល សហគ្រាសដែលទទួលបានទិន្នផលល្អ លុះណាតែ គ្រប់គ្រងដោយផ្នែក ឯកឯន។ ភោជនីយដ្ឋានរាំវែក របស់រដ្ឋ ដែលប្រគល់ឱ្យឯកជនគ្រប់គ្រង ទើបរកចំណូលបាន ទោះបីការផ្តាច់មុខ ក៏ដោយ ។

ទោះបីយ៉ាងណា ផ្នែករដ្ឋ សហគ្រាសរដ្ឋ ឬ ចម្រុះរដ្ឋឯកជន ក៏គ្រប់គ្រងបានល្អដែរ នៅមានការខិតខំកែលម្អ ការគ្រប់គ្រងផ្នែករដ្ឋនោះខ្លាំងក្លាដែរ ។ មតិខ្លះថា ផ្នែកនេះខ្វះបុគ្គលិកមានគុណភាព និង ស្មោះត្រង់ ដែលនៅកម្ពុជា មាន និយោជិក និង អ្នកដឹកនាំនយោបាយ ដឹកនាំផ្នែកនេះ ។

គេឃើញរដ្ឋអំណាចសាធារណៈ មិនស្ថិតនៅអសកម្មទេ ក្នុងវិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម ដែលនៅ បានបំពេញបន្ថែមនូវចំណុចខ្វះខាតជាច្រើន ដោយមានការចូលរួម ពីផ្នែកឯកជនផងដែរ ។

សកម្មភាពអំណាចសាធារណៈ ក្នុងវិស័យផែនការហេដ្ឋារចនាសម្ព័ន្ធ និង ផលិតកម្ម បង្កើតបានជា នយោបាយ សេដ្ឋកិច្ចរបស់រដ្ឋាភិបាលកម្ពុជា ។ ការវិភាគលើផ្នែកហិរញ្ញវត្ថុ ជាជំនួយដល់ការសិក្សានយោបាយសេដ្ឋកិច្ច ។

# មេរៀនទី ៩
# ប្រព័ន្ធសារពើពន្ធកម្ពុជា

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ប្រភេទពន្ធនានា
- ចំណូល ចំណាយថវិកាជាតិ
- កំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គោលនយោបាយសារពើពន្ធ

នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ប្រព័ន្ធសារពើពន្ធ ជាប្រព័ន្ធដែលមានសារៈប្រយោជន៍យ៉ាងខ្លាំងក្នុងការធ្វើ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ ការធ្វើប្រតិបត្តិការនៃគោលនយោបាយ សារពើពន្ធ គឺ ជាការគ្រប់គ្រង និង ចំណាយរបស់សេដ្ឋ កិច្ចមួយដើម្បីអោយមានភាពសមស្របទៅតាមចំនួនថវិការជាតិ ។

ក្នុងឆ្នាំ ២០០៩ ប្រទេសកម្ពុជា បានធ្វើប្រតិបត្តិការ គោលនយោបាយ សារពើពន្ធ ដែលមានលក្ខណៈពង្រីកដោយ មានការចំណាយថវិកាជាតិច្រើន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលទើបតែងើបផុតពីឥទ្ធិពលនៃវិបត្តិនៃសេដ្ឋកិច្ច ពិភពលោកក្នុងឆ្នាំ ២០០៨-២០០៩ ។ នៅក្នុងឆ្នាំ ២០១០ គោលនយោបាយរបស់រាជរដ្ឋាភិបាល ទៅលើប្រព័ន្ធសារពើពន្ធ មាន លក្ខណៈបង្រួមមកវិញ( fiscal contraction )។

សកម្មភាព នៃអំណាចសាធារណៈជាការបកស្រាយនូវវិស័យហិរញ្ញវត្ថុដោយជៀសមិនផុត។សមិទ្ធិផលនីមួយៗមានជាប់ទាក់ទងនឹងការចំណាយមួយឬច្រើន ដែលត្រូវបែងចែកចំណាត់ថ្នាក់តាមរូបភាពផ្សេងៗ។សំណុំនៃចំណាយតាមរូបភាពណាក៏ដោយក៏ត្រូវតែបិទ។ ការលំបាកនៃការប្រមូលការយល់ដឹងឱ្យបានច្បាស់ តាមតួលេខនៃចំណូល និង ចំណាយរបស់កម្ពុជា មានលក្ខណៈដូចតទៅ :

ទីមួយ គឺរក្សាការពារថាជារដ្ឋ ។ រដ្ឋកម្ពុជាក៏ដូចជារដ្ឋដ៏ដទៃដែរ បង្ហាញតាមរយៈរូបភាពផ្សេងៗ ដែលផ្នែក ទីមួយៗ មានគណនេយ្យ ហិរញ្ញវត្ថុរៀងៗខ្លួន ។ នៅក្បែររដ្ឋ មានការបំបែកជាសមូហភាពដែនដី ខេត្ត ឃុំ ក្រុង ស្វយ័ត គ្រឹះស្ថានសាធារណៈ រដ្ឋបាល អង្គការចូលនិវត្តន៍ និង ចំណូលផ្ទាល់ខ្លួន ចំណូលរបស់ផ្នែក មួយអាចចំណាយ របស់ផ្នែក មួយទៀត ។

ទីពីរ ជាសភាពស្មុគស្មាញ មកពីព្រឹត្តិការណ៍ នៃថវិកាជាតិ ដែលគោលការណ៍ប្រមូលផ្តុំឡើងវិញនូវចំណូល និង ចំណាយទាំងអស់ ដែលមុខនោះមិនបានចុះបញ្ជីត្រឹមត្រូវ មុខនេះជំនួយបរទេសដែលមានតួនាទីសំខាន់ ក៏មិន បានចុះ ក្នុងបញ្ជីគណនេយ្យ ថវិកាដែរ បន្ថែមលើនោះ ចំណូល មួយចំនួន ត្រូវ បានប៉ះពាល់ផ្ទាល់ ដោយសារ មធ្យោបាយ គណនេយ្យ នៃរត

នាគារ ។ការវិភាគថវិកាមិនបានផ្តល់រូបភាពត្រឹមត្រូវថាជាសំនុំនៃហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសនៅឡើយ ។

ទីបី ស្ថិតិប្រតិបត្តិការ ជាកិច្ចការលំបាកក្នុងការប្រមូលផ្តុំ មិនត្រឹមតែនៅសមូហភាពដែនដីនោះទេ ថវិកា ស្វយ័តនៃគ្រឹះស្ថានសាធារណៈ ក៏ដូចគ្នាដែរ ។ ជាអនុភាពថវិកា គឺជាការអនុញ្ញាត នៃការគ្រោងទុកដែលមិនបាន គោរពទាល់តែសោះ។ កិច្ចប្រតិបត្តិការថវិកា ក៏មិនទាន់បានផ្សព្វផ្សាយផ្លូវបាយការណ៍ទៀត ។

គេអាចនិយាយបន្ថែមថា តួលេខដែលបានចុះបញ្ជី គឺប្រមូលផ្តុំចំណុចទៅនិងលក្ខណៈការនិតិសាស្ត្រ ចំណូលបានត្រូវចាត់ថ្នាក់ តាមបែបនៃការកំណត់ពន្ធ ហើយការចំណាយ យោងទៅតាមរដ្ឋមន្ត្រី ដែលជាអ្នក ចំណាយ" ការធ្វើចំណាត់ថ្នាក់បែបនោះ នាំឱ្យមានការលំបាក និងគ្មានការលទ្ធភាព ដើម្បីចាត់ថ្នាក់ជាថ្មីទៀត តាមលក្ខខ័ណ្ឌសេដ្ឋកិច្ច ដែលមានសារៈសំខាន់ ដល់ការវិភាគសេដ្ឋកិច្ច ។

ដើម្បីឱ្យមានគំនិតត្រឹមត្រូវ ចំពោះហិរញ្ញវត្ថុសាធារណៈក្នុងសម័យនោះ ឱ្យមានសារៈប្រយោជន៍ គេចាំ បាច់ប្រមូលផ្តុំឡើងវិញ ហើយ "ដោះស្រាយ នូវតួលេខជាច្រើន ដែលភាគច្រើនមិនបានផ្សព្វផ្សាយ ។ ការងារដ៏ ធ្ងន់ធ្ងរនោះ បានប្រព្រឹត្តទៅសម្រាប់ឆ្នាំ ១៩៦២-១៦៣ និង ឆ្នាំ ១៩៦៤ តាមរយៈម្ចាស់គណនេយ្យសេដ្ឋកិច្ច ។ យើងក៏នៅបានគូសវាសនូវ តួលេខពន្ធអាករជាតិ លើកលែងតែពន្ធអាករ របស់សមូហភាពដែនដី នាឆ្នាំ ១៩៥៧ - ១៩៦៥ ។ តាមតួលេខនោះហើយ ដែលយកមកធ្វើជាមូលដ្ឋាន ដើម្បីសាកល្បងជាបន្តបន្ទាប់ នូវការចំណាយជាសាធារណៈ ចំណូលសាធារណៈ និង បញ្ហានានានៃថវិកាជាតិ ។

## ៩.១.ចំណូល-ចំណាយថវិកាជាតិ

ដើម្បីសិក្សានូវការចំណាយសាធារណៈ គេរក្សាទុកនូវពាក្យថា ការប្រើប្រាស់របស់រដ្ឋបាលតាម គណនេយ្យ ជាតិមួយដូចនិយមន័យបានបញ្ជាក់ គឺមានអត្ថន័យជាទូទៅរបស់រដ្ឋ ។ ជាពាក្យសេដ្ឋកិច្ច ហើយមិនមែនផ្នែក និតិសាស្ត្រទេ ។ នោះជាផលប្រយោជន៍របស់ជាតិ ។

ការចំណាយរបស់រដ្ឋបាល អាចចាត់ថ្នាក់តាម ធម្មជាតិរបស់វា ឬ តាមមុខងារ ។

### ៩.១.១.ការចំណាយតាមហិរញ្ញវត្ថុ

ការចំណាយរដ្ឋបាល មានរូបភាពអ្វីខ្លះ ? ជាប្រពៃណី គេបែងចែករវាងការចំណាយនៃការប្រព្រឹត្តិទៅ របស់រដ្ឋបាល និង ចំណាយបំពាក់សម្ភារ។ គិតជាភាគរយនៃការចំណាយសរុប។

| ប្រភេទចំណាយ----ឆ្នាំ | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ការចំណាយសម្រាប់ការប្រព្រឹត្តិទៅ | ៧៩ | ៧៧ | ៨០ |
| ការចំណាយសម្រាប់សម្ភារ | ២១ | ២៣ | ២០ |

ភាគចំណែក នៃការចំណាយនៃការប្រព្រឹត្តទៅរបស់រដ្ឋបាល លើចទ្បើងជាភាគដ៏ធំនៅកម្ពុជា ព្រោះការ ចំណាយ មានចំនួនជាង ៣/៤ នៃការចំណាយរដ្ឋបាល ។

ការចំណាយ នៃការប្រព្រឹត្តទៅរបស់រដ្ឋបាល គឺជាការសំខាន់ សម្រាប់ជាបៀវត្សរ៍ បើកឱ្យមន្ត្រីរាជការ ដែលមាន កម្រិតប្រហែលពាក់កណ្តាល នៃការចំណាយសរុបនៃរដ្ឋបាល ។ ជាតួលេខខ្ពស់បំផុត ។ នៅប្រទេសអភិវឌ្ឍន៍មូលធននិយម គេបានឱ្យតម្លៃទៅលើការចំណាយបៀវត្សរ៍ខ្ពស់ ថាជាគោលការណ៍ មួយខែមធ្យោបាយសកម្មភាព សេដ្ឋកិច្ច និង សង្គម ។

ការចំណាយបំពាក់សម្ភារជាការវិនិយោគរដ្ឋបាល ដែលឆ្លុះបញ្ចាំងនូវការខិតខំសម្រេចបានក្នុងវិស័យ ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារសង្គម។ ពាក់កណ្តាល នៃការចំណាយវិនិយោគគឺប្រព្រឹត្តិទៅនៅក្នុងសាធារណៈការការកសាង សំណង់ អាគារ។ នៅសល់ប៉ុន្មាន បូជាដល់ការទិញម៉ាស៊ីនឧបទេស ។ ការវិនិយោគទាំងនោះ យើង បានដឹងហើយថា មានពី ១/៣ នៃការវិនិយោគសរុប នៅកម្ពុជា ។

### ក.ការចំណាយនៃការប្រព្រឹត្តិទៅនៃកិច្ចការរដ្ឋបាល

ការចំណាយសាធារណៈ អាចចាត់ថ្នាក់ដូចតទៅ គិតជាភាគរយសរុបនៃការចំណាយរដ្ឋបាល៖

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| **សេវាកម្មសេដ្ឋកិច្ច** | ២០ | ២០ | ២៤ |
| មានកសិកម្ម | ៤ | 5 | 6 |
| ដឹកជញ្ជូន និង គមនាគមន៍ | ១១ | ១០ | ១៣ |
| **សេវាកម្មសង្គម** | ២៦ | ៣២ | ២៨ |
| មាន អប់រំ សិក្សា | ១៦ | ១៨ | ១៨ |
| សុខាភិបាល | ៥ | ៥ | ៦ |
| **សេវាកម្ម** | ២៤ | ៧៤ | ៨ |
| មាន អង្គរដ្ឋ | ៥២ | ១៣ | ១២ |
| ការពារប្រទេស | ១៧ | ២៥ | ២៨ |
| យុត្តិធម៌ និង | ៧ | ៧ | ៧ |

| | | | |
|---|---|---|---|
| នគរបាល | | | |
| ចំណាយមិនបង្វិល | ២ | ១ | ១ |

ការកត់សម្គាល់ទីមួយ គឺតួលេខទាំងនោះ ដែលគេហៅថា ជាសេវាកម្មទូទៅជាច់ នៃអត្ថិភាពរបស់ ប្រទេស ស្រូបយកប្រហែលពាក់កណ្តាល នៃការចំណាយសាធារណៈ។ គ្រាន់តែវិស័យការពារប្រទេស ស្រូបយកតែខ្លួនឯង មានចំនួនមួយភាគបួន នៃការចំណាយសរុប " សព្វថ្ងៃវិស័យការពារ ស្រូបយកសឹងតែពាក់កណ្តាលនៃ ការចំណាយថវិការដ្ឋ "។ តួលេខនោះខ្ពស់ណាស់ដូចប្រទេសកម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និង នៅមានសង្គ្រាមស៊ីវិល ប៉ះបោរទៀតផង ដែលបានបូជាថ្មី១ ដើម្បីចំណាយ លើផ្នែកសព្វាវុធ ។

ភាគចំណែកចំណាយ សម្រាប់សេវាកម្មសង្គម និងពិសេសវិស័យអប់រំសិក្សា ក៏មានសារៈសំខាន់ណាស់ដែរ ។ ការខិតខំរបស់រដ្ឋាភិបាលលើវិស័យនេះ មានលទ្ធភាពលេចឡើងគួរឱ្យចាប់អារម្មណ៍ ។

ផ្ទុយមកវិញ ការចំណាយសម្រាប់សេវាកម្មសេដ្ឋកិច្ច ដែលរួមវិភាគទានផ្ទាល់ ដល់ការបង្កើតឡើងនៃ ផលិតកម្មជាតិ មិនលើសពី ១/៥ នៃការចំណាយសរុបឡើយ ។ ការគួរឱ្យកត់សម្គាល់ថែមទៀតនោះ គឺការចំណាយ ទៅលើហេដ្ឋារចនាសម្ព័ន្ធ គឺ ដឹកជញ្ជូន និង គមនាគមន៍មានចំនួនពាក់កណ្តាលនៃការចំណាយ " សេដ្ឋកិច្ច " ហើយជះឥទ្ធិពលមិនសូវផ្ទាល់ទៅលើកសិកម្ម ហើយក្នុងរយៈពេលយូរទៀតផង ។ ការចំណាយជាសាធារណៈ ដោយផ្ទាល់ ទៅលើ "ផលិតកម្ម" មានចំនួនតិចតួចដែរ ។ កត់ដូចចុងក្រោយមានរូបភាពដូចតទៅ៖ សេវាកម្ម នៃបំណុលមាន ភាពស្រាលទេ នៅកម្ពុជា ។ ផ្ទុយពីប្រទេសនានា ដែលធ្វើកាខ្ចីបុលជាច្រើន ។

យើងពិនិត្យថែមទៀតថា តើប្រទេស មានចំណូលអ្វីខ្លះ ដែលសម្រាប់បំពេញដល់ការចំណាយ ។

### ៩.១.២.ចំណូលតាមពន្ធដារ

ដើម្បីសិក្សាពីសំណុំ នៃចំណូលសាធារណៈ គេត្រូវប្រើវិធីរដ្ឋបាល ។ ក្រោយពីការគូសវាសលូវការសិក្សា នោះ គេអាចធ្វើការ វិភាគលម្អិត លើបញ្ហាចំណូលពន្ធដារ ។

#### ក.រចនាសម្ព័ន្ធ ចំណូល

គេអាចពិនិត្យវាយតម្លៃ នូវរចនាសម្ព័ន្ធចំណូលរដ្ឋាភិបាលនានា សម្រាប់ឆ្នាំ ១៩៦២ ១៩៦៣ និង ១៩៦៤ ដែលគេមាននូវពត៌មានគ្រប់គ្រាន់ ពីគណនេយ្យជាតិ។ ចំណូលរដ្ឋបាលមានលក្ខណៈ ដូចខាងក្រោម៖

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ចំណូលពន្ធអាករ | ៦៤ | ៦៦ | ៧២ |
| ការប្រាក់និងទ្រព្យសម្បត្តិនៅបរទេស | ១ | ១ | ២ |

| | | | |
|---|---|---|---|
| អប្បមា សង្គម | ១ | ២ | |
| ជំនួយបរទេស | ២៦ | ២៦ | ១៧ |
| ការផ្ទេរផ្សេងៗ | ៨ | ៧ | ៨ |

ភាគចំណែក នៃការប្រាក់ និងទ្រព្យសម្បត្តិ ដែលជាធនធាន នៃសហគ្រាសរដ្ឋ ឬ ការចូលរួមជាភាគហ៊ុន ក្នុងក្រុមហ៊ុនសេដ្ឋកិច្ចចម្រុះ គឺ តិចជាង ២០% ។ ទ្រព្យធនទាំងនោះ មិនបានកើនឡើងទេ នៅឆ្នាំ ១៩៦៥-១៩៦៦ ឬ ១៩៦៧ ដោយហេតុថា សហគ្រាសជាច្រើន មិនចូលបានលទ្ធផលល្អ ។

ចំណូលបានមកពីសហគ្រាសរដ្ឋមួយចំនួន ដូចជាក្រុមហ៊ុន សុរាគារ គឺបានមកដោយភាគច្រើន ពីការបង់ ពន្ធអាករ របស់សហគ្រាសទាំងនោះជូនរដ្ឋ ។ ភាពផ្ដាច់មុខដែលសហគ្រាសរដ្ឋ ធ្វើបានតាមរយៈ ការប្រមូលពន្ធ ពីអ្នកប្រើប្រាស់ គឺជាសហគ្រាសឧស្សាហកម្មរបស់រដ្ឋ ។ មូលធនរដ្ឋ មិនមានផ្ដល់អ្វីច្រើនដល់ថវិកា ការផ្ទេរទាំងឡាយ និងចំណូលគ្រប់ប្រភេទ រាប់ទាំងចំណូលឆ្នោតជាតិ និងការចូលរួមវិភាគទានដោយសុធន្ទៈ និងចំណូលរបស់សហគ្រាសមានចំនួនជិត ៦០% នៃចំណូលសរុប ។

ជំនួយបរទេសក្រោមរូបភាព ឱ្យខ្ចីបុល និង អំណោយ បានរួមវិភាគទាន ដល់ចំណូលរដ្ឋាបាល ក្នុងភាគចំណែកយ៉ាងសំខាន់ ប្រហែល ២៦%នៅឆ្នាំ ១៩៦២ និង ១៩៦៣ ។ ការរួមវិភាគទាននោះ បានថយចុះយ៉ាងខ្លាំង នៅឆ្នាំ ១៩៦៤ "១៧%" ហើយបន្ទាប់កាន់តែថយចុះថែមទៀត។

ចំណូលរដ្ឋធំបំផុត គឺ ពន្ធអាករ ។ ភាគចំណែក នៃចំណូលពន្ធអាករ មានប្រហែល ៦៥% នាឆ្នាំ១៩៦២ និង ១៩៦៣ ហើយ ៧០% នៅឆ្នាំ ១៩៦៤ ។ ចំណូលនោះកើនឡើងលើសពី ៨០% ទៅទៀត នាឆ្នាំ ១៩៦៥ ដល់ ១៩៦៦ ។ គឺចំណូលពន្ធអាករ មានសារៈសំខាន់ត្រូវពិនិត្យ។

### ៩.១.៣ ចំណូលនិងចំណាយថវិកា: ២០០៩-២០១៣

ដោយសារវិបត្តិ ហិរញ្ញវត្ថុនិង សេដ្ឋកិច្ចសកលលោក ដែលបាននិងកំពុងកើតឡើងក្នុងប្រទេសអភិវឌ្ឍ បាន ជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ចំណូលថវិកាបានធ្លាក់ចុះពី ១៣,៣ ភាគរយនៃ GDP សរុបក្នុងឆ្នាំ២០០៨ មក ១១,៨ភាគរយនៃ GDPសរុបក្នុងឆ្នាំ ២០០៩។

ចំណូលថវិកា ត្រូវបានព្យាករណ៍ថានឹងកើនឡើងវិញជាបន្តបន្ទាប់ ហើយនឹងកើនលើសកម្រិតក្នុងឆ្នាំ២០០៨ នៅឆ្នាំ២០១២ហើយត្រូវបានព្យាករណ៍ថានឹងកើនដល់១៤,២ភាគរយនៃGDPសរុបក្នុងឆ្នាំ២០១៣។ ការអនុវត្តន៍វិធាន ការនានារបស់ រាជរដ្ឋាភិបាល ដែលផ្ដោតលើការការពារក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ ពីផលប៉ះពាល់អវិជ្ជមាននៃវិនភាពសេដ្ឋកិច្ច ក៏ដូចជា ការអនុវត្តវិធានការសម្រាប់ជំរុញតម្រូវការ តាមរយៈកញ្ចប់គោលនយោបាយសម្រាប់

ជំរុញ កំណើន បានធ្វើឱ្យចំណាយ ថវិកា ជាសមាមាត្រ GDP នៃសរុប បានកើនឡើងពី ១៥,៩ ភាគរយ ក្នុងឆ្នាំ២០០៨ ដល់ ១៧,៥ភាគរយ ក្នុងឆ្នាំ២០០៩ ។

ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន អនុវត្ត ដំណើរការចំនួនពីរដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ។ ទីមួយគឺក្របខ័ណ្ឌចំណាយសម្រាប់ រយៈមធ្យមដែលព្យាករណតួលេខចំណាយចរន្តសម្រាប់រយៈពេលបីឆ្នាំខាងមុខ។ ការព្យាករណនេះនឹងត្រូវធ្វើបច្ចុប្បន្នកម្ម រៀងរាល់ឆ្នាំ។ ការព្យាករណផ្អែកលើការវិភាគម៉ាក្រូសេដ្ឋកិច្ចពីលើចុះក្រោម ដោយមើលលើការអនុវត្តនៃសេដ្ឋកិច្ច។ គោលនយោបាយអាទិភាពក៏ដូចជាព័ត៌មានបានពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល។ នាយកដ្ឋានគោលនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលបន្ទុកធ្វើការវិភាគនេះ។ ទីពីរគឺក្របខ័ណ្ឌយុទ្ធ-សាស្ត្រនៃថវិកាសម្រាប់រយៈពេលបីឆ្នាំដែលអនុវត្តតាមអភិក្រមពីក្រោមទៅលើនិងរៀបចំដោយនាយកដ្ឋានថវិកានៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាតុចូលដែលសម្រាប់យកមកប្រើប្រាស់ក្នុងការវិភាគនេះគឺផ្អែកទៅលើព័ត៌មានដែល ប្រមូលបានពីការផ្លាស់ប្តូរយោបល់រវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយស្ថាប័ននានារបស់ រាជរដ្ឋាភិបាល និង ព័ត៌មានស្តីពី ចំណាយនិងតម្រូវការរយៈពេលពីរឆ្នាំទៅមុខនៃស្ថាប័នទាំងនោះ។ ក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងភាពផ្សារភ្ជាប់គ្នានៃដំណើរការទាំងពីរ ដើម្បីកែលម្អការ រៀបចំថវិកាប្រចាំឆ្នាំ ។

ក្នុងដំណាក់កាលនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅកម្ពុជា សព្វថ្ងៃយើងនៅមានការងារយ៉ាងធំចំពោះមុខ ក្នុងការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលចាំបាច់ដើម្បីសម្រេចបានគោលដៅម៉ាក្រូសេដ្ឋកិច្ចគឺកំណើន សេដ្ឋកិច្ច ខ្ពស់ ដើម្បីឈានទៅ កាត់បន្ថយភាពក្រីក្រ ។ ទោះបីជាប្រហែល ៤០ ភាគរយនៃចំណាយ សាធារណៈសរុបត្រូវបាន ប្រើប្រាស់ទៅលើចំណាយមូលធនក៏ដោយ ក៏ចំនួននេះនៅតិចតួចនៅឡើយ សម្រាប់ការស្តារ និង ការកសាងហេដ្ឋា រចនាសម្ព័ន្ធរូបវន្ត ដែលយើងកំពុងត្រូវការចាំបាច់ ដើម្បីកាត់បន្ថយភាពក្រីក្របន្ថែមទៀត ។ ការពឹងផ្អែកលើហិរញ្ញប្បទាន ពីខាងក្រៅ ប៉ះពាល់ដល់ជម្រើសរបស់រាជរដ្ឋាភិបាល ក្នុងការបំពេញតម្រូវការជាក់ស្តែងរបស់ខ្លួន។ រាជរដ្ឋាភិបាល បានប្រើប្រាស់ចំណាយមូលធន ដែលជាផ្នែកនៃថវិកាជាតិ ដើម្បីទាក់ទាញហិរញ្ញប្បទានពីខាងក្រៅប្រទេស សម្រាប់ បំពេញតម្រូវការនៃចំណាយមូលធនជាអាទិភាពរបស់ខ្លួន ។

**ចំណាយមូលធន និងចំណាយចរន្តសម្រាប់ឆ្នាំ ២០០៩ – ២០១៣**

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| **ចំណាយសរុប** (គិតជាពាន់លានរៀល) | ៧ ៥៤៨.៦ | ៨ ៤៩៩.៨ | ៩ ១៩៦.៨ | ១០ ០៣៩.៣ | ១០ ៩៣១.៦ |
| ចំណាយមូលធន (គិតជាពាន់លានរៀល) | ២ ៩៥១.៦ | ៣ ៣២៦៩ | ៣ ៥៣៤.៣ | ៣ ៨៧៦.៣ | ៤ ២៣៤.៩ |
| ចំណាយចរន្ត (គិតជាពាន់លានរៀល) | ៤ ៥៩៧.១ | ៥ ១៧២.៩ | ៥ ៦៦២.៥ | ៦ ១៦៣.០ | ៦ ៦៩៦.៨ |

*ប្រភព* : *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

## ៩.២.កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ( PFMRP )

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមធ្វើកំណែទំរង់លើគ្រប់វិស័យទាំងអស់ ចាប់តាំងពីឆ្នាំ ១៩៨០មកម្លេះ ជាពិសេសកំណែទំរង់ ទៅលើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងកំណែទំរង់ទៅលើរចនាសម្ព័ន្ធ ព្រមទាំងការធ្វើសមាហរន្តកម្មនៃសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ សមិទ្ធិផលដែលជាទីកត់សំគាល់នោះគឺ ការធ្វើសេរីកម្ម និងស្ថេរភាពនៃសេដ្ឋកិច្ច ប្រទេសយើង ។ ដែលក្នុងចន្លោះឆ្នាំ ១៩៩០-១៩៩៥ កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំនៃប្រទេសកម្ពុជា មានចំនួនជាមធ្យម ៦ % ទៅ ៧% ព្រមទាំងមានតំលៃអតិផរមោទាបជាង ៥% ប្រចាំឆ្នាំ ។ កំណែទំរង់ទាំងនេះ គឺដើម្បីបង្កើននូវការពង្រឹងការ គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសារជារណៈ ដែលរួមបញ្ចូលលទាំង

១.ការគ្រប់គ្រងរចនាសម្ព័ន្ធគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច
២.ការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធថវិការជាតិ និងលិទ្ធកម្មសាធារណៈ
៣.ការធ្វើទំនើបកម្មនៃប្រព័ន្ធ
៤.ការធ្វើ អោយប្រសើរឡើងនូវប្រព័ន្ធគណនេយ្យសាធារណៈ
៥.ការអភិវឌ្ឍនៃប្រព័ន្ធសោវនកម្ម និងការត្រួតពិនិត្យ
៦.ការធ្វើឯកជនរូបនីយកម្ម សហគ្រាសសាធារណៈ ព្រមទាំង
៧.ពង្រឹងការគ្រប់គ្រងលើទ្រព្យសម្បត្តិរដ្ឋ ។

ប្រទេសកម្ពុជាត្រូវបានគិតថា ការធ្វើអោយប្រសើរឡើង នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ដើរតួយ៉ាង សំខាន់ក្នុងការធ្វើកំនែទំរង់រដ្ឋបាលទូទៅនៃប្រទេសកម្ពុជា ។

ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលកំពុងពង្រឹងភាពផ្សារភ្ជាប់គ្នារវាងកម្មវិធី នានាដែល:

ទីមួយ -កំណត់ការវិនិយោគសាធារណៈអាទិភាព
ទីពីរ - កៀរគរធនធានពីខាងក្រៅ ទាំងពីដៃគូអភិវឌ្ឍន៍ចាស់និង ថ្មី និង
ទីបី -រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកា ។

រាជរដ្ឋាភិបាលដឹងច្បាស់ពីតម្រូវនៃការកែលម្អកម្មវិធីវិនិយោគសាធារណៈសម្រាប់រយៈ៣ឆ្នាំដើម្បីធានាថា

(១) តម្រូវការចំណាយចរន្តដែលពាក់ព័ន្ធដល់ការរៀបចថវិកាប្រចាំឆ្នាំគឺជាផ្នែកមួយដែលមិនអាចខ្វះបាននៃព័រមានដែលប្រមូលបាននៅក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ។ (២)គម្រោងនានានៃកម្មវិធីវិនិយោគសាធារណៈត្រូវបានចាត់ថ្នាក់តាមលំដាប់អាទិភាព។ ការងារនេះទាមទារឱ្យស្ថាប័នរបស់រាជរដ្ឋាភិបាលធ្វើចំណាត់ថ្នាក់គម្រោងដែលស្នើសុំទៅតាមលំដាប់ អទិភាពសម្រាប់ការអនុវត្តក្នុងរយៈបីឆ្នាំទៅមុខដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចទូទៅនិងការយល់ដឹងពីលទ្ធភាពនៃការកៀរគរធនធានពីប្រភពក្រៅប្រទេស ។

ការពង្រឹងដំណើរការនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ គឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅពេលដែលគុណភាពនៃព័ត៌មានរបស់កម្មវិធីវិនិយោគសាធារណៈល្អជាងមុននោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធានាថាមានតែកម្មវិធីឬគម្រោង ដែលស្ថិតនៅក្នុងកម្មវិធីវិនិយោគសាធារណៈប៉ុណ្ណោះដែលនឹងត្រូវដាក់បញ្ចូលសម្រាប់ការ ពិចារណាក្នុងការផ្តល់ហិរញ្ញប្បទាននៅក្នុងអំឡុងពេលនៃការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រនៃថវិកា។ គណៈកម្មាធិការនីតិ សម្បទានិងអភិវឌ្ឍកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា នឹងធានាថា នឹងជំរុញការធ្វើហិរញ្ញប្បទានដល់គម្រោងនានា ដែលជាផ្នែកនៃកម្មវិធីវិនិយោគសាធារ នៅក្នុងការងារកៀរគរធនធានរបស់ខ្លួន និងរៀបចំដោយទៀងទាត់នូវ របាយការណ៍អំពីគម្រោងក្នុង កម្មវិធីវិនិយោគសាធារណៈក៏ដូចជាគម្រោងក្រៅកម្មវិធីវិនិយោគសាធារណៈដែលគាំទ្រ ដោយដៃគូអភិវឌ្ឍន៍ខាងក្រៅ ។

### ៩.២.១.ការប្រឈមមុខនៃ PMFRP

ចំណូលពន្ធរបស់សេដ្ឋកិច្ចប្រទេសកម្ពុជា គឺនៅមានលក្ខណៈតូចចង្អៀតនៅឡើយដោយសារតែមានភាពទន់ ខ្សោយនៃរដ្ឋបាលក្នុងការប្រមូលពន្ធ(weak revenue administration)។

តាមការប៉ាន់ស្មានរបស់ IMF បានអោយដឹងថា តំលៃប្រភាគ (ratio) រវាងចំណូលធៀបនឹង GDPមានចំនួន ៥% ទៅ ៦%ទាបជាងតំលៃសក្តានុពលនៃតំលៃប្រភាគនេះ ។

តាមការវិភាគរបស់ IMF បានអោយដឹងថា ការរីកចំរើននៃរដ្ឋបាលកិច្ច នៃការប្រមូលចំណូលនេះអាចធ្វើអោយ ចំណូលប្រទេសកើនឡើងចន្លោះពី ១,២ ទៅ ៣,៤ នៃចំណូលប្រទេសបច្ចុប្បន្នកាលនេះ ។

យុទ្ធសាស្ត្រក្នុងការឈានឆ្ពោះទៅមុខដើម្បីសំរេចអោយបាននូវកំលាំងទំរង់នេះត្រូវ មានសមាសភាពសំខាន់ៗ ចំនួន ៣ដូចខាងក្រោមៈ

១.ការបង្កើតឡើងនូវការដឹកនាំទៅលើការអភិវឌ្ឍយុទ្ធសាស្ត្រ និងដំណើរការអនុវត្តនៃការអនុវត្ត។ នេះគឺ ដើម្បីធ្វើការយកចិត្តទុកដាក់ទៅលើការរៀបចំ និងការទទួលបន្ទុកទៅលើរដ្ឋបាលនៃការអនុវត្តសកម្មភាព ផ្សេងគ្នានីមួយៗ របស់កម្មវិធីកំណែទំរង់នេះ ។

២.ការយកចិត្តទុកដាក់លើតំណាក់កាលនិមួយៗនៃកម្មវិធីកំណែទំរង់ ។ ការធ្វើកំណែទំរង់មិនអាចប្រតិបត្តិ តំណាក់កាលនីមួយៗទៅបានដោយក្នុងពេលតែមួយនោះទេ ។ តំណាក់កាលមូលដ្ឋាន និងតំណាក់កាលស្នូល តំរូវអោយប្រតិបត្តិមុន ។ ដូច្នេះការបែងចែកតំណាក់កាលនីមួយៗនៃកម្មវិធីកំនែទំរង់នេះ មានសារៈសំខាន់ បំផុត ។

៣.ក្នុងការអនុវត្តប្រតិបត្តិតំណាក់កាលនីមួយៗ មិនត្រឹមរួមបញ្ចូលការអភិវឌ្ឍន៍ បច្ចេកទេស និងតំណើរការ នោះទេ ការពង្រឹង និងអភិវឌ្ឍន៍បច្ចេកទេស និងតំណើរការនោះទេ ការពង្រឹង និងអភិវឌ្ឍន៍ចំណោះដឹង និង សមត្ថភាព រចនាសម្ព័ន្ធ ក៏ត្រូវរួមបញ្ចូលក្នុងនោះដែរ ។

## ៩.៣.គោលនយោបាយសារពើពន្ធ

រាជរដ្ឋាភិបាលមានការតាំងចិត្តយ៉ាងមុតមាំ ក្នុងការធ្វើអោយប្រសើរឡើងនូវ រដ្ឋបាលចំណូល ដើម្បីអោយមាន លំនឹងជានិរន្តរភាព នៃសារពើពន្ធ ដែលអាចផ្តល់នូវភាពងាយស្រួល និងភាពទុកចិត្តក្នុងការប្រើប្រាស់ធនធានថវិការនេះ ទៅលើតំរូវការ មហាសាលនៃការអភិវឌ្ឍប្រទេសកម្ពុជា ។

រាជរដ្ឋាភិបាលកម្ពុជា បានចុះកិច្ចព្រមព្រៀងក្នុងការអនុវត្តប្លង់សកម្មភាពដោយរួមមាន

១.ពង្រឹងសមត្ថភាព លើវិស័យវិសោតនកម្ម

២.ពង្រីកនូវការចែកចាយពត៌មាននៃការប្រមូលពន្ធ និងច្បាប់ក្នុងការយកពន្ធ

៣.បង្កើនចំណេះ ដឹងអំពីការប្រមូលពន្ធដល់អ្នកដែលត្រូវបង់ពន្ធ

៤.ធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចលើភ្នាក់ងារប្រមូលពន្ធ ។

បន្ថែមពីនេះទៅទៀតការកាត់បន្ថយនូវសកម្មភាព នៃការគេចពន្ធ tax evation គឺជាផលល្អមួយ ក្នុងការ បង្កើនប្រសិទ្ធិភាពនៃគោលនយោបាយចំណូលពន្ធ។ ប្រសិទ្ធិភាពនៃការចែកចាយពត៌មានគ្រប់គ្រាន់ព្រមទាំងការបង្កើន សមត្ថភាពលើនាយកដ្ឋានពន្ធដារនិងគយ ប្រឆាំងនឹងការគេចពន្ធ នេះគឺជាកត្តាសំខាន់ដើម្បីអោយគោលនយោបាយសារពើ ពន្ធមានភាពប្រសើរឡើង ។

## ៩.៤.ប្រភេទពន្ធអាករនានា

ចំណូលពន្ធអាករ គឺ ពន្ធដែលប្រមូលបាន ពីរដ្ឋបាលនានា។ គេបែងចែករវាង "ជាតិ" គឺពន្ធប្រមូលបាននៅ "មជ្ឈឹម" ជាថវិកាជាតិ និង គណនេយ្យពិសេសនៃរតនាគារ ហើយនិង ពន្ធ "នៃសមូភាពដែនដី" ដែលខេត្ត-ក្រុង គ្រឹស្ថានសាធារណៈបានប្រមូលបាន។ តារាងខាងក្រោមបង្ហាញពីប្រតិបត្តិការនៃការបែងចែក ជាភាគរយសរុប នៃចំណូលពន្ធអាករ ៖

១៩៦២១៩៦៣១៩៦៤

ពន្ធជាតិ.......................៩២ ៩៣ ៩៤

ពន្ធសមូហភាពដែនដី ....................៨ ៧ ៦

តួលេខនេះធ្វើឱ្យមានការកេត់ចំណាំពីរយ៉ាង ។ ពន្ធដែលប្រមូលបានដោយសមូហភាពដែនដី មិនសូវមានសារៈសំខាន់ គឺ តិចជាង ៨០% នៃចំណូលពន្ធអាករសរុប ។ ជាសំខាន់ ពន្ធដែលប្រមូលបាននៅមជ្ឈឹម អាចចិញ្ចឹម គណនេយ្យរតនាជាគាបាន ពិសេសថវិការជាតិ។

ថវិកានៃសមូហភាពដែនដី មិនអាចទ្រទ្រង់បានដោយចំណូលពន្ធតិចតួចនោះបានទេ ខេត្ត-ឃុំ អំពាវនាវការជួយឧបត្ថម ពីថវិកាជាតិ ។ ថវិកាប្រមូលមូលនិធិ ដើម្បីបម្រើឱ្យសមូហភាពដែនដីដែរ។

ទីចាត់ការមួយបានធ្វើការសិក្សាតាមរយៈការបដិរូបពន្ធអាករដោយបង្កើតនូវចំណូពន្ធសមូហភាពដែនដី។

ការបង្កើតពន្ធអាករ របស់ខេត្ត-ឃុំ មានផលប្រយោជន៍បីយ៉ាង។ ទីមួយ គឺមានការគាំទ្រដល់ថវិកាជាតិក្នុងវិធានការបែបនេះ ជំនួយដល់ថវិកា ខេត្ត-ឃុំ គឺអាចត្រូវកាត់បន្ថយ ឬ លុបចោល ។ ទីពីរ ពន្ធអាករ ខេត្ត-ឃុំ គឺអាចទទួលយល់ព្រមបានជាកាតព្វកិច្ចរបស់ពលរដ្ឋនៅក្នុងកម្រិតសមូហភាពដែនដី។ ទីបីរដ្ឋអំណាចមូលដ្ឋានមានទីតាំងល្អជាងមន្ត្រីនៅរាជធានី ដើម្បីអ្វីៗដែលត្រូវធ្វើនៅខេត្ត-ក្រុង-ឃុំដូចនេះល្អណាស់ក្នុងការលើកទឹកចិត្តដល់កិច្ចផ្តើមនិងការទទួលខុសត្រូវឱ្យពួកគេគ្រប់គ្រងថវិកាមូលដ្ឋានយ៉ាងសំខាន់។

ប្រព័ន្ធពន្ធអាករខ្មែរ គឺបង្កើតឡើងពីពន្ធ "ជាតិ" ដែលត្រូវសិក្សាពីផ្នែកពន្ធផ្សេងៗទៀតដើម្បីវិភាគលក្ខណៈ ពីយ៉ាងនៃប្រព័ន្ធពន្ធដារ ពន្ធមានច្រើនប្រភេទផ្ទាល់។

១.អ្វីដែលគួរឱ្យចាប់អារម្មណ៍ នៅពេលពិនិត្យប្រព័ន្ធពន្ធដារនៅកម្ពុជា គឺភាពស្មុគស្មាញនៃប្រព័ន្ធនោះ ។ ភាពស្មុគស្មាញនោះ ជាផលវិបាកនៃ ចំនួននឹងភាពបុរាណដៃពន្ធដារ ។ពន្ធដារមានច្រើន មានចំនួនប្រហែល ៥០ ។ ប៉ុន្តែពន្ធមួយចំនួន ជាពន្ធនៃក្រុម ដូចជាករណី សិទ្ធនៃការចុះបញ្ជី ច្បាប់អនុញ្ញាត ។ ពន្ធប្រភេទនេះ មានចំនួនរាប់រយប្រភេទ ។ គេបង្កើតពន្ធដារថ្មី តែមិនបានលុបចោលពន្ធដារចាស់នៅឡើយ ។ ប្រព័ន្ធពន្ធដារបែបនេះមានភាពស្មុគស្មាញ តាមរយៈពេល ។

ភាគច្រើនពន្ធដារទាំងនោះ កើតមានតាំងពីសម័យអាណានិគមម្ល៉េះ ។ ដោយមិនរាប់បញ្ចូល នូវការដាល់នាវាចរ នៅឆ្នាំ ១៨៩៩ គេអាចរាប់បាននូវពន្ធលើផលទុននៃកំរៃ ចលនវត្ថុ ។ ពន្ធនៃការប្តូរទំនិញ ការផ្ទេរតម្លៃចលនវត្ថុ ដាក់ទៅក្នុងប្រទេសលើផលិតផលពន្ធ លើច្បាប់ចុះបញ្ជី និងតែម ។ល។.....

ជាពន្ធដែលរៀបចំមុនសង្គ្រាមលោកលើកទីពីរ ។ បាត់បង់ពីឆ្នាំ ១៩៤៦ ។ ជាមួយនៅសម័យឯករាជ្យ ពន្ធអាករថ្មី បានលេចឡើង : ពន្ធលើផលទុន ឆ្នាំ ១៩៥៤ ពន្ធលើឧបករណ៍ដឹកជញ្ជូន ឆ្នាំ ១៩៥៥ ពន្ធលើដំណាំកៅស៊ូ ឆ្នាំ ១៩៥៦ ពន្ធលើការនាំចេញអង្ករ និង កៅស៊ូចេញឆ្នាំ ១៩៥៦ ដាក់លើសម្ភារ ។ល។ ច្បាប់គយរដ្ឋាករ បានរៀបចំឡើងវិញ នៅឆ្នាំ ១៩៥៩ ។

ភាពស្មុគស្មាញដែលលេចចេញពី "រលក" បក់បោកជាបន្តបន្ទាប់នៃពន្ធអាករ បានកើនឡើង ដោយខ្វះក្រមពន្ធ និងការរៀបចំអង្គការពន្ធដារ ទទួលបន្ទុកប្រមូលពន្ធដារពីគ្នា។

គ្មានឯកសារប្រមូល ជាសំណុំបែបបទជាអត្ថបទពន្ធដារច្រើនសោះ ។ ការខិតខំធ្វើក្រម បានរៀបចំឡើងដោយបោះពុម្ព នៅទីចាត់ការទូទៅនៃពន្ធ នូវឯកសារអត្ថបទពន្ធអាករ ។ ការងារដ៏ល្អនេះបានផ្សព្វផ្សាយតាមពេលវេលា បាននិយាយតែប្រភេទពន្ធមួយចំនួនសម្រាប់ប្រមូលនៅទីចាត់ការពន្ធតែប៉ុណ្ណោះ។ អត្ថបទដែលនិយាយពីប្រភេទពន្ធដទៃទៀត ពិសេសច្បាប់រដ្ឋាករ មិនបានប្រមូលបោះពុម្ពនៅឡើយ ។ គេត្រូវស្រាវជ្រាវក្នុងក្រមនៃអគ្គទេសាភិបាលឥណ្ឌូចិន គឺក្រមនៃតម្លៃចលនវត្ថុ ក្រមចុះបញ្ជីការក្រម តែលកើតពីឆ្នាំ ១៩៦៩ ដែលចុះផ្សាយនៅក្នុងរដ្ឋកិច្ចឥណ្ឌូចិន ឬនៅក្នុងព្រះរាជកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។ តិចតួចណាស់ដែលនៅក្នុងមន្ទីរគយ និងរដ្ឋាករ ឃើញមាននូវបន្ត្រីទទួលខុសត្រូវ ទទួលពន្ធដែលមានអត្ថបទនិយាយពីពន្ធដារ ។ គេមិនបានលុបចោលច្បាប់ពន្ធចាស់ទេ ។ ច្បាប់ចាស់បាន ទទួលស្គាល់ពីមន្ត្រីគយ និងអ្នកបង់ពន្ធប៉ុន្មាននាក់ប៉ុណ្ណោះ ។

ដោយឡែក ច្បាប់ពន្ធជាថ្មីត្រូវយកទៅអនុវត្តន៍ ដោយអង្គការពន្ធដារ ជាច្រើន ដែលមិនបានបង់ចូលថវិកាជាតិផ្ទាល់នោះទេ ។ ទីចាត់ការទូទៅនៃពន្ធប្រមូល តែមួយភាគនៃពន្ធ គឺគយ និង រដ្ឋាករទេ ដែលទទួលខុសត្រូវលើចំណូលពន្ធដ៏ធំ ។ ប៉ុន្តែ ពន្ធក៏ត្រូវដកហូត ដោយសេវាកម្មផ្សេងៗទៀតដែរ ដូចជា ប៉ូលីស សុរិយោដី អន្តោប្រវេសន៍ ការចុះបញ្ជីនៃមន្ទីរជាតិប្តូរប្រាក់ ។

ភាពស្មុគស្មាញនេះ មានផលវិបាកបីយ៉ាងមិនសូវល្អ ។ វាលើកទឹកចិត្តដល់ការប្រព្រឹត្តិកំហុស ដែលការត្រួតពិនិត្យ មានការលំបាក ។ ទិន្នផលពន្ធអាករ នៅឆ្នាំខ្លះ ឡើងចុះក្នុងកម្រិតមួយដែលមិនអាចពន្យល់បានគ្រប់គ្រាន់ពេញចិត្ត ។

មិនទាន់មានសំណុំឯកសារណាមួយ ដែលឆ្លើយតបបាន ទៅនឹងបែបបទជារបៀបរៀបរយនៃភាពជាអាចិកំបាំង នៃអត្ថបទពន្ធអាករ ជាអត្ថបទថ្មី ក្នុងផ្នែកពន្ធ ។ ការងារដ៏ល្អនេះបានផ្សព្វផ្សាយជាទៀងទាត់ គឺនិយាយតែពីប្រភពពន្ធមួយចំនួន របស់ទីចាត់ការទូទៅនៃពន្ធ ។

អត្ថបទដែលនិយាយពីពន្ធផ្សេងៗទៀត ពិសេសភាគធំនៃច្បាប់រដ្ឋាករ មិនទាន់ប្រមូលផ្តុំបានល្អ ។ គេត្រូវរកមើលទៅក្នុងច្បាប់ពន្ធរបស់អគ្គទេសាភិបាលឥណ្ឌូចិន ច្បាប់តម្លៃចលនវត្ថុ ច្បាប់ចុះបញ្ជីការ ពន្ធលើតែម ដែលមានអាយុកាល តាំងពីឆ្នាំ ១៩៣៩ នីក្នុងរដ្ឋកិច្ចឥណ្ឌូចិន ដ៏ចាស់កំរិល ឬ ស្រាវជ្រាវចេញ ពីរាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។ គេមិនសូវឃើញមានខាងច្បាប់គយ និង រដ្ឋាករនៅឡើយ នាពេលនោះនូវមន្ត្រីទទួលខុសត្រូវខាងបញ្ជាក់បញ្ជីពន្ធ ដែលមានអត្ថបទច្បាប់និយាយពីពន្ធរបៀបនោះ ។ ច្បាប់ពន្ធចាស់មិនទាន់លុបចោលហើយ ច្បាប់នោះមានការចេះដឹង ពីមន្ត្រីប៉ុន្មាននាក់ និង អ្នកបង់ពន្ធតិចតួចប៉ុណ្ណោះ ។

ដោយឡែកប្រភពពន្ធជាច្រើនអង្គការផ្សេងៗដើរទារពន្ធដែលមួយចំនួនមិនបានបង់ចូលថវិការដ្ឋទេ ។ គឺគយ និង រដ្ឋាករ ជាអ្នកទទួលខុសត្រូវលើការយកពន្ធសំខាន់បំផុត ។ ប៉ុន្តែ ពន្ធបានត្រូវសេវាផ្សេងៗប្រមូលយកដែរ ដូចជា ប៉ូលីស អន្តោប្រវេសន៍ មន្ទីចុះបញ្ជីការ ក្រុមហ៊ុន មន្ទីជាតិប្តូរប្រាក់ ក្នុងករណីនៃការដាក់លើ ឧបករណ៍សម្ភារ លើសពីនេះ ក្នុងករណីខ្លះ កម្រិតពន្ធត្រូវផ្ទេរផ្ទាល់ចូលគណនេយ្យពិសេសនៃរតនាគារ ហើយមិនចូលក្នុងថវិកាជាតិទេ ។

ភាពស្មុគស្មាញនោះ បង្កើតនូវផលវិបាក បីមិនល្អ ។ វាបង្កើតនូវកំហុសក្នុងវិធានការ នៃការខ្វះលទ្ធភាពការប្រើអំណាចត្រួតពិនិត្យ ។ គេឃើញទិន្នផលនៃពន្ធដែលប្រមូលបានពីមួយឆ្នាំមានការខុសគ្នាឆ្ងាយណាស់ ហើយគ្មានអ្នកណាមានវិធានការពន្យល់ឱ្យបានជាទីពេញចិត្តនៅឡើយ ។ អត្ថបទពន្ធដែលមិនសូវស្គាល់ ជៀសមិនរួចពីការអនិវត្តន៍ លំបាកនោះឡើយ ។

ភាពស្មុគស្មាញធ្វើឱ្យអ្នកជាប់ពន្ធមានការព្រួយបារម្ភណ៍។ ពួកគេមិនដែលគិតថា បានបង់ពន្ធត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលឡើយ។ ការគណនាពីកម្រិតពន្ធទៀតសោធក៏មិនពិតទៀត។ ច្បាប់ពន្ធទីបួនចុងក្រោយបង្អស់បញ្ជាក់ថាពន្ធត្រូវតែពិតប្រាកដគឺមិនត្រូវបានពន្យល់ល្អនីកម្ពុជា។អ្នកជាប់ពន្ធទាំងឡាយតែងតែថ្លៃការពារផលប្រយោជន៍តាមរយៈការគេចពន្ធជាមួយអាជ្ញាធរ មិនបានអនុវត្តន៍ហ្មត់ចត់នូវច្បាប់ពន្ធ ។

នៅទីបញ្ចប់ ភាពស្មុគស្មាញនោះរាំងស្ទះ ដល់ការដាក់ឱ្យអនុវត្តន៍ នូវរាល់នយោបាយពន្ធដារ ។ ក្បាលម៉ាស៊ីន មានភាពស្មុគស្មាញណាស់ ដែលមិនអាចវាស់វែងបាន នូវអានុភាពរបស់វា ។

នៅពេលនោះ គេចង់បើករបាំងគយ លើផ្នែកផលិតផលណាមួយ គេមិនអាចកែប្រែការីគយបានទេ ប៉ុន្តែត្រូវបង្កើតច្បាប់ពិសេសលើផលិតផលនោះទៅវិញ។ ដើម្បីបង្កើននូបទិន្នផលនៃក្បាលម៉ាស៊ីន គេចូលចិត្តបង្កើននូវពន្ធដារថ្មីជាជាងលុបចោលច្បាប់ពន្ធចាស់ឬជំនួសដោយប្រភេទពន្ធដែលមានទិន្នផលខ្ពស់ជាងនោះក៏ព្រោះតែក្បាលម៉ាស៊ីន ស្មុគស្មាញ គេក៏កាន់តែធ្វើឱ្យស្មុគស្មាញថែមទៀត ។

ភាពផ្ទាំឆ្លងនេះ ហ៊ុមពទ្ធ័ដោយពន្ធចាស់កំរិលពេក ព្រោះជាច្បាប់គ្មានប្រយោជន៍ ។ ច្បាប់ពន្ធជាង ២០ រកចំណូលបានតិចជាង ១០ លានរៀល ហើយកន្លែងខ្លះ ប្រមូលបានតែ ១ លានរៀល ។

គេត្រូវការរក្សានូវ " ច្បាប់ពន្ធតែមួយ" ។ ប្រព័ន្ធពន្ធដារមួយ ដែលយុត្តិធម៌ និង មានប្រសិទ្ធភាព គឺ មិនងាយរៀបបានស្រួលនោះទេ ។ ប៉ន្តែប្រព័ន្ធពន្ធអាករ ដែលមានភាពស្មុគស្មាញខ្លាំងពេក ក៏មិនមានយុត្តិធម៌ និង ប្រសិទ្ធិភាពដែរ ។ ហើយភាពស្មុគស្មាញនៃប្រពន្ធពន្ធអាករកម្ពុជា គឺជាប្រព័ន្ធមួយ មានលក្ខណៈជាមូលដ្ឋាននៃប្រពន្ធនោះ ។ លក្ខណៈផ្សេងទៀត គឺបង្កឡើងដោយការគ្របសង្កត់ នៃពន្ធមិនផ្ទាល់ ។

២.ចំណុចទីពីរនៃប្រព័ន្ធពន្ធអាករខ្មែរ : គឺរចនាសម្ព័ន្ធនៃប្រភពពន្ធនោះ ។ នោះគឺការគ្របសង្កត់ ដោយភាគច្រើននៃពន្ធអាករមិនផ្ទាល់ ។ ក្នុងការប្រមូលពន្ធស្ថិតិ ដូចច្បាប់ហិរញ្ញវត្ថុពន្ធអាករកម្ពុជា ពិសេសផ្នែកទិន្នន័យត្រូវចាត់ថ្នាក់ជាជំពូក និង មាត្រា ។ ការចាត់ថ្នាក់នេះជារដ្ឋាបាលសុទ្ធសាធ ឬ តាមច្បាប់ការបែងចែក រវាងពន្ធដែលប្រមូលដោយអគ្គទីចាត់ការពន្ធ និងពន្ធដែលប្រមូលបានដោយរដ្ឋបាល នៃគយ និង រដ្ឋាករ ផលិតផលផ្សេងៗ និង សេវាកម្ម រដ្ឋបាល ។ល។ ការចាត់ថ្នាក់នេះ នៅមិនទាន់ជាទីពេញចិត្តនៅឡើយ ព្រោះមានលាយប្រភេទពន្ធផ្សេងៗបែងចែកនូវពន្ធនានាដែលមានប្រភេទដូចគ្នា ។ វាចាំបាច់ណាស់ដែលត្រូវចាត់ថ្នាក់ពន្ធ នៅ

តាមរចនាសម្ព័ន្ធនៃប្រព័ន្ធ ដែលទាមទានូវការចាត់ថ្នាក់ជាថ្មី ចេញពីលក្ខខណ្ឌសេដ្ឋកិច្ច ។ ដូចនេះហើយបានជាគេឃើញ ការប្រមូលព្រភពពន្ធជាង ៦ ប្រភេទ :

- ពន្ធលើផលទុន
- ពន្ធលើការចំណាយ
- ពន្ធលើទុន
- ពន្ធលើការនាំចេញ
- ពន្ធលើការចុះបញ្ជី និងតែម
- ពន្ធដារផ្សេងៗទៀត

ពន្ធអាករលើការចំណាយ ប្រមូលបានពី ៥០% ដល់ ៦៧% នៃចំណូលពន្ធសរុប ហើយពីឆ្នាំ ១៩៥៨ ដល់ ១៩៦៥ ភាគចំណែកនេះកើនឡើងជាប្រចាំ ។ ប្រភេទពន្ធអាករនោះកាន់តែមានសារៈសំខាន់ និង មានចំនួនកើនឡើង ។ គេអាចប្រមូលផ្តុំជាពីរផ្នែក : ពន្ធលើការនាំចូល និង ដាក់លើពាណិជកម្មនៃផលរបរ ។ ការបែងចែកនេះ មិនងាយស្រួលនោះទេ ព្រោះដាក់លើផលរបរ នៃផលិតផលនាំចូលតែមួយមុខ មាករពិបាកនឹងចាត់ថ្នាក់ ។

ពន្ធលើ ការនាំចូលមានច្បាប់គយ ជាអត្រាមធ្យមទទួលបាន ចែកនឹងកម្រិតនៃច្បាប់គយនៃការនាំចេញ គឺប្រហែល ២៥% មានចំណូលប្រចាំពី ៨០០ ទៅ ៩០០ លានរៀលក្នុងមួយឆ្នាំៗ ។ ហើយច្បាប់គយពិសេសៗ លើផលិតផលផ្សេងៗណាមួយ គឺលើសពី ៣០០ លានរៀលក្នុងមួយឆ្នាំៗ ។

ពន្ធលើផលរបរ រួមមានសមាសភាពនៃតាក់លើផលរបរ សុទ្ធសាធ ។ ពន្ធទំនើបនេះសង្កត់លើកម្រិតនៃការលក់ ឬ កិច្ចសន្យាសេវាកម្ម "ដែលចុះជាលាយលក្ខអក្សរ" នៅខ្វង់គណនេយ្យ ។ ក្នុងការសង្ស័យ ចង់កែប្រែពន្ធសង្កំយកតែការលក់ទីមួយ នៅកម្ពុជា ។ អត្រាដែលជានិច្ចកាលតែងតែមានការកែប្រែ គឺ ៥% សម្រាប់ផលិតផលក្នុងស្រុក និង ១២% សម្រាប់ផលិតផលនាំចូល ។ តាក់លើផលរបរ មានចំនួន ៨០០ ទៅ ៩០០ លានរៀល ក្នុងឆ្នាំថ្មីៗនេះ ពាក់កណ្តាលពន្ធ ជាផលរបរនៃផលិតផលនាំចូល ។ គេបានជួបនូវប្រភេទពន្ធផ្សេងៗទៀត "ទាំងផលរបរដែលជំនួយការតាក់នៃការដឹកជញ្ជូនស្រូវ ជាដើម ឬ លើ ថ្នាំជក់" ទិន្នផលកើនឡើងដល់ ៨០០លានរៀល នៅក្នុងឆ្នាំ ១៩៦៥។ធៀបនឹងពន្ធសរុបលើការនាំចូលគឺមានប្រហែល ៣០% បើគេមិនបញ្ចូល តាក់លើរបរ នៃផលិតផលនាំចូលទេ នោះមានប្រហែល ៥០% បើគេបញ្ចូលតាក់ប្រភេទខាងលើ ។ ភាពមាននិន្នាការកើនឡើង ដោយហេតុ នៃការកំណើនជាទូទៅនៃចំណូលពន្ធ ហើយនិង ភាពថយចុះនៃការនាំចូល ។

ភាគចំណែកនៃពន្ធលើផលរបរ មានប្រហែល ៣០% បើបញ្ចូលទាំង T C A នៃផលិតផលនាំចូល ហើយ ២០% នៅក្នុងករណីទាំងពីរ មានកំណើនច្បាស់ នៅឆ្នាំ ១៩៦៤ និង ១៩៦៥ ។

ពន្ធលើផលទុន ជាក្រុមពន្ធទីពីរសំខាន់ ព្រោះក្រុមពន្ធនេះ មានបរហែលពី ១៥% ទៅ ២០% នៃចំណូលពន្ធសរុប មានប្រហែល ៥០០ ទៅ ៦០០ លានរៀល ។

គេឃើញនៅក្នុងក្រុមពន្ធនោះ នូវទុនលើផលទុននៃរូបវន្តបុគ្គល "ពិសេសប៉ាតង់ជាសំខាន់" និង ពន្ធលើផលទុននៃក្រុមហ៊ុន "ទុនលើផលចំណេញ" ។ ទិន្នផលនៃទុនបានថយចុះ ឬ នឹងថ្កល់ ដោយសារទុននៃបុគ្គល ឬ ក្រុមហ៊ុននាយទុនមានការថយចុះ នៅឆ្នាំចុងក្រោយនៃទសវត្ស ៦០ ។

ក្រុមពន្ធអាករផ្សេងទៀត មានសារៈសំខាន់តិចតួច ពន្ធលើទុន លើដីចម្ការកៅស៊ូ តាក់តែមួយលើឧបករណ៍ដឹកជញ្ជូន មិនសូវមានសារៈសំខាន់ទេ។

ទិន្នផលនៃពន្ធលើការនាំចេញ មិនលើសពី ១០០ លានរៀលទេ តួនាទីពន្ធអាករ មានភាពខ្សោយនៅកម្ពុជា ។

គេដឹងថាគឺមិនដូចទាំងស្រុងទេ នៅក្នុងប្រទេសដែលនាំចេញនូវកសិផល ហើយប្រទេសជាតិដូច ស្រីលង្កា ឬ ម៉ាឡេស៊ី ព្រមទាំងប្រទេសនៅអាមេរិកកណ្តាល នៅពេលខ្លះ ប្រមូលពន្ធអាករ ប្រមូលពន្ធអាកររូបភាពបែបនេះ ជាប្រភពនៃចំណូលថវិកា ។ គេដឹងទៀតថាការអនុវត្តអត្រាពន្ធច្រើនប្រភេទ ហាក់ដូចជាប្រកាន់ពូជសាសន៍ ប្រឆាំងនឹងអ្នកធ្វើការនាំចេញ ដែលធ្វើការវិភាគលើការនាំចេញ ហើយប្រព័ន្ធបែបនេះ ត្រូវបានគេយកទៅប្រើប្រាស់យ៉ាងទូលាយ ពិសេសនៅអាមេរិកឡាទីន ។

គេឃើញមកវិញនូវកម្ពុជា បទបញ្ហានៃការប្តូរប្រាក់អាចឈានទៅដល់ ការជួយបំពេញបន្ថែម ដល់ការនាំចេញ បើដូចគេចង់ជំរុញឱ្យគេទូទាត់នូវពន្ធអាករអេវិដ្ឋមានមួយ ។

ច្បាប់ចុះបញ្ជី និងតែមដែលជារូបភាពពន្ធចាស់កំរឹល មានអាយុកាលពីសម័យអាណានិគម "រាប់ទាំងពន្ធនៃការនេសាទ និង កាប់ព្រៃឈើ " មានចំណូលដល់ទៅ ២០០ លានរៀលក្នុងមួយឆ្នាំៗ ។ គេបញ្ចប់ការកត់សម្គាល់នេះលើច្បាប់ពន្ធ ដោយរំពឹងពី "សំពាធពន្ធអាករ" ។ ការប្រៀបចំណូលពន្ធទៅនឹង ផលទុនដុល គិតជាភាគរយនៃឆ្នាំ P.I.B :

- ១៩៥៨..............១៣.៥
- ១៩៥៩..............១២.៤
- ១៩៦០.............១៥.១
- ១៩៦១.............១៤.៧
- ១៩៦២.............១៥.៦
- ១៩៦៣............១៥.២
- ១៩៦៤............១៣.៣

តួរលេខនេះ ធ្វើឱ្យលេចឡើងនូវសំពាធច្បាប់ពន្ធ ។ យើងសាកល្បងបង្ខិតឱ្យជិតគ្នា រវាងចំណូល និង ចំណាយ ដើម្បីលើកឡើងនូបបញ្ហាលំនឹងហិរញ្ញវត្ថុសាធារណៈ ។

## ៩.៥.លំនឹងនៃហិរញ្ញវត្ថុសាធារណៈ

ការចំណាយ និងចំណូល ត្រូវតែជានិច្ចកាលមានលំនឹង ។ បើមិនដូចនោះ នឹងលេចឡើងនូវអ្វីដែលហៅថា"ភាពទាល់ច្រក" ឬ " impasse " ដែលផ្តល់ជាហិរញ្ញវត្ថុ ដោយប្រភព

ពិសេសនោះ ជាសំខាន់គឺផលិតផលនៃគំរី " imprunts " ចំពោះគុណភាពនៃភាពទាន់ច្រក ទោះជាសំណុំនៃប្រត្តិបត្តិការរដ្ឋបាល និងគំរបរបស់វា ។

ក.ទោះបីខ្វះការបូកសរុបនូវកិច្ចប្រត្តិបត្តិការនៃច្បាប់ហិរញ្ញវត្ថុ គេអាចនិយាយថា ថវិការកម្ពុជា គឺជាកិច្ចការមានឱនភាព ចាប់ពីឆ្នាំ ១៩៥៩ មក ។ លំនឹងថវិកា អាចកើតមានបាន លុះណាតែរកបំពេញ ដោយចំណូលពិសេសប្រភពនៃរតនាគារ ជំនួយបរទេស បុរេប្រទាននៃធនាគារកម្ពុជា ដូចយកពីមូលនិធិផ្លូវថ្នល់ ការខ្ចីទូទាត់គណនេយ្យ ។ បើយើងចាត់ទុកថាកម្រិតនៃចំណូលពិសេសនោះស្មើនឹង ឱនភាពនៃថវិកាជាតិ ឱនភាពនោះមានតួរលេខគិតជាលានរៀល :

ឆ្នាំការីកម្ម១៩៥៩...............៧៣៨
១៩៦០...............១,១២០
១៩៦១...............១,២២៩
១៩៦២...............១,៧៦០
១៩៦៣...............១,៤១៦
១៩៦៤...............១,៧៤០
១៩៦៥..............២,០៤០
១៩៦៦...............២,០៦៩

តួលេខនេះ អាចប្រហាក់ប្រហែលនឹងតួលេខដែលបានរៀបចំស្តីអំពីចំណូលពន្ធដារ ។ ការបូកបន្ថែមនៅឆ្នាំ ការីកម្ម នូវកម្រិតមួយនៃការបូកសរុបលើការចំណាយ ។ កម្រិតនៃឱនភាពសរុបមានចំនួន ៣០% ។ វាអាចឡើងដល់ ៣៥% នៅឆ្នាំ ១៩៦២ និង ១៩៦៤ ។

ខ.ឱនភាពដ៏សំខាន់នេះ ជាយូរមកហើយ មិនធ្វើឱ្យមានផលវិបាកធ្ងន់ធ្ងរ ដល់សេដ្ឋកិច្ចកម្ពុជាទេ ។ ភាពទាល់ច្រកនេះ បានបុះពេញជំនួយបរទេស ពិសេសជំនួយអាមេរិក ។ ភាពទាល់ច្រកនោះ នៅក្នុងវិធានការណ៍ខ្លះ វាជា " ផ្នែកគណនេយ្យ " ជាការពិតនូងន័យថា ស្មើនឹងការចំណាយដែលផ្តល់ជាហិរញ្ញវត្ថុ ដោយជំនួយបរទេស ហើយបើអវត្តមាននៃចំនួយនោះ នោះប្រហែលជាខ្វះថវិកាដំណើរការដែរ ក្នុងវិស័យហិរញ្ញវត្ថុ សាធារណៈ ក៏ដូចជាជញ្ជីងទូទាត់ដែរ ជំនួយបរទេសជួយបន្ថែមជានិច្ចកាលដល់ចន្លោះប្រហោងទាំងនោះ ។

ចាប់ពីឆ្នាំ ១៩៦៤ មក រាល់ឱនភាពចាប់ផ្តើមទៅជាដំណោះស្រាយ ជាប្រចាំនយោបាយពង្រីកសមិទ្ធផលថ្មីៗ បានធ្វើឱ្យកើនឡើងនូវការចំណាយ ដែលជាអានុភាពសេចចេញពីការសាងសង់សាលារៀន រោងចក្រ រដ្ឋ ។ល។ ហើយឱនភាពនោះ លេចឡើងភ្លាមៗ ។ បន្ទាប់មកភាពទាល់ច្រកនោះ មិនអាចបន្ថែមបានដោយជនួយបរទេសទៀត ទេ ។ រតនាគារត្រូវអំពាវនាវរាល់ការខ្ចី ឬបុរេប្រទាន ពីធនាគាកម្ពុជា ។ ការចំណាយនេះកើនឡើងលើសពី ១,០០០ លានរៀល នៅចុងឆ្នាំ ១៩៦៦ ។ បែបបទនៃការធ្វើហិរញ្ញកិច្ចភាពទាល់ច្រក មិនមែនជះឥទ្ធិពលជាសំពាធអតិបិផនោះទេ ជាពិសេសកើតមានជាទូទៅនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជាដែលខិតខំធ្វើឱ្យនយោបាយរូបិយវត្ថុមានស្ថេរភាព ។

# មេរៀនទី ១០
# ប្រព័ន្ធហិរញ្ញវត្ថុ និង រូបិយវត្ថុនៅកម្ពុជា

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពី៖

- ចំណូល ចំណាយសាធារណៈ
- ប្រព័ន្ធធនាគារនៃប្រទេសកម្ពុជា
- តួនាទីធនាគារនៃប្រទេសកម្ពុជា
- គោលនយោបាយរូបិយវត្ថុ
- យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- និន្នាការនៃការប្តូរប្រាក់ និងគោលនយោបាយអត្រាប្តូរប្រាក់
- ហិរញ្ញវត្ថុសាធារណៈ

## ១០.១.សេចក្តីផ្តើម

គេដឹងថារូបិយវត្ថុមិនមែនជាក្តោងទេ តែជាគ្រឿងរំអិលសំខាន់នៃជីវភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅពេលដែលចម្លងការនានា ប្រព្រឹត្តិទៅតាមរូបិយវត្ថុនោះ ការសិក្សាពី Flux ការហូរនៃរូបិយវត្ថុ នូវការអង្កេតឱ្យបានច្បាស់លើសកម្មភាពនៃប្រទេស។ ប៉ុន្តែ ក្នុងវិធានការដែលការអនុវត្តឥណទានឱ្យធនាគារ ប្រើនូវអំណាចខ្លាំង ខាងការបង្កើតរូបិយវត្ថុ បានក្លាយទៅជាមានតួនាទីទីមួយ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ វាមានការលំបាក ក្នុងការបញ្ជាក់ជានិយមន័យនៃតួនាទីរូបិយវត្ថុ ដែលត្រូវមាននយោបាយរូបិយវត្ថុមួយ ។ នៅកម្ពុជា អស់រយៈពេលជាង ១០ ឆ្នាំនៃទសវត្ស ៥០- ៦០ ក្រោយពីសិក្សាក្រខណ្ឌគាំទ្រមធ្យោបាយនៃនយោបាយនោះ គឺសិក្សាពីរចនាសម្ព័ន្ធ ធនាគាររបស់ប្រទេស។

ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនជាគោលដៅចុងក្រោយដោយផ្ទាល់ទេប៉ុន្តែគឺជាទិដ្ឋភាពមួយដែល ទ្រទ្រង់ ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ មានកាតព្វកិច្ចជាច្រើន ដែលត្រូវធ្វើដើម្បីសំរេចគោលដៅដ៏ លំបាកនេះ ប៉ុន្តែមានការឯកភាពជាទូទៅថា ការបង្កើនល្បឿន និងបំបែកមុខព្រួញកំណើនសេដ្ឋកិច្ច គឺជាកត្តាគន្លឹះ និងជា ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុត្រូវបានពង្រីក និងអាចប្រើប្រាស់បានចំពោះសហគ្រាសបរទេសដែរ ។ កំណែទម្រង់ និងការ កែប្រែមានសារៈសំខាន់ណាស់សំរាប់កំនើនសេដ្ឋកិច្ច ប្រកបដោយសមធម៌ ។ ទន្ទឹមនោះដែរការពង្រីកវិស័យហិរញ្ញវត្ថុ នាំមកនូវហានិភ័យ ដូច្នេះត្រូវមានការពិចារណាយ៉ាងល្អិតល្អន់ ទៅលើបរិដ្ឋាននៃការអភិវឌ្ឍហិរញ្ញវត្ថុ ដោយត្រូវផ្តោត ទៅលើការប្រុងប្រយ័ត្ន កាត់បន្ថយហានិភ័យ តម្លាភាព និងការអនុវត្តជាឯកសមាធាននូវចំនួនបញ្ញាត ។

បច្ចុប្បន្នមានការទទួលស្គាល់យ៉ាងច្បាស់ថា ប្រព័ន្ធហិរញ្ញវត្ថុមួយដ៏សំបូរបែបប្រកបដោយភាពប្រកួតប្រជែង តែជាប្រព័ន្ធហិរញ្ញវត្ថុដែលមានភាពឬងមាំប្រុងប្រយ័ត្ន នឹងដើរតួ

នាទីយ៉ាងសំខាន់ក្នុងដំណើរការអភិវឌ្ឍតាមរយៈការជានា នូវការកេណ្ឌប្រមូល និងការបែងចែងធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ តាមរយៈការអភិវឌ្ឍប្រព័ន្ធ ហិរញ្ញវត្ថុនៅកម្ពុជា ប្រព័ន្ធនេះ នឹងជម្រុញដំណើរការប្រមូលផ្តុំរវាងអ្នកសន្សំនិងអ្នកវិនិយោគ រួមជាមួយនឹងអ្នកដែលមានតម្រូវការហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព ហើយដូចនោះនឹងពង្រឹងការបង្កើនកំណើនសេដ្ឋកិច្ច និងភាពមាន ការងារធ្វើ។

**ចក្ខុវិស័យនៃវិស័យហិរញ្ញវត្ថុ**




## ក្រាភិច១០.១ ចក្ខុវិស័យហិរញ្ញវត្ថុ

ទីផ្សាររូបិយវត្ថុ ជាទីផ្សារសម្រាប់ជួញដូរឧបករណហិរញ្ញវត្ថុដែលអាចជួញដូរបាន ដូចជាប័ណ្ណលិខិត បំណុល សញ្ញាប័ណ្ណរដ្ឋ និងប័ណ្ណភាគហ៊ុន និងសញ្ញាប័ណ្ណសាជីវកម្ម។ ទីផ្សារហិរញ្ញវត្ថុ រួមមានទីផ្សារ រូបិយវត្ថុនិងអន្តរធនាគារ និងទីផ្សារទុន។ ទីផ្សារអាចពាក់ព័ន្ធនឹងអន្តរការិយកម ដូចជាទីផ្សារមូលប្រ័ត ប្រតិបត្តិកររក្សាទុកមូលប្រ័ត និងមូល និធិវិនិយោគជាក្រុម និងមូលនិធិសោធននិវត្តន។ ទីផ្សារអន្តរ ធនាគារជាទីផ្សារសម្រាប់កម្ចីរយៈពេលខ្លី ជាទូទៅក្នុង រយៈពេលរវាង ២៤ម៉ោង និង១២ខែ ជារឿយៗ ក្នុងទម្រង់ជាមូលប្រ័ត ដូចជាប័ណ្ណ សងតាម បញ្ជា រវាងធនាគារនានា និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀតនៅ ក្នុងទីផ្សារហិរញ្ញវត្ថុ ដែលមានការអភិវឌ្ឍច្រើន។ ទីផ្សាររូបិយវត្ថុជាទីផ្សារ សម្រាប់ឥណទានរយៈពេលខ្លី ដែលមានរយៈពេលតិចជាងមួយឆ្នាំ ជាទូទៅក្នុងទម្រង់ជាមូលប្រ័ត ដូចជា ប័ណ្ណសង តាមបញ្ជា និងសញ្ញាប័ណ្ណរដ្ឋរយៈពេលខ្លី។ ទីផ្សារអន្តរធនាគារផ្តល់នូវយន្តការ ដ៏សំខាន់ក្នុងការកំណត់អត្រាការប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងហានិភ័យដោយធនាគារ និងអន្តរការិយផ្សេងទៀត។ ទីផ្សាររូបិយ វត្ថុពង្រីកនូវយន្តការក្នុងការកំណត់ថ្លៃ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និងការគ្រប់គ្រងហានិភ័យទៅ ដល់រដ្ឋា- ភិបាលនិងក្រុមហ៊ុន ។ បច្ចុប្បន្នពុំទាន់មានទីផ្សាររូបិយវត្ថុនិងអន្តរធនាគារនៅកម្ពុជាឡើយ ទោះបីជាមានការអនុម័ត ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិ

ការទូទាត់សងប្រាក់ និងច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្មនៅឆ្នាំ២០០៥ ពោលគឺ មានមូលដ្ឋានច្បាប់ជាសំខាន់សម្រាប់ទីផ្សាររូបិយវត្ថុ និងអន្តរធនាគាររួចក៏ដោយ។

## ១០.២.ប្រព័ន្ធធនាគារកម្ពុជា

បច្ចុប្បន្ន មានធនាគារដែលមានអាជ្ញាប័ណ្ណចំនួន ១៥ រាប់ទាំងធនាគារសាខាបរទេសចំនួន ៣ ធនាគារ ឯកទេសចំនួន៤ និងការិយាល័យតំណាងធនាគារបរទេសចំនួន២។ បន្ថែមលើនេះ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន ដែល ដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមែប្រមូលការសន្សំ និងអន្តរការិយកម្មហិរញ្ញវត្ថុសម្រាប់ឯកត្តជន និងសហគ្រាស ធុនតូច ជាពិសេសនៅក្រៅតំបន់ទីក្រុងសំខាន់ៗ។ ជាងនេះទៅទៀតមានអ្នកឱ្យខ្ចីចងការ និងអ្នកប្តូរប្រាក់ជាច្រើន បានដើរតួយ៉ាងសំខាន់ក្នុងការផ្ទេររូបិយប័ណ្ណបរទេស និងការឱ្យខ្ចីតូចៗ។

ទាក់ទងនឹងស្ថិរភាពហិរញ្ញវត្ថុ និងធនាគារ ធនាគារជាតិនៃកម្ពុជាបានដើរតួយ៉ាងសកម្មក្នុងការបង្កើត និងអនុវត្ត ក្របខ័ណ្ឌច្បាប់ ដើម្បីគាំទ្រសកម្មភាពធនាគារ និងធ្វើបញ្ញត្តិកម្មគ្រប់គ្រងលើធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស រាប់បញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផង។ សកម្មភាពទាំងនេះជួយជម្រុញឱ្យ មានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងកាត់បន្ថយភាពក្រីក្រ។

ដើម្បីអភិវឌ្ឍនវិស័យធនាគារមួយដែលឬងមាំ ចក្ខុវិស័យនិងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១ ដល់ ឆ្នាំ២០១០ បានសង្កត់ធ្ងន់លើផ្នែក ៦គឺ :

- បង្កើតក្របខ័ណ្ឌមូលដ្ឋានសម្រាប់គោលនយោបាយរូបិយវត្ថុ
- បង្កើតក្របខ័ណ្ឌត្រួតពិនិត្យធនាគារ
- កែទម្រង់រចនាសម្ព័ន្ធប្រព័ន្ធធនាគារ
- បង្កើតក្របខ័ណ្ឌសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់
- ឆ្ពោះទៅកាន់តំបន់ជនបទ និង
- ការកសាងសមត្ថភាព។

ចំពោះធនាគារ គោលដៅគឺការអភិវឌ្ឍប្រព័ន្ធធនាគារមួយមានប្រសិទ្ធភាព សមាហរណកម្មនិងមានលក្ខណៈ ប្រកួតប្រជែងដែលត្រូវបានបញ្ញត្តិកម្ម និងត្រួតពិនិត្យត្រឹមត្រូវ និងប្រមែប្រមូលការសន្សំដោយមានប្រសិទ្ធភាពដើម្បី ផ្តល់ហិរញ្ញប្បទានដើម្បីគាំទ្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ វិស័យធនាគារដែលខ្លាំងបែបនេះ និងគាំទ្រ កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ហើយជាមួយគ្នានោះ បន្ថយជាអប្បបរមានូវហានិភ័យនៃវិបត្តិហិរញ្ញវត្ថុ។

គោលដៅរួមទាំងនេះមានធាតុសំខាន់ពីរគឺ (១) ស្ថិរភាពហិរញ្ញវត្ថុ និង (២)ការអភិវឌ្ឍហិរញ្ញវត្ថុដើម្បីគាំទ្រ កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។

សារៈសំខាន់នៃស្ថិរភាពហិរញ្ញវត្ថុជាធម្មតាត្រូវបានមើលឃើញថា ជួយដល់ការអភិវឌ្ឍ និងកាត់បន្ថយនូវ ហេតុការណ៍នៃវិបត្តិហិរញ្ញវត្ថុត្រូវបានឯកភាពជាទូទៅ ដោយសង្កត់ធ្ងន់ទៅលើ

(១) បទបញ្ញត្តិហិរញ្ញវត្ថុ និងការត្រួត ពិនិត្យ និង (២) កែលំអប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងការអនុវត្តនឱ្យស្របតាមច្បាប់។

ចំពោះការអភិវឌ្ឍហិរញ្ញវត្ថុដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រមានជាតុសំខាន់ៗបីគឺ:

- មធ្យោបាយផ្ទេរប្រាក់ ការទូទាត់សងប្រាក់ និងការទូទាត់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព
- ការប្រមែប្រមូលការសន្សំ
- អន្តរការិយកម្ម និងការបែងចែកធនធាន។

កត្តាគន្លឹះចំពោះជាតុសំខាន់បីគឺ: រក្សា នឹងបង្កើនជំនឿទុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុ ស្ថាប័នហិរញ្ញវត្ថុ និង បញ្ញត្តិហិរញ្ញវត្ថុ:

-ជំនឿទុកចិត្តគ្រប់គ្រាន់របស់អ្នកសន្សំប្រាក់ ដូច្នេះពួកគេទុកប្រាក់នៅក្នុងស្រុក ហើយដាក់ការសន្សំរបស់ពួក គេក្នុងប្រពន្ធ័ហិរញ្ញវត្ថុផ្លូវការ

- ជំនឿទុកចិត្តរវាងអ្នកខ្ចីដើម្បីប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុផ្លូវការសម្រាប់ហិរញ្ញប្បទាន និង

- ជំនឿទុកចិត្តទៅវិញទៅមកក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ។

និយាយជារួម ជំនឿទុកចិត្តរបស់អ្នកសន្សំ អ្នកខ្ចីប្រាក់ និងគ្រឹះស្ថានហិរញ្ញវត្ថុ គឺជាលទ្ធផលនៃជំនឿទុកចិត្ត លើប្រព័ន្ធបទបញ្ញត្តិ និងត្រួតពិនិត្យ ដែលត្រលប់មកវិញ គឺអាស្រ័យទៅលើប្រសិទ្ធភាពរបស់វា។

ការចាត់ចែងធនាគារ និង ហិរញ្ញវត្ថុ នៅកម្ពុជាមានភាពធម្មតា ។ ភាពធម្មតានោះ ធ្វើឱ្យមានវត្តមាន នូវយន្តការបីសំខាន់ ទីផ្សារហិរញ្ញវត្ថុ អង្គការប្រមូលសន្សំសំចៃ និង រតនាគារសាធារណ: ដ៏សកម្មក្នុងវិស័យនោះ។ គ្មានផ្សារលក់ហ៊ុន គ្មាន cheques postaur postaux ហើយរតនាគារធ្វើអន្តរាគមន៍ ដោយមិនប្រាប់ទៅធនាគារកណ្ដាល ដើម្បីដោះស្រាយការលំបាកផ្នែករតនាគារឡើយ ។ ការផ្សាយនូវ bons du Tresor ទទួលបានតែលទ្ធផលដ៏ស្តួចស្តើង ដោយសារសារៈសំខាន់គាំទ្រធនាគារពាណិជ្ជកម្ម ។

គេសិក្សានូវរាល់ស្ថាប័នសកម្ម ក្នុងនិយមន័យ និង ការអនុវត្តនយោបាយរូបិយវត្ថុ ដោយពិនិត្យជាបន្តបន្ទាប់នូវៈ

- ធនាគារជាតិនៃកម្ពុជា
- ធនាគារផ្សេងៗទៀត
- អង្គការឥណទាន ផ្សេងៗទៀត

### ១០.២.១.ធនាគារជាតិនៃកម្ពុជា (B.N.C)

ធនាគារជាតិនៃកម្ពុជា (B.N.C) បានកើតឡើងថ្ងៃចុងក្រោយនៃឆ្នាំ ១៩៥៤ នៅសម័យនោះ មានការចុះហត្ថលេខា នៅក្រុងប៉ារីស នូវកិច្ចព្រមព្រៀងចតុភាគី ដែលនិយាយដល់ការ

បំបែកសហព័ន្ធរូបិយវត្ថុ ដែលបានបង្កើតឡើងនៅ Pau នៅឆ្នាំ ១៩៥០ ។ ប្រទេសនីមួយៗ នៃរដ្ឋបង្រួបបង្រួមឥណ្ឌូចិន បានជតទូលឯករាជ្យក្នុងវិស័យរូបិយវត្ថុហើយត្រូវបានបោះពុម្ពផ្សាយក្រដាសប្រាក់ផ្ទាល់ខ្លួន ។ បុព្វសិទ្ធិបោះពុម្ពផ្សាយនៅកម្ពុជាជាភារៈកិច្ចរបស់ B.N.C ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៥៥ ។

ធនាគារB.N.C បានបង្កើតឡើងក្រោមរូបភាពនៃក្រុមហ៊ុនសេដ្ឋកកិច្ចចម្រុះតែយកតាមច្បាប់ឯកជន។ តាមពិត គ្មានមូលធនណាមួយធ្លាប់បានចូលរួមទុន ដល់ធនាគារនេះទេ ។ នៅពេលមានការធ្វើបដិរូបសេដ្ឋកិច្ចពីខែ វិច្ឆិកា ១៩៦៣ B.N.C បានក្លាយជាគ្រឹះស្ថានសាធារណៈមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្ម ។

លក្ខណៈដើមប្រគល់ឱ្យធនាគារនូវភាពឯករាជ្យយ៉ាងទូលំទូលាយពីរដ្ឋាភិបាល។ បទឧទ្ទេសនាមនៃចំនុចនានារបស់ក្រិត្យ ដែលដាក់ឱ្យអនុវត្តបញ្ជាក់ថា"ចំនុចនានានៃលក្ខណៈត្រូវតែយកជាការបានដើម្បីឱ្យអាជ្ញាធរត្រៀមវាយតម្លៃជាមុនក្នុងកិច្ចការពារស្របច្បាប់នូវផល ប្រយោជន៍រូបិយវត្ថុ របស់ជាតិឈរលើនយោ-បាយរបស់រដ្ឋាភិបាលតែវា ដូចជាទទួលនូវឥទ្ធិពលរដ្ឋាភិបាលលោកតាមរយៈបំណងនៃភាគីនានា"។ អគ្គទេសាភិបាល និង អគ្គទេសាភិបាលរងត្រូវចាត់តាំងឡើង ដោយព្រះប្រមុខរដ្ឋ ដែលមានតែព្រះអង្គទេ ដែលអាចដកតំណែងបាន ។ ជាក់ស្តែង មានតែឥស្សរៈជនពីររូបនោះទេ ដែលកាន់តំណែង តាំងពីការបង្កើតធនាគារនោះមកសមត្ថកិច្ចរបស់គេ បានរួមវិភាគទានយ៉ាងច្រើនដល់អជ្ញាធរ ហើយគួរកត់សម្គាល់នូវឯករាជ្យភាពរបស់ធនាគារ ដែលមានការទាញអារម្មណ៍យ៉ាងខ្លាំង ។ នៅឆ្នាំចុងក្រោយៗនេះ សហសេវិកនៃ B.N.C បានបង្ហាញនូវតម្លៃដ៏សកម្ម ព្យាយាមបំផុតនៃស្ថាប័នមួយរបស់ព្រះរាជាណាចក្រ ។

ដើម្បីពិនិត្យមើលថា តើ B.N.C ជ្រៀតចូលក្នុងសៀគ្វីសេដ្ឋកិច្ចបែបណានោះ ត្រូវពិនិត្យនូវតុល្យការ ។ តុល្យការបានដកស្រង់ នូវគណនេយ្យ ដែលចលនាមានអត្ថន័យសេដ្ឋកិច្ច រហូតដល់ ថ្ងៃ ៣១-១២-១៩៦៥ គិតជារៀល ។

<u>អកម្ម</u> :-ផ្សព្វផ្សាយការងារគណនេយ្យឯកជន៤,៨០១,៧៣១,០០០

-គណនេយ្យតម្កល់ ៧១៣,៧៣១,០០០-គណនេយ្យកិច្ចព្រមព្រៀងទូទាត់ ១២៣,០០៧,០០០

-ទុនបម្រុង៦៨៧,៩៦០,០០០

សរុប៦,៣២៦,៤១៣,០០០

<u>សកម្ម</u> :-មាន និង រូបិយប័ណ្ណ៣,៦៦៥,៥៥៨,០០០

-Portefeuille ( titre et effet )៧៧,៦២៥,០០០-បុរេប្រទានដល់រតនាគារ C/C ពិសេស៥៦០,០០០,០០០

-អចលនទ្រព្យ ការចូលរួមហ៊ុន ។ល។២,០២២,៨២៩,០០០សរុប ៦,៣២៦,៤១៣,០០០

ដូចរាល់តុល្យការ គឺការបញ្ជាក់នូវសន្និធិប្រមូលជាស្ថិតិក្នុងខ្ទង់ផ្សេងៗ ក្នុងរយៈពេលមួយប្រាកដ។ ដោយដាក់តួលេខជិតគ្នា នូវតុល្យការ ពីរ ជាបន្តបន្ទាប់ គេអាចបញ្ចេញឱ្យឃើញ នូវ FLUX ការហូរ ។ ការសិក្សាពី FLUX នោះមានសារៈសំខាន់ ។ ដែលហៅថា FLUX NET ជា FLUX ដែលអាចលាក់នូវចលនាទិសផ្ទុយពីគ្នា ឧទាហរណ៍ កំណៃប្រាក់កំពុងចរាចរ មានចំនួន ៤.៨ ពាន់លានរៀល នៅថ្ងៃ ៣១ ធ្នូ ១៩៦៥ ឡើងដល់ ៥.៣ ពាន់លានរៀល នៅថ្ងៃ ៣១ធ្នូ ១៩៦៦ គេអាចនិយាយបានថា ចរាចរ Fiduciaire កើន ០.៥ ពាន់លានរៀលនៅឆ្នាំ១៩៦៦ ប៉ុន្តែកេដឹងភ្លាមថាតួលេខនេះបង្ហាញថាមិនសូវច្បាស់ បើដូចនេះ ជាក់ស្តែងនៃចរាចរ fiduciarre កើនឡើងទៅដល់ ៥.៧ ពាន់លានរៀល នៅថ្ងៃ ៣១ មេសា ១៩៦៦ រហូតដល់ថ្ងៃ ៣១ ធ្នូ ១៩៦៦វាចុះមកវិញនៅត្រឹម ៤.៩ពាន់លានរៀល នោះជាឧទាហរណ៍ប្រហាក់ប្រហែលដែលត្រូវប្រុងប្រយ័ត្ន ។

នៅផ្នែកអកម្មនៃតុល្យការ យើងឃើញដូចការអនុវត្ត គណនេយ្យជាទូទៅ ការបញ្ជាក់ពីប្រភពធនធានដែលធនាគារមានដល់ ថ្ងៃ ៣១ ធ្នូ ១៩៦៤ នូវប្រភពធនធានស្មើនឹងបំណុល ។ ប្រភពធនធាននោះប្រមូលផ្តុំជាបីក្រុម ៖ ទុន និង ប្រាក់ចំណេញ ក្រដាសប្រាក់ចរាចរ គណនីឥណទាន។

ការចុះបញ្ជីទុននៅផ្នែកអសកម្មនៃតុល្យការចាប្រពៃះ ធនាគារជាប់ឥណទានពន្ធ មានកម្រិតស្មើនឹងចំនួនទុនចំពោះរដ្ឋ ដែលបានផ្តល់ឱ្យខ្លួនខ្ចី ។ ចំនួនទុនដែលជាក់ស្តែង មានចំនួន ១៥០,០០០,០០០ រៀល បន្ថែមនូវមូលនិធិបម្រុង នៃអ្នកចុលនិវត្តន៍ រួមនិងគណនី ដែលវាយតម្លៃឡើងវិញ ដែលបង្កើតឡើងដោយប្រាក់ចំណេញ សម្រេចបានដោយធនាគារ ។ ទុនមានភាពដូចជាមុលនិធិសុទ្ធ នៃធនាគារ ។ ពីមួយឆ្នាំទៅមួយឆ្នាំ ទុននោះបានកើនឡើង ។ ពាក្យថា Poste emission fiduciaire ជាក្រដាសប្រាក់ ដែលធ្វើចរាចរក្នុងប្រទេស ដែលចំនួនពិតរបស់វាមិនដឹងជាប៉ុន្មានឡើយ ដោយសារគ្មានការអនុវត្ត នៃកិច្ចព្រមព្រៀងចតុភាគី នៅប៉ារីសនាខែធ្នូ ១៩៥៤ ។ ការចុះបញ្ជីនៅផ្នែកអកម្ម នៃប៉ុស្តិ៍នោះ ងាយស្រួលពន្យល់ដោយគ្រាន់តែចរាចរក្រដាសប្រាក់តែប៉ុណ្ណោះ ។ ការបោះប្រាក់ ជាវិធានការទូលាយសេរី ធនាគារបោះពុម្ពប្រាក់ ពេលមានបុលប្រទានរបស់រតនាគារ ផ្តល់ឥណទានដល់សេដ្ឋកិច្ច តាមកម្រិតមាស និង ស្តុករូបិយប័ណ្ណ ។ ប៉ុន្តែគ្មានតំនាក់ទំនងជាកាតព្វកិច្ចទេ រវាងបេឡា មាស និងការចរាចរសាច់ប្រាក់ ។ មានតែការកំណត់ជាលក្ខន្តិកៈទេ ដែលកំណត់បាននូវកម្រិតខ្ពស់នៃការបោះពុម្ពក្រដាសប្រាក់សរុបក្នុងការចរាចរ ។

គណនីតម្កល់ឥណទាន ជាសមាសភាពអកម្មទីបី នៃតុល្យការ ។ គណនីតម្កល់ឥណទានតាមរយៈការប្រគល់មូលនិធិនៃរតនាគារសហគ្រាស និង គេហជន និងធនាគារខ្លួនបង្កើតបានជាគណនីតម្កល់ឥណទាន ។

គណនីដែលហៅថា៖ កិច្ចព្រមព្រៀងទូទាត់ ជាកណនីឥណទានដែរ ហើយអាចចាត់ថ្នាក់ក្នុងប្រភេទខាងដើម ប៉ុន្តែត្រូវគិតជាមុន ដើម្បីបែងចែក គិតទៅតាមលក្ខណៈប្លែកៗ ។ ក្នុង

ទំនាក់ទំនងពាណិជ្ជកម្ម ជាមួយប្រទេសមួយចំនួន ពិសេសជាមួយប្រទេសកម្មុយនីស្ត ប្រតិបត្តិការមិនបានទៅដល់ការទូទាត់ទេ គឺគ្រាន់តែ បានចុះ ក្នុងខ្ទង់បញ្ជី ដែលហៅថា cleaning "បំភ្លឺ" ឬ ហៅថាកិច្ចព្រមព្រៀងចូខាត់ ។ គឺសមតុល្យ (solde) ខែការចុះ បញ្ជីនោះដែលមាននៅក្នុងតុល្យការនៃ B.N.C ខាងអកម្ម ព្រោះវាជាឥណជានខាងសកម្ម ព្រោះវាជាឥណទាន ។ នោះជាបំណុលចំពោះបរទេស នៃប្រទេសពិសេសមួយ ។

postes សកម្ម នៃតុល្យការ ក៏អាចប្រមូលផ្តុំបានដែរ ។ បេឡា មាស និងរូបិយវត្ថុ គឺជាដុំមាស hiyots និង ប្រាក់គ្រប់គ្រងរក្សាដោយ B.N.C នៅភ្នំពេញ ឬ តម្កល់ក្នុងនាម B.N.C នៅធនាគារបរទេស ព្រមទាំងរូបិយ វត្ថុបរទេស ដែលមាន ឬ ចុះបញ្ជីបរទេស ។

គួរកត់សម្គាល់ថា តួលេខជារៀល មិនអាចគិតជារូបិយប័ណ្ណបរទេសតែមួយនោះទេ B.N.C មានលុយ ហ្វ្រង់ ដែលកំណត់អត្រា ១០ រៀល ក្នុងមួយហ្វ្រង់ ឯដុល្លារមានអត្រាថ្លៃ ៣៥ រៀល ក្នុង មួយដុល្លារ៖ គេត្រូវវាយ តម្លៃគ្រឿងបម្រុងទាំងនោះជាដុល្លារ ឧទាហរណ៍ ចង់ស្គាល់កម្រិតលុយហ្វ្រង់ ដែលមានគិត ដូរជាអត្រា ៥ ហ្វ្រង់ ក្នុងមួយដុល្លារ ប៉ុន្តែការបែងចែករូបិយប័ណ្ណដោយប្រាក់ និងរូបិយប័ណ្ណផ្សេងៗ គឺរក្សាជាសម្ងាត់ដោយធនាគារ ។

ខ្ទង់ postfeuille , tite et effet មានពីរប្រភេទ ដែលតាមមុខងារផ្សេងគ្នា ។ ទីមួយ title កាន់កាប់ ដោយធនាគារ ជាចលនាវត្ថុបរទេស ដែលគិតជាមាស និង រូបិយប័ណ្ណបាន ។ ទីពីរ ឥណទាន ដែលធនាគារ ផ្តល់ដល់សេដ្ឋកិច្ច ក្រោមរូបភាពជា rée compte មានអនុភាព ជាពាណិជ្ជកម្ម ឬ ហិរញ្ញវត្ថុ ។

ជំនួយដល់រដ្ឋ គឺចុះបញ្ជីក្នុងខ្ទង់ "បុរេប្រទាន នៃរតនាគារក្នុងគណនី cuat" គេកត់សម្គាល់ថាលក្ខន្តិកៈ ធនាគារ សរសេរថា ការបូកសរុប នូវបុរេប្រទានដែលយល់តាំងពីការបង្កើតធនាគារ គឺគ្មានពេលណាដែលលើស ពី ១/៤ ខែចំណូលសារពើពន្ធប្រមូលបាន សម្រាប់គណនីនៃថវិការដ្ឋ ក្នុងរយៈពេលមុននេះឡើយ ។

ទទឹងនិងបុរេទាន នៃរតនាគារ courant គេឃើញតុល្យការគ្រប់គ្រាន់នៃធនាគារ នូវប៉ុស្តិ៍ផ្សេងមួយ ទៀត មានឈ្មោះថា " បុរេប្រទានរដ្ឋ " ជាអតីតបំណុលនៃរតនាគារឥណ្ឌូចិន ដែលជាបក្នុង នៃរដ្ឋកម្ពុជា នៅពេល ដោះស្រាយ រតនាគារឥណ្ឌូចិន គិង វិជ្ជាស្ថានបោះប្រាក់អន្តររដ្ឋ និងមួយទៀតជាបំណុល នៃរតនាគារចំពោះស្ថាប័ន ។ ជាបំណុលមិនសង ដែលត្រូវតែចុះក្នុងតុល្យការ ក្នុងកម្រិតប្រាក់ដដែលនោះ មានចំនួនមួយពាន់លានរៀល ។ នៅ ក្នុងផ្នែកប៉ុស្តិ៍ សកម្ម និង ឥណទានលើបរស ដូចគ្នា និង ប្រតិបត្តិការប្តូរផ្លាស់ ក្រដាសប្រាក់ នៅឆ្នាំ ១៩៥៥ ដែលហាក់ដូចជាមិនទាន់បានប្រមូលមកវិញនៅឡើយ ។

ការវិភាគ នៃការវិវដ្តប៉ុស្តិ៍នានា នៃធនាគារពាណិជ្ជកម្មរដ្ឋ ខែតុល្យការអាចនិយាយថា តើនយោបាយ អនុវត្តដោយធនាគារមានបែបណា ប៉ុន្តែត្រូវតែសិក្សានូវប្រព័ន្ធ នៃធនាគារសិន ។

### ១០.២.២.ធនាគារពាណិជ្ជកម្ម

នោះជាការផ្សាយ នូវអត្ថបទមួយដែលនិយាយពីការធ្វើជាតូបនីយកម្មនៃមុខរបរធនាគារ ។ ធនាគារឯកជនជាង ១០ នៅកម្ពុជាបាន ត្រូវជំនួយដោយធនាគាររដ្ឋពីរ ៖ ធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម និង ឥណទានជាតិ ។ INADANA JATI

### ១០.២.៣.បេឡាសោធនវត្តន៍ស៊ីវិល នៃកម្ពុជា (C.P.C.E)៖

បេឡាសោធនកិវត្តិ៍ស៊ីវិលកម្ពុជា ជាគ្រឹះស្ថានសាធារណៈមានស្វ័យហិរញ្ញកិច្ច ដែលធ្វើការបង្គាប់ពីបេឡាសោធនស៊ីវិលនៃឥណ្ឌូចិន បង្កើតនាឆ្នាំ ១៩៥៩ ។ បេឡានេះបានផ្គត់ផ្គង់ដោយការដកហូត ៦% លើប្រាក់បៀវត្សរ៍ ឱ្យមន្ត្រីរាជការ និង ការរួមវិភាគទាននៃថវិកាជាតិក្នុងអត្រា ១៤% ។ គោលដៅ គឺជាសោធនជំនួយដល់មន្ត្រីចូលវត្តន៍ ប៉ុន្តែក៏មានលទ្ធភាពទិញនូវអនុភាពដែលធានាដោយរដ្ឋាភិបាល ហើយសម្រាប់ឱ្យខ្ចីដល់សមូហភាពសាធារណៈ ទីពីរ នឹងឱ្យខ្ចីដល់គ្រឹះស្ថានសាធារណៈនោះជាតួនាទីសំខាន់មួយដែរ ។ ការឱ្យខ្ចីក្នុង អត្រាទន់ភ្លន់មួយ ២% ឬ ៣% ត្រូវបានធានាដោយអាជ្ញាធរជាម្ចាស់ រួចជាអភិបាលខេត្ត ឬ អភិបាលក្រុង រដ្ឋមន្ត្រីហិរញ្ញវត្ថុជាដើម ហើយផ្គត់ផ្គង់ តែលើហិរញ្ញកិច្ចការងារមានប្រយោជន៍សាធារណៈ ដែលមានសារៈសំខាន់ ខាងសេដ្ឋកិច្ចសង្គម ។

### ១០.២.៤ បេឡាសម្ភារៈ( C.N.E. )៖

C.N.E ជាអង្គការសំខាន់ដែលបានបង្កើតឡើងនៅឆ្នាំ១៩៥៦ ក្រោមរូបភាពនៃគ្រឹះស្ថានសាធារណៈ។ បំពេញមុខងារបីបែបខុសៗគ្នា ។

**ទីមួយ៖** បេឡារចុះបញ្ជីគណនីរដ្ឋនៃប្រតិបត្តិការវិនិយោគបញ្ជាក់ជាមុខ ២ ការដោយមានឥណទាន វិនិយោគជាជំនួយ និងការវិនិយោគ និងថវិការជាតិ ។

**ទីពីរ៖** បេឡាសង្កត់យកតែពីគណនីរដ្ឋ ដែលចូលហ៊ុនតិច ឬច្រើនក្នុងក្រុមហ៊ុន សេដ្ឋកិច្ចចម្រុះ ឬរដ្ឋ។ តាមរយៈទំងន់កែសំលេងរបស់ភាគហ៊ុននៃ CN.E.នៅក្នុងកិច្ចប្រជុំទៅទើបបេឡានេះប្រើឥទ្ធិពលនិងត្រួតពិនិត្យ លើអង្គការនេះ ។

**ទីបី៖** នៅចុងបញ្ចប់ C.N.E អាចតាមរយៈគណនីរបស់ខ្លួន អនុញ្ញាតឱ្យរយៈពេលមធ្យម និងដល់ ផលិតករ តូច និង មធ្យម ។ នៅផ្នែកនេះបេឡាមានប្រាក់ ១០០ លានរៀល ព្រមទាំងជំនួយសហរដ្ឋអាមេរិកចំនួន ៧០ លាន ដុល្លារនេះជា ( មូលនិធិសុទ្ធ ) នាទីឱ្យខ្ចីនេះបញ្ជាក់ថា C.N.E ជាធនាគារ ទោះបីបេឡាមានទទួលនាទីតែទទួលប្រាក់តម្កល់ក៏ដោយ។ ឥណទានដែលធនាគារនេះ ឱ្យខ្ចីមានកវិតត្រឹមតែបេឡាដែលមាន ដែលគ្មានកើតឡើងសោះ តាំងពីការកកើតមកនោះ ។ C.N.E ឱ្យខ្ចី បានលុះត្រាតែការឱ្យខ្ចីត្រូវបានសងវិញយ៉ាងទៀងទាត់ ។

### ១០.២.៥.មន្ទីររាជសហករណ៍ (OROC.)៖

O.R.O.C.ជាអង្គការដែលមានសារៈសំខាន់ខាងនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល អង្គការផ្តល់ ឥណទាន មិនមែនជានា ។

## ១០.៣.តួនាទីធនាគារនៃប្រទេសកម្ពុជា

ធនាគារជាតិនៃកម្ពុជា នឹងចាត់វិធានការចាំបាច់ ដើម្បីពង្រីកវិសាលភាពនៃសេវាកម្មមីក្រូហិរញ្ញវត្ថុ ដែលជា តម្រូវការចាំបាច់របស់អាជីវកម្មធុនតូច និងសហគមននៅតាមជនបទ ជាពិសេស ចំពោះកសិករទាំងឡាយ ដែលមាន ដីស្រែតិចតួច ។ គោលបំណងសំខាន់ គឺដាក់ចេញប្រព័ន្ធមីក្រូហិរញ្ញវត្ថុទូលំទូលាយ និងមានប្រសិទ្ធភាព ដែលគ្រប ដណ្តប់លើផ្ទៃប្រទេសទាំងមូល ។ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញវិធានការដើម្បីៈ

- ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិៈ តាមរយៈការបន្តលើកកម្ពស់សមត្ថភាពរបស់ធនាគារជាតិកម្ពុជា ដើម្បី ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យប្រព័ន្ធហិរញ្ញវត្ថុ ដែលរួមមាន ការឬតបន្តឹងវិធានការ ប្រុងប្រយ័ត្ន ដើម្បីកសាងទំនុកចិត្តសាធារណៈ លើការប្រើប្រាស់សេវាកម្មមីក្រូហិរញ្ញវត្ថុ និង ធនាគារពាណិជ្ជនានា ។
- ពង្រឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុៈ តាមរយៈការលើកទឹកចិត្ត អង្គការក្រៅរដ្ឋាភិបាលដែលមិនទាន់បានចុះបញ្ជីឱ្យក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ ដើម្បីមានសិទ្ធិស្របច្បាប់ក្នុងការប្រមូលប្រាក់បញ្ញើ ។
- ពង្រីកបណ្តាញមីក្រូហិរញ្ញវត្ថុៈ តាមរយៈ ការជំរុញកំណើន ដោយផ្តល់អាជ្ញាបណ្ណទៅដល់គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ សម្រាប់បង្កើតរចនាសម្ព័ន្ធគ្រប់គ្រង ពង្រីកបណ្តាញប្រតិបត្តិការ បង្កើនសមត្ថភាព និង ប្រសិទ្ធភាព និង បង្កើតប្រាក់ចំណេញឱ្យបានច្រើន ដើម្បីផ្តល់ជូនតាមតម្រូវការខ្ចីរបស់ប្រជាជន នៅក្នុងតំបន់ទាំងនោះ ។
- កសាងសមត្ថភាពៈ តាមរយៈ ការផ្តល់ការបណ្តុះបណ្តាលជាមូលដ្ឋានដល់ប្រជាជនជាពិសេស ជនក្រីក្រ ដើម្បីឱ្យបានយល់ពីសេវាកម្មមីក្រូហិរញ្ញវត្ថុ ដូចជា សេវាសន្សំប្រាក់ និងការប្រើប្រាស់ប្រាក់កម្ចី សម្រាប់បង្កើតចំណូល និងកម្រិតជីវភាពរបស់ពួកគេប្រសើរឡើង ។
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានៈ តាមរយៈ ការពង្រឹងនិងការពង្រីកប្រព័ន្ធព័ត៌មានឥណទាន សម្រាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការបង្កើនទំនាក់ទំនងហិរញ្ញវត្ថុ រវាង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារពាណិជ្ជ ។

ធនាគារជាតិនៃកម្ពុជា នឹងបន្តអភិវឌ្ឍ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីធ្វើឱ្យកាន់តែស៊ីជម្រៅលើវិស័យ ហិរញ្ញវត្ថុ តាមរយៈៈ

- ការពិនិត្យឡើងវិញនូវច្បាប់និងបទប្បញ្ញត្តិដែលគ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារៈធនាគារជាតិ នៃកម្ពុជា នឹងត្រួតពិនិត្យជម្រើសទាំងឡាយ ដើម្បីធ្វើប្រតិភូកម្មការទទួលខុសត្រូវចំពោះអាជ្ញាធរផ្សេងៗទៀត ដើម្បី ត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ មិនមែនធនាគារ ។

• ការជំរុញការអភិវឌ្ឍអាជីវកម្មភតិសន្យាផ្សេងៗ: តាមរយៈ ការលើកទឹកចិត្តដល់សកម្មភាពផ្តល់ឥណទានដល់អាជីវកម្មភតិសន្យា ដែលជាប្រភពធនធានមួយទៀត សម្រាប់អាជីវកម្មធុនតូចនិងមធ្យម តាមរយៈការបង្កើតច្បាប់ ភតិសន្យាហិរញ្ញវត្ថុ ដែលផ្តោតជាសំខាន់លើសិទ្ធិនិងកាតព្វកិច្ច នៃភាគីជាប់កិច្ចសន្យា។

• ការអភិវឌ្ឍប្រពន្ធ័ចែករំលែកព័ត៌មានឥណទាន: ដើម្បីកែលម្អប្រពន្ធ័ចែករំលែកព័ត៌មានឥណទាន និង ដើម្បីបង្កើតឱ្យមានក្របខណ្ឌ័សម្រាប់ប្រព័ន្ធព័ត៌មានឥណទានដែលមានទ្រង់ទ្រាយធំ ។

•ពង្រឹងការតាមដានទីផ្សារប្តូរប្រាក់:តាមរយៈការកែលម្អ និង ការធ្វើបញ្ញត្តិកម្មទីផ្សារអាជីវកម្មប្តូរប្រាក់ បរទេស ។

• បង្កើតប្រព័ន្ធទូទាត់ជាតិ: តាមរយៈ ការបន្តលើកកម្ពស់ សុវត្ថិភាព ប្រសិទ្ធភាព និង សមត្ថភាព របស់ ប្រព័ន្ធនេះ ដោយការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធទូទាត់មូលប្បទានបត្រធនាគារ និងការអភិវឌ្ឍប្រព័ន្ធទូទាត់ អេឡិចត្រូនិច នៅថ្នាក់ជាតិ ដើម្បីគាំទ្រទីផ្សារអន្តរធនាគារ ។

ចំពោះសកម្មភាពជាក់លាក់មួយចំនួន ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តវិធានការនានាដើម្បី:

• ពង្រឹងរចនាសម្ព័ន្ធច្បាប់: បន្តកែលម្អក្របខ័ណ្ឌច្បាប់បទប្បញ្ញត្តិ និង ការត្រួតពិនិត្យវិស័យធនាគារ ជា ពិសេសគឺការរៀបចំពង្រឹង ដើម្បីធ្វើវិសោធនកម្មលើច្បាប់ ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងឱ្យមាន ស្ថិរភាពនៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

• អភិវឌ្ឍធនធានមនុស្ស: បន្តកែលម្អការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា និងពង្រឹងសមត្ថភាពត្រួតពិនិត្យ វិស័យធនាគារ និងត្រួតពិនិត្យផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជា ។

• លើកកម្ពស់ការប្រកួតប្រជែងដោយសេរី: តាមរយៈ ការពង្រឹងបទប្បញ្ញត្តិនៃការផ្តល់អាជ្ញាបណ្ណ និងការ ដាក់ឱ្យដំណើរការនូវហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់សម្រាប់ការគាំទ្របេកគំហើញ និងផលិតផលថ្មីៗនៅក្នុងវិស័យ ហិរញ្ញវត្ថុ និង ពិពិធភាវូបនីយកម្មវិស័យហិរញ្ញវត្ថុ ។

• កែលម្អនូវគុណភាពតម្លៃនិងភាពជំនឿទុកចិត្ត: លើប្រព័ន្ធទូទាត់និងមិនអាចទូទាត់សងបាន នៃធនាគារទាំងឡាយ ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្រ្តចាកចេញឱ្យមានលក្ខណៈជាប្រព័ន្ធក្នុងការដកចេញនូវវិធានការពិសេសនានា ដែលបានដាក់ចេញ ដើម្បីដោះស្រាយនូវផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុនិងការធ្លាក់ចុះ នៃសេដ្ឋកិច្ចសកលលោក។

## ១០.៤.នយោបាយរូបិយវត្ថុកម្ពុជា

ដើម្បីសរសេរពីនយោបាយរូបិយវត្ថុកម្ពុជា ឬ និយាយពីការប្រព្រឹត្តទៅ នៃប្រព័ន្ធធនាគា និង ហិរញ្ញកិច្ច គេពិនិត្យពីការខិតខំក្នុងវិស័យ បី និង លទ្ធផលរបស់វិស័យទាំងនោះ ។ ប្រព័ន្ធធនាគារ ខិតខំធានានូវ មុខងារបី៖ ស្ថេរភាពរូបិយវត្ថុផ្គត់ផ្គង់ជាហិរញ្ញវត្ថុសល់ពាណិជ្ជកម្ម

និងលើកកម្ពស់ការអភិវឌ្ឍ ។ ត្រូវស្រាវជ្រាវរកថាតើមុខងារ នោះត្រូវបំពេញបានដោយរបៀបណា ។

### ១០.៤.១.ស្ថេរកម្មប្រាក់រៀល

អាជ្ញាធររូបិយប័ណ្ណបានអនុវត្តន៍ ដោយជោគជ័យនូវនយោបាយរូបិយប័ណ្ណខ្លាំង ។ នេះគ្មានសង្ស័យឡើយលក្ខណៈសំខាន់នៃនយោបាយរូបិយវត្ថុកម្ពុជា ។ ស្ថេរកម្មប្រាក់រៀលត្រូវបានរក្សា ហើយនៅចុងឆ្នាំ ៥០ ដើមឆ្នាំ ៦០ កម្ពុជាមិនបានស្គាល់នូវអតិផរណាសំខាន់ទេ ខុសគ្នាពីប្រទេសក្រីក្រភាគច្រើន ។

ទិន្នន័យនៃប្រាក់រៀលដែលជាមូលដ្ឋានបញ្ជាក់មានភាពប្រេះស្រួយដែរ ។ កំណើនថ្លៃប្រាក់រៀលរហូតដល់ ៥០% ក្នុងរយះពេល ១០ ឆ្នាំគឺកើនថ្លៃ ៥% ក្នុងមួយឆ្នាំ ។ ប៉ុន្តែតួលេខនោះ ផ្តល់តែទំនិញមិនមែនអាហារទេ ។ ការវិវឌ្ឍនៃថ្លៃអង្ករលម្អិត គឺ ពី ៤.២៧ រៀល ក្នុងមួយគីឡូក្រាម ពីឆ្នាំ ១៩៥៦ ដល់ ៥.២០ រៀល ទៅ ១៩៦៥ នោះជាអតិផរណាទន់ភ្លន់មួយ។ គេដឹងថាកម្រិតប្រាក់បៀវត្សរ៍ នៃមុខងារសាធារណៈគ្មានឡើងសោះ តាំងពីឆ្នាំ ១៩៥៣ មក ។ ការទប់មិនឱ្យដំឡើងប្រាក់បៀវត្សរ៍ នាំឱ្យអំណាចនៃថ្លៃទឹកថយចុះបន្តិចបន្តួច មិនមានសារៈសំខាន់ ។

ហេតុដូចម្តេចបានជាអតិផរណា ជាទូទៅត្រូវបានបញ្ចៀសរួច នៅកម្ពុជា។ ការសិក្សាពីការវិវឌ្ឍនៃសំណុំ រូបិយប័ណ្ណ ធ្វើឱ្យឃើញនូវវិធានការនោះ ។ គេដឹងថាសំណុំប្រាក់ " made moetaire " កើនឡើងដោយទន់ភ្លន់ បំផុត ។ កំណើនសំណុំប្រាក់ គឺកើនស្មើនឹង សន្ទស្សន៍ខាងក្រោម៖

សំណុំរូបិយវត្ថុ ផលទុនដុលជាតិក្នុងថ្លៃថេរ

១៩៥៦......................១០០១០០
១៩៥៧......................១០២១០៤
១៩៥៨......................១០៩១១០
១៩៥៩......................១២៩១២១
១៩៦០......................១៣៧១២៨
១៩៦១......................១៣៤១២៩
១៩៦២......................១៤៥១៣៧
១៩៦៣......................១៣៨១៤១
១៩៦៤......................១៣៤១៤៤

កូនសោរ ស្ថេរភាពលុយរៀល ស្ថិតនៅក្នុងភាពស្រប ។ ចំណុចសំខាន់មួយទៀត គឺសំណុំរូបិយប័ណ្ណ មានការប្រែប្រួល។ នៅដំណាក់កាលដើមនៃរូបិយប័ណ្ណ seripturale និងរូបិយប័ណ្ណ fidiciaire គឺមានតម្លល់ ៦០% និង ៣០% នៃសំណុំរូបិយវត្ថុសរុប ។ នៅដំណាក់កាលសមាមាត្រ គឺបានប្តូរគ្នា interelaugee ហើយ បរិមាណកទ្រព្យសម្បត្តិឯកជនកើនឡើងពី

មួយឆ្នាំទៅមួយឆ្នាំ តាមសង្វាក់កម្រិតនៃការផ្ញើរប្រាក់ទៅធនាគារ មាននិន្នាការទ្រឹង ហើយរាប់ពីឆ្នាំ ១៩៦៣ ការតម្កល់ប្រាក់នៅធនាគារថយចុះ ។ បដិរូបសេដ្ឋកិច្ច និង ធនាគារ សម្រេចឡើងនាចុងឆ្នាំ ១៩៦៣ នាំដល់វិបត្តិនៃការបាត់បង់ជំនឿ នាំទៅដល់ការដកយកនូវប្រាក់តម្កល់ពីធនាគារ B.N.C.បានធ្វើឱ្យជោគជ័យនូវការឆ្លើយតបនឹងតម្រូវការក្រដាសប្រាក់ ឬ "ឥណទាន" ។ B.N.C.មិនញញើត និង បង្កើតយ៉ាងច្រើននូវរូបិយប័ណ្ណនៃទ្រព្យសម្បត្តិ ។ កំណើន ៣០% រវាងថ្ងៃ ៣១ ធ្នូ ១៩៦២ ដល់ ៣១ ធ្នូ ១៩៦៣ ។

ការដែលគួរចាប់អារម្មណ៍បំផុតនោះ គឺនៅពេលដែលគេពិនិត្យភាគីទាំងសងខាងនូវសំណុំរូបិយវត្ថុ "ឥណទាន និង អ្នកចែកចាយចរាចរប្រាក់ B.N.C.និង ធនាគារពាណិជ្ជកម្ម ពិនិត្យលើប្រាក់ដែលកំពុងចរាចរ " នោះគឺ តួនាទីដ៏សំខាន់ដែល ឥណទានិក លើបរទេស creauce sur l'étranger មានចំនួនតិចបំផុត គឺ ៥០% នៃសំណុំ រូបិយវត្ថុ ពេលខ្លះឡើងដល់ ៧០% នៃសំណុំរូបិយវត្ថុនេះទៀត ផង ។ ឥណទានសម្រាប់សេដ្ឋកិច្ច មានការថយចុះ ក្រោយពេលធ្វើបដិរូបសេដ្ឋកិច្ច និងធនាគារ នៅឆ្នាំ ១៩៦៣ ទោះបីជាមានការងើបឡើងវិញខ្លួនក៏ដោយ ឥណទាននោះ បានកើនឡើងដល់កម្រិតដើមវិញ នៅឆ្នាំ ១៩៦៦ ឥណទាន លើរដ្ឋ créance sur l'Etat បានរក្សាក្នុងកម្រិតទន់ភ្លន់ ក្នុងដំណាក់កាលមានការកើនឡើងនៃសេដ្ឋកិច្ច ចាប់ពីឆ្នាំ ១៩៦៣ មក ។

សារៈសំខាន់នៃឥណទានិកលើបរទេសដោះស្រាយបាន ដោយផ្អែកលើបញ្ហានៃការ "ប្រគល់ប្រាក់រៀល" couverture du riel ។

អ្នកអត្ថាធិប្បាយ ចូលចិត្តបង្ខិតចូលគ្នា នូវកម្រិតនៃក្រដាសផ្ញើចរាចរ ទៅនឹងការប្រមូលតម្កល់ទុកមាស របស់ B.N.C និង គណនាពី "ភាគរយនៃការប្រមូលផ្តុំប្រាក់រៀល ដែលមានដល់ទៅ ៧០% នៃសំណុំប្រាក់ទាំង អស់ ។ ការពិត មិនមែនសមាមាត្រនេះទេ ដែលមានសារៈសំខាន់ និង មានអត្ថន័យនោះ មិនទាន់មានការ បែងចែករវាងរូបិយប័ណ្ណសរសេរ scripturale និងរូបិយប័ណ្ណ fiduciaire ប្រាក់តំណាងទ្រព្យសម្បត្តិឯកជនចរាចរ ។ B.N.C.មិនមែនជាធនាគារតែមួយ ដែលតម្កល់មាស និង រូបិយវត្ថុខ្លាំងនៅកម្ពុជានោះទេ ។ នោះគឺសមាមាត្រនៃកម្រិត"ឥណទានលើបរទេសប្រៀបនឹងសំណុំទឹកប្រាក់សរុបទេដែលត្រូវយកមកសិក្សា ។

មិនមែនភាគរយនោះទេ ដែលមានអត្ថន័យជាចិត្តសាស្ត្រនោះ ។ លោក M.L.J.MKarthal បានបញ្ជាក់ថា បើកត្តាប្រាក់ ជាកត្រូវយល់ព្រមទទួល ដោយភ្នាក់ងារសេដ្ឋកិច្ច ហើយមិនមែងប្រាក់នោះ អាចដូរជាមួយមាស ជាមួយរូបិយប័ណ្ណខ្លាំងបរទេសបាន មានន័យថា ប្រាក់នោះទេ គឺសេចក្តីសម្រេចចុងក្រោយលើ តម្លៃប្រាក់រៀល គឺការគោរពដល់ឯកតាប្រាក់ ដែលយកប្រាក់នោះទៅផលិតទំនិញបានលក់នៅលើទីផ្សារ ហើយអទិភាពនៃផលិតផលនោះទេ ដែលជាអ្នកបង្កើតតម្លៃប្រាក់រៀល គឺមិនមែនភាគីនានា ដែលធ្វើឱ្យមានតម្លៃប្រាក់រៀលនោះ ។

សំណុំប្រាក់ត្រូវបានបង្កើតឡើង ដូចផលចុងដុលរបស់ជាតិ ហើយយើងបានឃើញថា អ្វីខ្លះបានកើតនៅកម្ពុជា ។ ការបដិសេធ ពេលខ្លះធ្វើឡើងដោយ B.N.C.មិនព្រមបោះពុម្ពក្រដាសប្រាក់ឱ្យមានធុនល្មម ដល់ ភាគី ទាំងអស់ឱ្យស្មើទីងការតម្កល់មាស គឺគ្មានន័យទេ ។ រចនាស

ម្ព័ន្ធ នៃភាគីទាំងអស់ជាម្ចាស់ សំណុំប្រាក់ចោទ ជាបញ្ហា ដែលទាក់ទងគឹងគោលដៅពីរទៀត នៃនយោបាយរូបិយវត្ថុ៖ ផ្គត់ផ្គង់ដល់ផ្នែកពាណិជ្ជកម្មនោះ គឺ ការធានារ៉ាប់រង ដល់ស្ថេរភាពនៃប្រាក់រៀល គេត្រូវតែទទួលស្គាល់នូវនយោបាយ នៃអាជ្ញាធររូបិយវត្ថុនោះ គឺ B.N.C.ដែលធ្វើនយោបាយ នោះទទួលបានជោគជ័យ ។

យើងក៏ត្រូវដឹងផងដែរថាជោគជ័យនោះ ត្រូវខូល គំរាមកំហែងទៅវិញ នៅឆ្នាំ ១៩៦៧ វិនភាពថវិកា បកស្រាយដោយសារ បុរេប្រទានដ៏ច្រើនឡើងៗ របស់ B.N.C.ទៅលើរតនាគារ ហើយមានការព្រួយបារម្មណ៍ថា សង្វាក់ និង ការកើនឡើងនៃកម្រិតទឹកប្រាក់ ដែលធ្វើឱ្យថ្លៃទំនិញកើនឡើងលឿនពេក ។ ស្ថេរភាពប្រាក់រៀល ជា ត្រូវគំរាមកំហែងចេញពី អតិផរណាមានប្រភពពីថវិកា ។

## ១០.៤.២.ការផ្តល់ហិរញ្ញវត្ថុដល់ពាណិជ្ជកម្ម

មុខងារសំខាន់នៃប្រព័ន្ធធនាគារ គឺ ការចូលដល់ការផ្លាស់ប្តូរ ឬការរនៅក្នុងសេដ្ឋកិច្ច នូវកម្រិតមួយ liquidité គ្រប់គ្រាន់ សម្រាប់ការធានារ៉ាប់រងការផ្គត់ផ្គង់ហិរញ្ញវត្ថុដល់ពាណិជ្ជកម្ម។ តើមុខងារត្រូវបានបំពេញ ដែរឬ នៅកម្ពុជា ។

តាមការសង្កេតបង្ហាញឲ្យឃើញថា ពាណិជ្ជកម្មធ្វើសកម្មភាពនៅកម្ពុជាជាពិសេសផ្នែកពាណិជ្ជកម្មក្រៅប្រទេស។ នៅក្នុងទីផ្សារក្នុងប្រទេស មួយភាគនៃពាណិជ្ជកម្មនោះ នៅធ្វើឡើងតាមរបៀបដូចទិញគ្នាមិនប្រើលុយទេ៖ កសិករ បានដូរស្រូវ សណ្តែក ជាមួយទំនិញឧស្សាហកម្មពីឈ្មួញកណ្តាល ដែលខ្លួនត្រូវការ ។ គេដឹងថារូបភាពនៃឥណទា បុគ្គលនោះ គឺការបុលបណ្តាក់ចងការ prét auraire ចំពោះការនាំចេញ និងនាំចូល ។ ផ្ទុយទៅវិញ ឥណទាន ធ្វើអន្តរាគមន៍យ៉ាងទូលំទូលាយ ។ អ្នកណាផ្តល់នូវឥណទាននេះ ?

រហូតដល់ឆ្នាំ ១៩៦៣ គឺ ធនាគារពាណិជ្ជកម្ម ជាអ្នកធានាផ្នែកហិរញ្ញវត្ថុ ដល់ប្រតិបត្តិការពាណិជ្ជកម្ម ក្រោមរូបភាពបុរេប្រទាន ធានារ៉ាប់រងផ្តល់តាមគណនី courant ការឱ្យខ្ចីរបស់ O.R.O.C.ខុសប្លែកពីការឱ្យ របស់ធនាគារ គឺឱ្យផ្ទាល់ទៅផលិតករ មានតួនាទីមួយចំនួនដែរ ។ ប៉ុន្តែតួនាទីនោះ ពិតជាបរិមាណ គឺឈរនៅ ជួរទីពីរ ។

តើធនាគារ ផ្តល់ហិរញ្ញកិច្ច ជាឥណទានបែបណា ដល់អ្នកនាំចូលខំខិញ និងអ្នកនាំចេញ ពិនិត្យលើ តុល្យការរបស់ពួកគេ នៃហិរញ្ញកិច្ចស្ថិតនៅក្នុងប្រាក់តម្កល់នៃអតិថិជនរបស់ពួកគេ ឬក៏នៅក្នុងមូលនិធិផ្ទាល់ របស់ពួកគេ ។ ធនាគារកណ្តាល មិនសូវអនុវត្តការងារហិរញ្ញវត្ថុដល់ពាណិជ្ជកម្មទេ ។

បដិរូបឆ្នាំ ១៩៦៣ ធ្វើឱ្យក្រឡាប់ចាក់ដីលំយន្តការនោះ ។ បាតុភាពនោះ កើតមាននូវការដកចេញប្រាក់ ផ្ញើរ ដែលចេះតែថយទៅៗ នូវលទ្ធភាពនៃឥណទានរបស់ធនាគារ ។ ធនាគារ ដែលធ្វើការជម្រះបញ្ជី ហើយមិន អនុញ្ញាតឱ្យខ្ចីបានទេ ទោះបីរយៈពេលខ្លីក៏ដោយ ។ ធនាគារ ធ្វើការដោយប៉ិនប្រសព្វ ដើម្បីជៀសវាងរាល់ឧបសគ្គ ដែលរាំងស្ទះការប្រមូលទិន្នផលស្រូវ ។ B.N.C.បានផ្តល់ដល់ B.K.C." ធនាគារកម្ពុជាពាណិជ្ជកម្មរដ្ឋ " នូវភាពងាយស្រួលដល់ការរៀបចំ

បញ្ចីខ្ចង់ឥណទាន នូវទឹកប្រាក់ ៤០ ដល់ ៦០០ លានរៀល ហើយ អនុញ្ញាតនូវលទ្ធិភាព រកចលនាវត្ថុ ពីសូណិចស៊ីម ចំនួនប្រាក់មានតម្លៃ ២០០ លានរៀល ។

នៅខែ ធ្នូ ១៩៦៥ portefeuille-effett នៃធនាគារ មានការបំប៉ោងជាថ្មី ហើយឥណទានដែលឱ្យខ្ចី ត្រូវបានសងមកវិញ។ បន្ទាប់មកមានការផ្តល់ជាហិរញ្ញកិច្ច នៃប្រតិបត្តិការពាណិជ្ជកម្ម បានត្រូវជានាដោយឡែក ពីភាគីធនាគាររដ្ឋទាំងពីរ និងដោយសូណិចស៊ីមមួយចំណែកទៀត ធនាគារ B.K.C.ឥណទាន ជាទី I J ដើរ តួយ៉ាងមានប្រសិទ្ធភាព ដូចធនាគារឯកជនមុខនេះដែរ ។ ប្រាក់តម្កល់ មួយភាគជាទុក ហើយយកទៅប្រើប្រាស់ជា ហិរញ្ញវត្ថុដល់ប្រតិបត្តិការនាំចេញនាំចូល ។ សូណិចស៊ីម ក៏មានប្រាក់តម្កល់តាមរយៈការផ្ទេរប្រាក់ខែការនាំចូល នៅពេលដែលគេធ្វើបញ្ជាទិញ តាមរយៈក្រុមហ៊ុនប្រមូលទិញក្នុងស្រុក ។ បន្ទាប់មក B.N.C.ផ្តល់ឥណទានដល់ O.R.O.C.សម្រាប់ប្រមូលទិញស្រូវ ។

ឥណទានរយៈពេលខ្លី សម្រាប់ហិរញ្ញកិច្ចដល់ប្រតិបត្តិការពាណិជ្ជកម្ម ប្រព្រឹត្តិទៅយ៉ាងពេញចិត្ត នៅកម្ពុជា។ ប៉ុន្តែសភាពការណ៍ មិនសូវជាទីពេញចិត្តសោះ ចំពោះឥណទានរយៈពេលខ្លី និងរយៈពេលយូរ សម្រាប់បម្រើហិរញ្ញកិច្ច នៃប្រតិបត្តិការផលិតកម្ម ។

### ១០.៤.៣.ទុញទផលិតកម្ម

ប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ អាចបំពេញបាននូវ មុខងារផ្សេងទៀត រួមវិភាគទាន ដល់ការអភិវឌ្ឍតាមរយៈកំណែនការប្រមូលផ្តុំចលនាឥណទាន មូលនិធិសម្រាប់ជាហិរញ្ញវត្ថុ ដល់ប្រតិបត្តិការលិតកម្ម។ មុខងារបំពេញមិនបានល្អទេ នៅកម្ពុជា ។

គេមិនទាន់សន្និដ្ឋានពីស្ថាប័ននានា ដែលដើរតួជាប្រចាំ ជាឈ្មួញកណ្តាលរវាងសញ្ជ័យ និងការវិយោគ នៅឡើយ។ មិនទាន់មានធនាគារ d'affaire នៅឡើយ មិនទាន់មានអង្គការឯកទេស ដូចនៅបារាំង ដែល អនុញ្ញាតឱ្យខ្ចីឥណទានរយៈពេលមធ្យម និងយូរនៅឡើយ។ ស្ថាប័នបួនដើរតួនាទីក្នុងវិស័យនោះ គឺ C.P.C.K.C.S.E.O.R.O និងធនាគារនានា ។

C.P.C.X.និង C.N.E.មានមុខងារជាច្រើនក្នុងវិស័យបេឡា ។ យើងត្រូវបែងចែកឱ្យដាច់ពីគ្នា រវាង សកម្មភាពហិរញ្ញវត្ថុ និងការចូលរួម នៅក្នុងនោះបេឡាជាអង្គការប្រតិបត្តិរបស់រដ្ឋតែប៉ុណ្ណោះ និងសកម្មភាព នៃការឱ្យខ្ចី រយៈពេលមធ្យម និងរយៈពេលវែង ក្នុងបេឡាជាធនាគារីកសម្រួលដល់ការអភិវឌ្ឍ ។

ពីឆ្នាំ ១៩៥៧ ដល់ ១៩៦៥ បេឡាបានឱ្យខ្ចីចំនួន ១៥០ ដង មានចំនួនប្រាក់ដល់ទៅជាង ៨០០ លានរៀល។ កម្រិតទឹកប្រាក់ឱ្យខ្ចីនៅឆ្នាំ ១៩៦១ កើនលើស ៤០០ លានរៀល គឺពាក់កណ្តាលនៃការឱ្យខ្ចីសរុប។ ៤០% នៃការឱ្យខ្ចីមានចំខ្លួន ៥៧% នៃទឹកប្រាក់ គឺសម្រាប់ឱ្យខ្ចីរយៈពេលវែង ។ ការផ្សេងទៀត មានរយៈពេលមធ្យម ។

តួលេខនៃការបែងចែកការឱ្យខ្ចី តាមផ្នែកសកម្មភាព " ជាភាគរយសរុប " ។

ជាចំនួនជាកម្រិតទឹកប្រាក់

ផ្នែកសាធារណៈ ១០៦១

កសិកម្ម ៣៤១០
ការចិញ្ចឹមសត្វ១១២
ឧស្សាហកម្ម៤៥២៧

ទោះបីការឱ្យខ្ចីក្នុងផ្នែកកសិកម្ម និង ឧស្សាហកម្ម មានចំនួនច្រើន តែភាគច្រើននៃការឱ្យខ្ចីធំៗ គឺផ្តល់ដល់ផ្នែកសាធារណៈ។

O.O.C.ជាកឱ្យខ្ចីរយៈពេលមធ្យម និង អណត្តិវែង តែមានចំនួនតិច និងមិនសូវសំខាន់ ទោះបីមានការ កើនឡើងនៅពេលថ្មីៗ នៅឆ្នាំ ១៩៦៥ ក៏ដោយ រួមមានការធ្វើឱ្យអង្គការស្វយ័តបង្កើតឡើងដោយ O.R.O.C.ផ្ទាល់ ។ ជាសំខាន់ O.R.O.C.ឱ្យខ្ចីរយៈពេលខ្លី ព្រោះការធ្វើត្រូវសងឱ្យបានទាន់ពេលកំណត់ ហើយផ្ទេរជាការខ្ចីរយៈពេលមធ្យម ។

ការខ្ចីរយៈពេលមធ្យម ដោយធនាគារទាំងនោះ ក៏មិនជាសំខាន់ណាស់ណាដែរ កម្រិតទឹកប្រាក់ប្រហែល ២00 លានរៀល នៅឆ្នាំ ១៩៥៨ បានថយចុះយ៉ាងរហ័ស ហើយនៅសល់តិចជាង ១00 លានរៀល ។ ឥណទាន រយៈពេល ខ្លី ឱ្យខ្ចីដោយធនាគារ គឺបម្រើហិរញ្ញវត្ថុ នៃសហគ្រាស ។

គេឃើញថាប្រព័ន្ធធនាគាររួមវិភាគបានតិចតួចទេដល់ការផ្តល់ហិរញ្ញវត្ថុដល់ការវិនិយោគទុន។ ប្រព័ន្ធ ធនាគារនោះ មានការណែនាំតម្រង់ទិស ។ សញ្ច័យរបស់គេហជនមិនបានឆ្លងតាមហិរញ្ញវត្ថុកណ្តាល ។

សញ្ច័យនោះ ជាវិនិយោគផ្ទាល់ ទៅលើការកសាងអចលនវត្ថុ ការកែលម្អវិស័យកសិកម្ម ឬ ការកសាង សហគ្រាសតូចៗមានលក្ខណៈគ្រួសារ ។

ត្រង់ចំណុចនេះហើយ ដែលជាលក្ខណៈនៅកម្ពុជា ដែលគេត្រូវរកឱ្យឃើញ នៅពេលដែលគេគិតដល់តួនាទីសំខាន់ របស់ហិរញ្ញវត្ថុកណ្តាល ពិសេសតួនាទីធនាគារក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេស ដូចនៅបារាំង សហរដ្ឋអាមេរិច ហើយនៅជប៉ុន ។

តើប្រទេសកម្ពុជា មានសញ្ច័យតម្កល់អចលនវត្ថុរយៈពេលយូរឬទេ? គណនីសេដ្ឋកិច្ចសន្និដ្ឋានសញ្ច័យ នៃគេហជន មានជាង ១០% នៃទុនរបស់គេហជន ។ នោះជាតួលេខខ្ពស់ណាស់ ប៉ុន្តែសញ្ច័យនោះ បច្ចុប្បន្នមិនទាន់ មានជំនឿតាមរយៈការផ្ញើរក្រដាសប្រាក់ តែចូលចិត្តផ្ញើរជារូបិយប័ណ្ណបរទេស ឬវត្ថុមានតម្លៃ ដែលវិនិយោគជាអចលនវត្ថុឱ្យខ្ចីការប្រាក់ដូចការបុលបញ្ចាក់ចងការឬប្រាក់នោះចេញទៅបរទេសជាសម្ងាត់។ មួយផ្នែកទៀតការចុះថ្លៃប្រាក់នៅពេលនោះ វាមិនមែនជាឧបសគ្គដូចនៅប្រទេសក្រីក្រងទៀតទេព្រោះលុយរៀលពេលនោះមានស្ថេរភាព។ ដូចនោះ ការខ្វះនូវអង្គការប្រមូលសញ្ច័យរយៈពេលវែង ជាចំណុចលំបាក។

មិនចាំបាច់សុំខ្ចីរយៈពេលយូរ ដើម្បីឱ្យយូរនោះទេ។ យន្តការប្រែក្លាយ ប្រាក់តម្កល់រយៈពេលខ្លី ទៅជា ឥណទានរយៈពេលយូរ មានច្រើនណាស់ ហើយមានប្រសិទ្ធភាពទៀតផង ។ បែបបទធម្មតានេះ នាំឱ្យប៉ះពាល់ដល់គោលការណ៍ នៃឯកទេសរបស់ធនាគារ គឺមិនមែនគ្មានគ្រោះថ្នាក់នោះទេ។ ក្នុងការសុំខ្ចីរយៈពេលយូរធ្វើឱ្យ ភ័យបារម្ភ ដល់ផ្នែកសារធារណៈ ហើយមានភាពប្រថុយប្រថានទៀត ។

យើងត្រូវមានជ្រុងនៃតម្រូវការវិនិយោគ។ នៅមានការខ្វះខុនចាំបាច់ ជាហិរញ្ញវត្ថុ នៃការវិនិយោគ នៅ កម្ពុជា ជាងត្រូវការនូវធន្ទះ ឱកាសដែលចង់វិនិយោគ បើសហគ្រិនតវ៉ា ពីប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុនូវរយៈពេល យូរ ដើម្បីផ្គត់ផ្គង់ជាហិរញ្ញវត្ថុ ដល់គម្រោងសំខាន់មួយ គឺគ្មានការលំបាកនឹងរកបាននោះទេ ។ ប្រព័ន្ធនេះអាចបញ្ចេញស្ថាប័ននានា ហើយចាំបាច់បំពេញបន្ថែមទៀត។ ប៉ុន្តែតម្រូវការឱ្យខ្ចី ចេញមកពីពាណិជ្ជករ ដែលចង់បានរយៈពេលខ្លី ដើម្បីសម្រេចបាននូវប្រតិបត្តិការពាណិជ្ជកម្ម តិច ឬ ច្រើន តាមការបង្វិលរកចំណេញ ។ ធនាគារមិនអាចបំពេញបាន នូវសេចក្តីត្រូវការរបស់អតិថិជន ដែលមានគម្រោង មិនច្បាស់លាស់នោះទេ ។

ពិតហើយ ប្រព័ន្ធធនាគារ បានរួមវិភាគបានបង្គួរដែរ ដល់ការលើកស្ទួយកិច្ចអភិវឌ្ឍន៍កម្ពុជា ។ ប៉ុន្តែ វាដូច ជាអយុត្តិធម៌ពេក តាមរយៈការបដិសេធនូវប្រព័ន្ធធនាគារឯកជននោះ ។នៅមានការបរិយាយបន្ថែមទៀត ស្តីពីជំហរអន្តរជាតិរបស់កម្ពុជា ក្នុងវិស័យរូបិយវត្ថុ ។

## ១០.៥.យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

វិស័យហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យឯកជន និងជានាថីរភាពនៃកំណើនសេដ្ឋកិច្ច។ នៅ ឆ្នាំ២០០១រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត "ចក្ខុវិស័យ និងផែនការអភិវឌ្ឍនវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០" ដែលជាយុទ្ធសាស្ត្ររយៈពេលវែងសំរាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។ ចាប់ពីពេលនោះមក យុទ្ធសាស្ត្រនេះ បានបំរើជាមគ្គុទេសដល់ការខិតខំរបស់រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍនទាំងឡាយក្នុងការកំណត់គោលនយោបាយ និងកម្មវិធីនានាសំរាប់ទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាក្នុងបំណងសំរេចឱ្យបាននូវប្រព័ន្ធ ហិរញ្ញវត្ថុ ឬងមាំផ្អែកលើយន្តការទីផ្សារ។

ក្នុងរយៈពេល៦ខែដើម ឆ្នាំ២០០៦ ក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសមាសភាពមកពីធនាគារ ជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងមជ្ឈដ្ឋានពាក់ព័ន្ធក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារបច្ចេកទេសរបស់ធនាគារអភិវឌ្ឍនអាស៊ី និងដៃគូអភិវឌ្ឍន៍ដទៃទៀតតាម រយៈដំណើរការពិភាក្សាពិគ្រោះយោបល់ ដើម្បីបានជាធាតុចូលសំរាប់បង្កើតជា ឪឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥"នេះឡើង។ និយាយរួម "យុទ្ធសាស្ត្រអភិវឌ្ឍនវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ឱ នេះត្រូវបានបង្កើតឡើងតាមអភិក្រមមួយដែលមានការចូលរួមដ៏ទូលំទូលាយ ពីសំណាក់អ្នកពាក់ព័ន្ធនានាក្នុងវិស័យ ហិរញ្ញវត្ថុនៅកម្ពុជា។

គោលដៅរួមមានលក្ខណៈស៊ីសង្វាក់ និង ប្រកបដោយចរិភាព សម្រាប់ការអភវិឌ្ឍវិស័យហរិញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមនោះបន្ថែមលើតួនាទីជាមគ្គុទ្ទេសក៍ "យុទ្ធសាស្ត្រអភិវឌ្ឍនវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥" មានបំណងផ្តល់ នូវក្របខណ្ឌមួយសម្រាប់ទ្រទ្រង់ការសម្របសម្រួល និងសហប្រតិបត្តិការរវាងស្ថាបន័រាជរដ្ឋាភិបាល រវាងរាជរដ្ឋាភិបាល និងមជ្ឈដ្ឋានពាក់ព័ន្ធ និងអ្នកចូលរួមនានាក្នុងវិស័យឯកជននិងរវាងដៃគូអភិវឌ្ឍននានាដែលប្រាថ្នាគាំទ្រការអភិវឌ្ឍ វិស័យហិរញ្ញវត្ថុនៅកម្ពុជា ។

### ១០.៥.១.ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០

ក្នុងឆ្នាំ ១៩៩៩-២០០០ រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍនអាស៊ី បានសហការរៀបចំយុទ្ធសាស្ត្រ រយៈកាលវែងមួយ ដើម្បីអភិវឌ្ឍនវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ លទ្ធផលនៃការខិតខំនេះ គឺជាឯកសារចក្ខុវិស័យអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០១ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ហើយចាប់ពីពេលនោះមក បានបំរើ តួនាទីជាមគ្គុទេសក៍សម្រាប់ការខិតខំរបស់រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍន៍ទាំងឡាយក្នុងការទ្រទ្រង់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត ឯកសារចក្ខុវិសយ័ និងផែនការអភវិឌ្ឍ វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០ នៅក្នុងកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពរបស់សម្តេចនាយករដ្ឋ មន្ត្រីនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០១។ នេះជាគំនិតផ្តួចផ្តើមស្ថាបនារបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍវិស័យ ហិរញ្ញវត្ថុ។

ចក្ខុវិស័យនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០១-២០១០:

-ចក្ខុវិស័យនិងផែនការរយៈកាលវែង និងយុទ្ធសាស្ត្រអភិឌ្ឍន៍សម្រាប់វិស័យហិរញ្ញវត្ថុ និង

-មានបំនងអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយដ៏ឬងមាំផ្អែកលើយន្តការទីផ្សារ ដើម្បីទ្រទ្រង់ការកេណ្ឌប្រមូលធនធន និងកំណើនសេដ្ឋកិច្ចទូលំទូលាយប្រកបដោយចីរភាព។

យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈកាលវែង ដែលបានរៀបចំឡើងសម្រាប់អនុវត្តចក្ខុវិស័យនៃវិស័យហិរញ្ញវត្ថុ ត្រូវបានទាញចេញពី កត្តាដូចតទៅ:

(១)មេរៀនសំខាន់ៗបានមកពីបទពិសោធនរបស់បណ្តាសេដ្ឋកិច្ចនានាក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

(២)ស្ថានភាពបច្ចុប្បន្ននៃវិស័យហិរញ្ញវត្ថុរបស់កម្ពុជា និង

(៣)វឌ្ឍនភាពនៃកំណែទម្រង់ដែលពាក់ព័ន្ធទាំងឡាយ។

បទពិសោធន៍ក្នុងការធ្វើកំណែទម្រង់ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចនៃតំបន់អាស៊ី និងបណ្តាសេដ្ឋកិច្ច អន្តរកាលដទៃទៀត បានផ្តល់នូវមេរៀនជាច្រើនសម្រាប់ពិចារណាក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

- ក្នុងការកំណត់យុទ្ធសាស្ត្ររយៈកាលវែង គោលការណណែនាំគន្លឹះចំនួន ១០ ត្រូវបានកត់សម្គាល់

- នយោបាយសារពើពន្ធដ៏ឬងមាំ និងស្ថិរភាពថ្លៃ គឺជាបុរេលក្ខខណ្ឌសម្រាប់ឱ្យប្រព័ន្ធហិរញ្ញវត្ថុមានដំណើរការល្អ

- វិស័យហិរញ្ញវត្ថុនឹងមិនមានការអភិវឌ្ឍឡើយ បើពុំមានជំនឿទុកចិត្តរបស់សាធារណជនទៅលើការការពារ និង សុវត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ និងការអនុវត្តកិច្ចសន្យា ។

- វិស័យហិរញ្ញវត្ថុដ៏ឬងមាំ និងមិនអាចបង្កើតបានឡើយ បើពុំមានការបង្កើតនូវនីតិរដ្ឋដែលទ្រទ្រង់ដោយ ប្រពន្ធ័ច្បាប់ និងតុលាការសមស្រប និងការអនុវត្តច្បាប់។

- ដើម្បីឱ្យមាននូវអន្តរការិយកម្មហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវអភិវឌ្ឍន ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ហិរញ្ញវត្ថុជាពិសេសប្រព័ន្ធគណនេយ្យនិងសវនកម្មប្រព័ន្ធព័ត៌មានឥណ ទាន និងក្របខ័ណ្ឌបទបញ្ញត្តិ។

- ការប្រកួតប្រជែងដ៏ត្រឹមត្រូវនៅក្នុងទីផ្សារហិរញ្ញវត្ថុជាកំលាំងជម្រុញគន្លឹះ ដែលនាំឱ្យ មាននូវភាពស៊ីជម្រៅនៃ វិស័យហិរញ្ញវត្ថុតាមរយៈការលើកទឹកចិត្តចំពោះគ្រឹះស្ថានហិរញ្ញវត្ថុឱ្យស ម្រេចបាននូវសេដ្ឋកិច្ចមាត្រដ្ឋាន និងវិសាលភាព។

- វិស័យហិរញ្ញវត្ថុដ៏ឬងមាំត្រូវកសាងឡើងនៅលើគោលការណអភិបាលកិច្ចត្រឹមត្រូវ និង វិន័យទីផ្សារឬងមាំ ដែលទ្រទ្រង់ចំពោះវប្បធម៌ឥណទានដ៏ឬងមាំ។

- កម្មសិទ្ធិរដ្ឋនៅលើគ្រឹះស្ថានហិរញ្ញវត្ថុ និងអន្តរាគមនរបស់រដ្ឋនៅក្នុងការបែងចែក ធនធានហិរញ្ញវត្ថុ នឹងរារាំង ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុផ្អែកលើយន្តការទីផ្សារ។

- បញ្ញត្តិកម្មលើការបើកច្រកចូលដ៏តឹងឬងហួសហេតុចំពោះវិស័យហិរញ្ញវត្ថុ ជាកត្តាមួយ ដែលមានផលប៉ះពាល់ ជាអវិជ្ជមានទៅលើការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ព្រមទាំងប្រសិទ្ធភាពក្នុង ការបែងចែកមូលនិធិវិនិយោគ។

- លក្ខខណ្ឌបើកច្រកចូលដ៏ធូររលុងនៅក្រោមប្រព័ន្ធត្រួតពិនិត្យដ៏ទន់ខ្សោយ នាំឱ្យមាន នូវគ្រឹះស្ថានហិរញ្ញវត្ថុដ៏ ច្រើនហួសហេតុដែលពុំមានការគ្រប់គ្រងល្អ ។

- ដើម្បីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយចីរភាព ចាំបាច់ត្រូវកសាងការគ្រប់គ្រងមួយ ផ្អែកលើទីផ្សារប្រព័ន្ធ ប្រតិបត្តិការដ៏ឬងមាំ និងត្រូវលើកកម្ពស់សមត្ថភាពបច្ចេកទេស សមស្រប តាមបំរែបំរួលដែលប្រាថ្នានៅក្នុងហេដ្ឋារចនា សម្ព័ន្ធហិរញ្ញវត្ថុ។

ផ្អែកលើគោលបំណងចក្ខុវិស័យនិងគោលការណណែនាំខាងលើ សមាសធាតុគន្លឹះនៃ យុទ្ធសាស្ត្ររយៈកាលវែង សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដែលអនុម័តដោយរាជរដ្ឋាភិបាល មានដូចតទៅ:

(១) រក្សានយោបាយសារពើពន្ធនិងរូបិយវត្ថុដ៏សមស្រប ដើម្បីជានាស្ថិរភាពម៉ាក្រូសេដ្ឋ កិច្ច។

(២) បង្កើតក្របខ័ណ្ឌច្បាប់ឬងមាំសម្រាប់ការពារសិទ្ធិលើកម្មសិទ្ធិ និងការអនុវត្តនកិច្ច សន្យា។

(៣) បង្កើតនីតិរដ្ឋតាមរយៈកំណែទម្រង់ប្រព័ន្ធច្បាប់និងតុលាការ ដើម្បីទ្រទ្រង់ សកម្មភាពហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។

(៤) ការខិតខំជាលំដាប់លំដោយ ដើម្បីអភិវឌ្ឍនហេដ្ឋារចនាសម្ព័ន្ធវិស័យហិរញ្ញវត្ថុ ជា ពិសេសប្រព័ន្ធទាក់ទងនឹងការ ទូទាត់សងប្រាក់ប្រព័ន្ធគណនេយ្យនិងសវនកម្មប្រព័ន្ធពត៌មាន ឥណទាន និងក្របខ័ណ្ឌបទបញ្ញត្តិ។

(៥) កំណែទម្រង់ក្របខ័ណ្ឌបទបញ្ញត្តិនិងគោលនយោបាយ សំដៅលើកកម្ពស់ការប្រកួតប្រជែងនៅក្នុងទីផ្សារ ហិរញ្ញវត្ថុ និងលើកទឹកចិត្តចំពោះគ្រឹះស្ថានហិរញ្ញវត្ថុឱ្យសម្រេចបាននូវសេដ្ឋកិច្ចមាត្រដ្ឋាន និងវិសាលភាព។

(៦) បង្កើតក្របខណ្ឌ័ស្ថាបន័ និងបទបញ្ញត្តិ ដើម្បីលើកកម្ពស់គោលការណអភិបាលកិច្ចត្រឹមត្រូវ និងដើម្បីអនុញ្ញាត ឱ្យវិន័យទីផ្សារមានដំណើរការបានល្អនៅក្នុងការគ្រប់គ្រង និងប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ។

(៧) បង្កើតក្របខ័ណ្ឌសមស្របសម្រាប់ការអភិវឌ្ឍនៃវិស័យឯកជននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ តាមរយៈការលុបបំបាត់ ចោលនូវកម្មសិទ្ធិរដ្ឋ និងអន្តរាគមនរបស់រដ្ឋនៅក្នុងប្រព័ន្ធនោះ។

(៨) បង្កើតក្របខ័ណ្ឌបើកច្រកចូលប្រកបដោយតម្លាភាព ដើម្បីលើកទឹកចិត្តចំពោះប្រសិទ្ធភាព និងភាពស៊ីជម្រៅនៃ វិស័យហិរញ្ញវត្ថុ។

(៩) បង្កើតយន្តការចាកចេញប្រកបដោយប្រសិទ្ធភាពសម្រាប់គ្រឹះស្ថានដែលមានបញ្ហា សំដៅជម្រុញការរៀបចំឡើង វិញជាបន្តនៃប្រព័ន្ធហិរញ្ញវត្ថុ ដោយពុំបង្កនូវការខាតបង់ដល់សង្គម និង

(១០) អភិវឌ្ឍនសមត្ថភាពធនធានមនុស្ស និងស្ថាប័នទាំងនៅក្នុងវិស័យឯកជន និងសាធារណៈ តាមរយៈភាពជា ដៃគូរវាងវិស័យឯកជន និងសាធារណៈ។

## ១០.៥.២.ផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥

ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ ផ្តោតលើទិដ្ឋភាពដូចតទៅ ៖

- មូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុ
- វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ
- វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង
- ការពិចារណាឆ្លងវិស័យទូទៅ។

ដោយសម្លឹងឆ្ពោះទៅមុខក្រោមការណែនាំសម្រាប់គោលបំណងរយៈកាលវែង ចក្ខុវិស័យគោលការណ៍ណែនាំ និងយុទ្ធសាស្ត្រអត្តិភាពចំបងក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរួមមាន :

- លើកកម្ពស់ការអនុវត្តកិច្ចសន្យា និងយន្តការដោះស្រាយជម្លោះពាណិជ្ជកម្ម
- លើកកម្ពស់ការអនុវត្តនយោបាយសារពើពន្ធ ម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ
- អភិវឌ្ឍន៍ប្រព័ន្ធទូទាត់សងប្រាក់ និងផាត់ទាត់មួយប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព
- លើកកម្ពស់ការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ សំដៅដោះស្រាយឱ្យបានសមស្របនូវបញ្ហាហានិភ័យ ទន្ទឹមនោះ ផ្តល់ការលើកទឹកចិត្តចំពោះការអភិវឌ្ឍ និងការកែច្នៃថ្មីក្នុងវិស័យហិរញ្ញវត្ថុ និង

- ទ្រទ្រង់ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំផ្នែកហិរញ្ញវត្ថុចំពោះគ្រប់មជ្ឈដ្ឋាននៃប្រជាជនកម្ពុជា។

ជារួមគោលដៅគឺ កសាងទំនុកចិត្តទៅលើប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ហើយតាមរយៈនោះ លើកទឹកចិត្តនូវភាពជា ផ្លូវការនៃប្រតិបត្តិការហិរញ្ញវត្ថុ និងទ្រទ្រង់ការបែងចែកធនធានហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាពដែលនឹងទ្រទ្រង់ កំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងបន្ថយភាពក្រីក្រនៅកម្ពុជា។ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

### ១០.៥.៣.គោលនយោបាយទី១: គ្រប់គ្រងសេដ្ឋកិច្ច និង អភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ការអនុវត្តចំណាយថវិកាសម្រាប់គោលបំណងគោលនយោបាយទី១មានចំនួន ៣,៧៥៨.៩លាន រៀលស្មើនឹង ១០១% នៃឥណទានក្នុងច្បាប់ នៅក្នុងនោះកម្មវិធីទី១មានចំនួនរហូតដល់ទៅ ២,០១៦.១លានរៀលស្មើនឹង ១៧១.៨% នៃឥណទានក្នុងច្បាប់ និង កម្មវិធីទី២មានចំនួន ១,៧៤២.៨លានរៀលស្មើនឹង ៦៨.៤% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃគោលបំណងគោលនយោបាយទី១ សម្រេបាន ៨៥% ក្នុងនោះកម្មវិធីទី១ សម្រេចបាន ៩០% កម្មវិធីទី២សម្រេចបាន ៨០%។

ការអនុវត្តចំណាយលម្អិត និង ការវឌ្ឍនភាពសមិទ្ធកម្មតាមកម្មវិធីទាំង២ នៃគោលបំណងគោល នយោបាយទី១ មានដូចតទៅ៖

#### ក.កម្មវិធីទី១៖ ការគ្រប់គ្រងសេដ្ឋកិច្ច

កម្មវិធីទី១ មានតែអនុកម្មវិធីទី១.១ ចំនួន០១ប៉ុណ្ណោះ ដែលការអនុវត្តចំណាយមានចំនួន ២,០១ ៦.១លានរៀល ស្មើនឹង ១៧១,៨% នៃឥណទានក្នុងផែនការច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី១ សម្រេចបាន ៩០%។

**អនុកម្មវិធីទី១.១ (អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩០% នៃគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- របាយការណ៍ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សារពើពន្ធហិរញ្ញវត្ថុ និង របាយការណ៍សិក្សាតាមវិស័យ ត្រូវបានរៀបចំសម្រាប់វិស័យចំនួន០៤ គឺអប់រំ សុខាភិបាល កសិកម្ម និង ការអភិវឌ្ឍជំនាញ
- របាយការណ៍វាយតម្លៃសារពើពន្ធពាក់កណ្តាលឆ្នាំត្រូវបានរៀបចំ
- របាយការណ៍ចុងក្រោយស្តីពីអនុលោមភាពពន្ធគយនៅកម្ពុជា ត្រូវបានរៀបចំ

- ស្តង់ដារស្ថិតិ TOFE&GFS និង ឯកសារណែនាំស្តីពីការអនុវត្តស្តង់ដារស្ថិតិត្រូវបានគិតគូរ និងរៀបចំបង្កើនគុណភាព ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវិភាគនានា
- ទិន្នន័យស្ថិតិត្រូវបានចងក្រង រក្សាទុកក្នុងឃ្លាំងផ្ទុកទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ(MEF-Database) រួមមាន ១១ផ្នែក និង ៦០សូចនាករ
- របាយការណ៍ស្តីពីការអនុវត្តកម្មវិធីកាត់បន្ថយ និង លុបពន្ធនាំចូលរបស់កម្ពុជាលើ(HS2012) និង របាយការណ៍ស្តីពីបញ្ជីវិធានដោយឡែកសម្រាប់ផលិតផលលើ(HS2012) និង របាយការណ៍នានា ស្តីពីការអនុវត្តគម្រោងសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយនឹងលទ្ធផលនៃការស្រាវជ្រាវ និង ការវិភាគការអនុវត្តកាតព្វកិច្ចក្រោមតំបន់ពាណិជ្ជកម្មសេរី និង សហប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានរៀបចំ។

### ខ.កម្មវិធីទី២៖ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

កម្មវិធីទី២ មានអនុកម្មវិធីចំនួន ០៣ ក្នុងនោះការអនុវត្តចំណាយក្នុងអនុកម្មវិធីទី២.១ មានចំនួន ៩៩៥.៧លានរៀល ស្មើនឹង ៨១.៥% នៃឥណទានក្នុងច្បាប់ អនុកម្មវិធីទី២.២ អនុវត្តបាន ៤១០.៧ លានរៀលស្មើនឹង ៨៩.៦% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធី២.៣ អនុវត្តបាន ៣៣៦.៤លានរៀល ស្មើនឹង ៣៨.៨% នៃឥណទានក្នុងច្បាប់ ។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី២ សម្រេចបាន ៨០%។

ការសម្រេចបានតាមគោលដៅសូចនាករសមិទ្ធកម្មដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី២.១ (អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩០% នៃគោលដៅសូចនាករដែលបានកំណត់។ ដែលក្នុងនោះ សមិទ្ធកម្មគន្លឹះដែលសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត(ច្បាប់ អនុក្រឹត្យនិងប្រកាស)ពាក់ព័ន្ធនឹងវិស័យមូលបត្ររដ្ឋការគ្រប់គ្រងរមណីយដ្ឋានសមាហរណ៍ និង ពាណិជ្ជកម្មល្បែង ការផ្តល់អាជ្ញាប័ណ្ណកាស៊ីណូ ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍លំនៅដ្ឋាន និង ការគ្រប់គ្រងអាជីវកម្មបញ្ចាំ និង ប្រាតិភោគ ដោយអនុប្បទានត្រូវបានរៀបចំដោយមួយចំនួនកំពុងស្ថិតក្នុងដំណាក់កាលពិភាក្សាក្នុងក្រុមប្រឹក្សានីតិកម្មនិង មួយចំនួនទៀត ស្ថិតក្នុងកិច្ចពិភាក្សាអន្តរក្រសួង ស្ថាប័ន។

ការតាមដានត្រួតពិនិត្យស្ថានភាពអាជីវកម្មរបស់គ្រឹះស្ថានជានាប់រងដល់ទីកន្លែងត្រូវបានអនុវត្ត

**អនុកម្មវិធីទី២.១ (អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៧០% នៃគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- សេចក្តីព្រាងច្បាប់ស្តីពីគណនេយ្យ និង សវនកម្ម ត្រូវបានរៀបចំទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រី និង កំពុងស្នើសុំការអនុម័តយល់ព្រមពីរដ្ឋសភា
- បទបញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យ និង សវនកម្ម ត្រូវបានផ្សព្វផ្សាយតាមរយៈសិក្ខាសាលាចំនួន លើកនៅតាមរាជធានី ខេត្ត ។
- សមត្ថភាពមន្ត្រីលើស្តង់ដារគណនេយ្យ ត្រូវបានពង្រឹង និង បង្កើនតាមរយៈការបញ្ជូនចូលរួមសិក្ខាសាលានានា។

**អនុកម្មវិធីទី២ (គណៈកម្មការមូលបត្រកម្ពុជា)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធី សម្រេចបានសមិទ្ធកម្មកម្មជារួមប្រមាណ៧០% នៃគោលដៅសូចនករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- ក្របខ័ណ្ឌគតិយុត្តមួយចំនួនសម្រាប់ការគ្រប់គ្រងទីផ្សារមូលប័ត្រ យន្តការ និង ការត្រួតពិនិត្យអន្តរការីមូលបត្រ ការដោះស្រាយវិវាទក្នុងវិស័យមូលបត្រ និង ការបោះផ្សាយលក់មូលបត្រត្រូវបានរៀបចំរួចរាល់ក្នុងនោះរួមមានប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ និង ការគ្រប់គ្រងអាជីវកម្ម ឧបករណ៍និស្សន្ទប្រកាសស្តីពី ការបោះផ្សាយលក់មូលប័ត្រកម្មសិទ្ធិសាធារណៈសម្រាប់សហគ្រាសធុនតូច និង មធ្យម និងប្រកាសស្តីពីការស៊ើបអង្កេតក្នុងវិស័យមូលបត្រត្រូវបានរៀបចំ
- ការបណ្តុះបណ្តាល និង ការផ្សព្វផ្សាយលើវិស័យមូលបត្រ ត្រូវបានរៀបចំតាមរយៈសិក្ខាសាលា សាធារណៈសិក្ខាសាលានៅតាមសកលវិទ្យាល័យ និង នៅតាមបណ្តាញប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
  - ការស្រាវជ្រាវ និង ស៊ើបអង្កេតបទល្មើស ក្នុងវិស័យមូលបត្រត្រូវបានអនុវត្តពេញមួយឆ្នាំ ។

## ១០.៥.៤.គោលនយោបាយទី២: គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ទ្រព្យសម្បត្តិរដ្ឋ

ការអនុវត្តចំណាយថវិកា សម្រាប់គោលបំណងគោលនយោបាយទី២មានចំនួន ៣៩៥,២២៤.៤ លានរៀល ស្មើនឹង៩៦.៦% នៃឥណទានក្នុងច្បាប់ ក្នុងនោះចំណាយក្នុងកម្មវិធីទី៣អនុវត្តបានចំនួន ២៣ ៥,៤៧៤.១លានរៀល ស្មើនឹង៩៩.៥% នៃឥណទានក្នុងច្បាប់ ចំណាយក្នុងកម្មវិធីទី៤អនុវត្តបាន ៧,១១ ២.៨លានរៀលស្មើនឹង៨៧.២% នៃឥណទានក្នុងច្បាប់ និង ចំណាយក្នុងកម្មវិធីទី៥សម្រេចបាន ១៥២,៦៣៧.៥លានរៀល ស្មើនឹង៩៣% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃគោលបំណងគោលនយោបាយទី២សម្រេចបាន ៨៨% ក្នុងនោះកម្មវិធីទី២សម្រេចបាន ៨០% កម្មវិធីទី៣ សម្រេចបាន ៨៩% កម្មវិធីទី៤ សម្រេចបាន៩៤% និង កម្មវិធីទី៥សម្រេចបាន៨៣% ។

ការអនុវត្តការចំណាយលម្អិត និង វឌ្ឍនភាពសមិទ្ធកម្មតាមកម្មវិធីទាំង៣ នៃគោលបំណងគោលនយោបាយទី២ មានដូចតទៅ៖

**គ.កម្មវិធីទី៣ ការកៀរគរចំណូលថវិកាជាតិ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

កម្មវិធីទី៣ រួមមានអនុកម្មវិធីចំនួន ០៣ អនុវត្តចំណាយបាន ២៣៥,៤៧៤.១លានរៀល ស្មើនឹង ៩៩.៥% នៃឥណទានក្នុងច្បាប់ ដោយក្នុងនោះការអនុវត្តចំណាយក្នុងអនុកម្មវិធីទី៣.១ មានចំនួន ២១៣,៧៩១.៥លានរៀល ស្មើនឹង ១០២.៥% នៃឥណទានក្នុងច្បាប់ អនុកម្មវិធីទី៣.២ អនុវត្តចំណាយបាន ៥,៩៤៧.៣ លានរៀល ស្មើនឹង ៧៦.៩% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធីទី៣.៣ អនុវត្តចំណាយបាន ៥,៩៤៧.៣លានរៀល ស្មើនឹង ៧៩.២% នៃឥណទានក្នុងច្បាប់ ។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី ៣ សម្រេចបាន ៨៩% ។

ការសម្រេចបានតាមគោលដៅសូចនាករសមិទ្ធកម្ម បានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី៣.១ (អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩២% នៃគោលដៅសូចនាករដែលបានកំណត់ ។ ក្នុងនោះ សមិទ្ធកម្មគន្លឹះដែលសម្រេចបានរួមមាន៖

- យន្តការ និង វិធានការនៃការគ្រប់គ្រងប្រព័ន្ធហានិភ័យគយ ការពង្រឹងប្រសិទ្ធភាពការងារបង្ការ និង បង្រ្កាបអំពើរត់គេចពន្ធត្រូវបានគិតគូររៀបចំ
- ការវាយតម្លៃអនុលោមភាពតាមគោលការណ៍របស់ WTO លើតម្លៃគិតពន្ធគយ ការវាយតម្លៃការ អនុវត្តតម្លៃចម្លងលើទំនិញនាំចូល ក្រោមរបបអនុគ្រោះពន្ធ និង ការវាយតម្លៃប៉ះពាល់ផលិតកម្មក្នុងស្រុកជំនួសការនាំចូលត្រូវរៀបចំ
- ប្រសិទ្ធភាពនៃយន្តការភាពជាដៃគូរគយ ផ្នែកឯកជន ត្រូវបានពង្រឹង
- ប្រព័ន្ធម៉ាស៊ីគូដា និង ម៉ាស៊ីនស្កេន ត្រូវបានពង្រីកការគ្របដណ្តប់ដល់ ៥៧ ការិយាល័យបំពេញបែបបទគយ
- លើកកម្ពស់និង អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈសិក្ខាសាលា វគ្គជំនាញ និង ទស្សនកិច្ចសិក្សា
- អនុវត្តប្រកបដោយអប្បមានខ្ពស់ នូវគោលនយោបាយអន្តរាគមន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបា-ល

**អនុកម្មវិធីទី ៣.២ (អគ្គនាយកដ្ឋានពន្ធដារ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ៨៣%នៃគោលដៅសូចនករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះដែលសម្រេចបាន រួមមាន៖

- សមត្ថភាពមន្ត្រី និង ស្ថាប័ន ត្រូវបានពង្រឹងតាមរយៈ វគ្គបណ្តុះបណ្តាលមន្ត្រីលើជំនាញពន្ធដារ ទាំងក្នុង និង ក្រៅប្រទេស
- បណ្តាញបច្ចេកវិទ្យាព័ត៌មាន ត្រូវបានតភ្ជាប់ទៅគ្រប់សាខាពន្ធដារខេត្ត ខណ្ឌ ទូទាំងប្រទេស
- សហគ្រាសចំនួន ៣,៥៥១(ផែនការកំណត់ ២,៥៩០)ត្រូវបានចុះបញ្ជីតាមរបបស្វ័យប្រកាស
- ប្រសិទ្ធភាពនៃការផ្តល់សេវា និង ការយល់ដឹងពីការបង់ពន្ធ ត្រូវបានបង្កើនតាមរយៈការផ្តល់សេវា ពិសេស និង ការផ្សព្វផ្សាយដល់សាធារណជន ព្រមទាំងធ្វើសាមញ្ញកម្មនីតិវិធីតាមរយៈការបង្កើតសេវាកម្ម Online ក្នុងការចុះបញ្ជីពន្ធដារ ការប្រកាសពន្ធប្រចាំខែ និង ប្រចាំឆ្នាំ និង ការបង់ពន្ធតាមធនាគារពាណិជ្ជ
- សវនកម្មចំនួន២,២២២សហគ្រាស ត្រូវបានអនុវត្តដោយនាយកដ្ឋាន ថ្នាក់កណ្តាល និង ៤៥០ សហគ្រាស ត្រូវបានអនុវត្តដោយសាខាពន្ធដារខេត្ត-ខណ្ឌ
- យន្តការក្នុងការគ្រប់គ្រងមន្ត្រីពន្ធដារ និង ការផ្តល់សេវាដល់អ្នកជាប់ពន្ធ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យដំណើរការម៉ាស៊ីន ស្កែនម្រាមដៃ ការដាក់ឱ្យអនុវត្តក្រមសីលធម៌មន្ត្រីពន្ធដារ និង ការរៀបចំរចនាសម្ព័ន្ធថ្មីនៃអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ។

**អនុកម្មវិធីទី៣.៣ (អគ្គនាយកដ្ឋានទ្រព្យសម្បត្តិ និង ចំណូលមិនមែនសារពើពន្ធ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩១% នៃគោលដៅសូចនករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះ ដែលសម្រេចបានរួមមាន៖

- ការកៀងគរចំណូលមិនមែនសារពើពន្ធ និង ចំណូលពីទ្រព្យសម្បត្តរដ្ឋ ដោយក្រសួង ស្ថាប័នត្រូវ បានពង្រឹងដោយចំណូលមិនមែនសារពើពន្ធ សម្រេចបាន ៩៨.៤% និង ចំណូលពីទ្រព្យសម្បត្តិរដ្ឋសម្រេចបាន ៧៨.២៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៥
- ប្រកាសរួមនានា សម្រាប់ការផ្តល់សេវាសាធារណៈ និង ការផ្តល់រង្វាន់លើកទឹកចិត្តជាមួយក្រសួង ស្ថាប័នត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត
- ព្រះរាជក្រឹត្យស្តីពី វិសោធនកម្មលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល អនុក្រឹត្យគំរូស្តីពីការបង្កើតគ្រឹះស្ថាន សាធារណៈរដ្ឋបាល និង លិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀតត្រូវបានរៀបចំ និងប្រកាសដាក់អោយអនុវត្ត និង កំពុងបន្តរៀបចំ អនុក្រឹត្យស្តីពីថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- គម្រោងវិនិយោគសាធារណៈរបស់រដ្ឋ និង សម្បទានដទៃទៀត ត្រូវបានសិក្សាវាយតម្លៃព្រមទាំង ចាត់វិធានការណ៍ដើម្បីទមទារបំណុល និង កៀងគរចំណូលភាគលាភ ។

### ខ កម្មវិធីទី៤៖ បង្កើនប្រសិទ្ធភាពនិង ស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងចំសាធារណៈ

កម្មវិធីទី៤ រួមមានអនុកម្មវិធីចំនួន៤ អនុវត្តចំណាយបាន៧,១១២.៨លានរៀល ស្មើនឹង ៨៧.២% ធៀបនឹងឥណទានក្នុងច្បាប់ ក្នុងនោះអនុវត្តចំណាយក្នុងអនុកម្មវិធីទី៤.១ មានចំនួន ១,៤៦៩.២ លានរៀល ស្មើនឹង ៥៧% នៃឥណទានក្នុងច្បាប់ អនុវត្តកម្មវិធីទី៤.២ អនុវត្តចំណាយបាន ៨៥៤.១លានរៀល ស្មើនឹង ៦៨.៦% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធីទី ៤.៤ អនុវត្តចំណាយបាន ៤,១១៦.៨លាន រៀល ស្មើនឹង១១៥.៨% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី៤ សម្រេចបាន ៩៤%។

វឌ្ឍនភាពនៃការអនុវត្ត ផែនការសកម្មភាព ប្រចាំឆ្នាំ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី៤.១ (អគ្គនាយកដ្ឋានថវិកា**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៩៨% នៃគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- សារាចរទាំង៣( សារាចរណែនាំស្តីពីការអនុត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ និងសារាចរណែនាំស្តីពីការរៀបចំនូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៦) ត្រូវបានរៀបចំ និង ផ្សព្វផ្សាយអនុវត្តដោយអនុលោមទៅតាមប្រតិទិននៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ
- ការធានាចំណាយត្រូវបានអនុវត្តតាមគោលការណ៍ ១៤៥% នៃតម្លៃទំនិញ និងសេវា
- ការត្រួតពិនិត្យការអនុវត្តថវិកា ត្រូវបានអនុវត្តដោយអនុលោម តាធមសារាចរបិទបញ្ជីឆ្នាំ២០១៥
- គម្រោងវិនិយោគចំនួន១៧ ត្រូវបានដាក់ដេញថ្លៃតាមនីតិវិធីជាធរមាន។

**អនុកម្មវិធីទី ៤.២ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាព ក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្ម ៩០%នៃគោលដៅ សូចនាករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះ ដែលសម្រេចបានក្នុងឆ្នាំ ២០១៥ រួមមាន៖

- គោលការណ៍ និង វិធានក្នុងការអនុវត្តថវិការ និង ការផ្តល់សេវាដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំនិង ដាក់ឱ្យអនុវត្ត រួមមានសារាចរស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សារាចររៀបចំផែនការយុទ្ធសាស្ត្រ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សារាចរស្តីអំពីនីតិវិធីបច្ចេកទេសនៃការរៀបចំថវិកាប្រចាំឆ្នាំ ២០១៦ សារាចរបិទបញ្ជី និង រៀបចំរបាយការណ៍សម្រេចទូទាត់ថវិកាប្រចាំឆ្នាំ២០១៥ ប្រកាសស្តីពីវិធាន និងនីតិវិធីអនុវត្តបេសកកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសអន្តរក្រសួងស្តីពីការប្រើប្រាស់កញ្ចប់សេ

វាអនាម័យបរិស្ថាន សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹងរាវតាមទីប្រជុំជននៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ប្រកាសស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

- ការចុះតាមតានការអនុវត្តថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្ត។

**អនុកម្មវិធីទី ៤.៣ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាព នៃអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៨៩% នៃគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះ សម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- វិធាន និង គោលការណ៍ណែនាំ ក្នុងការរៀបចំផែនការលទ្ធកម្ម ការអនុវត្តកិច្ចលទ្ធកម្ម និង ការដោះស្រាយវិវាទពាក់ព័ន្ធកិច្ចលទ្ធកម្ម ត្រូវបានរៀបចំនិង ផ្សព្វផ្សាយការណែនាំអនុវត្តជូនក្រសួង ស្ថាប័ន ជាពិសេសក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី
- ការអនុម័តផែនការលទ្ធកម្ម ផែនការលទ្ធកម្មកែតម្រូវ និង ការអនុវត្តកិច្ចលទ្ធកម្មលើសិទ្ធិត្រូវបាន ផ្តល់ជូនក្រសួង ស្ថាប័ន
- របាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មរបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំបូកសរុប ។

**អនុកម្មវិធីទី ៤.៤ (អគ្គនាយកដ្ឋានរតនាគារជាតិ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះសម្រេចបានសមិទ្ធកម្មជារួមប្រមាណ៩៨% នៃគោលដៅសូចនករដែលបានកំណត់។ ក្នុងនោះ សមិទ្ធកម្មគន្លឹះដែលសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- ប្រតិបត្តិការចំណូលចំណាយ ត្រូវបានអនុវត្តតាមរយៈប្រព័ន្ធធនាគារ
- ការគ្រប់គ្រងសាច់ប្រាក់មានប្រសិទ្ធិភាពដោយសម្រេចបានអតិរេកសាច់ប្រាក់ ១,៨៣៨,៩៩០ លានរៀល
- កិច្ចបញ្ជីការគណនេយ្យមានភាពត្រឹមត្រូវ និង ស្របតាមស្តង់ដាអន្តរជាតិ ព្រមទាំងការរៀបចំនូវរបាយការណ៍ហិរញ្ញវត្ថុបានទាន់ពេលវេលា
- វិស័យព័ត៌មានវិទ្យានៅអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានពង្រឹងហើយប្រព័ន្ធគ្រប់គ្រងឯកសារ e-doc ត្រូវបានដាក់អោយដំណើរការនៅថ្នាក់កណ្តាល
- អគ្គនាយកដ្ឋានរតនាគារជាតិ និង រតនាគាររាជធានី-ខេត្ត បានអនុវត្តនូវភារកិច្ចក្នុងនាមជាគណនេយ្យករសាធារណៈ ប្រកបដោយភាពត្រឹមត្រូវ និង ទាន់ពេល ។

### គ.កម្មវិធីទី៥៖ ការផ្តល់សេវាគាំទ្រទូទៅ និង គណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីទី៥ រួមមានអនុកម្មវិធីចំនួន០៥ អនុវត្តចំណាយបាន ១៥២,៦៣៧.៥ លានរៀលស្មើនឹង ៩៣% នៃឥណទានថវិកាក្នុងច្បាប់ ដោយក្នុងនោះការអនុវត្តចំណាយក្នុងអនុកម្មវិធីទី

៥.១ មានចំនួន១,០៨៨.៥លានរៀល ស្មើនឹង៦៧.១% នៃឥណទានមានក្នុងច្បាប់ អនុកម្មវិធីទី៥.២ អនុវត្តចំណាយបាន ១៣២,៦៣៤.៩លានរៀល ស្មើនឹង៩៥.៦% នៃឥណទានក្នុងច្បាប់ ដោយក្នុងនោះអនុកម្មវិធីទី៥.៣ អនុវត្តចំណាយបាន ១៩,០៨៣.៩លានរៀល ស្មើនឹង៩៥.៦% នៃឥណទានក្នុងច្បាប់ អនុកម្មវិធីទី៥.៤ អនុវត្តចំណាយបាន ៦៤៦.១លានរៀល ស្មើនឹង ១១៧.១% នៃឥណទានក្នុងច្បាប់ និង អនុកម្មវិធីទី៥.៥ អនុវត្តចំណាយបាន ២៧២.៥លានរៀល ស្មើនឹង៨៥,៨% នៃឥណទានក្នុងច្បាប់។ វឌ្ឍនភាពសមិទ្ធកម្មនៃកម្មវិធីទី៥ សម្រេចបាន ៨៣%។ ចំណាយលម្អិតនៅក្នុងអនុកម្មវិធីនីមួយៗ នៃកម្មវិធីទី៥ សម្រេចបាន ៨៣% ។

ចំណាយលម្អិតក្នុងអនុកម្មវិធីនីមួយៗ និង ការសម្រេចបានតាមគោលដៅ សូចនាករសមិទ្ធកម្ម ដែលបានកំណត់ក្នុងផែនការ សកម្មភាពប្រចាំឆ្នាំ២០១៥ មានដូចតទៅ៖

**អនុកម្មវិធីទី៥.១ (អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៧៦% ធៀបនឹងគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះដែលសម្រេចបានក្នុងឆ្នាំ២០១៥ រួមមាន៖

- កិច្ចដំណើរការនៃការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានធានាប្រកបដោយ និរន្តរភាព និង ប្រសិទ្ធភាព ទន្ទឹមនឹងការត្រួតពិនិត្យកែលម្អ និង ដាក់ឱ្យអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង
- វឌ្ឍនភាពប្រចាំឆ្នាំ២០១៤ និង ប្រចាំត្រីមាសនៃឆ្នាំ២០១៥ ត្រូវបានត្រួតពិនិត្យវាយតម្លៃប្រកប ដោយសុក្រឹតភាព និង រាយការណ៍ជូនគណៈកម្មការការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផែនការសកម្មភាពរួមដំណាក់កាលទី៣(CAP3) និង ផែនការសកម្មភាព ការកែទម្រង់នៃក្រសួង ស្ថាប័ន(MAP3) និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(GDAP3) ត្រូវបានរៀបចំរួចរាល់និង ត្រៀមប្រកាសដាក់ឱ្យអនុវត្តនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៦
- របាយការណ៍វាយតម្លៃអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈរបស់កម្ពុជាឆ្នាំ២០១៥ (PEFA Report) ត្រូវបានរៀបចំរួចរាល់។
- សារាចរស្តីពីយន្តការដោះស្រាយកិច្ចប្រឈម និង សារាចរស្តីពីវិធាន និង នីតិវិធីនៃការរៀបចំការអនុវត្តការត្រួតពិនិត្យតាមដាន និង វាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបាន រៀបចំ និង ដាក់ឱ្យអនុវត្ត ។
- សមត្ថភាពមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន**គ.ហ.ស**ត្រូវបានពង្រឹងតាមរយៈវគ្គបណ្តុះបណ្តាលក្នុង និង ក្រៅប្រទេស ។

**អនុកម្មវិធីទី ៥.២ (អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួម ប្រមាណ ៨៥% នៃគោលដៅសូចនករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះសម្រេចបាន ក្នុងឆ្នាំ២០១៥ រួមមាន៖

- វិធាន និង គោលការណ៍ណែនាំផ្ទៃក្នុងក្រសួងសម្រាប់ការអនុវត្តថវិការកម្មវិធី និង សេចក្ដីព្រាងវិធាន និង គោលការណ៍សម្រាប់ដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ត្រូវបានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ(២០១៦-២០១៨) និង កញ្ចប់ថវិកាឆ្នាំ ២០១៦ របស់ក្រសួងត្រូវបានសម្របសម្រួលរៀបចំបូកសរុប និង ចងក្រងជាសៀវភៅ
- របាយការណ៍វឌ្ឍនភាពរបស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស៩ខែ និង ឆ្នាំ ត្រូវបានបូកសរុបជូន គណៈរដ្ឋមន្ត្រី
- កិច្ចស្រាវជ្រាវដើម្បីអភិវឌ្ឍផលិតភាព កម្លាំងពលកម្ម និង ភាពប្រកួតប្រជែង ត្រូវបានអនុវត្ត និង បានប្រមូលជាតុចូល ដើម្បីរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រសំខាន់ៗរបស់ជាតិ
- បញ្ហាប្រឈមនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវបានសម្របសម្រួលដោះស្រាយ
- កិច្ចការសម្រប និង ការគាំទ្រទូទៅ បានសម្រេចលទ្ធផលដូចតទៅ ៖
- សេវារដ្ឋបាល និង ហិរញ្ញវត្ថុ សម្រាប់ថ្នាក់ដឹកនាំក្រសួង អង្គភាពថវិកា ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព
- សេវាបុគ្គលិក រួមមាន ការកសាងផែនការបណ្តុះបណ្តាល, ការគ្រប់គ្រងបុគ្គលិក ការផ្ដល់ការលើ កទឹកចិត្ត និង ការរៀបចំបៀវត្សមន្ត្រីរាជការ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព
- សេវានីតិកម្មរួមមាន ការផ្តល់មិតប្រឹក្សាច្បាប់ លើការរៀបចំបទដ្ឋានគតិយុត្តរបស់អង្គភាពក្រោម ឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រៀបចំប្រមូលចងក្រង កម្រងសម្រង់បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង វិស័យហិរញ្ញវត្ថុសាធារណៈ វិស័យទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ និង វិស័យគយ
- សេវាបច្ចេកវិទ្យាពត៌មាន ត្រូវបានអនុវត្តប្រកបដោយរលូន
- សេវាបណ្ដុះបណ្ដាល ត្រូវបានអនុវត្តនិង បានឆ្លើយតបទៅតាមតម្រូវការជាក់ស្តែង ពិសេសការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអនុវត្តថវិការកម្មវិធី ។

**អនុកម្មវិធីទី ៥.៣៖ ផ្តល់សេវាគាំទ្រទូទៅ ថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាព និង ស័ក្តសិទ្ធភាព (មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី -ខេត្ត)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ សម្រេចបានសមិទ្ធកម្មជារួម ប្រមាណ ៩២% នៃគោលដៅសូចនាករដែលបានកំណត់ក្នុងនោះគ្រប់ចង្កោមសកម្មភាពទាំង ២៤ នៅមិនទាន់អាចសម្រេច បានតាមគោលដៅពេញលេញ នូវសូចនករគន្លឹះប្រចាំឆ្នាំ៖ ជានាប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅរាជធានី ខេត្ត ។

**អនុកម្មវិធីទី ៥.៤ (អគ្គាធិការដ្ឋាន)**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពក្នុងអនុកម្មវិធីនេះ៖ សម្រេចបានសមិទ្ធកម្មប្រមាណ ៧៥% នៃ គោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះសម្រេចបានក្នុងឆ្នាំ ២០១៥ រួមមាន៖

- ការចាត់វិធានការណ៍លម្អដល់ ក្រសួង ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ លើនីតិវិធីនៃការគ្រប់គ្រងចំណូលចំណាយថវិការដ្ឋ ត្រូវបានអនុវត្តចំនួន២៧ករណី
- ការដោះស្រាយបណ្តឹងតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំត្រូវបានអនុវត្ត ចំនួន២ក្រសួង និង ១មន្ទីរក្នុងទិសដៅពង្រឹងគណនេយ្យភាព ប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការចុះបញ្ជីធ្វើអធិការកិច្ចនៅតាមក្រសួង ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តសម្រេចបានមួយផ្នែកធំ ធៀបនឹងផែនការសកម្មភាព ។

**អនុកម្មវិធីទី ៥.៥ អគ្គនាយដ្ឋានសវនកម្មផ្ទៃក្នុង**

វឌ្ឍនភាពនៃការអនុវត្តសកម្មភាព ក្នុងអនុកម្មវិធីនេះសម្រេចបានសមិទ្ធកម្មជារួមប្រមាណ ៨៦% ធៀបនឹងគោលដៅសូចនាករដែលបានកំណត់។ ក្នុងនោះសមិទ្ធកម្មគន្លឹះ ដែលសម្រេចបានក្នុងឆ្នាំ២០១៥រួមមាន៖

- ការធ្វើសវនកម្ម នៅអង្គភាពថ្នាក់មូលដ្ឋានចំនួន៦៦ និង នៅអគ្គនាយកដ្ឋានចំនួន៥ អនុវត្តពាក្យ បណ្តឹងចំនួន៥ ចុះតាមតានការអនុវត្តអនុសាសន៍សវនកម្មនៅអង្គភាពថ្នាក់មូលដ្ឋានចំនួន២៩ និង ក្រុមការងារថ្នាក់ជាតិចុះខេត្តកោះកុងចំនួន៣លើក ។

## ១០.៦.និន្នាការនៃការប្តូរប្រាក់ និងគោលនយោបាយអត្រាប្តូរប្រាក់

### ១០.៦.១ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

ក្នុងអំឡុងឆ្នាំ ២០១០ អត្រាប្តូរប្រាក់រៀលមានស្ថិរភាពជាបន្តរដោយរងការប្រែប្រួលក្នុងគម្លាតមួយទាប ហើយ ប្រាក់រៀលបានឡើងថ្លៃថែមទៀតផងក្នុងរយៈពេលពីរ ឬ បីខែចុងក្រោយនៃឆ្នាំនេះ។ ពិនិត្យលើអត្រាប្តូរប្រាក់មធ្យម រវាងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ដែលជាមធ្យមភាគនៃអត្រាប្តូរប្រាក់ប្រចាំថ្ងៃក្នុងអំឡុងឆ្នាំ ២០១០ នេះរូបិយវត្ថុ ក្នុងស្រុកបានចុះខ្សោយជាធម្យម ១% ប៉ុណ្ណោះធៀបជាមួយប្រាក់ដុល្លារអាមេរិក ។ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ ២០១០ មានកម្រិត ៤.១៩៨ រៀលក្នុងមួយដុល្លារ ប្រៀបធៀបនឹង ៤.១៥៤ ក្នុងមួយដុល្លារកាលពីឆ្នាំ ២០០៩ ពោលគឺ មានការប្រែប្រួលប្រចាំឆ្នាំប្រហែល ៤៤ រៀល ឬ ១% ដែលជាការវិវត្តដ៏ប្រសើរមួយធៀបទៅនឹងបម្រែបម្រួលប្រមាណ ៩០ រៀល ឬ ២,២៥ កាលពីឆ្នាំ ២០០៩ ។

អត្រាប្តូររៀលមានការប្រែប្រួលខ្លាំង នៅក្នុងពាក់កណ្តាលឆ្នាំ ដែលកើនរហូតដល់ចំណុចកំពូល គឺ ៤.២៦៧ រៀល ក្នុងមួយដុល្លារនៅថ្ងៃទី ១ ខែ កក្កដា ហើយបានស្ថិតនៅក្នុងរង្វង់ ៤.២៥០រៀលក្នុងមួយដុល្លាររហូតដល់ដំណាច់ខែតុលា បន្ទាប់ពីមានការធ្វើអន្តរាគមន៍ដ៏សកម្មរបស់ធនាគារជាតិនៃកម្ពុជាដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ។ គួរកត់សម្គាល់ផង ដែរថា ជា

ទូទៅកត្តារដូវកាលគឺជាចំណុចសំខាន់មួយក្នុងការបកស្រាយពីការធ្លាក់ថ្លៃនៃរូបិយវត្ថុក្នុងស្រុក ក្នុងអំឡុងពេល ចាប់ពីខែឧសភា រហូតដល់ចុងខែតុលា។ ជាបន្ទាប់ នាអំឡុងខែក្រោយៗមកទៀត តម្រូវការកើនឡើងចំពោះរូបិយ វត្ថុជាតិនៅក្នុងរដូវកាលច្រូតកាត់ និងសម្រាប់ធ្វើការទូទាត់កាតព្វកិច្ចពន្ធ បានធ្វើឱ្យតម្លៃប្រាក់រៀលកើនឡើងនៅពេល ដែលអត្រាប្តូរប្រាក់មធ្យមក្នុងរយៈពេល ២ ខែចុងក្រោយ ធ្លាក់ចុះដល់ ៤.០៧២ រៀលក្នុងមួយដុល្លារ។

អត្រាចុងគ្រាបំផុតសម្រាប់ឆ្នាំ ២០១០ គឺ ៤.០៤៨ រៀល ។ ទិន្នន័យនេះ បង្ហានូវការឡើងថ្លៃនៃប្រាក់រៀលចំនួន ៣,២% ធៀបនឹងអត្រាប្តូរចុងគ្រានាឆ្នាំ ២០០៩ ដែលប្រាក់រៀលនៅពេលនោះរងការធ្លាក់ថ្លៃ ១,៨% ។




ក្រាភិច១០.២ ការវិវត្តនៃអត្រាប្តូរប្រាក់ធៀបនឹងដុល្លារ

### ១០.៦.២ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗមួយចំនួន

ដោយឡែក បើពិនិត្យលើរូបិយប័ណ្ណរបស់ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗ របស់កម្ពុជា អត្រាខ្វែងនៃឯកតា រូបិយប័ណ្ណ ទាំងនោះធៀបនឹងប្រាក់រៀល ដែលបានវាស់វែងតាមរយៈប្រាក់ដុល្លារ បានបង្ហាញនូវបម្រែបម្រួលយ៉ាងខ្លាំង ក្នុងគម្លាតរវាង ១០% និង -១០% ពីអត្រានាឆ្នាំគោល (ចុងខែធ្នូ ឆ្នាំ ២០០៩ –មើលក្រាហ្វខាងក្រោម) ។ ក្នុង ចំណោមរូបិយប័ណ្ណដែលបានតាមដានទាំងឡាយ រូបិយប័ណ្ណខាងក្រោមបានឡើងថ្លៃធៀប នឹងប្រាក់រៀល បើធៀបនឹង គ្រាគោល ៖ ប្រាក់ដុល្លាអូស្ត្រាលី និង ប្រាក់យ៉េនជប៉ុនចំនួន ១០,១% ប្រាក់រីងហ្គីតម៉ាឡេចំនួន ៨,៤ % ប្រាក់បាតថៃចំនួន ៧,២% ប្រាក់ដុល្លារសាំងហ្គាពួរចំនួន ៦% ប្រាក់រូពីឥណ្ឌូណេស៊ី និងប្រាក់ប៉េសូហ្វីលីពីន ចំនួន ២,៥%និង ប្រាក់ដុង វៀតណាមបានធ្លាក់ថ្លៃធៀបនឹងប្រាក់រៀលក្នុងចំនួន ៩,៩% និង ៧,៦% រៀងគ្នា លើតម្លៃរបស់រូបិយប័ណ្ណ ទាំងពីរកាល ពីមួយឆ្នាំមុន។



ក្រាភិច១០.៣ ការវិវត្តអត្រាប្រាក់រៀនធៀបនឹងរូបិយប័ណ្ណមួយចំនួន

កម្ពុជា មិនរស់នៅក្នុងសៀគ្វីបីធជីពនោះទេ ផ្ទុយទៅវិញ ពាណិជ្ជកម្មក្រៅប្រទេស មានតួនាទីសំខាន់ ណាស់ក្នុងសេដ្ឋកិច្ចប្រទេស។ សព្វថ្ងៃប្រាក់រៀលអាចដូរបានមួយរូបិយប័ណ្ណបរទេស។ គេត្រូវសួរបន្ថែម ទៀតលើទិដ្ឋភាពស្លាប័កបន្ទាប់មកពិនិត្យលើតថភាពនៃការបញ្ចូលប្រាក់រៀលនៅក្នុងប្រព័ន្ធរូបិយវត្ថុអន្តរជាតិ។

## ១០.៧.ហិរញ្ញវត្ថុសាធារណៈ

### ១០.៧.១.ទិដ្ឋភាពរូបិយប័ណ្ណ

គេឃើញបញ្ហាពាណិជ្ជកម្មក្រៅប្រទេស នូវជំហរសំខាន់ៗ ដែលធ្វើឱ្យមានភាពស្មុគស្មាញ ដល់ច្បាប់ នៃការប្តូរប្រាក់ ។ ពោរជាបទបញ្ញា ឬច្បាប់នៃការប្តូរប្រាក់ ។ នោះជាបទបញ្ញា ឬច្បាប់ដែលឱ្យនិយមន័យលក្ខខ័ណ្ឌនានា ក្នុងនោះមានការប្រព្រឹត្តទៅនៃការប្តូរប្រាក់ជាមួយប្រាក់បរទេល។ ចំណុចទីមួយ គឺថាការប្តូរនេះ មិនប្រព្រឹត្តទៅដោយសេរីនោះទេះ មានការអនុញ្ញាតជាចាំបាច់ ដើម្បីទិញរូបិយប័ណ្ណខ្លាំងជាមួយលុយរៀល។ ចំណុចទីពីរនោះ គឺ ការប្តូរប្រាក់ធ្វើឡើង នៅភ្នំពេញ លើទីផ្សារប្តូរប្រាក់ បង្កើតឡើងដោយ B.N.C.ហើយនៅក្នុងកម្រិតអត្រាប្តូរសម្រាប់រូបិយវត្ថុមួយនឹងន។ ទីបី អត្រាសម្រាប់រូបិយប័ណ្ណមួយ តាមទ្រឹស្តីតែមួយ ហើយអថេរយោងទៅតាមប្រភេទនៃការប្រតិបត្តិការ ឬទៅលើទំនិញនាំចូល និងនាំចេញ ។ ចំណុចទីបួន គឺមានការប្រៀបធៀបមិនដូចគ្នាមួយ តែការប្តូរប្រាក់ "disparité de change រវាងអត្រាប្តូរលុយហ្វ្រង់ ១F = ១០ riels និង អត្រា ប្តូរលុយដុល្លារ ១ ដុល្លារ = ៥ ហ្វ្រង់ " ។

ប្រាក់រៀលមាននិយមន័យ ធៀបនឹងមាន “ ១ រៀល = ២៥.៣៩០៥ មីលីក្រាម មាសសន្លឹក “ ប៉ុន្តែ និយមន័យនេះគ្មានន័យអ្វីទេ លុយរៀលប្តូរបានដោយបង្ខំ នៅក្នុងប្រទេស ប៉ុន្តែនៅបរទេស មិនអាចដូរ បានងាយទេ។ លុយរៀលមិនអាចបម្រើ ជាការកំណត់ នៃអត្រាប្តូរប្រាក់

ទៀត បាន៧ ក្រោម មាន "disparité de change" រវាងលុយ ហ្វ្រង់ រឹង លុយដុល្លារ ហើយ លុយហ្វ្រង់ និងលុយដុល្លារ ក៏ជាប្រាក់ដែលផ្តល់និយមន័យដោយ ធៀបនឹង មានដែរ ។

តើនៅពេលនោះ កម្ពុជាស្ថិតនៅក្នុងតំបន់លុយហ្វ្រង់ឬទេ? ប្រទេសបារាំង បានចាត់ទុកជាយូរមកហើយ ដើម្បីបដិសេធរាល់ប្រជាជនកម្ពុជា នូវបុព្វសិទ្ធ " ដែលអនុញ្ញាតតាំងពីឆ្នាំ ១៩៥៩ ដល់ អ្នកគ្មានទីលំនៅ នៅតំបន់ ។ ឱ្យប្តូរប្រាក់ដោយសេរី ប្តូរលុយហ្វ្រង់ ជាមួយរូបិយប័ណ្ណផ្សេងទៀត ។ ប៉ុន្តែ ក្នុងនាមជាសមាជិក នៅតំបន់ហ្វ្រង់ មកបង្កើតឱ្យមានផលវិបាកអ្វីទេ គេឃើញការផ្ទេរប្រាក់រវាងកម្ពុជា និង ប្រទេសក្នុងតំបន់លុយហ្វ្រង់ មិនសូវជាសេរីដែរទេ ជាងកម្ពុជា និងប្រទេសនានាក្នុងពិភពលោកដែរ ហើយកម្ពុជាមានទីផ្សារប្តូរប្រាក់ផ្ទាល់ខ្លួន គឺ កម្ពុជាចាត់ទុកខ្លួនថា មិនមែនជាសមាជិកនៅតំបន់ហ្វ្រង់ទេ ។ នៅឆ្នាំ ១៩៦៥ បារាំងបានពង្រីកការប្តូរប្រាក់ ដល់អ្នកតាំងទីលំនៅក្នុងតំបន់ហ្វ្រង់ ។ ប៉ុន្តែ ជនកម្ពុជា បន្តមិនធ្វើការប្តូរប្រាក់ដោយសេរី នូវហ្វ្រង់ដែលខ្លួនមាន ជាមួយរូបិយប័ណ្ណដ៏ទៃទៀយ ។ គេអាចនិយាយថា កម្ពុជាមិនមែនស្ថិតក្នុងតំបន់ហ្វ្រង់ទេ ។

កម្ពុជាមិនមែនជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ ឬក៏ធនាគារពិភពលោក ឬសាខារបស់ធនាគារនោះទេ ។ គេឆ្ងល់ដែរ ប្រទេសកម្ពុជានៅវាកែ មិនចូលជាសមាជិកអង្គការទាំងនោះ ។ កម្ពុជាចូលជាសមាជិក ធនាគារអភិវឌ្ឍន៍អាស៊ី នៅពេលបានបង្កើត ធនាគារនៅឆ្នាំ ១៩៦៦ ប៉ុន្តែមួយឆ្នាំក្រោយមក ក៏បានដកខ្លួនថយ ចេញវិញ ។ បើកម្ពុជា ជាសមាជិក F.M.L. នោះគេមានសិទ្ធិទទួល បាន Boa de Tirages spéciaux និង ការណែនាំ ជាទីប្រឹក្សាដ៏សំខាន់មានប្រយោជន៍ ។ ប៉ុន្តែ ទាំងរដ្ឋាភិបាលកម្ពុជា និង ធនាគារ B.S.C តែងតែបានចូល រួម ក្នុងនាម "ភ្ញៀវពិសេសៗ ខែកិច្ចប្រជុំរបស់អគ្គទេសាភិបាល នៃមូលនិធិនោះ ។

## ១០.៧.២.និដ្ឋភាពគថភាព

តើការវិវឌ្ឍន៍ ក្នុងព្រឹត្តិការណ៍ នៃសភាពការណ៍រូបិយវត្ថុអន្តរជាតិកម្ពុជា ប្រព្រឹត្តទៅបែបណា?

ព្រឹត្តិការណ៍ទីមួយ ដែលត្រូវការបញ្ជាក់នោះ គឺ ភាពរឹងមាំនៃប្រាក់រៀល ធៀបនឹងប្រាក់ដ៏ទៃទៀត។ ការប្រៀបធៀបផ្លូវការ នៃការធៀបហ្វ្រង់ បារាំង និងដុល្លារអាមេរិច បានត្រូវរក្សាទុករយៈពេលយូរ ដូចដែលធ្លាប់បានកំណត់អត្រាលុយ piatre នៅឥណ្ឌូចិន នាឆ្នាំ ១៩៥៣ ។ កម្ពុជាមិនដែលមានគំនិតបញ្ចុះថ្លៃដាក់ខ្លួនទេ ។

នៅក្នុងទីផ្សារងងឹត លុយរៀលមិនដែល បាត់តម្លៃខ្លួនឡើយ ព្រោះអត្រាដែលត្រូវប្តូរ វិលចុះឡើងជុំវិញ ៧៥ រៀល ក្នុងមួយដុល្លារ នៅក្នុងរយៈពេលនោះ ។ នេះជាអត្រាងងឹតដែលសមស្រប ។ ចំនួនប្រាក់ដែលប្តូរ នៅ លើទីផ្សារ គឺទាក់ទងតែនឹងការប្តូរ ដោយគ្មានការអនុញ្ញាតតែប៉ុណ្ណោះ ហើយការរត់ពន្ធគយ ដូចជាមិនសូវសំខាន់ ទេ ហើយទោះបីមានការប្រែប្រួលតិចតួចនៃអត្រានោះ ក៏មិនធ្វើឱ្យប៉ះពាល់ដល់អត្ថន័យ នៃសេដ្ឋកិច្ចដែរ ។ អស់ រយៈពេលជាង ១០ ឆ្នាំ នៃស្ថេរភាពប្រាក់រៀល ជាអត្ថន័យ នៃការគូសបញ្ជាក់ ។

អត្រាប្តូរប្រាក់ ជាផ្លូវការមានន័យគ្រប់គ្រាន់ ព្រោះរូបិយប័ណ្ណដែលខិញនៅលើទីផ្សារនោះ សម្រាប់បម្រើការទូទាត់ការនាំចូល ។ អត្រាផ្សារងងឹត ពេលខ្លះមានការប្រែប្រួលដល់ទៅ ៨២ រៀលក្នុងមួយដុល្លារ ។

ប្រាក់រៀលបានបង្ហាញថាខ្លួនមានភាពរឹងមាំ ចាប់តាំងពីពេលកើតឡើងនាឆ្នាំ ១៩៥៥ ។ ស្ថេរភាពនេះ ធ្វើ បង្កើតជាឥណទាន ដោយគ្មានអតិផរណាក្នុងប្រទេស និងការអភិវឌ្ឍដ៏ល្អដល់ជញ្ជីងទូទាត់ ។

ចំណុចទីពីរ មានលក្ខណៈពិសេសនៃប្រព័ន្ធរូបិយប័ណ្ណកម្ពុជា គឺហាក់ដូចជាប្រព័ន្ធ នៃអត្រាប្តូរច្រើនបែប មិនត្រឹមតែចំពោះប្រទេសនានាទេ (disparite) ប៉ុន្តែនៅលើប្រតិបត្តិការណ៍ផ្សេងៗ និង ការគិតគូរជាទ្រព្យសម្បត្តិ ក៏ដោយ ។

ជាគោលការណ៍ ប្រព័ន្ធនេះមិនមែនជាប្រព័ន្ធនៃអត្រាប្តូរច្រើនបែបនេ : ច្បាប់គយ គឺ គិតជារៀល តាម តម្លៃនៃរូបិយប័ណ្ណ នៃការផលិតនាំចូល គណនាតែអត្រាប្តូរផ្លូវការ ហើយអាជ្ញាធររូបិយវត្ថុ មានសិទ្ធិពិនិត្យ ក្នុង ការ អនុវត្តន៍ឡូវគណនី F.A.C.ឬ មើល péréquetoz យន្តការ នៃការជួយបំពេញក្នុងប្រទេស ដែលមិន ប្រព្រឹត្តិ ទៅតាមអត្រាប្តូរប្រាក់តែមួយទេ ។

តែការដាក់ស្តែងសម្រាប់ភ្នាក់ងារសេដ្ឋកិច្ច អត្រាផ្លូវការ "ឬហៅអត្រាប្តូរប្រាក់ផ្លូវការទាំងពីរ" បានប្រើប្រាស់ត្រឹមតែការផ្ទេរទុន ដែលមានការអនុញ្ញាត និងដើម្បីទូទាត់ការនាំចូលមិនសូវសំខាន់។ ឧទាហរណ៍ ទំនិញនាំចូលពីបារាំង ថ្លៃ ១,០០០ហ្វ្រង់ ហើយត្រូវដាក់ចូលទៅក្នុង "péréquation" ដល់ទៅ ៥២% អ្នកនាំចូលខ្មែរ ត្រូវទូទាត់ថ្លៃទំនិញនេះ ១,០០០រៀល បូកនឹង ៥២០រៀល។ អ្វីៗប្រព្រឹត្តទៅដូចដែលគេអនុវត្តន៍ លើមុខទំនិញនាំចូលនេះ នូវអត្រាប្តូរប្រាក់ ១៥.២ រៀល ក្នុងមួយហ្វ្រង់។ សម្រាប់ទំនិញផ្សេងទៀត ដែលត្រូវកំណត់យក péréquation ចំនួន ៤០% នោះអ្វីៗប្រព្រឹត្តទៅ ដូចក្នុងអត្រា ១៤រៀល ក្នុង ១ ហ្វ្រង់។ ចំពោះរូបិយប័ណ្ណដែលបានមកពីចំណូលទេសចរណ៍របស់បរទេស គឺកំណត់តាមអត្រាមួយប្លែកពីអត្រាផ្លូវការ ព្រោះទេសចរណ៍ទទួលបានរង្វាន់ "prime" គឺ ២ រៀល សម្រាប់មួយហ្វ្រង់ ហើយនៅចុងបញ្ចប់ ១ ហ្វ្រង់ = ១២ រៀល។ នោះគេប្រឈមមុខនឹងអត្រាប្តូរប្រាក់ដែលប្រែប្រួលទៅតាមប្រតិបត្តិការ ឬ ផលិតផល។ បែបបទប្តូរប្រាក់នេះ មានឥទ្ធិផល ជាឱសថព្យាបាលការកំណត់សន្និដ្ឋានតម្លៃប្រាក់រៀល។

អត្រា"ឬអត្រាទាំងពីរ" ផ្លូវការ និងទ្រឹស្តីតែមួយ គឺ probablement មានឥទ្ធិផលកំណត់"ទាបពេក"។ បើវាល់ចម្លងការប្រព្រឹត្តទៅតាមអត្រា ៣៥ រៀលមួយដុល្លារ "ឬ ១០ រៀលក្នុង ១ ហ្វ្រង់" វាមានការលំបាកក្នុងការធ្វើឱ្យមានការលំនឹង នៃជញ្ជីងទូទាត់។ ការនាំចេញ ពីការនាំចេញអង្ករ មិនអាចប្រព្រឹត្តទៅបាន។ ថ្លៃអង្ករលើទីផ្សារក្នុងស្រុកប្រហែល ៣,៥០០ រៀលមួយតោន គិតជាដុល្លារ អត្រាផ្លូវការស្មើ ១០០ ដុល្លារ គឺទាបជាងថ្លៃពិតពលោក ហើយថ្លៃនៃស្រូវនេះ គឺ លក់លើទីផ្សារអន្តរជាតិ។ ការនាំចេញនៃកម្ពុជា ដូចជា កៅស៊ូ ត្រូវតែប៉ះប៉ូវបន្ថែម គឺតាមរូបិយប័ណ្ណបន្សំ ដោយ E.F.A.C.ឬយកចេញពី péréquation ។ ប៉ុន្តែការបន្ថែមនេះ មិនមែនជាបន្ទុកនៃថវិកាទេ នោះជាបន្ទុកអ្នកនាំចូល និង អតិថិជនរបស់គេ ព្រោះគេជាអ្នកទូទាត់

ផលិតផលនាំចូលថ្លៃបំផុតតាមអត្រាប្តូរផ្លូវការ ដែលអនុវត្តតម្លៃនៃរូបិយប័ណ្ណនៃផលិតផលនោះ។ ដោយសារតែបែបបទលើកតម្លៃប្រាក់រៀល គឺ គ្មានផលប៉ះពាល់លើលំនឹងនៃហិរញ្ញវត្ថុក្រៅប្រទេសដែរ។ អត្រាប្តូរប្រាក់កំណត់ទាបមែន គឺ ១០រៀល ១ ហ្វ្រង់ តែគ្មានសារៈសំខាន់ទេ ព្រោះភាគខ្លះនៃចំណាងការ ប្រព្រឹត្តទៅតាមប្តូរប្រាក់ ១២ រៀល ១៤ រៀល ១៥ រៀល ២០ រៀល ក្នុងមួយហ្វ្រង់។

ប្រព័ន្ធ péréquation បង្ហាញនូវផលប្រយោជន៍ធំណាស់។ តែមានឱ្យមានអត្រាប្តូរប្រាក់ច្រើនប្រភេទហើយបញ្ចុះថ្លៃដោយមិនដឹងខ្លួន។ ចំណុចខ្សោយនៃប្រព័ន្ធនេះ ស្ថិតក្នុងភាពស្មុគស្មាញ។ អាវុធដ៏គ្រោះថ្នាក់នេះមិនអាចធ្លាក់ទៅវាល់ដៃនៃមនុស្សទេ។

## ១០.៨.ចំណូល ចំណាយសាធារណៈ

អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ ដើម្បី សម្រេចគោលដៅធម្មនុញ្ញនេះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងនៅក្រោមឱវាទនៃរាជរដ្ឋាភិបាលកម្ពុជា ដោយច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ មានសមត្ថកិច្ចដឹកនាំ និង គ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមុខងារ និង ភារកិច្ចជាសារវន្ត ដូចតទៅៈ

- បំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ ការអនុវត្ត ការតាមដាន និង ការគ្រប់គ្រងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និង រយៈពេលវែង របស់ព្រះរាជាណាចក្រកម្ពុជា
- បំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លើការលក់ ការជួល ការផ្ទេរ និង ការចាត់ចែងដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋ ការផ្តល់សម្បទានផ្សេងៗ របស់រដ្ឋព្រមទាំងការផ្ញើបញ្ញើសារពើភ័ណ្ឌ
- ដឹកនាំការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ ការរៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យម ការគោរពច្បាប់ហិរញ្ញវត្ថុ ព្រមទាំងធានាការត្រួតពិនិត្យជាប្រចាំលើការគ្រប់គ្រងថវិកា
- បំពេញមុខងារជាអាណាប័កចំណាយលើការប្រាក់នៃការខ្ចី ចំណាយផ្សេងៗ ចំណាយសំណង និង ចំណាយបង្វិលសងវិញព្រមទាំងចំណាយទូទាត់ប្រាក់ខ្ចីនៅក្នុងប្រទេស និង ពីក្រៅប្រទេស និង ទូទាត់បំណុលប្រហាក់ប្រហែល
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូលចំណាយ ការខ្ចី ការឱ្យខ្ចី និង ការធានារបស់រដ្ឋដែលត្រូវបានអនុញ្ញាតដោយច្បាប់
- ប្រមូល និង ត្រួតពិនិត្យពន្ធ អាករ និង ចំណូលសារពើពន្ធផ្សេងទៀត តាមការកំណត់របស់ច្បាប់

- មានសិទ្ធិឯកាទិភាពក្នុងការខ្ចីប្រាក់គេ ការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណងការវិនិយោគលើអចលកម្មហិរញ្ញវត្ថុ ការធានា និង ការសន្សំផ្នែកហិរញ្ញវត្ថុនានា និង ការឱ្យប្រាក់គេខ្ចីទាំងក្នុង និង ក្រៅប្រទេស ក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និង ក្រោមអំណាចរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រម្ពុជា។

- មានសិទ្ធិឯកាទិភាពរៀបចំកម្មវិធីដោះស្រាយបំណុលដែលរដ្ឋជំពាក់គេឬបំណុលដែលគេជំពាក់រដ្ឋ

- គ្រប់គ្រងលទ្ធកម្មសាធារណៈ និង ណែនាំក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។ នៅក្នុងក្របខ័ណ្ឌមុខងារ និង ភារកិច្ច ដែលកំណត់ដោយច្បាប់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចូលរួមចំណែកអនុត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ដើម្បី កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព

ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភានៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យ និង ប្រាកដនិយមរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ផ្អែកលើមូលដ្ឋាននៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៧១៤/០១៩ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៤ បានកំណត់លម្អិតជាគោលនយោបាយអាទិភាព សកម្មភាពការអនុវត្តគោលនយោបាយអាទិភាព និង វិស័យជាក់លាក់ ដើម្បីបែងចែកដល់ការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ចំណុះរាជរដ្ឋាភិបាល ម្ចាស់ការ ការចូលរួម និង សហការអនុវត្ត តាមសូចនាករគោលដៅសមិទ្ធកម្ម ប្រកបដោយស័ក្តិសិទ្ធិភាព និង ប្រសិទ្ធភាពទៅតាមតួនាទី និង បេសកកម្មដែលកំណត់ដោយរាជរដ្ឋាភិបាល។

## ១០.៨.១.តួនាទី និង បេសកកម្មចម្បងៗ សម្រាប់ឆ្នាំ(២០១៧-២០១៩)

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និង គ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និង លើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និង សមធម៌សង្គម។

បេសកកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំ និង ការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និង បទបញ្ញាទាំងឡាយទាក់ទងនឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និង ឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់ និង បទបញ្ញាពាក់ព័ន្ធផ្សេងទៀត។

ដើម្បីសម្រេចបេសកកម្ម ដែលរដ្ឋាភិបាលបានប្រគល់ជូនខាងលើនេះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានមុខងារ និង ភារកិច្ច ដូចតទៅ៖

- រៀបចំអនុវត្ត និង តាមដានអនុវត្តគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល

- គ្រប់គ្រង និង សម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ពង្រឹងអភិបាលកិច្ចលើអ្វីដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ

- វិភាគតាមដាន និង ព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី រយៈពេលមធ្យម និង រយៈពេលវែង និង ដាក់ចេញនូវវិធានការ ដើម្បីតម្រង់ទិស និង កែលម្អការគ្រប់គ្រងសេដ្ឋកិច្ច

- សហការជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំនិង ចូលរួមក្នុងការរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើកិច្ចការសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង កិច្ចការសមាហរណកម្មកម្ពុជា ទៅក្នុងសេដ្ឋកិច្ចសសេរីពិភពលោក ជាពិសេសកិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាក្នុងក្របខ័ណ្ឌអាស៊ាន

- កសាងប្រព័ន្ធហិរញ្ញវត្ថុឱ្យឯកភាពទូទាំងប្រទេស ហើយធានាអនុវត្តប្រព័ន្ធនេះឱ្យបានត្រឹមត្រូវតាមច្បាប់ពាក់ព័ន្ធ និង បទបញ្ញាដទៃទៀត

- ធ្វើការបែងចែក និង បែងចែកឡើងវិញ នូវផលទុនជាតិតាមរយៈការប្រមូលចំណូល និង កម្មវិធី នីយកម្ម និង ថវិកានីយកម្មនៃចំណាយសាធារណៈ

- រៀបចំ និង កសាងសេចក្តីព្រាងច្បាប់ និង បទបញ្ញាផ្សេងៗ សម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬជាលក្ខណៈអចិន្ត្រៃយ៍

- រៀបចំ និង គ្រប់គ្រងថវិការដ្ឋ

- រៀបចំ និង អនុវត្តគោលនយោបាយចំណូលថវិកាជាតិ

- ប្រមូលចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធបង់ចូលបេឡាថវិការដ្ឋ

- រៀបចំ និង អនុវត្តគោលនយោបាយចំណូលថវិកាជាតិ

- ប្រមូលចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និង វិភាគគណនានៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ

- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- ចូលរួមកសាង និង អនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានពីក្រៅប្រទេស និង ទទួលបន្ទុកគ្រប់គ្រងបំណុលសាធារណៈ

- ចូលរួមរៀបចំគោលនយោបាយ និង គ្រប់គ្រងកិច្ចការវិនិយោគ

- ពិនិត្យ និង ចុះទិដ្ឋាការលើចំណាយរបស់ក្រសួង និង ស្ថាប័នរដ្ឋនានា

- គ្រប់គ្រង និង ត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈនៃបណ្តាប្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលអង្គភាពរដ្ឋដទៃទៀត និង ដៃគូឯកជនសាធារណៈ

- ទទួលបន្ទុកដឹកនាំការរៀបចំ ជំរុញការអនុវត្ត និង ការតាមដាន ការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល

- វិភាគ គ្រប់គ្រង និង តាមដានការវិវត្តនៃវិស័យហិរញ្ញវត្ថុ ព្រមទាំងចូលរួមរៀបចំ និង អនុវត្តក្រប ខ័ណ្ឌគ្រប់គ្រងហានិភ័យនៃវិស័យហិរញ្ញវត្ថុ ដើម្បីជានាស្ថិរភាពហិរញ្ញវត្ថុ

- អភិវឌ្ឍ គ្រប់គ្រង និង ត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុ រួមមានកិច្ចការធានារ៉ាប់រង និង សោធនទីផ្សារ និង ស្ថាប័នហិរញ្ញវត្ថុ

- ចូលរួមរៀបចំ និង អនុវត្តគោលនយោបាយ និង ក្របខ័ណ្ឌនៃការប្រឆាំង ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- គ្រប់គ្រង និង ត្រួតពិនិត្យអាជីវកម្មភ្នាល់គ្រប់ប្រភេទ

- ធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈ ប្រហាក់ប្រហែល សហគ្រាសសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអនុវត្តប្រតិបត្តិការថវិការដ្ឋ

- បំពេញមុខងារសវនកម្មផ្ទៃក្នុង

- បណ្តុះបណ្តាល និង ធ្វើវិក្រឹតការជាប្រចាំនូវមុខជំនាញសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ការគ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋដល់មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ

- អនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ដោយឡែក ដើម្បីសម្រេចបេសកកម្មដែលរាជរដ្ឋាភិបាលប្រគល់ឱ្យនេះផងដែរ មានអង្គភាពចំនួន ៥ផ្សេងទៀតដែលចូលរួមបម្រើគោលបំណងគោលនយោបាយទាំងពីររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ផងដែរគឺ៖

១.គណៈកម្មធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

២.ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

៣.គណៈកម្មធិការមូលបត្រកម្ពុជា

៤.ក្រុមប្រឹក្សាជាតិគណនេយ្យ

៥.គណៈកម្មធិការផលិតភាពកម្ពុជា។

ក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន អង្គភាពទាំង៥ខាងលើនេះ បានចូលរួមចំណែកអនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈមុខងារសំខាន់ៗ ដូចខាងក្រោម៖

### ក.គណៈកម្មធិការដឹកនាំការងារកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ការសម្របសម្រួលការងារប្រចាំថ្ងៃរបស់ គ.ហ.ស ស្របតាមការណែនាំ និង ការសម្រេចរបស់គ.ហ.ស ដោយរួមទាំងការរៀបចំដាក់ឱ្យអនុវត្ត និង ការតាមដានត្រួតពិនិត្យគោល

នយោបាយយុទ្ធសាស្ត្រ និង ផែនការសកម្មភាពនៃកម្មវិធីកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំង ការរៀបចំឯកសាររបាយការណ៍កិច្ចប្រជុំ និង សិក្ខាសាលាផ្សេងៗ

- សម្របសម្រួលប្រចាំថ្ងៃលើការងាររដ្ឋបាល គណនេយ្យហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និង ផ្នែក ភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ផ្តល់យោបល់ និង លើកសំណើដោះស្រាយជូន គ.ហ.ស លើបញ្ហាប្រឈមនានា និង បញ្ហាជំនាញបច្ចេកទេសជំរុញល្បឿន និង ការបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- សហការ និង សម្របសម្រួល ជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ទីប្រឹក្សាបច្ចេកទេសគ្រប់អង្គភាព និង អ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំ និង ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមការចង្អុលបង្ហាញរបស់ គ.ហ.ស

- ផ្តល់ការគាំទ្រជូនអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និង អង្គភាពនានា ក្រោម ឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និង អង្គភាពនានារបស់រាជរដ្ឋាភិបាលតាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំការអនុវត្ត ការតាមដាន និង ត្រួតពិនិត្យ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យវាយតម្លៃ និង បូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសូចនាករកម្រិតម៉ាក្រូសេដ្ឋកិច្ច និង ការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាព ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការ និង អង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង នៅតាមក្រសួង ស្ថាប័ន ដោយរាប់បញ្ចូលបច្ចុប្បន្នកម្មជាទៀងទាត់លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ការសម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីការកែទម្រង់របស់រាជរដ្ឋាភិបាល ជា ពិសេសកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈនិងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- ផ្សព្វផ្សាយ និង ណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ខ.ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

- ពិនិត្យ និង រៀបចំឯកសារវិភាគស្រាវជ្រាវ និង សុន្ទរកថាសំខាន់ៗ ព្រមទាំងលើកឡើងនូវគំនិត ផ្តួចផ្តើមទាំងឡាយដែលមានចរិតជាចក្ខុវិស័យគោលនយោបាយ និង យុទ្ធសាស្ត្រកែទម្រង់ និង អភិវឌ្ឍសង្គមសេដ្ឋកិច្ចជូនប្រមុខរាជរដ្ឋាភិបាល

- រៀបចំអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវគុណភាព និង សង្គតិភាពនៃ គោលនយោបាយអភិវឌ្ឍសង្គមសេដ្ឋកិច្ច នៅក្នុងរវាងវិស័យនានា និង ផ្តល់

យោបល់ជូនប្រមុខរដ្ឋាភិបាល ដើម្បីដាក់ចេញនូវទិសដៅច្បាស់លាស់ សម្រាប់អនុវត្តឱ្យបានរលូនគោលនយោបាយយុទ្ធសាស្ត្រផែនការ និង កម្មវិធីនានារបស់រាជរដ្ឋាភិបាល

- ស្នើឡើងវិធានការដាក់ស្តែងនានា ក្នុងទិសដៅកែលម្អការគ្រប់គ្រងសង្គម សេដ្ឋកិច្ច និង ពង្រឹង អភិបាលកិច្ចជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និង សម្រេច

- ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាលក្នុងការតាមដាន និង បូកសរុបរបាយការណ៍នានាដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រផែនការនិងកម្មវិធីនានា របស់រាជរដ្ឋាភិបាលព្រមទាំងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីតម្រង់ទិស និង បង្កើនល្បឿនអនុវត្តគោលនយោបាយយុទ្ធសាស្ត្រផែនការ និង កម្មវិធីទាំងនោះ

- ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និង បូកសរុបការអនុវត្តការងារកែទម្រង់និង គំនិតផ្តួចផ្តើមនានា ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញដោយផ្ទាល់

- បូកសរុប និង ធ្វើរបាយការណ៍សង្ខេបជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដំណើរការ នយោបាយសេដ្ឋកិច្ចជាតិឱ្យស្របទៅតាមនិន្នាការវិវត្តន៍នៃសេដ្ឋកិច្ចតំបន់ និង សេដ្ឋកិច្ចអន្តរជាតិ។

### គ.គណៈកម្មការមូលបត្រកម្ពុជា

- គ្រប់គ្រង និង ត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុវត្តជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និង ទូទាត់ និង ប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌ ផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និង ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- ដើរតួជាស្ថាប័នពិនិត្យ និង ដោះស្រាយលើការតវ៉ា ចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិក អ្នកចូលរួម ឬអ្នកវិនិយោគ
- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយ សម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ឃ.ក្រុមប្រឹក្សាជាតិគណនេយ្យ

- ពិនិត្យ និង ផ្តល់យោបល់លើរាល់គម្រោងច្បាប់ និង បទបញ្ញានានា ដែលមានបទប្បញ្ញត្តិទាក់ទងនឹងការរៀបចំកិច្ចការគណនេយ្យសម្រាប់រាល់សហគ្រាស ឬសកម្មភាពសេដ្ឋកិច្ច
- រៀបចំក្របខ័ណ្ឌ ទស្សនាទាន និង ស្តង់ដារគណនេយ្យ
- ស្នើឡើងនូវមធ្យោបាយសម្រាប់កែលម្អបច្ចេកទេសគណនេយ្យ

- ធ្វើជាតំណាងព្រះរាជាណាចក្រកម្ពុជា នៅក្នុងអង្គការអន្តរជាតិ និង នៅក្នុងកិច្ចប្រជុំដើម្បីជជែក វែកញែកអំពីគណនេយ្យ។

**ង.គណៈកម្មាធិការផលិតភាពកម្ពុជា**

- សិក្សា និង វិភាគអំពីសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និង ភាពប្រកួតប្រជែងដើម្បីផ្តល់នូវអនុសាសន៍ និង ជាតុចូលជូនប្រមុខរាជរដ្ឋាភិបាល សម្រាប់ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រក្របខ័ណ្ឌគោលនយោបាយ និង គោលនយោបាយសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម ភាពប្រកួតប្រជែងការអភិវឌ្ឍភាពជាដៃគូរវាងផ្នែកសាធារណៈ ផ្នែកសាជីវកម្ម និង ផ្នែកទីផ្សារពេលកម្ម ដោយត្រូវធានាឱ្យបាននូវសង្គតិភាព និង ភាពស៊ីសង្វាក់គ្នាជាមួយគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និង កម្មវិធីនានា របស់រាជរដ្ឋាភិបាល ពិសេសជាមួយគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម

- ពិនិត្យ និង វាយតម្លៃអំពីសង្គតិភាព និង ភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងប្រសិទ្ធភាពនៃការអនុវត្ត យុទ្ធសាស្ត្រគោលនយោបាយ និង កម្មវិធីនានា របស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងសេដ្ឋកិច្ចពលកម្មផលិត ភាពពលកម្ម និង ភាពប្រកួតប្រជែង និង លើអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ចេញនូវវិធានការកែលម្អ

- សហការជាមួយអង្គភាពពាក់ព័ន្ធរួមមាន វិស័យឯកជន សហជីពពលករ និង ដៃគូអភិវឌ្ឍន៍សហប្រតិបត្តិការផ្លូវការដើម្បីជំរុញលើកកម្ពស់វប្បធម៌ផលិតភាពជាតិ និង ភាពប្រកួតប្រជែង សម្រាប់ការអភិវឌ្ឍន៍ជាតិ ព្រមទាំងបង្កើនភាពប្រកួតប្រជែងនៃផលិតផល និង ពលករកម្ពុជានៅក្នុងទីផ្សារតំបន់ និង ពិភពលោកដែលនាំឱ្យមានកំណើនប្រាក់ចំណូលពិតរបស់កម្មករនិយោជិតកម្ពុជា

- សិក្សា និង ផ្តល់នូវអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីគោលនយោបាយ និង ក្របខ័ណ្ឌសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិកលើគ្រប់វិស័យ ក្នុងគោលដៅធានាបាននូវជីវភាពសមរម្យជូនកម្មករ និង និយោជិតផង និង ដោយធានាអោយបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការលើកកម្ពស់ផលិតភាពពលកម្ម ភាពប្រកួតប្រជែង និង ភាពទាក់ទាញនៃសេដ្ឋកិច្ចកម្ពុជា សម្រាប់ការវិនិយោគ។

## ១០.៨.២- ការគ្រប់គ្រងចំណូលចំណាយសាធារណៈ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាក្រសួងមួយក្នុងចំណោមក្រសួងទាំង១០ដំបូងដែលត្រូវបាន សម្រេចឱ្យអនុវត្តថវិកាកម្មវិធីពេញលេញតាមរយៈប្រកាសលេខ០៦៨សហវប្រក. ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ និង សម្រេចបង្កើត និង ដាក់ឱ្យដំណើរការអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈប្រកាសលេខ១៣៣សហវ.ប្រក,ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥។ ក្នុងន័យនេះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានអនុវត្តគោលការណ៍ថវិកាកម្មវិធីក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាជាតិសម្រាប់ឆ្នាំ២០១៧-២០១៩ ដោយអនុលោមតាម

សារាចរណែនាំលេខ០១សរណន,ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ របស់រដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៧។ ស្ថិតក្នុងបរិការណ៍ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានធ្វើវិចារណកម្មស្ថាប័ន និង រៀបចំឡើងវិញនូវរចនាសម្ព័ន្ធដឹកនាំ និង គ្រប់គ្រងរបស់ក្រសួង ទន្ទឹមនឹង ការអនុវត្តសាកល្បងអង្គភាពថវិកាស្របតាមគោលការណ៍នៃថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពធៀបនឹងសូចនាករសមិទ្ធកម្ម និង វាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ២០១៥ ដែលត្រូវបានរៀបចំឡើងនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៦ កន្លងទៅនេះ ដើម្បីមូលដ្ឋានក្នុងការរៀបចំថវិកាឆ្នាំបន្តបន្ទាប់ខាងមុខ។

ទោះយ៉ាងណា ការអនុវត្តថវិកាកម្មវិធីនាឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានសម្រេចសមិទ្ធផលជាសារវន្ត ដូចខាងក្រោម៖

### ក.ការអនុវត្តចំណូល

ចំណូលដែលត្រូវបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ សម្រាប់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានចំនួនសរុប ១៣,៦០៨,៤៧៦លានរៀល ត្រូវបានបែងចែកជាពីរ គឺចំណូលនៅថ្នាក់កណ្តាលចំនួន ១៣,៦០៨,៣២៥លានរៀល និង ថ្នាក់មូលដ្ឋាន(មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានីខេត្ត)ចំនួន ១៥១លានរៀល។

ការអនុវត្តចំណូលសម្រេចបានជារួមចំនួន ១០,៧១០,៧៥៨.៣លានរៀល(*)ស្មើនឹង ៧៨.៧% នៃការកំណត់ក្នុងច្បាប់ ក្នុងនោះថ្នាក់កណ្តាលប្រមូលបាន ១០,៧១០,៤៣៥.២លានរៀល(*) ស្មើនឹង ៧៨.៧% និង ថ្នាក់មូលដ្ឋានប្រមូលបាន ៣២៣.១លានរៀល ស្មើនឹង ២១៤% នៃការកំណត់ក្នុងច្បាប់។

ការប្រមូលចំណូលនៅថ្នាក់កណ្តាលត្រូវបានបែងចែកជាបីគឺ៖

១- ចំណូលពីអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា,

២- ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ,និង

៣- ចំណូលក្នុងទីស្តីការក្រសួង

ដែលរួមមាន៖ ចំណូលពីអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ចំណូលមូលធនប្រតិបត្តិការឆ្លងកាត់រតនាគារជាតិ និង ប្រតិបត្តិការក្រៅរតនាគារជាតិ។ ការអនុវត្តចំណូលពន្ធគយ ចំណូលពន្ធដារ និង ចំណូលពីឧស្សាហកម្មហិរញ្ញវត្ថុ បានសម្រេចល្អប្រសើរលើសពីការកំណត់ក្នុងច្បាប់។ ប៉ុន្តែដោយហេតុថាពុំមានការរាយការណ៍ពីការប្រាក់នៃការឱ្យខ្ចី និង ពីចំណូលមូលធន នាំឱ្យតួលេខការអនុវត្តចំណូលនៅថ្នាក់កណ្តាលពុំសម្រេចបានតាមគោលដៅកំណត់ក្នុងច្បាប់ឡើយ។




**ក្រាភិចទី១០.៤៖ ទិន្នន័យចំណូលតាមប្រភពសំខាន់ៗ**

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២០១៦

ការអនុវត្តចំណូលលម្អិតតាមប្រភពនីមួយៗមានដូចតទៅ៖

**ក.ចំណូលថ្នាក់កណ្តាល**

- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា

ចំណូលកំណត់ក្នុងច្បាប់មានចំនួន ៥,២៨១,១០០លានរៀល អនុវត្តចំណូលសម្រេចបានមានចំនួន ៦,១១១,៩៦៧.៦លានរៀល ស្មើនឹង ១១៥.៧% នៃការកំណត់ក្នុងច្បាប់។

- អគ្គនាយកដ្ឋានពន្ធដារ

ចំណូលកំណត់ក្នុងច្បាប់មានចំនួន ៤,០២៧,២០០លានរៀល អនុវត្តចំណូលសម្រេចបានមាន ចំនួន ៤,៤៤៥,៥២៧.១លានរៀល( * ) ស្មើនឹង ១១០.៤% នៃការកំណត់ក្នុងច្បាប់។

- ទីស្តីការក្រសួង

ចំណូលកំណត់ក្នុងច្បាប់មានចំនួន ៤,៣០០,០២៥លានរៀល អនុវត្តចំណូលសម្រេចបានមាន ចំនួន ១៥២,៩៤០.៥លានរៀល ស្មើនឹង ៣.៦% នៃការកំណត់ក្នុងច្បាប់។

- អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

ចំណូលកំណត់ក្នុងច្បាប់មានចំនួន ១០២,១០១លានរៀល ហើយអនុវត្តចំណូលដែលសម្រេចបានមានចំនួន ១៥២,៩៤០.៥លានរៀល( * ) ស្មើនឹង ១៤៩.៨% នៃការកំណត់ក្នុងច្បាប់។

- ការប្រាក់នៃការឱ្យខ្ចី

ចំណូលកំណត់ក្នុងច្បាប់មានចំនួន ៧៧,៣៣៨លានរៀល, ពុំមានរបាយការណ៍ស្តីពីការអនុវត្ត ចំណូលឡើយ។

- ចំណូលមូលធន

ចំណូលកំណត់ក្នុងច្បាប់មានចំនួន ៤,១២០,៥៨៦លានរៀល ពុំមានរបាយការណ៍ស្តីការអនុវត្ត ចំណូលឡើយ។

**ខ.ចំណូលពីមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី ខេត្ត**

ចំណូលបានកំណត់ក្នុងច្បាប់មានចំនួន ១៥១លានរៀ ហើយអនុវត្តចំណូលដែលសម្រេចបានចំនួន ៣២៣.១លានរៀលស្មើនឹង ២១៤% នៃការកំណត់ក្នុងច្បាប់។

**<u>កំណត់សម្គាល់៖</u>**

តួលេខដែលបានសម្គាល់ដោយបញ្ញា( * )ជាតួលេខបឋម ដែលអាចនឹងប្រែប្រួលអាស្រ័យនឹងការ ផ្ទៀងផ្ទាត់រវាងអគ្គនាយកដ្ឋានសាមី និង អគ្គនាយកដ្ឋានរតនាគារជាតិ។

**ខ.ការអនុវត្តចំណាយ**

ការអនុវត្តចំណាយថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំនួន ៣៩៨,៩៨៣.៣ លានរៀល ស្មើនឹង ៩៦,៧% នៃឥណទានក្នុងច្បាប់ ក្នុងនោះគោលបំណងគោលនយោបាយទី១ អនុវត្តបានចំនួន ៣,៧៥៨.៩លានរៀល ស្មើនឹង ១០១% នៃឥណទានក្នុងច្បាប់ និង គោលបំណងគោលនយោបាយទី២ អនុវត្តបានចំនួន ៣៩៥,២២៤.៤លានរៀល ស្មើនឹង ៩៦.៧% នៃឥណទានក្នុងច្បាប់។

វឌ្ឍនភាពសមិទ្ធកម្ម ដែលសម្រេចបានធៀបនឹងសូចនាករ ដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០១៥ ជារួមមានប្រមាណ ៨៧% ក្នុងនោះគោលបំណងគោលនយោបាយទី១ សម្រេចបាន ៨៥% និង គោលបំណងគោលនយោបាយទី២ សម្រេចបាន ៨៨%។

**ក្រាភិចទី១០.៥៖ ទិន្នន័យអនុវត្តចំណាយតាមកម្មវិធី**




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២០១៦

# មេរៀនទី ១១
# សេដ្ឋកិច្ចទីផ្សារសេរីនៅកម្ពុជា

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាក្នុងក្របខណ្ឌសមារណរកម្មសេដ្ឋកិច្ចអាស៊ាននិងពិភពលោក
- សេដ្ឋកិច្ចទីផ្សារសេរី និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា
- សេដ្ឋកិច្ចឧស្សាហកម្មក្នុងស្រុក និងក្នុងតំបន់

សេដ្ឋកិច្ចប្រទេសកម្ពុជាជាសេដ្ឋកិច្ចមួយពឹងផ្អែកទៅលើវិស័យកសិកម្ម រហូតមកដល់ ឆ្នាំ ១៩៨០ ។ ចាប់ពីឆ្នាំ១៩៩០ រហូតដល់ឆ្នាំ១៩៩៥ ដោយសារតែមានស្ថេរភាពនយោបាយ ការអភិវឌ្ឍប្រទេសកម្ពុជាបានឈានឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ សេរី ដែលមានការធ្វើពាណិជ្ជកម្មអន្តរជាតិ ជាមួយប្រទេសជិតខាង នៅទ្វីបអាស៊ី ក៏ដូចជា សហរដ្ឋអាមេរិច និងទ្វីបអឺរ៉ុប ផងដែរ ។ នៅក្នុងកំឡុងពេលប្រហែល ១០ ឆ្នាំ ក្រោយមកប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរជាទីកត់សំគាល់ ។

## ១១.១.សេដ្ឋកិច្ចទីផ្សារសេរី និង កំណើនសេដ្ឋកិច្ចកម្ពុជា

តំណាក់កាលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដែលឈានឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរី អាចបែងចែកដូចខាង ក្រោម

១.ការចាប់ផ្តើមឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរី (បន្ទាប់ពីឆ្នាំ ១៩៩៣)

២.ដំណាក់ការសេដ្ឋកិច្ចដែលពឹងផ្អែកទៅលើ លំហូរជំនួយបរទេស (ចាប់ពីឆ្នាំ ១៩៩៤)

ដំណាក់ការសេដ្ឋកិច្ចដែលមានការផ្គត់ផ្គង់កំលាំងការងារខ្ពស់ ដែលមានលំហូរចូលនូវការវិនិយោគបរទេស (ចាប់ពីឆ្នាំ ១៩៩៥)

៣.ដំណាក់ការនៃការទទួលឥទ្ធិពលពីវិបត្ត រូបបិយវត្ថុអាស៊ី (ចាប់ពីឆ្នាំ ១៩៩៧-១៩៩៨)

៤.ដំណាក់ការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងសមាជិកសេដ្ឋកិច្ចអាស៊ាន (ចាប់ពីឆ្នាំ ១៩៩៩)

កំណើនសេដ្ឋកិច្ចកម្ពុជាក្រោយពេលឈានឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរីមានការចាប់ផ្តើមកើនឡើងខ្ពស់គួយ៉ាង ដូចជាកំណើន ផលិតផលក្នុងស្រុក អឌក ៦។៣% ក្នុងឆ្នាំ ១៩៩៤ និង ៨។៤% នៅឆ្នាំ ១៩៩៥។ ប៉ុន្តែដោយមាននូវការទទួល ឥទ្ធិពលពិវិបត្ត រូបបិយវត្ថុអាស៊ី ក្នុងឆ្នាំ ១៩៩៧ និង ឆ្នាំ ១៩៩៨ ធ្វើអោយកំណើនសេដ្ឋកិច្ចកម្ពុជាមានការថយចុះរហូតដល់ ១៥%

ក្នុងឆ្នាំ ១៩៩៨ ។ ចាប់ពីឆ្នាំ ១៩៩៩ មក សេដ្ឋកិច្ចកម្ពុជាក៏ចាប់ផ្តើមកើនឡើងវិញដោយកំណើន Real GDP ក្នុងឆ្នាំ ១៩៩៩ មានចំនួន ៦។៩% និង ៥។៤% ក្នុងឆ្នាំ ២០០០ ព្រមទាំង ៥។៣% ក្នុងឆ្នាំ ២០០១ ។ តំលៃ GDP per capita (ចំណូលរបស់ ប្រជាជនមួយនាក់ៗ)មានតំលៃចំនួនប្រហែល៣០០$ជាមធ្យមដោយសារមានការចូលរួមជាសមាជិកសេដ្ឋកិច្ច ASEAN។ បន្ទាប់មកកំឡុងឆ្នាំនោះដែរ តំលៃអតិផរមា មានការថយចុះ ព្រមទាំងមានលំនឹងអត្រាប្តូរប្រាក់ ។

## ១១.២.សេដ្ឋកិច្ចឧស្សាហកម្មក្នុងស្រុក និង សេដ្ឋកិច្ចក្នុងតំបន់

នាពេលបច្ចុប្បន្នសេដ្ឋកិច្ចនៃប្រទេសកម្ពុជាគឺ ផ្តោតខ្លាំងទៅលើ អភិវឌ្ឍន៍សេដ្ឋកិច្ចនៅតំបន់ទីក្រុង ។ ទីក្រុង ភ្នំពេញគឺជាទីប្រជុំជនដែលពោរពេញទៅដោយភាពជឿនលឿននូវសកម្មភាពសេដ្ឋកិច្ចជាច្រើនដូចជា ការធ្វើពាណិជ្ជកម្ម ក្នុងស្រុក ការធ្វើពាណិជ្ជកម្មអន្តជាតិ ការរីកចំរើននៃវិស័យប្រព័ន្ធធនាគារ ឬប្រព័ន្ធហិរញ្ញវត្ថុ ។

បន្ថែមពីនោះទៀតទីក្រុងភ្នំពេញគឺជាទីស្នាក់ការរបស់រាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជាដែលជាអ្នករៀបរៀង ច្បាប់ បញ្ញត្តិ , រដ្ឋបាលសាធារណៈ ព្រមទាំងមានតុលាការកំពូល ជាដើម ។ សេដ្ឋកិច្ចទីក្រុងបែងចែកជា ៤ ផ្នែកធំៗ គឺ

១ វិស័យកាត់ដេរ ការផលិត និង ការនាំចេញក្រណាត់ សំលៀកបំពាក់

២ សហគ្រាសធុនតូច និង មធ្យម SMEs

៣ គំរោង ឬកម្មវិធីជំនួយផ្សេងៗពីសំណាក់ស្ថាប័នជំនួយបរទេស

៤ ការរីកដុះដាលនូវវិស័យ informal sector សចេតៀរ ដូចជា អ្នកបើកបរ Taxi, motorbike ជាដើមដែលមានលក្ខណៈ ការងារមិនពេញម៉ោងជាផ្លូវការ និង ការធ្វើពាណិជ្ជកម្មលក្ខណៈគ្រួសារជាដើម ។

លើសពីនេះទៅទៀតប្រទេសកម្ពុជាមានលក្ខ័ណ្ឌភូមិសាស្រ្តល្អប្រសើរ ដែលជួយជំរុញនិង បង្កើនអោយមានភាព ងាយស្រួលក្នុងការដឹក ទំនិញក្នុង និងក្រៅប្រទេសតាមរយៈការរីកចំរើននៃប្រព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ថ្នល់ ស្ពាន អាកាសចរ ផ្លូវទឹក ផ្លូវសមុទ្រ និង កំពង់ផែជាដើម ។

ការធ្វើសេដ្ឋកិច្ច សមាហរន្តកម្មក្នុងតំបន់ មានតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើសហប្រតិបត្តការ សេដ្ឋកិច្ច ក្រៅប្រទេស និង ក្នុងតំបន់ ។ ការផ្តួចផ្តើមគំនិត , គំរោង ឬកិច្ចព្រមព្រៀងដូចជា ASEAN Industrial Cooperation (AICO) និង ASEAN Investment Area (AIA) គឺមានសារៈប្រយោជន៍សំខាន់ក្នុងការ ធ្វើសមាហរន្តកម្មក្នុងតំបន់នេះ ។

គោលបំណងសំខាន់ក្នុងការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចក្នុងតំបន់គឺដើម្បីបង្កើនកំរិត នៃការរស់នៅរបស់ប្រជាជន (Cambodia's people living standards) ពោលគឺ

1 កំណើនចំណូលដោយមានភាពស្មើគ្នាជាពិសេសកំណើនចំណូលរបស់ប្រជាជនក្រីក្រ

2 ភាពប្រសើរឡើង នូវសុខមាលភាព និង ជីវជាតិក្នុងការរស់នៅរបស់ប្រជាជន

3 បង្កើននូវភាពប្រសើរឡើងនៃវិស័យអប់រំ ព្រមទាំង

4 ពង្រឹងភាពយកចិត្តទុកដាក់ទៅលើបរិដ្ឋាន ។

## ១១.៣.ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានៅក្នុងអាស៊ាន

ប្រទេសកម្ពុជាបានឈានចូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលឈរទៅលើការកំណត់តាមរយៈទីផ្សារសេរីក្នុងកំឡុង ពេលពាក់កណ្តាលនៃការធ្វើ globalization របស់សេដ្ឋកិច្ចពិភពលោក ។ ប្រទេសកម្ពុជាក៏បានធ្វើសេរីកម្មទៅលើ ពាណិជ្ជកម្មអន្តរជាតិក៏ដូចជាការធ្វើវិនិយោគបរទេសក្នុងឆ្នាំ១៩៩៣និង១៩៩៤។ ទោះបីជាការចូលជាសមាជិកអាស៊ានត្រូវ បានផ្អាកមួយរយៈពេលក្នុងឆ្នាំ ១៩៩៧ ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែព្យាយាមដើម្បីចូលរួមជាសមាជិកអាស៊ានពេញសិទ្ធ ក្នុងឆ្នាំ១៩៩៩ ។

ទោះបីជាការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចក្នុងតំបន់ នឹងនាំមកនូវឳកាសក្នុងការអភិវឌ្ឍប្រទេសកម្ពុជាក្នុងពេល អនាគតក៏ដោយ ប្រទេសកម្ពុជាក៏មានការប្រឈមមុខមួយចំនួនដែរចំពោះអ្នកបង្កើត និង គ្រប់គ្រងគោលនយោបាយ សេដ្ឋកិច្ច ពីព្រោះប្រទេសកម្ពុជាទាមទារអោយមានការពង្រឹងសមត្ថភាព និង បទពិសោធន៍មួយចំនួយធំ ក្នុងការគ្រប់គ្រង សមាហរន្តកម្មសេដ្ឋកិច្ច ទីផ្សារនេះ ។

ការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចក្នុងតំបន់ និង ពិភពលោកមានលក្ខណៈនឹងប្រយោជន៍ដូចខាងក្រោម

១ ការកាត់បន្ថយ របាំង ឬឧបសគ្គក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ

២ ការបង្កើនតួនាទី របស់ច្បាប់បញ្ញត្ត ឬវិន័យក្នុងតំបន់ និង អន្តរជាតិដូច ASEAN និង WTO ជាដើម

៣ ការធ្វើ globalization ក្នុងការបង្កើនផលិតផល ដែលមានឥទ្ធិពលទៅលើ ប្រសិទ្ធភាពនៃការធ្វើពាណិជ្ជកម្ម និង វិនិយោគ។

គោលបំណងមួយរបស់ប្រទេសកម្ពុជាក្នុងការធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួននៅក្នុងអាស៊ាន គឺដើម្បីបង្កើននូវ ឳកាសការងារថ្មី ដែលជាយាន្តក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទន្ទឹមនឹងនេះដើម្បីធានាថាការធ្វើសមាហរន្តកម្មសេដ្ឋកិច្ច ក្នុងអាស៊ាននេះនាំអោយមានភាពជោគជ័យដែលនាំមអោយមាន កំណើនសេដ្ឋកិច្ចជាតិនោះប្រទេសកម្ពុជាគួរផ្តោតការ យកចិត្តទុកដាក់ទៅលើ

- ការពង្រឹងស្ថេរភាពនយោបាយក្នុងប្រទេស
- ការពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច
- ការពង្រឹងរចនាសម្ព័ន្ធច្បាប់ ឬបញ្ញ័តដើម្បីអោយមានតំលាភាព ក្នុងការធ្វើជំនួញឬពាណិជ្ជកម្មផ្សេងៗ

យុទ្ធសាស្រ្តដើម្បីទទួលបានសមិទ្ធិផលខ្ពស់ពីការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចក្នុងអាស៊ានគឺ

1 ការអភិវឌ្ឍ និរន្តភាពនៃវិស័យកសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ

2 ការអភិវឌ្ឍវិស័យឧស្សាហកម្ម និង សេវកម្ម ព្រមទាំង

3 ការបង្កើនអោយមានភាពស្មើគ្នាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ទោះបីជាប្រទេសកម្ពុជាបានចូលជាសមាជិកពេញសិទ្ធរបស់អាស៊ានហើយ ថែមទាំងបានទទួលផលប្រយោជន៍ យ៉ាងច្រើនក្នុងការធ្វើសមាហរន្តកម្មសេដ្ឋកិច្ចនេះក៏ដោយ ក៏ប្រទេសកម្ពុជាមានបញ្ហាប្រឈមមួយចំនួនក្នុងការអភិវឌ្ឍ សេដ្ឋកិច្ចឧស្សាហកម្ម ដូចខាងក្រោម

1 ការអភិវឌ្ឍ ឧស្សាហកម្មដែលទាក់ទិន្នទៅនឹងផលិតកសិកម្ម

2 កង្វះខាតនូវកម្មករជំនាញ

3 ការត្រូវការជំនួយទៅលើសហគ្រាសធុនមធ្យម និង តូច (SMEs)

4 ការគ្រប់គ្រងលើបញ្ហាបរិស្ថានដែលត្រូវបំពល់ដោយកាកសំណល់ ឧស្សាហកម្ម

# មេរៀនទី ១២
# កំណើនសេដ្ឋកិច្ចនៅកម្ពុជា

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ
- ប្រភពនៃកំណើនសេដ្ឋកិច្ច
- បញ្ហានៃកំណើនសេដ្ឋកិច្ច
- ការកាត់បន្ថយនៃបញ្ហារបស់កំណើនសេដ្ឋកិច្ចនៅកម្ពុជា

ប្រទេសកម្ពុជាមានការងើបឡើងវិញនូវ កំណើនសេដ្ឋកិច្ចបន្ទាប់ពីមានវិបត្តសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០០៩។ ប្រទេសកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ទៅលើ ទំរង់នៃការនាំចេញ ការវិនិយោគបរទេស និង ជំនួយបរទេស ព្រមទាំងតំរូវការក្នុងស្រុក ។ សមិទ្ធិផលទាំងអស់នេះបានធ្វើ អោយផលិតផលក្នុងស្រុក ( Real GDP ) មានការថយចុះ ចំនួន តែ 0.១% ប៉ុណ្ណោះ បន្ទាប់ពីមានកំណើនយ៉ាងខ្លាំងប្រហែល ៩.៧% ក្នុងចន្លោះ ឆ្នាំ ១៩៩៩ ដល់ ២០០៨ ។ វិស័យកាត់ដេរមាន ការកើនឡើងយ៉ាងខ្លាំង ដែលការនាំចេញទៅក្រៅប្រទេសមានការកើនឡើង ពីចំនួន ២៧ លានដុល្លារ ក្នុងឆ្នាំ ១៩៩៥ រហូត ដល់ ៣០ លានដុល្លារក្នុងឆ្នាំ ២០១០ ។ វិស័យទេសចរណ៍មានការរីកលូតលាស់យ៉ាងរហ័សផងដែរ ដែលវិកិយប័ត្រទេសចរណ៍មានការកើនឡើងចំនួន ១០ ដង ធៀបទៅនឹងមួយទសវត្សមុន ដែលមានរហូតទៅដល់ ១.៨ billions $ (WB) ក្នុងឆ្នាំ២០១០ ការអភិវឌ្ឍនៃវិស័យកសិកម្ម ផលិតផលស្រូវមានការកើនឡើងចំនួន ១៣% ប្រចាំឆ្នាំ ចាប់តាំងពីឆ្នាំ២០១០ មក ។ ៧០% នៃកំលាំងពលកម្មទាំងអស់ត្រូវបានប្រើប្រាស់នៅក្នុងវិស័យកសិកម្មនេះ ដែលជា មូលហេតុមួយដែលអាចកាត់បន្ថយភាពក្រីក្រ នៅប្រទេសកម្ពុជា ។

## ១២.១.ប្រភពនៃកំណើនសេដ្ឋកិច្ចកម្ពុជា

ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលមួយទសវត្សមុនក៏ប៉ុន្តែលក្ខណៈនៃកំណើនសេដ្ឋកិច្ចនេះនៅមានលក្ខណៈតូចចង្អៀតនៅឡើយដោយសារតែមានបញ្ហា រាំងស្ទះឬឧបសគ្គមួយចំនួន។សេដ្ឋកិច្ចប្រទេសកម្ពុជាអាចនិយាយបានថាឈរនៅលើទំនាញនៃការនាំចេញ (export-driven) ដែលក្នុងនោះមានការនាំចេញនូវវិស័យ កាត់ដេរ ព្រមទាំង លំហូរនៃភ្ញៀវទេសចរណ៍មកក្នុងប្រទេសយើង ។ ទីតាំងនៃប្រទេសកម្ពុជាក៏មានលក្ខណៈល្អដែលស្ថិតនៅក្នុងតំបន់អាស៊ី អាគ្នេយ៍ ក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ ក្នុងសេដ្ឋកិច្ចលំហ ។ ក្រៅពីនេះ សេដ្ឋកិច្ចជនបទ និង ផលិតកសិកម្ម ក៏ដើរតួ យ៉ាងសំខាន់ក្នុងការបង្កើនកំណើនសេដ្ឋកិច្ចប្រទេសយើង ។ បន្ថែមពីនេះទៅទៀត ប្រទេសយើង ក៏មានសក្តានុពលក្នុង ការរុករករ៉ែផ្សេងៗ ដែលជា

ប្រភពថ្មី ដូចជា រ៉ែ ប្រេងកាត និង ឧស្ម័ន ក្នុងការបង្កបង្កើនផល និងជាវត្ថុធាតុដើមមាន តំលៃបំផុត ក្នុងការឈានទៅរកការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

នាពេលបច្ចុប្បន្នកាលនេះ ប្រភពនៃកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាអាចបែងចែកចេញជា ៤ប្រភេទសំខាន់ៗ ដូចខាងក្រោម

១ វិស័យកាត់ដេរ (២៨%): មួយផ្នែកធំនៃវិស័យកាត់ដេរត្រូវបាននាំចេញទៅសហរដ្ឋអាមេរិច ក៏ប៉ុន្តែការនាំចេញ របស់ប្រទេសយើងក៏មានការប្រឈរមុខនិងការប្រជែងជាមួយការនាំចេញរបស់ប្រទេសជិតខាង ដូចជាប្រទេសវៀតណាម ជាដើម ។

២ វិស័យទេសចរណ៍ (២៦%): លំហូរនៃភ្ញៀវទេសចរណ៍មានការកើនឡើង ជាពិសេសទេសចរណ៍ ប្រាសាទ អង្គរវត្ត ជាដើម ។

៣ អចលនទ្រព្យ និង សំណង់ (២០%): កំណើនលើវិស័យសាងសង់ សណ្ឋាគារ និង វិស័យមធ្យោបាយធ្វើដំណើរ (Hotel/ Transports) ។

៤ តំណាំ វិស័យកសិកម្ម (១៣%): ការបង្កើននូវផលិតផលស្រូវ។

## ១២.២.បញ្ហានៃកំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា

បញ្ហាដែលចោទឡើងនៃកំណើនសេដ្ឋកិច្ចកម្ពុជាមានជាច្រើនដែលអាចសង្ខេបដូចខាងក្រោម

១- Large informal economy ដូចជាតំលៃនៃការនាំចូល (entry cost) ចំណូលជាផ្លូវការមានការកំណត់ តំរូវការ ហិរញ្ញទានសំរាប់ធ្វើជំនួញមានការកំណត់ ។

២- No sustained diversification:

- ការចែកចាយ , ការផ្តល់ពត៌មាន មិនមានលក្ខណៈល្អប្រសើរ
- ការលើកទឹកចិត្ត មិនមានលក្ខណៈសមស្រប
- ការលំបាកក្នុងការស្វែងរក Fund សំរាប់សហគ្រាស ធុនតូច និង មធ្យម (SMEs)៣- No Capital intensive or processing industry: ការពង្រីកអភិបាលកិច្ចគ្រប់គ្រង និង ភាពទន់ខ្សោយ លើធាតុចូលបន្ថែម ដូចជាការផ្គត់ផ្គង់អគ្គិសនី ការផ្គត់ផ្គង់ទឹក កង្វះខាតកម្មករជំនាញ ។

យើងអាចសង្ខេបបញ្ហាដែលចោទមានឡើងក្នុងការធ្វើកំណើនសេដ្ឋកិច្ចកម្ពុជាដូចរូបភាពខាងក្រោម




ក្រាភិច១២.១ បញ្ហាដែលចោទមានឡើងក្នុងការធ្វើកំណើនសេដ្ឋកិច្ចកម្ពុជា

## ១២.៣.ការកាត់បន្ថយនៃបញ្ហារបស់កំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា

ដើម្បីកាត់បន្ថយនៃបញ្ហារបស់កំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា , ចំណុចសំខាន់ដែលប្រទេសកម្ពុជាកំពុងតែ យកចិត្តទុកដាក់នោះ មានដូចខាងក្រោម

១ ការគ្រប់គ្រងរចនាសម្ព័ន្ធ ម៉ាក្រូសេដ្ឋកិច្ច (Macro Management): ដើម្បីអោយមានស្ថេរភាពសេដ្ឋកិច្ច ដូចជា ស្ថេរភាពតំលៃទំនិញ និង សេវាកម្ម , ស្ថេរភាពអត្រាប្តូរប្រាក់ជាដើម ។

២ ការបង្កើតលំហសារពើពន្ធ (Creating fiscal space): ការបង្កើននូវការប្រមូលពន្ធ ឬ កំណែទំរង់ប្រពន្ធ័ សារពើពន្ធដើម្បីបង្កើននូវការផ្តល់សេវាកម្ម សាធារណ:ដូចជា ហេដ្ឋារចនាសម្ព័ន្ធ វិស័យអប់រំ និង សេវកម្មសាធារណ: ផ្សេងៗ ។ ការបង្កើនចំណូលតាមរយ:ធនធាន ធម្មជាតិ ដូចជា ធនធានរ៉ែ ប្រេងកាត និង ឧស្ម័ន ជាដើម ។

៣ ការពង្រឹងលើគោលនយោបាយឧស្សាហកម្ម (Industrial policy): ដូចជាបន្ថយពន្ធលើការវិនិយោគ ឧស្សាហកម្ម , ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស , លើកទឹកចិត្តក្នុងការបង្កបង្កើនផល លើទំនិញដែលកំពុងផលិត ឬ ដែល មានស្រាប់ជាដើម ។

## ១២.៤.តុល្យភាព និង ទស្សនៈវិស័យ

យើងទើបនិងបានពិចារណាតាមបែបនយោបាយនិងសេដ្ឋកិច្ច ដែលមូលហេតុទាំងនោះធ្វើឱ្យកម្ពុជា កំរើកសកម្មភាពតាមរយៈសង្គមកម្ពុជាមួយ ឈរលើមូលដ្ឋានរបស់ខ្លួនផ្ទាល់ ។

យើងចាប់យកការវិភាគនិងមើលថាតើការរស់រាននៃប្រព័ន្ធកម្ពុជា ឈរលើការប្រព្រឹត្តទៅបីផ្នែកៈ

១.តុល្យការសង្គម

២.ផ្នែកនយោបាយ

៣.ការពិនិត្យនិងទស្សនៈវិស័យសេដ្ឋកិច្ច

### ១២.៤.១.តុល្យភាពសង្គម ការផ្តើមពីគ្នា

#### ក.សង្គមមួយដែលមានការអភិវឌ្ឍតាមល្បឿនថ្មី

នៅក្រោយការដាក់ឱ្យដំណើការសេដ្ឋកិច្ចជាទូទៅ មានឡូស៊ីបីដំណាក់កាល រីកចម្រើនៈ

១- ឡូស៊ីកជនបទសុទ្ធ អ្នកធ្វើស្រែចំការសប្បុករប្រពៃណី ។ល។ នៅមានការខ្វះខាតច្រើន តែអាចមានការផ្តួចផ្តើមនៅទិសដៅខ្លួនផ្ទាល់នៃថាមពលសេដ្ឋកិច្ចចំពោះជនកម្ពុជាម្នាក់ដោតជ័យផ្នែកសម្ភារ ជាមូល ដ្ឋាននៃការកែច្នៃ ពង្រីកការអភិវឌ្ឍប្រភពទ្រព្យសម្បត្តិ ។ តែបើក្រជារឿងរង្វង់កម្មព្រេងវាសនា ។

២- ឡូស៊ីកនៃក្រុមសង្គមអន្តរកាល គឺជាឡូស៊ីកនៃកំណើនធម្មតា ។ ក្រុមនេះមានផលប្រយោជន៍ មួយភាគនៃថាមពលពិភពជនបទ កសិករនៅជិតទីក្រុង ដែលស្ថិតនៅជាប់ផ្លូវទូរគមនាគមន៍ និង ពួកសហគ្រិនតូចៗ នៃពិភពទីក្រុង រោងជាងគ្រប់ផ្នែក ដែលធ្លាប់ធ្វើអាជីវកម្ម សភាពសេដ្ឋកិច្ចមុនសម័យសង្គ្រាម ។ ក្រុមនេះបានស្តាបនាឡើងវិញ នៅសសរសេដ្ឋកិច្ចជាមូលដ្ឋានស្តារឡើងវិញនៅកសិកម្មដែល ផ្តល់វត្ថុជាតុដើមដល់ ឧស្សាហកម្មតូចៗរបស់ពួកគេ។ល។ ការចាប់ផ្តើមឡើងវិញនេះ ជាស្នារដៃប្រឌិត ផលិតលើស បម្រើដល់ម៉ាស៊ីនសេដ្ឋកិច្ច ។

៣- កំពុងប្រាជ័រ ជាមនុស្សពាណិជ្ជករ ដែលមានឡូស៊ីកបន្ទាន់ ធ្វើសេដ្ឋកិច្ចឱ្យផ្ទុះ បុមឡើង ។ ពួកនេះ ឆ្លៀតឱកាសក្នុងកិច្ចដំណើរការសន្តិភាព និង ពេលសន្តិភាពជាម្ចាស់អចលនវត្ថុជាអ្នកធ្វើកិច្ចសន្យាសេវាកម្មជាទូទៅ ហើយគឺជាអ្នកមានការទាក់ទងជាមួយបរទេសឬបង្កើតក្រុមហ៊ុននាំចេញនាំចូល ក្រុមហ៊ុនអាកាសចរណ៍ ធនាគារ អ្នកផ្គត់ផ្គង់ជាដើម ។

បើឡូស៊ីកពីខាងដើមមានស្ថានភាពមនុស្សធម៌ វិជ្ជមានដែលបានរួមចំណែកក្នុងការស្តាររបៀបរបបសង្គមអ្នកក្នុងចំពួកទីមួយ ស្ថិននៅក្រៅអភិវឌ្ឍន៍សេដ្ឋកិច្ច ក្រុមទីពីជាសមាសភាពរួមវិភាគទានដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយក្រុមទីបីជាក្រុមសេដ្ឋកិច្ចដ៏ភ្លឺស្វាង គឺរឹតតែវិជ្ជមានថែមទៀត ពួកគេមិនត្រឹមតែជាក្រុមមានបុព្វសិទ្ធិនោះទេ គេឈរនៅលើការរកស៊ីបង្វិលរកចំណេញនៃផ្ទៃក្រមូលទុនបានរហ័សបំផុត នៅក្នុងសេដ្ឋកិច្ចជាសុំណុំមួយ នៃការផលិតបង្កើនតម្លៃបន្ថែមដល់ទុនដុលជាតិជាផ្លូវការ ។

នៅក្នុស្ថានភាពនៃការផ្ទុះ ប៉ុម នៃសន្តិភាពគឺជាការផ្តាចចេញនៃសង្គមដែលសមាសភាពទីពី និង ទីបីមានទំនាក់ទំនងគ្នា ជាសាមគីភាពយ៉ាងទូលាយ នៅកាលពេលមុនសង្គ្រាម ឥឡូវបានងើបឡើងធ្វើសេដ្ឋកិច្ចថ្មីទៀតហើយ ។

## ខ.ការបែកជាចំណែកៗនៃការអាកាសសង្គម

បញ្ហាស្ថិតនៅត្រង់ថាសង្វាកនៃការអភិឌ្ឍន៍ នៅមិនទាន់ស៊ីសង្វាក់គ្នាល្អ ប៉ុន្តែភាពនៃមិនស៊ីសង្វាក់គ្នា ជាឡូស៊ីកនៃបច្ចុប្បន្នកាលដែលធ្វើឱ្យអង្គសង្គមមានការផ្តាច់ចេញពីគ្នា ៖

១-ក្រុមដែលធ្លាប់ចុះ ១០ភាគរយនឧប្រជាជន ។ ទោះជារដ្ឋាភិបាលបានខិតខំធ្វើឱ្យប្រាកដនិយមហើយពួកអង្គការមិនមែនរដ្ឋាភិបាលដែលមិនសូវស្គាល់បែបបទជីវភាពប្រពៃណី ហើយសង្គមនេះបានទទួលនៅការប៉ះទង្គិចពីរដងនៃសង្គ្រាម និង សន្តិភាពមានមនុស្សដែលរងគ្រោះច្រើនណាស់ដូចជាស្ត្រីមេម៉ាយ និង ក្មេងកំព្រាកសិករខ្វះដីធ្លី ពួកទាហានរំសាយបង្កើតបានជាក្រុមយុវជនក្រៅសង្គម ហើយខ្វះសមត្ថភាព បុគ្គលប្តូរកន្លែងរស់នៅជនភៀសខ្លួនក្នុងប្រទេស និងមនុស្សរងទុក្ខដោយសារ វិបត្តិផ្លូវចិត្ត ។

២- អ្នកដែលនៅទ្រឹងមានចំនួនប្រហែល ៦០% នៃប្រជាជនគេរក្សាបាននៅ នាមក្រុមរបស់ខ្លួននិងបែបបទជីវភាព ជាក្រុមហ៊ុនក្នុងសង្គមដើមរបស់ពួកគេដែលតាមប្រភេទនៃស្ទាមសង្គមបាន ការបើកទូលាយជាមន្ត្រីមានបុព្វសិទ្ធិ ជាកសិករមានពួកអ្នកទីក្រុង ។ សំណុំមួយរបស់នៅស្ថានភាពប្រេះស្រួយនៃផ្នែកសម្ភារហើយមានមួយផ្នែកទៀតនៃសង្គម រស់នៅគ្មានសុវត្ថិភាពខាងរូបកាយ ។ នៅក្នុងក្រុមដ៏ធំនោះ មានក្រុមតូចមួយ ប្រហែល ១០% នៃប្រជាជន មានមធ្យោបាយពង្រីសេដ្ឋកិច្ច ។ មន្ត្រីតូចតាចដែលចេះភាសាបរទេសសប្បុរតូចៗដែលប្រើប្រាស់ការបិនប្រសប់ និងពួកកសិករ រស់នៅចំណុចប្រសព្វនៃផ្លូវទូរគមនាគមន៍ហើយអ្នកឯទៀតមានប្រហែលពាក់កណ្តាលនៃប្រជាជនខ្វះខាតសកត្តានុពល ។

៣- ចំពោះអ្នកដែលចេះតែរីកចម្រើន មានចំនួនប្រហែល ៣០% នៃប្រជាជន ។ នៅកំពូលជាស្នូលនៃអ្នកឆក់ឧកាសរកចំណេញនិងពួកបង្វិលរហ័សដែលប្រភពមានបានរបស់គេនោះក្នុងម្នាក់ប្រហែលរាប់សិបលានដុល្លារអាមេរិក។ នៅខាងក្នុងចំណោមពួកអ្នកក្រុង និងអ្នកជនបទទាំងនោះ មានដែលរកស៊ីមានបានពីការផ្ទុះនៃសេដ្ឋកិច្ចដោយប្រើប្រាស់មធ្យោបាយម៉ាស៊ីន។ សំណុំទាំងនោះមានប្រហែល ១៥០.០០០ គ្រួសារមានកម្មសិទ្ធរថយន្ត ២០.០០០ គ្រឿង និង ម៉ូតូ ៨០.០០០គ្រឿង នៅឆ្នាំ១៩៩២ ។ បច្ចុប្បន្នតួលេខមានកំណើននៅឆ្នាំ ១៩៩៥ រថយន្តតូចមានដល់ទៅ៥០.០០០ គ្រឿង និងម៉ូតូរាប់លានគ្រឿង ។

## គ.ការផ្តាច់នៃការគ្រប់គ្រងសេដ្ឋកិច្ចមួយដែលមានការផ្ទុះឡើង

បញ្ហាពិត នៃការគ្រប់គ្រងសេដ្ឋកិច្ចមួយដែលមានការផ្ទុះឡើងនៃសេដ្ឋកិច្ច ប៉ុម បង្កើតបានជាបំណែកអង្គសង្គម ។

ចាប់ពីចុងឆ្នាំ ១៩៩១ មករដ្ឋបន្ថយអន្តរាគមន៍របស់ខ្លួនលើប្រតិបត្តិការសេដ្ឋកិច្ច ក្នុងកម្រិតការផ្លាស់ ប្តូរពាណិជ្ជកម្ម ការផលិតផលចុងក្រោយ គឺធ្វើតែការអារពន្ធអាករ ។ ឡូស៊ីកសេដ្ឋកិច្ចឯកជន បានបែបជាផ្នែកៗ ជាសេដ្ឋកិច្ចចេញមកត្រួតពិត្យលើសំណុំទាំងអស់ ។ កំណើនសេដ្ឋកិច្ចដែលកត់សម្គាល់ឃើញបែរជាមានផលប៉ះពាល់ដល់ការ បំផ្លាញក្នុងកម្រិតសំណុំក្នុងក្របខ័ណ្ឌសង្គម ។

១- នៅពេលដែលកំណើនកើនខ្លាំង នោះពួកវិនិយោគបរទេសក៏គេងប្រវាញ់ ខ្លាំងដែរ ប្រោះខ្លះមាននិន្នាការបំផ្លាញសេដ្ឋកិច្ចខ្មែរផងដែរ ជាជាងការសាងឡើងវិញនៅប្រទេសដែលត្រូវខ្ទិចខ្ទាំដោយសង្គ្រាម ។

២- អង្គជាតុសេដ្ឋកិច្ចខ្មែរ បានត្រូវងើបឡើងមែនតែកាលណាសង្គមនៅទីក្រុងទទួលបានផលប្រយោជន៍តែងមានស្រទាប់មួយចំនួនទេ ដែលទទួលបានផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ចនោះមនុស្សក្នុងសង្គមភាគច្រើនជួបការលំបាកបាត់អាជិពការងារ ខ្វះកម្រៃចំណូលទន្ទឹមនោះ ការខ្វះអគ្គិសនី ខ្វះទឹកបរិសុទ្ធដែលត្រូវរងចាំរាបឆ្នាំទៀតទើបអាចបំពេញបាន ។

## ១២.៤.២.ការវិភាគនយោបាយ

តើនៅកម្ពុជាមានការស្ទុះឡើងនៅសេដ្ឋកិច្ច ប៉ុម ឬទេ? សកត្តានុពលសេដ្ឋកិច្ចអាចនាំឱ្យមានការជ្រើសរើសកិច្ចអភិវឌ្ឍន៍តាមបែបណា? ពួកម៉ាហ្វីយ៉ាចូលមកជ្រកកោះ ហើយទុកឱ្យមានការអភិវឌ្ឍដោយអនាធិបតេយ្យឬ?

### ក.ការប្រព្រឹត្តទៅនៃការអភិវឌ្ឍ

តាមរយៈអតិថិជននិងប្រព័ន្ធចិនកម្ពុជាមានយន្តការផ្លូវការបណ្តោះអាសន្ន និងមិនទាន់ច្បាស់លាស់ដែលត្រូវពឹងផ្អែក សម្រាប់ការអភិវឌ្ឍពិត។ ឡូស៊ីនៃការប្រព្រឹត្តិធ្វើយ៉ាងណាឱ្យកម្ពុជា ខ្លួនឯងធ្វើជាស្នូលនៃការអភិវឌ្ឍប្រព័ន្ធចិន អន្តរជាតិតែមួយ ដែលមានអំណាចសេដ្ឋកិច្ចជានាការភ្ជាប់គ្នានៃភាគីកម្ពុជាទាំងក្នុង និងក្រៅប្រទេស ឱ្យដំណើរក្នុងដំហរគ្រប់គ្រងតាមរយៈការកំណត់ខាងផ្លូវច្បាប់ ។ ប៉ុន្តែសង្គមកម្ពុជានៅត្រូវការស្ថេរភាពកុំឱ្យមានការគៀបសង្កត់ផលប្រយោជន៍ ពីអ្នកជិតខាងថែមទៀត ។

### ខ.ការបែកបាក់ កាលឱកាសសង្គមនយោបាយ

កត្តាចម្បងគឺការបង្រួបបង្រួមពិតប្រាកដ ធ្វើយ៉ាងណាឱកាសសង្គមនយោបាយជួប និងឡូស៊ីកនៃ ប៉ុម។ល។ ព្រោះ៖

- ទីមួយបែបបទនៃការបង្កើតប្រកពបានដាច់ ពីគ្នាដោយអយុត្តិធម៌ខ្លាំងពេក គឺផ្ទុយ និងបែបបទសង្គមកម្ពុជា ។

- ទីពីបញ្ហានេះគឺជាប់ទាក់ទងនឹងកត្តាខាងក្រៅជាឥទ្ធិពលគាបសង្កត់ ។

១ - បើគេស្ថិតនៅ ក្នុងឡូស៊ីកនៃការបន្តឱ្យសេដ្ឋកិច្ចផ្ទុះឡើង ប៉ុម ការបែងចែកកាលអាកាស សង្គមនយោបាយ ត្រូវតែរៀបចំបែបផ្សារភ្ជាប់ នយោបាយរៀងដំបន់ មានទិន្នន័យភ្នំពេញ និង ទីក្រុងនានា ភ្ជាប់ប្រព័ន្ធដែលជាដំបន់ មានផលចំណេញតិចតួច ជាពិភពជនបទឱ្យមានការរីកចម្រើនផងដែរ ។ កាលអាកាសសង្គមកម្ពុជា ពេលខ្លះទុកឱ្យនៅអំណាចមួយ ដែលប្រមូលផ្តុំទីប្រជុំផ្លូវគមនាគមន៍ និងប៉ូលីសសេដ្ឋកិច្ចសំខាន់ៗ សម្រាប់ធ្វើអាជីវកម្ម រកប្រាក់ចំណេញនៅឡើយ ។

២- បើមិនធ្វើឱ្យសេស្ឋកិច្ចជនបទរីកចម្រើនទាល់ទីក្រុង នោះគឺការទុកឱ្យជនបទធ្លាក់ខ្លួនទៅក្នុងការវិវដ្តកម្រិតសូន្យជាថ្មីទៀត ឬការជ្រើសរើសការអភិវឌ្ឍប្រទេសតាមរូបភាពថ្មី គឺមានការប្រុងប្រយត្ននូវការធ្វើការអភិវឌ្ឍកសិកម្មដែលបំផ្លាញបរិស្ថានព្រៃឈើ ឬធ្វើឧស្សាហូបនីយកម្ម ដោយបំពុលបរិយាកាស ឬរៀបចំឧទ្យានជាតិ ពីភពលោក ការពារសត្វព្រៃ បញ្ចូលទេសចរណ៍ រកចំណូលកសាងទឹកដី នោះជាការជ្រើសរើសមួយបោះបង់ចោលជនបទ ដោយត្រូវផ្សារភ្ជាប់ភ្នំពេញ ទៅនិងជនបទដាច់ស្រយ៉ាល ឥសាន ឧត្តរ ឱ្យកាន់តែជិតថែមទៀត ។

## ១២.៥.អនាគតនយោបាយ

នៅក្នុងក្របខ័ណ្ឌផែនការសន្តិភាព ដែលលទ្ធផលបោះឆ្នោតបង្រួបបង្រួមបានបីភាគីសំខាន់ ដែលជាទម្ងន់សង្គមសេដ្ឋកិច្ចនោះមិននិយាយដល់ពួកខ្មែរក្រហម ដែលគ្មានពេលណាវិលមករកប្រជាធិបតេយ្យតាម រយៈការបោះឆ្នោតនោះឡើយ ។ រដ្ឋាភិបាលស្របច្បាប់ កើតឡើងរៀចំប្រទេស ដែយទុកខ្មែរក្រហមទទួលវាសនាដូចពួកព្រៃ ម៉ាឡេ ថៃជាដើម ។

## ១២.៦.សក្តានុពលសេដ្ឋកិច្ច

នៅប្រទេសក្រីក្រជាច្រើន គេតែងជ្រើសរើសរវាងការអភិវឌ្ឍសូន្យ ឬអភិវឌ្ឍន៍អនាធិបតេយ្យ។ នៅប្រទេសកម្ពុជាមានសកត្តានុពលអភិវឌ្ឍន៍សេដ្ឋកិច្ចខ្លាំងក្លា។

### ១.ការផ្តុំយោបល់ លើនិន្នាការបច្ចុប្បន្ន ១៩៨០-១៩៩២ ដល់ឆ្នាំ ២០០០

ស្ថានភាពសព្វថ្ងៃនៃសម្មតិកម្ម បានផ្តល់នៅការបូកសារុបយោបល់នៃឡូស៊ីកអភិវឌ្ឍន៍ដែលដាក់ឱ្យដំណើរការ គឺការអភិវឌ្ឍក្រោយសង្គ្រាម ។

យោងទៅលើសារៈសំខាន់ដ៏ធំនៃផលទុនជាតិ ដែលលិចចេញឡើងពីឆ្នាំ ១៩៨០-១៩៩២ យើងអាចកសាងបាននៅការបូកសារុបពីរប្រទេស ៖

- ទីមួយឈរលើមូលដ្ឋាននៃ GNP លេចចេញឡើង ។
- ទីពីរឈរលើមូលដ្ឋាននៃ GNP លេចចេញកប់ ។

| | មូលដ្ឋាន GNP លេចចេញ | មូលដ្ឋាន GNPលេចកប់ |
|---|---|---|
| GNP | ៤ ពាន់លានដុល្លារ U.S. | ៦ ពាន់លានដុល្លារ U.S. |
| GNP ក្នុងម្នាក់ៗ | ៣៥០ ដុល្លារ U.S. | ៦៥០ ដុល្លារ U.S. |

យ៉ាងតិចណាស់ស្រូវកើនដល់ ៥លានតោន គឺជាផលិតកម្មទទួលបានម្នាក់ៗ តិចជាង ៥០០ គីឡូក្រាម ស្រូវក្នុងមួយឆ្នាំជានាការរស់តាមតំបន់ចនបទ ។

## ២.ការបូកសារុបយោបល់ យោងទៅតាមពេលសន្តិភាព

បើសន្តិភាពបានបន្តរយៈពេល ពីរសតវត្សមកនោះសកត្តានុពលកម្ពុជាជាតថភាពមានភាពផ្សេងទៅវិញហើយមានទស្សនៈវិស័យយុទ្ធសាស្ត្រផ្សេងទៅវិញ ។ ដើម្បីឱ្យមានគំនិតសុទិដ្ឋិនិយម នឹងបញ្ហានេះយើបានការបូកសរុប ឈរលើតួលេខ ក្នុងពេលសន្តិភាព ១៩៥០ ដូចតទៅ ៖

GNP នៅឆ្នាំ២០០០ ឈរលើមូលដ្ឋានលេខ ១៩៥០-១៩៧០

| | |
|---|---|
| GNP | ១៥ ពាន់លានដុល្លារ U.S. |
| GNPក្នុងម្នាក់ៗ | ១,០០០ ដុល្លារ U.S. |
| ប្រជាជន | ១៧ លាននាក់ |

យោងតួលេខខាងលើរចនាសម្ព័ន្ធនៃ P.N.B.មានដូចតទៅ៖

- ផ្នែកកសិកម្ម ១៤ ភាគរយ
- ផ្នែកឧស្សាហកម្ម ៣៣ ភាគរយ
- រដ្ឋបាល ៣៣ ភាគរយ
- សេវាកម្ម ២២ ភាគរយ
- ធៀបនឹងសភាពការបច្ចុប្បន្ន GNP លេចឡើង-លេចកប់ មានចំនួន ២.៣ពាន់លានដុល្លារ U.S.
- GNP អាចកំណត់តាមអាណត្តិ គុណនឹង ៦.៥
- ប្រជាជនកើនពីរដងហើយ GNP ម្នាក់ៗអាចគុណនឹងជាង ៣ ដង

ផលិតកម្មកសិកម្មជាលដ្ឋាន គឺស្រូវផលកើនលើសពីការហូបចុកយ៉ាងច្រើន ស្រូវ ១១ លានតោន ហើយមានការនាំចេញ ដោយមានផលិតកម្មក្នុងម្នាក់ៗ ៦៥០ គ.ក្រ.ក្នុងមួយឆ្នាំ ហើយនៅក្នុភាគចំណែករបស់ កសិកម្មក្នុងGNP ដែលមានក្នុងបញ្ជិការផ្នែកកសិកម្ម មានចំនួនតែ ១៤% នៃ GNP ប៉ុណ្ណោះ គឺស្មើនឹងភាគចំណែកក្នុង GNP ខ្ពស់ជាងភាគចំណែកវិស័យឧស្សាហកម្មថេរ នៅឆ្នាំ១៩៩០ ទៅទៀត ។

ការសិក្សាមួយនៃការបូកសរុបបានឱ្យដឹងថា ក្នុងក្របខ័ណ្ឌការអភិវឌ្ឍធម្មតាមួយ កម្ពុជាអាចប្រៀបបានរចនាសម្ព័ន្ធផលិតផលប្រហែល នឹងប្រទេសថៃដែរ ។

វិធានការ differential ជាមួយនៃការបូកសរុបនៃឆ្នាំ ១៩៨០-១៩៩២ យើងអាចឃើញ៖ ការប្រៀបធៀបនឹងការបូកសរុបសម្រាប់ឆ្នាំ ២០០០ និន្នាការនៃដំណាក់កាល ១៩៨០-១៩៩២ អាចមានដូចតទៅ៖

- GNP មួយជាមធ្យម ៥ពាន់លានដុល្លារ U.S.ឆ្លងទៅដល់១៥ ពាន់លានដុល្លារ គឺសកត្តានុពលកើន៣ដង ហើយ GNP នៃមនុស្សម្នាក់ៗ គឺកើនពី ៥០០ ដុល្លារ ទៅ ១០០០ ដុល្លារ ជាសកត្តានុពលកើនទ្វេដង ។

- បង្កើនផលិតផលស្រូវពី ៥ លានតោន ទៅ ១១លានតោន គឺសកត្តានុពលកើនទ្វេ ជាតួលេខមានផលិតកម្មតែពាក់កណ្ដាលផលិតកម្មស្រូវប្រទេសថៃនៅឆ្នាំ ១៩៩១ គឺ ៖ ស្មើនិងផលិតកម្មស្រូវនៅអតិតផែនដីកូសាំងស៊ីន កម្ពុជាក្រោមនៅឆ្នាំ ១៩៩១ ។កម្ពុជាមានសកត្តានុពលពិតប្រាកដ ។

**៣.តើមានអង្គធាតុអ្វីខ្លះ សម្រាប់យោងដល់គំរូក្រៅប្រទេស**

មើលមូលដ្ឋានទ្រឹស្ដីនេះគិតផ្ទុយទៅតាមសម្មតិកម្មថា មានការផ្ទុះឡើងនៅ ប៉ុម សេដ្ឋកិច្ចកម្ពុជាអាចស្គាល់នូវសម្មតិកម្ម សុវត្ថិភាព នៃការអភិវឌ្ឍមួយ ប្រដូចបាននឹងការលូតលាស់នៃរដ្ឋអាស៊ាននានា ឈរលើមូលដ្ឋានកសិកម្ម ដែលមានការរីកចម្រើននៅសេដ្ឋកិច្ចកសិកម្ម-ឧស្សាហកម្មមួយ មានដំណាក់កាលពីរ៖

- នៅក្នុងកម្រិតទីមួយ កសិកម្មដ៏រុងរឿងមួយអាចអនុញ្ញាតិផ្ដល់ហិរញ្ញវត្ថុ ដល់គម្រោងហេដ្ឋារចនា សម្ព័ន្ធរបស់រដ្ឋ និងអភិវឌ្ឍន៍ផលិតផលជាមូលដ្ឋាន ដោយពួកសហគ្រិនឯកជន ដូចជាស្រូវ កៅស៊ូ ដលផល និងផលដំណាំផ្សេងៗទៀត ។ ផលលើសនៃកសិផល យកទៅវិនិយោគឡើងវិញជាទំនិញសម្រាប់ប្រើប្រាស់នាំចេញ ។

- ការរីកចម្រើននេះនាំទៅដល់ ការចាប់ផ្ដើមឱ្យមានការផលិត នូវទិញសម្ភារជាមូលដ្ឋាន និងអភិវឌ្ឍន៍នៅឧស្សាហកម្មមួយ ដែលមានតិចណូឡូស៊ីថនស្រាល ការដំឡើងគ្រឿងអេឡិចត្រូនិច ជាសាខាផលិតគ្រឿងម៉ាស៊ីនបំណែក sous-traitant នៃសហគ្រាសពួកវិនិយោគតៃវ៉ាន់ ម៉ាឡេ និងថៃជាដើម ។

តើសង្វាក់ការអភិវឌ្ឍនោះប្រព្រឹត្តទៅបែបណា? សម្មតិកម្មអាចបែងចែកជាគំរូពីរបែប ៖

- គំរូទីមួយរចនាសម្ព័ន្ធរដ្ឋបាលនៅខ្សោយ និងការអភិវឌ្ឍយឺតៗ ប្រហែល១% នៃអត្រាកំណើនក្នុងមួយឆ្នាំលើមូលដ្ឋានចេញពីឆ្នាំ ១៩៨០-១៩៩២ តាមគំរូហ្វីលីពិន អាចពេលខ្លះ GNP ក្នុងម្នាក់នៅទ្រឹង ។

- ក្នុងគំរូទីពី រចនាសម្ព័ន្ធរដ្ឋបាលបានវិលទៅរកប្រសិទ្ធភាពដូចដើមវិញនាសម័យសង្គ្រាម ជាការ អភិឌ្ឍន៍មួយរហ័ស ប្រហែលពី ៥% ទៅ ៨% កំណើនក្នុងមួយឆ្នាំ ឈរលើមូលដ្ឋានឆ្នាំ ១៩៨០-១៩៩២ តាមគំរូថៃ ។

ការសេរុបនៅពេលមានសន្តិភាព ១៩៥០-១៩៧០ ហើយព្រឹត្តកាណ៍នៃសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍បានសម្គាល់នៅការកើនរហ័សពីឆ្នាំ ១៩៧០ ប្រទេសកម្ពុជាដើរឆ្លងកាត់ភាពខ្មៅងងឹតរបស់ខ្លួនក៏អាចមានអត្ថទត្តកម្មសេដ្ឋប្រៀបបាននឹងប្រទេសហ្វីលីពិន ដែលមាន GNP ក្នុងម្នាក់ៗច្រើនជាង ១៥០០ ដល្លារ U.S.នៅឆ្នាំ ២០០០ ឬ បើកើនតហ័សជាងនេះតាមរូបភាព នាគ ក្នុងកម្រិតប្រៀបបាននិងប្រតេសថៃ ដែល P.N.B.ក្នុងម្នាក់ជាង ៤០០០ ដុល្លារ U.S.។

តើកម្ពុជាអាចជ្រើសរើសសង្វាក់អភិវឌ្ឍន៍ បែបណាទៀតដើម្បីជៀសវាងការប៉ះពាល់ដល់បរិស្ថាន? កម្ពុជាមានសង្ឃឹមថា នៅឆ្នាំ ១៩៩៧ ធ្វើអាជីវកម្មប្រេងកាត និងឧស្ម័ន ចេញពីខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ដែលបង្កើត GNP បន្ថែមទៀតបាន ពី ៦០០ លានដុល្លារ ទៅ ៧០០ លានដុល្លារ ក្នុងមួយឆ្នាំនិងរៀបចំហេដ្ឋារចនា សម្ព័ន្ធ ប្រយលានយន្តហោះអន្តរជាតិ ប្រព័ន្ធទូរគមនាគមន៍ដឹកជញ្ជូន សណ្ឋាគារ ឧទ្យានជាតិ រក្សាព្រៃឈើ សត្វព្រៃ កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ដែលទេសចរណ៍នឹងមកទស្សនា អង្គរវត្ត សម្រាកឆ្នេសមុទ្រ ចាប់ពីឆ្នាំ ១៩៩៩ ទៅ ពី១លាននាក់ឡើងទៅ អាចបង្កើតបន្ថែមដល់ GNP ក្នុងមួយឆ្នាំៗយ៉ាងតិចក៏ ៤០០ ទៅ ៥០០ ដុល្លារ ថែមទៀត ។

តាមរយៈសកត្តានុពលដែលមាននៅខាងលើនេះកម្ពុជានិងជ្រៀតចូល ជាជំហ៊ានៗទៅក្នុងពភពទំនើប ខាងសេដ្ឋកិច្ចសង្គមនៅអាស៊ីអាគ្នេយ៍ ។

# មេរៀនទី ១៣
# ជំនួយអន្តរជាតិទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ទំនាក់ទំនងជាមួយភាគីនានាផ្សេងៗទៀត
- ទំនាក់ទំនងទ្វេភាគី
- ទំនាក់ទំនងពហុភាគី
- ទំនាក់ទំនងជាមួយ I.M.F.
- ទំនាក់ទំនងជាមួយអាស៊ាន
- ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា

ទាំងប្រទេសទទួលជំនួយ ទាំងប្រទេសផ្តល់ជំនួយ ដែលហៅថា "ជំនួយសេដ្ឋកិច្ច" គឺមានសារៈសំខាន់បញ្ចេញអានុភាពប្រតិកម្ម ដែលត្រូវសិក្សាថាជា "កិច្ចការសាមគ្គីមនុស្សជាតិ" ជា "ភាពខ្វះខាតនៃទ្រព្យសម្បត្តិសាធារណៈ" ជា "ឧបករណ៍អាណាគមន៍និយមថ្មី" ។ល។ ខ្លឹមសារនៃជំនួយស្ថិតនៅ "ជំនួយមានការលំបាក ក្នុងការឱ្យនិយមន័យក្នុងការដឹង និងវាស់វែងបាន" ។

បច្ចុប្បន្នក្នុងវិធានការនៃជំនួយបរទេសបានដើរតួ និងបន្តដើរតួសំខាន់មិនអាចខ្វះក្នុងសេដ្ឋកិច្ចកម្ពុជា។ ទោះបីខ្វះភាពប្រាកដនិយមក្តី និងការលំបាកក៏ដោយ គេត្រូវតែបរិយាយពីជំនួយនេះ និងអបអរចំពោះតួនាទីរបស់ជំនួយ។

## ១៣.១.ធម្មជាតិនៃជំនួយ

តើត្រូវផ្តល់និយមន័យ និងបញ្ជាក់លក្ខណៈជំនួយទទួលបានដោយកម្ពុជាបែបណា? ស្នាមជំនួយសំខាន់ៗ ហាក់ដូចជាមានលក្ខណៈប្លែកៗដែលសម្តែងចេញពីប្រភពនៃជំនួយ ក៏ដូចនៅក្នុងរូបភាពនៃជំនួយ។

### ១៣.១.១.ប្រភពជំនួយផ្សេងៗ

ស្នាមជំនួយដែលគួរឱ្យកត់សម្គាល់នោះ គឺជំនួយបរទេសដល់កម្ពុជា គឺមានប្រភពច្រើនណាស់។ កម្ពុជាធ្លាប់ទទួលជំនួយពីប្រទេសជាច្រើន។ ជំនួយនោះចេញពីប្រទេសជាច្រើន។ ជំនួយនោះចេញពី "ប្លុក"ពីរ។ នោះហើយជាអនុភាពនៃនយោបាយ "អព្យាក្រិត" នៃកម្ពុជា។ ប្រទេសជាច្រើនបានទទួលបរិមាណ ឬតាមមនុស្សម្នាក់ៗ ។ ជំនួយពីបរទេសច្រើនជាងកម្ពុជា ប៉ុន្តែមិនអាចទទួលបានពីប្លុកទាំងពីរបានឡើយ គឺមានន័យថាកម្ពុជាពេលនេះ បានសង្គ្រោះបាននូវឯករាជ្យរបស់ខ្លួន។ គេឃើញថា បឋមជំនួយមកពីអង្គការសហប្រជាជាតិពីប្រជាមានិតចិន សហរដ្ឋអាមេរិក បារាំង សហភាពសូវៀត ដែលមានសារៈសំខាន់ជាងជំនួយពីប្រទេសឯទៀត។

### ក.ជំនួយពីអង្គការសហប្រជាជាតិ

អ.ស.ប ដែលមានទីស្នាក់ការនៅភ្នំពេញ ដូចជាស្ថានឯកអគ្គរដ្ឋទូតរបស់ខ្លួននោះ បានផ្តល់ជំនួយដល់កម្ពុជា ក្រោមរូបភាពពីរបែប។

ទីមួយ អ្នកឯកទេសអន្តរជាតិមួយចំនួន បានធ្វើការផ្តល់ជំនួយដល់កម្ពុជា ហើយធ្វើការនៅក្រសួង និងស្ថាប័ន នៃប្រទេស "ក្រសួងផែនការ កសិកម្ម វិជ្ជាស្ថានស្រាវជ្រាវកៅស៊ូ" ។ល។

អ្នកឯកទេសទាំងនោះ បម្រើក្នុងក្របខ័ណ្ឌ នៃកម្មវិធីទាំងឡាយរបស់ អ.ស.ប ក៏ដូចនៅក្នុងកម្មវិធីភ្នាក់ងារពិសេស "អង្គការស្បៀងពិភពលោក អង្គការការងារអន្តរជាតិ អង្គាការសុខាភាពពិភពលោក អ៊ុយនីសេហ្វ" ។ល។

អ.ស.ប ក៏នៅបានចាត់តាំងបញ្ជូននៅបរទេស នូវអ្នកទទួលអាហារូបករណ៍ និងកម្មសិក្សាខ្មែរ។

ទីពីរ គណៈកម្មការទន្លេមេគង្គ ដែលជាផ្នែកនៃគណៈកម្មការសេដ្ឋកិច្ច សម្រាប់អាស៊ី និងចុងបូព៌ាបានដំណើរ ការគម្រោងរៀបចំអាងទន្លេមេគង្គ។ គម្រោងនោះ មានជាប់ទាក់ទងនឹងថៃ ឡាវ កម្ពុជា វៀតណាមជានិច្ច សហប្រតិបត្តិការ នៃប្រទេសទាំងនេះ ត្រូវជួបឧបសគ្គនយោបាន ហើយមិនដែលដោះស្រាយអ្វីបាន។ ហើយ កម្ពុជា នៅមិនទាន់បានចាប់ផ្តើមសិក្សាអ្វី ជាដំបូងបានច្រើននៅឡើយ។

### ខ.ជំនួយចិន

សាធារណរដ្ឋចិនប្រជាមានិត ផ្តល់ជំនួយសំខាន់ដល់កម្ពុជា ចាប់ផ្តើមពីរូបភាពកសាងរោងចក្រ។ ចិនបានផ្តល់ដល់កម្ពុជា នូវរោងចក្រតំបាញពីរ រោងចក្រក្តារបន្ទះ រោងចក្រក្រដាស ស៊ីម៉ង់ និ កែវ។ ចិនក៏ជួយកសាងរចនាសម្ព័ន្ធផងដែរ "កសាងផ្លូវយន្តហោះ ២,៥០០ ម៉ែត សម្រាប់យន្តហោះប្រតិកម្មនៅសៀមរាប បុរីកីឡា" ។ល។ អ្នកឯកទេសចិនមួយចំនួនមកកម្ពុជា ពិសេសនៅក្នុងរោងចក្រ ដែរប្រទេសចិនផ្តល់ឱ្យ។

### គ.ជំនួយសហរដ្ឋអាមេរិក

កម្ពុជាបានបដិសេធជំនួយសហរដ្ឋអាមេរិក នៅឆ្នាំ ១៩៦៣ ពីឆ្នាំ ១៩៥៥ ដល់ ១៩៦៣ កម្ពុជាបានទទួលជំនួយពីសហរដ្ឋអាមេរិកយ៉ាងសំខាន់។ ការសន្និដ្ឋានបង្ហាញថា មានចំនួនច្រើននៅក្នុងពេលនោះ គឺ ជាង ៣៥០ លានដុល្លារ។ នោះជាជំនួយដ៏ធំ ប្រៀបនឹងជំនួយបរទេសដែលកម្ពុជាបានទទួល។

ផ្លូវភ្នំពេញ-ក្រុងព្រះសីហនុ លើផ្នែកបច្ចេកទេស គឺមិនជាទីពេញចិត្តនោះទេ តែលើផ្នែកសេដ្ឋកិច្ច គឺមានប្រយោជន៍ណាស់ ជំនួយដ៏ច្រើនៗនោះ មិនសូវទុកស្នាមនោះទេ ដូចជាប្រព័ន្ធជាពសាស្ត្រ កសិកម្ម គ្រឹះស្ថានសិក្សាព្រឹទ្ធសភា ប៉ូលីស។

១/៤ នៃជំនួយ ជាផ្នែកយោធា ដែលរួមមានសម្ភារ ការហ្វឹកហ្វឺនទ័ព ជាតួនាទីមិនសូវយកចិត្តទុកដាក់របស់អ្នកសេដ្ឋកិច្ច។

### ឃ.ជំនួយបារាំង

បារាំងបានផ្តល់ជំនួយក្នុងវិស័យបីសំខាន់៖ បច្ចេកទេស ផ្នែកវប្បធម៌ និងហិរញ្ញវត្ថុ។ ពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៥៩ ជំនួយបរទេស និងសេដ្ឋកិច្ចនៅលើកទី១ រួមចំណែកដល់ការកសាងសមិទ្ធិផលហេដ្ឋារចនាសម្ព័ន្ធ៖ផែក្រុងព្រះសីហនុ ផ្លូវយន្តហោះពោធិចិនតុង មជ្ឈមណ្ឌលវះកាត់។ ពីឆ្នាំ ១៩៦០ បារាំងបញ្ជូនអ្នកជំនាញការ ជាកិច្ចអន្តរាគមបច្ចេកទេស ផ្តល់អាហារូបករណ៍ ការវិនិយោគមានលក្ខណៈបន្ថែម។

អ្នកជំនាញការ ៨០ នាក់ ជួយពង្រឹងដំណាំកប្បាស ស្ករ ដូង ស្រាវជ្រាវរ៉ែ ជួលបម្រើក្នុងសេវាកម្ម សាធារណៈខ្មែរ កសិកម្ម សាធារណៈការ ផ្លូវដែក ប៉ុស្តិ៍ទូរគមនាគមន៍ យុត្តិធម៌។ល។ ក្នុងមហាវិទ្យាល័យបច្ចេកទេសមជ្ឈមណ្ឌលបណ្តុះវិជ្ជាជីវៈ។ ការវិនិយោគលើសកលវិទ្យាល័យកសិកម្ម និងសកលគរុកោសល្យជាន់ខ្ពស់។

ជំនួយវប្បធម៌បារាំង មានសារៈសំខាន់ណាស់ដែរ តាមរយៈភាសាបារាំង។ ការបញ្ចូលសាស្ត្រចារ្យបារាំងនៅភូមិសិក្សាទាំងបីថ្នាក់។ សាស្ត្រាចារ្យទាំងនោះ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំជាតិ ឬ បង្រៀននៅវិទ្យាល័យបារាំង នៅភ្នំពេញ ដែលជាបន្ទុកនៃប្រទេសបារាំង។ អាហារូបករណ៍ជាច្រើនរបស់បារាំង បានផ្តល់ឱ្យនិស្សិតកម្ពុជា។ ជំនួយហិរញ្ញវត្ថុ បានផ្តល់ពេលក្រោយមកទៀត ចេញជារូបរាង ជាការឱ្យខ្ចីដល់ទៅ ១៦០ លានហ្វ្រង់ កសាងសមិទ្ធិផលបីធំសំខាន់ : ពង្រីកផែក្រុងព្រះសីហនុ ផ្លូវដែកភ្នំពេញ-ក្រុងព្រះសីហនុ និង ការកសាងរោងចក្រចម្រាញ់ប្រេងកាតក្រុងព្រះសីហនុ។

### ង.ជំនួយរបស់អតីតសហភាពសូវៀត

ជំនួយសហភាពសូវៀត សង្កត់លើចំណុចបី៖ ទីមួយ គឺសំណង់មន្ទីរពេទ្យ ៥០០ គ្រែ ដោយមានជំនួយឱសថ និងគ្រូពេទ្យជាង ២០ រូប ពីឆ្នាំ ១៩៦៦មក។

គម្រោងជំនួយអាស៊ីមួយទៀត គឺ ទំនប់វារីអគ្គិសនីកំចាយ ខេត្តកំពត។ ការផ្គត់ផ្គង់ហិរញ្ញវត្ថុ ជាការឱ្យខ្ចីក្នុងអត្រា ២.៥%។ គម្រោងនេះជួបឧបសគ្គបច្ចេកទេស សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សហភាពសូវៀត បានផ្តល់អាហារូបករណ៍សិក្សា កម្មសិក្សា ៧៥នាក់ នាឆ្នាំ ១៩៦៦។

### ច.ជំនួយប្រទេសដ៏ទៃទៀត

ប្រទេសចំនួន ១២ ទៀត បានជួយជាជំនួយដល់កម្ពុជា ខាងផ្នែកសេដ្ឋកិច្ច មានសារៈសំខាន់តិច ឬច្រើនដែរ។ ប្រទេសអូស្ត្រាលី កាណាដា កូរ៉េខាងជើង អង់គ្លេស ឥណ្ឌា អ៊ីស្រាអែល ហូឡង់ ប៉ូឡូញ និងអាល្លឺម៉ង់ទាំងពីរ។

ជប៉ុនបានសាង និងធ្វើឱ្យដំណើរការ នូវមជ្ឈមណ្ឌលកសិកម្ម ពិសោធន៍ពីរកន្លែង។ ជប៉ុនក៏បានសម្រេចជាស្ថាពរ នូវការសិក្សាសំខាន់ៗ នៃការដាក់ឱ្យមានតម្លៃដល់អាងទន្លេមេគង្គ។

ប្រទេសឆេកូស្លូវ៉ាគី មិនត្រឹមតែផ្តល់ជាសម្ភារ ផ្តល់អាហារូបករណ៍ និងបញ្ជូនជំនាញការថែមទាំងបានផ្តល់ជំនួយហិរញ្ញវត្ថុសម្រេចជាសមិទ្ធិផល នូវរោងចក្រចំនួនបួន : រោងចក្រអគ្គិ

សនី រោងចក្រផលិតកង់រថយន្តរោងចក្រចម្រាញ់ស្ករស រោងចក្រតម្លើងត្រាក់ទ័រ។ ជំនួយនោះមានរូបភាពជាការខ្ចីបុល ក្នុងអត្រាការប្រាក់ ២៥% សងវិញក្នុង រយៈពេលប្រាំបីឆ្នាំ តាមការចុះបញ្ជីគណនី clearing ឆេកូស្លូវ៉ាគី។

ប្រទេសយូហ្គោស្លាវី ក៏បានឱ្យកម្ពុជាខ្ចី អត្រាការប្រាក់ ៣% សងក្នុងរយៈពេល ១៥ឆ្នាំ ដើម្បីសាងសង់រោងចក្រវារីអគ្គសនីគីរីរម្យ ដែលមានបញ្ចប់ទៅនៅឆ្នាំ ១៩៦៧។

ការធ្វើពណ៌នាជារួមៗ នៃជំនួយដែលប្រទេសជាច្រើនបានជួយដល់កម្ពុជា បានបញ្ជាក់ពីធម្មជាតិនៃជំនួយនៃគំនិត ដែលត្រូវបញ្ជាក់តាមរយៈកំណត់ចំណាំ លើរូបភាពនៃជំនួយនោះ។

## ១៣.១.២.រូបភាពនានានៃជំនួយ

បទពណ៌នាដែលបញ្ជាក់ជាបន្តបន្ទាប់ មិនអាចធ្វើការសន្និដ្ឋានពីកម្រិតជំនួយទទួលបានពីមួយឆ្នាំទៅមួយឆ្នាំ។ ការសន្និដ្ឋានដែលមានហើយ ក៏មិនទាន់ត្រឹមត្រូវ ព្រោះមកពីរូបភាពនៃជំនួយមានច្រើនប្រភេទ។

ប្រទេសជំនួយមានច្រើនជាយោធា វប្បធម៌ បច្ចេកទេស និងសេដ្ឋកិច្ច។ ចំពោះជំនួយជាសេដ្ឋកិច្ច យោធាវប្បធម៌ មិនអាចដាក់ចូលនៅក្នុងផែនការដូចគ្នា និងជំនួយបច្ចេកទេស និងសេដ្ឋកិច្ចឡើយ ហើយប្រតិបត្តិការដែលត្រូវបូកផលសរុប ទទួលបានក្នុងនាមនៃជំនួយផ្សេងៗ មិនមានអត្ថន័យធំដុំនោះទេ។ គេក៏មិនត្រូវមិនយកទុកដាក់ ពីជំនួយយោធាដែល ព្រោះជាចំណែកមួយរួមវិភាគទាន ដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចដែរ។

បែបបទជំនួយខុសៗគ្នា ធ្វើឱ្យជំនួយកាន់តែមានភាពស្មុគស្មាញ។ គេអាចបែងចែកជំនួយជារូបបី៖ ជំនួយជាប្រាក់ ជំនួយជាទ្រព្យ ជំនួយជាមនុស្ស។

ជំនួយជាប្រាក់ តើអាចសន្និដ្ឋានថាជាអំណោយ ឬជាប្រាក់ខ្ចី។ ជារឿយៗ ការវាយតម្លៃនៃកម្រិតទឹកប្រាក់នៃជំនួយ គឺធ្វើឡើងតាមរូបភាពជាជំនួយការខ្ចី។ ជំនួយដែលមានចំនួនប្រាក់កម្រិតទាបជាងខ្ចី គឺត្រូវទូទាត់សងហើយ ប្រទេសខ្ចីគេ ត្រូវតែសងការប្រាក់ប្រចាំឆ្នាំ។ ប៉ុន្តែនៅជ្រុងម្ខាងទៀត ការខ្ចី គឺជាជំនួយ ព្រោះលក្ខខ័ណ្ឌពីអត្រាការ ប្រាក់ និងរយៈពេលខ្ចី ជាបុព្វសិទ្ធនៃលក្ខខ័ណ្ឌសង្គមនាពេលនោះ។ ជំនួយស្ថិតនៅក្នុងលក្ខខ័ណ្ឌនោះដែលនាំដល់ការ លំបាកក្នុងការគណនាកម្រិតរបស់ជំនួយនោះ។វាមានការលំបាកកាន់តែខ្លាំងឡើងទៀត ចំពោះប្រទេសឱ្យខ្ចី នៃប្លុកសង្គមនិយម ក្នុងការទូទាត់សងតាមរយៈការចុះបញ្ជីគណនី clearing នៃប្រទេសទាំងនោះ ការសងប្រាក់ត្រូវវិភាគថា ជាការនាំចេញ ឬនាំចូល ទៅប្រទេសអ្នកឱ្យខ្ចី។ ផលិតផលនាំចេញត្រូវទូទាត់សងនោះ ជាផលិតផលដែលអាចលក់បាន ទល់នឹងរូបិយប័ណ្ណខ្លាំងនៅផ្សារពិភពលោក។ បែបបទទូទាត់នោះ គ្មានបានផលប្រយោជន៍ដល់កម្ពុជាទេ។ ផ្ទុយទៅវិញផលិតផលដែលទទួលយក ដើម្បីទូទាត់ ដោយប្រទេសអ្នកផ្តល់ជំនួយអំណោយមិនមានតម្លៃ ជាទំនិញបែបបទ។

នេះ មានផលប្រយោជន៍ពិត។ ជំនួយជាសម្ភារ ក្នុងករណីកម្ពុជា "កម្ពុជាមិនត្រូវការជំនួយស្បៀងនោះ" ក៏លំបាកក្នុងការវាយតម្លៃដែរ។ ម៉ាស៊ីនដែលផ្តល់ឱ្យកម្ពុជា ឬសម្ភារយោធា

អាចថាមិនមានតម្លៃធំដុំទេ ចំពោះប្រទេសអ្នកផ្តល់ជំនួយតែមានតម្លៃខ្ពស់ ចំពោះកម្ពុជា-ប្រទេសអ្នកទទួល។

ជំនួយជាមនុស្ស ក្នុងនាមជំនួយបច្ចេកទេស កាន់តែលំបាកក្នុងការវាស់វែង។ ប្រាក់បៀវត្សរ៍ផ្តល់ឱ្យដោយប្រទេសអ្នកផ្តល់ជំនួយ ដល់អ្នកឯកទេសនៅបរទេសនោះ ជាតួលេខតែមួយដែលមានឈ្មោះ សន្និដ្ឋានជា "ជំនួយដល់ការចំណាយ របស់អ្នកឯកទេសនេះ"។ ប៉ុន្តែ តួលេខនោះ ពុំមានអត្ថន័យច្រើនដែរ។ ជំនួយបៀវត្សរ៍នោះក្រៅពីចំណាយនៅប្រទេសដែលខ្លួនទៅជួយជាបច្ចេកទេស ប្រាក់សន្សំមួយផ្នែកទៀត ត្រូវវិលទៅកាន់ប្រទេសដើមវិញ។

ការសន្និដ្ឋានកម្រិតជំនួយរបស់ប្រទេសមួយ គឺ មានភាពស្មុគស្មាញ ដោយសាររូបភាពជំនួយ មានភាពប្លែកពន់ពេក។ ការបង្កើតរោងចក្រមួយ ត្រូវការអ្នកបច្ចេកទេសដើម្បីសិក្សាដឹកនាំការងារ និងត្រួតពិនិត្យការប្រព្រឹត្តទៅ នៃការផ្គត់ផ្គង់ ដោយមិនគិតនូវថ្លៃម៉ាស៊ីន និងការឱ្យខ្ចី ដើម្បីទូទាត់ជាមួយម៉ាស៊ីនផ្សេងទៀត។ លេខនៃជំនួយ បែបនេះ តើត្រូវដាក់តម្លៃណា ដែលត្រូវនោះ?

## ១៣.២.តួនាទីនៃជំនួយ

តើជំនួយសេដ្ឋកិច្ច មានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេល ១០ឆ្នាំ "១៩៦៩" ។ ភាពមិនច្បាស់លាស់នៃជំនួយនោះ ធ្វើឱ្យមានការលំបាកក្នុងការរកចម្លើយត្រឹមត្រូវ។ គេអាចរកឃើញខ្លះ នូវផលប៉ះពាល់ផ្ទាល់ លើផលិតកម្ម និងមិនផ្ទាល់លើហិរញ្ញវត្ថុសាធារណៈ និងជញ្ជីងពាណិជ្ជកម្មនៃជំនួយ។

### ១៣.២.១.ផលប៉ះពាល់ផ្ទាល់នៃជំនួយ

ជាមូលដ្ឋានសំខាន់ ជំនួយបរទេសបម្រើកិច្ចអភិវឌ្ឍន៍រចនាសម្ព័ន្ធ និងសម្ភារសង្គម វប្បធម៌ "ផ្លូវ ផែព្រលានយន្តហោះ មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ។ល។" ការអភិវឌ្ឍផ្នែកទាំងនោះ ជាការលើកទឹកចិត្តចាំបាច់បំផុតព្រោះវាបានរួមវិភាគទានផ្ទាល់ ដល់ការបង្កើតផលិតផលជាតិ។ ក្នុងករណីខ្លះ ការប្រព្រឹត្តទៅនៃសម្ភារប្រទេសនោះជាបន្ទុករបស់ប្រទេស បើយកជំនួយនោះទៅបម្រើផលិតកម្ម នោះកានតែប្រសើរ។

ផលិតផលជាតិសំខាន់ គឺកសិកម្ម។ ជំនួយបរទេស តម្រង់ទិញជួយផ្នែកទីមួយនេះបន្តិចបន្តួច មជ្ឈ មណ្ឌលគំរូជប៉ុន ប្រព័ន្ធធារាសាស្រ្ត កសិកម្ម អាមេរិក ជំនួយបច្ចេកទេសបារាំងឬរបស់ អ.ស.ប មានភាគចំណែកតិចតួចនៃជំនួយទទួលបានដោយកម្ពុជា។ បើគិតទៅដល់ប្រសិទ្ធភាពនៃជំនួយនោះ ដល់កសិកម្ម មិនបានចំនួយច្រើនទេដោយលើកលែងដោយឡែកករណីដំណាំកៅស៊ូ។ យើងឃើញការជួយរបស់បរទេស ដល់វិស័យកសិកម្ម មានចំនួយតិចតួចណាស់។ កំណើននៃផលិតផលនេះ ដែលមានសារៈសំខាន់បង្គួរដែរ នោះនឹងរួមចំណែកយ៉ាងធំទូលាយដល់អត្រាកំណើននៃសេដ្ឋកិច្ចជាតិ។

ការរួមវិភាគទាននៃជំនួយបរទេស ដល់ការរីកចម្រើននៃផ្នែកឧស្សាហកម្មក៏មានសារៈសំខាន់ខ្លាំងដែរ។ រោងចក្រចំនួន ដប់ពីរ ដែរមានផលិតប្រយោជន៍ ដល់ប្រទេសជាជំនួយទាំងស្រុង ឬភាគខ្លះនៃជំនួយបរទេស។ យើងមិនចង់ពង្រីកនូវសារៈសំខាន់ នៃជំនួយនោះពេកទេ។

ជាបឋម ក្នុងករណីជាច្រើន ដូចជារោងចក្រធេកូនស្លូវ៉ាគី និងបារាំង ជំនួយមាន រូបភាពជាការខ្ចីបុល។ ការខ្ចីនោះ មានលក្ខខ័ណ្ឌល្អដែរ តែភាគចំណែកនៃជំនួយឥតចំណង មានតិចពេក។

រោងចក្រក្ដារបន្ទះ និងរោងចក្រ ក្រដាស "ជំនួយចិន" និងរោងចក្រតម្លើងត្រាក់ទ័រ ឆេកូ មិនផ្ដល់នូវសេចក្ដីពេញចិត្ត ទាំងស្រុងនៅត្រង់ចំណុចសេដ្ឋកិច្ច។ ដោយមិនបាច់និយាយថារោងចក្រនោះ "ផលិតជានិច្ចកាលខាត" ព្រោះថ្លៃដើម ផលិតកម្ម "ការប្រើប្រាស់ប្រភព ធនធានពលកម្ម និងវត្ថុធាតុដើម" នៃផលិតរោងចក្រខ្ពស់ហួស។

រោងចក្រនានាដែលទទួលបាន ពីជំនួយបរទេស រួមវិភាគទានខ្លះដែរ ដល់ផលិតផលឧស្សាហកម្ម ក្នុងសំណុំរបស់ខ្លួន។ ឧស្សាហផលនៃផ្នែកសាធារណៈ និងពាក់កណ្ដាលសាធារណៈ នៅខ្សោយប្រៀប នឹងផលិតផលឧស្សាហកម្មសរុប ទោះបីបរិមាណមានការកើនឡើងរហ័សក៏ដោយ។ ផលិតផលនៃរោងចក្រ "ជំនួយ" គឺមានសារៈសំខាន់តិចតួច ដល់ផលិតផលនៃផ្នែកសាធារណៈ។ គេគ្មានតួលេខបញ្ជាក់ច្បាស់ទេ តែគេអាចបញ្ជាក់ថាផលិតផលនៃរោងចក្រ "ជំនួយ" រួមវិភាគទានតិចជាង ១០% នៃផលិតផលផ្នែកទី ២ នោះ។

ជំនួយផ្នែកផលិតផលកសិកម្ម មិនសូវយកចិត្តទុកដាក់។ លើផ្នែកឧស្សាហកម្មវិញ ផលិតផលខ្សោយជំនួយបរទេសលើសេដ្ឋកិច្ចកម្ពុជា មានកម្រិតនៃប្រសិទ្ធភាព។ ជំនួយនោះ ក៏នៅបានរួមវិភាគទានមិនផ្ទាល់ ដល់ការអភិវឌ្ឍកម្ពុជាផងដែរ។

## ១៣.២.២.ផលប៉ះពាល់មិនផ្ទាល់នៃជំនួយ

ផលវិបាកមិនផ្ទាល់ នៃជំនួយបរទេស មានតួនាទីពិតប្រាកដ ដល់សេដ្ឋកិច្ចកម្ពុជា។ ជាបឋមការចូលរួមប្រឹងប្រែងឱ្យកម្ពុជាសម្រេចបានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងសម្រេចបានសម្ភារសង្គមជំនួយបរទេសក៏បានរួមចំណែកផងដែរ ដល់ការរៀបចំមូលដ្ឋានសម្ភារ និងមនុស្សសម្រាប់ការអភិវឌ្ឍរយៈពេលមធ្យម និងវែងនៅកម្ពុជា។

ប៉ុន្តែក្នុងស្ថានភាពបន្ទាប់ តួនាទីមិនផ្ទាល់ នៃជំនួយហាក់ដូចជាតួរឱ្យកត់សម្គាល់ក្នុងវិស័យនានា ដូចជាថវិកា រូបិយវត្ថុ និងពាណិជ្ជកម្មក្រៅប្រទេស។

ជំនួយបរទេស មានផលវិបាក លើហិរញ្ញវត្ថុសាធារណៈ។ ភាគច្រើននៃប្រតិបត្តិការហិរញ្ញវត្ថុ ដោយជំនួយបរទេសបានចាត់ទុកជា ជាចំណាយរដ្ឋបាលកម្ពុជា ដែលបំពេញដោយចំណូល ក្នុងកម្រិតស្មើនឹងជំនួយ។ ជំនួយបានត្រូវចាត់ទុកផងដែរ ជាចំណូលសាធារណៈ ប្រហែល ១/៤ នៅឆ្នាំ ១៩៦២ នឹង ១៩៦៣ ដប់ឆ្នាំមានតួលេខច្បាប់។ មានន័យថា ១/៤ នៃសកម្មភាពសាធារណៈ "បានមក" ពីជំនួយបរទេស។ ទោះបីជំនួយបច្ចេក ទេសអ្នកឯកទេស

ដែលបានត្រូវគិតជា លុយ នៃជំនួយនោះ ដូចជា បានជាគេលំបាកក្នុងការធ្វើឱ្យមានតួលេខច្បាស់លាស់ ដែលចុះក្នុងបញ្ជីចំណូល និងការចំណាយរដ្ឋបាល។ គម្រោងជំនួយសហរដ្ឋអាមេរិកដែលមិនមែនជាជំនួយ "ថ្លៃ" នាំទៅដល់ការចុះគណនី មានការបន្ថយចុះនូវចំណូល ហើយការចំណាយរដ្ឋបាល ក៏គ្មានវិធានការដូចគ្នាដែរ។

ជំនួយបរទេស មិនមែនគ្មានបាតុភាព ខាងរូបិយវត្ថុនោះទេ ព្រោះវាជាទិដ្ឋភាពដល់សំខាន់។ ជំនួយជាប្រាក់ផ្ទេរ ជារូបិយប័ណ្ណនាំចេញ បង្កើតនូវរូបិយវត្ថុជាតិថែមទៀត ដល់រតនាគារការបង្កើតលុយថ្មីនេះ នាំដល់មូលហេតុនៃអតិផរណា ព្រោះគ្មានភាគីម្ខាងទៀតពិតប្រាកដប៉ុន្តែអនុភាពអាក្រក់នេះមិនបានកើតមាននៅកម្ពុជាទេ ព្រោះជំនួយភាគច្រើន ជាជំនួយទំនិញ ឬការងារ ។

ជំនួយបរទេស ជួយដល់ជញ្ជីងទូទាត់ ។ អំណោយជាប្រាក់ គឺធ្វើឡើងជារូបិយវត្ថុ។ ពេលសិក្សាពីជញ្ជីងទូទាត់ឃើញថាជំនួយបានជួយឱ្យមានលំនឹង នៃប៉ុស្តិ៍ជញ្ជីងទូទាត់ "ជញ្ជីងពាណិជ្ជកម្ម ការទូទាត់ផ្សេងៗប្រតិបត្តិការទន់" ហើយក៏អាចឱ្យប្រមូលផ្តុំ ការបម្រុងមាស និងរូបិយវត្ថុ។ និយាយរួមជំនួយបរទេសដែលកម្ពុជាមានសារៈសំខាន់ខ្លាំង ដោយបន្ថយបន្ទុកកម្ពុជាពីភាពសង្ស័យនឹងបាត់បង់លំនឹងជញ្ជីងទូទាត់ ។ ការនាំចូលមកកម្ពុជាមួយចំនួន ទូទាត់ដោយជំនួយបរទេស ។ ជំនួយបរទេស ជួយបន្ថែមដល់ឱនភាពពាណិជ្ជកម្ម។

នៅវិស័យទីបី ជំនួយបរទេស ជះឥទ្ធិពលវិជ្ជមានពិត ប៉ុន្តែ ជំនួយនេះ ក៏មិនធ្វើឱ្យសប្បាយដែរ ក្នុងផ្នែក "សីលធម៌សាធារណៈ" ។ ជំនួយគ្រាប់ដណ្តប់ដោយភាពពុករលួយ ការខ្ជះខ្ជាយនៃសេដ្ឋកិច្ចជាតិ។

ផលវិបាកផ្ទាល់ នឹងមិនផ្ទាល់ លេចឡើងនូវសារៈសំខាន់ នៅពេលពិនិត្យឱ្យបានជិតដល់ហើយឥទ្ធិពលនៃជំនួយ លើអត្រាកំណើនសេដ្ឋកិច្ចកម្ពុជា ហាក់ដូចជានៅទាប ។ ជាទីទៅជំនួយបរទេសនាំឱ្យមានកិច្ចអភិវឌ្ឍន៍ប្រទេសមួយដែលក្រីក្រ នោះជាការរួមវិភាគទានដ៏មានប្រយោជន៍ ក្នុងវិស័យធនធានមនុស្ស និងជញ្ជីងទូទាត់ដែលមិនអាចប្រហែសបានជំនួយជាលក្ខខណ្ឌចាំបាច់នៃការអភិវឌ្ឍ ហើយរង់ចាំការវិភាគសេដ្ឋកិច្ចកម្ពុជា ក្នុងសង្គ្រាមតទៅទៀត។

## ១៣.៣.ទំនាក់ទំនងទ្វេភាគី

ទន្ទឹមនឹងកិច្ចសហប្រតិបត្តិការជាពហុភាគី ធនាគារជាតិនៃកម្ពុជាក៏បានបង្កើនកិច្ចសហការជាទ្វេភាគីដ៏ជិតស្និទ្ធ បន្ថែមទៀត ជាមួយបណ្តាធនាគារកណ្តាល និងស្ថាប័នអន្តរជាតិមួយចំនួន តាមរយៈការសិក្សាអង្កេតរួមគ្នា ការផ្លាស់ ប្តូរព័ត៌មាន និងការបណ្តុះបណ្តាលមន្ត្រីជាដើម ។

កិច្ចសហប្រតិបត្តិការជាមួយនឹងធនាគារកណ្តាលកូរ៉េក៏ត្រូវបានពង្រឹងថែមទៀត តាមរយៈដំណើរទស្សនកិច្ចរបស់ ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជា នាទីក្រុងសេអ៊ូលកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ដើម្បីចូលរួម អបអរសាទរខួបលើកទី៦០ឆ្នាំរបស់ធនា

គារកណ្តាលកូរ៉េ ។ បច្ចុប្បន្នមានមន្ត្រីជំនាញធនាគារកណ្តាលកូរ៉េពីររូបកំពុងជួយ ផ្នែកប្រព័ន្ធទូទាត់ ។

កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១០ កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ បានរៀបចំឡើងនៅទីក្រុងសៀមរាប ក្នុងគោលបំណងឬតចំណងសាមគ្គីភាព និងបន្តកិច្ចសហប្រតិបត្តិការដែលមាន កន្លងមក តាមរូបភាពជាការផ្លាស់ប្តូរបទពិសោធន៍ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងការអភិវឌ្ឍធនធាន មនុស្ស ។ ក្នុងឆ្នាំ២០១០ នេះដែរ ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីចំនួនពីររូបទៅទទួលការបណ្តុះបណ្តាលនៅធនាគារកណ្តាលថៃ ស្តីអំពីការត្រួតពិនិត្យធនាគារពាណិជ្ជ។ ដោយឡែក ធនាគារកណ្តាលថៃក៏បានបញ្ជូនមន្ត្រីជំនាញ របស់ខ្លួនមកជួយការបណ្តុះបណ្តាលនៅធនាគារជាតិនៃកម្ពុជាចំនួនពីរលើកដែរ ស្តីពី ការគ្រប់គ្រងគោលនយោបាយម៉ាក្រូ សេដ្ឋកិច្ចនិងរូបិយវត្ថុ និងប្រព័ន្ធទូទាត់ និងផាត់ទាត់ ។

កាលពីថ្ងៃទី ៦-៨ ខែសីហា ឆ្នាំ ២០១០ កិច្ចប្រជុំទ្វេភាគីជាលើកដំបូងរវាងធនាគារជាតិនៃកម្ពុជា និង ធនាគារកណ្តាលម៉ាឡេស៊ី បានធ្វើឡើងនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ក្នុងគោលដៅបង្កើនចំណងមិត្តភាព និង កិច្ចសហប្រតិបត្តិការលើវិស័យធនាគារនិងហិរញ្ញវត្ថុ និងជួយពង្រឹងវិស័យធនធានមនុស្សតាមរយៈការបណ្តុះបណ្តាល ដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។ នៅក្នុងអំឡុងកិច្ចប្រជុំនោះ ស្ថាប័នទាំងពីរបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ស្តីអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងការត្រួតពិនិត្យធនាគារឆ្លងដែន ។

ចំពោះកិច្ចសហប្រតិបត្តិការជាមួយធនាគាររដ្ឋវៀតណាម កាលពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១០ នាឱកាស ទស្សនកិច្ចនៃនាយករដ្ឋមន្ត្រីវៀតណាមនៅកម្ពុជា ធនាគារនៃកម្ពុជា និងធនាគាររដ្ឋវៀតណាមបានចុះហត្ថលេខាលើ អនុស្សារណៈយោគយល់ស្តីពី ការធ្វើបច្ចុប្បន្នកម្មកិច្ចព្រមព្រៀងប្រព័ន្ធទូទាត់ឆ្លងដែនរវាងប្រទេសទាំងពីរ។

ក្នុងឆ្នាំ២០១០ នេះដែរ អាជ្ញាធររូបិយវត្ថុសឹង្ហបូរីក៏បានផ្តល់ជំនួយបច្ចេកទេសទ្វេភាគីដល់ធនាគារជាតិនៃកម្ពុជា ដែរ ក្រោមរូបភាពជាទស្សនកិច្ចសិក្សាលើផ្នែកត្រួតពិនិត្យប្រព័ន្ធទូទាត់ និងការវិភាគស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលឡាវបន្ថែមទៀត កិច្ចប្រជុំទ្វេភាគី ដែលដឹកនាំដោយ ប្រតិភូជាន់ខ្ពស់រវាងធនាគារកណ្តាលទាំងពីរត្រូវបានធ្វើឡើងកាលពីថ្ងៃទី ៣-៦ ខែធ្នូ ឆ្នាំ២០១០ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ក្នុងគោលបំនងពិនិត្យលើការអនុវត្តអនុស្សារណៈយោគយល់ និងការផ្លាស់ប្តូរបទពិសោធន៍លើការងារមួយ ចំនួន ។

សម្រាប់ឆ្នាំ២០១០នេះ ធនាគារកណ្តាលលុចហ្សំបួរ បានបន្តផ្តល់ជំនួយផ្នែកបណ្តុះបណ្តាលធនធានមនុស្សតាម រយៈការផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ និងផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលខ្លីលើប្រធានបទស្តីពីសវនកម្មផ្ទៃ ក្នុងដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។

## ១៣.៤.ទំនាក់ទំនងពហុភាគី

### ១៣.៤.១.ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាមានទំនាក់ទំនងជាមួយភាគីអន្តរជាតិជាច្រើន ដែលក្នុងនោះ មូលនិធិរូបិយវត្ថុអន្តរជាតិ គឺជាដៃគូដ៏សំខាន់មួយដែលតែងតែអញ្ជើញ មកបំពេញបេសកម្មជារៀងរាល់ឆ្នាំ ។ នៅថ្ងៃទី៩-៣០ ខែមីនា ឆ្នាំ២០១០ នេះ តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក បានអញ្ជើញមកបំពេញបេសកកម្ម "កម្មវិធីវាយតំលៃ លើវិស័យហិរញ្ញវត្ថុ"(Financial Sector Assessment Program: FSAP) ដើម្បីធ្វើការវាយតំលៃលើស្ថានភាពបច្ចុប្បន្ននៃវិស័យហិរញ្ញវត្ថុ រួមទាំងក្របខ័ណ្ឌបទបញ្ញត្តិ។ ជារួម ការវាយតំលៃរបស់ FSAP បានឆ្លុះបញ្ចាំងនូវស្ថានភាព កំពុងអភិវឌ្ឍជាបណ្តើរៗរបស់វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ហើយអនុសាសន៍មួយចំនួនត្រូវបានលើកឡើង សំដៅពង្រឹងស្ថិរភាពវិស័យហិរញ្ញវត្ថុ លើកកំពស់ការត្រួតពិនិត្យនិងបញ្ញត្តិកម្ម បង្កើនការផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជន ទូទៅ និងបង្កើតប្រក ខ័ណ្ឌសម្រាប់គ្រប់គ្រងស្ថានភាពវិបត្តិហិរញ្ញវត្ថុជាដើម ។

ក្នុងពេលជាមួយគ្នានេះដែរ មូលនិធិរូបិយវត្ថុអន្តរជាតិក៏បានលើកឡើងពីសារៈសំខាន់នៃការរៀបចំសូចនាករ ភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ ((Financial Soundness Indicators)ការធ្វើតេស្តរកសញ្ញាហានិភ័យ (Stress Testing) និងវិធីសាស្រ្តត្រួតពិនិត្យដោយផ្អែកលើហានិភ័យ (Risk Based Examination) ផងដែរ ។

ទន្ទឹមនោះដែរ នៅក្នុងឆមាសទីពីរនៃឆ្នាំនេះ តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិក៏បានអនុវត្តបេសកកម្មមាត្រាទី៤ នៅប្រទេសកម្ពុជា ដែលចាប់ផ្តើមពីថ្ងៃទី ៣០ ខែសីហា ដល់ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០១០។ បេសកកម្មខាងលើនេះ បានវាយតំលៃជារួមលើស្ថានភាពសេដ្ឋកិច្ចហិរញ្ញវត្ថុថា កម្ពុជាងើបចេញផុតពីផលវិបាកនៃវិបត្តិសកលលោក ដោយសន្ទុះ រឹងមាំសមរម្យមួយ ហើយសេដ្ឋកិច្ចអាចមានកំណើន ៤,៥% - ៥% នៅឆ្នាំ២០១០ ដោយសារកំណើនវិស័យនាំចេញ និងទេសចរណ៍ ។ ប៉ុន្តែឧបសគ្គ និងហានិភ័យរបស់កម្ពុជាគឺមូលដ្ឋានកំណើនសេដ្ឋកិច្ចនៅតូច ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយ កម្រិតដុល្លារូបនីយកម្មខ្ពស់ និងលទ្ធភាពវិស័យសារពើពន្ធមានកម្រិត។ លើសពីនេះ បេសកកម្មបានផ្តល់អនុសាសន៍ល្អៗ មួយចំនួនដែរលើវិស័យសារពើពន្ធគោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់ និង វិស័យត្រួតពិនិត្យ ។

### ១៣.៤.២ ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

នៅឆ្នាំ២០១០ នេះ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារអភិវឌ្ឍន៍ អាស៊ីលើកម្មវិធីការងារនៃផែនការ "យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥"ធនាគារជាតិនៃកម្ពុជា ដែលជាភ្នាក់ងារប្រតិបត្តិគម្រោង រួមជាមួយបណ្តាក្រសួងពាក់ព័ន្ធនានា បានបន្តអនុវត្តកំណែទម្រង់នៅក្នុងកម្មវិធីឥណទាន អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទី២ (ធFSPL II) ។ កម្មវិធីឥណទាននេះមានទឹកប្រាក់ ៤០ លានដុល្លារអាមេរិក និងត្រូវបាន បែងចែកជា ៤ អនុកម្មវិធី ដែលអនុវត្តចាប់ពីខែកញ្ញា ឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ

២០១០។ អនុកម្មវិធីនីមួយៗក្រសោប នូវកំណែទម្រង់លើផ្នែកសំខាន់ៗនៃវិស័យធនាគារនិង ហិរញ្ញវត្ថុ ដែលត្រូវអនុវត្តជាដំណាក់កាលៗ ។ កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានទទួលការ បើកផ្តល់ឥណទានចំនួន ៣ ដង រួចមកហើយ ដែលមានទឹកប្រាក់សរុបចំនួន ៣០ លានដុល្លា អាមេរិក បន្ទាប់ពីបានបំពេញចប់នូវកំណែទម្រង់មួយចំនួននៅក្នុងអនុកម្មវិធីទី ១ ទី២ និងទី៣ ។ កាលពីថ្ងៃទី ៥ ខែតុលា ឆ្នាំ២០១០ ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាដែលមានធនាគារជាតិនៃ កម្ពុជាជាតំណាង បានចុះហត្ថលេខាជាមួយធនាគារ អភិវឌ្ឍន៍អាស៊ីលើកំណត់ហេតុនៃកិច្ចចរចា ឥណទាននិងជំនួយឥតសំនង នៅទីក្រុងម៉ានីឡាប្រទេសហ្វីលីពីន ដោយធនាគារ អភិវឌ្ឍន៍ អាស៊ីសន្យាផ្តល់ឥណទានចំនួន ១៥លានដុល្លារអាមេរិក ជាប្រាក់កម្ចីមានអត្រាការប្រាក់ ១,៥% ក្នុងមួយឆ្នាំ និង ៥លានដុល្លារអាមេរិកទៀតជាជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

កំណែទម្រង់នៃអនុកម្មវិធីទី៤ បានផ្តោតលើការងារដូចជា ការអភិវឌ្ឍប្រព័ន្ធទូទាត់សង ប្រាក់ ការកែប្រែប្រព័ន្ធ ចែករំលែកព័ត៌មានឥណទានអោយទៅជាការិយាល័យឥណទាន ការ ជំរុញការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ការធ្វើវិសោធន កម្មច្បាប់ស្តីពីគ្រឹះស្ថានធនាគារហិរញ្ញវត្ថុ និង ការលើកកំពស់ប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាដើម ។

ទន្ទឹមនឹងនោះ ដោយមានជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ីធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងគណៈកម្មាការមូលប័ត្រកម្ពុជា បានឯក ភាពផ្តួចផ្តើមធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០០៧ អោយទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យនិងតំរូវការនាពេលអនា-គត។ លើសពីនេះទៀត ក្រុមការងារបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងសិក្សាដើម្បីរៀបចំសំណុំកម្មវិធី ឥណ ទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទី៣ (FSPL II) សម្រាប់ឆ្នាំ ២០១១ តទៅទៀត ។

## ១៣.៥.ទំនាក់ទំនងជាមួយអាស៊ាន

### ១៣.៥.១.សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន

ក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន ធនាគារជាតិនៃកម្ពុជាបន្តគាំទ្រការប្តេជ្ញាក្នុងតំបន់ ចូលរួមយ៉ាងយកចិត្តទុកដាក់ និងជាប្រចាំក្នុងកិច្ចប្រជុំថ្នាក់នយោបាយ និងបច្ចេកទេសសំខាន់ៗ ។ គណៈប្រតិភូជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជាបាន ចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាល ធនាគារកណ្តាលអាស៊ានលើកទី៦ កិច្ចប្រជុំថ្នាក់ទេសាភិបាលរងធនាគារកណ្តាល និង ហិរញ្ញវត្ថុ របស់អាស៊ានលើកទី១៨ និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀតក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ក្នុងចំណោម អាស៊ាន១០ ព្រមទាំងអាស៊ាន + ៣ (ចិន ជប៉ុន និងកូរ៉េ) ដែលបានរៀបចំឡើង នៅថ្ងៃទី ៤-៨ ខែ មេសា ឆ្នាំ២០១០ នៅប្រទេសវៀតណាម។ ជាលទ្ធផលនៃកិច្ចប្រជុំចង្អុល ចម្បងបី រួមមានការអភិវឌ្ឍទីផ្សារទុនសេរីភាវូបនីយកម្ម គណនី ដើមទុន និងសេរីភាវូបនីយកម្មវិ ស័យហិរញ្ញវត្ថុ ។

ទន្ទឹមនោះ ការចរចាជុំទី៥នៃការបើកចំហវិស័យហិរញ្ញវត្ថុក៏បានចាប់ផ្តើមឡើងដែរ ហើយគ្រោងនឹងបញ្ចប់នា ដំណាច់ឆ្នាំនេះ ។

លើសពីនេះ អាស៊ានកំពុងរៀបចំ "ផែនការយុទ្ធសាស្ត្ររយៈកាល១០ឆ្នាំ សម្រាប់សមាហរណកម្មអាស៊ាន ២០១១-២០២០"លើវិស័យហិរញ្ញវត្ថុ រួមទាំងប្រព័ន្ធទូទាត់ក្នុងតំបន់ផងដែរ ។ ផែនការយុទ្ធសាស្ត្រនេះរំពឹងថានឹង ធ្វើការអនុម័តនៅខែមេសា ឆ្នាំ ២០១១ ខាងមុខ ។

## ១៣.៥.២ សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន + ៣

នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន + ៣ ការបង្កើតមូលនិធិរួមក្នុងតំបន់ហៅថា "ពហុនីយកម្ម គំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)" ដែលជាកិច្ចសម្របសម្រួលស្វប់ពហុភាគីរវាងប្រទេសអាស៊ាន + ៣ និង អាជ្ញាធរ រូបិយវត្ថុហុងកុង មានវឌ្ឍនភាពជាច្រើន។ មកទល់បច្ចុប្បន្ននេះ "កិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ" បានចូលជាធរមានរួចរាល់ហើយសម្រាប់ប្រទេសអាស៊ាន + ៣ និង អាជ្ញាធររូបិយវត្ថុហុងកុង និងបានប្រកាសជា ផ្លូវការនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនៅទីក្រុងតាស្សកិនកាលពីដើមខែឧសភា ឆ្នាំ២០១០ កន្លងមកនេះ ។ ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (AMRO) ដែលជាសេនាធិការសំខាន់នៃ CMIMនេះមានទីតាំង នៅប្រទេសសឹង្ហបូរី ។

បន្ថែមលើកិច្ចខិតខំខាងលើនេះ ប្រទេសអាស៊ាន + ៣ ក៏បានប្រឹងប្រែងផងដែរ ឆ្ពោះទៅអនុវត្តគំនិតផ្តួចផ្តើម ទីផ្សារសញ្ញាប័ណ្ណអាស៊ាន ។ គំនិតផ្តួចផ្តើមនេះមានគោលដៅអភិវឌ្ឍន៍និងពង្រឹងរូបិយវត្ថុ និងទីផ្សារសញ្ញាប័ណ្ណ ក្នុងតំបន់ ដើម្បីអនុញ្ញាតអោយមានការប្រើប្រាស់សញ្ច័យរបស់ប្រទេសអាស៊ីផ្ទាល់។ ដើម្បីសម្រេចនូគោលដៅនោះ ប្រទេសអាស៊ាន រួមជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើតនូវ "យន្តការធានាលើឥណទាននិងវិនិយោគ" ក្នុងគោលបំណងបង្កើន ការផ្តល់ឥណទានព្រមទាំងជំរុញការធ្វើវិនិយោគតាមរយៈការផ្តល់លទ្ធភាពចំពោះវិស័យឯកជនណា ដែលមានគុណវឌ្ឍិ អោយអាចបោះផ្សាយមូលប័ត្រនៅលើទីផ្សារសញ្ញាប័ណ្ណជារូបិយវត្ថុតំបន់ ហើយដូចនេះអាចជៀសវាងបាននូវអតុល្យភាព រូបិយវត្ថុ និងឥណប្រតិទានតាមរយៈការបោះផ្សាយនៅក្នុងតំបន់ ។ ខ្លឹមសារនៃកិច្ចព្រមព្រៀងបង្កើតយន្តការនេះ បានឯកភាព និងប្រកាសជាផ្លូវការរួចហើយនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនៅទីក្រុងតាស្សកិន ខែឧសភា ឆ្នាំ ២០១០ កន្លងមកនេះ ដែលរំពឹងថានឹងចុះហត្ថលេខាឆាប់ៗខាងមុខនេះ ។

## ១៣.៦.ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ស៊ាសិន SEACEN)

សមាជិកភាពរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងមជ្ឈមណ្ឌលស៊ាសិន (SEACEN) បានផ្តល់ឱកាសជាច្រើន ចំពោះធនាគារជាតិនៃកម្ពុជាការបណ្តុះបណ្តាលធនធានមនុស្ស និងការស្រាវជ្រាវលើវិស័យហិរញ្ញវត្ថុ និងធនាគារ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងជំនឿទុកចិត្តលើប្រតិបត្តិការនៃធនាគារកណ្តាលជាសមាជិកក្នុងការអនុវត្តគោល នយោបាយរូបិយវត្ថុ និងពង្រឹងវិស័យធនាគារ ។

ដើម្បីពង្រឹងនូវកិច្ចសហប្រតិបត្តិការជាមួយបណ្ដាសមាជិកនៃមជ្ឈមណ្ឌលស៊ាសិន ធនាគារជាតិនៃកម្ពុជា មាន កិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទថ្នាក់ទេសាភិបាលលើកទី៤៥ និងកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល លើកទី២៩ កាលពីថ្ងៃទី ២៦-២៧ ខែកុម្ភៈ ឆ្នាំ២០១០ នៅខេត្តសៀមរាប ក្រោមប្រធានបទស្តីពី "តួនាទីរបស់ ធនាគារកណ្តាលក្នុងការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយចីរភាពក្រោយពេលមានវិបត្តិ និងការសម្រេចបាននូវស្ថិរភាព ហិរញ្ញវត្ថុ" ។

ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយមជ្ឈមណ្ឌលស៊ាសិន រៀបចំសិក្ខាសាលាពីរ ស្តីពី "គោលការណ៍គ្រឹះនៃការគ្រប់គ្រងទ្រព្យសកម្ម/បំណុល"កាលពីថ្ងៃទី ២-៧ ខែឧសភា ឆ្នាំ២០១០ និងស្តីពី "ការគ្រប់ គ្រងហានិភ័យរបស់ធនាគារកណ្តាល" កាលពីថ្ងៃទី ១-៦ ខែសីហា ឆ្នាំ ២០១០ នៅខេត្តសៀមរាប ។

ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូន មន្ត្រីជាបន្តបន្ទាប់អោយចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំសំខាន់ៗនានា នៅក្នុក្របខ័ណ្ឌសហប្រតិបត្តិការស៊ាសិន ដែលបានប្រព្រឹត្តទៅនៅបណ្តាប្រទេសសមាជិកស៊ាសិនផងដែរ ។

លើសពីនេះទៀត នាពេលបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងត្រៀមរៀបចំទទួលធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំ គណៈកម្មការប្រតិបត្តិនៃមជ្ឈមណ្ឌលស៊ាសិន (EXCO) លើកទី៩ ដែលនឹងធ្វើឡើងនៅថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១១ ខាងមុខនេះ ។

៣.៥.ទំនាក់ទំនងជាមួយសមាគមន៍ធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (Francophone ហ្វ្រង់កូហ្វូន )

សមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង ហ្វ្រង់កូហ្វូន បានបង្កើតឡើងតាមគំនិតផ្តួចផ្តើម របស់ធនាគារកណ្តាលបារាំង និងមានធនាគារកណ្តាលចំនួន៥៤ ប្រទេសជាសមាជិក ។ ធនាគារជាតិនៃកម្ពុជា បានចូលជា សមាចជិកនៃសមាគមនេះតាំងពីឆ្នាំ ១៩៩៣ និងបានរក្សាសមាជិកភាពនោះមកទល់បច្ចុប្បន្នក្នុងគោលបំណងពង្រឹង ទំនាក់ទំនងផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានទៅវិញទៅមក និង ស្វែងរកការជួយឧបត្ថម្ភពីសំណាក់ធនាគារកណ្តាល ជាដៃគូ ជាពិសេសលើវិស័យបណ្តុះបណ្តាលធនធានមនុស្ស និងទំនាក់ទំនងធនាគារ។ កន្លងមកថ្នាក់ដឹកនាំជាន់ខ្ពស់នៃ ធនាគារជាតិនៃកម្ពុជា តែងចូលរួមជាប្រចាំនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់សមាគមហ្វ្រង់កូហ្វូន ដែលនៅក្នុងឱកាសនោះ ធនាគារជាតិនៃកម្ពុជា តែងត្រូវបានអញ្ជើញអោយធ្វើបទអន្តរាគមន៍លើប្រធានបទនានាពាក់ព័ន្ធនឹងគោលនយោបាយ រូបិយវត្ថុ ការគ្រប់គ្រងប្រព័ន្ធធនាគារ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុជាដើម ។

នៅក្នុងកិច្ចប្រជុំលើកទី១៧ កាលពីថ្ងៃទី ១២-១៥ ខែឧសភា ឆ្នាំ២០១០ នៅទីក្រុងម៉ុងត្រេអាលប្រទេស កាណាដា ប្រទេសជាសមាជិកហ្វ្រង់កូហ្វូនបានផ្តល់កិត្តិយសជូនធនាគារជាតិនៃកម្ពុជាអោយធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំ លើកទី១៨ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១-១៣ ខែឧសភា ឆ្នាំ២០១១ នាខេត្តសៀមរាប ។

# មេរៀនទី ១៤
# តុល្យការសេដ្ឋកិច្ច (១៩៥០~១៩៧០)

ក្នុងអាណត្តិនៃការវិភាគទាំងនោះ គិតទៅដល់សភាពការណ៍ គឺការចេញដំណើរនិងលទ្ធភាពសេដ្ឋកិច្ចនៃប្រទេសសេដ្ឋកិច្ចនៃសង្គមកម្ពុជា រវាងឆ្នាំ ១៩៨០ ទៅដល់ ១៩៧០ គឺមានការគ្រប់គ្រងត្រឹមត្រូវទាំងអស់។ ប្រទេសទទួលបានភាពរុងរឿង រូបិយប័ណ្ណ នៅតែស្ថេរភាព ផលិតកម្មកសិកម្ម មានកំណើនសម្ភារឧស្សាហកម្មមានតែការអភិវឌ្ឍ។ គេគ្រាន់តែធ្វើសេចក្ដីយោបល់ លើបញ្ហាពីប្រសិទ្ធភាព ពីនយោបាយ សេដ្ឋកិច្ច នៃយុវរាជាណាចក្រឯករាជ ជារចនាសម្ព័ន្ធ សភាពការណ៍ពេលនោះ គឺសុខសប្បាយណាស់ ហើយអត្រានៃកំណើនការវិវឌ្ឍរកលំនឹង ហើយគ្រប់ផ្នែកនៃសេដ្ឋកិច្ច កំពុងពេញរីកចម្រើន ឬ បានស្ដារ ដោយគួរឱ្យមានជំនឿ ដូចជាវិស័យទេសចរណ៍ជាដើម។

បើកុំឱ្យមានព្រឹត្តិការណ៍ ១៩៧០ សភាពការរីកចម្រើន នៃបណ្ដាឆ្នាំ ១៩៦០ នៅបន្តមិនចប់ទេ ។ យើងក៏មិនជឿតាមការអះអាងទាំងនោះដែរ ដែលមិនសង្កត់លើការសិក្សាពិស្ដារណាមួយនោះ មុនមានរដ្ឋប្រហាប៉ុន្មានខែមុននោះ។ ចំពោះការវិភាគត្រូវមានមាត្រាដ្ឋាន ដែលនាំទៅរកគំនិតផ្ទុយវិញ។ តើយើងត្រូវទទួលស្គាល់ថា មានវិបត្តិថវិកា និងហិរញ្ញវត្ថុដែលជាក់ស្ដែងមានការទាក់ទងទៅនឹងជោគជ័យនៃនយោបាយ អភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គមនោះទេ។

បើវិបត្តិឆ្នាំ ១៩៥០ មិនបានទៅភ្ជាប់ជាមួយនិងសភាពការណ៍ សេដ្ឋកិច្ចគេនៅពន្យល់ថាដូចម្ដេចបានជាកម្ពុជាធ្លាក់ខ្លួនយ៉ាងស្រាល ទៅក្នុងវិបត្តិនោះ។ ក្នុងបំណងវិភាគបែបនេះគេមិនត្រូវបដិសេធចោលនៅការបញ្ជាក់សារៈសំខាន់នៃបញ្ហាទាំងពីដូចខាងក្រោមនោះទេ។ ក្នុងទស្សនៈវិស័យយូអង្វែងមួយលំនឹងប្រវត្តិសា-ស្ត្រនិងវប្បធម៌នៃសង្គមកម្ពុជា ជាកត្តានៃមូលហេតុបន្ទាប់គឺតួនាទីនៃសង្គមវៀតណាមនិងការចូលរួមរបស់សហរដ្ឋអាមេរិក។

## ១៤.១.តុល្យការសង្គមវប្បធម៌

១.ជាមួយនិងសតវត្សទី២០ ជនធ្វើមខ្មែរ ត្រូវឆ្លងជាបន្តបន្ទាប់នៅការធ្លាក់ចុះនៃជំងឺនយោបាយនៃការនិយមពិភពលោកខាងលិច ទីមួយគំរូប្រជាធេបតេយ្យសភានិយម និងមួយទៀតគំរូម៉ាស៊ីល បដិវត្តន៍។

គេកត់សម្គាល់ឃើញនៅជំងឺនេះ មានបន្តនៅប្រវត្តិសាស្ត្រ នៃការចូលរួមមនោគមវិជ្ជា នៃគ្រួសារធំៗមួយចំនួនរបស់ខ្មែរហើយនិងពួកអតិថិជន ពួកបន្តវង្សត្រកូលនៃគ្រួសារជួនមុំ នៃព្រះអង្គម្ចាស់វង្សចម្រើន។ល។ ការបន្តក៏បានប្រព្រឹត្តទៅនៅពេលសម័យឯករាជផងដែរ ដោយហេតុនៃលក្ខណៈបរទេស និងការលាយចូលគ្នានៃគំរូទាំងនោះឱ្យទៅជារចនាសម្ព័ន្ធ នៃគ្រប់របៀបរបបនៃសង្គមខ្មែរដែលមានការលំបាកខ្លាំងក្នុថការរកនិយមន័យជាថ្មីក្នុងកុងសង់សួស សង្គម

នយោបាយ ។ ការលោបពណ៌នៃស្ថាប័នជា សមាគមប្រជារាស្ត្រ មួយឈ្មោះថាប្រព្រឹត្តក្នុងពេលមួយដូចជាបក្សតែមួយមិនអាចឈានទៅរកគុងសង់សួស ក្នុងរយៈពេលជាង១០ឆ្នាំ។

**២.ទី២ គឺបញ្ហាគ្រប់គ្រងក្របខណ្ឌ**

ព្រះរាជាណាចក្រឯករាជ្យ មិនទាន់ចេះ គ្រប់គ្រងបណ្ដុះបណ្ដាល និងធ្វើឱ្យទំនើបភាវូបនីយកម្មនៃក្របខណ្ឌរបស់ខ្លួនឡើង។ ដោយមានបំណងចង់កែលម្អរាល់រចនាសម្ព័ន្ធ ដោយយុត្តធម៌មានទាន់សមស្រប ប្រទេសកម្ពុជានៃសង្គមរាស្ត្រនិយម បានបណ្ដុះបណ្ដាលតែមន្ត្រីរាជការខ្មែរកាត់ចិន តាមបែបទីក្រុងនៅចំពោះមុខមហាប្រជាជនជនបទដែលជាកសិករ ចេញពីស្រែបណ្ដុះបណ្ដាល ឬចាក់ពុម្ពតាមវិស័យអប់រំ តាមគំរូបារាំងចាស់ កម្រិល។ គំរូអប់រំសិក្សាបែបនោះនាំទៅបង្កើត នូវភាពឥតការងារធ្វើ នៃបញ្ញវន្តដែលពេលខ្លះដាច់ខ្លួន ចេញពីប្រភពឫសគលរបស់ខ្លួនហើយគ្មានទីតាំងនៅក្នុងសង្គមថ្មី ដែលកំពុងកសាងនៅក្រោយភ្នែកខ្លួនតាមសង្វាក់នៃការអភិវឌ្ឍសេដ្ឋកិច្ច។

**៣.ទី៣ និយាយពីមូលដ្ឋានប្រជាជន**

ក្នុងអាណត្តិនៃអភិក្រមដែលវិបត្តិសម្បជ្ជញ្ញនៃមេដឹកនាំបានកើនភាពតឹងតែង តាមរយៈវិបត្តិសីលធម៌ នៃក្របខណ្ឌកម្មាភិបាល ផលប៉ះពាល់នៃសង្រ្គាម អាមេរោគបានធ្វើឱ្យបាក់ស្រុតទៅ នៃបរិយាកាសដ៏សុខសាន្តនៃសង្គមនិងវប្បធម៌ទម្លាក់មហាជននៃស្រទាប់ក្រោម និងបណ្ដាលឱ្យធ្លាក់ទៅក្នុងទុក្ខវេទនាក្នុងកម្រិតមួយធ្ងន់ធ្ងរ។

ពេលវេលាដែលត្រូវកសាងសេដ្ឋកិច្ចដ៏សមស្រប និងវិជ្ជមានបានឆ្លៀតពីនិន្នាការតំបន់បែបជាកើនឡើងនៅភាពតឹងតែងសង្គមវប្បធម៌ ដែលបើកចំហឱ្យអន្តរាគមន៍សហរដ្ឋអាមេរិកនៅឆ្នាំ ១៩៧០ ហើយភ័យអន្តរាយបានបន្តបំផ្លាញប្រទេស។

អ្វីពុំដែលកើនឡើងពីឆ្នាំ ១៩៧០ គឺសម័យប្រវត្តិសាស្ត្រនៃភាពរំជួល រវាងផលវិបាកពីរនៃភាពស្ងប់ស្ងាត់ ដូចការបំបាក់នូវរបៀបរាបរយសង្គម។ ការបំបាក់នេះធ្វើឱ្យឃើញនៅកម្រិតបីនៅការរីករាលដាលនៃសង្គ្រាម តាមរយៈវិភាគនៃប្រវត្តិសាស្ត្រ តាមរយៈបារាំង នៃសម្ភារនិយមបរទេស នៃព្រឹត្តិការណ៍ជាជម្រៅ នៃវិបត្តិវប្បធម៌ដ៏ធ្ងន់ធ្ងរ។

## ១៤.១.១.ការប៉ះទង្គិចសេដ្ឋកិច្ច

**ក.បញ្ហារូបិយវត្ថុ**

ដោយមិនចូលជ្រៅក្នុងរឿងពិស្ដារ នៃតុល្យការសេដ្ឋកិច្ច នៃបែបសាធារណរដ្ឋ គេរក្សាការវិភាគលើការបញ្ជាក់ពីរូបិយវត្ថុ។ ជាមួយសង្គ្រាមលុយរៀលផ្ទុយទៅវិញមិនរឹងមាំដូចប្រាក់សម័យរាជានិយមទេ ព្រោះរយៈពេលសង្គ្រាមពីរឆ្នាំលុយបានរអិលពី ៥០ - ៥៥ ទៅ ៨៤ រៀល/មួយដុល្លារគឺចុះថ្លៃ ១/៣ ប៉ុណ្ណោះ ។

សង្គ្រាមចេះតែបន្តភាពអន្តរាយនៃម៉ាស៊ីនសេដ្ឋកិច្ច ធ្វើឱ្យលុយរៀលមានអតិផរណាកាន់តែលឿន។ នៅចុងឆ្នាំ១៩៧៤ ជាឆ្នាំដែលមានទិន្នន័យច្បាស់លាស់ក្នុងមួយដុល្លារ ថ្លៃ

១.៦០០រៀល ។គេមិនយល់សោះថាហេតុដូចម្តេចបានជាពួកខ្មែរក្រហមដែលទាមទាអំពីទំហំនៃវិស័យកសិកម្ម និងការចាយប្រាក់មុននៃគំរូវប្បធម៌ខ្មែរ បែរជាលុបបំបាត់ប្រាក់ទៅវិញ។

### ខ.ភាពអន្តរាយពីរដងនៃហេដ្ឋារចនាសម្ព័ន្ធភាពអន្តរាយនៃឧបករណ៍បច្ចេកទេស និងក្របខណ្ឌមនុស្ស

លទ្ធផលនៃសង្គ្រាម និងការកាន់អំណាចខ្មែរក្រហម គឺជាការបំផ្លាញសឹងតែទាំងស្រុងនៃសរសៃផលិតកម្មផ្នែកឧស្សាហកម្មបើអង្គធំពុំគ្រាន់តែសង្រួមការងារសេដ្ឋកិច្ច ឬឈប់ផលិតសរសៃឧស្សាហកម្មស្រាល ដោះម៉ាស៊ីនសម្ភារៈ...ដើម្បីយកទៅធ្វើរោងចក្រដែលហៅថា រោងចក្រប្រជាជន គ្រប់គ្រងដោយជនល្ងិតល្ងង់ និងកុមា។ ឧទាហរណ៍នៃប្រពន្ធ័ផ្លូវអាចផ្តល់ជាគំនិតនៃភាពអន្តរាយ នៃហេដ្ឋារចនាសម្ព័ន្ធ។ ផ្លូវចាក់ក្រាលកៅស៊ូមានតែមួយភាគប្រាំស្ពានចំនួន ៤.១០០ ភាគច្រើនត្រូវបំផ្លាញ។ សរសៃនៃទីក្រុងត្រូវកាត់ផ្តាច់ហើយនេះ តែខូចខាតទៅដោយសារគ្មានការថែរក្សា( ទូរស័ព្ទ លូទឹក អគ្គិសនី) ។ ទីបញ្ចប់ ឧបករណ៍រដ្ឋបាល និងហិរញ្ញវត្ថុត្រូវបំផ្លាញ (សួរឃោដី ឯកសារ សារពើភ័ណ្ឌ ធនាគារ ។ល។) ។ ចំពោះក្របខណ្ឌដោយធនាដល់ទំនើបភាវូបនីយកម្មបានបាត់បង់ស្លាប់ ឬរត់ចោលស្រុក។ ក្រោយរបបខ្មែរក្រហមនៅសល់តែពីភាគរយនៃក្របខណ្ឌរដ្ឋបាលបច្ចេកទេសប៉ុណ្ណោះ។

## ១៤.១.២.ភាពអន្តរាយនៃបរិស្ថាន

ការបំផ្លាញរបស់ខ្មែរក្រហមក្នុងនាមការប្រមូលផ្តុំកម្លាំងស្តារ និង ជំរុញវិស័យកសិកម្មគ្មានបានផលអ្វីទាំងអស់គឺគ្រាន់តែនាំទៅដល់ការព្រោះដី។

ពួកខ្មែរក្រហមក៏ចង់អនុវត្តន៍នូវ ទិន្នផលខ្ពស់ពីវិស័យកសិកម្ម ក៏បង្ខំមនុស្សធ្វើការដូចអ្នកទោសក្រោមពាក្យស្លោកអ្វី ដើម្បីជាវាសាស្ត្រ ដែលនាំទៅដល់ការរំលោភលើលំនឹងនៃបរិស្ថាន។ ការពង្រីកភ្លឺស្រែ ពីប្រពៃណីនៃភ្លឺស្រែតូចៗ មកជាផ្ទៃដីធំៗ បួនជ្រុងទ្រវែង និងការរៀបចំប្រឡាយត្រង់ៗធ្វើឱ្យស្រែក្លាយជាវាលខ្សាច់។ល។

មិនត្រឹមតែការផ្តើមគំនិតបែបនេះ ជាអវិជ្ជមាននោះទេតែជាផលប៉ះពាល់ធ្វើឱ្យមានការរៀបចំឡើងវិញនៅភ្លឺប្រឡាយកែធម្មជាតិឡើងវិញ ហើយកាន់តែនាំទៅដល់ការប៉ះទង្គិចយ៉ាងខ្លាំងថែមទៀតដល់បរិស្ថានបាត់របបទឹកទូទៅបឹងទន្លេសាបកាន់តែជាក់ទៅធ្វើឱ្យខូចដល់ចរាចរណ៍របស់ទឹករវាងទន្លេមេគង្គ និងទន្លេសាបក្នុងពេលដែលពូជរុក្ខជាតិជាច្រើនបានបាត់ពូជបីសេសពូជស្រូវ និងពោតដែលជាពូជទ្រាំទ្រដល់សេចក្តីត្រូវការនៃទីផ្សារកណ្តាល។

រឿងនេះហួសពីជំនឿទៅទៀតគឺការបំផ្លាញព្រៃឈើនាំទៅដល់ជាង១០ឆ្នាំមកហើយ នូវការរាំងស្ងួតនឹងទឹកជំនន់។ ព្រៃឈើជាង ២/៣ បានបំផ្លាញនាំទៅដល់ភាពខ្សោះនៃស្រទាបដីដីការព្រោះដីទឹកជំនន់រាំងស្ងួតរដូវភ្លៀងកាន់តែខ្លី។ល។ តើដល់ចំណុចណាទៅដែលត្រូវស្តារឡើងនូវប្រព័ន្ធផ្នែកកសិកម្មជាមូលដ្ឋាននៃសេដ្ឋកិច្ចកម្ពុជាដែលមានភាពពិការយ៉ាងធ្ងន់ធ្ងរ ដោយសារចំការមីន ១០ លានគ្រាប់។

### ១៤.១.៣.ប៉ះពាល់ខាងប្រជាសាស្ត្រ

សង្គ្រាមនៃបទពិសោធន៍ខ្មែរក្រហម លើពីភាពព្រៃផ្សៃយទៅទៀតនោះ គឺជាឧបសគ្គសេដ្ឋកិច្ចដែលធ្វើវិចរិលដល់សក្តានុពលនៃប្រពន្ធ័នោះ ហើយផ្ទុយទៅវិញប្រជាពស្ត្រ្តបានរីកចម្រើនឡើងវិញ។

ប្រជាពស្ត្រ្តជាប្រភពនៃពលកម្មនោះត្រូវធ្វើអង្កេតស្ថិតិលទ្ធផលនៃស្ថិតិបច្ចុប្បន្ន នៃដំណើរសន្តិភាពរបស់ អ.ស.ប.។

## ១៤.២.តុល្យការបរិមាណ

រវាងឆ្នាំ ១៩៧០ និង ឆ្នាំ១៩៨០ ដែលជាឆ្នាំបញ្ចប់នៃរបបខ្មែរក្រហមប្រជាជនបានបាត់បង់ប្រហែល ១លាននាក់នៅសល់ ៦.៤ លាននាក់នៅឆ្នាំ១៩៨០។ ការបាត់បង់ប្រជាជនមានពីដំណាក់កាល៖

- ៣% នៃផលិតផលនាំចេញផ្សេងៗទៀត សុទ្ធតែជាផលិតផលមិនអាចដឹងពិតប្រាកដ។

ការវិវដ្តនៃផ្នែកសំខាន់ៗ

បើស្រូវ និង កៅស៊ូ មានសារៈសំខាន់ដល់កម្រិតខ្ពស់ នៅឆ្នាំ ១៩៦១ ការនាំចេញ កសិផលទាំងពីរប្រភេទវិវដ្តន៍ជាប្រព័ន្ធផ្ទុយគ្នា ៖

- នៅបណ្តាឆ្នាំ ១៩៥០ កៅស៊ូ ៥០% បាននាំចេញ គឺស្មើនឹងទ្វេដងនៃតម្លៃនាំអង្ករចេញ ២៥%
- ដល់ឆ្នាំ ១៩៥០ សភាពការណ៍ផ្ទុយមកវិញ ព្រោះកៅស៊ូបាននាំចេញតែជាង២០% ។
- ចំពោះ ៣០% ដែលនៅសល់ ការនាំចេញរួមមាន៖
- ពោត ដែលការនាំចេញថយចុះឃើតៗ តែនៅតែមាននាំចេញជាប្រចាំពី ១៥% ទៅ ១០% ។
- កសិផលផ្សេងៗទៀត ដែលភាគចំណែកកើន ១/៤ គឺជា ១៥% ទៅជិត ២០% ។

នៅក្នុងថាមពលនេះ គេយល់ថា ពួកខ្មែរក្រហមជឿដល់អនាគតកម្ពុជា លើវិស័យស្រូវអង្ករ ។ ការនាំស្រូវចេញ ឃើញមានតម្លៃស្ថេរភាព ។

### បន្លែ

បន្លែហាក់ជាមានសភាពដូចពោតដែរគឺផ្តល់នៅប្រាក់ចំណេញដល់កសិករ ។ បើបរិមាណផលិតផលពោតនិងបន្លែកើនស្មើគ្នានៅឆ្នាំ ១៩៨០ ផលិតផលបន្លែកើន១០ដងក្នុងពេល១០ឆ្នាំក្នុងអាណត្តិនិន្នាការលើសពី ១១០,០០០តោន ដល់ជិត ២២០,០០០ តោន ។

កំណើនខាងបារាំងជះឥទ្ធិពលដល់តម្លៃផងដែរ ។ ផ្ទៃដីផលិតផលរុក្ខជាតិក្រៅពីស្រូវមាននិន្នាការ ថយចុះដំណាំចំការនាំមកនៅចំណូលខ្ពស់គឺ បានការបញ្ជាទិញពីទីក្រុង។

- តុល្យការនៃកសិកម្ម

តុល្យការបរិមាណ

បើតួលេខបញ្ជាក់បកស្រាយទាំងស្រុងនៃការកើនឡើននៃផលិតផលជាមូលដ្ឋាន នោះស្រូវនិងការនេសាទត្រូវនៅមានការខ្វះខាត។ ត្រូវទទួលស្គាល់ថាការលំបាក់ក្នុងកម្រិតមធ្យមនៃសេចក្តីត្រូវការមនុស្សម្នាក់ៗនៅទាប។

ផលិតផលតែមួយដែលបានឃើញកំណើនពិត គឺផលិតផលបន្លែមនោះគឺបន្លែប៉ុន្តែសារៈសំខាន់របស់វានៅទាបណាស់សម្រាប់ជាមូដ្ឋាននៃសេដ្ឋកិច្ចជាតិ ។ ក្រោយឆ្នាំ១៩៨៧ ក្រោយពីមានការបង្ខិលញាប់នៃចម្លងការពាណិជ្ជកម្មនិងទីផ្សារនៅទីក្រុងផលិតផលបន្លែក៏កើនឡើងយ៉ាងរហ័ស ។

ផ្នែកកសិកម្មជារចនាសម្ព័ន្ធស្ថិតនៅឧនភាពខ្លាំង ទោះបីផ្នែកខ្លះមានកំណើនទាក់ទងនិង Boom នៃឆ្នាំចុងក្រោយនេះក៏ដោយ។

- តុល្យការរចនាសម្ព័ន្ធ

តិចណាស់ការពិនិត្យលើផ្នែកផលិតកម្មកសិកម្ម អាចឱ្យរក្សាបានរចនាសម្ព័ន្ធកសិកម្មឈរលើមូលដ្ឋាននៃនិន្នាការមធ្យមនៅជុំវិញបណ្តាលឆ្នាំ ១៩៩០ គេសន្និដ្ឋានថា៖

ផ្ទៃដីស្រូវដែលមានផ្ទៃដី ៩០% ផ្តល់ ២/៣ នៃកសិផលតម្លៃ

កៅស៊ូនិងផលិតផលសត្វ ចិញ្ចឹមនិងនេសាទ មានចំ ២០%សមាមាត្រនិងផ្នែកទាំងពីរនៃផលិតផលមានភាពផ្ទុយគ្នាផលិតផលកៅស៊ូមានភាពថយចុះប្រៀប និងកំណើនផលិតផលសត្វ ។

ផលិតផលរុក្ខផលបំពេញបន្ថែម ពោត ផ្លែឈើ និងបន្លែ គរ ដំណាំ ក្រវ៉ាញ...មាន២៥% ។

| តារាងសំយោគ | ផ្ទៃដីដាំដុះ(លានហិចតា) | ផលិតផល(លានតោន) | %ផលិតផលកសិកម្ម |
|---|---|---|---|
| ស្រូវ | ១.៩ | ២.២ | ៦៦% |
| កៅស៊ូ | 0.0៥ | 0.0៤ | ១0% |
| ផលិតផលសត្វ | 0.0៥ | 0.0៤ | ១0% |
| កសិផលដ៏ទៃទៀត | 0.១៧ | 0.0៤ | ១៥% |

ដោយធ្វើការប្រៀបធៀបតួលេខទាំងនេះទៅនឹងនិន្នាការនៅឆ្នាំ ១៩៧0 ដែលត្រូវបានផ្តល់ ៥0% នៃផលិតផលកសិកម្មហើយផ្នែកទីមួយនេះផ្តល់ ៣៧% នៃផលទុនដុលសារុបអាចទាញចេញនៅឆ្នាំ ១៩៩0 នៅផ្នែកតម្លៃនៃកសិកម្មនៅផលទុនដុលជាតិទាបជាងពាក់កណ្តាលនៃឆ្នាំ១៩៧0។

**ក.ផ្នែកទី២**

ដើម្បីវាយតម្លៃរចនាសម្ព័ន្ធផលិតកម្មឧស្សាហកម្ម គេមានប្រភេទនៃប្រភពស្ថិតិច្បាស់លាស់នោះជាផលិតផលឧស្សាហកម្ម នៅក្រោមក្រសួងឧស្សាហកម្ម គិតជាប្រាក់រៀលថេរ មានប្រភពពីរ៖

- ទីមួយ មានភាពមិនដាច់ខាត់ ទៅនិងកម្រិតសរុប នៃផលិតផលនោះ ហើយផលិតផលនោះ មាននិន្នាការ កើនពីឆ្នាំ ១៩៨០ ទៅ ១៩៩១ ។

- ទីពីរ ដែលផ្តល់នៅការសរុបផ្នែកនានា ចាប់ពីឆ្នាំ ១៩៨៤ ក្នុងពេលដែលរៀបចំគណនេយ្យជាតិ ។

**ក.១ ផលិតផលឧស្សាហកម្មសរុប**

- អថេរនៃបរិមាណ

ការវាយតម្លៃថា រៀលនៃផលិតផលឧស្សាហកម្ម មានបរិមាណកើនឡើងខ្លាំងព្រោះមានការគុណនឹង១៥ក្នុងរយៈពេល ១០ឆ្នាំ ហើយគុណនឹង ៣០ ក្នុងរយៈពេល១១ឆ្នាំ។

ការប្តូរជា U.S.ដុល្លារ បញ្ជាក់ថាមានភាពផ្ទុយទៅវិញ គឺហាក់ដូចជាមានការថយចុះ ១៧ លាន U.S.ដុល្លារ នៅឆ្នាំ ១៩៨០ តិចជាង ១៥ លាន U.S.ដុល្លារ នៅឆ្នាំ ១៩៩១ ផលិតកម្មបានថយចុះជាង ១០% ។

ការពិតហាក់ដូចជាមានភាពខុសគ្នាតិចតួច ។ ការចាប់អារម្មណ៍គួឱ្យព្រួយបារម្ភ ដោយកំណត់ព្រឹត្តិការណ៍នៃការវាយតម្លៃនសការថយចុះពីឆ្នាំ១៩៨០ ដល់ ១៩៨៤ ហាក់ដូចជាការបកស្រាយនូវការបន្ថែមជាថ្មីមួយនៃស្ថិតិ ។ ចំការបង្ហាញតួលេខពី១៩៨៤ ដល់ ១៩៩១ គឺដូចជាមានកំណើនតាមការសន្និដ្ឋានគឺ ១១ លានដុល្លារនៅឆ្នាំ១៩៨០ និង ១៧លានដុល្លារ នៅឆ្នាំ ១៩៩១ គឺលើស ៥០% នៃអត្រា កើនដល់ ៤០% ក្នុងមួយឆ្នាំ។

កំណើននោះដូចជាមិនប្រក្រតី គេត្រូវវិភាគជា ៤ ដំណាក់កាល៖

១.ពីឆ្នាំ ១៩៨០-១៩៨៤ មានការថយចុះដែលបញ្ជាក់ពីការបន្ថែមលើស្ថិតិ។

២.ពីឆ្នាំ ១៩៨៤-១៩៨៨ ឧស្សាហកម្មបានស្គាល់នៅកំណើនពីរដំណាក់កាល៖ មុនបង្អស់ពី ១៩៨៤-១៩៨៦ មានកំណើនយឺត ឧស្សាហកម្មកើនពី១២.២លានដុល្លារដល់១៣.១ លានដុល្លារបន្ទាប់មកគឺពី ១៩៨៦-១៩៨៨ កំណើនរហ័សមួយដែលឧស្សាហកម្មកើនពី១៣.១ ដល់១៨.៥ លានដុល្លារ ។

៣.ពីឆ្នាំ១៩៨៨-១៩៩០ ឧស្សាហកម្មបានស្គាស់នៅដំណាក់កាលថយចុះនៃផលិតផលជាថ្មីពី ១៨.៥ មកនៅ ១៣.៦ លានដុល្លារ ។

៤.ពីឆ្នាំ១៩៩០ ឧស្សាហកម្មចាប់ផ្តើមកើនឡើងជាបន្ទាន់ ឆ្លងពី ១៣.៦ លានដុល្លារ ទៅ ១៧.៩ លានដុល្លារ ។

ការវិភាគពីប្រភពមួយផ្សេងទៀត តាមផ្នែកដែលវែងមធ្យម ១៩៨៤-១៩៩១ អាចបញ្ជាក់នៅអ្វីដែលលាក់បំបាំង ក្រោយពីចលនានៃដំណាក់កាលទី៤ ។

### ក.២.វិភាគតាមផ្នែក

**១៤.៧** ក្រឧស្សាហកម្ម មិថុនា ១៩៩២

| លានរៀល | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ |
|---|---|---|---|---|---|---|---|---|
| ឧ.ស្បៀង | ៣៣៨ | ៦២៧ | ៨៦៥.១ | ១៣០៤ | ១៧៤៧ | ១៩០៩ | ៣៦១៨ | ១១០២៩ |
| ឧ.គីមី | ៩០ | ១១៣ | ១៥៦ | ១៣៤ | ២១៣ | ៤១១ | ១០០៩ | ១៨០៤ |
| ឧ.អគ្គិសនី | ២៥៧ | ២៩៥ | ៣០៦ | ៣៥២ | ៤៨២ | ៥៧៨ | ១៤៣១ | ១៣៨២ |
| យន្តសាស្ត្រ | ៥៧ | ៩៨ | ១៣១ | ១៥៤ | ១៣៨ | ១៩៦ | ៧៦៧ | ១២០៦ |
| វាយណភ័ណ្ឌ | ៨៦ | ៩៦ | ១៣៥ | ២១៤ | ២៥៥ | ៤២០ | ៧៥៧ | ៥២៣ |
| ឧ.ផុន ស្រាល | ១៧ | ១៤ | ៦៦ | ៥៦ | ៩០ | ១២៣ | ៣៩៧ | ១១៧ |
| សម្ភា សំណង់ | ១៣ | ១៧ | ៤០ | ៣១ | ៤៥ | ៧១ | ៨១ | ៧៩ |

ដើម្បីឱ្យកាន់តែពិស្តារប្រភពនោះមិនបង្ហាញនៅកំហុសពីរធំៗៈ ទី១ គុណភាព ទី២ បរិមាណ។

១- ប្រភពប្រមូលផ្ដុំ នៅក្រោមប្រភេទដូចគ្នា ឧស្សាហកម្មស្បៀង តត្តភាពសេដ្ឋកិច្ចពីរខុសគ្នា ឧស្សាហកម្មផលស្បៀង និង ឧស្សាហកម្មបារី ។

២-ការប្រមូលផ្ដុំបែបនោះ ធ្វើឱ្យស្រពិចស្រពិលដល់ការវិភាគនៃផលិតកម្មនោះដែលថាផលិតផលបារី តំណាងតែខ្លួនមួយ ៥០% នៃផលិតផលឧស្សាហកម្មសរុប។

### ក.៣.បញ្ហាឱ្យនិយមន័យដល់ឧស្សាហកម្មផលស្បៀង

នៅក្នុងពេលដំបូងគេត្រូវតែដកផលិតកម្មបារីចេញ ដោយនាំប្រភពទាំងនោះគិតជាភាគរយដើម្បីបញ្ជាក់នូវអ្វីជាសរសៃរឈាមនៃឧស្សាហកម្មពិតក្នុងនៃបច្ចេកទេឧស្សាហកម្ម។

| គិតជា% | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ |
|---|---|---|---|---|---|---|---|---|
| បារី ( ១៨ ) | ៣៥ | ៤៤ | ៥៤ | ៤៥ | ៥៣ | ៤៦ | ៤០ | ៦០ |
| ឧ.ផលស្បៀង ក្រៅពីបារី | ៤.២ | ៤៨ | ៤.៧ | ៤ | ៥.៧ | ៥.៤ | ៤.៣ | ១៨.៣ |
| គីមី | ១០.៥ | ៨.៨ | ៩.២ | ៥.៩ | ៧.១ | ១១ | ១២.៣ | ១១.១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ឧ.អគ្គិសនី | ២៩.៨ | ២៣ | ១៧.៩ | ១៥.៦ | ១៦.២ | ១៥.៥ | ១៧.៥ | ៨.៥ |
| យន្តសាស្ត្រ | ៦.៦ | ៧.៧ | ៧.៧ | ៦.៨ | ៤.៦ | ៥.៣ | ៩.៣ | ៨.៥ |
| វាយណភ័ណ្ឌ | ១០ | ៧.៥ | ៧.៩ | ៩.៥ | ៨.៥ | ១១.៣ | ១០.៥ | ៧.៤ |
| ឧ.ធុនស្រាល | ៤៩ | ២.៧ | ៣.៩ | ២.៥ | ៥ | ៣.៣ | ៤.៨ | ០.៧ |
| សម្ភារសំណង់ | ១.៥ | ១.៣ | ២.៤១ | ១.៣ | ១.៥ | ១.៩ | ០.៩ | ០.៤ |

| លានដុល្លារ (១៩) | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ |
|---|---|---|---|---|---|---|---|---|
| ផលិតផលឧ. ក្រៅបារី | ៧.៩៣ | ៧.១៧ | ៧.២៥ | ៧.៣៦ | ៨.៣៩ | ៨.០០ | ៨.១៦ | ៨.៩ |
| ផលិតផលបារី | ៤.២៧ | ៥.៦៣ | ៥.៨៥ | ៨.៦៤ | ៩.៩ | ៦.៨៥ | ៤៤ | ៨.៩៥ |

បើផលិតផលឧស្សាហកម្មសរុបឆ្លងពីតូចជាង១៣លានដុល្លារនៅឆ្នាំ ១៩៨៤ ទៅ ១៧ លានដុល្លារ នៅឆ្នាំ ១៩៩១ នោះកំណើនគឺ ១/៣ ក្នុង ឆ្នាំ។

កំណើននេះមិនមែនជាសភាពការផលិតកម្មឧស្សាហកម្មទាំអស់នោះទេដែលឆ្លងពី ៧ ទៅ ៨ លានដុល្លារ គឺកើន ១៥% ឯឧស្សាហកម្មបារីឆ្លងពី ៥ ទៅ ៨ លានដុល្លារ គឺកើន ២/៣។

### ក.៤.ការវិភាគឧស្សាហកម្មតែងកងង

ដូចជាលេចចេញនៅស្ថានភាពធម្មតាពេក ចំពោះប្តូទេសមួយដែលមានការផ្ទុះនៅសកម្មភាពសេដ្ឋកិច្ច Boom ។ គេអាចពិនិត្យលើភាគចំណែកនៃសកម្មភាពឧស្សាហកម្ម ២ ថយចុះប្រៀបនិងភាគចំណែកនៃបារីឱ្យឃើញនៅអ្វីៗ ដែលជាកំណើនឧស្សាហកម្មយើងត្រូវធ្វើការវិភាគតាមផ្នែកនៃផលិតកម្មគិតជាដុល្លារ ។

| លានដុល្លារ (១៨) | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ |
|---|---|---|---|---|---|---|---|---|
| ឧ.ស្បៀង | ០.៥១ | ០.២១ | ០.៧២ | ០.៦៤ | ០.០៥ | ០.៧៨ | ០.៤៨ | ៣.០៧ |
| ក្រៅពីបារី | | | | | | | | |
| បារី | ៤.២៧ | ៥.៦ | ៥.៨ | ៨.៦ | ៩.៨ | ៦.៨ | ៥.៤ | ៨.៩ |
| គីមី | ១.២៨ | ១.១២ | ១.២ | ០.៩៤ | ១.៣១ | ១.៦២ | ១.៦៧ | ១.៩៨ |
| ឧ.អគ្គិសនី | ៣.៦៣ | ២.៩៤ | ២.៣៤ | ២.៤៩ | ២.៩៩ | ២.២៩ | ២.៣៨ | ១.៥២ |
| យន្តសាស្ត្រ | ០.៨ | ០.៩៨ | ១ | ១.០៨ | ០.៨៥ | ០.៧៨ | ១.២៦ | ១.៣២ |
| វាយណភ័ណ្ឌ | ១.២២ | ០.៩៦ | ១.០៣ | ១.៥២ | ១.៥៧ | ១.៦៧ | ១.៤២ | ១.៥៧ |
| ឧ.ធុនស្រាល | ០.២៣ | ០.៣៤ | ០.៥១ | ០.៤ | ០.៥៥ | ០.៤៨ | ០.៦៥ | ០.១២ |
| សម្ភារសមណ | ០.១៨ | ០.១៦ | ០.៣១ | ០.២ | ០.២៧ | ០.២៨ | ០.១២ | ០.០៧ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ង់ | | | | | | | | |

ចេញពីតួលេខនេះ លេចចេញនៅការវិភាគដូចតទៅ៖

## ១.ការចាត់ថ្នាក់បរិមាណ

គេអាចចាត់ថ្នាក់តាមសារៈសំខាន់ថយចុះនៅផ្នែកទាំង៨នៃឧស្សាហកម្មដូចតទៅ៖

**ក្រុមទី១** ឧស្សាហកម្មដែលមានសារៈសំខាន់ពិត ៧៥% នៃផលិតកម្ម

- ឧស្សាហកម្មទីមួយនៃកម្ពុជា គឺផលិតកម្មបារីដែលមាន ៥០% នៃសកម្មភាពឧស្សាហកម្ម

- បន្ទាប់មក ឧស្សាហកម្មទីពីរដែលសរុបកន្សោមប្រហែល ៥០% នៃផលិតផលឧស្សាហកម្មគឺ៖ នៅលេខទី២ ឧស្សាហកម្មកសិផលស្បៀងលើកលែងតែបារីដែលមានចំនួន ១០% នៃផលិតផលឧស្សាហកម្ម ។ នៅលេខទី៣ ឧស្សាហកម្មគីមីដែលមានចំនួនប្រហែល ១០% ។

**ក្រុមទី២** ឧស្សាហកម្មមានចំនួន៥ទៀតសរុបតម្លៃផលិតកម្មបានតែ ២៥% នៃសកម្មភាពឧស្សាហកម្ម គឺ ៥% ផ្នែកទីមួយអាចចែកដូចតទៅ៖ នៅជួរទី ៤ ឧស្សាហកម្មយន្តសាស្ត្រ និងអគ្គិសនី មានសរុប ១៥% នៃសកម្មភាពឧស្សាហកម្ម ។ឧស្សាហកម្មយន្តសាស្ត្របានឈានមុខឧស្សាហកម្មគីមី។

ចុងបញ្ចប់សាខា៣សរុបបានតែ ១០% គឺមិនសូវសំខាន់

- នៅលេខ៦ ឧស្សាហកម្មវាយណភ័ណ្ឌ
- នៅលេខ៧ ឧស្សាហកម្មស្រាល
- នៅលេខ៨ ឧស្សាហកម្មសំណង់

## ២.ការចាត់ថ្នាក់គុណភាព និង ប្រវត្តិសាស្ត្រនៃផលិតផល

ការបែងចែកមិនមែនត្រឹមតែបរិមាណទេ គឺទាំងគុណភាពថែមទៀត ព្រោះផ្នែកឧស្សាហកម្ម ៨ នៅ កម្ពុជាអាចចាត់ថ្នាក់ទី៣ ផ្នែកយោងតាមមុខងារនៃការវិវឌ្ឍរបស់ឧស្សាហកម្មនោះ ៖

ផ្នែកឧស្សាហកម្មដែលកើនឡើងគួឱ្យកត់សម្គាល់ក្រោយពី បារី លេខ១ នោះគឺឧស្សាហកម្មផលិតផលស្បៀង លេខ២ ដែលកាលពីចាប់ផ្តើម គ្មានឧស្សាហកម្មបែបនេះទេតែនៅឆ្នាំ ១៩៩៣ គឺ១/៣ នៃផលិតផលឧស្សាហកម្មលើកលែងតែបារីជាផលិតកម្មផ្នែះ ។

ផ្នែកដែលអភិវឌ្ឍន៍យឺតៗ នោះគឺឧស្សាហកម្មយន្តសាស្ត្រ លេខ៤ ឧស្សាហកម្មគីមីលេខ៣ ។ ផ្នែកទាំងពីរនេះផលិតផលកើនពី ១/៤ ទៅ ១/៣ ។

ផ្នែកឧស្សាហកម្មធ្លាក់ចុះនៃកំណើន មានដូចជាឧស្សាហកម្មអគ្គិសនី លេខ៤ វាយណភ័ណ្ឌ លេខ៦ ឧស្សាហកម្មធុនស្រាល លេខ៧ សម្ភារសំណង់លេខ៨ ផលិតផលទាំងនោះមានចំនួន ៣/៤ នៃផលិតផលឧស្សាហកម្មក្រៅពីបារី ។

**តុល្យការស្តីពីហូបនីយកម្ម៖** ការផ្តាច់ពីការត្រួតពិនិត្យឧស្សាហកម្មការអភិវឌ្ឍវិស័យបារី គឺបញ្ជាក់ពីឡូស៊ីកនៃចំណូលថវិការដ្ឋយ៉ាងខ្លាំងជាឡូស៊ីកឧស្សាហកម្ម។ ការរក្សាឧស្សាហកម្ម គឺមីជាតិចណ្ឌូឡូស៊ីកធូន់ធូរបានឱ្យឮថាមានភាពងាយស្រួលព្រោះស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ។ កំណើននៃឧស្សាហកម្មស្បៀង និង យន្តសាស្ត្រ បញ្ជាក់ពីភាគចំណែកនៃ Boom នៃពីភពទីក្រុង។

ដើម្បីឱ្យការប្រៀបធៀបស្ថិតិ នៃឧស្សាហកម្មដ៏ទៃដែលផ្ទុយពីតត្ថភាពនៃការសង្កេតនោះ ជាការបាត់បង់នៅការត្រួតពិនិត្យរបស់រដ្ឋ ។

**ខ.ផ្នែកទី៣**

ក្រោយសិក្សាឧស្សាហកម្ម ឆ្លងចូលទៅពិនិត្យលើតួលេខដែលយកបានជាផ្លូវការតិចតួច ក៏ឃើញបន្ថែមនៅការលិចបាត់ផលិតផល នៃសកម្មភាពសេដ្ឋកិច្ច ក្នុងគណនេយ្យជាតិនោះ គឺផ្នែកសេវាកម្ម ។ មុនពេលសង្គ្រាមឆ្នាំ ១៩៧០ សេវាកម្មបង្កើតបានជាផ្នែកដែលត្រួតពិនិត្យបាន នៃគណនេយ្យជាតិប្រហែល ១/៤ នៃផលទុនដុលជាតិជាសភាពការប្រហាក់ប្រហែល នឹងផ្នែកសេវាកម្មរបស់ប្រទេសនៅក្នុងតំបន់គេមានគេមានការភ្ញាក់ផ្អើលដោយឃើញថាទស្សនាទាននៃសេវាកម្មហាក់ដូចជាការមិនលិចកប់នៅក្នុងគណនេយ្យថ្មីរបស់ជាតិ ដែលនិយាយយោងតែពាណិជ្ជកម្ម ការដឹកជញ្ជូន និង ទូរគមនាគមន៍។

**ពាក្យថាសេវាកម្ម**

ការលិចបាត់នៃពាក្យថាសេវាកម្ម មាននៃលើពីចំណុច៖

នៅលើផ្នែកទ្រឹស្តីវាមានការលំបាកជាទស្សនាទានក្នុងការចុះបញ្ជី ស្បែម៉ាលទ្ធិម៉ាក ជាសមភាពមួយដែលផលិតផលសេវាកម្មមិនមែនជាសម្ភារផ្ទាល់ ។ ជាងនេះទៀតដោយមានលាយគ្នានិងពាក្យ សេវាកម្មសាធារណៈ ការបាត់បង់នៅទស្សនាទាន រដ្ឋបម្រើរាស្ត្រ ដែលមុនសង្គ្រាម គណនេយ្យបានចុះបញ្ជីដោយឡែកនៅពាក្យថារដ្ឋបាល ។

លើផ្នែកគំនិតវាបកស្រាយថាជាសកម្មសេវាកម្ម គឺលាតសន្ធឹងលើទំហំប្រពៃណីដើម គឺជាកិច្ចសន្យាច្រើនឬតិចក្រៅផ្លូវការទាក់ទងដល់ខ្លឹមសារសេដ្ឋកិច្ចគុណភាពនិងទាក់ទងជាមួយវត្ថុសាធារណៈ ។ សេវាកម្មត្រូវបានធ្លាក់ទៅក្នុងវិស័យឯកជនគេវិលទៅរកប្រព័ន្ធថៅកែនិយម ។

ការបាត់បងមានន័យលើផ្នែកបច្ចេកទេស ព្រោះថាចំណុចខ្សោយរបស់រដ្ឋបាលដែលមុនបានឆ្លុះអំពីផលិតផលនៃមធ្យោបាយគណនេយ្យ ដែលធ្វើឱ្យមានភាពទំនើប ។ ការខ្វះប្រភពដែលមិនអាចបង្កើតនៅអ្វីដែលជាសម្មតិកម្មលើរចនាសម្ព័ន្ធគឺបានរក្សាទុក ដោយគណនេយ្យជាតិនៅឆ្នាំ ១៩៩០ ។

សេវាកម្មដែលកត់ត្រាដោយគណនេយ្យជាតិមាន ១០-២៥% នៃផលទុនដុលជាតិក្នុងនោះ៖

- ពាណិជ្ជកម្ម ៩០%

- ដឹកជញ្ជូននិង ទូរគមនាគមន៍ ៥%
- ទេសចរណ៍ណ៍ក្នុងន័យទូលាយ ៥% ។

យើងចង់បញ្ជាក់ឱ្យច្បាស់នៅអង្គធាតុនៃការសន្និដ្ឋានតាមស្ថាមគណនេយ្យ គឺជាផ្នែកៗនៃសកម្មភាពនោះ។

## ពាណិជ្ជកម្ម

| ពាន់លានរៀល | ១៩៨០ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ |
|---|---|---|---|---|---|---|---|---|
| ពាណិជ្ជកម្មធំ | ០.០៥ | ០.២០ | ០.២៥ | ០.៦៩៩ | ០.៨ | ១.៥៣ | ២.៤៦ | ២.៩១ |
| លានដុល្លារ | ២.៥ | ៦ | ៦.២ | ១៣.៨ | ២៨.៥ | ១៥.៣ | ១៨.៩ | ២០.៧ |
| លក់រាយ | ០.៦៥ | ០.៩៤ | ០.៩៤ | ១.០៦ | ២.១៣ | ២.៥៧ | ៣.៦៣ | ៣.៩៤ |
| លានដុល្លារ | ៣២.៥ | ៣១.៣ | ២៣.៥ | ២១.២ | ៣០.៤ | ២៥.៧ | ២៧.៩ | ២៨.១ |
| សរុប | ០.៧០ | ១.១៤ | ១.១៩១ | ១.៧៥ | ៤.១៣ | ៤.១ | ៦.០៩ | ៦.៨៥ |
| លានដុល្លារ | ៣៥ | ៣៨ | ២៩.៧ | ៣៥ | ៥៩ | ៤១ | ៤៦.៨ | ៤៨.៨ |
| អត្រាប្តូរ រៀល/ដុល្លារ | ២០ | ៣០ | ២០ | ៥០ | ៧០ | ១៧០ | ១៣០ | ១២០ |

យោងទៅលើតួលេខផ្លូវការ គិតជាលុយរៀល នឹងន ពាណិជ្ជកម្មកើនមិនឈប់ឈរ ហើយតាមរូបភាពកំណើនលឿន ៤ដងក្នុងរយៈពេល៧ឆ្នាំ ពី០.៧ពាន់លានរៀល ទៅ៦.៨៥ ពាន់លានរៀល

តាមពិតការបកស្រាយនៃដុល្លារ មិនដាចខាត់នៃការវិភាគនេះឃើញថាពាណិជ្ជកម្មកើននៅតម្លៃកើន យឺតៗក្នុងរយៈពេល៧ឆ្នាំ វាកើនតែ ៥០% គឺកើន៦០% ក្នុងមួយឆ្នាំ ។

កំណើននេះមានរយៈពេលបីៈ

១.ពីឆ្នាំ ១៩៨១-១៩៨៣ ពាណិជ្ជកម្មនៅនឹងជុំវិញ ៣៥ លានដុល្លារអាមេរិក ។

២.ការរុញច្រានមួយនៅ ឆ្នាំ ១៩៨៤ ពាណិជ្ជកម្មកើនទ្វេពី ៣៥ ទៅ ៥៩ លានដុល្លារ ។

៣.ពីឆ្នាំ ១៩៨៥-១៩៩៤ មានការធ្លាក់ចុះយ៉ាងខ្លាំងពី ៥៩ លានដុល្លារ មក ៤១ លានដុល្លារ ក្រោយមកឃើញមានកំណើនយឺតៗ នៃពាណិជ្ជកម្មពី ៤១ ទៅ ៤៨.៨ លានដុល្លារ ។

សេដ្ឋកិច្ចកម្ពុជា បញ្ជាក់ពីភាពចុះឡើងសោះ មានន័យថាការពិតនៃពាណិជ្ជកម្មនោះកើនឡើងក្រោម ស្ថិតិ ។ យើងវិភាគលើទំនាក់ទំនងរវាង ពាណិជ្ជកម្មដុំ និង ពាណិជ្ជកម្មរាយ ។

### ទំនាក់ទំនងរវាង ពាណិជ្ជកម្មដុំ និង ពាណិជ្ជកម្មរាយ

សញ្ញានៃផលកំណើនពាណិជ្ជកម្មដុំពីពេលចាប់ផ្តើមគ្មានរូបភាពនោះទេ ក្រោយមកកើនរហ័សព្រោះកើន ៤ ដងពីឆ្នាំ ១៩៨០ ដល់ ១៩៨៤ ឆ្លងពី ២.៥ លានដុល្លារ ទៅ២៨.៥ លានដុល្លារ វានាំទៅដល់កំណើនទូទៅនៃពាណិជ្ជកម្មដែលកើនទ្វេក្នុងរយៈពេលដូចគ្នាពី ៣៥ ដល់

៥៩លានដុល្លារ។ ពាណិជ្ជកម្មលក់រាយភាគច្រើនមាននិន្នាការថយចុះបន្តិចម្តងៗ ត្រឹម ២៥ លានដុល្លារ ។

សភាពការនេះដូចជាលំបាកព្រោះពាណិជ្ជកម្មមួយក្នុងចំណោមប្រទេសពីរដើបញ្ច្រាស គ្នា ។ ពាណិជ្ជកម្មខ្វះប្រសិទ្ធភាពព្រោះវាឃ្លាតឆ្ងាយពីការត្រួតពិនិត្យរបស់រដ្ឋ ចាប់ផ្តើមពីការលក់រាយ ។ ក្រោយពីឆ្នាំ ១៩៨៤ ការបាត់មុខនៃតួនាទីរដ្ឋគឺជាយថាហេតុហើយបន្ទាប់មកគឺ ពាណិជ្ជកម្មលក់ដុំដែលបាត់បង់ការត្រួតពិនិត្យ ពាក់កណ្តាលរបស់រដ្ឋដែលជាផ្លូវការពីរ ១៩៨៤ និង ១៩៨៥ ពី ២៨.៥ លានដុល្លារ ដល់ ១៣.៥ លានដុល្លារ ហើយពាណិជ្ជកម្មក៏ដូចគ្នាដែរ។

ដើម្បីឱ្យឆ្ងាយជាងការវិភាគគេមានតួនាទីពីរប្រភេទដែលផ្តល់ឱ្យពី ឆ្នាំ ១៩៨០ ដល់ ១៩៨៧ សម្រាប់ពាណិជ្ជកម្មុំ និង ពាណិជ្ជកម្មរាយ ។

### ការវិភាគតាមផលិតផល

ដើម្បីឱ្យមានផលប្រយោជន៍ដល់ការសិក្សានេះតួលេខបានបញ្ជាក់ ដែលត្រូវវិភាគល្អិតល្អន់ដែលត្រូវកេតម្លៃនៃពាណិជ្ជកម្មសរុប និងបញ្ជាក់ស្ថិតិតាមផលិតផលនៃឆ្នាំនីមួយៗ។ លើកឧទាហរណ៍មួយ៖ នៅឆ្នាំ ១៩៨០ ពាណិជ្ជកម្មរាយមានចំនួន ៩៣% នៃពាណិជ្ជកម្មសរុប ។ ការស្តារសេដ្ឋកិច្ចឡើងវិញ ។

- ការបង្កើតដំបូង ១៩៨០-១៩៨១ ផលិតផលស្បៀងជាសេចក្តីត្រូវការទីមួយក្នុងគំនិតជនកម្ពុជា ត្រូវលក់ជាដុំ អង្ករ អំបិល និង ត្រីងៀត។

- ក្នុងដំណាក់កាលទី២ ១៩៨២-១៩៨៣ ពាណិជ្ជកម្មផលិតផលស្បៀងត្រូវបែងចែកតាមកំណើនបរិមាណចរាចរស្បៀង ប្រណិត ស្ក និង ជ្រូក ។

- ចុងបញ្ចប់នៃដំណាក់កាលទី៣ ១៩៨៤-១៩៨៥ កើតមានអ្នកចរចាលក់ទិញផលិតផលភាពទំនើបបកស្រាយនៅសេដ្ឋកិច្ចទីក្រុងមួយ៖ បារី ក្រដាស សាប៊ូ និងវាយណភ័ណ្ឌ ។

- កំណើននៃពាណិជ្ជកម្មដុំ គឺទាក់ទងនិងកំណើននៃពាណិជ្ជកម្មផលិតផលដែលស្រួលត្រួតពិនិត្យ ដោយរដ្ឋបាលគឺ បារី ។

- ចំណែកកំណើនទាក់ទងដល់ពាណិជ្ជកម្មរាយភាគច្រើពាណិជ្ជកម្មតូច ដែលរួចផុតពីការត្រួតពិនិត្យរបស់រដ្ឋ។ បើយើងពិនិត្យមើលការទ្រាមជាមុនរបស់ក្រសួងផែនការ រាប់ឆ្នាំ ១៩៨៧ គឺសរុប ២.៣៨ ពាន់លានរៀល សម្រាប់ពាណិជ្ជកម្មទាំងអស់គេសន្និដ្ឋានថា ការគិតទុកជាមុននេះទាបជាងបរិមាណនៃពាណិជ្ជកម្មដុំ តែមួយជិត ១/៤ ដែលសម្រេចនៅឆ្នាំ ១៩៨៧ ហើយមានចំនួន ១/៣ នៃសុំនុំនៃសកម្មភាព ពាណិជ្ជកម្ម ដុំ បូក រាយ ដែលមិនសមស្របនិងតថភាពឡើយ។

ពាណិជ្ជកម្មដូចជាឈានទៅរកការបាត់បង់គឺគណនេយ្យកណ្តាលតាំងពីពាក់កណ្តាល ១៩៨០ ម្លេះ។ចំណែកឯការបញ្ឈប់ ការចុះស្ថិតិ ដែលងាយធ្វើបានគឺមិនមាននៃថារដ្ឋបាលយល់

ព្រមសារភាពចាប់តាំងពីចុងឆ្នាំ១៩៨០ មកគឺមិនមានអំណាចដើម្បីធ្វើអង្កេតស្ថិតិនៃសកម្មភាពពាណិជ្ជកម្ម ។

## ការដឹកជញ្ជូន និង ទូរគមនាគមន៍

អង្គជាតុនៃស្ថិតិខ្លះៗ ដែលចុះបញ្ជីក្នុងប៉ុស្តិ៍មួយ និងប៉ុស្តិ៍ផ្សេងៗទៀតគឺមិនសុទ្ធតែមិនទុកឱ្យ នូវព័ត៌មានដ៏មានតម្លៃស្តីពីការវិវដ្តនៃសភាពការណ៍កម្ពុជានោះទេ។

### ១.ការដឹកជញ្ជូន

គណនេយ្យជាតិមិនបានកត់ត្រានូវតម្លៃផលិតផល នៃសកម្មភាពដឹកជញ្ជូនមិនឆ្នាំ ១៩៩១ នៃសេវាកម្មគ្រប់គ្រងដោយរដ្ឋនោះទេ ។ ទិន្នន័យខ្លះៗដែលអាចងាយដឹងពីបរិមាណពាន់លានក្នុងគីឡូម៉ែត្រ ហ្នកដំណើរក្នុង គ.ម....អាចសន្និដ្ឋានថា៖

- ការដឹកជញ្ជូនក្នុងប្រទេសបានកើនរវាង ២០% និង ៣០ រវាងឆ្នាំ ១៩៨០ និង១៩៨៧ មធ្យោបាយដូចគ្នាការរីកចម្រើនកើនឡើងដោយកំណើននៃបរិមាណ នឹងការដឹកជញ្ជូនដោយផ្លូវទឹកដោយឡែកចំងាយផ្លូវរកដោយផ្លូវដែកបានកើនឡើងទ្វេបាមបញ្ជាក់ពីការស្តារឡើងវិញនូវរចនាសម្ព័ន្ធជាដុំៗ ។

ការអង្កេតទូទៅ៖គេត្រូវតែបែងចែកពីដំណាក់កាលមុនឆ្នាំ ១៩៨២-១៩៨៣ និង ទី២ ចាប់ពីឆ្នាំ ១៩៨៣។

- ដំណាក់កាលទី១ មានលក្ខណៈថយចុះនូវបរិមាណដឹកជញ្ជូន អ្នកដំណើរនិងផ្លាស់ប្តូរអាចពន្យល់ដោយរចនានៃការជួលទៅតាំងទីលំនៅជាថ្មី របស់ប្រជាជនក្រោយថ្ងៃរំដោះ ១៩៧៩ ចលនាដែលកើនឡើង ចន្លោះឆ្នាំ ១៩៧៩-១៩៨២ ។
- ចាប់ពីឆ្នាំ១៩៨២-១៩៨៣ ចាប់ផ្តើមដំណើរការទី២ នៃស្តេរកម្មនូវពេលដែលមានការដឹកជញ្ជូនមនុស្ស និង ទំនិញ ប្រព្រឹត្តទៅធម្មតា ។ គេឃើញថាការដឹកជញ្ជូនអ្នកដំណើរតាមភ្លូវគោកមានការកើនឡើងក្នុងនោះដឹកជញ្ជូនផ្លូវគោក មានសកម្មភាពខ្លាំងជាងផ្លូវដែក ។ និន្នាការគួកត់សម្គាល់ក្នុងការដឹកជញ្ជូនទំនិញមានភាគចំណែកកំណើនខ្លាំងជានាបានដោយផ្លូវគោក ។

### ២.ទូរស័ព្ទ

ពេលទើបរំដោះចេញពីខ្មែរក្រហមមាននូវសល់តែប្រព័ន្ធទូរស័ព្ទដែលទើបពន្លកហើយភ្នំពេញបានរៀបចំតាំងបណ្តាញនោះជាង ១០ឆ្នាំ កន្លងមកហើយដែលមានប៉ុស្តិ៍រាបពាន់កន្លែង។ ចំនួនទូរគមនាកមន៍តាមទូរស័ព្ទបានកើន ៥ដង ក្នុងចន្លោះ ១៩៨០-១៩៨៧ ។

គេឃើញមានអង្គជាតុ បី បែប ៖

១.កំណើននេះមុនជាប់ទាក់ទង ពីរដ្ឋធានីទៅខេត្តបានទេចាប់ពីឆ្នាំ ១៩៨៥ មក ព្រោះប្រព័ន្ធហាក់ដូចជាប្រើអស់លទ្ធិភាពហើយ។ ប៉ុន្តែការប្រើប្រាស់ក្នុងការហៅរកគ្នាក្នុងស្រុកកើនឡើងនោះជាការផ្លាស់ប្តូគុណភាពក្នុងការប្រើប្រាស់ទូរស័ព្ទជាទូរគមនាគមន៍ កាន់តែឆ្ងាយទៅៗ ។

២.ការវិត្តន៍នៃការហៅ ពីតំបន់មួយតៅតំបន់មួយ ពីសេសហៅទៅដល់វៀតណាម ពី ១៩៨៣១៩៨៦កើនឡើងហើយការហៅរវាងតំបន់ថយចុះ ព្រោះសភាពការន៍មានការផ្លាស់ប្តូ។

៣.នៅឆ្នាំ ១៩៨៦ ចំនួនទួរស័ព្ទកើន ៣ដង តភ្ជាប់ជាមួយវៀតណាមហើយនៅឆ្នាំ ១៩៨៧ វិញសភាពការថយមករកកម្រិត ឆ្នាំ ១៩៨៥ ។

**តុល្យការទូទៅ**

**ភាពផ្ទុយគ្នារវាង តុល្យការផ្លូវការ និង ព្រឹត្តិការន៍ពិនិត្យឃើញ**

តាមអណត្តិនៃការវិភាគនូវទិន្នន័យស្ថិតិផ្លូវការនូវ ឆ្នាំ១៩៨៩ យើងបានសន្និដ្ឋានថាមានកំណើនសេដ្ឋកិច្ច ៦% ដោយសារៈ

- ជាសំខាន់ ៥០% ផ្នែកកសិកម្មត្រូវមាន ៣/៤ នៃកំណើននោះ
- កំណើន ៤% នៅសល់គឺផ្នែកពាណិជ្ជកម្មនិងឧស្សាហកម្មនោះជាកំណើនទាបព្រោះបើប្រៀបវិស័យឧស្សាហកម្មឆ្នាំ ១៩៩១ មានប្រហែល ១/១០ នៃឧស្សាហកម្ម ១៩៨០ ហើយពាណិជ្ជកម្មមាន ១/៥ នៃពាណិជ្ជកម្មឆ្នាំ១៩៧០នេះមិនទាននិយាយដល់អថេរនៃប្រាក់ដុល្លារទៀត។

ការផ្តល់តួលេខផ្លូវការគឺមិនទាន់ច្បាស់លាស់ធៀបនឹងតថភាពនោះទេ នៅក្នុងវិស័យពាណិជ្ជកម្ម និងឧស្សាហកម្មយើងនឹងឃើញភាពនឹងថ្កល់ Stagnation ពេលខ្លះបាត់បង់ទិន្នន័យស្ថិតិមិនជាចខាតនៃសកម្មភាពដែលធ្លាប់រុងរឿងដូចជសាការលក់រាយសំណាងរាយណត័ណ្ឌ ។ល។ សេដ្ឋកិច្ចហាក់ដូចបានដំណើរការយើងអាចបញ្ចប់យោបល់បានតួលេខផ្លូវការមានជាផ្នែកៗ ហើយឈរលើមូលដ្ឋាននោះយើងមិនអាចរៀបចំជាសរុបស្តីពីថាមពលនៃកំណើន រវាងឆ្នាំ ១៩៨០ ដល់ ១៩៩២ បានត្រឹមត្រូវ ។

ដោយហេតុថាទិន្នន័យស្ថិត ដូចជាមិនស៊ីសង្វាក់គ្នាសោះ ពេលបូសរុបកម្រិតរួមដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធ នៃផលទុនដុលជាតិ ឬ និយាយបានពីប្រភតនៃការរៀបចំផ្នែកការងារនៃប្រជាជនសកម្ម ។

**តុល្យការរចនាសម្ព័ន្ធ និង ផលទុនដុលជាតិ**

| រចនាសម្ព័ន្ធផលទុនដុលជាតិ | កសិកម្ម | ឧស្សាហកម្ម និងសំណង់ | សេវាកម្ម | សរុបលើកលែងរដ្ឋបាល | រដ្ឋបាលនិងជំនួយ | សរុប |
|---|---|---|---|---|---|---|
| (ផ្នែកលោកខាងលិច) | ៦២% | ១៦% | ១២% | ៩០% | ១០% | ១០០% |
| | ៥២% | ១៧% | ១៩% | ៨៨% | ១២% | ១០០% |
| | ៤០.៩% | ១៥.៨% | ៣០% | ៨៦.៧% | ១៣.៣% | ១០០% |
| (ផ្នែកកម្ពុជា) ក្រសួងផែនការ | ៤៤.៤% | ៣៦.៣% | ១១% | ៤៧.៧% | ១២.៣% | ១០០% |

មានប្រភពពីបែបះ ទី១ ប្រភពកម្ពុជា ការសន្និដ្ឋាននៃក្រសួងការងារ ទី២ ប្រភពលោកខាងលិចះចំណាប់ថ្នាក់ជាថ្មីតាមមុខងារនៃទិន្នន័យផ្ទាល់កសិកម្ម ប្រភពបី ។

ក្រសួងផែនការវាយសម្លៃផ្នែកឧស្សាហកម្ម ខ្ពស់ពេកដល់ទៅ ៣៦.៣% ក្នុងនាមនៃឡូស៊ីក តាមលទ្ធិម៉ាកដែលធ្វើឱ្យកម្ពុជា ជាប្រទេសដែលមានភាពចំឡែកនៃឧស្សហកម្ម ក្នុងផលដុលទុនជាតិប្រៀបទៅនិងតៃវ៉ាន់ ៣៤.១% នៃផលដុលទុនជាតិ ឆ្នាំ១៩៩១ ។

Enagolopacdia ក៏វាយតម្លៃខ្ពស់ពេកដែរ លើផ្នែសេវា ៣0% ក្នុងនាមដែលឡូស៊ីកដែលជាឡូស៊ីក ផលកំរៃ តាមបែបលោកខាងលិច ដូចជា Asian Market Atlas ប៉ុន្តែតាមសមាមាត្រទាបនោះគឺ ១៩% ផ្តល់នៅការវាយតម្លៃត្រឹមត្រូវ ជាងក្នុងវិស័យកសិកម្មគឺ ៥២% ។

គេឃើញសម្រាប់ឆ្នាំ១៩៩០ ថាការសន្និដ្ឋានដែលត្រឹមត្រូវជាងគឺ E.I.U.។ ដែលបានផ្តល់សុំណមពរការវិភាគ តាមផ្នែកនៃផលទុនដុលជាតិ Gross Domestic Productsd ដូចតទៅះ

- កសិកម្ម ៦0% ទៅ ៧0% នៃ GDP
- ឧស្សាហកម្ម ១៥% នៃ GDP
- សេវាកម្មបូកនិងរដ្ឋបាល ១៥% ទៅ ២៥% នៃ GDP

វានៅសល់តែថាការសន្និដ្ឋាននៃផលទុនដុលជាតិមិនសូវស៊ីចង្វាក់គ្នាដែលធៀបនិងការវាយតម្លៃរចនាសម្ព័ន្ធប្រជាជនសកម្មទូទៅដោយសារះ

១.ក្នុងប្រទេសមួយដោយឧស្សាហកម្មមិនបានរៀបចំ ផ្នែកសម្ភារបានល្អដោយប្រើប្រាស់ពលកម្មសកម្មបានច្រើនតើឧស្សាហកម្មនេះមាន ៣% នៃប្រជាជនសកម្មដែរ ឬហើយតើគួឱ្យជឿបានទេឧស្សាហកម្មអាចតំណាង ១៥% នៃផលទុនដុលជាតិបាន ហើយក្នុងរយះពេល ១៩៨0 - ១៩៩១ គិតជាដុល្លារ កំណើនដល់ទៅ ១៥% នៃផលទុនដុលជាតិបាន ព្រោះពី ១៩៨0 ដើបចេញពីការបំផ្លាញរបស់ពួកខ្មែរក្រហមនោះ ។

២.ក្នុងកម្រិតនៃសេវាកម្មតើផ្តល់សុភវិនិច្ឆ័យបែបណាដែលថាសេវាកម្មអាចមានចំនួន ១៥% ទៅ ២៥% នៃផលទុនដុលជាតិហើយមាន ១៧% នៃប្រជាជនសកម្មហើយគេគ្មានស្ថិតិផ្លូវការ ពិតប្រាកដ ។

តុល្យការរចនាសម្ព័ន្ធ បន្ថែមនេះក្នុការសិក្សាវិស័យនានា នៃតួលេខខាងលើនេះ បញ្ជាក់ថាស្ថិតិផ្លូវការមុនសមស្របរួមទាំងកម្រិតសមាសភាពនានា ក៏ដូចកម្រិតនៃលទ្ធផលសកម្មសេដ្ឋកិច្ចផ្សេងៗទៀតហើយបើយើងធៀបនិងឆ្នាំ១៩៩២ នោះតួលេខដូចជាមិនច្បាស់លាស់ ។

និយាយសង្ខេបកិច្ចការអភិក្រមនៃកំណើនសេដ្ឋកិច្ច គឺមានការរៀបចំរចនាសម្ព័ន្ធផលិតកម្មឡើងវិញ។

## ២.តើជា ប៊ុម នៃផលិតកម្មឬ

ប៊ុម ៖ ការផ្ទុះឡើង Boom

មធ្យោបាយតែមួយដែលត្រូវពិចារណាឡើងវិញស្តីកិច្ចអភិក្រមធ្វើ ឱ្យឃើញច្បាស់នៅកំណើនគឺចាប់ផ្តើមវិភាគលើមូលដ្ឋានថ្មីមួយ ដោយឡែកឈរលើមុំផលិតកម្មគឺលើរចនាសម្ព័ន្ធ

ផលិតកម្មដែលជាប្រភពដើម និងមួយចំណែកទៀត គឺសិក្សាអំពីកម្រិតនៃការផ្លាស់ប្តូជាមួយក្រៅប្រទេស ដែលជាលទ្ធផលនៃសំណុំសកម្មភាពសេដ្ឋកិច្ច។

### ក.របនាសម្ព័ន្ធផលិតកម្ម

នៅក្នុងអំណាចមួយដែលនៅក្របខ័ណ្ឌរដ្ឋ គ្របដណ្តប់លើគ្រប់វិស័យនោះសកម្មភាពសេដ្ឋកិច្ចពីឆ្នាំ ១៩៨០ ដល់ ១៩៩១ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ហើយមធ្យាបាយផលិតកម្មចាត់ទុកជាសកម្មភាព សមូលភាព។ ក្នុងស្ថានភាពក្របខ័ណ្ឌកំពុងរៀបចំឡើវិញ នោះសមត្ថភាពធ្វើឱ្យដំណើរបនាសម្ព័ន្ធផលិតកម្មសេដ្ឋកិច្ច ទាំងស្រុងគឺខ្លឹមសារស្ថិតនៅក្នុងកម្មីវនៃការរៀបចំវិស័យកសិកម្មអន្តកាល ។

រដ្ឋបាលអនុញ្ញាតឱ្យមានពាណិជ្ជកម្មសេរី ដើម្បីរៀបចំកម្រិតផ្លាស់ប្តូរតូចធំ នៅក្នុងផ្ទៃប្រទេស ។ តាំងពីពេលរៀបចំឡើងវិញសមាសភាពសេដ្ឋកិច្ចរដ្ឋដំណើរការទន្ទឹមគ្នា និងសេដ្ឋកិច្ចឯកជន។

- វាសនានៃសេដ្ឋកិច្ចរដ្ឋ
- វាសនានៃផ្នែកឯកជន
- ប្រត្តិកម្មផ្នែករដ្ឋ ប្រៀបធៀបឯកជន

### ខ.សហគ្រាសរដ្ឋ ឡូស៊ីកនៃភាពអោក់អេួល

ដើម្បីថ្លឹងថ្លែងដល់ការប្រព្រឹត្តទៅនៃសេដ្ឋកិច្ចរដ្ឋគេត្រូមានប្រភពទិន្នន័យ ព្រោះឧស្សាហកម្ម ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងឧស្សាហកម្មដែលផ្តល់ព័ត៌មានដូចតទៅ៖

| សហគ្រាសក្រោមការគ្រប់គ្រងក្រសួងឧស្សាហកម្ម | ១៩៨០ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ |
|---|---|---|---|---|---|---|---|
| ចំនួនសហគ្រាស | ៦៣ | ៦៥ | ៦៤ | ៦៣ | ៦៣ | ៦៣ | ៥៦ |
| ចំនួនពលករ ពាន់នាក់ | ១៣ | ១២ | ១២ | ១២ | ១២ | ១៣ | ១៣ |
| តម្លៃពលកម្ម ពាន់ដុល្លារ | ១៥.៧ | ១៧.៨ | ១៣.២ | ១៤.៩ | ១២.២ | ១២.៨ | ១៣.១ |
| %នៃផលិតផលឧស្សាហកម្មសរុប | ៧២ | ៦៥ | ៦០ | ៥៦ | ៥៥ | ៥៤ | ៥៣ |

| សហគ្រាសក្រោមការគ្រប់គ្រងក្រសួងឧស្សាហកម្ម | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ |
|---|---|---|---|---|---|
| ចំនួនសហគ្រាស | ៥២ | ៥២ | ៥២ | ៥៣ | |
| ចមនួនពលករ ពាន់នាក់ | ១៣ | ១៣ | ១៣ | ១៤ | |
| តម្លៃពលកម្ម ពាន់ដុល្លារ | ១៦ | ១៨.៥ | ១៤.៨ | ១៣.៦ | ១៧.៩ |
| %នៃផលិតផលឧស្សាហកម្មសរុប | ៤៨ | ៤៦ | ៣៩ | ២៤ | ១០«៤» |

ពីឆ្នាំ ១៩៨០ ដល់ ១៩៩០ គេសន្និដ្ឋាន ៖

ស្ថេរភាពទូទៅមាននៃចំនួនសហគ្រាស មាននៅចន្លោះឆ្នាំ ១៩៨៦ មុនឆ្នាំនោះមានចំនួន ៦០ ក្រោយមកមានចំនួន៥០ ។

ភាពនឹងនមួយនៃចំនួនពលករដែលយោលចុះឡើងជុំវិញ ១២,០០០ ទៅ ១៣,០០០ នាក់ ។

និន្នាការមួយនៃការស្ថិតនៅនឹងថ្កល់ នៃផលិតផលឧស្សាហកម្ម នៃសហគ្រាសរដ្ឋ គិតតាមតម្លៃពិតដែលយោងចុះឡើងនៅជុំវិញ ២០ លានដុល្លារអាមេរិក ។

ការស្រុតចុះនៃភាគរយនៃផលិតកម្មរបសរដ្ឋបាលធៀបនឹងផលិតផលសរុប ដែលធ្លងពី ១០០% នៅឆ្នាំ ១៩៨០ មកត្រឹម ១០% នៅឆ្នាំ ១៩៩១ ។

តើផលិតកម្មប្រព្រឹត្តទៅបែបណា? តើត្រូវពន្យល់ពីភាពបរាជ័យសេដ្ឋកិច្ចនោះបែបណា ហើយការកែប្រែនយោបាយសេដ្ឋកិច្ច ពីការគ្រប់គ្រងបែបសមូហភាពមានដូចម្តេច? គេអាចពន្យល់ពីការស្រុតចុះ នៃផលិត កម្មតាមពីចំណុច ៖

- រដ្ឋបាលជួបប្រទះនៅការចូលរួមក្នានៃល្បែងផលិតកម្មតាមរយៈការលំបាកគ្រប់គ្រងនៃរចនាសម្ព័ន្ធផលិតកម្មនៃទីក្រុង ពិសេសក្នុងផ្នែកឧស្សាហកម្ម ខ្វះគ្រឿងបន្លាស ខ្វះកម្មាភិបាល អ្នកបច្ចេកទេសភាពខ្សោយនៃមូនិធិ...ឬផ្នែកទី៣ខ្វះការបែងចែកក្រុមហ៊ុនរដ្ឋអាចត្រឹមសម្រេចបានការលក់ដុំ ។
- គេអាចលើកមកនិយាយផងដែរពើមតិដូចជាការហំព័ទ្ធសេដ្ឋកិច្ច ការបំផ្លាញប្រភពធនធាន...។

## ការស្រុតចុះនៃឧស្សាហកម្មរដ្ឋបាល

ដើមហេតុនៃការស្រុតចុះនេះ លេចចេញពីបាតុភាពសេដ្ឋកិច្ច ដូចជាច្បាស់លាស់ណាស់ថា៖ ភាពវិចវិលនៃអត្រាទិន្នផល នៃសេដ្ឋកិច្ចសង្គមនិយមព្រោះតែចំនួនពលករចំនួនសហគ្រាស និងតម្លៃផលិតផលឧស្សាហកម្ម មិនអាចប្រគួតប្រជែងបាន។

គេសន្និដ្ឋានលើការវិវដ្ត នៃផលភាពការងារឧស្សាហកម្ម ៖

| សហគ្រាសក្រោមការត្រួតពិនិត្យនៃក្រសួងឧស្សាហ | ១៩៨០ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| កម្ម | | | | | | |
| តម្លៃផលិតផលក្នុងសហគ្រាស ពាន់ដុល្លារ/ឆ្នាំ | ៤០០ | ២៥០ | ២០០ | ២៣០ | ១៩០ | ២០០ |
| ផលិតផលក្នុងពលករ | ១៩៧០ | ១៤៨០ | ១១០០ | ១២៤១ | ១០១៦ | ៩៨៤ |

| សហគ្រាសក្រោមការត្រួតពិនិត្យនៃក្រសួងឧស្សាហកម្ម | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ |
|---|---|---|---|---|---|
| តម្លៃផលិតផលក្នុងសហគ្រាស ពាន់ដុល្លារ/ឆ្នាំ | ២៣០ | ៣០០ | ៣៥០ | ២៨០ | ៣៥០ |
| ផលិតផលក្នុងពលករ | ១០០៧ | ១២៣០ | ១៤៣០ | ១០០០ | ៩៧០ |

ពិនិត្យលើទិន្នន័យ នៃតារាងនេះយើងឃើញគូបនៃផលិតផលភាពការងារសហគ្រាស និងផលិតភាពការងារពលករលេចចេញនៅផលិតភាពសហគ្រាសស្ថិត នឹងនជុំវិញ២៥០,០០០ ដុល្លារ ក្នុងមួយឆ្នាំចំណែកផលិតភាព ការងារពលករចេះតែកើនឡើង ។ ចលនានេះកើនតហ័ស នៅដើមឆ្នាំ ១៩៨០ ដុល្លារ ទៅ ដុល្លារ ៩៨៧ ដុល្លារ ក្នុងមួយឆ្នាំដែលនាំទៅដល់ផលិតភាពការងារសូន្យនៅចុទស្សវត្សនោះ ។ រដ្ឋបានដកខ្លួនថយ ១០% ពីការគ្រប់គ្រងសហគ្រាសទាំងនោះដែលនាំឱ្យមានការលោតផ្លោះខាងផលិតកម្មឧស្សាហកម្ម នៅក្រៅការគ្រប់គ្រងរបស់ក្រសួង។ នៅឆ្នាំ ១៩៨៦ ផលិតផលឧស្សាហកម្មក្រោមការត្រួតពិនត្យរបស់ក្រសួង មានតែជាង ៥០% ទេ ។ ប៉ុន្តែឧសថនេះបានបន្តធ្វើស្វ័យភិបាលសហគ្រាស ដែលប្រសិទ្ធភាពផលិតកម្មបានកើនឡើង ។

ក្រោយឆ្នាំ ១៩៨៤ ក្រសួងចេះតែបន្ថយនូវការគ្រប់គ្រងសហគ្រាសដ៏ទៃទៀតរហូតដល់ដើមឆ្នាំ ១៩៩០ ឧស្សាហកម្មក្រោមការត្រួតពិនិត្យរបស់ក្រសួង នៅសល់តិចតួចបើប្រៀបនឹងទំងន់នៃឧស្សាហកម្មដែលកំពុងរីកចម្រើន រហូតដល់ ៩០% ផលិតផលឧស្សាហកម្ម ។

## ២.ភាគីមួយទៀតសហគ្រិនតូចធំផ្នែកឯកជន ៖ ឡូស៊ីកនៃកំណើន

នៅចំពោះមុខការស្រុតចុះ នៃសហគ្រាសរដ្ឋ រដ្ឋបានរៀបចំសមាសភាពសេដ្ឋកិច្ច ផ្នែកឯកជនដើម្បីពង្រឹកថមពលជាថ្មី នៅកម្ពុជាមានការកំណត់សម្គាល់ថា តាំងពីពាក់កណ្ដាលឆ្នាំ ១៩៨០ កមមានការរីកចម្រើនចំឡែកលើផ្នែសហគ្រាសតូចៗ ដែលបានចុះបញ្ជីខ្លះក្នុងគណនេយ្យស្ថិតិ ។ នៅភ្នំពេញដែលមានសហគ្រាសតូចៗ ប្រហែលពី ៧០% ទៅ ៨០% អាចបញ្ជាក់បានជាបាតុភាពនៃការអភិវឌ្ឍនេះ ។

| ឆ្នាំ | ១៩៨៣ | ១៩៨៩ | ១៩៩១ |
|---|---|---|---|
| សហគ្រាសគ្រួសារនៅ | ១,៧០០ | ១២,០០០ | ៣០,០០០ |

| ភ្នំពេញ | | | |
|---|---|---|---|

គេសន្និដ្ឋានថា ចំនួនសហគ្រាសកើនឡើងចំនួន ៧ដង ក្នុងរវាងឆ្នាំ ១៩៨៣ ដល់ ១៩៨៩ ហើយកំណើននេះកើនទៅរវាងឆ្នាំ ១៩៨៩ ដល់ ១៩៩១ ជាផលប៉ះពាល់ នៃការដើរទូលាយនិងផែកការសន្តិភាពដែលគេដឹងថានៅចុងឆ្នាំ ១៩៧៩ មានសហគ្រាសតូចៗ ចំជាង ៥០០ កន្លែងប៉ុណ្ណោះនៅទូទាំងប្រទេសកម្ពុជា ។ នោះជាការអនុគ្រោះដល់សហគ្រាសតូចៗទាំងនោះជាដំណើរការនៃសេដ្ឋកិច្ចទីផ្សារ ។

**ការវិភាគនៃកំណើនឯកជន**

កណើននេះមានប្រត្តិបត្តិការជាពីរដំណាក់ការៈ

១.ការលក់ដូរតូចតាច

២.ឧស្សាហកម្ម ចាប់ផ្តើមពី ឧស្សាហកម្មស្រាលនិងសប្បកម្ម

**១.កំណើនរហ័សនៃការលក់ដូរតូចតាចពីឆ្នាំ ១៩៧៩៖**

ការចាប់ផ្តើមផលិតកម្មឡើងវិញ នៅឆ្នាំ១៩៨០ នាំឱ្យមានការរីកចម្រើនពាណិជ្ជកម្ម នៅឆ្នាំបន្ទាប់មកខាងផ្នែកឯកជនដែលបន្ថែមដល់ភាពខ្វះខាតនៃសៀគ្វីរដ្ឋភិបាលខាងការងារបែងចែកលក់រាយ ។ ការរីចម្រើននោះរហ័សចំឡែកព្រោះឆ្នាំ ១៩៨៨ ពាណិជ្ជកម្មឯកជនមានជំនួន ៧៥% នៃសកម្មភាពពាណិជ្ជរបស់ប្រទេស ។ នៅឆ្នាំ ១៩៩២ នេះផ្នែកត្រួតត្រាទាំងស្រុងនៅការបែងចែកទាំងលក់ដុំនិងលក់រាយ ។

**កំណើននៃពាណិជ្ជកម្មឯកជន**

ដើម្បីបញ្ជាក់ពីភាពចំណែកដែលទាក់ទងនិងពាណិជ្ជកម្មរដ្ឋ ធៀបនិងពាណិជ្ជកម្មឯកជន គេមានទិន្នន័យពីរបែប ៖

១.ការសន្និដ្ឋានសរុប នៃពាណិជ្ជកម្ម ដក បូក រាយ គិតជាប្រាក់ដុល្លារហើយបានប្រើប្រាស់ក្នុងការវិភាគពាណិជ្ជកម្ម ការសិក្សាផ្នែកសេវាកម្ម ។

២.ការសន្និដ្ឋានមួយនៃ : E .I .U.Country Profile .ថានៅឆ្នាំ ១៩៨៨ ភាគចំណែកនៃពាណិជ្ជកម្មឯកជន គឺ ៧៥% នៃពាណិជ្ជកម្ម ឆ្នាំ១៩៩២ គណ ១០០% ដែលនៅឆ្នាំ ១៩៧៩ គ្មានទាល់តែសោះនៅ សកម្មភាពនេះ។ យើងត្រូវតែប្រៀបផ្ទឹមគ្នានូវទិន្នន័យទាំងនោះហើយធ្វើការបូកសរុប ពីរផ្នែក ទីមួយគឺថយចុះ ទីពីរ គឺកើនឡើងដើម្បីឱ្យដឹងពីភាពចំណែកនៃពាណិជ្ជកម្មឯកជនរវាងដំណាក់កាលទីបី ។គឺអាចធ្វើឱ្យសម្មតិកម្មពីរបែប រវាងឆ្នាំ ១៩៨០ ដល់ ១៩៨៨ ។

- អាចជាស្ថិតិផ្លូវការចុះបញ្ជីសុំណុំនៃពាណិជ្ជកម្មរដ្ឋបូកឯកជន
- ជាស្ថិតិចុះបញ្ជីការតែពាណិជ្ជកម្មរដ្ឋ

ដើម្បីជៀសវាងរាល់ការវាយតម្លៃខ្ពស់ពេកនៃពាណិជ្ជកម្មយើងជ្រើសរើសយករកករ ពិនិត្យលើសសម្មតិកម្មទីមួយ ។ យើងធ្វើមេគុណតាមគណនាបីមុន ដែលកម្រិតសរុបនៃពាណិជ្ជ

កម្ម ដោយមានតម្លៃវិវដ្តន៍ នៃពាណិជ្ជកម្ម ឯកជននិង បន្ថយនៅតម្លៃពាណិច្ចកម្មរដ្ឋតាមតារាងខាងក្រោម៖

| លានដុល្លារ/ឆ្នាំ | ១៩៨០ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ |
|---|---|---|---|---|---|---|---|
| សំណុំពាណិជ្ជកម្ម | ៣៥ | ៣៨ | ២៩.៧ | ៣៥ | ៥៩ | ៤១ | ៤៦.៨ |
| ពាណិជ្ជកម្មរដ្ឋ | ៣១.១ | ៣០.៤ | ២១ | ២២ | ៣២.៤ | ១៨.៨ | ១៨.២ |
| ពាណិជ្ជកម្មឯកជន | ៣.៨៥ | ៧.៦ | ៨.៦ | ១២.៩ | ២៦.៥ | ២២.១ | ២៨.៥ |

| លានដុល្លារ/ឆ្នាំ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៨៩ | ១៩៩០ | ១៩៩១ |
|---|---|---|---|---|---|---|
| សំណុំពាណិជ្ជកម្ម | ៤៨.៨ | ៥៥ | ៦១ | ៦៦ | ៨០ | ១២០ |
| ពាណិជ្ជកម្មរដ្ឋ | ១៥.៦ | ១៣.៧ | ១១ | ៨ | ៤ | ០០ |
| ពាណិជ្ជកម្មឯកជន | ៣៣.១ | ៤១.៣ | ៥០ | ៥៨ | ៦៧ | ១២០ |

ពាណិជ្ជកម្មឯកជន ដែលគ្មានសោះនូវឆ្នាំ ១៩៨៩ ហាក់ដូចជាកើនក្នុងសក្តាមួយដូចតទៅ ៖

- ពីឆ្នាំ ១៩៨៥ ដោយមាន ២២.១ លានដុល្លារ ដែលឆ្លងកាត់ពាណិជ្ជកម្មរដ្ឋតែជាង ១៨.៨លាន ដុល្លារ U.S..។

- ពីឆ្នាំ ១៩៨៥ ដល់ ១៩៩០ ក្នុងពេលដែលផ្ទៃចំណែកនៃពាណិជ្ជកម្ម ចេះតែថយចុះទៅរហូតដល់គ្មានសារៈសំខាន់ ៨ លានដុល្លារពាណិជ្ជកម្មឯកជនបន្តកើនឡើងពីរដងនៅឆ្នាំ ១៩៩០ គឺ ៥៨ លានដុល្លារ ។

- ពីឆ្នាំ១៩៩០ ដល់ ១៩៩២ នៅពេលដែលពាណិជ្ជកម្មរដ្ឋឈានទៅបញ្ចប់ពាណិជ្ជកម្មឯកជនបន្តកើនទ្វេដងក្នុងរយៈពេល ពីឆ្នាំ ឆ្លងពី៥៨ លានទៅដល់ ១២០ លានដុល្លារ ។ ទាំងនោះជាតួលេខពាណិជ្ជកម្មសរុប ព្រោះពាណិជ្ជកម្មរដ្ឋរលាយរលត់អស់ទៅហើយ ។

## ២.ការស្តារសកម្មភាពផ្នែកឧស្សាហកម្ម

| លានដុល្លារ/ឆ្នាំ | ១៩៨០ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ |
|---|---|---|---|---|---|---|
| សំណុំផលិតកម្មឧស្សាហកម្ម | ៣.៥៦ | ២៧.៣ | ២២ | ២៦.៦ | ២២.១ | ២៣.៧ |
| សហគ្រាសកម្មសិទ្ធិសមូហភាព | ៣២.៨ | ២២.៧ | ១៦.៩ | ១៩ | ១៥.៦ | ១៦.៣ |
| សហគ្រាសឯកជន | ២.៧ | ៤.៥ | ៥.១១ | ៧.៥៣ | ៦.៥ | ៧.៣ |
| លានដុល្លារ/ឆ្នាំ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ |
| សំណុំផលិតកម្មឧស្សាហ | ២៤.៧ | ៣៣.៣ | ៤០.២ | ៣៧.៩ | ៦៦.១ | ១៦១.១ |

| | | | | | | |
|---|---|---|---|---|---|---|
| កម្ម | | | | | | |
| សហគ្រាសកម្មសិទ្ធិសមូហភាព | ១៦.៧ | ២០.៤ | ២០.៦ | ១៨.៩ | ១៧.៤ | ២២.៩ |
| សហគ្រាសឯកជន | ៨.០ | ១២.៨ | ១៦.៦ | ១៩.០ | ៣២.២ | ១៣៨.២ |

រដ្ឋាភិបាលបានអនុគ្រោះតាំងពីពេលដំបូងនៅ ការកសាងសហគ្រាសឯកជនតូចៗដែលអាចបំពេញបន្ថែមជាភាគចំណែកខ្វះខាតនៃសគ្រាសរដ្ឋ សម្រាប់ទំនិញចាំបាច់ទីមួយៈ វាយណភ័ណ្ឌ ខោអាវ យន្តសាស្រ្ត រោងជាង ឡស្លដែក សិប្បកម្មកន្លែង ជួសជុល ។ល។ កំណើននៃរចនាសម្ព័ន្ធឯកជនតូចៗ នៅឆ្នាំ ១៩៩១ ដល់ ៤១,៩៤៥ អង្គភាពសិប្បកម្ម ដែលកត់ត្រាទុកចុះបញ្ជីនៃក្រសួងឧស្សាហកម្ម ធ្វើការក្នុងវិស័យផលិតផលប្រពៃណីៈ តំបាញ សារុង សំពតសូត្រ ស្បែក គ្រឿងអលង្កា ចលនាវត្ថុ។ល។ ដែលមានរោងជាងសកម្មភាពកែឆ្នៃ ពាក់កណ្តាលសម្រេចជាសេវា និងកម្មសាលតូចៗ មិនបានចុះបញ្ជីគណនេយ្យទេ ...។

សំណងក្លាយជាក្បាលម៉ាស៊ីន នៃការអភិឌ្ឍន៍នីក្រុង តាមរយៈការរកស៊ីបង្វិលរកចំណេញ។ ពីឆ្នាំ១៩៨៨ ហសគ្រាសឯកជនសម្រេចបាន ៧៤% នៃសំណងបច្ចុប្បន្ន ផ្នែកឯកជនជានាការសាងសង់ ទាំងស្រុងដែលប្រើប្រាស់ពលកម្មភាគច្រើនជាជនវៀតណាម ។

នៅចុងសត្តវត្ស ផ្នែកឯកជនប្រើប្រាស់អស់ប្រហែល ២/៤ នៃពលករដែលរដ្ឋបាលឈប់ប្រើប្រាស់ ពីសហគ្រាសនៃក្រសួងឧស្សាហកម្មមានតែ១/៦ នៃពលករជាផ្លូវការ។ ការវិវដ្តនេះបានប្រព្រឹត្តទៅដោយការសម្រប សម្រួលតាមបទបញ្ជា ។

### ៣.ការសម្របសម្រួលបទបញ្ជាទៅ និងសភាពការថ្មីនាំសហគ្រាស

#### ការបង្កើតក្រុមហ៊ុនចម្រុះ

ក្រុមវិនិយោគបរទេស នៅឆ្នាំ១៩៨៩ រកការទាក់ទាញទុនលើផ្នែកអ្នកបង្កើតរូបីយប័ណ្ណទេសចរណ៍ កសិករ និងឧស្សាហកម្ម ប៉ុន្តែភាពងាយស្រួល បានបង្កលក្ខណៈឱ្យក្រុមហ៊ុនអ្នករចនានៃឈ្មួញកណ្តាល និង បង្កើតនៅសាខាផលិតកម្មមួយមានកម្រិតចំឡែក ឯរចនាសម្ព័ន្ធមិនបានប៉ះពាល់ដោយជុំហរថ្មីនោះទេ ហើយការងារទំនើបសកម្ម ជាប់ទាក់ទងនិងជំនួយអន្តរជាតិ។ អ្នកវិនិយោគជាតថភាពទាំងអស់សុទ្ធតែពួកអាស៊ី ឯពួកលោកខាងលិចចូលចិត្តបើកការិយាល័យតំណាង ។

#### ការរំលាយជាតូបនីយកម្ម

ប្រឈមមុខ និងផលិតផលតិចតួច ពីការធ្វើក្រុមហ៊ុនចម្រុះ គេចាប់ផ្តើមនៅដើមឆ្នាំ ១៩៩០ នៅការផ្ទេរឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ដូចដែលផ្នែកឯកជនបង្កើត សមត្ថភាពផលិតកម្មបាន ៥០% លើកលែងតែសហគ្រាស១៨ ចេញ សុទ្ធតែបានលក់ទៅឱ្យឯកជន ។ នោះជាផលប្រយោជន៍សំខាន់របស់អ្នកទិញ ក្នុងជំហរមានលក្ខណៈរកចំណេញភ្លាម ជាជាងមានឆន្ទៈពិតប្រាកដការអភិឌ្ឍន៍ផលិតកម្ម ។

**យោបល់**

គេពិនិត្យឃើញផងដែរនៅការបោះបង់ចោលពីរចំណុចគឺភាគីរដ្ឋជ្រុងទីមួយ សហគ្រាសឯកជនតូចៗ ទាំងឧស្សាហកម្ម ទាំងពាណិជ្ជកម្ម កាន់តែកើនចំនួនឡើង ។ ជ្រុងមួយទៀតសហគ្រាសតូចៗដែលជាកម្មសិទ្ធសមូហភាព ដែលមិនសូវមានទិន្នផលក៏ត្រូវបានរំសាយពីសមូហភាព ។ ចលនាបាននាំទៅសល់ការកើតជាថ្មីនៅវណ្ណៈសហគ្រិនតូចៗ ដែលមានប្រភពចេញពីកូនកាត់ខ្មែរ-ចិន និងការមកដល់នសពួកវិនិយោគបរទេស ភាគច្រើនជនជាតិដើមជាចិន ។ ពួកទី១ ក៏ដូចចាពួកទី២ ដែលសុទ្ធតែរធ្វើការនៅក្រៅរដ្ឋបាល ។ ថាមពលនៃឯកជនភាវូបនីយកម្មមាននិន្នាការធ្វើឱ្យក្បាលម៉ាស៊ីនសេដ្ឋកិច្ចគ្រប់គ្រងល្អ និងក្លាយទៅជាមានផល្វភាពរៀបចំបាននៅឡូស៊ីកផ្ទៃក្នុងប្រទេសឱ្យដំណើរប្រព័ន្ធនោះបាន ។

យើងក៏ត្រូវប្តូនៅយុទ្ធសាស្ត្រនៃការវិភាគផងដែរ ដើម្បីមើលផលិតកម្មពិនិត្យលើការផ្លាស់ប្តូរក្រៅប្រទេស ។

## ១៤.៣.ការរុករកការផ្លាស់ប្តូរ

### ១៤.៣.១.ការវិភាគបរិមាណនៃការផ្លាសប្តូរក្រៅប្រទេស

ដើម្បីវិភាគការផ្លាសប្តូរ ក្រៅប្រទេសយើងត្រូវពិនិត្យប៉ារ៉ាម៉ែត្រពីរ ៖

-បរិមាណផ្លាសប្តូរ

-រូបភាពនៃមធ្យោបាយទូទាត់ ការផ្លាស់ប្តូរ ពិសេសបំណុលបរទេស

**ក.កំណើនមួយដ៏ប្លែកនៃបរិមាណផ្លាស់ប្តូរ**

| លានដុល្លារ U.S. | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ |
|---|---|---|---|---|---|---|---|
| ការនាំចេញ | ១០.២ | ៤.៣ | ៩.១ | ១២.៧ | ១៧.៧ | ២៥.៣ | ២៧.៤ |
| ការនាចូល | ៤៤.៩ | ៤៩.២ | ៧៣.៨ | ៩២.២ | ៩៦.២ | ១០៧.១ | ១៦.១ |
| គណនេយ្យខាងក្រៅ | ៥១.១ | ៥៣.៥ | ៨២.៩ | ១០៤.៩ | ១១៣.៩ | ១៣២.៤ | ១៤៣.៨ |
| អត្រាគម្រប | ២២.៧% | ៨.0% | ១២.៣% | ១៣.៧% | ១៨.៣% | ២៣.៦% | ២៣.៥% |
| %នាំចូល-នាំចេញ | ៤.៤ | ១១.៤ | ៨.៧ | ៧.២ | ៥.៤ | ៤.២ | ៤.២ |

| លានដុល្លារ U.S. | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ | ១៩៩២ |
|---|---|---|---|---|---|
| ការនាំចេញ | ៣២.៨ | ៤៤.២ | ៣៤.៧ | ៧១.៣ | ៧០.០ |
| ការនាចូល | ១៥៩.៥ | ១៧៩.០ | ១៥០.០ | ៣១១.៣ | ៤៧០ |
| អត្រាគម្រប | ២៥.៨% | ៣២.៧% | ៣០.០% | ២៩.៣% | ១៧.៥៥ |
| %នាំចូល-នាំ | ៣.៨ | ៣.០ | ៣.៣ | ៣.៤ | ៥.៧ |

| | | | | | |
|---|---|---|---|---|---|
| ចេញ | | | | | |

គេសន្និដ្ឋាននៅការវិវដ្តជាពីរដំណាក់កាលខាងបរិមាណខុសៗគ្នា ៖

១.ការរីកចម្រើនជាស្ថេរភាព ប៉ុន្តែតិចតួចរវាងឆ្នាំ ១៩៨២ ដល់ ១៩៨៩ លើកលែងតែនៅឆ្នាំ ១៩៨១ ដែលជាការចាប់ផ្តើមធៀបនិងសំណុំសរុបដែលជាការផ្លាស់ប្តូរកើន ៤ដងពី ៥០ លានដុល្លារ នៅជិត ២០០ លានដុល្លារ ហើយនឹងកំណើន៤ដងនៃអត្រាគម្របដែលឆ្លងពី ១០% ទៅជាង ៣០% ។

២.ឆ្លងឆ្នាំ ១៩៨៩ គេជួលទៅឡូស៊ីកផ្សេងមួយ ៖ បើការនៃចេញបន្តកំណើនស្ថេរ ទ្វេពី ៣៥ លាន ទៅ៧០ លាន U.S.ពី១៩៩០ ទៅ ១៩៩២ ផ្ទុយទៅវិញគេឃើញមានការកើនឡើងខ្ពស់នៃការនាំចូលដែលកើន៤ដងក្នុងរយៈពេល៣ឆ្នាំចាប់ពី ១០០ លានដុល្លារ ទៅ ៤០០ លានដុល្លារ U.S.ដែលនាំទៅអត្រាគម្របដែលធ្លាក់ចុះពី៣០% ទៅ ២០% ។ សមាមាត្រពី១ដល់៤ ធៀបពី១ដល់៦ រវាងការនាំចេញនិងការនាំចូល ។

## ខ.ការប៉ោងឡើងនៃបំណុលបរទេស

ម៉ាស៊ីនសេដ្ឋកិច្ចអាចប្រព្រឹត្តទៅបាន ដោយសារកំណើននៃបំណុលដែលបំពេញបន្ថែមឱ្យឧនភាពពាណិជ្ជកម្ម ។ ដើម្បីសន្និដ្ឋានចំណូលបរទេសគេមានប្រភពពីទិន្នន័យរបស់អនាគារអភិវឌ្ឍន៍អាស៊ី A.D.B.និងទិន្នន័យ O.C.D.E.។ ធៀបរវាង O.C.D.E.និង A.D.B.ឃើញការវាយតម្លៃខ្ពស់នៃបំណុលកម្ពុជា បំណុលជាសំខាន់គិតជាលុយរូប russe ដោយឈរលើមូលដ្ឋាននៃការធៀប រូប-ដុល្លារ រូបីយប័ណ្ណខ្លាំង។ ព្រឹត្តិការណ៍នេះបើវាខុសគ្នាពីអាណត្តិមួយទៅអាណត្តិមួយទៀត ការបន្តដំពាក់បំណុលគឺស្របគ្នា ។

| ការសន្និដ្ឋានរបស់ A.D.B. លានដុល្លារ | ១៩៨០ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៨ | ១៩៨៩ | ១៩៩០ |
|---|---|---|---|---|---|---|---|---|
| បំណុលបរទេស | ២៥២ | ២៤៤ | ២៦៨ | ៤២៦ | ៤៩១ | | | |

| ការសន្និដ្ឋានរបស់ O.C.D.E.លានដុល្លារ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ |
|---|---|---|---|---|---|---|---|---|
| បំណុលបរទេស | ២៩៣ | ២៨៥ | ៣១៨ | ៤៤១ | ៥៩៥ | ៧១៧ | ៩០០ | ១.៤ |
| C.A.E.M | ៨៥% | ៨៨៥% | ៨៤% | ៨៥% | ៨៧% | ៩០% | ៩០% | ៩០% |
| ជំនួយ O.C.D.E. | ៨% | ៨% | ៨% | ៧% | ៦% | ៥% | ៥% | ៥% |
| បំណុលក្រៅ/ P.I.B. | ៥០% | ៥៣% | ៥៦% | ៧៦% | ៩៥% | ១១៥% | ១២០ % | ១៥០% |

| ប្រភពE.I.U. | | | | | | | | |
|---|---|---|---|---|---|---|---|---|

យោងតាមប្រភព O.C.D.E.បំណុលក្រៅប្រទេសបានកើន៥ដងរវាងឆ្នាំ ១៩៨៣ និង ១៩៩០ ឆ្លងពី០.៣ ទៅ ១.៥ ពាន់លានដុល្លារ កើនគ្មានវិធានការរួមជាមួយ P.I.B.ផ្លូវការ ។ ពីឆ្នាំ១៩៨៨ បំណុលក្រៅប្រទេសលើសពី P.I.B.រចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលមិនទាន់ទទួលបានជំនួយមនុស្សធម៌អន្តរជាតិ និងរវាង ១៩៨៨ ដល់ ១៩៩០ បំណុលកើនទ្វេ។ បាតុភូតនេះកើនឡើងខ្លាំងព្រោះ ឧនភាពពាណិជ្ជកម្មបានកើនខ្ពស់ រវាង ១៩៩០ ដល់ ១៩៩២។

នេះជាផលិតផលនៃការផ្លាស់ប្តូរ ដែលម៉ាស៊ីនសេដ្ឋកិច្ចត្រូវបិទទ្វាដោយសារការខាត និងរលំ ។

គឺមិនត្រឹមតែម៉ាស៊ីនសេដ្ឋកិច្ចតែមួយ ត្រូវតាំងតំណើរនោះទេ ប៉ុន្តែបរិមាណផ្លាស់ប្តូរទំនិញកើន ៣ដងរវាងឆ្នាំ ១៩៩០ ដល់ ១៩៩២ ។

ការគិតគូឡើងវិញដោយការវិភាគលើទិន្នន័យផ្នែកនានា ធ្វើឱ្យយល់ដឹងថាតើត្រូវប៉ះពាល់បែបណា នៅឆ្នាំ១៩៨០ ពីកម្រិតបរិមាណមួយទៅកម្រិតការផ្លាស់ប្តូរ ដូចជាបំណុលក្រៅប្រទេស ។ ដើម្បីស្វែងយល់ពីការផ្លាស់ប្តូរឡូស៊ីកយើងវាភាគទាំងបរិមាណ និងតាមផ្នែកនានានៅប្រព័ន្ធផ្លាសប្តូរក្រោមរូបភាពសមូហភាពផលិត ផលនិងមុខងាររបស់ខ្លួននោះគឺភាគនានានិងភ្នាក់ងាផ្សេងៗ ។

## ១៤.៣.២.ការវិភាគគុណភាព និង ផ្នែកនានា

នៅមានការពង្រីកនៅរូបភូមិសាស្ត្រនៃការផ្លាស់ប្តូរ ចាប់ពីឆ្នាំ ១៩៩០ មកមានកំណើនពាណិជ្ជកម្មក្រៅប្រទេស និងការបំបោងនៃការនាំចូលព្រោះការផ្លាស់ប្តូរ បរទេសជាមួយកម្ពុជាទទួលបានទិន្នផលដែលនាំឱ្យមានការសិក្សាទៅតាមផលិតផលនីមួយៗ ។

### ក.ប្រភពនៃទិន្នផល

ភាពដូចគ្នានៃតារាងដែលបង្ហាញមិនអាចជ្រួលច្រលំបានទេលើមតិពីរ៖

១.តួលេខនោះជាផ្លែផ្កានៃការគណនាជាថ្មី ចេញពីប្រភពជាច្រើនតួលេខជាច្រើនបណ្តោះអាសន្ន និងមិនដូចគ្នាទេ។ ការប្រៀបធៀបពីមួយទៅមួយ៖

- ពីឆ្នាំ ១៩៨១ ដល់ ១៩៨៧ តួលេខដែលប្រមូលដោយ អង្គការសហប្រជាជាតិទទួលបន្ទុកអភិវឌ្ឍន៍ កម្ពុជា U.N.D.P.ដែលបំបែបសមាសភាពតាមប្រភេទនិងតម្លៃ ។

- ពីឆ្នាំ ១៩៨៨ ដល់ ១៩៩០ តួលេខនៃក្រសួងពាណិជ្ជកម្មដែលបានបំបែកសមាសភាពជាបរិមាណចាំបាច់មានការគណនាថ្មីជាអាណត្តិតម្លៃធៀបនឹងថ្លៃនៃឆ្នាំ ១៩៨៣ គេមានតួលេខជាបរិមាណក្រសួង និងតម្លៃ U.N.D.P ។

- សម្រាប់ឆ្នាំ១៩៩១ ដល់ ១៩៩២ ទិន្នន័យផ្តល់ឱ្យដោយក្រសួងពាណិជ្ជកម្មគិតជាអាជ្ញាប័ណ្ណនាំចូលនិងនាំចេញ តាមមុខផលិតផល និងតម្លៃ ដែលរីកធំពេកមិនអាចរកបាននូវ

រចនាសម្ព័ន្ធដែលនាំចូលសម្រាប់ឆ្នាំ១៩៩១ និង សម្រាប់ឆ្នាំ ១៩៩២ គេមានតែអាជ្ញាប័ណ្ណផ្តល់ឱ្យក្នុងរយៈពេលដំបូងនៃឆ្នាំនោះដែលសរុបយោបល់ដើម្បីការសន្និដ្ឋានឱ្យបានលើឆ្នាំនេះ ។

### ខ.មុខទំនិញមិនមានឈ្មោះ

និយមន័យនៃមុខទំនិញមានស្ថេរភាពរហូតដល់ឆ្នាំ ១៩៨៧ ។ ពីឆ្នាំ ១៩៨៨ គេត្រូវរៀបចំពិស្តារដល់ប៉ុស្តិ៍នានា ដែលបានទាប់មកមានកាប្តូរជាថ្មី នៅឆ្នាំ ១៩៩១ ដែលប្រភពព័ត៌មានតែមួយដែលអាចយកបាន គឺអាជ្ញាប័ណ្ណនាំចូល និងនាំចេញ ។ ឧទាហរណ៍រហូតដល់ឆ្នាំ ១៩៩០ ផលិតផលប្រណិតចាត់ចូលក្នុង ប្រទេសផ្សេងៗ រូបភាពនេះបានត្រូវដាក់ឈ្មោះចំនៅឆ្នាំ ១៩៩២ ដែលមានសមាសភាពផលិតនោះ គឺប្លែកៗ ដូចជារថយន្ត ស្រាបៀរ ទូរទស្សន៍ម៉ាញ៉េ និង ម៉ាស៊ីនត្រជាក់ ។

### ១.ការនាំចូល

| លានដុល្លារU.S.--- ឆ្នាំ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ |
|---|---|---|---|---|---|---|
| ទិញសម្ភារម៉ាស៊ីន និងរថយន្ត | ៧.៣ | ១៨.៦ | ២៩.០ | ៣៤.០ | ៣៥.២ | ៤៦.៣ |
| ផលិតផលប្រេងឥន្ធនៈ | ១៤.៩ | ១៣.០ | ២៣.០ | ៣៣.៥ | ៣១.៧ | ២៨.៥ |
| វាយណភ័ណ្ឌ | ២.៧ | ៥.៦ | ៧.០ | ៩.០ | ៩.០ | ១៣.០ |
| ផលិតផលគីមី និងឧសថ | ០ | ០ | ០ | ១.៤ | ៣.៤ | ២.៣ |
| ផលិតផលប្រណិត | ០ | ០ | ០ | ០ | ០ | ០ |
| ផ្សេងៗ[២៤] | ២០.០ | ១២.០ | ១៤.៨ | ១៤.៣ | ១៨.០ | ១៧.០ |

| លានដុល្លារU.S.--- ឆ្នាំ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ | ១៩៩២ |
|---|---|---|---|---|---|---|
| ទិញសម្ភារម៉ាស៊ីន និងរថយន្ត | ៤៦.០ | ៤១.៩ | ២០.៣ | ១១.៧ | _ | ៦០.០[២៥] |
| ផលិតផលប្រេងឥន្ធនៈ | ៣០.៥ | ៤៣.០ | ៤៥.០ | ៥០.៨[២៦] | _ | ១២០.៩ |
| វាយណភ័ណ្ឌ | ១៥.០ | ១៧.១[២៧] | ១៥.៥ | ៩.២ | _ | ០ |
| ផលិតផលគីមីនិងឧសថ | ២.០ | ១.៩ | ១.៦ | ១.១ | _ | ០ |
| ផលិតផលប្រណិត | _ | _ | _ | _ | _ | ២១៦[២៨] |
| ផ្សេងៗ | ២២.៩ | ២២.៨ | ៥២.៥ | ៤២.៥ | _ | ៣.៤ |

| ការនាំចូល %នៃតម្លៃ -ឆ្នាំ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ |
|---|---|---|---|---|---|---|
| ទិញសម្ភារ ម៉ាស៊ីន និងរថយន្ត | ១៦.២% | ៣៧.៨% | ៣៩.២% | ៣៦.៨% | ៣៦.៥% | ៤៣.២% |
| ផលិយផលប្រេងឥន្ទ: | ៣៣.១% | ២៦.៤% | ៣១.១% | ៣៦.៣% | ៣២.៨% | ២៦.៦% |
| វាយណភ័ណ្ឌ | ៦.០% | ១១.៣% | ៩.៤% | ៩.៧% | ៩.៣% | ១២.១% |
| ផលិតផលគីមី និងឧសថ | _ | _ | _ | ១.៥% | ២.៣% | ២.១% |
| ផលិតផលប្រណិត | _ | _ | _ | _ | _ | _ |
| ផ្សេងៗ | ៤៤.៥% | ២៤.៤% | ២០.០% | ១៥.៥% | ១៨.៧% | ១៥.៨% |

| ការនាំចូល %នៃតម្លៃ -ឆ្នាំ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ | ១៩៩២ |
|---|---|---|---|---|---|---|
| ទិញសម្ភារ ម៉ាស៊ីននិងរថយន្ត | ៣៩.៥% | ៣៣.០% | ១៥.១% | ១០.២% | _ | ១៤.៩% |
| ផលិយផលប្រេងឥន្ទ: | ២៦.២% | ៣៤.០% | ៣៣.៣% | ៤៤.០% | _ | ៣០.១% |
| វាយណភ័ណ្ឌ | ១២.៨% | ១៣.៥% | ១១.៥% | ៨.០% | _ | _ |
| ផលិតផលគីមី និងឧសថ | ១.៧% | ១.៥% | ១.២% | ១.០% | _ | _ |
| ផលិតផលប្រណិត | _ | _ | _ | _ | _ | ៥៣.៨% |
| ផ្សេងៗ | ១៩.៦% | ១៨.០% | ៣៨.៩% | ៣៦.៨% | _ | ០.៨% |

«២៥» មុខទីនិញដូចជាស៊ីម៉ង់ ដែកសំណង់ត្រាកទ័រ រថយន្តដឹកជញ្ជូន រថយន្តទេសចរណ៍ណ៍ នាំចូលឆ្នាំ ១៩៩២ ជាមុខទំនិញប្រណិត ។

«២៦» គិតថ្លៃប្រេងឥន្ទ:នឹងនពីឆ្នាំ១៩៨៧ ដល់ ១៩៨៩។ ទិន្នន័យឆ្នាំ១៩៨៧ ដល់ ១៩៨៩ខុស ។

«២៧»គណនាថ្លៃវាយណភ័ណ្ឌនឹងនពីឆ្នាំ១៩៨៧-១៩៨៩។ស្ថិតិពី១៩៨៧-១៩៨៩ នៅមិនត្រឹមត្រូវ ។

«២៨» បារីបរទេសមាន ១០៦% នៃអាផ្ជាប័ណ្ណនាំចូលក្នុង ៥ ខែ ដើមឆ្នាំ ១៩៩២ ។

ជាតម្លៃមិនដាច់ខាត របនាសម្ព័ន្ធនាំចូលមិនបានផ្លាសប្តូរទេលើកលែងតែចំណុចមួយផលិតផលប្រណិតដែល ឈានទៅជំនួសទំនិញទិញសម្ភារ ។

### ១៤.៣.៣.ការវិភាគពិស្តារ

វាងដើមឆ្នាំ ១៩៨០ ដល់ ១៩៩២សមាសភាពនាំចូលបានកែប្រែ ការផ្តល់ចេញកើតមានឡើងនៅ១៩៨៩ ៖

១.រហូតដល់ឆ្នាំ ១៩៨៨ ជារចនាសម្ព័ន្ធនឹងនដែលមានសារៈសំខាន់ ខាងទំនិញទិញសម្ភារ និង ផលិតផលប្រេងឥន្ទៈ ។ ភាពចំណែក ទិញសម្ភារ ម៉ាស៊ីន និង រថយន្ត មាន ៣០%-៤០% ជាមធ្យមភាគចំណែកនៃប្រេងឥន្ទៈមានពី ២៥%-៣៥% ហើយការដួលរាយណាក័ណ្ឌមាន ១០% ។

រចនាសម្ព័ន្ធដែលជាការអនុវត្ត ក្នុងនៃបម្រើឱ្យសង្គ្រាម ដែលកើតនូវការនាំចូលយុទ្ធសាស្ត្រ ឧបករណ៍យោធា ឯចំណែកនៃសេចក្តីត្រូវការឧសថ និងអាហារ នៅមិនគ្រប់គ្រាន់ទេលើកលែងតែជីគីមី ។

២.ពីឆ្នាំ ១៩៨៩ ការប្តូររចនាសម្ព័ន្ធផលិតផលនៃការប្រើប្រាស់មានរវាង ១/៣ នៃពាក់កណ្តាលនៃការនាំចូលភាគចំណែកនៃទិញសម្ភារ ម៉ាស៊ីន និង រថយន្ត ហើយថយពាក់កណ្តាលនៃភាគចំណែកនៃប្រេងឥន្ទនៈនឹងនហើយផលិតផលប្រណិតលេចឡើងវិញនៅឆ្នាំ ១៩៩១ ហើយឆ្នាំ ១៩៩២ មានលើសពាក់កណ្តាលនៃការទទួល ។

គេឃើញមានការឱ្យនិយមន័យជាថ្មី ដល់ការនាំចូលមិនមែនក្នុងនាមនៃទិញសម្ភារ ដែលជាអាណត្តិ នៃទំនិញប្រើប្រាស់ពិសេសគ្រឿងប្រណិត។ គឺថាមុនមែនទីផ្សារនៅក្នុងប្រទេសកម្ពុជាទេ ដែលស្របយកផលិត ផលទាំងនោះ គឺជាការនាំចេញទៅវិញនូវទំនិញទាំងនោះ ដែលប្រត្តិបត្តិការយោងទៅតាមប្រព័ន្ធនៃឥណទាន revolving ដែលជាប់ទាក់ទង។ ពួកប្រតិបត្តិការនោះ ជាឈ្មួញកណ្តាលជាពិសេសពួកចិននៅឯបរទេសមិនមែនបំពេញបំណងប្រាថ្នានៃម៉ាស៊ីនសេដ្ឋកិច្ចជាតិទេតែប្រើប្រាស់កម្ពុជាដូចជាចំណួចឆ្លងកាត់ស្របមួយ ។

នេះជាការបញ្ជាក់នៅរូបភាពនៃការប្រព្រឹត្តទៅ នៃការនាំចេញ ។

### ២.ការនាំចេញ

| លានដុល្លារ-ឆ្នាំ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ |
|---|---|---|---|---|---|---|
| កៅស៊ូ | ២.៥ | ៣.៣៩ | ៦.៩ | ៧.៦ | ១០.២ | ១៧.៤ |
| ឈើមូល | ០ | ០.០២ | ០.១៨ | ១.០៣ | ១.៧៣ | ១.៦ |
| ផលិតផលកសិកម្មដំទៃ | ៧.៦ | ០.៨៥ | ១.៧ | ២.៧៥ | ៣.៩៣ | ៥.៥៦ |
| ផ្សេងៗ | ០.១ | ០.០៤ | ០.៣៥ | ១.៣២ | ១.៨៤ | ០.៧៤ |

| លានដុល្លារ-ឆ្នាំ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ | ១៩៩២ |
|---|---|---|---|---|---|---|
| កៅស៊ូ | ១០.៦ | ២២.៦ | ២៥.៥ | ១៧.៧ | ១៧.៧ | ១១.២ |
| ឈើមូល | ១.៨ | ៣.៣ | ៧.៩ | ៧.៩ | ២៤.៨ | ២៩.៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ផលិតផលកសិកម្មដ៏ទៃ | ៤.៤៨ | ៥.៦៨ | ៩.៥៧ | ៧.២៦ | ២២.៧ | ១៣.៥ |
| ផ្សេងៗ | ១.៥២ | ១.២២ | ១.២៣ | ១.៥៤ | ៦.១០ | ១០.៩ |

| របនាសម្ព័ន្ធនាំចេញ % | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ |
|---|---|---|---|---|---|---|
| កៅស៊ូ | ២៤.៧% | ៧៨.២% | ៧៥.៨% | ៥៩.៨% | ៥៧.៦% | ៦៨.៧% |
| ឈើមូល | 0% | 0.៤% | ១.៦% | ៨.១% | ៩.៧% | ៦.៣% |
| ផលិតផលកសិកម្មដ៏ទៃ | ៧៥.២% | ១៩.៧% | ១៨.៦% | ២១.៦% | ២២.២% | ២១.៩% |
| ផ្សេងៗ | 0.១% | ១.៧% | ៤.0% | ១0.៥% | ១0.៥% | ៣.១% |

| របនាសម្ព័ន្ធនាំចេញ % | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ | ១៩៩១ | ១៩៩២ |
|---|---|---|---|---|---|---|
| កៅស៊ូ | ៧១.៥% | ៦៣.៦% | ៥៧.៦% | ៥១.0% | ២៤.៩% | ១៦.១% |
| ឈើមូល | ៦.៥% | ១0.0% | ១៧.៨% | ២២.៧% | ៣៤.៩% | ៤២.0% |
| ផលិតផលកសិកម្មដ៏ទៃ | ១៦.៣% | ១៧.៣% | ២១.៦% | ២0.៩% | ៣១.៩% | ១៥.៩% |
| ផ្សេងៗ | ៥.៧% | ៥.១% | ៣៣.0% | ៥.៤% | ៨.៣% | ២៦.0% |

ប្រទេសកម្ពុជានូវតែអ្នកនាំចេញកសិផលចម្បងក្នុងចន្លោះ៨៩%-៩៩%នៃការនាំចេញឆ្នាំ ១៩៩២ ប៉ុន្តែចំពោះការនាំចូលគេសន្និដ្ឋានថាការវិវដ្តពីដំណាក់កាលៈការនាំចេញដែលប្តូររចនាសម្ព័ន្ធនូវឆ្នាំ ១៩៩០ ។

១.ដំណាក់កាលទីមួយ ពីឆ្នាំ ១៩៨៩ បញ្ជាក់ពីសារៈសំខាន់នៃវិស័យកៅស៊ូ ។

- កៅស៊ូមានចំនួនរវាង ២/៣ នៃការនាំចេញប៉ុន្តែសារៈសំខាន់នោះ បានថយចុះជាបន្តបន្ទាប់ក្នុងដំណាក់កាលនោះ ។
- ភាគចំណែកនៃកសិផលដ៏ទៃទៀត នៅនឹងន ពីរវាង ១៦% ទៅ
- ឈើកើនឡើងជាប្រចាំពី 0.៦0% នៅឆ្នាំ ១៩៨១ ទៅ ២២.៧% នៅឆ្នាំ ១៩៩០ ។

**.ដំណាក់កាលទីពីរ ពី១៩៩០**

- កៅស៊ូថយចុះបី ៥១% នៅឆ្នាំ ១៩៩០ ទៅ ១៦% នៅឆ្នាំ ១៩៩៦ គឺមានការថយចុះ ២/៣ នៃតម្លៃមិនដាច់ខាត
- ភាគចំណែកឈើបានកើនទ្វេ ជានាបានជាង ១/៥ នៃចំណូលនៃការនាំចេញនៅឆ្នាំ ១៩៩០ ហើយនៅឆ្នាំ ១៩៩២ ឈើមានចំនួន២/៥ នៃការនាំចេញ ។

- ភាគចំណែកនៃផលិតផលកសិកម្មដ៏ទៃទៀតស្ថិតនៅនឹងន លើកលែងតែនូវឆ្នាំ ១៩៩១ ដែលគេសន្និដ្ឋានកើកឡើងពីដងដែលមិនអាចពន្យល់បាននៃការនាំចេញសណ្តែកសៀង ។

ការបើកទូលាយដល់កម្ពុជា បានទៅដល់ការប្តូរចនាសម្ព័ន្ធនាំចេញដូចតទៅ ៖

- បើកៅស៊ូមានសកម្មភាពដូចប្រភេទកសិឧស្សាហកម្ម

- កសិផលដ៏ទៃទៀត ក៏ដូចកិច្ចអភិវឌ្ឍន៍ កសិកម្មបង្វលចំណេញដែលមានប្រភពកសិផល ជាច្រើនដែលទប់ទល់បាននូវចលនាជំនោបន្ទាន់នៃទីផ្សារ ដូចការដាំដុះលើដីចំការ ។

- ហើយការលក់ឈើមូល នូវតែជាសកម្មភាពបំផ្លាញដែលគ្មានបានដាំឈើឡើងវិញសោះហើយការនាំឈើនោះទៀតមានចំនួនតែ ១/៣ ជាផ្លូវការទៀតផង ។ នៅពេលភាគរយឆ្នាំទៀត ១៩៩៥ កម្ពុជា គ្មានឈើនាំចេញទៀតទេ បើសិនសង្វាក់នៃការកាបឈើដូចសព្វថ្ងៃ ចេះតែប្រព្រឹត្តទៅនោះ ។ គេអាចនិយាយថាបាននាំចេញអាចកើនទ្វេបើអាចធ្វើការដាំដុះដីចំការបានកាន់តែច្រើននោះ ។

## ១៤.៤.ការកែប្រែមុខងារ

### ១៤.៤.១.ការប្តូរសមតាគី

ដើម្បីសន្និដ្ឋានរចនាសម្ព័ន្ធភូមិសាស្ត្រ គេអាចមានតួលេខច្បាស់កាស់មិនដាច់ខាត ដែលផ្តល់ឱ្យដោយក្រសួងពាណិជ្ជកម្មដែលឱ្យធ្វើការវិភាគជាអាណត្តិ ។

**ការវិភាគលើតួលេខ**

នៅពេលដែលមានការរកស៊ីជាមួយគ្នានៅឆ្នាំ ១៩៨០ ជាមួយតំបន់ប្តូរប្រាក់ បាននៅការផ្លាស់ប្តូរទំនិញមានចំនួន ៦០% នោះការវិវត្តពាណិជ្ជកម្មក្រៅប្រទេសនោះ មានសមាសភាពពីដំណាក់កាល ៖

១.ពីឆ្នាំ ១៩៨១ ដល់ ១៩៩០ កាផ្លាស់ប្តូរជាក្រុមព្រឹក្សាជួយគ្នាទៅចិញទៅមក C.A.E.M.មានជាង៨០% នៃមធ្យមភាគនៃការផ្លាស់ប្តូរដោយអតិតសហភាពសូវៀតជានា រវាងពាក់កណ្តាល និង ២/៣ នៃជំនួយ ។ ការផ្លាស់ប្តូរប្រព្រឹត្តទៅលើមូលដ្ឋាននៃសហភាគីនិងបែបបទ Clearing ជាយន្តបំពេញបន្ថែមឬការផ្លាស់ប្តូរធ្វើជាគណនេយ្យទាំងសងខាងដែលសមតុល្យតែមួយបានត្រូវដោះស្រាយពិតប្រាកដ និង ជំនួយពហុភាគី ។

២.នៅឆ្នាំ ១៩៩១ ការបញ្ឈប់ជំនួយសហភាពសូវៀតនឹងរលំរលាយនៃប្លុកខាងកើតបានកើតឡើនៅតំបន់ប្តូរប្រាក់ជំនួយឱ្យតំបន់លុយរូប ដែលនាំទៅដល់ការផ្តល់និយមន័យជាថ្មីដល់ទៅបីដងនៃប្រព័ន្ធផ្លាស់ប្តូរក្រៅប្រទេស។

- មានមនោគមន៍វិជ្ជាមិនមែនជាប្រទេសកម្មយនីស្តទៀតទេនោះជាសមភាគីនៃកម្ពុជាតែជាប្រទេសបូកធន

- ជាការប្រព្រឹត្តទៅនៃការផ្លាស់ប្តូរមិនមាននិយមន័យឈរលើមូលដ្ឋានរវាងរដ្ឋ និងរដ្ឋទៀតទេ ប៉ុន្តែឈរលើមូលដ្ឋាននៃចម្លងការពាណិជ្ជកម្មសុទ្ធសាធ ។

- ជាភូមិសាស្ត្រគឺទីមួយនៃការផ្លាស់ប្តូរ គឺមិនមែនប្រទេសអឺរ៉ុបទៀតទេ តែជាប្រទេសអាស៊ីអាគ្នេយ៍ចាប់ផ្តើមពីសឹង្ហបូរី ៦០% នៃការនាំចូលផ្លូវការ និង ២៦% នៃការនាំចេញកម្ពុជានៅឆ្នាំ១៩៩២ ។

ការឃ្លាតចេញនៃប្លុកខាងកើតនៅឆ្នាំ ១៩៩១ បានបង្ខំកម្ពុជាឱ្យបញ្ចូលខ្លួនទៅក្នុងឡូស៊ីកមួយក្នុងតំបន់ក្នុងការផ្លាស់ប្តូរពាណិជ្ជកម្មសុទ្ធសាធ ជំនួយឱ្យសាមគីសាធារណៈ លើមូលដ្ឋានប្តូរទំនិញ មិនប្រើរូបីយប័ណ្ណជាសាមគីឯកជន ដែលឈរលើឥណទាន ។

## ១៤.៤.២.ការប្តូរខ្នាត់ខារ

ការវិភាគភ្នាក់ងារអាចឱ្យកាន់តែយល់នៅការវិវដ្ត នៃការប្រព្រឹត្តិទៅនៃមុខងារនេះ ។ដូចយើងទើបបានឃើញនៅពេលនេះលើផែនការសង្គមសេដ្ឋកិច្ច ភាពផ្ទុយគ្នាអាណត្តិរបស់ការប្តូរជាគុណសម្បត្តិនិងមុខងារ ។

តាំងពីការរៀបចំជាថ្មីនៃម៉ាស៊ីសេដ្ឋកិច្ច កម្ពុជាបានប្រឈរមុខទៅនឹងការហាមឃាត់ពីរ ៖

- ការហាមឃាត់របស់លោកខាងលិច ចាប់សហរដ្ឋអាមេរិក បានផ្តល់សម្ភារសម្រាប់ឆ្នាំ ១៩៧០-១៩៧៥ ជាបញ្ហាគ្រឿនបន្លះ ។

- ហើយនឹងការហាមឃាត់នៃចិនប្រជាមានិតជាផលិតករ ទីមួយនៃទំនិញប្រើប្រាស់មានបទដ្ឋាននៅក្នុងភូមិភាគជាបញ្ហាផ្គត់ផ្គង់ ។

ជំនួយរបស់ C.A.E.M.មិនគ្រប់គ្រាន់បំពេញសេចក្តីត្រូវការទាំងស្រុង រដ្ឋាភិបាល បានបង្ខំចិត្ត លះបង់ការផ្តាច់មុខរបស់រដ្ឋដោយចាប់យកវិធានការពីរ ៖

១.ការបង្កើតក្រុមហ៊ុននាំចេញ-នាំចូលឯកជននៅក្នុងព្រំដែនច្បាប់ ព្រោះមិនទាន់ទទួលស្គាល់ដោយរដ្ឋ មុនឆ្នាំ ១៩៨៩ បានធ្វើប្រតិបត្តិការពីប្រភេទក្នុងការងារចម្លងការ ៖

- ចំណែកទី១ ការនាំចូលទំនិញអាចឱ្យប្តូរប្រាក់តាមរយៈការផ្ទេររូបិយប័ណ្ណរបស់ពួកពាណិជ្ជករបរទេសដែលតាមគោលការធនាគារ ធម្មតាធ្វើមិនបានតាមរយៈការហាមឃាត់រកស៊ីជាមួយលោកខាងលិចយោងតាមយន្តការបែបបទផ្ទេរប្រាក់អនុវត្តន៍នៅវៀតណាម ...ដែលធ្លាប់រកស៊ីប្តូរទំនិញជាមួយសឹង្ហបូរី ។

- មួយចំណែកទៀតការនាំចេញទៅវិញនូវទំនិញមួយចំណែកនៃទំនិញនាំចូលនោះ ៣០% យោងតាមក្រសួងពាណិជ្ជកម្ម តាមផ្លូវគោក តាមរូបភាពខុសច្បាប់ ជាទិសដៅទីពីរព្រោះទំនិញពាក់កណ្តាលធ្លាក់ចូលជាថ្មីឡើងវិញនៅក្នុងសៀគ្វី សេដ្ឋកិច្ចលាក់មុខ ។

២.ក្រុមហ៊ុនសមាគមន៍ អ្នកចរចា របស់រដ្ឋាភិបាល ជាមួយក្រុមហ៊ុនជប៉ុន តូចៗ ដែលអាចឱ្យបង្វិល កុងតឺន័រពីរដែលផ្គត់ផ្គង់គ្រឿងបន្លះ សម្រាប់ទិញសម្ភារ ម៉ាស៊ីនអាមេរិកកាំង និងចិន ។

ចាប់ពី ១៩៨០ មករដ្ឋាភិបាលបានរៀបចំឡើងនៅនឹងក្រុមហ៊ុនរដ្ឋាភិបាល ជាក្រុមហ៊ុនវត់គយ ប្រព្រឹត្តទៅពេខ្លះ ជាមួយនឹងក្រុមហ៊ុនជប៉ុន ឬជាមួយនិងក្រុមហ៊ុនឯកជនទាំងស្រុង ។

ការបើកទ្វារនៅឆ្នាំ ១៩៨៩ បានបង្កើតយ៉ាងបន្ទាន់នូវការអភិវឌ្ឍរបស់ក្រុមហ៊ុនអ្នករកស៊ីផ្ទេទំនិញឯនាយសមុទ្រ negoce ដែលជាថ្មីឡើងបានដួលផ្ញើសកម្មភាព ពេលអង្គការសហប្រជាជាតិមកដល់ នៅខែមិថុនា ១៩៩២ នៅកម្ពុជា មានក្រុមហ៊ុននាំចេញ-នាំចូលចំនួន ២១៤ ដែលបានចុះបញ្ជី នៅក្រសួងពាណិជ្ជកម្ម ដោយមិនរាប់ចូលពួកប្រតិបត្តិការលាក់មុខ។ ទំនាក់ទំនងរវាងពួកប្រតិបត្តិការរដ្ឋ និងឯកជន ក្នុងកម្រិតពាណិជ្ជកម្មផ្លូវការ មានវត្តមានពីឆ្នាំ ១៩៩១ ដូចតទៅ ៖

| ក្រុមហ៊ុនរដ្ឋ ៖ ក្រុមហ៊ុនឯកជន |
|---|
| ភាគរយនៃការនាំចេញ ១៩៩១ ៖ ៨៦.៥% ៖ ១១%<br>ភាគរយនៃការនាំចូល ១៩៩១ ៖ ១ ៖ ១ |
| ភាគរយនៃការនាំចេញ ១៩៩១ ៖ ៧៦% ៖ ២២%<br>ភាគរយនៃការនាំចូល ១៩៩១ ៖ ៣៣.៥% ៖ ៦៦.៣% |

រដ្ឋបានបាត់បង់នូវអ្វីដែលជាការត្រួតពិនិត្យ លើការផ្លាស់ប្តូរផ្លូវការ ៖

- ភាគចំណែកនៃក្រុមហ៊ុនរដ្ឋ និងការនាំចេញត្រូវថយចុះមិនមែនត្រឹមតែរម្លូសដាច់ខាតទេតែទាំងតម្លៃមិនដាច់ខាត ឈើមានចំនួនបរិមាណសំខាន់ សម្រាប់នាំចេញ ភាគចំណែកនៃការនាំចេញ ឈើត្រូវការបានថយចុះធៀបនឹងការលក់ក្រៅផ្លូវគយ និង រដ្ឋករ ។

- ការនាំចូលដែលមានចំនួន ៤/៥ នៃការផ្លាសប្តូទំនិញបានប្រព្រឹត្តទៅក្រៅផ្លូវការរដ្ឋ។ អំពើរត់ពន្ធគយ ប្រព្រឹត្តិទៅក្នុងសំណុំ នៃការផ្លាស់ប្តូរទំនិញ ។

## តុល្យការនៃការផ្លាស់ប្តូរទំនិញ

កំណើននៃការផ្លាស់ប្តូរពីឆ្នាំ ១៩៩០ ធ្វើឱ្យមានការផ្លាស់ប្តូរបីយ៉ាង៖

១.ជាគុណភាពមានការកែលម្អ នៅសមាសភាពការផ្លាស់ប្តូរ កម្ពុជានាំចូល នូវផលិតផលប្រណិត និងនាំចេញនៅឈើ ។

២.ជាមុខងារក្នុងកម្រិតបែបបទប្រតិបត្តិការការផ្លាស់ប្តូរបច្ចុប្បន្ន សម្រេចឡើងជាមួយប្រទេសនៅចុងបូព៌ាប្រតិបត្តិការ ប្រព្រឹត្តទៅជាឥណទាន ហើយមិនមែនជាជំនួយ ឬជាការប្តូរទំនិញគ្នានោះទេហើយក្រុមហ៊ុនឯកជនត្រួតត្រា ៣/៤ នៃការផ្លាស់ប្តូរផ្លូវការ ។

ឡូស៊ីកនៃការផ្លាស់ប្តូរ គឺផ្ទុយមកវិញ៖ ពេលចេញដំណើរ គឺធ្វើឡើងលើជំនួសពហុភាគីការផ្លាស់ប្តូរ បច្ចុប្បន្ន ឈរលើមូលដ្ឋានឡូស៊ីកបរិសុទ្ធ ភាពក្រៅច្បាប់ តាមរយៈពន្ធគយទៀតហើយ ។ កម្ពុជាបានក្លាយជាផ្លាក់វិល និងជាទឹកដីនៃការប្រម៉ាញ់ ក្នុងដៃនៃពួកប្រតិបត្តិការអាស៊ីអាគ្នេស៍ ដែលប្រព្រឹត្តទៅតាមបែបបទពួក ម៉ាហ្វីយ៉ា ។

### ១៤.៤.៣.តុល្យការៈ តើការសន្និដ្ឋានបែបណា ដែលអាចផ្តល់ឱ្យឃើញ នូវផលទុនដុលទុនដុលក្នុងប្រទេសរបស់កម្ពុជាបាន ?

ការវិភាគមុននេះបានធ្វើឱ្យលេចចេញថាសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈកំណើនពីរបែប ៖

- កំណើនទន់ភ្លន់មួយនៅផលិតកម្ម តែផលិតផលមួយចំនួនបាត់បង់ទៅវិញពីស្ថិតិផ្លូវការ ។

- កំណើនសកម្មមួយនៃការផ្លាស់ប្តូរក្រៅពីការត្រួតពិនិត្យខុសច្បាប់ ។

បញ្ហាផលទុនដុលរបស់ជាតិកម្ពុជា ស្ថិតនៅក្នុងអាណត្តិដែលផុតពីការធ្វើតុល្យការស្ថិតិផ្លូវការធម្មតា ដែលត្រូវធ្វើគណនាជាថ្មី។ យើងចាប់ផ្តើមតុល្យការដែលយើងបានដឹងពី P.N.B.ផ្លូវការហើយយើងធ្វើការវាយតម្លៃនូវ P.N.B.ដែលកប់លាក់មុខតាមរយៈការធ្វើសម្មតិកម្មលើ P.N.B.ពិតប្រាកដ ។

#### ១.បញ្ហា P.N.B.និងប្រភពធនធាន

តួលេខពាក់កណ្តាលផ្លូវការ ជាផ្នែកមិនគ្រប់គ្រាន់ និងជាការសន្និដ្ឋានផ្ទុយគ្នា ។យើងមានប្រភពច្រើនមួយចំណែកជាប្រភពផ្លូវការកម្ពុជាហើយមួយចំណែកទៀតជាប្រភពអន្តរជាតិ។ មានលទ្ធភាពក្នុងការសាងរកតួលេខ ចេញពិការបូកសារុបរួម ដើម្បីធ្វើការប្រៀបធៀប ។

#### ១.ប្រភពកម្ពុជា

គេមានការសន្និដ្ឋានមួយរបស់ក្រសួងជារៀលនឹងន រៀបចំលើមូលដ្ឋាននៃការប្រៀបធៀប រៀល/ដុល្លារ គឺ ២៨រៀល។ គេរកឃើញជាតម្លៃដុល្លារ ៖

| រៀល«នឹងន» ---ឆ្នាំ | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ |
|---|---|---|---|---|---|---|---|
| ការសន្និដ្ឋានរបស់ក្រសួងផែនការ១ដុល្លារ=២៨៛ «អត្រាផ្លូវការ» | ១៧.១ | ១៧.៧ | ១៨.៤ | ១៩.៧ | ២១.៧ | ២៣.៧ | ២៦.១ |
| | ១.៦១០ | ០.៦៣២ | ០.៦៥៧ | ០.៧០៣ | ០.៧៦៧ | ០.៨៤៦ | ០.៩៣២ |

#### ២.ប្រភពអន្តជាតិ

គិតដល់ភាពមិនច្បាស់លាស់ នៃការសន្និដ្ឋានរបស់ក្រសួងផែនការ ការប្រុងប្រយ័ត្នបានភ្ជាប់ជាមួយការសន្និដ្ឋានរបស់អង្គការអន្តរជាតិ ។ ការសន្និដ្ឋាននានាមួយចំនួន ៤ ៖

១.ការសន្និដ្ឋានដែលផ្តល់នៅឆ្នាំ ១៩៨៨ ដោយអ្នកឯកទេសអន្តរជាតិប្រជុំនូវភ្នំពេញគឺ ១.៥៦ ពាន់លានដុល្លារអាមេរិក ដែលចុះផ្សាយម្តងទៀតនៅក្នុង la F.E.E.R.my Asia yearbook នៅឆ្នាំ ១៩៩២ និង E.I.U.country profile 1992

២.ការសន្និដ្ឋានរបស់ L'Etat du Monde ផ្ដល់ការសន្និដ្ឋានទាបជាងច្រើន គឺ០.៦២៥ ពាន់លានដុល្លារ នៅឆ្នាំ ១៩៨៧

៣.ការវាយតម្លៃរបស់ B.I.R.D.នៅឆ្នាំ ១៩៨១ ដូចការសន្និដ្ឋានរបស់ Encyclopadia Universalis

៤.ការសន្និដ្ឋាន Alasseco

### ៣.ការរៀបចំឱ្យមានរបៀបនៃព័ត៌មានទាំងឡាយ

ការប្រឈរមុខគ្នានៃប្រភពនានា ធ្វើឱ្យមានការពន្យល់ខុសៗគ្នា ។ ចេញពីការប្រឈរមុខគ្នាគេអាចរៀបចំសម្មតិកម្មត្រឹមត្រូវនៃការរីកវិវឌ្ឍ P.N.B.។

| រៀលលាន នឹង នៅ ឆ្នាំ | ១៩៨១ | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ | ១៩៨៩ | ១៩៩០ |
|---|---|---|---|---|---|---|---|---|
| Est.A.N.A./P.P 1989 | - | - | - | - | - | ១.៥៦ | ១.៦ | - |
| ENC .Universalis | ០.៦ | - | - | - | - | - | - | - |
| B.I.R.D.World Alas 1989 | - | - | ១.០៣ | ១.១០ | ១.០៥ | - | - | - |
| Alaseco | - | ០.៩៣ | ១.០៣ | ១.១០ | ១.១៧ | ១.២៨ | ១.២០ | ១.៥៦ |
| Etat du Monde 1989-1992 | - | ០.៥៨៥ | ០.៥៨៥ | ០.៦២៥ | - | - | - | - |
| ក្រសួងផែនការ | - | ១៧.១ | ១៧.៧ | ១៨.៤ | ១៩.៧ | ២១.៥ | ២៣.៧ | ២៦.១ |

ប្រភពទាំងនោះអាចចាត់ថ្នាក់ជាថ្មី ជាបីប្រភព ៖

១.ប្រភពជារៀល "នឹងន" អាចប្រតិបត្តិការចេញពីការប្ដូរប្រាក់ផ្លូវការជាដុល្លារ ហើយទិន្នន័យផ្ដល់ឱ្យ មិនអាចពិតបានទេ ។ គេរក្សានូវផ្លូវការ ការគាំទ្រសម្មតិកម្មនោះថាការបូកសរុបយោបល់ មានការកើនឡើងនៃខ្សែកោងភ្ជាប់ឆ្នាំ ១៩៨៣ ជាការសន្និដ្ឋានដំបូងរបស់ក្រុងភ្នំពេញ គណនាជាអត្រាប្ដូរប្រាក់ផ្លូវការ ដែលជាភាពមិនជាប់ខាតជិតៗគ្នា និង អត្រាប្ដូរប្រាក់ពិតៗ ។ ការចុះបញ្ជីជាដុល្លារនៃប្រភពនេះ គិតជារៀល "នឹងន" មាននិន្នាការជិតប្រភពជាដុល្លារ នៃទិន្នន័យរបស់ "Etat du Mond "

២.វានៅសល់តែប្រភេទ នៃប្រភពមួយគត់គឺ "Etat du Monde" ដែលមានទុទិដ្ឋិនិយមច្រើនព្រោះនៅពាក់កណ្ដាលឆ្នាំ ១៩៨០ គឺបានត្រឹមសន្និដ្ឋានពាក់កណ្ដាលឆ្នាំនៃការសន្និដ្ឋានរបស់ B.I.R.D.និង Atlaseco ។ គេកត់សម្គាល់ថាបន្ទាត់ទ្រេតនៃការសន្និដ្ឋាននោះមានសុទិដ្ឋិនិយមច្រើនជាងបែបបទពីរពីមុន តែអាចចេញពីនិក្ខេមបទដែលរៀបចមឡើងដោការបូកសរុបនៃតួលេខរបស់ B.I.R.D.គិតដល់ឆ្នាំ ២០០០ ។

លទ្ធផលចេញពីការវិភាគ ឃើញថា P.N.D.កម្ពុជា ដោយបញ្ចូលគ្នានៃប្រភពធនធានផ្លូវការប្រមូលផ្តុំបានគឺជាង ១ ពាន់លានដុល្លារ បន្តិចពីការចាប់ផ្តើមធ្វើគណនេយ្យជាតិនៅពាក់កណ្តាលឆ្នាំ១៩៨០ ហើយកើនឡើងវារៀងរហូតគឺក្នុងចំនួន ៥០% ក្នុងរយៈពេញតិចជាង ១០ ឆ្នាំ រវាងដើមឆ្នាំ ១៩៨០ ដល់ ១៩៩០ គឺអត្រាកំណើនប្រចាំឆ្នាប្រហែល ៤.៥% ។

តាមតួលេខបូកសរុបរបស់ Atlasece កម្ពុជានិងមាន P.N.B.នៅឆ្នាំ២០០០ ជាកម្រិតមួយនៃករណីមិនស្មើគ្នាទៅនិងទេសភាពសេដ្ឋកិច្ចដែលគេឃើញពិតពីសកត្តានុពលដ៏មានប្រសិទ្ធភាព ដែលកំពុងប្រព្រឹត្តនៅកម្ពុជា។

## សំណួមពរសម្រាប់ការគណនាជាថ្មី

១.សារពើភ័ណ្ឌនៃផលិតកម្មនិងចំណូលផលទុនបន្ថែម នៅក្នុងវិតផ្នែកទីមួយ កសិកម្មនិងរ៉ែ មួយចំណែកនៃផលិតផលស្រូវប្រហែល ៥% យោងតយោងតាមក្រសួងកសិកម្ម ស្មើនិង ១០០,០០០ តោន នៅឆ្នាំ ១៩៩១ មិនបានបញ្ចូលក្នុងស្ថិតិទេ ឈើធ្វើអាជីវកម្មក្រៅបញ្ជីព័ន្ធគយជាង ៧០% នៃឈើ ១.១៥០.០០០ ម៣ នាឆ្នាំ ១៩៩១ យោងទៅតាម P.N.U.D.និងត្បូងមានតម្លៃនៅប៉ៃលិន ដែលក្នុងមួយឆ្នាំៗផលិតកម្មមាន ចំនួន ១០០ ទៅ ១៤០ លានដុល្លារ U.S និងនៅបកែវជាប់ព្រដែនវៀតណាម ។

នៅកម្រិតផ្នែកឧស្សាហកម្មះយ៉ាងតិច ៧៥% នៃផលិតផលឧស្សាហកម្ម គិតជាតម្លៃមិនបានចុះបញ្ជី គណនេយ្យនៅឆ្នាំ ១៩៩១ ដោយក្រសួងឧស្សាហកម្មយោងទៅតាមព័ត៌មានផ្សេងៗ ។

ក្នុងកម្រិតផ្នែកសេវាកម្មះ ផ្នែកនេះគ្មានការចុះបញ្ជីអ្វីសោះទាំងផលិតផល សណ្ឋាគារនិងទេសចរណ៍ពាណិជ្ជកម្ម ក្នុងប្រទេស គឺស្ថិតនៅក្រៅស្ថិតិក្រៅរដ្ឋាភិបាល តាំងពីឆ្នាំ ១៩៩០ ពួកឈ្មួញអន្តរជាតិ ឆ្លងកាត់ខេត្តកោះកុងហើយឆ្លងតាមភ្នំពេញ ដែលអាជ្ញាធរកំពុងផៃ មិនចុះបញ្ជីការនាំចេញ ហើយអាចជាឧបមាជាគណិតវិទ្យាថាមានចំនួនក្នុងកម្រិតនៃឧនភាពពាណិជ្ជកម្មផ្លូវការ ។

ក្នុងកម្រិតនៃផលទុនបន្ថែម

- ជនៅនៃចកនាហិរញ្ញវត្ថុក្នុងស្រុកះ

- សារៈសំខាន់គឺការធ្លាកចុះនៃការវិនិយោគបរទេស។ ក្រុមដែលមានឥទ្ធិពលនៅភ្នំពេញបានរៀបចំនៅចំណុចសំខាន់ៗជាមួយនិងគម្រោងវិនិយោគបរទេសតាមរយៈការដកយកក្រៅផ្លូវការ ។

- ភាពស្មុគស្មាញគឺប្រភពផលទុន ដែមានមកពីការលក់ទ្រព្យសកម្មរបស់រដ្ឋ ។ ការលក់សហគ្រាសរដ្ឋនៅកម្ពុជាមានចំណុលប្រហែល ១០០ លាន ដុល្លារ U.S.នៅដើមឆ្នាំ ១៩៩២ ។ កាសែត Le Monde ២៦/០៥/៩២ ជាផលទុន ១/៨ នៃជំនួយ អភិវឌ្ឍន៍របស់អ៊ុនតាក់ ។

-ជំនោរនៃចលនាហិរញ្ញវត្ថុក្រប្រទេសគឺបានមកពី ៖

- ជំនួយបរទេស។ ការធ្លាក់ចុះនៃជំនួយពហុភាគីអង្គការមិនមែនរដ្ឋាភិបាលអង្គការសហប្រជាជាតិនិងជំនួយពួកអានិកជនខ្មែរនៅបរទេសក្នុងនោះមានជំនួយទ្វេផាគីផងដែរដូចជាជំនួយអាមេរិកនិងចាប់ពីឆ្នាំ ១៩៨២ ជំនួយពីរាជាណាចក្រជិតខាង ។
- ផលទុនដែលមិនអាចកត់សម្គាល់ជាទូទៅបានជាទ្រព្យសកម្ម នៅបរទេស ។ ការតាំងទីរបស់បក្សតស៊ូនៅក្នុងទីក្រុងបាងកក ដូចជាខ្មែរក្រហម ។
-

**សមិទ្ធិកម្មនៃការកសាងនូវតុល្យការមួយ**

បើការរក្សានូវការសន្និដ្ឋានដូចតទៅៈ

១.ស្រូវកម្ពុជា ថ្លៃជាមធ្យម ២៣០ ដុល្លារក្នុងមួយតោន ហើយជាមធ្យមថ្លៃ៨៤ ដុល្លារក្នុង ១ ម$^{៣}$ ។

២.ផលិតផលរ៉ែនៅបកែវមានចំនួន ១/៤ នៃផលិតកម្មនៅប៉ៃលិន ។ គេសន្និដ្ឋានពី ១០០-១២០លានដុល្លារ ។

៣.យ៉ាងតិច ១០% នៃជំនួយបរទេស បានតួរបង្វែរកោលដៅផ្សេងៗ ។

៤.ទេសចរណ៍ណ៍ សម្រាប់សេវារបស់ពួកអ៊ុនតាក់ផងគឺ ១,៨០០ ដុល្លារ ក្នុងមួយនាក់ ។

៥.ពាណិជ្ជកររកបាន ១៥% យ៉ាងតិចទាំងនៅផ្សារក្នុងស្រុក ឬ ទាំងការនាំចេញ ។

គេឈានទៅដល់ការរកឃើញនូវផលទុនដុលរបស់ជាតិបន្ថែម ប្រហែល ៥០០ លានដុល្លារ U.S.សម្រាប់ឆ្នាំ ១៩៩១ ឬ ៧០០ លានដុល្លារ U.S.បើពួកពាណិជ្ជកររកបាន ៣០% នោះ ។

## ប្រភពធនធានផលទុនប្រចាំឆ្នាំ ១៩៩១-១៩៩២

| | | |
|---|---|---|
| ផលិតកម្ម | | |
| ត្បូងមានសម្លៃ | ១២០/១៤០ លានដុល្លារ | ១/៨ ទៅ ១/១០ នៃ P.N.B.លេ ឡើង |
| ឈើ | ៥០/៥៥ លានដុល្លារ | ៤/១៥ នៃការនាំចេញផ្លូវការ ១៩៩ |
| ផលិតផលឧស្សាហកម្មក្រៅការ គ្រប់គ្រងឧស្សាហកម្ម | ១២០ លានដុល្លារ | ១/១០ ទៅ ១/១២ នៃ P.N.B.លេ ឡើង |

ជំនោរនៃចលនាសេដ្ឋកិច្ច Flux

| | | |
|---|---|---|
| ឯកជនភាវូបនីយកម្ម ប្រភពមិនជួលរដ្ឋ | ១០០ លាន U.S.D. | ១/១០ ទៅ ១/១២ នៃ P.N.B.លេច ឡើង |
| ពាណិជ្ជកម្មក្នុងប្រទេស | ១០-២០ លាន U.S.D. | |
| ទេសចរណ៍ | ៥០-៦០ លាន U.S.D. | |
| ពួកឈ្មួញអន្តរជាតិ | ៥០ លាន U.S.D. | |
| ការផ្ញើរបស់ពួកអានិកជន | ២៥-២០ លាន U.S.D. | ១/៣ នៃការនាំចេញផ្លូវការ ១៩៩១ |
| ជំនួយអន្តរជាតិ | ៥០ លាន U.S.D. | ៤/៥ នៃការនាំចេញផ្លូវការ ១៩៩១ |
| ផលទុនសកម្មរក្សាបាននៅបរទេស | ៣០-៥០ លាន U.S.D. | ៣/៥-៤/៥ នៃការនាំចេញផ្លូវការ ១៩៩១ |
| សរុប | ៦០០-៨០០ លាន U.S.D. | រវាង ១/៣និង១/២ នៃ P.N.B.លេចឡើងរវាង ៥ទៅ៦ដងនៃការនាំចេញផ្លូវការ ១៩៩១ |

### សំយោគៈប្រភពធនធានពិតរបស់កម្ពុជា

អាចនិយាយបានដោយសរុបនូវតួលេខ P.N.B.ជាស្ថិតិរួមនិង P.N.B.ដុលបន្ថែមនិងបានសន្និដ្ឋានខាងលើគឺនៅឆ្នាំ ១៩៩២ ផលទុនដុលជាតិពិតរបស់កម្ពុជាក្នុងន័យទូលាយអាចស្ថិតនៅក្នុងរង្វង់ពី ២.២៥-២.៤៥ ពាន់លានដុល្លារជាសម្មតិកម្មនៃផលិតផលមិនត្រូវការដែលគ្មាននៅសល់អ្វីសោះ ក្រោយពីការចាកចេញនៃពួកខ្មែរក្រហម មកពាឆ្នាំ ១៩៧៩ គេអាចសន្និដ្ឋានបានថា Gross National Products សរុបមានកំណើនពីតិចជាង ១ ពាន់លាន U.S.D.ពី ១៩៨០ ទៅ ២.៣៥ ពាន់លាន U.S.D.នៅឆ្នាំ ១៩៩២ ។

GNP ពិតរបស់មនុស្សម្នាក់ៗនៃកម្ពុជាមាប្រហែល ២៥០ U.S.D.ជាមធ្យម

- រវាងតំបន់ជនបទ និងប្រជាជន ដែលមិនបានរួមចំណែកប្រហែល ដល់ boom ប៉ុម ដែល P.N.B.មនុស្សនៃមនុស្សម្នាក់ អាចសន្និដ្ឋានដល់ ១៥០ U.S.D.ក្នុងម្នាក់ៗ ។

- ហោប៉ៅនៃពួករុងរឿងទាក់ទងនឹង boom ដែល P.N.B.ក្នុងម្នាក់ៗប្រហែល ៥០០ U.S.D.ភាពចន្លោះដាច់ពីគ្នាមានប្រហែលពី ១ ទៅ ៣ ដងរវាងតំបន់ រុងរឿង និងជនបទឯទៀតនៃប្រទេស។

# បណ្ណាល័យសាស្ត្រ ( Bibliography )


ក្រុមប្រឹក្សានីតិកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២០២០ *កម្រងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម* បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា រោងពុម្ពក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ច័ន្ទ សារុន ២០០៦ *យុទ្ធសាស្ត្របង្កើនផលិកម្មដំណាំស្រូវប្រកបដោយចីរភាព* និក្ខេបបទបញ្ចប់កាសិក្សាកម្រិតថ្នាក់បណ្ឌិត មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យចំរើនពុហបច្ចេកវិទ្យា ព្រះរាជាណាចក្រកម្ពុជា

ឆាយ គង្គា ២០០១ *ការព្យាករណ៍តម្រូវការ ផ្គត់ផ្គង់ និងយុទ្ធសាស្ត្រនៃការជំរុញវិស័យដំណាំស្រូវនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សាលាក្រោយឧត្តម សាកលវិទ្យាល័យជាតិធុនណាំ រោងពុម្ពទស្សនាវដ្ដីវិទ្យាសាស្ត្រកសិកម្មខ្វាងជូ ទីក្រុងខ្វាងជូ សាធារណៈរដ្ឋកូរ៉េ( ប្រទេសកូរ៉េខាងតម្បូង )( ភាសាអង់គ្លេស )

ឆាយ គង្គា ២០០២ *ស្ថានភាពបច្ចុប្បន្ននៃទីផ្សារដំណាំស្រូវនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សាលាក្រោយឧត្តម សាកលវិទ្យាល័យជាតិធុនណាំ សាធារណៈរដ្ឋកូរ៉េរោងពុម្ពទស្សនាវដ្ដីវិទ្យាសាស្ត្រធុនណាំ ទីក្រុងខ្វាងជូ ( ប្រទេសកូរ៉េខាងត្បូង )( ភាសាអង់គ្លេស )

ឆាយ គង្គា ២០០៤ *ទីផ្សារនៃផលិតផលកសិកម្មនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត រោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ ទីក្រុងខ្វាងជូ សាធារណៈរដ្ឋកូរ៉េ( ប្រទេសកូរ៉េខាងត្បូង )( ភាសាអង់គ្លេស )

ឆាយ គង្គា ២០០៥ *ការវិភាគថ្លៃនៃផលិតផលកសិកម្មនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត រោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ រដ្ឋធានីសេអ៊ូល សាធារណៈរដ្ឋកូរ៉េ( ប្រទេសកូរ៉េខាងត្បូង )( ភាសាអង់គ្លេស )

ឆាយ គង្គា ២០០៥ *ពាណិជ្ជកម្មគ្រាប់ធញ្ញជាតិក្រោមគោលនយោបាយអង្គការពាណិជ្ជកម្មពិភពលោក* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត រោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ ទីក្រុងខ្វាងជូ សាធារណៈរដ្ឋកូរ៉េ( ប្រទេសកូរ៉េខាងត្បូង )( ភាសាអង់គ្លេស )

ឆាយ គង្គា ២០០៦ *ការព្យាករណ៍ការផ្គត់ផ្គង់ដំណាំស្រូវ* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត រោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិសង្គមកូរ៉េ រដ្ឋធានីសេអ៊ូល សាធារណៈរដ្ឋកូរ៉េ(ប្រទេសកូរ៉េខាងត្បូង)(ភាសាអង់គ្លេស)

ឆាយ គង្គា ២០០៦ *ប្រវត្តិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា* បោះពុម្ពលើកទី១ រោងពុម្ពមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម)(ភាសាខ្មែរ)

ឈាង នរិន្ទ ២០២០ *ប្រសិទ្ធភាពសេដ្ឋកិច្ចដំណាំស្រូវនៅកម្ពុជា៖ករណីសិក្សាខេត្តបាត់ដំបង តាកែវ ស្វាយរៀង* និក្ខេបបទបញ្ចប់កាសិក្សាកម្រិតថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ ព្រះរាជាណាចក្រកម្ពុជា

ធនាគារពិភពលោក ២០១៨ *របាយការណ៍ប្រចាំឆ្នាំរបស់ធនគារពិភពលោក* រោងពុម្ពធនាគារពិភពលោក

ធនាគារអភិវឌ្ឍន៍អាស៊ី ២០១៩ *របាយការណ៍ប្រចាំឆ្នាំរបស់ធនគារអភិវឌ្ឍន៍អាស៊ី* រោងពុម្ពធនគារអភិវឌ្ឍន៍អាស៊ី

ម៉ក់ ពុទ្ធី ២០១៦ *ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្ដាលពីឆ្នាំ២០០៦ ដល់២០១៥* និក្ខេបបទបញ្ចប់កាសិក្សាកម្រិតថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ២០២០ យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ផ្នែកហិរញ្ញវត្ថុ បោះពុម្ពដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លាប ប៉ូឡូ ២០១២ *ការគ្រប់គ្រងចំណូលសារពើពន្ធសម្រាប់ថវិកាថ្នាក់ក្រោមជាតិ* មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងសេដ្ឋកិច្ច សាកលវិទ្យាល័យឯកទេសនៃកម្ពុជា ព្រះរាជាណាចក្រកម្ពុជា

វង្ស ឌីណា ២០១៧ *ការគ្រប់គ្រង និងការប្រមូលពន្ធលើប្រាក់ចំណេញរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦* និក្ខេបបទបញ្ចប់ការសិក្សាកម្រិត

ថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ ព្រះរាជាណាចក្រកម្ពុជា

វ៉ាន់ ប៊ុនថេត ១៩៩៥ *សេដ្ឋកិច្ចកម្ពុជា* រោងពុម្ព សាលាភូមិន្ទរដ្ឋបាល ព្រះរាជាណាចក្រកម្ពុជា

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៨* រោងពុម្ពវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ព្រះរាជាណាចក្រកម្ពុជា

សឺន សុទ្ធ ២០២០ *ស្ថិរភាពសេដ្ឋកិច្ចកម្ពុជាតាមរយៈការគ្រប់គ្រងចំណូល និងចំណាយសាធារណៈ* និក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ

សឺន សុទ្ធ ២០២០ *ស្ថិរភាពសេដ្ឋកិច្ចកម្ពុជាតាមរយៈការគ្រប់គ្រងចំណូល និងចំណាយសាធារណៈ* និក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ ព្រះរាជាណាចក្រកម្ពុជា

ហង់ជួន ណារ៉ុន ២០១៧ *គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជានាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិត្យកម្ពុជា(ទសវត្សរ៍ឆ្នាំ១៩៨០)* បោះពុម្ពនៅកម្ពុជា រោងពុម្ពអេស អេច

CHHAY Kongkea, 2006, *Agricultural Development Strategy in Cambodia*, Dissertation Presented for the Ph.D.Degree, Department of Agricultural Economics, Graduate School, Chonnam National University, Gwangjy 500-757, Gwangju City, Republic of Korea(South Korea).

CHHAY Kongkea, 2003, *Rice-Supply-Demand and Improvement Strategy on Rice Industry in Cambodia*, Thesis Presented for the Master's Degree, Department of Agricultural Economics, Graduate School, Chonnam National University, Gwangjy 500-757, Gwangju City, Republic of Korea (South Korea).

CHHAY Kongkea and Joon-Keun Park, 2016, *Environmental-Friendly Agriculture in Cambodia: with an Emphasis on CGM*, Chonnam National University Press, South Korea.

CHHAY Kongkea Park Jon-Sik and Joon-Keun Park, 2009, *The Current Situation on Rice Supply in Cambodia from 1980 to 2005*, The Journal of Korean Society and International Agriculture, South Korea.